# សេដ្ឋកិច្ចកម្ពុជា

## មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង

*វឌ្ឍនភាព បញ្ហាប្រឈម និង ទស្សនវិស័យទៅអនាគត*



**បណ្ឌិត ហង់ ជួន ណារ៉ុន**

**២០១៥**



# សេដ្ឋកិច្ចនៃប្រទេសកម្ពុជា

## មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង

*វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត*

ដោយ **ហង់ ជួន ណារ៉ុន**

**២០១៥**

**ភ្នំពេញ**

បោះពុម្ពផ្សាយលើកទី១
ភ្នំពេញ ឆ្នាំ២០១៥
ISBN-13: 978-99963-914-0-8
រក្សាសិទ្ធិគ្រប់យ៉ាង

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ក្នុងរយៈពេលប្រមាណពីរទសវត្សកន្លងទៅ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងអត្រាប្រមាណ ៧,៧ % ក្នុងមួយឆ្នាំ ទោះជាត្រូវជួបប្រឈមនឹងភាពមិនប្រាកដប្រជា និងហានិភ័យជាច្រើនទាំងនៅក្នុង និងក្រៅប្រទេសយ៉ាងណាក៏ដោយ ជាពិសេសបានឆ្លងកាត់វិបត្តិធំពីរ គឺវិបត្តិហិរញ្ញវត្ថុអាស៊ីនៅឆ្នាំ ១៩៩៧ និងវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ ២០០៨ ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងស្ថាប័នសកលចាត់ទុកកម្ពុជាថា ជាប្រទេសមួយនៅក្នុងចំណោមប្រទេសប្រាំបីដែលមានភាពធន់នៃកំណើនសេដ្ឋកិច្ចខ្ពស់បំផុត ឬជើងឯកអូឡាំពិកផ្នែកកំណើនសេដ្ឋកិច្ច (Olympians of growth) ។ លើសពីនេះ ប្រទេសកម្ពុជាក៏ត្រូវបានវាយតម្លៃថា ជាប្រទេសស្ថិតនៅក្នុងចំណោមប្រទេស ៥ លើសកលលោក ដែលអាចសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្ស ។ ម្យ៉ាងទៀតអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ ក្នុងល្បឿនដ៏លឿនពីប្រមាណ ៤៧% នៅឆ្នាំ ២០០៧ មកនៅត្រឹមប្រមាណ ១៨,៩ % នាឆ្នាំ ២០១២ ។ លើសពីនេះ ផលនៃកំណើនសេដ្ឋកិច្ចត្រូវបានបែងចែកកាន់តែមានសមធម៌ឡើង ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះនៃមេគុណវិសមភាព (Gini Coefficient) ពី ០,៤១ % នៅឆ្នាំ ២០០៧ មកនៅត្រឹម ០,២៩ % នាឆ្នាំ ២០១២ ។

ការសម្រេចបាននូវសមិទ្ធផលទាំងអស់នេះ បានរុញច្រានកម្ពុជាឲ្យមកដល់ខ្លង់រាបថ្មីមួយទៀត គឺឈានដល់ដំណាក់កាលនៃការអភិវឌ្ឍថ្មីមួយ ដែលកំពុងប្រែក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាប និងស្ថិតក្នុងដំណើរផ្លាស់ប្តូរជារចនាសម្ព័ន្ធ ដែលកម្ពុជាត្រូវធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយបរិយាប័ន្ន សម្រាប់ជាមូលដ្ឋាននៃការបង្កើតការងារ និងឱកាសរកប្រាក់ចំណូលសមរម្យ ។ ជាមួយគ្នានេះដែរ កម្ពុជាក៏មានភាពចាំបាច់ក្នុងការរៀបចំខ្លួន ដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងក្របខណ្ឌពិភពលោក និងក្របខណ្ឌតំបន់ ជាពិសេសការចាប់ផ្តើមនៃសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ ២០១៥ ។ ក្នុងន័យនេះ កម្ពុជាត្រូវត្រៀមខ្លួនឲ្យបានគ្រប់គ្រាន់ដើម្បីសម្រេចឲ្យបានសមិទ្ធផលថ្មីៗថែមទៀត នៅក្នុងពេលអនាគត ដែលលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកាន់តែមានលក្ខណៈស្មុគស្មាញ ជាពិសេសខណៈដែលកម្ពុជាមានបំណងប្រាថ្នាចង់ក្លាយខ្លួនជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងឈានឆ្ពោះទៅកាន់ប្រទេសដែលមានចំណូលខ្ពស់ ។

សៀវភៅ **"សេដ្ឋកិច្ចនៃប្រទេសកម្ពុជាៈ មាគ៌ាឆ្ពោះទៅអនាគតដ៏ភ្លឺស្វាង វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត"** គឺជាការខិតខំដ៏ក្លាហានមួយ ដើម្បីបកស្រាយ និងពន្យល់ពីដំណើរនៃវិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលពីរទស្សវត្សកន្លងមក នៅទិដ្ឋភាពនៃកែវភ្នែករបស់អ្នកនិពន្ធ ដែលជាអ្នកសិក្សាស្រាវជ្រាវផង និងអ្នកអនុវត្តផ្ទាល់ផង ។ លើសពីនេះ សៀវភៅនេះក៏បានសាកល្បងពិភាក្សា និងវាយតម្លៃអំពីនិន្នាការ និងទិសដៅអនាគតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ក្នុងទស្សនៈវិស័យរយៈពេលវែងឆ្ងាយ។ ខ្ញុំជឿជាក់ថា អ្នកអានទាំងអស់នឹងស្វែងរកបានចម្លើយ ការបកស្រាយ និងការបំភ្លឺជាច្រើនអំពីបញ្ហាសេដ្ឋកិច្ច ក៏ដូចជាបញ្ហាសង្គមមួយចំនួន ថែមទាំងការគិតគូរ និង

ការវិភាគអំពីគោលនយោបាយសេដ្ឋកិច្ចរបស់ **រាជរដ្ឋាភិបាលកម្ពុជា** ក្នុងរយៈពេលពីរទសវត្សមកនេះ ។

ប្រាកដណាស់ថា សៀវភៅនេះនឹងក្លាយជាឯកសារយោងដ៏សំខាន់មួយ និងមិនអាចខ្វះបាននៅក្នុងបណ្ណាល័យនៃអ្នកសិក្សាទាំងអស់ និងមានតម្លៃកាន់តែពិសេសសម្រាប់អ្នកដែលមានចំណាប់អារម្មណ៍ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ទោះបីជាទស្សនៈទាំងអស់ ដែលមាននៅក្នុងសៀវភៅនេះ ជាការយល់ឃើញរបស់អ្នកនិពន្ធផ្ទាល់ ។

ជាចុងក្រោយ ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះស្នាដៃរបស់ **បណ្ឌិត ហង់ ជួន ណារ៉ុន** ដែលឆ្លៀតពេលវេលាដ៏មមាញឹក បានខិតខំរៀបចំចងក្រងនូវសៀវភៅមួយក្បាលនេះឡើង និងបានបោះផ្សាយជាភាសាជាតិ ដើម្បីអាចឲ្យប្រជាពលរដ្ឋទូទៅ ជាពិសេសយុវជន និងនិស្សិតទាំងអស់ អាចស្វែងយល់ពីបញ្ហាសេដ្ឋកិច្ច និងសង្គម បានកាន់តែប្រសើរជាងមុន និងបង្កើតជា "**ធុននៃពុទ្ធិ**" សម្រាប់ការរីកចម្រើនលូតលាស់នៃសេដ្ឋកិច្ច និងសង្គមកម្ពុជាបន្ថែមទៀត ក្នុងពេលអនាគត ។

**ហ៊ុន សែន**

# មាតិកា


**សេចក្តីផ្តើម** ....................................................... 01

**ការថ្លែងអំណរគុណ** ....................................................... 09

**សេចក្តីផ្តើម** ....................................................... 10

**ផ្នែកទី១: ភូមិសាស្ត្រនិងប្រជាជន** ....................................................... 15

ជំពូកទី១: ភូមិសាស្ត្រនៃប្រទេសកម្ពុជា ....................................................... 17

១.១.សណ្ឋានដី ....................................................... 17

១.២. ជលធារាសាស្ត្រ ....................................................... 19

១.៣. លក្ខណៈទូទៅនៃអាកាសធាតុ ....................................................... 21

១.៤. ភូមិភាគធម្មជាតិ ....................................................... 24

១.៥. ប្រព័ន្ធក្សេត្របរិស្ថាននិងចំណាត់ថ្នាក់ដី ....................................................... 27

១.៦. ធនធានរ៉ែ ....................................................... 30

១.៧. របបកម្មសិទ្ធិដី ....................................................... 35

ជំពូកទី២: ប្រជាករ និង រចនាសម្ព័ន្ធប្រជាសាស្ត្រ ....................................................... 39

២.១. លក្ខណៈទូទៅ ....................................................... 39

២.២. រចនាសម្ព័ន្ធប្រជាជនតាមអាយុនិងតាមភេទ ....................................................... 40

២.៣. ការវិវត្តចំនួនប្រជាជន ....................................................... 41

២.៤. ស្ថានភាពសេដ្ឋកិច្ចសង្គមនៃប្រជាជនកម្ពុជា ....................................................... 45

២.៥. គោលនយោបាយប្រជាជន ....................................................... 45

២.៦. គោលនយោបាយស្តីពីការងារនិងសុខមាលភាពសង្គម ....................................................... 45

២.៧. ជនជាតិនានានៅប្រទេសកម្ពុជា ....................................................... 45

**ផ្នែកទី ២: ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច** ....................................................... 51

ជំពូកទី៣: សមិទ្ធផលម៉ាក្រូសេដ្ឋកិច្ច និន្នាការជាប្រវត្តិសាស្ត្រ និងលក្ខណៈសំខាន់ៗ នៃ កំណែតម្រូវរចនាសម្ព័ន្ធ ....................................................... 53

៣.១. ដំណាក់កាលនៃកំណើនសេដ្ឋកិច្ច ....................................................... 53

៣.២. ឥរិយាបថសន្សំនិងវិនិយោគ ....................................................... 65

៣.៣. វិស័យហិរញ្ញវត្ថុសាធារណៈ ....................................................... 73

៣.៤. វិស័យរូបិយវត្ថុ ....................................................... 79

៣.៥. វិស័យខាងក្រៅ ....................................................... 107

៣.៦. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨ និងទស្សនវិស័យ ....................................................... 111

៣.៧. ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុពិភពលោកមកលើសេដ្ឋកិច្ចកម្ពុជា ....................................................... 112

៣.៨. សេចក្តីសន្និដ្ឋាន ....................................................... 121





fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជំពូកទី៤: វិស័យធនាគារ ....125
៤.១. សាវតារ ....125
៤.២. កំណែទម្រង់រចនាសម្ព័ន្ធនៃប្រព័ន្ធធនាគារ ....130
៤.៣. ស្ថាបត្យកម្មបច្ចុប្បន្ននៃប្រព័ន្ធធនាគារកម្ពុជា ....135
៤.៤. ប្រព័ន្ធធនាគារកម្ពុជា - ការវិភាគចំណុចខ្លាំងនិងចំណុចខ្សោយ ....143
៤.៥. មីក្រូហិរញ្ញវត្ថុ ....154
ជំពូកទី៥: វិស័យធានារ៉ាប់រង ....159
៥.១. ទីផ្សារធានារ៉ាប់រង - ទិដ្ឋភាពរួម ....159
៥.២. កំណែទម្រង់ក្នុងវិស័យធានារ៉ាប់រង ....163
ជំពូកទី៦: ការអភិវឌ្ឍទីផ្សារមូលធន ....167
៦.១. ដំណាក់កាលសម្រាប់ការអភិវឌ្ឍទីផ្សារមូលធន ....168
៦.២. បញ្ហាសំខាន់ៗនៃការអភិវឌ្ឍទីផ្សារមូលធន ....170
**ផ្នែកទី ៣: បញ្ហាទំនើបភាវូបនីយកម្មវិស័យកសិកម្ម ....175**
ជំពូកទី៧: វិស័យកសិកម្ម ....177
៧.១. ដំណាំស្រូវ ....180
៧.២. ប្រព័ន្ធផលិតកម្មកសិកម្ម ....182
៧.៣. វិស័យព្រៃឈើនិងគោលនយោបាយព្រៃឈើ ....191
៧.៤. វិស័យនេសាទ ....195
៧.៥. ការចិញ្ចឹមសត្វ ....201
ជំពូកទី៨: ឧបសគ្គចំពោះការលើកកម្ពស់កម្រិតជីវភាពរបស់កសិករ ....203
៨.១. ភាពគ្មានដីធ្លី ....203
៨.២. ការផ្គត់ផ្គង់ធាតុចូល ....204
៨.៣. ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គម ....207
៨.៤. ការពិនិត្យមើលឡើងវិញនូវគោលនយោបាយនិងបទពិសោធន៍នៃការ អភិវឌ្ឍជនបទ ....208
ជំពូកទី៩: គោលនយោបាយទំនើបភាវូបនីយកម្មវិស័យកសិកម្ម ....211
៩.១. ជម្រើសរវាងកសិដ្ឋានកម្រិតគ្រួសារនិងចម្ការទ្រង់ទ្រាយធំ ....213
៩.២. ពិពិធកម្មនិងការធ្វើទំនើបកម្មកសិកម្ម ....214
៩.៣. ការជម្រុញវិស័យកសិ-ឧស្សាហកម្ម ....216
៩.៤. ពង្រឹងសេវាបច្ចេកទេសនិងពាណិជ្ជកម្ម ....216
៩.៥. សន្តិសុខដីធ្លីនិងកំណែទម្រង់ការគ្រប់គ្រងដីធ្លី ....217
៩.៦. កំណែទម្រង់ការគ្រប់គ្រងធនធានទឹក ....218
៩.៧. ការបង្កើននិងពិពិធកម្មប្រាក់ចំណូលជនបទ ....220



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៩.៨. ការកាត់បន្ថយភាពងាយរងគ្រោះនៃសកម្មភាពកសិកម្ម ............ 221
៩.៩. ការចូលទីផ្សារក្នុងក្របខ័ណ្ឌតំបន់ភាវូបនីយកម្មពាណិជ្ជកម្ម ............ 221
៩.១០. កំណែទម្រង់ការគ្រប់គ្រងព្រៃឈើ ............ 222
៩.១១. ការលើកស្ទួយដំណាំកៅស៊ូ ............ 224
៩.១២. ការស្តារឡើងវិញនូវវិស័យជលផល ............ 225
៩.១៣. ការបង្កើតលក្ខខណ្ឌកំណើនខ្ពស់និងមានចីរភាពក្នុងអនុវិស័យចិញ្ចឹមសត្វ ............ 226
៩.១៤. ការកសាងសមត្ថភាពស្ថាប័ន ............ 226
៩.១៥. ការលើកកម្ពស់ការអភិវឌ្ឍជនបទចម្រុះនិងការបើកចំហរតំបន់ជនបទ ............ 228
៩.១៦. ការអភិវឌ្ឍប្រព័ន្ធហិរញ្ញប្បទានក្នុងសហគមន៍ជនបទ ............ 229
៩.១៧. ការអភិវឌ្ឍផ្នែកឯកជននិងការងារក្រៅកសិកម្មនៅទីជនបទ ............ 230
៩.១៨. និរន្តរភាពនៃគម្រោងដែលឧបត្ថម្ភដោយម្ចាស់ជំនួយ ............ 230
**ផ្នែកទី ៤: បញ្ហាប្រឈមនៃឧស្សាហូបនីយកម្ម ............ 233**
ជំពូកទី១០: ទិដ្ឋភាពទូទៅនៃវិស័យឧស្សាហកម្ម ............ 235
១០.១. សហគ្រាសរដ្ឋ ............ 235
១០.២. រចនាសម្ព័ន្ធឧស្សាហកម្ម ............ 237
១០.៣. សម្លៀកបំពាក់និងវាយនភ័ណ្ឌ ............ 239
១០.៤. សំណង់ ............ 243
១០.៥. កសិ-ឧស្សាហកម្មៈចំណីអាហារនិងភេសជ្ជៈ ............ 243
១០.៦. ឧស្សាហកម្មដទៃទៀតនិងការធ្វើពិពិធកម្មឧស្សាហកម្ម ............ 244
ជំពូកទី១១: ការអភិវឌ្ឍវិស័យឯកជន ............ 247
១១.១. វិស័យទំនើប ............ 249
១១.២. វិស័យក្រៅប្រព័ន្ធ (Informal Sector) ............ 259
១១.៣. ឧបសគ្គចំពោះការវិនិយោគ និងផលិតភាព ............ 261
ជំពូកទី១២: គោលនយោបាយឧស្សាហកម្ម ............ 263
១២.១. បញ្ហាប្រឈមនិងកាលានុវត្តិភាពនាពេលអនាគត ............ 263
១២.២. ពិពិធកម្មនៃការអភិវឌ្ឍឧស្សាហកម្ម ............ 264
១២.៣. ការអភិវឌ្ឍរបៀងឧស្សាហកម្ម ............ 269
**ផ្នែកទី ៥: សេវាកម្មនិងហេដ្ឋារចនាសម្ព័ន្ធ ............ 279**
ជំពូកទី១៣: វិស័យទេសចរណ៍ ............ 281
១៣.១. សារតារ ............ 281
១៣.២. ការទាក់ទាញនិងសកម្មភាពអ្នកទេសចរ ............ 281
១៣.៣. ទេសចរណ៍វប្បធម៌ ............ 282



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៣.៤. ទេសចរណ៍ជាប៉ូលនៃកំណើន......284
១៣.៥. គោលនយោបាយវិស័យទេសចរណ៍......289
ជំពូកទី១៤: ទូរគមនាគមន៍......293
១៤.១. ច្បាប់និងក្របខ័ណ្ឌនិយតកម្ម......293
១៤.២. លក្ខណៈពិសេសសំខាន់ៗនៃការអភិវឌ្ឍទីផ្សារ......296
១៤.៣. វឌ្ឍនភាពបច្ចេកវិទ្យានិងផលប៉ះពាល់របស់វាលើចំណូលគមនាគមន៍អេឡិចត្រូនិក.306
១៤.៤. យុទ្ធសាស្ត្រនិងគោលនយោបាយសម្រាប់ការអភិវឌ្ឍវិស័យទូរគមនាគមន៍......307
ជំពូកទី១៥: ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន......311
១៥.១. ស្ថានភាពផ្លូវថ្នល់បច្ចុប្បន្ននៅកម្ពុជា......312
១៥.២. បញ្ហាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់......319
១៥.៣. ការផ្តល់មូលនិធិអភិវឌ្ឍន៍ផ្លូវថ្នល់......320
១៥.៤. ផ្លូវរថភ្លើងនៅកម្ពុជា......326
១៥.៥. នាវាចរនិងកំពង់ផែ......330
១៥.៦. ផ្លូវទឹកក្នុងប្រទេស......332
១៥.៧. ការដឹកជញ្ជូនតាមជើងអាកាស......335
១៥.៨.បញ្ហាគោលនយោបាយក្នុងហេដ្ឋារចនាសម្ព័ន្ធជើងគោក......337
ជំពូកទី១៦: វិស័យថាមពល......339
១៦.១. ទិដ្ឋភាពរួម......339
១៦.២. ការផលិតអគ្គិសនី......341
១៦.៣. ផែនការអភិវឌ្ឍន៍វិស័យថាមពល......346
**ផ្នែកទី ៦: ការអភិវឌ្ឍធនធានមនុស្ស......351**
ជំពូកទី១៧: ស្ថានភាពនៃភាពក្រីក្រ......353
១៧.១. ទិដ្ឋភាពនិងចរិតលក្ខណៈនៃភាពក្រីក្រ......353
១៧.២. ការកំណត់លក្ខណៈនៃភាពក្រីក្រ......355
១៧.៣. យុទ្ធសាស្ត្រគោលនយោបាយនិងស្ថានភាពនៃភាពក្រីក្រ......358
ជំពូកទី១៨: វិស័យអប់រំ......377
១៨.១. សាវតារ......377
១៨.២. ការបំពេញការងារវិស័យអប់រំ......379
១៨.៣. យន្តការផ្តល់មូលនិធិដល់វិស័យអប់រំ......388
១៨.៤. សេចក្តីសន្និដ្ឋាន......390
ជំពូកទី១៩: សុខាភិបាល......391
១៩.១. សាវតារ......391
១៩.២. យុទ្ធសាស្ត្រគាំពារសុខភាពថ្នាក់ជាតិ......392



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៩.៣. ការអនុវត្តរបស់វិស័យសុខាភិបាល ....393
១៩.៤. ហិរញ្ញប្បទានសម្រាប់ប្រព័ន្ធថែទាំសុខភាព....398
**ផ្នែកទី ៧: ហិរញ្ញវត្ថុសាធារណៈ....403**
ជំពូកទី២០: ប្រព័ន្ធសារពើពន្ធ....405
២០.១. របបស្វ័យប្រកាស....405
២០.២. របបម៉ៅការ ....406
២០.៣. ប្រភេទពន្ធ និងអាករ....406
២០.៤. ការពិពណ៌នាអំពីប្រភេទពន្ធនៅកម្ពុជា....408
២០.៥. សមិទ្ធិកម្មសារពើរពន្ធនៅកម្ពុជា ....416
ជំពូក២១: ថវិការដ្ឋ ....421
២១.១. ក្របខ័ណ្ឌបច្ចេកទេសនៃថវិការដ្ឋ....421
២១.២. ការរៀបចំថវិកា ....423
២១.៣. ការបែងចែកឥណទានថវិកា....427
២១.៤. គោលការណ៍គណនីសាធារណៈ....431
២១.៥. ការត្រួតពិនិត្យហិរញ្ញវត្ថុ....441
២១.៦. ការត្រួតពិនិត្យខាងក្រៅ ....444
២១.៧. ថវិការបស់ខេត្តនិងរាជធានី ....444
២១.៨. ថវិកាឃុំ ....445
២១.៩. ការគ្រប់គ្រងវិនិយោគសាធារណៈ ....446
២១.១០. សហគ្រាសរដ្ឋ ....449
២១.១១. កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ....450
**ផ្នែកទី ៨: ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ ....455**
ជំពូកទី២២: ពាណិជ្ជកម្មក្រៅប្រទេស....457
២២.១. សេរីភាវូបនីយកម្មនៃពាណិជ្ជកម្មក្រៅប្រទេស....457
២២.២. ការកាត់បន្ថយពន្ធគយ (Tariff Restructuring)....459
២២.៣. របាំងមិនមែនពន្ធគយ ....465
២២.៤. កម្ពុជានិងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន ....467
២២.៥. សេរីភាវូបនីយកម្មលើសេវាកម្មហិរញ្ញវត្ថុក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម (AFAS) ....469
២២.៦. សមាជិកភាពរបស់កម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ....474
២២.៧. សមត្ថភាពពាណិជ្ជកម្មក្រៅប្រទេស ....476
ជំពូកទី២៣: បំណុលក្រៅប្រទេស....483
២៣.១. និយមន័យ....483



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

២៣.២. ការគ្រប់គ្រងបំណុលក្រៅប្រទេស ..... 485
២៣.៣. ក្លឹបទីក្រុងប៉ារីស និង ការចរចាបំណុលឡើងវិញ ..... 491
២៣.៤. ការពិពណ៌នាពីបំណុលសាធារណៈក្រៅប្រទេសរបស់កម្ពុជា ..... 494
២៣.៥. សមត្ថភាពសងបំណុលរបស់កម្ពុជា ..... 504
ជំពូកទី២៤: សមាហរណកម្មទៅក្នុងតំបន់ ..... 509
២៤.១. សមាហរណកម្មកម្ពុជាទៅក្នុងតំបន់ ..... 509
២៤.២. សមាហរណកម្មទៅក្នុងអាស៊ាន ..... 511
២៤.៣. ក្របខណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ..... 514
២៤.៤. ការបង្រួមគម្លាតអភិវឌ្ឍន៍ ..... 519
២៤.៥. សមាហរណកម្មហិរញ្ញវត្ថុក្នុងអាស៊ាន ..... 520
២៤.៦. ទំនាក់ទំនងការបរទេសអាស៊ាននិងយន្តការពិគ្រោះយោបល់ ..... 524
២៤.៧. ការបង្កើតសហគមន៍អាស៊ាន ..... 524
២៤.៨. បញ្ហាប្រឈមនៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ..... 527
២៤.៩. ការបង់ថ្លៃផ្នែកសង្គមកិច្ចសម្រាប់ដំណើរការសមាហរណកម្ម ..... 529
២៤.១០. ឆ្ពោះទៅសមាគមន៍អាស៊ាន ..... 529
២៤.១១. សមាហរណកម្មសេដ្ឋកិច្ចនៅក្នុងអាស៊ីបូព៌ា ..... 533
២៤.១២. កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ានបូកបី ..... 541
២៤.១៣. កិច្ចប្រជុំកំពូលអាស៊ីបូព៌ា ..... 547
**ផ្នែកទី ៩: សេចក្តីសន្និដ្ឋាន ..... 549**
ជំពូកទី២៥: ការពន្លឿនការអភិវឌ្ឍស្ថាប័ន-កូនសោរឆ្ពោះទៅវឌ្ឍនភាព ..... 551
២៥.១. ក្របខ័ណ្ឌនៃការអភិវឌ្ឍទូទៅ ..... 551
២៥.២. កំណែទម្រង់រដ្ឋបាលសាធារណៈ ..... 553
២៥.៣. វិមជ្ឈការនិងការអភិវឌ្ឍមូលដ្ឋាន ..... 556
២៥.៤. កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ ..... 558
២៥.៥. អភិបាលកិច្ចល្អនិងទំនើបកម្មរដ្ឋបាល ..... 560



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សេចក្តីផ្តើម

សង្គ្រាមត្រជាក់រវាងមហាអំណាចលើសកលលោក បានរុញច្រានកម្ពុជាឱ្យចូលបន្តិចម្តងៗ ក្នុងអណ្តាតភ្លើងនៃសង្គ្រាមដែលកំពុងឆាបឆេះឧបទ្វីបឥណ្ឌូចិន។ រដ្ឋប្រហារទម្លាក់សម្តេច **នរោត្តម សីហនុ** ដោយលោក **លន់ នល់** នៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០ បានរុញច្រានប្រទេសកម្ពុជាឱ្យធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាមដ៏សែនរន្ធត់ អំពើហិង្សា និងរបបប្រល័យពូជសាសន៍ដ៏ ឃោរឃៅយង់ឃ្នង។ ចាប់ពីពេលដែលពួកខ្មែរក្រហមបានឡើងកាន់អំណាច នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥មក ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងអន្លង់អន្ធការនៃរបបប្រល័យពូជសាសន៍ និងការសម្លាប់ជាតិសាសន៍ឯង។ ប្រជាជនត្រូវបានជម្លៀសចេញអស់ពីទីក្រុង មន្ទីរពេទ្យនៅសល់តែសម្បកអាគារ សាលារៀន បណ្ណាល័យ រោងចក្រ និងវត្តអារាម ត្រូវបានបិទទ្វារ ហើយរូបិយវត្ថុត្រូវបានគេបំផ្លាញចោល។ ប្រទេសកម្ពុជាត្រូវបន្តរស់នៅក្នុងស្ថានភាពងកោបែបនេះអស់រយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ។ ធនធានមនុស្សនៅកម្ពុជាត្រូវបានបំផ្លិចបំផ្លាញ និងកម្ទេចចោលអស់ស្ទើរទាំងស្រុង។ ប្រជាជនកម្ពុជាបាត់បង់ទាំងស្រុងនូវសិទ្ធិសេរីភាព ហើយបានក្លាយជាទាសករនៅក្នុងគុកឥតជញ្ជាំង។ មាតុភូមិកម្ពុជាដែលមានអរិយធម៌អង្គរថ្កុំថ្កើងរុងរឿង ត្រូវបានប្រែក្លាយជាវាលពិឃាត ដូចស្ថាននរកអវិចី។ ខ្មែរបាក់ស្មារតី ហើយបាត់បង់អស់នូវទស្សនវិស័យសម្រាប់អនាគតរបស់ខ្លួន។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺជាទិវាប្រវត្តិសាស្ត្រ ដែលមាតុភូមិកម្ពុជាត្រូវបានរំដោះចេញ ផុតពីរបបប្រល័យពូជសាសន៍ប៉ុល ពត ដោយ **រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា** ដោយមានការឧបត្ថម្ភគាំទ្រពីសំណាក់កងទ័ពស្ម័គ្រចិត្តវៀតណាម។ ប្រជាជនកម្ពុជាគ្រប់រូបដែលស្នេហាសន្តិភាព សេរីភាព និងយុត្តិធម៌ ចងចាំទិវានេះថា ជាថ្ងៃកំណើតទីពីររបស់ខ្លួន។

**សាធារណរដ្ឋប្រជាមានិតកម្ពុជា** បានចាប់បដិសន្ធិឡើង។ ប្រជាជនកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងអស់ពីកម្លាំងកាយចិត្ត ដើម្បីស្តារ និងកសាងប្រទេសជាតិឡើងវិញ រៀបចំខឿនសេដ្ឋកិច្ចថ្មី បង្កើតប្រព័ន្ធសិក្សាធិការជាតិ បើកមន្ទីរពេទ្យឡើងវិញ និងបណ្តុះបណ្តាលធនធានមនុស្ស ដោយចាប់ពីបាតដៃទទេ។ សាលារៀនដែលបើកទ្វារឡើងវិញមុនគេ គឺសាលាកុមារី (បច្ចុប្បន្នសាលាចតុមុខ) អនុវិទ្យាល័យកម្ពុជបុត្រ ហើយបន្ទាប់មកគឺ វិទ្យាល័យភ្នំដូនពេញ ដែលជា វិទ្យាល័យព្រះស៊ីសុវត្ថិ នាពេលបច្ចុប្បន្ន។ បុគ្គលិកសិក្សាដែលនៅសេសសល់បានខិតខំបំពេញការងារគ្មានឈប់ឈរ ដើម្បីចូលរួមចំណែកក្នុងការកសាងប្រព័ន្ធអប់រំ និងសិក្សាធិការជាតិ និងស្រោចស្រង់វប្បធម៌ខ្មែរឱ្យរស់ឡើងវិញ។ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមានសម្តេច **ហ៊ុន សែន** ជាប្រមុខ បានបញ្ជូននិស្សិតជាច្រើនឱ្យទៅបណ្តុះបណ្តាលវិជ្ជាជីវៈនិងទៅសិក្សាកម្រិតឧត្តមសិក្សានៅប្រទេសក្រៅ ជាពិសេសនៅអឺរ៉ុបខាងកើត ទន្ទឹមនឹងការខិតខំប្រឹងប្រែងបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងប្រទេស។ កម្លាំងថ្មីទាំងនេះបានពួតដៃគ្នាជាធ្លុងមួយជាមួយប្រជាជនកម្ពុជាទាំងមូល ដើម្បីជួយកសាងប្រទេសជាតិឡើងវិញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក៏ប៉ុន្តែ ក្រោយពីការដួលរលំនៃរបបខ្មែរក្រហមប្រល័យពូជសាសន៍ កម្ពុជានៅតែទទួលរងនូវការដាក់ទណ្ឌកម្មសេដ្ឋកិច្ចពីបរទេស ដោយសារតែវត្តមាននៃកងទ័ពវៀតណាមដែលជួយការពារ ប្រជាជនកម្ពុជាឱ្យរួចផុតពីការវិលត្រលប់នៃរបបប្រល័យពូជសាសន៍។ កម្ពុជាត្រូវបានកាត់ផ្តាច់ពីប្រព័ន្ធពាណិជ្ជកម្ម និងហិរញ្ញវត្ថុពិភពលោក។ ដោយសារមានជំនួយពីអតីតសហភាពសូវៀត វៀតណាម និងប្រទេសដទៃទៀតនៃប្លុកលោកខាងកើត ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនតូច រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដឹកនាំដោយសម្តេច **ហ៊ុន សែន** បានចាប់ផ្តើមកសាងខឿនសេដ្ឋកិច្ច និងសង្គមឡើងវិញ។ ក៏ប៉ុន្តែកង្វះធនធានមនុស្ស គឺជាឧបសគ្គចម្បងបំផុតនៃដំណើរការកសាងជាតិឡើងវិញលើគ្រប់វិស័យ។ ដូច្នេះ អាទិភាពដំបូងបំផុតក្នុងការអភិវឌ្ឍគឺការផ្តល់ការបណ្តុះបណ្តាលធនធានមនុស្ស។ ក្នុងន័យនេះ សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលបានចាប់បដិសន្ធិឡើងនៅក្នុងឆ្នាំ ១៩៧៩ បានដឹកនាំនាវាកម្ពុជាចូលក្នុងដំណាក់កាលជាប្រវត្តិសាស្ត្រថ្មីមួយគឺការស្តារ និងស្ថាបនាមាតុភូមិកម្ពុជាឡើងវិញលើគ្រប់វិស័យ ដោយចាប់ផ្តើមពីបាតដៃទទេ។

ថ្វីត្បិតតែរបបខ្មែរក្រហមបានដួលរលំក្នុងឆ្នាំ១៩៧៩ ក៏ដោយ ភ្លើងសង្គ្រាមស៊ីវិលនៅបន្តដុតដៃនដីសុវណ្ណភូមិ ដោយសារកម្លាំងខ្មែរក្រហមដែលនៅសេសសល់បានចាប់ដៃជាមួយភាគីខ្មែរ មិនមែនកុំមុយនីស្តពីរផ្សេងទៀត គឺចលនាសីហនុនិយម និងសឺនសាននិយម ដោយបង្កើតរដ្ឋាភិបាលត្រីភាគី ហើយបានវាយបកយ៉ាងខ្លាំងក្លាមកលើ **សាធារណរដ្ឋប្រជាមានិតកម្ពុជា** ដ៏ក្មេងខ្ចីនេះ។

ដោយយល់ឃើញថា ជម្លោះនៅកម្ពុជាមិនអាចបញ្ចប់បាន ដោយសារសង្គ្រាមទេនោះ ទើបប្រមុខនៃរដ្ឋាភិបាលនៃសាធារណរដ្ឋកម្ពុជា បានផ្តួចផ្តើមឱ្យមានជំនួបទ្វេភាគី **ហ៊ុន សែន-សីហនុ** ដើម្បីស្វែងរកដំណោះស្រាយបញ្ហាកម្ពុជាដោយសន្តិវិធី។ បន្ទាប់ពីមានជំនួបហូរហែរួចមក បារាំងបានសម្របសម្រួលរៀបចំសន្និសីទអន្តរជាតិមួយនៅទីក្រុងប៉ារីសនៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ ដោយមានភាគីកម្ពុជាទាំងបួន និងតំណាងប្រទេសចំនួន១៨ចូលរួម។សន្និសីទបានឈានទៅដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីដំណោះស្រាយនយោបាយគ្រប់ជ្រុងជ្រោយនៃវិបត្តិកម្ពុជា តាមរយៈការបោះឆ្នោតជាសកល ដែលរៀបចំឡើងដោយអង្គការ សហប្រជាជាតិនៅក្នុងឆ្នាំ១៩៩៣។

ក្រោយការបោះឆ្នោតនៅក្នុងឆ្នាំ ១៩៩៣ លក្ខខណ្ឌតម្រូវដំបូងៗសម្រាប់ការអភិវឌ្ឍពិតប្រាកដនៅមិនទាន់បានបង្កើតឡើងនៅឡើយ។ សង្គ្រាម និងអសន្តិសុខនៅបន្តញាំញីប្រជាជន កម្ពុជា ដោយសាភាគីខ្មែរក្រហមបានធ្វើពហិការ មិនចូលរួមការបោះឆ្នោត និងមិនបានទទួល យករាជរដ្ឋាភិបាលកម្ពុជា ដែលប្រសូតចេញពីការបោះឆ្នោតនេះ។ កម្ពុជាស្ថិតនៅក្នុងស្ថានភាព មានសង្គ្រាមផង និងមានសន្តិភាពផង ដោយសារកងកម្លាំងយោធាខ្មែរក្រហមនៅរាយប៉ាយពាសពេញផ្ទៃប្រទេស ហើយបង្កើតបានជាតំបន់ស្បែកខ្លាដែលពួកគេបន្តគ្រប់គ្រង។

ស្ថិតនៅចំពោះមុខសភាពការណ៍នេះ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានដាក់ចេញនូវ **គោលនយោបាយ** «**ឈ្នះ-ឈ្នះ**» ដើម្បីការផ្សះផ្សា និងការបង្រួបបង្រួមជាតិ ក្នុងគោលដៅទាក់ទាញកងកម្លាំងខ្មែរក្រហមឱ្យចុះចូលជាមួយរាជរដ្ឋាភិបាល។ ជាបដិការ រាជរដ្ឋាភិបាលកម្ពុជាបានធានាផ្តល់ឱ្យពួកគេនូវសន្តិសុខផ្លូវកាយ និងស្វ័យគ្រប់គ្រងលើតំបន់ដែលពួកគេត្រួតត្រាចំនួន១០ឆ្នាំ។ បន្ទាប់ពីកងកម្លាំង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យោធា និងនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យបានចុះចូលជាមួយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** រចនាសម្ព័ន្ធ និងអង្គការចាត់តាំងយោធា និងនយោបាយ របស់ខ្មែរក្រហមត្រូវរលំរលាយ។ នេះ គឺជាលើកទីមួយហើយ ក្នុងប្រវត្តិសាស្ត្រកម្ពុជាក្នុងរយៈពេលជាងប្រាំរយឆ្នាំកន្លងទៅនេះ ដែលទឹកដីកម្ពុជាទាំងមូលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល តែមួយ ដោយគ្មានវត្តមានកងកម្លាំងប្រដាប់អាវុធប្រឆាំងរដ្ឋាភិបាល។ ទោះបីជានៅក្នុងទសវត្សទី ៥០ និង ៦០ នៃរបបសង្គមរាស្ត្រនិយម ក៏គេឃើញមានវត្តមានកងកម្លាំងប្រដាប់អាវុធរបស់ខ្មែរស ខ្មែរខៀវ ឬ ខ្មែរក្រហម នៅបង្កប់តាមតំបន់ព្រំដែនផងដែរ។

ក៏ប៉ុន្តែ នៅក្នុងអំឡុងទសវត្សទី ៩០ កម្ពុជាគឺជាប្រទេសដែលមានកម្រិតអភិវឌ្ឍន៍ទាប ដោយសារកម្ពុជាទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារសង្គ្រាម និងការស្ថិតនៅឯកោពីសហគមន៍អន្តរជាតិ។ ប្រាក់ចំណូលប្រចាំឆ្នាំរបស់ប្រជាជនម្នាក់ៗមានចំនួនមិនដល់ ២០០ ដុល្លារផង។ ជាពិសេសមហន្តរាយផ្នែកសង្គមមានទំហំយ៉ាងធំធេងណាស់។ នៅដើមទសវត្សទី៩០ ប្រទេសកម្ពុជាមានអត្រាមរណភាពទារកកម្រិតខ្ពស់ជាងគេនៅលើពិភពលោក។ បើប្រៀបធៀបគ្នាទៅនឹងប្រទេសអាហ្វ្រិក និងឥណ្ឌា អត្រាមរណភាពស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលសម្រាលទារកនៅកម្ពុជា មានកម្រិតលើសគេទ្វេរដង។ មិនតែប៉ុណ្ណោះ ប្រទេសកម្ពុជាមានអត្រាជនពិការខ្ពស់ជាងគេ និងករណីជម្ងឺរបេងច្រើនជាងគេនៅលើពិភពលោកផងដែរ។ ប្រជាជនជនបទតែ ១២% ប៉ុណ្ណោះមានទឹកស្អាតប្រើប្រាស់។ នៅកន្លែងខ្លះនៅទីជនបទ ចំនួនកុមារចុះឈ្មោះចូលរៀនមានមិនដល់ ៣០%ផង។

ដើម្បីលើកកម្ពស់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពលើការវិនិយោគក្នុងវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយផ្តោតជាពិសេសលើផ្លូវដឹកជញ្ជូន និងទូរគមនាគមន៍ ថាមពលអគ្គិសនី ការអភិវឌ្ឍធនធានមនុស្ស ឧស្សាហកម្ម អតិពលកម្ម ព្រមទាំងផលិតផលកម្មន្តសាលសម្រាប់នាំចេញ និងទេសចរណ៍។ គោលនយោបាយនេះមានគោលដៅបង្កើតឡើងនូវមូលដ្ឋានគ្រឹះដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

ក្នុងរយៈពេល ១៥ ឆ្នាំតែប៉ុណ្ណោះ បន្ទាប់ពីមានសុខសន្តិភាពយ៉ាងពេញលេញចាប់ពីឆ្នាំ ១៩៩៩ មក ព្រះរាជាណាចក្រកម្ពុជាមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដោយប្រែក្លាយពីប្រទេសមួយដែលពោរពេញដោយអស្ថិរភាព សង្គ្រាមរ៉ាំរ៉ៃ ឧក្រិដ្ឋកម្ម និងការបែកបាក់ ទៅជាដែនដីប្រកបដោយសុខសន្តិភាព ស្ថិរភាព ការបង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ក៏ប៉ុន្តែប្រជាធិបតេយ្យនៅកម្ពុជានៅក្មេងខ្ចីនៅឡើយ ដែលទាមទារឱ្យមានវប្បធម៌នយោបាយសន្ទនាការទទួលខុសត្រូវ ភាពចាស់ទុំនយោបាយ និងការរក្សាវប្បធម៌សន្តិភាព។

ក្នុងវិស័យសេដ្ឋកិច្ច កម្ពុជាសម្រេចបាននូវសមិទ្ធផលយ៉ាងធំធេង។ សេដ្ឋកិច្ចកម្ពុជាបានប្រែក្លាយ ពីសេដ្ឋកិច្ចប្រពៃណីដែលផ្អែកលើវិស័យកសិកម្មជាចម្បង ទៅជាសេដ្ឋកិច្ចទំនើប ដែលវិស័យឧស្សាហកម្ម និងសេវាកម្មដើរតួនាទីឈានមុខ។ វិស័យកសិកម្មនាពេលបច្ចុប្បន្ន គឺវិស័យដែលប្រើប្រាស់នូវគ្រឿងយន្តកសិកម្ម ដែលទាមទារឱ្យកសិករត្រូវពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យក្លាយជាកសិករសម័យទំនើប។

ការសម្រេចបាននូវសុខសន្តិភាពយ៉ាងពេញលេញ បានបង្កើតឡើងលក្ខខណ្ឌចាំបាច់សម្រាប់ការវិនិយោគសាធារណៈ និងឯកជន ដែលជាកត្តាគន្លឹះសម្រាប់កំណើនសេដ្ឋកិច្ច ការបង្កើតការងារ និងការរៀបចំនូវទស្សនវិស័យច្បាស់លាស់សម្រាប់អនាគតមួយដ៏ភ្លឺស្វាង។ ក្នុងន័យនេះរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច តាមរយៈការពង្រឹងឧត្តមភាពប្រៀបធៀបរបស់កម្ពុជា ទាំងក្នុងតំបន់ទាំងលើឆាកអន្តរជាតិ។

រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់អាទិភាពដល់ការវិនិយោគសាធារណៈ ក្នុងការស្ដារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគឯកជន ដែលក្លាយជាមូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ច។ យុទ្ធសាស្ត្រសេដ្ឋកិច្ចកម្ពុជា គឺការប្រែក្លាយការវិនិយោគទាំងក្នុង និងក្រៅប្រទេស ឱ្យទៅជាការនាំចេញទំនិញ និងសេវាដែលកម្ពុជាមានឧត្តមភាពប្រៀបធៀប។ ដោយមានការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍ និងដៃគូពាណិជ្ជកម្មរបស់ខ្លួន កម្ពុជាបានបង្កើតឡើងនូវមូលដ្ឋានសេដ្ឋកិច្ចទីផ្សារ ហើយបាន និងកំពុងចូលរួមយ៉ាងសកម្មក្នុងប្រព័ន្ធពាណិជ្ជកម្មពិភពលោក និងដំណើរការសមាហរណកម្មក្នុងតំបន់។

ដោយមានមោទនភាពចំពោះអតីតកាលដ៏រុងរឿង និងសមិទ្ធិថ្មីៗក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម រាជរដ្ឋាភិបាលកម្ពុជាបានខិតខំអស់ពីកម្លាំងកាយចិត្ត និងបង្ហាញនូវឆន្ទៈយ៉ាងមុះមុត ក្នុងការធ្វើកំណែទម្រង់ចាំបាច់នានា ដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍ និងធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ប្រជាជនកម្ពុជាត្រូវតែមានការប្ដេជ្ញាចិត្តខ្ពស់ ក្នុងការប្រែក្លាយសក្ដានុពលនៃធនធានដែលខ្លួនមាន ឱ្យទៅជាការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងប្រកបដោយចីរភាព។ ការអភិវឌ្ឍទាមទារឱ្យប្រជាជនកម្ពុជាប្រមូលផ្តុំកម្លាំងរួម សាមគ្គីភាពជាធ្លុងមួយ និងការលះបង់ខ្ពស់ ដើម្បីដឹកនាំនាវាកម្ពុជាដណ្ដើមយកជោគជ័យលើសមរភូមិប្រយុទ្ធប្រឆាំងភាពក្រីក្រ និងសម្រេចបាននូវវឌ្ឍនភាពសេដ្ឋកិច្ច-សង្គម។

លើសមរភូមិសេដ្ឋកិច្ច ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០១៤ សេដ្ឋកិច្ចកម្ពុជាមានកំណើនជាមធ្យម ៧% ក្នុងមួយឆ្នាំ ដែលជាកំណើនខ្ពស់នៅក្នុងតំបន់។ ទោះបីជាសេដ្ឋកិច្ចពិភពលោកត្រូវបានឃាយីដោយវិបត្តិហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរក៏ដោយ កម្ពុជាសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការគ្រប់គ្រងសេដ្ឋកិច្ចប្រកបដោយចីរភាព អត្រាអតិផរណាទាប ស្ថិរភាពអត្រាប្ដូរប្រាក់ និងហិរញ្ញវត្ថុសាធារណៈរឹងមាំ។ ក៏ប៉ុន្តែ ទោះបីជាកម្ពុជាសម្រេចបាននូវវឌ្ឍនភាពដ៏ច្រើនសន្ធឹកសន្ធាប់យ៉ាងណាក្តី កម្ពុជាត្រូវបន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវកិច្ចការកំណែទម្រង់រចនាសម្ព័ន្ធ និងត្រូវពន្លឿនកំណែទម្រង់តាមវិស័យ ឱ្យមាននិរន្តរភាព ក្នុងគោលដៅធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងជម្រុញការអភិវឌ្ឍប្រកបដោយចីរភាព និងប្រកបដោយបរិយាប័ន្ន។

នៅឆ្នាំ ២០១៤ កំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានរង្វង់ ៧% ក្នុងនោះៈ ទី១-វិស័យឧស្សាហកម្មមានកំណើនប្រមាណ ៩,៦% ដោយសារការនាំចេញផលិតផលវាយនភ័ណ្ឌរក្សាបានកំណើនខ្ពស់ ហើយផ្នែកសំណង់បានកើនឡើងគួរឱ្យកត់សម្គាល់, ទី២-វិស័យសេវាមានកំណើន ៧,៥% ដោយការរួមចំណែកពីកំណើនខាងផ្នែកពាណិជ្ជកម្ម, ផ្នែកសណ្ឋាគារ និងភោជនីយដ្ឋាន, ផ្នែកអចលនទ្រព្យ, ផ្នែកធនាគារ និងភាពប្រសើរឡើងនៃប្រព័ន្ធឡូជីស្ទិក និង ទី៣-វិស័យកសិកម្ម សម្រេចបានកំណើន ២,៦% ដោយសារពិពិធកម្មនៃការដាំដុះ និងការកើនឡើងនៃផលិតភាព ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេដ្ឋកិច្ចកម្ពុជានៅបន្តកំណើនយ៉ាងរឹងមាំ និងជឿជាក់ ក្នុងរយៈពេលខ្លី និងមធ្យម។ នៅឆ្នាំ ២០១៥ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានក្នុងរង្វង់ ៧%។ កំណើនសេដ្ឋកិច្ចនេះទ្រទ្រង់ដោយៈ ទី១-កំណើនក្នុងវិស័យឧស្សាហកម្មចំនួន ៩,០% ដោយសារចលនការនៃពិពិធកម្មមូលដ្ឋានឧស្សាហកម្ម ដែលភ្ជាប់ទៅនឹងបណ្តាញផលិតកម្មតំបន់ ហើយនិងការបន្តការលូតលាស់នៃវិស័យឧស្សាហកម្មកាត់ដេរ សម្រាប់នាំចេញទៅទីផ្សារអាមេរិក និងសហគមន៍អឺរ៉ុបដែលកំពុងងើបឡើង ក៏ដូចជាការបន្តកើនឡើងនៃវិស័យសំណង់, ទី២-កំណើន ក្នុងវិស័យសេវាចំនួន ៧,១% ដោយសារកំណើនខាងផ្នែកទេសចរណ៍ វិស័យហិរញ្ញវត្ថុ ពាណិជ្ជកម្ម និងអចលនទ្រព្យ ទី៣-កំណើនក្នុងវិស័យកសិកម្មចំនួន ៣,៨% ដោយសារការបន្តកើនឡើងនៃផលិតកម្មស្រូវ/អង្ករ និងកសិផលផ្សេងទៀត ព្រមទាំងការចិញ្ចឹមសត្វ ក៏ដូចជាការពង្រីកការនាំចេញនូវផលិតផលទាំងនេះ ទៅកាន់ទីផ្សារអន្តរជាតិ ។

កំណើនសេដ្ឋកិច្ចដ៏ខ្ពស់នេះបានធ្វើឱ្យផលិតផលក្នុងស្រុកកម្ពុជា (ផសស) តាមថ្លៃបច្ចុប្បន្ន មានចំនួន ៧៤.៤៤៤ ពាន់លានរៀល ប្រមាណជា ១៨.៣៨១ លានដុល្លារអាមេរិក ។ ប្រការនេះធ្វើឱ្យប្រាក់ចំណូលសម្រាប់មនុស្សម្នាក់រំពឹងថានឹងទទួលបាន ១.២២៥ ដុល្លារអាមេរិក ដែលមានន័យថា កម្ពុជាកំពុងបោះជំហានពីប្រទេសដែលមានការអភិវឌ្ឍទាបជាងគេទៅកាន់ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ រាជរដ្ឋាភិបាលនីតិកាលទី៥ នេះបានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតា ដើម្បីប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងទៅជាប្រទេសអភិវឌ្ឍនៅឆ្នាំ ២០៥០។

ក្នុងបរិយាកាសសាកលលោក និងតំបន់ដែលពោរពេញទៅដោយបញ្ហាប្រឈមនេះ កម្ពុជានៅមានការងារច្រើនទៀតដែលត្រូវធ្វើ ទម្រាំអាចធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចដែលរឹងមាំ និងយូរអង្វែងមួយបានទៅអនាគត។ ដើម្បីសម្រេចបាននូវគោលដៅប្រកបដោយមហិច្ឆតាខាងលើតួអង្គដែលពាក់ព័ន្ធទាំងអស់ត្រូវតែឯកភាពគ្នាលើទិសដៅអភិវឌ្ឍរួម និងពន្លឿនការងារកំណែទម្រង់ក្នុងគ្រប់វិស័យ។

**ទីមួយ**-ត្រូវពង្រឹងស្ថេរភាពនយោបាយ អភិបាលកិច្ច និងការគោរពសណ្តាប់ធ្នាប់សាធារណៈ និងត្រូវពង្រឹងការអនុវត្តច្បាប់។ ក្នុងវិស័យការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងការលើកកម្ពស់ការគោរពសិទ្ធិមនុស្សវិញ ប្រទេសកម្ពុជាត្រូវបន្តអនុវត្តនូវប្រព័ន្ធអភិបាលកិច្ចមួយ សមស្របសម្រាប់មរតកប្រវត្តិសាស្ត្រ និងវប្បធម៌របស់ខ្លួន។ ការបោះឆ្នោតត្រូវបានរៀបចំជាប្រក្រតី និងប្រកបដោយតម្លាភាព និងយុត្តិធម៌។ សិទ្ធិ និងសេរីភាពបុគ្គល និងសមូហភាពត្រូវបានធានា។ គណបក្សនយោបាយ សហជីពកម្មករ និងអ្នកសារព័ត៌មានត្រូវបំពេញមុខងាររបស់ខ្លួន ដោយសេរីនៅក្នុងប្រទេសប្រជាធិបតេយ្យដ៏ក្មេងខ្ចីនេះ។ កម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើគ្រប់កិច្ចព្រមព្រៀងអន្តរជាតិស្តីពីការការពារសិទ្ធិមនុស្ស។ ការអប់រំប្រជាពលរដ្ឋអំពីសិទ្ធិពលរដ្ឋ និងការទទួលខុសត្រូវរបស់ពួកគាត់ គឺជាផ្នែកមួយដ៏សំខាន់នៃសកម្មភាពរបស់រដ្ឋាភិបាល។ ក៏ប៉ុន្តែ ការចង់បានសេរីភាពខាងនយោបាយ មិនគប្បីធ្វើឱ្យប៉ះពាល់ដល់ស្ថេរភាពនយោបាយ និងសង្គម ដែលកម្ពុជាទទួលបានក្រោយពីភាពកោលាហល និងការបង្ហូរឈាមគ្នាអស់ជាច្រើនទសវត្សរ៍មកហើយនោះទេ ហើយក៏មិនត្រូវដាក់សម្ពាធបន្ថែមទៅលើសមត្ថភាពស្ថាប័ន នយោបាយ សង្គម និងអភិបាលកិច្ចដែលងាយផុយស្រួយនៃពន្លកប្រជាធិបតេយ្យនេះនោះដែរ។ ជាមួយគ្នានេះផងដែរ ផ្លែផ្កានៃការអភិវឌ្ឍគប្បីត្រូវបានចែករំលែកឱ្យបានស្មើគ្នា រវាងអ្នកមាន និងអ្នកក្រ ដើម្បីរក្សាឱ្យបាននូវស្ថេរភាពសង្គម។

**ទីពីរ**-កិច្ចការជាច្រើនដែលត្រូវធ្វើបន្ត គឺការពង្រឹងយុត្តិធម៌សង្គម ដោយប្រើប្រាស់សេរីភាពសារព័ត៌មាន ជាកញ្ចក់សម្រាប់ឆ្លុះមើលបញ្ហាសង្គម និង ដោយសហការយ៉ាងជិតស្និទ្ធជាមួយបណ្ដាអង្គការក្រៅរដ្ឋាភិបាលជាច្រើន ទាំងជាតិ និងអន្តរជាតិ ដែលកំពុងបម្រើការងារក្នុងផ្នែកផ្សេងៗ ក្នុងការដោះស្រាយបញ្ហាសង្គមចម្បងៗ ជាអាទិ៍ គឺការជួញដូរស្ត្រីនិងកុមារ ការដោះស្រាយបញ្ហាកសិករគ្មានដីធ្លី។ ភាពជោគជ័យខាងផ្នែកសេដ្ឋកិច្ចត្រូវធានាឱ្យបាននូវយុត្តិធម៌សង្គម គុល្យភាពរវាងទីក្រុង និងជនបទ និងការបង្កើតការងារសម្រាប់កសិករគ្មានដីធ្លី និងយុវជនជំនាន់ក្រោយ។

**ទីបី**-ត្រូវពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការអនុវត្តគោលនយោបាយ។ ចាប់ពីឆ្នាំ១៩៩៣ ដល់ ២០០៨ មានការធ្វើកំណែទម្រង់ស្ថាប័ន និងគោលនយោបាយជាច្រើន។ ក្រសួង-ស្ថាប័នទាំងអស់ត្រូវប្រឹងប្រែងបន្ថែមទៀត ដើម្បីបំពេញមុខងារប្រកបដោយប្រសិទ្ធភាព និងមានចំណាត់ការជាក់លាក់ ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយដែលបានឯកភាពគ្នា។ កំណែទម្រង់ត្រូវតែពង្រឹងប្រសិទ្ធផលនៃស្ថាប័ននយោបាយ និងសេដ្ឋកិច្ចរបស់រដ្ឋ។ ចំណុចអាទិភាពខ្ពស់បំផុត គឺការអនុវត្តគោលនយោបាយអប់រំឱ្យមានប្រសិទ្ធភាព និងការផ្ដល់ការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ការទទួលបានការថែទាំសុខភាពដែលមានគុណភាព និងបញ្ញាបច្ចេកវិទ្យាចុងក្រោយខាងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដែលជឿនលឿនយ៉ាងខ្លាំង ឱ្យបានជ្រួតជ្រាបដល់គ្រប់វិស័យ និងដល់សាធារណៈជន។

**ទីបួន**-កិច្ចការពារ និងអភិវឌ្ឍធនធានធម្មជាតិ កាន់តែមានសារៈសំខាន់ខ្លាំងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ឆ្នាំ ២០១៥ នេះ គឺជាឆ្នាំអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីធានានិរន្តរភាពនៃស្ថិរភាពសង្គម និង ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយយុត្តិធម៌។ នៅក្នុងរបៀបវារៈក្រោយឆ្នាំ ២០១៥ គោលដៅនៃការអភិវឌ្ឍសហស្សវត្សត្រូវបានប្រែក្លាយឱ្យ ទៅជាគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ វិធានការក្នុងវិស័យបច្ចេកទេស ហិរញ្ញវត្ថុ វប្បធម៌ អប់រំ ស្រាវជ្រាវ កិច្ចសហប្រតិបត្តិការនយោបាយ និងស្ថាប័ន ត្រូវតែឆ្លុះបញ្ចាំងអំពីឆន្ទៈនយោបាយដើម្បីសម្រេចបាននូវការអភិវឌ្ឍដោយចីរភាពតាមរយៈកិច្ចការពារបរិស្ថាន។ យើងត្រូវមានយន្តការដែលមានតម្លាភាពមួយ ដើម្បីផ្ដល់នូវដីសម្បទានសង្គមកិច្ចដល់កសិករគ្មានដីធ្លី។

**ទីប្រាំ**-យើងត្រូវកៀគរធនធានបន្តទៀត ដោយផ្ដោតលើការប្រើប្រាស់ធនធានក្នុងស្រុក និងការសម្រិតសម្រាំងរកគម្រោងវិនិយោគទាំងឡាយដែលមានប្រសិទ្ធផលខ្ពស់។ យើងត្រូវលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សនៅគ្រប់កម្រិត។ សហគ្រិនដែលមានជំនាញ និងអ្នករដ្ឋបាល និងចំណេះដឹងខាងបច្ចេកទេសគឺជាកត្តាគន្លឹះនៃផលិតកម្ម និងមានសារៈសំខាន់ក្នុងយន្តការផលិតកម្មដូចគ្នាទៅនឹងមូលធនរូបវន្តដូច្នេះដែរ។ យើងត្រូវផ្ដល់អាទិភាពទៅលើការវិនិយោគដើម្បីបង្កើនផលិតភាពពលកម្ម និងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ ក្នុងថ្មីៗកន្លងទៅនេះ អ្នកវណ្ណៈកណ្ដាលមានការកើនឡើងនៅប្រទេសកម្ពុជា ដែលនេះជាការអភិវឌ្ឍដ៏គួរឱ្យស្វាគមន៍ ដែលនឹងជួយឱ្យមានស្ថេរភាពសង្គម។ អ្នកវណ្ណៈកណ្ដាលទាំងនេះគប្បីពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីទទួលបានប្រយោជន៍ឱ្យបានច្រើនពីកាលានុវត្តភាពនៃការអភិវឌ្ឍ និងសមាហរណកម្ម។ សហគ្រិនកម្ពុជាត្រូវតែធ្វើយ៉ាងណាតាមឱ្យទាន់ដៃគូប្រកួតប្រជែងរបស់ខ្លួនទាំងឡាយនៅក្នុងតំបន់ ខាងសមត្ថភាពស្ថាប័ន និងបច្ចេកទេស ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ទីប្រាំមួយ**-សាកលភាវូបនីយកម្មនិងទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសត្រូវតែគាំទ្រដល់ការអភិវឌ្ឍ តាមរយៈ (១) ជំនួយអភិវឌ្ឍផ្លូវការ (២) ការវិនិយោគផ្ទាល់ពីបរទេស និង (៣) ពាណិជ្ជកម្មក្រៅប្រទេស។ គេត្រូវតែពិចារណាអំពីសកម្មភាព និងលទ្ធផលរបស់វេទិកាអភិវឌ្ឍកម្ពុជា និងត្រូវពង្រឹងកិច្ចសហការជាមួយស្ថាប័នរូបិយវត្ថុអន្តរជាតិ ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូអភិវឌ្ឍទ្វេភាគីដទៃទៀត រួមទាំងការពិគ្រោះយោបល់ក្នុងក្របខ័ណ្ឌអាស៊ាន អាស៊ានបូកបី និងអង្គការពាណិជ្ជកម្មពិភពលោកផងដែរ។ ប្រទេសកម្ពុជាបានប្តេជ្ញាចិត្តប្រើប្រាស់យន្តការពិគ្រោះយោបល់ទាំងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីធានានូវការហក់ឡើងនៃសេដ្ឋកិច្ចជាតិ។

របាយការណ៍ និងការវិភាគនៃសមិទ្ធផលសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមសេវាសាធារណៈ ដូចជាការអប់រំ សុខាភិបាល ការដឹកជញ្ជូន គមនាគមន៍ ការផ្គត់ផ្គង់ទឹក និងថាមពល ប្រព័ន្ធធារាសាស្ត្រ និងបង្ហូរទឹក និងការវាយតម្លៃគុណភាពស្ថាប័ន និងអភិបាលកិច្ចល្អទាំងនេះសុទ្ធតែដើរតួយ៉ាងសំខាន់ដើម្បីទាក់ទាញការវិនិយោគឯកជន និងការគៀរគរការគាំទ្រទូលំទូលាយរបស់សហគមន៍អន្តរជាតិ សម្រាប់ជួយដល់កិច្ចខំប្រឹងប្រែងអភិវឌ្ឍន៍របស់កម្ពុជា។

សៀវភៅនេះមានបំណងពិនិត្យមើលជាទូទៅ លើការតស៊ូរបស់កម្ពុជាក្នុងការជំរុញការអភិវឌ្ឍប្រកបដោយចីរភាព និងការចែករំលែកវិបុលភាព យុទ្ធសាស្ត្រ និងគោលនយោបាយសម្រាប់កំណែទម្រង់ក្នុងវិស័យសំខាន់ៗ និងលទ្ធផលដែលទទួលបាន។ ការស្រាវជ្រាវនេះសង្កត់ធ្ងន់លើសមិទ្ធិរបស់កម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍មុន មុនឆ្នាំ ២០១០ កន្លងទៅនេះ និងបញ្ហាទាំងឡាយដែលត្រូវដោះស្រាយទៅអនាគត។ ដោយសារបញ្ហាពេលវេលា អ្នកនិពន្ធមិនអាចធ្វើ បច្ចុប្បន្នកម្មនៃតួលេខដែលត្រូវបានបោះពុម្ពជាភាសាអង់គ្លេស នៅឆ្នាំ ២០០៩ និង ជាភាសាបារាំងនៅឆ្នាំ ២០១០។ ស្នាដៃជាខេមរភាសា គឺជាការបកប្រែទាំងស្រុងពីភាសាអង់គ្លេស។ ដូច្នេះ សៀវភៅ «**សេដ្ឋកិច្ចកម្ពុជា**» ជាខេមរភាសានេះ អាចនឹងមានឃ្លាឃ្លោងមួយចំនួនដែលពិបាកយល់។ អ្នកនិពន្ធសង្ឃឹមថា ប្រិយមិត្តអ្នកអានច្បាស់ជាខន្តីអភ័យទោសចំពោះកំហុសដោយអចេតនាជាយថាហេតុនេះ ដោយសារអ្នកនិពន្ធគ្មានពេលគ្រប់គ្រាន់ដើម្បីផ្ទៀងផ្ទាត់។ ទោះជាយ៉ាងណាក៏ដោយ អ្នកនិពន្ធបានចំណាយពេល ១០ ឆ្នាំ ដើម្បីចងក្រងសៀវភៅនេះឡើង ដើម្បីចែករំលែកបទពិសោធន៍របស់ខ្លួនដល់កូនខ្មែរជំនាន់ក្រោយ។

សៀវភៅនេះរៀបចំចេញជាប្រធានបទសំខាន់ៗដូចតទៅនេះ (១).ទិដ្ឋភាពរួមនៃភូមិសាស្ត្រ និងលក្ខខណ្ឌអាកាសធាតុកម្ពុជា (២). ប្រជាសាស្ត្រកម្ពុជា (៣). ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច (៤). កសិកម្មនិងអភិវឌ្ឍន៍ជនបទ (៥). ឧស្សាហកម្មនិងការអភិវឌ្ឍវិស័យឯកជន (៦). វិស័យសេវាមិនមែនហិរញ្ញវត្ថុ (៧). ហេដ្ឋារចនាសម្ព័ន្ធ និង (៨). ការអភិវឌ្ឍធនធានមនុស្ស (៩). វិស័យហិរញ្ញវត្ថុ (១០). ហិរញ្ញវត្ថុសាធារណៈ(១១). ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ។ ចុងបញ្ចប់ សៀវភៅនេះពិភាក្សាអំពីបញ្ហាការកសាងសមត្ថភាពស្ថាប័ន និងសមត្ថភាពមនុស្ស ដែលជាបញ្ហាប្រឈមចំពោះមុខរបស់ប្រទេសកម្ពុជា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្ញុំមានការពេញចិត្តផ្ទាល់ខ្លួន ចំពោះការដែលខ្ញុំបានចូលប្រឡូកយ៉ាងជិតស្និទ្ធ ក្នុងដំណើរការអភិវឌ្ឍកម្ពុជា ស្ទើរតែពីដើមដំបូងមកម្ល៉េះ។ បទពិសោធន៍នេះផ្តល់ឱ្យខ្ញុំនូវការយល់ដឹងស៊ីជម្រៅ ដែលខ្ញុំបានប៉ុនប៉ងយកមកឆ្លុះបញ្ចាំងជូនក្នុងសៀវភៅនេះ។ ខ្ញុំនៅតែជឿជាក់ថាការជំរុញ និងការលើកទឹកចិត្តដើម្បីឱ្យមានការអភិវឌ្ឍប្រទេសកម្ពុជានៅកម្រិតមូលដ្ឋាន គឺត្រូវតែកើតចេញមកពីប្រជាជនកម្ពុជាខ្លួនឯងផ្ទាល់។ ដូច្នេះ ជាសំខាន់ប្រជាជនកម្ពុជាត្រូវដឹងអំពីសមិទ្ធិរបស់ប្រទេសខ្លួន និងបញ្ហាប្រឈមទាំងឡាយដែលនៅមាន។ សៀវភៅនេះជាវិភាគទានដ៏តូចមួយ ក្នុងការផ្តល់ព័ត៌មានអំពីប្រទេសកម្ពុជា ដើម្បីធ្វើឱ្យសាធារណៈជនកម្ពុជាអាចត្រៀមខ្លួនជាមុនឱ្យបានល្អ ក្នុងការដោះស្រាយបញ្ហាប្រឈមនានាក្នុងដំណើការអភិវឌ្ឍ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ការថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណអស់ពីដួងចិត្តជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយដែលផ្តោតលើការបង្កើតឲ្យមានសន្តិភាពឡើងវិញ និងការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជា។ ខ្ញុំសូមអរគុណផងដែរចំពោះ **ឯកឧត្តមអគ្គសេដ្ឋាបណ្ឌិត គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ** ដែលឯកឧត្តមបានជួយលើកទឹកចិត្តក្នុងអំឡុងពេលត្រៀមរៀបចំសរសេរសៀវភៅនេះ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងជា **ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** ដែលតែងតែផ្តល់ឱកាសដល់រូបខ្ញុំ ក្នុងការធ្វើការស្រាវជ្រាវលើបញ្ហាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះសហការីរបស់ខ្ញុំជាច្រើនទៀតនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនៅឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលបានជួយផ្តល់មតិល្អៗដើម្បីកែលម្អទម្រង់ និងមាតិការឿងនៃសៀវភៅនេះផងដែរ។ ខ្ញុំសូមអរគុណចំពោះ **សាកលវិទ្យាល័យជាតិគ្រប់គ្រង** ដែលបានជួយបោះពុម្ពផ្សាយសៀវភៅនេះ។

ខ្ញុំសូមសម្តែងនូវសេចក្តីដឹងគុណយ៉ាងជ្រាលជ្រៅចំពោះមាតា និងបិតារបស់ខ្ញុំ ដែលបានចិញ្ចឹមបីបាច់ខ្ញុំ និងអប់រំខ្ញុំអោយក្លាយជាធនធានមួយរបស់កម្ពុជា។ ខ្ញុំសូមអរគុណដល់លោកគ្រូអ្នកគ្រូទាំងអស់ដែលបានផ្តល់អោយខ្ញុំនូវចំណេះដឹង សម្រាប់ការស្រាវជ្រាវសរសេរសៀវភៅនេះឡើង។ ខ្ញុំសូមអរគុណដល់ភរិយា កូនប្រុស និងកូនស្រីខ្ញុំ ដែលអនុញ្ញាតអោយខ្ញុំចំណាយពេលវេលាដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីបំពេញការងារជូនជាតិ ក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះ ជាពិសេសការងារពេលយប់ និងពេលឈប់សម្រាក។ វិទ្យាសាស្ត្រ និងចំណេះដឹង ទាមទារអោយមានការលះបង់ខ្ពស់។

ជាពិសេស ទូលបង្គំសូមឧទ្ទិសស្នាដៃនេះថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** និងចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានចូលរួមវិភាគទានយ៉ាងថ្លៃថ្លាក្នុងការកសាងឡើងវិញនូវសុខសន្តិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ហង់ ជួន ណារ៉ុន**

**ភ្នំពេញ ថ្ងៃទី ៧ ខែ មករា ឆ្នាំ ២០១៥**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សេចក្ដីផ្ដើម

*"តាមនិយមន័យ ពាក្យថាអភិវឌ្ឍ ជាដំណើរការនៃការផ្លាស់ប្ដូរមួយ។ ការកើនឡើងផ្នែកផលិតភាពនិងកំណើនខាងកសិកម្ម ការបោះបង់ចោលសកម្មភាពស្រែចម្ការ ដើម្បីចាប់យកការងារក្នុងផ្នែកឧស្សាហកម្ម និងសេវានិងបន្ទាប់មកគឺការចាកចេញពីជនបទ ទាំងអស់នេះ សុទ្ធតែជាកត្តាកំណត់យ៉ាងសំខាន់ក្នុងដំណើរការមួយនេះ។"*

**នីកូឡា ស្ទើន**

ក្រោយពីសង្គ្រាមស៊ីវិលដែលបានអូសបន្លាយអស់រយៈពេលជាងបីទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានទទួលសន្តិភាពចាប់តាំងពីឆ្នាំ១៩៩៨ និងបានកំពុងស្ដាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងរចនាសម្ព័ន្ធជាមូលដ្ឋានរបស់សង្គម និងកំពុងផ្ដល់លទ្ធភាពឱ្យប្រទេសអាចបង្វែរទិសនៃធនធាន និងកម្លាំងរបស់ខ្លួនឆ្ពោះទៅរកទិសដៅនៃការអភិវឌ្ឍប្រកបដោយចីរភាពនិងស្មើភាពគ្នា។ សមិទ្ធិរបស់ប្រទេសក្នុងរយៈពេលម្ភៃឆ្នាំចុងក្រោយនេះ គិតចាប់តាំងពីខែមករាឆ្នាំ១៩៧៩មក បង្ហាញនូវអ្វីខ្លះដែលប្រជាជនកម្ពុជាមានលទ្ធភាពធ្វើបាន នៅពេលដែលខ្លួនយកទេពកោសល្យនិងគំនិតច្នៃប្រឌិតរបស់ខ្លួនមកប្រើប្រាស់ ដើម្បីបុព្វហេតុសន្តិភាព។ ឥឡូវនេះ ប្រទេសកម្ពុជាបានឯាកមករកគន្លងដ៏ត្រឹមត្រូវ ដើម្បីទទួលបានភាពជាប្រទេសនាំមុខគេមួយក្នុងចំណោមសហគមន៍ប្រជាជាតិ។

ប្រវត្តិសាស្ត្រថ្មីៗនៃសេដ្ឋកិច្ចកម្ពុជាចែកចេញជាដំណាក់កាលបីសំខាន់ៗគឺៈ ទីមួយ ដំណាក់កាលស្ដារឡើងវិញ ពីឆ្នាំ១៩៧៩-១៩៩០ ទីពីរ ដំណាក់កាលអន្តរកាល និងការស្ដាបនាឡើងវិញ ពីឆ្នាំ១៩៩១-១៩៩៨ និងទីបី ដំណាក់កាលអភិវឌ្ឍចាប់ផ្ដើមពីឆ្នាំ១៩៩៩។ សេដ្ឋកិច្ចកម្ពុជាកើនឡើងជាលំដាប់ក្នុងដំណាក់ទាំងបីនេះ។

ជាក់ស្ដែងប្រទេសកម្ពុជា ត្រូវចាប់ផ្ដើមកសាងប្រទេសពីបាតដៃទទេ បន្ទាប់ពីការបរាជ័យនៃរបបខ្មែរក្រហមរួចមក។ ពីដំបូង ប្រទេសកម្ពុជាត្រូវប្រឈមនឹងផលវិបាកនៃការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ចក្នុងឆ្នាំ១៩៧៩។ អត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំកើនឡើងមិនលើស ៣.៤% ក្នុង១៩៨៨-១៩៩១ ទោះបីជាកំណើនមធ្យមប្រចាំឆ្នាំក្នុងវិស័យរោងចក្រកើនឡើងដល់ ៦.៣% យ៉ាងណាក៏ដោយ។

ចាប់តាំងពីដើមទសវត្សរ៍ទី៩០មក សេដ្ឋកិច្ចមានកំណើនខ្លាំង ជាពិសេសជាមួយនឹងការអនុវត្តកំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ច និងធម្មនីយកម្មសេដ្ឋកិច្ច និងទំនាក់ទំនងពាណិជ្ជកម្ម ជាមួយបណ្ដាប្រទេសក្នុងតំបន់។ ក្នុងឆ្នាំ១៩៩៤-១៩៩៨ កម្ពុជាសម្រេចបានអត្រាមធ្យមប្រចាំឆ្នាំ ៦.៣% ទោះបីជាមានការជ្រួលច្របល់ខ្លាំងដែលបណ្ដាលមកពីវិបត្តិហិរញ្ញវត្ថុនៅអាស៊ីនៅឆ្នាំ ១៩៩៧-១៩៩៨ យ៉ាងណាក្ដី។

ចាប់តាំងពីឆ្នាំ១៩៩៩ ប្រទេសកម្ពុជាបាននិងកំពុងបន្តដំណើរឆ្ពោះទៅពន្លឿនការអភិវឌ្ឍ។ ក្នុងឆ្នាំ១៩៩៩ កំណើនមានរហូតដល់១១.៩% ប៉ុន្តែធ្លាក់ចុះមក៦.៦% វិញក្នុងឆ្នាំ២០០២។ ទោះជាយ៉ាងនេះក្ដី អត្រាកំណើនជាមធ្យមប្រចាំឆ្នាំសម្រាប់រយៈពេលប្រាំឆ្នាំពីឆ្នាំ១៩៩៩-២០០៣គឺស្មើនឹង ៨.៨%។ កំណើននេះបានមកពីវិស័យដែលមានសន្ទុះខ្លាំងចំនួនពីរៈ កាត់ដេរ និងទេសចរណ៍។ ទោះបីជាមានតួលេខនេះក៏ដោយក៏នៅឆ្នាំ២០០៥មានបញ្ហាចោទមួយចំនួន ទាក់ទងនឹងសមត្ថភាពរបស់កម្ពុជា ដើម្បីរក្សាឱ្យបាននូវចីរភាពនៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំណើនខ្ពស់ ស្របពេលដែលខ្លួនខ្វះភាពប្រកួតប្រជែង។ កិច្ចព្រមព្រៀងស្ដីពីវាយនភ័ណ្ឌ និងសម្លៀកបំពាក់បានអស់សុពលភាពក្នុងខែធ្នូ ឆ្នាំ២០០៤។ ប្រការនេះអនុញ្ញាតឱ្យប្រទេសសមាជិកអង្គការពាណិជ្ជកម្មពិភពលោកពិសេសប្រទេសចិន នាំចេញសម្លៀកបំពាក់ទៅពិភពលោកដោយពុំមានការកំណត់កូតាអ្វីនោះទេ។ គេបានប៉ាន់ប្រមាណឃើញថា នៅពេលដែលរោងចក្រវាយនភ័ណ្ឌធំៗដែលមានប្រសិទ្ធភាពខ្ពស់មានលទ្ធភាពនៅបន្តដំណើរការបាន ក្នុងស្ថានភាពប្រកួតប្រជែងកម្រិតពិភពលោកដូច្នេះ រោងចក្រតូចៗអាចនឹងបិទទ្វារអស់ត្បិតពួកគេមិនអាចប្រកួតប្រជែងនឹងគេបាន។

ពីដើមទសវត្សរ៍ទី៨០រហូតដល់ឆ្នាំ១៩៩១ សេដ្ឋកិច្ចកម្ពុជាត្រូវបានរៀបចំបែបលក្ខណៈប្រមូលផ្តុំ ប៉ុន្តែអនិយតកម្មសេដ្ឋកិច្ចត្រូវបានចាប់ផ្ដើមអនុវត្តចាប់តាំងពីឆ្នាំ១៩៩២មក។ ក្នុងអំឡុងទសវត្សរ៍ទី៩០ប្រទេសកម្ពុជាបានឆ្លងកាត់ដំណាក់កាលផ្លាស់ប្ដូរពីសេដ្ឋកិច្ចផែនការទៅសេដ្ឋកិច្ចទីផ្សារ។ កំណែទម្រង់និងគោលនយោបាយ សម្រាប់ជំរុញការអភិវឌ្ឍវិស័យឯកជន ដែលបានអនុម័តក្នុងឆ្នាំ១៩៨៩ និង១៩៩០ បានបើកទូលាយសេដ្ឋកិច្ច តាមរយៈការរំលាយចោលការត្រួតពិនិត្យតម្លៃ និងជំរុញការអភិវឌ្ឍវិស័យឯកជន រួមទាំងការវិនិយោគក្រៅប្រទេស។ ក្នុងរយៈពេលនេះកំណើនបានមកជាពិសេសពីវិស័យផលិតកម្មនិងសេវា។ ជាមធ្យម កំណើនផលិតកម្មកសិកម្មសម្រេចបានទាបជាងកំណើនប្រជាជន។

ក្នុងឆ្នាំ១៩៩៣-១៩៩៨រាជរដ្ឋាភិបាលកម្ពុជា នៅពុំទាន់អាចនាំមកនូវលក្ខខណ្ឌនយោបាយ និងសន្តិសុខ ដែលចាំបាច់សម្រាប់ឱ្យមានរដ្ឋាភិបាលបង្រួបបង្រួមនិងមានស្ថេរភាពមួយនៅឡើយទេ។ កម្លាំងយោធាខ្មែរក្រហមនៅតែជាកម្លាំងសំខាន់មួយ ដែលជាការគំរាមកំហែងយ៉ាងខ្លាំងមួយដល់សន្តិសុខរបស់ប្រទេស ចំណែកឯរចនាសម្ព័ន្ធសង្គមរបស់ប្រទេសនៅមានភាពផុយស្រួយនៅឡើយ។ លើសពីនេះទៅទៀត ទោះបីជារដ្ឋាភិបាលខិតខំយ៉ាងណាក៏ដោយ ក៏កំណើនមានតិចតួចប៉ុណ្ណោះក្នុងឆ្នាំ១៩៩៧-១៩៩៨ ដោយសារតែព្រឹត្តិការណ៍នយោបាយ និងវិបត្តិហិរញ្ញវត្ថុអាស៊ី។

ក្រោយពីអនុវត្តគោលនយោបាយ"**ឈ្នះ-ឈ្នះ**" ដែលដាក់ចេញដោយសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានដោយជោគជ័យក្នុងឆ្នាំ១៩៩៨រួចមក រាជរដ្ឋាភិបាលកម្ពុជាអាចរំលាយចោលអង្គការចាត់តាំងយោធា និងនយោបាយរបស់ខ្មែរក្រហម និងនាំមកនូវការស្ដារបនាជាតិឡើងវិញ សុខសន្តិភាពទូទាំងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសមាហរណកម្មទឹកដី និងការបង្រួបបង្រួមជាតិទាំងមូល។ រាជរដ្ឋាភិបាលអាចបោះជំហានជំហានទៅមុខយ៉ាងស្វាហាប់ ក្នុងស្មារតីផ្សះផ្សានិងបង្រួបបង្រួមជាតិ។ ការបោះឆ្នោតនៅឆ្នាំ១៩៩៨ បានបង្កើតនូវលក្ខខណ្ឌចាំបាច់នានាសម្រាប់បង្កើតបានឡើងវិញនូវស្ថេរភាពនយោបាយនៅក្នុងប្រទេស និងអាចឱ្យរាជរដ្ឋាភិបាលផ្តោតលើការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច។

ក្រោយការបោះឆ្នោតនៅខែកក្កដាឆ្នាំ១៩៩៨រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយុទ្ធសាស្ត្រត្រីកោណដែលមានទិសដៅជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។ មុំទីមួយនៃ "**យុទ្ធសាស្ត្រត្រីកោណ**" គឺការនាំមកនូវសុខសន្តិភាពនិងស្ថេរភាព និងការរក្សាបាននូវសន្តិសុខសម្រាប់ប្រទេសនិងប្រជាជនទាំងមូលដែលរាជរដ្ឋាភិបាលសម្រេចបានប្រកបដោយជោគជ័យ។ មុំទីពីរនៃ"**យុទ្ធសាស្ត្រត្រីកោណ**" ដែលផ្តោតលើសមាហរណកម្មប្រទេសកម្ពុជាចូលក្នុងតំបន់ និងធម្មនីយកម្មនៃទំនាក់ទំនងរបស់ខ្លួនជាមួយសហគមន៍អន្តរជាតិក៏បានសម្រេចដោយជោគជ័យផងដែរ។ ប្រទេសកម្ពុជាបានទទួលអាសនៈរបស់ខ្លួននៅឯអង្គការសហ

ប្រជាជាតិមកវិញ ដែលអាសនៈនេះបានបាត់បង់កាលពីក្រោយការប្រឈមគ្នាខាងប្រដាប់អាវុធនៅ ខែកក្កដា ឆ្នាំ១៩៩៧ ហើយកម្ពុជាបានក្លាយជាសមាជិកទីដប់នៃសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។ កម្ពុជាបានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកនៅខែតុលាឆ្នាំ២០០៤។ មុំទីបីនៃ"**យុទ្ធសាស្ត្រត្រកោណ**" គឺការជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ច តាមរយៈកម្មវិធីកំណែទម្រង់ស៊ីជម្រៅ ដូចជាកំណែទម្រង់មុខងារសាធារណៈ វិមជ្ឈការនិងវិសហមជ្ឈការ ការរំសាយកងកម្លាំងប្រដាប់អាវុធ កំណែទម្រង់ច្បាប់និងតុលាការ សមភាពយេនឌ័រ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការលុបបំបាត់អំពើពុករលួយ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។ ជារួម **យុទ្ធសាស្ត្រត្រកោណ** ត្រូវបានអនុវត្តដោយជោគជ័យដូចឃើញមានក្នុងកំណើនខ្ពស់ និងការវិនិយោគកើនឡើង ការគ្រប់គ្រងបានប្រសើរជាងមុនខាងគោលនយោបាយរូបិយវត្ថុនិងសារពើពន្ធ ដែលជាលទ្ធផល នាំឱ្យមានអតិផរណាទាប ទុនបម្រុងខ្ពស់ អត្រាប្តូរប្រាក់មានស្ថេរភាព លំហូរចូលនៃការផ្ទេររូបិយវត្ថុបរទេសនិងមូលធនឯកជនច្រើនជាងមុន និងការអភិវឌ្ឍវិស័យឯកជនបានលឿន។

ប៉ុន្តែ ប្រទេសកម្ពុជាបានដើរដល់ចំណុចផ្លូវប្រសព្វមួយ នៅចុងអាណត្តិនយោបាយទីពីររបស់រាជរដ្ឋាភិបាលនៅឆ្នាំ២០០៣។ ក្រោយការបោះឆ្នោតឆ្នាំ២០០៣ប្រទេសកម្ពុជាពិតជាចង់ធ្វើដំណើរឱ្យបានលឿនលើវិថីនៃទំនើបភាវូបនីយកម្ម។ នៅពេលចាប់ផ្តើមពិធីបើកកិច្ចប្រជុំគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានដាក់ចេញនូវ "***យុទ្ធសាស្ត្រចតុកោណ*** *ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា*"។ ចំណុចស្នូលនៃយុទ្ធសាស្ត្រនេះគឺអភិបាលកិច្ចល្អ។ ជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រនេះ គឺអាស្រ័យលើការបង្កើតនូវបរិយាកាសអំណោយផលមួយក្នុងផ្នែកសំខាន់ៗទាំងបួនៈ (១) សន្តិភាព ស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម (២) ភាពជាដៃគូសម្រាប់ការអភិវឌ្ឍជាពិសេសភាពជាដៃគូជាមួយវិស័យឯកជន សហគមន៍ម្ចាស់ជំនួយ និងសង្គមស៊ីវិល (៣) ស្ថេរភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិង (៤) សមាហរណកម្មកម្ពុជាចូលទៅក្នុងតំបន់ និងពិភពលោក។ មុំទាំងបួននៃចតុកោណដែលផ្តោតលើកំណែទម្រង់មានៈ (១) ការលុបបំបាត់អំពើពុករលួយ (២) កំណែទម្រង់ច្បាប់ និងតុលាការ (៣) កំណែទម្រង់រដ្ឋបាលសាធារណៈរួមទាំងវិមជ្ឈការ និងសហវិមជ្ឈការ និង (៤) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ជាពិសេសការកាត់រំសាយទ័ព។ ចុងក្រោយ មុំទាំងបួននៃចតុកោណសម្រាប់ការបង្កើតកំណើនគឺៈ (១) ការជំរុញវិស័យកសិកម្ម (២) ការអភិវឌ្ឍវិស័យឯកជន និងការបង្កើតការងារ (៣) ការស្តារនីតិសម្បទា និងការស្ថាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និង (៤) ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។

កម្ពុជាត្រូវតែបង្ហាញឱ្យឃើញថា ខ្លួនពិតជាអាចមានលទ្ធភាពធ្វើកំណែទម្រង់បាន។ កម្ពុជាបានប្តេជ្ញាចិត្តធ្វើកំណែទម្រង់វិមជ្ឈការបានយ៉ាងច្រើនហើយ។ កំណែទម្រង់ទាំងនេះត្រូវបានអនុវត្ត ដើម្បីធ្វើឱ្យប្រជាជនកម្ពុជាអាចរស់នៅក្នុងសង្គមទំនើបមួយ ដែលមានភាពជាទីគាប់ចិត្តជាមូលដ្ឋាន។ រាជរដ្ឋាភិបាលកំពុងដំណើរការកែទម្រង់វិស័យអប់រំ និងសុខាភិបាល ដើម្បីធានាយុត្តិធម៌សង្គម និងកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជាគ្រប់រូប។ កំណែទម្រង់ទាំងនេះមានភាពចាំបាច់ដើម្បីធ្វើឱ្យសង្គមកម្ពុជាអាចប្រឈមមុខនឹងអនាគតបានដោយភាពជឿជាក់។

កម្ពុជាមិនត្រឹមតែត្រូវជម្នះឧបសគ្គដែលរារាំងដល់កំណើន តាមរយៈដំណើរការកែទម្រង់ប៉ុណ្ណោះនោះទេ ប៉ុន្តែត្រូវបង្កើតលក្ខខណ្ឌសម្រាប់កំណើនប្រកបដោយចីរភាព តាមរយៈការបែងចែកការខាតបង់និងផលប្រយោជន៍អភិវឌ្ឍន៍ដោយសមធម៌ផងដែរ។ សម្រាប់ថ្លៃចំណាយដំបូងនៃកិច្ចការជំនួញចំណាយដែល

ដាក់បន្ទុកលើផ្នែកការងារនឹងត្រូវបានកាត់បន្ថយ។ កម្ពុជាត្រូវតែរៀបចំផែនការយុទ្ធសាស្ត្រឱ្យបានប្រយ័ត្នប្រយែង និងច្បាស់លាស់ និងអនុវត្តវា ដើម្បីបង្កើនភាពទាក់ទាញរបស់ខ្លួនជាទិសដៅវិនិយោគមួយ។

ស្ថេរភាព និងវិបុលភាព ពឹងផ្អែកលើលទ្ធភាពរបស់ប្រជាជនកម្ពុជា ក្នុងការពង្រឹងអភិបាលកិច្ចល្អ។ ការជំរុញតម្លាភាព សមធម៌ ប្រសិទ្ធផល និងគណនេយ្យភាព ដំបូងតម្រូវឱ្យមានការធ្វើបច្ចុប្បន្នភាពនៃរបៀបវារៈរដ្ឋាភិបាលខាងផ្នែកសេរីភាវូបនីយកម្ម សាកលភាវូបនីយកម្មនិងការកសាងភាពជាដៃគូនៅក្នុងកម្រិតជាតិ និងអន្តរជាតិ។

របៀបវារៈដើម្បីសម្រេចបាននូវកំណើននៅក្នុងប្រទេសកម្ពុជា មានកំណាត់ច្បាស់រួចហើយ ក្នុង **យុទ្ធសាស្ត្រចតុកោណ**។ ប៉ុន្តែ បញ្ហាប្រឈមរបស់យើង គឺធ្វើយ៉ាងណាឱ្យកំណើនសេដ្ឋកិច្ច ក្លាយទៅជាដំណើរការមួយ ដែលបង្កើតនូវលក្ខខណ្ឌអនុគ្រោះសម្រាប់ប្រជាជនក្រីក្រ។

ការកាត់បន្ថយភាពក្រីក្រតម្រូវឱ្យមានវិធានការសមស្របទាំងឡាយ ដូចជា៖ (ក) គោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលនឹងបង្កើនប្រាក់ចំណូលក្នុងមធ្យោបាយដែលមានសមធម៌ និងប្រាក់ចំណូលតាមរយៈការចំណាយសាធារណៈដែលផ្តោតទៅលើអ្នកក្រ (ខ) ការថែរក្សានូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង (គ) ការបង្កើត និងអនុវត្តគោលនយោបាយសមស្របសម្រាប់វិស័យនីមួយៗ រួមទាំងការបង្កើនការវិនិយោគក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ ការដោះស្រាយបញ្ហាយេនឌ័រ ការអភិវឌ្ឍរបស់ជនជាតិដើមភាគតិច កំណែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព និងកិច្ចការពារបរិស្ថាន។

នៅពេលដែលក្រុមប្រឹក្សាឃុំអាចឈានទៅកំណត់បាន និងរកដំណោះស្រាយ ពាក់ព័ន្ធនឹងបុព្វហេតុនៃភាពក្រីក្រនៅកម្រិតមូលដ្ឋាន ការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាពមួយបានតម្រូវឱ្យមានកំណើននៃវិនិយោគក្នុងផ្នែកសេដ្ឋកិច្ច។ យុទ្ធសាស្ត្រអភិវឌ្ឍត្រូវតែផ្តល់អាទិភាពខ្ពស់ ដល់ការទាក់ទាញការវិនិយោគទុនពីក្រៅប្រទេស ដោយបង្កើតនិងរក្សាឱ្យបាននូវបរិយាកាសអំណោយផលមួយ។ កម្ពុជាបានចាត់វិធានការជាច្រើនសម្រាប់ការកែលម្អបរិយាកាសវិនិយោគ ប៉ុន្តែខ្លួនគប្បីជានាថា រចនាសម្ព័ន្ធលើកទឹកចិត្តរបស់ខ្លួន មានលក្ខណៈប្រកួតប្រជែងជាមួយប្រទេសជិតខាង និងអ្នកប្រកួតក្នុងតំបន់។

រាជរដ្ឋាភិបាលកម្ពុជា កំពុងអនុវត្តយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពមួយ ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ជាពិសេសផ្លូវថ្នល់និងស្ពាន ដែលជាមូលដ្ឋានគ្រឹះសំខាន់នៃសេដ្ឋកិច្ចជាតិ សម្រាប់បង្កើតបណ្តាញផ្លូវថ្នល់លាតសន្ធឹងពេញផ្ទៃប្រទេស ដែលអាចឱ្យកម្ពុជាជំរុញសកម្មភាពសេដ្ឋកិច្ច និងទេសចរណ៍ សម្របសម្រួលចរាចរទំនិញ និងសេវា លើកស្ទួយការវិនិយោគក្នុងស្រុក និងពីក្រៅប្រទេស និងពង្រីកសក្តានុពលនៃសេដ្ឋកិច្ចជនបទ ការកាត់បន្ថយថ្លៃដឹកជញ្ជូន នឹងជំរុញការវិនិយោគពាណិជ្ជកម្មឯកជន និងការបង្កើតការងារសម្រាប់ជនជាតិកម្ពុជា។

ប្រទេសកម្ពុជាបានបោះជំហានយ៉ាងវែងក្នុងការអភិវឌ្ឍក្នុងទសវត្សរ៍កន្លងទៅនេះ។ ជាពិសេសដោយអនុវត្តនូវ **យុទ្ធសាស្ត្រចតុកោណ** ក្នុងអាណត្តិទីពីររបស់រាជរដ្ឋាភិបាល សង្គមកម្ពុជាបានផ្លាស់ប្តូរមុខមាត់ គួរឱ្យកត់សម្គាល់យ៉ាងខ្លាំង។ ក៏ប៉ុន្តែ នៅក្នុងគ្រប់ដំណាក់កាលនៃការឈានទៅសម្រេចបាននូវការអភិវឌ្ឍនេះ គឺតែងតែមានបញ្ហាប្រឈមថ្មីៗជាច្រើន។ សមិទ្ធផលនៃសេដ្ឋកិច្ចកម្ពុជាបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងចាប់តាំងពីឆ្នាំ២០០៨ ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រាជរដ្ឋាភិបាលបានចាត់វិធានការភ្លាមៗ ដើម្បីទប់ទល់នឹងផលប៉ះពាល់សង្គមនៃការថយចុះនៃប្រាក់ចំណូល និងការងារពីការធ្លាក់ចុះនៃការនាំចេញផ្នែកកាត់ដេរ ទេសចរណ៍ និងសំណង់ដោយសារវិបត្តិនេះ។ ជាលទ្ធផល សេដ្ឋកិច្ចកម្ពុជាដែលសម្រេចបាននូវកំណើនសូន្យភាគរយនៅក្នុងឆ្នាំ ២០០៩ បានងើបរួចពីវិបត្តិនេះនៅក្នុងឆ្នាំ ២០១០ ដោយសម្រេចបាននូវកំណើនចំនួន ៦ ភាគរយ ហើយក្នុងឆ្នាំជាបន្តបន្ទាប់ កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម ៧ ភាគរយ។

សម្រាប់រយៈពេលយូរអង្វែង កំណែទម្រង់សេដ្ឋកិច្ចត្រូវតែបង្កើនសន្ទុះនៃកំណើនសេដ្ឋកិច្ច និងធ្វើយ៉ាងណា ដើម្បីអោយសេដ្ឋកិច្ចកម្ពុជាមានភាពធន់ជាងមុន ដើម្បីទប់ទល់នឹងវិបត្តិសេដ្ឋកិច្ច ដែលអាចនឹងនឹងបណ្តាលមកពីប្រភពទាំងក្នុង និងក្រៅប្រទេស។ ប្រទេសកម្ពុជាត្រូវតែបន្តកសាងគ្រឹះដ៏រឹងមាំ ក្នុងការសម្រេចបាននូវវឌ្ឍនភាពថ្មីៗទៀត សំដៅកែលម្អនូវជីវភាពរស់នៅរបស់ប្រជាជន។ យើងទាំងអស់គ្នាដឹងហើយថា កំណាត់ផ្លូវដែលយើងត្រូវធ្វើដំណើរនៅវែងឆ្ងាយនៅឡើយ ហើយគ្មានអ្នកណាម្នាក់ដឹងរឿងនេះច្បាស់ជាងប្រជាជនកម្ពុជាយើងនោះឡើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី១
# ភូមិសាស្ត្រនិងប្រជាជន

ជំពូក១៖ ភូមិសាស្ត្រ

ជំពូក២៖ ប្រជាករនិងរចនាសម្ព័ន្ធប្រជាសាស្ត្រ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី១
# ភូមិសាស្ត្រនៃប្រទេសកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាស្ថិតនៅក្នុងអាស៊ីភាគអាគ្នេយ៍នៅចន្លោះខ្សែស្របទី ១០ និងទី ១៥ នៃរយៈទទឹងខាងជើង និងចន្លោះខ្សែបណ្តោយទី ១០២ និងទី ១០៨ នៃរយៈបណ្តោយខាងកើតដែលស្ថិតក្រោមឥទ្ធិពលខ្យល់មូសុង ។ កម្ពុជាមានផ្ទៃក្រឡាចំនួន ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា និងមានរាងជាពហុកោណដែលមានចំណុចកណ្តាលស្ថិតនៅត្រង់ខេត្តកំពង់ធំ។ កម្ពុជាមានព្រំប្រទល់ខាងជើងជាប់នឹងព្រះរាជាណាចក្រថៃឡង់ និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ខាងកើតជាប់នឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងត្បូងជាប់នឹងសាធារណរដ្ឋសង្គមនិយមវៀតណាមនិងឈូងសមុទ្រថៃ និងខាងលិចជាប់នឹងព្រះរាជាណាចក្រថៃឡង់។ កម្ពុជាមានព្រំដែនប្រវែង ២ ៦០០ គីឡូម៉ែត្រ ដែលក្នុងនោះប្រាំភាគប្រាំមួយ គឺជាព្រំដែនគោក ។




## ១.១. សណ្ឋានដី

សណ្ឋានដីនៃព្រះរាជាណាចក្រកម្ពុជាមានផ្ទៃផតកណ្តាលដែលមានជាយជុំវិញជាភ្នំជាកូនភ្នំ និងជាខ្ពង់រាប។ ផ្ទៃដីនេះចុះទេរពីភ្នំក្រវាញសំដៅទៅឈូងសមុទ្រថៃ ។ កម្ពុជាសម្បូណ៌ទំនាប និងខ្ពង់រាប ដោយមានរយៈកម្ពស់ទូទៅទាប។ ជារួម យើងអាចបែងចែកសណ្ឋានដីនេះជាភូមិភាគធម្មជាតិធំៗ ចំនួនប្រាំគឺ៖ ជួរភ្នំក្រវាញ តំបន់កូនភ្នំ តំបន់ទំនាបកណ្តាល ភូមិភាគខ្ពស់ខាងជើង និងតំបន់ខ្ពង់រាប ។

### ១.១.១. ជួរភ្នំក្រវាញ

ប្រជុំភ្នំក្រវាញស្ថិតនៅបរិវេណខាងលិចសណ្ដកពីអាគ្នេយ៍ទៅពាយ័ព្យដែលជាព្រំខ័ណ្ឌមួយផ្នែករវាងតំបន់មាត់សមុទ្រ និង ទំនាបកណ្ដាល។ ប្រជុំភ្នំនេះមានទិសស្របនឹងមាត់ឆ្នេរចាប់ពីខេត្តប៉ៃលិន មកទល់នឹងខេត្តកំពត ។ តំបន់នេះគឺជាខ្ពង់រាបដែលមានជួរភ្នំយ៉ាងវែង និងមានច្រាំងយ៉ាងចោតហើយកំពូលភ្នំខ្ពស់បំផុត គឺជាភ្នំឱរ៉ាល់ ដែលជាភ្នំខ្ពស់ជាងគេនៃព្រះរាជាណាចក្រកម្ពុជាដែលមានកម្ពស់ ១ ៨១៣ ម៉ែត្រ។ ប្រជុំភ្នំក្រវាញ គឺជាព្រៃក្រាស់ជាងគេនៅអាស៊ីភាគអាគ្នេយ៍យើងនេះ ។

### ១.១.២. តំបន់កូនភ្នំ

តំបន់កូនភ្នំគឺជាតំបន់ជុំវិញជួរភ្នំក្រវាញ។ តំបន់កូនភ្នំនេះបង្កើតបានជាខ្សែក្រវាត់ព័ទ្ធជុំវិញភ្នំក្រវាញដែលកូនភ្នំសំខាន់ៗមានដូចតទៅះ

- នៅក្នុងខេត្តបាត់ដំបងមានភ្នំរន្ធា ជាភ្នំក្រៃនិង ស៊ីស ភ្នំសំពៅ ភ្នំសិរីសោភ័ណជាភ្នំថ្មកំបោរ និងភ្នំវែង។
- នៅក្នុងខេត្តពោធិ៍សាត់និងកំពង់ឆ្នាំង មានកូនភ្នំកម្រែង ដែលជាភ្នំថ្មភក់ភ្នំក្រាំងល្វា ដែលជាភ្នំថ្មភ្នំភ្លើង។
- នៅក្នុងខេត្តកំពង់ស្ពឺមានភ្នំជម្រាយ ភ្នំពិស ភ្នំក្រោល និង ភ្នំរាជាគង់។
- នៅក្នុងខេត្តតាកែវនិង ខេត្តកំពត មានភ្នំចាំងអារ (៧២២ម.) ភ្នំព្រះ(៧៨០ម.) ភ្នំទ្វារ ភ្នំកំពង់ត្រាចភ្នំល្អាង ជាភ្នំថ្មកំបោរ ភ្នំនៅស្រុកទន្លេបាទីជាភ្នំថ្មភក់ ។
- នៅក្នុងខេត្តព្រះសីហនុមានកូនភ្នំជំនាប កូនភ្នំវាលរេញ។

ភ្នំដែលស្ថិតនៅក្នុងតំបន់កូនភ្នំនេះមានកម្ពស់មិនលើសពី ៨០០ម៉ែត្រឡើយ ។

### ១.១.៣. តំបន់ទំនាបកណ្ដាល

តំបន់ទំនាបកណ្ដាលគឺជាភូមិភាគល្បាប់ ដែលមានទទឹងប្រវែង១១០គ.ម. និងមានបណ្ដោយប្រវែង៥០០គ.ម. លាតសន្ធឹងពីព្រំប្រទល់ថៃដល់ប្រទេសវៀតណាម ។ បឹងទន្លេសាបស្ថិតនៅចំបេះដូងនៃតំបន់ទំនាបកណ្ដាលនេះ ហើយទន្លេមេគង្គពុះច្រៀកតំបន់នេះ ដោយដៃទន្លេមេគង្គគឺជាសរសៃឈាមដែលចិញ្ចឹមសរីរាង្គនៃតំបន់ទំនាបកណ្ដាលនេះ ។ ប្រជាជនកម្ពុជាប្រមាណជា៦លាននាក់រស់នៅក្នុងតំបន់ទំនាបកណ្ដាលនេះ ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេ ហើយសកម្មភាពសេដ្ឋកិច្ចទៀតសោតក៏មានសភាពផុលផុសជាងតំបន់ឯទៀតនៃព្រះរាជាណាចក្រកម្ពុជា។ តំបន់ទំនាបកណ្ដាលនេះចែកចេញជាបីផ្នែកះ

- តំបន់ដែលនៅជាប់មាត់ទន្លេ មាត់បឹង និងឆ្នេរកោះដែលមានទទឹងពី១០ម៉ែត្រទៅរាប់រយម៉ែត្រ។ ដីនៅទីនេះជាដីល្បប់ស្អិតដែលមានជីជាតិណាស់ ។
- តំបន់ដែលនៅជាប់តំបន់ខាងលើដែលជាព្រៃលិចទឹកនៅក្នុងរដូវវស្សាជាវាលភក់ និងជាតំបន់ដែលសម្បូណ៌កូនបឹង និងស្ទឹង ។
- តំបន់វាលស្រែដែលលាតសន្ធឹងល្វាល្វើរដាច់កន្ទុយភ្នែកដែលមានកូនភ្នំមួយៗ នៅលាយឡំអមដោយព្រៃរបោះ និងព្រៃក្រាស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.១.៤. ភូមិភាគខ្ពស់ខាងជើង

ភូមិភាគខ្ពស់ខាងជើង គឺជាខ្ពង់រាបដែលជាមធ្យមមានកម្ពស់១៥០ម. លាតសន្ធឹងពីភាគខាងជើងទៅដល់ភាគឦសានដែលងើបបន្តិចម្តងៗពីទំនាបកណ្តាលឆ្ពោះទៅកាន់ព្រំប្រទល់ថៃ ឡាវ និងវៀតណាម។ តំបន់នេះមានដីប្រកបដោយល្បប់ចាស់លាយឡំជាមួយថ្មបាយក្រៀម។ នៅក្នុងខេត្តកំពង់ចាមដីមានស្រទាប់ថ្មបាសាល់ ឬថ្មភ្នំភ្លើង ដែលមានផ្ទៃកខាងលើរលាយជាដីក្រហមមានជីជាតិល្អសម្រាប់ដំណាំកៅស៊ូ។

### ១.១.៥. តំបន់ខ្ពង់រាប

តំបន់ខ្ពង់រាប គឺជាតំបន់បន្តនៃខ្ពង់រាបនិងជួរភ្នំនៃប្រទេសជិតខាងដូចជាតំបន់ខ្ពង់រាបនៅក្នុងខេត្តរតនគិរី ដែលជាជាយនៃខ្ពង់រាបកន្ទង់នៃប្រទេសវៀតណាម។ ខ្ពង់រាបឆ្លងលើ គឺជាផ្នែកមួយនៃជួរភ្នំអាណាមផ្នែកខាងត្បូង ។

## ១.២. ជលធារាសាស្ត្រ

ជលធារាសាស្ត្រមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៃព្រះរាជាណាចក្រកម្ពុជា។ ផ្លូវទឹកកម្ពុជាត្រូវបានបែងចែកជាអាងទន្លេបីធំៗ៖

### ១.២.១. អាងទន្លេមេគង្គ

អាងទន្លេមេគង្គមានសារៈសំខាន់ណាស់សម្រាប់សេដ្ឋកិច្ចកម្ពុជា។ ទន្លេមេគង្គ គឺជាទន្លេមួយក្នុងចំណោមទន្លេដែលវែងជាងគេក្នុងពិភពលោកគឺមានប្រវែង ៤.២០០គ.ម.។ ទន្លេមេគង្គហូរកាត់ប្រទេសចិន (ខេត្តគុនមីង) ថៃឡង់ ភូមា ឡាវ កម្ពុជា និង វៀតណាម។ ទន្លេមេគង្គហូរកាត់កម្ពុជាតាមបណ្តោយមានប្រវែង ៥០០គ.ម.។ ទន្លេមេគង្គ គឺជាផ្លូវគមនាគមន៍យ៉ាងសំខាន់បំផុតដែលអាចចរាចរបានគ្រប់កាលគ្រប់រដូវទាំងអស់។ នៅរដូវទឹកជំនន់ទន្លេមេគង្គហូរនាំដីល្បប់ដែលមានជីជាតិស្រោចស្រពដីស្រែរបស់ប្រជាកសិករនិងហូរចាក់បំពេញព្រៃលិចទឹកដែលជាទីកន្លែងសម្រាប់មច្ឆាជាតិភ្ញាស់ពង និងចិញ្ចឹមកូនត្រីឱ្យតពូជ។ ក្នុងន័យនេះ វិស័យកសិកម្ម និងការនេសាទនៅកម្ពុជាអាស្រ័យលើកម្រិតនៃទឹកជំនន់ទន្លេមេគង្គតែម្តង ។ ជាធម្មតាមួយឆ្នាំក្រោយពីមានទឹកជំនន់គេសង្កេតឃើញថាទិន្នផលនេសាទនឹងកើនឡើងយ៉ាងខ្លាំង។ ម្យ៉ាងវិញទៀត ទន្លេមេគង្គ ដៃទន្លេមេគង្គ និងព្រែកទាំងឡាយ គឺជាសរសៃឈាមតូចធំដែលចិញ្ចឹមសរីរាង្គនៃផ្ទៃប្រទេសកម្ពុជាឱ្យរីកធំធាត់ជាលំដាប់ ។

### ១.២.២. អាងទន្លេសាប

អាងទន្លេសាបដើរតួនាទីជាទីប្រជុំផ្លូវទឹកនិងជាជង្រុកត្រីដែលជាប្រភពយ៉ាងសំខាន់នៃជីវជាតិប្រូតេអ៊ីនសម្រាប់ប្រជាជនកម្ពុជា។ បឹងទន្លេសាបគឺជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជាដែលស្ថិតនៅត្រង់ចំណុចប្រសព្វរវាងខេត្តចំនួនប្រាំមួយគឺ៖ កំពង់ធំ សៀមរាប បាត់ដំបង បន្ទាយមានជ័យ ពោធិ៍សាត់ និង កំពង់ឆ្នាំង ។ បឹងទន្លេសាបគឺជាប្រភពនៃវិបុលភាពនៅកម្ពុជាដោយសារ កសិកម្ម ការនេសាទត្រី ព្រៃឈើ ពាណិជ្ជកម្ម ផ្លូវគមនាគមន៍ និងជីវភាពរបស់គ្រួសារកម្ពុជាពឹងផ្អែកជាសំខាន់លើចរន្តទឹកហូរចូល និងហូរចេញពីបឹងទន្លេសាបនេះ។ បឹងទន្លេសាបគឺជាប្រភពដែលមិនចេះរីងស្ងួតនៃត្រីទឹកសាបដ៏មានតម្លៃនៅ

អាស៊ីអាគ្នេយ៍ទាំងមូលតែម្តង។ អាងទន្លេសាប និងអាងទន្លេមេគង្គរួមគ្នាបង្កើតបានជាប្រព័ន្ធនាវាចរប្រកប ដោយប្រសិទ្ធភាពដើម្បីសម្រួលដល់ការដឹកជញ្ជូនផ្លូវទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជានិង ដើរតួនាទីយ៉ាង សំខាន់ក្នុងសេដ្ឋកិច្ចជាតិ។

ប្រព័ន្ធអេកូឡូស៊ីនៃបឹងទន្លេសាបមានលក្ខណៈវិសេសវិសាលណាស់ដោយសារភាពសម្បូណ៌បែប ខាងផ្នែកជីវសាស្ត្រ និង តុល្យភាពរវាងមនុស្សនិងធម្មជាតិ ។ មួយផ្នែកនៃបឹងទន្លេសាបគឺជាប្រព័ន្ធអេកូឡូស៊ី នៃព្រៃលិចទឹកដែលបង្កបង្កើតបានជាលក្ខខណ្ឌពិសេសសម្រាប់ការករកើតឡើងវិញ និងការផ្តល់នូវចំណី អាហារដល់ប្រភេទត្រីរាប់រយមុខ ។ ម្យ៉ាងវិញទៀតបរិស្ថានបឹងទន្លេសាបដែលសម្បូណ៌ដោយត្រីទឹកសាប និង រុក្ខជាតិ បានបង្កើតឡើងនូវតុល្យភាពយ៉ាងសុខដុមរមនារវាងបក្សាបក្សី មច្ឆាជាតិ និងមនុស្ស ។

ប្រព័ន្ធទឹកបឹងទន្លេសាប និង ទន្លេមេគង្គបង្កើតបានជាបាតុភូតអច្ឆរិយដែលបង្កើតឱ្យទឹកទន្លេមេគង្គ អាចហូរចុះហូរឡើងបញ្ច្រាសទិសតាមរដូវកាលដែលមិនដែលមាននៅក្នុងពិភពលោក។

នៅដើមរដូវវស្សាក្នុងខែមិថុនាទឹកទន្លេមេគង្គចាប់ផ្តើមឡើងក្រោមឥទ្ធិពលនៃព្រិលដែលរលាយនៅ ភ្នំហេមពាន្ត និង ទឹកភ្លៀងមូសុងដែលធ្វើឱ្យប្រព័ន្ធជលធារទទួលរងនូវជំនន់យ៉ាងសន្ធឹកសន្ធាប់។ ទឹកទន្លេ មេគង្គហូរបុកចូលទន្លេសាប ហើយចាក់បំពេញបឹងទន្លេសាបជាហេតុធ្វើឱ្យកម្ពស់ទឹកនៃបឹងទន្លេសាបកើន ឡើងដល់ ៩ ម៉ែត្រហើយផ្ទៃទឹកបឹងកើនឡើងជាងប្រាំដងគ្របដណ្តប់ដីប្រមាណជា ១,២៥លានហិចតា ធ្វើឱ្យ លិចអស់ព្រៃភក់ល្បប់ និងបឹងបួព័ទ្ធជុំវិញបឹង។ បើគិតជាបរិមាណទឹកកំណើននេះស្មើនឹងបរិមាណទឹកខែ ប្រាំងគុណនឹង៧០ដង ។

នៅចុងរដូវភ្លៀងមូសុងក្នុងខែតុលាទឹកទន្លេមេគង្គចាប់ផ្តើមស្រកចុះហើយបង្កើតឱ្យមានបាតុភូត ធម្មជាតិទឹកហូរបញ្ច្រាស់ចេញពីបឹងទន្លេសាបចាក់ចូលទន្លេមេគង្គនិងហូរចូលឈូងសមុទ្រចិនខាងត្បូង។ ដូច្នេះបឹងទន្លេសាបប្រៀបបីដូចជាប្រព័ន្ធក្បាលរ៉ូប៊ីនេធម្មជាតិ ដែលគ្រប់គ្រងតាមបែបលក្ខណៈធម្មជាតិនូវ ប្រព័ន្ធជលធារ ដើម្បីកុំឱ្យទឹកជំនន់លិចតំបន់ខាងលើនៃបឹងទន្លេសាប។ នៅរដូវប្រាំងផ្ទៃទឹកបឹងទន្លេសាបគ្រប ដណ្តប់ប្រមាណតែ២.៧០០គីឡូម៉ែត្រក្រឡាប៉ុណ្ណោះហើយកម្ពស់ទឹកធ្លាក់ចុះមកនៅត្រឹម១ ទៅ ២ ម៉ែត្រ។

នៅរដូវភ្លៀងទឹកបឹងទន្លេសាបបានជន់លិចព្រៃនិងដីព័ទ្ធជុំវិញបឹង ។ ដូច្នេះហើយ ទើបគេចាត់ទុកថា ប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាបគឺជាប្រព័ន្ធអេកូឡូស៊ីនៃព្រៃលិចទឹក។ ទឹកជំនន់តាមរដូវកាលបង្កើតបាននូវ ជម្រកយ៉ាងល្អប្រណិតសម្រាប់ការបង្កបង្កើតឡើងវិញនូវពូជត្រីជាច្រើនប្រភេទដែលមានចំនួនជាង ២០០មុខ នៅបឹងទន្លេសាបនេះ។ ធនធានមច្ឆាជាតិដ៏សម្បូណ៌នេះគឺជាប្រភពនៃជាតិប្រូតេអ៊ីនសម្រាប់ប្រជាជនកម្ពុជា ប្រមាណជា ៦លាននាក់ ដែលរស់នៅក្នុងខេត្តជុំវិញបឹងទន្លេសាបនេះ។ បឹងទន្លេសាបគឺជាមជ្ឈមណ្ឌល នេសាទត្រីធំជាងគេនៅកម្ពុជានិងជាបឹងដែលមានត្រីច្រើនជាងគេក្នុងពិភពលោកបើគិតជាចំនួនត្រីក្នុងមួយ ម៉ែត្រក្រឡាដោយសារតែព្រៃលិចទឹកផ្តល់នូវចំណីដ៏សម្បូណ៌ហូរហៀរដល់ហ្វូងមច្ឆាជាតិទាំងនោះ។ម្យ៉ាងវិញ ទៀត ទឹកជំនន់បាននាំមកនូវដីល្បប់ដ៏មានជីជាតិសម្រាប់ឱ្យប្រជាកសិករប្រកបរបរកសិកម្មដាំដុះស្រូវនិង ដំណាំរួមផ្សំនានា ។ ជារួមទឹកជំនន់តាមរដូវកាលដែលហូរលិចតំបន់វាលទំនាបកណ្តាលមានសារៈសំខាន់ ខ្លាំងណាស់សម្រាប់សេដ្ឋកិច្ចកម្ពុជានិង មានឥទ្ធិពលយ៉ាងខ្លាំងក្លាលើសកម្មភាពរបស់ប្រជាជនកម្ពុជា។ ទឹក ជំនន់ដែលជន់លិចតំបន់ជុំវិញបឹងទន្លេសាបដល់ទៅ ២ លានហិចតាគឺជាកត្តាកំណត់ក្នុងការជ្រើសរើសមុខ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដំណាំនៅតាមដងទន្លេនិងនៅតាមតំបន់ព័ទ្ធជុំវិញបឹងនាំមកនូវជីជាតិ បង្កើនចំនួនត្រីនិងបង្កើននូវនាវាចរ។ ក៏ប៉ុន្តែ ទឹកជំនន់ក៏អាចបណ្តាលឱ្យមានគ្រោះមហន្តរាយដល់ជីវិត និងដំណាំរបស់ប្រជាកសិករផងដែរ។

ជលធារាសាស្ត្រអេកូឡូស៊ី និងផលិតភាពជីវសាស្ត្រនៃបឹងទន្លេសាបបង្កើតឡើងនូវប្រព័ន្ធអេកូឡូស៊ីមួយក្នុងចំណោមប្រព័ន្ធអេកូឡូស៊ីអច្ឆរិយក្នុងពិភពលោកនិងជាបឹងទឹកសាបធំជាងគេនៅអាស៊ីភាគអាគ្នេយ៍។ ដូច្នេះហើយ ទើបនៅក្នុងឆ្នាំ១៩៩៧ អង្គការដើម្បីការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌របស់សហប្រជាជាតិ បានដាក់បឹងទន្លេសាបចូលក្នុងបញ្ជីដែនបម្រុងជីវចម្រុះដែលមានសារៈសំខាន់ខាងផ្នែកអេកូឡូស៊ីសេដ្ឋកិច្ច និង វប្បធម៌។

### ១.២.៣. អាងឈូងសមុទ្រថៃ

កម្ពុជាព័ទ្ធជុំវិញដោយឆ្នេរសមុទ្រដែលមានប្រវែង៤៣៥ គ.ម. ដែលហៅថាឈូងសមុទ្រថៃ។ សមុទ្រនៅម្តុំនេះមានទឹករាក់មានបាតរាបស្មើ ហើយមានជម្រៅទឹកមធ្យមប្រមាណជា៥០ ម៉ែត្រ។ អាងឈូងសមុទ្រថៃគឺជាប្រព័ន្ធជលធារដែលមានស្ទឹងនិងទន្លេតូច និងខ្លីៗហូរចាក់ក្នុងសមុទ្រជិតម្តៃដែលបង្កើតឱ្យមាននូវរបបទឹកជោរ និង ទឹកនាច ដូចជា ស្ទឹងមេទឹកព្រែកតាតៃ ស្ទឹងថៃអាវែង ព្រែកពីផាត់ ព្រែកកំពង់សោមនិងស្ទឹងកំពតជាដើម ។ ឈូងសមុទ្រថៃគឺជាផ្លូវនាវាចរសមុទ្រដ៏មានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចកម្ពុជាដោយភ្ជាប់កម្ពុជាទៅនឹងពិភពលោកតាមផ្លូវសមុទ្រ។ កំពង់ផែស្វយ័តខេត្តព្រះសីហនុអាចឱ្យនាវាធំៗចូលចុះចតនិងចូលរួមវិភាគទានយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងពាណិជ្ជកម្ម។

## ១.៣. លក្ខណៈទូទៅនៃអាកាសធាតុ

### ១.៣.១. រដូវ

កម្ពុជាមានអាកាសធាតុមូសុងគឺក្តៅហើយសើម ក៏ប៉ុន្តែកំដៅ និងសំណើម ប្រែប្រួលតាមតំបន់និងតាមរដូវកាល ។ កម្ពុជាមានរដូវពីរគឺ ៖

- រដូវប្រាំងដែលស្ងួតហើយក្តៅ និង
- រដូវវស្សាដែលសើមហើយមានភ្លៀងច្រើន ។

លក្ខណៈពិសេសនៃអាកាសធាតុនៅកម្ពុជាគឺសីតុណ្ហភាពមានអតិបរមាពីរនៅខែមេសា និងខែសីហា និងអប្បបរមាពីរនៅខែធ្នូ និងខែកក្កដា ។ នៅភ្នំពេញសីតុណ្ហភាពមធ្យមអតិបរមាមានចំនួន៣៥ អង្សារ ហើយមធ្យមអប្បបរមាមានចំនួន២១ អង្សារ ។ អាកាសធាតុត្រជាក់មាននៅតំបន់ខ្ពង់រាបគឺខេត្តមណ្ឌលគិរី និងរតនគិរី។

របបខ្យល់មូសុងបង្កើតរបបទឹកភ្លៀងជាពិសេសបង្កើតរដូវ។ របបខ្យល់មូសុងចែកចេញជាពីរគឺៈ មូសុងប្រាំង និង មូសុងវស្សា។

មូសុងប្រាំង ចាប់ពីខែវិច្ឆិកាដល់ខែមេសាខ្យល់មូសុងបក់មកពីទិសឦសានចេញពីប្រភពស៊ីបេរី ។ ខ្យល់នេះមិននាំភ្លៀងមកទេ។ គេអាចបែងចែករដូវប្រាំងជាពីររដូវខ្លីៗទៀតគឺ *«រដូវរំហើយ»* ពីខែវិច្ឆិកាដល់ខែមករាដែលខ្យល់មូសុងប្រាំងពិតនាំមកនូវខ្យល់ត្រជាក់ពីស៊ីបេរីធ្វើឱ្យអាកាសធាតុត្រជាក់ស្រួល។ *«រដូវក្តៅ»* ពីខែកុម្ភៈ ដល់ខែមេសាដែលខ្យល់ត្រូពិចកណ្តាលទ្វីបបានបក់នាំមកនូវកម្តៅមកជាមួយផងដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មូសុងវស្សាចាប់ពីខែឧសភាដល់ខែតុលាខ្យល់មូសុងបក់មកពីទិសនិរតីនិងពីត្បូងដែលជាខ្យល់ក្តៅតែសើម ព្រោះបានបក់មកពីមហាសមុទ្រឥណ្ឌាដើម្បីសំដៅទៅស៊ីបេរីកណ្តាលវិញ។ មូសុងនេះនាំភ្លៀងមកជាមួយ។ នៅរដូវវស្សាការធ្លាក់ភ្លៀងមានលក្ខណៈអំណោយផលដល់ការដាំដុះដំណាំកសិកម្មនិងជាប្រភពនៃទឹកជំនន់ ។ ជាធម្មតា ទឹកជំនន់ចាប់ផ្តើមនៅខែកក្កដាក៏ប៉ុន្តែនៅខែកញ្ញាទឹកជំនន់មានលក្ខណៈខ្លាំងក្លានិងលិចអស់ផ្ទៃដីធំល្វឹងល្វើយ នៅពេលដែលទឹកទន្លេមេគង្គឡើងដល់កម្ពស់លើសពីធម្មតា។ ផ្ទុយទៅវិញគ្រោះរាំងស្ងួតនិងភ្លៀងធ្លាក់យឺតយ៉ាវអាចធ្វើឱ្យទិន្នផលស្រូវធ្លាក់ចុះ។ គ្រោះរាំងស្ងួតអាចបណ្តាលឱ្យមានសត្វល្អិតមកបំផ្លាញដំណាំដូចជាសត្វកណ្តូប សត្វអណ្តើកមាស សត្វកណ្តុរជាដើម ។ ប្រការនេះធ្វើឱ្យការភ្ជួររាស់ដីការសាបសំណាប និង ការដកស្ទូងមានការយឺតយ៉ាវ។ ម៉្យាងវិញទៀតប្រសិនបើទឹកទន្លេមេគង្គឡើងមិនដល់កម្ពស់ធម្មតា ទន្លេមេគង្គមិនអាចហូរចាក់ចូលបំពេញទំនប់ប្រឡាយ ឬ បឹងបួបានទេ ជាហេតុធ្វើឱ្យការធ្វើស្រែប្រាំងធ្លាក់ចុះដោយសារគ្មានទឹកសម្រាប់ស្រោចស្រពគ្រប់គ្រាន់ ។ ដូច្នេះទិន្នផលស្រូវអាស្រ័យលើបរិមាណទឹកភ្លៀងធ្លាក់ប្រចាំឆ្នាំ។

*រូបទី១-របបទឹកភ្លៀងនៅកម្ពុជា*




កម្ពុជាមានអាកាសធាតុសើមដែលនៅគ្រប់ខេត្តទាំងអស់កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំមានលើសពីមួយម៉ែត្រ ។ របបទឹកភ្លៀងមានអតិបរមាពីរ និង អប្បបរមាពីរ។ ខ្សែកោងកម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំមានអតិបរមាពីរគឺអតិបរមាទីមួយមានកម្ពស់ខ្ពស់នៅខែតុលា(២៥២មម.) និងមួយទៀតនៅខែ កក្កដា(១៦៥មម.) និងមានអប្បបរមាពីរគឺអប្បបរមាទីមួយនៅខែមករា(៧មម.) និងមួយទៀតនៅខែ សីហា(១៥៧មម.) ។

ការធ្លាក់ភ្លៀងឱ្យបានទៀងទាត់តាមរដូវកាលមានសារៈសំខាន់ណាស់សម្រាប់ដំណាំកសិកម្មជាពិសេសដំណាំស្រូវ ។ ភ្លៀងធ្លាក់ខ្លាំងក្នុងរយៈពេលបីខែចាប់ពីខែសីហា ដល់ខែតុលា ។ ក៏ប៉ុន្តែ ទិន្នផលស្រូវអាស្រ័យលើកត្តាទឹកភ្លៀងបីពេល ៖

**ទីមួយ**-ភ្លៀងធ្លាក់ដើមឆ្នាំខ្លាំងពេក គឺនៅក្នុងខែមីនានិង មេសា អាចនាំឱ្យមានសត្វល្អិតច្រើនដែលបំផ្លាញដំណាំស្រូវ។ ភ្លៀងដើមឆ្នាំនៅខែឧសភា និងមិថុនាពុំសូវទៀងទាត់ប៉ុន្មានទេ។ ប្រសិនបើភ្លៀងដើមដៃមកយឺតពេល នោះការភ្ជួររាស់សាបព្រោះ ដកស្ទូងនឹងមានការយឺតយ៉ាវ និងធ្វើឱ្យទិន្នផលស្រូវធ្លាក់ចុះ។

**ទីពីរ**-ជាធម្មតាមានកូនរដូវប្រាំងខ្លីមួយនៅក្នុងខែកក្កដា ពី ១០ ទៅ ១៥ថ្ងៃ ។ ប្រសិនបើកូនរដូវប្រាំងនេះអូសបន្លាយយូរក៏អាចនាំឱ្យទិន្នផលស្រូវធ្លាក់ចុះបានដែរ ។ នៅខែ កក្កដា និង សីហា ពេលដែលស្រូវត្រូវការទឹកច្រើនដើម្បីលូតលាស់នោះភ្លៀងច្រើនថយចុះថែមទៀតរហូតដល់រាំងក៏មាន ។ ប្រការនេះចោទជាចំណោទដល់កសិករកម្ពុជាដែលពឹងផ្អែកតែទឹកភ្លៀង។ ដូច្នេះ ប្រសិនបើរដូវប្រាំងខ្លីនេះអូសបន្លាយយូរឬ មានបញ្ហារាំងស្ងួតកសិករត្រូវបូមទឹកបញ្ចូលស្រែដើម្បីជួយឱ្យសន្ទូងលូតលាស់បានល្អ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ដីបី**-ភ្លៀងចុងដៃមានប្រយោជន៍ខ្លាំងណាស់សម្រាប់បង្កើនទិន្នផលស្រូវ។ ប្រសិនបើភ្លៀងអស់មុនរដូវកសិករចាំបាច់ត្រូវបូមទឹកបញ្ចូលស្រែដើម្បីកុំឱ្យស្រូវស្កក ។

ក្នុងន័យនេះប្រព័ន្ធធារាសាស្ត្រនៅកម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាបាននូវសន្តិសុខស្បៀងជាពិសេស នៅក្នុងការដោះស្រាយទឹកនៅដើមរដូវ និងនៅចុងរដូវវស្សា ។ យើងឃើញថាបន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានសាងសង់នូវប្រព័ន្ធធារាសាស្ត្រដ៏ច្រើនសន្ធឹកសន្ធាប់ពាសពេញផ្ទៃប្រទេសរួចមក ផលិតផលស្រូវនៅកម្ពុជាមានការកើនឡើងជាលំដាប់។

### ១.៣.៤. មណ្ឌលអាកាសធាតុ

កត្តាមួយចំនួនដែលធ្វើឱ្យអាកាសធាតុនៅកម្ពុជាខុសគ្នាបន្តិចៗ ពីភូមិភាគមួយទៅភូមិភាគមួយទៀត៖

- កត្តាសំខាន់គឺរបបខ្យល់មូសុងដែលបង្កើតឱ្យមានខ្យល់ត្រជាក់ឬ ក្តៅ ស្ងួត ឬ សើម បង្កើតឱ្យមានច្របល់បរិយាកាស និង កំណាកំណើតទឹកភ្លៀង។
- កត្តាបន្ទាប់បន្សំគឺ ឥទ្ធិពលរយៈទទឹង ឥទ្ធិពលសមុទ្រឬ ឥទ្ធិពលទ្វីប និង ឥទ្ធិពលសណ្ឋានដី។

កត្តាទាំងនេះបង្កើតជាមណ្ឌលអាកាសធាតុដូចតទៅ៖

**តំបន់មាត់សមុទ្រ**-លាតសន្ធឹងពីឆ្នេរកំពតទៅកោះកុង ។ តំបន់នេះមានសីតុណ្ហភាពខ្ពស់តែសើមជានិច្ច គឺភ្លៀងច្រើនពី២.៥០០មម ទៅ ៣.៥០០មម ក្នុងមួយឆ្នាំ និងមានកម្ដៅមធ្យម ២៥អង្សារ ។ អាកាសធាតុមានលក្ខណៈត្រជាក់ស្រួលដោយមានខ្យល់ជំនោរដីនិង ជំនោរខ្យល់សមុទ្រប្រចាំពេលថ្ងៃ។ កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តព្រះសីហនុមាន ៣.៨២៦មម កោះមូល មាន ៣.៧២៥មម ស្រែអំបិល មាន ២.៣២៨មម ។ ខេត្តកំពត ទទួលទឹកភ្លៀងត្រឹម២.០០០មម ដោយសារកោះត្រល់បាំងខ្យល់មូសុងវស្សាហើយភ្លៀងត្រូវបានធ្លាក់អស់មួយភាគធំទៅហើយមុននឹងមកដល់ឆ្នេរកំពត។

**តំបន់ទំនាប** - ទំនាបទន្លេសាបនិង ទំនាបមេគង្គមានអាកាសធាតុប្រហែលអាកាសធាតុស្ទើរទ្វីបព្រោះសណ្ឋានដីមានឥទ្ធិពលបន្ថែមកម្លាំងដល់ខ្យល់មូសុងប្រាំងថែមទៀត។ នៅតំបន់នេះមាន រដូវពីរយ៉ាងច្បាស់គឺ រដូវប្រាំង និង រដូវវស្សាហើយមានចន្លោះកម្ដៅខ្ពស់ជាងតំបន់ឆ្នេរពី ៤ ទៅ ៥ អង្សារ។ តំបន់ទំនាបមានលក្ខណៈមួយរួមគ្នាគឺរដូវប្រាំងប្រហែលគ្នាទាំងសីតុណ្ហភាព ទាំងរយៈពេល វែងជាងរដូវវស្សា ។ ក៏ប៉ុន្តែកម្ពស់ទឹកភ្លៀងមិនដូចគ្នាទេ៖ សៀមរាប ១.៤៣១មម(ភ្លៀង១២០ ថ្ងៃ) បាត់ដំបង១.៣៧៦មម(ភ្លៀង១០៣ ថ្ងៃ) ក្រគរ១.៤៨១មម ភ្នំពេញ ១.៣៧០មម(ភ្លៀង១២៧ ថ្ងៃ) ។

**តំបន់ខ្ពង់រាបខាងជើងនិងឦសាន្ត** - មានអាកាសធាតុកណ្ដាលទ្វីបដោយសារឥទ្ធិពលរយៈកម្ពស់គឺមានសីតុណ្ហភាពខ្ពស់ជាមធ្យមប្រចាំឆ្នាំ ២៧អង្សារ សម្បូណ៌ភ្លៀងតែមានរដូវដូចតំបន់ទំនាបដែរ។ កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំជាមធ្យម២.០០០មម តែមានលម្អៀងតាមទីកន្លែង៖ ចម្ការអណ្ដូង(២.៤៣២មម) ព្រែកឆ្លូង (២.៣៦៩មម) ជប់(២.១៤៨មម) មេមត់(១.៩៣៩មម) ស្នួល(១.៩២៩មម) ស្ទឹងត្រែង(១.៨២២មម) និងខ្ពង់រាបរតនគិរី(២.៥០០មម) ។

## ១.៤. ភូមិភាគធម្មជាត

កម្ពុជាសម្បូណ៌ទៅដោយធនធានធម្មជាតិជាពិសេស ធនធានព្រៃឈើ មច្ឆជាតិ ទឹកប្រៃ និងទឹកសាប ជីវចម្រុះសម្បូណ៌ បែបនិងតំបន់កសិកម្មដែលមានដំណាំដាំដុះផ្សេងៗ ជាច្រើនប្រភេទនិងមានសត្វពាហនៈទៀតផង ។ សណ្ឋានដីនៃព្រះរាជាណាចក្រកម្ពុជាមានផ្ទៃផតកណ្តាលដែលនៅចំណុចកណ្តាល គឺជាបឹងទន្លេសាបហើយមានជាយជុំវិញជាភ្នំជាកូនភ្នំ និង ជាខ្ពង់រាប។ ផ្ទៃនេះចុះទេរពីភ្នំក្រវាញសំដៅទៅឈូងសមុទ្រថៃដែលជាទីសម្បូណ៌កូនកោះ ។ ទន្លេមេគង្គ និងបឹងទន្លេសាបផ្គត់ផ្គង់នូវប្រភពទឹកដ៏ច្រើនលើសលប់ដែលចាំបាច់សម្រាប់ការដាំដុះនៅរដូវប្រាំងនិងជាប្រភពមិនចេះរីងស្ងួតដ៏សំខាន់នៃត្រីទឹកសាប។

យើងអាចបែងចែកភូមិភាគធម្មជាតិជាបីតំបន់ធំៗគឺ៖ តំបន់ខ្ពង់រាប តំបន់ទំនាប និងតំបន់មាត់សមុទ្រ ។

### ១.៤.១. តំបន់ខ្ពង់រាប

តំបន់ខ្ពង់រាបចែកចេញជាតំបន់ខ្ពង់រាបខាងជើងគឺតំបន់ភ្នំដងរែក និងតំបន់ខ្ពង់រាបឦសាន្ត គឺខ្ពង់រាបរតនគិរី និង ខ្ពង់រាបមណ្ឌលគិរី។

តំបន់ភ្នំដងរែកគឺជាគែមនៃខ្ពង់រាបក្រែនគរាជ ដែលស្ថិតនៅក្នុងប្រទេសថៃ។ គែមនេះមានច្រាំងចោតដែលមានកំពូលខ្ពស់បំផុតគឺភ្នំដងរែក(៧៥៦ម.) ហើយមានរយៈកម្ពស់មធ្យមពី ៣០០ ទៅ ៥០០ម. ។ នៅលើជួរភ្នំដងរែកនេះហើយដែលបុព្វបុរសខ្មែរបានកសាងនូវប្រាសាទបុរាណដើម្បីគោរពបូជាដល់ព្រហ្មញ្ញសាសនាហើយប្រាសាទដែលល្បីល្បាញជាងគេគឺ ប្រាសាទព្រះវិហារដែលអង្គការយូណេស្កូ បានបញ្ចូលទៅក្នុងបញ្ជីនៃបេតិកភណ្ឌវប្បធម៌ពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០០៨ ប្រាសាទតាមាន់ និង ប្រាសាទតាក្របីជាដើម។ ក្រៅពីភ្នំដងរែកនៅមានភ្នំអន្លង់ស្វាយ(៩៥៧ម.) និងភ្នំម៉ាកកៃ(៥៣៧ម.)។ តំបន់នេះមានដង់ស៊ីតេប្រជាជនទាប និងមានព្រៃក្រាស់ ហើយអ្នកស្រុកមួយចំនួនធ្វើដំណាំព្រៃដុត បេះផ្លែឈើព្រៃ និងបរបាញ់សត្វ ។

ខ្ពង់រាបរតនគិរីគឺជាខ្ពង់រាបកន្ទំនៃប្រទេសវៀតណាមដែលខណ្ឌកម្ពុជាពីប្រទេសឡាវ និង ប្រទេសវៀតណាម ។ ខ្ពង់រាបបរកែវស្ថិតនៅចន្លោះជ្រលងទន្លេសេសានទន្លេស្រែពក និងប្រទេសវៀតណាម ដែលមានលក្ខណៈជាទំនាបថ្មក្រែនិងជាខ្ពង់រាបថ្មបាសាល់ដែលមានរយៈកម្ពស់មធ្យម ៣០០ម. និងជាកន្លែងភ្នំភ្លើងចាស់មានវាលកម្អែភ្នំភ្លើង មានដីក្រហមមានផេះភ្នំភ្លើងហើយមាត់ភ្នំភ្លើងខ្លះបានក្លាយជាបឹងដូចជាបឹងយក្សឡោមជាដើម ។

ខ្ពង់រាបមណ្ឌលគិរីជាខ្ពង់រាបបន្តពីខ្ពង់រាបដាកឡាក់នៃប្រទេសវៀតណាម។ មណ្ឌលគិរីមានវាលថ្មក្រែដែលដើបចាប់ពីទន្លេមេគង្គ(៥០ម.) ទៅខាងជើងខ្ពង់រាបឆ្លូងលើ(២០០ម.) ។ ខ្ពង់រាបដាកឡាក់មានប្រជាជនជនជាតិដើមភាគតិចរស់នៅដែលនិយាយភាសាខ្មែរមន និងមានកម្ពស់ពី ៨០០ នៅ ១.០០០ម. ។ ខ្ពង់រាបឆ្លូងលើ ជាថ្មបាសាល់ដែលមានមួយភាគបានក្លាយជាដីក្រហម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តំបន់ខ្ពង់រាបជាតំបន់ដែលសម្បូណ៌ដោយព្រៃក្រាស់ដែលមានពូជដើមឈើល្អៗ ដូចជាបេង ធ្នង់ នាងនួន ស្រឡៅ ឈើទាល គគីរ ផ្ចឹក គ្រញូង ឈើក្រម ។ល។ និងមានព្រៃរបោះដែលមានសត្វច្រើនយ៉ាង ដូចជាអម្បូរគោព្រៃ ទន្សោង ខ្ទីង រមាស ដំរី ខ្លាធំ ខ្លាឃ្មុំ ស្វារ ពស់ ពង្រូល មាន់ព្រៃ ។ល។ តំបន់ឦសានមាន បណ្តាញផ្លូវទឹកសំខាន់ៗ ដូចជាទន្លេមេគង្គ ទន្លេសេសាន ទន្លេសេកុងទន្លេស្រែពក ដែលរាជរដ្ឋាភិបាលកំពុង សិក្សាក្នុងគោលដៅសាងសង់ស្ថានីយវ៉ារីអគ្គិសនី។

## ១.៤.២. តំបន់ដំណាប

តំបន់ទំនាបចែកចេញជាតំបន់ទំនាបបឹង ដែលមានបឹងទន្លេសាប និង ទំនាបទន្លេបួនមុខដែលមាន ទន្លេមេគង្គជាទន្លេមេ។

**តំបន់ដំណាបបឹង**-មានព្រំប្រទល់ខាងជើងទល់នឹងខ្ពង់រាបខាងជើងចាប់ពីរយៈកម្ពស់ពី ២៥ ទៅ ២០០ម. ខាងលិចបន្តពីកូនភ្នំដែលនៅជើងភ្នំក្រវាញមកទល់នឹងបឹងទន្លេសាបនិងបឹងតូចក្បែរនោះ ដែល សណ្ឋកតាមទិសពាយ័ព្យ-អាគ្នេយ៍។ តំបន់ទំនាបនេះមានប្រវែង២២ គ.ម. ពីបឹងធំទៅកំពង់ភ្លុក នៅជើងភ្នំ បាខែង(ខេត្តសៀមរាប) ១៥គ.ម. ពីកំពង់ហ្លួងទៅជើងភ្នំកំពែង(ខេត្តពោធិសាត់)១០៥គ.ម. ពីព្រែកត្នោលទៅ គុត្តសាត(ខេត្តបាត់ដំបង) និង៦៣ គ.ម. ពីផាត់សណ្តាយទៅតាំងក្រសាំង(ខេត្តកំពង់ធំ) ។ ផ្ទៃរាបយ៉ាងធំល្វឹង ល្វើយនៅខេត្តបាត់ដំបង និង កំពង់ធំជាភូមិភាគទាប ដែលមួយភាគធំជាតំបន់ទឹកជំនន់អាចលិចដែលជា ជង្រុកស្រូវរបស់កម្ពុជា។ ក៏ប៉ុន្តែ ទំនាបលិចទឹកជាប្រចាំមានផ្ទៃដីតូចនៅខេត្តសៀមរាប និង ពោធិ៍សាត់។

នៅតំបន់ទំនាបទឹកលិចចាប់ពីខែសីហា ដល់ខែតុលាហើយតំបន់នោះសម្បូណ៌ដោយបឹងដែលមាន ផ្ទៃទាំងអស់ប្រមាណ៣.០០០គីឡូម៉ែត្រក្រឡានៅពេលទឹកស្រក និង មានបណ្តោយពីព្រែកទោលមកទល់ កំពង់ឆ្នាំង ដែលមានប្រវែង១៦០គ.ម. ។ បឹងទាំងនោះព័ទ្ធជុំវិញដោយខេត្តសៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងកំពង់ធំ ។ បឹងទាំងនោះគឺៈ

**បឹងធំ**-នៅខាងជើងប្រវែងបណ្តោយពី៧៥ ទៅ ៨០គ.មទទឹងពី ៣២ ទៅ ៣៥គ.ម ជម្រៅទឹកនៅ ពេលទឹកស្រកមានកម្ពស់២ម។ ទទឹងនៅកន្លែងដែលតូចមានប្រវែងតែ ១២គ.មដោយសារទីនោះជាដីសណ្តូ ស្ទឹងពោធិ៍សាត់នៅខាងត្បូងនិងដីសណ្តស្ទឹងជីក្រែង និងស្ទឹងស្ទោងនៅខាងជើង ។

**បឹងតូច**-មានប្រវែងបណ្តោយពី ៣៥ ទៅ ៤០គ.មនិងមានទទឹង ២៨គ.មហើយមានចុងខាងត្បូងរួម ត្រង់ឆ្នុកទ្រូ ដោយចំណាក់ល្បាប់នៃស្ទឹងសែនដែលជាស្ទឹងធំជាងគេនៅកម្ពុជា ។ បឹងនេះ ភ្ជាប់ទៅទន្លេសាប ដោយវាលភក់ ។

**វាលភក់**-ស្ថិតនៅចន្លោះឆ្នុកទ្រូនិងខេត្តកំពង់ឆ្នាំង ដែលជាទីប្រជុំដៃទន្លេខ្វាត់ខ្វែងដែលបង្កើតកូន កោះជាច្រើន និងសម្បូណ៌ដោយខ្សាច់។ វាលភក់មានបណ្តោយប្រវែង ៤០គ.មនិងទទឹងប្រវែង ១២គ.មហើយ មានទឹកមិនដែលដាច់ទោះជានៅរដូវប្រាំងក៏ដោយ។

បណ្តាញផ្លូវទឹកនៅតំបន់ទំនាបមានអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងខ្លាំងក្លា។ ស្ទឹងនៅតំបន់នេះហូរ ធ្លាក់ពីកូនភ្នំខាងជើងពីភ្នំដងរែក ឬ ពីភ្នំក្រវាញចូលក្នុងបឹងពីគ្រប់ទិសទីដូចជាស្ទឹងសង្កែ ស្ទឹងមង្គលបូរី ស្ទឹង

សិរីសោភណ្ឌ ស្ទឹងស្វាយចេក ស្ទឹងស្រែង ស្ទឹងមោង ស្ទឹងពោធិ៍សាត់ ស្ទឹងបរិបូរ ស្ទឹងជីនិត ស្ទឹងសែន ស្ទឹងស្លោង ស្ទឹងជីក្រែង និងស្ទឹងសៀមរាប ។ល។ ស្ទឹងសែនវែងជាងគេមានប្រវែងប្រហែល ៤៥០ គ.ម។ ក្រៅពីស្ទឹងនៅមានប្រព័ន្ធអូរជាច្រើនដែលស្ងួតទឹកពីខែមករា ដល់ខែឧសភា។

**តំបន់ទំនាបទន្លេបួនមុខ**-គឺជាទីប្រសព្វនៃទន្លេសាបនិងទន្លេមេគង្គហើយនៅទីនេះទន្លេក៏បែកជាពីរគឺ ទន្លេមេគង្គ និង ទន្លេបាសាក់។ ប្រជាជនកម្ពុជាបានដាក់ឈ្មោះផ្សេងៗឱ្យទន្លេមេគង្គ តាមទំនៀមទម្លាប់របស់ប្រជាជនគឺៈ

- **ទន្លេធំខាងលើ**ត្រង់ចន្លោះខេត្តក្រចេះនិង កំពង់ចាម ។
- **ទន្លេធំកណ្តាល**ត្រង់ចន្លោះ កំពង់ចាម និងភ្នំពេញ ។
- **ទន្លេធំក្រោម**ចាប់ពីខាងត្បូងភ្នំពេញដល់ព្រំប្រទល់ប្រទេសវៀតណាម។

**ទន្លេធំកណ្តាល**-មានប្រវែងពី ៨៥ ទៅ ៩០គ.មនិងមានទទឹងពី០,៨គ.មទៅ ៧គ.ម (ត្រង់កោះសូទិន និងកោះល្វា) ហើយមានជម្រៅប្រហែល៣០ម ដល់ ៥០មនៅម្តុំកំពង់ចាម។

**ទន្លេធំក្រោម**-មានប្រវែងពី ១០០គ.ម ពីភ្នំពេញទៅដល់ព្រំដែនវៀតណាម និងមានទទឹងពី ០,៩គ.មទៅ ៤គ.ម (ត្រង់ពាមរន៍) ។

**ទន្លេបាសាក់**-មានប្រវែងប្រហែល ១០០គ.ម តែមានទទឹងពី ០,៤គ.ម ទៅ ០,៦គ.ម ជាមធ្យមនិងអាចដល់ ២,៥គ.ម (ត្រង់កោះធំ) ។

**ទន្លេសាប**-នៅចន្លោះទន្លេបួនមុខនិង កំពង់ឆ្នាំង មានប្រវែងពី៩៥ ទៅ ១០០គ.ម។

ក្រៅពីទន្លេធំនៅមានទន្លេតូចដែលមានប្រវែងជិត១០០គ.មដែលបែកពីទន្លេធំកណ្តាល ត្រង់ប្រធ្នស់មកភ្ជាប់ទន្លេវិញត្រង់ពាមរន៍។

តំបន់ទំនាបបឹងទាំងនេះសម្បូណ៌ទឹក ត្រី ដីមានជីជាតិ ដីដំណាំព្រៃរបោះលើទួល ដែលជាទីតាំងយ៉ាងល្អប្រសើរសម្រាប់ការតាំងទីលំនៅជាភូមិឬក្រុង ។ រាជធានីភ្នំពេញនិងទីប្រជុំខេត្តជាច្រើនដូចជាខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ តាកែវ កណ្តាល ព្រៃវែង ស្វាយរៀងសុទ្ធសឹងតែតាំងទីលើត្រើយខាងឆ្វេងនៃទន្លេ។

### ១.៤.៣. តំបន់មាត់សមុទ្រ

តំបន់មាត់សមុទ្រជាប់នឹងឈូងសមុទ្រថៃហើយជាទំនាបដែលមានរយៈកម្ពស់កើនយ៉ាងរហ័សពីសមុទ្រទៅទល់ជើងភ្នំក្រវាញ។ តំបន់នេះសម្បូណ៌កូនភ្នំដូចជាភ្នំជំនាបវាលរេញនិងសម្បូណ៌កោះណាស់ដូចជាកោះកុង(កម្ពស់៤១០ម.) ។ ឯផ្លូវទឹកក៏មានច្រើនតែជាព្រែកតូចៗដែលមានទឹកឡើងនិងស្រកយ៉ាងឆាប់រហ័សទៅតាមទឹកភ្លៀង ។ ស្ទឹងសំខាន់ៗច្រើនហូរធ្លាក់ពីរយៈកម្ពស់៥០០ ទៅ ៦០០មជាល្បាក់ហើយបត់បែនមុននឹងហូរទៅដល់មាត់សមុទ្រ ។ ផ្លូវទឹកទាំងនោះគឺៈ ស្ទឹងមេទឹក ស្ទឹងតាតី ស្ទឹងជាយអារ៉ែង ព្រែកជីផាត់ ស្ទឹងកំពត ស្ទឹងទូកមាស ជាដើម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឆ្នេរសមុទ្រកម្ពុជាមានប្រវែង ៤៣៥គ.ម ដែលហៅថាឈូងសមុទ្រថៃ ពោលគឺស្មើនឹងមួយភាគប្រាំមួយនៃព្រំប្រទល់សរុប ។ ឆ្នេរសមុទ្រកម្ពុជាមានជម្រៅមធ្យមមិនលើសពី៥៦មឡើយហើយមានស្នើរកោះពីរដាច់ពីគ្នាគឺស្នើរកោះស្មាច់ និងស្នើរកោះវាលរេញ ។ លក្ខណៈធម្មជាតិនិង លក្ខណៈអាកាសធាតុមានលក្ខណៈអំណោយផល ដែលអាចឱ្យកម្ពុជាអាចអភិវឌ្ឍតំបន់ខេត្តព្រះសីហនុ រាម កោះកុង និង កែប ឱ្យក្លាយទៅជាមជ្ឈមណ្ឌលទេសចរណ៍អន្តរជាតិនៅថ្ងៃអនាគត។ នៅតាមតំបន់ឆ្នេរមានវាលភក់លាយទឹកសាបនិងទឹកប្រៃ ដែលបង្កលក្ខណៈអំណោយផលឱ្យដុះព្រៃកោងកាងដែលជាទ្រនាប់មួយយ៉ាងសំខាន់ក្នុងការធានាបាននូវតុល្យភាពអេកូឡូស៊ីនៅតំបន់ឆ្នេរ។

ធនធានធម្មជាតិនៅតំបន់ឆ្នេរដីមាត់សមុទ្រចែកជាពីរសណ្ឋានគឺ ព្រៃកោងកាងពិត និងព្រៃកោងកាងក្រោយ ។ ដីនៅម្តុំនេះជាវាលភក់លាយទឹកប្រៃមានជាតិអាស៊ីតកកើតឆាប់ដែលសម្រាប់តែដំណាំដូងឬដូងប្រេងប៉ុណ្ណោះ ។ មានតែដើមកោងកាងនិងដើមចាកទេដែលដុះច្រើនលើដីសណ្ឋាននេះ។ មានក្រុមហ៊ុនបរទេសមួយចំនួនកំពុងសិក្សារុករកប្រេងនិងឧស្ម័ននៅតាមខ្ពង់រាបបាតសមុទ្រកម្ពុជាតែនៅមិនទាន់ផ្តល់នូវលទ្ធផលយ៉ាងណាទេ ។ ឈូងសមុទ្រកម្ពុជាមានជម្រៅមិនលើសពី ៧៥ម ទេហើយមានបាតរាបស្មើ ។ នៅលើឈូងសមុទ្រនេះ ពុំដែលមានព្យុះស៊ីក្លូង ឬព្យុះទីហ្វុងដូចនៅសមុទ្រចិនឡើយដោយមានតែព្យុះភ្លៀងនៅពេលប្តូររបបមូសុងប៉ុណ្ណោះ ។ ប្រការនេះផ្តល់នូវលក្ខណៈប្រសើរដល់អ្នកនេសាទតាមឆ្នេរ។

**ប្រជុំភ្នំក្រវាញ**-ប្រជុំភ្នំក្រវាញចែកជា៖

- **ភ្នំក្រវាញខាងលិច**-សណ្តូកពីប៉ៃលិនដល់ស្ទឹងពោធិ៍សាត់ គឺជាថ្មក្រាមនិង ថ្មស៊ីសលាយក្រែ និងមានកំពូលខ្ពស់ជាងគេ ឈ្មោះភ្នំទំពរ(១.៥១៦ម.)។
- **ភ្នំក្រវាញកណ្តាល**-ជាប្រជុំភ្នំមួយយ៉ាងធំលាតសន្ធឹងពីមោងដល់កោះកុង មានរយៈកម្ពស់លើសពី ១.០០០មកំពូលខ្ពស់ជាងគេគឺភ្នំសំកុះ(១.៧៨៥ម.)។
- **ភ្នំក្រវាញខាងកើត**-ដែលចែកជា៖(១) ប្រជុំភ្នំខ្មោចនៅចន្លោះខេត្តពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ។ នៅត្រង់ព្រំប្រទល់ចែកខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ ពោធិ៍សាត់ដែលមានកំពូលខ្ពស់ជាងគេនៅកម្ពុជាគឺភ្នំឱរ៉ាល់(១.៨១៣ម.)(២)ប្រជុំភ្នំអូរម្លូដែលមានកំពូលមិនលើសពី១.០០០ម.នៅចន្លោះស្រែអំបិលនិងខេត្តកំពង់ស្ពឺដូចជាខ្ពង់រាបគិរីរម្យ(៧០០ម.) ដែលសម្បូណ៌ដោយដើមស្រល់។

**ប្រជុំភ្នំដំរី**-នៅដាច់ពីភ្នំអូរម្លូដោយច្រកពេជ្រនិល និងផ្លូវជាតិលេខ៤ ពីភ្នំពេញ ទៅខេត្តព្រះសីហនុ។ ខាងត្បូងប្រជុំភ្នំនេះត្រូវបញ្ចប់ដោយចំណោតភ្នំបូកគោ(១.០៧៥ម.) ។ តំបន់នេះមានព្រៃក្រាស់ដែលជាព្រៃមាត់សមុទ្រនិងព្រៃទទួលភ្លៀងច្រើន(ជាង៤មក្នុងមួយឆ្នាំ) ។

## ១.៥. ប្រព័ន្ធអេកូឡូស៊ីបរិស្ថាន និង ចំណាត់ថ្នាក់ដី

### ១.៥.១. ប្រព័ន្ធអេកូឡូស៊ីបរិស្ថាន

តំបន់ដាំដុះនៅកម្ពុជាអាចត្រូវបានបែងចែកជាបួនតំបន់ធំៗដែលកំពុងដាំដុះឬ អាចដាំដុះបាន ដែលជាកត្តាកំណត់នៃការដាំដំណាំអចិន្ត្រៃយ៍ និងដំណាំប្រចាំឆ្នាំ គឺ៖

*រូបទី១.២-ប្រភេទដីនៅប្រទេសកម្ពុជា*




*ប្រភព៖ធនាគារពិភពលោក (2009).ស្ថេរភាពកំណើនសេដ្ឋកិច្ចដ៏លឿនក្នុងបរិយាកាសដែលមានភាពប្រឈម.ឧបសម្ព័ន្ធ. ទំព័រ. 115.*

**តំបន់ប្រព័ន្ធកេ្សត្របរិស្ថានជី១**-សម្រាប់ប្រកបកសិកម្មអាស្រ័យទឹកភ្លៀងលើខ្ពង់រាបនិងកូនភ្នំ គឺជាតំបន់ដែលអាចដាំដើមកៅស៊ូ ដើមស្វាយចន្ទី និងដើមឈើយកផ្លែ(ដែលជាដំណាំអចិន្ត្រៃយ៍) ។ ដំណាំប្រចាំឆ្នាំមាន ពោត សណ្តែកសៀង ស្រូវ កប្បាស និងវាលស្មៅ។

- **តំបន់ប្រព័ន្ធកេ្សត្របរិស្ថានជី២**-ស្រែទំនាបអាស្រ័យរបបទឹកភ្លៀងក្នុងទំនាបដីខ្សាច់នៅក្នុងតំបន់នេះគេអាចធ្វើស្រែ និងចិញ្ចឹមគោក្របី ។ កសិករអាចប្រកបរបរកសិកម្មដោយដាំដំណាំអចិន្ត្រៃយ៍អាស្រ័យទឹកភ្លៀង និងដាំដំណាំប្រចាំឆ្នាំ។
- **តំបន់ប្រព័ន្ធកេ្សត្របរិស្ថានជី៣**-ស្រែទំនាបអាស្រ័យរបបទឹកភ្លៀងក្នុងវាលជាំទឹក នៅក្នុងតំបន់នេះគេអាចធ្វើស្រែជាមួយនឹងការចិញ្ចឹមគោក្របី។
- **តំបន់ប្រព័ន្ធកេ្សត្របរិស្ថានជី៤**-ស្រែសម្រាប់ស្រូវឡើងទឹកក្នុងវាលលិចទឹក- នៅក្នុងតំបន់នេះគេអាចធ្វើស្រូវប្រដេញទឹកដោយច្រើនតែមានបឹង ព្រែក ឬប្រឡាយ ។

## ១.៤.២. ចំណាត់ថ្នាក់ដី

ដីនៅប្រទេសកម្ពុជាមានលក្ខណៈផ្សេងៗគ្នាដែលប្រែប្រួលតាមតំបន់ ។ ចំណាត់ថ្នាក់ដីពឹងផ្អែកលើធនធាននៃដីស្រទាប់លើដែលមានឥទ្ធិពលទៅលើការដាំដំណាំ។ គេអាចចែកតំបន់ដាំស្រូវនៅកម្ពុជាជាបីតំបន់ដោយយោងតាមលក្ខណៈរូបសាស្ត្ររបស់ដី(ម៉ែនសារុម-ដំណាំស្រូវនៅកម្ពុជាទំព័រ១៩៧-២២៧)៖ដីដែលវិវត្តលើវាលទំនាបនៃល្បាប់ចាស់និងល្បាប់ដីដែលវិវត្តទាំងស្រុងពីសិលាមេនៅខាងក្រោមនិងដីដែលវិវត្តនៅលើវាលទំនាបលិចទឹកទន្លេ ឬបឹងដែលទទួលកំណរដីល្បាប់ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១.៥.២.១. ដីដែលវិវត្តលើវាលទំនាបនៃល្បាប់ចាស់និងល្បាប់

**ដីជំនាបល្បាប់ចាស់** - ប្រភេទដីនេះជាដីដែលកកើតនៅគ្រប់បណ្តាខេត្តដែលធ្វើស្រូវនៅកម្ពុជា។ តំបន់នេះកាលពីដើមវាជាស្ទឹង បឹង ឬ វាលទំនាបលិចទឹកតែឥឡូវនេះស្ថិតនៅខ្ពស់ជាងនីវ៉ូទឹកធម្មតា។ ដីទាំងនេះមានប្រភពពីកំណកកករនៃល្បាប់ដែលបានហូរតាមទឹកទន្លេ ឬបឹងហើយដែលបានជន់លិចតំបន់ទាំងនេះម្តងម្កាល។ ដីនេះមិនបានទទួលដីជាតិបន្ថែមដោយដីល្បាប់ជារៀងរាល់ឆ្នាំដូចពេលមុនទេ។ ម្យ៉ាងវិញទៀត ដីនេះទទួលរងនូវការផ្លាស់រេដុកម្ម និងអុកស៊ីតកម្មជាមួយនឹងការច្រោះចុះក្រោមនៃដីជាតិនិងដីឥដ្ឋនៅស្រទាប់ក្រោម បណ្តាលឱ្យមានការបាត់បង់ដីជាតិដែលមានសេសសល់នៅផ្ទៃលើ។ ដីទាំងនេះក៏អាចស្ថិតនៅជាយៗបឹងឬ វាលទំនាបលិចទឹកទន្លេផងដែរ។ សណ្ឋានដីរបៀបនេះកើតមានឡើងនៅតាមបណ្តាខេត្តដាំដំណាំស្រូវជាច្រើននៅក្នុងប្រទេសកម្ពុជា។

**ដីល្បាប់**-ត្រូវបានកកើតឡើងដោយសារការសឹករេចរឹលនៅជុំវិញតំបន់ភ្នំនិងកូនភ្នំ និងបន្លាស់ទីនៃសារធាតុសំណឹកឆ្ពោះទៅកាន់ដីទាបៗដែលបង្កើតបានជារាងផ្លិត ។ នៅតំបន់លិចទឹកនៅវាលទំនាបដីល្បាប់ត្រូវបានគេជួបប្រទះច្រើន នៅតាមចំណុចដែលមានសណ្ឋានដីទាបៗដែលនៅទីនោះជាទូទៅមានលក្ខណៈជាដីល្បាប់ម៉ដ្ឋ។ នៅកម្ពុជាការកកើតទំនាបល្បាប់មានសារៈសំខាន់ណាស់នៅតំបន់ធ្វើស្រែ ជាពិសេសនៅក្នុងបណ្តាខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប និងនៅក្នុងផ្នែកខ្លះក្នុងខេត្តពោធិ៍សាត់ កំពង់ធំ កំពង់ចាម និងស្វាយរៀង។ នៅក្នុងតំបន់មួយចំនួនដែលពីដើមជាភ្នំ ឬ កូនភ្នំត្រូវបានសឹករេចរឹលអស់ទៅហើយហើយបង្កើតបានជាខ្ពង់រាបដែលមាន សណ្ឋានខ្ពស់ទាបៗ ។

### ១.៥.២.២. ដីដែលវិវត្តទាំងស្រុងពីសិលាមេនៅខាងក្រោម

**ដីដែលចានវិវត្តទាំងស្រុងពីសិលាមេនៅខាងក្រោម**-ប្រភេទដីនេះបានវិវត្តដោយឆ្លងកាត់ដំណើរសឹករិចរិលនិងពុកផុយនៃសិលាមេដែលស្ថិតនៅខាងក្រោម ។ទោះបីជាដីនេះត្រូវកើតឡើងនៅលើផ្ទៃកលើនៃសិលាមេក៏ដោយ នៅក្នុងករណីខ្លះដីទាំងនេះកកើតនៅតាមជម្រាលភ្នំដែលមានចំណោតទាបៗ។ នៅកម្ពុជាដីប្រភេទនេះក្លាយមកពីសិលាមេពីរប្រភេទគឺថ្មភក់ និងកំអែរម៉ាក់ម៉ា។ ដីដែលកើតមកពីសារធាតុនេះគឺជាដីថ្មី និងមានដីជាតិជាពិសេសដីដែលកើតលើថ្មបាសាល់។ មានតែដីដែលវិវត្តចេញពីសារធាតុកម្អែលភ្នំភ្លើងថ្មីទេដែលបង្កើតជាតំបន់ដាំដំណាំស្រូវមួយផ្នែកធំសំខាន់។ ដីទាំងនេះត្រូវបានជួបប្រទះនៅក្នុងខេត្តកំពង់ចាម កំពង់ធំ រតនគិរី ស្ទឹងត្រែង និងខេត្តបាត់ដំបង ។

### ១.៥.២.៣. ដីដែលវិវត្តនៅលើវាលទំនាបលិចទឹកទន្លេឬ បឹងដែលទទួលកំណដីល្បាប់

**ដីវាលជំនាបលិចជឹកកសិកម្ម**-នៅកម្ពុជាវាលទំនាបលិចទឹកសកម្មមានបីប្រភេទសំខាន់ៗ៖

- **វាលជំនាបលិចជឹកបត់បែន**-កើតឡើងតាមបណ្តោយផ្នែកនៃផ្លូវទឹកទន្លេហើយវាមានដៃទន្លេ តំបន់ក្រោយច្រាំងទន្លេ ខ្នងចំណោតនិងអាងទឹក ។ ទំនាបទាំងនេះត្រូវលិចទឹកនៅរដូវវស្សាពេលដែលទឹកជំនន់ជន់តាមដងទន្លេឬ ព្រែក កំណកកករប្រព្រឹត្តទៅតាមកម្រិតផ្សេងៗអាស្រ័យទៅតាមចរន្តហូររបស់ទឹក។ កករគ្រាប់ធំៗបំផុត(ខ្សាច់គ្រាប់ធំៗនិងក្រួសល្អិតៗ) ត្រូវកកនៅក្នុងផ្លូវទឹករីឯខ្សាច់ម៉ដ្ឋនិងល្បាប់ម៉ដ្ឋត្រូវកកជាប់នៅលើតំបន់ក្រោយច្រាំងទន្លេ ចំណែកឯដីឥដ្ឋត្រូវកកជាប់នៅក្នុងអាងទំនាប។ តំបន់ច្រាំងទន្លេ និងខ្នងជម្រាលក្រោយច្រាំងទន្លេត្រូវបានប្រើប្រាស់សម្រាប់សង់ផ្ទះដាំបន្លែ និងដំណាំសេដ្ឋកិច្ចឬសម្រាប់ធ្វើស្រែ ។ ជម្រាលក្រោយច្រាំងទន្លេគឺជាតំបន់កណ្តាល

ចន្លោះតំបន់ច្រាំងទន្លេនិងវាលទំនាបលិចទឹក ។ ដីនៅក្នុងអាងទឹកមានលក្ខណៈជាំទឹកហើយដីទាំងនោះត្រូវបានប្រើប្រាស់ជាសំខាន់សម្រាប់ដំណាំស្រូវនៅរដូវទឹកសម្រក។ ប្រព័ន្ធទន្លេមេគង្គនិងទន្លេបាសាក់ច្រើនមានបាក់ច្រាំងឬ ផ្លូវទឹកត្រូវបានកាត់ផ្តាច់ដោយបំពេញដោយកំណកកករឬបង្កើតជាដីដុះ ។ នៅភាគខាងត្បូងនៃខេត្តកណ្តាល តាកែវ និងព្រៃវែងនិងវាលទំនាបលិចទឹកនៃបឹងទន្លេសាបមានសណ្ឋានដីលាតសន្ធឹងជួបជាមួយនឹងវាលទំនាបលិចទឹកធំៗ។

- **វាលជំនាបលិចទឹកធំៗ** - កើតឡើងនៅតាមបណ្តោយផ្លូវទឹកផ្នែកខាងក្រោមនិងនៅជាទម្រង់វាលទំនាបលិចទឹកប្រៃ ។ តំបន់នេះច្រើនតែជាដៃទន្លេតំបន់ច្រាំងទន្លេដែលដីមានលក្ខណពីដីល្បាប់ទៅដីឥដ្ឋបន្តភ្ជាប់ដោយដីទំនាបដ៏ធំរាបស្មើដែលមានសណ្ឋានផ្សេងៗគ្នា។ ទំនាបនេះអាចលាតសន្ធឹងជាច្រើនគីឡូម៉ែត្រពីដៃទន្លេទៅតំបន់ខ្លះស្ថិតនៅក្នុងខេត្តតាកែវ។ ក្នុងមួយឆ្នាំៗទំនាបនិងច្រាំងទន្លេភាគច្រើនបានត្រូវជន់លិចក្នុងជម្រៅ២ម៉ែត្រក្នុងរយៈពេលដ៏វែង ។ផ្ទៃដីនៃវាលទំនាបលិចទឹកធំមានច្រើនគឺពាក់កណ្តាលភាគខាងត្បូងនៃខេត្តតាកែវនិងព្រៃវែង និងនៅជុំវិញតំបន់ប្រព័ន្ធទន្លេមេគង្គនិងបាសាក់ ។
- **វាលជំនាបលិចទឹកប្រៃ**-កើតឡើងនៅក្នុងតំបន់ឆ្នេរសមុទ្រ។ដំណាំស្រូវដែលគេធ្វើនៅតំបន់នេះត្រូវរងឥទ្ធិពលដោយសារចរន្តទឹកជោរជាប់ជានិច្ចនិងការទន្ទ្រានចូលនៃទឹកសមុទ្រ។ តំបន់នេះគ្រាន់តែជាតំបន់ស្រូវបន្ទាប់បន្សំប៉ុណ្ណោះ ។
- **វាលជំនាបលិចទឹកបឹង** - នៅកម្ពុជាវាលទំនាបលិចទឹកបឹងមានលក្ខណៈរួមច្រើនដូចគ្នានឹងវាលទំនាបធំដូចជាវាលទំនាបដែលនៅព័ទ្ធជុំវិញបឹងទន្លេសាបដែលបានវិវត្តយ៉ាងល្អដែលជាទូទៅមានផ្ទៃរាបស្មើហើយមានលក្ខណៈម៉ដ្ឋល្អ ។

## ១.៦. ធនធានរ៉ែ

*តារាងលេខ១.៣-ផែនទីភូគព្ភសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា*




*ប្រភព៖ Mitsui Mineral Development Engineering Co., Ltd (2008),កម្ពុជា -រ៉ែជាប្រភពនៃកំណើន, អត្ថបទដែលរៀបចំសម្រាប់របាយការណ៍"ស្ពេរភាពកំណើនដ៏លឿន"រៀបចំដោយធនាគារពិភពលោក.អត្ថបទព្រាង.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្រោមដីនៃព្រះរាជាណាចក្រកម្ពុជាមានថ្មដែលប្រែប្រួលសរីរាង្គមានកំណកកករ និងក្រានីតពីយុគសម័យប្រេកំប្រ៊ីយ៉ានដល់ម៉េសូអ៊ីក ជូរ៉ាស៊ីកដែលគ្របដណ្ដប់ដោយកម្អែលភ្នំភ្លើងនិងល្បាប់ ។ ស្រទាប់រ៉ែភូគព្ភសាស្ត្រលាតសន្ធឹងដល់ប្រទេសថៃឡង់ ឡាវ និងវៀតណាម ដែលជាសក្ខីភាពថាកម្ពុជាមានសក្ដានុពលខ្ពស់នឹងមានកំណប់រ៉ែដូចប្រទេសជិតខាងដែរ។

ការសិក្សាភូគព្ភសាស្ត្រនៅក្នុងអំឡុងឆ្នាំ១៩៦០ បានបញ្ជាក់ពីកំណប់រ៉ែនៅតាមតំបន់១៥៥កន្លែង។ បន្ទាប់មកការសិក្សានៅក្នុងអំឡុងឆ្នាំ ១៩៧០ និង ១៩៨០ បង្ហាញឱ្យឃើញនូវកំណប់រ៉ែមាសចំនួន ១០ទៀត។ ដោយឈរលើមូលដ្ឋាននៃការសិក្សារ៉ែចាប់ពីឆ្នាំ១៩៦៦ ដល់ ១៩៧០ នាយកដ្ឋានភូគព្ភសាស្ត្រនៃអគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានបោះពុម្ពផ្សាយនូវផែនទីភូគព្ភសាស្ត្រនៅក្នុងអំឡុងទសវត្សរ៍ទី៨០ ដែលបង្ហាញនូវធនធានរ៉ែចំនួន២៥ មុខ ដូចជា៖

ធនធានរ៉ែលោហៈមាន៖ រ៉ែប្រាក់ (Ag) បុកស៊ីត(Al) រ៉ែអាសេនិច (As) រ៉ែមាស(Au) រ៉ែប៊ីស្មុត ត្បូងថ្មត្បូងលីញ៉ីតថ្មកំបោរ (Ca) រ៉ែក្រូម(Cr) រ៉ែទង់ដែង (Cu)រ៉ែភ្លុយអរ (F) រ៉ែដែក (Fe)ដូឡូមីត (Mg) ពីរ៉ូលុយស៊ីត(Mn) រ៉ែម៉ូលីបដែន (Mo)ផូស្វាត (P) រ៉ែស្ពាន់ធ័រ(S) ស្ទីប៊ីន (Sb) ស៊ីលីស(Si) កាល់ស៊ីតេរីត (Sn)វ៉ុលប្រាមីត (W) ។

ធនធានរ៉ែលោហៈសំខាន់ៗមានដូចជា រ៉ែមាស ទង់ដែង ស័ង្កសីពីរ៉ូលុយស៊ីត ដែក និង បុកស៊ីត។ ការកកើតឡើងនៃធនធានរ៉ែនេះបណ្ដាលមកពីសកម្មភាពចំហេះជាច្រើនលើកច្រើនសារនៃថ្មកំណកកករដែលស្ថិតនៅក្នុងដំណាក់កាលផ្សេងៗគ្នានិងតាមតំបន់ផ្សេងៗ ។ ប្រការនេះបញ្ជាក់ឱ្យឃើញថាកំណប់រ៉ែទាំងនេះអាចនឹងមានតម្លៃពាណិជ្ជកម្ម។

*តារាងលេខ១.៨-ទីកន្លែងដែលអាចមានប្រេងនិងឧស្ម័នធម្មជាតិ*




*ប្រភព៖អាជ្ញាធរប្រេងកាតជាតិកម្ពុជា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំណាប់រ៉ែសំខាន់មាន៖

**ប្រេងនិងឧស្ម័នធម្មជាតិ**-ការស្រាវជ្រាវរុករកប្រេងកាតនិងឧស្ម័នធម្មជាតិនៅក្នុងឈូងសមុទ្រថៃបានទាក់ទាញនូវក្រុមហ៊ុនអន្តរជាតិជាច្រើនឱ្យមកដាក់ទុនវិនិយោគលើការស្រាវជ្រាវរុករកប្រេងនិងឧស្ម័នធម្មជាតិ ។

*តារាងលេខ១.៥-ប្លុកប្រេងដែលផ្តល់ឱ្យក្រុមហ៊ុនអន្តរជាតិ*



*ប្រភព៖អាជ្ញាធរប្រេងកាតជាតិកម្ពុជា*

តំបន់ក្នុងឈូងសមុទ្រថៃត្រូវបានបែងចែកជាប្លុកប្រេងនិងឧស្ម័ន និងត្រូវបានផ្តល់ឱ្យក្រុមហ៊ុនដូចតទៅដើម្បីធ្វើការសិក្សារុករកប្រេងនិងឧស្ម័ន ៖

- ប្លុក A : Chevron 55%, Moeco 30%, GS Caltex 15%
- ប្លុកB : PTTEP 30%, SPC 30%, Resourceful Petroleum 30% & Cooper Energy 10%
- ប្លុកC : Polytec 100%
- ប្លុកD : China Petrotech 100%
- ប្លុក E : Medco 60%, Kuwait Energy 30% and JHL 10%
- ប្លុកF : under negotiation with CNOOC Limited



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**រ៉ែបុកស៊ីត**-កម្អែលបាសាល់និងល្បាប់ដែលមានរ៉ែបុកស៊ីតដ៏ច្រើនលើសលប់ត្រូវបានគេរកឃើញនៅតំបន់ដាក់នង នៅក្នុងប្រទេសវៀតណាមភាគខាងត្បូងហើយកំណាប់នេះបន្តចូលដល់កម្ពុជាទៀត។

*រូបភាពលេខ១.៦-កំណាប់រ៉ែនៅកម្ពុជា*




*ប្រភព៖Mitsui MineralDevelopment Engineering Co., Ltd (2008), កម្ពុជា -រ៉ែជាប្រភពនៃកំណើន (Cambodge – L´exploitation minière, une source de croissance), អត្ថបទដែលរៀបចំសម្រាប់របាយការណ៍ធនាគារពិភពលោក"ស្ថេរភាពកំណើនដ៏លឿន "ស្ថេរភាពកំណើនដ៏លឿន". គម្រោង.*

**រ៉ែមាស**- ខ្សែក្រវ៉ាត់ដែលមានរ៉ែមាសនៃកំណាប់រ៉ែមាសនៅឆាទ្រី នៃប្រទេសថៃ លាតសន្ធឹងមកដល់ភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ការជីកយករ៉ែមាសគឺជាសកម្មភាពផលិតកម្មធំជាងគេនៅកម្ពុជាដែលមានកម្មករធ្វើការប្រមាណជា៥.០០០នាក់ ដែលភាគច្រើនជាលក្ខណៈសិប្បកម្ម។ កំណាប់រ៉ែមាសត្រូវបានគេរកឃើញនៅ ១៩ កន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយអណ្តូងរ៉ែទាំងនេះគឺសុទ្ធសឹងតែជាអណ្តូងរ៉ែប្រភេទតូចជាលក្ខណៈសិប្បកម្មដោយជីកយកតែដីនៅផ្ទៃលើតែប៉ុណ្ណោះ។

**រ៉ែទង់ដែង**- ក្នុងពេលថ្មីៗនេះក្រុមហ៊ុនអន្តរជាតិបានរកឃើញនិងជីកយករ៉ែទង់ដែងដែលមានគុណភាពកម្រិតអន្តរជាតិនៅក្នុងតំបន់សេពន នៃប្រទេសឡាវ ។

**ថ្មត្បូង និង ថ្មលម្អ មាន** ៖ថ្មថ្លើមអណ្តើក (J) ម៉ាប (M) ថ្មកែវ(P) ក្វាតអាមេទិស(quartz Qa) ក្វាតអ៊ីយ៉ាឡាំង (Qh) ថ្មត្បូង (Z) ត្បូងកណ្តៀង ត្បូងទទឹម។ កម្ពុជាសម្បូណ៌ថ្មសំណង់ ដូចជា ថ្មបាសាល់ថ្មបាយក្រៀមនៅក្នុងខេត្តកំពង់ចាមនិង កំពង់ស្ពឺ ថ្មក្រៃនៅខេត្តតាកែវ ខេត្តស្ទឹងត្រែងនិងខេត្តសៀមរាប ។ ចំណែកដីឥដ្ឋ ក្រួសនិង ខ្សាច់ មាននៅគ្រប់ទីកន្លែងតាមមាត់ ស្ទឹង ទន្លេ ។ល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រូបភាពលេខ១.៧-ទីតាំងអណ្តូងរ៉ែមាសនៅកម្ពុជា*




*ប្រភព៖Mitsui MineralDevelopment Engineering Co., Ltd (2008), កម្ពុជា -រ៉ែជាប្រភពនៃកំណើន (Cambodge – L'exploitation minière, une source de croissance), អត្ថបទដែលរៀបចំសម្រាប់របាយការណ៍ធានាគារពិភពលោក" ស្ថេរភាព កំណើនដ៏លឿន "ស្ថេរភាពកំណើនដ៏លឿន". គម្រោង.*

ធនធានរ៉ែសំខាន់ៗត្រូវបានរាយប៉ាយតាមភូមិសាស្រ្តដូចខាងក្រោម៖

- នៅខេត្តប៉ៃលិនដែលមានកំណាប់ត្បូងទទឹម និងត្បូងកណ្តៀង ។
- នៅខេត្តរតនគិរី(បរកែវ) មានកំណាប់ត្បូងនិងកំណាប់មាស ។
- នៅខេត្តកំពង់ធំមានរ៉ែដែក(ភ្នំដែក) និងមាស(ក្នុងដីល្បប់) និងសំណប៉ាហាំង ជាពិសេសនៅជុំវិញភ្នំជីនិង ភ្នំលឿង ។
- នៅខេត្តកំពតនិងបាត់ដំបង ដែលមានថ្មកំបោរនិងហ្វូស្វាត ។
- នៅខេត្តពោធិ៍សាត់មានថ្មកែវ នៅភ្នំតាសាយសម្រាប់រចនាវត្ថុសិល្បៈនានា។

នាពេលបច្ចុប្បន្ននេះមានក្រុមហ៊ុនទាំងអស់ចំនួន២០ មកពីប្រទេសអូស្រ្តាលី កូរ៉េ វៀតណាម ចិន។ល។ ដែលបានទទួលអាជ្ញាប័ណ្ណចំនួន៤២ ដើម្បីស្រាវជ្រាវរុករករ៉ែនៅកម្ពុជា។ ក្រុមហ៊ុនអូស្រ្តាលីប្រាំមួយទទួលបានអាជ្ញាប័ណ្ណចំនួន ២៤ ក្រុមហ៊ុនចិនបួនទទួលបានអាជ្ញាប័ណ្ណចំនួន៤ ក្រុមហ៊ុនវៀតណាម (Vina-comin) ទទួលបានអាជ្ញាប័ណ្ណ១ក្រុមហ៊ុនរុស្សីមួយទទួលបានអាជ្ញាប័ណ្ណចំនួន១ ក្រុមហ៊ុនកូរ៉េមួយទទួលបានអាជ្ញាប័ណ្ណចំនួន១ និងក្រុមហ៊ុនកម្ពុជាចំនួនប្រាំមួយទទួលបានអាជ្ញាប័ណ្ណរុករករ៉ែចំនួន៦ ។ ក្រុមហ៊ុនទាំងនេះទើបតែចាប់ផ្តើមសកម្មភាពរុករករ៉ែពីរទៅបីឆ្នាំមុនតែប៉ុណ្ណោះ។

ដូច្នេះមានតែក្រុមហ៊ុននៃប្រទេសលោកខាងលិចតែមួយចំនួនប៉ុណ្ណោះដែលកំពុងធ្វើអាជីវកម្មនៅកម្ពុជាដែលក្នុងនោះមានក្រុមហ៊ុនអូស្រ្តាលីដូចជាOz Mineral បៃពតល Southern Gold,Liberty Miningនិងក្រុមហ៊ុន BHP Billiton។ ក្រុមហ៊ុនអូស្រ្តាលីផ្តោតសកម្មភាពទៅលើការរុករករ៉ែបុកស៊ីតមាស ទង់ដែង និងស័ង្កសី ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រុមហ៊ុនអុកស៊ីអាណា កម្ពុជា **Oxiana Cambodia** បានបើកការិយាល័យនៅភ្នំពេញនៅក្នុងខែមេសា ឆ្នាំ ២០០៥និងទទួលបាននូវសម្បទានរុករករ៉ែនៅក្នុងឆ្នាំ២០០៦។ ក្រុមហ៊ុននេះមានសម្បទានរ៉ែចំនួន៤ ដែលផ្តោតទៅលើរ៉ែមាស ប្រាក់ម៉ូលីបដែន និង ស័ង្កសីដោយធ្វើការស្រាវជ្រាវរុករកដោយបង្កើតក្រុមហ៊ុនចម្រុះជាមួយក្រុមហ៊ុនផ្សេងទៀតដែលមានភាគហ៊ុនតិច។ រយៈពេលស្រាវជ្រាវមានចំនួន៦ឆ្នាំ ដោយអាចទទួលបាននូវអាជ្ញាប័ណ្ណសារជាថ្មីដោយកាត់បន្ថយទំហំដីក្នុង រយៈពេលពីរឆ្នាំម្តងដោយផ្អែកលើលទ្ធផលជាក់ស្តែង។ ក្រុមហ៊ុននេះមានផែនការធ្វើអង្កេតម៉ាញេទិចតាមយន្តហោះនិងជីកខួងសាកល្បង ។

ក្រុមហ៊ុនសារវឌ្ឍន ហ្គូល **Southern Gold** បានបើកការិយាល័យនៅភ្នំពេញនៅក្នុងឆ្នាំ២០០៦ ហើយចាប់ផ្តើមសកម្មភាពរុករករ៉ែនៅក្នុងឆ្នាំ២០០៧ ដោយផ្តោតជាសំខាន់លើរ៉ែទង់ដែង មាស និងស័ង្កសី។ ក្រុមហ៊ុននេះមានសម្បទានចំនួនប្រាំបីនៅក្នុងតំបន់ចំនួន ៦ ។ គម្រោងទាំងអស់សុទ្ធសឹងតែទើបនឹងចាប់ផ្តើម ហើយក្រុមហ៊ុនចាប់ផ្តើមធ្វើអង្កេតម៉ាញេទិចតាមយន្តហោះនិង ជីកខួងសាកល្បងក្នុងឆ្នាំ២០០៨ ។ ក្រុមហ៊ុនមានថវិកសម្រាប់រុករកចំនួន១,៥ ដល់ ៣លានដុល្លារក្នុងមួយឆ្នាំនិងមានផែនការធ្វើការសិក្សាជាបឋមក្នុងរយៈពេលពីរទៅបីឆ្នាំទៀតហើយនិងបង្កើតជាអណ្តូងយករ៉ែក្នុងរយៈពេល ៥ ទៅ ៦ ឆ្នាំក្រោយមក។ ក្រុមហ៊ុននេះបានចុះកិច្ចព្រមព្រៀងចម្រុះស្តីពីការស្រាវជ្រាវរុករករ៉ែជាមួយក្រុមហ៊ុនជប៉ុន(JOGMEG) នៅក្នុងផ្នែកខាងជើង និងខាងត្បូងនៃខេត្តក្រចេះក្នុងឆ្នាំ ២០០៧ ។

ក្រុមហ៊ុនលីប៊ើធី ម៉ាញនីង Liberty Mining បានប្រមូលព័ត៌មានស្តីពីធនធានរ៉ែនៅកម្ពុជានិងបានបើកការិយាល័យនៅភ្នំពេញនៅក្នុងឆ្នាំ២០០៥ ដោយផ្តោតជាសំខាន់លើរ៉ែទង់ដែងនិងមាស។ ក្រុមហ៊ុននេះមានសម្បទានចំនួនប្រាំ នៅក្នុងតំបន់ចំនួន៣ ដែលមានផ្ទៃដីចំនួន ១.៥០០គីឡូម៉ែត្រក្រឡា ។ សម្បទានបីធ្វើអាជីវកម្មដោយខ្លួនឯងទាំងស្រុងនិងពីរទៀតជាមួយដៃគូ។ ក្រុមហ៊ុនបានធ្វើអង្កេតភូគព្ភ-រូបសាស្ត្រតាមអាកាស និងបានកាត់បន្ថយទំហំសម្បទាន និងមានផែនការខួងសាកល្បងដោយផ្អែកលើលទ្ធផលជាក់ស្តែង។ក្រុមហ៊ុននេះមានថវិកាស្រាវជ្រាវចំនួន២លានដុល្លារក្នុងមួយឆ្នាំនិងមានផែនការបង្កើតអណ្តូងរ៉ែក្នុងរយៈពេល៣ ទៅ ៤ ឆ្នាំទៀត។

ក្រុមហ៊ុនឥណ្ឌូចិន រីស្សូស Indochine Resources Ltd. ដែលចុះបញ្ជីលើទីផ្សារភាគហ៊ុននៅប្រទេសស្វីស និងអង់គ្លេសទទួលបាននូវអាជ្ញាប័ណ្ណស្រាវជ្រាវចំនួន១៤ ដោយផ្តោតជាសំខាន់លើរ៉ែមាសទង់ដែង និងស័ង្កសី ។ ក្រុមហ៊ុនឥណ្ឌូចិន បានរកឃើញកំណប់រ៉ែ(Pb-Zn)កម្រិតខ្ពស់ដោយប្រើប្រាស់ការអង្កេតលើដី។

ក្រុមហ៊ុនវៀតណាកូមីន (Vinacomin) ដែលបានបង្កើតការិយាល័យនៅភ្នំពេញនៅក្នុងឆ្នាំ២០០៧ ទទួលបាននូវអាជ្ញាប័ណ្ណស្រាវជ្រាវរុករកចំនួន៣ ដោយផ្តោតជាសំខាន់លើរ៉ែបុកស៊ីតទង់ដែង និង រ៉ែដែក ។

## ១.៧. របបកម្មសិទ្ធិដី

របបកម្មសិទ្ធិដីមានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើកំណើនសេដ្ឋកិច្ច។ ក្របខ័ណ្ឌគតិយុត្តិ និងលិខិតបទដ្ឋាន ស្តីពីប្រព័ន្ធកម្មសិទ្ធិការគ្រប់គ្រង និងការប្រើប្រាស់ដីមានឥទ្ធិពលជាសំខាន់ទៅលើសុខមាលភាពរបស់ប្រជាជនជាពិសេសប្រជាជនក្រីក្រនៅទីក្រុងនិង ប្រជាជននៅតាមទីជនបទជាពិសេស គឺជាកត្តាមួយយ៉ាងសំខាន់នៃស្ថិរភាពនយោបាយ។ គ្រួសារដែលមានកម្មសិទ្ធិលើដីដែលខ្លួនកំពុងប្រើប្រាស់អាចចាត់ទុកថាជាគ្រួសារដែលគាំទ្រសណ្តាប់ធ្នាប់នយោបាយជាធរមាន។ កម្មករក្នុងវិស័យកសិកម្មនិងអ្នកស៊ីឈ្នួលធ្វើស្រែគ្មានទំនាក់ទំនងដ៏រឹងមាំជាមួយនឹងសណ្តាប់ធ្នាប់នេះទេ។ ប្រវត្តិសាស្ត្រនៃប្រទេសជាច្រើនបង្ហាញឱ្យឃើញថា

នៅពេលដែលប្រជាជនជនបទកាន់តែច្រើនឡើងបាត់បង់ដីធ្លីកសិករតែងតែធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាល។ ម៉្យាងវិញទៀត របបកម្មសិទ្ធិដីមានឥទ្ធិពលយ៉ាងសំខាន់ទៅលើផលិតភាពកសិកម្ម។ កសិករដែលម្ចាស់ដីដឹងច្បាស់ថាការបង្កើតការខិតខំប្រឹងប្រែងនិងការអនុវត្តបច្ចេកវិទ្យានឹងបង្កើនប្រាក់ចំណូលរបស់គេ។

## ១.៧.១. ក្របខ័ណ្ឌគតិយុត្តិ

កម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានលប់បំបាត់នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅកម្ពុជាក្នុងខែ មេសា ឆ្នាំ ១៩៧៥ ។ កម្មសិទ្ធិឯកជនត្រូវបានទទួលស្គាល់ឡើងវិញនៅក្នុងឆ្នាំ១៩៨៩ នៅពេលដែលរដ្ឋកម្ពុជាបានដាក់ចេញនូវកម្មវិធីកំណែទម្រង់កម្មសិទ្ធិរដ្ឋក្នុងគោលដៅត្រៀមអនុវត្តនូវគោលនយោបាយបង្រួបបង្រួមជាតិ។ គោលនយោបាយនេះត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ភូមិបាលដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩២។ ការបង្កើតឡើងនូវរាជរដ្ឋាភិបាលចម្រុះអាណត្តិទីមួយក្រោយការបោះឆ្នោតក្នុងខែកក្កដាឆ្នាំ ១៩៩៣ បានឈានទៅដល់ការបង្កើតឡើងនូវមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យការធ្វើកំណែទម្រង់រដ្ឋនិងការអភិវឌ្ឍវិស័យឯកជននៅកម្ពុជា។

បន្ទាប់ពីមូលដ្ឋាននៃសង្គមប្រជាធិបតេយ្យត្រូវបានពង្រឹង ជាពិសេសការពង្រឹងសណ្តាប់ធ្នាប់នយោបាយនិងសង្គម បន្ទាប់ពីការអនុវត្តនូវគោលនយោបាយសមាហរណកម្មអង្គការចាត់តាំងនយោបាយនិងយោធារបស់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យចូលក្នុងសង្គមកម្ពុជាឡើងវិញនៅក្នុងឆ្នាំ១៩៩៨ រួចមក រាជរដ្ឋាភិបាលអាណត្តិទីពីរបានរៀបចំនូវក្របខ័ណ្ឌគតិយុត្តិដើម្បីគ្រប់គ្រងវិស័យដីធ្លី។ ច្បាប់ភូមិបាលថ្មីត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០១ ។ ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ខ្លឹមសារសំខាន់ៗនៃច្បាប់ភូមិបាលថ្មីគឺ៖

- **ឧមេ្រង់នៃកម្មសិទ្ធិ**-កម្មសិទ្ធិបុគ្គលតែម្នាក់ទោះជារូបវន្តបុគ្គលក្តីឬ នីតិបុគ្គលក្តី គឺជាកម្មសិទ្ធិឯកត្តជន។ កម្មសិទ្ធិរបស់បុគ្គលមួយក្រុមដែលមានបុព្វសិទ្ធិរៀងៗខ្លួនតាមរយៈច្បាប់ដែលមានបញ្ញត្តិអំពីកម្មសិទ្ធិនេះគឺជាកម្មសិទ្ធិសម្ហូហភាព ។ កម្មសិទ្ធិរបស់បុគ្គលច្រើននាក់ដែលអនុវត្តសិទ្ធិរបស់ខ្លួនដោយសាមគ្គីគ្នាទៅលើទ្រព្យទាំងមូល គឺកម្មសិទ្ធិអវិភាគ។
- **ទ្រព្យសម្បត្តិរដ្ឋ**-មានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមានព្រៃឈើ ផ្លូវទឹក បឹង ច្រាំងទន្លេកំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង ផ្លូវថ្នល់ អគាររដ្ឋបាលមន្ទីរពេទ្យសាធារណៈបេតិកភណ្ឌបុរាណវិទ្យាវប្បធម៌និងប្រវត្តិសាស្ត្រ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈច្បាប់អនុបយោគ ។ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈអាចជាកម្មវត្ថុនៃការលក់ ការដូរ ការបែងចែក ឬ ការផ្ទេរសិទ្ធិតាមការកំណត់ដោយច្បាប់ ។
- **អចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច**-ដីសហគមន៍ជនជាតិដើមភាគតិចគឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាននិងប្រកបរបរកសិកម្មប្រពៃណី។ ដីសហគមន៍ជនជាតិដើមភាគតិចមិនមែនមានតែដីដែលបានដាំដុះដាក់ស្តែងនោះទេប៉ុន្តែមានដីបម្រុងចាំបាច់ក្នុងការផ្លាស់វេនដំណាំថែមទៀតដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមកហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល។ កម្មសិទ្ធិនៃអចលនវត្ថុត្រូវបានផ្តល់ដោយរដ្ឋជូន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព។ ប៉ុន្តែសហគមន៍នោះគ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាពដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅបុគ្គលឬក្រុមណាមួយបានឡើយ។ គ្មានអាជ្ញាធរណាមួយក្រៅពីសហគមន៍ អាចទទួលសិទ្ធិលើអចលនវត្ថុរបស់ជនជាតិដើមភាគតិចបានឡើយ។

- **លទ្ធកម្មនៃកម្មសិទ្ធិ**-បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធីនិងមិនមានពុការជំទាស់ចាប់ពី៥ឆ្នាំ យ៉ាងតិចគិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជនមានសិទ្ធស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។ ដើម្បីក្លាយជាកម្មសិទ្ធិលើអចលនវត្ថុបានលុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ដោយពិតប្រាកដគ្មានហឹង្សា ដឹងឮជាសាធារណៈគ្មានអាក់ខាន និងដោយសុចរិត។
- **អំពីសម្បទានដី**-សម្បទានដីត្រូវឆ្លើយតបទៅនឹងប្រយោជន៍សង្គមឬទៅនឹងប្រយោជន៍សេដ្ឋកិច្ច។ សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សង្គមអនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍រៀបចំដីដើម្បីសង់លំនៅឋានឬ/និងដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋដើម្បីធានាការចិញ្ចឹមជីវិត។

១៥ឆ្នាំក្រោយពីការបង្កើតឡើងវិញនៃព្រះរាជាណាចក្រកម្ពុជារបបកម្មសិទ្ធិដីធ្លីនៅកម្ពុជាឆ្លុះបញ្ចាំងនូវស្ថានភាពដូចតទៅ ៖

- **កសិកម្មជាលក្ខណៈគ្រួសារ**-កសិករជាម្ចាស់ដីកសិកម្មហើយការធ្វើស្រែចម្ការប្រើប្រាស់កម្លាំងពលកម្មដែលជាសមាជិកគ្រួសារ ។
- **កសិកម្មខ្នាតធំទ្រាយធំ**- គឺជាប្រព័ន្ធកសិកម្មដែលប្រើប្រាស់ផ្ទៃដីដាំដំណាំធំដូចជាចម្ការកៅស៊ូការដាំដំណាំឧស្សាហកម្មជាទ្រង់ទ្រាយធំដូចជាដូងប្រេង ស្វាយចន្ទី ឬការធ្វើស្រែចម្ការជាទ្រង់ទ្រាយធំ។កសិកម្មប្រភេទនេះត្រូវបានអនុវត្តតាមរយៈការផ្តល់ហិរញ្ញប្បទានដីសេដ្ឋកិច្ចដែលរដ្ឋជួលដីរយៈ ពេលវែងឱ្យឯកជនដាំចម្ការកៅស៊ូ ដំណាំឧស្សាហកម្ម ឬដីជាកម្មសិទ្ធិឯកជនរបស់ម្ចាស់ស្រែឬ ចម្ការដោយការធ្វើអាជីវកម្មទាមទារឱ្យប្រើប្រាស់នូវកម្លាំងពលកម្មដែលជាពលករកសិកម្ម ។
- **ការជួលដីកសិកម្ម**-ការជួលដីកសិកម្ម (Tenant farming)គឺជាប្រព័ន្ធកសិកម្មដែលកសិករជួលដីពីម្ចាស់ដីដើម្បីធ្វើស្រែចម្ការ ។
- **ការប្រវាស់ដៃ**-ការប្រវាស់ដៃ(sharecropping)គឺជាប្រព័ន្ធកសិកម្មដែលកសិករធ្វើស្រែចម្ការលើដីរបស់ម្ចាស់ដីតែត្រូវចែករំលែកភោគផលជាមួយម្ចាស់ដីកសិកម្ម។

ប្រព័ន្ធកសិកម្មដែលឈរលើមូលដ្ឋាននៃការជួលដីកសិកម្មនិងការប្រវាស់ដៃកើតមានឡើងដោយសារតែមានកសិករមួយចំនួនជាកសិករគ្មានដីធ្លី។ បើតាមទិន្នន័យនៃវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាប្រជាជនកម្ពុជាប្រមាណជា១៥%គ្មានដីធ្វើស្រែចម្ការនៅក្នុងឆ្នាំ ២០០៤ កើនឡើងពី៥%នៅក្នុងឆ្នាំ១៩៨៤ និង១២% ក្នុងឆ្នាំ២០០០ ។ ៦០%នៃអ្នកអត់ដីគឺជាសមាជិកគ្រួសារដែលមិនធ្លាប់មានដីនិង ៤០%ទៀតគឺជាអ្នកធ្លាប់មានដីតែត្រូវបាត់បង់ដីដោយសារត្រូវគេរំលោភយកដី ឬដោយសារការលក់ដីយកប្រាក់។ ទន្ទឹមនឹងនេះជម្លោះដីធ្លីមានចំនួនជាង ៣.០០០ករណី។

## ១.៧.២. គោលនយោបាយដីធ្លី

ក្នុងគោលដៅអនុវត្តនូវច្បាប់ភូមិបាលឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវក្រុមប្រឹក្សាគោលនយោបាយដីធ្លីនិងបានអនុម័តនូវលិខិតបទដ្ឋានមួយចំនួនដូចជា៖

- អនុក្រឹត្យស្តីពីដីសម្បទានសង្គមកិច្ច(មីនាឆ្នាំ ២០០៣)
- អនុក្រឹត្យស្តីពីនីតិវិធីរៀបចំផែនទីសុរិយោដីនិងសុរិយោដី(មីនាឆ្នាំ ២០០២)
- អនុក្រឹត្យស្តីពីការចុះបញ្ជីដីក្រៅប្រព័ន្ធ(មីនាឆ្នាំ ២០០២)
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណកម្មការសុរិយោដី។

# ជំពូកទី ២
# ប្រជាករ និង រចនាសម្ព័ន្ធប្រជាសាស្ត្រ

## ២.១.  លក្ខណៈទូទៅ

ប្រជាជនកម្ពុជាទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ ដោយសារសង្គ្រាម អសន្តិសុខសង្គម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ មុនសង្គ្រាមលោកលើកទីពីរ ចំនួនប្រជាជនកម្ពុជាមានមិនដល់៣ លាននាក់ផង។ យោងតាមជំរឿនប្រជាជននៅក្នុងឆ្នាំ១៩៦២ ប្រជាជនកម្ពុជាមានចំនួន ៥,៧លាននាក់ ។ លោក **ព្រុដខោម** ប៉ាន់ស្មានចំនួនប្រជាជនកម្ពុជាស្មើនឹង ៦,៩លាននាក់ នៅក្នុងឆ្នាំ ១៩៧០ និង ៧,៩លាននាក់ នៅក្នុងឆ្នាំ ១៩៧៥។ នៅក្នុងឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាត្រូវបានប៉ាន់ស្មានថាមានចំនួន ៦,៣លាននាក់ ។ យោងតាមអង្កេតប្រជាសាស្ត្រឆ្នាំ ១៩៨០ ចំនួនប្រជាជនកម្ពុជាត្រូវបានប៉ាន់ស្មានថាមានចំនួន ៦,៥លាននាក់ ។ ប្រការនេះមានន័យថាប្រជាជនកម្ពុជាជាង ១លាននាក់ ត្រូវបានបាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត។

*តារាងទី២.១-ចំនួនប្រជាជនកម្ពុជា*

| ឆ្នាំ | ចំនួនប្រជាជន | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ប្រជាជនសរុប | បុរស | ស្ត្រី | |
| ១៩២០ | ២៦០០០០០ | | | |
| ១៩៦២ | ៥៧២៨៧៧១ | ២៨៦២៩៣៩ | ២៨៦៥៨៣២ | ជំរឿនប្រជាជន |
| ១៩៧០ | ៦៨០០០០០ | | | |
| ១៩៧៥ | ៧៩០០០០០ | | | |
| ១៩៨០ | ៦៥៨៩៩៥៤ | ៣០៤៩៤៥០ | ៣៥៤០៥០៤ | ការអង្កេតប្រជាជនទូទៅ |
| ១៩៩៣-៩៤ | ៩៨៧០០០០ | ៤៧១៤០០០ | ៥១៥៦០០០ | ការអង្កេតសេដ្ឋកិច្ចសង្គម |
| ១៩៩៦ | ១០៧០២៣២៩ | ៥១១៩៥៨៧ | ៥៥៨២៧៤២ | ការអង្កេតប្រជាសាស្ត្រ |
| ១៩៩៨ | ១១៤៣៧៦៥៦ | ៥៥១១៩៥៨៧ | ៥៥៨២៧៤២ | ជំរឿនប្រជាជន |
| ២០០៤ | ១២៨២៤០០០ | ៦១៩៧០០០ | ៦៦២៧០០០ | ការអង្កេតប្រជាសាស្ត្រ |
| ២០០៨ | ១៣៣៨៨៩១០ | ៦៤៩៥៥១២ | ៦៨៩៣៣៩៨ | ជំរឿនប្រជាជន |

*ប្រភព៖Migozzi, Mysliwiec និងជំរឿនប្រជាជនទូទៅនៅកម្ពុជា២០០៨: ចំនួនប្រជាជនសរុបបណ្ដោះអាសន្នវិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ,សីហា២០០៨*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក៏ប៉ុន្តែនៅក្នុងអំឡុងទស្សវត្សរ៍ទី៨០ កម្ពុជាមានអត្រាកំណើតខ្ពស់ជាងគេក្នុងពិភពលោកដែលធ្វើឱ្យចំនួនប្រជាជនកម្ពុជាកើនឡើងវិញដល់កម្រិតមុនសង្គ្រាម ហើយថែមទាំងកើនឡើងច្រើនជាងនោះទៅទៀត។ ជាធម្មតា នៅក្រោយពេលមានសង្គ្រាមគេតែងតែសង្កេតឃើញនូវដំណាក់កាល ***«កំណើនប្រជាជនខ្លាំង»*** ហើយនៅកម្ពុជាដំណាក់កាលនេះកើតមានឡើងនៅក្នុងអំឡុងទស្សវត្សរ៍ទី៨០ ។ តាមទិន្នន័យរបស់អង្គការសហប្រជាជាតិដែលមានភារកិច្ចចុះឈ្មោះជនជាតិកម្ពុជាដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើងទៅដើម្បីរៀបចំការបោះឆ្នោតនៅក្នុងឆ្នាំ ១៩៩៣ អ្នកដែលមានសិទ្ធិទៅបោះឆ្នោតទាំងអស់មានចំនួន៤.៧៦៤.៤៣០ នាក់ ហើយ **អ៊ុនតាក់** បានប៉ាន់ស្មានថា កម្ពុជាមានប្រជាជនចំនួន ៨.៨២០.៧៦៦នាក់ ។ ក៏ប៉ុន្តែការអង្កេតសេដ្ឋកិច្ចសង្គមនៅក្នុងឆ្នាំ១៩៩៣-១៩៩៤ បានប៉ាន់ស្មានថា ប្រជាជនកម្ពុជាមានចំនួន៩,៨លាននាក់ ។ យោងតាមទិន្នន័យនៃជំរឿនប្រជាជននៅក្នុងឆ្នាំ១៩៩៨ កម្ពុជាមានប្រជាជនសរុបចំនួន ១១,៤លាននាក់ ។ មួយទស្សវត្សរ៍កន្លងទៅនេះតាមជំរឿនប្រជាជននៅក្នុងឆ្នាំ ២០០៨ កម្ពុជាមានប្រជាជនសរុបចំនួន១៣,៣លាននាក់ ពោលគឺមានកំណើន ១,៩៥លាននាក់ ក្នុងរយៈពេលដប់ឆ្នាំកន្លងទៅនេះ ។

## ២.២. រចនាសម្ព័ន្ធប្រជាជនតាមអាយុនិងតាមភេទ

*ក្រាហ្វិក ២.១. ពីរ៉ាមីតអាយុ, ១៩៦២–២០០៨*




*ប្រភព៖ ក្រសួងផែនការ*

គេតាងរចនាសម្ព័ន្ធប្រជាជនប្រទេសនីមួយៗដោយរូបពីរ៉ាមីត ដោយឈរលើមូលដ្ឋាននៃអាយុ និងភេទ។ ព្រឹត្តិការណ៍ដែលអាចធ្វើឱ្យពីរ៉ាមីតខូចរាងបានគឺ ទុរភិក្ស សង្គ្រាម របបប្រល័យពូជសាសន៍ជាដើម ។ ចំណែកឯចលនាប្រជាជន ដូចជា ចំណូល ឬ ចំណាកស្រុកដែលមានកម្រិតខ្លាំង ក៏អាចធ្វើឱ្យខូចរាងពីរ៉ាមីតនេះបានដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីរ៉ាមីតប្រជាជនកម្ពុជាបង្ហាញពីផលប៉ះពាល់នៃសង្គ្រាមឆ្នាំ១៩៧០-១៩៧៥ និងរបបប្រល័យពូជសាសន៍ខ្មែរក្រហមរវាងឆ្នាំ ១៩៧៥-១៩៧៩ ដែលក្នុងពេលនោះប្រជាជនកម្ពុជា ដែលទទួលមរណភាពមានកម្រិតខ្ពស់ ជាពិសេសចំពោះបុរស ហើយលទ្ធភាពផ្តល់កំណើតក៏បានថយចុះ។ នៅក្នុងអំឡុងទសវត្សរ៍ទី៨០ អត្រាកំណើតបានកើនឡើងយ៉ាងខ្លាំង ដោយបង្កើតសមាមាត្រដ៏ធំនៃប្រជាជនអាយុ២០ ឆ្នាំ ឬ ក្រោម ២០ឆ្នាំ ដូចបានបង្ហាញពីរ៉ាមីតអាយុ-ភេទ។

ពីរ៉ាមីតនេះរីកបាតយ៉ាងខ្លាំងជាពិសេសពីអាយុ ២០ ឆ្នាំចុះ ហើយឡើងកាន់តែស្តួចឡើងៗចាប់តាំងពីអាយុ៤០ឆ្នាំឡើងទៅ។ ផ្នែកខាងបុរសមានសមាមាត្រទាបជាងស្ត្រី ដែលបង្ហាញឱ្យឃើញថាបុរសត្រូវបានស្លាប់និង ត្រូវបានគេសម្លាប់ច្រើនជាងស្ត្រី។ ប្រការនេះក៏បញ្ជាក់ផងដែរថាមានស្ត្រីមេម៉ាយច្រើននៅក្នុងសង្គមកម្ពុជា។ ៥២%នៃប្រជាជនកម្ពុជាជាស្ត្រី ។ ពីរ៉ាមីតអាយុនៅឆ្នាំ ២០០៨បង្ហាញឱ្យឃើញថាកម្ពុជាមានអត្រាកំណើតខ្ពស់ ជាប្រជាជនក្មេង ដែលក្នុងនោះប្រជាជនកម្ពុជាដែលមានអាយុតិចជាង២០ ឆ្នាំស្មើនឹង ៥៥% ។

## ២.៣. ការវិវត្តចំនួនប្រជាជន

### ២.៣.១. អត្រាកំណើនប្រជាជន

អត្រានៃកំណើនប្រជាជននៅកម្ពុជាបានធ្លាក់ចុះពី២,៤% នៅក្នុងឆ្នាំ១៩៩៨ មកនៅត្រឹម ១,៨១% នៅក្នុងឆ្នាំ ២០០៦ ហើយមកនៅត្រឹម១,៥៤% នៅក្នុងឆ្នាំ២០០៨។ ក៏ប៉ុន្តែអត្រានេះនៅតែខ្ពស់ជាងអត្រាកំណើនប្រជាជនជាមធ្យមនៅអាស៊ីអាគ្នេយ៍ដែលស្មើនឹង ១,៣%។ មានតែប្រទេសឡាវប៉ុណ្ណោះដែលមានកំណើនប្រជាជន១,៧% ចំណែកប្រទេសថៃមានអត្រាកំណើនប្រជាជន០,៥% និងវៀតណាម ១,៤%។ យើងសង្កេតឃើញថាចំនួនសមាជិកគ្រួសារនៃប្រជាជនកម្ពុជាមាននិន្នាការធ្លាក់ចុះទាំងនៅទីក្រុង ទាំងនៅជនបទ។ ប្រជាជនកម្ពុជាមានចំនួន២,៥លានគ្រួសារ ដែលក្នុងនោះ២៩,២% មានស្ត្រីជាមេគ្រួសារ។

### ២.៣.២. អត្រាលទ្ធភាពផ្តល់កំណើត

ប្រជាជនកម្ពុជាអាចរស់នៅបានជាមធ្យម ៥៤,៥ឆ្នាំសម្រាប់បុរស និង ៥៨,៣ឆ្នាំ សម្រាប់ស្ត្រី ។ អត្រាលទ្ធភាពផ្តល់កំណើតត្រូវបានកាត់បន្ថយពីកូន ៦នាក់នៅក្នុងស្ត្រីម្នាក់នៅក្នុងឆ្នាំ១៩៨៤-១៩៨៨ មកនៅត្រឹមកូន ៤នាក់ក្នុងស្ត្រីម្នាក់នៅក្នុងឆ្នាំ ១៩៩៤-១៩៩៨ហើយធ្លាក់ចុះមកនៅត្រឹម ៣,៣៤នៅក្នុងឆ្នាំ ២០០៨ ។ ដោយសារការធ្លាក់ចុះនៃអត្រាលទ្ធភាពផ្តល់កំណើតចំនួនមធ្យមនៃសមាជិកគ្រួសារកម្ពុជាថយចុះពី៥,២នាក់នៅក្នុងឆ្នាំ ១៩៩៨មកនៅត្រឹម ៤,៧នាក់នៅក្នុងឆ្នាំ ២០០៨ ។

### ២.៣.៣. អត្រាមរណភាព

ការបង្កើនវិនិយោគលើវិស័យសុខាភិបាលក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅនេះបានធ្វើឱ្យអត្រាមរណភាពរបស់កុមារថយចុះពី ៩៥លើចំនួនក្មេងកើតរស់ចំនួន១០០.០០០នាក់ នៅក្នុងឆ្នាំ ២០០០ មកនៅត្រឹម ៦៦ លើចំនួនក្មេងកើតរស់ចំនួន១០០.០០០នាក់ នៅក្នុងឆ្នាំ ២០០៥ ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អត្រាមរណភាពកុមារក្រោម៥ឆ្នាំ ត្រូវបានកាត់បន្ថយពី១២៤ លើចំនួនកុមារកើតរស់ចំនួន ១០០.០០០នាក់ នៅក្នុងឆ្នាំ ២០០០មកទៅត្រឹម ៨៣ លើចំនួនក្មេងកើតរស់ចំនួន១០០.០០០នាក់ នៅក្នុងឆ្នាំ ២០០៥។ អត្រាមរណភាពរបស់មាតានៅតែខ្ពស់ដដែល គឺមានចំនួន ៤៧៣ នាក់ ក្នុង១០០.០០០កំណើត ។

## ២.៣.៤. បម្រែបម្រួលដង់ស៊ីតេ

របាយប្រជាជនមានលក្ខណៈមិនស្មើគ្នាទេនៅលើទឹកដីកម្ពុជា។ ការបែងចែកប្រជាជនតាមខេត្តធ្វើឱ្យមានផលវិបាកជារចនាសម្ព័ន្ធទៅលើវិស័យកសិកម្មដែលចែកប្រទេសកម្ពុជាជា«តំបន់ធ្វើស្រែចម្ការ»និង«តំបន់ព្រៃឈើ» ។ ផ្នែកកណ្តាលនៃប្រទេសកម្ពុជាមានប្រជាជនរស់នៅយ៉ាងច្រើនកកកុញ(១១លាននាក់) ក៏ប៉ុន្តែនៅក្នុងតំបន់ជុំវិញ ជាពិសេសតំបន់ព្រៃភ្នំនិង តំបន់ខ្ពង់រាបវិញមានដង់ស៊ីតេយ៉ាងទាប(២លាននាក់) ។

នៅតាមតំបន់ទំនាបកណ្តាល ដង់ស៊ីតេប្រជាជនមានចំនួន២៦១ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េក្នុងឆ្នាំ ២០០៨ ។ នៅតាមតំបន់បឹងទន្លេសាបដង់ស៊ីតេប្រជាជនមានចំនួន៦២ នាក់ នៅតំបន់ឆ្នេរដង់ស៊ីតេប្រជាជនមានចំនួន៨៧ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ នៅតំបន់ភ្នំ និងខ្ពង់រាបដង់ស៊ីតេប្រជាជនមានចំនួនតែ ២២ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េតែប៉ុណ្ណោះ។ ផ្ទៃដីកម្ពុជាតែ៥%តែប៉ុណ្ណោះត្រូវបានប្រើប្រាស់សម្រាប់ដាំដំណាំកសិ-កម្ម។ ដង់ស៊ីតេប្រជាជនមធ្យមស្មើនឹង៧៥នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡាក្នុងឆ្នាំ ២០០៨ បើប្រៀបធៀបទៅនឹង៣៧នាក់នៅក្នុងឆ្នាំ ១៩៨១ហើយកើនដល់ ៦៣ នាក់ក្នុងឆ្នាំ១៩៩៨ ។

## ២.៣.៥. ប្រជាជនក្រុងនិងប្រជាជនជនបទ

*តារាងលេខ២.២- ប្រជាជនក្រុងនិង ជនបទ*

| *ប្រជាជន* | *១៩៦២* | | *១៩៩៨* | | *២០០៨* | |
|---|---|---|---|---|---|---|
| | ប្រជាជន | % | ប្រជាជន | % | ប្រជាជន | % |
| ប្រជាជនសរុប | ៥៧២៨៧៧១ | ១០០ | ១១៤៣៧៦៥៦ | ១០០ | ១៣៣៨៨៩១០ | ១០០ |
| ប្រជាជនក្រុង | ៥៤៦៨៦៥ | ៩,៥ | ១៧៩៥៥៧៥ | ១៥,៧ | ២៦១៤៤៤០ | ១៩,៥ |
| ប្រជាជនជនបទ | ៥១៨១៩០៦ | ៩០,៥ | ៩៦៤២០៨១ | ៨៤,៣ | ១០៧៧៤៤៧០ | ៨០,៥ |

*ប្រភព៖Migozzi, Mysliwiec និងជំរឿនប្រជាជនទូទៅ២០០៨ : ប្រជាជនសរុបបណ្តោះអាសន្នវិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ,សីហា២០០៨.*

កម្ពុជាជាប្រទេសកសិកម្មមានប្រជាជនជនបទច្រើនជាងប្រជាជនក្រុង។ អ្នកស្រុកជនបទភាគច្រើនជាអ្នកធ្វើស្រែ ឬ ធ្វើចម្ការឬ ធ្វើស្រែផងនិងចម្ការផង ។ អត្រាប្រជាជនក្រុងនៅកម្ពុជាមានចំនួនតិចតួចនៅឡើយ។ ក៏ប៉ុន្តែអត្រានេះកើនឡើងយ៉ាងលឿនពី ៩,៥% នៅក្នុងឆ្នាំ១៩៦២ ដល់ ១៥,៧% នៅក្នុងឆ្នាំ ១៩៩៨ ហើយកើនឡើងដល់១៩% នៅក្នុងឆ្នាំ២០០៨ ដោយសារតែមានចលនាចំណាកស្រុកពីជនបទមករស់នៅទីក្រុង ។ ប្រជាជនក្រុងច្រើនប្រកបរបរជំនួញឬ ជាអ្នកដែលមានជំនាញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២.៣.៦. ប្រជាជនសកម្ម

ប្រជាជនសកម្មកម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័យពី៥៥,៥% នៅក្នុងឆ្នាំ ១៩៩៩ ដល់ ៦៥,៥% ក្នុងឆ្នាំ ២០០៤ ហើយចំនួនប្រជាជនសកម្មសរុបស្មើនឹង៨,៨លាននាក់ ។ ទិន្នន័យនេះខ្ពស់ជាងអត្រាប្រជាជនសកម្មនៅក្នុងអំឡុងទស្សវត្សរ៍ដែលស្មើនឹង៤៤% នៅក្នុងឆ្នាំ១៩៦២ ។ ប្រជាជនសកម្មនេះភាគច្រើន(៨៥,៧%) គឺជាអ្នកដែលធ្វើការជាលក្ខណៈគ្រួសារដោយគ្មានកម្រៃ ។ អត្រានិកម្មភាពកើនឡើងពី៥,៣% ដល់៧,១% នៅក្នុងឆ្នាំ ២០០៤ ។

*តារាងលេខ២.៣- ប្រជាជនសកម្មនៅកម្ពុជា*

| ប្រជាជន | ១៩៦២ | | ១៩៩៨ | | ២០០៤ | |
|---|---|---|---|---|---|---|
| | ប្រជាជន | % | ប្រជាជន | % | ប្រជាជន | % |
| ប្រជាជនសរុប | ៥៧២៨៧៧១ | | ១១៤៣៧៦៥៦ | | ១៣៣៨៨០១០ | |
| ប្រជាជនសកម្មសរុប | ២៥០០០០០ | ៤៤% | ៥១១៨៩៤៥ | ៤៥% | ៧០៥៣៣៩៨ | ៥៣% |
| ប្រជាជនសកម្មទីក្រុង | ៤៧៥០០០ | ៨% | ៨៥៧២៣៣ | ៧% | ១២៩១៥១១ | ១០% |
| ប្រជាជនសកម្មជនបទ | ២០២៥០០០ | ៣៥% | ៤២៦១៧១២ | ៣៧% | ៥៧៦១៨៨៧ | ៤៣% |
| *ប្រភព៖Migozzi.ជំរឿនប្រជាជនទូទៅ១៩៩៩.លទ្ធផលវិភាគជំរឿន* | | | | | | |

## ២.៣.៧. ការអភិវឌ្ឍធនធានមនុស្ស

អនក្ខរកម្មមាននិន្នាការធ្លាក់ចុះជាប្រចាំ។ នៅក្នុងឆ្នាំ ១៩៩៨ ប្រជាជនកម្ពុជាពីរភាគបីបាននិយាយថាពួកគេចេះអាននិង ចេះសរសេរ ។ នាពេលបច្ចុប្បន្ននេះអត្រានេះកើនឡើងដល់បីភាគបួន ។ អត្រាអក្ខរកម្មស្ត្រីក្នុងរយៈពេលបានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេល ៦ ឆ្នាំចុងក្រោយនេះពី ៥០% ដល់៧០% ។ អត្រាអក្ខរកម្មកុមារដែលមានអាយុពី១០ ដល់ ១៤ឆ្នាំបានកើនឡើងយ៉ាងលឿនពី ៦៧,៦% នៅក្នុងឆ្នាំ១៩៩៨ ដល់ ៨៧,៦% នៅក្នុងឆ្នាំ២០០៨។ កំណើនដ៏ឆាប់រហ័សនេះបណ្តាលមកពីកំណើននៃការចុះឈ្មោះចូលរៀនរបស់កុមារានិងកុមារីកម្ពុជា ។

ប្រជាជនកម្ពុជាដែលមានទឹកស្អាតប្រើប្រាស់កើនពី២៩% នៅក្នុងឆ្នាំ១៩៩៨ ដល់ ៤៤% នៅក្នុងឆ្នាំ២០០៨ ។ គ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់កើនពី១៤,៥% ដល់២១,៩% ។ គ្រួសារដែលប្រើប្រាស់ចង្កៀងប្រេងកាតថយចុះពី ៨០% មកនៅត្រឹម៦៥% ។

## ២.៣.៨. រចាយប្រជាជនសកម្មតាមវិស័យសេដ្ឋកិច្ច

ប្រជាជនសកម្មប្រមាណ៧៤,២% ប្រកបរបរកសិកម្មនៅក្នុងឆ្នាំ ២០០៤ បើប្រៀបធៀបនឹងចំនួន ៨១% នៅក្នុងឆ្នាំ១៩៦២ ។ មានប្រជាជនសកម្មតែ៧% តែប៉ុណ្ណោះដែលធ្វើការក្នុងវិស័យឧស្សាហកម្មនៅក្នុងឆ្នាំ ២០០៤ បើប្រៀបធៀបនឹង៤% នៅក្នុងឆ្នាំ១៩៦២ ។ វិស័យសេវាកម្មគឺជាវិស័យធំជាងគេបន្ទាប់ពីកសិកម្មមកដែលមានប្រជាជនសកម្មចំនួន១៨,៨% ធ្វើការក្នុងវិស័យនេះបើប្រៀបធៀបនឹង ១៥% នៅក្នុងឆ្នាំ១៩៦២។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាងលេខ២.៤- ផលិតផលសរុបក្នុងស្រុកនិង ការបែងចែកពលកម្ម*

| វិស័យ | ១៩៦២ | | ១៩៩៨ | | ២០០៨ | |
|---|---|---|---|---|---|---|
| | %GDP | កម្លាំងពលកម្ម | %GDP | កម្លាំងពលកម្ម | %GDP | កម្លាំងពលកម្ម |
| វិស័យទីមួយ | ៤៩ | ៨១ | ៤៤,៥ | ៤៤,៥ | ៣២,៤ | ៧២,៣ |
| វិស័យទីពីរ | ១៩ | ៤ | ១៦,៧ | ១៦,៧ | ២២,៤ | ៨,៥ |
| វិស័យទីបី | ៣២ | ១៥ | ៣៤,៨ | ៣៤,៨ | ៣៨,៨ | ១៨,២ |

*ប្រភព៖Migozzi,ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,« ជំរឿនប្រជាជនទូទៅនៅកម្ពុជា ១៩៩៩, ការវិភាគលទ្ធផលជំរឿន, របាយការណ៍ទី៣, កម្លាំងពលកម្ម និង អ្នកមានការងារ »*

## ២.៣.៩. ចលនាប្រជាជន

ចំណាកស្រុកអាចប្រព្រឹត្តទៅក្នុងផ្ទៃប្រទេសឬ ទៅក្រៅប្រទេស ។ មូលហេតុសំខាន់នៃចំណាកស្រុកក្នុងផ្ទៃប្រទេសមានដូចតទៅ៖

- គឺការស្វែងរកដីថ្មីធ្វើស្រែចម្ការ។ ប្រជាជនដែលរស់នៅខេត្តជុំវិញបឹងទន្លេសាបភាគច្រើនមានដីកន្លះហិកតា។
- ពេលរដូវទំនេរអស់ការធ្វើស្រែចម្ការអ្នកស្រុកទៅក្រុងដើម្បីធ្វើជាង ធាក់ស៊ីក្លូ រត់ម៉ូតូឌុប ឬទៅព្រៃកាប់អុស ដែលជាចំណាកស្រុកតាមរដូវ។

តាមលទ្ធផលជំរឿនឆ្នាំ១៩៩៨ ប្រជាជនកម្ពុជា ៣,៦លាននាក់ ឬ ៣១,៥% ត្រូវបានចាត់ទុកថាជាជនផ្លាស់ទីលំនៅនៅក្នុងជីវិតរបស់ពួកគេ។ ភាគច្រើននៃចំណាកស្រុកនេះគឺធ្វើឡើងពីតំបន់ជនបទទៅតំបន់ជនបទ(៦៨,២%)។ ការផ្លាស់ប្តូរទីលំនៅទាំងគ្រួសារ (រួមបញ្ចូលទាំងការរៀបការ) មានសមាមាត្រធំជាងគេ(៥០,២%) ហើយការផ្លាស់ប្តូរទីលំនៅដោយមូលហេតុរកការងារធ្វើមានសមាមាត្រធំជាងគេទីពីរ(២២,៦%) ។ ភាគច្រើននៃអ្នកផ្លាស់ប្តូរទីលំនៅចេញពីតំបន់ជនបទគឺបុរសវ័យក្មេង។ កត្តាផ្សេងទៀតរួមមានសម្ពាធនៃប្រជាជនទៅលើដីធ្លីការវិនិយោគតិចតួចលើវិស័យកសិកម្មការបាត់បង់កម្មសិទ្ធិដីធ្លីដោយសារភាពក្រីក្រនិងបញ្ហាផ្សេងៗ។

ចំណាកស្រុកភាគច្រើនគឺប្រជាជនចាកចេញពីតំបន់ជនបទដើម្បីមករស់នៅក្នុងទីក្រុង (៦៨,៩%) ចំណែកឯចំណាកស្រុកពីទីក្រុងទៅរស់នៅតាមទីជនបទមានតិចតួចប៉ុណ្ណោះ(១៣,៩%)។ ចំណាកស្រុករបស់នារីវ័យក្មេងចេញពីទីជនបទទៅតំបន់ទីក្រុងមានការកើនឡើងដោយសារការបង្កើតការងារនៅក្នុងរោងចក្រកាត់ដេរ។ ចំណាកស្រុកចូលទីក្រុងអាចឱ្យអ្នកចំណាកស្រុកផ្ញើប្រាក់ទៅឱ្យគ្រួសារគេនៅតំបន់ជនបទដែលបង្កលក្ខណៈសម្រាប់ការបង្កើនផលិតភាពកសិកម្មនិងបង្កើនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច។ ក៏ប៉ុន្តែ ចំណាកស្រុកចូលទីក្រុងនាំឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃការតាំងទីលំនៅបណ្តោះអាសន្ន និងមិនស្រប-ច្បាប់កាន់តែមានលក្ខណៈធ្ងន់ធ្ងរថែមទៀត ។

## ២.៤. ស្ថានភាពសេដ្ឋកិច្ចសង្គមនៃប្រជាជនកម្ពុជា

## ២.៥. គោលនយោបាយប្រជាជន

គោលនយោបាយជាតិសម្រាប់ប្រជាជន មានគោលដៅស្វែងរកការផ្លាស់ប្តូរនៃនិន្នាការប្រជាជន ដើម្បីឱ្យទំហំសមាសភាពនិងរបាយប្រជាជនមានលក្ខណៈសមស្របជាមួយនឹងតម្រូវការនៃការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការកែលម្អគុណភាពនៃជីវភាពរបស់ប្រជាជនកម្ពុជា។ គោលនយោបាយជាតិប្រជាជនមានទិសដៅចម្បងៗដូចតទៅ៖

- គាំទ្រដល់គូស្វាមីភរិយានិងបុគ្គលម្នាក់ៗឱ្យធ្វើការសម្រេចចិត្តដោយសេរីនិងដោយទទួលខុសត្រូវលើចំនួនកូននិងការពន្យារកំណើត ហើយឱ្យទទួលបាននូវព័ត៌មានការអប់រំ សេវាកម្មនានា និងមធ្យោបាយ ដើម្បីអនុវត្តការសម្រេចចិត្តខាងលើ
- កាត់បន្ថយអត្រាមរណភាពនិងជំងឺដម្កាត់របស់ទារកកុមារ និងមាតា
- កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃការផ្លាស់ប្តូរទីលំនៅរវាងទីក្រុងនិងជនបទ
- លើកកម្ពស់សមភាពនិងសមធម៌យេនឌ័រ និងការអភិវឌ្ឍធនធានមនុស្ស
- កាត់បន្ថយផលប៉ះពាល់នៃសម្ពាធប្រជាជនទៅលើបរិស្ថាននិងធនធានធម្មជាតិ
- ពង្រឹងការទប់ស្កាត់ការវិលត្រឡប់មកវិញនៃការរីករាលដាលនៃមេរោគហ៊ីវនិងជំងឺអេដស៍
- បញ្ចូលអថេរប្រជាជនទៅក្នុងគោលនយោបាយសេដ្ឋកិច្ចនិងសង្គមកិច្ច នៅគ្រប់កម្រិតទាំងអស់នៃផែនការ និង កម្មវិធី ។

## ២.៦. គោលនយោបាយស្តីពីការងារនិងសុខមាលភាពសង្គម

## ២.៧. ជនជាតនានានៅប្រទេសកម្ពុជា

ក្នុងចំណោមប្រជាជនកម្ពុជាមានជនជាតិជាច្រើន ដូចជាជនជាតិខ្មែរ-ចិន វៀតណាម ខ្មែរ-អ៊ីស្លាម កុលសម្ព័ន្ធជនជាតិដើមភាគតិចអ្នកចំណូលស្រុកដែលមករស់នៅកម្ពុជាជាប់តែម្តងនិងអ្នកចំណូលស្រុកដែលមកនៅមិនឋិតថេរ។

### ២.៧.១. ខ្មែរ

ប្រជាជនកម្ពុជាប្រមាណ៩០% ជាជនជាតិខ្មែរដែលស្ថិតនៅក្នុងក្រុមអូស្ត្រូ-អាស៊ីដែលមកតាំងទីលំនៅ នៅអាស៊ីភាគអាគ្នេយ៍តាំងតែពីសម័យបុរេប្រវត្តិមកម្ល៉េះ។

### ២.៧.២. ចិន

ចំណាកស្រុករបស់ចិនមកកម្ពុជាចាប់ផ្តើមតាំងពីសតវត្សរ៍ទី១ មកម្ល៉េះ ដោយឆ្លងកាត់តាមភូមិសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ដែលជាកំពង់ផែដែលជនជាតិចិនធ្វើជំនួញជាមួយនឹងនគរហ្វូណនរបស់

អាណាចក្រខ្មែរ។ ចំណាកស្រុកនេះបន្តនៅក្នុងសតវត្សរ៍ទី៦ សតវត្សរ៍ទី១៣ សតវត្សរ៍ទី១៨និង សតវត្សរ៍ទី២០ទៀត ។ នៅឆ្នាំ១២៩៦- ១២៩៧លោក ជីវ តាក្វាន់បានសរសេរថា៖«*អ្នកធ្វើដំណើរតាមសំពៅជនជាតិចិនតែងតែភៀសខ្លួនមកតំបន់នេះ(កម្ពុជា)។ អ្នកទាំងនេះមិនបានបង្កើតសហគមន៍សម្រាប់រស់នៅឱ្យបានត្រឹមត្រូវដោយខ្លួនឯងឡើយ ប៉ុន្តែផ្ទុយទៅវិញពួកគេបានចូលទៅរស់នៅក្នុងសង្គមកម្ពុជា ជាពិសេសកន្លែងណាដែលងាយស្រួលក្នុងការរកផលប្រយោជន៍ ដូចជាចំណីអាហារស្ត្រី ទីស្នាក់អាស្រ័យគ្រឿងសង្ហារិម និងជំនួញ*» ។ សន្ធិសញ្ញាដែលបានចុះហត្ថលេខានៅឆ្នាំ១៨៦០ មុនពេលបង្កើតឡើងនូវរបបអាណាព្យាបាលបារាំងនៅកម្ពុជាបានបើកចំហឱ្យមានការធ្វើដំណើរអន្តោប្រវេសន៍ពីសំណាក់ជនជាតិចិនថ្មីៗច្រើនទៀតដែលជាប្រការធ្វើឱ្យមានជនជាតិចិនកាន់តែច្រើននៅកម្ពុជា។

ជនជាតិចិននៅកម្ពុជាមាន ៥ក្រុមធំៗ ដែលមកពីប្រទេសចិនភាគខាងត្បូង៖ ចិនកន្តាំង ចិនហៃណាំ ចិនខិ(ហាក់កា) ចិនហុកកៀននិង ចិនទាជីវ(ហានសុខុម-២០០៩) ។ មកដល់ឆ្នាំ ១៨៨៤ ចិនហៃណាំនិង ចិនហុកកៀនមានសហគមន៍យ៉ាងសកម្មជាច្រើននៅទីក្រុងភ្នំពេញ។

តាមការប៉ាន់ស្មាននៅក្នុងអំឡុងទសវត្សរ៍ទី៧០ សហគមន៍អ៊ីស្លាមកម្ពុជា ជនជាតិចិនមានចំនួន ១៥០.០០០នាក់ ។ ជនជាតិចិនចូលចិត្តប្រកបរបរពាណិជ្ជកម្មនិងក្តោបក្តាប់នូវសកម្មភាពសេដ្ឋកិច្ចធំៗនៅកម្ពុជា ។ ក៏ប៉ុន្តែក៏មានជនជាតិចិននិងចិនកាត់ខ្មែរជាច្រើនដែលប្រកបមុខរបរជាកសិករនៅខេត្តបាត់ដំបង ខេត្តកណ្តាល ខេត្តកំពង់ធំ ខេត្តតាកែវ និង ខេត្តព្រៃវែងជាដើម។

### ២.៧.៣. វៀតណាម

ចំណាកស្រុករបស់ជនជាតិវៀតណាមមកកម្ពុជាកើនឡើងជាពិសេសចាប់ពីសតវត្សរ៍ទី១៧ ជាមួយនឹង«ដំណើរឆ្ពោះទៅទិសខាងត្បូង»ដែលជាគោលនយោបាយបញ្ជូនជនជាតិវៀតណាមទៅរស់នៅក្នុងដីសណ្តទន្លេមេគង្គដើម្បីប្រកបមុខរបរកសិកម្មលើដីមានជីជាតិ។ ម្យ៉ាងវិញទៀតជនជាតិវៀតណាមចូលចិត្តមកតាំងទីលំនៅតាមច្រាំងទន្លេនិងនៅតាមបឹងទន្លេសាបដែលជាកន្លែងសម្បូរត្រី។ គោលនយោបាយ«ដំណើរឆ្ពោះទៅទិសខាងត្បូង» នេះត្រូវបានបញ្ឈប់ដោយការបង្កើតអាណាព្យាបាលបារាំងនៅក្នុងឆ្នាំ១៨៦៣ ។ ក៏ប៉ុន្តែនៅក្នុងសតវត្សរ៍ទី១៩ ជនជាតិវៀតណាមបន្តចូលមកកម្ពុជាដោយតាំងទីលំនៅជាកសិករ ឬបង្កើតភូមិនេសាទនៅជុំវិញបឹងទន្លេសាប និង តាមបណ្តោយដងទន្លេ ។ ទន្ទឹមនឹងនេះក៏មានជនជាតិវៀតណាមដែលមកតាំងទីលំនៅនៅក្រោយឆ្នាំ១៩៧៩ ផងដែរ ។

ជនជាតិវៀតណាមចូលចិត្តប្រកបមុខរបរនេសាទត្រី សំណង់ ជាងឈើ ជាងភ្លើង ជាងម៉ាស៊ីននិងពាណិជ្ជកម្មតូចតាចជាដើម។

### ២.៧.៤. ខ្មែរអ៊ីស្លាម

តាមស្នាដៃប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញថា ចំណាកស្រុកដំបូងរបស់ជនជាតិចាមមកកម្ពុជាចាប់ផ្តើមឡើងពីចលនាណាមទៀន(ដំណើរឆ្ពោះទៅទិសខាងត្បូង) របស់វៀតណាម ជាពិសេសការវាយយកក្រុងវិជ័យក្នុងឆ្នាំ១៤៧១ ។ នៅចុងសតវត្សរ៍ទី១៥កម្ពុជាគឺជាគោលដៅរបស់មូស្លីមចាមអន្តោប្រវេសន៍ដ៏ច្រើនសន្ធឹកសន្ធាប់ដែលខិតខំរត់គេចចេញពីការត្រួតត្រារបស់វៀតណាមពីព្រោះនៅឆ្នាំ១៤៧១ ស្តេចឡេថាញ់តុង

បានត្រួតត្រាទាំងស្រុងលើប្រទេសចម្ប៉ាបុរាណដែលក្លាយទៅជាដែនដីកូសាំងស៊ីនអណ្ណាម។ ចលនាអន្តោប្រវេសន៍នេះបន្តរហូតដល់ដើមទស្សវត្សរ៍ឆ្នាំ ១៨៣០ ដោយត្រូវបានគេចោទថាជាអ្នកបះបោរប្រឆាំងនឹងជនជាតិវៀតណាមនៅក្នុងរជ្ជកាលព្រះមហាក្សត្រិយានីអង្គម៉ី ។ ជនជាតិចាមគោរពសាសនាអ៊ីស្លាមនិកាយភាគតិចស៊ីអ៊ីតដូចនៅពែក្ស និង ឥណ្ឌាដែរ។ ជនជាតិចាមអនុញ្ញាតឱ្យអ្នកដឹកនាំរបស់ខ្លួនបំពេញនូវកាតព្វកិច្ចសាសនាសំពះព្រះប្រចាំថ្ងៃ និងតមអាហារជំនួសសហគមន៍ទាំងមូល។

សហគមន៍អ៊ីស្លាមកម្ពុជាបែងចែកចេញជាក្រុមជនជាតិសំខាន់ៗដូចតទៅ(ហានសុខុម-២០០៩)៖

- **ជ្វា**ជាក្រុមជនជាតិដ៏សំខាន់ដែលរស់នៅក្នុងឬជុំវិញខេត្តកំពត ដែលមានដើមកំណើតមកពីចាវា (Java)។ ពួកគេមិនចេះនិយាយភាសាចាមទេហើយនិយាយភាសាខ្មែរ និងម៉ាឡេ តិចតួច ។
- ក្រុមខ្មែរអ៊ីស្លាមទី២គឺ **ចាហេដ ឬអ៊ីម៉ាម់ សាន់ ចាម** ដែលមានន័យថារឹងរូសមិនចូលរួមជាមួយអ្នកដទៃដោយសារពួកគេសូត្រធម៌ថ្វាយបង្គំនៅព្រះវិហារតែម្តង(ថ្ងៃសុក្រ) ក្នុងមួយសប្តាហ៍មិនមែន ៥ ដងក្នុងមួយថ្ងៃដូចសាសនិកជនអ៊ីស្លាមកម្ពុជាឡើយ។ ក្រុមនេះហៅខ្លួនគេថា«សាវ័ករបស់អ៊ីម៉ាម់សាន់» ហើយប្រមូលផ្តុំគ្នារស់នៅក្នុងភូមិមួយចំនួននៅជុំវិញឧត្តុង្គខេត្តពោធិ៍សាត់ និងបាត់ដំបង ហើយជាក្រុមបុរាណនិយមខ្លាំងជាងគេដែលនៅរក្សាអក្សរភាសាចាម ។
- **ចាម**ជាក្រុមសាសនិកជនអ៊ីស្លាមភាគច្រើនជាងគេនៅកម្ពុជាដែលសំពះព្រះប្រាំដងក្នុងមួយថ្ងៃ។ ដោយសារក្រុមចាមនេះមានភាគច្រើនលើសលប់គេប្រើពាក្យចាមដើម្បីសំដៅលើសហគមន៍អ៊ីស្លាមកម្ពុជាតែម្តង។ ក្រុមនេះនិយាយទាំងភាសាខ្មែរនិងទាំងភាសាចាម ហើយបានបោះបង់ការប្រើប្រាស់អក្សរចាមហើយ។

ចាមនិងជ្វាសរសេរភាសាម៉ាឡេដោយប្រើអក្សរអារ៉ាប់ «***ហ្សាវី***» ។ ពួកគេឱ្យតម្លៃខ្ពស់លើវប្បធម៌ម៉ាឡេនិង លើការសិក្សាភាសាម៉ាឡេដើម្បីជាយានរៀនសូត្រផ្នែកសាសនា។

តាមការប៉ាន់ស្មាននៅក្នុងអំឡុងទស្សវត្សរ៍ទី៧០ សហគមន៍អ៊ីស្លាមកម្ពុជាមានចំនួន១៥០.០០០នាក់ ។ ពួកគេប្រកបរបរនេសាទជំនួញ ជាពិសេសជំនួញសត្វពាហនៈ(គោ) ។

### ២.៧.៤. *ឡាវ*

ជនជាតិឡាវបានធ្វើចំណាកស្រុកមកកម្ពុជាដោយបានគៀសខ្លួនពីការឈ្លានពានរបស់សៀមនៅសតវត្សរ៍ទី ១៩ ដោយរស់នៅតាមបណ្តោយទន្លេមេគង្គនិងនៅតាមដៃទន្លេ ៣ ទៀតគឺទន្លេសេកុង សេសាន និងស្រែពកក្នុងខេត្តស្ទឹងត្រែង និងខេត្តរតនគិរី ។ ជនជាតិឡាវមួយចំនួនបានចាកចេញពីខេត្តចម្ប៉ាសាក់និងពីតំបន់អត្តពើ មកកាន់ខេត្តរតនគិរី ដែលមានរ៉ែមាសនិងរ៉ែត្បូងមានតម្លៃ។ ក៏ប៉ុន្តែ នៅខេត្តស្វាយរៀងនិងខេត្តព្រៃវែង ក៏មានភូមិឡាវជាច្រើនដែលគេហៅថា«ឡាវលុងសាត» ដែលត្រូវបានកាត់ផ្តាច់ពីប្រទេសខ្លួន។ តាមការប៉ាន់ស្មាន នាពេលបច្ចុប្បន្ននេះជនជាតិឡាវនៅខេត្តស្ទឹងត្រែងនិង ខេត្តមណ្ឌលគិរី មានចំនួនប្រមាណជាង ២២.០០០នាក់ ។

### ២.៧.៦. ថៃ

ជនជាតិថៃបានធ្វើចំណាកស្រុកមកកម្ពុជានៅក្នុងអំឡុងសតវត្សរ៍ទី១៩ និងទី២០ ហើយច្រើនរស់នៅក្នុងខេត្តបន្ទាយមានជ័យ និងខេត្តកោះកុង ។ ជនជាតិថៃរស់នៅខេត្តបន្ទាយមានជ័យប្រកបមុខរបរធ្វើស្រែចម្ការ ហើយខ្លះទៀតទៅរកការងារធ្វើនៅប្រទេសថៃខ្លួនឯង។ ចំណែកឯជនជាតិថៃនៅកោះកុងវិញ(ព្រៃកោងកាង) ច្រើនធ្វើការនេសាទនិង ធ្វើស្រែចម្ការដែរ ។

### ២.៧.៧. ភូមា

ជនជាតិភូមា(កូឡា) មកតាំងទីលំនៅនៅកម្ពុជានៅក្នុងតំបន់ប៉ៃលិនចាប់តាំងពីចុងសតវត្សរ៍ទី ១៩ ដើម្បីប្រកបរបរជីកត្បូង ។ ពួកគេជាឈ្មួញឯកទេសខាងត្បូង។ នៅក្នុងទស្សវត្សរ៍ឆ្នាំទី៦០ មានជនជាតិកូឡាប្រហែល៣.០០០នាក់នៅប៉ៃលិន ដែលនិយាយតែភាសាសានទេ(ហានសុខុម-២០០៩)។

### ២.៧.៨. ជនជាតិដើមតំបន់ខ្ពង់រាប

ជនជាតិដើមតំបន់ខ្ពង់រាបដែលភាសាខ្មែរសាមញ្ញហៅថាខ្មែរលើ ឬ ជនជាតិដើមភាគតិច គឺជាកុលសម្ព័ន្ធជនម្ចាស់ស្រុករស់នៅតាមតំបន់ខ្ពង់រាប ជាពិសេសនៅក្នុងភូមិភាគឦសានដែលមានប្រជាជនកម្ពុជាជាជនជាតិដើមចម្រុះជាច្រើនដូចជា ជនជាតិព្រៅ ចារ៉ាយ កាចក់ ក្រោល ក្រាវ៉ែត គ្រឹង កួយ ពួង ស្មៀង និងទំពួន ។ កុលសម្ព័ន្ធទាំងនេះមានជនជាតិទីទៃពីគ្នាដោយមានភាសាដាច់ដោយឡែកពីគ្នា ហើយរស់នៅខុសប្លែកពីគ្នាទៅតាមទំនៀមទម្លាប់របស់ជនជាតិនីមួយៗ។ ក៏ប៉ុន្តែ ក្រុមជនជាតិដើមមានចំណុចរួមគ្នាគឺគេរស់នៅក្នុងតំបន់ខ្ពង់រាបនិងមានជំនឿថា បរិស្ថានធម្មជាតិទាំងមូលដោយមានមេឃ ដី ព្រៃឈើ ប្រភពទឹក ភ្នំ ផ្ទាំងថ្ម និងស្រែចម្ការសុទ្ធតែមានបារមីឬ ព្រលឹងជាច្រើនរស់នៅ(ហានសុខុម-២០០៩ទំព័រ ៤៦០)។

លោក **ហ្វ្រេឌ្រិក បួរឌីយេ** (Frédéric Bourdier) (CAS, 2009) បានធ្វើចំណាត់ថ្នាក់នូវជនជាតិដើមតំបន់ខ្ពង់រាបតាមចំណាត់ថ្នាក់ភូមិវិទ្យាភាសារបស់ជនជាតិដើមធំៗដោយប្រើប្រាស់បទដ្ឋានចំណាត់ថ្នាក់អាមេរិកដូចតទៅ៖

*តារាងលេខ ២.៥- ក្រុមជនជាតិនៅកម្ពុជា*

| *ក្រុមជនជាតិ* | *អនុក្រុម* | *ភាសា* | *អម្បូរ* | *ស្ថិតិ* | *ទីតាំង* |
|---|---|---|---|---|---|
| ចារ៉ាយ | ចាម | អូស្ត្រូនេស្យាង | អូស្ត្រូ-ថៃ | ១៤.០០០ | រតនគិរី |
| រដែតិចតួច | ចាម | អូស្ត្រូនេស្យាង | អូស្ត្រូ-ថៃ | ១៥៦ | មណ្ឌលគិរី |
| កាចក់ | បាណាខាងជើង | បាណា | មន-ខ្មែរ | ៣.១៦៥ | រតនគិរី ស្ទឹងត្រែង |
| ទំពួន | បាណាខាងលិច | បាណា | មន-ខ្មែរ | ២៧.៣៣៦ | រតនគិរីនិងមណ្ឌលគិរី ស្ទឹងត្រែង |
| ព្រៅ | បាណាខាងលិច | បាណា | មន-ខ្មែរ | ៧.៤៧៩ | រតនគិរីនិងស្ទឹងត្រែង |
| គ្រឹង | បាណាខាងលិច | បាណា | មន-ខ្មែរ | ១៨.១៩២ | រតនគិរី មណ្ឌលគិរី |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | | | | |
|---|---|---|---|---|---|
| ក្រាវ៉ែត | បាណាខាងលិច | បាណា | មន-ខ្មែរ | ៤.៦៧៦ | រតនគិរីនិងស្ទឹងត្រែង |
| លុន | បាណាខាងលិច | បាណា | មន-ខ្មែរ | ៦៩៤ | រតនគិរី ស្ទឹងត្រែង |
| ព្នង | បាណាខាងត្បូង | បាណា | មន-ខ្មែរ | ១០.៨៣៦ | មណ្ឌលគិរី ស្ទឹងត្រែង |
| ស្មៀង | បាណាខាងត្បូង | បាណា | មន-ខ្មែរ | ៣.៣០០ | ក្រចេះ មណ្ឌលគិរី |
| ក្រោល ? | | បាណា? | មន-ខ្មែរ | ១.៩៦០ | ក្រចេះ មណ្ឌលគិរី |
| មិល ? | ? | បាណា? | មន-ខ្មែរ | ២.១០០ | ក្រចេះ |
| ផង (ព័រនៅថៃ) | ព័រ | ព័រ | មន-ខ្មែរ ? | ១ ០៩១ | ពោធិ៍សាត់ កោះកុង? |
| សម្រែ (សម្រែ សៀមរាប) | | ព័រ | មន-ខ្មែរ ? | | ពោធិ៍សាត់និងកោះកុង |
| ព័រព័រ? | ព័រ | ព័រ | មន-ខ្មែរ | ៨៨៨ | ពោធិ៍សាត់និងកោះកុង |
| ស្អូច | ស្អូច | ព័រ | មន-ខ្មែរ | ១៧៥ | កំពតនិងជួរភ្នំក្រវាញ |
| សួយ | ? | | មន-ខ្មែរ | ១.២០០ | កំពង់ស្ពឺ |
| ខ្មែរខិ | ខ្មែរ | ខ្មែរ | មន-ខ្មែរ | ១.៦០០ | ស្ទឹងត្រែង |
| កួយ- | ខ្មែរ | កាទុ | មន-ខ្មែរ | ១៤.២០០ | ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង |

*ប្រភព:ប្រេ្យឌ្រិកបូរឌីយេ«ទំនាក់ទំនងឆ្លងជាតិសាសន៍និងអត្តភាពជនជាតិដើមនៃប្រទេសកម្ពុជា» នៅក្នុងក្រុមជនជាតិដើមភាគតិចនៅកម្ពុជាក្រោមការដឹកនាំរបស់ហាន សុខុម ភ្នំពេញគ្រឹស្ថានបោះពុម្ពផ្សាយសាស្ត្រា២០០៩*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ផ្នែកទី២
# ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច

ជំពូក៣៖ សមិទ្ធផលម៉ាក្រូសេដ្ឋកិច្ចនិន្នាការជាប្រវត្តសាស្រ្ត និង លក្ខណៈសំខាន់ៗនៃកំណែទម្រង់រចនាសម្ព័ន្ធ

ជំពូក៤៖ វិស័យធនាគារ

ជំពូក៥៖ វិស័យធានារ៉ាប់រង

ជំពូក៦៖ ការអភិវឌ្ឍទីផ្សារមូលធន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី៣
# សមិទ្ធផលម៉ាក្រូសេដ្ឋកិច្ច និន្នាការជាប្រវត្តសាស្ត្រ និងលក្ខណៈសំខាន់ៗនៃកំណែតម្រូវរចនាសម្ព័ន្ធ

## ៣.១. ដំណាក់កាលនៃកំណើនសេដ្ឋកិច្ច

ចាប់តាំងឆ្នាំ១៩៨៩ ប្រទេសកម្ពុជាបានអនុវត្តការកែទម្រង់ជាច្រើន ដើម្បីផ្លាស់ប្តូរពីផែនការប្រមូលផ្តុំមកជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចទីផ្សារវិញ។ ទាំងអស់នេះរួមបញ្ចូលទាំងការអនុវត្តកម្មសិទ្ធិឯកជនទៅលើទ្រព្យសម្បត្តិ សេរីភាវូបនីយកម្មថ្លៃ និងពាណិជ្ជកម្មយ៉ាងលឿន ការធ្វើអោយរូបិយប័ណ្ណអាចដោះដូរបាន ការបើកទូលាយទីផ្សារក្នុងស្រុកដល់ធុរកិច្ចឯកជន ការធ្វើឯកជនភាវូបនីយកម្មក្រុមហ៊ុនរដ្ឋ ការលុបបំបាត់ភាពផ្តាច់មុខក្នុងឧស្សាហកម្មនិងសេវាកម្ម និងកំណែទម្រង់បទដ្ឋានគណនេយ្យ ប្រព័ន្ធពន្ធដារ ប្រព័ន្ធច្បាប់ និងវិស័យហិរញ្ញវត្ថុ។

ការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជាអាចចែកចេញជាដំណាក់កាលបីខុសៗគ្នា៖

- ដំណាក់កាលស្តារនិងនីតិសម្បទា ក្នុងឆ្នាំ១៩៨៩-១៩៩៨
- ដំណាក់កាលស្ថាបនាឡើងវិញ ក្នុងឆ្នាំ១៩៩៩-២០០៣
- ដំណាក់កាលហក់ឡើងនៃសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៤-២០០៨

***ដំណាក់កាលស្តារនិងនីតសម្បទាក្នុងឆ្នាំ១៩៨៩-១៩៩៨៖*** ការកកើតដំបូងនៃសេដ្ឋកិច្ចទីផ្សារត្រូវបានចាប់ផ្តើមបង្កើតឡើង ដោយការទទួលស្គាល់កម្មសិទ្ធិឯកជន ឯកជនភាវូបនីយកម្មនៃក្រុមហ៊ុនរដ្ឋ និងបដិសម្ភូហភាវូបនីយកម្មកសិកម្ម ពោលគឺដើម្បីត្រួសត្រាយផ្លូវសម្រាប់ការផ្សះផ្សារនិងបង្រួបបង្រួមជាតិ និងរៀបចំ ការបោះឆ្នោតសាកលនៅក្នុងឆ្នាំ១៩៩៣។ ប៉ុន្តែ កិច្ចខិតខំប្រឹងប្រែងអនុវត្តកំណែទម្រង់ទីផ្សារជួបនូវបញ្ហា ប្រឈមជាច្រើន ដោយសារអតុល្យភាពម៉ាក្រូសេដ្ឋកិច្ច ដែលបណ្តាលមកពីកត្តាមួយចំនួនដូចខាងក្រោមនេះ (ធនាគារពិភពលោក ឆ្នាំ១៩៩២)៖

- សេរីភាវូបនីយកម្មសេដ្ឋកិច្ច ដែលចាប់ផ្តើមឡើងក្នុងឆ្នាំ១៩៨៩ ធ្វើឱ្យរាំងស្ទះដល់ការប្រមូលចំណូល និងធ្វើអោយថវិកាជាតិបាតិតុល្យភាព។ ឯកជនភាវូបនីយកម្មនិងកំណែទម្រង់សហគ្រាសរដ្ឋ និង សេរីភាវូបនីយកម្មតម្លៃនិងពាណិជ្ជកម្ម បានកាត់បន្ថយចំណូលពុំមែនសារពើពន្ធ ដែលធ្លាប់តែជាប្រភពយ៉ាងសំខាន់សម្រាប់ថវិកាជាតិ។ ការខាតបង់ចំណូលនេះមិនអាចប៉ះប៉ូវបានវិញ ដោយចំណូលសារពើពន្ធ ដែលប្រមូលបានពីវិស័យឯកជនដែលកំពុងងើបឡើងនោះទេ។ ចំណូលថវិកាពីសហគ្រាសសាធារណៈនៅក្នុងចំណូលសរុបនៃថវិកាចរន្ត បានធ្លាក់ចុះពី៣៦% នៃចំណាយសរុបក្នុងឆ្នាំ ១៩៨៩ ដល់ ២២% ក្នុងឆ្នាំ១៩៩១។ ការអនុវត្តពន្ធថ្មីចូលវិភាគទានបានតិចតួចប៉ុណ្ណោះដល់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថវិកា។ ចំណូលមិនមែនពន្ធបានធ្លាក់ចុះពី៥.៥% នៃចំណាយថវិកា ក្នុងឆ្នាំ១៩៨៩ រហូតដល់ក្រោម ១% ក្នុងឆ្នាំ១៩៩១។ ប៉ុន្តែការលុបចោលនូវការលើកលែងពន្ធគយ នាំឱ្យបង្កើនចំណូលពន្ធដារពី ៨.៥% នៃចំណាយថវិកា ក្នុងឆ្នាំ១៩៨៩ ដល់ ៣៧% ក្នុងឆ្នាំ១៩៩១។

*ប្រអប់ ៣.១. "**កុងសង់ស៊ុសទីក្រុងវ៉ាស៊ីនតោន** (Washington Consensus)"*

*កុងសង់ស៊ុសទីក្រុងវ៉ាស៊ីនតោនមានគោលការណ៍ចំនួន១០សម្រាប់គ្រប់គ្រងការរៀបចំនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចៈ*

- ដាក់វិន័យគោលនយោបាយសារពើពន្ធដើម្បីបញ្ចៀសសំពាធអតិផរណា និងការហូរចេញមូលធន
- ការបង្វែរចំណាយសាធារណៈ ពីការឧបត្ថម្ភធន (ជាពិសេសមិនរើសអើងការឧបត្ថម្ភធន") *ឆ្ពោះទៅរកការផ្តល់សេវាជាមូលដ្ឋានធំទូលាយសំខាន់ៗ ដែលផ្តោតលើកំណើនសេដ្ឋកិច្ច និងជនក្រីក្រ (ដូចជា ការអប់រំជាមូលដ្ឋាន ការថែទាំសុខភាពជាមូលដ្ឋាន និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ)*
- កំណែទំរង់សារពើពន្ធ ដោយពង្រីកមូលដ្ឋានពន្ធ និងការអនុម័តអត្រាពន្ធមធ្យម
- អត្រាការប្រាក់វិជ្ជមាន ដើម្បីជំរុញការសន្សំ និងទប់ស្កាត់ការហូរចេញនៃមូលធន
- *អត្រាផ្ទូរប្រាក់ប្រកួតប្រជែង*
- សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងការលុបបំបាត់ការយកពន្ធលើផលិតផលពាក់កណ្តាលសម្រេច នៅក្នុងផលិតកម្មទំនិញសម្រាប់ការនាំចេញ
- សេរីភាវូនីយកម្មនៃលំហូរចូលការវិនិយោគផ្ទាល់ពីបរទេស
- ឯកជនភាវូបនីយកម្មនៃសហគ្រាសរដ្ឋ
- កាត់បន្ថយច្បាប់បញ្ញត្តិ ដើម្បីលុបបំបាត់ឧបសគ្គចូលក្នុងទីផ្សារ ឬចាកចេញពីទីផ្សារ ព្រមទាំងការលុបបំបាត់អោយអស់នូវប្រភពនៃអំពើពុករលួយ
- សុវត្ថិភាពច្បាប់សម្រាប់កម្មសិទ្ធិបញ្ញា

*ប្រភព៖Williamson, J. (២០០២) "What Should the Bank Think About the Washington Consensus?" World Bank Research Observer, Vol. 15, No. 2, August, p. 251-264.*

- ចំពោះខាងផ្នែកចំណាយថវិកា ការលុបចោលការត្រួតពិនិត្យថ្លៃទំនិញបានធ្វើឱ្យថ្លៃទំនិញក្នុងមួយឯកតា ដែលផ្គត់ផ្គង់សម្រាប់បចំណាយប្រតិបត្តិការ និងការវិនិយោគបានកើនឡើងយ៉ាងខ្ពស់។ គោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីជៀសវាងការកាត់បន្ថយប្រាក់បៀវត្សរ៍ និងចំណាយយោធាបានដាក់សម្ពាធលើចំណាយវិនិយោគសាធារណៈចំណាយប្រតិបត្តិការ និងចំណាយថែទាំ។ ចំណែកនៃចំណាយទាំងនេះក្នុងថវិកាបានធ្លាក់ចុះពី៤១% ក្នុងឆ្នាំ១៩៨៩ដល់១៦% ក្នុងឆ្នាំ១៩៩១។
- ការលុបចោលជំនួយឥណទាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មនិងការទូទាត់ឆ្នាំ១៩៨៦-១៩៩០ រវាងកម្ពុជានិងសហភាពសូវៀត។ ជំនួយជាទំនិញប្រើប្រាស់ដែលទទួលបានក្នុងក្របខ័ណ្ឌកិច្ចព្រម



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រៀងមានចំណែកស្មើនឹង ១៥% នៃចំណាយថវិកាក្នុងឆ្នាំ១៩៨៩។ ជំនួយមនុស្សធម៌មានចំនួនត្រឹមតែ ២០-៣០ លានដុល្លារសហរដ្ឋអាមេរិកប៉ុណ្ណោះក្នុងមួយឆ្នាំ ក្នុងឆ្នាំ១៩៩១-១៩៩២។

- ស្ថិតក្នុងកាលទេសៈបែបនេះ រដ្ឋាភិបាលពឹងផ្អែកលើការបោះផ្សាយក្រដាសប្រាក់ ដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិកា។ ការធ្វើហិរញ្ញប្បទានដោយបោះផ្សាយក្រដាសប្រាក់មានចំណែកជាងពាក់កណ្តាលនៃឱនភាពថវិកាក្នុងឆ្នាំ ១៩៩១ ហើយកង្វះខាតសាច់ប្រាក់ស្មើនឹង ២០% នៃថវិកាដែលនៅសេសសល់។ ការបើកប្រាក់បៀវត្សរ៍ក៏មិនបានទៀងទាត់។ ការធ្វើហិរញ្ញប្បទានដោយបោះផ្សាយក្រដាសប្រាក់ បណ្តាលឱ្យមានអតិផរណាខ្ពស់ដែលមានអត្រាជាមធ្យម ៧០% ក្នុងឆ្នាំ១៩៨៩ និង១៥៧% ក្នុងឆ្នាំ១៩៩០ និង១២១% ក្នុងឆ្នាំ១៩៩១។ បញ្ហាទាំងនេះបណ្តាលឱ្យសាធារណៈជនលែងមានការជឿទុកចិត្តមកលើរូបិយវត្ថុជាតិ ដែលជាហេតុធ្វើអោយមានដុល្លារូបនីយកម្មខ្ពស់។

ការបង្កើតរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ១៩៩៣ បានឈានទៅបញ្ចប់ទណ្ឌកម្មសេដ្ឋកិច្ចដែលដាក់មកលើកម្ពុជាតាំងពីឆ្នាំ១៩៧៩មកនោះ និងនាំឱ្យមានការហូរចូលនៃការវិនិយោគផ្ទាល់ពីក្រៅប្រទេសនិងជំនួយអភិវឌ្ឍន៍ផ្លូវការសម្រាប់ការស្តារនីតិសម្បទាសេដ្ឋកិច្ច។ ក្នុងអំឡុងឆ្នាំ១៩៩៣-១៩៩៨ ប្រទេសកម្ពុជានៅមិនទាន់មានសន្តិភាពពេញលេញនៅឡើយទេ។ អាណត្តិដំបូងរបស់រាជរដ្ឋាភិបាលកម្ពុជាមិនអាចផ្តល់អាទិភាពពេញលេញលើការអភិវឌ្ឍសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្របានឡើយ ដោយសារតែរាជរដ្ឋាភិបាលត្រូវប្រយុទ្ធគ្នាជាមួយកងកម្លាំងរបស់ខ្មែរក្រហមដែលមាននៅពាសពេញផ្ទៃប្រទេស។ ចំណាយការពារជាតិនិងសន្តិសុខ មានចំនួន៦.៣%នៃផលិតផលសរុបក្នុងស្រុក (ផសស) ក្នុងឆ្នាំ១៩៩៤ ចំណែកឯចំណាយលើវិស័យសង្គមមានតែ ២.១%ប៉ុណ្ណោះ។ ប៉ុន្តែពេលនោះ ក៏នៅមានការយកចិត្តទុកដាក់ដើម្បីអនុវត្តកំណែទម្រង់ជំនាន់ទីមួយផងដែរ។ អតិផរណាត្រូវបានគ្រប់គ្រងបាន ហើយធ្លាក់ចុះ ពី១២១% នៅឆ្នាំ១៩៩១ មកត្រឹម -០.៧% ក្នុងឆ្នាំ១៩៩៣។ ប្រព័ន្ធថវិកាថ្មីមួយដែលផ្អែកលើមូលដ្ឋានបារាំងត្រូវបានដាក់អោយអនុវត្ត ហើយក្របខ័ណ្ឌគតិយុត្តិសម្រាប់សហគ្រាសសាធារណៈត្រូវបានបង្កើតឡើង។

បន្ទាប់ពីការដាក់អោយអនុវត្តនូវគោលនយោបាយ "**ឈ្នះ-ឈ្នះ**" របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** អង្គការចាត់តាំងនយោបាយនិងយោធារបស់ខ្មែរក្រហម ត្រូវបានរំលាយចោលក្នុងឆ្នាំ១៩៩៨។ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី១បានរៀបចំមូលដ្ឋានគ្រឹះសម្រាប់សន្តិភាព សន្តិសុខនិងកំណើនសេដ្ឋកិច្ចនៅកម្ពុជា។ ទោះបីជាមានបញ្ហាបឈមខ្លះក៏ដោយ កំណើនសេដ្ឋកិច្ចក្នុងអំឡុងឆ្នាំ១៩៩៤-១៩៩៨ សម្រេចបាន ៦.៣% ជាមធ្យម។ កំណើនក្នុងរយៈពេលនេះត្រូវបានផ្តល់ហិរញ្ញប្បទានភាគច្រើន ពីការប្រើប្រាស់ធនធានធម្មជាតិហួសកម្រិត ជំនួយអភិវឌ្ឍន៍ផ្លូវការ និងលំហូរចូលនៃការវិនិយោគផ្ទាល់ពីក្រៅប្រទេស ទៅក្នុងវិស័យហិរញ្ញវត្ថុ។ វិស័យដែលលេចធ្លោជាងគេគឺព្រៃឈើ កៅស៊ូ សេវាសាធារណៈ រដ្ឋបាលសាធារណៈ និងធនាគារ។ តម្លៃបន្ថែមផ្នែកព្រៃឈើបានកើនឡើងជាមធ្យម១៧.២% ក្នុងមួយឆ្នាំ ដោយផលិតផលឈើ ក្រដាស និងការបោះពុម្ពផ្សាយបានកើនឡើង២២.៩% ក្នុងមួយឆ្នាំ។ ការផលិតកៅស៊ូបានកើនឡើង២១.៩%។ ក្នុងអំឡុងឆ្នាំ១៩៩៤-១៩៩៨ ភាគច្រើននៃជំនួយអភិវឌ្ឍន៍ផ្លូវការត្រូវបានយកមកប្រើប្រាស់ ដើម្បីស្តារឡើងវិញនូវសមត្ថភាពទាញយកថាមពលអគ្គិសនី និងការផ្គត់ផ្គង់ទឹក។ អគ្គិសនី ឧស្ម័ន និងទឹក ដែលជាអនុវិស័យនៃការផលិតបានកើនឡើងនៅអត្រាមធ្យមប្រចាំឆ្នាំ១៤.៩%។ រដ្ឋបាលសាធារណៈបានកើនឡើងចំនួន ២០.៨% ហើយវិស័យហិរញ្ញវត្ថុបានកើនឡើង ៣៨.៥%។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ដំណាក់កាលស្តាបនាឡើងវិញក្នុងឆ្នាំ១៩៩៩-២០០៣៖** ប្រទេសកម្ពុជាទទួលជោគជ័យក្នុងការអនុវត្ត យុទ្ធសាស្ត្រត្រីកោណ ដែលបានអនុម័តដោយរដ្ឋាភិបាលនីតិកាលទី២ (ឆ្នាំ១៩៩៩-២០០៣)។ ស្ថេរភាពនយោបាយត្រូវបានស្តារឡើងវិញនិងស្ថាប័នប្រជាធិបតេយ្យត្រូវបានបង្កើតឡើង។ ដំណាក់កាលនេះបានបង្កើតកាលានុវត្តភាព ដែលមិនធ្លាប់មានសម្រាប់កំណែទម្រង់សេដ្ឋកិច្ចនិងវឌ្ឍនភាពសង្គម។ កម្ពុជាត្រូវបានអន្តរជាតិទទួលស្គាល់ខ្លួនឡើងវិញ បន្ទាប់ពីព្រឹត្តិការណ៍ប្រយុទ្ធគ្នានៅក្នុងខែកក្កដាឆ្នាំ១៩៩៧ ហើយកម្ពុជាបានទទួលមកវិញនូវអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិក្នុងខែធ្នូឆ្នាំ១៩៩៨ និងបានចូលជាសមាជិកផ្លូវការរបស់អាស៊ាននៅក្នុងខែមេសាឆ្នាំ១៩៩៩។ កម្ពុជាចាប់ផ្តើមធ្វើកំណែទម្រង់ទ្រង់ទ្រាយធំ ដោយផ្តោតលើការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិស័យធនាគារនិងហិរញ្ញវត្ថុ និងការស្តារនីតិសម្បទា និងស្តាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលជាបណ្តាញផ្លូវជាតិ។ កំណែទម្រង់សេដ្ឋកិច្ចដែលរាជរដ្ឋាភិបាលអនុវត្តក្នុងឆ្នាំ១៩៩៩-២០០៣ ជាពិសេសការពង្រឹងកំណែទម្រង់ទីផ្សារទៅតាមទ្រឹស្តីសេរីភាវូបនីយកម្មសេដ្ឋកិច្ច ក្នុងគោលដៅធានាការអភិវឌ្ឍប្រកបដោយចីរភាព និងកំណើនសេដ្ឋកិច្ចខ្ពស់។ អភិក្រមសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនេះសង្កត់ធ្ងន់លើកំណែទម្រង់ម៉ាក្រូសេដ្ឋកិច្ចយុទ្ធសាស្ត្រកំណើនដោយផ្អែកលើការនាំចេញ និងគុណភាពនៃស្ថាប័ន ដូចឃើញមាននៅតាមបណ្តាប្រទេសមួយចំនួននៅអាស៊ីបូព៌ា ជាពិសេសការគោរពវិន័យថវិកាដ៏មឺុងម៉ាត់ ការពង្រឹងប្រព័ន្ធតុលាការ ផលិតភាពពលកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការរក្សាអត្រាប្តូរប្រាក់ឱ្យមានលក្ខណៈប្រកួតប្រជែង ការធ្វើឱ្យមានការទាក់ទាញដល់វិនិយោគិនក្រៅប្រទេស ការលើកកម្ពស់ការនាំចេញ និងសមាហរណកម្មចូលក្នុងសេដ្ឋកិច្ចក្នុងតំបន់ និងសកលលោក។

កំណើនសេដ្ឋកិច្ចនៅអំឡុងឆ្នាំ១៩៩៩-២០០៣ សម្រេចបានជាមធ្យម៨.៨%។ ទោះបីជាជំនួយអភិវឌ្ឍន៍ផ្លូវការបន្តផ្គត់ផ្គង់ដល់កំណើនយ៉ាងណាក្តី ការវិនិយោគផ្ទាល់ពីក្រៅប្រទេស ជាពិសេសក្នុងផ្នែកកាត់ដេរនិងទេសចរណ៍ គឺជាកូនសោរសម្រាប់ជំរុញកំណើន។ វិស័យដែលលេចធ្លោរជាងគេមានស្រូវអង្ករនិងផលិតកម្មដំណាំរួមផ្សំ សេវាសាធារណៈ សំណង់ ទេសចរណ៍ ទូរគមនាគមន៍ ការដឹកជញ្ជូន និងអចលនវត្ថុ។ ការធ្លាក់ចុះនៃតម្លៃបន្ថែមដែលបណ្តាលមកពីផ្នែករុក្ខាប្រមាញ់ ត្រូវប៉ះប៉ូវមកវិញបានដោយសារលក្ខណៈល្អប្រសើរខាងផលិតកម្មស្រូវនិងដំណាំរួមផ្សំ ដែលកើនឡើងជាមធ្យម៦.៨%ក្នុងមួយឆ្នាំ។ វិស័យវាយនភ័ណ្ឌបានកើនឡើងចំនួន ៣៥.១% ក្នុងមួយឆ្នាំ។ ការបន្តស្តារនីតិសម្បទាខាងផ្នែកថាមពលអគ្គិសនីនិងទឹក ធ្វើឱ្យអនុវិស័យអគ្គិសនីឧស្ម័ននិងទឹកកើនឡើងជាមធ្យម១០.២%ក្នុងមួយឆ្នាំ។វិស័យសំណង់ក្លាយជាសសរទ្រូងនៃកំណើន ដោយកើនឡើងជាមធ្យម ២០.១%។ សន្តិភាពដែលបានបង្កើតឱ្យមានឡើងវិញនេះជួយដល់ការអភិវឌ្ឍយ៉ាងឆាប់រហ័សខាងទេសចរណ៍ ដោយវិស័យនេះកើនឡើងជាមធ្យម ១៣.៦%ក្នុងមួយឆ្នាំ។ ទន្ទឹមនឹងនេះ អនុវិស័យទូរស័ព្ទចល័តក៏មានការវិវឌ្ឍខ្លាំងផងដែរ។ ចំណែកឯវិស័យដឹកជញ្ជូននិងទូរគមនាគមន៍បានកើនឡើងជាមធ្យម ១២.១%ក្នុងមួយឆ្នាំ។ ផ្នែកអចលនវត្ថុក៏កើនឡើងយ៉ាងឆាប់រហ័សដោយកើនដល់ ១២.១% នៅដើមដំបូងពេលមានការចម្រើនលូតលាស់ខ្លាំងក្នុងផ្នែកអចលនវត្ថុ។

**ដំណាក់កាលហក់ឡើងនៃសេដ្ឋកិច្ចក្នុងឆ្នាំ២០០៤-២០០៨៖** រាជរដ្ឋាភិបាលកម្ពុជាប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីអនុវត្តកំណែទម្រង់ជំនាន់ទី២ ដូចដែលមានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ជាពិសេសការអនុវត្តដំណាក់កាលទី១នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការបន្ត វិនិយោគក្នុងការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្ពានថ្នល់នៅតាមខេត្តនិងទីជនបទ។ កំណើនសេដ្ឋកិច្ចក្នុងអំឡុងឆ្នាំ២០០៤-២០០៨សម្រេចបានជាមធ្យម១០.៣%។ ប្រការនេះ គឺជាលើកទីមួយហើយ ដែលប្រទេសកម្ពុជាសម្រេចបានកំណើនលេខពីរខ្ទង់ ដែលកំណើននេះបានមកពីហិរញ្ញប្បទានវិស័យធនាគារ ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស និងលំហូរការវិនិយោគផ្ទាល់ពីក្រៅប្រទេស។ វិស័យដែលលេចធ្លោរជាងគេមានផ្នែកស្រូវអង្ករនិងដំណាំរួមផ្សំ (កំណើនប្រចាំឆ្នាំជាមធ្យម៩.៧%) អាជីវកម្មរ៉ែ (១៨.២%) វាយនភ័ណ្ឌ (១៦.១%) សេវាសាធារណៈ (១៦.៧%) សំណង់ (១៥.៥%) ទេសចរណ៍ (១៧.៤%) ទូរគមនាគមន៍និងដឹកជញ្ជូន (៨.៣%) ហិរញ្ញវត្ថុ (២១.៦%) និងអចលនវត្ថុ (១២.៤%)។

## ៣.១.១. បម្រែបម្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ច

ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចបានល្អរបស់ប្រទេសកម្ពុជា ត្រូវបានឆ្លុះបញ្ចាំងក្នុងកំណើនសេដ្ឋកិច្ច ដែលមានជាមធ្យម៩.៥% ក្នុងទសវត្សរ៍កន្លងទៅ និង១០.៣% ក្នុងអំឡុងឆ្នាំ២០០៣ ដល់ឆ្នាំ២០០៨ និងកើនឡើងខ្ពស់គួរឱ្យកត់សម្គាល់រហូតដល់១៣.៣% ក្នុងឆ្នាំ២០០៥។

យោងតាមការសិក្សាមួយរបស់ធនាគារពិភពលោក ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេស១៥ ដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនជាងគេនៅក្នុងពិភពលោកក្នុងឆ្នាំ១៩៩៨-២០០៧ ដោយនាំមុខប្រទេសចិនបន្តិច និងមានកំណើនលើសប្រទេសអាស៊ីប៉ាស៊ីហ្វិកក្នុងអត្រាមធ្យម ៨.៤%។ ប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនជាងកម្ពុជាដូចជា ហ្គីណេអេគីតូរីយ៉ាល់ អាហ្សែបាយហ្សង់ និងអង់ហ្គោឡាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ដោយសារប្រទេសទាំងនោះ ជាប្រទេសធ្វើអាជីវកម្មលើធនធានធម្មជាតិ។

*គំនូសតាង៣.១ ប្រទេសកម្ពុជាប្រទេសមួយក្នុងចំណោមប្រទេសមានកំណើនសេដ្ឋកិច្ចលឿនជាងគេ*




*ប្រភព៖ ធនាគារពិភពលោក*

លក្ខណៈសំខាន់ពីរនៃការអនុវត្តសេដ្ឋកិច្ចក្នុងឆ្នាំថ្មីៗនេះ គឺការកើនឡើងនៃពិពិធកម្មនៃវិស័យដែលជួយដល់កំណើនសេដ្ឋកិច្ច និងវិភាគទានយ៉ាងសំខាន់ពីវិស័យកសិកម្មដល់កំណើនសេដ្ឋកិច្ចនេះ។ ការអនុវត្តនេះគឺដោយសារតែរាជរដ្ឋាភិបាលបានវិនិយោគយ៉ាងច្រើនក្នុងវិស័យកសិកម្ម និងកាត់ដេរ។

ទោះជាយ៉ាងនេះក្តីកំណើនមិនមែនមានតែក្នុងវិស័យទាំងនេះប៉ុណ្ណោះទេ។ វិស័យទេសចរណ៍និងសំណង់ក៏ជាសសរស្តម្ភនៃកំណើនសេដ្ឋកិច្ចដ៏សំខាន់មួយផងដែរ។ ជារួម ប្រភពសំខាន់ៗនៃកំណើនសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះ គឺបានមកពីវិភាគទានប្រកបដោយតុល្យភាពពីវិស័យកសិកម្ម កម្មន្តសាល សំណង់ និងសេវា។ ប្រការនេះបានបង្ហាញយ៉ាងច្បាស់ក្នុងឆ្នាំ២០០៧។

ក្នុងអំឡុងពេល៥ឆ្នាំនៃអាណត្តិទី២ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចលើសពីគោលដៅកំណើនសេដ្ឋកិច្ចពី ៦ ទៅ ៧%។ កំណើនផលិតផលក្នុងស្រុកសរុបសម្រេចបានជាមធ្យម ៨.៨% ក្នុងអំឡុងឆ្នាំ ១៩៩៩-២០០៣ ទោះបីជាមានគ្រោះធម្មជាតិ ដូចជាទឹកជំនន់ផ្ទួនៗគ្នា និងគ្រោះរាំងស្ងួតយ៉ាងណាក៏ដោយ។

*គំនូសតាង៣.២សមិទ្ធផលនៃកំណើនសេដ្ឋកិច្ចឆ្នាំ១៩៩៤-២០១២*




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ*

ជារួម កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងមួយទសវត្សរ៍កន្លងទៅនេះ បានលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ការប្រើប្រាស់ជាមធ្យមក្នុងមនុស្សម្នាក់ៗកើនឡើង ៣២% ក្នុងចន្លោះឆ្នាំ១៩៩៤ និង២០០៤។ ការទទួលបានកម្រិតកាឡូរីក្នុងមនុស្សម្នាក់ៗកើនឡើងថេរ និងឡើងដល់២៩៣២កាឡូរីក្នុងមួយថ្ងៃក្នុងឆ្នាំ២០០៤។ នៅភ្នំពេញនិងទីប្រជុំជនដទៃទៀត ការកើនឡើងនេះមានល្បឿនលឿន។ ប៉ុន្តែការកាត់បន្ថយភាពក្រីក្រដើរតាមមិនទាន់ល្បឿននៃកំណើននេះទេ។ នេះសបញ្ជាក់ឱ្យឃើញថានៅក្នុងប្រទេសកម្ពុជា វិសមភាពបានកើនឡើង។

ទនឹងនឹងនេះ យើងមានការកត់សម្គាល់ខាងក្រោមនេះ៖

- កម្លាំងចលករសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រគឺកំណើនសេដ្ឋកិច្ច។ ហើយមានតែកំណើនតែប៉ុណ្ណោះដែលអាចនាំឱ្យមានភាពប្រសើរឡើងនៃសូចនាករសង្គម ដូចជាអត្រាមរណភាពរបស់ទារក និងការចុះឈ្មោះចូលរៀន។
- ប៉ុន្តែកំណើនដែលជាលក្ខខណ្ឌចាំបាច់នោះ នៅតែពុំមានគ្រប់គ្រាន់សម្រាប់ស្ថេរភាពសង្គមនៅឡើយ។ ការកាត់បន្ថយភាពក្រីក្រត្រូវតែធ្វើឡើងទន្ទឹមគ្នានឹងការកើនឡើងនៃសមធម៌ក្នុងការទទួលប្រាក់ចំណូល និងការបែងចែកធនធាន។

ទោះបីសេដ្ឋកិច្ចមានការរីកចម្រើនខ្លាំង កង្វះអាហាររូបត្ថម្ភក្នុងវ័យកុមារភាពនៅតែបន្តមាន។ ប្រការនេះសបញ្ជាក់ឱ្យឃើញថា រាជរដ្ឋាភិបាលមិនទាន់អាចពេញចិត្តចំពោះកំណើនខ្ពស់នេះបានទេ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាង៣.១កម្ពុជា៖សូចនាករម៉ាក្រូសេដ្ឋកិច្ច២០០១-២០០៨*

| | ៩៨ | ៩៩ | ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ | ០៧ | ០៨ |
|---|---|---|---|---|---|---|---|---|---|---|
| វិស័យពិត | | | | | | | | | | |
| ផសសពិត (%កំណើន) | ៩.១ | ១១.៩ | ៨.១ | ៦.៦ | ៨.៥ | ១០.៣ | ១៣.៣ | ១០.៨ | ១០.២ | ៦.៧ |
| - កសិកម្ម | ៩.៧ | ២.២ | ៣.៦ | -២.៥ | ១០.៥ | -០.៩ | ១៥.៧ | ៥.៥ | ៥.០ | ៥.៧ |
| - ឧស្សាហកម្ម | ១៤.២ | ២១.២ | ១១.២ | ១៧.១ | ១២.០ | ១៦.៦ | ១២.៧ | ១៨.៣ | ៨.៤ | ៤.០ |
| - សេវា | ០.៦ | ១៤.៦ | ១១.១ | ៧.៧ | ៥.៩ | ១៣.២ | ១៣.១ | ១០.១ | ១០.១ | ៩.០ |
| ផសសក្នុងមនុស្សម្នាក់ៗ | ២៤៨ | ២៨១ | ៣១២ | ៣៣១ | ៣៥៦ | ៤០២ | ៤៦៨ | ៥៣៤ | ៦២៣ | ៧៣៩ |
| ការសន្សំក្នុងស្រុក (មិនបានផ្ទេរ) | | | ៨.២ | ៤.៣ | ១.៨ | ៣.៦ | ២.០ | ២.៩ | ៣.៧ | ៤.៤ |
| ការសន្សំជាតិ | ១៩.៤ | ១៦.៦ | ២០.១ | ២១.៣ | ១៦.២ | ១៦.៣ | ១៧.២ | ២១.៧ | ២២.៦ | ១២.៧ |
| ការសន្សំរបស់រដ្ឋាភិ-បាលកណ្តាល | -១.០ | ១.៦ | ១.០ | ១.០ | ០.៨ | ១.៧ | ១.៨ | ១.២ | ៣.២ | ៣.៥ |
| ការសន្សំឯកជន | ២៤.៤ | ២០.៣ | ២០.៣ | ២១.៥ | ១៨.៣ | ១៦.៩ | ១៩.៦ | ២១.៥ | ២៣.២ | ២០.៩ |
| ការវិនិយោគក្នុងស្រុក | ១២.១ | ១១.៨ | ១២.១ | ១១.៩ | ១២.២ | ១១.៨ | ១១.១ | ១១.២ | ១១.១ | ១១.៥ |
| ការវិនិយោគសាធារណៈ | ៤.៧ | ៥.៤ | ៧.០ | ៨.៣ | ៦.៤ | ៥.៧ | ៥.២ | ៥.៧ | ៦.១ | ៦.៣ |
| ការវិនិយោគរបស់ម្ចាស់ជំនួយ | ៥.៥ | ៣.៨ | ៥.៦ | ៧.៣ | ៥.៤ | ៤.៥ | ៤.៤ | ៤.៩ | ៥.៣ | ៥.៣ |
| ការវិនិយោគឯកជន | ១៨.៧ | ១៦.៥ | ១៤.២ | ១៤.២ | ១២.៨ | ១២.៩ | ១៦.៣ | ១៧.០ | ២០.៤ | ១៨.០ |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា មូនិធិរូបិយវត្ថុអន្តរជាតិ*

មធ្យោបាយប្រសើរបំផុតដើម្បីជំរុញកំណើន សម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចតូច គឺការធ្វើសមាហរណកម្មជាមួយប្រព័ន្ធពាណិជ្ជកម្មពិភពលោក។

ដោយសារប្រជាជនកម្ពុជាចំនួន៧០% ចិញ្ចឹមជីវិតដោយប្រកបរបរកសិកម្ម កិច្ចខិតខំក្នុងការកាត់បន្ថយភាពក្រីក្រត្រូវតែផ្តោតលើវិស័យនេះ។ ពោលគឺការបង្កើនការនាំចេញនូវផលិតផលកសិកម្ម និងការអនុវត្តកំណែទម្រង់ តាមរយៈសមាជិកភាពនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។

- ប្រទេសកម្ពុជានៅខ្វះហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គម។ ជំនួយហិរញ្ញវត្ថុក្រៅប្រទេសត្រូវតែផ្តល់អាទិភាពដល់ការវិនិយោគក្នុងវិស័យនេះ។

*គំនូសតាង៣.៣ការព្យាករណ៍GDP ពិតក្នុងមនុស្សម្នាក់*




*ប្រភព៖ IMF Cambodia*

- ប្រព័ន្ធរដ្ឋបាលសាធារណៈដើរតួនាទីនាំមុខ ក្នុងការកសាងសមត្ថភាពដើម្បីគ្រប់គ្រងដំណើរការអភិវឌ្ឍន៍។

ចាប់តាំងពីការអនុវត្តកំណែទម្រង់ទីផ្សារ ដែលបានចាប់ផ្តើមក្នុងឆ្នាំ១៩៨៩ រួចមក ផ.ស.សរបស់កម្ពុជាបានកើនឡើង៥ដង ពី ១,២៧ ពាន់លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៨៩ ដល់១០,៣ពាន់លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៨។ ក្នុងរយៈពេលនេះ ចំណូលមនុស្សម្នាក់ៗបានកើនឡើងបួនដងពី ១៥២ ដុល្លារសហរដ្ឋអាមេរិកដល់ ៧៣៩ ដុល្លារសហរដ្ឋអាមេរិកផងដែរ។ ដោយសារតែកំណើនខ្ពស់ ប្រកបដោយចីរភាព អត្រាភាពក្រីក្របានថយចុះពី៣៥% ក្នុងឆ្នាំ២០០៤ ដល់ប្រមាណ៣០% ក្នុងឆ្នាំ២០០៧។

បញ្ហាវិបត្តិសេដ្ឋកិច្ចពិភពលោកក៏មានផលប៉ះពាល់ផងដែរលើសេដ្ឋកិច្ចកម្ពុជា ដោយកំណើនមានការធ្លាក់ចុះដល់ ៦.៧% ក្នុងឆ្នាំ២០០៨ និងសម្រេចបាន ០,១% ក្នុងឆ្នាំ២០០៩។ កម្លាំងចលករសំខាន់ៗនៃកំណើនបី ក្នុងចំណោមបួន គឺវិស័យកាត់ដេរទេសចរណ៍ និងសំណង់បានបង្ហាញនូវសញ្ញាធ្លាក់ចុះ តែចាប់ផ្តើមងើបឡើងវិញក្នុងពាក់កណ្តាលឆ្នាំ២០០៩។ ការវិនិយោគឯកជនក៏ទទួលរងផលប៉ះពាល់ផងដែរ។ ការងារចំនួន៩ម៉ឺននាក់ ក្នុងវិស័យរោងចក្រកាត់ដេរត្រូវបានបាត់បង់។

កំណើនត្រូវបានគេប៉ាន់ប្រមាណទុកថានឹងងើបឡើងវិញដល់៤¼ភាគរយនៅឆ្នាំ២០១០ប៉ុន្តែហានិ-ភ័យដែលអាចធ្វើឱ្យខាតបង់ក្នុងការវិនិយោគនៅតែមាននៅឡើយ។ សកម្មភាពពាក់ព័ន្ធនឹងការនាំចេញងាយនឹងរងគ្រោះដោយសារតែមូលដ្ឋានចង្អៀតការផ្តោតខ្ពស់ទៅសម្លៀកបំពាក់សម្រាប់នាំចេញទៅសហរដ្ឋអាមេ-រិកនិងតម្រូវការទាបសម្រាប់ការលក់រាយនៅសហរដ្ឋអាមេរិក។ ការកើនឡើងផ្នែកផលិតភាពកសិកម្មអាចនាំឱ្យមានកំណើនខ្ពស់ជាងមុនបាន។

ឧបមាថា បើសេដ្ឋកិច្ចកម្ពុជាសម្រេចបាននូវកំណើនថេរចំនួន១០% ក្នុងមួយឆ្នាំ នោះផ.ស.សសម្រាប់មនុស្សម្នាក់ៗរំពឹងថានឹងកើនដល់១០០០ដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ២០១៥ ហើយថែមទាំងអាចសម្រេចបានមុនឆ្នាំនេះទៀតផង ប្រសិនបើកម្ពុជាចាប់ផ្តើមផលិតកម្មប្រេងនិងឧស្ម័ន។ យ៉ាងណាមិញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចខ្ពស់ទាមទារឱ្យមានចំណាត់ការឯកភាពរួមគ្នា ដោយផ្តោតលើការពង្រឹង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភាពប្រកួតប្រជែង និងការកែលម្អបរិយាកាសធុរកិច្ច ក្នុងគោលដៅធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែង ដើម្បីបំពេញឱ្យបានពេញលេញនូវលក្ខខណ្ឌរបស់អង្គការពាណិជ្ជកម្មពិភពលោក និងកាត់បន្ថយចំណាយសម្រាប់ធ្វើធុរកិច្ច។ ទន្ទឹមនឹងនេះ កម្ពុជាក៏ត្រូវធ្វើវិសោធនកម្មលើច្បាប់ដែលមានស្រាប់ និងអនុមតិច្បាប់និងបទបញ្ញត្តថ្មីៗថែមទៀត។ ដើម្បីកាត់បន្ថយពេលវេលាសម្រាប់ការត្រួតពិនិត្យទំនិញគយ ចាំបាច់ត្រូវរៀបចំនីតិវិធីសវនកម្មក្រោយចំណាយ និងកាត់បន្ថយនីតិវិធីវាយតម្លៃ និងត្រួតពិនិត្យទំនិញអោយកាន់តែមានលក្ខណៈសាមញ្ញ។ កំណែទម្រង់គប្បីផ្តោតលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងពង្រឹងជំនាញរបស់កម្មករ ព្រមទាំងពង្រីកទីផ្សារ តាមរយៈការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងការកាត់បន្ថយថ្លៃដើមធ្វើធុរកិច្ច និងតាមរយៈការកាត់បន្ថយនីតិវិធីអនុមតិសំណើវិនិយោគនិងនីតិវិធីគយ។

## ៣.១.២. កសិកម្ម

វិស័យកសិកម្មនៅកម្ពុជា គឺជាវិស័យមួយដែលមានទាំងការធ្វើកសិកម្មតាមបែបប្រពៃណី ការធ្វើស្រែចំការ ដោយមិនប្រើប្រាស់គ្រឿងយន្តកសិកម្ម ពោលគឺការពឹងផ្អែកខ្លាំងលើអាកាសធាតុ ដោយដាំដំណាំលើដីតូចៗនិងការធ្វើកសិកម្មទ្រង់ទ្រាយធំ ដោយប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ផលិតផលនាំចេញ។ គោលនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជាផ្តោតលើការជំរុញផលិតភាពកសិកម្ម និងបង្កើនចំណូលក្នុងវិស័យកសិកម្ម។

ចំណែកនៃវិស័យកសិកម្មក្នុងផ.ស.សបានធ្លាក់ចុះខ្លាំង ពី៤៥.៨% ក្នុងឆ្នាំ១៩៨៩ ដល់ ២៩.៧% ក្នុងឆ្នាំ២០០៧ ក្នុងខណៈដែលកម្លាំងពលកម្មដែលធ្វើការក្នុងវិស័យកសិកម្មបានថយចុះពី៨០% ដល់៦០%នៃកម្លាំងពលកម្មសរុប។ កំណើនក្នុងវិស័យនេះសម្រេចបានជាមធ្យម៤.៥% ក្នុងមួយឆ្នាំក្នុងឆ្នាំ១៩៩៣-២០០៧។ បន្ទាប់ពីមានកំណើនខ្លាំងក្នុងឆ្នាំ២០០៥ (១៥.៧%) និងក្នុងឆ្នាំ២០០៦ (៥.៥%) កសិកម្មបានកើនឡើង៤.០% ក្នុងឆ្នាំ២០០៧។ ពោលគឺក្នុងរយៈពេល២០ឆ្នាំកន្លងទៅនេះ ចំណែកនៃផ្នែកកសិកម្មក្នុងផ.ស.ស បានថយចុះ ១៦.១%។ ការថយចុះនេះគឺមកពីការធ្លាក់ចុះនៃចំណែកនៃផលិតកម្មស្រូវអង្ករ និងផលផលក្នុងតម្លៃបន្ថែមកសិកម្ម។ ទោះបីជាមានការថយចុះខ្លាំងក្នុងចំណែកនៃផ.ស.សយ៉ាងណាក្តី វិស័យកសិកម្មនៅតែបន្តជួយដល់សេដ្ឋកិច្ចជនបទ។ ការអភិវឌ្ឍកសិកម្មជាកូនសោរគន្លឹះ ដើម្បីកំណើនប្រកបដោយចីរភាពនិងសមធម៌នៅកម្ពុជា។

**ដំណាំស្រូវ**នៅតែជាកត្តាកំណត់មួយក្នុងកំណើននៃវិស័យកសិកម្ម។ស្រូវជាស្បៀងមូលដ្ឋានរបស់ប្រជាជនកម្ពុជានិងផ្តល់កាឡូរីប្រហែល៧៥% ចំណែកកាឡូរីផ្សេងទៀតគឺបានមកពីត្រី ពោត ដំណាំមើម (ដំឡូងឈើនិងដំឡូងជ្វា) ផ្លែឈើ និងបន្លែ។ កៅស៊ូបានក្លាយជាវិស័យដែលមានកំណើនលឿនជាងគេនៃសេដ្ឋកិច្ចជនបទ ជាពិសេសក្រោយពីតម្រូវការនៃវត្ថុធាតុដើមបានកើនឡើងយ៉ាងខ្លាំង។ ផលិតកម្មកៅស៊ូជាមធ្យម សម្រេចបានចំនួន៥ម៉ឺនតោនក្នុងមួយឆ្នាំ។ ឧស្សាហកម្មនិងដំណាំរួមផ្សំផ្សេងទៀតរួមមាន ពោត សណ្តែកសៀង សណ្តែកបាយ សណ្តែកដី ល្ង អំពៅ ថ្នាំជក់ និងម្រេច។ ផលិតកម្មស្រូវងាយនឹងរងផលប៉ះពាល់ពីលក្ខខណ្ឌអាកាសធាតុ។ ផលិតកម្មស្រូវនិងដំណាំកើនឡើងជាមធ្យម៦.៧% ក្នុងមួយឆ្នាំ។ ផលិតកម្មស្រូវរងផលខូចខាតយ៉ាងដំណំ ដោយសារទឹកជំនន់និងគ្រោះរាំងស្ងួតក្នុងឆ្នាំ២០០០ និងក្នុងឆ្នាំ២០០២។ ដើម្បី


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពង្រឹងភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជាជាប្រទេសនាំចេញអង្ករ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់លើការវិនិយោគក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនិងស្ថានីយបូមទឹក ដើម្បីពង្រីកវិសាលភាពផ្ទៃដីស្រោចស្រព និងធានាការផ្គត់ផ្គង់ទឹកក្នុងអំឡុងពេលមានគ្រោះរាំងស្ងួត។ ជាលទ្ធផល កម្ពុជាផលិតស្រូវបាន៦លានតោន ដែលក្នុងនោះ ស្រូវដែលផលិតលើស២លានតោនក្នុងឆ្នាំ២០០៧ ត្រូវបាននាំចេញ។ ទោះបីជាយ៉ាងនេះក្តី ចំណែកនៃផលិតផលស្រូវនិងដំណាំដទៃទៀតក្នុងតម្លៃបន្ថែមកសិកម្មបានថយចុះ ចំនួន២៨.៩%ក្នុងឆ្នាំ១៩៨៩ ដល់១៥.៥% ក្នុងឆ្នាំ២០០៧។

**ការនេសាទត្រី** បានកើនឡើងជាមធ្យម ៣.២% ក្នុងឆ្នាំ១៩៨៩-២០០៧។ ប៉ុន្តែចំណែករបស់វាក្នុង ផ.ស.សបានធ្លាក់ចុះពី២៨.៩% ក្នុងឆ្នាំ១៩៨៩ ដល់ ១៥.៥% ក្នុងឆ្នាំ២០០៧។ ការនេសាទត្រីសម្រេចបានជាមធ្យម ៣៦៥,០០០តោនសម្រាប់ត្រីទឹកសាប និង៦៦,០០០តោន សម្រាប់ត្រីសមុទ្រ និង៤០,០០០តោនសម្រាប់ត្រីវារីវប្បកម្មទឹកសាប។ ត្រីទឹកសាបប្រមាណជា៧០%នៃត្រីដែលនេសាទបានចំនួន ៣៦៥,០០០តោន នេះត្រូវបានប្រើប្រាស់សម្រាប់ការបរិភោគក្នុងផ្ទះ។ កសិករនេសាទត្រីនៅក្នុងស្រែ ដោយដាក់បង្គៃ ឬដាក់មងក្នុងបឹងនៅពេលមានទឹកជំនន់ ឬនេសាទនៅក្នុងទន្លេនិងស្ទឹង។ ការនេសាទត្រីសម្រាប់រស់នៅប្រចាំថ្ងៃក៏អាចប្រព្រឹត្តទៅនៅក្នុងរដូវប្រាំង។ ចាប់តាំងពីឆ្នាំ២០០២មក រាជរដ្ឋាភិបាលបានលុបចោលនូវឡូត៍នេសាទអាជីវកម្មជាងពាក់កណ្តាល ដោយផ្ទេរឡូត៍នេសាទទាំងនេះទៅឱ្យសហគមន៍ប្រជានេសាទជាអ្នកគ្រប់គ្រង។ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងដល់អនុវិស័យគន្លឹះមួយនេះក្នុងគោលដៅធ្វើអោយវិស័យនេះមានភាពរស់រវើកឡើងវិញ ដែលផ្តល់ការរកស៊ីចិញ្ចឹមជីវិតសម្រាប់ប្រជាជនក្រីក្រ។

**បសុសត្វ** បានកើនឡើងជាមធ្យម២.៧%ក្នុងឆ្នាំ១៩៩៣-២០០៧។ប៉ុន្តែចំណែករបស់វាក្នុងផ.ស.ស បានធ្លាក់ចុះពី៧.៣% ដល់ ៤.៤% ក្នុងរយៈពេលនេះ។ បសុសត្វនៅតែសំខាន់សម្រាប់កសិករតូចតាចដែលពឹងផ្អែកទាំងស្រុងលើការចិញ្ចឹមសត្វពាហនៈ ជ្រូក និងមាន់ទានៅលើដីកសិដ្ឋាន ដើម្បីយកសាច់និងរកប្រាក់ចំណូល។ ការប្រើសត្វពាហនៈសម្រាប់បង្កបង្កើនផលបានថយចុះ ដោយសារប្រជាជនកម្ពុជាកំពុងងាកទៅប្រើប្រាស់ត្រាក់ទ័រ បរិក្ខារ និងគ្រឿងយន្តកសិកម្មសម្រាប់ធ្វើកសិកម្ម។

**អាជីវកម្មឈើ**បានកើនលឿនក្នុងឆ្នាំ១៩៩៤-១៩៩៨ជាមធ្យម ១៧.២% ក្នុងមួយឆ្នាំ។ សន្តិសុខដែលពុំទាន់សម្រេចបានពេញលេញនៅឡើយ និងការវិវាទផ្ទៃក្នុងជាញឹកញាប់នាំឱ្យមានការកាប់ឈើខុសច្បាប់ជាទ្រង់ទ្រាយធំ និងនាំឱ្យមានការបាត់បង់ធនធានព្រៃឈើយ៉ាងសន្ធឹកសន្ធាប់ក្នុងអំឡុងពេលនោះ។ ការកែឆ្នៃផលិតផលឈើបានត្រឹមការអារឈើដោយរោងចក្រអារឈើ ហើយឈើអារភាគច្រើនសម្រាប់តែការនាំចេញប៉ុណ្ណោះ។ ក៏ប៉ុន្តែ ចាប់ពីឆ្នាំ១៩៩៩មក រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តការហាមឃាត់ការកាប់ឈើ និងលុបចោលសម្បទានចំនួន១២របស់ក្រុមហ៊ុន៩ ដែលគ្របដណ្តប់លើផ្ទៃដីព្រៃឈើជាង២លានហិកតា។ ស្វយសារពីផលិតផលឈើត្រូវបានដម្លើងពី១៤ដុល្លារក្នុង១ម៉ែត្រត្រីគុណ ដល់៥៤ដុល្លារក្នុង១ម៉ែត្រត្រីគុណ។ ជាលទ្ធផល អាជីវកម្មឈើបានធ្លាក់ចុះពី៥.៨% នៃផ.ស.សក្នុងឆ្នាំ១៩៩៣-១៩៩៨ ដល់៣.៣% ក្នុងឆ្នាំ១៩៩៩-២០០៧។ ក្នុងឆ្នាំ១៩៩៤-២០០៧ ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ផ្នែកព្រៃឈើបានកើនឡើងជាមធ្យម ៤.៧% ក្នុងមួយឆ្នាំ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.១.៣. ឧស្សាហកម្ម

ឧស្សាហូបនីយកម្មនៅកម្ពុជាមានលំនាំដូចប្រទេសកំពុងអភិវឌ្ឍជាច្រើន ដោយចាប់ផ្តើមពីឧស្សាហកម្មធុនស្រាល ដូចជាវាយនភ័ណ្ឌ ការកាត់ដេរសំលៀកបំពាក់ និងការកែច្នៃផលិតផលកសិកម្ម ដូចជាការកិនស្រូវ ការកែច្នៃម្ហូបអាហារ។ ឧស្សាហូបនីយកម្មនេះឈានបន្តិចម្តងៗ ទៅរកឧស្សាហកម្មធុនធ្ងន់ ដូចជាអាជីវកម្មរ៉ែ ការរុករកប្រេងនិងឧស្ម័ន វិស័យកម្មន្តសាលនិងសំណង់។ មានក្រុមហ៊ុនជាច្រើនបានបង្កើតរោងចក្រតម្លើងម៉ូតូនិងខ្លះទៀតតម្លើងឡាននៅកម្ពុជា ។ នៅពេលដែលចំណូលក្នុងប្រជាជនម្នាក់ៗកើនឡើង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគុណភាពនៃកម្លាំងពលកម្មបកម្ពុជានឹងត្រូវបានកែលម្អ។ កម្ពុជានឹងធ្វើពិពិធកម្មឧស្សាហកម្មរបស់ខ្លួនខាងផ្នែកព័ត៌មានវិទ្យា និងការតម្លើងនិងផលិតគ្រឿងអគ្គិសនី និងឧបករណ៍អេឡិចត្រូនិកក្នុងរយៈពេលមធ្យមមួយ។

**វិស័យឧស្សាហកម្ម**បង្ហាញនូវជវភាព ដែលបណ្តាលមកពីការអនុវត្តគោលនយោបាយបើកទូលាយ លើកទឹកចិត្តដល់ធុរកិច្ច និងគោលនយោបាយសេរីដទៃទៀត។ កំណើនប្រកបដោយចីរភាពនិងស្ថេរភាពក្នុងវិស័យឧស្សាហកម្មសម្រេចបានដោយសារការអភិវឌ្ឍផ្នែកនាំចេញសម្លៀកបំពាក់ សហគ្រាសខ្នាតតូចនិងមធ្យម ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកទីផ្សារក្នុងស្រុកសម្រាប់ទំនិញប្រើប្រាស់ជាមូលដ្ឋាន។ អត្រាកំណើនឧស្សាហកម្មសម្រេចបានជាមធ្យម១៥% ក្នុងរយៈពេល១៥ឆ្នាំកន្លងទៅនេះ ដែលអាចចែកលម្អិតជា៖ ១២.១%ក្នុងឆ្នាំ១៩៩៤-១៩៩៨ ១៨.៥%ក្នុងឆ្នាំ១៩៩៩-២០០៣ និង១៤% ក្នុងឆ្នាំ២០០៤-២០០៧។ ចំណែកនៃផលិតផលក្នុងស្រុកសរុបរបស់វាធ្លាក់ចុះពី១៦.៧% ក្នុងឆ្នាំ១៩៨៩ ទៅ១២.៦% ក្នុងឆ្នាំ១៩៩៣ ដោយសារតែឯកជនភាវូបនីយកម្មនៃសហគ្រាសខ្នាតតូចនិងមធ្យមប៉ុន្តែបានកើនឡើងវិញពី១២.៦% ក្នុងឆ្នាំ១៩៩៣ ដល់២៥% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០០៧ ដោយសារតែការនាំចេញនៃផលិតផលវាយនភ័ណ្ឌនិងសំលៀកបំពាក់ និងដោយសារការពង្រីកសកម្មភាពសំណង់ ដែលបានក្លាយជាកម្លាំងចលករដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចនៅកម្ពុជា។

**ឧស្សាហកម្មវាយនភ័ណ្ឌ**និងកាត់ដេរសម្លៀកបំពាក់ ដែលជិតស្មើពាក់កណ្តាលនៃតម្លៃបន្ថែមខាងវិស័យឧស្សាហកម្ម បានចូលរួមវិភាគទានដ៏សំខាន់មួយដល់កំណើនឧស្សាហកម្មនៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ។ ការអភិវឌ្ឍឧស្សាហកម្មវាយនភ័ណ្ឌ និងកាត់ដេរសម្លៀកបំពាក់អាចសម្រេចទៅបាន ដោយសារកម្ពុជាទទួលបាននូវឋានៈនៃប្រទេសទទួលការអនុគ្រោះបំផុត (MFN) និងប្រព័ន្ធអនុគ្រោះទូទៅ (GSP) ដែលសហរដ្ឋអាមេរិកបានផ្តល់ឱ្យកម្ពុជានៅក្នុងឆ្នាំ១៩៩៦ និង១៩៩៧ ពោលគឺការយកពន្ធគយទាបលើទំនិញដែលកម្ពុជានាំចូលសហរដ្ឋអាមេរិក។ ក្នុងឆ្នាំ១៩៩៦-១៩៩៨ ការនាំចេញសម្លៀកបំពាក់បានកើនឡើងចំនួន ៧០% ទៅ១៩០% ក្នុងមួយឆ្នាំៗ។ កំណើននេះបានថយចុះមកវិញ នៅក្រោយពេលដែលសហរដ្ឋអាមេរិកបានកំណត់កូតាលើផលិតផលសម្លៀកបំពាក់កម្ពុជាចំនួន១២មុខ។ ក៏ប៉ុន្តែ វិស័យវាយនភ័ណ្ឌនិងកាត់ដេរសម្លៀកបំពាក់ គឺជាវិស័យដែលមានកំណើនយ៉ាងឆាប់រហ័សជាងគេនៅកម្ពុជា ដោយវាកើនឡើងជាមធ្យម ៣៧% ក្នុងមួយឆ្នាំក្នុងអំឡុងឆ្នាំ១៩៩៣-២០០៧ ហើយចំណែករបស់ក្នុងផ.ស.សបានកើនឡើងពី១% ក្នុងឆ្នាំ១៩៩៣ ដល់១២% ក្នុងឆ្នាំ២០០៧។ ការនាំចេញសម្លៀកបំពាក់បានកើនឡើង១០៧ដង ពី២៦.៧លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៥ ដល់២,៨ពាន់លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៧។ ចំនួនរោងចក្រកាត់ដេរបានកើនឡើងពី៥៣រោងចក្រ ដល់៣៩៨រោងចក្រក្នុងអំឡុងពេលនេះ។ ចំនួនកម្មករដែលទទួលបានប្រាក់បៀវត្សរ៍



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងឧស្សាហកម្មនេះបានកើនឡើងដល់៣៥ម៉ឺននាក់ក្នុងឆ្នាំ២០០៥។ ដើម្បីជួយឱ្យឧស្សាហកម្មកាត់ដេរអាចពុះពារឧបស័គ្គក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ចពិភពលោក រាជរដ្ឋាភិបាលបានផ្តល់ការអនុគ្រោះពន្ធលើប្រាក់ចំណេញដល់ក្រុមហ៊ុនវាយនភ័ណ្ឌ ដែលធ្វើឱ្យខាតបង់ថវិកា១០០លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ។

**ឧស្សាហកម្មរ៉ែ**បានកើនឡើង១៥% ក្នុងមួយឆ្នាំជាមធ្យមក្នុងអំឡុងឆ្នាំ១៩៩៤-២០០៨។ ការបន្តកំណើនក្នុងវិស័យនេះគឺបានមកពីការរុករកប្រេងក្នុងឈូងសមុទ្រថៃ និងការរុករករ៉ែនៅខេត្តមួយចំនួនទៀតនៅកម្ពុជា។ នេះរួមមានទាំងការរុករករ៉ែដែកនៅខេត្តព្រះវិហារ បុកស៊ីត ទង់ដែង និងមាសនៅប៉ៃកញ្ចសាន។ ក្រុមហ៊ុនអាជីវកម្មរ៉ែអន្តរជាតិសម្លឹងមើលមកប្រទេសកម្ពុជាថា ជាទិសដៅថ្មីមួយដែលពុំទាន់ដែលមាននរណារុករកនៅឡើយ។ ក្នុងមួយសតវត្សរ៍កន្លងទៅនេះអាជីវកម្មរ៉ែបានជួយដល់ផលិតផលក្នុងស្រុកសរុបស្មើនឹង ០.២% ទៅ០.៤%។ ចំណែកនេះគេរំពឹងថានឹងកើនឡើងច្រើនថែមទៀតនៅពេលក្រុមហ៊ុនកាន់តែច្រើនចាប់ផ្តើមរំកិលពីការរុករកទៅរកការអភិវឌ្ឍននិងផលិតកម្ម។

**សំណង់** ជាសសរទ្រូងមួយនៃកំណើនសេដ្ឋកិច្ច។ ការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការស្តារនីតិសម្បទា និងស្ថាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងរយៈពេល១៥ឆ្នាំចុងក្រោយនេះបានជួយដល់ការពង្រីកសកម្មភាពសំណង់។ អត្រាកំណើនប្រចាំឆ្នាំផ្នែកសំណង់គឺ១៣% ជាមធ្យមក្នុងអំឡុងឆ្នាំ១៩៩៤-២០០៧។ ការចម្រើនលូតលាស់ខ្លាំងផ្នែកសំណង់បានកើតឡើងក្នុងឆ្នាំ២០០២-២០០៦ ដោយពេលនោះអត្រាកំណើនមធ្យមប្រចាំឆ្នាំមានស្ទើរតែ២០%។ ភាពរីកលូតលាស់ខ្លាំងបណ្តាលមកពីការសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធជាច្រើន និងពីសំណង់លំនៅដ្ឋាននៅភ្នំពេញនិងសៀមរាប។ កំណើននេះបានថយចុះដល់៦.៧%ក្នុងឆ្នាំ២០០៧ និងស្ទើរតែនៅជាប់គាំងទ្រឹងនៅក្នុងឆមាសទីពីរក្នុងឆ្នាំ២០០៨ ដោយសារតែមានវិបត្តិសេដ្ឋកិច្ចពិភពលោក និងដោយសារតែការវិនិយោគក្រៅប្រទេសចាប់ធ្លាក់ចុះ។

ឥឡូវនេះគម្រោងសាងសង់បុរីថ្មីៗ និងសំណង់ស្ពានឆ្លងកាត់ទន្លេមេគង្គនៅភ្នំពេញ និងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស អាចនឹងជួយលើកស្ទួយផ្នែកសំណង់ក្នុងរយៈពេលមធ្យមបាន។

### ៣.១.៤. វិស័យសេវា

តម្លៃបន្ថែមរបស់វិស័យសេវាបានកើនឡើងជាមធ្យមក្នុងអត្រា៨.៦% ក្នុងឆ្នាំ១៩៩៤-២០០៧។ អត្រាកំណើនខ្ពស់នេះ គឺដោយសារតែការពង្រីកផ្នែកទេសចរណ៍ ការដឹកជញ្ជូននិងគមនាគមន៍ ធនាគារ និងការរីកដុះដាលនៃវិស័យអចលនវត្ថុ។ ចំណែកនៃវិស័យសេវាបានធ្លាក់ចុះបន្តិចវិញ ក្នុងរយៈពេល១៤ឆ្នាំចុងក្រោយនេះគឺថយចុះពី៣៩.៤% ក្នុងឆ្នាំ១៩៩៤ ដល់៣៨.៥% នៃផ.ស.ស ក្នុងឆ្នាំ១៩៩៤-២០០៨។

ការពង្រីក**ឧស្សាហកម្មទេសចរណ៍**និងសណ្ឋាគារនៅបន្ត ដោយមានអត្រាកំណើន១៤.៣%។ នៅក្នុងឆ្នាំ២០០៧ មានភ្ញៀវទេសចរ២លាននាក់បានមកលេងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើទំនាក់ទំនងគ្នារវាងទេសចរណ៍ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដើម្បីបំប្លែងតំបន់សៀមរាប ឱ្យក្លាយទៅជាផលិតកម្មកសិកម្មក្រវាត់បៃតង ក្នុងគោលដៅបង្កើតឱ្យមានការផ្សារភ្ជាប់គ្នាត្រឡប់ក្រោយវិញនៃផ្នែកទេសចរណ៍ ជាមួយនឹងកសិកម្មក្នុងមូលដ្ឋាន។

**ការដឹកជញ្ជូន និងគមនាគមន៍** បានកើនឡើងក្នុងអត្រា៨.៥% ជាមធ្យមប្រចាំឆ្នាំ។ អនុវិស័យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទូរគមនាគមន៍មានកំណើនមធ្យមប្រចាំឆ្នាំច្រើនរហូតដល់ប្រមាណ៥០% ជាពិសេសសេវាទូរស័ព្ទចល័ត។ ក្នុងរយៈពេល១៥ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានបំពេញចប់សព្វគ្រប់នូវការសាងសង់និងស្តាបនាឡើងវិញនៃបណ្តាញផ្លូវជាតិ និងបានចាប់ផ្តើមកែលម្អហេដ្ឋារចនាសម្ព័ន្ធតាមបណ្តាខេត្តនិងជនបទ ដើម្បីតភ្ជាប់សហគមន៍ជនបទរបស់កម្ពុជា ទៅនឹងតំបន់ទីក្រុងដែលមានការអភិវឌ្ឍជាង និងបញ្ចូលតំបន់ជនបទកម្ពុជាអោយចូលក្នុងចរន្តសេដ្ឋកិច្ចជាតិ។

**វិស័យហិរញ្ញវត្ថុ**បានរីកលូតលាស់ជាមធ្យមក្នុងអត្រា២៤.៧% ប្រចាំឆ្នាំ ដែលឆ្លុះបញ្ចាំងអំពីជម្រៅហិរញ្ញវត្ថុ ដែលរីកចម្រើនយ៉ាងឆាប់រហ័ស និងការកើនឡើងនៃអន្តរការីកម្មហិរញ្ញវត្ថុ។

តម្លៃបន្ថែមនៃ**អចលនវត្ថុ** (ការជួល និងសេវាអចលនវត្ថុ) បានកើនឡើងក្នុងអត្រាមធ្យម៨.៣% ប្រចាំឆ្នាំ ដែលឆ្លុះបញ្ចាំងការកើនឡើងនៃការវិនិយោគផ្ទាល់ពីក្រៅប្រទេស និងសំណង់លំនៅដ្ឋាននៅក្នុងសកម្មភាពសេដ្ឋកិច្ចនេះ។

## ៣.២. ឥរិយាបថសន្សំនិងវិនិយោគ

### ៣.២.១. ការសន្សំ

អត្រានៃការសន្សំនៅកម្ពុជាមានសមល្មមគឺក្នុងចន្លោះពី១៨-២៦% នៃផ.ស.ស ក្នុងអំឡុងឆ្នាំ១៩៩៣-២០០៨។គណនីសន្សំរបស់ជាតិមានចំនួន១៣-២២%នៃផ.ស.សក្នុងខណៈពេលដែលការសន្សំរបស់បរទេសសម្រេចបានរវាងពី១ ទៅ៧០%។ ការសន្សំបង្កើតបានជាធនធានសំខាន់សម្រាប់ការវិនិយោគក្នុងស្រុក និងការវិនិយោគផ្ទាល់ពីក្រៅប្រទេស។ គំនូសតាង៣.៤ខាងលើបង្ហាញពីរចនាសម្ព័ន្ធនៃការសន្សំក្នុងអំឡុងឆ្នាំ១៩៩៣-២០០៨។

*គំនូសតាង៣.៤ រចនាសម្ព័ន្ធនៃការសន្សំក្នុងឆ្នាំ១៩៩៣-២០០៨ (% នៃផសស)*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

យើងអាចសង្កេតមើលលក្ខណៈនៃឥរិយាបថសន្សំដូចតទៅនេះ។ ដំបូងការសន្សំរបស់រាជរដ្ឋាភិបាលបង្ហាញអំពីនិន្នាការកំណើនពីអវិជ្ជមាន(ឱនភាពថវិកាបច្ចុប្បន្នគឺ-១.២%នៃផសស)ក្នុងឆ្នាំ១៩៩៣ទៅកាន់

អត្រាសន្សំវិជ្ជមាន (អតិរេកថវិកាបច្ចុប្បន្នគឺ៣.៥% នៃផសស) ក្នុងឆ្នាំ២០០៨។ ទីពីរការសន្សំពីតាមផ្ទះនិងសហគ្រាស គឺបង្កើតបានជាការសន្សំដុលរបស់ជាតិ។ ទីបីការសន្សំបរទេសបន្តដើរតួសំខាន់នៅកម្ពុជាដោយកើនឡើងពី១.៦% នៃផ.ស.សក្នុងឆ្នាំ១៩៩៣ ទៅ១២% នៃផ.ស.សក្នុងឆ្នាំ២០០៨ ភាគច្រើនគឺមកពីការកើនឡើងលំហូរមូលធនក្នុងឱនភាពគណនីចរន្តហិរញ្ញវត្ថុ។

### ៣.២.២. ការវិនិយោគ

គំនូសតាង៣.៥បង្ហាញអំពីការធ្វើហិរញ្ញប្បទាននៃការវិនិយោគដោយការសន្សំជាតិ និងបរទេសក្នុងអំឡុងឆ្នាំ១៩៩៣-២០០៨។ ក្នុងរយៈពេលនេះ ការវិនិយោគដែលធ្វើហិរញ្ញប្បទាននៅក្នុងស្រុកស្មើនឹង ៥៣% នៃការវិនិយោគសរុប ហើយការវិនិយោគដែលធ្វើហិរញ្ញប្បទានពីបរទេស ក្នុងទម្រង់ជាការវិនិយោគផ្ទាល់ពីបរទេសនិងជំនួយអភិវឌ្ឍន៍ផ្លូវការមានចំនួន ៤៧%។ ក្នុងខណៈដែលជំនួយអភិវឌ្ឍន៍ផ្លូវការមានចំនួនថេរ លំហូរនៃការវិនិយោគផ្ទាល់ពបរទេសបានកើនឡើង ជាពិសេសក្នុងអំឡុងពេលមុនមានវិបត្តិសេដ្ឋកិច្ចពិភពលោក។ ជារួម ប្រភពនៃហិរញ្ញប្បទានវិនិយោគរបស់ប្រទេសកម្ពុជាមានដូចតទៅ៖ (១) ជំនួយអភិវឌ្ឍន៍ផ្លូវការចំនួន ៦០០លានដុល្លារក្នុងមួយឆ្នាំ សម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធសង្គមនិងរូបវន្ត ដើម្បីកែលម្អបរិយាកាសសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងកំណែទម្រង់ស្ថាប័ន (២) ការវិនិយោគផ្ទាល់ពីបរទេសចំនួន ៧០០-៨០០លាន ដុល្លារក្នុងមួយឆ្នាំ សម្រាប់ការពង្រឹកសមត្ថភាពផលិតរបស់សេដ្ឋកិច្ច (៣) ថវិការដ្ឋសម្រាប់ចំណាយចរន្តនិងការវិនិយោគមូលធនចំនួន ១,២ ពាន់លានដុល្លារ ដើម្បីកែលម្អការផ្តល់សេវាសាធារណៈ។ ថវិកានេះនឹងបន្តកើនឡើងយ៉ាងឆាប់រហ័ស ដោយសារតែការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និង (៤) ឥណទានធនាគារចំនួន ២,៥ ពាន់លានដុល្លារ ដើម្បីធ្វើហិរញ្ញប្បទានដល់គម្រោងវិស័យឯកជន។

*គំនូសតាង៣.៥ រចនាសម្ព័ន្ធនៃការវិនិយោគក្នុងឆ្នាំ១៩៩៣-២០០៨ (% នៃផសស)*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ប្រទេសកម្ពុជាបានកំណត់ទិសដៅច្បាស់លាស់ស្តីពីការបង្កើតទីផ្សារមូលប័ត្រ និងប័ណ្ណបំណុលនៅចុងឆ្នាំ២០០៩ ដូចមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥។ មានវឌ្ឍនភាពមួយចំនួនហើយក្នុងការកែលម្អបទដ្ឋានគណនេយ្យធានាអភិបាលកិច្ចសាជីវកម្មល្អ និងរៀបចំវិស័យសាជីវកម្មដើម្បីចុះបញ្ជីក្នុងទីផ្សារមូលប័ត្រ។ រាជរដ្ឋាភិបាលកម្ពុជាបានអញ្ជើញក្រុមហ៊ុន Korea Exchange (KRX) និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រុមហ៊ុនមូលប័ត្របរទេសដើម្បីមកចូលរួមក្នុងកិច្ចការនេះ។ នៅពេលបើកដំណើរការពេញលេញ ទីផ្សារមូលប័ត្រនឹងក្លាយជាប្រភពសំខាន់ទី៥នៃហិរញ្ញប្បទានវិនិយោគសម្រាប់កម្ពុជា។

### ៣.២.២.១. *ជំនួយអភិវឌ្ឍន៍ផ្លូវការ*

ហិរញ្ញប្បទានខាងក្រៅជាពិសេសជំនួយអភិវឌ្ឍន៍ផ្លូវការបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើតមូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ចនៅកម្ពុជា។ ជំនួយអភិវឌ្ឍន៍ផ្លូវការរួមមាន ជំនួយឥតសំណង ឥណទាន និងជំនួយបច្ចេកទេស បានកើនឡើងពី៥០០លានដុល្លារក្នុងឆ្នាំ១៩៩៣ ដល់ ៧០០លានដុល្លារក្នុងឆ្នាំ២០០៨។

*តំនូសតាង៣.៦ប្រភេទនៃជំនួយបរទេសឆ្នាំ១៩៩៣-២០០៧ (ពាន់ដុល្លារសហរដ្ឋអាមេរិក)*




| | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Others | | | | | | | | | | | 22 | 4642 | 8520 | 1443 | 6889 |
| Emergency relief | 95634 | 44150 | 53674 | 54780 | 40580 | 5546 | 30937 | 54020 | 33633 | 24992 | 27515 | 20175 | 17066 | 21035 | 18164 |
| Budgetary aids | 73486 | 69170 | 77887 | 66493 | 2647 | 0 | 35856 | 38091 | 45975 | 39416 | 32059 | 6379 | 6945 | 91023 | 34713 |
| Investment projects | 67,47 | 122,5 | 174,4 | 159,1 | 130,6 | 167,8 | 114,4 | 143,9 | 189,8 | 191,1 | 232,8 | 260,7 | 290,1 | 354,1 | 399,5 |
| Technical Cooperation | 85300 | 122215 | 207312 | 237625 | 209347 | 259893 | 218441 | 230742 | 202430 | 275386 | 247055 | 263444 | 287313 | 245251 | 339023 |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ចាប់តាំងពីឆ្នាំ១៩៩៣ ដៃគូឧបត្ថម្ភទ្វេភាគីនិងពហុភាគីបានសន្យាផ្តល់ទឹកប្រាក់៥៥០លានដុល្លារជាមធ្យមក្នុងមួយឆ្នាំ។ នៅចន្លោះឆ្នាំ១៩៩៣និងឆ្នាំ២០០៧ ការបើកផ្តល់ជំនួយទាំងនេះទៅប្រើប្រាស់មានចំនួន៧,៦ ពាន់លានដុល្លារ ឬ៥០៧លានដុល្លារជាមធ្យមក្នុងមួយឆ្នាំ។

ពាក់ព័ន្ធនឹងចីរភាពនៃបំណុលរយៈពេលមធ្យមនិងវែង រាជរដ្ឋាភិបាលបានផ្តល់អាទិភាពទៅលើជំនួយឥតសំណងជាងកម្ចីសម្បទាន។ ជាទូទៅរាជរដ្ឋាភិបាលកម្ពុជាជៀសពីកម្ចីមានលក្ខណៈពាណិជ្ជកម្ម។

សរុបមក កម្ពុជាបានទទួលជំនួយអភិវឌ្ឍន៍ស្មើនឹង ៧,៦ ពាន់លានដុល្លារក្នុងឆ្នាំ ១៩៩៣-២០០៧ ដែលក្នុងនោះមាន៖ ៤៥%ជាជំនួយបច្ចេកទេស ៤០%ជាគម្រោងវិនិយោគ ៨%ជាការគាំទ្រថវិកា និង ៧% ជាជំនួយស្បៀងអាហារនិងជំនួយសង្គ្រោះបន្ទាន់។

ផ្អែកលើតារាងខាងលើយើងអាចឃើញថា ទីភ្នាក់ងារអង្គការសហប្រជាជាតិបានផ្តល់ថវិកាចំនួន ៦៥២លានដុល្លារ ឬ៨.៤%នៃជំនួយអភិវឌ្ឍន៍ ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ចំនួន៧៤៥លានដុល្លារឬ៩.៨% ធនាគារពិភពលោកចំនួន ៥៤១លានដុល្លារឬ៧.១% អង្គការរូបិយវត្ថុអន្តរជាតិចំនួន ២៤១លានដុល្លារឬ ៣.២% ប្រទេសជាសមាជិកសហភាពអឺរ៉ុបបានផ្តល់ចំនួន ១,៨ ពាន់លានដុល្លារ ឬ ២៣.៨% និងម្ចាស់ជំនួយឧបត្ថម្ភគីដទៃទៀតចំនួន ២,៩ពាន់លានដុល្លារឬ៣៨.៣% និងអង្គការក្រៅរដ្ឋាភិបាលបានផ្តល់ចំនួន ៦៥២លានដុល្លារ ឬ៨.៦%។

*តារាង៣.២៖ការបើកប្រាក់យកទៅប្រើប្រាស់ផ្ដល់ឱ្យដោយម្ចាស់ជំនួយ៖*

| ដៃគូអភិវឌ្ឍន៍ | (ពាន់ដុល្លារអាមេរិក) | ភាគរយ |
|---|---|---|
| ទីភ្នាក់ងារអង្គការសហប្រជាជាតិ | | |
| - កម្មវិធីដែលបានប្រគល់៖ មូលនិធិ | 794,310 | |
| របស់ខ្លួនដែលបានបើកឱ្យសរុប | 642,469 | 8.4% |
| គ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ | | |
| - IBRD/ធនាគារពិភពលោក | 541,418 | 7.1% |
| - រូបិយវត្ថុអន្តរជាតិ | 241,523 | 3.2% |
| - ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារដទៃទៀត | 745,394 | 9.8% |
| - ផ្សេងៗទៀត | | |
| -មូលនិធិសកលលោក | 61,767 | 0.8% |
| ចំនួនសរុបតាមផ្នែក៖ ទីភ្នាក់ងារអង្គការសហប្រជាជាតិនិងមូនិធិរូបិយវត្ថុអន្តរជាតិ | 2,232,571 | 29.3% |
| សហភាពអឺរ៉ុប | | |
| គណៈកម្មការអឺរ៉ុប | 467,517 | 6.1% |
| បែលហ្ស៊ិក | 59,532 | 0.8% |
| ដាណឺម៉ាក | 97,382 | 1.3% |
| ហ្វាំងឡង់ | 23,965 | 0.3% |
| បារាំង | 450,404 | 5.9% |
| អាល្លឺម៉ង់ | 228,940 | 3.0% |
| ហុល្លង់ | 69,027 | 0.9% |
| អេស្ប៉ាញ | 7,937 | 0.1% |
| ស៊ុយអែត | 230,782 | 3.0% |
| ចក្រភពអង់គ្លេស | 178,800 | 2.3% |
| សមាជិកសភាពអឺរ៉ុបដទៃទៀត | 10 | 0.0% |
| ចំនួនសរុបតាមផ្នែកសហភាពអឺរ៉ុប | 1,814,296 | 23.8% |
| ម្ចាស់ជំនួយឧបតោភាគីធំ | | |

| | | |
|---|---|---|
| អូស្ត្រាលី<br>កាណាដា<br>ចិន<br>ជប៉ុន<br>ណូវែលហ្សេឡង់<br>ន័រវេ<br>សាធារណៈរដ្ឋកូរ៉េ<br>សហព័ន្ធរុស្ស៊ី<br>ស្វីស<br>សហរដ្ឋអាមេរិក | 323,824<br>69,323<br>303,796<br>1,491,020<br>17,287<br>22,395<br>119,782<br>10,297<br>17,454<br>514,068 | 4.3%<br>0.9%<br>4.0%<br>19.6%<br>0.2%<br>0.3%<br>1.6%<br>0.1%<br>0.2%<br>6.8% |
| ម្ចាស់ជំនួយទ្វេភាគីដទៃទៀត | 24,248 | 0.3% |
| ចំនួនសរុបតាមផ្នែកៈ ម្ចាស់ជំនួយឧបតោភាគី | 2,913,494 | 38.3% |
| អង្គការក្រៅរដ្ឋាភិបាល (មូលនិធិគោល) | 652,866 | 8.6% |
| ប្រាក់ដែលបានបើកយកមកប្រើប្រាស់សរុប | 7,613,227 | 100.0% |

*ប្រភពៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

ជំនួយបរទេសលម្អិតទៅតាមវិស័យអាទិភាពនៅក្រោមកម្មវិធីវិនិយោគសាធារណៈសម្រាប់ឆ្នាំ ១៩៩៣-២០០៧ មានដូចតទៅៈ ១៤% សម្រាប់សុខភិបាល ១១%សម្រាប់អប់រំ ៨%សម្រាប់កសិកម្ម ១១% សម្រាប់ការអភិវឌ្ឍជនបទនិងការគ្រប់គ្រងដីធ្លី ១%សម្រាប់ទឹកនិងអនាម័យ ៨%សម្រាប់សហគមន៍និងសុខុមាលភាពសង្គម៥% សម្រាប់វប្បធម៌និងសិល្បៈ១% សម្រាប់បរិស្ថាននិងអភិរក្ស ១៨%សម្រាប់អភិបាលកិច្ច និងរដ្ឋបាល និង៥%សម្រាប់វិស័យផ្សេងទៀត។

***គំនូសតាង៣.៧ការបែងចែកជំនួយបរទេសតាមវិស័យឆ្នាំ១៩៩៣-២០០៧***




*ប្រភពៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.២.២.២. ការវិនិយោគផ្ទាល់ពីបរទេស

ការវិនិយោគផ្ទាល់ពីបរទេសបានដើរតួកាន់តែសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ដែលមានទឹកប្រាក់សរុប៨៦៧លានដុល្លារក្នុងឆ្នាំ២០០៧។ ពីឆ្នាំ១៩៩៤ ដល់ខែកក្កដាឆ្នាំ២០០៨ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុមតិលើការវិនិយោគឯកជនដែលមានទឹកប្រាក់សរុប ២១,២ ពាន់លានដុល្លារ។ ក៏ប៉ុន្តែមានតែទឹកប្រាក់ចំនួន៨,២ ពាន់លានដុល្លារនៃការវិនិយោគផ្ទាល់ពីបរទេសប៉ុណ្ណោះ ដែលត្រូវបានយកមកវិនិយោគជាក់ស្តែង។ យើងបានកត់សម្គាល់ឃើញនូវការកើនឡើងនៃការវិនិយោគផ្ទាល់ពីបរទេស និងវិនិយោគ ជាការទិញភាគហ៊ុនក្នុងអំឡុងឆ្នាំ២០០៣-២០០៨ ឆ្លុះបញ្ចាំងពីភាពល្អប្រសើរដែលថេរក្នុងបរិយាកាសវិនិយោគនិងតួនាទីលប់លើគេរបស់វិស័យឯកជនក្នុងការលើកស្ទួយការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។ មូលនិធិការវិនិយោគពីក្រៅប្រទេសបានជួយយ៉ាងច្រើនដល់កំណើនសេដ្ឋកិច្ចខ្ពស់នៅកម្ពុជា។

ការវិនិយោគផ្ទាល់ពីក្រៅប្រទេសក្នុងវិស័យកាត់ដេរសម្លៀកបំពាក់បានបង្កើតការងារប្រមាណ៣សែន៥ម៉ឺននៅក្នុងប្រទេស។ ប៉ុន្តែTodaro និងSmith បានបញ្ជាក់រួចហើយថាការវិនិយោគផ្ទាល់ពីក្រៅប្រទេសពាក់ព័ន្ធច្រើនជាងការផ្ទេរមូលធនធម្មតាឬការបង្កើតរោងចក្រក្នុងស្រុកមួយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ វិនិយោគិនបរទេសនាំមកជាមួយពួកគាត់នូវបច្ចេកវិទ្យានៃការផលិតរសជាតិនិងរបៀបរស់នៅសេវាគ្រប់គ្រង និងការអនុវត្តធុរកិច្ចចម្រុះ។ ផលប៉ះពាល់វិជ្ជមានមកពីក្រៅពាក់ព័ន្ធនឹងការវិនិយោគផ្ទាល់ពីក្រៅប្រទេសទាំងអស់នេះបានផ្តល់ផលប្រយោជន៍ដល់ប្រទេសកម្ពុជា។

ក្នុងខណៈពេលដែលការវិនិយោគផ្ទាល់ពីបរទេសមានទឹកប្រាក់រវាង ១៥០-២៥០លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៥-២០០៤ ចាប់ពីឆ្នាំ២០០៥មក ចំនួននេះចាប់ផ្តើមកើនឡើងយ៉ាងខ្លាំងរហូតដល់៨៦៧លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៧។ វិបត្តិសេដ្ឋកិច្ចសកលលោកបានធ្វើឱ្យថយចុះលំហូរនៃការវិនិយោគផ្ទាល់ពីក្រៅប្រទេសនៅកម្ពុជា ដោយសារតែតម្រូវការតិចតួចពីក្រៅប្រទេស និងការថយចុះនៃឱកាសវិនិយោគដើម្បីរកផលចំណេញនៅក្នុងប្រទេស។

បញ្ហាប្រឈមនៅបន្តមានដើម្បីបង្កើតបរិយាកាសអំណោយផលដល់ការវិនិយោគ តាមរយៈការពង្រឹងប្រព័ន្ធតុលាការនិងអភិបាលកិច្ចល្អ ព្រមទាំងសមត្ថភាពរបស់រាជរដ្ឋាភិបាល ដើម្បីផ្តល់សេវាអតិបរមាសម្រាប់វិស័យឯកជន។ ការអភិវឌ្ឍធនធានមនុស្សក៏ត្រូវបញ្ចូលក្នុងក្របខ័ណ្ឌនេះផងដែរ។ ឧទាហរណ៍ដ៏ស័ក្តិសម គឺការបង្កើតគ្រឹះស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ខ្លួននៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលកំពុងបណ្តុះបណ្តាលនិយោជិតផ្នែកការិយាល័យជាច្រើននាក់ ដោយមានការជួយឧបត្ថម្ភគាំទ្រពីម្ចាស់ជំនួយជាច្រើន និងវិស័យឯកជន។

*គំនូសតាង៣.៨a. ការវិនិយោគផ្ទាល់ពីបរទេស, 1993-2007 (គិតជាលានដុល្លា)*




*គំនូសតាង៣.៨b. ការវិនិយោគតាមប្រទេស*




*ប្រភព៖ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

មានទស្សនៈពីរពាក់ព័ន្ធនឹងការលើកទឹកចិត្តដល់ការវិនិយោគដែលបានផ្តល់ឱ្យដល់វិនិយោគិន៖

- **ទស្សនៈទី១៖** ប្រទេសកម្ពុជាពុំមានចំណុចទាក់ទាញណាមួយដល់វិនិយោគិនក្រៅពីការលើកទឹកចិត្តផ្នែកពន្ធនោះទេ។ បរិយាកាសទូទៅដូចជាស្ថេរភាពនយោបាយ សន្តិសុខចំពោះរូបរាងកាយ សណ្តាប់ធ្នាប់សង្គម ក្របខ័ណ្ឌច្បាប់ និងស្ថាប័នរចនាសម្ព័ន្ធ (ទឹក អគ្គិសនី ផ្លូវ) ធនធានមនុស្ស និងទីផ្សារខាងក្រៅពុំមានលក្ខណៈអំណោយផលច្រើនដូចនៅប្រទេសជិតខាងទេ។ មិនតែប៉ុណ្ណោះ ប្រទេសអាស៊ានទាំងអស់បានចាត់វិធានការច្បាស់លាស់រួមទាំងផ្តល់ការលើកទឹកចិត្តខាងផ្នែកពន្ធដើម្បីទាក់ទាញការវិនិយោគ។ ដូច្នេះប្រសិនបើគ្មានការផ្តល់ការលើកទឹកចិត្តខាងផ្នែកពន្ធសម្រាប់ការវិនិយោគទេប្រទេសកម្ពុជានឹងមិនអាចទាក់ទាញការវិនិយោគផ្ទាល់ពីក្រៅប្រទេសបានទេ។
- **ទស្សនៈទី២៖** កិច្ចខិតខំប្រមូលចំណូលថវិកានៅព្រះរាជាណាចក្រកម្ពុជានៅមានកម្រិតទាបនៅឡើយគឺមានតែ១៣%នៃផ.ស.សប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងមធ្យមភាគក្នុងតំបន់ដែលមានពី២០% ទៅ២៥% នៃផ.ស.ស។ ទោះបីជាប្រទេសក្នុងតំបន់បានចាត់វិធានការច្បាស់លាស់ដើម្បីទាក់ទាញការវិនិយោគ ក៏ច្បាប់វិនិយោគរបស់ព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈសេរីជាងបើប្រៀបធៀប នឹងប្រទេសនៅក្នុងតំបន់។ គេមិនអាចទាក់ទាញឱ្យមានការវិនិយោគបានទេ បើគ្រាន់តែមានការលើកទឹកចិត្តពន្ធ ប៉ុន្តែគ្មានបរិយាកាសអំណោយផលជាទូទៅ ដូចជាស្ថេរភាពនយោបាយ សន្តិសុខចំពោះរូបរាងកាយ សណ្តាប់ធ្នាប់សង្គម ក្របខ័ណ្ឌច្បាប់ និងស្ថាប័នរចនាសម្ព័ន្ធ (ទឹក អគ្គិសនី ផ្លូវ) ធនធានមនុស្សនិងទីផ្សារខាងក្រៅ។ រាជរដ្ឋាភិបាលគប្បីចាត់វិធានការដើម្បីកែលម្អបរិយាកាសទូទៅសម្រាប់ការវិនិយោគ និងមិនគប្បីលើកលែងពន្ធចំណូល ដែលកំពុងត្រូវការខ្លាំងបំផុត ដោយសារតែចង់លើកទឹកចិត្តដល់ការវិនិយោគនោះទេ។ ដូច្នេះ រាជរដ្ឋាភិបាលគប្បីចាត់វិធានការពង្រឹងចំណូល តាមរយៈការរឹតបន្តឹងនិងការធ្វើវិចារណកម្មការលើកទឹកចិត្ត ដើម្បីប្រមូលធនធានបន្ថែមយកមកជួយពង្រឹងស្ថាប័នរដ្ឋាភិបាល បង្កើនការវិនិយោគខាងហេដ្ឋារចនាសម្ព័ន្ធ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធនធានមនុស្ស សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងការស្រាវជ្រាវទីផ្សារ។ លើសពីនេះទៅទៀត ប្រសិនបើវិនិយោគិនទទួលបានការអនុគ្រោះពន្ធនៅកម្ពុជា ពួកគេនឹងត្រូវមានកាតព្វកិច្ចបង់ពន្ធទាំងនេះនៅប្រទេសរបស់ខ្លួនពួកគេជាស្វ័យប្រវត្តិ។ បើធ្វើដូច្នេះវាមិនខុសអ្វីពីការបង្វិលជំនួយបញ្ច្រាសទៅវិញនោះទេ ឧទាហរណ៍ធនធានហិរញ្ញវត្ថុពីកម្ពុជា នឹងហូរចេញទៅក្រៅទៅបង្កើនចំណូលពន្ធនៃប្រទេសអភិវឌ្ឍន៍ទាំងនោះទៅវិញ។ ជាលទ្ធផល គេត្រូវដាក់ចេញភ្លាមៗនូវវិធានការដើម្បីរឹតបន្តឹងការលើកទឹកចិត្តពន្ធនេះ គឺដើម្បីបង្ការការបង្វិលជំនួយបរទេសបញ្ច្រាសទៅវិញនេះឯង ដ្បិតប្រទេសកម្ពុជាជាប្រទេសក្រីក្រ តែបែរជាមានកាតព្វកិច្ចក្នុងការផ្តល់ជំនួយថវិកាទៅជួយឧបត្ថម្ភដល់ប្រទេសអភិវឌ្ឍន៍ទៅវិញ។

រាជរដ្ឋាភិបាលកម្ពុជាបានពិនិត្យឡើងវិញនូវប្រព័ន្ធលើកទឹកចិត្តនេះ (អនុក្រឹត្រលេខ៥៣ ចុះថ្ងៃទី១១ ខែមិថុនាឆ្នាំ១៩៩៩)។ ជំហានបន្ទាប់គឺត្រូវធ្វើវិសោធនកម្មច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយសេវាប្រឹក្សាយោបល់វិនិយោគក្រៅប្រទេស (FIAS)/សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) នៃក្រុមធនាគារពិភពលោក ដើម្បីរៀបចំសេចក្តីព្រាងវិសោធនកម្មនៃច្បាប់វិនិយោគ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣.៣. វិស័យហិរញ្ញវត្ថុសាធារណៈ

ទិសដៅរយៈពេលវែងនៃគោលនយោបាយសារពើពន្ធ គឺដើម្បីធានាកម្រិតចំណាយឱ្យមានសង្គតិភាពជាមួយនឹងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីរក្សាឱ្យបាននូវសារពើពន្ធដែលមានចីរភាពមួយ មានតុល្យភាពគ្នាទៅនឹងកំណើនជាលំដាប់ ក្នុងការបែងចែកថវិកាសម្រាប់វិស័យសង្គមនិងសេដ្ឋកិច្ច តាមរយៈការធ្វើវិចារណកម្មចំណាយសាធារណៈនិងពង្រីកមូលដ្ឋានយកពន្ធ បង្ការការធ្លះធ្លាយ និងពង្រឹងរដ្ឋបាលគយនិងពន្ធដារដើម្បីប្រមូលចំណូលបន្ថែម។

ទិសដៅនៃគោលនយោបាយសារពើពន្ធសម្រាប់រយៈពេលមធ្យម គឺដើម្បីពង្រឹងការប្រមូលចំណូល និងតម្រង់ទិសចំណាយ ដើម្បីឆ្លើយតបនឹងអាទិភាពចំណាយសម្រាប់កាត់បន្ថយភាពក្រីក្រ។ នៅចុងឆ្នាំ ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកម្មវិធីកំណែទម្រង់លម្អិតច្រើនឆ្នាំដើម្បីសម្រេចទិសដៅនេះ។ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះត្រូវបានបង្កើតឡើង ដើម្បីធ្វើឱ្យហិរញ្ញវត្ថុសាធារណៈមានលក្ខណៈប្រសើរឡើងដើម្បីផ្ដល់ការគាំទ្រប្រកបដោយប្រសិទ្ធភាពសម្រាប់កំណើន និងការកាត់បន្ថយភាពក្រីក្រ តាមរយៈការកែលម្អអភិបាលកិច្ចល្អ។ គេបានធ្វើសកម្មភាពពង្រឹងប្រសិទ្ធភាពដំណើរការថវិកា និងកែលម្អការគ្រប់គ្រងថវិកា រួមទាំងការអនុម័តតារាងគណនីថ្មី បន្ទាត់ថវិកាថ្មី និងការណែនាំឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS)។

ចាប់តាំងពីឆ្នាំ២០០៤មក មានវឌ្ឍនភាពជាច្រើនដើម្បីកែលម្អការប្រមូលចំណូលដោយរាជរដ្ឋាភិបាលកម្ពុជាកំពុងឯកភាពគ្នាជាផ្លូវមួយ ឆ្ពោះទៅសម្រេចប្រមូលចំណូលឱ្យបាន១៣.៣% នៃ ផ.ស.សសម្រាប់ឆ្នាំ២០០៨។ ចំណាយចរន្តត្រូវបានថយចុះដល់៩% នៃផ.ស.ស ដោយសារតែអតិរេកថវិកាដំបូងស្មើនឹង៣.៧% នៃផ.ស.ស។ ប្រការនេះបាននាំឱ្យមានការធ្លាក់ចុះក្នុងឱនភាពសរុបដល់2¾% នៃផ.ស.សក្នុងឆ្នាំ២០០៨ ធ្លាក់ចុះពី៧¼% ក្នុងឆ្នាំ២០០២។ គោលនយោបាយសារពើពន្ធនៅតែបន្តមានភាពជាក់ស្ដែងក្នុងឆ្នាំ២០០៨ ដើម្បីទប់ស្កាត់អតិផរណា។

*តារាង៣.៣ ប្រទេសកម្ពុជា៖ សូចនាករវិស័យហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០១-២០០៨*
*(គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប)*

| | ៩៨ | ៩៩ | ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ | ០៧ | ០៨ |
|---|---|---|---|---|---|---|---|---|---|---|
| វិស័យហិរញ្ញវត្ថុសាធារណៈ | | | | | | | | | | |
| ចំណូលសរុប | 8.3 | 9.9 | 10.0 | 10.6 | 9.8 | 10.4 | 10.6 | 11.4 | 12.1 | 13.3 |
| ចំណូលពន្ធ | 5.1 | 7.2 | 7.2 | 7.6 | 6.8 | 7.7 | 7.7 | 8.0 | 10.2 | 11.2 |
| ពន្ធក្នុងស្រុក | 1.2 | 4.0 | 4.8 | 5.0 | 4.7 | 5.3 | 5.5 | 5.9 | 7.3 | 8.4 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 4.0 | 3.2 | 2.4 | 2.5 | 2.1 | 2.4 | 2.2 | 2.2 | 2.9 | 2.8 |
| ចំណូលមិនមែនពន្ធ | 3.2 | 2.6 | 2.7 | 3.0 | 2.8 | 2.5 | 2.2 | 2.1 | 1.8 | 1.9 |
| ចំណូលមូលធន | 0.0 | 0.1 | 0.1 | 0.1 | 0.2 | 0.1 | 0.6 | 1.3 | 0.0 | 0.2 |
| ចំណាយសរុប | 14.0 | 13.6 | 16.4 | 18.0 | 16.2 | 14.2 | 13.2 | 14.1 | 14.7 | 15.7 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ចំណាយចរន្ត | 9.3 | 8.2 | 9.3 | 9.7 | 9.7 | 8.5 | 8.0 | 8.3 | 8.6 | 9.0 |
| ប្រាក់ឈ្នួលនិងប្រាក់បៀវត្ស | 4.1 | 3.9 | 3.3 | 3.5 | 3.3 | 3.0 | 2.8 | 2.8 | 3.0 | 3.4 |
| រដ្ឋបាលស៊ីវិល | 4.9 | 4.5 | 6.2 | 6.8 | 7.1 | 5.9 | 5.7 | 6.0 | 6.2 | 6.9 |
| យោធានិងសន្តិសុខ | 4.4 | 3.5 | 2.7 | 2.4 | 2.2 | 2.0 | 1.8 | 1.7 | 1.8 | 1.9 |
| ការទូទាត់ការប្រាក់ | 0.01 | 0.17 | 0.14 | 0.16 | 0.18 | 0.23 | 0.21 | 0.17 | 0.20 | 0.19 |
| បំណុលខាងក្រៅ | 0.01 | 0.17 | 0.14 | 0.16 | 0.18 | 0.23 | 0.21 | 0.17 | 0.20 | 0.19 |
| ការចំណាយទៅលើទ្រព្យសម្ភារបរិក្ខារ | 4.7 | 5.4 | 7.0 | 8.3 | 6.4 | 5.7 | 5.2 | 5.7 | 6.1 | 6.3 |
| សមតុល្យដំបូង(រួមទាំងជំនួយឧបត្ថម្ភ) | -1.0 | 1.8 | 1.1 | 1.1 | 1.0 | 1.9 | 2.0 | 1.4 | 3.4 | 3.7 |
| ឱនភាពសរុប | -1.0 | 1.6 | 1.0 | 1.0 | 0.8 | 1.7 | 1.8 | 1.2 | 3.2 | 3.5 |
| ឱនភាពសរុប(រួមទាំងជំនួយឧបត្ថម្ភ) | 5.9 | -3.8 | -6.0 | -7.2 | -5.4 | -3.8 | -2.7 | -3.3 | -2.8 | -2.7 |
| ហិរញ្ញប្បទានក្នុងស្រុក | -0.2 | -0.3 | 0.1 | -1.0 | 0.5 | -0.5 | -1.5 | -1.6 | -2.2 | -3.3 |
| ហិរញ្ញប្បទានខាងក្រៅ | 6.1 | 3.9 | 5.7 | 7.4 | 4.9 | 4.3 | 4.4 | 4.8 | 5.2 | 5.8 |

*ប្រភពៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,ធនាគារជាតិកម្ពុជា*

ការអនុវត្តកំណែទម្រង់ស៊ីជម្រៅ ដែលចាប់ផ្ដើមក្នុងឆ្នាំ២០០៧ គឺមានទាំងការកាត់បន្ថយនីតិវិធីក្នុងការអនុវត្តថវិកា ការដាក់ឱ្យអនុវត្តនូវថវិកាកម្មវិធី និងការអនុម័តតារាងគណនីថ្មី។ វិធានការទាំងនេះ គឺជាការបន្តអនុវត្តនូវវិធានការកំណែទម្រង់ស៊ីជម្រៅ ដែលចាប់ផ្ដើមនៅក្នុងឆ្នាំ២០០៥ និង២០០៦ ជាពិសេសៈ ការប្រមូលចំណូលពន្ធគយនិងពន្ធដារតាមប្រព័ន្ធធនាគារ ការបើកផ្ដល់ថវិកាតាមរតនាគារទៅឱ្យអ្នកផ្គត់ផ្គង់ដោយប្រើប្រាស់មូលប្បទានប័ត្រឬសាច់ប្រាក់ ការលុបបំបាត់ចោលនូវបំណុលបុរេប្រទានចាស់ ដែលក្រសួងស្ថាប័នមិនបានទូទាត់ ការកាត់បន្ថយនូវនីតិវិធីលទ្ធកម្ម និងការពង្រឹងនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៅតាមក្រសួងនិងស្ថាប័នដែលមានការពាក់ព័ន្ធ។

## ៣.៣.១. ចំណូល

ចំណូលក្នុងស្រុកបានកើនឡើងពី១០៦លានដុល្លារសហរដ្ឋអាមេរិកឬ៤.៣.% នៃផ.ស.ស នៅឆ្នាំ១៩៩៣ ដល់២៤៩លានដុល្លារសហរដ្ឋអាមេរិកឬ៨.0% នៃផ.ស.សក្នុងឆ្នាំ១៩៩៨ និងទៅដល់១.៣៧ពាន់លានដុល្លារសហរដ្ឋអាមេរិកឬ១៣.៣% នៃផ.ស.សក្នុងឆ្នាំ២០០៨ និងកើនឡើង៥.៣%នៃផ.ស.សឬកើនឡើងជាង៥ដងក្នុងអំឡុងឆ្នាំ១៩៩៨-២០០៨។ ចំណូលថវិកាសរុបបានកើនឡើងក្នុងអំឡុងឆ្នាំ២០០៤-២០០៨ដោយសារតែការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយជោគជ័យ។

វិធានការនានាត្រូវបានអនុវត្ត ដើម្បីពង្រឹងការអនុវត្តច្បាប់ពន្ធដារ កែលម្អការប្រមូលចំណូល ពង្រីកមូលដ្ឋានពន្ធ ដើម្បីក្ដោបបញ្ចូលទាំងវិស័យក្រៅផ្លូវការនិងពង្រឹងសវនកម្មពន្ធ។ វិធានការផ្សេងទៀតរួមមានការរៀបចំនាយកដ្ឋានពន្ធដារឡើងវិញ ការធ្វើទំនើបភាវូបនីយកម្មនាយកដ្ឋានគយនិងរដ្ឋាករ ការបង្កើត



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

នាយកដ្ឋានចំណូលមិនមែនពន្ធ និងការពង្រឹងការអនុវត្តផែនការប្រឆាំងការរត់ពន្ធ។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលបានខិតខំអនុវត្តវិធានការយ៉ាងហ្មឹងម៉ាត់ ដើម្បីផ្ទេរចំណូលដែលប្រមូលបានទាំងអស់ ទៅដាក់ក្នុងរតនាគារជាតិដោយត្រង់ និងហាមឃាត់ការអនុគ្រោះពន្ធលើសពីកម្រិត ដែលអនុញ្ញាតដូចមានចែងក្នុងច្បាប់វិនិយោគ។ សម្តេចនាយករដ្ឋមន្ត្រីក៏បានចេញនូវបទបញ្ជានៅក្នុងឆ្នាំ ២០០៥ ដើម្បីបង្កើតនីតិវិធីដេញថ្លៃប្រកបដោយតម្លាភាពសម្រាប់កិច្ចសន្យាសម្បទានរបស់រាជរដ្ឋាភិបាល នៅពេលអនាគតផងដែរ។

### ៣.៣.១.១. ចំណូលពន្ធ

ចំណូលពន្ធបានកើនឡើងដល់១១.២% នៃផ.ស.សក្នុងឆ្នាំ២០០៨ ប្រៀបធៀបទៅនឹង៥.៨% នៃផ.ស.សក្នុងឆ្នាំ១៩៩៨ ដែលជាការកើនឡើងស្មើនឹង៥.៤% នៃផ.ស.ស។ ក្នុងអំឡុងឆ្នាំ២០០៤-២០០៨ ចំណូលពន្ធបានកើនឡើង៣.៥% នៃផ.ស.ស។ ការអនុវត្តនេះឆ្លុះបញ្ចាំងអំពីកិច្ចខិតខំរបស់ប្រទេសកម្ពុជា ដើម្បីកែលម្អរដ្ឋបាលពន្ធដារនិងពន្ធគយ ការប្តេជ្ញាចិត្តក្នុងការអនុវត្តច្បាប់ដោយគ្មានការលើកលែងចំពោះការគេចពន្ធនិងវិធានការពន្ធផ្សេងៗមួយចំនួនទៀត។ កំណែទម្រង់ពន្ធនឹងនៅតែបន្តដោយប្រកាន់នូវទស្សនៈមួយ គឺដើម្បីពង្រឹងការអនុវត្តតាមការបង់ពន្ធ និងពង្រឹងការប្រមូលពន្ធតាមរបបមៅការ។ ពាក់ព័ន្ធនឹងប្រការនេះ វិស័យឯកជនគប្បីអនុវត្តឱ្យបានពេញលេញ តាមកាតព្វកិច្ចសារពើពន្ធរបស់ខ្លួន។

*គំនូសតាង៣.៩ការប្រមូលចំណូលឆ្នាំ១៩៩៣-២០០៨ (គិតជាលានដុល្លារសហរដ្ឋអាមេរិក)*




*ប្រភព៖ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

### ៣.៣.១.២. ចំណូលមិនមែនពន្ធ

ចំណូលមិនមែនពន្ធបានកើនឡើងពី២៦លានដុល្លារសហរដ្ឋអាមេរិកឬ ១.០% នៃផ.ស.សក្នុងឆ្នាំ ១៩៩៣ ដល់៦០លានដុល្លារសហរដ្ឋអាមេរិកឬ១.៩%នៃផ.ស.សក្នុងឆ្នាំ១៩៩៨ ហើយឡើងដល់១៩៧លានដុល្លារសហរដ្ឋអាមេរិក ឬ១.៩%នៃផ.ស.សក្នុងឆ្នាំ២០០៨។ ភាពប្រសើរឡើងក្នុងការប្រមូលចំណូលនេះ ឆ្លុះបញ្ចាំងកិច្ចខិតខំ ដើម្បីទាញយកមកវិញនូវចំណូលពីផ្នែកប្រៃសណីយ៍និងទូរគមនាគមន៍ ការជួលទ្រព្យសម្បត្តិរដ្ឋ ការពង្រឹងការប្រមូលចំណូលទិដ្ឋាការ និងចំណូលទេសចរណ៍។

ជារួម ចំណូលដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករប្រមូលបានមានចំនួនស្មើនឹង៥៥% នៃចំណូលចរន្ត (៦៨៤លានដុល្លារសហរដ្ឋអាមេរិក) ចំណូលដែលប្រមូលបានដោយអគ្គនាយកដ្ឋានពន្ធដារមានចំនួនស្មើនឹង២៩% (៣៦៣លានដុល្លារសហរដ្ឋអាមេរិក) ចំណែកឯចំណូលមិនមែនពន្ធមានចំនួនស្មើនឹង១៦% នៃចំណូលចរន្ត (១៩៧លានដុល្លារសហរដ្ឋអាមេរិក)។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងពេលនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពីឆ្នាំ២០០៤ ដល់២០០៨នេះ ចំណូលដែលប្រមូលបានពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកើនឡើងជាងពីរដង គឺពី២៨៩លានដុល្លារសហរដ្ឋអាមេរិកដល់៦៨៤លានដុល្លារសហរដ្ឋអាមេរិក ចំណូលដែលប្រមូលបានពីអគ្គនាយកដ្ឋានពន្ធដារបានកើនឡើងជិតបីដង គឺពី១៤លានដុល្លារសហរដ្ឋអាមេរិកដល់ ៣៦៣លានដុល្លារសហរដ្ឋអាមេរិក ហើយចំណូលមិនមែនពន្ធបានកើនឡើង៤៥% ពី១៤០លានដុល្លារសហរដ្ឋអាមេរិក ដល់១៩៧លានដុល្លារសហរដ្ឋអាមេរិក។

### ៣.៣.១.៣. ចំណូលមូលធន

ចំណូលមូលធនពុំមានលក្ខណៈថេរទេគឺកើនឡើងពី ៣លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ ១៩៩៥ ទៅ៩លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៨ រួចហើយកើនខ្លាំងដល់៩២លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៦ ប៉ុន្តែធ្លាក់ចុះមកវិញរហូតដល់២០លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៨។ ចំណូលមូលធនបានមកភាគច្រើនពីការធ្វើឯកជនភាវូបនីយកម្មនៃទ្រព្យសម្បត្តិរដ្ឋ។

## ៣.៣.២. ចំណាយ

ការអនុវត្តចំណូលដែលមានលក្ខណៈកាន់តែល្អប្រសើរនេះ បានបង្កើតនូវលក្ខខណ្ឌអំណោយផលសម្រាប់ធានានូវការអនុវត្តចំណាយខ្ពស់ជាងមុន ប៉ុន្តែភាគច្រើនតែក្នុងវិស័យសង្គមកិច្ច វិស័យកសិកម្ម ដូចជាការវិនិយោគលើការសាងសង់ប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រព និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាផ្លូវថ្នល់និងវិស័យថាមពល។ ចំណាយសរុបបានកើនឡើងជាងបីដងក្នុងទសវត្សរ៍កន្លងទៅនេះ។

ចំណាយសរុបបានកើនឡើងពី២២២លានដុល្លារសហរដ្ឋអាមេរិកឬ៨.៩%នៃផ.ស.សក្នុងឆ្នាំ១៩៩៣ ទៅ៤១៣លានដុល្លារសហរដ្ឋអាមេរិកឬ១៣.៣%នៃផ.ស.សក្នុងឆ្នាំ១៩៩៨ និងដល់១.៦ពាន់លានដុល្លារអាមេរិកឬ១៥.៦%នៃផ.ស.សក្នុងឆ្នាំ២០០៨។ ក្នុងមួយទសវត្សរ៍កន្លងទៅនេះចំណាយសរុបបានកើនឡើងជាងបីដង ចំណែកឯក្នុងអំឡុងពេលនៃការកែទម្រង់ក្នុងឆ្នាំ២០០៤-២០០៨កំណើននេះមានច្រើនជាងពីរដង។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលប្រយោជន៍ពីមូលនិធិផ្តួចផ្តើមលើកលែងបំណុលរយៈពេលមធ្យមនៃមូលនិធិរូបិយវត្ថុអន្តរជាតិ (ចំនួន៨២លានដុល្លារសហរដ្ឋអាមេរិក) ដែលត្រូវបានយកមកប្រើប្រាស់ក្នុងការបង្កើនការចំណាយយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធជនបទ។

***គំនូសតាង៣.១០ចំណាយៈឆ្នាំ១៩៩៣-២០០៨ (គិតជាលានដុល្លារសហរដ្ឋអាមេរិក)***




*គំនូសតាង៣.១០ចំណាយៈឆ្នាំ១៩៩៣-២០០៨ (គិតជាលានដុល្លារសហរដ្ឋអាមេរិក)*

### ៣.៣.២.១. ចំណាយចរន្ត

ចំណាយចរន្តបានកើនឡើងពី១៣៦លានដុល្លារសហរដ្ឋអាមេរិក (៥.៥% នៃផ.ស.ស) ក្នុងឆ្នាំ១៩៩៣ ដល់២៨៦លានដុល្លារសហរដ្ឋអាមេរិក (៧.៩% នៃផ.ស.ស) ក្នុងឆ្នាំ១៩៩៨និងដល់៩៣០លានដុល្លារសហរដ្ឋអាមេរិក (៩% នៃផ.ស.ស) ក្នុងឆ្នាំ២០០៨។ ក្នុងមួយទសវត្សរ៍កន្លងទៅនេះ ចំណាយបច្ចុប្បន្នកើនឡើងលើសពីបីដង និងកើនឡើងលើសពីពីរដងក្នុងអំឡុងពេលនៃកំណែទម្រង់ឆ្នាំ២០០៤-២០០៨។ បៀវត្សមន្ត្រីរាជការនិងកងទ័ពនិងមន្ត្រីសន្តិសុខបានធ្លាក់ចុះ ពី៦.៧% នៃផ.ស.ស ឬ៧២% នៃចំណាយចរន្តក្នុងឆ្នាំ១៩៩៤ ដល់ ៣.៦% នៃផ.ស.ស ឬ៨៤% នៃចំណាយចរន្តក្នុងឆ្នាំ២០០៧ ប៉ុន្តែក្រោយមកបានកើនឡើងដល់៤.៦% នៃផ.ស.សដែលស្មើនឹង៥១% នៃចំណាយចរន្តក្នុងឆ្នាំ២០០៨។ ការកើនឡើងនៃចំណាយប្រាក់បៀវត្សក្នុងឆ្នាំ២០០៨ បានឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការតម្លើងប្រាក់បៀវត្សមន្ត្រីរាជការនិងកងទ័ពនិងមន្ត្រីសន្តិសុខចំនួន២០% ក្នុងមួយឆ្នាំ និងការអនុវត្តកំណែទម្រង់មុខងារសាធារណៈក្រោមកម្មវិធីគំនិតផ្តួចផ្តើមបៀវត្សផ្អែកលើគុណសម្បត្តិ និងគម្រោងក្រុមការងារអាទិភាព។ ប្រការនេះចាត់ទុកថាជាចំណាយមួយដោយគិតគូលើធនធានមនុស្ស ដ្បិតវាមានសារៈសំខាន់ខ្លាំងសម្រាប់ការកសាងសមត្ថភាពស្ថាប័ន ហើយអាចមានផលវិជ្ជមានដល់ការពង្រឹងអភិបាលកិច្ចក្នុងរយៈពេលមធ្យម។

ចំណាយផ្នែកយោធានិងសន្តិសុខមានចំនួន ២២% នៃចំណាយចរន្តក្នុងឆ្នាំ ២០០៨ ហើយចំណាយលើរដ្ឋបាលស៊ីវិលមានចំណែកស្មើនឹង ៧៦%។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលចំណាយយោធានិងសន្តិសុខដែលជាចំណាយចរន្ត ទៅតាមលក្ខណៈធម្មជាតិនៃចំណាយផ្នែកនេះ ចំណាយខាងរដ្ឋបាលស៊ីវិលរួមមានទាំងចំណាយថវិកាចរន្តផង និងចំណាយថវិកាមូលធនផង។

ចាប់តាំងពីឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានកាត់បន្ថយការចំណាយផ្នែកយោធានិងសន្តិសុខ បន្ទាប់ពីអង្គការយោធានិងនយោបាយរបស់ខ្មែរក្រហមត្រូវបានរំលាយចោល ហើយចំណាយនេះត្រូវបានបង្វែរទៅខាងចំណាយផ្នែកសង្គមវិញ។ ចំណែកនៃការចំណាយការពារជាតិនិងសន្តិសុខក្នុងផ.ស.សបានថយចុះជាលំដាប់ ពី៥.១% ក្នុងឆ្នាំ១៩៩៥ ដល់៣.៥% ក្នុងឆ្នាំ១៩៩៩ បន្ទាប់មកចុះដល់១.៧% ក្នុងឆ្នាំ ២០០៦។ ក៏ប៉ុន្តែ ចំណាយផ្នែកការពារជាតិនិងសន្តិសុខបានកើនឡើងវិញដល់១.៩%នៃផ.ស.សវិញ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជា ត្រូវចំណាយសម្រាប់ការពង្រឹងការការពារបូរណភាពដែនដីរបស់កម្ពុជា។ ក្នុងអំឡុងឆ្នាំ១៩៩៤-១៩៩៨ ចំណាយលើផ្នែកសុខាភិបាល និងអប់រំសម្រេចបានត្រឹម ១.៣% នៃផ.ស.ស។

*គំនូសតាង៣.១១ចំណែកនៃការចំណាយក្នុងថវិកាផ្នែកការពារជាតិនិងវិស័យសង្គម*






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចាប់តាំងពីឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ដល់ការបង្កើនចំណាយលើវិស័យសេដ្ឋកិច្ចនិងសង្គម ជាពិសេសវិស័យអប់រំសុខាភិបាល កសិកម្ម និងការអភិវឌ្ឍជនបទ។ ចំណាយលើវិស័យសុខាភិបាលនិងអប់រំបានកើនឡើងពី១.៧% នៃផ.ស.សក្នុងឆ្នាំ១៩៩៩ ដល់២.៧% ក្នុងឆ្នាំ២០០២។ ក្នុងអំឡុងឆ្នាំ២០០៤-២០០៨ ចំនួននេះកើនឡើងបន្តិច ពី២.២% ទៅ២.៤%។ ក្រសួងសុខាភិបាលនិងអប់រំបានណែនាំឱ្យប្រើប្រាស់អភិក្រមគ្របដណ្តប់តាមវិស័យ (SWAP) តាមរយៈការរៀបចំគោលនយោបាយធ្វើផែនការរៀបចំថវិកា ការត្រួតពិនិត្យនិងវាយតម្លៃដំណើរការ ស្របតាមយុទ្ធសាស្ត្រតាមវិស័យ ហើយបន្តិចៗម្តងធ្វើការតម្រង់អាទិភាពឡើងវិញដើម្បីផ្តោតទៅលើការកាត់បន្ថយភាពអ្នកក្រ។

ការកើនឡើងនៃចំណាយផ្នែកសង្គមនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បាននាំឱ្យមាននិន្នាការវិជ្ជមានក្នុងលទ្ធផលផ្នែកអប់រំនិងសុខាភិបាល។ ការបង្កើតយុទ្ធសាស្ត្រតាមវិស័យនិងប្រព័ន្ធផ្ទៀងផ្ទាត់សម្រាប់ការធ្វើផែនការការរៀបចំថវិកានិងការត្រួតពិនិត្យនិងវាយតម្លៃ បានផ្តល់ក្របខ័ណ្ឌមួយ ដែលនាំឱ្យមានការវិនិយោគក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (មានសាលារៀននិងមន្ទីរព្យាបាលរោគ) និងការកើនឡើងចំនួនអ្នកមានវិជ្ជាជីវៈជំនាញនិងកម្មករក្នុងផ្នែកអភិវឌ្ឍន៍សង្គម (មានគ្រូបង្រៀន វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកា) និងបានកែលម្អគុណភាពផ្នែកផ្តល់សេវាជូរមុខរបស់បុគ្គលិក និងបានជួយឱ្យមានការកើនឡើងក្នុងសូចនាករនៃចំនួនការអភិ-វឌ្ឍធនធានមនុស្ស។ ការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សាបានកើនឡើងយ៉ាងច្រើន។ អត្រាជុលនៃការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សាមានលក្ខណៈប្រសើរឡើងជាងមុន ប៉ុន្តែអត្រាជុលនៃការចុះឈ្មោះចុះរៀនថ្នាក់អនុវិទ្យាល័យមានការថយចុះ។ ជាមួយគ្នាផងដែរផ្នែកសុខាភិបាលបានទទួលជោគជ័យគួរឱ្យកត់សម្គាល់ ក្នុងការគ្រប់គ្រងនិងកាត់បន្ថយការរីករាលដាលនៃមេរោគហ៊ីវនិងអត្រាមរណៈភាពទារកនិងកុមារអាយុក្រោមប្រាំឆ្នាំមានការថយចុះច្រើន ទោះបីជាការថយចុះនេះពុំទាន់ឆ្លើយតបបានទៅនឹងបទដ្ឋានតំបន់យ៉ាងណាក៏ដោយ។

### ៣.៣.២.២. ចំណាយមូលធន

ចំណាយមូលធនមានចំណាយហិរញ្ញប្បទានក្នុងស្រុក ឧទាហរណ៍ហិរញ្ញប្បទានដែលបានពីចំណូលក្នុងស្រុក និងចំណាយហិរញ្ញប្បទានខាងក្រៅ ឧទាហរណ៍ហិរញ្ញប្បទានដែលបានពីដៃគូអភិវឌ្ឍឧបតោភាគីនិងពហុភាគី ក្នុងរូបភាពជាជំនួយឧបត្ថម្ភនិងកម្ចីសម្បទាន។

ចំណាយមូលធនសរុបបានកើនឡើងពី៨៦លានដុល្លារសហរដ្ឋអាមេរិកឬ៣.៥% នៃផ.ស.សក្នុងឆ្នាំ១៩៩៣ ទៅ១៦៦លានដុល្លារសហរដ្ឋអាមេរិកឬ៥.៤%នៃផ.ស.សក្នុងឆ្នាំ១៩៩៨ និងកើនដល់៦៥៤លានដុល្លារសហរដ្ឋអាមេរិកឬ៦.៣%នៃផ.ស.សក្នុងឆ្នាំ២០០៨។ ក្នុងទសវត្សរ៍កន្លងទៅនេះចំណាយមូលធនសរុបកើនឡើងលើសពីបីឡើង។ ចំណាយហិរញ្ញប្បទានក្នុងស្រុកបានកើនឡើងពី២៦លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៣ ដល់៣១លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៨ និងដល់១៧៥លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៨។ ចំណាយហិរញ្ញប្បទានក្នុងស្រុកបានកើនឡើងបីដងក្នុងអំឡុងមួយទសវត្សរ៍ចុងក្រោយនេះ និងបានកើនឡើងជាងពីរដងចាប់តាំងពីឆ្នាំ២០០៤។ ចំណាយមូលធនដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលគឺមានជាសំខាន់នៅក្រសួងបី៖ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងធនធានទឹកនិងឧត្តុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ។ ចំណាយទៅលើទ្រព្យសម្ភារបរិក្ខារ ដែលធ្វើហិរញ្ញប្បទានពីខាងក្រៅ (ភាគច្រើន ពី

ធនាគារអភិវឌ្ឍន៍អាស៊ីនិងធនាគារពិភពលោក) បានកើនឡើងពី៩៧លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៤ ដល់១៧១លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៩៨ និងដល់៤៧៨លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៨។ ចំណាយហិរញ្ញប្បទានខាងក្រៅបានកើនឡើង ៣.៦ដង ក្នុងអំឡុងពេលមួយទសវត្សរ៍ចុងក្រោយនេះនិងបានកើនឡើងទ្វេដងក្នុងអំឡុងឆ្នាំ២០០៤-២០០៨។

### ៣.៣.៣. សមតុល្យថវិកា

ថវិកាចរន្តបានងាកពីឱនភាពប្រមាណ១% នៃផ.ស.សទៅអតិរេក១.៦% នៃផ.ស.សក្នុងឆ្នាំ១៩៩៩ និងដល់៣.៥%នៃផ.ស.សក្នុងឆ្នាំ២០០៨។ ការកើនឡើងក្នុងអតិរេកថវិកាចរន្តក្នុងអំឡុងពេលនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុញ្ញាតឱ្យរាជរដ្ឋាភិបាលបង្កើនមូលធនចំណាយសម្រាប់ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច។ ឱនភាពថវិកាសរុបមានពី៤.១% ទៅ៦.៧% នៃផ.ស.សក្នុងឆ្នាំ១៩៩៣-១៩៩៨។ ឱនភាពនេះបានធ្លាក់ចុះពី៧.២%នៃផ.ស.សក្នុងឆ្នាំ២០០២ ដល់២.៧%នៃផ.ស.សក្នុងឆ្នាំ២០០៨។ ឱនភាពថវិកាសរុបត្រូវបានផ្តល់ហិរញ្ញប្បទាន ដោយកម្ចីសម្បទាននិងជំនួយឧបត្ថម្ភដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍របស់កម្ពុជា។ យុទ្ធសាស្ត្រសារពើពន្ធរបស់កម្ពុជា មិនអនុញ្ញាតឱ្យធ្វើហិរញ្ញប្បទានជារូបិយវត្ថុលើឱនភាពថវិកាឡើយ។

### ៣.៣.៤. គោលនយោបាយសារពើពន្ធក្នុងឆ្នាំ២០០៩

គោលនយោបាយសារពើពន្ធមានលក្ខណៈទូលំទូលាយក្នុងឆ្នាំ២០០៩។ ឱនភាពថវិកាឆ្នាំ២០០៩ បានកើនឡើងដល់ ៦¾នៃផ.ស.ស ប្រៀបធៀបនឹងគោលដៅពីដំបូង៤¼ភាគរយ (កើនឡើងពី២¾ភាគរយក្នុងឆ្នាំ២០០៨)។ ការធ្វើហិរញ្ញប្បទានក្នុងស្រុក (ការបន្ថយប្រាក់បញ្ញើរបស់រដ្ឋាភិបាល) ត្រូវបានព្យាករណ៍ទុកថាមានចំនួន ១¼ភាគរយនៃផ.ស.ស។ ចំណាយបានកើនឡើងយ៉ាងខ្លាំង ដោយមានការកើនឡើងច្រើននៃប្រាក់បៀវត្សរ៍និងចំណាយមូលធនហិរញ្ញប្បទានក្នុងស្រុក។ ជាទូទៅ ការប្រមូលចំណូលមានលក្ខណៈល្អប្រសើរ។ ពាក់ព័ន្ធនឹងផ្នែកចំណូលនេះ រាជរដ្ឋាភិបាលបានខិតខំបន្ថែមទៀតក្នុងឆ្នាំ២០១០ ដើម្បីពង្រឹងរដ្ឋបាលសារពើពន្ធ។ ពាក់ព័ន្ធនឹងផ្នែកចំណាយ រាជរដ្ឋាភិបាលនឹងជៀសវាងកំណើនចំណាយលើប្រាក់បៀវត្សរ៍ និងពង្រឹងការគោរពវិន័យថវិកា។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលនឹងខិតខំបន្ថែមទៀតដើម្បីបន្តកំណែទម្រង់ការគ្រប់គ្រងហិញ្ញវត្ថុសាធារណៈ និងបង្កើនគណនេយ្យភាព រួមទាំងការកែលម្អការធ្វើសមាហរណកម្មថវិកា ការបង្កើតគណនីរតនាគាររួមមួយ និងនីតិវិធីលទ្ធកម្មម៉ឺងម៉ាត់។

## ៣.៤. ទស្សនៈរូបិយវត្ថុ

### ៣.៤.១. ការអភិវឌ្ឍរូបិយវត្ថុ

គោលនយោបាយរូបិយវត្ថុមានគោលបំណងរក្សាស្ថេរភាពនៃតម្លៃ។ ធនាគារជាតិនៃកម្ពុជាប្រមើលឃើញថានិងមានអតិផរណាក្រោម៥% នៅពេលខ្លីនិង៣½% ក្នុងរយៈពេលមធ្យម។ បន្ទាប់ពីបានកើនឡើង ៣៨.២% ក្នុងឆ្នាំ២០០៦និង៦៣% ក្នុងឆ្នាំ២០០៧សន្ទនីយភាពនៃវិស័យធនាគារ (M2) បានកើនឡើងបន្តិចគឺតែ៤.៨% ប៉ុណ្ណោះក្នុងឆ្នាំ២០០៨។

ខាងក្រោមនេះជាការអភិវឌ្ឍខាងផ្នែករូបិយវត្ថុសំខាន់ៗក្នុងឆ្នាំ២០០៨៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- សន្ទនីយភាពបានកើនឡើង៤.៨%
- ទ្រព្យសកម្មបរទេសសុទ្ធនៃប្រព័ន្ធធនាគារបានថយចុះ៣.៦%
- ទ្រព្យសកម្មក្នុងស្រុកសុទ្ធនៃប្រព័ន្ធធនាគារបានកើនឡើង១៦៣%
- ប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលកើនឡើង៥៤%
- ឥណទានទៅវិស័យឯកជនកើនឡើង៥៥%

*តារាង៣.៤ប្រទេសកម្ពុជា៖សូចនាករវិស័យរូបិយវត្ថុឆ្នាំ២០០១-២០០៨*

| | ៩៤ | ៩៩ | ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ | ០៧ | ០៨ |
|---|---|---|---|---|---|---|---|---|---|---|
| វិស័យរូបិយវត្ថុ | | | | | | | | | | |
| អតិផរណា(% ចុងឆ្នាំ) | 17.8 | 0.0 | -0.5 | 3.0 | 0.5 | 5.8 | 6.8 | 3.4 | 9.7 | 15.8 |
| អតិផរណា (% មធ្យម) | -0.7 | 4.0 | -0.9 | -0.1 | 1.2 | 3.9 | 5.8 | 4.7 | 5.9 | 19.7 |
| បរិត្តផរណា(% ប្រែប្រួល) | -4.4 | 2.0 | 2.6 | 0.7 | 1.8 | 4.8 | 6.1 | 4.6 | 6.5 | 12.3 |
| អត្រាប្តូរប្រាក់ | 2,570 | 3,814 | 3,924 | 3,921 | 3,975 | 4,016 | 4,092 | 4,103 | 4,068 | 4,060 |
| សន្ទនីយភាព(កំណើនជា %) | 35.1 | 17.2 | 22.3 | 28.9 | 15.3 | 30.4 | 16.1 | 38.2 | 62.9 | 4.8 |
| ល្បឿនវិលជុំ(ផ.ស.ស) | 15.7 | 9.2 | 7.0 | 5.8 | 5.6 | 5.0 | 5.1 | 4.3 | 3.1 | 3.5 |
| ឥណទានវិស័យឯកជន (% នៃM2) | 52.6 | 52.9 | 41.7 | 36.7 | 40.2 | 42.0 | 43.9 | 52.3 | 56.4 | 83.4 |

*ប្រភព៖ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធនាគារជាតិនៃកម្ពុជា*

## ៣.៤.២. សន្ទនីយភាព

កំណើននៃសន្ទនីយភាព (M2) ក្នុងឆ្នាំ២០០៨ គឺដោយសារកំណើនឆាប់រហ័សក្នុងទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ប្រព័ន្ធធនាគារ (១៦២.៧%) ប៉ុន្តែត្រូវបានកាត់បន្ថយដោយការធ្លាក់ចុះនៃទ្រព្យសកម្មបរទេសសុទ្ធនៃប្រព័ន្ធធនាគារអស់៣.៦%។ បន្ទាប់ពីមានកំណើន៦% ពី១.៧ ពាន់លានដុល្លារក្នុងឆ្នាំ២០០៦ ដល់ ២.៨ ពាន់លានដុល្លារក្នុងឆ្នាំ២០០៧ សន្ទនីយភាពនៃប្រព័ន្ធធនាគារឬការផ្គត់ផ្គង់សាច់ប្រាក់ជាទូទៅបានកើនឡើងត្រឹមតែ៤.៨% ដល់២.៩ ពាន់លានដុល្លារក្នុងឆ្នាំ២០០៨ ឬ២៨.៣% នៃផ.ស.ស។ ប្រការនេះឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌរូបិយវត្ថុ ដែលកាន់តែតឹងតែងក្នុងអំឡុងនៃវិបត្តិសេដ្ឋកិច្ចសាកលលោក។ ការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុនេះ គឺបង្កើតឡើងដើម្បីទប់ទល់តម្រូវខ្ពស់ផ្នែកប្រតិបត្តិការពាក់ព័ន្ធនឹងការពង្រីកសេដ្ឋកិច្ចក្នុងអត្រា៦.៧%ក្នុងឆ្នាំ២០០៨។

សន្ទនីយភាពនេះគឺបង្កើតឡើងជាចម្បងពីបញ្ញើរូបិយប័ណ្ណបរទេស ដែលមានចំនួនស្មើនឹង៧៨% នៃសន្ទនីយភាព រូបិយប័ណ្ណក្រៅធនាគារមានចំណែកស្មើនឹង ១៩% និងកត្តាសេសសល់ ៣% ទៀត គឺបានមកពីបញ្ញើតាមកាលកំណត់និងបញ្ញើសន្សំ។

*គំនូសតាង៣.១២. កំណើននៃរូបិយវត្ថុទូទៅក្នុងការផ្គត់ផ្គង់ ២០០០-២០០៧*




*ប្រភព៖ធនាគារជាតិនៃកម្ពុជា*

ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុបានចាប់ផ្តើមទើបតែក្នុងឆ្នាំ១៩៩៩ប៉ុណ្ណោះ ជាមួយនឹងការស្តារឡើងវិញនៃប្រព័ន្ធរូបិយវត្ថុ។ សមាភាគនៃទ្រព្យសកម្មហិរញ្ញវត្ថុ (M2) ចែក GDP ដែលជារង្វាស់នៃភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុនោះ ត្រូវបានប៉ាន់ស្មាននៅកម្រិត១០.៨% ក្នុងឆ្នាំ១៩៩៩។ ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុមានសន្ទុះកើនឡើងក្នុងអំឡុងឆ្នាំ១៩៩៩-២០០៨ ជាមួយនឹងសមាសភាគ M2/GDP ឈានដល់៣២.៣% នៅត្រឹមបំណាច់ឆ្នាំ២០០៨។ សមាភាគនេះបានធ្លាក់ចុះដល់២៨.៥% ក្នុងខែមេសាឆ្នាំ២០០៩។

ការអភិវឌ្ឍនៃវិស័យធនាគារចាប់តាំងពីឆ្នាំ១៩៩៩ បានរួមចំណែកដល់ដំណើរការរូបិយវត្ថុនីយកម្មនៃសេដ្ឋកិច្ចជាតិ ពោលគឺការកើនឡើងនៃការប្រើប្រាស់នូវរូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច។ ដំណើរការនេះគៀរគរនូវដើមទុនពីធនាគារពាណិជ្ជកម្មនិងក្រុមហ៊ុនធានារ៉ាប់រងនានា ដើម្បីប្រមូលធនធានទាំងនេះសម្រាប់ផ្តល់ជូនអ្នកវិនិយោទុន។ ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុជាកត្តាសំខាន់ក្នុងដំណើរការរូបិយវត្ថុនីយកម្មនេះ ដែលបានបង្កើនកម្រិតប្រាក់សន្សំនិងការវិនិយោគ។ កំណើនសេដ្ឋកិច្ចខ្លាំងដែលកម្ពុជាបានជួបប្រទះតាំងពីឆ្នាំ១៩៩៩ បានរួមចំណែកដល់ការពង្រីកនូវទ្រព្យសកម្មហិរញ្ញវត្ថុក្នុងប្រព័ន្ធធនាគារ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គំនូសតាង៣.១៣a. សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ (លាន រៀល)




គំនូសតាង៣.១៣b. (M2/GDP)




*ប្រភព៖ ធនាគារជាតិកម្ពុជា*

### ៣.៤.២.១. ប្រាក់បញ្ញើ

ការពង្រីកនៃប្រាក់បញ្ញើរូបិយវត្ថុបរទេសរបស់និវាសនជននិងអនិវាសនជន បានក្លាយជាកត្តារួមចំណែកដ៏សំខាន់ នៃកំណើនសន្ទនិយភាព។ បន្ទាប់ពីសម្រេចបាននូវអត្រាកំណើនខ្ពស់បំផុតរបស់ខ្លួនក្នុងឆ្នាំ២០០៧មក សមាសធាតុរូបិយវត្ថុបរទេសនៃរូបិយវត្ថុទូទៅបានធ្លាក់ចុះបន្តិច ដោយកើនត្រឹមតែ១.៥% ពី២.២៩ពាន់លានដុល្លារអាមេរិកក្នុងខែធ្នូឆ្នាំ២០០៧ ដល់២.២៨ពាន់លានដុល្លារអាមេរិកក្នុងខែធ្នូឆ្នាំ២០០៨ និងឈានដល់២.៩៩ពាន់លានដុល្លារអាមេរិកក្នុងខែមេសាឆ្នាំ២០០៩។ ខណៈដែលប្រាក់បញ្ញើរូបិយវត្ថុបរទេសបន្តជំរុញកំណើននៃរូបិយវត្ថុទូទៅសមាសធាតុរបស់វាទាំងអស់គឺប្រាក់សន្សំរូបិយវត្ថុបរទេសប្រាក់បញ្ញើមានកាលកំណត់និងប្រាក់បញ្ញើចរន្តមានការគាំទ្រជាមួយវិនិយោគិន។ កំណើនក្នុងប្រាក់បញ្ញើចរន្តនិវេសនជនដែលត្រូវបានចារឹកជារូបិយវត្ថុក្នុងស្រុកនោះក៏មានសន្ទុះផងដែរ។ តែទោះជាយ៉ាងណាក្តីដោយសារតែទីតាំងមូលដ្ឋានទាបខ្លាំងរបស់វាការរួមចំណែកនៃចំណុចនេះចំពោះM1គឺជាភាពបន្ទាប់បន្សំ។ ប្រាក់បញ្ញើជាមួយនិងប្រព័ន្ធធនាគារបានកើនឡើងដល់៤៥% ចាប់ពី ១.៣ពាន់លានដុល្លារក្នុងខែធ្នូឆ្នាំ២០០៦រហូតដល់២.៣៥ពាន់លានដុល្លារក្នុងខែធ្នូឆ្នាំ២០០៨។ ប្រាក់បញ្ញើទាំងនេះរួមមានប្រាក់បញ្ញើរូបិយវត្ថុបរទេស២.២៨ពាន់លានដុល្លារប្រាក់បញ្ញើសន្សំនិងមានកាលកំណត់ ៩៥.៥ពាន់លានដុល្លារ និងប្រាក់បញ្ញើចរន្ត២៥.៨ពាន់លានដុល្លារ។

### ៣.៤.២.២. រូបិយវត្ថុចង្អៀត

នៅកម្ពុជា ជាទូទៅ រូបិយវត្ថុចង្អៀតកើនឡើងដោយស្របគ្នាជាមួយនឹងកំណើននៃរូបិយវត្ថុខាងក្រៅធនាគារ ដោយឆ្លុះបញ្ចាំងពីសេដ្ឋកិច្ចសាច់ប្រាក់កម្រិតដ៏ខ្ពស់។គណនីប្រាក់បញ្ញើចរន្តនៅមានទំហំតិចតួចដោយសារតែប្រាក់បញ្ញើប្រភេទនេះផ្តល់នូវអត្រាការប្រាក់ទាប។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រូបិយវត្ថុចង្អៀតបានកើនពី៥០៥លានដុល្លារនៅចុងខែធ្នូឆ្នាំ២០០៧ ដល់៥៩១លានដុល្លារនៅចុងខែធ្នូឆ្នាំ២០០៨ ដែលជាការកើនឡើង១៧%។ ការកើនឡើងនេះបានឆ្លុះបញ្ចាំងជាចម្បងនូវការពង្រីកខ្លួនខាងរូបិយវត្ថុក្រៅធនាគារ(១៥.៣%)ដើម្បីសម្រួលដល់តម្រូវការកិច្ចការជំនួញកាន់តែខ្ពស់ដែលពាក់ព័ន្ធជាមួយនឹងការពង្រីកសេដ្ឋកិច្ចដោយឆ្លុះបញ្ចាំងផងដែរ នូវគោលនយោបាយរបស់ធនាគារជាតិក្នុងការទិញប្រាក់ដុល្លារធ្វើឱ្យមានស្ថេរភាពនូវអត្រាប្តូរប្រាក់នាមករណ៍ និងដើម្បីបង្កើនធនបម្រុងអន្តរជាតិ និងការកើនឡើង ៦៨% នៃប្រាក់បញ្ញើចរន្ត។

សរុបមក ការអភិវឌ្ឍផ្នែករូបិយវត្ថុក្នុងរយៈឆ្នាំ២០០៦-២០០៨នេះ បង្ហាញពីភស្តុតាងនៃការកើនឡើងគួរឱ្យកត់សម្គាល់មួយក្នុងការប្រើប្រាស់សេវាកម្មធនាគារពីសាធារណជន បន្ទាប់ពីការចូលមករបស់ធនាគារថ្មីៗក្នុងប្រព័ន្ធនេះ និងការផ្តួចផ្តើមរបស់រដ្ឋាភិបាលដើម្បីលើកកម្ពស់ការប្រើប្រាស់នៃសេវាកម្មធនាគារក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុសាធារណៈ។

## ៣.៤.៣. អត្រាប្តូរប្រាក់

គោលនយោបាយអត្រាប្តូរប្រាក់ដើរតួរនាទីយ៉ាងសំខាន់មួយ ក្នុងសេដ្ឋកិច្ចបើកទូលាយដ៏តូចមួយជាពិសេស សេដ្ឋកិច្ចប្រាក់ដុល្លារ។ ការប្រយុទ្ធនឹងអតិផរណាតម្រូវឱ្យអត្រាប្តូរប្រាក់នាមករណ៍មានការឡើងថ្លៃ ដោយប្រៀបធៀបនឹងអត្រាប្តូរប្រាក់ពិតប្រសិទ្ធភាព (Real effective exchange rate)។ រូបិយវត្ថុដែលឡើងថ្លៃល្មមក៏នឹងជួយបន្ស្រាយគំនាបអតិផរណា តាមរយៈការបន្ទាបការចំណាយនាំចូល។ គោលនយោបាយអត្រាប្តូរប្រាក់គឺមានសារៈសំខាន់ណាស់សម្រាប់ប្រទេសនានា ដូចជាកម្ពុជានិងសិង្ហបុរី ដែលជាប្រទេសមានការពឹងផ្អែកខ្លាំងលើគោលនយោបាយអត្រាប្តូរប្រាក់ ដែលជាឧបករណ៍គោលនយោបាយរូបិយវត្ថុដ៏មានប្រសិទ្ធភាពមួយ។

ការរក្សាជំហគោលនយោបាយរូបិយវត្ថុនិងអត្រាប្តូរប្រាក់មួយតាមរយៈ sterilization នោះមានការចំណាយខ្ពស់ណាស់ ដោយសារការកើនឡើងយ៉ាគគំហុកនូវលំហូរចូលទុនឯកជនក្នុងពេលថ្មីៗនេះ។ តែទោះជាយ៉ាងណាក៏ដោយ បើគ្មាន sterilization លំហូរចូលទុនគ្មានដែនកំណត់នឹងធ្វើឱ្យរូបិយវត្ថុឡើងថ្លៃដ៏ឆាប់រហ័ស និងធ្វើឱ្យមានកំណើនលំហូរសាច់ប្រាក់លើសលប់ និងធ្វើឱ្យថ្លៃទ្រព្យសកម្មឡើងថ្លៃដូចពពុះសាប៊ូ។ គម្លាតកាន់តែខ្លាំងរវាងអត្រាការប្រាក់ក្នុងស្រុក និងប្រាក់ដុល្លារនឹងបន្តជំរុញលំហូរទុនចូល។ សេដ្ឋកិច្ចខ្លះក្នុងតំបន់បានណែនាំការគ្រប់គ្រងទុន ដើម្បីទទួលបានការគ្រប់គ្រងទៅលើគោលនយោបាយរូបិយវត្ថុ។ តែទោះជាយ៉ាងណាក៏ដោយ ការគ្រប់គ្រងទុនអាចកាត់បន្ថយទំនុកចិត្តរបស់វិនិយោគិន និងគួរត្រូវបានប្រើប្រាស់ដោយប្រុងប្រយ័ត្ននិងនឹងនរបំផុត។

ការលើកកម្ពស់ទីផ្សារហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាពនិងសម្បូរបែបនោះនឹងមិនគ្រាន់តែជួយដល់ទុនចូលទៅកាន់ការប្រើប្រាស់ប្រកបដោយផ្លែផ្កាទេ តែក៏អាចជួយឱ្យមានការគ្រប់គ្រងកាន់តែមានប្រសិទ្ធភាពមួយនៃលំហូរទុននិងធនបម្រុងប្តូរប្រាក់បរទេសផងដែរ។ ភាពស៊ីជម្រៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនិងការអនុវត្តកំណែទម្រង់ទីផ្សារ គឺជាវិធីមានសារៈសំខាន់ណាស់ប្រសិនបើជារយៈពេលយូរដើម្បីកសាងស្ថេរភាពហិរញ្ញវត្ថុ។ វិធានការដើម្បីអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុដែលមានតម្លាភាពនិងកាន់តែទូលំទូលាយស៊ីជម្រៅត្រូវការជំរុញថែម ដើម្បីបែងចែកធនធានហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព និងដើម្បីពង្រឹងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុក្នុងស្រុកដើម្បីទ្រាំទ្រនឹងភាពរង្គោះរង្គើ ពីការគំរាមកំហែងបច្ចុប្បន្ននៃអាកប្បកិរិយារបស់វិនិយោគិនអន្តរជាតិ។

កម្ពុជាបានជ្រើសយករបបអត្រាប្តូរប្រាក់អណ្តែតគ្រប់គ្រងមួយ ដោយគាំទ្រការបង្គរទុកសន្សឹមៗនៃធនបម្រុងអន្តរជាតិដោយធនាគារជាតិ។ នៅក្នុងបរិបទនៃសេដ្ឋកិច្ចប្រាក់ដុល្លារមួយ ធនាគារជាតិនៃកម្ពុជាប្រើប្រាស់ការអន្តរាគមន៍នៅក្នុងទីផ្សារប្តូរប្រាក់បរទេស ជាឧបករណ៍ប្រយោលមួយនៃគោលនយោបាយរូបិយវត្ថុ។ តាមរយៈការអន្តរាគមន៍នៅក្នុងទីផ្សាររូបិយវត្ថុបរទេស ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងស្ថេរភាពនៃអត្រាប្តូរប្រាក់។ គោលនយោបាយរូបិយវត្ថុដ៏តឹងរឹងដែលធ្វើដោយធនាគារជាតិនៃកម្ពុជា និងការគោរពវិន័យសារពើពន្ធដ៏ហ្មត់ចត់ ដែលរាជរដ្ឋាភិបាលកម្ពុជាប្រកាន់ដោយខ្ជាប់ បានបណ្តាលឱ្យមានបរិយាកាសអតិផរណាទាប និងអត្រាប្តូរប្រាក់ថេរ។

ដើម្បីធ្វើឱ្យមានស្ថេរភាពនូវអត្រាប្តូរប្រាក់ និងធ្វើការទូទាត់នូវលំហូរទុនចូលនិងចេញដែលមានការរំខាននោះ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ តាមរយៈការជាវនិងលក់នូវរូបិយវត្ថុបរទេស ជាពិសេសគឺប្រាក់ដុល្លារអាមេរិក។ ឧទាហរណ៍ ក្នុងករណីនៃការធ្លាក់ថ្លៃប្រាក់រៀល ធនាគារជាតិនៃកម្ពុជានឹងដេញថ្លៃលក់ប្រាក់ដុល្លារពីធនបម្រុងអន្តរជាតិរបស់ខ្លួន។ តែទោះជាយ៉ាងណាក៏ដោយ ការអន្តរាគមន៍នេះគ្រាន់តែមានគោលបំណងធ្វើការសម្រាលគំនាបបណ្តោះអាសន្នទៅលើប្រាក់រៀល។ វាមិនមែនជាគោល-នយោបាយសម្រាប់ធនាគារជាតិនៃកម្ពុជាដើម្បីធ្វើអន្តរាគមន៍ទេ ប្រសិនបើការធ្លាក់ថ្លៃប្រាក់រៀលកើតឡើងដោយសារតែអតុល្យភាពផ្នែករចនាសម្ព័ន្ធនោះ។ ការជាវប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជាមានឥទ្ធិពលពីរយ៉ាង។ ទីមួយវាកាត់បន្ថយនូវការកាន់កាប់ធនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា។ ទីពីរការចរាចររូបិយវត្ថុក្នុងស្រុកនឹងធ្លាក់ចុះ។ ការធ្លាក់ចុះនៃមូលដ្ឋានរូបិយវត្ថុនេះ នឹងលុបចោលនូវគំនាបសង្កត់ទៅលើប្រាក់រៀលឱ្យធ្លាក់ថ្លៃ។ ក្នុងករណីនៃការធ្លាក់ថ្លៃប្រាក់ដុល្លារវិញធនាគារជាតិនៃកម្ពុជានឹងទិញប្រាក់ដុល្លារអាមេរិក (លក់រូបិយវត្ថុជាតិ) ក្នុងទីផ្សារប្តូរប្រាក់បរទេស ដែលបណ្តាលឱ្យមានការពង្រីកនូវមូលដ្ឋានរូបិយវត្ថុ និងការបង្គរទុកនូវធនបម្រុងអន្តរជាតិ។

| *គំនូសតាង ៣.១៨a. អត្រាការប្រាក់ និង អតិផរណា* | *គំនូសតាង ៣.១៨b. ការប្រែប្រួលអត្រាការប្រាក់ប្រចាំខែ* |
|---|---|
|  |  |





*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

កិច្ចអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់បរទេស ដែលក្នុងនោះធនាគារជាតិនៃកម្ពុជាអនុញ្ញាតឱ្យមានការជាវ ឬលក់នូវរូបិយវត្ថុជាតិ ដើម្បីឱ្យមានឥទ្ធិពលមួយទៅលើមូលដ្ឋានរូបិយវត្ថុនោះ គឺជាឧទាហរណ៍មួយនៃ"ការអន្តរាគមន៍ការប្តូរប្រាក់បរទេសដែល unsterilize" ។ នៅក្នុងការអន្តរាគមន៍ unsterilized មួយ រូបិយវត្ថុក្នុងស្រុកត្រូវបានជាវដោយការលក់ទ្រព្យសកម្មបរទេស ដោយនាំទៅរកការធ្លាក់ចុះនៃធនបម្រុងអន្តរជាតិ ការធ្លាក់ចុះនៃការផ្គត់ផ្គង់ប្រាក់ និងការឡើងថ្លៃនូវរូបិយវត្ថុក្នុងស្រុក។ រូបិយវត្ថុក្នុងស្រុកក៏អាចត្រូវបានលក់ដើម្បីជាវទ្រព្យសកម្មបរទេសផងដែរ ដែលនាំទៅរកការកើនឡើងនៃធនបម្រុងអន្តរជាតិ ការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុ និងការធ្លាក់ថ្លៃនៃរូបិយវត្ថុជាតិ។

ផ្ទុយទៅវិញក្នុង "ការអន្តរាគមន៍ sterilized" មួយ ធនាគារជាតិមិនចង់ឱ្យប្រតិបត្តិការរបស់ខ្លួនក្នុងទីផ្សារប្តូរប្រាក់បរទេសជះឥទ្ធិពលដល់មូលដ្ឋានរូបិយវត្ថុទេ។ ក្នុងការបន្តគោលនយោបាយនេះ ធនាគារជាតិនៃនកម្ពុជានឹងអនុវត្តប្រតិបត្តិការទីផ្សារបើកចំហ ដើម្បីទូទាត់នូវឥទ្ធិពលរបស់ប្រតិបត្តិការទីផ្សារប្តូរប្រាក់ បរទេសរបស់ខ្លួនលើមូលដ្ឋានរូបិយវត្ថុ។ ឧទាហរណ៍ ក្នុងករណីយកប្រាក់រៀលទៅជាវទឹកប្រាក់១០០លានដុល្លារអាមេរិក និងការលក់ដោយស្របគ្នានូវទ្រព្យសកម្មបរទេស ដែលមានតម្លៃចំនួន១០០លានដុល្លារ នៅក្នុងទីផ្សារប្តូរប្រាក់បរទេសដែលនឹងកាត់បន្ថយនូវមូលដ្ឋានរូបិយវត្ថុត្រឹម ១០០លានដុល្លារនោះ ធនាគារជាតិនឹងអនុវត្តការជាវទីផ្សារបើកចំហនៃសញ្ញាប័ណ្ណរដ្ឋ ដែលមានទឹកប្រាក់១០០លានដុល្លារ។ នេះនឹងបង្កើនមូលដ្ឋានរូបិយវត្ថុត្រឹម១០០លានដុល្លារ។ ការអន្តរាគមន៍ទីផ្សារប្តូរប្រាក់បរទេស និងការទូទាត់ប្រតិបត្តិការទីផ្សារបើកទូលាយនាំឱ្យមិនមានការប្រែប្រួលនូវមូលដ្ឋានរូបិយវត្ថុទេ។ ដោយសារតែមានវិសាលភាពតិចតួចសម្រាប់ប្រតិបត្តិការទីផ្សារបើកទូលាយនៅកម្ពុជា នោះការអន្តរាគមន៍ទីផ្សារប្តូរប្រាក់បរទេសដោយធនាគារជាតិនៃកម្ពុជា ជាទូទៅមានឥទ្ធិពល unsterilized មួយទៅលើមូលដ្ឋានរូបិយវត្ថុ។

តែទោះជាយ៉ាងណា លំហូរចូលនូវមូលធនដ៏ច្រើនសន្ធឹកសន្ធាប់ និងការធ្លាក់ថ្លៃប្រាក់ដុល្លារដ៏ឆាប់រហ័សក្នុងឆ្នាំ ២០០៧-២០០៨ បានដាក់គំនាបទៅលើប្រាក់រៀលឱ្យឡើងថ្លៃខ្លាំង។ គោលនយោបាយសារពើពន្ធនិងរូបិយវត្ថុដ៏ប្រុងប្រយ័ត្នបានជួយសម្រាលអតិផរណា និងរក្សានូវអត្រាប្តូរបាក់ឱ្យមានស្ថេរភាព។ ឧទាហរណ៍ក្នុងឆ្នាំ២០០៧ - ២០០៨ ការឡើងថ្លៃមាសឡើងកាន់តែខ្ពស់ និងលំហូរទុនចូលនិងការកើនឡើងនូវប្រាក់បញ្ញើដុល្លារក្នុងវិស័យធនាគារ បានធ្វើឱ្យប្រាក់ដុល្លារទោរទន់ទៅរកការធ្លាក់ថ្លៃ។ ធនាគារជាតិនៃកម្ពុជាបានជាវប្រាក់ដុល្លារក្នុងទីផ្សារប្តូរប្រាក់បរទេស។ ជាលទ្ធផល ធនបម្រុងអន្តរជាតិរបស់កម្ពុជាបានកើនឡើងពី ១,០៧៩លានដុល្លារនៅចុងឆ្នាំ២០០៦ដល់១,៦១៦លានដុល្លារក្នុងឆ្នាំ២០០៧និងដល់២,១៦៤លានដុល្លារត្រឹមចុងឆ្នាំ២០០៨។

ការអនុញ្ញាតឱ្យប្រាក់រៀលឡើងថ្លៃយឺតៗនឹងធ្វើឱ្យការនាំចូលគិតជាប្រាក់រៀលមិនសូវថ្លៃ តែវាមិនបានដោះស្រាយបញ្ហាជាមូលដ្ឋានដែលអតិផរណាត្រូវបានជុតបញ្ឆេះ ដោយការធ្លាក់ថ្លៃប្រាក់ដុល្លារនិងការកើនឡើងតម្លៃប្រេងនិងអាហារ។ អ្នកឈ្នះនឹងរួមបញ្ចូលអាជីវកររកស៊ីប្រើប្រាស់ប្រាក់រៀលនិងជាវការនាំចូល។ អ្នកចាញ់នឹងរួមបញ្ចូលអាជីវកររកស៊ីប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ដោយរួមមានអ្នកនាំចេញនិងអ្នកដែលកាន់កាប់ប្រាក់ដុល្លារ។ ខណៈដែលជាវទំនិញដែលនាំចូលពីសហរដ្ឋអាមេរិក សមត្ថភាពជាវរបស់គេបានចុះអន់ថយ។ ដោយសារតែភាគច្រើននៃប្រជាជនកម្ពុជាកាន់ប្រាក់ដុល្លារជាឧបករណ៍សន្សំប្រាក់ដ៏ចម្បងរបស់ពួកគេនោះ វិធានការនេះប្រហែលមិនអាចទទួលយកបានទេ។ តែការឡើងថ្លៃប្រាក់រៀលអាចលើកទឹកចិត្តភ្នាក់ងារសេដ្ឋកិច្ច ឱ្យប្តូរទៅប្រាក់រៀលវិញ និងកាត់បន្ថយនូវដុល្លាររូបនីយកម្ម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់បរទេសនៅក្នុងស្រុក ដើម្បីរក្សាស្ថេរភាពអត្រាប្តូររូបិយវត្ថុជាតិ។ ក្នុងឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានជាវទឹកប្រាក់សរុបចំនួន២៦១.១៨លានដុល្លារពីអ្នកប្តូរប្រាក់ ក្នុងការដោះដូរប្រាក់រៀលចំនួន១,០៥៨.៣ពាន់លានរៀល។ ជាងនេះទៅទៀត ធនាគារជាតិបានដេញថ្លៃលក់ចេញ៩.១លានដុល្លារនៅក្នុងទីផ្សារ ហើយលក់៨៩.៥លានដុល្លារទៅឱ្យក្រុមហ៊ុនអគ្គិសនីកម្ពុជាដើម្បីស្រូបយកប្រាក់រៀលកម្ពុជាត្រឡប់មកវិញ។

| គំនូសតាង៣.១៥a. អតិផរណា | គំនូសតាង៣.១៥b. អតិផរណាប្រចាំឆ្នាំ និងខែ |
| --- | --- |
|  |  |





*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

ការអន្តរាគមន៍ខាងលើតម្រូវឱ្យអត្រាប្តូរប្រាក់មានស្ថេរភាព ដែលត្រូវបានបណ្តាលមកពីឥទ្ធិពលនៃការចំណាយរបស់រដ្ឋាភិបាល និងការឡើងចុះតាមរដូវកាល។ ឧទាហរណ៍អត្រាប្តូរប្រាក់ជាមធ្យមសម្រាប់ឆ្នាំ២០០៨ ត្រូវបានកត់ត្រានូវចំនួន៤,០៦៥រៀលក្នុងមួយដុល្លារបើប្រៀបធៀបទៅនឹង៤,០៦២រៀលក្នុងមួយដុល្លារសម្រាប់ឆ្នាំ២០០៧។ ទោះបីយ៉ាងនេះក្តីមានការឡើងចុះដ៏សម្បើមក្នុងចលនានៃអត្រាប្តូរប្រាក់អំឡុងឆ្នាំ២០០៨ ដែលកើនពី៣,៩៧៨រៀល ទៅដល់៤,១៥១រៀល។ ការឡើងចុះតាមរដូវកាលបានកើតឡើងពីពាក់កណ្តាលខែឧសភារហូតដល់ចុងខែតុលា ជាលទ្ធផលនៃតម្រូវការកើនឡើងសម្រាប់ប្រាក់រៀលអំឡុងរដូវកាលច្រូតកាត់ ដែលបានបង្កើនតម្លៃប្រាក់រៀលទៅនឹងប្រាក់ដុល្លារអាមេរិក។

អត្រាប្តូរប្រាក់រៀលទល់នឹងប្រាក់ដុល្លារអាមេរិកនៅចុងឆ្នាំ២០០៨ គឺ ៤,១០៨ រៀលចំពោះប្រាក់១ដុល្លារ។ នេះមានន័យថា ប្រាក់រៀលធ្លាក់ថ្លៃចំនួន ២.៧%ទល់នឹងប្រាក់ដុល្លារក្នុងឆ្នាំមុន។ ការធ្លាក់ចុះក្នុងតម្លៃប្រាក់រៀលក្នុងឆ្នាំ២០០៨បានឆ្លុះបញ្ចាំងពីការថយចុះក្នុងលំហូរទុនចូលទៅក្នុងប្រទេស ដែលជាលទ្ធផលមួយនៃវិបត្តិសេដ្ឋកិច្ចពិភពលោក។

## ៣.៤.៤. អតិផរណា

កម្ពុជាគឺជាសេដ្ឋកិច្ចប្រាក់ដុល្លារដែលបើកចំហនិងតូចមួយ។ ទីផ្សារប្តូរប្រាក់បរទេសរាក់និងភាពពឹងផ្អែកដោយបើកចំហទៅលើការនាំចូលរបស់អ្នកប្រើប្រាស់ភាគច្រើនហើយផលិតផលប្រេងធ្វើឱ្យប្រទេសកម្ពុជាងាយទទួលរងចំពោះភាពរង្គោះរង្គើពីខាងក្រៅ។ ការចុះឡើងនៃអត្រាប្តូរប្រាកនិងទំនិញក្នុងទីផ្សារពិភពលោក នឹងមានឥទ្ធិពលយ៉ាងឆាប់រហ័សមកសេដ្ឋកិច្ចក្នុងស្រុក។

កម្ពុជាបានឆ្លងកាត់ដំណាក់កាលអតិផរណាដ៏ខ្ពស់មួយក្នុងឆ្នាំ ១៩៩៥-១៩៩៨។ អតិផរណាបានស្ទុះឡើងដល់១៤.៧%ក្នុងឆ្នាំ១៩៩៨ ជាលទ្ធផលនៃហិរញ្ញប្បទានរូបិយវត្ថុនៃឱនភាពថវិកា។ ការអនុវត្តវិន័យថវិកាដោយធ្វើសនិទានទៅលើការចំណាយ ការគៀរគរប្រាក់ចំណូល និងការបញ្ឈប់ការអនុវត្តហិរញ្ញប្បទានធនាគារនៃឱនភាពថវិកានោះ បានជួយឱ្យកម្ពុជារក្សាបានអតិផរណានៅកម្រិតទាបមួយ អំឡុងឆ្នាំ១៩៩៩-២០០៤។ តែទោះជាយ៉ាងណា អតិផរណាបានចាប់ផ្តើមមានសន្ទុះក្នុងឆ្នាំ២០០៥ (៥.៨%) ប៉ុន្តែបានធ្លាក់ចុះមកត្រឹម៤.៧%ក្នុងឆ្នាំ២០០៦ បន្ទាប់ពីថ្លៃប្រេងឆៅធ្លាក់ចុះ។ កំណើនដ៏ខ្លាំងនៃការផ្គត់ផ្គង់រូបិយវត្ថុកំពុងចរាចរ ការឡើងថ្លៃប្រេងដល់កម្រិតយ៉ាងខ្ពស់ និងការកើនឡើងថ្លៃផលិតផលម្ហូបអាហារ ជាពិសេសអង្ករ បានរួមចំណែកឱ្យអតិផរណាកើនឡើងក្នុងកម្រិតមួយល្មម។

អតិផរណា(មធ្យមប្រចាំឆ្នាំ) បានកើនពី៤.៧%ក្នុងឆ្នាំ២០០៦ ទៅដល់៥.៩%ក្នុងឆ្នាំ២០០៧។ ការកើនឡើងលឿននៃថ្លៃប្រេង កំណើនថ្លៃម្ហូបអាហារ ការឡើងថ្លៃប្រាក់បាតថៃ និងការធ្លាក់ថ្លៃប្រាក់ដុល្លារអាមេរិកបានរួមចំណែកដល់អតិផរណាខ្ពស់នេះ។ ថ្លៃអង្ករលក់រាយបានកើនឡើង១៦.៨% ពី១,៤១០រៀល ដល់១,៦០២រៀលក្នុងមួយគីឡូ សម្រាប់អង្ករគុណភាពល្អ ដោយសារតែការនាំចេញអង្ករមានការកើនឡើងទៅកាន់ប្រទេសជិតខាង ជាហេតុធ្វើឱ្យខ្វះខាតអង្ករសម្រាប់ផ្គត់ផ្គង់។ ថ្លៃប្រេងនៅតាមស្ថានីយបានកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ២០០៧និងក្នុងឆមាសទី១ឆ្នាំ២០០៨។ ដើម្បីកុំឱ្យការឡើងថ្លៃប្រេងខ្ពស់យ៉ាងខ្ពស់នេះ ធ្វើឱ្យថ្លៃទំនិញផ្សេងទៀតឡើងដោយស្វ័យប្រវត្តិ ដែលអាចបណ្តាលឱ្យមានអតិផរណាកាន់តែខ្ពស់នោះ រាជ- រដ្ឋាភិបាលបានផ្តល់ឧបត្ថម្ភធនប្រេងមានចំនួនដល់ ១៧០លានដុល្លារអាមេរិក (ដោយកំណត់នូវតម្លៃរដ្ឋបាលទាបសម្រាប់ការគណនានៃពន្ធអាករនាំចូល)។ រាជរដ្ឋាភិបាលក៏បានរក្សាពន្ធអគ្គិសនីនៅកម្រិតដូចគ្នា ដោយឧបត្ថម្ភធនដោយផ្ទាល់ដល់ក្រុមហ៊ុនអគ្គិសនីកម្ពុជា(EDC) ដែលផ្តល់សេវាផ្គត់ផ្គង់ថាមពលដ៏ចម្បង។ ដោយកម្ពុជាបាននាំចូលមួយផ្នែកធំនៃផលិតផលប្រើប្រាស់ពីប្រទេសថៃ ការឡើងថ្លៃប្រាក់បាតថៃ ក៏បានបណ្តាលឱ្យតម្លៃទំនិញប្រើប្រាស់ឡើងខ្ពស់ផងដែរ។

អតិផរណាបានកើនឡើងក្នុងពាក់កណ្តាលដំបូងឆ្នាំ២០០៨ ជាលទ្ធផលនៃការកើនឡើងដ៏ឆាប់រហ័សនៃថ្លៃម្ហូបអាហារនាំចូលពីបរទេស និងថ្លៃថាមពល។ ក្នុងឆ្នាំ២០០៨ អតិផរណាប្រចាំឆ្នាំជាមធ្យមសម្រេចបាន១៩.៧%។ អតិផរណាបានឈានដល់កម្រិតខ្ពស់ជាងគេមួយ គឺ២៥.៧%ក្នុងខែឧសភាឆ្នាំ២០០៨ ប៉ុន្តែបានបន្ថយល្បឿនបន្តិចម្តងៗមកត្រឹម១៣.៥%ក្នុងខែធ្នូឆ្នាំ២០០៨ ដែលបណ្តាលមកពីការធ្លាក់ចុះយ៉ាងគំហុកនៃថ្លៃប្រេងសាំងនិងម្ហូបអាហារ បន្ទាប់ពីការចាប់ផ្តើមនៃវិបត្តិសេដ្ឋកិច្ចពិភពលោកនៅចុងឆ្នាំ២០០៨។ កត្តាដែលរួមចំណែកដ៏ចម្បងដល់ការកើនឡើងនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) ក្នុងឆ្នាំ២០០៨ គឺម្ហូប អាហារភេសជ្ជៈនិងថ្នាំជក់ (២៣.២%) និងគ្រឿងសង្ហារឹមក្នុងគេហដ្ឋាន និងប្រតិបត្តិការតាមគ្រួសារ២៦.១% ដែលកំណត់នូវការកើនឡើងទាំងពីរខាងលើនេះ។ តម្លៃអង្ករបានកើនដល់៦១%ចន្លោះខែមករានិងសីហាឆ្នាំ២០០៨។ ទម្ងន់នៃស្រូវនិងត្រីក្នុងCPI មានទំហំធំធេង ដោយសារតែពួកវាគឺជាក្រុមទំនិញអាហារចម្បងរបស់ប្រជាជនកម្ពុជា។ អតិផរណាដែលវាស់ដោយកំណើននៃ CPI គឺងាយប៉ះពាល់ដល់ការប្រែប្រួលនៃថ្លៃទំនិញសំខាន់ៗទាំងនេះនៅក្នុងកន្ត្រកម្ហូបអាហារ។ នាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលបានផ្តល់អាទិភាពយ៉ាងខ្លាំងទៅលើការអភិវឌ្ឍវិស័យកសិកម្ម ជាយុទ្ធសាស្ត្ររយៈពេលយូរអង្វែងដើម្បីគ្រប់គ្រងអតិផរណា។

ថ្លៃឱសថនិងសេវាកម្មព្យាបាលបានកើន១០.៦% សេវាទឹកភ្លើងនិងស្នាក់នៅបានកើន៥.៨%ក្នុងឆ្នាំ២០០៨។ ការដឹកជញ្ជូន និងគមនាគមន៍ ការកំសាន្តនិងអប់រំ និងសម្លៀកបំពាក់និងស្បែកជើងបានកើនជាមធ្យមមិនលើសពី១%ទេ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិស័យចម្បងនានាដែលប៉ះពាល់ដល់អតិផរណារួមមាន អត្រាប្តូរប្រាក់ គោលនយោបាយសារពើពន្ធ កត្តាតាមរដូវកាល បាននាំឱ្យមានការរុញច្រានថ្លៃទំនិញ និងការរំពឹងទុកនៃអតិផរណា។ ការវាយតម្លៃដោយសង្ខេបមួយនៃកត្តាផ្សេងៗ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រទប់ទល់និងអតិផរណាដ៏ទូលំទូលាយមួយត្រូវបានផ្តល់ជូនដូចខាងក្រោម៖

- អត្រាប្តូរប្រាក់ថេរមួយមានសារៈសំខាន់ណាស់ដើម្បីគ្រប់គ្រងអតិផរណា។ អត្រាប្តូរប្រាក់រៀលនៅមានស្ថេរភាពក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ កម្រិតនៃដុល្លារូបនីកម្មហាក់ដូចជាបានកើនឡើងនិងមិនទំនងជាដាក់ការគំរាមកំហែងខាងអតិផរណាសំខាន់នាថ្ងៃអនាគតទេប៉ុន្តែវាអាចផ្ទុយពីនេះក៏ថាបាន។

- ថ្លៃប្រេងត្រូវបានបញ្ចូលក្នុង CPI តាមរយៈថ្លៃដឹកជញ្ជូននិងផលិតកម្ម។ រចនាសម្ព័ន្ធធាតុចូលនិងធាតុចេញនៃទីផ្សារប្រេងកម្ពុជា និងយន្តការបញ្ជូនគួរត្រូវបានយល់ឱ្យកាន់តែច្បាស់ល្អថែមទៀតសម្រាប់ការពិចារណាជម្រើសនានា ដូចជាការកែរចនាសម្ព័ន្ធពន្ធសម្រាប់ការគ្រប់គ្រងអតិផរណា។

- ឱនភាពថវិកាជារួមនឹងមានឥទ្ធិពលដ៏សំខាន់មួយទៅលើអតិផរណា។ តែទោះជាយ៉ាងណាក្តី គោលនយោបាយសារពើពន្ធដ៏ចង្អៀតដែលបន្តធ្វើដោយរដ្ឋាភិបាលក្នុងឆ្នាំថ្មីៗនេះ ជាឧបករណ៍ចម្បងនៃយុទ្ធសាស្ត្រគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចរបស់ខ្លួននោះបានលុបបំបាត់នូវហានិភ័យនេះ។ ក្នុងការយល់ឃើញពីតួនាទីដ៏សំខាន់នៃគោលនយោបាយសារពើពន្ធ ក្នុងការគ្រប់គ្រងតម្រូវការក្នុងបរិស្ថានដុល្លារូបនីយកម្ម នោះវាអាចមិនមានការបន្ធូរបន្ថយនៃអភិក្រមយុទ្ធសាស្ត្រនេះទេ។

- ថ្លៃទំនិញក្នុងស្រុកតែងតែកើនឡើងក្នុងអំឡុងខែមិថុនានិងតុលា (រដូវកាលដ៏លំបាក) ហើយធ្លាក់ចុះក្នុងអំឡុងខែវិច្ឆិកានិងធ្នូ (រដូវប្រមូលផល)។ ផលប៉ះពាល់តាមរដូវកាលអាចត្រូវបានកាត់បន្ថយតាមរយៈការវិនិយោគច្រើនថែមទៀត ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធទីផ្សារនិងការស្តុកទុក។

- កម្ពុជានៅតែងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុភ្លាមៗ ទោះបីរដ្ឋាភិបាលបានធ្វើការវិនិយោគច្រើនក្នុងសេវាធារាសាស្ត្រក៏ដោយ។ ជាវិធានការរយៈពេលយូរអង្វែង ដើម្បីទប់ទល់នឹងអតិផរណា កម្ពុជាគួរពង្រីកមូលដ្ឋានផលិតកម្មរបស់ខ្លួន ជាពិសេសក្នុងវិស័យកសិកម្ម ដែលរួមចំណែកច្រើនដល់ការប្រើប្រាស់របស់អ្នកក្រីក្រ។ ការអភិវឌ្ឍបច្ចេកវិទ្យាដែលនាំឱ្យវិស័យកសិកម្មមិនសូវរងគ្រោះដោយសារលក្ខខណ្ឌអាកាសធាតុអាក្រក់ និងវិធានការដែលរៀបផែនការបានល្អដើម្បីសម្រាលឬទប់ទល់ជាមួយមហន្តរាយដែលមិនបានរំពឹងទុក នឹងមានប្រយោជន៍ដើម្បីរាំងអតិផរណានិងឥទ្ធិពលអាក្រក់របស់វា។

- ជាទីបញ្ចប់ រាជរដ្ឋាភិបាលដែលគេទុកចិត្ត ដោយសារមានបទពិសោធន៍ច្បាស់លាស់ក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនិងប្រយុទ្ធជាមួយអតិផរណានោះ នឹងជួយបន្ធូរការរំពឹងទុកនៃអតិផរណា។ ប្រការនេះនឹងជួយសម្រួលដល់ការផ្លាស់ប្តូរតាមលំដាប់លំដោយ ឆ្ពោះទៅរកសេដ្ឋកិច្ចផ្អែកលើប្រាក់រៀល ដែលនៅពេលនោះគេអាចគ្រប់គ្រង ដោយប្រើប្រាស់បច្ចេកទេសនៃគោលនយោបាយរូបិយ-វត្ថុជាប្រពៃណី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អតិផរណាបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំ២០០៩ ជាចម្បងដោយសារតែតម្លៃប្រេង និងអាហារធ្លាក់ចុះយ៉ាងទាប។ អតិផរណាត្រូវបានរំពឹងទុកថាស្មើនឹង៥% ត្រឹមចុងឆ្នាំ២០០៩។ អតិផរណាក្នុងឆ្នាំ២០១០ត្រូវបានរំពឹងទុកថានឹងធ្លាក់ទាប ទោះបីហានិភ័យវិជ្ជមាននៅតែមានក៏ដោយ ដោយសារតែជំហរសារពើពន្ធទូលាយ ការធ្លាក់ថ្លៃកាន់តែខ្លាំងនៃប្រាក់ដុល្លារអាមេរិក និងតម្លៃប្រេងកាន់តែខ្ពស់។

### ៣.៤.៤.១. លំហូរមូលធននិងអតិផរណាកើនឡើង

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ លំហូរមូលធនបានដើរតួនាទីកាន់តែសំខាន់ឡើង ក្នុងជញ្ជីងទូទាត់។ ចាប់តាំងពីឆ្នាំ២០០៥ ទិន្នន័យនៃគណនីមូលធននិងហិរញ្ញវត្ថុនៃជញ្ជីងទូទាត់បានកើនឡើងយ៉ាងខ្លាំង។ គណនីហិរញ្ញវត្ថុបានកើន៣៩% ពី៣២៤លានដុល្លារក្នុងឆ្នាំ២០០៦ ដល់៤៥១លានដុល្លារក្នុងឆ្នាំ២០០៧។ ការផ្ទេរមូលធន ក្នុងទម្រង់នៃប្រាក់កម្ចីរយៈវែងនិងមធ្យមបានកើន៤១% ពី១២៣លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៦ ដល់ ១៧៣លានដុល្លារក្នុងឆ្នាំ២០០៦ និងដល់ ១៧៣លានដុល្លារក្នុងឆ្នាំ២០០៧។

*តំនូសតាង៣.១៦a. រូបិយវត្ថុ, ឥណទាន និង អតិផរណា*




*តំនូសតាង៣.១៦b. ការប្រែប្រួលអតិផរណា*




*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

ការហូរចូលមូលធនឯកជនក្នុងទម្រង់ FDI បានកើនដល់៥០% ពី៤៧៥លានដុល្លារក្នុងឆ្នាំ២០០៦ ដល់៨៦៧លានដុល្លារក្នុងឆ្នាំ២០០៧។ កំណើនវិនិយោគទុនឆ្លុះបញ្ចាំងពីទំនុកចិត្តរបស់វិនិយោគិនដោយសារមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចនិងនយោបាយ។ FDI គឺជាឧបករណ៍គ្មានបំណុលមួយនៃហិរញ្ញប្បទានពីព្រោះ FDI មិនបានបន្ថែមទៅនឹងបំណុលពីខាងក្រៅទេ។ វិនិយោគិនទិញភាគហ៊ុនក្នុងសហគ្រាសក្នុងស្រុក ឬបង្កើត ឬពង្រីកសម្ព័ន្ធវង់មួយ ហើយគ្មានមានកាតព្វកិច្ចកិច្ចសន្យាណាមួយទេ។ លក្ខណៈពិសេសដាច់ដោយឡែកនៃប្រភេទលំហូរមូលធនចូលនេះគឺថាវាពាក់ព័ន្ធមិនត្រឹមតែការផ្ទេរធនធានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលទ្ធកម្មនៃការគ្រប់គ្រងមួយផ្នែក ឬពេញលេញរបស់ទ្រព្យសម្បត្តិក្នុងស្រុកមួយពីជនបរទេសម្នាក់ ឬនិតិបុគ្គលមួយ។ FDI គឺជាយានដ៏សំខាន់មួយសម្រាប់ការផ្ទេរជំនាញគ្រប់គ្រងនិងជំនាញបច្ចេកទេសនានា ពីបរទេស។ អត្ថប្រយោជន៍នៃការផ្ទេរបច្ចេកវិទ្យាដូចនេះ ជាញឹកញាប់ត្រូវបានគេឃើញថាមានសារៈសំខាន់ជាងលំហូរមូលធនខ្លួនឯងទៀតផង។

ក្នុងឆ្នាំ២០០៧ ជញ្ជីងទូទាត់រួម សម្រេចបាននូវអតិរេកដល់២៩០លានដុល្លារអាមេរិក (៣.៥% នៃ GDP ក្នុងឆ្នាំ២០០៧ បើប្រៀបធៀបជាមួយនឹង២.៨% ក្នុងឆ្នាំ២០០៦)។ ផលសម្រេចនេះត្រូវបានពង្រឹងដោយការកើនឡើងនៃទឹកប្រាក់វិស័យទេសចរណ៍ (១.១ពាន់លានដុល្លារអាមេរិក) អតិរេកនៃការផ្ទេរប្រាក់ជាផ្លូវការនិងឯកជន (៧៤៨លានដុល្លារអាមេរិក) កំណើននៃប្រាក់កម្ចីសម្បទាន និងកំណើនក្នុងការវិនិយោគដោយផ្ទាល់ពីបរទេស (៧១១លានដុល្លារ)។

លំហូរមូលធនទាំងនេះបានជួយផ្តល់ហិរញ្ញប្បទានដល់ឱនភាពគណនីចរន្តដ៏ធំ ដែលពាក់ព័ន្ធជាមួយការនាំចូលខ្ពស់ និងកំណើនសេដ្ឋកិច្ចខ្ពស់។ វាក៏បង្កើននូវធនបម្រុងផងដែរ។ នៅពេលជាមួយគ្នា ការកញ្ច្រោលភ្លាមៗនៃលំហូរចូលដែលមានទំហំធំទាំងនេះ បានបណ្តាលឱ្យមានបញ្ហាខ្លះនៃការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច។

ក្តីបារម្ភទាំងនេះគឺៈ

- លំហូរមូលធនគឺនៅបណ្តោះអាសន្ន និងអាចត្រឡប់បញ្ច្រាសភ្លាមៗ។
- លំហូរមូលធនអាចនាំឱ្យមានកំណើនក្នុងការផ្គត់ផ្គង់ប្រាក់ និងបណ្តាលឱ្យអតិផរណាកើនឡើង ពេលដែលធនាគារកណ្តាលគឺធនាគារជាតិនៃកម្ពុជា (NBC) បានអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់បរទេស ដើម្បីកែលម្អអត្រាប្តូរប្រាក់បរទេស ក្នុងគោលដៅធ្វើឱ្យមានស្ថេរភាពអត្រាប្តូរប្រាក់នាមករណ៍។ ពីពាក់កណ្តាលឆ្នាំ២០០៦ ដល់ពាក់កណ្តាលឆ្នាំ២០០៨ ធនបម្រុងអន្តរជាតិរបស់កម្ពុជាបានកើនដល់ ១ពាន់លានដុល្លារអាមេរិក ខណៈពេលដែលធនាគារជាតិនៃកម្ពុជាចំណាយពេលអស់១២ឆ្នាំ ដើម្បីបង្កើនធនបម្រុងអន្តរជាតិពី ១០០លានដុល្លារអាមេរិកក្នុងឆ្នាំ១៩៩៤ ដល់ ១ពាន់លានដុល្លារអាមេរិក នៅក្នុងឆ្នាំ២០០៦។
- ផលវិបាកនៃអតិផរណាមិនអាចជៀសផុតបានទេ ដោយសារអន្តរាគមន៍នៅទីផ្សារប្តូរប្រាក់បរទេសមិនត្រូវបាន sterilized។ ឧទាហរណ៍ រាជរដ្ឋាភិបាលមិនអាចចេញសញ្ញាប័ណ្ណរដ្ឋ ដើម្បីស្រូបយកអតិរេកនៃប្រាក់រៀលដែលកំពុងចរាចរនៅលើទីផ្សារ ដោយសារការជាវប្រាក់ដុល្លារអាមេរិក។
- ប្រសិនបើធនាគារជាតិនៃកម្ពុជាមិនធ្វើអន្តរាគមន៍ទេនោះ លំហូរមូលធនចូលកម្ពុជាអាចបណ្តាលឱ្យប្រាក់រៀលឡើងថ្លៃខ្លាំង ជាហេតុធ្វើឱ្យប៉ះពាល់ដល់ការប្រកួតប្រជែងរបស់កម្ពុជា។
- មូលធនដែលហូរចូលត្រូវបានប្រើប្រាស់ដើម្បីអភិវឌ្ឍវិស័យអចលនទ្រព្យ ដែលជាកត្តាសំខាន់ក្នុងការកាត់បន្ថយការប្រើប្រាស់ធនធានទាំងនេះសម្រាប់គោលដៅផលិតកម្ម ជាពិសេសការវិនិយោគទុន។ ប្រការនេះនឹងបង្កើតផងដែរនូវហានិភ័យសម្រាប់សេដ្ឋកិច្ចជាតិ នៅពេលដែលលំហូរនូវមូលធនដ៏ច្រើនសន្ធឹកសន្ធាប់នឹងនាំឱ្យថ្លៃអចលនទ្រព្យកើនឡើងលើសពីថ្លៃជាក់ស្តែង ដូចជាពពុះសាប៊ូ ដែលនឹងនាំឱ្យមានវិបត្តិសេដ្ឋកិច្ចកើតឡើង នៅពេលដែលពពុះសាប៊ូនេះនឹងផ្ទុះបែកនោះ។

### ៣.៤.៤.២. អតិផរណាបណ្ដាលមកពីតម្រូវការ

អតិផរណាបណ្ដាលមកពីតម្រូវការ គឺជាអតិផរណាដែលបណ្ដាលមកពីការកើនឡើងខាងតម្រូវការសរុប ដោយសារតែចំណាយថវិការដ្ឋនិងឯកជនកើនឡើង។ ការកើនឡើងខ្លាំងនៃតម្រូវការម្ហូបអាហារ និងសេវាកម្មជាទូទៅ (តម្រូវការសរុប) បាន"ទាញ"ថ្លៃទំនិញផ្សេងៗទៀតឱ្យឡើងថ្លៃខ្ពស់ ជាពិសេសនៅពេលដែលការផ្គត់ផ្គង់សរុបមិនអាចកើនឡើងបាន ដោយកំហិតសមត្ថភាពនោះ។

គេឃើញមានទំនាក់ទំនងយ៉ាងខ្លាំងក្លា រវាងកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុនិងអតិផរណា (ក្រាហ្វិក)។ យោងតាមទស្សនរបស់លោក Milton Friedman "អតិផរណានៅគ្រប់ពេល និងគ្រប់ទីកន្លែងគឺជាបាតុភូតរូបិយវត្ថុ"។ ប្រការនេះត្រូវបានគេហៅថា **អតិផរណាបណ្ដាលមកពីតម្រូវការ**។

តែទោះជាយ៉ាងណាក៏ដោយ បញ្ហាដែលសំខាន់នោះ គឺការកំណត់ថាតើអតិផរណាដែលបណ្ដាលដោយការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុមានកម្រិតច្រើនប៉ុណ្ណា ដែលបណ្ដាលមកពីចំណាយ ឧទាហរណ៍. កំណើនខាងតម្លៃម្ហូបអាហារនិងថាមពលមានកម្រិតប៉ុណ្ណា។

ក្រាហ្វិកខាងលើបង្ហាញពីការកើនឡើងខ្លាំងនៃលំហូរសាច់ប្រាក់ឬការផ្គត់ផ្គង់រូបិយវត្ថុ M2 ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅ។ ក្នុងការឆ្លើយតបទៅនឹងអតិផរណាដែលបណ្ដាលមកពីតម្រូវការនេះ ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការរូបិយវត្ថុដូចខាងក្រោម៖

- អនុវត្តគោលនយោបាយរូបិយវត្ថុឱ្យបានតឹងរឹងនិងប្រុងប្រយ័ត្ន។
- បន្តអនុវត្តគោលនយោបាយអត្រាគ្រប់គ្រងបណ្ដែត ក្នុងគោលបំណងរក្សាអត្រាប្ដូរប្រាក់ឱ្យមានស្ថេរភាព ដោយការពង្រឹងទំនុកចិត្តពីសាធារណជននិងការទ្រទ្រង់កម្លាំងទិញប្រាក់រៀល។ ដើម្បីជៀសវាងភាពមិនខ្ជាប់ខ្ជួននៃអត្រាប្ដូរប្រាក់និងចលាចលទីផ្សារនោះ ធនាគារជាតិនៃកម្ពុជានឹងខំរក្សាកម្រិតឡើងថ្លៃនៃរូបីយប័ណ្ណក្នុងស្រុកក្នុងការចរាចរ និងបន្តលក់ប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារប្ដូរប្រាក់បរទេស។
- បង្កើនទុនបម្រុងកាតព្វកិច្ចរបស់ធនាគារពាណិជ្ជពី៨% ទៅ១៦% ដើម្បីបន្ថឹងឥណទានចំពោះវិស័យឯកជន (ជាបន្តបន្ទាប់វានឹងកាត់បន្ថយមកត្រឹម១២% ដើម្បីបង្កើនលំហូរសាច់ប្រាក់ក្នុងវិស័យធនាគារ ក្នុងអំឡុងរយៈពេលនៃវិបត្តិហិរញ្ញវត្ថុពិភពលោក)។
- អនុញ្ញាតឱ្យធនាគារមានហិរញ្ញវត្ថុល្អជាមួយនឹងភាពលើសលប់នៃលំហូរសាច់ប្រាក់ដើម្បីវិនិយោគទ្រព្យខ្លះរបស់ពួកគេទៅបរទេស។
- កំណត់ចំណាយថវិការដ្ឋ ជាពិសេសបង្កើនអតិរេកនៃថវិកាចរន្ត និងកាត់បន្ថយឱនភាពថវិកាជារួម និងប្រាក់បង្កើនប្រាក់បញ្ញើរដ្ឋាភិបាលក្នុងប្រព័ន្ធធនាគារ។
- រឹតបន្តឹងវិធានរបស់សមត្ថភាពធនាគារដើម្បីឱ្យខ្ចី ដូចជាការកើនឡើងតម្រូវការមូលធនផ្ទាល់របស់ខ្លួន។ និង
- លើកកម្ពស់គោលនយោបាយ **បដិដុល្លារូបនីយកម្ម** សន្សឹមៗ។

### ៣.៤.៤.៣. អតិផរណាបណ្តាលមកពីថ្លៃដើម

អតិផរណាបណ្តាលមកពីថ្លៃដើមត្រូវបានបណ្តាលមកពីការធ្លាក់ចុះក្នុងការផ្គត់ផ្គង់សរុប ដោយសារតែថ្លៃទុនធាតុចូលកើនឡើង។ កត្តា"បណ្តាលមកពីថ្លៃដើម"នេះរួមមាន ការកើនឡើងនៃថ្លៃទំនិញដូចជាប្រេងនិងម្ហូបអាហារ ការកំណត់ថ្លៃផ្តាច់មុខដោយសហគ្រាសនិងប្រាក់បៀវត្សរ៍។ ផលិតករដែលត្រូវចំណាយលើធាតុចូលកាន់តែខ្ពស់ បានបន្តបង្កើនថ្លៃទំនិញដោយផ្ទេរទៅឱ្យអ្នកប្រើប្រាស់ ក្នុងទម្រង់ជាថ្លៃនៃធាតុចេញដែលកើនឡើង។

អតិផរណានៅកម្ពុជាបន្តតាមយ៉ាងកៀកកិតនឹងការកើនឡើងតម្លៃប្រេង។ អតិផរណា គឺសូន្យក្នុងឆ្នាំ ២០០២ ដោយកើនដល់១.១៥% ក្នុងឆ្នាំ២០០៣ ដែលឆ្លុះបញ្ចាំងពីស្ថានភាពអនុគ្រោះនៃថ្លៃប្រេងអន្តរជាតិរហូតដល់ឆ្នាំ២០០៣។ ថ្លៃប្រេងបានចាប់ផ្តើមកើនឡើងក្នុងឆ្នាំ២០០៣។ ក្នុងការឆ្លើយតបមកវិញ អតិផរណាបានកើនឡើងដល់ ៣.៩% ក្នុងឆ្នាំ២០០៤។ ដោយថ្លៃប្រេងបានស្ទុះឡើងក្នុងឆមាសទីពីរនៃឆ្នាំ២០០៧ នោះអតិផរណាបានឈានដល់១០.៨% ក្នុងខែធ្នូឆ្នាំ២០០៧ ។ កំណើននៃថ្លៃម្ហូបអាហារក៏មានសន្ទុះកើនឡើងនៅដើមឆ្នាំ២០០៨ផងដែរ និងជំរុញឱ្យអតិផរណាកាន់តែឡើងខ្ពស់។

អតិផរណាខ្ពស់ដោយសារតែកំណើននៃថ្លៃទំនិញចាំបាច់ ជាពិសេសការកើនឡើងនៃថ្លៃម្ហូបអាហារត្រូវតែយកចិត្តទុកដាក់ឱ្យបានខ្លាំង ពីព្រោះវាមានឥទ្ធិពលវិសមមាត្រខាងសុខុមាលភាពទៅលើអ្នកក្រីក្រ និងក្រុមមនុស្សដែលមានប្រាក់ចំណូលថេរ ហើយបង្កឱ្យមានអស្ថេរភាពសង្គមសេដ្ឋកិច្ចផងដែរ។ គោលនយោបាយសារពើពន្ធ គឺជាឧបករណ៍ដ៏មានឥទ្ធិពលមួយ ដើម្បីលើកឡើងពីអតិផរណាបណ្តាលមកពីថ្លៃដើម។

គោលនយោបាយសារពើពន្ធឆ្លើយតបចំពោះអតិផរណាបណ្តាលមកពីថ្លៃដើមនៅកម្ពុជារួមមាន៖

- ផ្តល់នូវការឧបត្ថម្ភធនទៅលើការនាំចូលប្រេងសាំង ដោយការប្រើប្រាស់ថ្លៃរដ្ឋបាល (ថ្លៃមូលដ្ឋានឆ្នាំ២០០១) ដើម្បីគណនាបំណុលពន្ធ (ឧបត្ថម្ភធនប្រេង៖១៧០លានដុល្លារក្នុងឆ្នាំ២០០៧ និង២៥០លានដុល្លារក្នុងឆ្នាំ២០០៨)។
- ផ្តល់នូវការឧបត្ថម្ភធនបណ្តោះអាសន្ននិងរយៈពេលខ្លីឱ្យ EDC ដើម្បីរក្សាពន្ធនាំចូលអគ្គិសនីនៅកម្រិតដូចគ្នា (ឧបត្ថម្ភធនចំពោះវិស័យអគ្គិសនី ប្រហែល៣០លានដុល្លារ)។
- ទប់ឱនភាពថវិកា។ ថវិកាឆ្នាំ២០០៨នឹងត្រូវបានអនុវត្តក្នុងកំហិតនៃច្បាប់ថវិកា។
- ការប៉ះប៉ូវផ្នែកប៉ះពាល់ដល់សង្គម។ ក្នុងឆ្នាំ២០០៨ ប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និងនិវត្តន៍ជន ប្រាក់ឧបត្ថម្ភសហព័ទនិងកូន និងមន្ត្រីបាត់បង់សមត្ថភាពពលកម្មបានកើនឡើង ២០% ខណៈដែលប្រាក់ឧបត្ថម្ភគ្រូបង្រៀនបានកើន១០%។ ប្រាក់ឧបត្ថម្ភជីវភាពសម្រាប់មន្ត្រីរដ្ឋាភិបាលនិងកងកម្លាំងប្រដាប់អាវុធ បានកើន ២០,០០០រៀលក្នុងមួយខែ ពីខែសីហាដល់ខែធ្នូឆ្នាំ២០០៨។ ពន្ធបអប្បបរិមា១% សម្រាប់រោងចក្រកាត់ដេរត្រូវបានព្យួរអស់រយៈពេលបីឆ្នាំ ដើម្បីលើកទឹកចិត្តក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់។ ប្រការនេះអនុញ្ញាតឱ្យរោងចក្រកាត់ដេរបង្កើនប្រាក់កម្រៃអប្បបរិមាបន្ថែមចំនួន ៦ដុល្លារ លើប្រាក់កម្រៃបច្ចុប្បន្ន៥០ដុល្លារក្នុងមួយខែ។

- រដ្ឋាភិបាលបានណែនាំគ្រប់ក្រសួង និងស្ថាប័នសាធារណៈទាំងអស់ ឱ្យសន្សំសំចៃប្រេងនិងអគ្គិសនី។ ក្នុងឆ្នាំ២០០៨ ការប្រើប្រាស់ប្រេងសម្រាប់គោលបំណងផ្នែករដ្ឋបាលត្រូវបានកំណត់ត្រឹមចំនួនដែលបានចែងក្នុងច្បាប់ថវិកា។

- ការផ្តល់តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ នោះហិរញ្ញប្បទានពិសេសក្នុងទម្រង់នៃមូលធនសម្រាប់ដំណើរការត្រូវបានផ្តល់ជូនម្ចាស់ម៉ាស៊ីនកិនស្រូវឯកជន ដើម្បីទិញស្រូវសម្រាប់ការកែច្នៃក្នុងស្រុក។ កម្មវិធីនេះចាប់ផ្តើមដំបូងក្នុងឆ្នាំ២០០៥ ហើយបានចំណាយថវិកាច្រើនឡើងៗ ដល់ចំនួន១០លានដុល្លារអាមេរិក ក្នុងឆ្នាំ២០០៨។

- ការអនុញ្ញាតឱ្យនាំចូលឡើងវិញនូវផលិតផលម្ហូបអាហារ ជាពិសេសសាច់ជ្រូក ដែលកាលពីមុនត្រូវបានហាមឃាត់ដោយសារតែការបារម្ភផ្នែកសុខភាព។

- ការកាត់បន្ថយពន្ធគយលើការនាំចូលធាតុចូលផ្នែកឧស្សាហកម្ម។ ការបាត់បង់ប្រាក់ចំណូលនឹងត្រូវបានទូទាត់ ដោយកំណើននៃចំណូលពន្ធលើទំនិញប្រណិតៗ ដូចជារថយន្ត ទូរស័ព្ទ ទូរទស្សន៍ ឧបករណ៍សម្លេងហាយហ្វាយ ម៉ាស៊ីនត្រជាក់ VCR VCP សុរា គ្រឿងសម្អាង និងផលិតផលប្រណិតដំទៃទៀត។

- ការលើកលែងអាករលើតម្លៃបន្ថែម (VAT) បណ្តោះអាសន្នទៅលើផលិតផលកសិកម្ម ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងលើកទឹកចិត្តនូវការកែច្នៃផលិតផលកសិកម្ម ក្នុងគោលដៅផ្គត់ផ្គង់ទីផ្សារក្នុងស្រុក។ និង

- ការដាក់ឱ្យអនុវត្ត (បន្ទាប់មកលើកលែង) នូវការហាមឃាត់ការនាំចូលស្រូវ អង្ករក្នុងរយៈពេល២ខែ និងការណែនាំឱ្យក្រុមហ៊ុន Green Trade Co. និងសមាគមម៉ាស៊ីនកិនស្រូវកម្ពុជាឱ្យលក់ស្រូវពីឃ្លាំងស្តុករបស់ពួកគេ ដើម្បីកាត់បន្ថយថ្លៃស្រូវនិងអង្ករ។

ក្នុងរយៈពេលវែង ការអភិវឌ្ឍវិស័យកសិកម្មនឹងក្លាយជាអាទិភាពមួយនៃគោលនយោបាយដើម្បីបង្កើនការផ្គត់ផ្គង់ ដើម្បីគ្រប់គ្រងអតិផរណា។ ការឡើងថ្លៃម្ហូបអាហារក្នុងកម្រិតមួយយ៉ាងខ្ពស់ គឺជាការផ្តល់រង្វាន់មួយសម្រាប់កសិករដើម្បីបង្កើនវិនិយោគទុនខាងវិស័យកសិកម្ម និងការបង្កើនកាលានុវត្តភាពសម្រាប់ការបង្កើនផលិតកម្មនិងការនាំចេញ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីពីរ ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០៨ ក្នុងគោលដៅកំណត់នូវគោលនយោបាយសង្គមសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលអាណត្តិទីបួន បានផ្តល់អាទិភាពខ្ពស់ដល់ការអភិវឌ្ឍវិស័យកសិកម្ម និងកសិឧស្សាហកម្ម។ ក្នុងន័យនេះ យុទ្ធសាស្ត្រចតុកោណទទួលស្គាល់នូវឧត្តមភាពប្រៀបធៀបរបស់កម្ពុជាក្នុងវិស័យកសិកម្ម។

### ៣.៤.៤.៤. *អតិផរណាដោយស្វ័យប្រវត្តិ*

អតិផរណាដោយស្វ័យប្រវត្តិកើតឡើងដោយសារ **ការរំពឹងទុក** ដែលជាប់ទាក់ទងជាមួយនឹង "វដ្តនៃការឡើងថ្លៃទំនិញ/ប្រាក់បៀវត្សរ៍" ដោយសារតែកម្មករតែងតែសុំឡើងប្រាក់បៀវត្សរ៍របស់ខ្លួន ដើម្បីឱ្យតាមទាន់ថ្លៃទំនិញដែលឡើងកាន់តែខ្ពស់ (បៀវត្សរ៍ដុលត្រូវតែកើនឡើងលើសសន្ទស្សន៍ថ្លៃ CPI ប្រសិនបើគេមិនចង់ឱ្យប្រាក់ចំណូលពិតធ្លាក់ចុះ ក្រោយពេលតម្លើងប្រាក់បៀវត្សរ៍) ហើយបន្ទាប់មកនិយោជកនឹងបញ្ចូល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថ្លៃដើមកើនឡើងនេះ ទៅក្នុងថ្លៃដើមទំនិញ ដែលជាយន្តការផ្ទេរចំណាយកាន់តែខ្ពស់ទៅឱ្យអ្នកប្រើប្រាស់។ ដូច្នេះ ប្រការនេះបានបង្កើតឡើងនូវវដ្តនៃអន្ទាក់វិលវល់មួយ រវាងការឡើងប្រាក់បៀវត្សរ៍ និងថ្លៃទំនិញ។ អតិផរណាដោយស្វ័យប្រវត្តិឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍នានាកាលពីអតីតកាល ដែលបង្កើតឱ្យមានអតិផរណានេះផងដែរ។

កម្មវត្ថុនៃវិធានការគោលនយោបាយដែលរាជរដ្ឋាភិបាលបានដាក់ចេញ គឺត្រូវបង្កើតលក្ខខណ្ឌអំណោយផលដើម្បីឱ្យសេដ្ឋកិច្ចកម្ពុជាបន្តសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព ក្នុងបរិបទនៃអតិផរណាទាបនិងមានស្ថេរភាព។ ដើម្បីសម្រេចបាននូវគោលដៅដ៏មានសារៈសំខាន់នេះទាមទារឱ្យរាជរដ្ឋាភិបាលរៀបចំនូវគោលនយោបាយឆ្លើយតបជាកញ្ចប់ ដែលមានសង្គតិភាពក្នុងគ្រប់វិស័យទាំងអស់។ ប្រការនេះរួមមានវិធានការរចនាសម្ព័ន្ធ ដែលត្រូវដាក់ចេញដើម្បីលើកកម្ពស់ប្រសិទ្ធភាពទីផ្សារ ក៏ដូចជាការកែសម្រួលគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុផងដែរ។ ភាគីពាក់ព័ន្ធទាំងអស់ត្រូវមានកាតព្វកិច្ច អនុវត្តវិធានការគោលនយោបាយនេះ ប្រកបដោយការទទួលខុសត្រូវខ្ពស់។ រដ្ឋាភិបាលត្រូវដាក់ចេញនូវគោលនយោបាយ សំដៅធានានូវកម្រិតអតិផរណាមួយស្ថេរ ដែលសង្គមទាំងមូលអាចទទួលយកបានជាជាងការជៀសវាងមិនឱ្យមានអតិផរណាទាំងស្រុង។ រាជរដ្ឋាភិបាលគប្បីដាក់ចេញនូវវិធានការខាងផ្នែកផ្គត់ផ្គង់កាន់តែទូលំទូលាយមួយ ដើម្បីជាមូលដ្ឋានសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជាដែលនឹងកាត់បន្ថយអតិផរណា។ វិធានការទាំងនេះរួមមានដូចខាងក្រោម៖

- អនុមតិនូវគោលនយោបាយដើម្បីជំរុញវិនិយោគទុនក្នុងវិស័យប្រេង និងធនធានថាមពល និងដើម្បីពង្រឹងរបបវិនិយោគទុនឱ្យមានស្ថេរភាព និងអាចព្យាករណ៍បាន ដោយលើកទឹកចិត្តកិច្ចសហប្រតិបត្តិការឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព រវាងទីភ្នាក់ងារជាតិនិងអន្តរជាតិ តាមរយៈភាពជាដៃគូដែលដំណើរការល្អ។
- បើកយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ អនុវត្តកម្មវិធីនិងគោលនយោបាយអប់រំដើម្បីលើកកម្ពស់ការអភិរក្សនិងប្រសិទ្ធភាពថាមពលដែល នឹងជួយកាត់បន្ថយកំណើននៃតម្រូវការថាមពល។ និង
- ការផ្ដោតការយកចិត្តទុកដាក់ទៅលើការកែលម្អគោលនយោបាយកសិកម្ម ដែលមានគោលដៅកែលម្អហេដ្ឋារចនាសម្ព័ន្ធ ការចែកចាយនិងប្រព័ន្ធស្តុកទុក ពង្រីកប្រព័ន្ធធារាសាស្ត្រនិងបង្វែរការឧបត្ថម្ភធន ទៅផលិតផលដែលមានទិន្នផលខ្ពស់ និងធាតុចូលកសិកម្មសំខាន់ៗដូចជាជីជាដើម។

វិធានការពង្រឹងការគ្រប់គ្រងតម្រូវការសរុបត្រូវផ្ដោតទៅលើវិស័យដូចខាងក្រោម៖

១. ដាក់ចេញនូវវិធានការសារពើពន្ធថ្មីៗ ដែលផ្ដាតលើការត្រួតពិនិត្យតាមដាន ការគ្រប់គ្រង និងប្រសិនបើចាំបាច់ ការធ្វើឱ្យមានស្ថេរភាពនូវវិស័យសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា ដែលមានសារៈសំខាន់ សម្រាប់ការកាត់បន្ថយហានិភ័យអវិជ្ជមាន ដែលអាចកើតមានឡើងចំពោះកំណើនសេដ្ឋកិច្ច ដូចជាវិស័យអចលនទ្រព្យនិងវិស័យហិរញ្ញវត្ថុ។ និង

២. ការរឹតបន្តឹងការកើនឡើងនូវឥណទាន ដែលផ្ដល់ឱ្យវិស័យដែលមានអាទិភាពទាប ក្នុងគោលដៅកាត់បន្ថយអតិផរណា ដោយមិនបណ្ដាលឱ្យមានសម្ពាធទៅលើថ្លៃដើមឡើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.៤.៤.៥. វិធានការបន្ថែម

ថ្លៃទំនិញដែលចេះតែកើនឡើងយ៉ាងឆាប់រហ័ស គឺជាបញ្ហាប្រឈមមួយចំពោះវឌ្ឍនភាពនិងវិបុលភាពសេដ្ឋកិច្ច។ការឆ្លើយតបគោលនយោបាយរបស់រដ្ឋាភិបាលត្រូវតែមានភាពសមស្រប មានលក្ខណៈរលូនជាមួយនឹងរចនាសម្ព័ន្ធ និងមានសង្គតិភាព ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ ទៅលើទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចទូទៅរបស់កម្ពុជា។ ក្រៅពីវិធានការដែលត្រូវបានពិពណ៌នាខាងលើ រដ្ឋាភិបាលត្រូវពិចារណាលើវិធានការដូចតទៅៈ

- បន្តគោលនយោបាយនៃការមិនផ្តល់ហិរញ្ញប្បទាននៃឱនភាពថវិកា ដោយធនាគារ។
- បន្ថយកំណើននៃចំណាយចរន្ត ដែលចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ច ក្នុងគោលដៅរក្សានូវអតិរេកនៃថវិកាចរន្ត ឱ្យបានក្នុងកម្រិតមួយដែលមិនទាបជាង ២.៥%នៃផសស។
- រក្សានូវឱនភាពថវិកាសរុបឱ្យនៅប្រហែល២.៥% នៃផសសក្នុងឆ្នាំ២០១០ ដើម្បីកាត់បន្ថយការរំពឹងទុកនៃអតិផរណា។
- បង្កើនប្រាក់បញ្ញើរបស់រដ្ឋាភិបាលក្នុងប្រព័ន្ធធនាគារ។
- ក្នុងករណីមិនអាចប្រមូលចំណូលថវិកាឱ្យបានគ្រប់តាមផែនការ ត្រូវដាក់ចេញនូវវិធានការសន្សំថ្មីឬកាត់បន្ថយចំណាយចរន្ត ដោយកាត់បន្ថយចំណាយមិនមែនអាទិភាព។
- ពង្រឹងការអនុវត្តពន្ធលើអចលនទ្រព្យនិងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដោយរួមការដាក់អោយអនុវត្តពន្ធលើកំណើនមូលធន។
- បន្តការអនុវត្តចំណាយវិនិយោគទុនសាធារណៈក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាផ្លូវថ្នល់ប្រព័ន្ធធារាសាស្ត្រនិងថាមពល ដែលមានគោលដៅកាត់បន្ថយថ្លៃដើមសេដ្ឋកិច្ចនិងលើកកម្ពស់ផលិតកម្មនិងផលិតភាព ព្រមទាំងបង្កើនចំណាយលើវិស័យអប់រំនិងសុខាភិបាលក្នុងក្របខ័ណ្ឌនៃច្បាប់ថវិកាឆ្នាំ២០០៨។
- គ្រប់ក្រសួងនិងស្ថាប័នរដ្ឋត្រូវដាក់ចេញនូវវិធានការថ្មីៗ ក្នុងគោលដៅលើកកម្ពស់ការសន្សំសំចៃនិងកៀរគរការប្រមូលចំណូលថវិកាគ្រប់ប្រភេទទាំងអស់។ និង
- កាត់បន្ថយការជ្រើសរើសក្របខ័ណ្ឌរដ្ឋបន្ថែមត្រឹម១០% ក្នុងឆ្នាំ២០០៩។

វិធានការដទៃទៀតរួមមានៈ

- បង្កើនអាករលើទំនិញប្រណិតនិងសុរា។
- ប្រើប្រាស់ថ្លៃនាំចូលជាក់ស្តែង ក្នុងការធ្វើការវាយតម្លៃពន្ធ ដោយរួមទាំងពន្ធលើសុរា បារី និងប្រេងឥន្ធនៈ។
- ដាក់ឱ្យអនុវត្តអាករលើតម្លៃបន្ថែម (VAT) សម្រាប់អគ្គិសនីនិងទឹក។

- ពង្រឹងបន្ថែមទៀតការប្រមូលពន្ធលើការទិញលក់ដីធ្លី។
- ដាក់ឱ្យអនុវត្តពន្ធលើអចលនទ្រព្យក្នុងទីប្រជុំជនសំខាន់ៗ។
- បង្កើនអត្រាអាករ ជាពិសេសអាករលើស្រាបៀរនិងបារី។
- ដាក់ឱ្យអនុវត្តការឧបត្ថម្ភលើការវិនិយោគទុន ឥណទានពន្ធនិងការរំលស់លឿន ដើម្បីជំនួសការលើកទឹកចិត្តខាងផ្នែកពន្ធដារចំពោះការធ្វើវិនិយោគ។

## ៣.៤.៥. ការផ្គត់ផ្គង់រូបិយវត្ថុ

### ៣.៤.៥.១. ទ្រព្យសកម្មបរទេសសុទ្ធ

ខាងផ្នែកទ្រព្យសកម្មនៃតារាងតុល្យការរបស់ប្រព័ន្ធធនាគារ ការផ្គត់ផ្គង់រូបិយវត្ថុ គឺត្រូវបានផ្សំឡើងដោយទ្រព្យសកម្មបរទេសសុទ្ធ និងទ្រព្យសកម្មក្នុងស្រុកសុទ្ធ។ កំណើនដ៏ខ្លាំងនៃទ្រព្យសកម្មបរទេសសុទ្ធគឺជាកត្តារួមចំណែកដ៏សំខាន់ដល់កំណើនរូបិយវត្ថុក្នុងឆ្នាំ២០០៧ ដោយសូចនាករនេះបានកើនឡើង ៥០% ពី ១.៧៦ពាន់លានដុល្លារនៅចុងខែធ្នូឆ្នាំ២០០៦ ដល់២.៦ពាន់លានដុល្លារក្នុងឆ្នាំ២០០៧។ ទ្រព្យសកម្មបរទេសសុទ្ធបានឡើងដល់កំពូលក្នុងខែសីហាឆ្នាំ២០០៨ ហើយសម្រេចបាន ២.៧៩ពាន់លានដុល្លារ។ ជាមួយនឹងការចាប់ផ្តើមនៃវិបត្តិសេដ្ឋកិច្ចពិភពលោក ទ្រព្យសកម្មបរទេសសុទ្ធនៃប្រព័ន្ធធនាគារបានចាប់ផ្តើមធ្លាក់ចុះដោយធនាគារពាណិជ្ជកម្ម និងអ្នកផ្ញើប្រាក់បញ្ញើមួយចំនួនបានបញ្ជូនថវិការបស់ពួកគេពីកម្ពុជា ទៅគោលដៅបរទេស។ ទ្រព្យសកម្មបរទេសសុទ្ធបានធ្លាក់ចុះ៥% ក្នុងខែធ្នូឆ្នាំ២០០៨ បើប្រៀបធៀបទៅនឹងខែកញ្ញាឆ្នាំ ២០០៨។ និន្នាការធ្លាក់ចុះត្រូវបានប្រែត្រឡប់មកវិញក្នុងខែធ្នូឆ្នាំ២០០៨ ហើយទ្រព្យសកម្មបរទេសសុទ្ធបានងើបឡើងវិញដល់២.៥ពាន់លានដុល្លារអាមេរិក។ ទ្រព្យសកម្មបរទេសសុទ្ធបានកើន៩% ក្នុងខែមេសាឆ្នាំ ២០០៩ ដល់២.៨ពាន់លានដុល្លារ បើប្រៀបធៀបទៅនឹងខែធ្នូឆ្នាំ២០០៨ ជាមួយនិងការបើកសម្ពោធធនាគារពាណិជ្ជកម្មកូរ៉េ គឺធនាគារគុកមិន (Kookmin bank)។

### ៣.៤.៥.២. ទ្រព្យសកម្មក្នុងស្រុកសុទ្ធ

ឥណទានក្នុងស្រុកត្រូវបានបង្កើតឡើងដោយឥណទេយ្យសុទ្ធរបស់រដ្ឋាភិបាលនិងឥណទានចំពោះវិស័យឯកជន និងសាធារណៈ។ ក្នុងឆ្នាំ ២០០៧ ទ្រព្យសកម្មក្នុងស្រុកសុទ្ធនៃវិស័យធនាគារស្មើនឹង ១៤២លានដុល្លារអាមេរិក ជាលទ្ធផលនៃការកើនឡើងខ្លាំងនៃឥណទានក្នុងស្រុក ដែលកើនឡើងលឿនខ្លាំងជាងកំណើននៃប្រាក់បញ្ញើតាមកាលកំណត់ និងមូលធននៃប្រព័ន្ធធនាគារ។ ឥណទានក្នុងស្រុកសុទ្ធកើនឡើងជាងទ្វេដងក្នុងឆ្នាំ២០០៨ ដល់ ៣៧៣លានដុល្លារអាមេរិក។ កំណើនដ៏ឆាប់រហ័សនៃឥណទានចំពោះវិស័យឯកជនក្នុងស្រុកត្រូវបានកាត់កង មួយផ្នែកដោយការកាត់បន្ថយខាងឥណទេយ្យសុទ្ធរបស់រដ្ឋាភិបាលជាចម្បង ដោយសារតែកំណើនខាងប្រាក់បញ្ញើរបស់រដ្ឋាភិបាល។

### ៣.៤.៥.៣. ឥណទេយ្យសុទ្ធរបស់រដ្ឋាភិបាល

ជាលទ្ធផលមួយនៃកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ប្រាក់បញ្ញើរដ្ឋាភិបាលបានកើនច្រើនជាងប្រាំដងពី១៩១លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៥ រហូតដល់៨០២លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០៨ ខណៈដែលឥណទេយ្យសុទ្ធរបស់រដ្ឋាភិបាលត្រូវបានរក្សាទុកឱ្យនៅកម្រិតដដែលប្រមាណ ៦៥-៩០


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លានដុល្លារអាមេរិក។ កំណើនដ៏ឆាប់រហ័សនៃប្រាក់បញ្ញើរបស់រដ្ឋាភិបាលបាននាំឱ្យមានភាពប្រសើរឡើងក្នុងឥណទេយ្យសុទ្ធរបស់រដ្ឋាភិបាលពី-៥២លានដុល្លារក្នុងខែធ្នូឆ្នាំ២០០៤ដល់-៧៣៥លានដុល្លារក្នុងខែធ្នូឆ្នាំ២០០៨។ បរិមាណនេះគឺជាធនធានហិរញ្ញវត្ថុមួយរបស់រដ្ឋាភិបាល។

### ៣.៤.៥.៤. *ទុនបម្រុងអន្តរជាតិដុល*

នៅក្នុងសេដ្ឋកិច្ចប្រាក់ដុល្លារមួយដូចជាប្រទេសកម្ពុជានេះ ទុនបម្រុងអន្តរជាតិដុលដើរតួនាទីដ៏សំខាន់មួយ ក្នុងការពង្រឹងទំនុកចិត្តពីសាធារណជនក្នុងប្រព័ន្ធធនាគារ។ ទុនបម្រុងអន្តរជាតិដុលរបស់កម្ពុជាបានកើនទ្វេដង ពី១ពាន់លានដុល្លារក្នុងពាក់កណ្តាលឆ្នាំ២០០៦ ទៅដល់២ពាន់លានដុល្លារក្នុងពាក់កណ្តាលឆ្នាំ២០០៨។ ទុនបម្រុងទាំងនេះត្រូវបានកាន់កាប់តាមទម្រង់ផ្សេងៗ រួមមានជាវិនិយោគទុនភ្លាមៗជាប្រាក់បញ្ញើរយៈពេលខ្លីនិងមធ្យម ជាឧបករណ៍រយៈពេលមធ្យម (MTI) និងជាមូលប័ត្រកម្រិតវិនិយោគដែលចេញដោយស្ថាប័នអនិវាសនជនកម្រិតខ្ពស់។ នៅត្រឹមចុងឆ្នាំ២០០៨ ការវិនិយោគ (មិនរួមបញ្ចូលមាសនិងSDRs) មានទឹកប្រាក់រហូតដល់២.២៥ពាន់លានដុល្លារអាមេរិក កើន២៧.៥% បើប្រៀបពីមួយឆ្នាំទៅមួយឆ្នាំ ពីកម្រិតនៅចុងឆ្នាំ២០០៧។

កំណើនដ៏ឆាប់រហ័សនៃទុនបម្រុងអន្តរជាតិដុល ឆ្លុះបញ្ចាំងពីសមិទ្ធិផលល្អនៃការនាំចេញ កំណើននៃការវិនិយោគដោយផ្ទាល់ពីបរទេស និងការកើនឡើងខ្លាំងជាងមុននៃលំហូរមូលធន។

*គំនូសតាង៣.១៧. ទុនបម្រុងអន្តរជាតិដុលឆ្នាំ(១៩៩៣-២០០៩ (គិតជាលានដុល្លារ)*




*ប្រភពៈធនាគារជាតិនៃកម្ពុជា*

រូបភាព៣.១៧បង្ហាញថា ទុនបម្រុងផ្លូវការដុលត្រូវគេរំពឹងទុកថាជាទូទៅមានស្ថេរភាព ក្នុងរង្វង់ ២.២ ពាន់លានដុល្លារអាមេរិក (ដែលអាចធានាដល់ការនាំចូលចំនួន៤ខែ) នៅចុងឆ្នាំ២០០៩។

## ៣.៤.៦. គោលនយោបាយរូបិយវត្ថុ

ក្នុងឆ្នាំ ១៩៨៩ រដ្ឋាភិបាលនៃរដ្ឋកម្ពុជា បានដាក់ចេញនូវកំណែទម្រង់ដ៏សំខាន់ ដើម្បីបង្កើតនូវមូលដ្ឋានគ្រឹះនៃកម្មសិទ្ធិឯកជននិងសេដ្ឋកិច្ចទីផ្សារនៅកម្ពុជា។ ចាប់ពីពេលនោះមកកម្ពុជាបានអនុវត្តនូវកំណែទម្រង់រចនាសម្ព័ន្ធ និងការកែប្រែនូវមូលដ្ឋានគ្រឹះសេដ្ឋកិច្ចបន្តិចម្តងៗពីសេដ្ឋកិច្ចផែនការមកសេដ្ឋកិច្ចទីផ្សារ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*គំនូសតាង៣.១៨. ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ (M2/GDP)*




*ប្រភព៖ធនាគារជាតិនៃកម្ពុជា*

គោលនយោបាយរូបិយវត្ថុមានគោលបំណងរក្សាស្ថេរភាពថ្លៃទំនិញ។ ធនាគារជាតិនៃកម្ពុជាបានកំណត់គោលដៅអតិផរណា ឱ្យនៅកម្រិតតិចជាង៥% ក្នុងរយៈពេលខ្លី និងនៅប្រហែល៣½% ក្នុងរយៈពេលមធ្យម។ អំឡុងឆ្នាំ២០០៦-២០០៧ រូបិយវត្ថុ (M2) នៃវិស័យធនាគារបន្តកើនឡើងយ៉ាងខ្លាំង។ អត្រាកំណើននៃM2ក្នុងឆ្នាំ២០០៦ (៣៨.២%) គឺច្រើនជាងពីរដងនៃឆ្នាំ២០០៥ (១៦.១%) ដែលបានឈានដល់៦៣% ក្នុងឆ្នាំ២០០៧ ប៉ុន្តែបានកើនត្រឹមតែ៤.៨% ក្នុងឆ្នាំ២០០៨ នៅពេលដែលវិបត្តិហិរញ្ញវត្ថុពិភពលោកបានចាប់ផ្តើមក្នុងខែកញ្ញាឆ្នាំ២០០៨។ យើងនឹងផ្តល់ជូនខាងក្រោមនូវការធ្វើពិពណ៌នាដ៏លម្អិតជាងនេះនៃការវិវត្តខាងលើនេះ។

| *គំនូសតាង៣.១៩ក. ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ* | *គំនូសតាង៣.១៩ខ. កំណើនរូបិយវត្ថុទូទៅ* |
|---|---|
|  |  |





*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

ការវិភាគនៃការកែប្រែរចនាសម្ព័ន្ធនៃប្រព័ន្ធធនាគារកម្ពុជា ត្រូវឈរលើមូលដ្ឋាននៃសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេលប្រាំពីរឆ្នាំកន្លងទៅ គឺពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៦។ មុខងារចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺ៖

(ក) ដើរតួនាទីជាអាជ្ញាធររូបិយវត្ថុ និងអនុវត្តគោលនយោបាយរូបិយវត្ថុ។ ក្នុងតួនាទីនេះ ធនាគារជាតិបានធ្វើអន្តរាគមន៍យ៉ាងសកម្មក្នុងទីផ្សារប្តូរប្រាក់បរទេស ដើម្បីធានាបាននូវអត្រាប្តូរប្រាក់ថេរ និងស្ថេរភាពនៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថ្លៃទំនិញក្នុងស្រុក។ ជាលទ្ធផល ថ្លៃប្រាក់រៀលទល់នឹងប្រាក់ដុល្លារអាមេរិកត្រូវបានរក្សានៅកម្រិតថេរមួយក្នុងរយៈពេលបីឆ្នាំកន្លងទៅ។

(ខ) ដើរតួនាទីស្នូលជាអ្នកបោះផ្សាយតែមួយគត់នៃរូបិយវត្ថុជាតិ។ ដូច្នេះ ធនាគារជាតិបានបង្កើនចំនួនឯកតារូបិយវត្ថុ និងជំនួសក្រដាសប្រាក់រហែកនិងចាស់ខ្លាំង។

(គ) ដើរតួនាទីជាអាជ្ញាធរនិយតកម្មនិងអធិការកិច្ចនៃប្រព័ន្ធហិរញ្ញវត្ថុនិងធនាគារ។

(ឃ) ត្រួតពិនិត្យមើលប្រព័ន្ធទូទាត់នៅកម្ពុជានិង

(ង) គ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ប្រទេស។

ដុល្លារូបនីកម្មបានជះឥទ្ធិពលដល់ជម្រើសនៃគោលដៅរូបិយវត្ថុ ការអនុវត្តនៃគោលនយោបាយរូបិយវត្ថុ និងរចនាសម្ព័ន្ធនៃអធិការកិច្ចដែលប្រុងប្រយ័ត្ន។ ការជំនួសរូបិយវត្ថុបង្ហាញឱ្យឃើញថាទ្រព្យសកម្មរូបិយវត្ថុដែលចារឹកជាដុល្លារ គឺត្រូវបានចាត់ទុកថាជាផ្នែកមួយនៃការផ្គត់ផ្គង់រូបិយវត្ថុ ក្នុងគោលដៅកំណត់កម្រិតថ្លៃទំនិញ។

សេដ្ឋកិច្ចដែលប្រើប្រាក់ដុល្លារខ្លាំងតម្រូវឱ្យធនាគារជាតិប្រើប្រាស់ឧបករណ៍ ចារឹកជាប្រាក់ដុល្លារក្នុងការគ្រប់គ្រងរូបិយវត្ថុ។ តែទោះជាយ៉ាងណា ប្រសិទ្ធភាពនៃឧបករណ៍នេះនឹងទទួលរងឥទ្ធិពលដោយកម្រិតនៃលទ្ធភាពជំនួសបានរវាងសញ្ញាប័ណ្ណរដ្ឋចារឹកជាប្រាក់ដុល្លារ និងទ្រព្យសកម្មបរទេសសុទ្ធ។ នៅពេលដែលលទ្ធភាពជំនួសបានមានកម្រិតកាន់តែខ្ពស់ ប្រសិទ្ធភាពនៃឧបករណ៍នេះក៏កាន់តែទាប (IMF, ១៩៩៩)។ តែទោះជាយ៉ាងណា បញ្ហានេះស្ថិតនៅក្នុងទ្រឹស្តីនៅឡើយសម្រាប់កម្ពុជានាពេលបច្ចុប្បន្ននេះ ដោយសារទាំងទីផ្សារសញ្ញាប័ណ្ណរដ្ឋ ទាំងទីផ្សារភាគហ៊ុននៅមិនទាន់មានវត្តមាននៅក្នុងប្រទេសកម្ពុជានៅឡើយ។

ស្ថិតក្នុងបរិបទនៃសេដ្ឋកិច្ចប្រើប្រាក់ដុល្លារ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់បរទេស ជាឧបករណ៍ប្រយោលមួយនៃគោលនយោបាយរូបិយវត្ថុ។ ឧបករណ៍ផ្សេងទៀតដូចជាទុនបម្រុងកាតព្វកិច្ច និងអត្រាបុនអបហារ មានចែងក្នុងច្បាប់ ប៉ុន្តែមិនត្រូវបានប្រើប្រាស់ទេ។ ការយកអត្រាប្តូរប្រាក់ជា គោលដៅនៃការធ្វើអន្តរាគមន៍ គឺជាឧបករណ៍ដ៏ចម្បងនៃគោលនយោបាយរូបិយវត្ថុរបស់កម្ពុជា។

### ៣.៤.៦.១. *ទុនបម្រុងកាតព្វកិច្ច*

ក្នុងសេដ្ឋកិច្ចដែលប្រើប្រាក់ដុល្លារខ្លាំង ទុនបម្រុងកាតព្វកិច្ចជារូបិយវត្ថុបរទេសអាចដើរតួនាទីដ៏មានប្រយោជន៍ ជាឧបករណ៍ធ្វើឱ្យមានស្ថេរភាពសន្ទនីយភាពដោយស្វ័យប្រវត្តិ (IMF, ១៩៩៩)។ គេអាចប្រើនូវទុនបម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើរូបិយវត្ថុបរទេស ដើម្បីយកពន្ធលើធនាគារនិងកាត់បន្ថយនូវលំហូរមូលធនចូលផងដែរ។ ជាទូទៅ ទុនបម្រុងកាតព្វកិច្ចអាចត្រូវបានប្រើប្រាស់ ជាមធ្យោបាយមួយនៃការធ្វើឱ្យមានស្ថេរភាពនូវលំហូរសាច់ប្រាក់ដែលលើសលប់។ ឧទាហរណ៍ ការកាត់បន្ថយនៃអត្រាទុនបម្រុងកាតព្វកិច្ចបានកាត់បន្ថយនូវទុនបម្រុងដែលធនាគាររក្សាទុក ហើយដូច្នេះ ធនាគារអាចបង្កើតប្រាក់កម្ចីថែមទៀត។ បរិមាណប្រាក់កម្ចីកាន់តែធំ បានបន្ថែមទៅលើការផ្គត់ផ្គង់រូបិយវត្ថុ និងជំរុញសេដ្ឋកិច្ច។

តែទោះជាយ៉ាងណា ការប្រើប្រាស់មិនរើសមុខនៃទុនបម្រុងកាតព្វកិច្ចអាចនាំឱ្យមានផលលំបាកធ្ងន់ធ្ងរសម្រាប់វិស័យហិរញ្ញវត្ថុ។ ទុនបម្រុងកាតព្វកិច្ចដែលមិនបានផ្តល់លាភការ គឺមានតម្លៃស្មើនឹងការយក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពន្ធទៅលើវិស័យហិរញ្ញវត្ថុ និងអាចលើកទឹកចិត្តដល់ការលក់តាមអ៊ិនធឺណិតនូវផលិតផលហិរញ្ញវត្ថុ។ ការបង្កើនទុនបម្រុងកាតព្វកិច្ចនឹងបង្កើនថ្លៃដើមចំពោះធនាគារពាណិជ្ជកម្ម និងមិនអាចប៉ះពាល់ច្រើនទៅលើបរិមាណឥណទានដែលធនាគារឱ្យខ្ចី ឬសន្ទនីយភាពនៃប្រព័ន្ធធនាគារ ដែលជាទូទៅត្រូវបានបណ្ដាលមកពីតម្រូវការ។ ម្យ៉ាងវិញទៀត ទោះបីជាបង្កើនអត្រាទុនបម្រុងកាតព្វកិច្ចក៏ដោយ ក៏ការហូរចូលប្រាក់ដុល្លារចូលមកក្នុងប្រទេសនៅតែអាចបន្ត ប្រសិនបើអត្រាការប្រាក់ទីផ្សារក្នុងស្រុកខ្ពស់ជាងអត្រាការប្រាក់ពីបរទេស លក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ចក្នុងប្រទេសមានភាពល្អប្រសើរ ឬមានកាលានុវត្តភាពវិនិយោគដ៏ទាក់ទាញនានាក្នុងប្រទេស។ ទុនបម្រុងកាតព្វកិច្ចក្នុងបរិបទនៃសេដ្ឋកិច្ចប្រើប្រាក់ដុល្លារ គឺជាឧបករណ៍ដែលត្រូវបានប្រើកាន់តែច្រើនដោយធនាគារជាតិ ដើម្បីគ្រប់គ្រងធនាគារពាណិជ្ជនានា ក្នុងគោលដៅធានានូវសន្តិសុខ និងស្ថេរភាពនៃប្រព័ន្ធធនាគារ។

### ៣.៤.៦.២. *ឥណទានអបបហារ*

ច្រកអបបហាររបស់ធនាគារជាតិនៃកម្ពុជាផ្ដល់នូវសន្ទះសុវត្ថិភាពមួយ សម្រាប់ការបន្ធូរនូវសម្ពាធនៃទុនបម្រុងកាតព្វកិច្ច។ តាមរយៈការឱ្យខ្ចីមូលនិធិទល់នឹងការដាក់វត្ថុបញ្ចាំ ធនាគារជាតិបានផ្ដល់សាច់ប្រាក់ឱ្យទៅស្ថាប័នហិរញ្ញវត្ថុ ទន្ទឹមនឹងការជួយធានាស្ថេរភាពជាមូលដ្ឋាននៃទីផ្សាររូបិយវត្ថុនិងប្រព័ន្ធធនាគារ។ ក្នុងការអនុវត្តជាក់ស្ដែង ឧបករណ៍នេះមិនត្រូវបានប្រើប្រាស់នៅឡើយ សម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុនៅកម្ពុជា។

ការអនុវត្តនូវគោលនយោបាយរូបិយវត្ថុក្នុងអំឡុងឆ្នាំ២០០៣-២០០៨ ទទួលបាននូវជោគជ័យក្នុងការទទួលបានស្ថេរភាពថ្លៃទំនិញ តាមរយៈកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ ដែលគ្រប់គ្រងដោយប្រុងប្រយ័ត្នជាពិសេស ការដាក់កំហិតទៅលើការផ្ដល់ឥណទានឱ្យរដ្ឋាភិបាលដោយវិស័យធនាគារ និងដោយការរក្សាបាននូវទ្រព្យសកម្មបរទេសសុទ្ធក្នុងកម្រិតមួយដ៏សមស្រប។ គោលនយោបាយរូបិយវត្ថុត្រូវមានគោលដៅដូចតទៅ៖ (១) ការគ្រប់គ្រងកាន់តែសកម្មនៃទ្រព្យសកម្មដែលប្តូរយកប្រាក់បាន (២) លក្ខខណ្ឌល្អប្រសើរសម្រាប់អន្តរការីកម្មធនាគារ និងការផ្ដល់ហិរញ្ញប្បទានវិស័យឯកជននិង (៣) គោលនយោបាយអត្រាប្តូរប្រាក់ ដែលកំណត់ដោយលក្ខខណ្ឌទីផ្សារ។

គោលនយោបាយរូបិយវត្ថុក្នុងរយៈពេលមធ្យម ត្រូវតែធានាបាននូវស្ថេរភាពនៃសូចនាករសរុបខាងផ្នែករូបិយវត្ថុ ដោយប្រកាន់យកវិធានការ ដូចជាការជម្រះបញ្ជីជាបន្តនៃបំណុលរដ្ឋាភិបាល ជាមួយប្រព័ន្ធមិនមែនធនាគារ និងការគ្រប់គ្រងដ៏សកម្មនៃទ្រព្យប្តូរយកប្រាក់បាន។ ធនាគារកណ្ដាលគួរធានានូវការផ្ដល់ហិរញ្ញប្បទានឱ្យបានល្អប្រសើរនៃតម្រូវការលំហូរសាច់ប្រាក់របស់រដ្ឋាភិបាល តាមរយៈការប្រើប្រាស់សញ្ញាប័ណ្ណរតនាគារ និងជៀសវាងការផ្ដល់ហិរញ្ញប្បទានដោយធនាគារកណ្ដាល។ ការដាក់ឱ្យអនុវត្តនូវសញ្ញាប័ណ្ណរតនាគារនឹងអនុញ្ញាតឱ្យធនាគារកណ្ដាល ប្រើប្រាស់យ៉ាងសកម្មនូវឧបករណ៍ដ៏សំខាន់នៃគោលនយោបាយរូបិយវត្ថុនេះដើម្បីគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ។ ការកាត់បន្ថយបន្ថែមទៀតនូវឥណទានដែលផ្ដល់ឱ្យវិស័យសាធារណៈ នឹងបង្កើតកាលានុវត្តភាពបន្ថែមទៀតសម្រាប់ការបង្កើនឥណទានឱ្យវិស័យឯកជន សម្រាប់គោលដៅបង្កើនផលិតកម្ម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.៤.៧. ដុល្លាររូបនីយកម្ម

យើងមានឯកសារជាច្រើនសន្ធឹកសន្ធាប់ស្តីពីបញ្ហាដុល្លាររូបនីយកម្ម។ ដុល្លាររូបនីយកម្មត្រូវបានបង្ហាញតាមវិធីជាច្រើនក្នុងសេដ្ឋកិច្ចផ្សេងៗគ្នា។ ឯកសារសេដ្ឋកិច្ចបានបែងចែករវាងទស្សនាទានផ្សេងៗនៃដុល្លាររូបនីយកម្ម ពោលគឺដុល្លាររូបនីយកម្មផ្លូវការ ដុល្លាររូបនីយកម្មមិនផ្លូវការ ដុល្លាររូបនីយកម្មពាក់កណ្តាលផ្លូវការ ដុល្លាររូបនីយកម្មពេញលេញ ការជំនួសរូបិយប័ណ្ណ និងការជំនួសទ្រព្យសម្បត្តិ។ល។

Ortiz (១៩៨៣) បានឱ្យនិយមន័យ **ដុល្លាររូបនីយកម្ម** ថា ជាកម្រិតនៃប្រតិបត្តិការនៅក្នុងវិស័យសេដ្ឋកិច្ចពិត និងវិស័យហិរញ្ញវត្ថុ ដែលប្រើប្រាស់នូវប្រាក់ដុល្លារអាមេរិក ដោយប្រៀបធៀបជាមួយនឹងប្រតិ-បត្តិការដែលប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។និយមន័យនៃដុល្លាររូបនីយកម្មនេះទទួលស្គាល់នូវការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ជាមធ្យោបាយនៃការលក់ដូរក្នុងសេដ្ឋកិច្ចមួយក្រៅពីសហរដ្ឋអាមេរិក។

យោងទៅតាម Calvo និងVegh (១៩៩២) វិញ **ការជំនួសរូបិយប័ណ្ណ** មានន័យថា ការប្រើប្រាស់តែរូបិយប័ណ្ណបរទេស និងប្រាក់បញ្ញើរូបិយវត្ថុបរទេស ធ្វើជាមធ្យោបាយមួយនៃការលក់ដូរនៅក្នុងសេដ្ឋកិច្ចក្នុងស្រុក។ McKinnon (១៩៩៦) ធ្វើការបែងចែករវាងការជំនួសរូបិយប័ណ្ណ និងការជំនួសទ្រព្យសកម្ម ថាជាមូលហេតុជំរុញពីរយ៉ាង សម្រាប់តម្រូវការនៃទ្រព្យសកម្មចារឹកជារូបិយប័ណ្ណបរទេស ដូច្នេះធ្វើការសង្កត់ធ្ងន់ទៅលើការប្រើប្រាស់ប្រាក់ដុល្លារ ជាមធ្យោបាយនៃការលក់ដូរ (ការជំនួសរូបិយប័ណ្ណ) និងការរក្សាទុកតម្លៃ (ការជំនួសទ្រព្យសកម្ម)។

ការសិក្សានានាដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC ២០០២) និង De Zamaroczy និង Sa (២០០២) បានពិនិត្យឡើងវិញលើទិដ្ឋភាពវិជ្ជមាននិងអវិជ្ជមាននៃដុល្លាររូបនីយកម្ម។ ប៉ុន្តែការសិក្សាតិចតួចបំផុតបានផ្តោតទៅលើទំនាក់ទំនងរវាងដុល្លាររូបនីយកម្ម និងគោលនយោបាយសារពើពន្ធនិងរូបិយវត្ថុ។ ការវិភាគដែលមានជាបន្តនៅក្នុងផ្នែកនេះ មានគោលបំណងដើម្បីបំពេញចន្លោះប្រហោងនេះ។

នៅក្នុងបរិបទរបស់ប្រទេសកម្ពុជា ដុល្លាររូបនីយកម្មអាចត្រូវបានគេដាក់និយមន័យថា ជាការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅក្នុងមុខងារណាមួយនៃមុខងារទាំងបីរបស់រូបិយវត្ថុក្នុងសេដ្ឋកិច្ចក្រៅពីសហរដ្ឋអាមេរិកៈ ឯកតាគណនី មធ្យោបាយនៃការលក់ដូរ និងដោយឡែកការរក្សាទុកនៃតម្លៃ។ ជាទូទៅពាក្យថាការជំនួសរូបិយប័ណ្ណ សំដៅទៅលើការប្រើប្រាស់រូបិយប័ណ្ណបរទេសក្រៅពីរូបិយប័ណ្ណក្នុងស្រុក ជាមធ្យោបាយនៃការលក់ដូរនៅក្នុងសេដ្ឋកិច្ចក្នុងស្រុក។ ពាក្យដុល្លាររូបនីយកម្មត្រូវបានប្រើប្រាស់ដោយជាក់លាក់ ដើម្បីពិពណ៌នាពីរបបរូបិយប័ណ្ណនៅកម្ពុជា ដែលនៅទីនេះ ប្រាក់ដុល្លារអាមេរិកគឺជារូបិយប័ណ្ណដែលត្រូវបានប្រើប្រាស់ក្នុងកម្រិតអតិបរិមាក្នុងការធ្វើចរាចររូបិយវត្ថុ ទោះបីជាមានរូបិយប័ណ្ណក្នុងស្រុក គឺប្រាក់រៀលក៏ដោយ។

**ដុល្លាររូបនីយកម្ម** កើតឡើងមានក្នុងរូបភាពមួយចំនួន។ **ដុល្លាររូបនីយកម្មមួយផ្នែក** កើតឡើង នៅពេលដែលនិវាសនជនកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុមួយផ្នែករបស់គេ ជាទ្រព្យសកម្មបរទេស។ ប្រការនេះសមមូលទៅនឹង"**ការជំនួសទ្រព្យសម្បត្តិ**"។ ក្នុងករណីផ្សេងទៀត **ការជំនួសរូបិយប័ណ្ណ** កើតមានឡើង ទោះបីជារូបិយប័ណ្ណបរទេសនោះ មិនត្រូវបានចាត់ទុកថាជារូបិយប័ណ្ណផ្លូវការក៏ដោយ។ បាតុភូតនេះ គេហៅថា **ដុល្លាររូបនីយកម្មក្រៅផ្លូវការ**។ គេប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុកដើម្បី បើក

ប្រាក់បៀវត្សរ៍ បង់ពន្ធ និងទូទាត់ចំណាយប្រចាំថ្ងៃ ក៏ប៉ុន្តែ ចំពោះប្រតិបត្តិការដែលមានទំហំធំ ជាញឹកញាប់ គេតែងតែប្រើរូបិយប័ណ្ណបរទេសដើម្បីទូទាត់។

***ដុល្លាររូបនីយកម្មពាក់កណ្តាលផ្លូវការ*** កើតឡើងពេលដែល ធាតុពិត ប្រព័ន្ធរូបិយវត្ថុចែកចេញជាពីរដាច់គ្នា។ នៅក្នុងប្រព័ន្ធនេះ រូបិយប័ណ្ណបរទេស គឺជារូបិយវត្ថុស្របច្បាប់ ហើយប្រាក់បញ្ញើធនាគារដ៏ច្រើនលើសលប់គឺជារូបិយប័ណ្ណបរទេស។ ក៏ប៉ុន្តែ រូបិយប័ណ្ណបរទេសមានតួនាទីបន្ទាប់បន្សំប៉ុណ្ណោះ បើប្រៀបធៀបជាមួយនឹងរូបិយប័ណ្ណក្នុងស្រុក ក្នុងការបើកផ្តល់ប្រាក់បៀវត្សរ៍ និងការបង់ពន្ធ។ សេដ្ឋកិច្ច ***ដុល្លាររូប-នីយកម្មពាក់កណ្តាលផ្លូវការ*** ដូចជាប្រទេសកម្ពុជានេះ មានធនាគារកណ្តាលនិងអាជ្ញាធររូបិយវត្ថុផ្សេងៗទៀត និងមានភាពទន់ភ្លន់ក្នុងការអនុវត្តនូវគោលនយោបាយរូបិយវត្ថុ។

***ដុល្លាររូបនីយកម្មផ្លូវការ*** ដែលត្រូវបានហៅផងដែរថាជា ***ដុល្លាររូបនីយកម្មពេញលេញ*** កើតឡើងនៅពេលដែលរូបិយប័ណ្ណបរទេសមានឋានៈផ្តាច់មុខ ឬលើសលប់ជារូបិយប័ណ្ណផ្លូវការពេលលេញ។ ប្រការនេះមានន័យថារូបិយប័ណ្ណបរទេស មិនត្រឹមតែជារូបិយប័ណ្ណស្របច្បាប់សម្រាប់ការប្រើប្រាស់ក្នុងកិច្ច-សន្យារវាងភាគីឯកជនប៉ុណ្ណោះទេ ក៏ប៉ុន្តែរដ្ឋាភិបាលក៏ប្រើប្រាស់វាក្នុងប្រតិបត្តិការក្នុងស្រុកផងដែរ។ រូបិយប័ណ្ណក្នុងស្រុកនៅតែមានវត្តមាន ប៉ុន្តែតួនាទីរូបិយវត្ថុរបស់វាគឺ មានលក្ខណៈបន្ទាប់បន្សំតែប៉ុណ្ណោះ។

***ការជំនួសរូបិយប័ណ្ណ*** កើតឡើងនៅពេលដែលអត្រាអតិផរណាខ្ពស់និងប្រែប្រួល មិនលើកទឹកចិត្តដល់ការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។ ***ការជំនួសទ្រព្យសកម្ម*** ក៏អាចបណ្តាលមកពីការគេចចេញពីរូបិយប័ណ្ណក្នុងស្រុក នៅពេលដែលនិវាសនជនងាកទៅរកទ្រព្យសកម្ម ចារឹកជារូបិយប័ណ្ណបរទេស ក្នុងការបំពេញតួនាទីរបស់រូបិយវត្ថុ ជាអ្នករក្សាទុកនូវតម្លៃ។ ជាងនេះទៅទៀត ក្នុងឆ្នាំថ្មីៗនេះ ដុល្លាររូបនីយកម្មកាន់តែរីកដុះដាលឡើងនៅក្នុងប្រទេសខ្លះ ដោយសារតែបម្រែបម្រួលស្ថាប័ន ជាពិសេស សេរីភាវូបនីយកម្មនៃគណនីមូលធនបានលើកទឹកចិត្តដល់ដំណើរការនេះ។ ដូច្នេះ ការកើនឡើងនៃទ្រព្យសកម្មចារឹកជារូបិយប័ណ្ណបរទេស នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ គឺជាលទ្ធផលនៃការសម្រេចចិត្តក្នុងការវិនិយោគទិញភាគហ៊ុន ដោយសារតែស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានស្ថេរភាព ហើយមិនមែនជាការគេចចេញពីរូបិយប័ណ្ណក្នុងស្រុកនោះទេ។

ដុល្លាររូបនីយកម្មនៃសេដ្ឋកិច្ចកម្ពុជាបានចាប់ផ្តើមក្នុងដើមទសវត្សរ៍ឆ្នាំ១៩៩០ ក្នុងបរិការណ៍នៃការហូរចូលយ៉ាងសន្ធឹកសន្ធាប់នូវជំនួយបរទេស និងការផ្ទេរប្រាក់ឯកជន អតិផរណាកម្រិតខ្ពស់និងភាពមិនប្រាកដប្រជាខាងផ្នែកនយោបាយ។ ក្នុងដំណាក់កាលដំបូង ដុល្លាររូបនីយកម្មបានកើតឡើងក្នុងសេដ្ឋកិច្ចកម្ពុជា ដោយសារតែការបាត់បង់ទំនុកចិត្តពីសាធារណជនក្នុងប្រាក់រៀល អតិផរណាកម្រិតខ្ពស់និងការបាត់បង់យ៉ាងលឿននូវអំណាចទិញរបស់រូបិយប័ណ្ណក្នុងស្រុក។ ក៏ប៉ុន្តែ ដុល្លាររូបនីយកម្មនៅតែបន្តទៀត ទោះបីជាកម្ពុជាបានកែលម្អនូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាសមិទ្ធផលយ៉ាងធំធេងក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅក៏ដោយ។ ការកើនឡើងនៃរូបិយវត្ថុទូទៅបាននាំឱ្យមានការកើនឡើងនៃទ្រព្យសកម្មបរទេស ហើយប្រការនេះបណ្តាលមកពីការកើនឡើងនៃប្រាក់បញ្ញើរូបិយប័ណ្ណបរទេស។

នាពេលបច្ចុប្បន្ន កម្ពុជាមានសេដ្ឋកិច្ចប្រើប្រាក់ដុល្លារយ៉ាងខ្លាំងមួយ ជាមួយនឹង៩៧.៨%នៃទ្រព្យ-សកម្មធនាគារ ជាប្រាក់ដុល្លារអាមេរិក។ និន្នាការនេះនឹងមិនត្រឡប់បញ្ច្រាស់មកវិញក្នុងរយៈពេលឆាប់ៗនេះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទេ។ នៅចុងឆ្នាំ២០០៦ ប្រាក់បញ្ញើធនាគារជាប្រាក់រៀលបានកើនត្រឹមតែ២៦% តែប៉ុណ្ណោះ ខណៈពេលដែលប្រាក់បញ្ញើជាដុល្លារអាមេរិកបានកើន៩៦%។ ប្រាក់បញ្ញើរូបិយប័ណ្ណបរទេសបានកើនឡើងពី ៨៥.៣%នៃបញ្ញើសរុបក្នុងឆ្នាំ១៩៩៣ ដល់៩៧%ក្នុងឆ្នាំ២០០៦។ ដូច្នេះ ប្រាក់បញ្ញើធនាគារជាប្រាក់រៀលមានចំណែកត្រឹមតែ៣% ប៉ុណ្ណោះ ហើយចំណែកនៃប្រាក់កម្ចីធនាគារជាប្រាក់រៀលមានចំនួន៥%។

សេដ្ឋកិច្ចកម្ពុជា គឺជាសេដ្ឋកិច្ចដុល្លារូបនីយកម្មកម្រិតខ្ពស់ តែមិនមែនពេញលេញទាំងស្រុងទេ។ ដោយសារតែគ្មានទិន្នន័យច្បាស់លាស់ពីបរិមាណពិតនៃប្រាក់ដុល្លារ និងរូបិយប័ណ្ណបរទេសផ្សេងៗដែលចរាចរខាងក្រៅប្រព័ន្ធធនាគារ គេពិបាកកំណត់ទំហំដុល្លាររូបនីយកម្មក្នុងសេដ្ឋកិច្ចកម្ពុជា ឱ្យបានត្រឹមត្រូវណាស់ (ទោះបីជាទូទៅ គេអាចសន្មតបានថា រូបិយប័ណ្ណបរទេសមានចំណែកប្រមាន ៩០% នៃរូបិយប័ណ្ណសរុបដែលកំពុងចរាចរ)។ ប្រាក់ដុងវៀតណាម និងប្រាក់បាតថៃ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងខេត្តនានាជាប់ព្រំប្រទល់ប្រទេសទាំងពីរ។ តែទោះជាយ៉ាងណាក្តី ប្រាក់ដុល្លារអាមេរិកមានចំណែកច្រើនជាងគេក្នុងចំណោមរូបិយប័ណ្ណបរទេសដែលកំពុងចរាចរនៅកម្ពុជា។

### *៣.៤.៧.១. ដុល្លាររូបនីយកម្ម និង គោលនយោបាយរូបិយវត្ថុ*

ដុល្លាររូបនីយកម្មក៏មានទិដ្ឋភាពវិជ្ជមានផងដែរ ដូចជាការលើកកម្ពស់ស្ថេរភាពនិងការអភិវឌ្ឍនៃវិស័យហិរញ្ញវត្ថុ។ ក៏ប៉ុន្តែ ដុល្លារូបនីយកម្មបានធ្វើឱ្យគោលនយោបាយរូបិយវត្ថុ គ្មានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ ខាងក្រោមនេះ គឺជាទិដ្ឋភាពវិជ្ជមាននិងអវិជ្ជមាននៃដុល្លាររូបនីយកម្ម។

**ស្ថេរភាពនិងការការពារទល់នឹងហានិភ័យអត្រាប្តូរប្រាក់** - ក្នុងសេដ្ឋកិច្ចចាយប្រាក់ដុល្លារដ៏ខ្ពស់បែបនេះ ប្រតិបត្តិការហិរញ្ញវត្ថុដ៏ធំ និងដែលពាក់ព័ន្ធជាមួយពាណិជ្ជកម្មត្រូវបានទូទាត់ជាប្រាក់ដុល្លារ។ ប្រការនេះបានកាត់បន្ថយហានិភ័យនៃការធ្លាក់ចុះនៃតម្លៃរូបិយបណ្ណ។ តម្រូវការប្រាក់រៀលសម្រាប់ប្រតិបត្តិការទូទាត់នៅទាបនៅឡើយ ហើយទីផ្សារសម្រាប់ប្រាក់រៀលគឺនៅតូច ហើយវិសាលភាពនៃការប្រើប្រាស់ប្រាក់រៀលសម្រាប់ប្រតិបត្តិការរកផលចំណេញ មានតិចតួច។ ដូច្នេះ ប្រាក់រៀលរក្សាបានស្ថេរភាពខ្លាំង ហើយជាមធ្យមការធ្លាក់ចុះនៃតម្លៃប្រាក់រៀលទល់នឹងប្រាក់ដុល្លារប្រហែលជាស្មើនឹង១%សម្រាប់រយៈពេលពីឆ្នាំ២០០៦ដល់ឆ្នាំ២០០៨។ ដូច្នេះ ការឡើងថ្លៃនៃទំនិញនាំចូលមានឥទ្ធិពលតិចតួចទៅលើអតិផរណា។

**ការការពារទល់នឹងវិបត្តិរូបិយប័ណ្ណ** - ដោយសារតែកម្ពុជាមិនដែលធ្វើអន្តរាគមន៍ ដើម្បីការពារអត្រាប្តូរប្រាក់ នោះមានហានិភ័យដ៏តិចតួចប៉ុណ្ណោះដែលនាំឱ្យមានវិបត្តិសេដ្ឋកិច្ច ដែលបណ្តាលមកពីជញ្ជីងទូទាត់ និងមិនសូវមានភាពងាយទទួលរងគ្រោះដែលបណ្តាលមកពីការរាលដាលនៃវិបត្តិ។ ក្នុងប្រព័ន្ធរូបិយវត្ថុជាតិធម្មតា គេតែងតែប្រើប្រាស់នូវគោលនយោបាយរូបិយវត្ថុ ដើម្បីកាត់បន្ថយតម្រូវការនៅគ្រប់ផ្នែក។ ចំពោះសេដ្ឋកិច្ចចាយប្រាក់ដុល្លារកម្រិតខ្ពស់គេគ្មានជម្រើសបែបនេះឡើយ។ក៏ប៉ុន្តែប្រព័ន្ធកែសម្រួលថ្លៃទំនិញបែបនេះ នៅតែអាចប្រើប្រាស់បាន ក្នុងទីផ្សារកត្តាផលិតកម្មនិងទំនិញមួយចំនួន។

**ការបាត់បង់នូវគោលនយោបាយរូបិយវត្ថុដែលមានប្រសិទ្ធភាព** - ការខាតបង់ដ៏សំខាន់មួយទៀត គឺការខាតបង់ភាពទន់ភ្លន់នៃគោលនយោបាយរូបិយវត្ថុ។ ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលមិនអាចប្រើប្រាស់ឧបករណ៍រូបិយវត្ថុណាមួយ ដើម្បីជះឥទ្ធិពលទៅលើសមាសធាតុរូបិយវត្ថុបរទេស

នៅក្នុងរូបិយវត្ថុទូទៅ និងមិនអាចកំណត់ការផ្គត់ផ្គង់រូបិយវត្ថុបានឡើយ។ ការផ្គត់ផ្គង់រូបិយវត្ថុពឹងផ្អែកទៅលើអាកប្បកិរិយារបស់ទីភ្នាក់ងារដែលមានទ្រព្យសកម្មជាប្រាក់ដុល្លារ និងប្រាក់រៀល។ ដូច្នេះ សេដ្ឋកិច្ចដុល្លារូបនីយកម្មពេញលេញ គ្មានជម្រើសណាមួយ ក្រៅពីការទទួលយកគោលនយោបាយរូបិយវត្ថុរបស់ប្រទេសដែលបោះផ្សាយក្រដាសប្រាក់នោះទេ។ ប្រការនេះបង្កើតបាននូវស្ថានភាពមួយដែលគេហៅថាការប៉ះទង្គិចគ្មានដែនកំណត់ (Calvo ១៩៩៩)។

**ការខាតបង់តួនាទីជាធនាគារកណ្តាលជាអ្នកឱ្យខ្ចីប្រាក់ជាចុងក្រោយ**-ដុល្លាររូបនីយកម្មមិនបានលុបបំបាត់នូវហានិភ័យនៃវិបត្តិធនាគារទេ។ នៅក្នុងពេលដែលមានវិបត្តិធនាគារ ធនាគារកណ្តាលត្រូវមានតួនាទីជាអ្នកឱ្យខ្ចីប្រាក់ចុងក្រោយ ទៅដល់ធនាគារពាណិជ្ជកម្មនានា តាមរយៈការផ្តល់បុរេប្រទាន ឬផ្តល់នូវឥណទាន ដល់ធនាគារពាណិជ្ជទាំងឡាយណាដែលកំពុងដំណើរការ តែដែលត្រូវការសាច់ប្រាក់បន្ថែមដើម្បីធានានូវប្រតិបត្តិការជាប្រចាំ។ ដុល្លាររូបនីយកម្មមិនបង្ករលក្ខណៈឱ្យអាជ្ញាធររូបិយវត្ថុផ្តល់នូវសាច់ប្រាក់រយៈពេលខ្លីដល់ប្រព័ន្ធធនាគារ ដើម្បីដោះស្រាយស្ថានភាពខ្វះខាតសាច់ប្រាក់ឡើយ។ ការប្រើប្រាស់ប្រាក់ដុល្លារដោយធនាគារពាណិជ្ជក្នុងប្រតិបត្តិការរបស់ខ្លួន មិនផ្តល់លទ្ធភាពឱ្យធនាគារកណ្តាល ក្នុងការផ្តល់ការធានារ៉ាប់រងនៃប្រព័ន្ធទូទាត់និងប្រាក់បញ្ញើធនាគារ។ ធនាគារកណ្តាលមិនអាចបញ្ចូលប្រាក់រៀល ចូលទៅក្នុងប្រព័ន្ធមួយ ដែលគ្របដណ្តប់ដោយប្រាក់ដុល្លារបានទេ។ ដំណោះស្រាយតែមួយគត់ គឺត្រូវរៀបចំខ្ចីឥណទានពីធនាគារបរទេស។ ក៏ប៉ុន្តែ ដំណោះស្រាយនេះនឹងនាំឱ្យមានចំណាយខ្ពស់ ទោះបីជាគេអាចរកប្រភពឥណទាននេះបានក៏ដោយ។ ជម្រើសមួយផ្សេងទៀតសម្រាប់ធនាគារកណ្តាល គឺត្រូវបង្គរទុកនូវទុនបម្រុងជារូបិយប័ណ្ណបរទេស ហើយបង្កើតឡើងជាមួយរតនាគារជាតិ នូវមូលនិធិស្ថេរភាពមួយ ដែលអាចប្រើប្រាស់ ដើម្បីទប់ទល់នឹងការបើកប្រាក់ច្រើនចេញពីធនាគារក្នុងពេលតែមួយ។ ដូចនេះ ធនាគារជាតិនៃ កម្ពុជាមិនអាចរៀបចំឧបករណ៍គោលនយោបាយរូបិយវត្ថុដែលមានប្រសិទ្ធភាព ហើយក៏មិនអាចបំពេញតួនាទីរបស់ខ្លួនជាអ្នកឱ្យខ្ចីប្រាក់ជាចុងក្រោយដល់ធនាគារពាពិជ្ជ ដែលប្រឈមមុខនឹងបញ្ហាលំហូរសាច់ប្រាក់នោះបានដែរ។ ឧបករណ៍គោលនយោបាយតែមួយគត់ ដែលធនាគារកណ្តាលអាចប្រើប្រាស់បាន គឺការប្រើប្រាស់ទុនបម្រុងអន្តរជាតិរបស់ខ្លួន ដើម្បីឱ្យធនាគារពាណិជ្ជខ្ចី។ ដំណោះស្រាយនេះប្រហែលមិនអាចមានចីរភាពបានទេ ប្រសិនបើវិបត្តិនេះនៅអូសបន្លាយក្នុងរយៈពេលយូរអង្វែង។

**ការប៉ះទង្គិចពីខាងក្រៅ** - ដូចជាការកើនឡើងខ្លាំងនៃថ្លៃប្រេងឥន្ទនៈក្នុងពិភពលោក ឬ ការធ្លាក់ចុះនៃថ្លៃផលិតផលនាំចេញសំខាន់ៗមួយចំនួន អាចជំរុញឱ្យប្រទេសមួយឱ្យទម្លាក់តម្លៃរូបិយវត្ថុរបស់ខ្លួនក្នុងសេដ្ឋកិច្ចចាយប្រាក់ដុល្លារ។ ប្រសិនបើការកែតម្រូវនេះត្រូវបានដោះស្រាយតាមរយៈការធ្លាក់ចុះនៃប្រាក់បៀវត្សរ៍ និងការតម្រូវនៃថ្លៃទំនិញក្នុងស្រុក នោះប្រទេសជាតិនឹងជួបនូវហានិភ័យ ដែលស្ទើរតែមិនអាចគេចផុតបាន គឺការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរនៃសេដ្ឋកិច្ច ជាពិសេស នៅក្នុងសេដ្ឋកិច្ចណា ដែលមានទីផ្សារពលកម្មគ្មានភាពទន់ភ្លន់។

ដុល្លាររូបនីយកម្មមិនអាចលុបបំបាត់ប្រភពទាំងអស់នៃវិបត្តិធនាគារបានទេ ទោះបីដុល្លាររូបនីយកម្មពេញលេញបានការពារប្រព័ន្ធធនាគារពីហានិភ័យនៃការធ្លាក់តម្លៃ។ ប្រសិនបើវិបត្តិដូចនេះកើតឡើងមែន សមត្ថភាពរបស់ធនាគារកណ្តាល ដើម្បីដើរតួនាទីជាអ្នកឱ្យខ្ចីជាចុងក្រោយ ក្នុងស្ថានភាពប្រកាសអាសន្នដែលមានរយៈពេលយូរ នោះនឹងត្រូវបានគេធ្វើការសាកល្បងយ៉ាងធ្ងន់ធ្ងរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តែទោះជាយ៉ាងណា ដុល្លាររូបនីយកម្មនឹងមិនបង្ករគ្រោះថ្នាក់លើសលប់ដល់លទ្ធភាពរបស់អាជ្ញាធរនានាក្នុងការផ្តល់សាច់ប្រាក់ទៅឱ្យប្រព័ន្ធនេះ នៅលើមូលដ្ឋានរយៈពេលខ្លីឬជួយដល់ធនាគារនីមួយៗដែលយល់ថាខ្លួនកំពុងស្ថិតក្នុងផលវិបាក។ ធនាគារកណ្តាលអាចដើរតួនាទីនេះប្រសិនបើវាអាចបង្កើនទុនបម្រុងឱ្យបានច្រើនជាមុន ឬ ប្រសិនបើធនាគារកណ្តាលអាចទទួលឥណទានពីធនាគារអន្តរជាតិនោះ។

ក្នុងករណីនៃការបាត់បង់នូវជំនឿទុកចិត្តធំធេង អាជ្ញាធរនានានឹងមិនអាចមានសមត្ថភាពក្នុងការធានាបាននូវប្រព័ន្ធទូទាត់ ឬ ប្រាក់បញ្ញើទាំងអស់របស់ធនាគារពាណិជ្ជ ដោយសារតែការបាត់បង់នៃទុនបម្រុង។ ទាល់តែធនាគារកណ្តាលអាចបោះផ្សាយប្រាក់សម្រាប់ចរាចរ ទើបធនាគារកណ្តាលមានលទ្ធភាពធានាដោយគ្មានការសង្ស័យក្នុងការសងបំណុលនៃប្រព័ន្ធធនាគារ (ជារូបិយប័ណ្ណជាតិ) ជាយថាហេតុ។ នៅពេលណាដែលធនាគារកណ្តាលបាត់បង់សមត្ថភាពនេះ តួនាទីរបស់ខ្លួនជាអ្នកឱ្យខ្ចីជាចុងក្រោយមិនអាចអនុវត្តទៅបាន។ ប្រទេសចាយប្រាក់ដុល្លារទាំងស្រុងមួយ ដែលបានបង់នូវធនបម្រុងរូបិយប័ណ្ណបរទេសរួចហើយនោះនឹងគ្មានជម្រើសណានៅសល់ ក្រៅតែពីការបោះបង់ចោលរបបដុល្លាររូបនីយកម្ម ប្រសិនបើប្រឈមមុខជាមួយនឹងស្ថានភាព ដែលអតិថិជនសម្រុកដកប្រាក់បញ្ញើដ៏ច្រើនចេញពីធនាគារ។

### *៣.៤.៧.២. ដុល្លាររូបនីយកម្ម និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ*

**ការលើកកម្ពស់វិន័យថវិកា** - ដុល្លាររូបនីយកម្មបានលើកកម្ពស់វិន័យថវិកា។ ខណៈដែលវាមិនអាចលុបបំបាត់ឱនភាពថវិកាបាន នោះឱនភាពនេះនឹងត្រូវបានផ្តល់ហិរញ្ញប្បទានតាមរយៈវិធីសាស្ត្រមានតម្លាភាពត្រឹមត្រូវនៃការផ្តល់ហិរញ្ញប្បទានបរទេស ការតម្លើងពន្ធ ឬបំណុលរដ្ឋាភិបាលដ៏មានតម្លាភាព។ ដូច្នេះ ដុល្លាររូបនីយកម្មបានលើកកម្ពស់ការយល់ដឹងដោយអ្នកបង្កើតគោលនយោបាយ អំពីតម្រូវការនេះ ដើម្បីជៀសវាងការផ្តល់ហិរញ្ញប្បទានដោយធនាគារនៃឱនភាពសាធារណៈ ដែលអាចនាំទៅរកកំណើននៃអតិផរណាកាន់តែខ្លាំងឡើង។ ការផ្តល់ហិរញ្ញប្បទានធនាគារនៃឱនភាពថវិកា ឧទាហរណ៍ការខ្ចីដោយរដ្ឋាភិបាលពីធនាគារកណ្តាល ដើម្បីផ្តល់ហិរញ្ញប្បទាននៃឱនភាពថវិកា នឹងកាត់បន្ថយជាខ្លាំងនូវការផ្គត់ផ្គង់រូបិយវត្ថុជាប្រាក់រៀល ដែលនឹងជះឥទ្ធិពលភ្លាមៗដល់ទីផ្សាររូបិយវត្ថុ ដែលនាំឱ្យប៉ះពាល់ដល់តម្រូវការ និងការផ្គត់ផ្គង់រូបិយវត្ថុជាដុល្លារ។ ការឡើងចុះនៃអត្រាប្តូរប្រាក់អាចកើតឡើងតាមរយៈច្រកនេះ។ ដូច្នេះ ដុល្លារ-រូបនីយកម្មតម្រូវឱ្យរដ្ឋាភិបាលធានានូវវិន័យថវិកា និងជ្រើសរើសប្រើការផ្តល់ហិរញ្ញប្បទាននៃឱនភាពថវិកាតាមរយៈជំនួយឥតសំណង ឬកម្ចីមានសម្បទានប៉ុណ្ណោះ ឧទាហរណ៍ ការខ្ចីពីខាងក្រៅដែលមានលក្ខណៈសម្បទាន (ជាប្រាក់ដុល្លារអាមេរិកជាចម្បង)។

**ការគ្រប់គ្រងអត្រាប្តូរប្រាក់មានស្ថេរភាព** - ដុល្លាររូបនីយកម្មតម្រូវឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបើកផ្តល់ចំណាយថវិកាជាប្រាក់រៀល ក្នុងទម្រង់មួយដែលធានាបាននូវស្ថេរភាពនៃអត្រាប្តូរប្រាក់។ ដោយសារតែដុល្លាររូបនីយកម្មកាត់បន្ថយសមត្ថភាពរបស់ធនាគារកណ្តាល ដើម្បីប្រើប្រាស់អត្រាការប្រាក់ដើម្បីគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ និងតម្លៃរបស់រូបិយប័ណ្ណជាតិ ពោលគឺអត្រាប្តូរប្រាក់នោះ គោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវតែដើរតួនាទីឱ្យបានលើសលប់ ក្នុងការធានាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ ការផ្គត់ផ្គង់ប្រាក់រៀលហួសកម្រិតក្នុងទីផ្សាររូបិយវត្ថុនឹងជះឥទ្ធិពលភ្លាមដល់អត្រាប្តូរប្រាក់។ តែទោះជាយ៉ាងណាជាមួយនឹងលទ្ធភាពប្តូរបាននៃគណនីចរន្តនិងសេរីភាវូបនីយកម្មគណនីមូលធន នោះគោលនយោបាយ

ហិរញ្ញវត្ថុសាធារណៈ ត្រូវយកចិត្តទុកដាក់ចំពោះលំហូរចូលនិងលំហូរចេញរបស់ប្រាក់ដុល្លារអាមេរិក តាមរយៈការកែសម្រួលអត្រាប្តូរប្រាក់។ សរុបមក នៅក្នុងបរិបទនៃដុល្លាររូបនីយកម្ម យន្តការតែមួយគត់ ដែលអាចប្រើប្រាស់ក្នុងការ គ្រប់គ្រងអត្រាប្តូរប្រាក់ គឺការអនុវត្តថវិកាជាតិដោយប្រុងប្រយ័ត្ន។ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរក្នុងសេដ្ឋកិច្ចចាយប្រាក់ដុល្លារ តម្រូវឱ្យមានការសម្របសម្រួលយ៉ាងជិតស្និទ្ធរវាងធនាគារកណ្តាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ការលើកកម្ពស់ស្ថេរភាពថ្លៃទំនិញ** - គោលដៅមួយ ក្នុងចំណោមគោលដៅនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច នោះគឺត្រូវធានានូវស្ថេរភាពថ្លៃទំនិញនិងកំណើនសេដ្ឋកិច្ច។ គេឃើញមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ រវាងកម្រិតនៃអតិផរណា និងកំណើនសេដ្ឋកិច្ច ដូចបានពិភាក្សារួចហើយក្នុងផ្នែកទីពីរនៃឯកសារនេះ។ ក្នុងបរិបទនៃសេដ្ឋកិច្ចចាយប្រាក់ដុល្លារ ស្ថេរភាពថ្លៃទំនិញអាចសម្រេចបាន តាមរយៈស្ថេរភាពអត្រាប្តូរប្រាក់។ ដោយកម្ពុជានាំចូលទំនិញប្រើប្រាស់ដ៏ច្រើនសម្រាប់ការប្រើប្រាស់ក្នុងស្រុក នោះការឡើងចុះនៃអត្រាប្តូរប្រាក់អាចនាំឱ្យថ្លៃទំនិញឡើងចុះភ្លាមៗ។ ដូច្នេះ ការគ្រប់គ្រងថវិកាដ៏ប្រុងប្រយ័ត្ន គឺចាំបាច់ដើម្បីធានាបាននូវស្ថេរភាពអត្រាប្តូរប្រាក់ និងស្ថេរភាពថ្លៃទំនិញ។

**ការសម្រួលពាណិជ្ជកម្មអន្តរជាតិនិងសមាហរណកម្មសេដ្ឋកិច្ច** - ដុល្លាររូបនីយកម្មបានកាត់បន្ថយថ្លៃដើមប្រតិបត្តិការ ដែលបណ្តាលមកពីភាពខុសគ្នារវាងអត្រាលក់និងទិញ ដោយសារការប្តូររូបិយប័ណ្ណក្នុងស្រុកទៅជារូបិយប័ណ្ណបរទេស។ តាមរយៈការកាត់បន្ថយថ្លៃដើមប្រតិបត្តិការពាណិជ្ជកម្មដោយសារតែមិនចាំបាច់ប្តូររូបិយប័ណ្ណ ប្រការនេះបានរួមចំណែកដល់កំណើនដ៏ឆាប់រហ័សនៃឧស្សាហកម្មកាត់ដេរ ដែលកំពុងរីកដុះដាលយ៉ាងឆាប់រហ័ស។ ក្នុងស្ថានភាពនេះ គេមិនចាំបាច់ទិញធានារ៉ាប់រង ដើម្បីឱ្យជៀសផុតពីហានិភ័យដែលបណ្តាលមកពី បម្រែបម្រួលអត្រាប្តូរប្រាក់រៀលទល់នឹងប្រាក់ដុល្លារ។ ប្រការនេះនឹងជួយផងដែរដល់សមាហរណកម្មនៃទីផ្សារក្នុងស្រុក ចូលទៅក្នុងទីផ្សារក្នុងពិភពលោក។ នៅក្នុងសេដ្ឋកិច្ចចាយប្រាក់ដុល្លារខ្ពស់ ទុនបម្រុងអន្តរជាតិនឹងត្រូវបានគេប្រើកាន់តែច្រើនឡើង ដើម្បីធានាបាននូវសុខភាពនៃប្រព័ន្ធធនាគារ និងកាន់តែតិចឡើងៗ ដើម្បីធានានូវស្ថេរភាពអត្រាប្តូរប្រាក់។ ដូច្នេះ ដុល្លាររូបនីយកម្ម អាចត្រូវបានគេប្រើប្រាស់ ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរស្ថាប័ន គណនីយភាព និងតម្លាភាពហិរញ្ញវត្ថុ។

**ការខាតបង់** seigniorage -ទិដ្ឋភាពអវិជ្ជមានដ៏ចម្បងនៃដុល្លាររូបនីយកម្ម គឺការខាតបង់នូវ seigniorage សម្រាប់រដ្ឋាភិបាល។ seigniorage គឺជាប្រាក់ចំណូលបានមកពីការបោះផ្សាយរូបិយប័ណ្ណ។ seigniorage គឺជាផលសង រវាងចំណាយក្នុងការបោះផ្សាយនិងចែកចាយក្រដាសប្រាក់និងកាក់ និងកម្លាំងទិញរបស់វា។ ការប៉ាន់ស្មានមួយចំនួនបង្ហាញថា ការខាតបង់ seigniorage អាចមានទំហំធំសម្រាប់កម្ពុជា។ ធនាគារជាតិនៃកម្ពុជាបានប៉ាន់ស្មានថា ប្រាក់ចំណូលដែលបាត់បង់នេះ អាចមានចំនួនពី២០ ទៅ៩០លានដុល្លារអាមេរិក។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣.៥. ទស្ស័យខាងក្រៅ

យើងអាចពិពណ៌នាដោយសង្ខេបក្នុងតារាងខាងក្រោមនេះ នូវលក្ខណៈពិសេសដ៏សំខាន់នៃការអភិវឌ្ឍវិស័យខាងក្រៅរបស់កម្ពុជា ក្នុងអំឡុងឆ្នាំ២០០១-២០០៨ ។

- ការនាំចេញបានកើនឡើងយ៉ាងឆាប់រហ័សក្នុងទសវត្សរ៍ចុងក្រោយនេះ ប៉ុន្តែបានថយចុះវិញ ក្នុងឆ្នាំ២០០៧ និង ២០០៨ ដោយឆ្លុះបញ្ចាំងពីភាពងាយរងគ្រោះនៃសកម្មភាពដែលទាក់ទងនឹងការនាំចេញ ដោយសារតែមូលដ្ឋាននាំចេញចង្អៀត និងផ្តោតជាសំខាន់ទៅលើវិស័យកាត់ដេរ ដែលបានកើនឡើងសម្រាប់ទីផ្សារអាមេរិក។
- ការនាំចូលកំពុងតែកើនឡើងលឿនជាងការនាំចេញ ប៉ុន្តែមាននិន្នាការដូចគ្នា។ ការកើនឡើងនៃថ្លៃទំនិញ និងថ្លៃប្រេងឥន្ធនៈ គឺជាការរួមចំណែកដល់កំណើននៃការនាំចូល។
- ឱនភាពគណនីចរន្តបានរីកធំយ៉ាងខ្លាំងក្នុងឆ្នាំ២០០៨ ដោយឆ្លុះបញ្ចាំងពីការឡើងខ្ពស់នៃថ្លៃប្រេងឥន្ធនៈ និងថ្លៃទំនិញផ្សេងទៀត។ ក៏ប៉ុន្តែ គេបានរំពឹងទុកថា ឱនភាពនេះនឹងថយចុះក្នុងឆ្នាំ២០០៩។

*តារាង៣.៥. កម្ពុជា៖ សូចនាករវិស័យខាងក្រៅ ឆ្នាំ២០០១-២០០៨*

| | 94 | 99 | 01 | 02 | 03 | 04 | 05 | 06 | 07 | 08 |
|---|---|---|---|---|---|---|---|---|---|---|
| វិស័យខាងក្រៅ | | | | | | | | | | |
| ការនាំចេញក្នុងស្រុក (% បម្រែបបម្រួល) | 1315 | 47 | 15 | 13 | 16 | 29 | 13 | 28 | 11 | 9 |
| ការនាំចូល(% បម្រែបបម្រួល) | 55 | 37 | 8 | 11 | 10 | 28 | 20 | 21 | 14 | 23 |
| ការនាំចូល (មិនរាប់បញ្ចូលសម្លៀកបំពាក់, % បម្រែបបម្រួល) | 55 | 28 | 6 | 8 | 8 | 29 | 27 | 21 | 16 | 32 |
| សមតុល្យនៃជញ្ជីងទូទាត់ចរន្ត (មិនរាប់បញ្ចូលការផ្ទេរ)លានដុល្លារ | -347 | -444 | -349 | -359 | -450 | -440 | -591 | -526 | -730 | -1,705 |
| សមតុល្យនៃជញ្ជីងទូទាត់ចរន្ត (រាប់បញ្ចូលការផ្ទេរ) លានដុល្លារ | -112 | -188 | -45 | -47 | -137 | -122 | -256 | -77 | -332 | -1,205 |
| ការវិនិយោគដោយផ្ទាល់(US$,លានដុល្លារ) | 162 | 221 | 142 | 139 | 74 | 121 | 375 | 483 | 866 | 785 |
| សមតុល្យសរុប | -113 | -49 | 45 | 60 | 33 | 31 | 65 | 193 | 426 | 511 |
| ទុនបម្រុងសរុប(US$,លានដុល្លារ) | 100 | 422 | 548 | 663 | 737 | 809 | 915 | 1,097 | 1,616 | 2,104 |
| (ចំនួនខែនៃការនាំចូល) | 1.78 | 2.84 | 2.79 | 3.05 | 3.08 | 2.67 | 2.55 | 2.54 | 3.29 | 3.51 |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

- វិនិយោគទុនដោយផ្ទាល់ពីបរទេស (FDI) បានកើនឡើងអំឡុងឆ្នាំ២០០៥-២០០៨ប៉ុន្តែត្រូវបានរំពឹងថានឹងធ្លាក់ចុះក្នុងឆ្នាំ២០០៩ ដែលជាលទ្ធផលមួយនៃវិបត្តិហិរញ្ញវត្ថុពិភពលោក។
- ទុនបម្រុងផ្លូវការសរុបបានកើនឡើងទ្វេដង ចន្លោះខែមករា ឆ្នាំ២០០៦ និងខែធ្នូ ឆ្នាំ២០០៨ ដែលឆ្លុះបង្ហាញឱ្យឃើញពីការអនុវត្តការនាំចេញបានល្អ និងមានកំណើនខ្លាំងក្នុងលំហូរមូលធន រួមមានវិនិយោគទុនដោយផ្ទាល់ពីបរទេស (FDI) និងហិរញ្ញប្បទានសហប្រតិបត្តិការ (ODA)។

## ៣.៤.៧. អាហរណ៍ និង នីហរណ៍

ការនាំចេញបានកើន១៥% ពី៤ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៧ ទៅដល់ ៤.៧ពាន់លានដុល្លារក្នុងឆ្នាំ២០០៨។ ការនាំចេញសម្លៀកបំពាក់បានកើនឡើងបន្តិចត្រឹម២% ដល់៣ពាន់លានដុល្លារ។ វិស័យកាត់ដេរត្រូវបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីវិបត្តិហិរញ្ញវត្ថុពិភពលោក ដែលនាំឱ្យមានតម្រូវការធ្លាក់ចុះ។ ការធ្លាក់ចុះនៃការនាំចេញសម្លៀកបំពាក់ ត្រូវបានទូទាត់ដោយការកើនឡើង៥២% នៃការនាំចេញផលិតផលមិនមែនសម្លៀកបំពាក់ ដែលជាលទ្ធផលមួយនៃការកើនឡើងខ្ពស់នៃថ្លៃស្រូវ កៅស៊ូ និងផលិតផលកសិកម្មផ្សេងៗទៀត។ សហរដ្ឋអាមេរិកនៅតែជាទីផ្សារនាំចេញនាំមុខគេដែលមានចំណែក ៧០% នៃការនាំចេញសរុបរបស់កម្ពុជា។ បន្ទាប់មកគឺសហភាពអឺរ៉ុបដែលមានចំណែក ២១% និងកាណាដា៤%។ ការនាំចេញបន្តបានកើន១៩% ពី២១៥លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៧ ដល់២៨៤លានដុល្លារក្នុងឆ្នាំ២០០៨។

| តំនូសតាង៣.២០a. ពាណិជ្ជកម្មអន្តរជាតិ | តំនូសតាង៣.២០b. ការនាំចេញសម្លៀកបំពាក់ (fob, លានដុល្លារ) |
| --- | --- |
|  |  |




*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

ការនាំចូលបានកើន១៩% ពី៥.៥លានដុល្លារក្នុងឆ្នាំ២០០៧ ទៅដល់៦.៥លានដុល្លារក្នុងឆ្នាំ២០០៨។ ក្នុងចំណោមនេះ ការនាំចូលសម្រាប់ក្នុងស្រុកបានកើន១៩% ទៅដល់៦.៣ពាន់លានដុល្លារ។ កំណើននេះគឺបណ្តាលមកពីការកើនឡើងចំនួន ៤៣% នៃការនាំចូលប្រេងសាំង កំណើន១៦% នៃការនាំចូលទំនិញប្រើប្រាស់ផ្សេងៗ និងកំណើន៣១% នៃការនាំចូលសម្រាប់ការនាំចេញបន្ត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.៤.៨. ជញ្ជីងពាណិជ្ជកម្ម

ឱនភាពពាណិជ្ជកម្មរបស់កម្ពុជាបានកើន៣២% ពី១.៣ពាន់លានដុល្លារក្នុងឆ្នាំ២០០៧ ទៅដល់១.៨ពាន់លានដុល្លារក្នុងឆ្នាំ២០០៨ ជាចម្បងដោយសារតែកំណើននៃថ្លៃទំនិញនាំចូលនៃផលិតផលប្រេងសាំង។

### ៣.៤.៩. សេវាកម្ម ចំណូល និង ការផ្ទេរ

ចំណូលពីសេវាកម្មបានកើន៦% ពី១.៥ពាន់លានដុល្លារក្នុងឆ្នាំ២០០៧ ទៅដល់១.៦ពាន់លានដុល្លារក្នុងឆ្នាំ២០០៨។ សេវាកម្មសុទ្ធសម្រេចបាននូវអតិរេកចំនួន ៥៨៧លានដុល្លារ គឺធ្លាក់ចុះ៤%។ សេវាកម្មដឹកជញ្ជូនបានកើន១៤% និងការធ្វើដំណើរ៨%។ ចំនួនអ្នកទេសចរបានកើនឡើង៥% ហើយសម្រេចបាន ២.១លាននាក់ក្នុងឆ្នាំ២០០៨។ ទេសចរពីកូរ៉េខាងត្បូងទទួលបានចំណាត់ថ្នាក់ទីមួយ ដោយមានចំណែក ១៣% នៃចំនួនទេសចរសរុប បន្ទាប់មកគឺទេសចរពីប្រទេសវៀតណាម (១០%) ជប៉ុន (៨%) សហរដ្ឋអាមេរិក (៧%) និងចិន (៦%)។ ចំណូលពីវិស័យទេសចរណ៍ត្រូវបានគេប៉ាន់ស្មានថាមានចំនួន១.៥ពាន់លានដុល្លារក្នុងឆ្នាំ២០០៨។

ប្រាក់ចំណូលសុទ្ធសម្រេចបាននូវឱនភាពចំនួន ៤០៨លានដុល្លារ ដោយកើនឡើង១៧% បើប្រៀបធៀបទៅនឹងឆ្នាំ២០០៧។ កត្តារួមចំណែកដ៏ចម្បងនៃឱនភាពនេះ បណ្តាលមកពីការកើនឡើងនៃចំណាយដែលទាក់ទងទៅនឹងប្រាក់ចំណូលវិនិយោគ ភាគលាភ ចំណាយការប្រាក់ និងការផ្ទេរប្រាក់ចំណូលពីបរទេស ។ ការផ្ទេរប្រាក់ឯកជនសុទ្ធសម្រេចបាននូវអតិរេកចំនួន៣៧២លានដុល្លារ។ ការផ្ទេរប្រាក់ទាំងនេះគឺជាការផ្ទេរប្រាក់មកកម្ពុជា ដោយជនជាតិកម្ពុជាដែលធ្វើការ និងរស់នៅបរទេស។

### ៣.៤.១០. គណនីចរន្ត និង ការផ្ទេរមូលធន

ឱនភាពគណនីចរន្ត (មិនរួមបញ្ចូលការផ្ទេរប្រាក់ផ្លូវការទេ) បានកើន៧៤% ពី៧៣២លានដុល្លារឬ ៨.២% នៃផសស ក្នុងឆ្នាំ២០០៧ ទៅដល់១.២៧ពាន់លានដុល្លារ ឬ១២.៣% នៃផសស ក្នុងឆ្នាំ២០០៨។ កំណើននៃឱនភាពគណនីចរន្តគឺបណ្តាលមកជាចម្បង ពីឱនភាពពាណិជ្ជកម្មកាន់តែកើនឡើង ដោយសារការកើនឡើងនៃថ្លៃទំនិញប្រើប្រាស់ និងផលិតផលប្រេងសាំង។

ឱនភាពគណនីចរន្ត (រួមបញ្ចូលទាំងការផ្ទេរប្រាក់) ត្រូវគេរំពឹងទុកថាធ្លាក់ចុះក្នុងឆ្នាំ២០០៩មកត្រឹមប្រហែល៥½ភាគរយនៃGDP ដោយសារតម្រូវការនាំចូលធ្លាក់ចុះ ហើយការធ្លាក់ចុះនៃថ្លៃប្រេងឥន្ធនៈបានប៉ះប៉ូវនូវការកាត់បន្ថយការនាំចេញ និងការធ្លាក់ចុះនៃចំណូលទេសចរណ៍។ តែទោះជាយ៉ាងណាក្តី ឱនភាពគណនីចរន្តនឹងកើនឡើងដល់១១%នៃGDP ក្នុងឆ្នាំ២០១០ ដោយសារតែការនាំចេញកើនឡើងយឺត ហើយការនាំចូលនិងថ្លៃប្រេងឥន្ធនៈនឹងកើនឡើង។

ការផ្ទេរផ្លូវការ រួមមានជំនួយឥតសំណង ជំនួយម្ហូបអាហារ ជំនួយគម្រោង និងប្រាក់បៀវត្សរ៍ TA សម្រេចបានចំនួន៤៨៦លានដុល្លារក្នុងឆ្នាំ២០០៨ ធ្លាក់ចុះ១% បើប្រៀបធៀបទៅនឹងឆ្នាំមុន។ ក្នុងការឆ្លើយតបទៅនឹងវិបត្តិស្បៀងវិញ ជំនួញស្បៀងបានកើន៥២% ដល់៣០លានដុល្លារក្នុងឆ្នាំ២០០៨។ ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ និងការផ្ទេរមូលធនបានកើនឡើងទ្វេដងដល់ចំនួន៧៨៩លានដុល្លារ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៧។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៣.៤.១១. គណនីហិរញ្ញវត្ថុ

គណនីហិរញ្ញវត្ថុគឺជាកម្ចីវិស័យផ្លូវការ និងវិនិយោគទុនវិស័យមិនមែនសាធារណៈ។ លំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុបានកើនឡើង៧០% ពី៦៩៥លានដុល្លារក្នុងឆ្នាំ២០០៧ដល់១,១៨៤លានដុល្លារក្នុងឆ្នាំ២០០៨។ ការកើនឡើងនៃលំហូរចូលសុទ្ធក្នុងគណនីហិរញ្ញវត្ថុ មានសារៈសំខាន់ណាស់ក្នុងការផ្ដល់ហិរញ្ញប្បទាននៃឱនភាពគណនីចរន្តដែលកំពុងកើនឡើង។

កម្ចីផ្លូវការដែលត្រូវបានផ្ដល់ដល់រាជរដ្ឋាភិបាលកម្ពុជា ដោយរដ្ឋាភិបាលនៃប្រទេសជាមិត្ត និងស្ថាប័នពហុភាគីនានា បានកើនឡើង១៨% ពី១៩៩លានដុល្លារក្នុងឆ្នាំ២០០៧ ទៅដល់២៣៥លានដុល្លារក្នុងឆ្នាំ២០០៥។ ការបើកផ្ដល់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានកើនឡើង១៨៣% ដែលបានប៉ះប៉ូវការកាត់បន្ថយចំនួន ៥៥% នៃការបើកផ្ដល់កម្ចីពីធនាគារពិភពលោក។ កម្ចីពីមូលនិធិហិរញ្ញវត្ថុអន្តរជាតិ (IMF) មិនត្រូវបានរាប់បញ្ចូល ក្នុងកម្ចីផ្លូវការទេ ដោយសារកម្ចីនេះត្រូវបានប្រើប្រាស់ ដើម្បីបង្កើននូវទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា។

ការវិនិយោគនៃវិស័យមិនមែនសាធារណៈបានកើនឡើង៩២% ពី ៤៩៥លានដុល្លារក្នុងឆ្នាំ២០០៧ ទៅដល់៩៤៥លានដុល្លារក្នុងឆ្នាំ២០០៨។ លំហូរចូលសុទ្ធនៃវិនិយោគដោយផ្ទាល់ពីបរទេស (FDI) បានកើន ៨% ពី៨៦៦លានដុល្លារក្នុងឆ្នាំ២០០៧ ទៅដល់៧៩៥លានដុល្លារក្នុងឆ្នាំ២០០៨។ ក្នុងចំណោមលំហូរចូលសុទ្ធនេះ វិនិយោគផ្ទាល់ក្នុងវិស័យធនាគារបានកើនឡើងដល់៣៤៤លានដុល្លារ ហើយវិនិយោគផ្ទាល់ក្នុងវិស័យមិនមែនធនាគារសម្រេចបាន៤៦២លានដុល្លារ។

ដូច្នេះការកើនឡើងនៃគណនីហិរញ្ញវត្ថុ គឺបណ្ដាលមកទាំងស្រុងពីការកើនឡើងនៃការវិនិយោគសុទ្ធផ្សេងៗទៀត ដែលបានកើនឡើងរហូតឈានដល់១៦៨លានដុល្លារ ដែលឆ្លុះបញ្ចាំងពីកំណើននៃទ្រព្យសកម្មបរទេសសុទ្ធនៃធនាគារពាណិជ្ជ (៨១៤លានដុល្លារ) និងប្រាក់បញ្ញើមិនកំណត់ថេរវេលារបស់ធនាគារពាណិជ្ជ ជាមួយនឹងធនាគារជាតិនៃកម្ពុជា (២៦៤លានដុល្លារ)។ ជាងនេះទៅទៀត លំហូរចេញនៃខ្ទង់ផ្សេងៗក្នុងគណនីវិនិយោគផ្សេងៗចំនួន៥៥២លានដុល្លារក៏បានរួមចំណែកដល់លទ្ធផលនេះដែរ។

### ៣.៤.១២. សមតុល្យរួម

គណនីហិរញ្ញវត្ថុនិងមូលធនបានកើនឡើង៤១% ពី១,១៨៤.២លានដុល្លារ (១៣.៥% នៃGDP) ក្នុងឆ្នាំ២០០៧ ទៅដល់១,៦៧០.២លានដុល្លារ (១៦.២% នៃGDP) ក្នុងឆ្នាំ២០០៨។ ការកើនឡើងដល់១៦.២% នៃGDP នេះគឺគ្រប់គ្រាន់ដើម្បីផ្ដល់ហិរញ្ញប្បទានដល់ឱនភាពគណនីចរន្តចំនួន១២.៣% នៃGDP ដែលនាំឱ្យមានអតិរេកនៃជញ្ជីងទូទាត់ជារួម ចំនួន៣៩៥.២លានដុល្លារអាមេរិក (៣.៣៩% នៃGDP)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*គំនូសតាង៣.២១. តុល្យការនៃការចំណាយរបស់កម្ពុជា (ជា%នៃGDP)*




សរុបឡើងវិញមក ឱនភាពគណនីចរន្តដែលកើនឡើង ត្រូវបានផ្តល់ហិរញ្ញប្បទានដោយការផ្ទេរផ្លូវការ (៨៨៥.៨លានដុល្លារ) កម្ចីសម្បទាន (២៣៩.៧លានដុល្លារ) វិនិយោគផ្ទាល់សរុបក្នុងវិស័យធនាគារនិងមិនមែនធនាគារ (៧៩៩.៧លានដុល្លារ) និងវិនិយោគសរុបផ្សេងទៀត (១៦៨.០លានដុល្លារ)។ ហិរញ្ញប្បទានបរទេសនៃឱនភាពគណនីចរន្តនឹងនៅតែមានទំហំធំក្នុងឆ្នាំខាងមុខ។

## ៣.៦. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨ និង ទស្សនវិស័យ

បន្ទាប់ពីសម្រេចបាននូវកំណើនសេដ្ឋកិច្ចដល់កំពូល ដែលមិនធ្លាប់មានពីពេលមុនមក គឺ១៣.៣% ក្នុងឆ្នាំ២០០៥ នោះកំណើន ផសស ពិតបានធ្លាក់ចុះមកនៅត្រឹម ១០.៨% ក្នុងឆ្នាំ២០០៦ បន្ទាប់មក ១០.២% ក្នុងឆ្នាំ២០០៧ និងរហូតមកត្រឹម ៦.៧% ក្នុងឆ្នាំ២០០៨។ កំណើនផសស ពិត បានកើនឡើងជាមធ្យម ១០.៣% អំឡុងឆ្នាំ២០០៤-២០០៨។ សមិទ្ធិផលនេះសម្រេចបាន ដោយសាររាជរដ្ឋាភិបាលកម្ពុជាបាន និងបន្តជួយគាំទ្រយ៉ាងខ្លាំងដល់វិស័យកសិកម្ម និងឧស្សាហកម្មកាត់ដេរ។ វិស័យទេសចរណ៍និងសំណង់បានក្លាយជាក្បាលរទេះភ្លើងដ៏សំខាន់ដែលជំរុញកំណើនសេដ្ឋកិច្ច។ ដូច្នេះ សមិទ្ធិផលសេដ្ឋកិច្ចគួរឱ្យកោតសរសើរនេះអាចសម្រេចទៅបាន ដោយសារការរួមចំណែកស្មើៗគ្នាពីវិស័យកសិកម្ម កម្មន្តសាល សំណង់និងសេវាកម្ម។

ក៏ប៉ុន្តែ កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០០៨ សម្រេចបាន ៦.៧% ដែលជាសមិទ្ធិផលមួយគួរជាទីពេញចិត្ត ក្នុងបរិការណ៍នៃវិបត្តិសេដ្ឋកិច្ចពិភពលោក តែកំណើននេះធ្លាក់ចុះបន្តិច បើប្រៀបធៀបជាមួយឆ្នាំ ២០០៤-២០០៧។ សមិទ្ធិផលសេដ្ឋកិច្ចដ៏ខ្លាំងក្លាក្នុងឆ្នាំ២០០៨ នេះអាចសម្រេចទៅបាន ដោយសារមានកំណើនប្រកបដោយចីរភាពនៃវិស័យកសិកម្ម (៥.៧%) វិស័យទេសចរណ៍ (៩.៨%) ការកើនឡើងនៃនាំចេញសម្លៀកបំពាក់ទោះបីមានជំហានចុះថយជាងមុនក៏ដោយ (២.២%) ការពង្រីកជាបន្តបន្ទាប់នៃសេវាកម្មហិរញ្ញវត្ថុ (១៩.២%) និងសកម្មភាពសំណង់ (៥.៨%)។

### ៣.៦.៧. កសិកម្ម

កសិកម្មសម្រេចបាននូវកំណើនដ៏ខ្ពស់ចំនួន៥.៧% ក្នុងឆ្នាំ២០០៨ តែនៅទាបជាងកំណើនជាមធ្យមប្រចាំឆ្នាំចំនួន៨% ក្នុងអំឡុងឆ្នាំ២០០៥-២០០៨។ ផលិតផលស្រូវនិងដំណាំផ្សេងទៀតបានកើន៦.៦% ដោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សារាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បានធ្វើការវិនិយោគយ៉ាងច្រើនក្នុងប្រព័ន្ធធារាសាស្ត្រ។ បសុសត្វបានកើន៣.៨% ហើយនេសាទកើនឡើង ៦.៥%។ ព្រៃឈើសម្រេចបាននូវកំណើនត្រឹមតែ ០.៩%។

### ៣.៦.៨. ឧស្សាហកម្ម

វិស័យឧស្សាហកម្មសម្រេចបាននូវកំណើនខ្ពស់ក្នុងអត្រា ៩% ដោយការរីកដុះដាលនៃវិស័យរ៉ែ (១៥.៨%) និងកំណើនជាបន្តបន្ទាប់នៃឧស្សាហកម្មកាត់ដេរ (២.២%)។ សកម្មភាពចម្បងៗដែលរួមចំណែកដល់កំណើននេះគឺការធ្វើអាជីវកម្មរុករករ៉ែបុកស៊ីត ដែក ទង់ដែង និងមាសក្នុងខេត្តភាគបូព៌ានិងឦសាន្តនៃប្រទេសកម្ពុជា។ ក្រុមហ៊ុន Oz Mineral បានចំណាយជាង៤លានដុល្លារ ទៅលើការរុករកស្រទាប់រ៉ែមាសក្នុងខេត្តក្រចេះ។

វិស័យសំណង់បានកើនត្រឹមតែ ៥.៨% ក្នុងឆ្នាំ២០០៨។ សកម្មភាពសំណង់បានបង្ហាញពីសញ្ញានៃការធ្លាក់ចុះក្នុងឆមាសទីពីរនៃឆ្នាំ២០០៨។ យើងសង្កេតឃើញថា គម្រោងការស្ថាបនាទីក្រុងរណបថ្មីៗ តំបន់សេដ្ឋកិច្ចពិសេស និងគម្រោងអភិវឌ្ឍន៍វិស័យទេសចរណ៍មួយចំនួន ដូចជាគម្រោងអភិវឌ្ឍន៍កោះពស់ គម្រោងទីក្រុងកាំកូ គម្រោងអភិវឌ្ឍន៍បឹងស្នោ និងគម្រោងទីក្រុងសាន់វេជាដើម ស្ថិតក្នុងភាពជាប់គាំង។ យ៉ាងណាមិញ អ្នកអភិវឌ្ឍន៍វិស័យអចលនទ្រព្យខ្លះនៅតែបន្តគម្រោងរបស់ខ្លួន ទោះបីជាត្រូវបោះជំហានយឺតជាងមុន ហើយត្រូវកាត់បន្ថយទ្រង់ទ្រាយនិងទំហំក៏ដោយ។ ការថយចុះនៃគម្រោងដែលវិនិយោគដោយឯកជននេះត្រូវបានប៉ះប៉ូវដោយការកើនឡើងនៃការអនុវត្តគម្រោងសាធារណៈ ដូចជាការស្ថាបនាស្ពាន និងផ្លូវថ្នល់។

### ៣.៦.៩. វិស័យសេវាកម្ម

ផ្នែកសេវាកម្មបានកើន៩.០% ក្នុងឆ្នាំ២០០៨ ជាមួយនឹងការរួមចំណែកដ៏ខ្លាំងពីគ្រប់អនុវិស័យទាំងអស់។ ការពង្រីកឧស្សាហកម្មវិស័យទេសចរណ៍និងសណ្ឋាគារនៅតែបន្ត ជាមួយនឹងអត្រាកំណើន៩.៨%។ អនុវិស័យដឹកជញ្ជូននិងគមនាគមន៍បានកើនសមល្មម ៧.១%។ បន្ទាប់ពីការបញ្ចប់ការស្តារឡើងវិញនិងការស្ថាបនានូវបណ្តាញផ្លូវជាតិនោះ រាជរដ្ឋាភិបាលកម្ពុជាបានបង្វែរការយកចិត្តទុកដាក់ទៅលើការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជនបទនិងខេត្ត សម្រាប់ការបញ្ចូលទីជនបទ ឱ្យចូលទៅក្នុងចរន្តមេនៃសេដ្ឋកិច្ចកម្ពុជា។ អនុវិស័យទូរគមនាគមន៍បានបង្ហាញពីកំណើនដ៏ខ្លាំង ជាពិសេសទីផ្សារសេវាកម្មទូរស័ព្ទចល័ត។ តែទោះជាយ៉ាងណាក្តី ថ្លៃសេវាទូរស័ព្ទក្នុងប្រទេសកម្ពុជានៅមានកម្រិតខ្ពស់នៅឡើយ ដែលជាកត្តាមួយដែលមិនលើកទឹកចិត្តដល់កំណើនដ៏ឆាប់រហ័សនៃវិស័យទូរគមនាគមន៍។ សេវាកម្មហិរញ្ញវត្ថុបានកើន១៩.២%។ កត្តារួមចំណែកដ៏ចម្បងដល់កំណើនដ៏ឆាប់រហ័សនេះ គឺសេវាកម្មធនាគារពាណិជ្ជ។ សេវាកម្មអចលនទ្រព្យបានកើន៥%។ សកម្មភាពពាណិជ្ជកម្មបានកើនឡើង ៩.៤%។

## ៣.៧. ផលប៉ះពាល់នៃវិបត្តហិរញ្ញវត្ថុពិភពលោកមកលើសេដ្ឋកិច្ចកម្ពុជា

### ៣.៧.៧. បុព្វហេតុនៃវិបត្តិ

វិបត្តិហិរញ្ញវត្ថុចាប់ផ្តើមនៅ ខែ សីហា ឆ្នាំ ២០០៧ ជាវិបត្តិកម្ចីអនុគ្រោះ (subprime crisis) ដែលកើតឡើងដោយសារអតុល្យភាពនៃហិរញ្ញវត្ថុពិភពលោក និងក្នុងបរិបទសេរីភាវូបនីយកម្មនៃទីផ្សារហិរញ្ញវត្ថុពិភព



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លោក ។ ទីផ្សារកម្ចីអនុគ្រោះ មានកំណើនយ៉ាងលឿនក្នុងរយៈពេលពីរ ឬ បីឆ្នាំចុងក្រោយនៅសហរដ្ឋអាមេរិក ដែលទីផ្សារនេះមានប្រាក់ទុនមិនតិចជាង ១.០០០ ពាន់លានដុល្លារ ប្រៀបនឹងដើមទុនទីផ្សារមូលប័ត្រដែលមានប្រាក់ទុន ២០.០០០ ពាន់លានដុល្លារ ឬ ទ្រព្យសម្បត្តិនៃគ្រួសារអាមេរិក ដែលមានទឹកប្រាក់ ៦០.០០០ ពាន់លានដុល្លារ ។

កត្តាដូចខាងក្រោមនេះ មានជាមូលហេតុដែលនាំឱ្យមានវិបត្តិកម្ចីអនុគ្រោះ ៖

**អតិរេកសាច់ប្រាក់នៅក្នុងពិភពលោក និងការអភិវឌ្ឍស៊ីជម្រៅនៃវិស័យហិរញ្ញវត្ថុ** (ការផ្គត់ផ្គង់រូបិយវត្ថុចែកនឹង ផ.ស.ស នៃប្រទេសឧស្សាហកម្ម ០៦ មានសហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ជប៉ុន ចិន ចក្រភពអង់គ្លេស និងកាណាដា) បានកើនឡើងពី ២០ % ក្នុងឆ្នាំ ១៩៨០-១៩៧០ ដល់ ៣០ % ក្នុងឆ្នាំ ២០០៦-២០០៧។ ទុនបម្រុងបរទេសរបស់ប្រទេសកំពុងងើបឡើង និងការពង្រីកឥណទានកើនឡើងលឿនពេក (កំណើនសេដ្ឋកិច្ច ការធ្លាក់ចុះអត្រាការប្រាក់ពិត និង ការបង្កើតមុខទំនិញហិរញ្ញវត្ថុថ្មីៗ ) ។

**ការធ្លាក់ចុះអតិផរណា និង ភាពប្រែប្រួល៖** ក្នុងពិភពលោក ។

**ការធ្លាក់ចុះនៃបុព្វលាភហានិភ័យ ដោយសារតែឥរិយាបថហ៊ានទទួលយកហានិភ័យ៖** កំណើនខ្លាំងនៃអតិរេកសាច់ប្រាក់នាំឱ្យភ្នាក់ងារសេដ្ឋកិច្ចនាំគ្នាទិញយកទ្រព្យសកម្មដែលមានហានិភ័យខ្ពស់ ដើម្បីពង្រឹងស្ថានភាពហិរញ្ញវត្ថុខ្លួន និងស្វែងរកផលវិនិយោគខ្ពស់ ។ ផ្ទុយទៅវិញចាប់តាំងពីខែសីហា ឆ្នាំ ២០០៧ មក ការហ៊ានទទួលយកហានិភ័យបានកើនឡើងយ៉ាងខ្លាំង ។

**ការធ្លាក់ចុះអត្រាការប្រាក់រយៈពេលវែង អតិផរណាទាប និងការប្រែប្រួល៖** ជាមួយនឹងការធ្លាក់ចុះនៃបុព្វលាភហានិភ័យនាំឱ្យអត្រាប្តូរប្រាក់រយៈពេលវែងធ្លាក់ចុះ ទោះបីជាមានការអនុត្ត (ដោយយឺតពេល) នៃគោលនយោបាយរូបិយវត្ថុតឹងរ៉ឹងនៅសហរដ្ឋអាមេរិកក៏ដោយ។

**ការពង្រីកឥណទានក្នុងបរិបទអត្រាអតិផរណាទាប ៖** ការធ្លាក់ចុះអត្រាការប្រាក់និងតម្លៃហានិភ័យ បង្កើតលក្ខខណ្ឌឱ្យឃើញថា ឥណទានមានការប្រាក់ទាប និងសម្បូរ។ កំណើនដែលមានអត្រាអតិផរណាទាបបានបន្តកើតឡើង ទោះបីជាតម្លៃវត្ថុធាតុដើម (ប្រេង លោហធាតុ និង ម្ហូបអាហារ) កើនឡើងដោយសារតែកំណើនតម្រូវការពីប្រទេសកំពុងងើបឡើង។ ការធ្លាក់ចុះអត្រាការប្រាក់ និងបុព្វលាភហានិភ័យផ្តល់ជាលក្ខខណ្ឌអនុគ្រោះសម្រាប់សកម្មភាពដែលមានគំនាស់ខ្លាំង (ដែលមានអត្រាបំណុលខ្ពស់) ក្នុងនោះរួមមានកំណើនបំណុលនៃមូលនិធិធនាគារពាណិជ្ជ (debt leverage of commercial bank) មូលនិធិបង្ការបម្រុង (hedge funds) និងមូលនិធិម្ចាស់ទុនឯកជន (private equity funds)។

**កំណើនតម្លៃទ្រព្យសកម្ម៖** នៅពេលមានអតិរេកសាច់ប្រាក់តែមិនជះឥទ្ធិពលលើតម្លៃទំនិញនិងសេវាកម្ម ឥទ្ធិពលនឹងជះទៅលើតម្លៃទ្រព្យសកម្មវិញ ដោយសារតែការផ្គត់ផ្គង់ទ្រព្យសកម្មតិច។ កំណើនតម្លៃទ្រព្យសកម្មបង្កើតលក្ខខណ្ឌល្អសម្រាប់បង្កើនកម្ចីបញ្ចាំទ្រព្យ។ កំណើនតម្លៃទ្រព្យសកម្មធ្វើឱ្យមានកំណើន សុខមាលភាព រួចនាំទៅរកកំណើនចំណាយប្រើប្រាស់ ។

**កំហុសផ្នែកមីក្រូសេដ្ឋកិច្ច៖** ១)-ការស្វែងរកផលវិនិយោគខ្ពស់វិនិយោគិនពឹងទៅលើទីផ្សារប័ណ្ណបំណុល (ការងាកពីទីផ្សារភាគហ៊ុនមកវិនិយោគនៅលើទីផ្សារបំណុល ដែលផ្តល់ប្រាក់ចំណេញខ្ពស់)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

២)-ធនាគារពាណិជ្ជប្រើយុទ្ធសាស្ត្រមុខពីរ ដោយបង្កើនទំហំសកម្មភាពស្របពេលនឹងការបន្ធូរលក្ខខណ្ឌឱ្យខ្ចីប្រាក់ និងការដាក់ចេញនូវផលិតផលហិរញ្ញវត្ថុថ្មី និង ៣)-ការបន្ធូរលក្ខខណ្ឌឱ្យខ្ចីឥណទាន ទំហំនៃកម្ចីអនុគ្រោះ (ផ្តល់ជូនចំពោះអ្នកខ្ចីដែលហានិភ័យខ្ពស់) កើនឡើង ៧ ដង ពី ៩៤ ពាន់លានដុល្លារ នៅឆ្នាំ ២០០១ ដល់ ៦៨៥ ពាន់លានដុល្លារ នៅឆ្នាំ ២០០៦ ។ កម្ចីដែលមានអត្រាការប្រាក់អណ្តែតកើនឡើងយ៉ាងខ្លាំង ស្របនឹងការថយចុះកម្ចីការប្រាក់ថេរ ។

**ការទទួលយកហានិភ័យខ្ពស់ក្នុងវិស័យហិរញ្ញវត្ថុ៖** ដើម្បីពង្រឹងប្រព័ន្ធធនាគារ និយ័តករត្រូវបង្កើនដើមទុនរបស់ធនាគារឱ្យសមស្របតាមទំហំឥណទានដែលធនាគារផ្តល់ទៅឱ្យអតិថិជន ។ បទប្បញ្ញត្តិប្រុងប្រយ័ត្ននេះមានគោលដៅកាត់បន្ថយការផ្តល់ឥណទានកុំឱ្យកើនឡើយលឿនពេក ការពារដល់អ្នកផ្ញើប្រាក់ និងធានាដល់សុខភាពនៃប្រព័ន្ធធនាគារ។ ក៏ប៉ុន្តែ ស្ថាប័នហិរញ្ញវត្ថុបានបង្កើតយុទ្ធសាស្ត្រគេចមិនព្រមអនុវត្តតាមបទបញ្ញត្តិនេះ ដោយប្រើការធានារ៉ាប់រងកម្ចី ។

## ៣.៧.៨. ដំណើរឆ្ពោះទៅរកវិបត្តិ

អ្នកផ្តល់ឥណទានសាងសង់បានផ្តល់កម្ចីអនុគ្រោះ (subprime loans) ដល់គ្រួសារដែលមានប្រាក់ចំណូលទាប ដែលគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់ទទួលបានកម្ចីធម្មតា (prime rate loans) និង ដែលមានប្រវត្តិធ្លាប់មិនបានសងបំណុលផ្សេងទៀតរួចទៅហើយ ។ គ្រួសារទាំងនេះមិនដឹងថា អត្រាការប្រាក់ជាអត្រាអណ្តែតឬនឹងកើនក្រោយពេល ១ ឬ ២ ឆ្នាំបន្ទាប់ឡើយ ។

អ្នកផ្តល់ឥណទានសាងសង់បានលក់កម្ចីអនុគ្រោះទៅឱ្យធនាគារវិនិយោគ (ជួនកាលអ្នកផ្តល់ឥណទានសាងសង់ និង ធនាគារវិនិយោគជាក្រុមតែមួយ)។

ដោយសារ**នវានុវត្តន៍ហិរញ្ញវត្ថុ** វិស្វករហិរញ្ញវត្ថុបានយកកម្ចីអនុគ្រោះទៅធ្វើជាវត្ថុធាតុដើម ដើម្បីផលិតឧបករណ៍ហិរញ្ញវត្ថុថ្មីតាមរយៈដំណើរការធនបត្រនីយកម្ម(securitization)ឱ្យទៅជាមូលប័ត្រមានដូចជា **មូលប័ត្របញ្ចាំទ្រព្យបណ្តាក់** Morgage-Backed Securities (MBS)ឬ (ការប្រាក់ និងប្រាក់ដើមនៃមូលបត្រនេះបានមកពីការសងការប្រាក់និងប្រាក់ដើមនៃឥណទានទិញផ្ទះសម្បែង) ឬ ឱ្យទៅជា**មូលប័ត្របញ្ចាំទ្រព្យសកម្ម** Asset-Backed Securities (ABS) ឬ (ការប្រាក់ និង ប្រាក់ដើមនៃមូលប័ត្រនេះបានមកពីការសងការប្រាក់ និងប្រាក់ដើមនៃឥណទានផ្សេងៗ ដូចជាឥណទានផ្តល់ឱ្យនិស្សិតសិក្សានៅឧត្តមសិក្សាជាដើម)។ ហើយបន្ទាប់មកវិស្វករហិរញ្ញវត្ថុបានយក**មូលប័ត្របញ្ចាំទ្រព្យបណ្តាក់** និង**មូលប័ត្របញ្ចាំទ្រព្យសកម្ម** ទៅចិតច្រៀកផ្តល់ការធានាដើម្បីបង្កើតជាមូលប័ត្រថ្មីគឺ **កាតព្វកិច្ចបំណុលមានទ្រព្យបញ្ចាំ** (Collateralized Debt Obligations)។ **កាតព្វកិច្ចបំណុលមានទ្រព្យបញ្ចាំ**ដែលផលិតពី**មូលប័ត្រទ្រព្យបញ្ចាំ** និង **មូលប័ត្រទ្រព្យសកម្ម** ត្រូវបានដាក់ចំណាត់ថ្នាក់ដោយភ្នាក់ងារចាត់ថ្នាក់ (rating agencies) មានដូចជាក្រុមហ៊ុនមូឌី ឬ អេសនិងភី ដើម្បីបំបែកហានិភ័យ និងដាក់លក់ឱ្យវិនិយោគិនទៅតាមកម្រិតហានិភ័យ និងទិន្នផលចំណូលដែលគេចង់បាន ។

ធនាគារវិនិយោគទិញកាតព្វកិច្ចបំណុលមានទ្រព្យបញ្ចាំ(Collateralized Debt Obligations) ដែលមានប្រភពពីមូលប័ត្រទ្រព្យសកម្មរាប់កោដិដុល្លារដើម្បីទុកខ្លួនឯង និងទិញឱ្យអតិថិជនរបស់ខ្លួន ពីព្រោះតែវាផ្តល់ប្រាក់ចំណេញខ្ពស់ជាងប័ណ្ណរតនាគារអាមេរិក។ ដើម្បីការពារហានិភ័យ ធនាគារវិនិយោគទិញសេវាធានា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រងឯកទេស (ក្រុមហ៊ុនធានាឥណទាន) ឬក៏ទិញមូលប័ត្រពិសេសដែលហៅថា **បណ្ណរបំណុលខូច** (Credit Default Swap) ដែលជាឧបករណ៍ការពារហានិភ័យចេញលក់ដោយធនាគារវិនិយោគមួយចំនួន។បណ្ណរបំណុលខូច(Credit Default Swap) បានក្លាយជាទីផ្សារពេញដ៏ធំមួយដែលផ្តល់កម្រៃដ៏សន្ធឹកសន្ធាប់ នៅពេលដែលមិនទាន់មានវិបត្តិ។ ក៏ប៉ុន្តែ ហានិភ័យប្រភេទនេះមិនអាចដោះស្រាយបានដោយការធានារ៉ាប់រងឡើយ ។

នៅពេលដែលអត្រាការប្រាក់ចាប់ផ្តើមកើនឡើងនៅចុងឆ្នាំ២០០៦ គ្រួសារអាមេរិកដឹងថាខ្លួនមិនអាចទូទាត់សំណងប្រចាំខែបានទេ។ ដោយសារតែមិនអាចសងការប្រាក់លើកម្ចីបញ្ចាំទ្រព្យបាន ធនាគារបានរឹបអូសយកផ្ទះសម្បែងទាំងនោះ ដើម្បីយកទៅលក់ឡាយឡុងក្នុងគោលដៅទូទាត់បំណុល។ ក៏ប៉ុន្តែដោយសារតែមានគ្រួសារច្រើនពេកជួបបញ្ហាដូចគ្នានេះ ទីផ្សារអចលនវត្ថុត្រូវចុះថ្លៃដួលរលំ។

វិនិយោគិនដែលទិញ**កាតព្វកិច្ចបំណុលមានទ្រព្យបញ្ចាំ** (Collateralized Debt Obligations) តាមរយៈមូលនិធិសង្គហធន (Mutual Funds) ដឹងថាមូលប័ត្រមានការធានាដោយទ្រព្យបញ្ចាំមិនអាចផ្តល់ផលទៀតឡើយ ។ ដូចនេះ អ្នកដែលមានមូលប័ត្រទាំងនេះ ក៏ចាប់ផ្តើមលក់វាចោលដោយអ្នកលក់មានច្រើនតែគ្មានអ្នកទិញទីផ្សារនេះបានដួលរលំ។ ក្រុមហ៊ុនធានាឥណទាន ដែលត្រូវធានាលើតម្លៃមូលប័ត្រមិនអាចទូទាត់សំណងបានក៏ប្រកាសក្ស័យធន ។ រួចហើយ ធនាគារវិនិយោគត្រូវបញ្ចុះតម្លៃកាតព្វកិច្ចបំណុលមានទ្រព្យបញ្ចាំដែលមាននៅក្នុងសៀវភៅបញ្ជីរបស់ខ្លួន ។

ធនាគារទាំងអស់ដឹងច្បាស់ពីតម្លៃ «**បំពុល**» របស់កាតព្វកិច្ចបំណុលមានទ្រព្យបញ្ចាំ ដែលមានក្នុងបញ្ជីរបស់ខ្លួន ប៉ុន្តែមិនដឹងថាធនាគារផ្សេងទៀតមានបញ្ហាកម្រិតណាទេ។ ធនាគារប្រយ័ត្នដោយមិនឱ្យធនាគារមួយទៀតខ្ចីប្រាក់ លើកលែងតែទទួលបានអត្រាការប្រាក់ខ្ពស់។ ដូចនេះ ធនាគារដែលអាស្រ័យទៅលើទីផ្សារអន្តរធនាគារក្នុងការបំពេញហិរញ្ញប្បទានមានភាពទុនខ្សោយ។ ទីផ្សារកាន់តែស្មុគស្មាញ និងមិនច្បាស់លាស់ហើយភាពក្ស័យធនរបស់ស្ថាប័នហិរញ្ញវត្ថុមួយនឹងជះឥទ្ធិពលដល់ធនាគារមួយទៀត ហៅថាឥទ្ធិពលសម្លកំពឹស (interconnected financial institutions world wide)។ ដូចនេះ ការក្ស័យធនរបស់ធនាគារមួយជះរលកឥទ្ធិពលដល់ធនាគារដទៃទៀតដែលពាក់ព័ន្ធ។

## ៣.៧.៩. ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុពិភពលោកមកលើសេដ្ឋកិច្ចកម្ពុជា

វិបត្តិសេដ្ឋកិច្ចពិភពលោកនាពេលបច្ចុប្បន្នបានជះឥទ្ធិពលដោយប្រយោលតែប៉ុណ្ណោះមកលើសេដ្ឋកិច្ចកម្ពុជា។ ធនាគារពាណិជ្ជកម្មរបស់កម្ពុជាមិនមានហានិភ័យដោយផ្ទាល់ចំពោះកម្ចីដែលមានការប្រាក់ខ្ពស់ទេ។ វិស័យធនាគាររបស់កម្ពុជាជារួមនៅតែមានភាពក្លៀវក្លា។ ឥទ្ធិពលនេះគឺមានកម្រិតតិចតួចចំពោះធនាគារតូចៗ។ ទោះបីប្រាក់បញ្ញើរូបិយប័ណ្ណបរទេសបានជួបនឹងការធ្លាក់ចុះបន្តិចក៏ដោយ ឥណទានចំពោះវិស័យឯកជននៅតែបន្តលូតលាស់ដដែល ដោយផ្តោតទៅលើលំហូរសាច់ប្រាក់លើសលប់នៃវិស័យធនាគារ។

ទោះជាយ៉ាងនេះក្តី មានផលប៉ះពាល់ដោយប្រយោល ភាគច្រើនទៅលើវិស័យពិតប្រាកដរបស់សេដ្ឋកិច្ច។ កំណើន GDP របស់កម្ពុជាបានធ្លាក់ចុះពី១០.២%ក្នុងឆ្នាំ២០០៧ មកត្រឹម៦.៧% ក្នុងឆ្នាំ២០០៨និងត្រូវបានប៉ាន់ប្រមាណជា ២.១%ក្នុងឆ្នាំ២០០៩។ ផលប៉ះពាល់ដោយប្រយោលនេះនឹងត្រូវបានកត់សម្គាល់នៅកម្រិតដូចខាងក្រោម៖

### ៣.៧.៩.១. ផលប៉ះពាល់ប្រយោលលើធនាគារពាណិជ្ជ

វិបត្តិហិរញ្ញវត្ថុពិភពលោកបច្ចុប្បន្ននឹងមានផលប៉ះពាល់ដោយប្រយោលមានកំណត់តែប៉ុណ្ណោះ ប្រសិនបើមានទៅលើធនាគារនៅកម្ពុជា។ ថ្មីៗនេះធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យធនាគារពាណិជ្ជ ដែលមានហិរញ្ញវត្ថុល្អជាមួយនឹងសាច់ប្រាក់លើសលប់ឱ្យវិនិយោគទ្រព្យសកម្មរបស់ពួកគេខ្លះនៅឯបរ-ទេស។ ទ្រព្យសកម្មបរទេសនៃប្រព័ន្ធធនាគារត្រូវបានវិនិយោគនៅឯបរទេស ក្នុងឧបករណ៍ហិរញ្ញវត្ថុសុវត្ថិ-ភាពប៉ុណ្ណោះ ក្រោមការត្រួតពិនិត្យយ៉ាងជិតដិតពីធនាគារជាតិនៃកម្ពុជា។ ដូច្នេះហានិភ័យចំពោះវិបត្តិនេះអាច កើតមានតែតាមរយៈច្រកនៃឥទ្ធិពលលើប្រតិបត្តិការបរទេសរបស់ធនាគារពាណិជ្ជអន្តរជាតិមួយចំនួន ប៉ុណ្ណោះដែលមានមូលដ្ឋាននៅកម្ពុជា។ កន្លងមកមិនមានព័ត៌មានណាមួយ ដែលថាធនាគារមួយបានទទួល រងឥទ្ធិពលជាដំណំពីវិបត្តិកម្ចីការប្រាក់ខ្ពស់នេះទេ។

ប្រព័ន្ធធនាគាររបស់កម្ពុជាមានភាពត្រឹមត្រូវ មានមូលធនល្អ និងលំហូរយ៉ាងល្អនៅមុនពេលវិបត្តិ។ សមាភាគសមល្មមនៃមូលធន (ទ្រព្យសរុបឬទ្រព្យតម្លៃ/ទម្ងន់សរុបយោងទៅតាមកម្រិតហានិភ័យ) គឺ២៦% ក្នុងឆ្នាំ២០០៧ ដែលល្អលើសពីកម្រិតអប្បបរិមារបស់បទបញ្ញាគឺ១៥%។ សមាភាគសាច់ប្រាក់ (ទ្រព្យសាច់ប្រាក់/ទ្រព្យសរុប) គឺ៥០% ក្នុងឆ្នាំ២០០៧។ កម្ចីពិបាកទារ (NPLs) បានធ្លាក់ចុះពី៩.៥% ក្នុងឆ្នាំ២០០៦មកត្រឹម ៣.៤% ក្នុងឆ្នាំ២០០៧ និងបន្តធ្លាក់មកត្រឹម ២.៦% ក្នុងខែមិថុនាឆ្នាំ២០០៨។

បន្ទាប់ពីការចាប់ផ្ដើមនៃវិបត្តិនេះទីផ្សារអចលនទ្រព្យបានធ្លាក់ចុះ ប៉ុន្តែមិនមានសញ្ញានៃការឱ្យខ្ចីមិន សមប្រកប ឬពិបាកណាមួយចំពោះវិស័យពីធនាគារនេះទេ។ តែទោះជាយ៉ាងណា សេដ្ឋកិច្ចធ្លាក់ចុះរបស់ កម្ពុជាបានបន្សាយទៅដល់តារាងតុល្យការរបស់ធនាគារនិងបញ្ឈប់ការឱ្យខ្ចីថ្មីៗ។ ទោះបីធនាគារនៅកម្ពុជា មិនបានទទួលរងនូវទ្រព្យបំពុលនានាពីបរទេសក៏ដោយ ក៏លក្ខខណ្ឌសាច់ប្រាក់បានរឹតបន្តឹងនៅឯពេល ចាប់ផ្ដើមនៃវិបត្តិហិរញ្ញវត្ថុសកល។ ក្នុងឆ្នាំ២០០៨ លំហូរសាច់ប្រាក់បានធ្លាក់ចុះត្រឹម១.៦% ក្នុងខែកញ្ញា៥.៤% ក្នុងខែតុលានិង២.៧% ក្នុងខែវិច្ឆិកា។ ប្រាក់បញ្ញើរូបិយប័ណ្ណបរទេសបានធ្លាក់ចុះ ២.២% ៥.៤% និង៣.៣% ស្របជាមួយខែខាងលើផងដែរ។ តែទោះជាយ៉ាងណាក៏ដោយ ឥណទានចំពោះវិស័យឯកជនបន្តកើនឡើង។ វាកើន ១.៦% ក្នុងខែកញ្ញាឆ្នាំ២០០៨និង១.៧% ក្នុងខែតុលាឆ្នាំ២០០៨ប៉ុន្តែបានធ្លាក់ចុះ០.៦% ក្នុងខែវិច្ឆិកា ឆ្នាំ២០០៨។ ប៉ុន្តែ លំហូរសាច់ប្រាក់បានចាប់ផ្ដើមល្អប្រសើរវិញក្នុងដើមឆ្នាំ២០០៩។ ប្រាក់បញ្ញើរូបិយប័ណ្ណ បរទេស (FCDs) បានកើន២១% នៅ៨ខែដំបូងនៃឆ្នាំ២០០៩ ដែលមួយផ្នែកបណ្ដាលមកពីអត្រាការប្រាក់ បញ្ញើខ្ពស់។ តែទោះជាយ៉ាងណា កំណើនឥណទានបានធ្លាក់ចុះយ៉ាងគំហុកពី ៥៥%ក្នុងឆ្នាំ២០០៨មកត្រឹម៤% ក្នុងខែសីហាឆ្នាំ២០០៩។

វិធានការដើម្បីលើកកម្ពស់ប្រព័ន្ធធនាគាររួមមាន៖

- កំហិតការពាក់ព័ន្ធរបស់ធនាគារពាណិជ្ជកម្មទៅនឹងវិស័យ ដែលមានហានិភ័យខ្ពស់ជាពិសេស វិស័យអចលនទ្រព្យ ដោយដាក់អោយអនុវត្តកំហិតអតិបរមា ១៥% សម្រាប់កម្ចីចំពោះការធ្វើពាណិជ្ជកម្មផ្នែកអចលនទ្រព្យ
- បង្កើនមូលធនអប្បបរមា ពី៥០ពាន់លានរៀល (១៣លានដុល្លារ) ទៅ១៥០ពាន់លានរៀល (៣៦.៥ លានដុល្លារ) សម្រាប់ធនាគារពាណិជ្ជ លើកលែងតែពួកគេមានអត្រាចំណាត់ថ្នាក់វិនិយោគមួយ ពីទីភ្នាក់ងារដាក់ចំណាត់ថ្នាក់ ដែលគេទទួលស្គាល់ថាជាម្ចាស់ភាគហ៊ុនរបស់ធនាគារឬស្ថាប័ន

ហិរញ្ញវត្ថុមួយផ្សេងទៀត និងការបង្កើនមូលធនអប្បបរមាដល់ ៣០ពាន់លានរៀល (៧.៣លានដុល្លារ) សម្រាប់ធនាគារឯកទេស

- កាត់បន្ថយទុនបម្រុងកាតព្វកិច្ចសម្រាប់ធនាគារពាណិជ្ជពី១៦% ទៅ១២% ដើម្បីបង្កើនលំហូរសាច់ប្រាក់នៃប្រព័ន្ធធនាគារ។

វិធានការផ្សេងទៀតដែលស្ថិតក្រោមការពិចារណានោះរួមមានៈ

- លើកកម្ពស់ការចំណាត់ថ្នាក់នៃប្រាក់កម្ចី ដើម្បីពង្រឹងការត្រួតពិនិត្យ និងកំហិតការពាក់ព័ន្ធជាមួយវិស័យដែលមានហានិភ័យ ជាពិសេសកម្ចីដែលលើសពី១០០,០០០ដុល្លារ
- រឹតបន្តឹងតម្លៃនៃវត្ថុបញ្ចាំក្នុងការឱ្យខ្ចីពីធនាគារ
- បន្តពង្រឹងប្រព័ន្ធធនាគារ តាមរយៈការអនុវត្តឱ្យបានខ្លាំងក្លានៃធ្វើអធិការកិច្ចនិងត្រួតពិនិត្យនៅនឹងកន្លែងនិងក្រៅពីកន្លែងធ្វើការ
- ពង្រឹងប្រព័ន្ធព័ត៌មានឥណទានធនាគារ
- ពង្រឹងប្រព័ន្ធសម្រាប់ការអនុវត្តទុនបម្រុងកាតព្វកិច្ច
- ធ្វើសេចក្តីព្រៀងប្រកាសមួយស្តីពីសវនកម្មផ្ទៃក្នុងរបស់ធនាគារ
- ធ្វើសេចក្តីព្រៀងប្រកាសមួយស្តីពីសវនកម្មផ្ទៃក្រៅរបស់ធនាគារ
- ធ្វើសេចក្តីព្រៀងប្រកាសមួយស្តីពីអភិបាលកិច្ចសាជីវកម្មនៃធនាគារនិងស្ថាប័នហិរញ្ញវត្ថុ
- ធ្វើសេចក្តីព្រៀងប្រកាសមួយស្តីពីការដាក់ចំណាត់ថ្នាក់នៃការកម្កល់ធានានៃទ្រព្យសកម្មពីធនាគារនិងស្ថាប័នហិរញ្ញវត្ថុ។

ជំហររូបិយវត្ថុជារួមមានភាពសមស្រប។ ដូច្នេះ អាជ្ញាធររូបិយវត្ថុមិនចាំបាច់កាត់បន្ថយបន្ថែមទៀតនូវទុនបម្រុងកាតព្វកិច្ចឡើយ ប្រសិនបើឈរលើមូលដ្ឋាននៃលក្ខខណ្ឌរូបិយវត្ថុ ឬ ទស្សនវិស័យប្រុងប្រយ័ត្ន។ កំណើនឥណទានត្រូវបានរំពឹងថា នឹងងើបឡើងវិញក្នុងឆ្នាំ២០១០ដល់១៧ភាគរយ (y/y) បើប្រៀបធៀបទៅនិង៣½ភាគរយក្នុងឆ្នាំ២០០៩។

វឌ្ឍនភាពបានបន្តធ្វើឡើងក្នុងការលើកកម្ពស់ការគ្រប់គ្រងលំហូរសាច់ប្រាក់ ប៉ុន្តែការអនុវត្តគោលនយោបាយរូបិយវត្ថុត្រូវបានរំខាន ដោយការខ្វះខាតនូវឧបករណ៍ផ្អែកលើទីផ្សារ សកម្មភាពអន្តរធនាគារចុះខ្សោយ និងកម្រិតខ្ពស់នៃដុល្លារូបនីយកម្ម ដែលរារាំងដល់ការបង្កើតគោលដៅភ្លាមៗនិងកំពុងប្រតិបត្តិការ។ បទបញ្ញាស្តីពីការចេញឧបករណ៍មូលប័ត្រ និងស្តីពីកិច្ចព្រមព្រៀង repo master នោះ ត្រូវគេរំពឹងថានឹងបញ្ចប់ត្រឹមចុងឆ្នាំ២០០៩។ ការចេញនូវឧបករណ៍ផ្អែកលើប្រាក់ដុល្លារថ្មីៗ អាចផ្តល់នូវទ្រព្យបញ្ចាំសម្រាប់កិច្ចការជំនួញប្រាក់រៀលថែមទៀតរវាងធនាគារនិងធនាគារ ហើយជាចុងក្រោយនឹងត្រួសត្រាយផ្លូវសម្រាប់ការធ្វើពាណិជ្ជកម្មមូលប័ត្ររូបិយប័ណ្ណក្នុងស្រុក។

តែទោះជាយ៉ាងណា ការគ្រប់គ្រងរូបិយវត្ថុដ៏មានប្រសិទ្ធភាពត្រូវការជំនឿទុកចិត្ត និងការប្រើប្រាស់ប្រាក់រៀលកាន់តែខ្លាំង ក៏ដូចជាត្រូវការការរៀបចំអត្រាប្តូរប្រាក់ ដែលមានភាពទន់ភ្លន់ជាងមុនមួយផងដែរ។ ដើម្បីសម្រេចគោលដៅនេះធនាគារជាតិនៃកម្ពុជាត្រូវធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តែក្នុងលក្ខខណ្ឌកំណត់ណាមួយ ពោលគឺក្នុងគោលដៅកាត់បន្ថយនូវការឡើងចុះខ្លាំងពេកលើទីផ្សារ ហើយប្រការនេះនឹងជួយការពារទុនបម្រុងបរទេស ពង្រីកនិងពង្រឹងទីផ្សារប្តូរប្រាក់ និងសម្របសម្រួលដល់ការកែតម្រូវផ្នែកខាងក្រៅ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាច់ប្រាក់របស់ធនាគារមានភាពប្រសើរឡើង ក៏ប៉ុន្តែ តារាងតុល្យការរបស់វាបានចុះខ្សោយ។ ហានិភ័យឥណទានបានកើនឡើង ទន្ទឹមនិងកម្ចីពិបាកទារ (NPLs) កំពុងកើនឡើង។ NPLs បានកើនដល់៥¼ ភាគរយនៅខែមិថុនាឆ្នាំ២០០៩ ពី៣¾ភាគរយក្នុងខែធ្នូឆ្នាំ២០០៨។ តារាងតុល្យការដែលចុះខ្សោយ គឺបណ្តាលមកពីការគ្រប់គ្រងហានិភ័យទន់ខ្សោយ ការធ្លោះធ្លោយផ្នែកត្រួតពិនិត្យពីមុននេះ និងកំណើនឥណទានច្រើនជ្រុល ដែលធ្វើឱ្យរឹតតែធ្ងន់ឡើង ដោយការថយចុះកំណើន និងការដួលរលំនៃតម្លៃទ្រព្យសកម្ម។ ការកើនឡើងនៃការប្រាក់អវិជ្ជមាន និងតម្រូវការទាបសម្រាប់ឥណទានកំពុងកាត់បន្ថយប្រាក់ចំណូល ដែលធ្វើឱ្យមានការពិបាកសម្រាប់ធនាគារ ដែលចង់ងើបចេញឱ្យផុតពីបញ្ហាទាំងនេះ។

ធនាគារជាតិនៃកម្ពុជាបានអនុមតិលើវិធានការ ដើម្បីដោះស្រាយជាមួយធនាគារដែលមានបញ្ហា។ ចាប់តាំងពីឆ្នាំ២០០៩ ធនាគារជាតិនៃកម្ពុជាបានអនុវត្តការធ្វើអធិការកិច្ចនៅនឹងកន្លែង ទៅតាមអាទិ-ភាព ហើយចេញលិខិតត្រួតពិនិត្យដល់ធនាគារដែលមិនប្រតិបត្តិតាមវិធាន និងរៀបចំផែនការសកម្មភាពដ៏ត្រឹមត្រូវ ដើម្បីដោះស្រាយនូវឱនភាពហិរញ្ញវត្ថុនិងប្រតិបត្តិការមួយចំនួន។ វិធានការទាំងនេះមានគោលដៅតម្រូវឱ្យធនាគារពាណិជ្ជអនុវត្តឱ្យបានខ្ជាប់ខ្ជួន នូវតម្រូវការមូលធនអប្បបរមាថ្មីៗមុនកាលកំណត់នៅចុងឆ្នាំ២០១០។ សកម្មភាពជាមួយភាគីពាក់ព័ន្ធរបស់ធនាគារកំពុងត្រូវបានត្រួតពិនិត្យច្រើនថែមទៀត ហើយអភិបាលកិច្ចផ្ទៃក្នុងកំពុងត្រូវបានពង្រឹង តាមរយៈការបង្កើតគណៈកម្មាធិការឥណទាន និងការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ។ ការអនុវត្តយ៉ាងហ្មឹងម៉ាត់នូវចំណាត់ថ្នាក់កម្ចី ដែលទើបនឹងត្រូវបានអនុមតិនេះ ស្តង់ដារសំវិធានធន និងការទទួលស្គាល់នូវការខាតបង់កម្ចី ការអនុវត្តផែនការសកម្មភាពដើម្បីកែលម្អ និងការរៀបចំនូវក្របខ័ណ្ឌដើម្បីស្តារឡើងវិញនូវធនាគារពាណិជ្ជដ៏គ្រប់ជ្រុងជ្រោយ មានសារៈសំខាន់ខ្លាំងណាស់ ចំពោះការធានានូវសុខភាពនៃប្រព័ន្ធធនាគារ។

### ៣.៧.៩.២. ផលប៉ះពាល់ប្រយោលលើការនាំចេញសម្លៀកបំពាក់

*គំនូសតាង៣.២២. ការនាំចេញវាយនភ័ណ្ឌ៖ ឆ្នាំ២០០៨ទល់នឹងឆ្នាំ២០០៩ (គិតជាលានដុល្លារអាមេរិក)*




*ប្រភព៖ នាយកដ្ឋានគយនិងរដ្ឋាករ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅពេលដែលជួបវិបត្តិ អ្នកប្រើប្រាស់នឹងកាត់បន្ថយនូវការប្រើប្រាស់ ហើយបង្កើនការសន្សំប្រាក់ដើម្បីត្រៀមលក្ខណៈសម្រាប់ពេលវេលាលំបាកនៅពេលខាងមុខ។ការធ្លាក់ចុះនៃការប្រើប្រាស់នឹងជះឥទ្ធិពលទៅលើការនាំចូលពីប្រទេសទីបី ហើយជាលទ្ធផល នឹងនាំទៅរកការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ច។កម្ពុជានាំចេញប្រមាណជា៧០% នៃផលិតផលសម្លៀកបំពាក់របស់ខ្លួន ទៅកាន់សហរដ្ឋអាមេរិក ដែលមានសេដ្ឋកិច្ចធ្លាក់ចុះ។ តែទោះជាយ៉ាងណា អ្នកប្រើប្រាស់អាមេរិកអាចប្តូរពីទំនិញប្រណិត ទៅប្រើប្រាស់ជំនួសនូវទំនិញដែលមានថ្លៃថោក ដូចជាសម្លៀកបំពាក់ផលិតដោយកម្ពុជា។ ជាការពិតណាស់ រហូតទាល់តែសេដ្ឋកិច្ចនៃសហរដ្ឋអាមេរិកនិងអឺរ៉ុបងើបឡើងវិញ ទស្សនវិស័យនៃការវិលត្រលប់មកវិញនូវកំណើនដ៏ខ្ពស់ ក្នុងការនាំចេញសម្លៀកបំពាក់នៅមានការស្រពេចស្រពិលនៅឡើយ។

អំឡុងពេល៩ខែដំបូងនៃឆ្នាំ២០០៩ ការនាំចេញសម្លៀកបំពាក់ក្រោមកម្មវិធី GSP/MFN បានធ្លាក់ចុះ ១៧.៩% ទៅដល់ ១.៩ពាន់លានដុល្លារអាមេរិក ជាចម្បង ដោយសារតែការធ្លាក់ចុះជាខ្លាំងក្នុងការនាំចេញសម្លៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក (-២៦.១%)។ ការនាំចេញសម្លៀកបំពាក់ទៅកាន់សហភាពអឺរ៉ុបបានធ្លាក់ចុះត្រឹមតែ៥.៣% ខណៈពេលដែលការនាំចេញទៅកាន់ប្រទេសជប៉ុនបានកើនឡើង៥១.៦%។ ចំនួនកម្មករកាត់ដេរបានធ្លាក់ចុះពី ៣៥១,៣៤០នាក់ក្នុងខែមករាឆ្នាំ២០០៨ មកត្រឹម២៧៨,៣៩៨កម្មករនៅក្នុងខែតុលាឆ្នាំ២០០៩ ហើយកម្មករចំនួន ៩២,៩៤២នាក់ត្រូវបានគេបញ្ឈប់ពីការងារ។ នៅពេលជាមួយគ្នានេះ ចំនួនរោងចក្របានធ្លាក់ចុះពី ២៩៣ មកនៅត្រឹម ២៤៣។

## ៣.៧.៩.៣. ផលប៉ះពាល់ប្រយោលលើទេសចរណ៍

ទេសចរនឹងពន្យារមិនធ្វើវិស្សមកាលនៅពេលជួបការលំបាក។ ការបាត់បង់ការងារនិងទស្សនវិស័យស្រពេចស្រពិលប្រាកដជាមិនអំណោយផលសម្រាប់វិស្សមកាលទេ។ តែទោះជាយ៉ាងណា ចំនួនភ្ញៀវទេសចរដែលមកទស្សនាកម្ពុជាក្នុងឆ្នាំ២០០៨បានកើនលើសឆ្នាំ២០០៧ចំនួន៥%។ ក៏ប៉ុន្តែ នៅក្នុងត្រីមាសទីបួននៃឆ្នាំ២០០៨ ចំនួនភ្ញៀវទេសចរបានធ្លាក់ចុះប្រហែល៥% បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០៧។ នៅក្នុងឆ្នាំ២០០៩ កម្ពុជារងផលប៉ះពាល់ពេញទំហឹងនៃការធ្លាក់ចុះវិស័យទេសចរណ៍ ។

*គំនូសតាង៣.២៣.ការមកដល់នៃភ្ញៀវទេសចរនៅកម្ពុជា៖ ឆ្នាំ២០០៨ទល់នឹងឆ្នាំ២០០៩*




*ប្រភព៖ ក្រសួងទេសចរណ៍*

ទោះបីចំនួនសរុបនៃភ្ញៀវទេសចរបានកើនឡើង ២% ហើយសម្រេចបាន ១.៥៧លាននាក់ អំឡុងពេល៩ខែដើមឆ្នាំ ២០០៨ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០០៧ ជាពិសេសដោយសារ តែកំណើនភ្ញៀវទេសចរដែលធ្វើដំណើរតាមផ្លូវគោក ពីប្រទេសក្នុងតំបន់នោះ ភ្ញៀវទេសចរកម្រិតខ្ពស់ដែលមកពីទ្វីបអឺរ៉ុបនិងអាមេរិកបានធ្លាក់ចុះជាខ្លាំងជាមួយនឹងការកាត់បន្ថយនូវចំនួនភ្ញៀវដែលធ្វើដំណើរតាមយន្តហោះចំនួន ១២.៩៦% ក្នុង៩ខែដំបូង ដែលឆ្លុះបញ្ចាំងពីផលប៉ះពាល់អវិជ្ជមាននៃវិបត្តិហិរញ្ញវត្ថុ ដែលប៉ះពាល់ជាសំខាន់ទៅលើសណ្ឋាគារកម្រិតខ្ពស់។ ចំណូលពីការទស្សនាប្រាសាទអង្គរវត្តសម្រេចបានទាបជាងឆ្នាំ២០០៨ ៣០%។

### ៣.៧.៩.៤. ផលប៉ះពាល់ប្រយោលលើសំណង់

វិស័យអចលនវត្ថុនៅកម្ពុជានៅនឹងថ្កល់ចាប់តាំងពីខែមិថុនា ឆ្នាំ២០០៨ មកម្ល៉េះ។ គោលនយោបាយរបស់ធនាគាជាតិក្នុងការកំហិតធនាគារកុំឱ្យផ្តល់ឥណទានច្រើនពេក សម្រាប់ទីផ្សារអចលនវត្ថុធ្វើឱ្យសីគុណ្ណភាពនៃទីផ្សារអចលនវត្ថុត្រជាក់បន្តិច និងការពារវិបត្តិមិនឱ្យផ្ទុះឡើង។ មួយវិញទៀត វិនិយោគិនមានការប្រយ័ត្នប្រយែង ដោយសារតែមានវិបត្តិអចលនវត្ថុយ៉ាងពេញទំហឹងនៅសហរដ្ឋអាមេរិក និងនៅវៀតណាម។ តែទោះជាយ៉ាងណា មិនមានសញ្ញាណាមួយដែលបង្ហាញថា ធនាគារបានឱ្យប្រាក់ខ្ចីដោយធ្វេសប្រហែសទៅឱ្យទីផ្សារអចលនទ្រព្យឡើយ។ សកម្មភាពសំណង់នៅតែបន្តធ្លាក់ចុះក្នុងឆ្នាំ២០០៩ ដោយឆ្លុះបញ្ចាំងពីការធ្លាក់ចុះនៃលំហូរវិនិយោគទុនបរទេស និងការឱ្យខ្ចីប្រាក់ពីធនាគារ ដែលប្រុងប្រយ័ត្ន។

គម្រោងការស្ថាបនាទីក្រុងរណបថ្មីៗ តំបន់សេដ្ឋកិច្ចពិសេស និងគម្រោងអភិវឌ្ឍន៍វិស័យទេសចរណ៍មួយចំនួន ដូចជាគម្រោងអភិវឌ្ឍន៍កោះពស់ គម្រោងទីក្រុងកាំកូ គម្រោងអភិវឌ្ឍន៍បឹងស្នោ និងគម្រោងទីក្រុងសាន់វេជាដើម ស្ថិតក្នុងភាពជាប់គាំង។ យ៉ាងណាមិញ អ្នកអភិវឌ្ឍន៍វិស័យអចលនទ្រព្យខ្លះនៅតែបន្តគម្រោងរបស់ខ្លួន ទោះបីជាត្រូវបោះជំហានយឺតជាងមុន ហើយត្រូវកាត់បន្ថយទ្រង់ទ្រាយនៃគម្រោងក៏ដោយ។ ការថយចុះនៃគម្រោងដែលវិនិយោគដោយឯកជននេះ ត្រូវបានប៉ះប៉ូវដោយការកើនឡើងនៃការអនុវត្តគម្រោងសាធារណៈ ដូចជាការស្ថាបនាស្ពាន និងផ្លូវថ្នល់។ ក្នុងឆ្នាំ២០០៩ សកម្មភាពសាងសង់ត្រូវបានប៉ាន់ស្មាននៅកម្រិត -២.៦%។

## ៣.៧.១០. ឧស្សាហ៍វិស័យសម្រាប់ឆ្នាំ២០០៩-២០១០

វិបត្តិសេដ្ឋកិច្ចពិភពលោកកំពុងជះឥទ្ធិពលមកដល់សេដ្ឋកិច្ចនៃប្រទេសកម្ពុជា ជាមួយនឹងកំណើនក្នុងឆ្នាំ២០០៩ ត្រូវបានធ្វើចំណោលនៅក្នុងចន្លោះ0% និង -១% (IMF ព្យាករណ៍ -២¾ភាគរយ)។ កត្តានាំមុខបីក្នុងចំណោមកត្តាជំរុញសំខាន់ៗបួននៃកំណើនពោលគឺ ឧស្សាហកម្មកាត់ដេរ ទេសចរណ៍ និងសំណង់បានបង្ហាញពីការធ្លាក់ចុះ ហើយវិស័យទាំងនេះចុះទាបដល់បាត ចាប់ពីពាក់កណ្តាលឆ្នាំ ២០០៩។ ការវិនិយោគឯកជនក៏ទទួលរងនូវវិបត្តិនេះដែរ។ កម្មកររោងចក្រកាត់ដេរចំនួន៥០,០០០នាក់បាត់បង់ការងារ។

កំណើនបានកើនឡើងដល់ ៦ ភាគរយក្នុងឆ្នាំ២០១០។ សកម្មភាពដែលទាក់ទងនឹងការនាំចេញគឺជាវិស័យងាយរងគ្រោះ ដោយសារមូលដ្ឋានផលិតកម្មរបស់កម្ពុជានៅតូច ហើយផ្តោតជាសំខាន់លើវិស័យកាត់ដេរសម្លៀកបំពាក់សម្រាប់ទីផ្សារសហរដ្ឋអាមេរិក។ ដោយពាណិជ្ជកម្មលក់រាយនៅសហរដ្ឋអាមេរិកនៅមានភាពមិនច្បាស់លាស់ ធ្វើឱ្យទស្សនវិស័យនៃកំណើនសេដ្ឋកិច្ចនៅកម្ពុជានៅមិនទាន់ជាក់លាក់នៅឡើយ។ ម្យ៉ាងវិញទៀត ផលិតភាពក្នុងវិស័យកសិកម្មដែលចេះតែកើនឡើង អាចធ្វើឱ្យសម្រេចបាននូវកំណើនខ្ពស់ជាងមុន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងរយៈពេលមធ្យម កម្ពុជាអាចនឹងសម្រេចបាននូវកំណើនសមល្មម ក្នុងរង្វង់ ៨-៩% ក្នុងមួយឆ្នាំ។

*ហានិភ័យអវិជ្ជមានសំខាន់ៗពីរបានគំរាមកំហែងដល់ទស្សនវិស័យសេដ្ឋកិច្ចរបស់កម្ពុជា៖*

- ភាពមិនប្រាកដប្រជាទាក់ទងទៅនឹងផលប៉ះពាល់លើសេដ្ឋកិច្ចនៃវិបត្តិសេដ្ឋកិច្ចពិភពលោក ទៅលើការនាំចេញសម្លៀកបំពាក់និងការឆ្លងរាលដាលទៅលើវិស័យទេសចរណ៍។ និង
- ល្បឿននៃការងើបឡើងវិញផ្នែកសេដ្ឋកិច្ចក្នុងប្រទេសជឿនលឿនទាំងឡាយ។

ការបង្កើនល្បឿននៃកំណើនសេដ្ឋកិច្ច គឺជាការសំខាន់ណាស់សម្រាប់ការលើកស្ទួយសូចនាករ ខាងផ្នែកសង្គមនិងការពង្រីកមូលដ្ឋានយកពន្ធ ដើម្បីបង្កើតប្រាក់ចំណូលឱ្យបានគ្រប់គ្រាន់ ក្នុងគោលដៅបង្កើនចំណាយសម្រាប់វិស័យសង្គម។ កំណើននឹងសម្រេចបាន ដោយសារការធ្វើពិពិធកម្មនៃប្រភពផលិតកម្មនិងការបង្កើនការវិនិយោគក្នុងវិស័យកម្មន្តសាលថ្មីៗ វិស័យកសិឧស្សាហកម្ម និងការអភិវឌ្ឍវិស័យទេសចរណ៍ ដែលជាវិស័យគន្លឹះ ក្នុងការលើកស្ទួយសកម្មភាពសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត។

ការជំរុញល្បឿននៃកំណើនសេដ្ឋកិច្ចជនបទនឹងមានឥទ្ធិពលដោយផ្ទាល់ ទៅលើការកាត់បន្ថយភាពក្រីក្រ។ រាជរដ្ឋាភិបាលនឹងពង្រឹង និងពង្រីកសក្តានុពលនៃវិស័យកសិកម្ម ដើម្បីបង្កើតការងារ និងបង្កើនប្រាក់ចំណូលក្នុងតំបន់ជនបទ តាមរយៈការបង្កើនការវិនិយោគក្នុងការសាងសង់ប្រព័ន្ធធារាសាស្ត្រ និងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មឱ្យបានដល់ប្រជាកសិករគ្រប់ៗរូប។

រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តខ្ពស់ ក្នុងការធានាបាននូវបរិស្ថានម៉ាក្រូសេដ្ឋកិច្ចដែលមានស្ថេរភាព។ គោលដៅរយៈពេលមធ្យមនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរួមមាន៖ សម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងកម្រិត ៦-៧% រក្សាអត្រាអតិផរណាក្រោម៥% កំណត់បំណុលបរទេសក្នុងកម្រិតមួយដែលសមស្របជាមួយលំហូរនៃការផ្តល់ហិរញ្ញប្បទាន និងការវិនិយោគផ្ទាល់ពីបរទេស និងបង្កើនទុនបម្រុងអន្តរជាតិដុលក្នុងកម្រិតមួយ ដែលអាចធានាការនាំចូលចំនួន ៣ខែ។

## ៣.៨. សេចក្តីសន្និដ្ឋាន

យោងទៅតាមសេនារីយ៉ូមូលដ្ឋានរបស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងកើនឡើងនៅអត្រាទាបបន្តិចប្រមាណ៨-៩%ក្នុងមួយឆ្នាំ នៅប៉ុន្មានឆ្នាំខាងមុខនេះ។ ប៉ុន្តែកំណើននេះនឹងបង្កើនល្បឿនលឿនជាងមុន បន្ទាប់ពីកម្ពុជាចាប់ផ្តើមផលិតប្រេងនាពេលអនាគត។ ផ្នែកសំខាន់មួយនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងទៅនេះ គឺដោយសាររាជរដ្ឋាភិបាលខិតខំប្រឹងប្រែងដាក់ចេញនូវវិធានការគោលនយោបាយ ក្នុងគោលដៅតាមឱ្យទាន់ប្រទេសក្នុងតំបន់ ដោយសារកម្ពុជាជាប្រទេសដែលបាត់បង់កាលានុវត្តិភាពក្នុងការអភិវឌ្ឍអស់រយៈពេលជាងបីទសវត្សរ៍នេះ ដោយសារសង្គ្រាម។ នាពេលអនាគត កម្ពុជាត្រូវប្រឈមមុខនឹងការប្រកួតប្រជែងដ៏ស្វិតស្វាញពីសកលភាវូបនីយកម្ម នោះថ្លៃដើមផលិតខ្ពស់ ដែលបណ្តាលមកពីថ្លៃដឹកជញ្ជូននិងថ្លៃថាមពលខ្ពស់នោះ ក៏នឹងក្លាយជាឧបសគ្គចម្បងផងដែរ។ ជាលទ្ធផលនៃឥទ្ធិពលទាំងនេះ កម្ពុជាត្រូវអនុវត្តនូវវិធានការកំណើនក្នុងវិស័យឈានមុខទាំងនេះ ដើម្បីរក្សានូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព។ ក្នុងរយៈពេលខ្លីខាងមុខ សេដ្ឋកិច្ចកម្ពុជានឹងបន្តពឹងផ្អែក

លើវិស័យកសិកម្ម វិស័យទេសចរណ៍ ឧស្សាហកម្មកាត់ដេរ និងសំណង់ ដែលជាវិស័យយុទ្ធសាស្ត្ររបស់កម្ពុជា ក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ច។

តែទោះជាយ៉ាងណាក្តី ក្នុងរយៈពេលមធ្យមនិងក្នុងរយៈពេលវែង កម្ពុជាត្រូវធ្វើពិពិធកម្មនៃប្រភពកំណើនរបស់ខ្លួន ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងអត្រា ៧% ក្នុងមួយឆ្នាំ។ កំណែទម្រង់ក្នុងការលើកកម្ពស់វិនិយោគទុនពីបរទេស និងការបង្កើតនូវបរិស្ថានអនុគ្រោះសម្រាប់វិស័យឯកជន គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន ក្នុងការបង្កើតវិស័យសេដ្ឋកិច្ចថ្មីក្រៅពីឧស្សាហកម្មកាត់ដេរនិងទេសចរណ៍ ជាអាទិ៍វិស័យអេឡិចត្រូនិច បច្ចេកវិទ្យាព័ត៌មាន វិស្វកម្ម កម្មន្តសាល កសិឧស្សាហកម្ម ដែលនឹងរួមចំណែកកាន់តែខ្លាំងឡើងក្នុងការទ្រទ្រង់កំណើន។ វិស័យកសិកម្មក៏នឹងត្រូវបានលើកកម្ពស់ តាមរយៈការអនុវត្តកំណែទម្រង់ស៊ីជម្រៅរួមទាំងកំណែទម្រង់ការគ្រប់គ្រងដីធ្លី និងការបង្កើនការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធជនបទ។ ឱនភាពគណនីចរន្តក្នុងជញ្ជីងទូទាត់នឹងកាត់បន្ថយ ក្នុងរយៈកាលមធ្យម។ អតិផរណានឹងធ្លាក់ចុះដល់កម្រិតប្រមាន ៣% ក្នុងរយៈពេលមធ្យម។

**ការបង្កើនល្បឿនកំណើនសេដ្ឋកិច្ចជនបទ នឹងមានឥទ្ធិពលពិតៗ ទៅលើការកាត់បន្ថយភាពក្រីក្រ។** ទិដ្ឋភាពសំខាន់មួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរបស់ប្រទេសកម្ពុជាគឺការតម្រង់ទិសនៃការវិនិយោគសាធារណៈកាន់តែច្រើន ទៅលើប្រព័ន្ធធារាសាស្ត្រ និងការបង្កើនថវិកាសម្រាប់សេវាផ្សព្វផ្សាយកសិកម្ម។ រាជរដ្ឋាភិបាលនឹងបន្តបង្កើនចំណាយថវិកាសម្រាប់វិស័យកសិកម្ម ក្នុងគោលដៅទ្រទ្រង់វិស័យនេះ ឱ្យមានសក្តានុពលខ្ពស់ ក្នុងរយៈពេលមធ្យម។ ការបន្តគោលនយោបាយបង្កើនកំណើនសេដ្ឋកិច្ចជនបទ គឺជាកត្តាគន្លឹះក្នុងការកាត់បន្ថយភាពក្រីក្រ។

ការសម្លឹងទៅថ្ងៃអនាគតដើម្បីទ្រទ្រង់ការរីកចម្រើនដែលមានជាងមួយទសវត្សរ៍កន្លងទៅ កម្ពុជាត្រូវអនុវត្តវិធានការថ្មីៗថែមទៀត ដើម្បីកាត់បន្ថយវិសមភាពក្នុងសង្គម។ យុទ្ធសាស្ត្រចតុកោណមានគោលដៅកាត់បន្ថយគម្លាតដែលចេះតែកើនឡើង រវាងអ្នកមាននិងអ្នកក្រ តាមរយៈការអភិវឌ្ឍជនបទ។ ក្នុងន័យនេះ ក្នុងអាណត្តិទីបួនរបស់ខ្លួន រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការលើកស្ទួយ និងការពង្រឹងការអនុវត្តនូវគោលនយោបាយកំណើន ដែលគាំទ្រដល់អ្នកក្រីក្រ ។ នៅក្នុងទំនាក់ទំនងនេះ អភិក្រមខាងក្រោមនឹងត្រូវបានអនុវត្តបន្តយ៉ាងសកម្ម។

ការបង្កើនចំណងទំនាក់ទំនង រវាងតំបន់ជនបទនិងទីក្រុងនឹងកាត់បន្ថយវិសមភាពជនបទ-ទីក្រុង។ ភាពរុងរឿងនៅទីក្រុងបានបង្ហាញពីការមានឥទ្ធិពលបន្តដែលមានកម្រិត ទៅលើតំបន់ជនបទ ដោយបង្ហាញពីការតភ្ជាប់រវាងជនបទនិងទីក្រុងចុះខ្សោយ និងចំណងទំនាក់ទំនងថយចុះរវាងវិស័យជនបទនិងទីក្រុង។ ជាងនេះទៅទៀត ទំនាក់ទំនងជាវិជ្ជមានរវាងអត្រាភាពក្រីក្រ និងភាពដាច់ស្រយាល ចង្អុលបង្ហាញយ៉ាងថាអ្នកក្រីក្រនៅតំបន់ជនបទ មិនមានឱកាសគ្រប់គ្រាន់ក្នុងការទទួលបាននូវហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងសេវាសាធារណៈទេ ដូចជាផ្លូវថ្នល់ ការអប់រំសេវាសុខភាព និងទីផ្សារជនបទ។

ការផ្លាស់ប្តូរគោលនយោបាយ ដែលសំដៅបង្កើនកំណើនសេដ្ឋកិច្ចជនបទ នឹងមានឥទ្ធិពលដោយផ្ទាល់មួយ ទៅលើវិសមភាពនិងការកាត់បន្ថយភាពក្រីក្រ។ ទិដ្ឋភាពសំខាន់មួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរបស់កម្ពុជា គឺការតម្រង់ទិសការវិនិយោគសាធារណៈកាន់តែច្រើនទៅលើប្រព័ន្ធធារាសាស្ត្រ និងការបង្កើនថវិកាសម្រាប់លើកកម្ពស់គុណភាពសេវាកម្មសាធារណៈនៅជនបទ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**កាត់បន្ថយភាពងាយរងគ្រោះនៃការក្លាយជាអ្នកក្រ** - អ្នកមធ្យមដែលស្ថិតលើបន្ទាត់នៃភាពក្រីក្រតែបន្តិចបន្តួច អាចនឹងធ្លាក់ទៅក្រោមបន្ទាត់នៃភាពក្រីក្រ នៅពេលដែលពួកគេជួបប្រទះនឹងបញ្ហាប្រឈមផ្សេងៗ។ ដោយឡែកនៅតំបន់ជនបទ កសិករក្រីក្រអាចនឹងបង្ខំចិត្តលក់ទ្រព្យសម្បត្តិរបស់ខ្លួន រួមមានដីធ្លី នៅពេលដែលពួកគេត្រូវការចំណាយដោះទ័លខាងផ្នែកសុខភាព និងដោះស្រាយបញ្ហាផ្សេងៗទៀត។ រាជរដ្ឋាភិបាលនឹងពិនិត្យមើលលទ្ធភាព ក្នុងការបង្កើតសេវាធានារ៉ាប់រងសុខភាពសង្គម និងបណ្តាញសុវត្ថិភាពសង្គម ជាពិសេសសម្រាប់ជនដែលងាយរងគ្រោះជាងគេ។

**ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដែលមានសុវត្ថិភាព**- ភាពជាម្ចាស់កម្មសិទ្ធិដីធ្លី គឺជាមូលដ្ឋាននៃទ្រព្យសម្បត្តិ ជាពិសេសនៅក្នុងសង្គមកសិកម្មមួយដូចជាប្រទេសកម្ពុជា៖ គំរូនៃភាពជាម្ចាស់កម្មសិទ្ធិដីធ្លីនឹងក្លាយជាការសាកល្បងមួយ ដើម្បីពិនិត្យឱ្យឃើញថាកម្ពុជាដើរតាមវិថីនៃកំណើនប្រកបដោយបរិយាប័ន្ន និងមានការចែករំលែក បើពុំនោះសោតទេនឹងមានគម្លាតដែលចេះតែកើនឡើងរវាងអ្នកមាននិងអ្នកក្រ។ គោលនយោបាយនេះគឺត្រូវផ្តោតលើការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីមានសុវត្ថិភាព តាមរយៈការបង្កើនល្បឿន និងការពង្រីកការចេញប័ណ្ណកម្មសិទ្ធិ ទៅឱ្យតំបន់ដែលក្រីក្រនិងដាច់ស្រយាល កន្លែងដែលជម្លោះដីធ្លីធ្ងន់ធ្ងរខ្លាំង ក្នុងគោលដៅបង្កលក្ខណៈឱ្យគ្រួសារក្រីក្រដែលគ្មានដី ទទួលបានដីដែលទុកទំនេរ។

**ពង្រីកមូលដ្ឋានកំណើនសេដ្ឋកិច្ច**- ភាពពឹងផ្អែកផ្នែកសេដ្ឋកិច្ចដ៏សំខាន់ទៅលើឧស្សាហកម្មកាត់ដេរបានដាក់ជាហានិភ័យខ្ពស់មួយដល់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច។ ប្រសិនបើកំណើននៃការនាំចេញសម្លៀកបំពាក់ត្រូវរអាក់រអួល ដោយសារតែកត្តាខាងក្រៅ នោះដូចជាក្រោមវិបត្តិសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្ននឹងមានការបាត់បង់ការងារដ៏ច្រើនក្នុងសេដ្ឋកិច្ច។ វាអាចជាការរំខានផ្នែកសង្គម ពីព្រោះកម្មករកាត់ដេរផ្ញើរប្រាក់កម្រៃរបស់ខ្លួនមួយភាគធំទៅដល់គ្រួសាររបស់ខ្លួននៅតំបន់ជនបទ ដើម្បីបំពេញបន្ថែមប្រាក់ចំណូលបានពីការធ្វើស្រែចម្ការ។ ការបាត់បង់ជាសក្តានុពលនៃទីផ្សារទៅឱ្យប្រទេសប្រកួតប្រជែងជាងខ្លួននោះនឹងធ្វើឱ្យកម្ពុជាជួបការលំបាកនាពេលអនាគត។ ដូច្នេះ កម្ពុជាត្រូវធ្វើពិពិធកម្មនៃវិស័យឧស្សាហកម្មជាបន្ទាន់។ រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវវិធានការច្រើនថែមទៀត ដើម្បីពង្រឹងឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជា ដោយកាត់បន្ថយថ្លៃដើមសេដ្ឋកិច្ចនានា រួមទាំងសេវាកំពង់ផែនិងការដឹកជញ្ជូនផ្សេងៗទៀត ថ្លៃអគ្គិសនី និងជាពិសេស ត្រូវកាត់បន្ថយចំណាយក្រៅផ្លូវការ ដែលមានកម្រិតខ្ពស់នៅកម្ពុជា។

**ការពង្រឹងសមត្ថភាពរបស់ប្រទេសកម្ពុជាក្នុងបរិស្ថានក្រោយវិបត្តិ**- ការត្រឡប់មកវិញនូវកំណើនខ្ពស់ តម្រូវឱ្យមានវិធានការរួបរួមគ្នា សំដៅពង្រឹងការប្រកួតប្រជែង និងការលើកកម្ពស់ បរិយាកាសធុរៈកិច្ច ក្នុងគោលដៅធ្វើពិពិធកម្មនៃមូលដ្ឋានផលិតកម្ម។ កិច្ចប្រឹងប្រែងឆ្ពោះទៅការគោរពឱ្យបានពេញលេញនូវគោលការណ៍នៃអង្គការពាណិជ្ជកម្មពិភពលោកនឹងកាត់បន្ថយថ្លៃដើមធុរៈកិច្ច។ តែទោះជាយ៉ាងណាកម្ពុជាត្រូវអនុមតិនិងធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានជាច្រើន។ ការអនុវត្តសវនកម្មក្រោយការត្រួតពិនិត្យ ការធ្វើឱ្យសាមញ្ញនូវនីតិវិធីគយក្នុងការវាយតម្លៃ និងយកទំនិញចេញបានកាត់បន្ថយពេលវេលាដែលត្រូវការសម្រាប់ការត្រួតពិនិត្យគយ។ កំណែទម្រង់នានាគួរសំដៅចំពោះការលើកកម្ពស់ហេដ្ឋរចនាសម្ព័ន្ធមូលដ្ឋាន និងការលើកស្ទួយជំនាញរបស់ពលករកម្ពុជា ក៏ដូចជាការពង្រីកទីផ្សារក្រៅប្រទេស តាមរយៈការប្តេជ្ញាចិត្តនិងការកាត់បន្ថយថ្លៃដើមធុរៈកិច្ច រួមមានការបង្កើនប្រសិទ្ធភាពក្នុងការអនុមតិគម្រោងវិនិយោគ និងការកាត់បន្ថយនីតិវិធីគយ។

កម្ពុជាមិនត្រូវនៅស្ងៀម ហើយពេញចិត្តនឹងសមិទ្ធផលដែលសម្រេចបានឡើយ។ កម្ពុជាត្រូវបន្តពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចឱ្យបានល្អ ជាពិសេសអនុវត្តដោយប្រុងប្រយ័ត្ន នូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងរូបិយវត្ថុ អនុវត្តនូវយុទ្ធសាស្ត្រកំណើនសម្លឹងទៅមុខមួយ ដោយផ្តាតលើការ ពង្រឹងការប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ។ ការលើកកម្ពស់គុណភាពស្ថាប័នសាធារណៈ និងកម្មវិធីវិនិយោគសាធារណៈ តាមរយៈការអនុវត្តដ៏ស្វាហាប់នៃកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់អភិបាលកិច្ចដូចជាការលើកកម្ពស់ប្រព័ន្ធតុលាការនោះ គឺជាផ្នែកអាទិភាពនៃរបៀបវារៈគោលនយោបាយរបស់រាជ-រដ្ឋាភិបាល។ កម្ពុជាគាំទ្រនូវការប្រកួតប្រជែងក្នុងក្របខ័ណ្ឌនៃសកលភាវូបនីយកម្ម និងសមាហរណកម្មអាស៊ាន។ ផ្លូវឆ្ពោះទៅមុខសម្រាប់កម្ពុជា គឺការធ្វើសមាហរណកម្មខ្លួនឯងកាន់តែខ្លាំងថែមទៀត ជាមួយសេដ្ឋកិច្ចអន្តរជាតិ។ កម្ពុជាកំពុងស្វែងរកដៃគូច្រើនថែមទៀតក្នុងការអភិវឌ្ឍ ដែលនឹងព្រួតដៃជាមួយខ្លួនដើម្បីទាញប្រទេសនេះឱ្យចេញពីភាពក្រីក្រនិងភាពអន់ថយ។

រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការអនុវត្តយ៉ាងមធ្យ័តនូវគោលនយោបាយរូបិយវត្ថុ និងគោលនយាបាយហិរញ្ញវត្ថុសាធារណៈ ជាពិសេស កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅកែលម្អគុណភាពសេវាសាធារណៈ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចនឹងផ្តោតផងដែរ ទៅលើការពង្រឹងឧត្តមភាពប្រៀបធៀប និងភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងគោលដៅវាតទីដណ្តើមយកទីផ្សារថ្មីៗទៀត សម្រាប់ផលិតផលកម្ពុជា។ ប្រការនេះទាមទារឱ្យមានការលើកទឹកចិត្តក្នុងការទាក់ទាញការវិនិយោគក្នុងវិស័យផលិតកម្មថ្មីៗ ការគាំទ្រវិស័យកសិកម្មនិងកសិឧស្សាហកម្ម និងការអភិវឌ្ឍហេរដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គម និងរូបវន្ត ជាពិសេស ការបង្កើតឱ្យបានច្រើននូវតំបន់សេដ្ឋកិច្ចកិច្ចពិសេស និងតំបន់ទេសចរណ៍ថ្មីៗ ដែលនឹងមានឥទ្ធិពលទ្វេដងដ៏សំខាន់ ទៅលើវិស័យសេដ្ឋកិច្ចផ្សេងទៀត

**ការបង្កើតការងារនឹងក្លាយជាអាទិភាពខ្ពស់** - តួនាទីជាចម្បងនៃវិស័យកសិកម្មជាប្រភពនៃការបង្កើតការងារថ្មីៗបានថយចុះ។ នាពេលបច្ចុប្បន្ន ឧស្សាហកម្មកាត់ដេរបានក្លាជាប្រភពមួយដ៏សំខាន់ក្នុងការបង្កើតការងារថ្មីៗ និងបង្កើនប្រាក់ចំណូលរបស់ប្រជាជន។ តែទោះជាយ៉ាងណាក៏ដោយ ការពង្រីកដ៏ឆាប់រហ័សនៃការងារក្នុងវិស័យកម្មន្តសាល មិនអាចឆ្លើយតបបានគ្រប់គ្រាន់ទៅនឹងការស្រូបយកការងារដែលកំពុងថយចុះក្នុងវិស័យកសិកម្មទេ។ដូច្នេះការអភិវឌ្ឍផ្នែកកសិឧស្សាហកម្មនឹងអាចធ្វើឱ្យតួនាទីនៃវិស័យកសិកម្មរស់ឡើងវិញបាន ដែលជាកត្តារួមចំណែកដ៏សំខាន់មួយ ចំពោះការងារនិងការបង្កើតប្រាក់ចំណូល។ តែទោះជាយ៉ាងណាភាពមិនខ្ជាប់ខ្ជួននៃផលិតកម្មកសិកម្ម គឺមិនគ្រាន់តែជាបុព្វហេតុមួយនៃគម្លាតប្រាក់ចំណូល វិសមភាពទ្រព្យសម្បត្តិនិងឧបសគ្គចំពោះការកាត់បន្ថយភាពក្រីក្រទេ ប៉ុន្តែថែមទាំងជាឧបសគ្គដ៏ ចម្បងមួយចំពោះការអភិវឌ្ឍប្រកបដោយចីរភាព ផ្អែកលើភាពទូលំទូលាយនៃសេដ្ឋកិច្ចមិនមែនកសិកម្ម។ រាជរដ្ឋាភិបាលបានបង្កើនវិនិយោគទុនក្នុងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដោយកាត់បន្ថយបានមួយចំនួនចំពោះភាពងាយរងគ្រោះនៃផលសម្រេចកសិកម្ម ដោយលក្ខខណ្ឌអាកាសធាតុ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៤
# វិស័យធនាគារ

កម្រិតនៃការអភិវឌ្ឍនៃវិស័យហិរញ្ញវត្ថុ គឺជាសូចនាករសមស្របនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។ Jalian និង Kirpatrick (២០០៥) បានបង្ហាញថា ទោះបីសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្តី ការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុឱ្យល្អប្រសើរបានបង្កើនល្បឿននៃផលិតភាពក្នុងមនុស្សម្នាក់ៗ និងធានាបាននូវកំណើនផលិតកម្ម ដោយសារប្រព័ន្ធហិរញ្ញវត្ថុ គឺជាវិស័យមួយដែលបែកចែកធនធានក្នុងសង្គម ឆ្ពោះទៅសកម្មភាពដែលផ្តល់ផ្លែផ្កា និងនាំឱ្យទទួលបានផលិតភាពខ្ពស់។ Rioja និង Valev (២០០៤) បានលើកឡើងថា ការបង្កើនអន្តរការីកម្មហិរញ្ញវត្ថុនឹងមានឥទ្ធិពល ដោយផ្ទាល់ទៅលើកំណើន ប្រសិនបើធនាគារសម្រេចបាននូវការអភិវឌ្ឍក្នុងកម្រិតមួយខ្ពស់ ដែលឥណទាន ឯកជនយ៉ាងហោចណាស់ស្មើនឹង ១៤%នៃផលិតផលសរុបក្នុងស្រុក (GDP)។

យើងឃើញថា វិស័យហិរញ្ញវត្ថុដែលរឹងមាំមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយនឹងកំណើនសេដ្ឋកិច្ច ដោយសារតែវិស័យហិរញ្ញវត្ថុដែលរឹងមាំមានឥទ្ធិពលជាវិជ្ជមាន ទៅលើការសន្សំប្រាក់ឯកជន និងការបែងចែកធនធាន។ រដ្ឋមានតួនាទីដ៏ចម្បង ក្នុងការលើកទឹកចិត្តដល់ការអភិវឌ្ឍស្ថាប័ន ដែលពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានរយៈពេលវែង ស្ថាប័នឯកទេស និងគាំទ្រដល់ឧបករណ៍ ដែលត្រូវដើរតួនាទីមួយដ៏សមស្រប ដើម្បីបំពេញសេចក្តីត្រូវការជាក់ស្តែងនានា។ រដ្ឋត្រូវមានតួនាទីក្នុងការដាក់ចេញនូវវិធានការ ដែលពាក់ព័ន្ធនឹងការលើកកម្ពស់ និងកែលម្អក្របខ័ណ្ឌនិយតកម្មនិងគតិយុត្តិ (ការប្រកួតប្រជែង វិធានប្រុងប្រយ័ត្នប្រព័ន្ធពន្ធ អត្រាការប្រាក់ ឥណទាន និងច្បាប់ទារឥណទានវិញ។ល។)។

ទោះបីជាយ៉ាងនេះក្តី បទប្បញ្ញត្តិដែលតឹងតែងពេកតែងតែបន្ថយបង្អាក់ការអភិវឌ្ឍនៃប្រព័ន្ធធនាគារនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទៅវិញ។ ការគាបសង្កត់ផ្នែកហិរញ្ញវត្ថុ (Agenor និង Montiel ១៩៩៩) កើតឡើងពេលដែលធនាគារពាណិជ្ជទាំងឡាយ ត្រូវបានតម្រូវឱ្យរក្សាសមាមាត្រខ្ពស់នូវលំហូរសាច់ប្រាក់ និងធនបម្រុង។ នៅពេលដែលវិធានការនេះ ត្រូវបានអនុវត្តក្នុងបរិបទនៃក្របខ័ណ្ឌគតិយុត្តិនិងស្ថាប័នមួយ ដែលមិនរឹងមាំ នោះការត្រួតពិនិត្យតឹងតែងហួសហេតុបែបនេះ បានក្លាយទៅជាមូលហេតុចម្បងមួយ ដែលធ្វើឱ្យវិស័យហិរញ្ញវត្ថុមិនអាចអភិវឌ្ឍទៅមុខរួច។ ស្ថាប័នដែលទន់ខ្សោយមានជាអាទិ៍ ៖ (១) ព័ត៌មានស្តីពីអ្នកខ្ចីប្រាក់ (២) ការអនុវត្តកម្មសិទ្ធិឯកជន និង (៣) ការធានា និងការចុះបញ្ជីដីធ្លី។

## ៤.១. សាវតារ

សង្គ្រាមស៊ីវិល និងចលាចលផ្នែកនយោបាយដែលកើតមានឡើង ជាងបីទសវត្សរ៍កន្លងទៅនេះ បានធ្វើឱ្យសាធារណជនបាត់បង់ជំនឿទុកចិត្ត ទៅលើវិស័យធនាគារ និងធ្វើឱ្យអន្តរការីកម្មហិរញ្ញវត្ថុបំពេញតួនាទីមានកម្រិត។ បន្ទាប់ពីកម្ពុជាទទួលបានឯករាជ្យក្នុងឆ្នាំ១៩៥៣មក សេដ្ឋកិច្ចនៃប្រទេសកម្ពុជាសម្រេចបាននូវកំណើន និងការលូតលាស់យ៉ាងខ្លាំង ក្នុងរយៈពេលមួយទសវត្សរ៍ រហូតទាល់តែមានការដាក់ឱ្យអនុវត្តនូវគោលនយោបាយសេដ្ឋកិច្ចផែនការ ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ តាមរយៈការធ្វើជាតូបនីយកម្មធនាគារពាណិជ្ជ និងពាណិជ្ជកម្មក្រៅប្រទេស ក្នុងឆ្នាំ១៩៦៣។

សង្គ្រាមស៊ីវិលដែលផ្ទុះឡើងនៅថ្ងៃទី១៨ ខែមិនាឆ្នាំ១៩៧០ បានបំផ្លិចបំផ្លាញនូវការខិតខំប្រឹងប្រែងស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញ។ បន្ទាប់ពីពួកខ្មែរក្រហមបានដណ្តើមអំណាចបាន នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពួកគេបានអនុវត្តនូវគោលនយោបាយប្រល័យពូជសាសន៍ និងបានបង្កើតនូវសង្គមកសិករមួយ ដែលមិនចាយប្រាក់ ហើយពួកគេបានឈានទៅបំបាត់ចោលទាំងស្រុង នូវកម្មសិទ្ធិឯកជន រូបិយប័ណ្ណជាតិ ធនាគារ និងទីផ្សារ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កើតឡើងវិញនូវធនាគារកណ្តាល។ ប្រព័ន្ធធនាគាររដ្ឋទោលមួយត្រូវបានបង្កើតឡើងដែលបំពេញតួនាទីជាធនាគារកណ្តាលផង និងបំពេញសកម្មភាពជាធនាគារពាណិជ្ជផង ដែលប្រព័ន្ធបែបនេះ គេតែងតែជួបប្រទះនៅក្នុងប្រទេសសង្គមនិយម។ សេដ្ឋកិច្ចកម្ពុជានៅពេលនោះ គឺជាសេដ្ឋកិច្ចផែនការ។

ក្នុងឆ្នាំ១៩៨៩ រដ្ឋាភិបាលកម្ពុជានៅពេលនោះ បានអនុវត្តនូវកំណែទម្រង់សេដ្ឋកិច្ចស៊ីជម្រៅមួយដើម្បីប្រែក្លាយសេដ្ឋកិច្ចផែនការ ឱ្យទៅជាសេដ្ឋកិច្ចទីផ្សារ។ កំណែទម្រង់ទាំងនេះផ្តោតទៅលើ ការបង្កើតឡើងវិញនូវកម្មសិទ្ធិឯកជន ការបំបាត់ចោលនូវការត្រួតពិនិត្យថ្លៃទំនិញ ការធានាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងការកាត់បន្ថយអតិផរណា។ សេរីភាវូបនីយកម្មសេដ្ឋកិច្ចនេះ ក៏មានគោលដៅកាត់បន្ថយការត្រួតពិនិត្យរបស់រដ្ឋ និងបើកទូលាយឱ្យមានការវិនិយោគពីបរទេស។ ម៉្យាងវិញទៀត រដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តដំណើរការឯកជនភាវូបនីយកម្ម ហើយបានដាក់ចេញនូវគោលនយោបាយ ដើម្បីធ្វើសមាហរណកម្មនៃសេដ្ឋកិច្ចកម្ពុជា ចូលទៅក្នុងសេដ្ឋកិច្ចក្នុងតំបន់ និយាយដោយឡែក និងចូលទៅក្នុងសេដ្ឋកិច្ចពិភពលោកនិយាយជារួម។ គេរំពឹងទុកថា ការផ្លាស់ប្តូរនេះនឹងលើកកម្ពស់កំណើនសេដ្ឋកិច្ច ផលិតភាព និងការបង្កើតការងារធ្វើ។

ក្នុងបរិបទនេះ កម្ពុជាបានអនុវត្តនូវកំណែទម្រង់ប្រព័ន្ធធនាគារ ដើម្បីបំបែកមុខងាររបស់ធនាគារពាណិជ្ជ ពីសកម្មភាពរបស់ធនាគារជាតិនៃកម្ពុជា និងបើកទូលាយឱ្យមានការប្រកួតប្រជែងពីបរទេសក្នុងវិស័យធនាគារ។ ជាមួយនឹងកំណែទម្រង់រចនាសម្ព័ន្ធយ៉ាងលឿននេះ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាគឺជាប្រព័ន្ធមួយដែលមានធនាគារកណ្តាលនិងធនាគារពាណិជ្ជមួយចំនួនដែលត្រូវបានបង្កើតឡើង ក្នុងគោលដៅផ្តល់ឥណទានដល់ធុរៈកិច្ចឯកជន។ ធនាគារពាណិជ្ជទាំងនេះ ត្រូវបានបង្កើតឡើងក្នុងរូបភាពជាសហគ្រាសចម្រុះ រវាងផ្នែកឯកជន និងធនាគារជាតិនៃកម្ពុជា។

### ៤.១.១. កំណែទម្រង់ធនាគារមុនវិបត្តិហិរញ្ញវត្ថុអាស៊ី

បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាត្រូវបានបង្កើតឡើង ក្នុងក្របខ័ណ្ឌនៃលទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានអនុវត្តនូវកំណែទម្រង់សេដ្ឋកិច្ចស៊ីជម្រៅ ដែលជាកំណែទម្រង់ជំនាន់ទីមួយ ក្នុងគោលដៅរក្សាស្ថេរភាពរូបិយវត្ថុ និងសេដ្ឋកិច្ច លើកទឹកចិត្តដល់សេរីភាវូបនីយកម្មសេដ្ឋកិច្ច ដែលរួមមានការកាត់បន្ថយតួនាទីរបស់រដ្ឋនៅក្នុងសកម្មភាពទីផ្សារ ការអនុវត្តគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រយ័ត្នប្រយែង និងការលើកកម្ពស់សហគ្រាសឯកជន។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ ដល់ការបង្កើតបរិស្ថានមានស្ថេរភាព និងបរិយាកាសមានការជឿជាក់ ដើម្បីជំរុញកំណើនប្រាក់សន្សំឯកជន ការវិនិយោគបរទេស និងជំនួយអភិវឌ្ឍន៍ផ្លូវការ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំណែទម្រង់ទូលំទូលាយនេះ ត្រូវបានអនុវត្តដោយឈរលើអភិក្រមពីរគឺ៖ វិធានការស្ថេរភាព-នីយកម្ម និងកំណែទម្រង់រចនាសម្ព័ន្ធ ដែលជាកំណែទម្រង់ជំនាន់ទីមួយ និងទីពីរ។ កំណែទម្រង់ជំនាន់ទីមួយផ្ដោតលើគោលដៅម៉ាក្រូសេដ្ឋកិច្ចរយៈពេលខ្លី ចំណែកឯកំណែទម្រង់ជំនាន់ទីពីរ មានចរិតលក្ខណៈពិសេសសំដៅលើការពង្រឹងសមត្ថភាពស្ថាប័ន និងរចនាសម្ព័ន្ធ។

កម្ពុជាសម្រេចបានវឌ្ឍនភាពក្នុងការអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធ ៖ ប្រព័ន្ធធនាគារមួយ ដែលមានធនាគារពីរប្រភេទត្រូវបានបង្កើតឡើង និងបានដាក់ឱ្យចរាចរនូវក្រដាសប្រាក់ឯកតាតម្លៃធំ ដើម្បីសម្រួលដល់ធុរៈកិច្ច។ កម្ពុជាបានបោះជំហានឆ្ពោះទៅរកការស្ដារឡើងវិញ នូវស្ថេរភាពនយោបាយ និងសេដ្ឋកិច្ច និងធ្វើសមាហរណកម្មជាមួយសហគមន៍អន្តរជាតិ។ ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលនយោបាយប្ដូរប្រាក់ ដែលមានភាពទន់ភ្លន់ តាមរយៈការប្រើប្រាស់យន្តការទីផ្សារ ការកែតម្រូវ និងការសម្របសម្រួលអត្រាប្ដូរប្រាក់ផ្លូវការ ជាមួយនឹងអត្រាប្ដូរប្រាក់ទីផ្សារ ក្នុងរង្វង់កំណត់មួយ។

ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ រាជរដ្ឋាភិបាលបានអនុវត្តនូវគោលនយោបាយលើកកម្ពស់ការអភិវឌ្ឍ តាមរយៈការធ្វើសេរីភាវូបនីយនៃប្រព័ន្ធធនាគារ។ រដ្ឋបានបង្កើតធនាគារ ក្រោមរូបភាពជាក្រុមហ៊ុនចម្រុះមួយចំនួនរវាងរដ្ឋ និងឯកជន ជាពិសេស ជាមួយនឹងអ្នកវិនិយោគទុនបរទេស។ ក៏ប៉ុន្តែ ធនាគារពាណិជ្ជភាគច្រើនត្រូវបានបង្កើត ដោយមានមូលធនបរទេស ជាភាគទុនិកភាគច្រើន។ ចាប់តាំងពីឆ្នាំ១៩៩៣ កំណែទម្រង់សំខាន់ៗត្រូវបានអនុវត្ត មួយដំណាក់កាលម្ដងៗ។ កំណែទម្រង់នេះត្រូវបានអនុវត្ត ទន្ទឹមនឹងសេរីភាវូបនីយកម្មនៃអត្រាការប្រាក់ ការបែកចែកឥណទាន និងការបង្កើតទីផ្សាររូបិយវត្ថុ ក្នុងគោលដៅលើកទឹកចិត្តដល់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុមួយ ដែលមានភាពទន់ភ្លន់ និងប្រកួតប្រជែង ដោយឈរលើគោលការណ៍ទីផ្សារ។

កំណែទម្រង់ទាំងនេះបានលើកទឹកចិត្តឱ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍពាណិជ្ជកម្មនិងលំហូរវិនិយោគទុន ស្របជាមួយនឹងការស្ដារឡើងវិញនៃកំណើនសេដ្ឋកិច្ច។ កំណើនប្រចាំឆ្នាំពិតសម្រេចបានប្រមាណ៧% ក្នុងអំឡុងឆ្នាំ១៩៩៣-១៩៩៦។ ការអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈនិងរូបិយវត្ថុដ៏ប្រុងប្រយ័ត្នបាននាំឱ្យមានការកាត់បន្ថយអតិផរណាពីអត្រាជាមធ្យម១៩០% ក្នុងឆ្នាំ១៩៩០-៩២ មកដល់ ៧.៧% ក្នុងឆ្នាំ១៩៩៥-៩៧។ ប្រាក់ចំណូលក្នុងមនុស្សម្នាក់បានកើនពី ប្រមាណ១៥០ដុល្លារក្នុងឆ្នាំ១៩៩១ ដល់ ២៨១ដុល្លារក្នុងឆ្នាំ ១៩៩៧។

ចំនួនធនាគារបានកើនឡើងដល់៣០ ត្រឹមចុងឆ្នាំ១៩៩៤។ កំណើននេះអាចសម្រេចបាន ដោយសារការបន្ធូរបន្ថយលក្ខខណ្ឌក្នុងការចេញអាជ្ញាប័ណ្ណ និងការកំណត់ដើមទុនអប្បបរមាក្នុងកម្រិតមួយដ៏ទាបបំផុត។ នៅពេលដែលចំនួនធនាគារពាណិជ្ជបានកើនទ្វេដង នោះបានដាក់សម្ពាធយ៉ាងខ្លាំង លើសមត្ថភាពនិយតកម្ម និងសមត្ថភាពគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ដែលនាំឱ្យមានការបញ្ឈប់ជាផ្លូវការទៅលើការចេញអាជ្ញាប័ណ្ណដល់ធនាគារថ្មីៗក្នុងឆ្នាំ១៩៩៤។

ក្នុងឆ្នាំ១៩៩៦ ធនាគារជាតិនៃកម្ពុជាបានពង្រឹងវិធានការប្រុងប្រយ័ត្ននានា ដោយតម្រូវឱ្យធនាគារពាណិជ្ជរៀបចំរបាយការណ៍សវនកម្មផ្ទៃក្រៅ និងរបាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវបានបញ្ជាក់ហើយរៀបចំរួចជាស្រេចនូវប្រព័ន្ធគ្រប់គ្រងនៅនឹងកន្លែង។ ប្រព័ន្ធធនាគារងាយទទួលរងគ្រោះ ដោយសារមានធនាគារពាណិជ្ជច្រើនពេក ដែលធ្វើសកម្មភាពក្នុងទីផ្សារមួយដ៏តូច។ ក្នុងបរិបទនេះ ធនាគារពាណិជ្ជទាំងអស់ត្រូវធ្វើអាជីវកម្ម ដោយទទួលបាននូវប្រាក់ចំណេញ ក្នុងកម្រិតមួយដែលទាបក្រៃលែង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៤.១.២. ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុទៅលើប្រព័ន្ធធនាគារកម្ពុជា

កម្ពុជាត្រូវបានទទួលរងនូវវិបត្តិហិរញ្ញវត្ថុអាស៊ី ដែលបានកើតឡើងនៅក្នុងឆ្នាំ១៩៩៧-១៩៩៨។ ទ្វីបអាស៊ី គឺជាទីផ្សារនាំចេញមួយដ៏សំខាន់សម្រាប់ទំនិញដែលកម្ពុជាផលិត ហើយក៏ជាប្រភពដ៏សម្បូរហូរហៀរនៃប្រាក់សន្សំបរទេស និងប្រាក់ចំណូលសារពើពន្ធដែលទទួលបានពីពាណិជ្ជកម្មបរទេស។ ដូច្នេះហើយ ទើបសេដ្ឋកិច្ចកម្ពុជាងាយនឹងរងគ្រោះដោយសារការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់ បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុអាស៊ីនេះបានចាប់ផ្តើមឡើង (Okonjo-Iweala el al, ១៩៩៩)។

ម្យ៉ាងវិញទៀត ភាពមិនប្រាកដប្រជាខាងផ្នែកនយោបាយ ដែលបណ្តាលមកពីវិវាទប្រដាប់អាវុធដែលបានផ្ទុះឡើងក្នុងខែកក្កដា ឆ្នាំ ១៩៩៧ មុននឹងមានវិបត្តិហិរញ្ញវត្ថុអាស៊ី បានធ្វើឱ្យកំណែទម្រង់រចនាសម្ព័ន្ធដូចបានពិពណ៌នាខាងលើ បាត់បង់អស់នូវថាមពលរបស់ខ្លួនផងដែរ។ ប្រការនេះបានក្លាយជាកត្តារាំងចំពោះការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរចំណូលថវិការ និងការពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ។ ដូច្នេះ សេដ្ឋកិច្ចកម្ពុជាកាន់តែងាយទទួលរងគ្រោះ ពីការប៉ះទង្គិចពីខាងក្រៅ។ តែទោះជាយ៉ាងណាក៏ដោយ ដុល្លារូបនីយកម្មស៊ីជម្រៅនៃសេដ្ឋកិច្ចកម្ពុជាបានជួយសម្រាលផលប៉ះពាល់នៃវិបត្តិនេះទៅលើវិស័យរូបិយវត្ថុ និងធនាគារ។

ទន្ទឹមនឹងនេះ សាខាធនាគារបរទេសបានជួបការលំបាក ក្នុងការរក្សាទុនអប្បបរមាដែលតម្រូវដោយច្បាប់ ដោយសារតែវិបត្តិនេះបានជះឥទ្ធិពលអវិជ្ជមានទៅលើប្រតិបត្តិការរបស់ធនាគារនៃក្រុមហ៊ុនមេក្នុងតំបន់ ។ ម្យ៉ាងវិញទៀត កង្វះកាលានុវត្តភាពសម្រាប់កម្ចីធនាគារ និងបរិស្ថានមានហានិភ័យខ្ពស់ បានដាក់ពិន័យបន្ថែមទៀតដល់ធនាគារទាំងនេះ។ ក្នុងបរិបទនេះ ទំនុកចិត្តទៅលើវិស័យធនាគារបានឈានដល់កម្រិតមួយទាបបំផុត ដោយសារធនាគារមួយចំនួនកំពុងតែស្ថិតនៅក្នុងសភាពជិតក្ស័យធន។

វិបត្តិហិរញ្ញវត្ថុអាស៊ីបានផ្តល់នូវបទពិសោធន៍ដ៏ល្អមួយ សម្រាប់កំណែទម្រង់វិស័យធនាគារនៅកម្ពុជា។ កម្ពុជានៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីអនុវត្តវិធានការប្រុងប្រយ័ត្ន និងពង្រឹងរចនាសម្ព័ន្ធឃ្លាំមើល។ ឆ្លុះបញ្ចាំងតាមរយៈនៃវិបត្តិនេះ រាជរដ្ឋាភិបាលកម្ពុជាបានដឹងយ៉ាងច្បាស់ ពីភាពចាំបាច់ក្នុងការពង្រឹងសមត្ថភាពស្ថាប័ននិងក្របខ័ណ្ឌគតិយុត្តិ រដ្ឋបាលនៃកិច្ចការសាធារណៈដ៏រឹងមាំ និងមូលដ្ឋានរឹងដ៏មាំមួយសម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យធនាគារ ក្នុងគោលដៅអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុដ៏រឹងមាំមួយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ប្រអប់ ៤.១. ទិដ្ឋភាពនៃការប្រុងប្រយ័ត្ន

### មូលធនដើមអប្បបរមា និងមូលនិធិផ្ទាល់អប្បបរមារបស់ធនាគារ

ធនាគារពាណិជ្ជបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុន ដែលមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬ ជាគ្រឹះស្ថានហិរញ្ញវត្ថុដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៥០ ពាន់លានរៀល។ ចំពោះធនាគារពាណិជ្ជដែលមានភាគទុនិកជាវិនិយោគិន ដែលជាឯកត្តជន ឬ ក្រុមហ៊ុន ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១៥០ពាន់លានរៀល។ ធនាគារឯកទេស ដែលមានការវាយតម្លៃ "ចំណាត់ថ្នាក់វិនិយោគ" ត្រូវមានដើមទុនអប្បបរមាស្មើនឹង ១០ ពាន់លានរៀល។ ចំពោះធនាគារឯកទេសដែលមានភាគទុនិកជាវិនិយោគិនដែលជា ឯកត្តជន ឬ ក្រុមហ៊ុន ត្រូវមានដើមទុនអប្បបរមាស្មើនឹង ៣០ពាន់លានរៀល។

### ប្រាក់បម្រុងកាតព្វកិច្ច

ធនាគារត្រូវរក្សាទុកនូវប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាចំនួន ១២% នៃមូលធនអប្បបរមាជាមួយនឹងធនាគារជាតិនៃកម្ពុជា (បន្ទាប់ពីវិបត្តិឆ្នាំ២០០៨)។

### អនុបាតសាធនភាព (Basel 1)

ធនាគារទាំងអស់ត្រូវគោរពគ្រប់ពេលវេលា នូវអនុបាតសាធនភាព រវាងមូលនិធិផ្ទាល់សុទ្ធ និងហានិភ័យឥណទានសរុប ដែលមិនត្រូវតិចជាង១៥% ឡើយ។ ត្រូវបានកំណត់ថាជាសមាភាគអប្បបរមាមួយរវាងទីមួយតម្លៃសរុបឧទាហរណ៍:ភាពច្រើនលើសនៃទ្រព្យសម្បត្តិទៅលើចំនួនសរុបនៃបំណុលកម្ចីរបស់ភាគីទីបីទាយជ្ជទានសម្រាប់ការធ្លាក់ថ្លៃនិងការផ្តល់ជូនដែលត្រឹមត្រូវនិងទីពីរទ្រព្យសម្បត្តិរបស់ខ្លួន និងការប្តេជ្ញាចិត្តដែលត្រូវបានកំណត់ទម្ងន់លាយចម្រុះមួយអាស្រ័យលើកម្រិតហានិភ័យរបស់គេ។ សមាភាគសាធនភាពអប្បបរមាត្រូវបានកំណត់ចំនួន១៥% (ចាប់តាំងពីខែមករាឆ្នាំ២០០៥)។

### អនុបាតហានិភ័យធំ

ធនាគារពាណិជ្ជត្រូវរក្សាឱ្យបានគ្រប់ពេលវិលា នូវអនុបាតអតិបរមាចំនួន ១០% រវាងហានិភ័យ សរុប ដែលកើតចេញពីប្រតិបត្តិការជាមួយនឹងអត្ថគាហកជាឯកត្តជននីមួយៗ និងមូលនិធិផ្ទាល់សុទ្ធរបស់ ខ្លួន។

### អនុបាតសាច់ប្រាក់ងាយស្រួល

ធនាគារត្រូវធានាគ្រប់ពេលវេលា នូវអនុបាតសាច់ប្រាក់សាច់ប្រាក់ងាយស្រួល៖ ដែលជាផលចែករវាង ទីមួយ សមតុល្យសាច់ប្រាក់ និងទីពីរ (១) សមតុល្យសាច់ប្រាក់ (២) ៨០% នៃចំណែកប្រាក់បញ្ញើមានកាលកំណត់ដែលមានរយ:ពេលនៅសល់មិនលើសពី ១ ខែ (៣) ៥០% នៃចំណែកប្រាក់បញ្ញើមានកាលកំណត់ដែលមានរយ:ពេលនៅសល់លើសពី១ខែ (៤) ៥០% នៃប្រាក់បញ្ញើសញ្ច័យ និង (៥) ៦០% នៃប្រាក់បញ្ញើគ្មានកាលកំណត់។

### ចំណាត់ថ្នាក់និងសំវិធានធនលើបំណុល

ទ្រព្យសកម្មត្រូវតែចាត់ថ្នាក់ជា៥ប្រភេទ ៖ (១) ធម្មតា៖ ចំពោះទ្រព្យសកម្មកំពុងដំណើរការ សំវិធានធន១% (២) ឃ្លាំមើល៖ ចំពោះឥណទានមិនទាន់ហួសកាលកំណត់សង សំវិធានធន៣% (៣) ក្រោមស្តង់ដារ សំវិធានធន២០% (៤) សង្ស័យ និង សំវិធានធន៥០% (៥) បាត់បង់ សំវិធានធន១០០% (២០០៩)។

*Source: Banque nationale du Cambodge.*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.២. កំណែទម្រង់រចនាសម្ព័ន្ធនៃប្រព័ន្ធធនាគារ

ដើម្បីពង្រឹងសមត្ថភាពនិយតកម្មរបស់ខ្លួន ធនាគារជាតិនៃកម្ពុជាបានដាក់ចេញ និងអនុវត្តជាបន្តបន្ទាប់នូវវិធានការខាងផ្នែកគតិយុត្តិ និយតកម្ម និងថវិកា ដើម្បីលើកកម្ពស់តម្លាភាពហិរញ្ញវត្ថុ និងពង្រឹងស្ថេរភាពហិរញ្ញវត្ថុ។ ក្របខ័ណ្ឌច្បាប់សម្រាប់វិស័យធនាគារនេះ អាចសង្ខេបបានដូចខាងក្រោមនេះ ៖

- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ឆ្នាំ១៩៩៦
- ច្បាប់ស្តីពីឆ្នាំ១៩៩៩
- ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ឆ្នាំ១៩៩៧
- ច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ឆ្នាំ២០០៥។

ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានកំណត់នូវគោលការណ៍ សកម្មភាព និងប្រតិបត្តិការធនាគារដែលបម្រើសេវាពេញលេញ ឬ ធនាគារសកល។ បទបញ្ញត្តិនៃច្បាប់នេះមានគោលដៅពង្រឹងតម្លាភាព និងធានាបាននូវគណនីភាព។ ដើម្បីកែលម្អគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុ និងធានាតម្លាភាពកាន់តែខ្លាំងនោះ ច្បាប់នេះបានចែងនូវលក្ខខណ្ឌបន្ថែមមួយចំនួន ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាន។

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានបង្កើតឡើង ក្រោមរូបភាពជាក្រុមហ៊ុនភាគហ៊ុននៃច្បាប់ពាណិជ្ជកម្ម ឬជាក្រុមហ៊ុនមិនមែនពាណិជ្ជកម្ម សង្គហសមាគម ឬសហករណ៍ ដែលស្ថិតនៅក្រោមលក្ខន្តិកៈនិត្យានុកូលដោយឡែក (មាត្រា១១)។ ច្បាប់នេះបានកំណត់យ៉ាងច្បាស់ នូវលក្ខខណ្ឌក្នុងការផ្តល់អាជ្ញាប័ណ្ណជូនដល់គ្រឹះស្ថានចំណុះច្បាប់ និងបានបង្កើននូវចំនួនទឹកប្រាក់នៃដើមទុនអប្បបរមា និងសាធនភាព។

ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកំណត់ផងដែរ នូវតួនាទីរបស់ធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធរអាណាព្យាបាលលើប្រព័ន្ធធនាគារ និងលើសកម្មភាពប្រទាក់គ្នា ដូចជាផ្សាររូបិយវត្ថុ ប្រព័ន្ធទូទាត់អន្តរធនាគារ និងអន្តរការីកម្មហិរញ្ញវត្ថុ។ ក្នុងបរិបទនេះ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចក្នុងការចេញនូវបទបញ្ជាជាប្រកាស និងសារាចរណែនាំ ក្នុងគោលដៅអនុវត្តច្បាប់ខាងលើនេះឱ្យមានប្រសិទ្ធភាព ជាពិសេសការកំណត់៖

- ដើមទុនអប្បបរមានិងការយកទៅប្រើក្នុងប្រភេទទ្រព្យសកម្ម
- វិធានការប្រុងប្រយ័ត្ន និងអនុបាតឬ មេគុណផ្សេងៗដែលពាក់ព័ន្ធជាពិសេសនឹង សាច់ប្រាក់ងាយស្រួល សាធនភាព ការបំបែងហានិភ័យ និងការប្រឈមមុខទល់នឹងហានិភ័យនៃការប្តូរប្រាក់ ឬទីផ្សារ
- វិធីសាស្ត្រក្នុងការវាយតម្លៃសមតុល្យនៃគណនី
- លក្ខខណ្ឌនានា ដែលគេអាចចូលភាគកម្មក្នុងដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនហិរញ្ញវត្ថុ
- ចំណាត់ថ្នាក់ប្រភេទឥណទាននិងការធ្វើសំវិធានធនចំពោះបំណុលពិបាកទារ។ប្រព័ន្ធគណនេយ្យធនាគារ និងបទដ្ឋានដែលពាក់ព័ន្ធ ក៏ដូចជា លក្ខខណ្ឌនានាដែលប្រតិបត្តិការ ធនាគារ ឬ ហិរញ្ញវត្ថុត្រូវបានអនុវត្តចំពោះអតិថិជន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការរៀបចំសេវាកម្មអន្តរធនាគារ ជាអាទិ៍ ការបង្កើតមជ្ឈការនៃព័ត៌មាននៃហានិភ័យ ឬ នៃបំណុលពិបាកទារ។

ធនាគារជាតិនៃកម្ពុជាមានតួនាទីតាមដាន និងត្រួតពិនិត្យប្រព័ន្ធធនាគារ តាមវិធីពិនិត្យផ្ទៀងផ្ទាត់ជាអចិន្ត្រៃយ៍លើឯកសារ និងតាមវិធីត្រួតពិនិត្យតាមកាលវេលាចាំបាច់ដល់ទីកន្លែងនៃគ្រឹះស្ថានធនាគារ។ ធនាគារជាតិនៃកម្ពុជាអាចទាមទារការផ្តល់ព័ត៌មាន របាយការណ៍សវនកម្មផ្ទៃក្រៅ និងរបាយការណ៍ហិរញ្ញវត្ថុ ដែលមានការទទួលស្គាល់ ពីគ្រឹះស្ថានធនាគារ ពីរដ្ឋបាលនានា ពីស្នងការគណនី ឬពីគ្រប់នីតិបុគ្គលឬរូបវន្តបុគ្គលដទៃទៀត។

ប្រសិនបើមានគ្រោះភ័យធ្ងន់ធ្ងរ និងជាក់ស្តែងលើសាធនភាពរបស់គ្រឹះស្ថានធនាគារ នោះអាជ្ញាធរអាណាព្យាបាលអាច ជាស្វ័ប្រវត្តិ ឬ តាមសំណើរបស់អ្នកដឹកនាំ ឬរបស់ភាគទុនិក: តែងតាំងអភិបាលបណ្តោះអាសន្ន ដែលមានបេសកកម្មចម្បងក្នុងការរៀបចំជាបន្ទាន់នូវការវាយតម្លៃថា គ្រឹះស្ថានធនាគារនេះអាច ឬមិនអាចមានសាធនភាព ទន្ទឹមនឹងធានាការគ្រប់គ្រងកិច្ចការប្រចាំថ្ងៃ ដោយការពារនូវសាធនភាព និងសមភាពរវាងអ្នកផ្ញើប្រាក់ ឬឥណទាយក។ ប្រសិនបើបន្ទាប់ពីការវាយតម្លៃ គ្រឹះស្ថានអាចមានសាធនភាព ប៉ុន្តែប្រសិនបើគ្រឹះស្ថាននេះ ក្នុងរយៈពេលបីខែ គ្មានលទ្ធភាពអនុវត្តវិធានការតាមបទដ្ឋានប្រុងប្រយ័ត្នទាក់ទងដល់មូលនិធិផ្ទាល់សុទ្ធ និងទាក់ទងដល់សាច់ប្រាក់ងាយស្រួល អាជ្ញាប័ណ្ណអាចត្រូវបានដកហូតវិញ ហើយការអភិបាលបណ្តោះអាសន្ននោះ ត្រូវបានប្រែក្លាយទៅជាការជម្រះបញ្ជីក្រៅផ្លូវតុលាការ។

ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានចែងពីបញ្ញត្តិស្តីពីការប្រឆាំងនឹងការសម្អាតប្រាក់ដែលតម្រូវឱ្យគ្រឹះស្ថានធនាគារ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ចាត់គ្រប់វិធានការសំដៅ ម៉្យាងកត់អត្តសញ្ញាណច្បាស់លាស់របស់អតិថិជន និងរបស់ប្រតិបត្តិការទាំងឡាយដែលធ្វើតាមរយៈខ្លួន ប្រសិនបើលើសពីកម្រិតមួយ ដែលអាជ្ញាធរបានកំណត់ ហើយសំដៅម៉្យាងទៀត រក្សានូវឯកសារពាក់ព័ន្ធទាំងអស់ យ៉ាងតិចឱ្យបានដប់ឆ្នាំ (មាត្រា៥១)។ ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការច្រើនថែមទៀត ក្នុងគោលដៅពង្រឹងក្របខ័ណ្ឌគតិយុត្តិ ដើម្បីប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងការផ្តល់ហិរញ្ញប្បទានដល់អំពើភេរវកម្ម។

## ៤.២.១. ការបង្កើនមូលដ្ឋានគ្រឹះការពង្រឹងវិស័យធនាគារឱ្យកាន់តែប្រសើរឡើង

រាជរដ្ឋាភិបាលកម្ពុជាយល់យ៉ាងច្បាស់ពីតួនាទីនៃប្រព័ន្ធហិរញ្ញវត្ថុដ៏រឹងមាំ ក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងក្នុងការបង្កើតការងារ ក៏ដូចជាផ្តល់ឱ្យសេដ្ឋកិច្ចនូវធនធានចាំបាច់នានា ដើម្បីឱ្យប្រព័ន្ធធនាគារនេះមានភាពធន់នឹងការប៉ះទង្គិច ទាំងពីខាងក្នុងនិងពីខាងក្រៅ។ ក្នុងន័យនេះ កំណែទម្រង់ធនាគារ គឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយដើម្បីពង្រឹងប្រព័ន្ធធនាគារ។ កំណែទម្រង់ធនាគារនេះ ត្រូវបានអនុវត្តដោយឈរលើមូលដ្ឋាននៃសសរស្តម្ភពីរសំខាន់ៗ៖ ទីមួយ-ការដាក់ចេញនូវវិធានការ ដើម្បីពង្រឹងស្ថាប័ននិងស្តារនូវសុខភាពហិរញ្ញវត្ថុនៃប្រព័ន្ធធនាគារ ពោលគឺ ការបង្កើតនូវបទដ្ឋានថ្មីសម្រាប់ការគ្រប់-គ្រងនិងការអនុមតិនូវផែនការសកម្មភាព ដែលជម្រុញឱ្យគ្រឹះស្ថានធនាគារសម្រេចបាននូវអនុបាតប្រុង-ប្រយ័ត្ន ដែលមានកម្រិតអន្តរជាតិ។ ទីពីរ-ត្រូវផ្តោតការយកចិត្តទុកដាក់ លើប្រសិទ្ធភាពនៃប្រព័ន្ធធនាគារដែលរួមមានវិធានការធ្វើទំនើបកម្មនៃប្រព័ន្ធធនាគារទាំងមូល។

ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់នូវក្របខ័ណ្ឌជាមូលដ្ឋាន សម្រាប់ប្រតិបត្តិការធនាគារនិងការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ទៅលើសកម្មភាពនៃធនាគារពាណិជ្ជ រួមមាន៖ (១) ការ

កំណត់អត្តសញ្ញាណរបស់ធនាគារ និងវិសាលភាពនៃប្រតិបត្តិការធនាគារ (២) ការកំណត់សិទ្ធិអំណាចរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការត្រួតពិនិត្យនិងគ្រប់គ្រងធនាគារ រួមមានអំណាចដាក់វិធានការខាងផ្នែកវិន័យរដ្ឋបាល និងទណ្ឌកម្មខាងព្រហ្មទណ្ឌ ក្នុងករណីដែលគ្រឹះស្ថានធនាគារមិនបានគោរពឱ្យបានហ្មឺងម៉ាត់នូវវិធានការប្រុងប្រយ័ត្ន (៣) ចែងពីកាតព្វកិច្ចរបស់គ្រឹះស្ថានធនាគារ ដើម្បីធានានូវភាពស្អាតស្អំរបស់ក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានធនាគារ និង (៤) ដាក់ចេញនូវនីតិវិធីជំរះបញ្ជី ប្រសិនបើគ្រឹះស្ថានធនាគារមិនអាចធានានូវសាធនភាពទេនោះ។

ក្នុងគោលដៅស្តារប្រព័ន្ធធនាគារឱ្យមានជវភាពឡើងវិញ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការដើម្បីបង្កើនមូលធនអប្បបរមានៃធនាគារពាណិជ្ជ ធានាតម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ និងរឹតបន្តឹងការត្រួតពិនិត្យទៅលើវិស័យធនាគារ។ វិធានការធ្វើកំណែទម្រង់រចនាសម្ព័ន្ធទាំងនេះត្រូវបានអនុវត្តជាមួយនឹងការបង្កើនមូលធនអប្បបរមារបស់ធនាគារពាណិជ្ជ ដែលត្រូវតម្លើងដល់យ៉ាងតិចណាស់ ចំនួន១២.៥លានដុល្លារអាមេរិក។ មូលធនអប្បបរមាដើរតួនាទី ជារបាំងរារាំងមិនឱ្យធនាគារពាណិជ្ជចូលទៅក្នុងទីផ្សារធនាគារ និងកំណត់ចំនួនរបស់ធនាគារពាណិជ្ជ ដែលអាចត្រូវបានអនុញ្ញាតឱ្យដំណើរការនៅកម្ពុជា។

ច្បាប់នេះបានផ្តល់អំណាចឱ្យធនាគារជាតិនៃកម្ពុជា ក្នុងការចេញអាជ្ញាប័ណ្ណឡើងវិញដើម្បីឱ្យធនាគារពាណិជ្ជអាចធ្វើប្រតិបត្តិការ។ មកត្រឹមចុងឆ្នាំ១៩៩៩ ចំនួនធនាគារពាណិជ្ជបានកើនឡើងដល់ ៣១ ដែលក្នុងនោះមាន ធនាគារពាណិជ្ជដែលមានភាគហ៊ុនរដ្ឋចំនួន ធនាគារពាណិជ្ជឯកជនចំនួន ២២ និងសាខានៃធនាគារបរទេសចំនួន ៧។

ក៏ប៉ុន្តែ ធនាគារទាំងនេះមានបំណុលអាក្រក់និងបំណុលសង្ស័យជាច្រើន និងមិនបានផ្តល់នូវកម្ចីវិនិយោគក្នុងវិស័យកសិកម្ម និងឧស្សាហកម្មឡើយ។ ជាការពិតណាស់ បញ្ហាប្រឈមចម្បងៗដែលវិស័យឯកជនបានជួបប្រទះ គឺការលំបាកក្នុងការទទួលបាននូវឥណទានពីធនាគារពាណិជ្ជ។

ម្យ៉ាងវិញទៀត ធនាគារឯកជនទាំងនេះចំណាយខុសៗគ្នា លើសកម្មភាពអន្តរការីកម្ម ហើយគុណភាពនៃឥណទាននៃធនាគារទាំងនេះ ក៏ខុសគ្នាដែរ។ ធនាគារដែលចំណាយខ្ពស់លើសកម្មភាពអន្តរ-ការីកម្ម ក៏អាចដំណើរការជាមួយគ្នានឹងគ្រឹះស្ថានធនាគារ ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់។ ក៏ប៉ុន្តែដោយសារតែធនាគារទាំងនេះតែងតែជួបប្រទះជាប្រចាំនឹងហានិភ័យ ដែលអ្នកផ្ញើប្រាក់អាចមកដកប្រាក់បញ្ញើក្នុងពេលតែមួយព្រមៗគ្នា នោះធនាគារពាណិជ្ជខ្នាតតូចនិងមធ្យមដែលទន់ខ្សោយទាំងនោះ បានក្លាយជាការគំរាមកំហែងមួយ ដល់ស្ថេរភាពនៃប្រព័ន្ធធនាគារទាំងមូល។

កំណែទម្រង់ចម្បងៗដែលចាប់ផ្តើមក្នុងឆ្នាំ២០០០ ត្រូវបានគេអនុវត្តដើម្បីកែប្រែរចនាសម្ព័ន្ធនៃវិស័យធនាគារឡើងវិញ ក្នុងគោលដៅបង្កើនតម្លាភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ និងពង្រឹងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។ ធនាគារជាតិនៃកម្ពុជាបានបង្កើតឡើងនូវប្រព័ន្ធត្រួតពិនិត្យលើឯកសារ តាមរយៈការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធរបាយការណ៍ស្តីពីសមិទ្ធផលវិស័យធនាគារ និងរបាយការណ៍ត្រួតពិនិត្យលើឯកសារធនាគាររបស់កម្ពុជាសម្រាប់ការអនុវត្តវិធានការកែតម្រូវជាបន្ទាន់ ដែលហៅកាត់ថារបាយការណ៍ COBRA។ នាយកដ្ឋានត្រួតពិនិត្យធនាគារ ដែលស្ថិតក្រោមធនាគារជាតិនៃកម្ពុជា បានធ្វើការត្រួតពិនិត្យដល់ទីកន្លែង និងធ្វើការត្រួតពិនិត្យលើឯកសារ ជារៀងរាល់ប្រាំមួយខែម្តង ដោយផ្អែកលើគោលការណ៍ Basel1 និងវិធានផ្តល់ព័ត៌មាននៃវិស័យធនាគារ។ ធនាគារពាណិជ្ជទាំងអស់ត្រូវតែអនុវត្តឬមួយសវនកម្មពេញលេញឬមួយសវនកម្មតាមផ្នែក។ ធនាគារជាតិនៃកម្ពុជាបានប្រើប្រាស់នូវវិធីសាស្ត្រ CAMEL ក្នុងការធ្វើការត្រួតពិនិត្យដល់ទីកន្លែង។ ធនាគារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ នូវតារាងគណនីថ្មីមួយ និងទម្រង់របាយការណ៍ដែលមានស្តង់ដាររួមមួយ ក្នុងគោលដៅលើកកម្ពស់គុណភាពនៃយន្តការត្រួតពិនិត្យ។

ធនាគារជាតិនៃកម្ពុជាបានចាត់ថ្នាក់ធនាគារពាណិជ្ជកម្មជាបីប្រភេទ ដោយផ្អែកលើប្រព័ន្ធចំណាត់ថ្នាក់ CAMEL៖ (១) ធនាគារគួរឱ្យជឿទុកចិត្ត ដែលមានមូលធនពេញលេញ និងមិនត្រូវធ្វើកំណែទម្រង់រចនាសម្ព័ន្ធ (២) ធនាគារដែលមានសក្តានុពលទន់ខ្សោយ ប៉ុន្តែស្ថិតក្រោមកាតព្វកិច្ចចាត់វិធានការកែតម្រូវ និង(៣) ធនាគារដែលមិនគួរឱ្យជឿទុកចិត្ត។ ធនាគារពាណិជ្ជកម្មដែលត្រូវបានចាត់ថ្នាក់ចូលក្នុងប្រភេទទីពីរ ត្រូវបានទទួលបញ្ជា ឱ្យរៀបចំផែនការស្តារឡើងវិញមួយ សម្រាប់ការអនុម័តដោយធនាគារជាតិនៃកម្ពុជា រួមទាំងរយៈពេលដើម្បីគោរពទៅតាមមូលធនអប្បបរមាចំនួន ១៣លានដុល្លារអាមេរិក។

ក្នុងការអនុវត្តច្បាប់ថ្មីស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារពាណិជ្ជទាំងអស់មានកាតព្វកិច្ចដាក់សំណុំបែបបទសុំអាជ្ញាប័ណ្ណឡើងវិញ ត្រឹមថ្ងៃទី៣១ខែឧសភាឆ្នាំ២០០០។ បន្ទាប់ពីបានពិនិត្យឯកសាររបស់ធនាគារពាណិជ្ជទាំងនោះហើយ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណដល់ធនាគារពាណិជ្ជកម្មចំនួន១៤ និងធនាគារឯកទេស ចំនួន៥។

ការពិនិត្យឯកសារឡើងវិញនេះបានបង្ហាញឱ្យឃើញផងដែរថា ធនាគារមួយចំនួនធំគួរឱ្យជឿទុកចិត្តាន ដូច្នេះហើយត្រូវតែជម្រះបញ្ជីដើម្បីបិទទ្វារ។ ធនាគារជាតិនៃ កម្ពុជាបានតែងតាំងអ្នកគ្រប់គ្រងបណ្តោះអាសន្ន ដើម្បីជៀសវាងការលក់ទ្រព្យសកម្ម ដែលជាកម្មសិទ្ធិរបស់ គ្រឹះស្ថានទាំងនោះ។ ប្រព័ន្ធធនាគារកម្ពុជាត្រូវបានធ្វើកំណែទម្រង់រចនាសម្ព័ន្ធឡើងវិញ ត្រឹមខែមេសាឆ្នាំ ២០០២ ហើយបានជម្រះបញ្ជីចេញ នូវធនាគារដែលមិនអាចបំពេញតាមលក្ខខណ្ឌរបស់ធនាគារជាតិនៃកម្ពុជាបាន ចំនួន១៥។ សាខាពីរនៃធនាគារបរទេសគឺ Crédit Agricole និង Standard Chartered Bank ក៏បានបិទទ្វារផងដែរ។

ក្នុងគោលដៅអនុវត្តនូវគោលនយោបាយរូបិយវត្ថុឱ្យមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្តនូវវិធានការកែប្រែរចនាសម្ព័ន្ធមួយចំនួន ដើម្បីពង្រឹងប្រសិទ្ធផល និងស្ថេរភាពនៃប្រព័ន្ធហិរញ្ញ - វត្ថុរបស់កម្ពុជា។ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្តនូវកុំព្យូទ័រនីយកម្មនៃតារាងគណនីនៃធនាគារ ហើយនៅចុងឆ្នាំ២០០៣ ធនាគារជាតិនៃកម្ពុជាបានបង្កើតយន្តការមួយ ដើម្បីប្រយុទ្ធប្រឆាំងនឹងការលាងសំអាតប្រាក់។ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យអនុវត្តនូវស្តង់ដារគណនីអន្តរជាតិ (IAS) ដើម្បីជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយធនាគារពាណិជ្ជ។

ធនាគារជាតិនៃកម្ពុជាបានអនុវត្តនូវវិធានការប្រុងប្រយ័ត្ន ដូចខាងក្រោម៖

- បង្កើនតម្លាភាព ពង្រឹងអភិបាលកិច្ចនិងភាពប្រកួតប្រជែងនៃវិស័យនេះ ដោយតម្រូវឱ្យធនាគារទាំងអស់ផ្តល់កម្ចីទៅឱ្យតែអតិថិជនណា ដែលអាចសងបំណុលបានតែប៉ុណ្ណោះ
- ពន្លឿនការដាក់ឱ្យអនុវត្តនូវប្រព័ន្ធព័ត៌មានវិទ្យាថ្មីមួយ សម្រាប់ផ្តល់ទិន្នន័យធនាគារនិងអនុវត្តការតាមដាន ឃ្លាំមើល ដោយផ្អែកលើហានិភ័យ ថាជាយន្តការផ្តល់ព័ត៌មានជាមុន
- កែលម្អបទប្បញ្ញត្តិស្តីពីប្រតិបត្តិការធនាគារ ដែលធ្វើឡើងដោយគ្រឹះស្ថានឥណទាន តាមរយៈការពង្រឹងការអនុវត្តបទបញ្ញត្តិគណនេយ្យ និងការកត់ត្រាទិន្នន័យហិរញ្ញវត្ថុ ស្តង់ដារគ្រប់គ្រង និងលក្ខខណ្ឌក្នុងការបំពេញការងារក្នុងអាជីពគណនេយ្យករ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- អនុមតិ និងដាក់ឱ្យប្រើប្រាស់នូវស្តង់ដារប្រុងប្រយ័ត្នថ្នាក់អន្តរជាតិ និង
- កែលម្អការធ្វើចំណាត់ថ្នាក់ឥណទាន និងពង្រឹងនីតិវិធីក្នុងការអនុមតិកម្ចី។

កំណែទម្រង់រចនាសម្ព័ន្ធនេះទទួលបានជោគជ័យ ក្នុងការពង្រឹងប្រព័ន្ធធនាគារ។ បន្ទាប់ពីការកំណែទម្រង់រចនាសម្ព័ន្ធរួចមក ប្រព័ន្ធធនាគាររបស់កម្ពុជាត្រូវបានបង្កើតឡើង ដោយធនាគារជាតិនៃកម្ពុជា ជាមួយសាខាតាមខេត្តចំនួន១៩របស់ខ្លួន និងធនាគារពាណិជ្ជសកលចំនួន១៥ និងធនាគារឯកទេសចំនួន១៦។

តាមរយៈដំណើរការនៃការកែទម្រង់រចនាសម្ព័ន្ធនេះ វិធានការប្រុងប្រយ័ត្នត្រូវបានពង្រឹង។ ប្រព័ន្ធធនាគារមានភាពរឹងមាំគួរឱ្យកត់សម្គាល់។ ជារួម ធនាគារពាណិជ្ជទាំងអស់បាននិងកំពុងអនុវត្តតាមវិធានការប្រុងប្រយ័ត្ននេះ ក៏ដូចជាតាមស្តង់ដារនានា ដែលពាក់ព័ន្ធនឹងហានិភ័យអត្រាប្តូរប្រាក់ និងការធ្វើសវនកម្មផ្ទៃក្នុង។ ការបង្កើនមូលធនអប្បបរមារបស់ធនាគារពាណិជ្ជត្រូវបានបញ្ចប់សព្វគ្រប់ទាំងស្រុង។ វិស័យមីក្រូហិរញ្ញវត្ថុត្រូវបានពង្រឹងដូចគ្នាផងដែរ។

### ៤.២.២. ការពង្រឹងការត្រួតពិនិត្យធនាគារ

ធនាគារជាតិនៃកម្ពុជាបានដាក់ចេញវិធានការ ដើម្បីពង្រឹងសមត្ថភាពត្រួតពិនិត្យក្នុងការធ្វើសវនកម្មធនាគារ តាមរយៈការកែលម្អការត្រួតពិនិត្យដល់ទីកន្លែង និងការត្រួតពិនិត្យលើឯកសារចំពោះធនាគារសាធារណៈធំៗ ក្នុងគោលដៅធានាឱ្យបាននូវការអនុវត្តយ៉ាងតឹងរ៉ឹងនូវវិធានការប្រុងប្រយ័ត្ន។ សមត្ថភាពត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានពង្រឹងលើទិដ្ឋភាពពីរ៖ (១) ការកែលម្អបទបញ្ញត្តិប្រុងប្រយ័ត្ន និង (២) ការពង្រឹងសមត្ថភាពត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា (ឆ្នាំ១៩៩៦) និងច្បាប់ស្តីពីគ្រឹះស្ថានហិរញ្ញវត្ថុនិងធនាគារ (ឆ្នាំ១៩៩៩) បានបង្កើតក្របខ័ណ្ឌគតិយុត្តិសម្រាប់ការត្រួតពិនិត្យធនាគារ។ ក្នុងឆ្នាំ២០០០ ធនាគារជាតិនៃកម្ពុជាបានអនុមតិជាបន្តបន្ទាប់នូវប្រកាសស្តីពីការពង្រឹងការអនុវត្តវិធានការប្រុងប្រយ័ត្ន រួមមាន សារាចរស្តីពីសាធនភាព មូលធនអប្បបរមា សន្ទីយភាព ហានិភ័យធំ ចំណាត់ថ្នាក់ទ្រព្យសកម្ម និងសំវិធានធន ការដាក់កំហិតលើការផ្តល់កម្ចីជូនភាគីពាក់ព័ន្ធ និងលទ្ធកម្មនៃទ្រព្យសកម្ម។ ធនាគារជាតិនៃកម្ពុជាក៏បានអនុមតិផងដែរនូវបទបញ្ញត្តិ ដែលតម្រូវឱ្យធនាគារពាណិជ្ជអនុវត្តនូវវិធានការកែតម្រូវភ្លាមៗ វិធានការខាងផ្នែកវិន័យ ចំពោះធនាគារណាដែលគ្មានមូលធនអប្បបរមាគ្រប់គ្រាន់ និងនីតិវិធីស្តីពីការត្រួតពិនិត្យដល់ទីកន្លែង និងការត្រួតពិនិត្យលើឯកសារ។

ក្នុងខែកុម្ភៈឆ្នាំ២០០២ ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការ ដើម្បីពង្រឹងបទបញ្ញត្តិប្រុងប្រយ័ត្នសម្រាប់ស្ថាប័នមីក្រូហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជាបានកំណត់ចំនួនប្រាក់ចំណូលអប្បបរមា ដែលតម្រូវឱ្យស្ថាប័នមីក្រូហិរញ្ញវត្ថុត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណ ដើម្បីអនុវត្តសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ៤.២.៣. ឯកជនភាវូបនីយកម្មនៃធនាគារពាណិជ្ជកម្មក្រៅប្រទេស

កំណែទម្រង់រចនាសម្ព័ន្ធនៃប្រព័ន្ធធនាគារបានឈានដល់ចំណុចកំពូលមួយ ជាមួយនឹងការធ្វើឯកជនភាវូបនីយកម្មនៃធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB) ដែលត្រូវបានបង្កើតឡើងក្នុងទសវត្សរ៍ទី១៩៨០ ជានាយកដ្ឋានមួយរបស់ធនាគារជាតិនៃកម្ពុជា ទទួលបន្ទុកខាងផ្នែកប្រតិបត្តិការហិរញ្ញវត្ថុអន្តរជាតិ។ ដើម្បីបង្កើតប្រព័ន្ធធនាគារពីរជាន់ ធនាគារពាណិជ្ជកម្មក្រៅប្រទេសត្រូវបានបំបែកចេញពីធនាគាជាតិនៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្ពុជា ក្នុងខែសីហាឆ្នាំ២០០០។ **ធនាគារពាណិជ្ជកម្មក្រៅប្រទេស**ត្រូវបង្កើតក្រុមប្រឹក្សាភិបាល និងបង្កើនមូលធនដើម្បីធ្វើប្រតិបត្តិការជាធនាគាររដ្ឋ។ ក្នុងខែមិថុនាឆ្នាំ២០០១ **ធនាគារជាតិកម្ពុជា**បានបង្កើនមូលធនឱ្យដល់ចំនួន ១៣លានដុល្លារអាមេរិក ពោលគឺតម្រូវឱ្យធនាគារពាណិជ្ជទាំងអស់គោរពទៅតាមវិធានការប្រុងប្រយ័ត្ន។

ម៉្យាងវិញទៀត ដើម្បីបំបែកមុខងារធនាគារពាណិជ្ជចេញពីធនាគារជាតិនៃកម្ពុជា នោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទិញយកភាគហ៊ុនរបស់ FTB ចំនួន ៨០% នៅក្នុងខែមេសាឆ្នាំ២០០២ ដែលនាំឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានក្លាយជាម្ចាស់ភាគហ៊ុនភាគច្រើនរបស់ធនាគារនេះ។ បន្ទាប់មក ក្នុងខែមករា ឆ្នាំ២០០៣ រាជរដ្ឋាភិបាលបានដាក់ឱ្យដេញថ្លៃ ដើម្បីរកដៃគូយុទ្ធសាស្ត្រសម្រាប់ឯកជននីយកម្មនៃធនាគារ FTB។ ធនាគារពាណិជ្ជកម្មក្រៅប្រទេសត្រូវបានធ្វើឯកជននីយកម្ម ដោយរដ្ឋាភិបាលបានក្លាយជាម្ចាស់ភាគហ៊ុនតូចតាចប៉ុណ្ណោះ ក្នុងធនាគារពាណិជ្ជកម្មក្រៅប្រទេសនេះ។

## ៤.៣. ស្ថាបត្យកម្មបច្ចុប្បន្ននៃប្រព័ន្ធធនាគារកម្ពុជា

### ៤.៣.១. លក្ខណៈពិសេសសំខាន់ៗនៃប្រព័ន្ធធនាគារកម្ពុជា

វិស័យហិរញ្ញវត្ថុនៅកម្ពុជា គឺមានភាពរស់រវើក ប្រកួតប្រជែង និងកំពុងរីកលូតលាស់យ៉ាងឆាប់រហ័ស។ កំណើនដ៏ឆាប់រហ័សនៃប្រាក់បញ្ញើនៅតាមធនាគារពាណិជ្ជនិងក្នុងអនុវិស័យ (សូមមើលតារាង៤.១) បង្ហាញឱ្យឃើញនូវជំនឿទុកចិត្តពីសាធារណជនកាន់តែខ្លាំង ទៅលើវិស័យនេះ ដោយសារតែតម្លាភាពនៃគោលនយោបាយវិស័យហិរញ្ញវត្ថុ និងការធានាភាពស្មើភាពសម្រាប់អ្នកវិនិយោគទុនក្នុងវិស័យនេះ។ តែទោះជាយ៉ាងណាក្តី វិស័យនេះនៅកំពុងអភិវឌ្ឍនៅឡើយ និងខ្វះខាតលក្ខណៈពិសេសជាច្រើននៃហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុមួយដែលជឿនលឿន។

ថ្វីត្បិតតែ ផសស ពិតបានកើនឡើងជាប្រចាំ ក៏ប៉ុន្តែកំណើនក្នុងវិស័យកសិកម្មយឺតជាងវិស័យឧស្សាហកម្មនិងវិស័យសេវាកម្ម។ អាត្រាការប្រាក់សម្រាប់កម្ចីជាប្រាក់ដុល្លារអាមេរិក (ជាចម្បងផ្នែកពាណិជ្ជកម្មនិងទីក្រុង) និងកម្ចីប្រាក់រៀលបានធ្លាក់ចុះ។ អាត្រាការប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុបានធ្លាក់ចុះមកនៅ ៣៦% ក្នុងមួយឆ្នាំកាលពីពេលថ្មីៗនេះ ដោយសារការប្រកួតប្រជែងបានកើនឡើង។ សូចនាករសំខាន់ៗពាក់ព័ន្ធនឹងឥណទាន និងកម្ចីវិស័យឯកជនបានបង្ហាញពីកំណើនដ៏ខ្លាំង ជាអាទិ៍ចំនួនកម្ចី និងបរិមាណសរុប ដែលធនាគារពាណិជ្ជនិងស្ថាប័នមីក្រូហិរញ្ញវត្ថុឱ្យអតិថិជនខ្ចី។

ប្រព័ន្ធធនាគាររបស់កម្ពុជាមានសមាសភាពដូចតទៅ៖ (ត្រឹមខែធ្នូឆ្នាំ២០០៨)

- ធនាគារជាតិនៃកម្ពុជា (NBC) ដែលជានិយ័តករនៃវិស័យធនាគារ
- ធនាគារពាណិជ្ជចំនួន២៤ ដែលជាកម្មសិទ្ធិរបស់វិនិយោគិនឯកជនរួមមាន៖ ធនាគារពាណិជ្ជចំនួន ២១ ដែលបង្កើតឡើងតាមច្បាប់កម្ពុជា និងសាខាធនាគារបរទេសចំនួន៣
- ធនាគារឯកទេសចំនួន៦ រួមទាំងធនាគាររដ្ឋមួយ
- ការិយាល័យដំណាងពីរនៃធនាគារបរទេសគឺ Vietnamese Bank for Agriculture and Rural Development និងធនាគារ Standard Chartered



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) ដែលមានអាជ្ញាប័ណ្ណ ចំនួន១៨
- សាខាធនាគារជាតិនៃកម្ពុជានៅតាមខេត្ត ចំនួន២១
- អង្គការក្រៅរដ្ឋាភិបាលខាងផ្នែកមីក្រូហិរញ្ញវត្ថុ ដែលចុះបញ្ជីចំនួន ២៦ និងអង្គការក្រៅរដ្ឋាភិបាល ដែលមិនបានចុះបញ្ជីមានចំនួនប្រហែល ៦០ និង
- អាជីវករប្តូរប្រាក់ដែលចុះបញ្ជីចំនួន ៨,៣២០។

ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាបានរីកចម្រើនយ៉ាងឆាប់រហ័ស ដោយមានការចូលរួមដ៏សកម្មពីវិស័យឯកជន។ ការអភិវឌ្ឍបែបនេះអាចសម្រេចឡើងបាន បន្ទាប់ពីកម្ពុជាមានស្ថេរភាពនយោបាយ និងសេដ្ឋកិច្ច និងបន្ទាប់ពីកម្ពុជាបានរៀបចំនូវក្របខ័ណ្ឌគតិយុត្តិ និងនិយតកម្ម ដែលជួយគាំទ្រដល់ការប្រព្រឹត្តិទៅ និងការពង្រីកវិស័យហិរញ្ញវត្ថុ។

ជាទូទៅ ធនាគារស្ថិតក្នុងស្ថានភាពល្អក្នុងឆ្នាំ២០០៨ ដោយមានអនុបាតនៃភាពគ្រប់គ្រាន់នៃដើមទុនចំនួន២៨% បើប្រៀបធៀបទៅនឹង២៤% ក្នុងឆ្នាំ២០០៧។ អនុបាតនេះខ្ពស់ជាងអនុបាតគោលចំនួន ១៥% ដែលធនាគារកណ្តាលបានកំណត់ពោលគឺខ្ពស់ជាងប្រមាណជា១៣ភាគរយ។អនុបាតសាច់ប្រាក់ងាយស្រួលបានធ្លាក់ចុះពី១០៨% ក្នុងឆ្នាំ២០០៧ មកត្រឹម៨១% ក្នុងឆ្នាំ២០០៨។ អនុបាតឥណទានមិនដំណើរការសម្រេចបាន ៣,៧% បើប្រៀបធៀបទៅនឹង៣,៤%ក្នុងឆ្នាំ២០០៧ និង៩,៩%ក្នុងឆ្នាំ ២០០៦។ទ្រព្យសកម្មសរុបនៃប្រព័ន្ធធនាគារបានកើនឡើង២៦%។ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៧ ឥណទានសរុបដែលផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុនិងធនាគារបានកើនពី ៦.៣៣៦ពាន់លានរៀល ទៅដល់ ៩.៨៣២ ពាន់លានរៀល (២,៤១ពាន់លានដុល្លារអាមេរិក) ឬ៥៥%។ នៅរយៈពេលដូចគ្នានេះ ប្រាក់បញ្ញើសរុបរបស់និវាសនជន និងអនិវាសនជនបានកើនឡើងពី៩.៩២២ពាន់លានរៀល ទៅដល់១០,២៨៧ពាន់លានរៀល (២,៥២ពាន់លានដុល្លារអាមេរិក) ឬ ៣,៧%។ ក្នុងត្រីមាសទីបីនៃឆ្នាំ២០០៨ ល្បឿននៃកំណើននៃប្រាក់បញ្ញើរបស់អតិថិជនបានថយចុះគួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងឆ្នាំមុន។ ការធ្លាក់ចុះនេះ គឺជាលទ្ធផលមួយនៃវិបត្តិសេដ្ឋកិច្ចពិភពលោក។

ក្នុងឆ្នាំ២០០៨ វិស័យមីក្រូហិរញ្ញវត្ថុបានរីកចម្រើនយ៉ាងឆាប់រហ័ស។ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិង**ប្រតិបត្តិករឥណទានជនបទបានផ្តល់ឥណទានសរុប ដែលមានទឹកប្រាក់ដ៏ច្រើនលើសលុប ចំនួន១,១៣០ ពាន់លានរៀល (២៧៤លានដុល្លារ) ដល់អ្នកខ្ចីប្រាក់ចំនួន ៨៥២,០៩០នាក់។ ប្រការនេះឆ្លុះបញ្ចាំងនូវកំណើននៃឥណទានចំនួន ៨១% និងកំណើននៃអ្នកខ្ចីប្រាក់ចំនួន៣៦% បើប្រៀបធៀបទៅនឹងឆ្នាំ២០០៧។ ទន្ទឹមនឹងនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើនិងប្រតិបត្តិករឥណទានជនបទបានប្រមូលប្រាក់បញ្ញើបានចំនួន២៦ពាន់លានរៀល (៥,៤លានដុល្លារ) ពីអ្នកផ្ញើប្រាក់ចំនួន១៥៥.២៩១នាក់ ដែលឆ្លុះបញ្ចាំងនូវកំណើនចំនួន៧% និង៥% រៀងគ្នា បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០៧។អនុបាតនៃភាពគ្រប់គ្រាន់នៃដើមទុនសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរក្សាបាន២០% ខ្ពស់ជាងវិធានការប្រុងប្រយ័ត្នចំនួន១៥%។ អនុបាតឥណទានមិនដំណើរការសម្រេចបាន១%។ សូចនាករដូចនេះបង្ហាញពីកំណើននៃអន្តរការីកម្មហិរញ្ញវត្ថុនៅតំបន់ជនបទ និងការកើនឡើងនៃជំនឿជឿជាក់របស់វិនិយោគិន ក្នុងផ្នែកហិរញ្ញវត្ថុជនបទនៅកម្ពុជា ដែលជាលទ្ធផលនៃស្ថេរភាពនយោបាយនិងសេដ្ឋកិច្ច។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធនាគារជាតិនៃកម្ពុជាក៏បានដាក់ចេញនូវវិធានការកសាងសមត្ថភាព ដែលមានគោលដៅអនុវត្តយ៉ាងហ្មឹងម៉ាត់នូវវិធាន និងបទបញ្ញាផ្សេងៗរបស់ខ្លួន ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័នក្នុងស្រុកនិងអន្តរជាតិ។ កិច្ចសហប្រតិបត្តិការនេះផ្តោតលើ ការផ្តល់ជំនួយបច្ចេកទេស ដែលរួមមាន៖ ជំនួយបណ្តុះបណ្តាលបុគ្គលិកក្នុងការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពនៃបទដ្ឋានគតិយុត្តិចាស់ៗ និងដែលមានស្រាប់ ឬការចេញបទបញ្ញាថ្មីៗ ដោយធ្វើការពិចារណាទៅលើបទពិសោធន៍ និងការអនុវត្តល្អរបស់ប្រទេសនានាក្នុងសកលលោក ជាពិសេសគោលការណ៍ជាមូលដ្ឋាននៃការត្រួតពិនិត្យធនាគារដ៏មានប្រសិទ្ធភាព។

ធនាគារក្នុងស្រុកចំនួន៤ រួមមាន៖ ធនាគារកាណាឌីយ៉ា ភីអិលស៊ី Union Commercial Bank, Singapore Banking Corporation និងធនាគារមេគង្គបានសហការគ្នាក្នុងឆ្នាំ២០០៨ ដើម្បីដាក់ឱ្យប្រើប្រាស់នូវសេវា Easy Cash និងសេវាកម្មធនាគារអេឡិចត្រូនិចនៅក្នុងទីផ្សារ ក្នុងគោលដៅសម្រួលដល់ការដកសាច់ប្រាក់តាមម៉ាស៊ីនស្វ័យប្រវត្តិរួមគ្នា និងការទូទាត់ប្រាក់តាមវិធីអេឡិចត្រូនិច។ នៅចុងឆ្នាំ២០០៨វិស័យធនាគារមានម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិចំនួន ៣១៣កន្លែង នៅទូទាំងប្រទេស។ នវានុវត្តន៍នេះ គឺជាលទ្ធផលនៃការបង្កើតឡើងនូវបរិយាកាសប្រកួតប្រជែងយ៉ាងល្អ ដែលធនាគារជាតិនៃកម្ពុជាបានលើកទឹកចិត្តយ៉ាងសកម្ម។

ក្នុងគោលដៅចែករំលែកព័ត៌មានឥណទានស្តីពីអ្នកដែលគ្មានលទ្ធភាពសងបំណុល ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមគំនិតកែលម្អនូវប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (CIS) ដែលបច្ចុប្បន្នកំពុងត្រូវបានប្រើប្រាស់ដោយគ្រឹះស្ថានធនាគារ។ គេរំពឹងថាវិធានការទាំងនេះនឹងអាចឱ្យអ្នកឱ្យខ្ចីធ្វើការផ្តល់ជូនឥណទានបានកាន់តែលឿន ជូនអតិថិជនដែលគ្មានប្រវត្តិអាក្រក់។ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀងមួយជាមួយនឹងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដើម្បីផ្តួចផ្តើមការសិក្សាមួយស្តីពីប្រព័ន្ធចែករំលែកព័ត៌មានឥណទានបច្ចុប្បន្ន និងការសិក្សាលទ្ធភាពបង្កើតការិយាល័យឥណទានឯកជននៅកម្ពុជា។

ប្រព័ន្ធធនាគារកម្ពុជាមានលក្ខណៈសំខាន់ៗដូចតទៅ៖

- ដុល្លារូបនីយកម្មកម្រិតខ្ពស់ និងអនុបាតសាច់ប្រាក់ងាយស្រួលខ្ពស់ ដោយសារតែគ្មានប្រព័ន្ធទូទាត់ជាតិ និងសេវាកម្មហិរញ្ញវត្ថុនៅតំបន់ជនបទ ដែលមិនសូវសម្បូណ៌បែប
- អវត្តមាននៃប្រព័ន្ធទូទាត់ជាតិមានន័យថា ធនាគារពាណិជ្ជត្រូវតែធ្វើការផ្ទេរប្រាក់ជារូបីយប័ណ្ណជាតិតាមរយៈបណ្តាញធនាគាររបស់គេ ឬគណនីរបស់គេនៅធនាគារជាតិនៃកម្ពុជា។ ការផ្ទេរប្រាក់ជាអន្តរជាតិត្រូវបានធ្វើឡើង តាមរយៈធនាគារឆ្លើយឆ្លងនៅបរទេស ឬតាមរយៈគណនីរបស់គេនៅធនាគារជាតិនៃកម្ពុជា
- បណ្តាញធនាគារពាណិជ្ជត្រូវបានបង្កើតឡើងតែនៅក្នុងទីប្រជុំជនតែប៉ុណ្ណោះ
- អន្តរការីកម្មហិរញ្ញវត្ថុកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ក៏ប៉ុន្តែស្ថិតនៅក្នុងភាពក្មេងខ្ចីនៅឡើយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### គំនូសតាង៤.១. សូចនាករសំខាន់ៗនៃវិស័យហិរញ្ញវត្ថុ

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 |
|---|---|---|---|---|---|---|---|---|
| ផសស ពិត (%) | 8,8 | 8,1 | 6,6 | 8,5 | 10,3 | 13,3 | 10,8 | 10,2 |
| -កសិកម្ម | 35,9 | 34,3 | 31,1 | 32,0 | 29,4 | 30,7 | 30,1 | 29,7 |
| -ឧស្សាហកម្ម | 21,9 | 22,3 | 24,3 | 25,0 | 25,6 | 25,0 | 26,2 | 24,9 |
| -សេវាកម្ម | 37,1 | 38,4 | 39,3 | 38,2 | 39,3 | 39,1 | 38,7 | 38,5 |
| អតិផរណា (ប្រចាំឆ្នាំ) | (0,8) | (0,9) | (0,1) | 1,2 | 3,9 | 3,9 | 4,7 | 5,8 |
| អត្រាការប្រាក់ (ដុល្លារ) | | | | | | | | |
| - បញ្ញើសន្សំ | 2,3 | 1,6 | 1,5 | 1,3 | 0,9 | 0,9 | 1,0 | 1,0 |
| - បញ្ញើមានកាលកំណត់ | 3,7 | 2,7 | 2,8 | 2,6 | 2,4 | 2,4 | 3,3 | 4,9 |
| - កម្ចី | 17,4 | 15,0 | 18,6 | 18,2 | 17,3 | 17,3 | 16,2 | 16,0 |
| រូបិយវត្ថុទូលាយ (%) | | | | | | | | |
| -រូបិយវត្ថុទូទៅ (M2) | 26,9 | 20,4 | 31,1 | 15,3 | 30,0 | 16,1 | 38,2 | 62,9 |
| -Vélocité | 7,9 | 7,7 | 6,4 | 6,0 | 5,4 | 5,4 | 4,8 | 3,1 |
| -(PIB/M2) | 12,6 | 13,0 | 15,6 | 16,5 | 18,6 | 18,7 | 20,8 | 32,3 |
| ឥណទានវិស័យឯកជន | | | | | | | | |
| -ឥណទាន | 6,4 | 6,0 | 6,3 | 7,3 | 8,6 | 9,4 | 12,3 | 18,3 |
| -បញ្ញើ | 9,5 | 10,4 | 12,7 | 13,3 | 15,2 | 14,8 | 18,2 | 26,8 |
| ផលធៀបឥណទាន/ បញ្ញើ | 67,3 | 57,6 | 49,9 | 55,2 | 56,5 | 64,0 | 67,9 | 63,9 |
| ឥណទាន/ទ្រព្យសកម្ម | | | | | | 42,9 | 45,6 | 46,1 |
| ធនាគារពាណិជ្ជ | | | | | | | | |
| -ចំនួនឥណទាន | | | 86,757 | 105,347 | 123,937 | 145,161 | 164,931 | 197,337 |
| -តម្លៃ (លានដុល្លារ) | | | 269,3 | 360,7 | 482,7 | 598,4 | 882,3 | 2 480,0 |
| -ឥណទានមិនដំណើរការ | | 8,0 | 15,00 | 14,00 | 10,00 | 8,00 | 9,80 | 3,4 |
| មីក្រូហិរញ្ញវត្ថុ | | | | | | | | |
| -ចំនួនឥណទាន | | 409,963 | 328,295 | 265,044 | 322,056 | 366,962 | 471,009 | 624,089 |
| -តម្លៃ (លានដុល្លារ) | | 35,9 | 51,3 | 32,6 | 40,8 | 49,2 | 92,2 | 160,4 |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- កង្វះខាតនៃអន្តរការីយកម្មធនាគារ ដែលមានប្រសិទ្ធភាព ឬទីផ្សារប្តូរប្រាក់ និងឧបករណ៍នៃទីផ្សារប្តូរប្រាក់
- ហេដ្ឋារចនាសម្ព័ន្ធគតិយុត្តិ ដែលកំពុងតែរៀបចំ

ប្រព័ន្ធធនាគារកម្ពុជាដើរតួនាទីដ៏សំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា។ ដោយឆ្លុះបញ្ចាំងពីសារៈសំខាន់កាន់តែខ្លាំងឡើងនៃវិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចជាតិ អត្រានៃអន្តរការីកម្មហិរញ្ញវត្ថុក្នុងផលិតផលសរុបក្នុងស្រុកបានកើនឡើងពី០.៣% ក្នុងឆ្នាំ១៩៩៣ ទៅដល់១.៣% ក្នុងឆ្នាំ២០០៨។ ក្នុងមួយទសវត្សរ៍កន្លងទៅនេះ អន្តរការីយកម្មនៃវិស័យធនាគារមាន ១.១% នៃផសស ជាមធ្យម។

## ៤.៣.២. ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា គឺជានិយ័តករនៃប្រព័ន្ធធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារជាតិនៃកម្ពុជាមានបេសកកម្មចម្បងក្នុងការកំណត់ និងអនុវត្តគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងលើកកម្ពស់កំណើនសេដ្ឋកិច្ច។ ម៉្យាងវិញទៀត ធនាគារជាតិដើរតួនាទីជាសភាជាត់ទាត់ និងមជ្ឈមណ្ឌលព័ត៌មាន។ ធនាគារជាតិនៃកម្ពុជាមានមុខងារនិងភារកិច្ចចម្បងដូចតទៅ៖

- រៀបចំ និងអនុវត្តគោលនយោបាយរូបិយវត្ថុ ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលកម្ពុជា
- រៀបចំ និងអនុវត្តគោលនយោបាយប្តូរប្រាក់ និងត្រួតពិនិត្យការប្តូរប្រាក់
- ត្រួតពិនិត្យទីផ្សារហិរញ្ញវត្ថុ និងរូបិយវត្ថុ
- ត្រួតពិនិត្យប្រព័ន្ធទូទាត់ និងដាក់ចេញវិធានការកែលម្អប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ
- ផ្តល់សេវាកម្មពិសេសដល់រតនាគារជាតិ និង
- កំណត់អត្រាការប្រាក់។

### *៤.៣.២.១. ការត្រួតពិនិត្យធនាគារ និងការធានាស្ថេរភាពហិរញ្ញវត្ថុ*

ធនាគារជាតិនៃកម្ពុជាបំពេញតួនាទីជាអាណាព្យាបាលលើប្រព័ន្ធធនាគារ និងមានភារកិច្ចត្រួតពិនិត្យវិស័យធនាគារ តាមរយៈនាយកដ្ឋានត្រួតពិនិត្យធនាគាររបស់ខ្លួន។ ក្នុងគោលដៅត្រួតពិនិត្យធនាគារ និងធានាស្ថេរភាពហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាមានភារកិច្ចដូចខាងក្រោម ៖

- ផ្តល់ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- ផ្តល់ឬដកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ ទីផ្សារមូលប័ត្រត្បូងថ្ម និងលោហធាតុមានតម្លៃ
- ត្រួតពិនិត្យគ្រឹះស្ថានខាងលើ ដើម្បីឱ្យគ្រឹះស្ថានទាំងនេះប្រតិបត្តិតាមច្បាប់ និងបទបញ្ញាជាធរមាន តាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង
- រៀបចំនិងធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យធនាគារនិងហិរញ្ញវត្ថុ
- ធានានូវប្រតិបត្តិការយ៉ាងរលូននិងសន្តិសុខនៃប្រព័ន្ធទូទាត់ និងការជាត់ទាត់នៃឧបករណ៍ហិរញ្ញវត្ថុ
- ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិ។

#### ៤.៣.២.២. ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

ធនាគារជាតិនៃកម្ពុជាកាន់កាប់ និងគ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់រដ្ឋ ក្នុងទម្រង់ជាដុំមាសនិងរូបិយប័ណ្ណបរទេស។ ធនាគារជាតិក៏អាចធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់ផងដែរ។ ជាក់ស្តែង ទ្រព្យសកម្មបរទេសសុបរបស់គ្រឹះស្ថានរូបិយវត្ថុបានកើនឡើងពី៣០លានដុល្លារអាមេរិក ក្នុងខែធ្នូឆ្នាំ១៩៩៣ ដល់១ពាន់លានដុល្លារក្នុងខែធ្នូឆ្នាំ២០០៣ បន្ទាប់មកស្ទុះដល់២.៧ពាន់លានដុល្លារអាមេរិកក្នុងខែធ្នូឆ្នាំ២០០៧ រួចមកក៏ធ្លាក់ចុះមកត្រឹម ២.៥ពាន់លានដុល្លារអាមេរិក ក្នុងខែធ្នូឆ្នាំ២០០៨ ដោយសារតែវិបត្តិហិរញ្ញវត្ថុ។

ទុនបម្រុងអន្តរជាតិដុលបានកើនពី៧០លានដុល្លារអាមេរិក ក្នុងខែធ្នូឆ្នាំ១៩៩៣ ដល់២.១ពាន់លានដុល្លារអាមេរិក ក្នុងខែធ្នូឆ្នាំ២០០៨ ដោយសារតែកំណើនយ៉ាងគំហុកនៃការនាំចេញ និងការវិនិយោគទុនផ្ទាល់ពីបរទេស។

#### ៤.៣.២.៣. ការងារស្ថិតិនិងការស្រាវជ្រាវ

ធនាគារជាតិនៃកម្ពុជាមានភារកិច្ចៈ

- ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុនៅកម្ពុជា
- រៀបចំតារាងជញ្ជីងទូទាត់និងស្ថានភាពទំនាក់ទំនងបរទេសនៃប្រទេសកម្ពុជា
- រៀបចំតារាងស្ថិតិហិរញ្ញវត្ថុនិងរូបិយវត្ថុ។

#### ៤.៣.២.៤. ការផ្តល់សេវាកម្មពិសេសដល់រតនាគារជាតិ

ធនាគារជាតិនៃកម្ពុជាធ្វើការចុះបញ្ជីកាគណនេយ្យសម្រាប់រតនាគារជាតិ ដែលជាផ្នែកមួយនៃប្រព័ន្ធគណនេយ្យទោលរបស់រតនាគារជាតិ។ ធនាគារជាតិនៃកម្ពុជាទទួលភារៈផ្តាច់មុខ ក្នុងការទទួលប្រាក់បញ្ញើរបស់រតនាគារជាតិ។ ធនាគារជាតិចុះបញ្ជីកានៃប្រាក់បញ្ញើ និងការដកសាច់ប្រាក់ទាំងអស់សម្រាប់រតនាគារជាតិ ព្រមទាំងកត់ត្រានូវរាល់ចំណូលថវិកាជាតិ ដែលជាគណនីទោលនៃរតនាគារជាតិ។

ធនាគារជាតិនៃកម្ពុជាមានសិទ្ធិផ្តល់បុនហិរញ្ញប្បទានដល់រតនាគារជាតិ ជាបណ្តោះអាសន្ន សម្រាប់រយៈពេលមួយមិនលើសពី៣ខែ តាមអត្រាបុនហិរញ្ញប្បទាន។ ធនាគារជាតិនៃកម្ពុជាមិនផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ឬដោយប្រយោលដល់រដ្ឋាភិបាលឡើយ ជាពិសេសតាមរយៈការជាវមូលប័ត្រ ដែលរាជរដ្ឋាភិបាល ឬគ្រឹះស្ថានសាធារណៈបានបោះផ្សាយជាលើកតំបូង ឬផ្តល់ការធានា។

### ៤.៣.៣. ធនាគារពាណិជ្ជសកល និងធនាគារឯកទេស

ធនាគារពាណិជ្ជសកលអាចធ្វើបាននូវអន្តរការិយកម្មហិរញ្ញវត្ថុ តាមរយៈការទទួលប្រាក់បញ្ញើ និងការបែងចែកឥណទានដល់អតិថិជនរបស់ខ្លួន នៅលើទីផ្សារមួយដែលបើកចំហរនិងប្រកួតប្រជែង។ គ្រឹះស្ថានធនាគារភាគច្រើនមានមូលធនលើសពី១៣លានដុល្លារអាមេរិក ហើយមូលធនអប្បបរមានេះត្រូវបានបង្កើនឡើងដល់ ៣៦.៥លានដុល្លារអាមេរិក។

ធនាគារឯកទេសត្រូវបានបង្កើតឡើង ក្នុងគោលដៅផ្តលឥណទានរយៈពេលមធ្យមនិងវែង ដែលមានប្រភពមកពីមូលនិធិផ្ទាល់របស់ខ្លួន ឬពីធនធានកម្ចីផ្ទៃក្នុងនិងពីបរទេស។ ធនាគារឯកទេសមិនអាចទទួល

ប្រាក់បញ្ញើពីនិវាសនជនបានឡើយ។ មូលធនអប្បបរមាសម្រាប់ធនាគារឯកទេសត្រូវបានកំណត់ត្រឹមចំនួន ៣.៥លានដុល្លារអាមេរិក តែបន្ទាប់មកត្រូវបានបង្កើនឡើងដល់៧.៣លានដុល្លារអាមេរិក។

## ៤.៣.៤. បទប្បញ្ញត្តិធនាគារនិងការត្រួតពិនិត្យ

ជំពូកទី១២នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានចែងថា ធនាគារកណ្តាលត្រូវបំពេញតួនាទីជាអាណាព្យាបាលលើប្រព័ន្ធធនាគារ និងលើសកម្មភាពពាក់ព័ន្ធ។ ដោយអនុវត្តនូវតួនាទីនេះ ធនាគារជាតិនៃកម្ពុជាចេញអាជ្ញាប័ណ្ណ និងចេញបទបញ្ជា ដើម្បីអនុវត្តច្បាប់នេះ ដែលអនុញ្ញាតឱ្យកំណត់វិធានការប្រុងប្រយ័ត្ន រួមមាន៖ (១) កម្រិតមូលធនអប្បបរមា (២) អនុបាត ឬមេគុណប្រុងប្រយ័ត្នផ្សេងៗ ដែលពាក់ព័ន្ធនឹងសាច់ប្រាក់ងាយស្រួល សាធនភាព ការបែងចែកហានិភ័យ និងការប្រឈមទៅនឹងហានិភ័យនៃការប្តូរប្រាក់ ឬនៃទីផ្សារ និង (៣) បំណុលដែលត្រូវបានចាត់ទុកជាការបាត់បង់ និងការធ្វើសំវិធានធន។

កំណែទម្រង់និងការច្របាច់បញ្ចូលគ្នានៃធនាគារក្នុងអំឡុងឆ្នាំ២០០២-២០០៦ មានគោលដៅពង្រឹងសមត្ថភាព និងប្រសិទ្ធភាពហិរញ្ញវត្ថុនៃប្រព័ន្ធធនាគារ។ កំណែទម្រង់នេះមានគោលដៅអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវបទបញ្ញត្តិ ដែលស្តែងចេញក្នុងរូបភាពបីសំខាន់ៗគឺ៖ សាធនភាព សាច់ប្រាក់ងាយស្រួល និងការបែងចែកនៃហានិភ័យ។

ធនាគារកណ្តាលមានភារកិច្ចតម្រូវឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរក្សាបានខ្ជាប់ខ្ជួននូវកម្រិតនៃទុនបម្រុងកាតព្វកិច្ច។ ទុនបម្រុងកាតព្វកិច្ចនេះត្រូវបានរក្សាក្នុងទម្រង់ ជាមូលនិធិពិសេសឬប្រាក់បញ្ញើក្នុងគណនីចរន្តរបស់ធនាគារកណ្តាល។

### ៤.៣.៤.១. *សាធនភាព*

អនុបាតហានិភ័យ ឬ អនុបាត COOKE ត្រូវបានកំណត់ចំនួន១៥% ចាប់តាំងពីឆ្នាំ២០០៥។ ដូច្នេះអនុបាតសាធនភាពរវាងមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារនីមួយ និងហានិភ័យឥណទានសរុបមិនត្រូវឱ្យតិចជាង១៥%ឡើយ។ អនុបាតនេះមានសារៈសំខាន់ណាស់ ដើម្បីធានាសន្តិសុខនៃប្រព័ន្ធធនាគារ ដោយធានាបានថា ប្រសិនបើអ្នកខ្ចីប្រាក់គ្មានលទ្ធភាពសងឥណទានវិញ វានឹងមិនបណ្តាលឱ្យមានប្រតិកម្មជាខ្សែសង្វាក់ដែលនឹងធ្វើឱ្យធនាគារពាណិជ្ជនោះក្ស័យធនឡើយ។

### ៤.៣.៤.២. *សាច់ប្រាក់ងាយស្រួល*

អនុលោមតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៧ខែកុម្ភៈឆ្នាំ២០០០ស្តីពីចំណាត់ថ្នាក់និងសំវិធានធនលើបំណុលអាក្រក់និងបំណុលសង្ស័យ ធនាគារត្រូវធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មរបស់ខ្លួនចំពោះអតិថិជនគ្រប់ប្រភេទ លើកលែងតែបំណុលចំពោះធនាគារកណ្តាល។ ធនាគារនីមួយៗត្រូវធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនជាបួនប្រភេទ គឺ៖ បំណុលស្តង់ដារ បំណុលក្រោមស្តង់ដារ បំណុលសង្ស័យ និងបំណុលបាត់បង់ ដែលឆ្លុះបញ្ចាំងពីកម្រិតនៃហានិភ័យនៃការមិនអាចសងឥណទាន (សូមមើលប្រអប់ ៤.១ និងតារាង៤.២)។

### ៤.៣.៤.៣. ការបែងចែកហានិភ័យ

វិធានបីដែលត្រូវតែគោរពតាមគឺ៖

- ការកំណត់ហានិភ័យចំពោះអតិថិជនធំៗ (ហានិភ័យធំ)៖ ធនាគារពាណិជ្ជមិនត្រូវផ្តល់ឥណទានឱ្យអត្តគាហក ជាឯកត្តជន ឬនីតិបុគ្គលលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន (មាត្រា១នៃប្រកាស ចុះថ្ងៃទី៣ខែវិច្ឆិកាឆ្នាំ២០០៦ ស្តីពីការត្រួតពិនិត្យនៃហានិភ័យធំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ)។
- ការកំណត់ហានិភ័យចំពោះអត្តគាហកនីមួយៗ មិនត្រូវលើសពី២៥% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ (មាត្រា២នៃប្រកាស)។
- ការកំណត់ហានិភ័យចំពោះបុគ្គលសម្ព័ន្ធនិងសម្ព័ន្ធញ្ញាតិ សម្រាប់គ្រឹះស្ថានគោលដៅមួយ (ឥណទានផ្តល់ឱ្យភាគីពាក់ព័ន្ធ) (សមាជិកក្រុមប្រឹក្សាភិបាល នាយក ម្ចាស់ភាគហ៊ុន និងសវនករ)៖ ធនាគារត្រូវកំណត់ឥណទានចំពោះភាគីពាក់ព័ន្ធ មិនឱ្យលើសពី១០% នៃមូលនិធិ ផ្ទាល់សុទ្ធរបស់ធនាគារ (មាត្រា ៤នៃប្រកាសចុះថ្ងៃទី១៥ខែតុលាឆ្នាំ២០០១ ស្តីពីឥណទានដែលផ្តល់ឱ្យភាគីពាក់ព័ន្ធ)។

*តារាង៤.២. ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មនិងសំវិធានធន*

| ចំណាត់ថ្នាក់ | ការទូទាត់ | ស្ថានភាពហិរញ្ញវត្ថុ |
|---|---|---|
| ធម្មតា | -ទូទាត់ទៀងទាត់<br>-សំវិធានធន:1%នៃឥណទានដុល | - ស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ។ |
| ឃ្លាំមើល | -30 ថ្ងៃ<យឺតយ៉ាវក្នុងការទូទាត់< 90 ថ្ងៃ<br>-សំវិធានធន: 3% នៃឥណទានដុល | -គុណភាពទ្រព្យសកម្មចុះខ្សោយ ឬ និន្នាការចុះខ្សោយនៃស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី។ |
| ក្រោមស្តង់ដារ | -90 ថ្ងៃ<យឺតយ៉ាវក្នុងការទូទាត់< 180 ថ្ងៃ<br>-សំវិធានធន: 20% នៃឥណទានដុល | ទ្រព្យសកម្មមិនត្រូវបានការពារគ្រប់គ្រាន់ ដោយទ្រព្យសម្បត្តិ និងសមត្ថភាពសងបំណុលរបស់សមភាគី ។ ប្រភពធនធានសងបំណុល មានមិនគ្រប់គ្រាន់។ ធនាគារត្រូវតែសម្លឹងមើលប្រភពធនធានបន្ទាប់ ដូចជាវត្ថុបញ្ចាំ ការលក់អចលនទ្រព្យ បុនហិរញ្ញប្បទាន ឬក៏ការបំពេញធនធានបន្ថែមសម្រាប់ទូទាត់បំណុល។ |
| សង្ស័យ | -180 ថ្ងៃ<យឺតយ៉ាវក្នុងការទូទាត់<មួយឆ្នាំ<br>-សំវិធានធន: 50% នៃឥណទានដុល | លក្ខខណ្ឌនៃឥណទានមិនមានធានាបានល្អ ហើយនាំឱ្យមានការសង្ស័យថា ឥណទានមិនអាចប្រមូលបានមកវិញទាំងស្រុង។ |
| បាត់បង់ | -360 ថ្ងៃ<យឺតយ៉ាវក្នុងការទូទាត់<br>-សំវិធានធន: 100% នៃឥណទានដុល | ទ្រព្យសកម្មទាំងឡាយណា ដែលត្រូវបានចាត់ទុកថាមិនអាចប្រមូលមកវិញបាន ឬនៅមានតម្លៃតិចតួច។ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រឹះធនាគារនិងហិរញ្ញវត្ថុត្រូវគោរពតាមបទបញ្ញា ប្រកាស និងសារាចររបស់ធនាគារជាតិនៃកម្ពុជា ដែលតម្រូវឱ្យគ្រឹះស្ថានទាំងនេះ ផ្តល់របាយការណ៍ហិរញ្ញវត្ថុ និងចុះបញ្ជិកាគណនី ដែលពាក់ព័ន្ធនឹងមូលធនអប្បបរមា កម្រិតអប្បបរមានៃមូលនិធិផ្ទាល់ខ្លួនសុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការហាមឃាត់ ការរឹតបន្តឹង ការដាក់លក្ខខណ្ឌ និងប្រកាសផ្សេងៗទៀត។

ប្រកាសរបស់ធនាគារជាតិនៃកម្ពុជា គឺជាយន្តការសម្រាប់ពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង។ ប្រកាសទាំងនេះតម្រូវឱ្យធនាគារពាណិជ្ជពង្រឹងនិងកែលម្អវិធីសាស្ត្រ ក្នុងការវាយតម្លៃហានិភ័យ ធ្វើចំណាត់ថ្នាក់ឥណទានចំពោះប្រភេទអ្នកខ្ចីផ្សេងៗគ្នា ត្រួតពិនិត្យហានិភ័យរបស់គេ និងវាយតម្លៃពីសង្គតិភាពរវាងហានិភ័យ និងនៃមូលធនផ្ទាល់ខ្លួនសុទ្ធរបស់គេ។

វិធានប្រុងប្រយ័ត្នជាធរមានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គិតបញ្ចូលអចលនទ្រព្យនិងវត្ថុបញ្ចាំផ្នែកហិរញ្ញវត្ថុ ក្នុងការកំណត់បរិមាណនៃសំវិធានធនដែលត្រូវការ ដើម្បីសងបំណុលអាក្រក់ដោយធានាបានការគោរពស្តង់ដារអន្តរជាតិ។ ធនាគារជាតិនៃកម្ពុជាអាចពង្រឹងការត្រួតពិនិត្យធនាគារ តាមរយៈការរឹតបន្តឹងស្តង់ដារទាំងនេះ។ ស្តង់ដារនេះពាក់ព័ន្ធនឹងបញ្ហានានាដូចជា "**កម្ចីដែលមានហានិភ័យ**" វត្ថុបញ្ចាំអចលនទ្រព្យ។ល។ ឧទាហរណ៍: ប្រសិនបើតម្លៃអចលនទ្រព្យកើនឡើងខ្លាំងដូចពពុះសាប៊ូ រួចហើយផ្ទុះបែក នោះប្រព័ន្ធធនាគារនឹងមានហានិភ័យជាលក្ខណៈប្រព័ន្ធកាន់តែធ្ងន់ធ្ងរ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្តល់ឱ្យធនាគារជាតិនៃកម្ពុជា នូវទិន្នន័យឬព័ត៌មានជាប្រចាំ ដូចមានចែងក្នុងប្រកាសដែលធនាគារកណ្តាលបានកំណត់សម្រាប់កិច្ចដំណើរការនៃគ្រឹះស្ថានទាំងនេះ។ យើងសង្កេតឃើញថា គុណភាពនៃលិខិតុបករណ៍ស្តីពីការត្រួតពិនិត្យធនាគារត្រូវបានកែលម្អយ៉ាងច្រើន ហើយប្រព័ន្ធធនាគារកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការអនុវត្តគោលការណ៍ Basel 1។ ការកែលម្អសំខាន់ៗរួមមានការចាត់វិធានការរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការពង្រឹងការត្រួតពិនិត្យហានិភ័យឥណទាន និងការពង្រឹងសមត្ថភាពស្ថាប័នត្រួតពិនិត្យ តាមរយៈការបណ្តុះបណ្តាលអធិការ។

## ៤.៤. ប្រព័ន្ធធនាគារកម្ពុជា - ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

ធនាគារពាណិជ្ជភាគច្រើនបានបង្កើតសាខាបន្ថែមទៀត នៅតាមទីប្រជុំជននានា ហើយកំពុងដាក់ចេញផែនការបង្កើតការិយាល័យកាន់តែច្រើន នៅតាមទីប្រជុំជននានា។ នាពេលបច្ចុប្បន្ននេះ ជាមធ្យមសាខាធនាគារនីមួយៗផ្តល់សេវាកម្មធនាគារពេញលេញ ជូនដល់អតិថិជនចំនួន ១២០,០០០នាក់។

ការចូលរួមរបស់ធនាគារពាណិជ្ជ ក្នុងការអភិវឌ្ឍនៃសេដ្ឋកិច្ចរបស់កម្ពុជានៅមានកម្រិតនៅឡើយ។ ក៏ប៉ុន្តែតួនាទីរបស់ធនាគារនៅក្នុងសេដ្ឋកិច្ចកម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័ស ដោយសារជាមធ្យម ប្រាក់បញ្ញើធនាគារបាននិងកំពុងកើនឡើងយ៉ាងឆាប់រហ័សជាងមុន ក្នុងអត្រាពី៩០ ទៅ១០០%។រូបភាព៤.២ ខាងក្រោមបង្ហាញពីការកើនឡើងយ៉ាងឆាប់រហ័សនៃឥណទាន និងប្រាក់បញ្ញើធនាគារអំឡុងឆ្នាំ១៩៩៩-២០០៩។

លំហូរសាច់ប្រាក់នៃគម្រោងដែលបានស្នើឡើង គឺជាធាតុចូលគន្លឹះ ក្នុងការវាយតម្លៃឥណទាន។ ជាក់ស្តែង ធនាគារមិនអាចអនុម័តឥណទានបានឡើយ ប្រសិនបើអ្នកខ្ចីគ្មានអចលនទ្រព្យដែលចុះបញ្ជីត្រឹមត្រូវ ដើម្បីយកមកធ្វើជាវត្ថុបញ្ចាំទេនោះ។ មូលហេតុសំខាន់ក្នុងការប្រើនូវអភិក្រមអភិរក្សនេះ គឺថាយោងទៅតាមរបាយការណ៍ធនាគារ ៩០%នៃសហគ្រាសតូចនិងមធ្យមមិនបានចុះបញ្ជិកាគណនេយ្យ ហើយគ្មាន

របាយការណ៍ហិរញ្ញវត្ថុឡើយ។ ដូច្នេះ សហគ្រាសទាំងនេះមិនអាចផ្តល់នូវការពន្យល់ឱ្យបានច្បាស់លាស់ពាក់ព័ន្ធនឹងទិដ្ឋភាពហិរញ្ញវត្ថុនៃសំណើគម្រោងនេះ។ ដើម្បីត្រួតពិនិត្យហានិភ័យឱ្យបានជិតដល់ ធនាគារត្រូវទាមទារនូវវត្ថុបញ្ចាំដែលមានគុណភាពខ្ពស់ ដូចជាដីធ្លីដែលចុះបញ្ជីហើយជាដើម។ នាពេលបច្ចុប្បន្ននេះ ធនាគារពាណិជ្ជបានលើកទឹកចិត្តអតិថិជន និង**សហគ្រាសទាំងនេះ** ប្រើប្រាសនូវមូលធនរបស់ខ្លួន ដើម្បីចងក្រងនិងរក្សានូវកំណត់ត្រាហិរញ្ញវត្ថុ។

ក្នុងន័យនេះ ទាំងរាជរដ្ឋាភិបាល ទាំងសេដ្ឋកិច្ច និងទាំងវិស័យធនាគារ ច្បាស់ជានឹងទទួលបាននូវអត្ថប្រយោជន៍យ៉ាងខ្លាំង ពីគម្រោងចុះបញ្ជីដីធ្លីជាប្រព័ន្ធនេះ។ ធនាគារនឹងចំណេញ ដោយមានអចលទ្រព្យច្រើនជាងមុន ដែលគេអាចប្រើប្រាស់ជាវត្ថុបញ្ចាំសម្រាប់អោយអតិថិជនខ្ចីឥណទាន។ រាជរដ្ឋាភិបាលក៏នឹងទទួលបាននូវផលប្រយោជន៍ ពីកំណើនចំណូលពន្ធលើប្រាក់ចំណេញរបស់វិស័យធនាគារ។ ក៏ប៉ុន្តែ សំខាន់ជាងនេះទៅទៀតនោះ គឺអតិថិជនរបស់ធនាគារម្នាក់ៗដែលនឹងសន្សំប្រាក់ប្រមាណ ពី២,០០០ ទៅ៣,០០០ ដុល្លារអាមេរិកជាមធ្យម ដែលពួកគេត្រូវបង់ឱ្យរដ្ឋបាលសុរិយោដី ក្នុងករណីដែលពួករត់ការសុំប័ណ្ណកម្មសិទ្ធិឱ្យបានលឿនដើម្បីអាចសុំកម្ចីពីធនាគារ។ ទន្ទឹមនឹងនេះ ធនាគារពាណិជ្ជក៏អាចជៀសវាងបាននូវការអនុវត្តមិនស្មោះត្រង់របស់អ្នកខ្ចី ដែលយកអចលនទ្រព្យដដែលនេះ ទៅធ្វើជាវត្ថុបញ្ចាំ ដើម្បីបានខ្ចីច្រើនដង។

ការត្រួតពិនិត្យដ៏តឹងរឹង បទបញ្ញត្តិនិយ័តកម្មធនាគាររបស់ធនាគារជាតិនៃកម្ពុជា ចំណាយខ្ពស់ និងពេលវេលាដ៏យូរ សម្រាប់ការដោះស្រាយការរឹបអូសយកទ្រព្យសម្បត្តិតាមផ្លូវតុលាការ មិនបានលើកទឹកចិត្តឱ្យអ្នកខ្ចីធ្វើសកម្មភាពខុសច្បាប់ឡើយ។ ជាលទ្ធផល ធនាគារភាគច្រើនបានរាយការណ៍ថា ពួកគេមានឥណ-ទានមិនដំណើរការបន្តិចបន្តួចឬគ្មានសោះតែម្តង។ធនាគារភាគច្រើនបានសម្តែងនូវការគាំទ្រ ចំពោះវិធានការកែលម្អប្រព័ន្ធតុលាការ និងស្វាគមន៍ការបង្កើតឡើងនូវតុលាការពាណិជ្ជកម្មនាពេលអនាគត។ ធនាគារពាណិជ្ជបានរង់ចាំការអនុមតិ និងការដាក់ឱ្យប្រើប្រាស់នូវច្បាប់មួយចំនួន ដែលត្រូវបានដាក់ជូនសភាជាតិ ដោយពួកគេយល់ឃើញថា វិស័យធុរកិច្ចនឹងកើនឡើងយ៉ាងខ្លាំង នៅពេលដែលអាជីវកម្មនឹងមានភាពកាន់តែច្បាស់លាស់ខ្លាំងឡើង ដោយកម្ពុជានឹងមានប្រព័ន្ធតុលាការដែលមានយុត្តិធម៌ត្រឹមត្រូវ សម្រាប់ឱ្យពួកគេធ្វើការសម្រេចចិត្ត ក្នុងការដាក់ទុនវិនិយោគនិងធ្វើអាជីវកម្ម។

ដូចជាឧស្សាហកម្មកំពុងលូតលាស់ផ្សេងទៀតដែរ កង្វះខាតនៃធនធានមនុស្សមានបទពិសោធន៍ក្នុងវិស័យធនាគារពាណិជ្ជនៅគ្រប់កម្រិត បានក្លាយជាឧបសគ្គរាំងដល់កំណើនដែលបានគ្រោងទុក និងបណ្តាលឱ្យមានកំណើនប្រាក់បៀវត្សរ៍ខ្លាំង ដោយសារតែការផ្គត់ផ្គង់មិនឃើត និងតម្រូវការកាន់តែកើនឡើងខ្លាំងៗ ចំពោះធនធានមនុស្សដ៏កម្រនេះ។ ដូច្នេះ ការកសាងសមត្ថភាពក្នុងវិស័យធនាគារ និងសកម្មភាពក្នុងវិស័យហិរញ្ញវត្ថុទាំងមូលមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការធានាបាននូវកំណើនខ្ពស់នៃវិស័យហិរញ្ញវត្ថុ។

នៅពេលដែលសាធារណជនកាន់តែមានទំនុកចិត្តខ្លាំងឡើងមកលើប្រព័ន្ធធនាគារ មូលប្បទានប័ត្រកំពុងតែក្លាយជាឧបករណ៍ ដែលអតិថិជនចូលចិត្តប្រើ សម្រាប់ការទូទាត់និងការផ្ទេរមូលធន។ ដើម្បីឆ្លើយតបទៅនឹងនិន្នាការនេះ គ្រឹះស្ថានធនាគារចំនួន៥បានសហការគ្នា ដើម្បីបង្កើតសភាផាត់ទាត់អន្តរធនាគារក្រៅផ្លូវការមួយ សម្រាប់ការផាត់ទាត់មូលប្បទានប័ត្រនៅធនាគារជាតិនៃកម្ពុជា។ សភាផាត់ទាត់នេះដំណើរការបានល្អ។ ដូច្នេះ ធនាគារពាណិជ្ជទាំងអស់នឹងគាំទ្រដល់ការបង្កើតឡើងនូវសភាផាត់ទាត់ផ្លូវការមួយ ដែលត្រួតពិនិត្យនិងគ្រប់គ្រងដោយធនាគារជាតិនៃកម្ពុជា។ ម្យ៉ាងវិញទៀត ធនាគារពាណិជ្ជនឹងចំណេញច្រើន ពី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការពង្រីកប្រព័ន្ធផាត់ទាត់មូលប្បទានប័ត្រ ទៅកាន់ទីប្រជុំជនផ្សេងៗទៀត ដែលមានសក្តានុពលធុរកិច្ចខ្ពស់ ហើយមានតម្រូវការសម្រាប់សេវាផាត់ទាត់នេះ។

ខណៈពេលដែលមានការគាំទ្រកើនឡើង សម្រាប់ការបង្កើតទីផ្សារកម្ចីអន្តរធនាគារ បរិមាណនៃសញ្ញាប័ណ្ណ និងឧបករណ៍រយៈពេលខ្លីដែលអាចចរចាបានផ្សេងៗទៀតនៅមានកម្រិតទាបណាស់ ដែលជាកត្តាមិនអំណោយផល សម្រាប់ការបង្កើតទីផ្សាររូបិយវត្ថុអន្តរធនាគារប្រកបដោយនិរន្តរភាព ក្នុងពេលអនាគតដ៏ខ្លីខាងមុខ។ ការបង្កើតឡើងនូវទីផ្សារមូលធនមួយ ដែលផ្តោតលើការជួញដូរភាគហ៊ុនក្រុមហ៊ុន អាចនឹងមានអំណោយផលជាង ដោយសារតែស្ថាប័នសំខាន់ៗ និងបទបញ្ញត្តិនិងលិខិតបទដ្ឋានគាំទ្រនានាត្រូវបានអនុមតិនិងកំពុងតែត្រូវបានអនុវត្ត។ អ្វីដែលនៅសេសសល់ គឺការកំណត់យកវិធាននៃការធ្វើពាណិជ្ជកម្មនិងការបង្កើតអាជ្ញាធរនិយតកម្មមួយ ដើម្បីត្រួតពិនិត្យមើលការធ្វើពាណិជ្ជកម្មប្រកបដោយតម្លាភាព និងយុត្តិធម៌។ តែទោះជាយ៉ាងណាក៏ដោយ បទពិសោធន៍នៃទីផ្សារមូលធនបានបង្ហាញឱ្យឃើញថា បន្ទាប់ពីទីផ្សារនេះត្រូវបានបង្កើតនិងដាក់ឱ្យដំណើរការ ពេលនោះពាណិជ្ជករ និងវិនិយោគិនច្បាស់ជាខិតខំប្រឹងប្រែងរៀនសូត្រពីទីផ្សារថ្មីនេះ។ ក្នុងអំឡុងពេលនេះ ស្ថានភាពឡើងចុះនៅលើទីផ្សារ និងហានិភ័យដែលបង្កើតឡើងដោយស្ថានភាពនេះ នឹងមានទំហំធំធេង រហូតទាល់តែទីផ្សារនេះឈានដល់កម្រិតអភិវឌ្ឍន៍។

ជាការពិត វិស័យធនាគារពាណិជ្ជក្នុងប្រទេសកម្ពុជាពិតជាមានការរីកចម្រើនយ៉ាងលឿន ថ្វីត្បិតតែវិស័យនេះមិនទាន់ឈានដល់កម្រិតចាស់ទុំនៅឡើយ។ ក្នុងន័យនេះ ធនាគារកណ្តាលត្រូវបន្តពង្រឹងយន្តការត្រួតពិនិត្យនិងនិយតកម្ម ក្នុងគោលដៅបង្កើតលក្ខខណ្ឌ ដែលធានាបាននូវនិរន្តរភាពនៃប្រព័ន្ធធនាគារ។ ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធគតិយុត្តិ ការរៀបចំកិច្ចដំណើរការរបស់ធនាគារជាតិនៃកម្ពុជា ដែលគាំទ្រដោយប្រព័ន្ធអេឡិចត្រូនិក និងកុំព្យូទ័រ ការបង្កើតនូវទីផ្សារអន្តរធនាគារនិងទីផ្សារមូលធន (ទីផ្សារភាគហ៊ុន) និងការកសាងសមត្ថភាពបន្ថែមទៀត នឹងជួយពង្រឹងការអភិវឌ្ឍប្រព័ន្ធធនាគារឱ្យកាន់តែឈានឡើងថែមទៀត។

សរុបមក ប្រព័ន្ធធនាគាររបស់កម្ពុជាមានមូលធនកម្រិតខ្ពស់ និងសម្បូណ៌សាច់ប្រាក់ងាយស្រួល។ អនុបាតសាធនភាពជាមធ្យមស្មើនឹង២៨% ដែលមានកម្រិតខ្ពស់ខ្លាំង បើប្រៀបធៀបនឹងអនុបាតគោលដៅចំនួន១៥%។ អនុបាតសាច់ប្រាក់ងាយស្រួល (ទ្រព្យសកម្មជាសាច់ប្រាក់/ទ្រព្យសកម្មសរុប) គឺស្មើនឹង៨១%។ ឥណទានមិនដំណើរការមានតែ ៣.៦% ប៉ុណ្ណោះនៃឥណទានសរុបនៅចុងឆ្នាំ២០០៨។ អនុបាតចំណេញនៃប្រព័ន្ធធនាគារបានកើនឡើងទ្វេដង ប៉ុន្តែបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំ ២០០៨ បន្ទាប់ពីព្យុះនៃវិបត្តិហិរញ្ញវត្ថុពិភពលោកបានចាប់ផ្តើមបក់បោកមកលើសេដ្ឋកិច្ចកម្ពុជា។

### ៤.៤.១. ទ្រព្យសកម្ម

ទ្រព្យសកម្មសរុបនៃធនាគារពាណិជ្ជបានកើនយ៉ាងឆាប់រហ័ស ក្នុងអំឡុងឆ្នាំ២០០៦-២០០៩។ អត្រាកំណើននេះសម្រេចបាន២១-២៤% ក្នុងឆ្នាំ២០០៣-២០០៥ ប៉ុន្តែបានស្ទុះឡើងដល់៣៩% ក្នុងឆ្នាំ២០០៦ និង៧៤% ក្នុងឆ្នាំ២០០៧ តែបានធ្លាក់ចុះមកវិញដល់២១% ក្នុងឆ្នាំ២០០៨។ ទ្រព្យសកម្មសរុបនៃប្រព័ន្ធធនាគារបានកើនពី៩៥៦លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៣ ដល់ជាង៤ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៨។ ទ្រព្យសកម្មប្រមាណជា៩៨%របស់ធនាគារពាណិជ្ជត្រូវបានចារឹកជាប្រាក់ដុល្លារអាមេរិក ដែលបានឆ្លុះបញ្ចាំងនូវកម្រិតដុល្លារូបនីយកម្មដ៏មហាសែនខ្ពស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| រូបភាព៤.១ក.ទ្រព្យសកម្មនៃធនាគារពាណិជ្ជ ឆ្នាំ២០០៨ (គិតជាលានដុល្លារ) | រូបភាព៤.១ខ.ទ្រព្យសកម្មសរុបប្រៀបធៀបនឹងផសស (គិតជាលានដុល្លារ) |
| --- | --- |
|  |  |





*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

ការរីកលូតលាស់យ៉ាងឆាប់រហ័សនៃប្រព័ន្ធធនាគារបណ្តាលមកពីកត្តាដូចតទៅ៖ ស្ថេរភាពនយោបាយ ដែលធ្វើឱ្យសាធារណជនមានទំនុកចិត្តលើប្រព័ន្ធធនាគារការ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានអំណោយផលល្អ ដោយកំណើន**សេដ្ឋកិច្ច** ជាមធ្យមសម្រេចបាន១០.៦% ក្នុងអំឡុងឆ្នាំ២០០៥-២០០៨ និង ការពង្រឹងក្នុងការត្រួតពិនិត្យ និងការធ្វើនិយ័តកម្មបានល្អប្រសើរដោយធនាគារជាតិនៃកម្ពុជា។ ការគ្រប់គ្រងធនាគារមានតម្លាភាព និងការអនុវត្តបទបញ្ញត្តិដ៏តឹងរឹង គឺជាកត្តាគន្លឹះក្នុងការលើកកម្ពស់ទំនុកចិត្តពីសាធារណៈជនកាន់តែខ្លាំងឡើងមកលើប្រព័ន្ធធនាគារ។

## ៤.៤.២. ការប្រមូលផ្តុំ

ការប្រមូលផ្តុំនៃប្រព័ន្ធធនាគារត្រូវបានវាស់ស្ទង់ដោយ សមមាត្រនៃធនាគារពាណិជ្ជធំៗក្នុងប្រតិបត្តិការធនាគារ។ ការប្រមូលផ្តុំនៃធនាគារធំជាងគេបំផុតចំនួនប្រាំបានកើនឡើងក្នុងឆ្នាំ២០០៦ ដោយធនាគារធំជាងគេបំផុតទាំងប្រាំនេះ មានទ្រព្យសកម្មចំនួន៧១%នៃទ្រព្យសកម្មសរុប ដែលកើនដល់ ២.៩ពាន់លានដុល្លារអាមេរិក។ សមមាត្រនៃប្រាក់បញ្ញើនិងការប្រមូលផ្តុំឥណទានក៏មានកម្រិតខ្ពស់ដែរ។ ធនាគារធំជាងគេទាំងប្រាំ (ធនាគារកម្ពុជាសាធារណៈ ACLEDA កាណាឌីយ៉ា ANZ Royal និងFTB) ផ្តល់ឥណទានចំនួន៧៧%នៃឥណទានសរុប ដែលក្នុងនោះឥណទានចំនួន១៤% ត្រូវបានផ្តល់ឱ្យវិស័យសេវាកម្ម (សណ្ឋាគារ និងភោជនីយដ្ឋាន)។ នៅចុងឆ្នាំ២០០៨ ធនាគារធំជាងគេបីទទួលបានប្រាក់បញ្ញើចំនួន ៧២%នៃប្រាក់បញ្ញើទាំងអស់នៃប្រព័ន្ធធនាគារ។

## ៤.៤.៣. ប្រាក់បញ្ញើនិងឥណទាន

ប្រាក់បញ្ញើនិងឥណទានធនាគារបានបន្តកើនឡើងក្នុងឆ្នាំ២០០៨ ដែលឆ្លុះបញ្ចាំងពីទំនុកចិត្តរបស់សាធារណជន ទោះបីជាពិភពលោកបានជួបនឹងវិបត្តិដ៏ហិនហោចក៏ដោយ។ ប្រាក់បញ្ញើបានកើនឡើងយ៉ាងសម្បើមអស្ចារ្យក្នុងអំឡុងឆ្នាំ២០០៤-២០០៨ ដែលឆ្លុះបញ្ចាំងពីការកើនឡើងនៃលំហូរមូលធនវិនិយោគផ្ទាល់ពីបរទេស ការវិនិយោគទុនជាមូលប័ត្រ និងកំណើនខាងការនាំចេញទំនិញ និងសេវា (ជាពិសេសវិស័យទេសចរណ៍ដែលកំពុងរីកចម្រើន)។ ប្រាក់បញ្ញើបានកើនជាមធ្យម ៣៣% ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។ វាកើនឡើងត្រឹម៩៤% ក្នុងឆ្នាំ២០០៦ ៧៧% ក្នុងឆ្នាំ២០០៧ ប៉ុន្តែធ្លាក់ចុះវិញមកនៅត្រឹម ៤% ក្នុងឆ្នាំ២០០៨។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឥណទានក្នុងប្រទេសចំពោះវិស័យឯកជនក៏បានកើនឡើងយ៉ាងឆាប់រហ័សផងដែរ ក្នុងអំឡុងឆ្នាំ ២០០៦-២០០៨។ ខណៈដែលឥណទានក្នុងស្រុកចំពោះវិស័យឯកជនបានកើនឡើងជាមធ្យម ៥០% ក្នុងមួយឆ្នាំ ក្នុងអំឡុងឆ្នាំ២០០៣-២០០៨ នោះឥណទានកើនឡើង៤៨% ក្នុងឆ្នាំ២០០៦ ៧៩% ក្នុងឆ្នាំ២០០៧ និង៧៥% ក្នុងឆ្នាំ២០០៨។ ឥណទានបានកើន១០០% ក្នុងត្រីមាសដំបូងនៃឆ្នាំ២០០៨ បើប្រៀបធៀបនឹងត្រីមាសទី១នៃឆ្នាំ២០០៧។ កំណើនដ៏ឆាប់រហ័សនេះបានបង្កើតនូវបញ្ហាប្រឈមខ្លះសម្រាប់វិស័យធនាគារៈ (១) គុណភាពឥណទានអាចធ្លាក់ចុះ (២) ការរីកលូតលាស់ដ៏ឆាប់រហ័សនៃវិស័យធនាគារបានធ្វើឱ្យធនាគារកណ្តាលមានការងារច្រើនដែលត្រូវធ្វើ ក្នុងគោលដៅបង្កើនការត្រួតពិនិត្យធនាគារពាណិជ្ជ និង(៣) ហានិភ័យនៃវិស័យធនាគារចំពោះវិស័យអចលទ្រព្យបានកើនឡើង ដោយសារវិស័យនេះអាចបង្កើតជាកំណើនពពុះសាប៊ូ ដែលនឹងអាចបែកធ្លាយនៅថ្ងៃណាមួយជាក់ជាមិនខាន។

ដើម្បីទ្រទ្រង់កំណើន និងធានាបាននូវវិស័យធនាគារមួយដែលរឹងមាំ នោះអាជ្ញាធរមានសមត្ថកិច្ចបានចាត់វិធានការ ដើម្បីតម្រូវឱ្យធនាគារពាណិជ្ជបង្កើនមូលធនអប្បបរមា កែលម្អវិធានប្រុងប្រយ័ត្ន និងពង្រឹងការត្រួតពិនិត្យៈ

- បង្កើនទុនបម្រុងកាតព្វកិច្ចរបស់ធនាគារពាណិជ្ជពី៨%ទៅ១៦% ដើម្បីស្រូបយកលំហូរសាច់ប្រាក់លើសក្នុងសេដ្ឋកិច្ច និងរឹតបន្តឹងការផ្តល់ឥណទានចំពោះវិស័យឯកជន។ បន្ទាប់ពីស្ថានភាពនៃវិបត្តិហិរញ្ញវត្ថុពិភពលោកបានធូរស្រាលបន្តិច ទើបកាត់បន្ថយទុនបម្រុងកាតព្វកិច្ចនេះមកនៅត្រឹម ១២%វិញ
- កំណត់កម្រិតនៃហានិភ័យរបស់ធនាគារពាណិជ្ជចំពោះវិស័យដែលមានហានិភ័យខ្ពស់ ជាពិសេសការជួញដូរអចលនទ្រព្យ ដោយកម្រិតឱ្យធនាគារពាណិជ្ជផ្តល់ឥណទានចំពោះវិស័យអចលនទ្រព្យយ៉ាងច្រើនត្រឹម១៥%នៃឥណទានសរុប
- បង្កើនមូលធនអប្បបរមាសម្រាប់ធនាគារពាណិជ្ជកម្មសកល និងធនាគារឯកទេស។

កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លា ក្នុងអំឡុងមួយទសវត្សរ៍កន្លងទៅនេះ បានរួមចំណែកក្នុងការធានានូវកំណើនដ៏ឆាប់រហ័សនៃទ្រព្យសម្បត្តិ និងបានលើកកម្ពស់តារាងតុល្យការរបស់គ្រួសារ និងក្រុមហ៊ុនក្នុងប្រទេសកម្ពុជា ដែលជាកត្តាបណ្តាលឱ្យមានកំណើនដ៏ឆាប់រហ័សនៃប្រាក់បញ្ញើក្នុងធនាគារ។ ក្នុងអំឡុងឆ្នាំ ១៩៩៩-២០០៨ កំណើនប្រចាំឆ្នាំនៃប្រាក់បញ្ញើសម្រេចបានជាមធ្យម៣០% ហើយប្រាក់បញ្ញើបានកើនឡើងលឿនជាងកំណើននៃផសស។ ឧទាហរណ៍: ប្រាក់បញ្ញើធនាគារបានកើនពី២៥០លានដុល្លារក្នុងឆ្នាំ ១៩៩៩ ដល់២.៣លានដុល្លារក្នុងឆ្នាំ២០០៨ គឺជាការកើនឡើងមួយចំនួន៩ដង ដែលបណ្តាលមកពីកំណើនប្រាក់បញ្ញើដែលចារឹកជាប្រាក់ដុល្លារ។ ក្នុងអំឡុងរយៈពេលនេះ ផលិតផលសរុបក្នុងស្រុកបានកើនឡើងទ្វេដងតែប៉ុណ្ណោះ។ ប្រាក់បញ្ញើបានកើនឡើងយ៉ាងគំហុកដល់ ៧៩% ក្នុងឆ្នាំ២០០៧ ប៉ុន្តែបានធ្លាក់ចុះដល់៤% ក្នុងឆ្នាំ ២០០៨ ហើយប្រាក់បញ្ញើសរុបសម្រេចបានចំនួនខ្ពស់បំផុតគឺ ២.៣៥ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៨។ ប្រាក់បញ្ញើបានកើនឡើងខ្លាំងឡើងដល់២.៥ពាន់លានដុល្លារ ក្នុងខែមេសាឆ្នាំ២០០៩។ វត្តមាននៃធនាគារដែលគេទទួលស្គាល់ជាអន្តរជាតិ និងកំណើនក្នុងទំនុកចិត្តរបស់សាធារណជនទៅលើវិស័យធនាគារ គឺជាកត្តាដែលបានរួមចំណែក ចំណែកដល់ការកើនឡើងនៃប្រាក់បញ្ញើធនាគារផងដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឥណទានចំពោះវិស័យឯកជនដើរតួនាទីដ៏សំខាន់ ក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ក្នុងអំឡុងឆ្នាំ១៩៩៩-២០០៨ ឥណទានចំពោះវិស័យឯកជនក៏បានកើនឡើង ៣៦% ក្នុងឆ្នាំ២០០៤ ៣០%ក្នុងឆ្នាំ២០០៥ ៤៨%ក្នុងឆ្នាំ២០០៦ ៧៩%ក្នុងឆ្នាំ២០០៧ និង៥៥%ក្នុងឆ្នាំ២០០៨ បន្ទាប់មកឈានដល់កំណត់ត្រាកំពូលចំនួន២.៤ពាន់លានដុល្លារក្នុងឆ្នាំ២០០៨។

*រូបភាព៤.២ក. ប្រាក់បញ្ញើធនាគារ*




*រូបភាព៤.២ខ. ឥណទានចំពោះវិស័យឯកជន*




*រូបភាព៤.៣ក. អត្រាកំណើន*




*រូបភាព ៤.៣ខ. អនុបាតឥណទាន-ប្រាក់បញ្ញើ*




*ប្រភព ៖ ធនាគារជាតិនៃកម្ពុជា*

តែទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធធនាគារមានឧបករណ៍ហិរញ្ញវត្ថុដ៏តិចតួច ពោលគឺប្រាក់បញ្ញើចរន្ត ប្រាក់បញ្ញើមានកាលកំណត់ និងប្រាក់បញ្ញើសន្សំ។ ប្រាក់បញ្ញើមួយភាគធំ គឺជាប្រាក់បញ្ញើរបស់បុគ្គលម្នាក់ៗ ក៏ប៉ុន្តែប្រាក់បញ្ញើជំនួញពាណិជ្ជកម្មបាននិងកំពុងកើនឡើងយ៉ាងឆាប់រហ័ស ដោយចង្អុលបង្ហាញពីការកំណើននៃការប្រើប្រាស់ប្រព័ន្ធធនាគារ ក្នុងគោលដៅធ្វើប្រតិបត្តិការពាណិជ្ជកម្ម។

ឥណទានមានតួនាទីបង្កើតតម្លៃសម្រាប់ធនាគារ។ ដូច្នេះ ធនាគារត្រូវធានានូវការគ្រប់គ្រងឱ្យសមស្រប និងយ៉ាងប្រុងប្រយ័ត្ននូវហានិភ័យឥណទាន។ រូបភាព៤.៤ក.បង្ហាញពីការបែងចែកឥណទានធនាគារ តាមវិស័យសេដ្ឋកិច្ច។

| *រូបភាព៤.៤ក. ឥណទានចំពោះវិស័យឯកជន (គិតជាលានដុល្លារ)* | *រូបភាព៤.៤ខ. ឥណទានតាមវិស័យ (%)* |
|---|---|
|  |  |





*ប្រភព៖ធនាគារជាតិនៃកម្ពុជា*

ក្រាហ្វិក ៤.៤ខ. ខាងលើបង្ហាញពីការបែងចែកឥណទានធនាគារចំពោះវិស័យឯកជន តាមវិស័យសេដ្ឋកិច្ចជាតិសំខាន់ៗ។ វិស័យសេវាកម្ម (ឧស្សាហកម្ម សណ្ឋាគារ និងទេសចរណ៍) ទទួលបាន៣៣% ពាណិជ្ជកម្ម២៣% វិស័យផលិតកម្ម ១២% និងវិស័យអចលនទ្រព្យ ៩%។ ការសាងសង់ទទួលបានឥណទានចំនួន៨% ហើយវិស័យកសិកម្មត្រឹមតែ៥%ប៉ុណ្ណោះ។ តែទោះជាយ៉ាងណាក៏ដោយវិស័យកសិកម្មសម្រេចបាននូវកំណើនខ្ពស់ជាងគេក្នុងឆ្នាំ២០០៨ លើសពីឆ្នាំ២០០៧ (+១១៤.៦%) បន្ទាប់មកអចលនទ្រព្យ សេវាកម្ម និងសេវាសាធារណៈ (+១០១.៩%) និងការសាងសង់ (+៨៥.៦%)។

រយៈពេល៥ឆ្នាំកន្លងទៅនេះ ធនាគារពាណិជ្ជបានបង្កើនវត្តមានរបស់ខ្លួនយ៉ាងឆាប់រហ័ស នៅតាមខេត្ត តាមរយៈការពង្រីកបណ្តាញសាខាធនាគារ។ ចំនួនសាខាធនាគារបានកើនដល់១១៦កន្លែង ហើយសេវាកម្មធនាគារឥឡូវនេះគ្របដណ្តប់នៅគ្រប់ទីប្រជុំជនទាំងអស់ក្នុងប្រទេស។ តែទោះជាយ៉ាងណាក្តី សេវាកម្មធនាគារតាមទីជនបទនៅតែមិនទាន់រីកចម្រើននៅឡើយ ទោះបីជា៨០%នៃប្រជាជនរស់នៅក្នុងតំបន់ជនបទក៏ដោយ។ សញ្ញាគួរជាទីលើកទឹកចិត្តក្នុងការអភិវឌ្ឍវិស័យធនាគារតាមជនបទ គឺថាឥណទានមីក្រូហិរញ្ញវត្ថុបានកើន៧៥% ក្នុងឆ្នាំ២០០៨ ហើយសម្រេចបាន២៧៤លានដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០០៧។ ម្យ៉ាងវិញទៀត ការកើនឡើងនៃការប្រើប្រាស់ម៉ាស៊ីនបើកប្រាក់ដោយស្វ័យប្រវត្តិ ATMs ដែលមានចំនួនសរុប៣៣៨កន្លែងក្នុងឆ្នាំ២០០៨ ក៏ជាសក្ខីកម្មនៃការពង្រីកសកម្មភាពធនាគារពាណិជ្ជផងដែរ។

ធនាគារ ACLEDA ដែលជាធនាគារពាណិជ្ជកើតចេញពីស្ថាប័នមីក្រូហិរញ្ញវត្ថុ គឺជាធនាគារដែលមានចំនួនបុគ្គលិកច្រើនជាងគេបង្អស់។ ធនាគារនេះមានសាខា១៥៧កន្លែង និងប្រើប្រាស់បុគ្គលិកចំនួន៣,០០០នាក់ ក្នុងឆ្នាំ ២០០៦។ ចំនួនបុគ្គលិករបស់ធនាគារនេះបានកើនឡើងដល់ប្រមាណ៦,១២៨នាក់ ក្នុងឆ្នាំ២០០៨ នៅពេលដែលធនាគារ ACLEDA បានពង្រីងបណ្តាញសាខារបស់ខ្លួនទូទាំងព្រះរាជាណាចក្រកម្ពុជា។

*រូបភាព៤.៥. បុគ្គលិករបស់វិស័យធនាគារឆ្នាំ២០០៨*




## ៤.៤.៤. សាច់ប្រាក់ងាយស្រួលនិងសាធនភាព

សូចនាករពីរអាចពិពណ៌នាដោយសង្ខេបនូវប្រព័ន្ធធនាគារ៖ អនុបាតសន្ទនីយភាព ឬ សាច់ប្រាក់ងាយស្រួល និងអនុបាតសាធនភាព។អនុបាតសាច់ប្រាក់ងាយស្រួល គឺជាផលធៀបរវាងសមតុល្យនៃធនាគារពាណិជ្ជ និងប្រាក់បញ្ញើរយៈពេលខ្លី។ ក្នុងឆ្នាំ២០០៨ អនុបាតសាច់ប្រាក់ងាយស្រួលបានធ្លាក់ចុះដល់៨១% ដោយសារតែកំណើនឥណទានដ៏ឆាប់រហ័ស និងកំណើនប្រាក់បញ្ញើដ៏យឺតយ៉ាវ។ ក៏ប៉ុន្តែ អនុបាតនេះនៅតែខ្ពស់ច្រើនជាងកម្រិតបទបញ្ញត្តិអប្បបរមា ៥០%។

*រូបភាព៤.៦. អនុបាតសាច់ប្រាក់ងាយស្រួលនិងសាធនភាព*




*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

សាធនភាពនៃប្រព័ន្ធធនាគារអាចត្រូវវាយតម្លៃបាន តាមរយៈសមិទ្ធិនៃធនាគារ ដោយប្រៀបធៀបនឹងវិធានការប្រុងប្រយ័ត្ន។ អនុបាតសាធនភាព (ឬអនុបាតការគ្រប់គ្រាន់នៃមូលធន) គឺជាផលធៀបរវាងសមតុល្យ និងទ្រព្យសកម្មរបស់ធនាគារពាណិជ្ជកម្ម។ អនុបាតនេះសម្រេចបាន ២៨% ក្នុងឆ្នាំ២០០៨ ដោយលើសពីកម្រិតនៃបទបញ្ញត្តិ១៥%។ ការកើនឡើងនៃដើមទុនរបស់ធនាគារក៏ដូចជាសមតុល្យ គឺបណ្តាលមកពីធនាគារថ្មីៗនិងធនាគារមានស្រាប់បានបញ្ចូលមូលធនបន្ថែម។ ប្រការនេះបានធ្វើឱ្យអនុបាតសាធនភាពកើនឡើង ដោយសារធនាគារថ្មីៗតែងតែមានសាធនភាពខ្ពស់ជាងធនាគារចាស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.៤.៥. អត្រាចំណេញនៃប្រព័ន្ធធនាគារ

គេអាចប្រើប្រាស់វិធីសាស្ត្រពីរ ដើម្បីវិភាគប្រាក់ចំណេញនៃធនាគារ៖ អនុបាតចំណូលពីមូលធន (ROE) និងអនុបាតចំណូលពីទ្រព្យសកម្ម (ROA)។ ROE គឺជាអនុបាតស្តីពីការចំណេញហិរញ្ញវត្ថុ ដែលជាផលចែករវាងចំណេញសុទ្ធជាមួយនឹងមូលធនដើម។ អនុបាតនេះបង្ហាញនូវប្រាក់ចំណេញពីទស្សនទានរបស់ម្ចាស់ភាគហ៊ុន ដោយរំលេចឃើញនូវប្រាក់ចំណេញនៃការវិនិយោគរបស់ពួកគេ។ តែទោះ ជាយ៉ាងណាក្តី អនុបាតនេះគឺជាសូចនាករមិនប្រាកដប្រជាមួយ ដែលបង្ហាញពីប្រាក់ចំណេញ ដោយសារតែប្រសិនបើគេចង់ឱ្យឃើញថាគេបានចំណេញច្រើន នោះគេត្រូវរក្សាទុកមូលធនដើមឱ្យនៅទាប។ ROA ត្រូវបានគណនាដោយផលចែករវាងប្រាក់ចំណេញសុទ្ធ ជាមួយនឹងទ្រព្យសកម្ម។

*រូបភាព៤.៧ក. ប្រាក់ចំណេញសុទ្ធ*




*រូបភាព៤.៧ខ.ប្រាក់ចំណូលពីទ្រព្យសកម្ម/ម្ចាស់ទ្រព្យ*




*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

សូចនាករចម្បងដែលកំណត់ **ROA និង ROE** គឺជាប្រាក់ចំណេញសុទ្ធរបស់ធនាគារពាណិជ្ជ។ នៅពេលដែលធនាគារជាតិនៃកម្ពុជាដាក់លក្ខខណ្ឌរឹតបន្តឹង ក្នុងការបង្កើតធនាគារថ្មី នោះចំនួនធនាគារពាណិជ្ជត្រូវបានកាត់បន្ថយ ជាហេតុធ្វើឱ្យប្រាក់ចំណេញកាន់តែកើនឡើង។ ប្រាក់ចំណេញសុទ្ធសរុបបានកើនពី ៨ លានដុល្លារក្នុងឆ្នាំ២០០៣ ដល់ ២៤លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៥។ វាបានកើនឡើងថែមទៀតចំនួន ១២៨% ក្នុងឆ្នាំ២០០៦ ដោយប្រៀបធៀបនឹងឆ្នាំ២០០៥ និងសម្រេចបាន៥៤.៦លានដុល្លារអាមេរិក ហើយឡើងដល់កំពូលចំនួន ៩២លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៧។ ក្នុងឆ្នាំ២០០៨ ដោយសារតែវិបត្តិហិរញ្ញវត្ថុ អនុបាតនេះបានធ្លាក់ចុះដល់០.៥លានដុល្លារអាមេរិក។ ការកើនឡើងដ៏ឆាប់រហ័សនៃប្រាក់បញ្ញើបានផ្តល់ឱ្យធនាគារនូវកាលានុវត្តភាពទទួលប្រាក់ចំណេញបន្ថែមទៀត និងផ្តល់មធ្យោបាយក្នុងការពង្រីកឥណទាន។ នៅក្នុងរូបភាព៤.៧ខ. យើងឃើញថា ROE មានកម្រិតទាបនៅកម្ពុជា។ ក៏ប៉ុន្តែ សូចនាករនេះកំពុងកើនឡើងយ៉ាងឆាប់រហ័ស។ ROE របស់ធនាគារបានកើនឡើងពី១.៧% ក្នុងឆ្នាំ២០០១ ដល់១៦.៥៨% ក្នុងឆ្នាំ២០០៧ ទោះបីជាកម្រិតនៃឥណទាននៅខ្ពស់ក៏ដោយ។ ទន្ទឹមនឹងនេះ ចំណាយក្នុងការផ្តល់ឥណទាននៅកម្ពុជាក៏ខ្ពស់ផងដែរ។ ROE បានធ្លាក់ចុះដល់១៣% ក្នុងឆ្នាំ២០០៨ ចំពេលដែលធនាគារថ្មីៗចំនួន៦ទៀតទទួលបានអាជ្ញាប័ណ្ណឱ្យធ្វើអាជីវកម្មក្នុងឆ្នាំ២០០៨។ ជាធម្មតា ធនាគារថ្មីៗទាំងនេះនឹងដំណើរការទាំងខាត ក្នុងអំឡុងឆ្នាំដំបូងនៃការធ្វើអាជីវកម្ម។ ការកើនឡើងនៃប្រាក់ចំណូលលើការវិនិយោគ (មូលធនដំបូងបូកនឹងប្រាក់ចំណេញដែលបានបង្គរទុក) នឹងកើនឡើងច្រើនសម្រាប់ធនាគារ ដែលមានប្រាក់បញ្ញើកើនឡើងយ៉ាងខ្លាំង។ កំណើននៃប្រាក់ចំណេញបានធ្វើឱ្យវិស័យធនាគារ ក្លាយជាគោលដៅនៃការវិនិយោគគួរឱ្យទាក់ទាញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធនាគារដែលមានប្រាក់បញ្ញើកើនឡើងខ្លាំង គឺជាធនាគារដែលបង្កើនប្រាក់ចំណេញដល់ម្ចាស់ភាគហ៊ុនរបស់ខ្លួន។

ប្រាក់ចំណេញពីការវិនិយោគទុនក្រោយបង់ពន្ធត្រូវបានវិនិយោគិនប្រើប្រាស់ជាញឹកញាប់ ដើម្បីវាស់ស្ទង់ប្រាក់ចំណេញនៃវិនិយោគទុនរបស់ពួកគេ។ ROA របស់ធនាគារបានកើនពី០.៥៨% ក្នុងឆ្នាំ ២០០១ ដល់២.៨៨% ក្នុងឆ្នាំ២០០៨។ ROA គឺមានស្ថេរភាពគួរសមក្នុងកម្រិត២.៨%។ ការកើនឡើងនេះ គឺបណ្តាលមកពីកំណើនចំណូលការប្រាក់ និងការប្រមូលបំណុល។ ឥណទាន គឺជាទ្រព្យសកម្មដែលផ្តល់ចំណូលច្រើនជាងគេបំផុត (៥៧%នៃទ្រព្យសកម្មសរុប) ហើយបន្ទាប់មកគឺប្រាក់បញ្ញើជាមួយនឹងធនាគារជាតិនៃកម្ពុជា (២៣%)។ ធនាគារពាណិជ្ជអាចវិនិយោគមូលនិធិរបស់ខ្លួនជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីរកផលចំណេញ ដោយសារតែកម្ពុជាមិនសូវមានផលិតផលហិរញ្ញវត្ថុ និងមិនទាន់មានទីផ្សារអន្តរធនាគារ។

## ៤.៤.៦. វិធានការប្រុងប្រយ័ត្ន

### ៤.៤.៦.១. ហានិភ័យធំ

យើងអាចវិភាគហានិភ័យធនាគារ ដោយពិនិត្យមើលហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យអាត្រាការប្រាក់។ល។ ធនាគារពាណិជ្ជដែលគ្រប់គ្រងហានិភ័យឥណទានរបស់ខ្លួនបានល្អ ហើយប្រសិនបើអ្វីៗគ្រប់យ៉ាងនៅដដែល អាចទទួលបានពិន្ទុខ្ពស់ក្នុងការគ្រប់គ្រងហានិភ័យ។ ដូច្នេះ ការគ្រប់គ្រងហានិភ័យឥណទាន គឺជាវិធានការប្រុងប្រយ័ត្នបំផុតក្នុងការគ្រប់គ្រងហានិភ័យ។ ធនាគារដែលគ្រប់គ្រងហានិភ័យឥណទានរបស់ខ្លួនមិនបានល្អ នឹងទទួលពិន្ទុយ៉ាងទាប។ ជារួម ការប្រឈមនឹងហានិភ័យរបស់ធនាគារពាណិជ្ជកម្មបានឡើងដល់ចំណុចកំពូលក្នុងឆ្នាំ២០០៥ ដោយសារតែមានហានិភ័យនៃការផ្តល់ឥណទានឱ្យសម្ព័ន្ធញាតិ និងហានិភ័យធំ។ ក៏ប៉ុន្តែ ហានិភ័យនេះបានធ្លាក់ចុះក្នុងឆ្នាំ២០០៦។

*រូបភាព៤.៨ក. ភាគីពាក់ព័ន្ធនិងហានិភ័យធំ*




*រូបភាព៤.៨ខ. កម្ចីដល់ភាគីពាក់ព័ន្ធ*




*ប្រភព៖ធនាគារជាតិនៃកម្ពុជា*

ការឱ្យខ្ចីចំពោះសម្ព័ន្ធញាតិបានធ្លាក់ចុះជាខ្លាំង បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ។ ការឱ្យខ្ចីចំពោះសម្ព័ន្ធញាតិបានធ្លាក់ចុះពី២១.៦% ក្នុងឆ្នាំ២០០៣ មកនៅត្រឹម៩.៨% ក្នុងឆ្នាំ២០០៦ ដែលជាលទ្ធផលមួយដែលទទួលបាន ក្រោយពីឥណទាននេះត្រូវបានសងរួចចប់សព្វគ្រប់ និងការផ្លាស់ប្តូរកម្មសិទ្ធិ។ អនុបាតនេះសម្រេចបានចំនួន ៣.៦% នៃតារាងតុល្យការ តែនៅទាបជាងកម្រិតបទប្បញ្ញត្តិប្រុងប្រយ័ត្ន១០%។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហានិភ័យធំបានកើនឡើងពី២៦% ក្នុងឆ្នាំ២០០២ ដល់៩០.៤% ក្នុងឆ្នាំ២០០៥។ ក៏ប៉ុន្តែវាបានធ្លាក់ចុះមកត្រឹម៨៧.២%នៃតារាងតុល្យការក្នុងឆ្នាំ២០០៦ ដោយសារតែមានការផ្លាស់ប្តូរក្នុងវិធីសាស្ត្រគណនា។ ធនាគារធំៗមួយចំនួនត្រូវបានគេរកឃើញថា បានប្តល់ឥណទានលើសពីការកម្រិតនៃបទបញ្ញត្តិ។

### ៤.៤.៦.២. ឥណទានមិនដំណើរការ

ការវាយតម្លៃហានិភ័យសម្រាប់ធនាគារពាណិជ្ជ ត្រូវឈរលើមូលដ្ឋាននៃអនុបាតមួយចំនួន ៖ អនុបាតមូលធនចែកនឹងទ្រព្យសកម្មតាមកម្រិតហានិភ័យ អនុបាតឥណទានមិនដំណើរការចែកនឹងទ្រព្យ-សកម្មតាមកម្រិតហានិភ័យ និងអនុបាតសំវិធានធនសម្រាប់ឥណទានមិនដំណើរការ។ អចលទ្រព្យសកម្មត្រូវបានប្រើជាវត្ថុបញ្ចាំសម្រាប់ការឱ្យខ្ចី។ ចំពោះអ្នកត្រួតពិនិត្យ អនុបាតនេះមានសារៈសំខាន់ខ្លាំងណាស់ ដោយសារតែថ្លៃអចលនទ្រព្យ អាចកើនឡើងលើសពីតម្លៃពិតរបស់វាដែលអ្នកសេដ្ឋកិច្ចហៅថា មានពពុះ (bubble) អចលនទ្រព្យ។ នៅពេលដែលពពុះនេះបែកភ្លាម នឹងធ្វើឱ្យថ្លៃអចលទ្រព្យធ្លាក់ចុះ ហើយតម្លៃទ្រព្យ-សកម្មក្នុងតារាងតុល្យការរបស់ធនាគារនឹងត្រូវបានកាត់បន្ថយ។

*រូបភាព៣.៩ក. NPL ចំពោះTL*




*រូបភាព៤.៩ខ.NPL ចំពោះទ្រព្យសម្បត្តិសរុប*




*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

អនុបាតឥណទានមិនដំណើរការ ឬ NPL បានធ្លាក់ចុះពី១៤.៦% ក្នុងឆ្នាំ២០០២ ទៅដល់៧.៥% ក្នុងឆ្នាំ២០០៥ ប៉ុន្តែបានកើនឡើងវិញទៅដល់៩.៨% ក្នុងឆ្នាំ២០០៦ ដោយសារតែការណែនាំនូវស្តង់ដារគណ-នេយ្យអន្តរជាតិដ៏តឹងរឹងពីធនាគារជាតិនៃកម្ពុជា។ ការកើនឡើងនេះមានសង្គតិភាព ជាមួយនឹងការកើនឡើងក្នុងការឱ្យខ្ចីកាលពីប៉ុន្មានឆ្នាំកន្លងទៅ និងសមស្របជាមួយនឹងយុទ្ធសាស្ត្ររបស់ធនាគារជាតិនៃកម្ពុជា ដើម្បីរឹតបន្តឹងការវាយតម្លៃលើអ្នកខ្ចី នៅក្នុងប្រព័ន្ធដាក់ចំណាត់ថ្នាក់ឥណទាន។ ការធ្វើសំវិធានធនបានថយចុះ ១៦.៥% អំឡុងឆ្នាំ២០០៥-២០០៦ ដោយសារតែប្រមូលបំណុលចំពោះឥណទានមិនដំណើរការសម្រេចបានខ្ពស់ចំនួន១៨%។ អនុបាត NPL បានធ្លាក់ចុះដល់៣.៤% ក្នុងឆ្នាំ២០០៧ បន្ទាប់មកបានកើនឡើងដល់៣.៦៨% ក្នុងឆ្នាំ២០០៨ នៅពេលដែលវិបត្តិហិរញ្ញវត្ថុពិភពលោកបានចាប់ផ្តើម។ ដូច្នេះ ឥណទានមិនដំណើរការបានកើនឡើងយ៉ាងឆាប់រហ័សក្នុងឆ្នាំ២០០៩។

### ៤.៤.៧. អាជីវករប្តូរប្រាក់

នាពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមការចុះបញ្ជីអាជីវករប្តូរប្រាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។ អាជីវកម្មប្តូរប្រាក់ត្រូវបានអនុវត្តក្រៅប្រព័ន្ធធនាគារផ្លូវការ ហើយផ្តល់សេវាកម្ម ២៤ម៉ោង ដែលធនាគារពាណិជ្ជកម្មថ្មីៗនេះមិនបានផ្តល់ជូនទេ។ នៅក្នុងទីក្រុងភ្នំពេញនិងតាមបណ្តាខេត្តនានាមានការិយាល័យប្តូរប្រាក់ចំនួន៤,៣២០កន្លែង។

ការត្រួតពិនិត្យទៅលើអាជីវកម្មប្តូរប្រាក់ទាំងនេះ គួរត្រូវផ្តោតទៅលើការធ្វើអធិការកិច្ចដោយមិនជូនដំណឹងមុន ឬដោយឈរលើមូលដ្ឋាននៃការតវ៉ា ឬពាក្យបណ្តឹងស្តីពីការអនុវត្តមិនល្អរបស់អាជីវករទាំងនោះ។ ការត្រួតពិនិត្យគួរផ្តោតទៅលើកិច្ចការពារដល់អ្នកប្រើប្រាស់ និងការលើកកម្ពស់ការអនុវត្តល្អ។ ដើម្បីសម្រួលអាជីវកម្មនេះ អាជីវករទាំងអស់ត្រូវតែចុះបញ្ជី (អាជីវករប្តូរប្រាក់ត្រូវបានគេចុះបញ្ជីនាពេលបច្ចុប្បន្ន)។ គោលបំណងចម្បងនៃការចុះបញ្ជីបែបនេះ គឺដើម្បីផ្តល់ការធានាដល់អតិថិជនថា អាជីវករប្តូរប្រាក់ដែលបានចុះបញ្ជីមិនបានប្រព្រឹត្តសកម្មភាពផ្គេសផ្គាស់ ដែលមិនអាចទទួលយកបានឡើយ។

## ៤.៥. មីក្រូហិរញ្ញវត្ថុ

### ៤.៥.១. កំណើនឥណទានមីក្រូហិរញ្ញវត្ថុនិងប្រាក់បញ្ញើ

វិស័យមីក្រូហិរញ្ញវត្ថុកំពុងរីកដុះដាលយ៉ាងឆាប់រហ័ស។ ក្នុងឆ្នាំ២០០៧ ឥណទានមីក្រូហិរញ្ញវត្ថុបានកើនឡើងប្រមាណ៨០% ហើយស្ថាប័នមីក្រូហិរញ្ញវត្ថុខ្លះបង្កើនឥណទានដល់២០០%។ កំណើននេះបានធ្វើឱ្យវិស័យមីក្រូហិរញ្ញវត្ថុជួយគាំទ្រដល់កំណើនសេដ្ឋកិច្ចក្នុងតំបន់ដាច់ស្រយាល និងតំបន់ក្រីក្រខ្លាំង ដែលធនាគារពាណិជ្ជមិនអាចទៅដល់ ដោយសារតែហានិភ័យឥណទានខ្ពស់។

គិតត្រឹមដំណាច់ឆ្នាំ ២០០៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) មានអាជ្ញាប័ណ្ណមានចំនួន១៨ និងប្រតិបត្តិករឥណទានជនបទចុះបញ្ជីមានចំនួន២៦ ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមិនបានចុះបញ្ជីមានចំនួន៦០កំពុងដំណើរការក្នុងប្រទេសកម្ពុជា។ គ្រឹះស្ថានទាំងនេះមួយចំនួនត្រូវបានបង្កើតឡើង ជាអង្គការក្រៅរដ្ឋាភិបាល ដែលធ្លាប់ទទួលជំនួយឧបត្ថម្ភពីម្ចាស់ជំនួយ ប៉ុន្តែខ្លះទៀតត្រូវបានបង្កើតឡើងជា MFIs រកប្រាក់ចំណេញបែបពាណិជ្ជកម្មតាំងពីពេលដំណើរការតំបូង។ គ្រឹះស្ថានភាគច្រើនមានផែនការដើម្បីបន្តពង្រីកអាជីវកម្មឱ្យបានឆាប់រហ័ស ជាមួយនឹងការបង្កើតសាខាច្រើនថែមទៀត និងតាមរយៈការឱ្យខ្ចីកាន់តែច្រើននៅតាមសាខាដែលមានស្រាប់។ គិតត្រឹមដំណាច់ឆ្នាំ២០០៨ ឥណទានមីក្រូហិរញ្ញវត្ថុមានចំនួនសរុប ៨៥២,០៩០កម្ចីដែលមិនទាន់បានសង ជាមួយនឹងហានិភ័យសរុបចំនួន១,១៦១.៧ពាន់លានរៀល (២៧៤ លានដុល្លារអាមេរិក) ជាការកើនឡើង៨១%លើសពីឆ្នាំ២០០៧ ដែលបង្ហាញពីកំណើនឥណទានយ៉ាងឆាប់រហ័ស។ ខណៈដែលវិស័យមីក្រូហិរញ្ញវត្ថុមានការរីកចម្រើនយ៉ាងខ្លាំងក្លា អ្នកក្រីក្រភាគច្រើន ជាពិសេសអ្នកក្រីក្រតាមទីជនបទ មិនទាន់បានទទួលសេវាហិរញ្ញវត្ថុផ្លូវការនេះនៅឡើយទេ រួមទាំងសេវាមីក្រូហិរញ្ញវត្ថុផងដែរ។ នាពេលបច្ចុប្បន្ន កំណើននៃចំនួនឥណទានសរុបសម្រេចបានប្រមាណ១០% ក្នុងមួយឆ្នាំ។ ប្រាក់បញ្ញើមីក្រូហិរញ្ញវត្ថុបានកើនចំនួន៧% និងសម្រេចបាន២៦ពាន់លានរៀលក្នុងឆ្នាំ២០០៨ បានមកពីអ្នកដាក់ប្រាក់បញ្ញើចំនួន១៥៥,២៩១នាក់។ ដូច្នេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនត្រូវខ្ចីឥណទានពីក្រៅប្រទេស ក្នុង

គោលដៅផ្ដល់ឥណទានមីក្រូហិរញ្ញវត្ថុ។ អត្រាការប្រាក់នៃឥណទានមីក្រូហិរញ្ញវត្ថុនៅតែមានកម្រិតខ្ពស់ គឺ៣% ក្នុងមួយខែ សម្រាប់កម្ចីជាប្រាក់រៀល និង២.៥% ក្នុងមួយខែសម្រាប់កម្ចីជាប្រាក់ដុល្លារ។

លក្ខណៈពិសេសគួរឱ្យលើកទឹកចិត្តនៃការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ គឺ វិស័យនេះគ្មានលេចឡើងនូវសកម្មភាពបោកប្រាស់ផ្នែកហិរញ្ញវត្ថុអ្វីឡើយ ទោះបីជាវិស័យមីក្រូហិរញ្ញវត្ថុបាននិងកំពុងរីកដុះដាលយ៉ាងខ្លាំងក្លា។ មូលហេតុសំខាន់ គឺការត្រួតពិនិត្យដ៏តឹងរឹងនិងការគ្រប់គ្រងមានប្រសិទ្ធភាពរបស់ធនាគារជាតិនៃកម្ពុជា និងការយល់របស់គ្រឹះស្ថានទាំងនេះ ដែលធ្វើឱ្យពួកគេត្រូវតែរក្សាស្តង់ដារប្រុងប្រយ័ត្នខ្ពស់ ក្នុងបរិស្ថានប្រតិបត្តិការដែលមានហានិភ័យខ្ពស់មួយ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានប្រើប្រាស់គំរូជំនួញដ៏សម្បូរបែបមួយ ដើម្បីផ្ដល់សេវាកម្ម និងផលិតផលរបស់ខ្លួន។ ប្រការទាំងនេះមានសង្គតិភាព ជាមួយនឹងការពង្រឹងអភិបាលកិច្ចសាជីវកម្មល្អ និងការអភិវឌ្ឍទីផ្សារមានរបៀបរៀបរយ។ អនុបាតសាធនភាពរបស់MFIs សម្រេចបាន២០%ក្នុងឆ្នាំ២០០៨ បើធៀបនឹងតម្រូវការចំនួន១៥%។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបង្ហាញពីស្នាដៃរបស់ខ្លួន ក្នុងការគ្រប់គ្រងឥណទាន ការកាត់បន្ថយឥណទានអាក្រក់ និងឥណទានមិនដំណើរការ ដោយសម្រេចបាននូវការលប់ឥណទានចោលទាំងស្រុងតិចជា១%។

អនុបាតសងប្រាក់ហួសកាលកំណត់បានធ្លាក់ចុះពី០.៨% ក្នុងឆ្នាំ២០០៥ មកត្រឹម០.៤២% ក្នុងឆ្នាំ២០០៨។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់កម្ពុជាបានទទួលបាននូវជ័យលាភីខាងផ្នែកតម្លាភាពហិរញ្ញវត្ថុចំនួន ៤ ក្នុងចំណោមជ័យលាភីទាំងអស់ចំនួន ២០ ដែលបានផ្ដល់ដោយក្រុមប្រឹក្សាយោបល់ដើម្បីជួយជនក្រីក្រ។ ប្រការនេះបង្ហាញថា ស្តង់ដារនៃប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាបានឈានដល់កម្រិតមួយយ៉ាងខ្ពស់ ។ វិស័យមីក្រូហិរញ្ញវត្ថុប្រើប្រាស់បុគ្គលិកជាង៥,០០០នាក់ ក្នុងឆ្នាំ២០០៨។

ទោះបីមានការអភិវឌ្ឍដ៏វិជ្ជមានទាំងនេះក្ដី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការខ្វះខាតមូលនិធិ ដោយសារតម្រូវការឥណទានខ្ពស់ជាងការផ្គត់ផ្គង់យ៉ាងច្រើន។ គេបានប៉ាន់ស្មានថា កម្ពុជាត្រូវការឥណទានមីក្រូហិរញ្ញវត្ថុ ដែលលើសពីការផ្គត់ផ្គង់ប្រហែល៦០-៧០លានដុល្លារអាមេរិក។ ទន្ទឹមនឹងនេះ វិស័យនេះក៏ត្រូវការផងដែរនូវបុគ្គលិកដែលមានជំនាញ និងគុណសម្បត្តិខ្ពស់ផងដែរ។ ក្នុងន័យនេះ វិស័យមីក្រូហិរញ្ញវត្ថុត្រូវពង្រឹងថែមទៀតនូវហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ។

### ៤.៥.២. ឧស្សូនវិស័យនិជ័បញ្ហា

ក្នុងគោលដៅបង្កើនឥណទានមីក្រូហិរញ្ញវត្ថុ ស្ថាប័នពាក់ព័ន្ធគួរដាក់ចេញវិធានការដូចតទៅ៖

- បង្កើនតម្រូវការនិងពង្រឹងការត្រួតពិនិត្យការបង់ពន្ធ ដោយតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយនូវរបាយការហិរញ្ញវត្ថុ
- កាត់បន្ថយចំណាយក្នុងការទទួលបាននូវប័ណ្ណកម្មសិទ្ធិដីធ្លី ដើម្បីឱ្យធនាគារអាចប្រើប្រាស់បានកាន់ទូលំទូលាយជាវត្ថុបញ្ចាំ ក្នុងការផ្ដល់ឥណទាន
- ពង្រឹងប្រព័ន្ធតុលាការ និងនីតិវិធីក្នុងការប្ដឹងរកយុត្តិធម៌ ដោយដាក់ឱ្យដំណើរការនូវតុលាការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាណិជ្ជកម្ម ដែលជាផ្នែកមួយនៃវិធានការធ្វើឱ្យប្រតិបត្តិការពាណិជ្ជកម្មគួរឱ្យទុកចិត្តបាន

ចាប់តាំងពីឆ្នាំ២០០០ ធនាគារជាតិនៃកម្ពុជាបានពង្រឹងវិធានការមួយចំនួន ក្នុងគោលដៅបំពេញនូវកង្វះខាតនៃប្រព័ន្ធធនាគារ៖

- ទីមួយ-ជំហានសំខាន់ដំបូងគឺការបង្កើតឡើងនូវប្រព័ន្ធធនាគារ ដែលមានពីរកម្រិត ៖ កម្រិតទីមួយ គឺធនាគារកណ្តាលដែលបំពេញតួនាទីជាអាណាព្យាបាលលើប្រព័ន្ធធនាគារ និងកម្រិតទីពីរ គឺធនាគារពាណិជ្ជជាប្រតិបត្តិករ។ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវគោលនយោបាយបង្កើតប្រព័ន្ធធនាគារពីរកម្រិតនេះ តាមរយៈការធ្វើឯកជននីយកម្មនៃធនាគារពាណិជ្ជកម្មបរទេស ដើម្បីបង្កើតបរិយាកាសយុត្តិធម៌មួយ សម្រាប់ការប្រកួតប្រជែងដោយសេរី និងឈរលើលក្ខខណ្ឌស្មើគ្នា។
- ទីពីរ-ធនាគារជាតិនៃកម្ពុជាបានអនុវត្តកម្មវិធីកំណែទម្រង់មួយ ដើម្បីអនុវត្តច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ឥណទានមិនដំណើរការក៏ត្រូវបានដោះស្រាយយ៉ាងហ្មត់ចត់។
- ទីបី- ការកែលម្អបទបញ្ញត្តិពាក់ព័ន្ធនឹងមូលនិធិផ្ទាល់ខ្លួនសុទ្ធ និងចំណាត់ថ្នាក់ឥណទានតាមកម្រិតនៃហានិភ័យ។វិធានប្រុងប្រយ័ត្នរួមមាន៖ បទដ្ឋានសម្រាប់មូលនិធិផ្ទាល់ខ្លួនសុទ្ធ ទុនបម្រុងជារូបិយ-ប័ណ្ណបរទេស ចំណាត់ថ្នាក់ឥណទាននិងសំវិធានធនចំពោះឥណទានបាត់បង់ ប្រតិបត្តិការជាមួយនឹងសហគ្រាសសម្ព័ន្ធញាតិ ការច្របាច់បញ្ចូលគ្នា សវនកម្មផ្ទៃក្នុងនិងផ្ទៃក្រៅ និងការបែងចែកហានិភ័យ។ ធនាគារជាតិនៃកម្ពុជាបានពង្រឹងតួនាទីរបស់នាយកដ្ឋានត្រួតពិនិត្យ ក្នុងការអនុវត្តឱ្យបានហ្មឹងម៉ាត់ នូវបទបញ្ញត្តិស្តីពីវិធានការប្រុងប្រយ័ត្ន។ ក្នុងន័យនេះ នាយកដ្ឋានត្រួតពិនិត្យបានពង្រឹងដំណើរការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារពាណិជ្ជដោយផ្អែកលើហានិភ័យ និងទស្សនៈអនាគត និងដាក់ចេញនូវសកម្មភាពកែតម្រូវ និងការតាមដានបន្ត ជាពិសេសធ្វើអន្តរាគមន៍ទាន់ពេលវេលាចំពោះគ្រឹះស្ថានដែលមានបញ្ហា។
- ទីបួន-ពង្រឹងប្រព័ន្ធទូទាត់អន្តរធនាគារ។ ប្រព័ន្ធទូទាត់របស់កម្ពុជាផ្អែកយ៉ាងខ្លាំងលើការទូទាត់ជាសាច់ប្រាក់។កំណែទម្រង់មានគោលដៅពង្រឹងប្រព័ន្ធនេះតាមរយៈការដាក់ឱ្យអនុវត្តនូវឧបករណ៍បន្ថែមទៀត ដូចជាមូលប្បទានប័ត្រ ប័ណ្ណចំណាយ កាតឥណទាន និងឥណពន្ធប័ណ្ណ ប្រាក់ការផ្ទេរដោយស្វ័យប្រវត្តិពីសភាផាត់ទាត់ បេឡាករធនាគារស្វ័យប្រវត្តិ។ល។ ការប្រើប្រាស់កាន់តែកើនឡើងនៃការទូទាត់អេឡិចត្រូនិច និងឥណទាន-ឥណពន្ធដោយផ្ទាល់នឹងបង្កើនប្រាក់បញ្ញើមូលដ្ឋាន និងចំនួនផ្ញើប្រាក់។

ការដ្ឋានកំណែទម្រង់ទាំងនេះកំពុងតែត្រូវអនុវត្តបន្ត។ កង្វះខាតរបាយការណ៍ហិរញ្ញវត្ថុគួរឱ្យទុកចិត្តបាន ដែលក្រុមហ៊ុនត្រូវបោះផ្សាយ គឺជាឧបស័គ្គដ៏សំខាន់ ដែលរារាំងដល់ការបង្កើនឥណទានជូនដល់អតិថិ-ជនដែលរស់នៅតាមគ្រប់ទីកន្លែង។ ធនាគារពាណិជ្ជពិតជាមិនអាចវាយតម្លៃឱ្យបានត្រឹមត្រូវ នូវកាលានុវត្ត-ភាពជាសក្តានុពលរបស់អតិថិជនបានឡើយ ប្រសិនបើគ្មានតម្លាភាព និងស្តង់ដារផ្តល់ព័ត៌មានអោយបានជាក់លាក់។ ជាងនេះទៅទៀត ច្បាប់ក្ស័យធន និងពាណិជ្ជកម្មដែលចូលជាធរមានក្នុងពេលថ្មីៗនេះ មិនទាន់មានការអនុវត្តឱ្យបានទូលំទូលាយនៅឡើយ ដែលជាកត្តាមួយធ្វើឱ្យធនាគារពាណិជ្ជមានលំបាក។

ភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុ គឺ អាស្រ័យលើភាពល្អប្រសើរនៃមូលដ្ឋានហិរញ្ញវត្ថុរបស់វា ទាក់ទង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នឹងមូលនិធិប្រភពផ្ទាល់ខ្លួន។ សមិទ្ធផលដ៏ខ្សោយនៃប្រព័ន្ធធនាគារ ក្នុងការផ្តល់ហិរញ្ញប្បទានវិនិយោគទុនអាចបណ្តាលមកពីឱនភាពនៃមូលនិធិប្រភពផ្ទាល់ខ្លួន នៅក្នុងទ្រព្យសកម្មរយៈពេលវែង និងអតុល្យភាពដែលកើតឡើងនៅពេលដែល ការឱ្យខ្ចីរយៈពេលវែងពឹងផ្អែកលើប្រាក់បញ្ញើរយៈពេលខ្លី។

ដោយសារតែការផ្លាស់ប្តូរនៃបរិស្ថានក្នុងការទូទាត់ ដែលស្ថាប័នហិរញ្ញវត្ថុកំពុងប្រឈមមុខ នោះការធ្វើទំនើបកម្មនៃប្រព័ន្ធសភាផាត់ទាត់ បានក្លាយជាអាទិភាពដ៏កំពូលមួយ ក្នុងកំណែទម្រង់ធនាគារ។ ដូច្នេះអាជ្ញាធររូបិយវត្ថុត្រូវបង្កើតឱ្យបានរួសរាន់ នូវប្រព័ន្ធសភាផាត់ទាត់ពីចម្ងាយមួយ ដែលអតិថិជនមានជំនឿទុកចិត្ត និងដែលដំណើរការប្រកបដោយប្រសិទ្ធភាព។ យន្តការសភាផាត់ទាត់ថ្មីនេះត្រូវធ្វើការផាត់ទាត់ក្នុងរយៈពេលពីរថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃប្រតិបត្តិការ ដោយមិនគិតពីទីកន្លែងនៃការទូទាត់ និងតម្លៃនៃឧបករណ៍ផាត់ទាត់ (មូលប្បទានប័ត្រ ឧបករណ៍ ឬការផ្ទេរ)។ អត្ថប្រយោជន៍ចម្បងនានា រួមមានការធ្លាក់ចុះនៃចំណាយឯកតានៃដំណើរការផាត់ទាត់ ការកែលម្អនៃផលិតភាពរបស់ធនាគារ និងការកើនឡើងនៃប្រាក់ចំណេញ ក៏ដូចជាការកើនឡើងនៃគុណភាពនៃសេវាកម្មដែលបានផ្តល់ជូនអតិថិជន។

ការប្រើប្រាស់កាន់តែច្រើនឡើងៗនៃឧបករណ៍ទូទាត់ (មូលប្បទានប័ត្រ ការដកប្រាក់ រូបិយណត្តិ និងការផ្ទេរ) បានជំរុញឱ្យមានការអភិវឌ្ឍនៃទូទាត់អេឡិចត្រូនិច និងមានឥទ្ធិពលជាវិជ្ជមានទៅលើចំណាយប្រតិបត្តិការធនាគារ។ ដំណើរការនេះត្រូវតែបង្កើនល្បឿន។ តែទោះជាយ៉ាងណាក៏ដោយ គេត្រូវធានាសន្តិសុខនៃប្រតិបត្តិការធនាគារ នៅពេលដែលដំណើរការប្រព័ន្ធធនាគារត្រូវបានរៀបចំដោយប្រព័ន្ធកុំព្យូទ័រ។ ការលើកកម្ពស់សន្តិសុខនៃប្រព័ន្ធកុំព្យូទ័រ គឺជាអាទិភាពខ្ពស់ជាងគេមួយ។ ជាមួយនឹងការកើនឡើងជាបន្តនៃបរិមាណនៃប្រតិបត្តិការធនាគារ នោះកុំព្យូទ័របានក្លាយជាឧបករណ៍ដ៏សំខាន់មួយ ក្នុងការគ្រប់គ្រងធនាគារ និងការចុះបញ្ជិការគណនេយ្យ។ ការដាច់ចរន្តអគ្គិសនី ឬ ការបិទប្រព័ន្ធកុំព្យូទ័រ គឺជាការគំរាមកំហែងមួយសម្រាប់ប្រតិបត្តិការរបស់ធនាគារ និងអាចឱ្យខូតខាតដល់មុខមាត់ក្រុមហ៊ុនរបស់ខ្លួន និងប៉ះពាល់ដល់សន្តិសុខនៃប្រតិបត្តិការធនាគារ។ ដើម្បីពង្រឹងសន្តិសុខកុំព្យូទ័រផ្ទៃក្នុង នោះគេត្រូវបង្កើតមជ្ឈមណ្ឌលផ្ទុកឯកសារថតចម្លងខាងក្រៅ ដែលអាចចម្លង និងផ្ទុកទិន្នន័យ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៥
# វិស័យធានារ៉ាប់រង

## ៥.១. ទីផ្សារធានារ៉ាប់រង - និន្នាការរួម

ឧស្សាហកម្មធានារ៉ាប់រងនៅប្រទេសកម្ពុជាទើបនឹងចាប់ផ្ដើមចាក់ឫសគល់ នាពេលថ្មីៗនេះ ហើយកំពុងតែវិវឌ្ឍឈានទៅមុខ។ រចនាសម្ព័ន្ធហានិភ័យ និងការកំណត់ថ្លៃនៃឧស្សាហកម្មនេះ នៅមិនទាន់ត្រូវបានគេយល់ច្បាស់នៅឡើយ។ ដូច្នេះហើយ ទើបក្រុមហ៊ុនធានារ៉ាប់រងខ្លះបានអំពាវនាវ សុំឱ្យអាជ្ញាធរបន្ធូរបន្ថយនូវតម្រូវការនិយតកម្មមួយចំនួន។

### ៥.១.១. និយ័តកម្មនៃឧស្សាហកម្មធានារ៉ាប់រង

ឧស្សាហកម្មធានារ៉ាប់រងនៅកម្ពុជា ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីធានារ៉ាប់រង ដែលចូលជាធរមានក្នុងខែមិថុនាឆ្នាំ២០០០។ ច្បាប់ស្ដីពីធានារ៉ាប់រងត្រូវបានបំពេញបន្ថែម ដោយអនុក្រឹត្យស្ដីពីធានារ៉ាប់រង ដែលត្រូវបានអនុម័តនៅថ្ងៃទី២២ខែតុលាឆ្នាំ២០០១ ដែលចែងយ៉ាងលម្អិតនូវកិច្ចសន្យាធានារ៉ាប់រង។

ច្បាប់ស្ដីពីធានារ៉ាប់រង និងអនុក្រឹត្យតម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ (មានសកម្មភាពឬគ្មានសកម្មភាព) ធ្វើការចុះបញ្ជីមូលធនជាប្រាក់រៀល ដែលកម្រិតអប្បបរមាត្រូវស្មើនឹង៥,០០០,០០០SDR ឬ ៧ លានដុល្លារអាមេរិក។

ក្នុងឆ្នាំ២០០២ ដោយយល់ឃើញថាឧស្សាហកម្មធានារ៉ាប់រងនៅមានទំហំតូច និងខ្វះខាតមូលធនសម្រាប់ដំណើរការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្ដល់ភាពទន់ភ្លន់ ក្នុងការអនុវត្តមូលធនអប្បបរមាសម្រាប់ដំណើរការក្រុមហ៊ុន ដោយផ្ដល់ឱ្យក្រុមហ៊ុនទាំងនោះនូវរយៈពេលបន្ធូរបន្ថយ ក្នុងរយៈពេលប្រាំឆ្នាំ ដើម្បីគោរពទៅតាមតម្រូវការមូលធន។

ដើម្បីទទួលបានអាជ្ញាប័ណ្ណធានារ៉ាប់រង ក្រុមហ៊ុនត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បង់ប្រាក់តម្កល់ចំនួន១០% នៃមូលធនដែលបានចុះបញ្ជី (៧លានដុល្លារអាមេរិក) ចូលទៅក្នុងគណនីបញ្ញើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឯធនាគារជាតិនៃកម្ពុជា។ ប្រការនេះ គឺដើម្បីការពារសាធារណជនពីហានិភ័យដែលអាចកើតឡើង ដែលបណ្ដាលដោយការក្ស័យធនរបស់ក្រុមហ៊ុនធានារ៉ាប់រង។
- បង់ប្រាក់តម្កល់ចំនួន៥០%នៃមូលធនដែលបានចុះបញ្ជី(៧លានដុល្លារអាមេរិក)ចូលទៅក្នុងគណនីណាមួយដោយនៃធនាគារពាណិជ្ជកម្ម ដែលត្រូវបានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់នេះត្រូវបានចាត់ទុកថា ជាអប្បហារសាធនភាពមួយ ដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវរក្សាទុក។

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានភារកិច្ចធ្វើការត្រួតពិនិត្យទៅលើក្រុមហ៊ុនធានារ៉ាប់រង។ ដំណើរការត្រួតពិនិត្យនេះរួមមាន៖ ការប្រមូលស្ថិតិពីក្រុមហ៊ុនធានារ៉ាប់រង ការវិភាគទិន្នន័យដែលទទួលបាន ការដាក់ចេញនូវវិធានការអនុវត្តបន្តបន្ទាប់ពីរកឃើញបញ្ហាផ្សេងៗ និងការធ្វើអធិការកិច្ចនៅកន្លែងដោយក្រុមនិយ័តករផងដែរ។

ដោយអនុលោមតាមនីតិវិធីបច្ចុប្បន្ន ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្ដល់របាយការណ៍ហិរញ្ញវត្ថុពេញលេញ អមដោយលិខិតបញ្ជាក់របស់សវនករម្ដងក្នុងមួយឆ្នាំ។ អ្នកត្រួតពិនិត្យអាចប្រមូលព័ត៌មានស្ថិតិបន្ថែមក្នុងរយៈពេលនៅក្នុងឆ្នាំនីមួយៗ។ ម្យ៉ាងទៀត ក្រុមហ៊ុនធានារ៉ាប់រងត្រូវបំពេញទម្រង់បែបបទ សម្រាប់អ្នកត្រួតពិនិត្យធានារ៉ាប់រងអាស៊ានផងដែរ បន្ថែមលើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម។

## ៥.១.២. ទីផ្សារធានារ៉ាប់រងក្នុងប្រទេសកម្ពុជា

ឧស្សាហកម្មធានារ៉ាប់រងសម្រេចបាននូវកំណើនថេរ ក្នុងអត្រាពី១១ទៅ៤២% ក្នុងមួយឆ្នាំក្នុងរយពេល៧ឆ្នាំចុងក្រោយនេះ។ បុព្វលាភធានារ៉ាប់រងដុលបានកើនឡើងច្រើនជាងប្រាំពីរដង ពីកម្រិតទាប មួយចំនួន២.៣លានដុល្លារអាមេរិកក្នុងឆ្នាំ២០០០ ទៅដល់១៧.៥លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៧។ ក៏ប៉ុន្តែឧស្សាហកម្មហិរញ្ញវត្ថុនៅកម្ពុជាមិនទាន់មានផលិតផលធានារ៉ាប់រងឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ។ នៅក្នុងឆ្នាំ២០០៧ បុព្វលាភធានារ៉ាប់រងបានកើនឡើងយ៉ាងខ្លាំង ហើយសម្រេចបានចំនួន៥.៤លានដុល្លារ បើប្រៀបធៀបនឹងឆ្នាំ២០០៦ ដោយសារតែការធានារ៉ាប់រងខាងឧស្សាហកម្មប្រេងនិងឧស្ម័ន។

*រូបភាព៥.១. បុព្វលាភធានារ៉ាប់រងដុលក្នុងប្រទេសកម្ពុជា*




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

គិតត្រឹមចុងខែធ្នូឆ្នាំ ២០០៧ មានក្រុមហ៊ុនធានារ៉ាប់រងចំនួន៥ ដែលកំពុងប្រតិបត្តិការក្នុងប្រទេសកម្ពុជា៖ គឺ Forte, Asia Insurance, Caminco, Infinity Insurance, និង Long Pac Insurance និងក្រុមហ៊ុនធានារ៉ាប់រងបន្ត Cambodia Re។

*រូបភាព៥.២. ចំណែកទីផ្សារធានារ៉ាប់រងតាមក្រុមហ៊ុន*




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រុមហ៊ុនធានារ៉ាប់រង Forte មានចំណែកទីផ្សារចំនួន ៥០% នៃបុព្វលាភដុលលើទីផ្សារធានារ៉ាប់រង បន្ទាប់មកគឺ Asia Insurance ដែលមានចំណែក៣៥%។ ក្រុមហ៊ុនផ្សេងទៀតកំពុងប្រកួតប្រជែងដណ្តើមទីផ្សារដូចជា Caminco (១០%) Campu Bank Lonpac (៣%) និង Infinity (២%)។ ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ត្រូវប្រគល់បុព្វលាភធានារ៉ាប់រងចំនួន១០% ទៅឱ្យ Cambodia Re ដើម្បីធ្វើការធានារ៉ាប់រងហានិភ័យបន្ត។

ផលិតផលធានារ៉ាប់រងសំខាន់ជាងគេលើទីផ្សារ គឺគ្រោះអគ្គីភ័យ (២៧%នៃតម្លៃទ្រព្យសម្បត្តិសរុបសម្រាប់ធ្វើការធានារ៉ាប់រង) បន្ទាប់មកគឺការធានារ៉ាប់រងយានយន្ត (១៩%)។ ការធានារ៉ាប់រងលើគ្រោះភ័យឯទៀតរួមមានៈ ការធានារ៉ាប់រងហានិភ័យដែលពាក់ព័ន្ធនឹងមន្ទីរពេទ្យ និងការវះកាត់ ការធានារ៉ាប់រងឧប្បទវហេតុបុគ្គល ការដឹកជញ្ជូនទំនិញតាមសមុទ្រ និងការធ្វើការធានារ៉ាប់រងអ្នកធ្វើដំណើរ។ ការធ្វើការធានារ៉ាប់រងប្រេងនិងឧស្ម័នបានក្លាយជាផលិតផលមួយ ក្នុងចំណោមផលិតផលធានារ៉ាប់រងដ៏សកម្ម។

ផលិតផលផ្សេងៗ (ចោរគាស់ផ្ទះ ចោរលួច ការទទួលខុសត្រូវ ការធ្វើដំណើរ ការធានាភាពស្មោះត្រង់របស់បុគ្គលិក ការទទួលខុសត្រូវរួមរបស់តតិយជន និងការទទួលខុសត្រូវរបស់និយោជក) មានចំណែកធំជាងគេនៃបុព្វលាភរ៉ាប់រងក្នុងឆ្នាំ២០០៧ ឬក៏២៩%នៃទីផ្សារ (៤.៩លានដុល្លារអាមេរិក)។

*តារាង៥.១. ក្រុមហ៊ុនធានារ៉ាប់រងតាមប្រភេទជំនួញ*

| *សកម្មភាព តាមវិស័យ* | *ASIA* | *CAMINCO* | *LONPAC* | *FORTE* | *INFINITY* | *សរុប* |
|---|---|---|---|---|---|---|
| យានយន្ត | 801 256 | 1 074 475 | 112 117 | 950 955 | 85 977 | 3 024 781 |
| អគ្គីភ័យ | 959 899 | 306 444 | 185 078 | 2 641 500 | 39 309 | 4 132 231 |
| ដឹកនាំតាមសមុទ្រ | 171 126 | 19 947 | 9 180 | 223 677 | 1 683 | 425 614 |
| វិស្វកម្ម | 1 383 762 | 71 980 | 35 263 | 335 744 | 2 813 | 1 829 562 |
| គ្រោះថ្នាក់នៅកន្លែងធ្វើការ | 171 053 | 13 295 | - | 5 424 | - | 189 772 |
| ឧប្បទវហេតុ | 371 047 | 135 138 | 28 537 | 1 076 925 | 73 327 | 1 684 975 |
| មន្ទីរពេទ្យ និង ការវះកាត់ | 290 629 | 16 386 | 5 483 | 826 713 | 82 310 | 1 221 521 |
| ផ្សេងៗទៀត | 1 937 933 | 65 678 | 143 730 | 2 740 587 | 97 363 | 4 985 291 |
| សរុប | 6 086 705 | 1 704 695 | 519 389 | 8 801 527 | 382 783 | 17 493 747 |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

អគ្គីភ័យជាប់លំដាប់ទីពីរ បើគិតជាចំណែកភាគលាភលើទីផ្សារ ដែលមានចំនួន៤.១លានដុល្លារអាមេរិក (២៤%នៃបុព្វលាភធានារ៉ាប់រង)។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### *រូបភាព៥.៣. ចំណែកផលិតផលធានារ៉ាប់រង*




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ផលិតផលបន្ទាប់គឺការធានារ៉ាប់រងយានយន្ត ដែលចំនួន៣លានដុល្លារ ឬ១៧%នៃទីផ្សារ។ សំណងឧប្បទវហេតុបុគ្គល និងគ្រោះថ្នាក់នៅកន្លែងធ្វើការជាប់លំដាប់ទីបួន ហើយសម្រេចបានចំនួន១.៨លានដុល្លារ ឬក៏១១%នៃបុព្វលាភធានារ៉ាប់រងលើទីផ្សារ។

ផលិតផលវិស្វកម្មសម្រេចបាន១.៨លានដុល្លារ បន្ទាប់មកគឺ ការធានារ៉ាប់រងសុខភាព និងការវះកាត់ចំនួន ១.២លានដុល្លារ និងការដឹកនាំទំនិញតាមសមុទ្រសម្រេចបាន ០.៤លានដុល្លារ។

### *រូបភាព៥.៤. សំណងធានារ៉ាប់រងសរុបតាមប្រភេទផលិតផល*




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

សំណងលើការធានារ៉ាប់រងគ្រោះអគ្គីភ័យ គឺជាប្រភេទសំណងដែលកើតមានឡើងញឹកញាប់ជាងគេ ហើយកាន់តែកើនឡើងច្រើនឡើងៗ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេស ក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុពិភពលោក។ សំណងធំផ្សេងទៀត គឺពាក់ព័ន្ធទៅនឹងយានយន្តនិងផលិតផលផ្សេងៗ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## ៥.២. កំណែទម្រង់ក្នុងវិស័យធានារ៉ាប់រង

ឧស្សាហកម្មធានារ៉ាប់រងត្រូវដើរតួនាទីពិសេស ដែលខុសពីវិស័យហិរញ្ញវត្ថុដទៃទៀត។ ដោយឧស្សាហកម្មធានារ៉ាប់រងនៅកម្ពុជានៅក្មេងខ្ចីនៅឡើយ នោះកម្ពុជាខ្វះអ្នកឯកទេសខាងផ្នែកធានារ៉ាប់រងនេះ ដូច្នេះហើយ កម្ពុជាត្រូវតែបណ្ដុះបណ្ដាលធនធានមនុស្សខាងផ្នែកនេះ (*ឧ.* អ្នកចេញប័ណ្ណធានារ៉ាប់រង អ្នកវាតម្លៃសុវត្ថិភាពហិរញ្ញវត្ថុ អ្នកវាយតម្លៃការខាតបង់ និងអ្នកគ្រប់គ្រងមូលនិធិ)។

ឧស្សាហកម្មធានារ៉ាប់រងត្រូវដោះស្រាយបញ្ហាប្រឈមជាអាទិភាពដូចតទៅ៖

- **ការពិនិត្យឡើងវិញនៃឧស្សាហកម្មនេះទាំងមូល** ដើម្បីធានាបាននូវការអនុវត្តបទពិសោធល្អៗបំផុតលើពិភពលោក។
- **ការរៀបចំស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ៖** ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងត្រូវឈរលើមូលដ្ឋាននៃវិធានច្បាស់លាស់ចំពោះការធ្វើសំវិធានធនជាមូលធនបម្រុងចំពោះសំណង ដែលអាចកើតឡើងនៅពេលអនាគត និងស្តង់ដារស្តីពីការធ្វើសវនកម្មលើក្រុមហ៊ុនធានារ៉ាប់រងត្រូវតែកំណត់ឱ្យបានច្បាស់លាស់។
- **បញ្ហាដែលជាក់ទងនៅនឹងនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ៖** ត្រូវកសាងសមត្ថភាពរបស់បុគ្គលិកនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ រួមមានការបណ្ដុះបណ្ដាល កិច្ចសហប្រតិបត្តិការ និងការចែករំលែកធនធានក្នុងតំបន់ ដោយលើកទឹកចិត្តដល់មន្ត្រីជំនាញ រួមមានការប្រើប្រាស់របបធ្វើរបាយការណ៍ជាឯកសារអេឡិចត្រូនិច ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការចូលជាសមាជិកក្នុងសហគមន៍អន្តរជាតិនៃអ្នកត្រួតពិនិត្យធានារ៉ាប់រង (IAIS)។
- **ឯកជននីយកម្មក្រុមហ៊ុន CAMINCO៖** ការធ្វើឯកជននីយកម្មក្រុមហ៊ុន CAMINCO គឺជាដំណាក់កាលចុងក្រោយនៃការធ្វើឯកជនភាវូបនីយកម្មនៃវិស័យធានារ៉ាប់រងនៅកម្ពុជា។
- **កិច្ចសហការអន្តរក្រសួង៖** ក្រុមទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយធានារ៉ាប់រង រួមទាំងបុគ្គលិកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលពាក់ព័ន្ធនោះ គួរចូលរួមក្នុងគណៈកម្មាធិការអន្តរក្រសួង ជាមួយនឹងតំណាងក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយ-កម្មនិងសំណង់ ក្រសួងទេសចរណ៍ និងក្រសួងមហាផ្ទៃ ដើម្បីរិះរកវិធានការ ក្នុងការលើកកម្ពស់ការគោរពវិធានស្តីពីការធានារ៉ាប់រងយានយន្ត និងការដ្ឋានសំណង់ជាកាតព្វកិច្ច។
- **ការគាំទ្រដល់ការអភិវឌ្ឍការធានារ៉ាប់រងអាយុជីវិត៖** តាមរយៈការសិក្សាពីលទ្ធភាពក្នុងការរៀបចំឱ្យមានការធានារ៉ាប់រងជីវិត និងការរៀបចំក្របខ័ណ្ឌគតិយុត្តិនិងនិយ័តកម្ម ជាពិសេសការវាយតម្លៃពីសក្ដានុពលទីផ្សារ និងការរៀបចំផលិតផលមីក្រូហិរញ្ញវត្ថុផងដែរ។
- **វិស័យមីក្រូធានារ៉ាប់រង៖** រៀបចំយន្តការដើម្បីធ្វើនិយ័តកម្ម និងធ្វើការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលផ្តល់នូវការពារធានារ៉ាប់រងចំពោះសមាជិករបស់ខ្លួន។ វិធានសម្រាប់អនុវិស័យនេះត្រូវឱ្យធូររលុង ជាងវិធានដែលប្រើប្រាស់ចំពោះក្រុមហ៊ុនធានារ៉ាប់រងទូទៅ ដោយរួមបញ្ចូល

ទាំងលក្ខខណ្ឌកំណត់អំពី ប្រភេទនៃគ្រឹះស្ថាន ដែលអាចផ្តល់ផលិតផលមីក្រូធានារ៉ាប់រង និងកំណត់ដែនកំណត់សមស្របទៅលើវិសាលភាពនៃប្រតិបត្តិការក្រុមហ៊ុនទាំងនេះ។

- **ការធានារ៉ាប់រងជីវិត៖** ការអភិវឌ្ឍយុទ្ធសាស្ត្រសមស្រប សម្រាប់ការអភិវឌ្ឍធានារ៉ាប់រងជីវិត ដែលរួមមាន សមាសធាតុសំខាន់ៗនៃក្របខ័ណ្ឌគតិយុត្ត និងការរៀបចំការសិក្សាអំពីការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តិនិងនិយតកម្ម។ ការសិក្សានេះត្រូវផ្តោតលើការវាយតម្លៃអំពីសក្តានុពលទីផ្សារសម្រាប់ការធានារ៉ាប់រងជីវិតនៅកម្ពុជា ដោយរួមទាំងការដាក់អោយអនុវត្តនូវមីក្រូធានារ៉ាប់រង។ ក្នុងន័យនេះ កម្ពុជាត្រូវពិនិត្យឡើងវិញនូវក្របខ័ណ្ឌនិយតកម្មនិងគតិយុត្តិ ដែលពាក់ព័ន្ធនឹងការផ្តល់អាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនធានារ៉ាប់រងជីវិត។

វិធានការជាអាទិភាពសម្រាប់រយៈពេលមធ្យមមានដូចតទៅ៖

- **ធានារ៉ាប់រងជីវិត៖** អនុញ្ញាតឱ្យមានកិច្ចសន្យាធានារ៉ាប់រងជីវិតដែលជាមធ្យោបាយគៀរគរធនធានសម្រាប់ការដាក់ឱ្យអនុវត្តនូវមូលនិធិសោធននិវត្តន៍ និងផែនការសន្សំប្រាក់សម្រាប់និវត្តជន។
- **ការគណនាតម្លៃ៖** នៅកម្ពុជានៅមិនទាន់មានអ្នកឯកទេសខាងវាយតម្លៃសុវត្ថិភាពហិរញ្ញវត្ថុ (actuaries) នៅឡើយ ហើយការបង្កើតឡើងនូវសហគ្រាសខាងផ្នែកវាយតម្លៃសុវត្ថិភាពហិរញ្ញវត្ថុប្រហែលជាមិនទាន់អាចទៅរួចទេ។ ការវាយតម្លៃសុវត្ថិភាពហិរញ្ញវត្ថុនេះ នឹងជួយកំណត់កាតព្វកិច្ចខាងផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងរយៈពេលវែង សម្រាប់ក្រុមហ៊ុនធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍។ នៅក្នុងទីផ្សារដែលកំពុងអភិវឌ្ឍភាគច្រើន ដើម្បីរកអ្នកឯកទេសខាងគណនាសុវត្ថិភាពហិរញ្ញវត្ថុ ចាំបាច់ស្វែងរកនៅតាមការិយាល័យអន្តរជាតិ ដែលស្ថិតនៅក្នុងមជ្ឈមណ្ឌលសំខាន់ៗ។ ដូច្នេះ ដើម្បីបង្កើតឡើងនូវការធានារ៉ាប់រងជីវិត អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំនូវលិខិតបទដ្ឋានពាក់ព័ន្ធនឹងការអនុញ្ញាតឱ្យប្រើអ្នកឯកទេសជនជាតិបរទេស ដែលមានជំនាញខាងផ្នែកវាយតម្លៃសុវត្ថិភាពហិរញ្ញវត្ថុ ក្នុងគោលដៅធ្វើការវាយតម្លៃសំណើពាក់ព័ន្ធនឹងការធានារ៉ាប់រងជីវិត និងមូលនិធិសោធននិវត្តន៍។
- **វិទ្យាស្ថានបណ្តុះបណ្តាល៖** នាពេលបច្ចុប្បន្ន មិនមានស្ថាប័នបណ្តុះបណ្តាលផ្នែកធានារ៉ាប់រងទេ។ យើងត្រូវកសាងសមត្ថភាពរបស់បុគ្គលិកនៃក្រុមហ៊ុនធានារ៉ាប់រងឯកជន និងរបស់បុគ្គលិកដែលត្រួតពិនិត្យក្រុមហ៊ុន។ ប្រសិនបើឧស្សាហកម្មនេះបង្ហាញពីកំណើនដ៏ខ្លាំងក្លានោះក្នុងរយៈពេលមធ្យម អាជ្ញាធរមានសមត្ថកិច្ចត្រូវពិចារណាបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលផ្នែកធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា។ វិទ្យាស្ថាននេះអាចរួមចំណែក ក្នុងការបណ្តុះបណ្តាលអ្នកលក់ប័ណ្ណធានា-រ៉ាប់រង អ្នកត្រួតពិនិត្យ និងអ្នកគ្រប់គ្រងការិយាល័យ។
- **ការការពារអ្នកប្រើប្រាស់និងការយល់ដឹងរបស់អ្នកប្រើប្រាស់ ៖** ធានារ៉ាប់រង គឺជាជំនួញមួយពាក់ព័ន្ធនឹងកិច្ចសន្យា។ ដើម្បីឱ្យជំនួញធានារ៉ាប់រងរីកដុះដាល ភាគីដែលចុះកិច្ចសន្យាត្រូវមានចំណេះដឹងឱ្យបានច្រើនអំពីលក្ខខណ្ឌនៃកិច្ចសន្យា មុនពេលគេចុះកិច្ចសន្យា។ ប្រសិនបើមានមតិខុសគ្នាដែលកើតឡើងដោយសារកិច្ចសន្យា ជម្លោះនោះត្រូវតែដោះស្រាយដោយប្រព័ន្ធ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តុលាការ ឬដោយប្រព័ន្ធដោះស្រាយជម្លោះជាផ្លូវការផ្សេងៗទៀត។ ក្នុងន័យនេះ កម្ពុជាអាចបង្កើតអង្គភាពការពារអ្នកប្រើប្រាស់មួយ ដែលដាច់ចេញពីស្ថាប័នត្រួតពិនិត្យ។ ម៉្យាងវិញទៀត រាជរដ្ឋាភិបាលនិងឧស្សាហកម្មធានារ៉ាប់រងត្រូវសហការគ្នា ក្នុងការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីជំនួញធានារ៉ាប់រង និងសេវាកម្មដែលទទួលបានពីប័ណ្ណធានារ៉ាប់រង។ គេក៏គួរពិចារណារៀបចំវគ្គបណ្តុះបណ្តាលអំពីច្បាប់ធានារ៉ាប់រង និងនីតិវិធីតុលាការផងដែរ។

- **ការកំណត់ថ្លៃប័ណ្ណធានារ៉ាប់រង** និងការប្រើប្រាស់លក្ខខណ្ឌឱ្យឯកភាពគ្នា៖ សមាគមក្រុមហ៊ុនធានារ៉ាប់រងទូទៅកម្ពុជា (GIAC) គួររៀបចំ និងកំណត់តារាងថ្លៃអប្បបរមាសម្រាប់ផលិតផលធានារ៉ាប់រងរួម។ តារាងថ្លៃផលិតផលធានារ៉ាប់រងនេះត្រូវតែវាយតម្លៃដោយអ្នកជំនាញការអាជីពឯករាជ្យ ដើម្បីធានាធានាថាចំណូលបុព្វលាភដែលប្រមូលបាននឹងមានចំនួនគ្រប់គ្រាន់ដើម្បីទូទាត់សំណង ដែលអាចកើតមានឡើងពីប័ណ្ណធានារ៉ាប់រងនេះ។ អ្នកត្រួតពិនិត្យផ្នែកធានារ៉ាប់រងទទួលយកតារាងថ្លៃនេះ ហើយទាមទារឱ្យក្រុមហ៊ុនកំណត់ថ្លៃមិនឱ្យទាបជាងថ្លៃនៃតារាងឡើយ។ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុត្រូវដាក់ចេញនូវវិធានការ ដើម្បីអនុវត្តតារាងថ្លៃនេះឱ្យបាន។ ម៉្យាងវិញទៀត ត្រូវមានលក្ខខណ្ឌធានារ៉ាប់រងឱ្យឯកភាពគ្នា ដើម្បីឱ្យក្រុមហ៊ុននីមួយៗអាចកំណត់វិសាលភាព និងសារធាតុនៃសំណងការខូចខាត និងការបាត់បង់ឱ្យបានដូចៗគ្នា។ ការប្រើប្រាស់លក្ខខណ្ឌទាំងនេះត្រូវតែជាកាតព្វកិច្ច និងត្រូវតែគោរពអោយបានហ្មឺងម៉ាត់។
- **ការសិក្សាបង្កើតបេឡាសោធននិវត្តន៍ឯកជនដោយស្ម័គ្រចិត្ត៖** បេឡាសោធននិវត្តន៍ឯកជនដែលត្រូវបានបង្កើតឡើងដោយស្ម័គ្រចិត្ត គឺជាមូលនិធិដែលអ្នកវិនិយោគស្ថាប័ន និង ក្រុមហ៊ុនធានារ៉ាប់រងចូលចិត្តវិនិយោគ។ខណៈដែលក្រសួងសង្គមកិច្ចជាស្ថាប័នដែលទទួលបន្ទុករៀបចំ និងដំណើរការនៃកម្មវិធីសន្តិសុខសង្គម និងបេឡាសោធននិវត្តន៍កាតព្វកិច្ច រាជរដ្ឋាភិបាលត្រូវលើកទឹកចិត្តឱ្យបង្កើតមូលនិធិសោធននិវត្តន៍ឯកជនស្ម័គ្រចិត្ត។ ក្នុងន័យនេះ រាជរដ្ឋាភិបាលត្រូវផ្តល់ការលើកទឹកចិត្តខាងផ្នែកសារពើពន្ធ ក្នុងគោលដៅលើកទឹកចិត្តឱ្យប្រជាពលរដ្ឋ (ឬនិយោជក) ធ្វើការសន្សំផ្នែកខ្លះនៃប្រាក់ចំណូលរបស់ខ្លួន សម្រាប់ចំណាយនៅពេលចូលនិវត្តន៍។ ការរៀបចំនិងដាក់ឱ្យអនុវត្តនូវបេឡាសោធននិវត្តន៍សម្រាប់វិនិយោគិនស្ថាប័ន នឹងក្លាយជាកាតាលីករសម្រាប់ការវិវត្តទៅមុខនៃទីផ្សារមូលប័ត្រក្នុងស្រុក។

គោលដៅក្នុងរយៈពេលវែងរបស់រាជរដ្ឋាភិបាល រួមមាន៖

- **ការអនុវត្តច្បាប់សន្តិសុខសង្គម ៖** រួមមានការអនុមតិនូវឧបករណ៍គតិយុត្តិសមស្របនានា។
- **ការរៀបចំ និងការអនុវត្តច្បាប់និងលិខិតបទដ្ឋាន** ស្តីពីការបង្កើត និងដំណើរការនូវទីផ្សារមូលបត្រ ការប្រព្រឹត្តទៅនៃក្រុមហ៊ុនមូលបត្រ និងការប្រព្រឹត្តទៅនៃមូលនិធិសោធននិវត្តន៍ឯកជន។ លិខិតបទដ្ឋានទាំងនេះរួមមានវិធានការ ដែលលើកទឹកចិត្តឱ្យនិយោជកបង្កើតឡើងនូវមូលនិធិសោធននិវត្តន៍ ក្នុងគោលដៅធានានូវអត្ថប្រយោជន៍របស់និយោជិត និងកម្មករ។ មូលនិធិសោធននិវត្តន៍ឯកជនទាំងនេះ នឹងត្រូវបានប្រើប្រាស់ ដើម្បីវិនិយោគលើទីផ្សារមូលបត្រ។ ភាគលាភដែលនឹងទទួលបានពីការវិនិយោគនេះ នឹងត្រូវបានប្រើប្រាស់ ដើម្បីបើកផ្តល់ឱ្យនិវត្តន៍ជន នៅពេលដែលពួកគេត្រូវការបើកប្រាក់សោធននិវត្តន៍ ដើម្បីចំណាយលើជីវភាពប្រចាំថ្ងៃ។

- **ការពង្រឹងស្តង់ដារគណនេយ្យ និងសវនកម្ម៖** ស្តង់ដារគណនេយ្យ និងសវនកម្មដើរតួនាទីសំខាន់ សម្រាប់ការធ្វើឱ្យមានជំនឿជឿជាក់របស់សាធារណជនមកលើប្រព័ន្ធហិរញ្ញវត្ថុ និយាយជារួម និង មកលើទីផ្សារមូលបត្រ និយាយដោយឡែក។ វិធានការនេះនឹងលើកទឹកចិត្តឱ្យនិវត្តន៍ជនមានជំនឿទុកចិត្តទៅលើមូលនិធិសោធននិវត្តន៍ឯកជន ដែលនឹងដើរតួនាទីជាអ្នកប្រមូលធនធានហិរញ្ញវត្ថុសម្រាប់ការវិនិយោគ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៦
# ការអភិវឌ្ឍទីផ្សារមូលធន

"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥" មានគោលដៅអភិវឌ្ឍនូវប្រព័ន្ធហិរញ្ញវត្ថុ ដែលមានសុខភាពរឹងមាំ និងឈរលើមូលដ្ឋាននៃទីផ្សារ។ ទីផ្សារមូលធននិងធនាគារដើរតួនាទីបង្គ្រប់ និងបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ដើម្បីលើកស្ទួយប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ដែលជាកត្តាមួយមិនអាចខ្វះបានក្នុងការធានានូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងរយៈពេលវែង។ ទស្សនវិស័យក្នុងការអភិវឌ្ឍទីផ្សារមូលធន រួមមានការបង្កើតឡើងនូវរចនាសម្ព័ន្ធទីផ្សារមូលធនដែលមានតម្លាភាព និងប្រសិទ្ធភាព ដែលមានវត្តមាននៃក្រុមហ៊ុនបោះផ្សាយមូលប័ត្រមានចំនួនគ្រប់គ្រាន់ ក្នុងគោលដៅកៀរគរមូលនិធិ សម្រាប់ការធ្វើវិនិយោគទុនរយៈពេលវែង។ ទីផ្សារនេះនឹងកាត់បន្ថយហានិភ័យ និងជំនះនូវឧបសគ្គ ដែលអាចកើតមានឡើងក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងហានិភ័យ និងលើកទឹកចិត្តដល់ការប្រមូលផ្តុំមូលធន និងបែងចែកធនធានហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការអភិវឌ្ឍទីផ្សារមូលប័ត្រនឹងនាំមកនូវអត្ថប្រយោជន៍ដូចខាងក្រោម៖

- ទីផ្សារមូលធនដើរតួនាទីបំពេញបង្គ្រប់ឱ្យប្រាក់បញ្ញើធនាគារ ដែលជាយន្តការប្រមូលប្រាក់សន្សំក្នុងរយៈពេលខ្លីនិងមធ្យម។ ទីផ្សារមូលធននឹងបង្កើននូវការកៀរគរប្រាក់សន្សំ ដោយផ្តល់នូវឧបករណ៍សន្សំប្រាក់ដ៏ទាក់ទាញ ដែលអាចត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគទុនរយៈពេលវែង។ ទីផ្សារមូលធនក៏ផ្តល់នូវយន្តការងាយស្រួលមួយផងដែរ សម្រាប់ការប្រមូលប្រាក់សន្សំពីបរទេស ដើម្បីយកទៅទិញភាគហ៊ុនក្រុមហ៊ុន ដែលជាការវិនិយោគផលប័ត្រ។ នាពេលបច្ចុប្បន្ន កម្ពុជាទើបតែអាចទាក់ទាញបានត្រឹមតែវិនិយោគទុនផ្ទាល់ពីបរទេសតែប៉ុណ្ណោះ ដោយសារតែទីផ្សារមូលធន និងហេដ្ឋារចនាសម្ព័ន្ធនៃទីផ្សារមូលប័ត្រនៅមិនទាន់មាននៅឡើយ។ កម្ពុជានឹងអាចទាក់ទាញការវិនិយោគផលប័ត្រពីបរទេស នៅពេលដែលទីផ្សារមូលប័ត្រ ត្រូវបានបង្កើតឡើង ហើយវិធាននានាត្រូវបានអនុមតិដើម្បីលើកទឹកចិត្តវិនិគិនបរទេសដើម្បីដាក់ធ្វើការវិនិយោគមូលប័ត្រនៅកម្ពុជា។
- ការបង្កើតទីផ្សារមូលប័ត្រនឹងបង្កើតនូវយន្តការបែងចែកធនធានហិរញ្ញវត្ថុ ប្រកបដោយវិចារណញ្ញាណ ដោយសារតែ ប្រសិនបើគ្មានទីផ្សារនេះទេ ធនធានទាំងនេះនឹងត្រូវយកចំណាយលើការប្រើប្រាស់ ឬត្រូវបានរក្សាទុកជាប្រាក់បញ្ញើចរន្តទំនេរនៅតាមធនាគារពាណិជ្ជ។ ដូច្នេះ ទីផ្សារមូលប័ត្រគឺជាយន្តការសម្រាប់កៀរគរធនធានហិរញ្ញវត្ថុ ក្នុងគោលដៅបែងចែកធនធានទាំងនេះឱ្យធ្វើហិរញ្ញប្បទាននៃសកម្មភាពជំនួញ ដែលបម្រើផលិតកម្ម។
- ជាទូទៅ វិនិយោគិនមានការស្ទាក់ស្ទើរ ក្នុងការចូលរួមក្នុងគម្រោងវិនិយោគទុនរយៈពេលវែង ទោះបីគម្រោងដែលមានប្រាក់ចំណូលខ្ពស់ក៏ដោយ។ ជាមួយនឹងទីផ្សារមូលធន វិនិយោគិនអាចនៅតែមានធនធានជាសាច់ប្រាក់ងាយស្រួល ទោះបីជាគេវិនិយោគរយៈពេលវែងក៏ដោយ។
- ទីផ្សារមូលប័ត្រលើកកម្ពស់អភិបាលកិច្ចសាជីវកម្ម តាមរយៈតម្រូវការបើកចំហរព័ត៌មាន ដែលធានានូវស្តង់ដារ និងប្រសិទ្ធភាពនៃការគ្រប់គ្រងបានល្អប្រសើរ។
- ក្រុមហ៊ុនសាធារណៈដែលកាន់កាប់ដោយម្ចាស់ភាគហ៊ុនច្រើន តាមរយៈទីផ្សារភាគហ៊ុន និង ដោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សារមានតម្រូវការគោរពតាមបទបញ្ញត្តិផ្សេងៗ មានសមិទ្ធិល្អប្រសើរក្នុងការគ្រប់គ្រង ជាងក្រុមហ៊ុនដែលកាន់កាប់ដោយឯកជនជាបុគ្គល។

- ក្រុមហ៊ុនអាចទិញយកភាគហ៊ុនរបស់ក្រុមហ៊ុនដ៏ទៃទៀត ដើម្បីពង្រីកខ្សែសង្វាក់ផលិតកម្ម និងពង្រីកចំណែកទីផ្សាររបស់ខ្លួន បង្កើនច្រកចែកចាយទំនិញ ទិញធានារ៉ាប់រងការពារការប្រែប្រួលនៅលើទីផ្សារ និងធ្វើលទ្ធកម្មទ្រព្យសកម្មចាំបាច់ផ្សេងៗទៀត។

ផ្សារមូលប័ត្រ គឺជាទីផ្សារសម្រាប់៖

- ផ្តល់នូវសាច់ប្រាក់ងាយស្រួលដល់មូលប័ត្រ និងលើកកម្ពស់ថ្លៃធ្វើពាណិជ្ជកម្មដ៏យុត្តិធម៌ ដែលឆ្លុះបញ្ចាំងពីតុល្យភាពរវាងការផ្គត់ផ្គង់និងតម្រូវការ។ តាមរយៈតួនាទីនេះ វិនិយោគិនអាចដាក់ទុនទិញមូលប័ត្រ ដោយទទួលបាននូវព័ត៌មានពេញលេញ ហើយទន្ទឹមនឹងនេះ សហគ្រាសនានាអាចកៀរគរមូលនិធិបានយ៉ាងរលូន តាមរយៈការលក់មូលប័ត្រ។
- ថ្លៃផាត់ទាត់លើទីផ្សារមូលប័ត្រនឹងក្លាយជាសូចនាករដ៏ត្រឹមត្រូវ ដែលឆ្លុះបញ្ចាំងនូវសមិទ្ធិរបស់ក្រុមហ៊ុនលើមូលដ្ឋានសមហេតុផលមួយ និងអាចត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃវត្ថុបញ្ចាំឬតម្លៃទ្រព្យសកម្មនៃមូលប័ត្រទាំងនេះ។

វិនិយោគិនមូលប័ត្រនឹងទទួលបាននូវអត្ថប្រយោជន៍ដូចតទៅ៖

- កាលានុវត្តភាពដើម្បីទិញ និងដាវមូលប័ត្រ តាមថ្លៃដ៏យុត្តិធម៌ ដែលកំណត់ដោយទីផ្សារ។
- ជម្រើសដ៏ច្រើនសម្រាប់ឧបករណ៍សន្សំប្រាក់។
- ការចូលរួមធ្វើជាម្ចាស់កម្មសិទ្ធិរបស់ក្រុមហ៊ុន ដែលបានបំពេញទៅតាមបទដ្ឋានអភិបាលកិច្ចសាជីវកម្មដ៏តឹងរឹង។
- ជំនឿទុកចិត្តកាន់តែខ្ពស់និងគុណតម្លៃកេរ្តិ៍ឈ្មោះកាន់តែខ្ពស់។
- តម្លៃមូលប័ត្រលើទីផ្សារអាចត្រូវបានប្រើប្រាស់ ជាសូចនាករមួយក្នុងការកំណត់តម្លៃក្រុមហ៊ុនដោយមានការធានាកាន់តែច្រើន។
- មូលប័ត្រនៃក្រុមហ៊ុនដែលបានចុះបញ្ជី អាចត្រូវបានប្រើប្រាស់ជារូបិយប័ណ្ណ ក្នុងសកម្មភាពជំនួញខាងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការធ្វើលទ្ធកម្ម។

## ៦.១. ដំណាក់កាលសម្រាប់ការអភិវឌ្ឍទីផ្សារមូលធន

ផែនការអភិវឌ្ឍន៍ទីផ្សារមូលធននៃយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុនេះ បែងចែកជាបីដំណាក់កាល សម្រាប់ការអភិវឌ្ឍជាលំដាប់លំដោយដូចបានពិភាក្សាខាងក្រោម។ ទស្សនវិស័យនៃផែនការនេះ គឺត្រូវសម្រេចបានរចនាសម្ព័ន្ធនៃទីផ្សារមូលធនមួយ ដែលមានប្រសិទ្ធភាពខ្ពស់។

### ៦.១.១. ដំណាក់កាលទី ១ (២០០៦-២០០៩)

ដំណាក់កាលនេះរួមមាន៖

- ការអនុម័តច្បាប់ស្តីពីមូលប័ត្ររដ្ឋនៅថ្ងៃទី១០ខែមករាឆ្នាំ២០០៧។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំអនុក្រឹត្យ និងប្រកាសដើម្បីអនុវត្តច្បាប់នេះ។
- ប្រតិបត្តិការនៃទីផ្សារជួញដូរមូលប័ត្ររដ្ឋ ដែលត្រូវដាក់ឱ្យដំណើរការមុនការបង្កើត និងការដាក់ឱ្យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដំណើរការយ៉ាងពេញលេញនៃទីផ្សារមូលប័ត្រ។ ប្រការនេះនឹងធ្វើឱ្យវិនិយោគិនមានទំនុកចិត្តទៅលើទីផ្សារមូលប័ត្រ និងបន្សាំពួកគេទៅនឹងដំណើរការនៃទីផ្សារមូលប័ត្រ។

- ការអភិវឌ្ឍក្របខ័ណ្ឌនិយតកម្មដែលសមស្រប ពាក់ព័ន្ធនឹងអសាធនភាព និងក្របខ័ណ្ឌអភិបាលកិច្ចសាជីវកម្ម ដែលចាប់ផ្តើមដំណើរការ។
- ការអនុម័តច្បាប់ស្តីពីបោះផ្សាយ និងការជួញដូរមូលប័ត្រឯកជន ដែលចូលជាធរមាននៅក្នុងឆ្នាំ២០០៧។
- ភាពប្រសើរឡើងជាបន្តនៃសមត្ថភាពធ្វើសវនកម្ម/គណនេយ្យ។
- ការអនុវត្តអនុសារណៈស្តីពីការយោគយល់គ្នាសម្រាប់ការបង្កើតឡើងនូវផ្សារភាគហ៊ុនមួយជាមួយនឹងផ្សារភាគហ៊ុនកូរ៉េ (KRX)។
- ការបណ្តុះបណ្តាលដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ ការអប់រំដល់វិនិយោគិន និងការអភិវឌ្ឍធនធានមនុស្ស ដើម្បីគាំទ្រដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ។

### ៦.១.២. ដំណាក់កាលទី ២ (២០០៩-២០១២)

ដំណាក់កាលទីពីររួមមាន៖

- ការអនុវត្តក្របខ័ណ្ឌអភិបាលកិច្ចសាជីវកម្ម ជាបណ្តើរៗ សម្រាប់ក្រុមហ៊ុន។
- ការសម្ពោធដាក់ឱ្យដំណើរការ **ទីផ្សារមូលប័ត្រកម្ពុជា** (CSE) ក្នុងឆ្នាំ២០០៩។
- ការបើកទីកន្លែងទុកមូលប័ត្រមួយក្នុង**ទីផ្សារមូលប័ត្រកម្ពុជា**សម្រាប់ក្រុមហ៊ុនសាធារណៈទាំងអស់ និងការបង្កើតក្រុមហ៊ុនចុះបញ្ជីសាធារណៈមួយ។
- ការអនុវត្តវិធានស្តីពីអភិបាលកិច្ចនិងបទបញ្ជាហិរញ្ញវត្ថុ។
- ការអភិវឌ្ឍជាបន្តខាងផ្នែកព័ត៌មានហិរញ្ញវត្ថុនិងបទបញ្ជាក្រុមហ៊ុន។
- ការរៀបចំការបោះផ្សាយមូលប័ត្រជាសាធារណៈ តាមរយៈទីផ្សារមូលប័ត្រតែប៉ុណ្ណោះ។
- ការបង្កើតយន្តការផ្តល់សំណងដល់វិនិយោគិន ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាលមកពី ការបរាជ័យនៃអន្តរការីកម្មមូលប័ត្រដែលកាន់កាប់ទ្រព្យសម្បត្តិអតិថិជន។

*រូបភាព៦.១. រចនាសម្ព័ន្ធទីផ្សារមូលធន*




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

### ៦.១.៣. ដំណាក់កាលទី ៣ (២០១២-២០១៥)

ដំណាក់កាលចុងក្រោយនេះរួមមាន៖

- ការអភិវឌ្ឍមូលនិធិវិនិយោគទុន។
- ការអភិវឌ្ឍកម្មវិធីមូលនិធិសោធននិវត្តន៍។
- ការអភិវឌ្ឍក្របខ័ណ្ឌ និងស្ថាប័នមូលប័ត្រនីយកម្ម (Securitization)។
- ការអភិវឌ្ឍទីផ្សារនិស្សន្ទ (Derivatives)។
- ការផ្តល់ការលើកទឹកចិត្តសារពើពន្ធដើម្បីទាក់ទាញវិនិយោគិនឱ្យទិញមូលប័ត្ររដ្ឋ។

## ៦.២. បញ្ហាសំខាន់ៗនៃការអភិវឌ្ឍទីផ្សារមូលធន

បញ្ហាចម្បងៗក្នុងការអភិវឌ្ឍទីផ្សារមូលធនផ្តោតជាសំខាន់ លើដំណាក់កាលដែលត្រូវអនុវត្ត ដើម្បីបង្កើតទីផ្សារមូលធន ដោយអនុលោមតាមច្បាប់ស្តីពីបោះផ្សាយ និងការជួញដូរមូលប័ត្រឯកជន ដែលរួមមាន៖

- ការបង្កើត**គណៈកម្មការមូលប័ត្រកម្ពុជា** (SEC) ដែលជាអង្គភាពតែមួយគត់ដែលគ្រប់គ្រង និងត្រួតពិនិត្យរាល់ជំនួញមូលប័ត្រទាំងអស់ (វាត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨)។
- ការបង្កើតទីផ្សារបឋមមួយសម្រាប់ការផ្តល់ និងបោះផ្សាយនូវមូលប័ត្រថ្មីដល់វិនិយោគិនសាធារណៈ។
- ការបង្កើតផ្សារមូលប័ត្រមួយ និងប្រព័ន្ធអន្តរការីកម្មមូលប័ត្រ ការផាត់ទាត់ ការទូទាត់ និងកន្លែងរក្សាទុកមូលប័ត្រ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

• បទបញ្ញានានាសម្រាប់ទីផ្សារមូលប័ត្រ ដែលមានតម្លាភាព ប្រសិទ្ធភាព និងយុត្តិធម៌ និងការពារវិនិយោគិន។

## ៦.២.១. ការអនុវត្តគម្រោងទីផ្សារមូលបត្រកម្ពុជា

ក្រសួងហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រនៃសាធារណរដ្ឋកូរ៉េ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈស្តីពីការយោគយល់គ្នា ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៦ ដោយចង្អុលបង្ហាញពីចេតនានៃកិច្ចសហការ ក្នុងការបង្កើតនូវផ្សារមូលប័ត្រមួយនៅកម្ពុជា។ ផែនទីចង្អុលផ្លូវមួយ ត្រូវបានរៀបចំដើម្បីតម្រង់ទិសក្នុងការអនុវត្តគម្រោង។

គោលបំណងនៃផែនទីចង្អុលផ្លូវនេះគឺ (១) ត្រូវកំណត់តួនាទីរបស់ភាគីនីមួយៗ ក្នុងការបង្កើតទីផ្សារមូលប័ត្រនៅកម្ពុជា និងការរៀបចំសម្រាប់ប្រតិបត្តិការទីផ្សារមូលប័ត្រដែលទើបបង្កើតថ្មីនេះ (២) បញ្ជាក់ច្បាស់នូវការងារស្នូលដែលនឹងត្រូវអនុវត្តដោយភាគីនីមួយៗ ក្នុងការបង្កើតផ្សាហ៊ុនមូលប័ត្រ និង (៣) កំណត់ពេលវេលាសម្រាប់ការបញ្ចប់ការងារស្នូលទាំងនោះ។ សកម្មភាពទាំងអស់នេះនឹងត្រូវបានអនុវត្ត ក្នុងរយៈពេល៣៦ខែ បន្ទាប់ពីការចុះហត្ថលេខាលើអនុស្សរណៈស្តីពីការយោគយល់គ្នានេះ ដោយទីផ្សារមូលប័ត្រកូរ៉េ (KRX) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្របខ័ណ្ឌគតិយុត្តិដ៏សមស្របមួយគឺមានសារៈសំខាន់សម្រាប់ការបង្កើត និងការអភិវឌ្ឍនៃទីផ្សារមូលធន។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំ និងអនុមតិនូវក្របខ័ណ្ឌគតិយុត្តិសម្រាប់ការបង្កើតទីផ្សារមូលប័ត្រនៅកម្ពុជា។ ក្រុមហ៊ុនទីផ្សារមូលប័ត្រកូរ៉េ (KRX) បានផ្តល់អ្នកជំនាញការសមស្រប ដើម្បីជួយដល់ការងារត្រៀមរៀបចំនេះ។

*រូបភាព៦.១. រចនាសម្ព័ន្ធទីផ្សារមូលធន*

**(គំនូសកាលវិភាគ)**




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

កាលវិភាគសម្រាប់ការបង្កើតទីផ្សារមូលប័ត្រកម្ពុជាត្រូវបានព្រមព្រៀងគ្នាដូចខាងក្រោម៖

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់អាទិភាពដល់សកម្មភាពដូចខាងលើ ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីផ្សារមូលធន។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- បង្កើត និងអនុវត្តច្បាប់ និងបទបញ្ញត្តិសម្រាប់ការបង្កើត **គណៈកម្មការមូលប័ត្រកម្ពុជា** ដែលជាទីផ្សារមូលប័ត្រមួយនិងក្រុមហ៊ុនមូលប័ត្រ។
- បង្កើតនិងប្រតិបត្តិច្បាប់និងបទបញ្ញត្តិសម្រាប់ការជំរុញដល់ក្រុមហ៊ុន និងវិនិយោគិននានាដែលត្រូវបានចុះបញ្ជីជាសក្តានុពល។ និង
- ពង្រឹងស្តង់ដារសវនកម្មនិងគណនេយ្យស្តីពីជំនួញសាជីវកម្មទាំងឡាយ។

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ៣
# បញ្ហាទំនើបភាវូបនីយកម្មវិស័យកសិកម្ម

ជំពូកទី ៧៖  វិស័យកសិកម្ម

ជំពូកទី ៨៖  ឧបសគ្គនៃការលើកកម្ពស់ជីវភាពរបស់កសិករ

ជំពូកទី ៩៖  គោលនយោបាយទំនើបភាវូបនីយកម្មវិស័យកសិកម្ម

# ជំពូកទី ៧

## វិស័យកសិកម្ម

វិស័យកសិកម្មគឺជាមូលដ្ឋានគ្រឹះក្នុងការបង្កើនប្រាក់ចំណូលនៅតំបន់ជនបទ ជាពិសេស ក្នុងចំណោមប្រជាជនក្រីក្រនៅទីនេះ ។ វិស័យនេះរួមចំណែកប្រមាណជា ២៩% នៃផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) នៅឆ្នាំ២០០៥។ ដោយសារតែនៅកម្ពុជា ប្រជាជន ៨៥% រស់នៅតំបន់ជនបទ ហើយក្នុងនោះមានប្រជាជនជាង ៦០% កំពុងប្រកបរបរក្នុងវិស័យកសិកម្ម ហើយម៉្យាងទៀត មេគ្រួសារនៃគ្រួសារក្រីក្រជាកសិករមានរហូតដល់ ៧៥% ដូចនេះហើយ ការអភិវឌ្ឍវិស័យនេះមានសារសំខាន់ខ្លាំងណាស់ ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។

ក្រាហ្វិចខាងក្រោមនេះ បង្ហាញពីការប្រៀបធៀបរវាងផលិតភាពនៃមុខដំណាំសំខាន់ៗនៅកម្ពុជាធៀបនឹងប្រទេសជិតខាង។ ជារួម យើងពិនិត្យឃើញថាផលិតភាពនៃដំណាំស្រូវនិងពោត នៅមានសក្តានុពលនឹងបង្កើនថែមទៀត។

*រូបភាព ៧.១. ផលិតភាពវិស័យកសិកម្ម (តោនក្នុងមួយហិចតា)*




*ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

ការអភិវឌ្ឍវិស័យកសិកម្ម គឺស្ថិតចំណុចស្នូលនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងសហគមន៍ជនបទ ធានាឱ្យបាននូវសន្តិសុខស្បៀង និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។ ទោះបីជាផលិតកម្មសរុបពីវិស័យកសិកម្ម នេសាទ និងព្រៃឈើបានកើនឡើងក្នុងឆ្នាំ១៩៩៨-២០០៣ ចំណែកនៃវិស័យនេះក្នុងផ.ស.ស.បានធ្លាក់ចុះពី៤៣.៧% ក្នុងឆ្នាំ១៩៩៨មកនៅត្រឹមតែ២៩.៦% ក្នុងឆ្នាំ២០០៧ មូលហេតុចម្បងបណ្តាលមកពីកំណើនដ៏ឆាប់រហ័សនៃវិស័យឧស្សាហកម្ម នៅក្នុងអំឡុងពេលនោះ។

កំណើនក្នុងវិស័យកសិកម្មមានល្បឿនយឺតជាងកំណើនក្នុងវិស័យឧស្សាហកម្ម និងវិស័យសេវា។ ជាងនេះទៅទៀត កំណើនសេដ្ឋកិច្ចក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះបានប្រមូលផ្តុំតែទៅលើតែវិស័យមួយចំនួនតូចនៅតាមទីប្រជុំជនសំខាន់ៗប៉ុណ្ណោះ ដូចជាវិស័យកាត់ដេរ ទេសចរណ៍និងសំណង់។ ការអភិវឌ្ឍវិស័យឯកជន ការវិនិយោគ និងវិស័យពាណិជ្ជកម្មបានបង្កើតកាលានុវត្តភាពសម្រាប់អ្នកនៅទីក្រុង/ទីប្រជុំជនច្រើនជាងសម្រាប់អ្នកនៅជនបទ។ ជាលទ្ធផល គម្លាតរវាងតំបន់ទីក្រុង/ទីប្រជុំជន និងតំបន់ជនបទបានលេចចេញឡើងគួរឱ្យកត់សម្គាល់ ស្របពេលនឹងកំណើនសេដ្ឋកិច្ចនៃតំបន់ទាំងពីរមានលក្ខណៈខុសគ្នា។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វិសមភាពរវាងអ្នកមាននិងអ្នកក្រនៅក្នុងប្រទេសកម្ពុជាមានការកើនឡើង។ នៅចន្លោះពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០០៤ ផ.ស.ស.សម្រាប់មនុស្សម្នាក់នៃបញ្ចភាគ(Quintile)អ្នកមានបំផុត បានកើនឡើង៤៥% បើប្រៀបធៀបទៅនឹងកំណើនតែ៨% សម្រាប់បញ្ចភាពអ្នកក្រីក្របំផុត ដែលអ្នកទាំងនោះភាគច្រើនរស់នៅតំបន់ជនបទនិងប្រកបរបរកសិកម្ម។ ជាងនេះទៅទៀត អ្នកក្រីក្រតាមជនបទពឹងផ្អែកទៅលើធនធានព្រៃឈើ និងធនធានធម្មជាតិ ដើម្បីបំពេញតម្រូវការរបស់គេ។ ការធ្វើឯកជនភាវូបនីយកម្ម និងការបាត់បង់ធនធានធម្មជាតិនិងដីធ្លី បានធ្វើឱ្យវិសមភាពនេះនឹងរីតតែធំខ្លាំងឡើងៗ។

នៅក្នុងបរិបទនៃកំណើនប្រជាជនខ្ពស់ ការកាត់បន្ថយភាពក្រីក្រអាចសម្រេចបានឆាប់រហ័ស លុះត្រាតែកំណើនក្នុងវិស័យកសិកម្មអាចសម្រេចបានពី៥ទៅ៦% ក្នុងមួយឆ្នាំ។ ការសម្រេចបានក្នុងអត្រានេះមិនមែនការងាយស្រួលនោះទេ។ សក្តានុពលនៃកំណើនខាងវិស័យកសិកម្ម តាមរយៈការធ្វើប្រពលវប្បកម្ម និងវិត្ថារកម្មផ្ទៃដីដាំដុះមិនអាចធ្វើទៅបានដោយសារទីផ្សារក្នុងស្រុកតូចចង្អៀត គុណភាពមិនអាចនាំចេញបាន និងតម្រូវការផលិតផលកសិកម្មក្នុងតំបន់មិនទាន់មាន។ កសិផលក៏ប្រឈមទៅនឹងការប្រកួតប្រជែងដ៏ខ្លាំង ជាមួយនឹងប្រទេសនាំចូល ព្រមជាមួយនឹងគោលនយោបាយគាំពារនិយមរបស់ប្រទេសទាំងនោះ។

វិស័យកសិកម្មភាគច្រើនលើសលប់ គឺជាផលិតស្រូវ និងការចិញ្ចឹមសត្វ ដែលសរុបទៅមានទំហំប្រហែលមួយភាគបីនៃផលិតកម្មកសិកម្មសរុប ពោលជិតស្មើនឹង២៧%នៃផ.ស.ស.។ ក្នុងវិស័យព្រៃឈើ និងវិស័យនេសាទ មានទំហំតែ៥%នៃផ.ស.ស.ប៉ុណ្ណោះ ប៉ុន្តែនិទស្សន៍នៃកំណើនអាចមានសក្តានុពលខ្ពស់។ អ្នកដឹកនាំដែលមានបំណងលើកកម្ពស់ស្ថានភាពរស់នៅរបស់ប្រជាជនភាគច្រើន គឺអាចធ្វើបានតាមរយៈការបង្កើនផលិតភាពកសិផល និងជំរុញការធ្វើពាណិជ្ជកម្ម ដែលអាចនឹងបង្កើនថ្លៃ។

**ផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចឆ្នាំ១៩៩៦-២០០០** គិតគូរពីការបង្កើតការងារ និងបង្កើនប្រាក់ចំណូល តាមរយៈការអភិវឌ្ឍវិស័យកសិកម្ម និងការអភិវឌ្ឍតំបន់ជនបទ នៅក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារ។ ផែនការនេះបានកំណត់អាទិភាពចំនួនប្រាំ រួមមាន៖ (១) ការដោះមីន និងការកែលម្អដីស្រែចម្ការ ២) ការស្តារនិងការពង្រីកប្រព័ន្ធធារាសាស្ត្រ រួមផ្សំនឹងការលើកកម្ពស់ការគ្រប់គ្រងទឹក (៣) ការរៀបចំផែនការប្រើប្រាស់ដីធ្លី (៤) ការពង្រឹងការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម និង(៥) ការផ្តល់សេវាគាំទ្រ ជាពិសេសឥណទាន ការស្វែងរកទីផ្សារ រួមជាមួយទទួលបានការអប់រំ និងការផ្សព្វផ្សាយពីលទ្ធផលនៃការស្រាវជ្រាវ។

ក្នុងឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលបានប្រកាសពីការចាប់ផ្តើមរៀបចំផែនការបីឆ្នាំ ក្នុងគោលបំណងលើកកម្ពស់ការវិនិយោគទុន សំដៅបង្កើនផលិតកម្មកសិកម្ម និងតម្លៃបន្ថែមក្នុងវិស័យនេះ។អាទិភាពនានា រួមមានការវិនិយោគក្នុងវិស័យដឹកជញ្ជូននិងផ្លូវថ្នល់ ដើម្បីពង្រីកច្រកចេញទៅកាន់ ទីផ្សារ និងទៅកាន់ឧស្សាហកម្មកែច្នៃកសិកម្ម ដើម្បីបង្កើនតម្លៃបន្ថែម។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានខិតខំផលិត និងនាំចេញអង្ករដែលមានគុណភាពខ្ពស់ ទៅកាន់ទីផ្សារក្នុងប្រទេសថៃនិងវៀតណាម ដែលអាចទទួលបានប្រាក់ចំណេញខ្ពស់។

ផលិតកម្មស្រូវនៅកម្ពុជា នៅតែជាកត្តាកំណត់នៃកំណើនក្នុងវិស័យកសិកម្ម ទោះបីជាត្រូវទទួលរងផលប៉ះពាល់ជាញឹកញាប់ពីទឹកជំនន់ និង/ឬភាពរាំងស្ងួតក៏ដោយ។ ស្រូវអង្ករគឺជាទំនិញកសិកម្មដែលសំខាន់បំផុតសម្រាប់ប្រទេសកម្ពុជា និងមានចំណែកប្រមាណជាមួយភាគបីនៃផលិតផលកសិកម្មទាំងអស់។ កៅស៊ូ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងដំណាំផ្សេងទៀត (ដូចជា ក្រចៅ) មានទំហំ២៩% នៃផលិតផលកសិកម្មសរុប ចំណែកការចិញ្ចឹមសត្វមានទំហំ២៩% ចំណែងវិស័យជលផល និងព្រៃឈើរួមគ្នាមានទំហំមានតិចជាង១០% នៃផលិតកម្មកសិកម្មសរុប និងតិចជាង៤% នៃផ.ស.ស.។ នៅអំឡុងឆ្នាំ១៩៩៣-១៩៩ តម្លៃបន្ថែមក្នុងវិស័យព្រៃឈើបានកើនឡើងយ៉ាងខ្ពស់ ក្នុងអត្រាមធ្យមប្រចាំឆ្នាំ២១.៥%។ វិស័យព្រៃឈើបានធ្លាក់ចុះចាប់តាំងពីពេលនោះមក ដែលឆ្លុះបញ្ចាំងពីគោលនយោបាយរបស់រដ្ឋាភិបាល ក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព។

បន្ទាប់ពីមានកំណើនខ្ពស់ក្នុងឆ្នាំ១៩៩៤-១៩៩៨មក វិស័យដំណាំបានធ្លាក់ចុះយ៉ាងគំហុក ពោលគឺកំណើនមធ្យមប្រចាំឆ្នាំតែ០.៤%ប៉ុណ្ណោះ ពីឆ្នាំ១៩៩៩ដល់ឆ្នាំ២០០២ ដោយសារតែទឹកជំនន់ និងឱនភាពនៃរបាយទឹកភ្លៀង។ កំណើនផលិតកម្មស្រូវបានធ្លាក់ចុះ ដែលពីឆ្នាំ១៩៩៩-២០០០ មានកំណើនតែ២.៥% ប្រៀបធៀបនឹងកំណើន៤.៦% ក្នុងឆ្នាំ១៩៩៩-២០០៣។ ការចិញ្ចឹមសត្វ និងការនេសាទក៏បានទទួលរងផលប៉ះពាល់ស្រដៀងគ្នានេះដែរ។ បន្ទាប់ពីការធ្លាក់ចុះ-១.៦% នៅឆ្នាំ១៩៩៩ ជលផលមានកំណើនឡើងវិញក្នុងឆ្នាំ ២០០០-២០០២ ហើយវិស័យនេះមានអត្រាកំណើនមធ្យមប្រចាំឆ្នាំ៣.១% គិតពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០២។ នៅអំឡុងពេលនេះ រាជរដ្ឋាភិបាលបានដាក់អនុវត្តនូវគោលនយោបាយស្តីពីការគ្រប់គ្រងធនធានជលផលដោយចីរភាព។

កម្ពុជាមានផ្ទៃដីមានផ្ទៃដាំដុះ និងដំណាំអចិន្ត្រៃយ៍ទំហំ ៣.៨លានហិចតានៃ ក្នុងនោះ ១.៥លានហិចតាជាតំបន់ដំណាំអចិន្ត្រៃយ៍ ព្រមទាំងមានផ្ទៃដី១២លានហិចតាជាដីព្រៃនិងព្រៃឈើ។ តំបន់ដាំដុះកំពុងកើនឡើងជាប្រចាំ នៅក្នុងឆ្នាំ១៩៩៨-២០០៨ តំបន់ដាំដុះស្រូវបានកើនឡើង ទោះបីជាទទួលរងនូវទឹកជំនន់និងភាពរាំងស្ងួតក៏ដោយ។ តំបន់ដាំដុះកៅស៊ូកំពុងពង្រីកជាបន្តបន្ទាប់ប៉ុន្តែមានទំហំត្រឹមតែ ២% ប៉ុណ្ណោះនៃផ្ទៃដីដាំដុះក្នុងប្រទេស។

*តារាង ៧.១. តំបន់ដាំដុះ (គិតជាពាន់ហិចតា)*

| | 1966 | 1980 | 1990 | 2000 | 2002 | 2003 | 2004 | 2005 | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| ស្រូវ | 2510 | 1441 | 1890 | 2318 | 2137 | 2314 | 2374 | 2443 | 2541 | 2585 |
| ពោត | 117 | 123 | 44 | 71,46 | 80,47 | 93,36 | 91,20 | 90,73 | 108,83 | 142,39 |
| ជ័រកៅស៊ូ | 46 | 5 | 51 | - | 31,21 | 28,72 | - | - | - | - |
| សណ្តែកដី | 23 | 6 | 6 | 10 | 13 | 14 | 19 | 17 | 13 | 21 |
| ល្ង | 14 | 3 | 9 | 19,22 | 20,85 | 33,99 | 64,47 | 79,25 | 56,26 | 47,81 |
| សណ្តែកសៀង | 8 | 4 | 15 | 33,25 | 33,43 | 53,06 | 84,88 | 118,76 | 75,05 | 76,98 |
| ម្រេចខ្មៅ | 1 | 0 | 016 | -9,67 | - | - | - | - | - | - |
| ថ្នាំជក់ | 17 | 7 | | | 4,07 | 6,4 | 1,7 | 8,1 | 8,7 | 7,2 |

*ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

វិស័យកសិកម្មនៅកម្ពុជា គ្របដណ្តប់ភាគច្រើនដោយកសិករខ្នាតតូច (Small Holders) ការធ្វើកសិកម្មលើផ្ទៃដីធំមិនទាន់មានច្រើននៅឡើយ។ កសិករភាគច្រើនលើសលប់ ជាម្ចាស់ដីស្រែផ្ទាល់ ។ ប៉ុន្តែជម្លោះដីធ្លីតែងតែកើតមានជាញឹកញាប់។ គ្រួសារកសិករដែលគ្មានដីធ្លីមានប្រមាណជា ១៣% ទៅ១៥% នៃគ្រួសារកសិករសរុប ប៉ុន្តែស្ថានភាពសមភាពនេះ កំពុងមានការប្រែប្រួលយ៉ាងឆាប់រហ័ស។

## ៧.១. ដំណាំស្រូវ

ប្រជាជនក្រីក្រជាង៩០%រស់នៅតំបន់ជនបទ ហើយ៨០%នៃអ្នកក្រីក្រនៅជនបទពឹងផ្អែកលើដំណាំស្រូវ។ វាលស្រែគ្របដណ្តប់ប្រមាណ២០%នៃផ្ទៃដី វាលស្មៅគ្របដណ្តប់២០% និងនៅសល់ប្រហែល ៦០%ជាដីព្រៃគុម្ពោតនិងព្រៃស្រោង។ ដើមត្នោតមានដុះគ្រៀបគ្រាលើតំបន់វាលស្រែនៅទំនាបកណ្តាល។ ការដាំដុះស្រូវរួមចំណែកប្រមាណ១០% នៃផ.ស.ស.ពិតនៅក្នុងឆ្នាំ២០០៨។

ស្រូវគឺផលិតផលសំខាន់បំផុតសម្រាប់ប្រជាជនកម្ពុជា ដែលស្មើនឹង៨៤%នៃផលិតកម្មស្បៀងអាហារប្រចាំឆ្នាំ និងផ្គត់ផ្គង់ ៦៨%នៃតម្រូវការអាហារថាមពលសរុប។ ដំណាំស្រូវត្រូវបានដាំដុះភាគច្រើនក្នុងតំបន់អាងកណ្តាលនៃដែនដីសណ្តរទន្លេមេគង្គ និងវាលទំនាបនៃទន្លេសាប។ ក្នុងដើមទសវត្សរ៍ឆ្នាំ១៩៨០ ក្រោយពីសង្គ្រាមស៊ីវិលក្នុងរយៈពេល២០ឆ្នាំ និងភាពឯកកោផ្នែកសេដ្ឋកិច្ច ប្រទេសកម្ពុជាបានជួបនូវឱនភាព(ការផលិតតិចជាតម្រូវការហូប)ស្រូវប្រចាំឆ្នាំចំនួន ២៨៣,០០០តោនជាមធ្យម។

តំបន់ដាំដុះស្រូវបានធ្លាក់ចុះពីប្រមាណ២.៥លានហិចតានៅចុងទសវត្សរ៍ឆ្នាំ១៩៦០ មកត្រឹម ១.៨លានហិចតាក្នុងឆ្នាំ១៩៩២-១៩៩៣ ដោយសារតែអសន្តិសុខនិងសង្គ្រាម។ អំឡុងពាក់កណ្តាលទីមួយនៃទសវត្សរ៍ឆ្នាំ១៩៩០ ការស្តារនិងការពង្រីកផលិតកម្មស្រូវត្រូវបានរាំងខ្ទប់ មួយផ្នែកដោយសារតែគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ដែលតាមការប៉ាន់ស្មានរាយប៉ាយលើផ្ទៃដីដំណាំជិត៣០%។ តែចាប់តាំងពីឆ្នាំ១៩៩៥មកក្រោយពេលទទួលបានសន្តិភាព ផ្ទៃដីផលិតកម្មស្រូវបានកើនឡើងជាបន្តបន្ទាប់ ហើយនៅឆ្នាំ១៩៩៩ ផ្ទៃដីប្រមូលផលបានសម្រេចបានយ៉ាងច្រើន។

*តារាង៧.២. សូចនាករសំខាន់ៗនៃដំណាំស្រូវ*

| | | 2000 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|
| ផ្ទៃដីដំណាំស្រូវ | M ha | 2,318 | 2,314 | 2,374 | 2,443 | 2,541 | 2,585 | 2,616 |
| ផ្ទៃដីប្រមូលផល | M ha | 1,903 | 2,242 | 2,109 | 2,414 | 2,516 | 2,567 | 2,613 |
| ទិន្នផលស្រូវជាមធ្យម | T/ha | 2,115 | 2,101 | 1,977 | 2,479 | 2,489 | 2,621 | 2,746 |
| ផលិតកម្មស្រូវ | MT | 4,026 | 4,711 | 4,170 | 5,986 | 6,264 | 6,727 | 7,175 |
| តម្រូវការចំណីអាហារក្នុងមួយឆ្នាំ | MT | 1,981 | 1,937 | 1,906 | 2,014 | 2,054 | 2,096 | 1,970 |
| អង្ករលើសតម្រូវការ | MT | 0,091 | 0,686 | 0,416 | 1,320 | 1,434 | 1,650 | 2,025 |
| ស្រូវលើសតម្រូវការ | MT | 0,142 | 1,073 | 0,650 | 2,062 | 2,240 | 2,578 | 3,164 |

*ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងឆ្នាំ១៩៩៣-២០០៨ ផលិតកម្មស្រូវបានកើនឡើងយ៉ាងឆាប់រហ័ស និងឈានទៅប្រមូលផលបាន ៧.១៧លានតោនក្នុងឆ្នាំ២០០៨ លើផ្ទៃដីចំនួន២.៦១លានហិចតា ដែលបានមកពីការកើនឡើងផ្ទៃដីដាំដុះ និងទិន្នផល ទោះបីរបាយទឹកភ្លៀងមិនទៀងទាត់ ការខ្វះខាតកម្លាំងពលកម្មនិងមូលធន និងការខ្ទេចខ្ទាំនៃស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធបណ្តាលមកពីសង្គ្រាមក៏ដោយ។

ផលិតកម្មស្រូវនៅឆ្នាំ២០០៨ មានទំហំស្មើនឹង ៨០% នៃផលិតកម្មកសិកម្មសរុប ឬស្មើនឹង១៤% នៃ ផ.ស.ស.។ ទំហំផលិតកម្មនេះ ធ្វើឱ្យកម្ពុជាមានអតិរេកស្មើនឹង ៣លានតោនស្រូវដែលមិនទាន់កែច្នៃ ឬស្មើនឹង ២លានតោនអង្ករ សម្រាប់ការនាំចេញ។ នៅក្នុងឆ្នាំ២០០៨នេះ ក្នុងចំណោមផ្ទៃដីដាំដុះសរុប ៣លានហិចតា ទំហំ៧៨% (២.៦លានហិចតា) ត្រូវបានដាំស្រូវ ទំហំ៦% ដាំដំណាំស្បៀងអាហារផ្សេងទៀត ទំហំ៤% ដាំដំណាំឧស្សាហកម្ម និងទំហំ៦% ដាំដំណាំហូបផ្លែ និងដំណាំផ្សេងៗ។ ក្នុងចំណោមផ្ទៃដីដាំស្រូវ ២.៦លានហិចតា ផ្ទៃដីក្រោមប្រព័ន្ធស្រោចស្រពមានប្រមាណ៤៣០,០០០ហិចតា (២៣%នៃផ្ទៃដីធ្វើស្រែសរុប)។ វិស័យកសិកម្មនៅតែជាបេះដូងនៃសង្គមកម្ពុជាប៉ុន្តែមានសារសំខាន់ផ្នែកសេដ្ឋកិច្ចបន្តធ្លាក់ចុះ។

ដីស្រែមានទំហំកាន់តែតូច ដោយសារតែសម្ពាធប្រជាជន។ គ្រួសារកសិករមានដីស្រែជាមធ្យម១.៥ ហិចតា ហើយពាក់កណ្តាលនៃគ្រួសារកសិករមានទំហំដីតិចជាង០.៧៥ហិចតា។ ស្ថានភាពបែបនេះ បណ្តាលឱ្យមានចំណាកស្រុកទៅកាន់ទីប្រជុំជន និងធ្វើឱ្យសហគមន៍ជនបទកាន់តែ ពឹងផ្អែកខ្លាំងឡើងទៅលើសកម្មភាពក្រៅពីកសិកម្ម ដើម្បីរកប្រាក់ចំណូលបន្ថែម។

ការចំណាយលើអង្ករមានពីទំហំពី ២៥% ទៅ៣០% នៃការចំណាយសរុបសម្រាប់គ្រួសារក្រីក្រ។ ទោះជាបែបនេះក្តី តំបន់តែមានប្រជាជនច្រើនការធ្វើកសិកម្មសម្រាប់ហូប និងតំបន់មិនមានប្រជាជនការធ្វើកសិកម្មសម្រាប់លក់។ កំណើនផលិតភាពនៃកសិករផលិតសម្រាប់ហូប នឹងជួយកាត់បន្ថយភាពក្រីក្របានច្រើន និងសម្រួលដល់ការឆ្លងអន្តរកាលឆ្ពោះទៅកសិកម្មសម្រាប់ពាណិជ្ជកម្ម។

ការកើនឡើងនៃទិន្នផលស្រូវនិងការពង្រីកផ្ទៃដីដាំដុះ បានធ្វើឱ្យផលិតកម្មស្រូវកើនសមស្របទៅនឹងកំណើនប្រជាសាស្ត្រ។ ការប្រមូលកសិផលសរុបបានកើនឡើងជាលំដាប់ ជាពិសេសដំណាំស្រូវដោយបង្កើតអតិរេកនាំចេញក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ទិន្នផលស្រូវបានកើនពី១.៧៩តោនក្នុងមួយហិចតាក្នុងឆ្នាំ១៩៩៨ ដល់២.៧តោនក្នុងមួយហិចតាក្នុងឆ្នាំ២០០៨។ ប៉ុន្តែ ទិន្នផលនេះនៅទាបនៅឡើយធៀបនឹងប្រទេសជិតខាង។

កំណើនផលិតកម្មស្រូវជាសារវន្ត បណ្តាលមកពីការដាក់ឱ្យប្រើប្រាស់នូវពូជស្រូវដែលមានទិន្នផលខ្ពស់ និងបច្ចេកទេសដាំដុះថ្មី ដែលបង្កើតដោយ**វិទ្យាស្ថានអភិវឌ្ឍន៍និងស្រាវជ្រាវវិស័យកសិកម្មកម្ពុជា** (CARDI) ព្រមទាំងសេវាផ្សព្វផ្សាយកសិកម្មដែលផ្សព្វផ្សាយបន្ថែមដោយក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ។ ទោះបីមានការខិតខំប្រឹងប្រែងយ៉ាងនេះក្តី ទិន្នផលបច្ចុប្បន្ននៅទាប និងចំនួននៃការបង្កើនរដូវដាំដុះនៅតិច ។ ប្រសិនបើប្រៀបធៀបក្នុងប្រព័ន្ធអេកូឡូស៊ីស្រដៀងគ្នា កម្ពុជាទទួលបានទិន្នផលប្រហែល ២.៧តោនស្រូវក្នុងមួយហិចតា ធៀបទៅនឹងទិន្នផលពី ៥ទៅ៨តោនក្នុងមួយហិចតា ដែលប្រទេសជិតខាងទទួលបាន ។កំណើននៃផលិតភាពកសិកម្មមិនមានលក្ខណៈប្រហាក់ប្រហែលគ្នាទេ ពោលគឺសហគមន៍ដាំដុះជាង ៦៥% ទទួលបានទិន្នផលតិចជាង១.៧៥តោនក្នុងមួយហិចតា (រូបភាព៧.៣.)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រូបភាព៧.៣. ប្រោកង់នៃទិន្នផល*




*ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

វិស័យកសិកម្មក្នុងប្រទេសកម្ពុជារួមទាំងវិស័យព្រៃឈើនិងវិស័យនេសាទស្ថិតក្នុងស្ថានភាពខ្វះខាតមូលធននិងបច្ចេកវិទ្យា។ បណ្តាញផ្លូវថ្នល់ជនបទ និងប្រព័ន្ធដឹកជញ្ជូនត្រូវបានកែលម្អបន្ទាប់ពីបានខូចខាត និងមិនត្រូវយកចិត្តទុកដាក់។ ក្នុងចំណោមផ្ទៃដីស្រែប្រាំង ២៨៣,៥០០ហិចតា មានតែចំណែកតូចប៉ុណ្ណោះដែលមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ ។ដំណាំស្រូវ រួមជាមួយនឹងពោត កៅស៊ូ សណ្តែក ដំណាំយកមើម សណ្តែកដី សណ្តែកសៀង ក៏ដូចជាផ្លែឈើនិងបន្លែ ទទួលរងនូវផលរងគ្រោះជាញឹកញាប់ពីមហន្តរាយធម្មជាតិ ជាពិសេសទឹកជំនន់និងភាពរាំងស្ងួត។ ការរងគ្រោះក្នុងទ្រង់ទ្រាយធំ កើតឡើងជារៀងរាល់បីទៅបួនឆ្នាំម្តង។ រាជរដ្ឋាភិបាលកំពុងផ្តល់អាទិភាពដល់ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ដើម្បីជំរុញផលិតភាពវិស័យកសិកម្ម។

ផលិតកម្មស្រូវរដូវវស្សាមានជិត៨០% នៃដំណាំស្រូវសរុប ក្រៅពីនេះជាការប្រមូលផលពីស្រូវរដូវប្រាំង និងស្រូវប្រដេញទឹក។ នៅក្នុងរដូវវស្សា កសិករធ្វើស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់ អាស្រ័យទៅលើទីតាំងភូមិសាស្ត្រ ជីជាតិដី និងលក្ខខណ្ឌអាកាសធាតុទូទៅ។ ទោះបីស្រូវប្រាំងមានតែ១០%នៃផ្ទៃដីដាំដុះសរុបក៏ដោយ ក៏ផលិតកម្មនេះមានសមាមាត្រប្រហែល១៨% ទៅ២០% ដោយសារតែទិន្នផលខ្ពស់។ ទោះក្នុងឆ្នាំណាក៏ដោយ ផ្ទៃដីនិងផលិតស្រូវប្រាំងគឺពឹងផ្អែកទៅលើរបបទឹកភ្លៀងនៅរដូវវស្សា និងការជន់លិចនៃប្រព័ន្ធទន្លេមេគង្គ ដែលកំណត់ពីបរិមាណទឹកនៅក្នុងអាង និងបរិមាណទឹកដក់ស្រុបដោយដី។

ដោយសារការផលិតសម្រាប់ហូបលក្ខណៈគ្រួសារ ការប្រើប្រាស់ធាតុចូលមានតិចតួច រួមទាំងពូជទិន្នផលខ្ពស់ និងការប្រើប្រាស់ជី។ ជាងនេះទៅទៀត ចំណាយខ្ពស់លើគ្រឿងយន្តកម្មធ្វើឱ្យការធ្វើកសិកម្មរបៀបទំនើបមិនទាន់អាចប្រព្រឹត្តទៅបាន។ សេវាគាំទ្រវិស័យកសិកម្ម ជាពិសេសការផ្គត់ផ្គង់ធាតុចូល ការស្រាវជ្រាវនិងការផ្សព្វផ្សាយបច្ចេកទេស ការស្វែងរកទីផ្សារនិងឥណទាន គឺស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ ហើយពឹងផ្អែកជាចម្បងទៅលើជំនួយបរទេស។

## ៧.២. ប្រព័ន្ធផលិតកម្មកសិកម្ម

ក្នុងទិដ្ឋភាពភូមិសាស្ត្រ តំបន់កសិកម្មសំខាន់ៗ រួមមានតំបន់អាងទំនាបកណ្តាល តំបន់ខ្ពង់រាបនិងតំបន់ជួរភ្នំ ដែលកំណត់ពីលក្ខណៈនៃប្រព័ន្ធដំណាំស្រូវខុសៗគ្នា៖ (១) ប្រព័ន្ធផលិតកម្មកសិកម្មបែបប្រពៃណី (២) ប្រព័ន្ធផលិតកម្មបែបចម្ការ និង(៣) ប្រព័ន្ធផលិតកម្មឧស្សាហកម្ម (GRET និងអ្នកដទៃ, ២០០០)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រព័ន្ធដាំដុះស្រូវ អាចត្រូវបានបែងចែកទៅតាមភាពខុសគ្នានៃរបបទឹកជំនន់ ការគ្រប់គ្រងប្រភពទឹក រយៈពេលនិងរបៀបនៃការដាំដុះ ទីតាំងភូមិសាស្ត្រ និងប្រភេទដី។ ការជ្រើសរើសប្រព័ន្ធដាំដុះ និងពូជ គឺស្រូវសម្របទៅភាពភាពខុសគ្នានៃស្ថានភាពអេកូឡូស៊ី ហើយកសិករតែងព្យាយាមគ្រប់គ្រងហានិភ័យ ដើម្បីទប់ទល់នឹងបរិស្ថានធម្មជាតិដែលមិនទៀងទាត់។

## ៧.២.១. ប្រព័ន្ធផលិតកម្មកសិកម្មតាមប្រពៃណី

ប្រព័ន្ធដំណាំស្រូវបែបប្រពៃណី អាចចាត់ថ្នាក់តាមវិធីខុសៗគ្នាជាច្រើន ។ ប្រសិនជាយករដូវកាលជាលក្ខណៈវិនិច្ឆ័យ នោះប្រព័ន្ធដំណាំស្រូវដាំដុះនៅកម្ពុជាមានបួនបែបខុសគ្នា ក្នុងនោះបីប្រភេទនៅក្នុងរដូវវស្សា និងមួយប្រភេទក្នុងរដូវប្រាំង។ ប្រភេទទាំងបួននេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងលក្ខខណ្ឌអាកាសធាតុ៖

- **ស្រូវវស្សាជំនាប៖** គ្រប់ដណ្តប់៥៨% នៃតំបន់ដាំដុះស្រូវនៅតំបន់ទំនាប។
- **ស្រូវវស្សាខ្ពង់រាបឬស្រូវចម្ការ៖** ជាប្រភេទស្រូវដែលមានវដ្តលូតលាស់ខ្លីបំផុត សម្របខ្លួនយ៉ាងល្អទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌជុំវិញ ជាពិសេសកសិកម្មពនេចរ និងមានទំហំផ្ទៃដីជិត២% នៃផ្ទៃដីដាំដុះស្រូវ។ ជាទូទៅ ស្រូវប្រភេទនេះត្រូវបានដាំដុះជាមួយនឹងដំណាំសម្រាប់លក់យកប្រាក់ផ្សេងទៀត។
- **ស្រូវលិចទឹក៖** ត្រូវបានដាំនៅក្នុងតំបន់ដែលមានរយៈកម្ពស់ទាប ជាទីដែលទឹកអាចឡើងដល់ជម្រៅពី ២ទៅ៣ម៉ែត្រ និងគ្រប់ដណ្តប់៣២%នៃផ្ទៃដីដាំស្រូវ។
- **ស្រូវប្រាំង៖** ស្រូវប្រាំងរួមមានស្រូវប្រាំងដែលស្រោចស្រពដោយធារាសាស្ត្រនិងស្រូវប្រាំងប្រដេញទឹក។ ការស្រោចស្រពស្រូវប្រាំង ធ្វើឡើងតាមរយៈទឹកដែលរក្សាទុកក្នុងអាងស្តុកទឹក ឬទឹកទន្លេដែលនៅសេសសល់។ ស្រូវប្រាំងក៏អាចជាស្រូវប្រដេញទឹកដែលត្រូវបានដាំដុះក្នុងតំបន់លិចទឹក ឬតាមបណ្តោយមាត់បឹងទន្លេសាប ជាទីដែលកម្រិតទឹកបានស្រកចុះបន្តិចម្តងៗ។

ប្រសិនបើផ្អែកប្រភេទដីជាលក្ខណៈវិនិច្ឆ័យ ប្រភេទដីដាំដុះដំណាំស្រូវមានចំនួន៤ប្រភេទសំខាន់ៗ៖

- ស្រូវវស្សា ដែលដុះលើដីពណ៌ខ្មៅលាយក្រហម។
- ស្រូវវស្សាមានប្រព័ន្ធស្រោចស្រព ដែលដុះលើផ្ទៃទំនាបដីខ្សាច់។
- ស្រូវវស្សាមានប្រព័ន្ធស្រោចស្រព ដែលដុះលើផ្ទៃទំនាបដីជាំទឹក។
- ស្រូវដែលដុះលើតំបន់ដែលជន់លិចពីបឹង/ទន្លេ។

ស្រូវវស្សានៅតំបន់ទំនាប គឺជាដំណាំដែលសំខាន់ជាងគេ ដែលត្រូវដាំដុះនៅក្នុងរដូវវស្សាពីខែឧសភាដល់ខែធ្នូ។ ស្រូវវស្សាមានបីប្រភេទ ទៅតាមរយៈពេលនៃការលូតលាស់ និងប្រមូលផល គឺ ស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់។ ស្រូវប្រាំងត្រូវបានដាំដុះពីខែធ្នូដល់ខែឧសភា មានផ្ទៃដីប្រមាណ១០%នៃផ្ទៃដីសរុប និងប្រមូលផលបានប្រមាណជា១៨%នៃផលិតកម្ម ដែលជាការឆ្លៀតឱកាសក្នុងពេលទឹកសម្រក ហើយប្រើប្រាស់ទឹកស្រោចស្រពបំពេញបន្ថែមចុងដៃ។ ផ្ទៃដីដាំដុះស្រូវប្រាំងបានកើន១៧% ក្នុងឆ្នាំ១៩៩៩-២០០៣

ដែលមានផ្ទៃដីសរុបចំនួន២៨៣,៥៥០ហិចតា នៅចុងឆ្នាំ២០០៣។ តំបន់ទាំងនេះពឹងផ្អែកទៅលើរបបទឹកភ្លៀងប្រចាំឆ្នាំផង និងរបបទឹកជំនន់នៃទន្លេមេគង្គផង ដែលជាកំណត់បរិមាណទឹកអាងស្តុក។ ផលិតកម្មស្រូវប្រែប្រួលខ្លាំងទៅតាមរបបទឹកភ្លៀង ប៉ុន្តែរបបទឹកភ្លៀងមានភាពអំណោយផលល្អ ក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

*តារាង៧.៣. ប្រភេទនៃការដាំស្រូវ តំបន់ស្រូវ និងផលិតកម្មស្រូវ ក្នុង២០០៧*

| *ប្រភេទស្រូវ* | *% នៃផ្ទៃដី* | *ផ្ទៃដី (ហិចតា)* | *ទិន្នផល (ហិច/ឆ្នាំ)* | *ផលិតកម្ម (តោន)* |
|---|---|---|---|---|
| ស្រូវមានប្រព័ន្ធស្រោចស្រពគ្រាប់គ្រាន់ | 6,06% | 174 365 | 5 | 230 000 |
| ស្រូវប្រដេញទឹក | 4,03% | 115 917 | 3 | 360 000 |
| ស្រូវវស្សា បន្ថែមប្រព័ន្ធស្រោចស្រព | 10,35% | 297 861 | 3 | 810 000 |
| សរុបស្រូវមានប្រព័ន្ធស្រោចស្រព | 20,43% | 588 143 | | 1 400 000 |
| ស្រូវលិចទឹក | 9,77% | 281 114 | 1 | 210 000 |
| ស្រូវវស្សា | 69,80% | 2 009 326 | 2 | 470 000 |
| សរុប | < 3 លានហិចតា | | | > 6 លានតោន |

*ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

## ៧.២.១.១. ការប្រើប្រាស់ធាតុបចូលកសិកម្ម និងបច្ចេកវិទ្យាក្រោយការប្រមូលផល

ការធ្វើស្រែលក្ខណៈគ្រួសារប្រើប្រាស់ធាតុចូល ដូចជាជីនិងគ្រាប់ពូជសុទ្ធ ក្នុងបរិមាណតិចតួច។ ការដាំដុះជាប់ជាបន្តធ្វើឱ្យដីមិនអាចបំពេញសារធាតុចិញ្ចឹមឡើងវិញ និងធ្វើឱ្យដីខ្សោះអស់ជីជាតិ។ នៅឆ្នាំ២០០៨ ការប្រើប្រាស់ជីខនិកសរុបទូទាំងប្រទេសត្រូវបានគេប៉ាន់ស្មានថាមានប្រមាណពី ៤០,០០០តោន ទៅ ៥០,០០០តោន មានន័យថា កម្រិតនៃការប្រើប្រាស់ជីគឺប្រមាណ ២០-២៥គីឡូក្រាម ក្នុងមួយហិចតា។

បច្ចុប្បន្ននេះ កសិករជាច្រើនតែប្រើប្រាស់គ្រាប់ពូជដែលបានសន្សំទុក ឬទិញគ្រាប់ពូជដែលគ្មានអាជ្ញាប័ណ្ណពីឈ្មួញឯកជន។ ការប្រើប្រាស់គ្រាប់ពូជសុទ្ធល្អ មានតែប្រមាណ ២% ប៉ុណ្ណោះលើផ្ទៃដីដាំដុះទាំងអស់។ ភាគរយនេះកាន់តែទាបជាងនេះ សម្រាប់ដំណាំផ្សេងទៀត។

ក្នុងពេលនេះ កម្ពុជាអាចផលិតស្រូវគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ក្នុងប្រទេស និងមានអតិរេកសម្រាប់ការនាំចេញ។ លទ្ធភាពនៃការបំពេញតម្រូវការខ្លួនឯងសម្រាប់ដំណាំស្រូវ សម្រេចបានដប់ឆ្នាំកន្លងមកហើយ ឥឡូវកម្ពុជាអាចរក្សាបានអង្ករនៅសល់ចំនួន២លានតោនសម្រាប់ការនាំចេញក្នុងមួយឆ្នាំៗ។ ក្នុងតំបន់ដែលមានផលិតភាពខ្ពស់ អតិរេកត្រូវបានធ្វើពាណិជ្ជកម្មនៅក្នុងស្រុកនិងធ្វើការនាំចេញ។ នៅក្នុងតំបន់ក្រីក្រនៃខេត្តដែលមានប្រជាជនកកកុញ ឱនភាពនៃផលិតកម្មស្រូវតម្រូវឱ្យកសិករងាកទៅរកការដាំដំណាំ ឬសកម្មភាពបន្ទាប់បន្សំ (ឧទា. ការធ្វើសិប្បកម្ម ការចិញ្ចឹមសត្វ ការលក់កម្លាំងពលកម្ម។ល។) ដែលអាចរកប្រាក់ចំណូលបានបន្ថែម សម្រាប់ការបំពេញតម្រូវការនៃជីវភាពប្រចាំថ្ងៃ។

កំណើននៃផលិតកម្មស្រូវ គឺកើតឡើងដោយសារតែការពង្រីកផ្ទៃដីដាំដុះ ការប្រើប្រាស់ពូជប្រពៃណីដែលបានកែលម្អ តាមរយៈការផលិតពូជ ដោយប្រើប្រាស់គ្រាប់ពូជដែលបានរក្សាទុកក្នុងធនាគារសេនេទិចពូជនៃវិទ្យាស្ថានអភិវឌ្ឍន៍និងស្រាវជ្រាវកសិកម្មកម្ពុជា (CARDI) និងការជួសជុលនិងពង្រីកប្រព័ន្ធធារាសាស្ត្រផង។ រដ្ឋាភិបាលបានផ្តល់សារៈសំខាន់លើការបង្កើននិងចែកចាយប្រភេទពូជកែលម្អ ចេញពីពូជក្នុងស្រុក និងមានតម្រូវការខ្លាំងនៅលើទីផ្សារអន្តរជាតិ ដូចជាពូជនាងម្លិះជាដើម។

រោងម៉ាស៊ីនកិនស្រូវ និងម៉ាស៊ីនវែងអង្កាមដែលមានបច្ចេកវិទ្យាខ្ពស់កំពុងត្រូវបានប្រើប្រាស់អំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅឆ្នាំ ២០០៣ ម៉ាស៊ីនបែបនេះមានចំនួនតែ ១០ប៉ុណ្ណោះ ប៉ុន្តែពេលនេះមានច្រើននៅតាមតំបន់ជនបទ ។ ដោយប្រើបច្ចេកវិទ្យាទំនើបនេះ អាត្រានៃការកិនស្រូវទៅជាអង្ករស្មើនឹង ៧០%។ ម៉ាស៊ីនវែងអង្កាមបច្ចេកវិទ្យាខ្ពស់នេះដើរតួនាទីដ៏សំខាន់ក្នុងការលើកកម្ពស់ការនាំចេញអង្ករ តាមរយៈប្រព័ន្ធធ្វើស្រែតាមកិច្ចសន្យា ដោយសារការនាំចេញត្រូវការគុណភាពខ្ពស់។

### ៧.២.១.២. ទីផ្សារអង្ករ

អង្ករភាគច្រើនត្រូវបានធ្វើពាណិជ្ជកម្មជាលក្ខណៈឯកជន។ កសិករមានសមត្ថភាពស្តុកទុកតិចតួចបំផុត ហើយលក់កសិផលភ្លាមៗ បន្ទាប់ពីប្រមូលផលទៅឱ្យឈ្មួញកណ្តាល ដែលជាអ្នកលក់បន្តនៅលើទីផ្សារ។ ស្រូវសំបូរហូរហៀរបន្ទាប់ពីការប្រមូលផលក្នុងខែវិច្ឆិកានិងខែធ្នូ។ កសិករជាប្រញាប់លក់ស្រូវចេញភ្លាមមួយភាគធំ បន្ទាប់ពីការប្រមូលផលដើម្បីទូទាត់បំណុល និងបំពេញចំណាយចាំបាច់មួយចំនួន។ មានន័យថាស្រូវមានតម្លៃទាបបំផុតនៅពេលប្រមូលផល និងជំរុញឱ្យឈ្មួញនៅតាមបណ្តាខេត្តជាប់ព្រំដែននាំចេញទៅកាន់ប្រទេសជិតខាង។ បន្ទាប់ពីរយៈពេលនោះក្រោមការប្រមូលផលរួច អង្ករបានឡើងថ្លៃនៅដើមឆ្នាំ និងទាក់ទាញការនាំចូលវិញ។

តម្លៃអង្ករនៅទីក្រុងនិងជនបទមានភាពខុសគ្នាខ្លាំង ដោយសារតែថ្លៃដឹកជញ្ជូនពីទីផ្សារមួយទៅទីផ្សារមួយទៀត ដែលជាបុព្វហេតុមួយដ៏សំខាន់គឺបណ្តាលមកពីប្រព័ន្ធទីផ្សារស្រូវអង្ករមានលក្ខណៈដាច់ជាកង់ៗ (Fragmentation)។ ពាណិជ្ជកម្មស្រូវកើតឡើងជាទូទៅតាមព្រំដែនរវាងប្រទេសកម្ពុជាថៃនិងវៀតណាម ប៉ុន្តែមិនមានទិន្នន័យដែលទាក់ទងទៅនឹងទីផ្សារទាំងនេះទេ។ ប៉ុន្តែគេដឹងថា កម្ពុជាជាអ្នកនាំស្រូវចេញតាំងពីឆ្នាំ១៩៩៥មកម្ល៉េះ ដែលស្ថានភាពនេះធ្វើការបរិមាណផ្គត់ផ្គង់ស្រូវសម្រាប់ទីផ្សារក្នុងស្រុកថយចុះ និងធ្វើឱ្យថ្លៃអង្ករកើនឡើងខ្ពស់ជាបន្តបន្ទាប់សម្រាប់អ្នកប្រើប្រាស់ក្នុងប្រទេស។

### ៧.២.១.៣. សន្តិសុខស្បៀង

វិស័យកសិកម្មត្រូវតែរួមចំណែកដល់សន្តិសុខស្បៀង ដែលមានសារសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ។ សន្តិសុខស្បៀង រួមមានសមាសធាតុសំខាន់ៗពីរយ៉ាងៈ ទីមួយ ការផ្គត់ផ្គង់ស្បៀងគ្រប់គ្រាន់ និងទីពីរ ថ្លៃស្បៀងស្ថិតក្នុងកម្រិតដែលប្រជាជនមានលទ្ធភាពទិញបាន។

ក្នុងចំណោមខេត្តដែលផលិតស្រូវធំៗទាំង១៥ខេត្ត មានខេត្តចំនួន៥ស្ថិតក្នុងឱនភាព។ ខេត្តប្រាំបីផ្សេងទៀតដែលបច្ចុប្បន្នមានអតិរេក ក៏អាចប្រឈមនឹងឱនភាពដែរ ប្រសិនបើផលិតកម្មកើនឡើងទាន់នឹងកំណើនប្រជាជននិងតម្រូវការ។ មានគ្រួសារដែលទទួលរងគ្រោះ ពីអសន្តិសុខស្បៀងនៅក្នុងបណ្តាខេត្តទាំងអស់ តួយ៉ាងដូចគ្រួសារកសិករ ដែលមានទំហំដីស្រែតូច (តិចជាង០.៥ហិចតា) ។ ពួកគេជាមុខសញ្ញានៃកម្មវិធី

ឧបត្ថម្ភស្បៀងអាហារ និងការឧបត្ថម្ភផលិតកម្ម ទោះបីជាស្ថានភាពសន្តិសុខស្បៀងជារួមក្នុងខេត្តនោះល្អប្រសើរក្តី។

ថ្លៃដឹកជញ្ជូនស្បៀងនៅក្នុងប្រទេសកម្ពុជាត្រូវចំណាយខ្ពស់ណាស់។ ក្នុងករណីខ្លះ រោងម៉ាស៊ីនកិនស្រូវ ដែលអាចដឹកដល់ និងល្អៗ មានបោះទីតាំងតាមបណ្តោយព្រំដែន ដែលធ្វើឱ្យទីផ្សារក្នុងខេត្តពិបាកប្រមូលទិញបាន ជាពិសេសនៅបណ្តាខេត្តជាប់ព្រំដែនអន្តរជាតិ។ ដូចនេះ ការលក់ទៅឱ្យប្រទេសម្ខាងទៀតនៃព្រំដែនទទួលប្រាក់ចំណេញបានខ្ពស់ជាង ការលក់នៅកាន់តំបន់ដែលមានឱនភាពនៅក្នុងប្រទេស។ ការនាំចូលអង្ករពីប្រទេសជិតខាងចូលទៅកាន់ខេត្តដែលមានឱនភាពស្រូវ ក៏ថោកជាងការចល័តស្រូវអង្ករក្នុងប្រទេសពីកន្លែងដែលមានអតិរេក ទៅទៅកាន់ខេត្តដែលមានឱនភាពដែរ។

សម្រាប់រយៈពេលវែងនិងមធ្យម អាទិភាពខ្ពស់ត្រូវតែតម្រង់ទៅរកការកែលម្អប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រង ការផ្សព្វផ្សាយកសិកម្ម និង ប្រតិបត្តិការក្រោយការប្រមូលផល។ ការលើកកម្ពស់ផលិតភាពវិស័យកសិកម្ម ក៏ដូចជាដល់ការធ្វើប្រពលវប្បកម្ម និងពិពិធកម្មមុខដំណាំត្រូវជំរុញឱ្យបានខ្លាំងក្លា។ ដើម្បីធ្វើប្រពលវប្បកម្ម ចាំបាច់ត្រូវបង្កើនការផលិតគ្រាប់ពូជសុទ្ធល្អ បង្កើនការផ្តល់ឥណទានសម្រាប់ផលិតកម្ម និងឥណទានសម្រាប់ទីផ្សារ ។

តំបន់សន្តិសុខស្បៀងផ្សេងគ្នាមានរចនាសម្ព័ន្ធជីវភាពផ្សេងគ្នា។ទោះបីការដាំដុះជាសកម្មភាពចម្បងក្នុងទ្រទ្រង់ជីវភាពគ្រួសារជនបទក៏ដោយ ក៏ប៉ុន្តែគ្រួសារទាំងនេះបញ្ជាក់ថាទទួលបានប្រាក់ចំណូលពីប្រភពផ្សេងៗទៀតប្រមាណជា ២៦%។ សូម្បីតែនៅក្នុងចំណោមគ្រួសារដែលធ្វើស្រែជាចម្បង ក៏កម្រិតនៃពឹងផ្អែកប្រាក់ចំណូលបានពីស្រែខុសៗគ្នាទៅតាមគ្រួសារដែរ។ ផ្អែកលើមូលដ្ឋាននៃគម្របប្រភេទដំណាំ និងទិន្នន័យពីការអង្កេតសង្គម-សេដ្ឋកិច្ច គេអាចកំណត់តំបន់សេដ្ឋកិច្ចស្បៀងកម្ពុជា ជាប្រាំកន្លែងគឺ វាលទំនាបរងទឹកភ្លៀង ព្រៃគុម្ពោត ព្រៃស្រោង ទន្លេ ទីក្រុង/ផ្សារ ក៏ដូចជាតំបន់ចម្រុះខ្លះផងដែរ។ ក្នុងការកំណត់តំបន់ទាំងនេះ ក៏មានរាប់ បញ្ចូលពីផលប៉ះពាល់នៃកត្តានានាដូចជា ភាពរាំងស្ងួត ការបាត់បង់ព្រៃឈើ និងការខ្វះខាតនូវធនធានទឹក ។

ទាក់ទងទៅនឹងក្រុមគ្រួសារដែលមានលទ្ធភាពរបស់ទទួលបានស្បៀងនោះ ប្រជាជនដែលរស់នៅលើវាលទំនាបដែលមិនមានប្រព័ន្ធស្រោចស្រពឬដីព្រៃគុម្ពោត គឺគ្រួសារដែលងាយរងគ្រោះបំផុត។ ជាទូទៅពួកគេជួបប្រទះនឹងការខ្វះខាតស្បៀង ក្នុងរយៈពេលពី១ទៅ២ខែ ជារៀងរាល់ឆ្នាំ ហើយជាប់ជំពាក់បំណុលលើសពីកម្រិតមធ្យម និងមានទ្រព្យសម្បត្តិមានតម្លៃតិចតួច ហើយត្រូវរកវិធីផ្សេងៗ ដើម្បីបំពេញតម្រូវការ (ដូចជា ការខ្ចីប្រាក់ ការលក់ទ្រព្យសម្បត្តិ ការធ្វើចំណាកស្រុកជាដើម)។ កំណើនសេដ្ឋកិច្ចជារួម ទំនងជាមិនផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្រុមទាំងនោះទេ។ នៅក្នុងឆ្នាំធម្មតា ក្រុមមនុស្សទាំងនោះរងគ្រោះពីអសន្តិសុខស្បៀង ហើយត្រូវការជំនួយឧបត្ថម្ភស្បៀង ក៏ដូចជាការបំប៉នចំណូល និងការងារបន្ថែម។ ជាក់ស្តែង ជំនួយឧបត្ថម្ភស្បៀងអាហារចំនួន៧០% ត្រូវបានវិភាជន៍សម្រាប់សហគមន៍ដែលមានអសន្តិសុខស្បៀងរស់នៅតំបន់ទំនាបដែលគ្មានប្រព័ន្ធស្រោចស្រព និងនៅតំបន់ព្រៃគុម្ពោត។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ ធនាគារស្រូវ ក៏ដូចជាការបណ្តុះបណ្តាល គួរត្រូវបានផ្តោតនៅតំបន់ទាំងនោះ ដើម្បីអាចជំនះបាននូវស្ថានភាពអសន្តិសុខស្បៀងរ៉ាំរ៉ៃ ក្នុងរយៈពេលយូរអង្វែង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កសិករដែលរស់នៅតាមបណ្ដោយច្រាំងទន្លេ និងមាត់បឹងជាធម្មតាមានជីវភាពធូរធាលើមធ្យមផ្នែកសន្តិសុខស្បៀង។ ក្នុងឆ្នាំធម្មតា ជំនួយឧបត្ថម្ភស្បៀងតិចជាង១០% ត្រូវបានបែងចែកទៅដល់ក្រុមកសិករទាំងនោះ។ តែទោះជាយ៉ាងណា ភាគច្រើននៃប្រជាជនដែលរងគ្រោះដោយទឹកជំនន់ គឺជាសហគមន៍កសិករប្រភេទនេះ។ យុទ្ធសាស្ត្រដោះទាល់របស់ពួកគេរួមមាន៖ (ក) ការធ្វើចំណាកស្រុក (ខ) ការនេសាទគ្រួសារ (គ) ការធ្វើស្រែប្រាំងនិងស្រែប្រដេញទឹក (ឃ) ការឡើងត្នោតនិង (ង) សកម្មភាពជួញដូរតិចតួច។ ការអង្កេតបង្ហាញថា សហគមន៍ទាំងនេះភ័យខ្លាចថាការប្រមូលផលស្រូវប្រាំង (ក៏ដូចជា យន្តការសម្របខ្លួនផ្សេងទៀត) មិនគ្រប់គ្រាន់ដើម្បីបំពេញបាននូវឱនភាពស្បៀង ហើយចុងក្រោយត្រូវជំពាក់បំណុលគេ ទោះបីបានខិតខំធ្វើសកម្មដែលបានរៀបរាប់ខាងលើហើយក្តី។

កសិករដែលមិនសូវទទួលរងគ្រោះពីទឹកជំនន់ ពួកគេក៏មិនសូវស្វែងរកការដោះទាល់ ឬ ជួបគ្រោះភ័យ។ ដូច្នេះ កសិករដែលត្រូវការដោះទាល់ គឺកសិករដែលត្រូវការជំនួយឧបត្ថម្ភបន្ទាន់ ជាពិសេសក្នុងករណីមានគ្រោះមហន្តរាយធម្មជាតិ។ ប្រសិនបើគ្រួសារកសិករទាំងនេះត្រូវបានជួយកុំឱ្យជាប់ជំពាក់បំណុលវន្តែក ពួកគេនឹងអាចក្រោកឈរឡើងវិញដោយខ្លួនឯង នៅពេលប្រមូលផលនៅឆ្នាំក្រោយបាន ហើយនឹងមិនត្រូវការជំនួយឧបត្ថម្ភស្បៀងយូរអង្វែងនោះទេ។

ពាក់ព័ន្ធនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនោះ ចំណុចខ្លាំងរបស់កម្ពុជាគឺ សមត្ថភាពក្នុងការផលិតបានលើសពីតម្រូវការ រហូតដល់១លានតោនអង្ករ ដោយមិនប៉ះពាល់ដល់ព្រៃឈើពីព្រោះតំបន់ដាំដុះនៅពេលនេះ នៅមិនទាន់ឈានដល់ទំហំនៅមុនពេលសង្គ្រាមនៅឡើយទេ។ជាងនេះទៅទៀត ការបង្កើនផលិតភាពពី ២ទៅ៣តោនក្នុងមួយហិចតា ឬខ្ពស់ជាងនេះនឹងជួយពង្រឹងសន្តិសុខស្បៀងនិងជួយបង្កើនការនាំចេញផងដែរ។ វិស័យកសិកម្មធានាបាននូវការផ្គត់ផ្គង់ស្បៀងគ្រប់គ្រាន់ដោយខ្លួនឯង ប៉ុន្តែតំបន់ជាច្រើននៅតែជួបភាពកង្វះខាតស្បៀងដ៏ធ្ងន់ធ្ងរ ជាពិសេសនៅអំឡុងពេលដែលរបបទឹកភ្លៀងធ្លាក់មិនបានល្អ។

ការអភិវឌ្ឍធនធានធម្មជាតិដែលគាំទ្រដល់អ្នកក្រីក្រនិងមានសណ្ដាប់ធ្នាប់ នឹងជួយបំពេញបន្ថែមប្រាក់ចំណូលដល់គ្រួសារកសិការតូចតាច និងពង្រឹងបន្ថែមសន្តិសុខស្បៀង។ ធនធានធម្មជាតិនិងដីធ្លី ដើរតួនាទីយ៉ាងសំខាន់មួយក្នុងយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ តាមរយៈការលើកកម្ពស់សុខុមាលភាព និងការកាត់បន្ថយភាពងាយទទួលរងគ្រោះរបស់សហគមន៍ជនបទ។ ការជ្រើសរើសទម្រង់កម្មសិទ្ធិ និងលទ្ធភាពទទួលបានដីធ្លីនិងទាញផលពីធនធានធម្មជាតិ គឺជាធាតុដ៏សំខាន់មួយក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។

### ៧.២.២. ប្រព័ន្ធផលិតកម្មកសិកម្មចម្ការ

**ចម្ការ** គឺជាប្រព័ន្ធមួយនៃផលិតកម្មកសិកម្ម ដែលស្រូវត្រូវបានដាំដុះអមជាមួយនឹងដំណាំរួមផ្សំផ្សេងទៀត ដូចជាថ្នាំជក់ សណ្ដែកខៀវ ពោត សណ្ដែកសៀង ចេក។ល។ ប្រព័ន្ធផលិតកម្មកសិកម្មនេះអាចត្រូវបានបែងចែកជាពីរប្រភេទ៖ (១) ផលិតកម្មតាមបណ្ដោយមាត់បឹង និងច្រាំងទន្លេ និង(២) ផលិតកម្មក្នុងតំបន់ខ្ពង់រាប ដែលមានដីក្រហមលាយខ្មៅ។

ក្រៅពីដំណាំស្រូវ ដំណាំដែលសំខាន់បំផុតមាន ពោត សណ្ដែកបាយ បន្លែ ថ្នាំជក់ សណ្ដែកខៀវ សណ្ដែកសៀង ដំឡូងមី ដំឡូងជ្វា អំពៅ និងសណ្ដែកដី។ ដំណាំទាំងនេះត្រូវបានដាំដុះជាចម្បងក្នុងខេត្តដែលមានប្រជាជនកុះករ ដូចជាខេត្តកណ្ដាល ខេត្តកំពង់ចាម និងខេត្តកំពង់ស្ពឺ។ ខេត្តទាំងនេះជាទម្លាប់ជួបប្រទះនូវឱនភាពស្រូវ ហើយកសិករឆ្លើយតបដោយការដាំដំណាំដែលអាចមានប្រាក់ចំណេញច្រើនជាងស្រូវ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាង៧.៤. ផលិតកម្មដំណាំក្រៅពីស្រូវ*

| | 1967 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|
| ពោត | 133 | 151,88 | 185,58 | 148,89 | 314,60 | 256,66 | 247,76 | 365,83 | 522,70 |
| ដំឡូងមី | 23 | 147,76 | 142,26 | 122,01 | 330,64 | 362,05 | 535,62 | 2.200,28 | 2.215,42 |
| ដំឡូង | 13 | 28,17 | 26,25 | 21,25 | 34,89 | 53,13 | 39,14 | 47,80 | 38,31 |
| សណ្តែកខៀវ | | 15,10 | 17,15 | 23,92 | 31,81 | 45,25 | 45,04 | 60,95 | 54,49 |
| សណ្តែកដី | 20 | 7,49 | 8,91 | 9,73 | 18,48 | 21,54 | 22,62 | 18,22 | 30,50 |
| ល្ង | 9 | 9,85 | 8,95 | 10,15 | 21,95 | 54,95 | 90,19 | 34,94 | 31,94 |
| សណ្តែកសៀង | 7 | 28,11 | 24,65 | 38,80 | 63,18 | 110,30 | 179,09 | 100,10 | 117,87 |
| ថ្នាំជក់ | 10 | 7,66 | 4,66 | 2,50 | 7,6 | 2,4 | 14,1 | 15,3 | 13,6 |

*ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

ដោយសារថ្លៃខ្ពស់ ការផលិតសណ្តែកសៀងបានកើនឡើងយ៉ាងខ្លាំង លើសពីកម្រិតនៅមុនឆ្នាំ ១៩៦៧ ទៀត។ ដំណាំទាំងនេះត្រូវបានចាត់ទុកថាជាដំណាំបន្ទាប់បន្សំ ប៉ុន្តែជាប្រភពចំណូលដ៏សំខាន់ចំពោះកសិករតូចតាច។ ផ្ទៃដីសរុបសម្រាប់ដាំពោត សណ្តែកសៀង សណ្តែកខៀវ និងដំឡូងមី បាននឹងកំពុងកើនឡើងយ៉ាងខ្លាំង ដោយសារតែថ្លៃខ្ពស់ល្អធៀបទៅនឹងដំណាំផ្សេងទៀត ជាពិសេសស្រូវ។ ផលិតកម្មនៃដំណាំដូចជាសណ្តែកដី ល្ង អំពៅ ថ្នាំជក់ និងម្រេចនៅមានកម្រិត ដោយសារតែសមត្ថភាពនៃការកែច្នៃ ទំហំនៃទីផ្សារ ក្នុងស្រុក និងតម្រូវការនាំចេញ។ ផ្ទៃដីដាំបន្លែមានទំហំតូច ដែលជះឥទ្ធិពលយ៉ាងខ្លាំងលើអាហារូបត្ថម្ភ។

### *ប្រអប់៧.១. ថ្នាំជក់និងផ្ទាលបណ្តុះ*

សកម្មភាពដ៏ចម្បងនៃក្រុមហ៊ុនថ្នាំជក់អាមេរិកនិងចក្រភពអង់គ្លេស(BAT) នៅកម្ពុជា គឺការធ្វើសមាហរណកម្មខ្សែចង្វាក់ផលិតកម្មបារី ចាប់តាំងពីចម្ការថ្នាំជក់ រហូតទៅដល់ការលក់នៅលើទីផ្សារ។ ក្រុមហ៊ុននេះមានបុគ្គលិកប្រចាំចំនួន៣៨៥នាក់ និងមានកម្មករតាមរដូវកាលចំនួន១,៣០០នាក់ បម្រើការងារនៅចម្ការថ្នាំជក់របស់ខ្លួន នៅមជ្ឈមណ្ឌលការងារខេត្តកំពង់ចាម នៅរោងចក្រសម្ងួតក្នុងក្រុងតាខ្មៅ និងនៅទីស្នាក់ការកណ្តាលក្រុងភ្នំពេញ។ ក្រុមហ៊ុននេះបានបោះទុនចំនួន ២៥លានដុល្លារ។

បច្ចុប្បន្ន BAT មានទីផ្សារ ៥០% ឬបារី៣ពាន់លានដើមក្នុងមួយឆ្នាំ។ ផ្ទៃដីដាំដុះមានទំហំ៨០០ហិចតា ក្នុងចំណោមផ្ទៃដីសរុប១,៥០០ហិចតានៅកម្ពុជា។ ទិន្នផលទទួលបានមានពី ៧៥០ ទៅ១,៩៥០គីឡូក្រាម/ហិចតា និង បរិមាណផលិតបានជាមធ្យម ២,០០០តោនក្នុងមួយឆ្នាំ។ BAT ទិញថ្នាំជក់ពីកសិករ ៧៤៧នាក់ ក្រោមកិច្ចសន្យាជាមួយក្រុមហ៊ុន។ BAT បានព្រងព្រៀងទិញថ្នាំជក់ដែលផលិតបាន ដែលធានាថាកសិករបានផលវិនិយោគ៤០%។ ការនាំចូលដែលពីមុនមានទំហំ ៥៥% នៃថ្នាំជក់ដែលបានប្រើប្រាស់នោះ បានធ្លាក់ចុះមកត្រឹម២០% ហើយការនាំចេញឈានដល់៥០០តោនក្នុងមួយឆ្នាំ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៧.២.៣. ផលិតកម្មកសិកម្មជាទ្រង់ទ្រាយឧស្សាហកម្ម

ផលិតកម្មកសិកម្មទ្រង់ទ្រាយឧស្សាហកម្មត្រូវបានអនុវត្តភាគច្រើន នៅលើដីសម្បទានសេដ្ឋកិច្ច ដែលត្រូវបានផ្ដល់ដោយរដ្ឋាភិបាល សម្រាប់ការផលិតដំណាំដូចជា កៅស៊ូ ម្រេច កាហ្វេនិងកប្បាស។ ក្រសួងកសិកម្មរុក្ខា ប្រម៉ាញ់និងនេសាទ បានអនុម័តដីសម្បទានសេដ្ឋកិច្ចក្នុងទំហំ ៨២៧,២៨៦ហិចតា គិតនៅត្រឹមចុងឆ្នាំ២០០០។ ប៉ុន្តែនៅចុងឆ្នាំ២០០២ ក្រសួងនេះបានលុបចោលសម្បទានលើផ្ទៃដី ១០៣,៦៨០ហិចតា។ នាពេលបច្ចុប្បន្ន ដីសម្បទានសេដ្ឋកិច្ចមានចំនួន ២៦ នឹងមានផ្ទៃដីសរុបចំនួន ៧២៣,៦០៦ហិចតា។ តែទោះជាយ៉ាងណា អំឡុងពីឆ្នាំ២០០៣-២០០៨ ចម្ការទំហំតូចនិងមធ្យម ដែលផលិតកម្មក្នុងទ្រាយឧស្សាហកម្មបានកើតឡើងកាន់តែច្រើនឡើង។

#### *៧.២.៣.១. ចម្ការកៅស៊ូ*

កៅស៊ូគឺជាដំណាំឧស្សាហកម្មដ៏សំខាន់មួយនៅកម្ពុជាជាយូរយាណាស់មកហើយ និងមានសក្ដានុពលរកចំណូលពីការនាំចេញ។ កៅស៊ូគឺជាប្រភពដ៏សំខាន់មួយនៃប្រាក់ចំណូលបានពីការនាំចេញក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ចម្ការកៅស៊ូគ្របដណ្ដប់លើផ្ទៃដីចំនួន៦៥,០០០ហិចតា ដែលក្នុងនោះ៣៩,០០០ហិចតាកំពុងប្រមូលផល ដែលទទួលបានទិន្នផលចំនួន៥២,០០០តោន។ ក្នុងឆ្នាំ២០០៣ កម្ពុជាទទួលបានជោគជ័យក្នុងការបង្កើនផ្ទៃដីប្រមូលផល ទៅដល់កម្រិតមួយនៃចុងទសវត្សរ៍ឆ្នាំ១៩៦០។ ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៨ ការដាំដុះថ្មីៗត្រូវបានចាប់ផ្ដើម និងផ្ទៃដីប្រមាណ៥២,៧៧១ហិចតាត្រូវបានដាំដុះសារជាថ្មី។

រាជរដ្ឋាភិបាលគ្រប់គ្រងផលិតកម្មនិងទីផ្សារ តាមរយៈក្រុមហ៊ុនដែលកាន់កាប់ដោយរដ្ឋ។ ដោយដំណាំកៅស៊ូប្រើប្រាស់ពលកម្មច្រើន ឧស្សាហកម្មនេះអាចរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារនៅតំបន់ជនបទ។ តំបន់ដាំដុះកៅស៊ូកំពុងកើនឡើងជាបន្តបន្ទាប់ ដោយសារជំរុញឱ្យមានចម្ការលក្ខណៈគ្រួសារ។ ចម្ការរដ្ឋក៏បានអនុវត្តកម្មវិធីយុវកម្ម ដោយប្រើប្រាស់ពូជកៅស៊ូទិន្នផលខ្ពស់។

ការអភិវឌ្ឍចម្ការកៅស៊ូលក្ខណគ្រួសារ គឺជាគោលបំណងរបស់រាជរដ្ឋាភិបាល ហើយចាំបាច់ត្រូវមានការបណ្ដុះបណ្ដាលផ្នែកបច្ចេកទេសជាមុន និងជំនួយផ្នែកហិរញ្ញវត្ថុ។ គម្រោងសម្រាប់អភិវឌ្ឍចកម្ការកៅស៊ូលក្ខណគ្រួសារកំពុងត្រូវបានផ្ដល់មូលនិធិ ដោយទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD)។ ការគ្រប់គ្រងផ្នែកបច្ចេកទេសនិងរដ្ឋបាលនៃចម្ការកៅស៊ូលក្ខណគ្រួសារ ស្ថិតក្រោមអគ្គនាយកដ្ឋានចម្ការកៅស៊ូ។ នៅក្នុងឆ្នាំ ២០០៣ កម្មវិធីនេះបានជួយដល់ចម្ការកៅស៊ូលក្ខណគ្រួសារចំនួន៥១០ហិចតា។ បន្ថែមទៅការស្ដារគម្របផ្ទៃដីព្រៃដែលខូចខាតឡើងវិញ ចម្ការកៅស៊ូផ្ដល់ជាប្រភពចំណូលរយៈពេលយូរអង្វែងសម្រាប់អ្នកនៅទីនោះ។ នៅត្រឹមឆ្នាំ២០០៨ ចម្ការកៅស៊ូលក្ខណៈគ្រួសារ ត្រូវបានគេប៉ាន់ស្មានថាមានទំហំលើសពី ៥១,០០០ហិចតា។

ការស្ដាររចនាសម្ព័ន្ធវិស័យកៅស៊ូឡើងវិញ គឺជាបញ្ហាប្រឈមមួយសម្រាប់កម្ពុជា។ កិច្ចប្រឹងប្រែងនេះត្រូវការការវិនិយោគខ្ពស់ ហួសពីសមត្ថភាពរបស់សហគ្រាសរដ្ឋ ឬថវិកាជាតិ។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចអនុញ្ញាតឱ្យវិស័យឯកជនចូលអនុវត្តនៅក្នុងផែនការអភិវឌ្ឍន៍វិស័យនេះ។ អភិក្រមនេះកំពុងត្រូវបានសាកល្បង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាង៧.៥. ចម្ការកៅស៊ូក្នុងឆ្នាំ២០០៨*

| | ផ្ទៃដីចៀរជ័រ (ហិចតា) | ផលិតកម្ម (MT) | ផ្ទៃដីកៅស៊ូដាំថ្មី (ហិចតា) | កម្លាំងពលកម្ម (2007) |
|---|---|---|---|---|
| ជប់ | 6 269 | 9 027 | 2 773 | 4 052 |
| ពាមជាំង | 2 001 | 2 153 | 284 | 1 172 |
| ក្រែក | 1 363 | 966 | 320 | 1 063 |
| មេមត់ | 1 903 | 1 213 | - | 1 378 |
| ស្នួល | 1 004 | 1 065 | - | 820 |
| ចំការអណ្ដូង | 1 955 | 1 341 | - | 1 556 |
| បឹងកេត | 1 300 | 650 | - | 908 |
| CRRI | 284 | 184 | - | 299 |
| តាប៉ៅ | 1 053 | 559 | - | - |
| ឡាបានសៀក | 36 500 | 2 133 | - | - |
| សម្បទាន | - | - | 8 205 | - |
| គ្រួសារ | 13 037 | 12 385 | 41 190 | - |
| Total | 33 670 | 31 676 | 54 227 | 11 678 |

*ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

ក្នុងឆ្នាំ២០០៨ ចម្ការកៅស៊ូគ្រប់ដណ្ដប់លើផ្ទៃដី ១០៧,៩០០ហិចតា ដែលក្នុងនោះ ៤៥,៤៦៩ ហិចតាជាចម្ការមានស្រាប់ ៥៤,២២៧ ហិចតាជាចម្ការលក្ខណគ្រួសារ និង៨,២០៥ហិចតាជាការវិនិយោគថ្មីៗ។ ប្រមាណ ៣៣,៦៧០ហិចតាកំពុងប្រមូលផល ដោយផ្ដល់ទិន្នផលបានចំនួន ៣១,៦៧៦តោន។ តំបន់ដែលដាំដើមកៅស៊ូកំពុងតែកើនឡើងឥតឈប់ឈរ ដោយសារតែការចម្ការលក្ខណៈគ្រួសារ។ ចម្ការដែលកាន់កាប់ដោយរដ្ឋក៏បានអនុវត្តកម្មវិធីយុវកម្ម ដោយជំនួសដោយពូជទិន្នផលខ្ពស់។

ចម្ការកៅស៊ូភាគច្រើនបំផុត មានទីតាំងនៅខ្ពង់រាបភាគខាងក្រោមនៃដីគ្រួសក្រហមក្នុងខេត្តកំពង់ចាម និងខេត្តក្រចេះ។ ដីគ្រួសក្រហមផ្ដល់នូវលក្ខខណ្ឌអេកូឡូស៊ីល្អបំផុតសម្រាប់ការដាំដុះកៅស៊ូ ជាដីឥដ្ឋជ្រាបទឹកចូលជ្រៅ ដែលមានជីជាតិខ្ពស់។ របបទឹកភ្លៀងទៀតសោតមានឥតខ្វះនៅក្នុងខេត្តទាំងនេះ។

តំបន់ទីពីរដែលមានសក្ដានុពលខ្ពស់គឺស្ថិតនៅក្នុងខេត្តរតនគិរីនិងខេត្តមណ្ឌលគិរី ដែលស្ថិតនៅភាគបូព៌ាប្រទេសកម្ពុជា ដែលមានលក្ខខណ្ឌអេកូឡូស៊ីសមស្រប។ តំបន់ទីបីក្រៅពីតំបន់ដីក្រហម គឺតំបន់ដីថ្មខ្សាច់ដែលមាននៅតំបន់ផ្សេងៗនៃប្រទេស ដូចជាខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តកំពត។ ចម្ការកៅស៊ូនៅកម្ពុជាមានបីប្រភេទ រួមមាន៖

**ចម្ការឧស្សាហកម្មកាន់កាប់ដោយរដ្ឋ៖** ចម្ការកៅស៊ូដែលកាន់កាប់ដោយរដ្ឋ សរុបទាំងអស់មានចំនួនប្រាំពីរ នៅក្រោមការគ្រប់គ្រងនៃអគ្គនាយកដ្ឋានចម្ការកៅស៊ូនៃក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងស្ថិតក្នុងដំណើរការសាកល្បងកម្មវិធីឯកជនភាវូបនីយកម្មចម្ការរដ្ឋ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(អវិនិយោគរបស់រដ្ឋ) ដោយប្រើជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី។ វិនិយោគិនបរទេសពីទ្វីបអាស៊ី អឺរ៉ុប និងវិនិយោគិនក្នុងស្រុកកំពុងស្វែងរកការទទួលបានដីសម្បទានដើម្បីពង្រីកការដាំដុះដំណាំកៅស៊ូថ្មីៗ។

**ចម្ការលក្ខណគ្រួសារ៖** ចម្ការទាំងនេះមានទំហំតិចជាង២០ហិចតា ដែលភាគច្រើនជារបស់កសិករដែលមានជីវភាពធូរធា ជាការវិនិយោគក្នុងស្រុកខ្នាតមធ្យមនិងតូច និងមួយចំណែកតូចជារបស់កសិករ "ក្រីក្រ" (គាំទ្រដោយគម្រោងអភិវឌ្ឍន៍)។ វិស័យចម្ការលក្ខណៈគ្រួសារបច្ចុប្បន្នកំពុងរីករាយនិងកំណើនប្រកបដោយជវភាព។

**ចម្ការឧស្សាហកម្មឯកជន៖** ដែលជា"តួអង្គ"លេចចេញថ្មីដ៏សំខាន់ៗ ដែលចម្ការមានទំហំចាប់ពី២០ហិចតាទៅដល់រាប់ពាន់ហិចតា ដែលត្រូវបានអភិវឌ្ឍដោយវិនិយោគិនឯកជនកម្ពុជា និងដែលមិនមែនជាកសិករ។ ក្នុងចំណោមនោះ អ្នកខ្លះជាវិនិយោគិនមកពីបណ្ដាខេត្ត ប៉ុន្តែភាគច្រើនគឺជាវិនិយោគិនដែលមានទ្រព្យស្ដុកស្ដមពីទីក្រុងភ្នំពេញ។ នាពេលបច្ចុប្បន្ន ចម្ការឯកជនមួយចំនួនមានតូច ដែលស្ថិតនៅក្នុងតំបន់កៅស៊ូចាស់ ប៉ុន្តែគម្រោងថ្មីៗមួយភាគធំគឺស្ថិតក្នុងខេត្តរតនគិរីនិងខេត្តមណ្ឌលគីរី។ និន្នាការនៃការពង្រីកផ្ទៃដីដាំដុះនៃវិស័យឯកជន ក៏អាចនឹងបិទបាំងដោយការធ្វើបរិកប្ប(speculation)ដីធ្លីដែរ។ មានការប៉ុនប៉ង ក្នុងការបង្កើតចម្ការឯកជននៅភាគខាងជើង និងខាងលិចក្រៅពីតំបន់ដាំដុះកៅស៊ូដែលគេស្គាល់ ប៉ុន្តែលទ្ធភាពផ្នែកសេដ្ឋកិច្ច និងបច្ចេកទេសនៅមិនទាន់ប្រាកដនៅឡើយ។

*ប្រអប់៧.២. ផលិតកម្មសូត្រនិងការត្បាញក្រណាត់ជាការរស់ឡើងវិញនៃឧស្សាហកម្មសូត្រក្នុងប្រទេសកម្ពុជា*

កោះដាច់ឬកោះសូត្រត្រូវបានស្គាល់ទូទាំងប្រទេសថាល្បីខាងផលិតសូត្រ។ នៅគ្រប់ផ្ទះទាំងអស់គេឮសូរសម្លេងកីតម្បាញ ដែលកំពុងមាមាញឹកផលិតចេញជាក្រណាត់សូត្រ។ ប្រជាជននៅកោះដាច់ខេត្តកណ្ដាលទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជាបន្តបន្ទាប់ ដែលផ្ដល់មូលនិធិដោយសហគមន៍អន្តរជាតិ ក្នុងបំណងជំរុញសន្ទុះផលិតកម្មអំបោះនិងក្រណាត់សូត្រ។

ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) បានចាប់ផ្ដើមកម្មវិធីមួយក្នុងការគាំទ្រដល់វិស័យសូត្រនេះ។ កម្មវិធីនេះមានបំណងស្ដារឡើងវិញនូវរបស់ដែលមានស្រាប់នៅកម្ពុជាប៉ុន្តែផ្ដោតលើបច្ចេកទេសចិញ្ចឹមដង្កូវនាងនិងកីតម្បាញដែលប្រសើរជាងមុន។ ក្នុងពេលដូចគ្នានេះ AFD ព្យាយាមបង្កើតទំនាក់ទំនងឱ្យបានល្អប្រសើររវាងក្រុមអ្នកចិញ្ចឹមនាង និងអ្នកត្បាញ ដែលមាននៅតំបន់ផ្សេងៗនៃប្រទេស។

ការចិញ្ចឹមដង្កូវនាងបច្ចុប្បន្នមិនទាន់កាក់កបប៉ុន្មានទេ។ ជាមធ្យម គេអាចរកចំណូលបានប្រមាណ២០០ដុល្លារក្នុងមួយឆ្នាំ។ ប៉ុន្តែអ្នកបង្កាត់ពូជដង្កូវនាងដែលជោគជ័យអាចបានចំណេញទ្វេរដង។ ស្ថិតក្រោមគម្រោងសាកល្បងមួយ ដង្កូវនាងដែលសម្បុករបស់វាត្រូវបានគេយកធ្វើជាសរសៃរសូត្រដ៏ប្រណិតនោះ ត្រូវបានចិញ្ចឹមនៅខេត្តរតនគិរី។ ក្នុងឆ្នាំ២០០៣ នៅក្រោមកម្មវិធី AFD មានអ្នកចូលរួមជាអ្នកត្បាញសូត្រជាង១,៨០០នាក់ និងនៅចុងឆ្នាំ ២០០៤ អ្នកបង្កាត់ពូជនាងចំនួន១,០០០នាក់ ទទួលបានការបណ្ដុះបណ្ដាល។ ការបណ្ដុះបណ្ដាលដាំដើមនាង ដែលយកស្លឹកជាចំណីដល់ដង្កូវនាង ត្រូវបានផ្ដលល់បន្ថែមដល់អ្នកបង្កាត់ពូជ។

*ប្រភព ៖ Cambodge Soir ១៩ ឧសភា ២០០៤*

## ៧.៣. ខស័យព្រៃឈើនិងគោលនយោបាយព្រៃឈើ

ធនធានធម្មជាតិភាគច្រើនគឺជាទំនិញសាធារណៈ ពីព្រោះកម្មសិទ្ធនៃធនធានទាំងនោះមិនត្រូវបានកំណត់។ ឧទាហរណ៍ល្អបំផុត និងដែលមានសារៈសំខាន់សម្រាប់កម្ពុជានោះគឺធនធានព្រៃឈើ និងនេសាទ។ បរិស្ថានប្រកួតប្រជែងមួយដែលគ្មាននិយតកម្ម នឹងនាំទៅដល់ការបាត់បង់ព្រៃឈើ និងភាពហិនហោចនៃជង្រុកត្រី ពីព្រោះអ្នកនេសាទម្នាក់ៗមិនបាច់បារម្ភដល់ការងារអភិរក្ស។ ម្យ៉ាងទៀត វិស័យទេសចរណ៍គឺជាឧស្សាហកម្មមួយផ្សេងទៀតដែលពឹងផ្អែកទៅលើការគ្រប់គ្រងធនធានធម្មជាតិឱ្យបានល្អ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រៃឈើគឺជាសមាសធាតុសំខាន់មួយនៃមរតកធម្មជាតិ។ អង្គការFAO បានប៉ាន់ស្មានថា នៅចុងទសវត្សរ៍ឆ្នាំ១៩៩០ព្រៃឈើបានគ្របដណ្តប់ជិត៦០% នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជាឬប្រមាណ១០ទៅ១១លានហិចតា បើប្រៀបធៀបនឹង៧៥% នៅដើមទសវត្សរ៍ឆ្នាំ១៩៦០។ ប្រសិនបើប្រៀបធៀបជាមួយប្រទេសថៃ និងវៀតណាម គម្របព្រៃឈើមានតែ២០% ស្ថានភាពនៅកម្ពុជាគឺមិនគួរឱ្យព្រួយបារម្ភណ៍ខ្លាំងពេកទេ ប៉ុន្តែការថយចុះទំហំព្រៃឈើបង្កជាក្តីបារម្ភណ៍មួយ។ ការបំផ្លាញព្រៃឈើគឺបណ្តាលមកពីការធ្វើពាណិជ្ជកម្ម ការកាប់ឈើពីសំណាក់ក្រុមបំបែកខ្លួនផ្សេងៗក្នុងអំឡុងឆ្នាំនៃសង្គ្រាមតស៊ូ (ជាពិសេសនៅតាម បណ្តោយព្រំដែនថៃ) និងការកាប់ឈើដោយគ្មានការគ្រប់គ្រង។ ទោះបីជាយ៉ាងណា យោងទៅតាមរដ្ឋបាលព្រៃឈើ នៅឆ្នាំ២០០៨ គម្របព្រៃឈើមានទំហំប្រមាណ ៦០% (ឬ១១,១០៩,២៨៥ហិចតា) ទោះបីជាអត្រានៃការដាំដើមឈើឡើងវិញនៅទាបនៅឡើយក្តី។

ដោយការពិចារណាទៅលើលក្ខណៈពិសេសនៃពពួកសត្វនិងជីវចម្រុះរបស់ប្រទេសកម្ពុជា នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ រាជរដ្ឋាភិបាលកម្ពុជាកំណត់យកតំបន់អភិរក្សព្រៃឈើ ក្នុងទម្រង់ជាឧទ្យានជាតិ ដែនជម្រកសត្វព្រៃ និងអាងរងទឹកភ្លៀងនៃប្រភពទឹកត្រូវការពារ។ ក្នុងឆ្នាំ២០០៩ ព្រៃឈើជាតិបម្រុងទុក ឧទ្យានជាតិ និងតំបន់ការពារ មានផ្ទៃក្រឡា៣.៣លានហិចតា។ ព្រៃឈើប្រមាណជា ១១០,០០០ហិចតា ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៍។

កម្ពុជាមានជម្រុកដ៏សំខាន់មួយនៃធនធានធម្មជាតិ។ ជារួម ធនធានទាំងនេះរួមមាន៖ (១) ពពួកសត្វនិងព្រៃឈើ (២) ធនធានជលផលនិង(៣) ឆ្នេរសមុទ្រ។ ទោះបីប្រភេទសត្វខ្លះលែងមានវត្តមាន ក៏ដោយពពួកសត្វនៅកម្ពុជានៅសំបូរនៅឡើយ មួយផ្នែកដោយសារតែវត្តមានព្រៃត្រូពិច។ពពួកសត្វដែលរួមមានបក្សី ដំរី និងអណ្តើក ទទួលការគំរាមកំហែង ដោយសារការធ្វើអាជីវកម្មនិងពាណិជ្ជកម្មខុសច្បាប់។

តាមច្បាប់ ព្រៃឈើជាកម្មសិទ្ធិរបស់រដ្ឋ។ ក្រោមបទបញ្ជារបស់រដ្ឋ គម្របព្រៃឈើត្រូវបានបែងចែកជាអចិន្ត្រៃយ៍ជាដែនអភិរក្ស និងដែនការពារ។ ដែនអភិរក្ស គឺស្ថិតនៅក្រោមវិធានអភិវឌ្ឍន៍ ឬអភិរក្សដ៏តឹងរឹងនោះ រួមបញ្ចូលទាំងដែនសម្រាប់ផលិតកម្ម និងការការពារ។ ដែនការពារ រួមមានព្រៃឈើទាំងអស់ដែលមិនរួមបញ្ចូលក្នុងដែនអភិរក្ស។

ការអភិវឌ្ឍធនធានព្រៃឈើក្នុងប្រទេសកម្ពុជាជួយនូវឧបសគ្គច្រើន ដោយសារប្រព័ន្ធនិយតកម្មលើការធ្វើអាជីកម្មព្រៃឈើមិនទាន់ល្អ រួមផ្សំនឹងកំណើននគរូបនីយកម្មដ៏ឆាប់រហ័ស គួបផ្សំជាមួយនឹងភាពក្រីក្រផងនេះ បាននាំទៅដល់ការបំផ្លាញព្រៃឈើ។ បញ្ហាចម្បងក្នុងការគ្រប់គ្រងធនធានធម្មជាតិនោះ គឺការអភិវឌ្ឍប្រកបដោយចីរភាពនៃធនធានទាំងនេះ ឱ្យមានសង្គតិភាពទៅនឹងការគ្រប់គ្រងសេដ្ឋកិច្ចក្នុងវិស័យជាយុទ្ធសាស្ត្រ ដូចជាកសិកម្ម ជលផល និងទេសចរណ៍។ ដើម្បីដោះស្រាយបញ្ហានេះរដ្ឋាភិបាលបានប្រើប្រាស់នូវយុទ្ធសាស្ត្រមុខបី ដូចខាងក្រោម៖

- ប្រើប្រាស់ឧត្តមានុវត្តអន្តរជាតិសម្រាប់ការគ្រប់គ្រងព្រៃឈើ រួមមានព្រៃបម្រុងក្នុងទំហំគ្រប់គ្រាន់ ដើម្បីបំពេញនូវតម្រូវការនៃការប្រើប្រាស់ក្នុងស្រុក ទប់ស្កាត់ភាពរាំងស្ងួតនិងទឹកជំនន់ និងផ្តល់ជាតំបន់ដីសើម ដែលមានសារសំខាន់ដល់ការបម្រុងទុកផ្នែកជលផល។
- ប្រើប្រាស់ប្រព័ន្ធតំបន់ការពារ ដើម្បីអភិរក្សជីវចម្រុះនិងប្រភេទសត្វ ដែលទទួលរងនូវការគំរាមកំហែង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ជំរុញការអភិវឌ្ឍសហគមន៍ព្រៃឈើដែលមានតម្លាភាព និងជឿជាក់នៅថ្នាក់មូលដ្ឋាន។

ដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពដូចខាងក្រោម៖

- ការពង្រឹងការគ្រប់គ្រងនិងការការពារព្រៃឈើ។
- សនិទានកម្មនិងធ្វើចំណាត់ថ្នាក់ព្រៃឈើដែលនៅសល់ ដើម្បីធានានូវការការពារបរិស្ថាន និងការអភិរក្សជីវចម្រុះ ដោយអនុវត្តតាមអនុក្រឹត្យស្តីពីការធ្វើចំណាត់ថ្នាក់ព្រៃឈើ។
- ការពង្រឹងការអនុវត្តបទបញ្ជាស្តីពីព្រៃឈើ ជាពិសេសបទបញ្ជាលេខ០១បប ចុះថ្ងៃទី៩ខែមិថុនាឆ្នាំ២០០៩ស្តីពីវិធានការសម្រាប់ការគ្រប់គ្រងការកាប់បំផ្លាញព្រៃឈើ និងការទន្ទ្រានយកដីព្រៃ។
- ការពង្រឹងយុទ្ធសាស្ត្រការពារ ដូចជាការការពារព្រៃ ការគ្រប់គ្រងផ្ទៃអាងរងទឹកភ្លៀង ការប្រមូលសេនេទិច ការពារសត្វព្រៃវិស័យ អេកូទេចរណ៍ និងគម្រោងការពារផ្សេងៗទៀតដោយមានការចូលរួមដោយសហគមន៍ និងផ្អែកលើផែនការគ្រប់គ្រងដ៏មានប្រសិទ្ធភាព។
- អនុវត្តដោយម៉ឺងម៉ាត់នូវបច្ចេកទេសគ្រប់គ្រងព្រៃឈើ រួមមានការគ្រប់គ្រងនិងការប្រើប្រាស់ប្រកបដោយចីរភាពនៃធនធាននិងសម្បទានព្រៃឈើ។
- ការអប់រំនិងយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីធនធានព្រៃឈើ។
- លើកស្ទួយការរួមចំណែកនៃវិស័យព្រៃឈើ ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច៖
    - រំលេចពីភាពចាំបាច់ផ្នែកសង្គមសេដ្ឋកិច្ច ក្នុងការការពារព្រៃឈើនិងជីវចម្រុះ។
    - លើកកម្ពស់ការដាំដើមឈើឡើងវិញក្នុងតំបន់ព្រៃឈើជាតិ តាមរយៈការលើកទឹកចិត្តឱ្យមានការវិនិយោគទុនឯកជន និងការចូលរួមពីសហគមន៍។
    - ប្រើប្រាស់ កែច្នៃ និងធ្វើពាណិជ្ជកម្មផលិតផលព្រៃឈើក្នុងកម្រិតល្អប្រសើរបំផុត(optimal) ដើម្បីបំពេញតាមតម្រូវការនាំចេញនិងតម្រូវការក្នុងស្រុក។
    - លើកកម្ពស់ការដាំដើមឈើឡើងវិញ និងការការពារដើមឈើ។
- ធ្វើសមាហរណកម្មការអភិវឌ្ឍព្រៃឈើ ជាមួយនឹងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ៖
    - ពង្រឹងការការពារផ្លូវច្បាប់ចំពោះសិទ្ធិសហគមន៍ ក្នុងការគ្រប់គ្រងព្រៃឈើដើម្បីធានា សន្តិសុខស្បៀង និងលើកកម្ពស់ការកាត់បន្ថយភាពក្រីក្រ។ សិទ្ធិទាំងនេះត្រូវបានធានាដោយច្បាប់ព្រៃឈើនិងបទបញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត។
    - ធានាថាសហគមន៍នៅមូលដ្ឋានទទួលបានប្រយោជន៍ពីការប្រើប្រាស់ និងការគ្រប់គ្រង ធនធានព្រៃឈើ។
- កសាងសមត្ថភាព និងអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងព្រៃឈើ៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- បន្តធ្វើការកសាងសមត្ថភាពស្ថាប័ននៅគ្រប់កម្រិត។
- បើយុទ្ធនាការណែនាំ អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងក្នុងចំណោម សហគមន៍មូលដ្ឋាន ដើម្បីជំរុញការចូលរួមពីសហគមន៍ក្នុងការការពារ និងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព។
- លើកកម្ពស់ការកសាងសមត្ថភាពនៅគ្រប់កម្រិតរបស់រដ្ឋបាលព្រៃឈើ ដែលមន្ត្រីពាក់ព័ន្ធ អាចបំពេញការងារប្រកបដោយការទទួលខុសត្រូវ និងសហប្រតិបត្តិការល្អជាមួយនឹងស្ថាប័នដែលពាក់ព័ន្ធ។

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ចំពោះការគ្រប់គ្រងព្រៃឈើ ចាប់តាំងពីខែមករាឆ្នាំ១៩៩៩។ សកម្មភាពខុសច្បាប់នានាត្រូវបានកាត់បន្ថយ។ នាយកដ្ឋានអធិការកិច្ចដែនព្រៃឈើមួយត្រូវបានបង្កើតឡើង ដោយមានការចូលរួមពេញទំហឹងពី Société Générale de Surveillance (SCS) និងដំណើរការត្រួតពិនិត្យឡើងវិញអំពីប្រព័ន្ធសម្បទាន ត្រូវបានបំពេញចប់សព្វគ្រប់។ ដោយផ្អែកទៅលើលទ្ធផលនៃការបូកសរុបរបស់ SCS រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការលុបចោលសម្បទានព្រៃឈើ។ សម្បទានព្រៃឈើត្រូវបានកាត់បន្ថយ ពី៦.៤លានហិចតាក្នុងឆ្នាំ១៩៩៩ មកនៅត្រឹម២.៤លានហិចតា (សម្បទានចំនួន៨) ក្នុងឆ្នាំ២០០៤។ ច្បាប់ព្រៃឈើថ្មីមួយត្រូវបានអនុម័តក្នុងឆ្នាំ២០០២ បន្ទាប់ពីមានការពិគ្រោះពិភាក្សាថ្នាក់ជាតិ ជាបន្តបន្ទាប់មួយ ជាមួយនឹងភាគីពាក់ព័ន្ធ។

វិធានការតឹងរឹងដែលត្រូវបានអនុវត្តដោយរដ្ឋាភិបាល ប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់នោះ គ្របដណ្តប់នីតិវិធីអនុវត្តច្បាប់ ទាំងការបង្ការ ការស៊ើបអង្កេត និងការដាក់ទោស។ ក្នុងខែមិថុនាឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវបទបញ្ជាលេខ០១ប.ប ស្តីពីការទប់ស្កាត់ បង្រ្កាប និងលុបបំបាត់ការកាប់រាញ ដុត ឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃ ដោយបានបង្កើតនូវគណៈកម្មាធិការជាតិមួយ ដែលគាំទ្រដោយអនុគណកម្មាធិការថ្នាក់ខេត្តដើម្បីអនុវត្តបទបញ្ជានេះ។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តប្រយុទ្ធប្រឆាំងយ៉ាងខ្លាំងក្លាទៅនឹងអាជីវកម្មខុសច្បាប់។

រាជរដ្ឋាភិបាលនឹងបន្តបង្កើនកម្រិតបច្ចេកទេសដល់អ្នកទទួលបានសម្បទាន និងទីភ្នាក់ងាររដ្ឋាភិបាល ដែលបំពេញការងារគ្រប់គ្រងសម្បទានព្រៃឈើ។ រាជរដ្ឋាភិបាលត្រូវធានាឱ្យបានពីការគ្រប់គ្រងឱ្យបានល្អនៃតំបន់ព្រៃឈើ ដែលដកចេញមកពីប្រព័ន្ធសម្បទាន។ ក្នុងហេតុផលនេះហើយ គេត្រូវប្តេជ្ញាបង្កើនកិច្ចប្រឹងប្រែងទ្វេដងថែមទៀត ដើម្បីលើកកម្ពស់ប្រតិបត្តិការរបស់នាយកដ្ឋានអធិការកិច្ចដែនព្រៃឈើ។

ទាក់ទងនឹងផ្នែកច្បាប់វិញ រាជរដ្ឋាភិបាលកម្ពុជាបានអភិវឌ្ឍយន្តការគ្រប់គ្រងនិងបទបញ្ញត្តិចាំបាច់បន្ថែមទៀត ដើម្បីអនុវត្តច្បាប់ព្រៃឈើឆ្នាំ២០០២។ អនុក្រឹត្យស្តីពីការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ត្រូវបានប្រកាសក្នុងខែធ្នូឆ្នាំ២០០៣ ដោយបានដាក់ទ្រព្យសម្បត្តិព្រៃឈើ ឱ្យស្ថិតនៅក្រោមការដឹកនាំរបស់សហគមន៍មូលដ្ឋាន នៅក្នុងក្របខណ្ឌនៃផែនការគ្រប់គ្រងរួម និងមានកិច្ចព្រមព្រៀងក្នុងចែករំលែកផលចំណេញ។ អនុក្រឹត្យនេះ គឺជាលទ្ធផលនៃការស្រាវជ្រាវនិងការប្រឹក្សាយោបល់ជាមួយភាគីពាក់ព័ន្ធជាច្រើន រយៈពេលប្រាំមួយឆ្នាំ និងជាការបំពេញបន្ថែមចំពោះវិធានការផ្សេងៗទៀត ដូចជាអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចក្នុងគោលដៅគ្រប់គ្រងផលិតភាព ធនធានធម្មជាតិឱ្យកាន់តែប្រសើរឡើង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រព័ន្ធសម្បទានព្រៃឈើនិងសម្បទានបុគ្គលត្រូវបានកែប្រែក្រោមច្បាប់ឆ្នាំ២០០២ ដោយចាប់ឱ្យមានគណនេយ្យភាពចំពោះសហគមន៍ ដែលរស់នៅអាស្រ័យផលនឹងព្រៃឈើ និងយកចិត្តទុកដាក់ថែមទៀតចំពោះប្រយោជន៍សាធារណៈ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងបន្តអនុវត្តកំណែទម្រង់នៃការគ្រប់គ្រងព្រៃឈើ រួមមានការកែសម្រួលឡើងវិញនូវកិច្ចសន្យាជាមួយនឹងសម្បទានិក ដែលកំពុងប្រតិបត្តិការ និងការអនុវត្តវិធានការប្រឹក្សាជាមួយនឹងសហគមន៍មូលដ្ឋាន ព្រមទាំងចៀសវាងជម្លោះនានា និងផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន។ ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើបានផ្តល់អំណាចឱ្យសហគមន៍តាមជនបទ ក្នុងការគ្រប់គ្រងធនធានធម្មជាតិ។

រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការជាដៃគូជាមួយម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដើម្បីសាកល្បងគំនិតផ្តួចផ្តើមសហគមន៍ នៅក្នុងតំបន់មួយចំនួននៃប្រទេស។ ផ្ទៃដី១១០,០០០ហិចតា ត្រូវបានអភិវឌ្ឍក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងការអភិវឌ្ឍសហគមន៍ព្រៃឈើ។

## ៧.៤. វិស័យនេសាទ

វិស័យនេសាទរួមចំណែកប្រហែល ១០% នៅក្នុងផ.ស.ស.នៃវិស័យកសិកម្ម។ ត្រីគឺជាផលិតផលមួយ ក្នុងចំណោមផលិតផលនាំចេញដ៏សំខាន់របស់កម្ពុជា។ នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ការនេសាទពាណិជ្ជកម្មផ្តល់ទិន្នផលជាមធ្យម ១២០,០០០តោន ក្នុងនោះការនេសាទទឹកប្រៃមាន ៤០,០០០តោន និងវារីវប្បកម្មទឹកសាបមាន ៥,៨០០តោន។ នៅឆ្នាំ២០០៦ ផលិតកម្មជលផលសរុបបានកើនដល់ ៥១៦,៧០០តោន ដែលក្នុងនោះការនេសាទត្រីទឹកសាបបែបពាណិជ្ជកម្មបានកើនដល់ប្រមាណ១៣៩,០០០តោន ការនេសាទត្រីទឹកប្រៃមាន៦០,៥០០តោន វារីវប្បកម្មមាន៣៤,២០០តោន និងផលនេសាទសហគមន៍និងវាលស្រែមាន ២៨៣,០០០តោន នេះជាសញ្ញានៃការនេសាទហួសហេតុនៅក្នុងប្រទេសកម្ពុជា។ ការនេសាទជាសកម្មភាពរកប្រាក់ចំណូល ដែលបង្កើតការងារ ១៧% ឬប្រហែល១.៣លាននាក់។

ត្រីគឺជាមុខអាហារដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា។ ទាំងការនេសាទត្រីទឹកសាប និងទឹកប្រៃប្រព្រឹត្តទៅនៅកម្ពុជា ប៉ុន្តែការនេសាទត្រីទឹកសាបមានសារសំខាន់ជាង។ ធនធានត្រីទឹកសាបរបស់កម្ពុជាមានភាពសំបូរ ដោយសារតែជំនន់ទន្លេមេគង្គប្រចាំឆ្នាំ និងទឹកបឹងទន្លេសាបដ៏ធំល្វឹងល្វើយ។ ប៉ុន្តែការនេសាទនិងការធ្វើកសិកម្មជាបង្កើតជាជម្លោះ ដោយសារតែការប្រកួតប្រជែងដណ្តើមទីកន្លែង។

ត្រីបានផ្គត់ផ្គង់ជាមធ្យម ៣៤% នៃប្រូតេអ៊ីនក្នុងរបបអាហាររបស់ប្រជាជនកម្ពុជា។ សន្តិសុខស្បៀងរបស់មនុស្សរាប់លាននាក់ផ្សេងទៀតជាពិសេស ក្នុងតំបន់ជនបទដាច់ស្រយាល និងប្រជាជនដែលកំពុងធ្វើការក្នុងឧស្សាហកម្មនេសាទ ពឹងពាក់យ៉ាងខ្លាំងលើការនេសាទត្រីបែបប្រពៃណី។ នៅក្នុងការកែច្នៃនិងទិញលក់ត្រីធ្វើឡើងភាគច្រើនលើសលប់ដោយស្ត្រី។ យោងតាមការប៉ាន់ស្មាន មានស្ត្រីរហូតដល់ប្រមាណ៥០% នៃកម្លាំងការងារសរុបក្នុងវិស័យនេសាទ។

បឹងទន្លេសាបស្ថិតចំកណ្តាលនៃវាលទំនាបកណ្តាល។ ទន្លេសាបហូរចេញចូលបឹងបួរ និងទន្លេ តាមទិសជើង-ត្បូង។ទន្លេមេគង្គហូរចូលកម្ពុជានៅចំណុចនៃព្រំដែនប្រទេសថៃនិងឡាវជួបគ្នា។ ផ្លូវទឹកហូរកាច់កុងចាក់ទៅភាគខាងកើតនៃអាងកណ្តាល មុនពេលបន្តហូរចាក់ដល់ភ្នំពេញ។

នៅភ្នំពេញទន្លេសាបនិងទន្លេមេគង្គមកជួបប្រសព្វគ្នា។ នៅឆ្ងាយពីនេះប៉ុន្មានរយម៉ែត្រពីចំណុចប្រសព្វនេះ ទន្លេមេគង្គបានបែកខ្លួនជាពីរ ដែលចំណុចផ្តើមនៃដែនដីសណ្តរបស់វា។ ដៃទន្លេមួយនៅរក្សាឈ្មោះមេគង្គដដែល ហើយដៃទន្លេមួយផ្សេងទៀតត្រូវបានហៅថាទន្លេបាសាក់។ ការហូរចាក់មកប្រសព្វគ្នានិងការញែកចេញរបស់ទន្លេមេគង្គបង្កើតបានរាងអក្សរ X ដែលត្រូវបានគេហៅថា **ចតុមុខ**។ នៅទីនេះ គឺជាលក្ខណពិសេសមានតែមួយក្នុងពិភពលោក គឺការហូរបញ្ច្រាស់នៃចរន្តទឹកទន្លេ។ អាស្រ័យទៅលើកម្រិតទឹកជំនន់ទឹកទន្លេសាបហូរចេញពីបឹងទន្លេសាប(ពីខែ វិច្ឆិកា ដល់មិថុនា)ឬហូរចូលបឹងវិញ(ពីខែមិថុនាដល់តុលា)។ ពីធីបុណ្យអុំទូក ប្រារព្ធឡើងនៅពេលដែលទឹកទន្លេសាប ហូរត្រឡប់ទៅទន្លេមេគង្គវិញនៅចុងខែតុលា ឬដើមខែវិច្ឆិកា។

*តារាង៧.៥. ផលិតផលនេសាទ (ពាន់តោន)*

| | 1999 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|
| ឡូត៍នេសាទធំ និងកណ្តាល | 71,0 | 110,3 | 94,8 | 94,5 | 139,0 | 139,0 | 125,0 | 115,0 |
| ផលនេសាទសហគមន៍ និង វាលស្រែ | 160,0 | 250,0 | 214,0 | 229,5 | 166,0 | 283,0 | 270,0 | 250,0 |
| វារីវប្បកម្ម | 15,0 | 18,3 | 26,4 | 25,8 | 21,6 | 34,2 | 35,3 | 40,0 |
| ផលិតផលនេសាទសមុទ្រ | 38,1 | 45,9 | 54,5 | 32,6 | 33,9 | 60,5 | 63,5 | 66,0 |
| សរុប | 284,1 | 424,4 | 389,7 | 382,4 | 360,5 | 516,7 | 493,8 | 471,0 |

*ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

បឹងទន្លេសាបគឺជាធនធានធម្មជាតិពិសេសមួយ។ ក្រៅពីតួនាទីជលសាស្ត្រ បឹងនេះមានព្រៃលិចទឹកនៅជុំវិញ ដែលជាប្រភពដ៏សំខាន់មួយនៃផលិតកម្មត្រីទឹកសាប។ ផលនេសាទទឹកសាបប្រហែលជា ៦០% នៃបរិមាណត្រីទឹកសាប ដែលលក់លើទីផ្សារផ្នែកពាណិជ្ជកម្មមានប្រភពពីបឹងនេះ។ បឹងនេះសំបូរទៅដោយសារជាតិចិញ្ចឹម ហើយត្រីដែលរកបានពីបឹងនេះមានទំហំធំច្រើនជាងត្រីដែលធំធាត់នៅតាមទន្លេ។ តែទោះជាយ៉ាងណា ភាពគំរាមកំហែងផ្នែកអេកូឡូស៊ីកំពុងគ្របដណ្តប់ទៅលើបឹងទន្លេសាប។ អាត្រានៃកំណរដីល្បាប់បានកើនឡើងខ្ពស់ ដោយសារតែការបំផ្លាញព្រៃឈើ និងកំណកល្បាប់ដែលនាំមកពីទន្លេមេគង្គ។

មួយភាគប្រាំមួយនៃឆ្នេរសមុទ្ររបស់កម្ពុជាប្រវែង៤៣៥គីឡូម៉ែត្របង្កើតបានជាផ្នែកមួយនៃខ្សែឆ្នេររបស់ឈូងសមុទ្រថៃ ដែលសមស្របទៅនឹងការនេសាទសមុទ្រ។

## ៧.៤.១. ផលផលត្រីទឹកសាប

ការនេសាទត្រីទឹកសាបអំឡុងខែវិច្ឆិកាដល់ខែឧសភា គឺជាមុខរបបដ៏សំខាន់របស់សហគមន៍រស់នៅតាមបណ្តោយមាត់បឹងទន្លេសាប និងច្រាំងទន្លេមេគង្គ។ នៅពេលដែលទឹកចាប់ផ្តើមស្រកភ្លាម ជីវិតតាមបណ្តោយខ្សែទឹកនិងបឹងចាប់ផ្តើមមានសកម្មភាពរស់រវើកឡើង។ បឹងនេះគឺទីពំនាក់សម្រាប់ប្រជាជនរាប់លាននាក់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បឹងទន្លេសាប គឺជាមជ្ឈមណ្ឌលមមាញឹកជាងគេបង្អស់ក្នុងប្រទេសកម្ពុជា។ គេប៉ាន់ប្រមាណថា ផលិតកម្មត្រីអាចឈានដល់ ២០០,០០០តោនក្នុងមួយឆ្នាំ (ត្រីទឹកសាប)។ បរិមាណនេះហាក់ដូចជាច្រើនសម្បើមណាស់ ធៀបនឹងផ្ទៃបឹងនៅពេលទឹករាក់ទំហំ ២,៧០០គីឡូម៉ែត្រការ៉េ និងមានផ្ទៃក្រឡា ១០,០០០គីឡូម៉ែត្រការ៉េនៅពេលទឹកឡើងខ្ពស់។ ទន្លេសាបពិតណាស់គឺជាដែននេសាទត្រីទឹកសាបដែលមានផលិតភាពខ្ពស់ និងមានដង់ស៊ីតេ (ធៀបនឹងផ្ទៃអតិបរមា)គ្មានគូរប្រៀបនៅក្នុងពិភពលោក ដែលផ្គត់ផ្គង់៧៥%នៃបរិមាណត្រីទឹកសាបប្រចាំឆ្នាំសម្រាប់ប្រទេស។ នៅចុងរដូវវស្សា ទឹកទន្លេត្រឡប់ទៅសភាពធម្មតា ហើយត្រីបង្កើតកូននៅខ្សែទឹកខាងក្រោម។ បឹងនេះ និងធនធានបម្រុងត្រី ផ្តល់ជាជម្រកដល់សត្វស្លាបធំៗចំនួន១៥ប្រភេទ ដែលជិតផុតពូជ។

ផលិតភាពរបស់បឹងនេះ គឺដោយសារតែលក្ខខណ្ឌពិសេសៗនៃអេកូឡូស៊ី។ បឹងដ៏ធំនេះគឺទំនងជាបាតនៃឈូងសមុទ្រ ក្នុងសម័យបុរាណកាល ហើយតំណភ្ជាប់ទៅនឹងសមុទ្រត្រូវបានកាត់ផ្តាច់ ដោយសារការរីកធំនៃដីសណ្តរទន្លេមេគង្គ។ បន្ទាប់ពីមាត់ឈូងសមុទ្រត្រូវបានចាក់បំពេញជិតនោះ ទន្លេមេគង្គបានរុញច្រានដីសណ្តររបស់វាចេញទៅក្នុងសមុទ្រ។ ប្រវត្តិនៃបឹងនេះ គេអាចដឹងដោយសារមានភស្តុតាងច្បាស់លាស់មិនត្រឹមតែមកអំពីលក្ខណពិសេសផ្នែកភូមិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានវត្តមាននៃសំណល់ពពួកសត្វសមុទ្រ ឬដោយភាពភ្លៀវនៃទឹកក្រោមដីដែលត្រូវបានរកឃើញក្នុងដីឆ្ងាយបន្តិចភាគខាងត្បូងនៃទីក្រុងភ្នំពេញ។

កត្តាទាំងនេះពន្យល់បានមួយចំណែកអំពីមូលហេតុ ដែលធ្វើឱ្យបឹងទន្លេសាបសំបូរត្រី។ ជាក់ស្តែងត្រីទទួលបាននូវបរិស្ថានអនុគ្រោះបំផុតមួយ សម្រាប់ពងកូន នៅក្នុងព្រៃលិចទឹក និងគុម្ពោតនៅក្នុងខែមិថុនា។ បន្ថែមពីនេះ ភាពសំបូរហូរហៀរនៃពពួកវារិជាតិនិងជីវិតសត្វមីក្រូទស្សន៍រីកធំធាត់ក្នុងព្រៃលិចទឹកនេះធ្វើឱ្យទឹកប្រែជាពណ៌ខ្មៅ ខាប់ទៅដោយរូបធាតុបន្លែនិងសត្វ ដែលត្រីគ្រាន់តែបើកចំហរមាត់ដើម្បីចិញ្ចឹមជីវិតតែប៉ុណ្ណោះ។

គេអាចនិយាយបានថា ត្រីដែលហែលក្នុងចំណី ធំធាត់យ៉ាងឆាប់រហ័សបំផុត។ អត្រានៃការរីកធំធាត់គឺខ្ពស់គួរឱ្យកត់សម្គាល់ ហើយធំរហូតស្មើនឹងទំហំត្រីទឹកប្រៃនៅទ្វីបអឺរ៉ុប។ ត្រីក្អែកក្នុងបឹងមានប្រវែងដល់៣២ស.ម ក្នុងរយៈពេលពីរឆ្នាំ ប្រៀបធៀបនឹងត្រីទឹកសាបនៅតំបន់ដ៏ទៃទៀតក្នុងប្រទេសកម្ពុជាមិនធំលូតលាស់ឆាប់រហ័សដូចនេះទេ។ ក្នុងមួយឆ្នាំៗត្រីរាប់លានក្បាលមកបង្កបង្កើតក្នុងព្រៃលិចទឹកជុំវិញមាត់បឹងដែលទាក់ទាញបក្សីទឹកជាច្រើនអនេក។

ធនធានត្រីក្នុងបឹងទន្លេសាបបានទាក់ទាញអ្នកនេសាទជាច្រើន។ មនុស្សបានសម្របខ្លួនទៅនឹងជីវស្ថាននេះ ដោយតាំងទីលំនៅជាភូមិបណ្តែតទឹក ដែលខ្សែជីវិតរសាត់ហូរទៅតាមចង្វាក់ទឹក។ ទីលំនៅអចិន្ត្រៃយ៍នៃអ្នកនេសាទ គឺរស់នៅក្នុងផ្ទះដែលផុតពីដីលើសសរខ្ពស់ៗ ឬនៅលើក្បូនឬស្សី។ ភូមិប្រភេទនេះត្រូវបានរកឃើញនៅគ្រប់ទីកន្លែងតាមបណ្តោយមាត់បឹង។ សហគមន៍តាមបឹងទាំងនេះចំណាយពេលខ្លះនៅលើដី និងពេលខ្លះនៅលើទីរៀងរាល់ឆ្នាំ ហើយចិញ្ចឹមជីវិតដោយដោយផលពីបឹង និងព្រៃលិចទឹក ដែលជាជម្រកត្រី។ ប៉ុន្តែនៅរដូវប្រាំង ចំនួនអ្នកនេសាទកើនឡើងខ្លាំង និងត្រូវបានប៉ាន់ប្រមាណថា មានមនុស្សជាង៣០,០០០នាក់ ធ្វើការទាក់ទងនឹងការនេសាទ។

ក្នុងចំណោមទិន្នផលត្រីទឹកសាបប្រចាំឆ្នាំចំនួន២០០,០០០តោនបានពីបឹងទន្លេសាប ផលត្រីប្រហែលជា៥០,០០០តោនត្រូវបានបរិភោគស្រស់ៗ។ ចំនួនដែលនៅសល់ត្រូវបានកែច្នៃតាមបែបប្រពៃណីទៅជាត្រីឆ្អើរ ត្រីងៀត ប្រហុក និងទឹកត្រី។ ប្រជាជនកម្ពុជាធ្វើត្រីជាម្ហូបតាមវិធីច្រើន គេអាចយកទៅអាំង ចៀន ប្រឡាក់អំបិល ចំហុយ ឬផ្អាប់ទុក។ ក្នុងនោះមានអនុផល ដូចជាខ្លាញ់ត្រី និងចំណីត្រី ត្រូវបានប្រើជាជី ឬចំណីមាន់។ បន្ទាប់ពីបំពេញតម្រូវការក្នុងស្រុក ត្រីប្រមាណជា២៨,០០០តោន ត្រូវបាននាំចេញទៅប្រទេសជិតខាង។

វិធីសាស្ត្រនេសាទត្រីមានពីរប្រភេទ ជាទ្រង់ទ្រាយតូចមិនត្រូវការពលកម្មច្រើន ឬធនធានច្រើនទេ និងទ្រង់ទ្រាយធំដែលត្រូវការគ្រឿងយន្តចំណាយប្រាក់ច្រើន និងមូលធនច្រើន។ ការនេសាទជាទ្រង់ទ្រាយតូចត្រូវបានប្រព្រឹត្តទៅដោយថ្មើរជើង ឬដោយទូកជាមួយនឹងឧបករណ៍នេសាទសាមញ្ញៈខ្សែសន្ទូច ស្នូរ ឬសំណាញ់។ ប្រតិបត្តិករទ្រង់ទ្រាយធំប្រើប្រាស់ប្រួល និងសំណាញ់ធំៗ។

## ៧.៤.២. វារីវប្បកម្ម

ការនេសាទ ការកែច្នៃ និងការលក់ត្រី គឺជាសកម្មភាពសេដ្ឋកិច្ចដ៏សំខាន់បំផុតនៅបឹងនេះបន្ទាប់មកគឺការចិញ្ចឹមត្រីអណ្តែង និងត្រីឆ្ដោបនៅក្នុងបែរ។ សម្រាប់គ្រួសារដែលធ្វើវារីវប្បកម្ម ត្រីមានតម្លៃស្មើនឹងគណនីធនាគារមួយ។ ពួកគេបោះទុនក្នុងការចិញ្ចឹមត្រី ដែលតម្លៃកើនឡើង នៅពេលត្រីនោះធំធាត់និងបង្កកំណើតជាថ្មី ដូចជាការប្រាក់ក្នុងគណនីធនាគារមួយដែរ។ ពេលដែលគ្រួសារត្រូវការប្រាក់ ពួកគេគ្រាន់តែលក់ត្រីខ្លះប៉ុណ្ណោះ។

វារីវប្បកម្មកំពុងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដោយការពង្រឹងសន្តិសុខស្បៀង និងការលើកកម្ពស់ជីវភាពរស់នៅ។ វារីវប្បកម្មមាន៨% នៃផលិតកម្មត្រីប្រចាំឆ្នាំ និងដើរតួនាទីដ៏សំខាន់មួយក្នុងការអភិវឌ្ឍតំបន់ជនបទ។ វារីវប្បកម្មមិនត្រឹមតែអាចឱ្យគ្រួសារជនបទទទួលបានអាហារូបត្ថម្ភគ្រប់គ្រាន់ និងកសិករតូចតាចអាចចិញ្ចឹមជីវិតបាន ប្រសិនបើប្រមូលផលមិនបានល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ការងារ និងជួយបង្កើនកម្រិតប្រាក់ចំណូល ក្នុងសហគមន៍ថែមទៀតផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាបានសហប្រតិបត្តិការជាមួយអង្គការស្បៀងអាហារនិងកសិកម្មសហប្រជាជាតិ (FAO) បានរៀបចំវគ្គបណ្តុះបណ្តាលនានាស្តីពីវារីវប្បកម្ម ដើម្បីជួយសហគមន៍មូលដ្ឋានចេះរៀបស្រះផលិតកូនត្រី និងអោយចំណីត្រី។ វិទ្យាស្ថាន CARDI ក៏បានផ្តល់នូវការបណ្តុះបណ្តាលស្តីពីការចិញ្ចឹមត្រីនិងកូនត្រីក្នុងវាលស្រែដែរ។

## ៧.៤.៣. កំណែទម្រង់វិស័យជលផល

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញការដ្ឋានកែទម្រង់ជ្រាលជ្រៅ ក្នុងការគ្រប់គ្រងវិស័យជលផលចាប់តាំងពីឆ្នាំ២០០២ ដោយបានផ្តល់ឡូត៍នេសាទជូនដល់អ្នកនេសាទក្រីក្រ។ គិតចាប់ពីត្រឹមឆ្នាំ ២០០២ រាជរដ្ឋាភិបាលបានបែងចែកផ្ទៃទឹកទំហំ ៥៩៥,០០០ហិចតា ទៅឱ្យសហគមន៍មូលដ្ឋាន។បញ្ហាប្រឈមគឺជាការគ្រប់គ្រងឡូត៍នេសាទប្រកបដោយចីរភាព។ ក្រៅពីការនេសាទលក្ខណគ្រួសារ ការនេសាទបែបពាណិជ្ជ-កម្មត្រូវបានអនុញ្ញាតចំពោះតែឡូត៍សម្បទាន។ សិទ្ធិក្នុងធ្វើការនេសាទជារបស់រដ្ឋតែមួយគត់ ហើយត្រូវបាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រគល់ជូនទៅឱ្យអ្នកជាប់កិច្ចសន្យាជារៀងរាល់ឆ្នាំ។ ផ្ទៃទឹកប្រមាណ៥០០,០០០ហិចតាត្រូវបោះបង្គោលទុកជាធនធានជលផលបម្រុង ។

រាជរដ្ឋាភិបាលនឹងចាត់វិធានការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍នេសាទ ដោយការលើកស្ទួយគំនិតផ្តួចផ្តើមនៅមូលដ្ឋាន និងក្នុងតំបន់ លើវិស័យជលផលស្របតាមអេកូឡូស៊ី។ សកម្មភាពអាទិភាពបានផ្តោតទៅលើការគាំទ្រសម្រាប់សហគមន៍ ដើម្បីលើកកម្ពស់ការគ្រប់គ្រងជលផល និងការត្រួតពិនិត្យលើការនេសាទខុសច្បាប់។ បន្ទាប់ពីកំណែទម្រង់ឡូត៍នេសាទក្នុងឆ្នាំ២០០០ ចំនួនឡូត៍បានថយចុះពី ប្រហែល ២៣៥ឡូត៍ ដែលគ្របដណ្តប់ផ្ទៃទឹកជិតមួយលានហិចតា មកនៅត្រឹម១៦៤ឡូត៍ ដែលគ្របដណ្តប់លើផ្ទៃដីប្រមាណជា ៤២០,០០០ ហិចតា។ ការថយចុះនៃចំនួនឡូត៍នេសាទនេះ ក៏នាំឱ្យមានការកាត់បន្ថយជម្លោះជាមួយសហគមន៍កសិកម្ម ដែលមានព្រំប្រទល់នៅជាប់ ឬនៅក្បែរឡូត៍នេសាទ។

*តារាង៧.៧. សហគមន៍នេសាទ*

| ខេត្ត | លេខ | ស្រុក | ឃុំ | ភូមិ | សមាជិក | ផ្ទៃដី(Ha) |
|---|---|---|---|---|---|---|
| កំពង់ឆ្នាំង | 31 | 5 | 19 | 62 | 9 557 | 14 889 |
| កំពង់ចាម | 18 | 2 | 5 | 18 | 2 440 | 6 997 |
| ក្រចេះ | 13 | 5 | 11 | 48 | 5 417 | 17 831 |
| ស្ទឹងត្រែង | 15 | 3 | 7 | 22 | 1 887 | 22 150 |
| មណ្ឌលគិរី | 3 | 2 | 3 | 9 | 1 076 | 3 104 |
| កំពត | 5 | 2 | 3 | 11 | 2 137 | 1 993 |
| កោះកុង | 2 | 2 | 2 | 3 | 455 | 3 790 |
| បាត់ដំបង | 13 | 5 | 5 | 13 | 1 138 | 2 664 |
| ស្វាយរៀង | 2 | 2 | 2 | 4 | 308 | 525 |
| កំពង់ស្ពឺ | 7 | 4 | 7 | 20 | 1 631 | 4 366 |
| កំពង់ធំ | 50 | 6 | 15 | 75 | 8 388 | 40 915 |
| សៀមរាប | 36 | 11 | 23 | 71 | 10 664 | 17 146 |
| ពោធិ៍សាត់ | 46 | 5 | 14 | 46 | 5 180 | 5 116 |
| រតនគិរី | 6 | 2 | 5 | 24 | 1 479 | 14 599 |
| ព្រះវិហារ | 3 | 2 | 3 | 10 | 1 197 | 7 274 |
| ប៉ៃលិន | 7 | 2 | 4 | 21 | 1 704 | 2 250 |
| ឧត្តរមានជ័យ | 5 | 3 | 5 | 16 | 1 494 | 9 893 |
| បន្ទាយមានជ័យ | 1 | 1 | 1 | 1 | 320 | 3 019 |

| | | | | | | |
|---|---|---|---|---|---|---|
| តាកែវ | 1 | 1 | 3 | 10 | 780 | 500 |
| សរុប | **264** | **65** | **137** | **484** | **57 252** | **179 020** |

*ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

ដំណាក់កាលទីពីរនៃកំណែទម្រង់វិស័យជលផល កំពុងអនុវត្តនៅតាមបណ្តាខេត្តមួយចំនួន។ ជាង ៥៦%នៃឡូត៍នេសាទត្រូវបានផ្តល់ជូនសហគមន៍មូលដ្ឋាន ដើម្បីលើកកម្ពស់ការបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងបែបសហគមន៍។ ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទត្រូវបានអនុម័តដោយរដ្ឋាភិបាល។ ឡូត៍នេសាទសហគមន៍ចំនួន៣៦០ត្រូវបានបង្កើតឡើងដោយមានការការគាំទ្រពីដៃគូអភិវឌ្ឍន៍។ ច្បាប់ជលផលដែលទទួលស្គាល់ហាគមន៍នេសាទទាំងនេះ ត្រូវបានដាក់ជូនគណៈរដ្ឋមន្ត្រី និងទទួលបានការអនុម័តដោយសភាជាតិ។

តែទោះជាយ៉ាងណា ដូចគ្នាទៅនឹងវិស័យកសិកម្មដែរ វិស័យនេសាទកំពុងប្រឈមមុខជាមួយឧបសគ្គចម្បងៗ ដែលអាចសង្ខេបបានដូចខាងក្រោម៖ (១) លក្ខណៈនៃឡូត៍នេសាទមានទំហំកាន់តែតូច និងរឹតត្បិត ដើរផ្ទុយពីការកើនឡើងនៃសារសំខាន់របស់ការនេសាទនិងភាពខ្សត់ ដែលបានបង្ករឱ្យមានជម្លោះកាន់តែខ្លាំង (២) កង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានក្នុងមជ្ឈមណ្ឌលជលផល (កំពង់ផែ ការក្សាទុក ការដឹកជញ្ជូន ។ល។) (៣) កង្វះខាតការបណ្តុះបណ្តាល និងភាពទន់ខ្សោយរបស់ភាគីពាក់ព័ន្ធក្នុងខ្សែសង្វាក់ផលិតកម្មនិងការចែកចាយ និង(៤) ផលិតភាពនិងតម្លៃបន្ថែមទាប។ ជាមួយនឹងគោលបំណងនៃការជំនះឧបសគ្គទាំងនេះ កម្មវត្ថុខាងក្រោមនៃកំណែទម្រង់វិស័យជលផលគួរត្រូវយកចិត្តទុកដាក់លើ៖ (១) ការគ្រប់គ្រងប្រកបដោយចីរភាព និងការស្តារឡើងវិញនូវធនធានជលផល (២) បំពេញសេចក្តីត្រូវការ តាមរបៀបដែលមានចីរភាពផ្នែកបរិស្ថាន (៣) ការទាញផលជាអតិបរមាពីធនធានទាំងនេះ និង(៤) ការផ្តល់អំណាចដល់អ្នកប្រកបអាជីពក្នុងវិស័យនេះ។

អាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍវិស័យជលផល ដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណមានដូចខាងក្រោម៖

- លើកកម្ពស់ការអភិវឌ្ឍសហគមន៍នេសាទ ដោយផ្តល់ជូនសហគមន៍ក្នុងស្រុកនូវមធ្យោបាយចាំបាច់ ដើម្បីឱ្យពួកគេអ្នកនេសាទអាចចូលរួមយ៉ាងសកម្មដោយផ្ទាល់ និងដោយសមភាពក្នុងការធ្វើផែនការ ប្រតិបត្តិការ និងការគ្រប់គ្រងកម្មវិធីនេសាទ។
- ប្រែក្លាយឡូត៍នេសាទដែលកិច្ចសន្យាសម្បទានហួសកាលកំណត់ ទៅជាធនធានជលផលបម្រុង ដើម្បីបង្កើនធនធានជលផល និងការពារប្រភេទសត្វដែលរងការគំរាមកំហែង។
- ពង្រីកឡូត៍នេសាទសហគមន៍ លើកកម្ពស់វារីវប្បកម្មក្នុងការឆ្លើយតបចំពោះតម្រូវការកាន់តែច្រើន និងកាត់បន្ថយសម្ពាធលើធនធានជលផល។

ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍នេសាទ គួរមានការផ្តល់ការគាំទ្រដល់ប្រជាជនមូលដ្ឋាន។ តែទោះជាយ៉ាងណាដើម្បីឱ្យការផ្តួចផ្តើមនេះអាចទទួលបានជោគជ័យ អ្នកទទួលផលត្រូវមានឆន្ទៈរៀនសូត្រ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បច្ចេកវិទ្យា និងវិធីសាស្ត្រថ្មីៗ និងចូលរួមសកម្មជាមួយនឹងអ្នកផ្តល់ជំនួយ។ ការធ្វើផែនការនិងអភិវឌ្ឍន៍ ដោយមានការចូលរួមពីអ្នកប្រើប្រាស់ធនធាន គឺមានសារសំខាន់ណាស់សម្រាប់ការធានាសំណើនៃការកែទម្រង់ត្រូវបានទទួលយក និងត្រូវបានអនុវត្ត។ ការពង្រឹងសមត្ថភាពរដ្ឋអំណាចមូលដ្ឋាន និងសហគមន៍ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងការកែទម្រង់ក៏មានសារសំខាន់ដែរ។ យុទ្ធសាស្ត្ររាជរដ្ឋាភិបាលសង្កត់ធ្ងន់លើទិដ្ឋភាពទាំងពីរក្នុងការកែទម្រង់នេសាទនេះ។

## ៧.៥. ការចិញ្ចឹមសត្វ

ការចិញ្ចឹមសត្វគឺជាផលិតកម្មចម្បងមួយរបស់កម្ពុជា និងរួមចំណែក ៥%នៃផ.ស.ស.។ចំនួនសត្វ ចិញ្ចឹមបានកើនឡើងជាបណ្តើរៗក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ តារាងខាងក្រោមនេះ សង្ខេបពីលទ្ធភាពមានសត្វចិញ្ចឹមក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០០៨។

*តារាង៧.៧. ធនធានសត្វចិញ្ចឹមនៅកម្ពុជាឆ្នាំ២០០៨*

| ខេត្ត | លេខ | ស្រុក | ឃុំ | ភូមិ | សមាជិក | ផ្ទៃដី(Ha) |
|---|---|---|---|---|---|---|
| កំពង់ឆ្នាំង | 31 | 5 | 19 | 62 | 9 557 | 14 889 |
| កំពង់ចាម | 18 | 2 | 5 | 18 | 2 440 | 6 997 |
| ក្រចេះ | 13 | 5 | 11 | 48 | 5 417 | 17 831 |
| ស្ទឹងត្រែង | 15 | 3 | 7 | 22 | 1 887 | 22 150 |
| មណ្ឌលគិរី | 3 | 2 | 3 | 9 | 1 076 | 3 104 |
| កំពត | 5 | 2 | 3 | 11 | 2 137 | 1 993 |
| កោះកុង | 2 | 2 | 2 | 3 | 455 | 3 790 |
| បាត់ដំបង | 13 | 5 | 5 | 13 | 1 138 | 2 664 |
| ស្វាយរៀង | 2 | 2 | 2 | 4 | 308 | 525 |
| កំពង់ស្ពឺ | 7 | 4 | 7 | 20 | 1 631 | 4 366 |
| កំពង់ធំ | 50 | 6 | 15 | 75 | 8 388 | 40 915 |
| សៀមរាប | 36 | 11 | 23 | 71 | 10 664 | 17 146 |
| ពោធិ៍សាត់ | 46 | 5 | 14 | 46 | 5 180 | 5 116 |
| រតនគិរី | 6 | 2 | 5 | 24 | 1 479 | 14 599 |
| ព្រះវិហារ | 3 | 2 | 3 | 10 | 1 197 | 7 274 |
| ប៉ៃលិន | 7 | 2 | 4 | 21 | 1 704 | 2 250 |
| ឧត្តរមានជ័យ | 5 | 3 | 5 | 16 | 1 494 | 9 893 |
| បន្ទាយមានជ័យ | 1 | 1 | 1 | 1 | 320 | 3 019 |

| | | | | | | |
|---|---|---|---|---|---|---|
| តាកែវ | 1 | 1 | 3 | 10 | 780 | 500 |
| សរុប | **264** | **65** | **137** | **484** | **57 252** | **179 020** |

*ប្រភព ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

នៅក្នុងឆ្នាំ១៩៨៧ ចំនួនសត្វពាហណៈ (រួមទាំងគោ និងក្របីផងដែរ) បានឡើងទៅដល់កម្រិតចុងទសវត្សរ៍ឆ្នាំ១៩៦០។ សត្វជ្រូកបាននឹងកំពុងលូតលាស់ជាបន្តបន្ទាប់ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដែលមានចំនួន ២.២លានក្បាលក្នុងឆ្នាំ២០០៨។ ចំនួនមាន់ត្រូវបានប៉ាន់ស្មានមានចំនួន១៦.៩លានក្បាល។ កសិដ្ឋានជ្រូកនិងការចិញ្ចឹមមាន់ជាទូទៅ មានជាលក្ខណៈជាគ្រួសារ។ ក្រុមហ៊ុនឯកជនមួយចំនួនថ្មីៗនេះ បានចាប់ផ្តើម យុទ្ធនា-ការធ្វើប្រតិបត្តិការទ្រង់ទ្រាយពាណិជ្ជកម្ម រួមមានសាច់គោ សាច់ជ្រូក និងស៊ុត។ តែទោះជាយ៉ាងណាសត្វភាគច្រើនមានគោ ក្របី ជ្រូក និងមាន់ ត្រូវបានចិញ្ចឹមក្នុងទ្រង់ទ្រាយតូច ជាលក្ខណៈគ្រួសារ។

មានមនុស្សមួយចំនួនប្រកបរបរចិញ្ចឹមសត្វ។ ការមានសត្វសម្រាប់លក់ ផ្តល់ជាប្រភពនៃប្រាក់សន្សំដែលក្រុមគ្រួសារកសិករអាចយកមកប្រើប្រាស់នៅពេលចាំបាច់។ វិស័យនេះប្រឈមមុខជាមួយនឹងឧបសគ្គផ្នែករចនាសម្ព័ន្ធមួយចំនួនរួមមាន៖ (១) បច្ចេកទេសអន់ថយ ដូចជាប្រេវ៉ាឡង់នៃជំងឺ និងកង្វះវាលស្មៅ និងទឹកន្លែងផ្គត់ផ្គង់ទឹក (អនុផលកសិកម្មនិងការឱ្យចំណីគោមិនអាចជំនួសការផ្តល់ចំណីលើវាលស្មៅបានទេដោយសារតែការចំណាយខ្ពស់របស់វា) និង(២) កង្វះជំនួយផ្នែកហិរញ្ញវត្ថុ ដោយសារតែការវិនិយោគពីសាធារណៈមានកម្រិតទាបក្នុងអនុវិស័យចិញ្ចឹមសត្វនេះ។

កម្មវត្ថុជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល សម្រាប់ការលើកស្ទួយការរួមចំណែកនៃការចិញ្ចឹមសត្វដល់ GDP និងការកាត់បន្ថយភាពក្រីក្ររួមមាន៖ (១) ការអភិវឌ្ឍការចិញ្ចឹមសត្វជាទិដ្ឋភាពដ៏សំខាន់មួយនៃសន្តិសុខស្បៀងតាមជនបទ (២) ការលើកកម្ពស់លទ្ធភាពទទួលបានដីធ្លីនិងធនធានធម្មជាតិនៃវិស័យនេះ (៣) ការគ្រប់គ្រងដ៏ប្រសើរនៃបរិស្ថានដើម្បីរក្សាដើមទុនដីធ្លីការអភិរក្សមូលដ្ឋានដែលផ្តល់ផ្លែផ្កា និងការលើកកម្ពស់ប្រព័ន្ធផលិតកម្ម (៤) ការធានាបាននូវកំណើនផលិតភាព និង(៥)ការបំបាត់ចោលភាពមិនប្រាកដប្រជាដែលរារាំងដល់ផលិតកម្មសត្វ។ កិច្ចផ្តួចផ្តើមរយៈពេលខ្លីនិងមធ្យមត្រូវបានកំណត់សម្រាប់ការសម្រួលដល់ប្រតិ-បត្តិការដំរលូនក្នុងសង្វាក់ផលិតកម្មចិញ្ចឹមគោយកសាច់ ការបង្កាត់ពូជប្រភេទសត្វ ដែលមានវដ្តជីវិតខ្លី (សត្វគោមាឌតូច និងបក្សីស្រុក) សន្តិសុខចិញ្ចឹមសត្វ និងការថែរក្សានិងការកែច្នៃនូវអនុផលសត្វ (ស្បែក ស្នែង។ល។)។

ការអភិវឌ្ឍសូត្រត្រូវបានស្គាល់ថា មានសក្តានុពលដ៏ល្អសម្រាប់ការបំពេញបន្ថែមប្រាក់ចំណូលតាមជនបទ។ សូត្រកម្ពុជាបានបាត់សាបសូន្យជាសកម្មភាពសេដ្ឋកិច្ចអំឡុងពេលរបបខ្មែរក្រហមប៉ុន្តែកំពុងឈានត្រឡប់មកវិញដ៏ខ្លាំង។ ប្រអប់ខាងក្រោមផ្តល់នូវបណ្តុំព័ត៌មានមួយនៃវឌ្ឍនភាពដែលកំពុងត្រូវបានធ្វើក្នុងការបង្កើតឡើងវិញនូវឧស្សាហកម្មសូត្រនៅកម្ពុជា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៨
# ឧបសគ្គចំពោះការលើកកម្ពស់កម្រិតជីវភាពរបស់កសិករ

## ៨.១. ភាពគ្មានដីធ្លី

ក្នុងឆ្នាំ២០០៤ គ្រួសារនៅជនបទពាក់កណ្តាល ឬជាងមួយលានគ្រួសារមានកម្មសិទ្ធិផ្ទៃដីដាំដុះតិចជាង០.៥ហិចតា។ ពីព្រោះតែទំហំដីគ្មានលក្ខណសេដ្ឋកិច្ច គ្រួសារកសិករខ្លះបានលក់ដីរបស់ខ្លួន ហើយទៅរកការងារនៅក្នុងវិស័យក្រៅពីកសិកម្ម។ ជាទូទៅ គ្រួសារមួយដែលមានដីរវាងពី០.៥ ទៅ០.៧៥ហិតតានៃដីមានជីជាតិមធ្យម និងអាចរកប្រាក់ចំណូលបានប្រចាំឆ្នាំបានចំនួនពី៣០០ទៅ៤០០ដុល្លារ ក្នុងទិន្នផល២តោនក្នុងមួយហិចតា និងថ្លៃ២០០ដុល្លារក្នុងមួយតោន។

ផ្ទៃដីដាំដុះមានប្រហែលជា ២០% នៃផ្ទៃដីសរុបរបស់ប្រទេស។ ទំហំឡូត៍ដីជាមធ្យមតាមការអង្កេតឃើញធ្លាក់ចុះនៅពេលដែលសមាជិកគ្រួសារកើនឡើង នោះដោយសារតែកំណើនផ្នែកប្រជាសាស្រ្ត។ ឡូត៍ដីមានទំហំតិចជាង០.៥ហិចតាមាន ៩០% និងដីស្រែទំហំតិចជាង១.០ហិតតាមាន៧៥%។

យោងទៅតាមការសិក្សាមួយពីអង្គការ Oxfam (២០០៦) បានបង្ហាញថាគ្រួសារនៅជនបទចំនួន២៥%គ្មានដី តែបើតាមការអង្កេតសង្គមសេដ្ឋកិច្ចរបស់កម្ពុជា(SESC ខែមេសាឆ្នាំ២០០៣)ដែលអាចយកជាការបាន បង្ហាញថា២៥% នៃប្រជាជនទាំងក្នុងវិស័យកសិកម្ម និងក្រៅកសិកម្មគ្មានដីធ្លី។ ការអង្កេតមួយទៅលើគ្រួសារកសិករ បានបង្ហាញថា ១២% គ្មានដីធ្លី (Biddulph 2000, Biddulph 2004)។

ច្បាស់ណាស់ថា ការប្រមូលផ្តុំនៃកម្មសិទ្ធិដីធ្លីបានកើនឡើង និងមានល្បឿនខ្ពស់ខ្លាំងនៅរវាងឆ្នាំ១៩៩៩ និងឆ្នាំ២០០៤។ SESC ខែមេសាឆ្នាំ២០០៣បានរកឃើញថា ក្នុងឆ្នាំ២០០៤ក្រុមគ្រួសារដែលមានដីតិចជាង០.៥ហិចតាមានចំនួន៥.៤% នៃផ្ទៃដីដាំដុះប៉ុណ្ណោះ រីឯអ្នកដែលមានដីច្រើនជាង៣ហិចតាមាន៤៨% នៃផ្ទៃដី។ គេប៉ាន់ប្រមាណថា១០% នៃម្ចាស់ដីកាប់កាន់ផ្ទៃដីប្រមាណ ៩០% នៃផ្ទៃដីសរុប។

ការប្រមូលផ្តុំកម្មសិទ្ធីដីកសិកម្មអាចអនុញ្ញាតឱ្យធ្វើទំនើបកម្មនីយកម្មវិស័យកសិកម្មអាចធ្វើទៅបានតាមរយៈការទាញប្រយោជន៍ពីវិមាត្រសេដ្ឋកិច្ច និងការប្រើប្រាស់បច្ចេកវិទ្យាទំនើប។ តែទោះជាយ៉ាងណាក្តី វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ក្នុងនោះវិស័យទេសចរណ៍ ការនាំចេញវាយនភណ្ឌ និងសំណង់មានកំណើនខ្ពស់ក៏ដោយ ក៏មិនទាន់អាចស្រូបយកកម្លាំងពលកម្មដែលច្រើនសំបូរនៅជនបទនៅឡើយទេ យ៉ាងហោចណាស់ក្នុងរយៈពេលមធ្យមដែរ។ ក្នុងន័យនេះ ការប្រមូលផ្តុំដីធ្លីកាន់តែខ្លាំង អាចបណ្តាលឱ្យភាពក្រីក្រតាមជនបទមិនងាយធ្លាក់ចុះ និងនាំឱ្យមានការរំដើបរំជួលខ្លាំងឡើងនៅទីប្រជុំជន។

ការសិក្សាមួយរបស់ Oxfam (២០០៤) អំពីជម្លោះដីធ្លីចំនួន៧៩៧ករណី នៅក្នុង ២៣ខេត្តក្រុងនៅក្នុងប្រទេសកម្ពុជាបានបង្ហាញថា ជម្លោះដីធ្លីចំនួន ៣៦% ពាក់ព័ន្ធនឹងដីចម្ការ ចំនួន ៣២%ពាក់ព័ន្ធនឹងធ្វើស្រែ និង ចំនួន២៦% ពាក់ព័ន្ធនឹងការសាងសង់។ ការសិក្សានេះបានបង្ហាញថា៧១% នៃករណីទាំងអស់ពាក់ព័ន្ធជាមួយប្រជាជនដែលគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី ២៤%មានកម្មសិទ្ធិជាបង្កាន់ដៃចុះបញ្ជីដី និង៥% ប៉ុណ្ណោះដែលមានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៨.២. ការផ្គត់ផ្គង់ធាតុចូល

### ៨.២.១. ទឹកសម្រាប់វិស័យកសិកម្ម

ធាតុចូលដ៏សំខាន់សម្រាប់បង្កើនផលិតភាពវិស័យកសិកម្មគឺទឹក។ គ្រាប់ពូជគុណភាពល្អនិងជីគីមី ការគ្រប់គ្រងដីស្រែប្រកបដោយជំនាញ ការប្រើប្រាស់ឧបករណ៍ទាន់សម័យ និងជីជាតិដីល្អ មិនអាចសម្រេចបាននូវទិន្នផលស្រូវខ្ពស់ទេ ប្រសិនបើមិនអាចគ្រប់គ្រងទឹកបាន។

ទិន្នផលស្រូវបានប្រែប្រួលគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ និងមានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងលក្ខខណ្ឌអាកាសធាតុ។ ក្នុងឆ្នាំ២០០៨ ទិន្នផលស្រូវមធ្យមក្នុងប្រទេសកម្ពុជាបានឈានដល់កម្រិតជាប្រវត្តិសាស្ត្រមួយ គឺសម្រេចបាន ២.៧តោនក្នុងមួយហិចតា មូលហេតុចម្បងដោយសារតែរបបទឹកភ្លៀងទទួលបានល្អ និងប្រព័ន្ធស្រោចស្រពដែលបានវិនិយោគដោយរាជរដ្ឋាភិបាល។

យោងតាមក្រសួងធនធានទឹក និងឧតុនិយម ក្នុងឆ្នាំ២០០៦ ផ្ទៃដីស្រែដែលមានប្រព័ន្ធស្រោចស្រពមាន ២៩% ប្រសិនបើប្រៀបធៀបទៅនឹងប្រាំឆ្នាំមុខមានប្រមាណជុំវិញ ២០% ។ តែទោះជាយ៉ាងណាក្តី តំបន់ដាំដុះស្រូវប្រាំងដែលមានប្រព័ន្ធស្រោចស្រពមានតែ១១% ប៉ុណ្ណោះ ឬស្មើនឹង៣០០,០០០ហិចតា។

ហេតុផលដែលការវិនិយោគលើធារាសាស្ត្រមិនសូវមាន និងប្រព័ន្ធស្រោចស្រពប្រើមិនអស់សមត្ថភាព គឺជាផលវិនិយោគផ្នែកហិរញ្ញវត្ថុពីគម្រោងធារាសាស្ត្រមានអត្រាទាប។ តែទោះជាយ៉ាងនេះក្តី គម្រោងធារាសាស្ត្រពិតជាមានផលវិនិយោគផ្នែកសេដ្ឋកិច្ច និងសង្គមខ្ពស់ ប្រសិនបើអត្ថប្រយោជន៍សង្គមសម្រាប់សហគមន៍ សំខាន់បំផុតការបង្កើនលទ្ធភាពរកប្រាក់ចំណូល ត្រូវបានគិតបញ្ចូល។ រាជរដ្ឋាភិបាលបានកំណត់យកការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ជាយុទ្ធសាស្ត្រមួយ ដើម្បីដោះស្រាយដំណើរថយក្រោយនៃការអភិវឌ្ឍន៍ជនបទ។ ការវិនិយោគទុនរបស់រាជរដ្ឋាភិបាលក្នុងគម្រោងប្រព័ន្ធស្រោចស្រពបានកើនឡើងជាមធ្យម ២% ប្រចាំឆ្នាំក្នុងអំឡុងឆ្នាំ២០០៣-២០០៦ និងឈានដល់១០លានដុល្លារក្នុងឆ្នាំ ២០០៦។

### ៨.២.២. គ្រាប់ពូជ ជី និងថ្នាំសំលាប់សត្វចង្រៃ

ការប្រើប្រាស់គ្រាប់ពូជដែលផ្តល់ទិន្នផលខ្ពស់ ការប្រើប្រាស់ជីនិងថ្នាំសំលាប់សត្វចង្រៃបានត្រឹមត្រូវតាមក្បួនខ្នាត អាចបង្កើនទិន្នផលនិងប្រាក់ចំណេញសម្រាប់កសិករ។ យោងតាមគម្រោងលើកកម្ពស់គុណភាពកសិកម្ម (AQIP) មានកសិករតែ ៨០,០០០នាក់ឬតិចជាង៥% ប្រើប្រាស់គ្រាប់ពូជដែលផ្តល់ទិន្នផលខ្ពស់ ពីព្រោះពូជគុណភាពខ្ពស់ថ្លៃលើសបីដងធៀបនឹងគ្រាប់ពូជធម្មតា។

កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេស ដែលមានបរិយាកាសអំណោយផលទាបជាងគេបង្អស់មួយក្នុងចំណោមប្រទេសអាស៊ី ផ្នែកការដាំដុះស្រូវ ដោយសារតែដីមិនសូវមានជីជាតិ។ ក្នុងទស្សនៈរបស់ក្សេត្រសាស្ត្រវិទូ ដីនៅកម្ពុជាជាទូទៅមិនសំបូរជាតិផូស្វាត និងប៉ូតាស្យូមទេ(Young, Raab et al, ២០០០)។ ដូចនេះ ជីបំប៉នត្រូវតែប្រើប្រាស់ទើបអាចបង្កើនទិន្នផលបាន។ យោងទៅតាមមូលដ្ឋានទិន្នន័យរបស់ឃុំសង្កាត់ គ្រួសារប្រើប្រាស់ជីមានតែ ៥០% ប៉ុណ្ណោះ និងមិនបានប្រើទៅតាមបច្ចេកទេសទេ។

កសិករកម្ពុជាជាធម្មតា មិនប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃទេ។ ប៉ុន្តែក្រុមគ្រួសារដែលបានប្រើប្រាស់ថ្នាំនេះ ជាទូទៅប្រើសម្រាប់ការដាំបន្លែនិងស្រូវ។ ក្នុងឆ្នាំ២០០៥ កសិករ ២៧% ត្រូវបានរាយការណ៍ថាបានប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៨.២.៣. ថាមពល និងអគ្គិសនី

ក្រុមគ្រួសារត្រឹមតែ១០% ប៉ុណ្ណោះមានលទ្ធភាពទទួលបានអគ្គិសនីប្រើប្រាស់។ ក្នុងឆ្នាំ២០០៥ ថ្លៃអគ្គិសនីបានកើនពី០.០៩ដុល្លារទៅ០.២៥ដុល្លារក្នុងមួយគីឡូវ៉ាត់ម៉ោង នៅតំបន់ទីក្រុង និងពី០.៤ទៅ០.៨ ដុល្លារនៅសហគមន៍ជនបទ។

ប្រេងឥន្ធនៈ និងអគ្គិសនីមានសារៈសំខាន់ណាស់សម្រាប់ការគ្រប់គ្រងទឹក។ ការកាត់បន្ថយថ្លៃថាមពល នឹងជួយឱ្យកសិករបង្កើនផលិតកម្មវិស័យកសិកម្ម។ ថាមពលក្នុងប្រទេសកម្ពុជាមានថ្លៃខ្ពស់ជាងគេបំផុតនៅក្នុងតំបន់ លើកលែងតែប្រទេសសិង្ហបុរីមួយចេញ។

### ៨.២.៤. ឧបករណ៍សម្រាប់ការផ្សំស្រែ ថ្លៃ និងទីផ្សារ

កង្វះខាតនូវឃ្លាំងស្តុក ស្ថានភាពផ្លូវទ្រុឌទ្រោម និងសិទ្ធិផ្តាច់មុខនៃរោងម៉ាស៊ីនកិនស្រូវគឺជាបុព្វហេតុចម្បង ដែលត្រូវចំណាយខ្ពស់ និងធ្វើឱ្យថ្លៃស្រូវកសិករទទួលបានទាប។ ក្នុងទីផ្សារជាក់ស្តែង កសិករកម្ពុជាទទួលបានតែ៧០សេនដុល្លារតែប៉ុណ្ណោះ ពីតម្លៃលក់រាយ ប្រសិនបើប្រៀបធៀបនឹង ៨០ ទៅ៩០សេន ដែលកសិករវៀតណាម និងថៃទទួលបាន(Arulpagason, J. et al, ២០០៣។ សេរីភាវូបនីយកម្មនៃពាណិជ្ជកម្មស្រូវ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធអាចបង្កើនការប្រកួតប្រជែង និងធ្វើឱ្យថ្លៃស្រូវឡើងខ្ពស់។

ការប្រមូលផល ការហាលសម្ងួត និងការកែច្នៃស្រូវមានឥទ្ធិពលលើថ្លៃអង្ករ។ ប្រសិនបើការសម្ងួតធ្វើមិនបានសព្វ ការកិនអង្ករនឹងធ្វើឱ្យគ្រាប់ស្រូវបាក់បែក និងខូច។ ម៉ាស៊ីនកិនស្រូវដែលមានគុណភាពទាបធ្វើឱ្យគុណភាពអង្ករទាប និងលក់មិនបានថ្លៃ។ JICA (២០០១) បានប៉ាន់ប្រមាណពីការខាតបង់ ដោយសារការកែច្នៃក្រោយការប្រមូលផលក្នុងកម្រិត៧%នៃផលិតកម្មសរុប។ ការកែច្នៃអង្ករនៅមានលក្ខណៈបែបអន់ថយនៅឡើយ ទោះបីមានកិច្ចប្រឹងប្រែងដើម្បីធ្វើយន្តកម្មក៏ដោយ។ ការខាតបង់ក្រោយការប្រមូលផលអាចធ្លាក់ចុះបាន លុះត្រាតែប្រើប្រាស់ម៉ាស៊ីនកិនស្រូវដែលមានបច្ចេកវិទ្យាខ្ពស់។

#### ៨.២.៤.១. ទីផ្សារអង្ករ

មានទំនើបកម្មតិចតួចណាស់ក្នុងប្រព័ន្ធទីផ្សារស្រូវ/អង្ករ។ កសិករភាគច្រើននៅតែលក់អង្កររបស់ខ្លួនទៅឱ្យឈ្មួញនៅតាមភូមិ ឈ្មួញកណ្តាល និងរោងម៉ាស៊ីនកិនស្រូវ តាមថ្លៃទីផ្សារ។ រោងម៉ាស៊ីនកិនស្រូវ និងឈ្មួញកណ្តាល ទិញស្រូវពីកសិករផង និងពីឈ្មួញក្នុងភូមិផង។ បន្ទាប់ពីកិនជាអង្កររួម គេអង្ករទៅឱ្យអ្នកលក់ដុំ អ្នកលក់រាយ និងក្រុមហ៊ុនឯកជន សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងសម្រាប់ការនាំចេញ។

មានឈ្មួញកណ្តាលជាច្រើនក្នុងខ្សែចង្វាក់តម្លៃទីផ្សារស្រូវ/អង្ករ ដោយសារតែមានទីផ្សារមានលក្ខណៈដាច់ៗពីគ្នា ព័ត៌មានមិនស៊ីមេទ្រី(Asymetric Information) និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមិនល្អ។ ទីផ្សារប្រពៃណីខ្លះ នៅដាច់តែឯង និងឯករាជ្យ ដោយគ្មានអន្តរសកម្មជាមួយនឹងទីផ្សារដទៃផ្សេងទៀត។ ថ្លៃដែលកំណត់ដោយតម្រូវការ និងការផ្គត់ផ្គង់នៅទីក្រុង មិនបានបញ្ជូនទៅដល់ជនបទ ។ ក្នុងន័យនេះ ឈ្មួញកណ្តាលបណ្តាក់គ្នាបង្អាប់ថ្លៃចំពោះកសិករ។ ដោយសារអវត្តមាននៃព័ត៌មានថ្លៃ ឬយន្តការដែលគួរឱ្យទុកចិត្តក្នុងការធានាថ្លៃ កសិករមានជម្រើសតិចតួចអំពីមុខដំណាំដែលត្រូវដាំដុះ ទីផ្សារដែលត្រូវលក់ នឹងថ្លៃដែលត្រូវលក់។

ក្រុមហ៊ុនអង្គរកសិកម្មរុងរឿង (AKR) បានលើកកម្ពស់យន្តការទីផ្សារ ដោយធ្វើការទាក់ទងផ្ទាល់ជាមួយនឹងកសិករ នឹងសន្យាថ្លៃទិញខ្ពស់មួយ។ ប្រព័ន្ធបែបនេះលុបបំបាត់ឈ្មួញកណ្តាលចេញ។ កសិករទទួលបានព័ត៌មានជាមុនអំពីថ្លៃលក់ និងដឹងពីថ្លៃដឹកជញ្ជូន។ កសិករចុះកិច្ចសន្យាអាចលក់ស្រូវរបស់ខ្លួនបានថ្លៃជាង ប្រសិនបើប្រៀបធៀបជាមួយទីផ្សារតាមប្រពៃណី ដែលត្រួតត្រាដោយឈ្មួញកណ្តាល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ៨.២.៤.២. ប្រព័ន្ធទីផ្សារសម្រាប់គ្រាប់ស្វាយចន្ទី ដំឡូង ពោត សណ្ដែកសៀង និងកៅស៊ូ

ជាទូទៅ រាជរដ្ឋាភិបាលចៀសវាងមិនធ្វើអន្តរាគមន៍ដោយផ្ទាល់នៅក្នុងទីផ្សារ ដោយគោរពតាមអភិក្រមទីផ្សារសេរី។ ទីផ្សារសម្រាប់ផលិតផលកសិកម្មក្រៅពីស្រូវ ការតភ្ជាប់កសិករជាមួយនឹងអ្នកនាំចេញ និងអ្នកលក់រាយ ធ្វើឡើងតាមរយៈឈ្មួញក្នុងភូមិ/ឈ្មួញកណ្ដាល/អ្នកលក់ដុំ។ ការនាំចេញស្រូបយកប្រមាណ ៩៥% នៃផលិតផលកសិកម្ម (លើកលែងតែស្រូវ) ដូចជាគ្រាប់ស្វាយចន្ទី ដំឡូង ពោត និងសណ្ដែកសៀង។ ដោយសារតែឈ្មួញកណ្ដាលថ្លៃដែលកសិករទទួលបានមិនច្រើនជាង ៧០-៧៥%នៃថ្លៃនាំចេញនោះទេ។ អត្រានេះស្រដៀងគ្នាទៅនឹងថ្លៃស្រូវដែរ។

ភាពខុសគ្នាខ្លាំងរវាងថ្លៃទីផ្សារ និងថ្លៃកសិករ គឺមិនត្រឹមតែដោយសារឈ្មួញកណ្ដាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារតែថ្លៃដឹកជញ្ជូនខ្ពស់ និងការចំណាយក្រៅផ្លូវការនៅតាមច្រកព្រំដែន ប្រៀបដូចជាពន្ធនាំចេញលាក់មុខ។ ដើម្បីបង្កើនថ្លៃកសិករឱ្យដល់កម្រិតកៀកនឹងថ្លៃទីផ្សារ នោះថ្លៃដឹកជញ្ជូនត្រូវតែកាត់បន្ថយចំណាយមិនផ្លូវការនានានៅតាមព្រំដែនត្រូវតែលុបបំបាត់ និងជំរុញការប្រកួតប្រជែងក្នុងចំណោយឈ្មួញកណ្ដាល និងអ្នកទិញកសិផល។

### ៨.២.៤.៣. អ្នកដាំដុះ និងព័ត៌មានស្ដីពីថ្លៃទំនិញ

នៅក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ននៃទីផ្សារស្រូវ បន្ទាប់ពីការប្រមូលផលរួច កសិករលក់ផលលើសរបស់ខ្លួនភ្លាមៗទៅឈ្មួញកណ្ដាល ដើម្បីយកប្រាក់។ ឈ្មួញកណ្ដាលទទួលបានប្រាក់ចំណេញខ្ពស់ ពីការលក់ស្រូវបន្តទៀត នៅពេលដែលថ្លៃឡើងខ្ពស់។

JICA បានធ្វើការពិសោធន៍មួយដោយបានបង្កើតឡើងនូវទីផ្សារស្រូវបើកទូលាយ (OPM) ក្នុងខេត្តព្រៃវែង ដើម្បីបង្កើនថ្លៃលក់របស់កសិករ។ OPM ផ្ដល់នូវទីកន្លែងឃ្លាំងស្ដុកដល់អ្នកទិញ និងអ្នកលក់ សម្រាប់រក្សាស្រូវទុក និងជាកន្លែងដេញថ្លៃ។ សេវាកម្មឃ្លាំងស្ដុកស្រូវរួមមានការថ្លឹង ការដឹកជញ្ជូន ការជ្រើសគុណភាព ការសម្ងួត ការស្ដុកទុកក្រោយពេលប្រមូលផល ការចែកចាយជីដែលមានគុណភាពខ្ពស់ និងឥណទានបញ្ចាំស្រូវ។ ការប្រកួតប្រជែងក្នុងចំណោមពាណិជ្ជករស្រូវនិងឈ្មួញកណ្ដាល មានសន្ទុះខ្លាំងគ្រប់គ្រាន់ដើម្បីបង្កើនថ្លៃកសិករ ដែលបានចូលរួមក្នុងគម្រោង OPM នេះ។

## ៨.២.៥. សេដ្ឋកិច្ចតាមជនបទមិនមែនកសិកម្ម

សមត្ថភាពនៃវិស័យកសិកម្មដើម្បីស្រូបយកប្រជាជន ដែលសកម្មផ្នែកសេដ្ឋកិច្ចដែលកំពុងកើនឡើងនេះ នៅមានកម្រិតនៅឡើយ។ ចំនួនពលកម្មនៅក្នុងវិស័យកសិកម្មត្រូវបានប៉ាន់ស្មានកើនឡើងចំនួន ២៥០,០០០នាក់បន្ថែមជារៀងរាល់ឆ្នាំ។ ស្ថានភាពការងារនៅជនបទកាន់តែធ្ងន់ធ្ងរឡើង ដោយសារកង្វះធនធានធម្មជាតិ និងដីធ្លី។

សកម្មភាពបង្កើតប្រាក់ចំណូលក្រៅពីកសិកម្មបែបប្រពៃណីមានដូចជា ការប្រមូលអនុផលព្រៃឈើ ការនេសាទ ការកែច្នៃត្រី ការផលិតសូត្រ តម្បាញ ស្មូន ផលិតផលថ្មកែវ និងការធ្វើតជ្ជ។ជាទូទៅសកម្មភាពទាំងនេះគឺមិនសូវមានប្រសិទ្ធភាព និងគ្មានឧត្តមភាពប្រៀបធៀប ដោយសារតែបច្ចេកទេសហួសសម័យ កង្វះការបណ្ដុះបណ្ដាល គ្មានលទ្ធភាពទទួលបានបច្ចេកទេសទំនើប កង្វះធនធានហិរញ្ញវត្ថុ កន្លែងលក់ចេញ និងការផលិតជាទ្រង់ទ្រាយតូច។

## ៨.៣. ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម

### ៨.៣.១. ការអប់រំ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ

នៅក្នុងឆ្នាំ២០០៥ អត្រាចុះឈ្មោះចូលរៀនសុទ្ធថ្នាក់បឋមសិក្សានៅក្នុងប្រទេសកម្ពុជា គឺ៩១.៣% (អត្រាចុះឈ្មោះចូលរៀនដុលគឺ១២៤%) ប៉ុន្តែមានសិស្សចុះឈ្មោះតែ ៤៣% ប៉ុណ្ណោះដែលបានបញ្ចប់ថ្នាក់ទី៦។ អត្រាចុះឈ្មោះចូលរៀនសុទ្ធថ្នាក់អនុវិទ្យាល័យគឺ ៣១.៣% (អត្រាចុះឈ្មោះចូលរៀនដុលគឺ៥០%) ហើយសម្រាប់ថ្នាក់វិទ្យាល័យ គឺ១១.៣% ក្នុងឆ្នាំ២០០៥។ អាស្រ័យហេតុនេះ មានសិស្សចុះឈ្មោះតែ១៩.៣% ប៉ុណ្ណោះបានបញ្ចប់ការអប់រំនៅអនុវិទ្យាល័យ។ អត្រានៃការបោះបង់ចោលការសិក្សាមានទំហំធំ ដែលមានចាប់ពី ១១.៨% សម្រាប់ថ្នាក់ទី១ ដល់ ២៥.៨% សម្រាប់ថ្នាក់ទី៩។ អនុបាតសិស្ស-គ្រូដែលមានចំនួន៥៣ទល់នឹង១ត្រូវបានគេចាត់ទុកថាជាចំនួនខ្ពស់ នៅក្នុងសហគមន៍តាមទីជនបទ ដើម្បីអោយការបង្រៀនមានប្រសិទ្ធភាព។ អ្វីដែលសំខាន់ជាងនេះ គឺតម្លៃឱកាសនៃការបញ្ជូនកូនទៅសាលាមានកម្រិតខ្ពស់ ប្រសិនបើឪពុកម្ដាយជាអ្នកក្រីក្រ និងមិនចេះអក្សរ។

មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅក្នុងវិស័យរៀបរយ ជាពិសេសនៅក្នុងទីជនបទ មិនទាន់មានគ្រប់គ្រាន់នៅឡើយទេ។ ឱកាសការងារក្រៅវិស័យកសិកម្មមានតិចតួចណាស់។ អ្នកធ្វើការងារដែលគ្មានលក្ខណសម្បត្តិចូលក្នុងទីផ្សារពលកម្ម ពឹងផ្អែកលើវិស័យកសិកម្មបែបប្រពៃណី និងធនធានធម្មជាតិដើម្បីការចិញ្ចឹមជីវិត។ ខណៈដែលការបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅក្រៅប្រព័ន្ធមានការរីករាលដាល ឥទ្ធិពលទៅលើទីផ្សារពលកម្មពិបាកប៉ាន់ស្មានណាស់។ ដើម្បីបន្ថយ ឬលុបបំបាត់ការពឹងផ្អែកខ្លាំងពេករបស់សហគមន៍ជនបទទៅលើវិស័យកសិកម្មនិងធនធានធម្មជាតិក្នុងការចិញ្ចឹមជីវិត ចាំបាច់ណាស់ត្រូវស្វែងរកមធ្យោបាយផ្ដល់នូវការបណ្ដុះបណ្ដាល និងការងារនៅក្នុងវិស័យមិនមែនកសិកម្មនៅជនបទ ជាពិសេសយុវជន ដែលទើបតែចូលទៅក្នុងទីផ្សារពលកម្ម។

### ៨.៣.២. សេវាអនាម័យ និងសុខភាព

អត្រាមានគិកបានធ្លាក់ចុះ ពី៤នាក់នៅឆ្នាំ២០០០ មកត្រឹម៣.៤នាក់ក្នុងឆ្នាំ២០០៨។ អត្រាស្លាប់របស់ទារកក៏បានធ្លាក់ចុះដែរ ពី៩៥នាក់លើកុមារមានជីវិត១០០០នាក់ មកនៅត្រឹម៦៦នាក់ក្នុងឆ្នាំ២០០៥ ខណៈដែលអត្រាមរណៈកុមារក្រោមអាយុ៥ឆ្នាំបានធ្លាក់ចុះ ពី១២៤ ដល់៨៣នាក់ លើកុមាររស់រានមានជីវិត១០០០នាក់។ អាត្រាកុមារទទួលថ្នាំបង្កាបានកើនឡើងយ៉ាងខ្លាំង ហើយមានតែកុមារ៧.២% ប៉ុណ្ណោះទេដែលមិនបានទទួលថ្នាំបង្កាទាល់តែសោះ។ ប្រហែលជា១៥% នៃកំណើតកុមារកម្ពុជាមិនគ្រប់ទម្ងន់។ ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារមានភាពប្រសើរឡើង ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។ បច្ចុប្បន្ននេះ កុមារ ៣៧% ក្រិន និង ៧% ឧស្សាហ៍មានជំងឺ ប្រៀបធៀបទៅនឹងអត្រា៤៥% និង១៥% ក្នុងឆ្នាំ២០០០។

ការទទួលបានសេវាថែទាំសុខភាព គឺជាកង្វល់ដ៏ចម្បងមួយ។ ដោយសារតែបុគ្គលិកសុខាភិបាល និងគ្រឹះស្ថានសុខាភាពភាគច្រើន ជាពិសេសគ្រឹះស្ថានសាធារណៈគឺមានតែនៅក្នុងតំបន់ទីក្រុង ការផ្ដល់សេវាថែទាំសុខភាពនៅក្នុងសហគមន៍ជនបទអាស្រ័យជាចម្បង ទៅលើផ្នែកឯកជននិងប្រព័ន្ធព្យាបាលបែបបុរាណ។ ប្រជាជនជនបទ ៣០% ប្រើប្រាស់សេវាសុខភាពឯកជន និង ២៤% ផ្សេងទៀតប្រើប្រាស់ថ្នាំបុរាណ ហើយអត្រានៅសល់ប្រើប្រាស់សេវាសុខភាពសាធារណៈ។

### ៨.៣.៣. ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ

ការកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅតំបន់ជនបទចាប់តាំងពីឆ្នាំ២០០២មក គឺជាសមិទ្ធផលដ៏ធំធេងរបស់រាជរដ្ឋាភិបាលកម្ពុជា។ កម្មវិធីសិលាបានចូលរួមចំណែកយ៉ាងច្រើនក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់នោះ។ ទោះបីជាមានការរីកចម្រើនក៏ដោយ ក៏ថ្លៃដឹកជញ្ជូនក្នុងប្រទេសកម្ពុជានៅតែខ្ពស់បំផុតធៀបនឹងតំបន់ហាក់ដូចជាងពន្ធនាំចេញ។ ការកាត់បន្ថយថ្លៃដឹកជញ្ជូន តាមរយៈទីផ្សារ ដែលតភ្ជាប់គ្នាបានល្អ និងការថែរក្សាផ្លូវថ្នល់ជនបទឱ្យបានប្រសើរ ក៏អាចកាត់បន្ថយចំណាយដឹកជញ្ជូនបានដែរ។

បណ្តាញផ្លូវថ្នល់នៅកម្ពុជា ៦៣% នៃជាផ្លូវគ្រួសក្រហម និងផ្លូវដី។ ថ្លៃខ្ពស់នៃការដឹកជញ្ជូនតាមផ្លូវថ្នល់ និងកំពង់ផែ ធ្វើឱ្យកសិករកម្ពុជាមិនអាចប្រកួតប្រជែងឈ្នះប្រទេសជិតខាងដូចជា ប្រទេសថៃ និងប្រទេសវៀតណាម ដែលនៅប្រទេសនេះហេដ្ឋារចនាសម្ព័ន្ធមានគុណភាពល្អជាង។ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងនៃកសិផលសម្រាប់នាំចេញនៅកម្ពុជា ចាំបាច់ត្រូវកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។

## ៨.៤. ការពិនិត្យមើលឡើងវិញនូវគោលនយោបាយ និងបទពិសោធន៍នៃការអភិវឌ្ឍជនបទ

ការកែលម្អជីវភាពរស់នៅរបស់ប្រជាជនជនបទមានន័យថា៖

**ទីមួយ**-ផលិតភាពនៃប្រព័ន្ធផលិតកម្មលក្ខណៈគ្រួសារ និងកសិករតូចតាច ត្រូវតែធ្វើការកែលម្អ។ ប្រការនេះនឹងទាមទារឱ្យដាក់ចេញនូវវិធានការដូចជា៖ ការកែលម្អការគ្រប់គ្រងដីធ្លីយន្តការទីផ្សារ និងថ្លៃកសិករទទួលបាន និងការធានាឱ្យបាននូវការផ្គត់ផ្គង់ធាតុចូលកសិកម្មក្នុងតម្លៃសមរម្យ។

**ទីពីរ**-បង្កើតឱកាសឱ្យបានច្រើននៅក្នុងសេដ្ឋកិច្ចទីជនបទ ដើម្បីអាចរកប្រាក់ចំណូលបានក្រៅពីវិស័យកសិកម្ម និងដើម្បីស្រូបយកពលកម្មបន្ថែម ចូលទៅក្នុងទីផ្សារការងារ។ គោលដៅនេះគឺដើម្បីដកសម្ពាធចេញពីវិស័យកសិកម្ម ដោយរួមមានការបណ្តុះបណ្តាលអំពីសកម្មភាពក្រៅកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។ ការកែច្នៃកសិផលផ្តល់នូវឱកាសល្អសម្រាប់ការងារ និងបង្កើនប្រាក់ចំណូល ពីព្រោះជាធម្មតាការកែច្នៃនេះត្រូវការវិនិយោគតិចតួចទៅលើបរិក្ខាបច្ចេកវិទ្យា និងការបណ្តុះបណ្តាល។

### ៨.៤.១. អន្តរាគមន៍លើវិស័យកសិកម្ម

#### *៨.៤.១.១. ទីផ្សារសម្រាប់ផលិតផលសរីរាង្គ និងផលិតផលបែបប្រពៃណី*

ទីផ្សារពិភពលោកកំពុងផ្តល់នូវឱកាសថ្មីៗ សម្រាប់ការលក់ដូរផលិតផលសរីរាង្គ។ មជ្ឈមណ្ឌលកម្ពុជាដើម្បីការសិក្សានិងអភិវឌ្ឍន៍កសិកម្ម (CEDAC) និងក្រុមហ៊ុនអង្គរកសិកម្មរុងរឿង (Angkor Kasekam Rungroueung Company = AKR) បានធ្វើការខិតខំរបស់ខ្លួនទ្វេឡើងជាថ្មីម្តងទៀត ដើម្បីលើកស្ទួយផលិតកម្មអង្ករសរីរាង្គ និងទទួលបានជោគជ័យ។ AKR នាំចេញអង្ករសរីរាង្គជាង៣០ម៉ឺនតោន រៀងរាល់ឆ្នាំទៅកាន់ទ្វីបអាស៊ីនិងអឺរ៉ុប។ ក្រុមហ៊ុនស្រែខ្មែរ (SRE Khmer) ដែលជាសហគ្រាសនាំចេញមួយផ្សេងទៀតបានផ្តល់នូវជំនួយបច្ចេកទេស ដល់អ្នកដាំបន្លែសរីរាង្គនៅក្នុងខេត្តសៀមរាប ប៉ុន្តែទទួលបានជោគជ័យតិចតួច។ ក្រុមហ៊ុនក្នុងស្រុកមួយផ្សេងទៀតក៏មានលទ្ធភាពផលិតនូវដំណាប់ធ្វើពីផ្លែស្វាយម្នាស់ល្ហុងនិងខ្ទី សម្រាប់ការនាំចេញទៅកាន់ប្រទេសអូស្ត្រាលី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

#### ៨.៤.១.២. ការតភ្ជាប់ពីគ្រួសារទៅកាន់ទីផ្សារ

ការនាំចេញកសិផលរបស់ប្រទេសកម្ពុជា ភាគច្រើនលើសលប់ទៅកាន់ប្រទេសវៀតណាម និងប្រទេសថៃ ជាពិសេសតាមរយៈពាណិជ្ជកម្មឆ្លងព្រំដែន។ ការលុបបំបាត់ឈ្មួញកណ្តាលដែលនៅចន្លោះរវាងកសិករនិងអ្នកប្រើប្រាស់ នឹងជំរុញឱ្យថ្លៃកសិករទទួលបាន កើនឡើងខ្ពស់ជាងមុនសម្រាប់ផលិតផលនាំចេញរបស់កម្ពុជា។

វិធីសាស្ត្រពីរយ៉ាងត្រូវបានគេធ្វើការសាកល្បង ក្នុងគោលបំណងដើម្បីសម្រួលដល់ប្រព័ន្ធទីផ្សារក្នុងគោលដៅគាំទ្រកសិករ ក្នុងនោះមាន ធនាគារស្រូវនិងប្រព័ន្ធកសិកម្មកិច្ចសន្យា។

#### ៨.៤.១.៣. ការកែលម្អផលិតភាព - ការផ្ទេរបច្ចេកវិទ្យា

ការស្ទង់មតិកសិករនៅខេត្តកំពង់ស្ពឺ តាកែវ និងកំពតបានបង្ហាញថាមានតែកសិករ៥០% ប៉ុណ្ណោះមានលទ្ធភាពទទួលបានព័ត៌មានបច្ចេកទេស តាមរយៈសេវាផ្សព្វផ្សាយកសិកម្ម ហើយក្នុងនោះមានតែ ១២% ប៉ុណ្ណោះ ដែលបានទទួលព័ត៌មាននេះពីរាជរដ្ឋាភិបាល។ ភាគច្រើននៃកសិករបានរៀនសូត្រនូវវិធីសាស្ត្រកែលម្អផលិតភាពពីកសិករដូចគ្នា។

ការចុះកិច្ចសន្យាបន្តឱ្យអង្គការក្រៅរដ្ឋាភិបាល វិមជ្ឈការនៃសេវាព័ត៌មាន និងបច្ចេកទេសកសិកម្ម ការតម្រង់ឱ្យចំកសិករគោលដៅ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ អាចនឹងមានប្រសិទ្ធភាពជាងការផ្តល់សេវាបច្ចេកទេសកម្មបែបមជ្ឈការ នៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### ៨.៤.២. អន្តរាគមន៍ក្រៅពីវិស័យកសិកម្ម

ឱកាសដូចខាងក្រោមនេះ ជាឱកាសការងារក្រៅវិស័យកសិកម្ម និងធនធានធម្មជាតិ៖

- ទេសចរណ៍ជនបទ ដែលទទួលអត្ថប្រយោជន៍ពីការអភិវឌ្ឍថ្មីៗនៃហេដ្ឋារចនាសម្ព័ន្ធជនបទ និងសុវត្ថិភាពក្នុងសហគមន៍ជនបទ។
- ការអភិវឌ្ឍអាជីវកម្មខ្នាតតូចនិងមធ្យម ដោយផ្អែកលើការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក និងធាតុចូលកសិកម្មនៅមូលដ្ឋាន។
- គម្រោងការងារសាធារណៈក្នុងរដូវប្រាំង។

#### ៨.៤.២.១. ការអភិវឌ្ឍវិស័យទេសចរណ៍

រដ្ឋាភិបាលអាចសម្របសម្រួលលើកទឹកចិត្ត និងផ្តល់ការគាំទ្រដល់សហគមន៍ជនបទ ដើម្បីលើកស្ទួយទេសចរណ៍តាមភូមិ ជាមួយនឹងគោលបំណងដើម្បីទាក់ទាញភ្ញៀវទេសចរជាតិនិងអន្តរជាតិ។

#### ៨.៤.២.២. ផលិតកម្មសិប្បកម្ម

ផលិតផលសិប្បកម្មដូចជាគ្រឿងស្មូន គ្រឿងឈើ ការកែច្នៃកសិផល ការជួសជុលថែទាំបរិក្ខារ ការស្លរដែក ការផលិតក្បឿង ការលក់ខ្នាតតូច ផ្តល់នូវឱកាសជាច្រើនសម្រាប់ការងារក្រៅពីកសិកម្ម។ ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មានសារៈសំខាន់ណាស់ ក្នុងការអភិវឌ្ឍន៍នូវចំណេះដឹងបច្ចេក-ទេសសមស្រប សម្រាប់សេដ្ឋកិច្ចជនបទ។ គ្រឹះស្ថានស្រាវជ្រាវនានាដែលលើកស្ទួយដល់ការពង្រីកនូវចំណេះដឹងបច្ចេកទេសក្នុងទីជនបទ ត្រូវទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងគោលនយោបាយគាំទ្របច្ចេកទេស។

ការទទួលឥណទានមានកម្រិត គឺជាឧបសគ្គមួយនៃកំណើនសេដ្ឋកិច្ចជនបទ។ កង្វះខាតនៃផលិត-ផលហិរញ្ញវត្ថុរយៈពេលវែង ដែលមានអត្រាការប្រាក់សមរម្យបានធ្វើឱ្យរាំងស្ទះដល់គំនិតផ្តួចផ្តើម ដែលអាចនាំមកនូវភាពជោគជ័យជាច្រើន។

ថ្លៃភ្លើងអគ្គិសនីសមរម្យ ក៏អាចបង្កើននូវផលិតកម្មនៃឧស្សាហកម្មជនបទបានដែរ។ ការតភ្ជាប់ភូមិកាន់តែច្រើនទៅកាន់បណ្តាញចែកចាយមេ អាចធ្វើឱ្យស្ថានភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចនៃគម្រោងអគ្គិសនីកាន់តែទាក់ទាញ។

*ការងារសង្គម និងសាធារណៈ*

មូលនិធិសាធារណៈជាច្រើនត្រូវបានវិនិយោគជារៀងរាល់ឆ្នាំ ទៅលើការសាងសង់ហេដ្ឋារចនា-សម្ព័ន្ធថ្មី ជាពិសេសប្រព័ន្ធធារាសាស្ត្រ សាលារៀន ផ្លូវថ្នល់ និងស្ពាន។ បច្ចេកទេសដែលប្រើកម្លាំងពលកម្មអាចត្រូវបានប្រើប្រាស់ សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបង្កើតនូវការងារនៅក្នុងទីជនបទ។ វិធីសាស្ត្រ ដែលអនុម័តដោយគម្រោងនានានៃកម្មវិធីស្បៀងអាហារពិភពលោក (WFP) នៅក្នុងគំនិតផ្តួចផ្តើមស្បៀងអាហារដើម្បីការងារអាចត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីឱ្យស៊ីគ្នាទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងសហគមន៍មូលដ្ឋាន។

## ៨.៤.៣. ក្របខ័ណ្ឌសេដ្ឋកិច្ចជនបទដែលប្រកបដោយជវភាព និងនិរន្តរភាព

ស្ថេរភាពនយោបាយ និងសមាហរណកម្មទៅក្នុងអាស៊ាននិងក្នុងតំបន់ បានបើកច្រកចូលសម្រាប់កសិផលកម្ពុជា ទៅក្នុងទីផ្សារតំបន់និងពិភពលោក។ រាជរដ្ឋាភិបាលនិងវិស័យឯកជនត្រូវធ្វើការរួមគ្នា ដើម្បីទទួលបានអត្ថប្រយោជន៍ពីឱកាសទាំងអស់នេះ។ ប៉ុន្តែបញ្ហាប្រឈមរបស់កម្ពុជាគឺថាហេដ្ឋារចនាសម្ព័ន្ធ និងយន្តការទីផ្សាររបស់ខ្លួននៅមានភាពទន់ខ្សោយ។

រាជរដ្ឋាភិបាលត្រូវដើរតួនាទីយ៉ាងសកម្ម និងប្រកបដោយយុទ្ធសាស្ត្រ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ទាំងក្នុងផ្នែកផ្គត់ផ្គង់ និងក្នុងផ្នែកតម្រូវការ។ ពាក់ព័ន្ធទៅនឹងតម្រូវការ រាជរដ្ឋាភិបាលត្រូវជួយជំរុញកសិផលកម្ពុជាឱ្យចូលទៅក្នុងទីផ្សារពិភពលោក តាមរយៈការបញ្ជៀតកសិផលកម្ពុជាចូលកន្លែងលក់ថ្មីៗ កំណើនទីផ្សារដោយខ្លួនឯង និងទីផ្សារសក្តានុពលតូចៗ។ អន្តរាគមន៍ផ្នែកផ្គត់ផ្គង់ រួមបញ្ចូលនូវវិធានការដែលមានបំណងលុបបំបាត់នូវឧបសគ្គក្នុងការពង្រីកនៃផលិតកម្មកសិកម្ម ជាពិសេស ការកែលម្អការគ្រប់គ្រងដីធ្លី និងការផ្គត់ផ្គង់ធាតុចូលកសិកម្ម ព្រមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៩
# គោលនយោបាយទំនើបភាវូបនីយកម្មវិស័យកសិកម្ម

សម្រាប់រយៈពេលមួយទសវត្សរ៍ខាងមុខ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ គឺធ្វើអោយវិស័យនេះទៅជាវិស័យកាតាលីករចម្បង ក្នុងការប្រែក្លាយសេដ្ឋកិច្ចជនបទអោយមានផលិតភាពខ្ពស់ មានចំណូលសមរម្យ និងមាននិរន្តរភាពបរិស្ថាន ដោយមានការគាំទ្រពីបច្ចេកវិទ្យា ស្ថាប័ន និងគោលនយោបាយ ។ ខ្លឹមសាររួមនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺ "**ការអភិវឌ្ឍដើម្បីប្រជាជន**" (Development with Human Face)។

ការពង្រីកផលិតកម្មនិងការពង្រឹងផលិតភាពកសិកម្ម គឺជាមធ្យោបាយក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជាគ្រប់រូប។ ការសម្រេចបានដូចនេះនៅជនបទ ទាមទារឱ្យមានអភិក្រមប្រទាក់ក្រឡា គ្រប់ជ្រុងជ្រោយ និងស្មុគស្មាញ ដែលរួមមានៈ (១) ក្របខណ្ឌគោលនយោបាយនិងនិយ័តកម្ម ដើម្បីពង្រីកការទទួលបាន និងពង្រីកការគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗដូចជា ដីធ្លី ព្រៃឈើ ជលផល និងទឹក, (២) យុទ្ធសាស្ត្រដែលធានាបាននូវសង្គតិភាព និងឯកភាពរវាងវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ, (៣)ការបង្កើតនូវកាលានុវត្តភាពការងារ ក្រៅពីវិស័យកសិកម្ម។

**ផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គម**លើកទីពីរ (SEDP)ឆ្នាំ ១៩៩៦-២០០០ បានដាក់ចេញទិសដៅសម្រាប់អភិវឌ្ឍន៍វិស័យជនបទ។ គំនិតផ្តួចផ្តើមសំខាន់ៗរួមមាន៖ (១) កែលម្អមុខងារទីផ្សារដើម្បីជួយគាំទ្រដល់ប្រជាជនក្រីក្រ, (២)វិភាជធនធានជួយឱ្យអ្នកក្រីក្រទទួលបានសេវាអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការផ្សព្វផ្សាយបច្ចេកទេស, (៣) បង្កើតក្របខ័ណ្ឌអនុគ្រោះដល់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ នៅក្នុងសហគមន៍ជនបទ, (៤) ការធានាសន្តិសុខដីធ្លី, (៥) កែលម្អការគ្រប់គ្រងធនធានព្រៃឈើ និងជលផល, (៦) កសាងសមត្ថភាពក្នុងការគ្រប់គ្រងទឹក ទាំងក្នុងកម្រិតបច្ចេកទេស (ការអភិវឌ្ឍបណ្តាញ) និងកម្រិតគ្រប់គ្រង (លើកកម្ពស់សហគមន៍អ្នកប្រើប្រាស់ទឹក), និង (៧) ផ្តល់ហិរញ្ញប្បទានកសាងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាននៅតាមសហគមន៍ជនបទ។

ទន្ទឹមនឹងទិសដៅនៃគំនិតផ្តួចផ្តើមទាំងនេះ ក្រុមការងារបច្ចេកទេសកសិកម្មនិងទឹកបានរៀបចំសេចក្តីព្រាង **យុទ្ធសាស្ត្រដឹកនាំវិស័យកសិកម្ម** ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ ពង្រឹងសន្តិសុខស្បៀង និងលើកស្ទួយកំណើនសេដ្ឋកិច្ច តាមរយៈការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ទន្ទឹមជាមួយនឹងការកែលម្អការអភិវឌ្ឍនិងគ្រប់គ្រងធានធានទឹក។ យុទ្ធសាស្ត្រនេះឈរលើការវិភាគលើចំណុចខ្លាំង ខ្សោយ ឱកាស និងការគំរាមកំហែង (SWOT) ដូចមានខាងក្រោម៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | |
|---|---|
| **ចំណុចខ្លាំង**<br>- ដីធ្លីនៅមានច្រើន។<br>- ធនធានទឹកនៅមានច្រើន។<br>-កំលាំងពលកម្មច្រើន និងថ្លៃឈ្នួលទាបនៅជនបទ។<br>- ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និង ក្រសួងធនធានទឹកនិងឧតុនិយមមានសក្តានុពលធនធានមនុស្ស។<br>- គោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រត្រូវបានរៀបចំឡើងសម្រាប់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និង ក្រសួងធនធានទឹកនិងឧតុនិយមមានសក្តានុពលធនធានមនុស្ស។<br>-គ្រប់ភាគីពាក់ព័ន្ធទាំងអស់មានការប្តេជ្ញាចិត្តខ្ពស់ និងទទួលស្គាល់ពីសារសំខាន់របស់វិស័យ (ទាំងរាជរដ្ឋាភិបាល ទាំងម្ចាស់ជំនួយ ទាំងអង្គការក្រៅរដ្ឋាភិបាល និងទាំងកសិករ)។<br>- ប្រព័ន្ធអេកូឡូស៊ីនៃកសិកម្មមានច្រើនប្រភេទ ដែលធ្វើឱ្យប្រភេទដីមានច្រើនបែប/សណ្ឋាន។<br>- ការប្តេជ្ញាចិត្ត និងការផ្តល់សិទ្ធិអំណាចដល់សហគមន៍ ក្នុងក្របខណ្ឌនៃអាជ្ញាធរមូលដ្ឋាន តាមរយៈក្រុមប្រឹក្សាឃុំសង្កាត់ ដែលកំពុងដំណើរការ។<br>- សកម្មភាពកសិ-ឧស្សាហកម្មកំពុងអភិវឌ្ឍន៍។ | **ចំណុចខ្សោយ**<br>- សមត្ថភាពស្ថាប័ន ការគ្រប់គ្រង និងអនុវត្តគម្រោងរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និងក្រសួងធនធានទឹកនិងឧតុនិយមនៅទន់ខ្សោយ។<br>-ធនធានទឹកមានសភាពខុសគ្នាខ្លាំង ទៅតាមពេលវេលានិងទីកន្លែង ហើយបច្ចេកវិទ្យានៃការគ្រប់គ្រងទឹកនៅមិនទាន់ជឿនលឿននៅឡើយ។<br>- សមត្ថភាព និងការចាប់អារម្មណ៍លើការវិនិយោគក្នុងវិស័យកសិកម្មនៅមានតិចតួចនៅឡើយ។<br>- ការផ្ទេរបច្ចេកវិទ្យា ចំណេះធ្វើ ព្រមទាំងការផ្តល់បច្ចេកទេស និងជំនាញ ទៅដល់កសិករ និងមន្ត្រីផ្សព្វផ្សាយ នៅមានភាពទន់ខ្សោយនៅឡើយ។<br>- ជីជាតិដីមិនសូវល្អនៅតាមតំបន់ជាច្រើន។<br>- ភាពទន់ខ្សោយនៃសង្គមវប្បធម៌ ដែលរួមមានសាមគ្គីភាពនៅសហគមន៍ ភាពងាយរងគ្រោះនៃកសិករ ដោយសារបញ្ហាអត់ដី និងវប្បធម៌នៃកសិកម្មសម្រាប់ហូប។<br>- ព័ត៌មានមិនស៊ីមេទ្រីក្នុងចំណោមភាគីពាក់ព័ន្ធ។<br>- ផលិតភាពទាបនៃកំលាំងពលកម្ម ដី និងទឹក (ការប្រើប្រាស់ធនធានមិនមានប្រសិទ្ធភាព)។<br>- ការចូលទៅក្នុងទីផ្សារនៅមានកម្រិត។<br>- ក្របខ័ណ្ឌច្បាប់សម្រាប់កសិកម្មនិងធនធាននៅមានមិនទាន់គ្រប់គ្រាន់។ |
| **កាលានុវត្តភាព**<br>- ការកែលម្អអភិបាលកិច្ច រួមទាំងការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល និងស្ថេរភាពនយោបាយ។<br>- ការអភិវឌ្ឍទីផ្សារ និងការធ្វើសមាហរណកម្ម ទៅក្នុងទីផ្សារតំបន់ និងពិភពលោក។<br>- ការគាំទ្រពេញទំហឹង ពីសំណាក់ដៃគូអភិវឌ្ឍសម្រាប់ការវិនិយោគខាងកសិកម្ម និងទឹក។<br>- វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្មី។<br>- ការប្រើប្រាស់ធនធានធម្មជាតិឱ្យអស់លទ្ធភាព (ដី និងទឹក) ដែលមានការអភិវឌ្ឍតិចតួច ឬ មិនទាន់មានការអភិវឌ្ឍនៅឡើយ។<br>- មិនទាន់មានមូលនិធិវិនិយោគនៅឡើយ រួមទាំងការលើកទឹកចិត្ត មូលនិធិឯកជន និងឥណទានខ្នាតតូច។<br>- គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ | **ការគំរាមកំហែង**<br>- ការផ្លាស់ប្តូរកំពុងកើតមាននៅក្នុងទីផ្សារ រួមមានទីផ្សារអន្តរជាតិ ប្រកបដោយការប្រកួតប្រជែងខ្ពស់ ដែលនាំឱ្យមានការកេងបន្លំ និង មានភាពមិនប្រាកដប្រជា។<br>- ប្រេង និងឧស្ម័នមានតម្លៃខ្ពស់។<br>-ស្ថានភាពនយោបាយ នាំឱ្យមានតម្រូវការមូលនិធិរាជរដ្ឋាភិបាលសម្រាប់វិស័យដទៃ។<br>- ស្ថានភាពគតិយុត្តិ ដែលធ្វើឱ្យការអនុវត្តច្បាប់ភូមិបាល ច្បាប់ទឹក និងច្បាប់ព្រៃឈើ ជាដើម។ល។ មិនបានពេញលេញ<br>- គ្រោះធម្មជាតិ។<br>- ការខូចខាតគុណភាពបរិស្ថាន។<br>- កង្វះលទ្ធភាពក្នុងការអនុវត្តការកែទម្រង់អភិបាលកិច្ច ច្បាប់ និងការកែទម្រង់ដទៃទៀត។<br>- ការផ្លាស់ប្តូរសង្គម និងនយោបាយ រួមមានវិវាទសង្គម ក្នុងការទទួលបានទឹក និងដីធ្លី និងការធ្វើចំណាកស្រុក។<br>-ការធ្លាក់ចុះការគាំទ្រពីដៃគូអភិវឌ្ឍនៅក្នុងវិស័យកសិកម្មនិងទឹក។ |

*ប្រភព៖រាជរដ្ឋាភិបាលកម្ពុជា"យុទ្ធសាស្ត្រកសិកម្មនិងទឹក-២០០៦-២០១០"ថ្ងៃទី៩ខែមករាឆ្នាំ២០០៧ ទំព័រទី៦*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដើម្បីឈានទៅដល់ការផ្លាស់ប្តូរវិស័យកសិកម្មពិតប្រាកដមួយ កម្ពុជាត្រូវតែផ្លាស់ប្តូរពីកសិកម្មសម្រាប់ហូប (ដែលកសិផលមានតិចតួចលក់នៅទីផ្សារ និងមិនសូវមានទំនាក់ទំនងជាមួយនឹងឧស្សាហកម្មម្ហូបអាហារ) ទៅរកកសិកម្មសម្រាប់ពាណិជ្ជកម្ម (ដែលកសិផលអាចមានលទ្ធភាពលក់នៅទីផ្សារ និងមានទំនាក់ទំនងខ្លាំងជាមួយនឹងឧស្សាហកម្មម្ហូបអាហារ)។ ការផ្លាស់ប្តូរបែបនេះទាមទារឱ្យមានការបង្កើនធាតុចូល និងបង្កើតទីផ្សារកសិផល ក៏ដូចជាការធ្វើសមាហរណកម្មទីផ្សារនេះជាមួយនឹងទីផ្សារនៃវិស័យដទៃទៀតទាំងក្នុងសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចអន្តរជាតិ។ នៅក្នុងដំណើរការផ្លាស់ប្តូរនេះ ប្រភពនៃកំណើនអាចសម្រេចបាន តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាកាន់តែច្រើន ការកែលម្អវិធីសាស្ត្រគ្រប់គ្រង និងការកែលម្អក្របខណ្ឌស្ថាប័ន។

រាជរដ្ឋាភិបាលបានកំណត់ការដ្ឋានបូនជាចម្បងសម្រាប់ធ្វើអន្តរាគមន៍ និងសមស្របទៅតាមគោលដៅអភិវឌ្ឍន៍វិស័យជនបទ រួមមាន៖

- ការកាត់បន្ថយភាពក្រីក្រ និងសន្តិសុខស្បៀង។
- ការពង្រឹងកិច្ចខិតខំប្រឹងប្រែងធានាសមធម៌នៃកំណើនសេដ្ឋកិច្ច។
- ការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថាន។
- ការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្សផ្តោតទៅលើអ្នកក្រីក្រ។

នៅក្រោមយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលកម្ពុជាមានផែនការប្រមូលផ្តុំកម្មវិធីវិនិយោគរបស់ខ្លួនផ្តោតជាពិសេសទៅលើវិស័យ ដូចខាងក្រោម៖

### ៩.១. ជម្រើសរវាងកសិដ្ឋានកម្រិតគ្រួសារនិងចម្ការទ្រង់ទ្រាយធំ

មានប្រតិបត្តិការផលិតកម្មកសិកម្មពីរប្រភេទ មួយផលិតកម្មលក្ខណគ្រួសារ និងមួយបែបទៀតជាចម្ការទ្រង់ទ្រាយធំលក្ខណឧស្សាហកម្ម។ ប្រសិនពិនិត្យមើលក្នុងទិដ្ឋភាពនៃការលើកទឹកចិត្ត និងការគ្រប់គ្រងប្រព័ន្ធផលិតកម្មលក្ខណៈគ្រួសារហាក់ដូចជាល្អប្រសើរជាង។ ការប្រើប្រាស់នូវបច្ចេកវិទ្យាទំនើប ក៏មិនមានអ្វីជាឧបសគ្គដែរ។ ទោះបីជាមានទំហំដីតូច ការប្រើប្រាស់គោយន្តអាចនឹងផ្តល់ប្រាក់ចំណេញ ដូចគ្នានឹងការធ្វើចម្ការទ្រង់ទ្រាយធំលក្ខណៈឧស្សាហកម្មដែរ។ ផលិតកម្មគ្រួសារស្រូបយកកម្លាំងពលកម្មកសិកម្មពី ៦០% ទៅ ៧០%។ នៅកម្ពុជា សេដ្ឋកិច្ចនៅជនបទប្រមូលផ្តុំភាគច្រើនដោយផលិតកម្មគ្រួសារ ហើយបានដើរតួយ៉ាងសំខាន់ក្នុងការថែរក្សាស្ថិរភាពសេដ្ឋកិច្ច សង្គម និងនយោបាយនៅក្នុងប្រទេស។ ផលិតកម្មគ្រួសារក៏មានភាពប្រកួតប្រជែងផងដែរ សម្រាប់កសិផលសរីរាង្គ។

ផលិតកម្មគ្រួសារអាចមានប្រសិទ្ធភាពច្រើនថែមទៀត ប្រសិនបើសមាជិកគ្រួសារខិតខំធ្វើការដើម្បីបង្កើនទិន្នផលឱ្យបានជាអតិបរមា គឺសម្រាប់ទាំងបំពេញតម្រូវការហូបចុក និងទាំងនៅសល់សម្រាប់លក់នៅទីផ្សារ។ កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនផលិតភាពផលិតកម្មគ្រួសារ គប្បីរួមបញ្ចូលការផ្សារភ្ជាប់កសិករទៅកាន់ទីផ្សារ និងជាមួយនឹងវិស័យឯកជន។ ផលិតកម្មគ្រួសារអាចមានប្រសិទ្ធភាព នៅក្រោមលក្ខខណ្ឌដូចខាងក្រោមនេះ (១) ការប្រើប្រាស់បច្ចេកវិទ្យាសមស្រប មានលទ្ធភាពលក់ទៅទីផ្សារ និងសហគមន៍មូលដ្ឋានមានសមត្ថភាព (២) បណ្តាញពាណិជ្ជកម្មនៅមូលដ្ឋានមានប្រសិទ្ធភាព និង(៣)មានហេដ្ឋារចនាសម្ព័ន្ធ និងមានការស្រាវជ្រាវ និងផ្សព្វផ្សាយ អំពីការកែលម្អសេដ្ឋកិច្ចផលិតកម្មគ្រួសារ។ ផលិតកម្មគ្រួសារសមស្របសម្រាប់ការផលិតកសិផលជាប្រពៃណីដូចជាស្រូវ ពោត លូ ជាពិសេសកសិផលសម្រាប់ប្រើប្រាស់ក្នុងស្រុក។

ការប្រមូលផ្តុំដីធ្លីកំពុងតែកើតមានឡើងក្នុងពេលបច្ចុប្បន្ន ដែលបង្កើនកាលានុវត្តភាពក្នុងការធ្វើចម្ការទ្រង់ទ្រាយធំបែបឧស្សាហកម្ម។ យោងតាម លោក **ហាយ៉ាមិ** ចម្ការទ្រង់ទ្រាយធំដែលប្រើប្រាស់គ្រឿងយន្ត សមស្របសម្រាប់ការផលិតកសិផលនាំចេញ ដូចជា កៅស៊ូ ប្រេងដូង តែ និងចេក ដែលទាមទារឱ្យមានការគ្រប់គ្រង ការកែច្នៃ និងការវេចខ្ចប់ជាប្រព័ន្ធ។ គុណសម្បត្តិនៃចម្ការទ្រង់ទ្រាយធំ គឺត្រូវផ្សារភ្ជាប់នឹងការវិនិយោគលើផ្លូវ ស្ពាន និងកំពង់ផែ ដើម្បីធ្វើការដឹកជញ្ជូនកសិផលទាំងអស់នោះ ទៅកាន់ទីផ្សារអន្តរជាតិ។ ទោះបីជាយ៉ាងនេះក្តី ផលិតកម្មគ្រួសារខ្នាតតូចក៏អាចរៀបចំជាប្រព័ន្ធផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីបង្កើតជាបរិមាណគ្រប់គ្រាន់សម្រាប់ការនាំចេញបានដែរ។

ទោះបីជាយ៉ាងណាក៏ដោយ ការកើតឡើងនូវចម្ការទ្រង់ទ្រាយធំ ដោយប្រើគ្រឿងយន្ត នៅក្នុងតំបន់នៃផលិតកម្មគ្រួសារ នាំឱ្យមានហានិភ័យរីកធំឡើង ពិសេសឆ្លុះបញ្ចាំងឱ្យឃើញវិសមធម៌ក្នុងការបែងចែកទ្រព្យសម្បត្តិនិងចំណូលនៅក្នុងសង្គម។ សញ្ញាអវិជ្ជមាននៃការអភិវឌ្ឍបែបនេះ រួមមានកំណើននៃកសិករគ្មានដីធ្លី ការដណ្តើមដីពីប្រជាជនក្រីក្រនិងអ្នកតំបន់ភ្នំ និងកំណើននៃកេងយកចំណេញពីការដោះដូរដី។ ការអភិវឌ្ឍបែបនេះ ប្រសិនបើកើតមានឡើង នឹងនាំមកនូវភាពរីករវក្នុងសង្គម និងនយោបាយ។ លើសពីនេះ ការកសាងផ្លូវថ្មីៗ ដើម្បីឱ្យអ្នកមានទ្រព្យសម្បត្តិទៅទិញដីដែលនៅតំបន់ដាច់ស្រយាល នឹងនាំឱ្យភាពតឹងតែងកាន់តែធ្ងន់ធ្ងរឡើងនៅក្នុងសង្គម ។

ក្នុងការលើកកម្ពស់វិស័យកសិកម្ម ការផ្តោតការយកចិត្តទុកដាក់ជាសំខាន់ ទៅលើការធ្វើពិពិធកម្ម និងទំនើបកម្មកសិកម្ម ការលើកកម្ពស់វិស័យកសិឧស្សាហកម្ម ការពង្រឹងសេវាបច្ចេកទេសនិងពាណិជ្ជកម្ម ការធានាសុវត្ថិភាពនៃកម្មសិទ្ធិដីនិងកំណែទម្រង់រដ្ឋបាលដីធ្លី ការកែទម្រង់ការគ្រប់គ្រងធនធានទឹក ការលើកកម្ពស់និងពិពិធកម្មចំណូលជនបទ ការកាត់បន្ថយភាពងាយរងគ្រោះផ្នែកកសិកម្ម ការចូលទៅក្នុងទីផ្សារតំបន់ ការកែទម្រង់ការគ្រប់គ្រងព្រៃឈើ ការជំរុញការដាំកៅស៊ូ ការស្តារវិស័យនេសាទ ការបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ជំរុញវិស័យចិញ្ចឹមសត្វឱ្យបានខ្ពស់ ការកសាងសមត្ថភាពស្ថាប័ន រួមមាន ការពង្រឹងតួនាទីនៃអង្គការកសិករ ការលើកកម្ពស់ការអភិវឌ្ឍជនបទឱ្យមានភាពប្រទាក់ក្រឡាគ្នា និងបើកចំហរតំបន់ជនបទ ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុនៅក្នុងសហគមន៍ជនបទ ការគាំទ្រចំពោះការអភិវឌ្ឍវិស័យឯកជន និងបង្កើតការងារក្រៅកសិកម្ម និងការធានាឱ្យបាននូវចីរភាពនៃគម្រោងដែលឧបត្ថម្ភដោយម្ចាស់ជំនួយ។

## ៩.២. ពិពិធកម្មនិងការធ្វើទំនើបកម្មកសិកម្ម

វិធានការចាំបាច់នានាក្នុងការធ្វើប្រពលវប្បកម្ម វិត្ថារកម្ម និង ទំនើបកម្មមានដូចតទៅៈ

- **ពង្រីកដីដាំដុះ៖** ការវិភាគប្រព័ន្ធអេកូឡូស៊ីកសិកម្ម ការកែលម្អការធ្វើផែនការ ការធ្វើចំណាត់ថ្នាក់ និងសន្និធិនៃការប្រើប្រាស់ ព្រមទាំងការកំណត់តំបន់ដាំដុះ អាចជួយឱ្យកសិករពង្រីកផ្ទៃដីដាំដុះ និងវិនិយោគច្រើនថែមទៀតក្នុងវិស័យកសិកម្ម។
- **ការធ្វើពិពិធកម្មកសិកម្ម៖** អាទិភាពទីមួយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺធ្វើឱ្យមានពិពិធកម្មផលិតកម្មកសិកម្ម ដើម្បីបង្កើនការចូលរួមចំណែកនៃវិស័យកសិកម្មក្នុងកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដែលរួមមាន៖ (១)ការតម្រង់ទិសវិនិយោគសាធារណៈ និងការលើកទឹកចិត្តដល់ការវិនិយោគឯកជននៅក្នុងវិស័យកសិកម្ម ទន្ទឹមនឹងការលើកកម្ពស់គុណភាពកសិផលកម្ពុជា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យស្របតាមស្តង់ដារអន្តរជាតិ (២) អភិវឌ្ឍតំបន់ព្រំដែននិងតំបន់ដាច់ស្រយាល ដើម្បីប្រយុទ្ធប្រឆាំងនឹងចំណាកស្រុកជនបទ (៣) អភិវឌ្ឍទីរួមខេត្តដោយបំពាក់នូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ដើម្បីជំរុញសេដ្ឋកិច្ចនៅមូលដ្ឋាន និង ផ្តល់ជាមធ្យោបាយក្នុងការទ្រទ្រង់ជីវភាពសហគមន៍នៅតាមខេត្ត។

- **ការកែលម្អផលិតភាពកសិកម្ម៖** ផលិតភាពស្រូវអាចជំរុញឱ្យខ្ពស់ថែមទៀតបាន តាមរយៈការអនុវត្តតាមផលិតកម្មសរីរាង្គចំពោះដីស្រែតូចៗ និងជាលក្ខណគ្រួសារ។ កត្តាទាំងនេះរួមបញ្ចូលទាំងការកែលម្អគុណភាពពូជ ការប្រើប្រាស់ជី ការគ្រប់គ្រងជម្ងឺ ការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រឱ្យមានប្រសិទ្ធភាព ការពង្រឹងបច្ចេកវិទ្យាក្រោយពេលប្រមូលផល និងការប្រើប្រាស់ប្រព័ន្ធដាំដុះថ្មីៗ ដូចជាប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ និងប្រព័ន្ធផលិតកសិកម្មចម្រុះ ។ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម គឺជាកត្តាគន្លឹះបំផុតដើម្បីអាចទទួលបានជោគជ័យក្នុងការធ្វើប្រពលវប្បកម្ម។ ការពង្រឹងសមត្ថភាពក្រុមហ៊ុនពូជស្រូវ ដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា សហការជាមួយនឹង AusAID ដែលជាផ្នែកមួយនៃគម្រោង AQIP ក៏ជាកត្តាសំខាន់ផងដែរ។
- **ការអនុវត្តយុទ្ធសាស្ត្រផលិតកម្មស្រូវ៖** ផ្តោតការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រមុខពីរ ក្នុងនោះមុខទីមួយគឺការប្រើប្រាស់ពូជដែលមានទិន្នផលខ្ពស់សម្រាប់ផលិតកម្មស្រូវដែលមានគុណភាពល្អ (យុទ្ធសាស្ត្ររបស់ប្រទេសថៃ) និង មុខទីពីរ គឺពូជទិន្នផលខ្ពស់សម្រាប់ស្រូវគុណភាពអន់ (យុទ្ធសាស្ត្ររបស់ប្រទេសវៀតណាម) ទៅតាមសណ្ឋានដីរបស់កម្ពុជា។
- **ការលើកទឹកចិត្តឱ្យដាំដុះដំណាំជីវឥន្ធនៈ៖** ជីវឥន្ធនៈអាចឆ្លើយតបបានមួយចំណែក ទៅនឹងការឡើងថ្លៃប្រេង និងការរួមតូចនៃសន្និធិប្រេង។ ជីវឥន្ធនៈមានបីប្រភេទ (១) ជីវឥន្ធនៈដែលចម្រាញ់ចេញមកពីរុក្ខជាតិមានសារជាតិប្រេង ឧទា.ដូងប្រេង (២) ជីវឥន្ធនៈដែលចម្រាញ់ចេញពីជាតិអាល់កុលក្នុងរុក្ខជាតិដែលមានជាតិស្ករ ឧទា.អំពៅ និង (៣) ជីវឥន្ធនៈដែលបានមកពីការផ្អាប់កាកសំណល់សរីរាង្គឱ្យលួយ (កាកសំណល់ម្ហូបអាហារ បន្លែនិងកាកសំណល់គ្រាប់ធញ្ញជាតិជាដើម) ដែលផលិតបានជាជីវឧស្ម័ន (មេតាន) ដែលអាចប្រើដោយផ្ទាល់ក្រោយពេលធ្វើបន្សុទ្ធកម្ម ដូចជាឧស្ម័នធម្មជាតិដទៃទៀត សម្រាប់យានជំនិះ។
- **ការប្រើប្រាស់បច្ចេកវិទ្យាថ្មីសម្រាប់ការធ្វើជំនើបកម្មការអនុវត្តកសិកម្ម** និង ការ និងការធ្វើប្រពលវប្បកម្មផលិតកម្មសត្វ និងរុក្ខជាតិ។
- **កែលម្អប្រព័ន្ធផ្គត់ផ្គង់វត្ថុធាតុដើម៖** ការបង្កើនការប្រើប្រាស់ពូជដែលមានទិន្នផលខ្ពស់ និង ពូជកែលម្អ ត្រូវដើរទន្ទឹមគ្នានឹងកំណើនក្នុងការប្រើប្រាស់ជី។ ទោះបីជាកសិករយល់ដឹងពីការប្រើប្រាស់ជីក៏ដោយ ក៏ឧបសគ្គចម្បងបំផុត គឺការផ្គត់ផ្គង់មិនគ្រប់គ្រាន់ កង្វះនូវការធានាគុណភាព និងថ្លៃជីខ្ពស់ពេក។
- **ការជំរុញ និង ការពង្រីកលទ្ធភាពប្រើប្រាស់ឧបករណ៍កសិកម្ម និង កត្តាផលិតកម្មផ្សេងទៀត។**
- **ការបណ្តុះបណ្តាល ការបង្កើតក្រុមប្រឹក្សាកសិកម្ម និងការពង្រឹងស្ថាប័នជនបទ៖** ការបង្កើតស្ថាប័នអភិវឌ្ឍជនបទ ដែលមានកាតព្វកិច្ចក្នុងការបង្កើនល្បឿននៃការផ្ទេរបច្ចេកវិទ្យាទៅដល់កសិករ មានសារៈសំខាន់ជាសារវន្ត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **ការជំរុញការអប់រំដល់កសិករ៖** ប្រសិទ្ធភាពនៃមន្ត្រីផ្សព្វផ្សាយបច្ចេកទេសកសិកម្ម គឺការប្រាស្រ័យទាក់ទង និងការជឿទុកចិត្ត។ ការអប់រំនៅជនបទ នឹងរួមចំណែកដល់ការបើកច្រកនៃការធ្វើការប្រាស្រ័យទាក់ទង។ ប្រសិនបើកសិករចេះអាន ការប្រាស្រ័យទាក់ទងអាចធ្វើឡើង តាមរយៈឯកសារជាលាយលក្ខអក្សរ និងដោយផ្ទាល់មាត់ផងដែរ។ ការជឿទុកចិត្តគឺជាកត្តាចាំបាច់។ ភាគច្រើនកសិកររៀនសូត្រពីអ្នកជិតខាងរបស់ខ្លួន។ ប្រការចាំបាច់គឺការលើកកម្ពស់ចំណេះដឹង ការទទួលបានព័ត៌មាន និងការផ្ទេរបច្ចេកវិទ្យាទាក់ទងនឹងការអនុវត្តកសិកម្ម ការគ្រប់គ្រងទឹក និងធារាសាស្ត្រ និងការលក់ផលិតផលកសិកម្មទៅទីផ្សារ តាមរយៈសិក្ខាសាលា និងមធ្យោបាយផ្សេងៗទៀត ដោយមានអន្តរសកម្មភាពជាមួយនឹងកសិករផ្ទាល់។

## ៩.៣. ការជម្រុញវិស័យកសិ-ឧស្សាហកម្ម

វិស័យកសិឧស្សាហកម្មគឺជាវិស័យទីមួយផង និងជាវិស័យទីពីរផង ដែលជាសកម្មភាពចម្បងទាក់ទងទៅនឹងការកែច្នៃកសិផល និងជលផល ទៅជាផលិតផលឧស្សាហកម្ម ឬពាក់កណ្ដាលឧស្សាហកម្ម។ ការអភិវឌ្ឍវិស័យកសិឧស្សាហកម្មនឹងបង្កើនតម្លៃបន្ថែមលើកសិផល ដែលនឹងជំរុញកសិករឱ្យចាកចេញពីការធ្វើកសិកម្មសម្រាប់ហូប និងលើកទឹកចិត្តឱ្យមានការចូលរួមក្នុងសកម្មភាពទីផ្សារកសិកម្ម។ ផ្នែកសំខាន់ៗនៃការអភិវឌ្ឍវិស័យកសិឧស្សាហកម្មមាន ដូចខាងក្រោម៖

- **ការជំរុញឧស្សាហកម្មកែច្នៃ៖** កម្ពុជាមានសក្ដានុពល សម្រាប់ការកែច្នៃផលិតផលកសិកម្ម ដែលរួមមានផ្លែឈើតំបន់ត្រូពិច អាហារសមុទ្រដូចជា ត្រី បង្គារ សិប្បិសត្វ និង សត្វប្រភេទខ្យង ខ្ចៅ គ្រំ។
- **ការពង្រីកសកម្មភាពកសិឧស្សាហកម្ម** ក្នុងវិស័យឯកជន សម្រាប់ផ្គត់ផ្គង់ធាតុចូលកសិកម្ម និងការផ្ដល់សេវាកសិកម្មដល់សហគមន៍តាមជនបទ។
- **ការលើកទឹកចិត្តឱ្យមានការវិនិយោគពីវិស័យឯកជន** ក្នុងការធ្វើធុរកិច្ចផ្នែកកសិ-ឧស្សាហកម្ម ទាំងផ្នែកស្តុកទុក ការវេចខ្ចប់ និងកិច្ចការទីផ្សារនៃកសិផល។
- **ការបង្កើតទំនាក់ទំនងរវាងពាណិជ្ជកម្មឯកជននិងគ្រួសារតាមជនបទ** តាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យា និងចម្ការភូមិ។
- **ការផ្តល់ព័ត៌មាននិងការព្យាករណ៍ពីស្ថានភាពទីផ្សារក្នុងស្រុកនិងបរទេស។**

## ៩.៤. ពង្រឹងសេវាបច្ចេកទេសនិងពាណិជ្ជកម្ម

សេវាផ្សព្វផ្សាយកសិកម្មគឺជាការផ្សារទំនាក់ទំនងដ៏សំខាន់ រវាងវិទ្យាស្ថានស្រាវជ្រាវ ឬកសិដ្ឋានពិសោធន៍ ទៅនឹងសហគមន៍ជនបទ ដែលជាអ្នកទទួលបានប្រយោជន៍ពីលទ្ធផលនៃការស្រាវជ្រាវទាំងនោះ។ ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មនៅមិនទាន់យកចិត្តទុកដាក់នៅឡើយ ដោយសារមានតែកសិករ ១% ទេ ដែលអាចមានទទួលបានសេវានេះ។ សកម្មភាពក្នុងពេលអនាគតគប្បីគួររួមបញ្ចូល៖

- **ការពង្រីកសេវាផ្សព្វផ្សាយបច្ចេកទេស៖** សកម្មភាពនេះនឹងអាចកាត់បន្ថយគម្លាតបច្ចេកទេសទៅនឹងការប្រតិបត្តិរបស់កសិករពេលបច្ចុប្បន្នក្នុងផ្នែកផលិតកម្ម ការប្រមូលផល និងការកែច្នៃកសិផល ដោយប្រើប្រាស់គ្រប់មធ្យោបាយ ទាំងការផ្ទេរបច្ចេកវិទ្យា និងការរួមផ្សំការផ្តល់ឥណទានជាមួយនឹងសេវាផ្សព្វផ្សាយបច្ចេកទេសជាដើម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **ការគាំទ្រផ្នែកបច្ចេកទេសដល់សមាគមន៍កសិករ៖** ការលើកទឹកចិត្តដល់កសិករឱ្យធ្វើការផ្លាស់ប្តូរ និងចែករំលែកការអនុវត្តល្អ ក្នុងចំណោមសមាគមន៍របស់ខ្លួន។
- **ការកសាងសមត្ថភាពស្រាវជ្រាវដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា** (CARDI)៖ ក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ រាជរដ្ឋាភិបាលនិងទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) បានផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្លាំង ដល់ការកសាងសមត្ថភាពនៃប្រព័ន្ធស្រាវជ្រាវកសិកម្មថ្នាក់ជាតិ តាមរយៈវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)។ ការបន្តពង្រឹងវិទ្យាស្ថាន CARDI គួរតែជាការងារអាទិភាព។

## ៩.៥. សន្តិសុខដីធ្លីនិងកំណែទម្រង់ការគ្រប់គ្រងដីធ្លី

បញ្ហាដីធ្លី គឺជាឫសគល់នៃជម្លោះសង្គមនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន រួមទាំងប្រទេសកម្ពុជាដែរ។ ភាពតានតឹងផ្នែកនយោបាយ និងភាពស្មុគស្មាញនៃបញ្ហាទាក់ទងនឹងដីធ្លីអាចបណ្តាលឱ្យមានភាពចលាចលក្នុងសង្គម ដែលនឹងធ្វើឱ្យការអនុវត្តកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលមិនអាចសម្រេចបាន។ ប៉ុន្តែប្រទេសកាន់តែច្រើនឡើងៗទទួលបានជោគជ័យក្នុងការដោះស្រាយបញ្ហាដីធ្លីនេះ។ អភិក្រមនៃការអនុវត្តអាចនឹងខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ប៉ុន្តែគោលនយោបាយទាំងនេះត្រូវធានានូវកម្មសិទ្ធិដីសម្រាប់ជនក្រីក្រ សម្រួលប្រតិបត្តិការដីធ្លី និងពិចារណាដោយចិត្តទុកដាក់លើសមធម៌ និងប្រយោជន៍ទាំងអស់គ្នា ។

នៅកម្ពុជា ជាមួយនឹងកំណើនប្រជាជន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងការឡើងថ្លៃដី នឹងធ្វើឱ្យដីទំនេរមានកាន់តែតិចទៅៗ ដែលធ្វើឱ្យការប្រកួតប្រជែងដណ្តើមយកដីកាន់តែស្រួចស្រាវ និងធ្វើឱ្យមានជម្លោះកាន់តែអាក្រក់ឡើងថែមទៀត។ ដើម្បីជំរុញការអភិវឌ្ឍដីធ្លី និងលើកទឹកចិត្តដល់ការវិនិយោគប្រកបដោយផលិតភាព វិធានការដូចខាងក្រោមគួរត្រូវអនុវត្ត៖

- **ពង្រឹងក្របខ័ណ្ឌច្បាប់នៅថ្នាក់សហគមន៍ជនបទ** ដើម្បីផ្តល់ការលើកទឹកចិត្តពិតប្រាកដឱ្យមានការអភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។
- • **ពង្រឹងសន្តិសុខនៃកម្មសិទ្ធភាព៖** ពង្រីកកម្មវិធីចុះបញ្ជីដីជាប្រព័ន្ធ ចេញប័ណ្ណកម្មសិទ្ធិជូនសហគមន៍និងបុគ្គល និងកំណត់ឱ្យបានច្បាស់ពីសហគមន៍ជនបទ ដើម្បីបញ្ចៀសនូវវិវាទ ឬជម្លោះ ដោយផ្តល់ធនធានឱ្យបានគ្រប់គ្រាន់ ដល់នាយកដ្ឋានវាស់វែងដីធ្លីដើម្បីសម្រេចបានបេសកកម្មនេះ។
- **ពង្រឹងយន្តការដោះស្រាយវិវាទដីធ្លី៖** ដោយសារតែសមត្ថភាពរបស់តុលាការនៅមានកម្រិត រាជរដ្ឋាភិបាលបានបង្កើតឱ្យមានអាជ្ញាធរដោះស្រាយវិវាទដីធ្លី ដែលមានភារកិច្ច ដោះស្រាយវិវាទដីធ្លី មុនពេលចូលទៅដល់ការដោះស្រាយតាមផ្លូវតុលាការ។
- **ធ្វើចំណាត់ថ្នាក់ប្រភេទដីធ្លីដើម្បីជំរុញការប្រើប្រាស់ដីឱ្យមានប្រសិទ្ធភាព៖** ដីប្រហែលជា២០% នៅក្នុងប្រទេសកម្ពុជាបានត្រូវចាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ។ ប៉ុន្តែ ដីកសិកម្មមួយភាគធំដែលមិនប្រើប្រាស់ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលអាចត្រូវបានដកចេញពីប្រភេទ

ដីនេះ។ លើសពីនេះទៀត មួយផ្នែកធំនៃដីសាធារណៈរបស់រដ្ឋត្រូវបានបង្វែរទៅជាដីកសិកម្មរួចហើយ។

- **ការធ្វើវិចារណកម្មដីសម្បទានសេដ្ឋកិច្ចៈ** ច្បាប់ភូមិបាលកំណត់ទំហំដីសម្បទានត្រឹម ១០,០០០ ហិកតា។ ដីសម្បទានសេដ្ឋកិច្ចត្រូវបានផ្ដល់ចំពោះតំបន់ដីព្រៃរបស់រដ្ឋ។ សម្បទានទាំងនេះមិនបានរកប្រាក់ចំណូលច្រើនដល់រដ្ឋនោះទេ។
- **ការផ្ដល់ដីដល់កសិករដែលគ្មានដីដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចតាមរយៈការអនុវត្តអនុក្រឹត្យស្ដីពីសម្បទានដីសង្គមកិច្ចៈ** វិធានការនេះនឹងដោះស្រាយបញ្ហាកសិករគ្មានដីធ្លី និងជំរុញការប្រើប្រាស់ដីមិនបានប្រើប្រាស់ឱ្យមានផលិតភាព។
- **ជំរុញការអភិវឌ្ឍដីនិងផលិតភាពនៃការវិនិយោគៈ** ការប្រើប្រាស់ដីត្រូវតែផ្សារភ្ជាប់នឹងការអភិវឌ្ឍនៅថ្នាក់មូលដ្ឋាន។ ដើម្បីធានាបាននូវចីរភាពនៃការអភិវឌ្ឍ និងផលិតភាពនៃការវិនិ-យោគលើហេដ្ឋារចនាសម្ព័ន្ធថ្នាក់មូលដ្ឋាន (ការកសាងផ្លូវ ទំនប់ទឹក ប្រឡាយទឹកសាលារៀន និងមន្ទីរពេទ្យ) ការផ្ដល់ដីដល់កសិករត្រូវធ្វើឡើងទន្ទឹមគ្នា។
- **ការអភិវឌ្ឍធនធានមនុស្សៈ** មូលដ្ឋានជំនាញរបស់មន្ត្រីរដ្ឋបាលដីធ្លីត្រូវតែពង្រឹងបន្ថែមទៀតទាំងក្នុងផ្នែកបច្ចេកទេស ផ្នែកច្បាប់ ការគ្រប់គ្រង និងការត្រួតពិនិត្យ។
- • **ការគ្រប់គ្រងធនធានធម្មជាតិឱ្យបានល្អជាងមុនៈ** គំនិតផ្ដួចផ្ដើមនេះនឹងប្រមូលផ្ដុំលើការអភិវឌ្ឍប្រព័ន្ធកម្មសិទ្ធិដីធ្លីប្រកបដោយនវានុវត្ត សម្រាប់ធានាថាក្នុងរយៈពេលវែងគ្រួសារតាមជនបទនឹងមានការលើកទឹកចិត្តគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងដីធ្លី ទឹក និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

## ៩.៦. កំណែទម្រង់ការគ្រប់គ្រងធនធានទឹក

ទឹកគឺជាសមាសធាតុយុទ្ធសាស្ត្រក្នុងកម្មវិធីទំនើបកម្មកសិកម្ម។ ការប្រើប្រាស់ពូជល្អ និង ប្រើប្រាស់ជីអាចនឹងទទួលទិន្នផលល្អ ដរាបណាមានទឹកគ្រប់គ្រាន់សមរម្យ ទៅតាមពេលវេលាដែលត្រូវការ។ ដោយសារតែមូលហេតុនេះ ការគ្រប់គ្រងធនធានទឹក ប្រព័ន្ធស្រោចស្រព ការគ្រប់គ្រងទឹកជំនន់ ប្រព័ន្ធទឹកស្អាត និងលក្ខខណ្ឌអនាម័យ សុទ្ធតែជាកត្តាសំខាន់ដល់ការអភិវឌ្ឍវិស័យជនបទនៅក្នុងប្រទេសកម្ពុជា។

ការធ្វើផែនការ និងការគ្រប់គ្រងធនធានទឹកក្នុងអាងស្តុកទឹកទន្លេមានសារៈសំខាន់ណាស់ដើម្បីធានានូវចីរភាពនៃការប្រើប្រាស់ធនធានទឹកជាប្រយោជន៍ដល់សហគមន៍មូលដ្ឋាន។ អាងទន្លេត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃការគ្រប់គ្រងទឹក នៅក្នុងប្រព័ន្ធគ្រប់គ្រងធនធានទឹកបែបសមាហរណកម្ម។ ការគ្រប់គ្រងទឹកជំនន់ទន្លេទាមទារជាចាំបាច់នូវការសម្របសម្រួល និងរដ្ឋបាលមួយ ដែលអាចជឿជាក់បាន ជាពិសេសការបំពាក់ហេដ្ឋារចនាសម្ព័ន្ធមានតម្លៃខ្ពស់ដូចជា ប្រព័ន្ធទំនប់វារីអគ្គិសនី ប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់ទឹក។ល។ តាមទស្សនៈបច្ចេកទេស សេដ្ឋកិច្ច និងបរិស្ថាន យុទ្ធសាស្ត្រស្រោចស្រពតាមអភិក្រមនៃការគ្រប់គ្រងទឹកជំនន់ទន្លេ គឺជា«ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៃធនធានទឹក និងដីសម្រាប់ផលិតកម្មកសិកម្មនៅតំបន់ទាំងនោះ»។ ប្រការនេះទាមទារការចូលរួមពីរដ្ឋាភិបាលថ្នាក់កណ្ដាល អ្នកប្រើប្រាស់ទឹក និងគ្រប់ភាគីពាក់ព័ន្ធនៅក្នុងអាងទន្លេទាំងអស់ ដើម្បីធ្វើផែនការ និងអនុវត្ត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាគឺៈ (១) រៀបចំរចនាសម្ព័ន្ធ និងពង្រីកប្រព័ន្ធធារាសាស្ត្រ (២) ការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព តាមរយៈការប្រើប្រាស់ឱ្យមានប្រសិទ្ធភាព នូវប្រព័ន្ធដែលមានស្រាប់ (៣) អភិវឌ្ឍ និងជំរុញប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកនៅក្នុងសហគមន៍កសិកម្ម និង (៤) កាត់បន្ថយភាពងាយរងគ្រោះនៃសហគមន៍ចំពោះគ្រោះធម្មជាតិ និងការពឹងផ្អែកទៅលើលក្ខខណ្ឌអាកាសធាតុ។

រាជរដ្ឋាភិបាលនឹងចាត់វិធានការដូចខាងក្រោមដើម្បីធានាឱ្យមានការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់សម្រាប់ការធ្វើស្រែចម្ការៈ

- **រៀបចំអភិក្រមសមាហរណកម្មមួយសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹកនិងកសិកម្ម** ដែលគិតគូរអំពីធនធានទឹកសរុប ទៅនឹងទំនាក់ទំនងរវាងធនធានទឹក ផលិតកម្មកសិកម្ម ការប្រើប្រាស់និងគ្រប់គ្រងដីធ្លីនិងបរិស្ថាន និងការប្រើប្រាស់បច្ចេកវិទ្យាគ្រប់គ្រងត្រឹមត្រូវ ជាពិសេសនៅតំបន់កសិកម្មដែលរងផ្ទៃទឹកភ្លៀងតិច។ ការប្រើប្រាស់ទឹកក្រោមដីនៅតំបន់រងទឹកជំនន់នឹងត្រូវធ្វើនិយ័តកម្មដោយហ្មត់ចត់។ ការបង្កការខូចខាតផ្នែកអេកូឡូស៊ី និងការបំពុលទឹកទន្លេនិងបឹង តាមរយៈការប្រើប្រាស់សារធាតុគីមី ក៏ដូចជាការបំពុលផ្សេងៗទៀត គឺជាកង្វល់មួយដ៏ធំដែលត្រូវដោះស្រាយ នៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាលស្តីពីសមាហរណកម្មនៃការប្រើប្រាស់ធនធានទឹក។
- **កំណត់ក្របខណ្ឌនៃផែនការអភិវឌ្ឍរយៈពេលខ្លី មធ្យម និងវែង** សម្រាប់ការគ្រប់គ្រងផ្ទៃទឹកជំនន់ទន្លេ ដោយគិតគូរពិចារណាលើការផ្លាស់ប្តូរប្រព័ន្ធជលសាស្ត្រ ជាពិសេស លំហូរទឹកទន្លេ និងកម្រិតស្រទាប់ថ្មឬដី ក្នុងគោលបំណងធានាប្រសិទ្ធភាព និងចីរភាពនៃការប្រើប្រាស់ធនធានទឹក។ ផែនការនេះនឹងផ្តោតការយកចិត្តទុកដាក់ជាពិសេសលើសមាហរណកម្មនៃការគ្រប់គ្រងទន្លេមេគង្គ ទន្លេសាប ដៃទន្លេនានា ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ដើម្បីបង្កើតទិន្នន័យធនធានតម្រូវការ និងការប្រើប្រាស់ទឹក។ ជាផ្នែកមួយនៃការធ្វើផែនការ ចាំបាច់ត្រូវមានបញ្ជីសារពើភណ្ឌការវិភាគដីកសិកម្ម និងការវិភាគធនធានទឹក ដើម្បីអាចកំណត់មុខដំណាំតាមតំបន់កសិកម្ម។ ការធ្វើដូចនេះ អនុញ្ញាតឱ្យមានការពង្រីកប្រព័ន្ធធារាសាស្ត្របន្ថែម ដោយប្រើប្រាស់ប្រព័ន្ធធារាសាស្ត្របង្ហូរទៅតំបន់ក្រីក្រ។
- **ការពង្រីកប្រព័ន្ធធារាសាស្ត្រ** ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើទឹកភ្លៀងក្នុងវិស័យកសិកម្ម ដោយការសាងសង់ទំនប់ ប្រឡាយមេ និងប្រឡាយបង្ហូរ។ គំនិតផ្តួចផ្តើមនេះនឹងផ្តល់អាទិភាពដល់ការស្តារ និងកសាងឡើងវិញនូវបណ្តាញធារាសាស្ត្រដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទឹកជាបន្ទាន់នៃវិស័យកសិកម្ម។
- **ពង្រីកការស្តុកទឹកនៅលើដីនិងប្រព័ន្ធចែកចាយ** ដូចជា អាងស្តុកនិងបឹងប្រឡាយប្រព័ន្ធបង្ហូរ ដែលសមស្របទៅនឹងចីរភាពបរិស្ថាន។
- **ជំរុញប្រព័ន្ធធារាសាស្ត្រខ្នាតតូច៖** ការពង្រីកប្រព័ន្ធធារាសាស្ត្រខ្នាតតូច គឺជាផ្នែកសំខាន់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទសមាហរណកម្ម ដែលរាជរដ្ឋាភិបាលព្យាយាមសម្រេចអោយបាន។ ចីរភាពនៃគំនិតផ្តួចផ្តើមនេះនឹងត្រូវបានកែលម្អ ប្រសិនបើភាគីទទួលផលទាំងអស់ចូលរួមគ្នារ៉ាប់រងទៅលើការចំណាយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **ពង្រឹងសមាគមអ្នកប្រើប្រាស់ទឹក៖** ដើម្បីធានាបានប្រសិទ្ធភាពនៃការបែងចែកនិងការប្រើប្រាស់ទឹក ប្រតិបត្តិការនិងការថែទាំប្រព័ន្ធធារាសាស្ត្រនៅថ្នាក់មូលដ្ឋាននឹងត្រូវផ្តល់ទៅឱ្យក្រុមនិងសមាគមន៍អ្នកប្រើប្រាស់ទឹក ដែលរស់នៅផ្ទាល់ក្នុងសហគមន៍ជនបទនោះ។

- **កៀរគរកម្លាំងពលកម្មដើម្បីកសាងមូលដ្ឋានជនបទ៖** ផ្លូវថ្នល់ បណ្តាញធារាសាស្ត្រ និងសមាសធាតុផ្សេងទៀតនៃហេដ្ឋារចនាសម្ព័ន្ធ មានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍជនបទ។ កសិករ និងភាគីពាក់ព័ន្ធដទៃទៀត ក៏ដូចជាផ្នែកឯកជនត្រូវកៀរគរចូលរួមនៅគ្រប់ដំណាក់កាលទាំងការរចនា ការអភិវឌ្ឍ និងការកែលម្អប្រព័ន្ធធារាសាស្ត្រ ។ ចំពោះករណីប្រឡាយធារាសាស្ត្រ ឬការកសាងផ្លូវថ្នល់ អាចជួយដល់ការបង្កើនទិន្នផលដីដែលនៅជិតនឹងប្រឡាយ ឬសម្រាប់ថ្នល់ផ្តល់នូវភាពងាយស្រួលទៅទីផ្សារសម្រាប់កសិផលដែលផលិតនៅក្បែរផ្លូវថ្នល់។ ដីដែលនៅឆ្ងាយពីប្រឡាយ ឬផ្លូវថ្នល់នឹងផ្តល់ប្រាក់ចំណេញតិច ឬមិនចំណេញតែម្តង។ ប៉ុន្តែការលើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍ជនបទទាំងមូលលើគម្រោងនេះ ទើបអាចទទួលបានជោគជ័យ។

- **ការលើកកម្ពស់ការទទួលបានទឹកស្អាតសម្រាប់សហគមន៍ជនបទ៖** ដើម្បីឆ្លើយតបទៅនឹងគោលដៅនេះ ត្រូវជីកអណ្តូងថ្មីៗ ត្រូវជួសជុលអណ្តូងដែលចាស់ៗ ត្រូវសាងសង់អាងស្តុកទឹកថ្មីៗ និងត្រូវស្តារអាងស្តុកទឹកចាស់ ។

## ៩.៧. ការបង្កើននិងពិពិធកម្មប្រាក់ចំណូលជនបទ

ការអភិវឌ្ឍការងារក្រៅពីវិស័យកសិកម្មនៅជនបទ គឺជាអន្តរាគមន៍ជាយុទ្ធសាស្ត្រក្នុងការកាត់បន្ថយភាពក្រីក្រ។ គំនិតផ្តួចផ្តើមសំខាន់ៗ រួមមាន៖

- **ការលើកស្ទួយផលិតកសិកម្មមិនមែនជាប្រពៃណី** សម្រាប់ការនាំចេញ តាមរយៈការបង្កើននិងធ្វើពិពិធកម្មប្រាក់ចំណូលរបស់កសិករ។

- **ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ផលិតផលមានលក្ខណៈពិសេសសម្រាប់នាំចេញ** និងម្យ៉ាងទៀត បង្កើនការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក។ ដើម្បីសម្រេចបានការងារនេះ ចាំបាច់ត្រូវដោះស្រាយបញ្ហាដោយឡែកពីគ្នាក្នុងផលិតកម្ម និងការធ្វើទីផ្សារ ចំពោះផលិតផលនីមួយៗ ដូចជាស្រូវ ត្រី សត្វពាហនៈ និងកៅស៊ូ ។

- **ការផ្លាស់ប្តូរពីវិស័យកសិកម្មសម្រាប់ហូប បែបឯករប្បកម្ម** ទៅជាការផលិតកសិផលបែបពិពិធកម្ម និងអាចលក់បាននៅទីផ្សារ។

- **ការកែច្នៃផលិតផលកសិកម្ម** និងការសម្របសម្រួលស្វែងរកទីផ្សារទាំងក្នុងស្រុក និងបរទេស។

- **ការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងស្រុក** ដើម្បីគាំទ្រដល់សហគ្រាសខ្នាតមីក្រូ ឬខ្នាតតូចនៅជនបទ។

- **ការបង្កើតជីផ្សារប្រកួតប្រជែងមួយ** ដែលក្នុងនោះឧស្សាហកម្មជនបទអាចរីកលូតលាស់បានល្អ ដោយរួមទាំងការបង្កើនលទ្ធភាពទទួលបានសេវាកម្មហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(ជំនួយបច្ចេកទេស ការបណ្តុះបណ្តាល ព័ត៌មានទីផ្សារ ការគាំទ្រផ្នែកបច្ចេកទេស) និងការកសាងសមត្ថភាពរបស់អង្គការសាធារណៈនិងឯកជន ដែលគាំទ្រដល់សហគ្រាសខ្នាតមីក្រូទាំងនោះ។

## ៩.៨. ការកាត់បន្ថយភាពងាយរងគ្រោះនៃសកម្មភាពកសិកម្ម

ក្នុងប្រទេសកម្ពុជា ការធ្វើកសិកម្មពឹងផ្អែកទៅលើរបបទឹកភ្លៀងល្អទាន់ពេលវេលា និងគ្រប់គ្រាន់។ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ ដែលប្រឈមមុខជាមួយគ្រោះថ្នាក់ធម្មជាតិជាប្រចាំ រាជរដ្ឋាភិបាលនឹងចាត់វិធានការដូចខាងក្រោម៖

- រៀបចំការសិក្សាមួយស្តីអំពីការស្តារ និងការកសាងឡើងវិញនៃប្រព័ន្ធការពារទឹកជំនន់ ទំនប់ទឹក និងប្រព័ន្ធបង្ហៀរ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះថ្នាក់ធម្មជាតិជាអតិបរមា។
- ក្រសួងធនធានទឹកនិងឧតុនិយមនឹងត្រូវកសាងសមត្ថភាពបន្ថែម ដើម្បីជំរុញឱ្យមានការផ្សព្វផ្សាយរបាយការណ៍អាកាសធាតុបច្ចុប្បន្នភាព និងកាត់បន្ថយភាពងាយរងគ្រោះពីទឹកជំនន់៖ បង្កើតនូវប្រព័ន្ធតាមដានអាកាសធាតុមួយ ដែលប្រមូលទិន្នន័យអាកាសធាតុបច្ចុប្បន្នភាព (Real Time) សម្រាប់ការព្យាករណ៍អាកាសធាតុសាស្ត្រ ផ្តល់ព័ត៌មានអាកាសធាតុកសិកម្ម ការព្យាករណ៍ពីទឹកជំនន់។ល។, ផ្លាស់ប្តូរសម្ភារបរិក្ខារកត់ត្រាទិន្នន័យជលវិទ្យា ឧតុនិយម និងកម្ពស់ទឹកភ្លៀង នៅស្ថានីយ៍ជលវិទ្យា ឧតុនិយមសាស្ត្រ និងស្ថានីយកត់ត្រាកម្ពស់ទឹកភ្លៀងនៅតាមដងទន្លេនិងនៅតាមទីតាំងដទៃទៀត, ប្រមូលនិងផ្សព្វផ្សាយទិន្នន័យ, បង្កើតការអង្កេតផ្នែកជលវិទ្យាដែលនឹងផ្សព្វផ្សាយព័ត៌មានបច្ចុប្បន្នភាពស្តីអំពីកម្ពស់និងលំហូរទឹកទន្លេ, និង ប្រើប្រាស់ទិន្នន័យជលសាស្ត្រសម្រាប់ការរៀបចំគម្រោងធនធានទឹក និងការគ្រប់គ្រងធនធានទឹក។
- ការកសាងសមត្ថភាព សម្រាប់ការឆ្លើយតបរហ័សក្នុងការជួយដល់សហគមន៍ដែលរងគ្រោះពីការរាំងស្ងួត ទឹកជំនន់ និងហានិភ័យអាកាសធាតុដទៃទៀត ដើម្បីកាត់បន្ថយផលប៉ះពាល់ពីគ្រោះធម្មជាតិ។
- ការពង្រឹងសហប្រតិបត្តិការណ៍ជាមួយគណៈកម្មាធិការទន្លេមេគង្គ (Mekong River Commission) និងជាមួយកម្មវិធីគ្រប់គ្រងទឹកជំនន់អន្តរជាតិនានា លើការកាត់បន្ថយការរងគ្រោះនៃទឹកជំនន់។

## ៩.៩. ការចូលទីផ្សារក្នុងក្របខ័ណ្ឌតំបន់ភាវូបនីយកម្មពាណិជ្ជកម្ម

ការចូលទៅក្នុងទីផ្សារតំបន់ គឺជាធាតុផ្សំដ៏សំខាន់នៃទិសដៅថ្មីនៃការអភិវឌ្ឍវិស័យកសិកម្ម។ ដើម្បីទទួលបានផលប្រយោជន៍ពីពាណិជ្ជកម្មតំបន់ កម្ពុជាត្រូវតែធានានូវភាពប្រកួតប្រជែងនៅក្នុងខ្សែសង្វាក់ផលិតកម្ម និងខ្សែសង្វាក់តម្លៃ ហើយត្រូវដោះស្រាយនូវឧបសគ្គផ្សេងៗ រួមទាំងកង្វះខាតហិរញ្ញប្បទាន និងវិវាទដីធ្លី។ ការចូលរួមកាន់តែជ្រៅទៅក្នុងពាណិជ្ជកម្មតំបន់មានន័យថា៖

- **ការពង្រីកផលិតកម្មកសិកម្មតាមកិច្ចសន្យា** សម្រាប់ផលិតផលកសិកម្មសរីរាង្គដូចជា អង្ករ ពោត និងថ្នាំជក់ ហើយកំណត់គោលដៅទីផ្សារនាំចេញពិសេសៗ។
- **ការស្វែងរក និងលើកស្ទួយការនាំចេញផលិតផលថ្មីៗ** ដូចជាសណ្តែកសៀង គ្រាប់ស្វាយចាន់ទី និងផលិតផលសូត្រ។

- **ការរៀបចំយុទ្ធសាស្ត្រ** ប្រកួតប្រជែងជាមួយកសិផលនាំចូល។ គំនិតផ្តួចផ្តើមទាំងនោះរួមមានការបង្កើតខ្សែក្រវាត់ពណ៌បៃតង (Green belt) នៅជុំវិញខេត្តសៀមរាប និងទីក្រុងភ្នំពេញដើម្បីធ្វើការប្រកួតប្រជែងជាមួយទំនិញកសិកម្ម ដែលនាំចូលពីប្រទេសជិតខាងនាពេលបច្ចុប្បន្ននេះ។
- **ការកសាងសមត្ថភាពប្រកួតប្រជែងនៃផលិតផលកសិកម្ម:** វិធានការសំដៅកែលម្អប្រព័ន្ធប្រមូលផល និងជម្នះឧបសគ្គនានាពាក់ព័ន្ធនឹងពាណិជ្ជកម្ម រួមបញ្ចូលទាំង គុណភាពកសិផល ការបន្ថយការខាតបង់ក្រោយពេលប្រមូលផល ការកែលម្អស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ និងសេវាគាំទ្រផ្សេងៗ ការពង្រឹកប្រព័ន្ធចែកចាយ និងការកាត់បន្ថយចំណាយអាជីវកម្មដែលមិនចាំបាច់។
- **ការសម្របសម្រួលផ្នែកពាណិជ្ជកម្ម:** វិធានការនានារួមមាន ពន្លឿននិងធ្វើសុខដុមនីយកម្មឯកសារការនាំចូលនិងនាំចេញតាមបទដ្ឋានអន្តរជាតិ, ពិនិត្យលទ្ធភាពប្រើប្រាស់ប្រតិវេទសន៍សាមញ្ញ, កែលម្អនីតិវិធីពន្ធគយ តាមរយៈវិធីសាស្ត្រដូចជា ការវាយតម្លៃហានិភ័យ, ពន្លឿននីតិវិធីនាំចូល និងលើកកម្ពស់តម្លាភាព និងបង្កើតឱ្យមាននីតិវិធីប្តឹងជំទាស់ទៅនឹងវិធានការ និងការសម្រេចចិត្តផ្នែកពន្ធគយ។
- **ពង្រីងសេវាកម្មដឹកជញ្ជូនការស្តុកទុកនិងការរកទីផ្សារ** សម្រាប់ផលិតផលកសិកម្ម ដោយរួមមានការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងកន្លែងផ្ទុកព្រមទាំងការបង្កើតទីផ្សារលក់ដុំនៅតាមតំបន់ព្រំដែនដែលអនុញ្ញាតឱ្យកសិករកម្ពុជាមានទំនាក់ទំនងជាមួយទីផ្សារក្នុងតំបន់និងពិភពលោក។
- **ការពង្រឹងសេវាកម្មកិច្ចការទីផ្សារនិងព័ត៌មាន** ដើម្បីធ្វើឱ្យសញ្ញាណទំនាក់ទំនងប្រសើរជាងមុនពីទីផ្សារពិភពលោកទៅដល់កសិករអ្នកដឹកជញ្ជូនអ្នកកែច្នៃមន្ត្រីទីផ្សារហិរញ្ញវត្ថុនានានិង
- **ការបង្កើតការិយាល័យវិញ្ញាបនបត្រទំនិញនាំចេញ** (Export Products Certification Bureau) និងមន្ទីរពិសោធន៍មួយដើម្បីពិសោធន៍គុណភាព និង ការបង្កើតនិយាមអនាម័យនិងភូតាមអនាម័យ (Phytosanitary) សម្រាប់ផលិតផលកសិកម្ម។

## ៩.១០. កំណែទម្រង់ការគ្រប់គ្រងព្រៃឈើ

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវក្របខណ្ឌ សម្រាប់ការគ្រប់គ្រងព្រៃសម្បទាន ដូចខាងក្រោម៖

- ប្រតិបត្តិការនៃព្រៃសម្បទានអាចធ្វើទៅបាន លុះត្រាតែមានផែនការយុទ្ធសាស្ត្រគ្រប់គ្រងព្រៃសម្បទាន ដោយរួមទាំងការវិភាគអំពីផលប៉ះពាល់ដល់បរិស្ថាននិងសង្គម ហើយទទួលបានការអនុម័ត អនុលោមទៅតាមអនុក្រឹត្យស្តីអំពីការគ្រប់គ្រងព្រៃសម្បទាន។
- ឯកសារទាំងនេះត្រូវផ្សព្វផ្សាយជាសាធារណៈ និងត្រូវអញ្ជើញអ្នកឯកទេសឯករាជ្យអោយចូលរួមត្រួតពិនិត្យផែនការយុទ្ធសាស្ត្រ និងរបាយការណ៍អំពីផលប៉ះពាល់ មុនពេលរាជរដ្ឋាភិបាលផ្តល់ការសម្រេចចិត្តចុងក្រោយ។
- ព្រៃសម្បទានដែលមិនមានផែនការយុទ្ធសាស្ត្រនឹងត្រូវបានដកហូតយកមកវិញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាការឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា អនុក្រឹត្យស្តីអំពីការអភិវឌ្ឍព្រៃសហគមន៍ត្រូវបានប្រកាសអោយប្រើប្រាស់កាលពីខែធ្នូ ឆ្នាំ២០០៣ ដោយដាក់ព្រៃឈើសាធារណៈក្រោមការដឹកនាំរបស់សហគមន៍មូលដ្ឋាន ដោយមានផែនការគ្រប់គ្រងរួមគ្នា និងកិច្ចព្រមព្រៀងផ្តល់ប្រយោជន៍គ្នាទៅវិញទៅមក។ រាជរដ្ឋាភិបាលបានធ្វើការក្នុងភាពជាដៃគូជាមួយម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន លើការអភិវឌ្ឍព្រៃសហគមន៍ដោយដាក់ចេញនូវការសាកល្បងគំនិតផ្តួចផ្តើមនានា ក្នុងទីតាំងមួយចំនួនទូទាំងប្រទេស។ មកដល់ពេលបច្ចុប្បន្ននេះ ផ្ទៃដីជិតដប់មួយម៉ឺនហិចតាត្រូវបានបង្កើតឡើងនៅក្រោមក្របខណ្ឌនៃកិច្ចព្រមព្រៀងអភិវឌ្ឍព្រៃសហគមន៍។

ដើម្បីលើកស្ទួយការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកត្តាអាទិភាពដូចខាងក្រោម៖

- **ការពង្រឹងការគ្រប់គ្រងនិងការការពារព្រៃឈើ**: (១) ធ្វើសនិទានកម្ម និងធ្វើចំណាត់ថ្នាក់ព្រៃឈើដែលនៅសល់ ដើម្បីធានាអោយបាននូវការការពារផ្នែកបរិស្ថាន និងការអភិរក្សជីវចម្រុះ ដោយការដាក់អោយប្រើប្រាស់និងជំរុញអនុក្រឹត្យស្តីអំពីការធ្វើចំណាត់ថ្នាក់ព្រៃឈើ (២) ការជំរុញអោយអនុវត្តនូវបទបញ្ញត្តិព្រៃឈើ ជាពិសេសបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ បបចុះថ្ងៃទី ៩ ខែមិថុនាឆ្នាំ២០០៤ ស្តីអំពីវិធានការលុបបំបាត់ការកាប់បំផ្លាញព្រៃឈើនិងអាជីវកម្មព្រៃឈើ (៣) ការពង្រឹងយុទ្ធសាស្ត្រការពារដូចជា៖ តំបន់ព្រៃការពារ ការគ្រប់គ្រងតំបន់ផ្ទៃរងទឹកភ្លៀង ការចងក្រងសេនេទិច និងការការពារពពួកសត្វជិតផុតពូជ ការអភិវឌ្ឍអេកូទេសចរណ៍ និងគម្រោងការពារផ្សេងៗទៀត ដោយមានការចូលរួមពីសហគមន៍ដោយមានផែនការគ្រប់គ្រងច្បាស់លាស់ (៤) អនុវត្តអោយម៉ឺងម៉ាត់នូវបទបញ្ញត្តិគ្រប់គ្រងព្រៃឈើ ដោយរួមទាំងការប្រើប្រាស់ដោយចីរភាពនូវធនធាន និង សម្បទានព្រៃឈើ និង (៥) បើកយុទ្ធនាការអប់រំ និងលើកកម្ពស់ការយល់ដឹងស្តីអំពីបញ្ហាព្រៃឈើ។
- **សនិទានកម្មនៃការប្រើប្រាស់ព្រៃឈើ**: (១) វាយតម្លៃគម្របព្រៃដោយរួមទាំងតំបន់ការពារ ដើម្បីកំណត់អត្តសញ្ញាណតំបន់ព្រៃឈើដែលត្រូវថែរក្សាជាសម្បត្តិរបស់រដ្ឋ (២) ធានាប្រសិទ្ធភាពនៃការការពារដល់ជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (៣) កំណត់អត្តសញ្ញាណតំបន់ព្រៃឈើដែលអាចឱ្យសហគមន៍គ្រប់គ្រង និងតំបន់ដែលអាចប្រែក្លាយទៅជាផ្ទៃដីកសិកម្មនិង (៤) គូសផែនទីព្រៃឈើ ដែលបង្ហាញពីព្រំដែននិងសន្និធិនៃតំបន់ព្រៃឈើ។
- **ការចូលរួមចំពោះការអភិវឌ្ឍសេដ្ឋកិច្ចសង្គម**: (១) គូសរំលេចពីផលប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមចំពោះការអភិរក្សព្រៃឈើនិងជីវចម្រុះ (២) លើកស្ទួយការដាំដុះព្រៃបែបឧស្សាហកម្មជំនួសអោយព្រៃធម្មជាតិ ដោយលើកទឹកចិត្តអោយមានការវិនិយោគពីឯកជននិងការចូលរួមពីសហគមន៍ (៣)រៀបចំយន្តការអុបទីម៉ាល់សម្រាប់ការប្រើប្រាស់ការកែច្នៃនិងការធ្វើទីផ្សារនៃផលិតផលព្រៃឈើ ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងស្រុកនិងការនាំចេញ និង (៤) លើកស្ទួយអោយមានការដាំដើមឈើឡើងវិញ។
- **ការចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ**:(១)ពង្រឹងការការពារផ្លូវច្បាប់ចំពោះសិទ្ធិរបស់សហគមន៍ ក្នុងការគ្រប់គ្រងព្រៃដែលពួកគេរស់នៅ ដើម្បីធានាបាននូវសន្តិសុខស្បៀង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាហារ និងជំរុញការកាត់បន្ថយភាពក្រីក្រ។ សិទ្ធិទាំងអស់នោះត្រូវបានការពារនៅក្រោមច្បាប់ព្រៃឈើនិងបទបញ្ញត្តិពាក់ព័ន្ធដទៃទៀត (២) ធានាថាសហគមន៍មូលដ្ឋានទទួលផលប្រយោជន៍ពីការប្រើប្រាស់ និងការគ្រប់គ្រងធនធានព្រៃឈើទាំងនោះ។

- **ការកសាងសមត្ថភាពនិងអភិបាលកិច្ចល្អ**: (១) តាមដានការពង្រឹងសមត្ថភាពស្ថាប័នគ្រប់កម្រិតទាំងអស់ (២) បើកយុទ្ធនាការអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងក្នុងចំណោមសហគមន៍មូលដ្ឋាន ដើម្បីលើកទឹកចិត្តអោយមានការចូលរួមរបស់សហគមន៍ក្នុងការការពារ និងគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព (៣) ពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើគ្រប់កម្រិតទាំងអស់ក្នុងការអនុវត្តតួនាទី ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗ និង(៤) ពង្រឹងការប្រមូលប្រាក់ចំណូលពីព្រៃឈើ។

## ៩.១១. ការលើកស្ទួយដំណាំកៅស៊ូ

ជាប្រពៃណី កៅស៊ូគឺជាកសិផលឧស្សាហកម្មដែលដាំសម្រាប់លក់ ដាំនៅលើដីសម្បទានធំរបស់រដ្ឋក្នុងគោលដៅនាំចេញ ប៉ុន្តែដំណាំកៅស៊ូកំពុងតែជាជម្រើសដ៏ទាក់ទាញមួយសម្រាប់ម្ចាស់ដីខ្នាតតូច នៅក្នុងតំបន់ទាំងឡាយណា ដែលសមស្របសម្រាប់ការដាំកៅស៊ូ។ រាជរដ្ឋាភិបាលចាត់ទុកដំណាំកៅស៊ូ គឺជាប្រភពមួយផ្សេងទៀតក្នុងការលើកកម្ពស់ជីវភាពរស់នៅក្នុងកម្រិតគ្រួសារ។ ចម្ការកៅស៊ូរបស់រដ្ឋក៏បានអនុវត្តនូវកម្មវិធីនានា ដើម្បីជំនួសដើមកៅស៊ូចាស់ដែលមានអាយុច្រើនដោយប្រើដើមកៅស៊ូថ្មីដែលនាំមកនូវទិន្នផលខ្ពស់។

គំនិតផ្តួចផ្តើមសំខាន់ៗក្នុងការផ្សព្វផ្សាយពីដំណាំកៅស៊ូគឺ៖

- **ការអភិវឌ្ឍចម្ការកៅស៊ូជាប្រព័ន្ធ៖** ប្រការនេះរួមមាន (១) ការកៀងគរការវិនិយោគទុនធំៗដែលមិនអាចអនុវត្តបាន តាមរយៈប្រភពទុនរបស់សហគ្រាសរដ្ឋបច្ចុប្បន្នឬ តាមរយៈថវិកាជាតិ (២) ការសិក្សាអំពីដីដែលសមរម្យសម្រាប់ការដាំដើមកៅស៊ូ និង (៣) ការផ្គត់ផ្គង់កូនកៅស៊ូ ដែលមានទិន្នផលខ្ពស់។
- **ពង្រីកកម្មោភាពនៃការបណ្តាក់ទុនឯកជនក្នុងចម្ការកៅស៊ូរដ្ឋ៖** គំនិតផ្តួចផ្តើមនេះមានគោលបំណងពង្រឹងនូវការគ្រប់គ្រងក្រុមហ៊ុនរដ្ឋ និងទាក់ទាញការវិនិយោគឯកជនទៅលើចម្ការកៅស៊ូដែលមានស្រាប់។
- **ការពង្រីកនិងការពង្រីកចម្ការកៅស៊ូគ្រួសារ៖** ប្រការនេះគួរត្រូវបានអនុវត្តជាដំបូង ដោយការបណ្តុះបណ្តាលបច្ចេកទេសដល់អ្នកដាំដុះខ្នាតតូច ភាពអាចរកបាននៃការផ្គត់ផ្គង់ហិរញ្ញវត្ថុ ការផ្សព្វផ្សាយបច្ចេកវិទ្យានិងព័ត៌មានស្តីអំពីនិន្នាការទីផ្សារកៅស៊ូ និងការកសាងសមត្ថភាពក្នុងការគ្រប់គ្រងចម្ការកៅស៊ូ និងបច្ចេកវិទ្យានៃការដាំដំណាំកៅស៊ូ។
- **ការពង្រីកនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា៖** ជាពិសេសការជ្រើសរើសពូជកៅស៊ូ ដែលមានទិន្នផលខ្ពស់ និងលូតលាស់ឆាប់រហ័ស ព្រមទាំងប្រើប្រាស់បច្ចេកវិទ្យាថ្មីនិងការបង្កើតមន្ទីរពិសោធន៍ ដើម្បីបង្កើនស្តង់ដារទិន្នផលកម្រិតអន្តរជាតិ។

- **ការជំរុញសហប្រតិបត្តិការអន្តរជាតិលើផលិតកម្មកៅស៊ូ៖** គំនិតផ្តួចផ្តើមនេះគឺដើម្បីពង្រឹងសហប្រតិបត្តិការត្រីភាគីជាមួយប្រទេសបារាំង ប្រទេសថៃ និងបណ្តាប្រទេសសមាជិកដទៃទៀតនៃក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍ដំណាំកៅស៊ូអន្តរជាតិ (International Rubber Research and Development Board) និងសមាគមកៅស៊ូអន្តរជាតិ (International Rubber Association) ដើម្បីបង្កើនគុណភាពនៃកៅស៊ូកម្ពុជា និងលើកស្ទួយដល់ទំនើបភាវូបនីយកម្មនៃឧស្សាហកម្មកែច្នៃ។ល។

## ៩.១២. ការស្តារឡើងវិញនូវវិស័យជលផល

ជាមួយនឹងគោលដៅស្តារឡើងវិញនូវវិស័យជលផល រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំផែនការមេមួយនៅឆ្នាំ២០១១ ដែលផែនការនេះនឹងដើរតួនាទីបង្គោលធៀប (Benchmark) សម្រាប់ការអភិវឌ្ឍក្នុងវិស័យជលផល។ ដំណោះស្រាយត្រូវបានរៀបចំតាមដំណាក់កាលៗទៅតាមវដ្តនៃវិស័យជលផល រួមមានការនេសាទ ប្រតិបត្តិការទិញលក់ ការកែច្នៃ និងការធ្វើទីផ្សារ។ ផែនការមេនោះនឹងលើកឡើងអំពី៖

- **ការអភិវឌ្ឍសហគមន៍នេសាទ៖** ដោយការផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន ដើម្បីលើកស្ទួយការចូលរួមរបស់កសិករដោយសកម្ម ដោយផ្ទាល់ និងដោយសមធម៌ នៅក្នុងការរៀបចំផែនការ ការអនុវត្ត និងការគ្រប់គ្រងកម្មវិធីនេសាទ។
- **ការបង្វែរឡូត៍នេសាទ៖** ដែលកិច្ចសន្យាសម្បទានអស់សុពលភាព ទៅជាជម្រកត្រីបម្រុងដើម្បីបង្កើនសន្និធិត្រី និងការពារប្រភេទត្រីជិតផុតពូជ។
- **ការជំរុញឡូត៍នេសាទសហគមន៍៖** ផ្សារភ្ជាប់នឹងការលើកកម្ពស់វារីវប្បកម្ម ដើម្បីឆ្លើយតបទៅនឹងតម្រូវការកំពុងកើនឡើង និងដើម្បីបន្ថយសម្ពាធលើធនធានជលផលនៅក្នុងដែនជម្រកធម្មជាតិ។
- **ការកំណត់ព្រំដែនឡូនេសាទ៖** កំណត់អត្តសញ្ញាណ និងការពារសុវត្ថិភាព និងគ្រប់គ្រងតំបន់ទាំងនោះ ប្រឆាំងនឹងការនេសាទខុសច្បាប់។។
- **ការគ្រប់គ្រងចីរភាព និងស្តារធនធានជលផល៖** ប្រការនេះនឹងរួមបញ្ចូល (១) ការទទួលបាននូវតម្លៃជាអតិបរមាពីធនធាន (២) ការធានានូវចំណេះដឹងបច្ចេកទេស គ្រប់គ្រាន់ក្នុងវិជ្ជាជីវៈនៅក្នុងវិស័យជលផលនិង (៣) ការធ្វើឱ្យប្រសើរឡើងនិងទំនើបភាវូបនីយកម្ម នៃ របៀបនេសាទបែបបុរាណ។
- **ការកសាងសមត្ថភាពស្រាវជ្រាវនៃវិទ្យាស្ថានស្រាវជ្រាវនិងការអភិវឌ្ឍជលផលទឹកសាប៖** Inland Fisheries Research and Development Institute) ដែលត្រូវបានបង្កើតឡើងនៅក្នុងខែកុម្ភៈឆ្នាំ២០០៣ ដើម្បីលើកស្ទួយការគ្រប់គ្រងការនេសាទ និងលើកស្ទួយលទ្ធភាពទទួលបានចំណេះដឹង និងចំណេះថ្មីៗទំនើបៗ ដល់សាធារណៈជនទូទៅសហគមន៍ និងជាពិសេសអ្នកនេសាទ។
- **ការប្រើប្រាស់ធនធានជលផលប្រកបដោយសនិទានកម្ម និងការទទួលខុសត្រូវ៖** ការការពារធនធានជលផលឱ្យប្រសើរជាងមុន និងការលើកស្ទួយបរិស្ថានស្ថាប័នឱ្យសមស្របទៅនឹងតម្រូវការអភិវឌ្ឍនៃវិស័យជលផល និងរក្សាតុល្យការផ្នែកសហប្រតិបត្តិការអន្តរជាតិ។ គំនិតផ្តួចផ្តើមនេះមានបំណងធានាអោយបាននូវការគ្រប់គ្រងនៃធនធានប្រកបដោយចីរភាព និងភាពរីក

លូតលាស់នៃផ្នែកជលផល ដែលអាចឆ្លើយតបបានទៅនឹងតម្រូវការក្នុងស្រុកចំពោះជលផល ការកែលម្អនិងទំនើបភាវូបនីយកម្មលក្ខខណ្ឌ ដែលអាចឱ្យការនេសាទបែបបុរាណអាចប្រតិបត្តិបានទទួលបានតម្លៃខ្ពស់ជាងមុនពីផលិតកម្ម និងអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញប្បទានប្រកបដោយចីរភាពមួយសម្រាប់វិស័យជលផល។

- **ការអភិវឌ្ឍវារីវប្បកម្មខ្នាតតូច** ដើម្បីបង្កើនចំណូលរបស់កសិករ។

## ៩.១៣. ការបង្កើតលក្ខខណ្ឌកំណើនខ្ពស់និងមានចីរភាពក្នុងអនុវិស័យចិញ្ចឹមសត្វ

ភាគច្រើននៃការសត្វចិញ្ចឹម ដូចជា គោក្របី ជ្រូក មាន់ ទា ត្រូវបានចិញ្ចឹមដោយកសិករខ្នាតតូចដើម្បីសម្រាប់ហូបតាមគ្រួសារ។ វិធានការរយៈពេលខ្លី និងមធ្យម ដើម្បីគាំទ្រការចិញ្ចឹមសត្វរួមមាន៖

- **ការអភិវឌ្ឍប្រព័ន្ធចិញ្ចឹមសត្វចម្រុះ៖** ដែលរួមមាន (១) ការរៀបចំហេដ្ឋារចនាសម្ព័ន្ធអោយបានគ្រប់គ្រាន់ (២) ចាត់វិធានការប្រឆាំងជំងឺរាតត្បាត ដើម្បីបង្កើនគុណភាពគោក្របី និងការគ្រប់គ្រងជំងឺ (៣) ការពង្រឹងនាយកដ្ឋានត្រួតពិនិត្យសុខភាព និងអធិការកិច្ច (៤) ផលិតកម្មចំណីសត្វ និងចំណីត្រី ព្រមទាំងការកែច្នៃសាច់សត្វ និងសាច់ត្រី អោយទៅជាផលិតផល (៥) ការបង្កើនចំនួនបុគ្គលិកពេទ្យសត្វ ដើម្បីកាត់បន្ថយអត្រាងាប់ និងការឆ្លងរោគ និង (៦) ការធ្វើប្រព្រឹត្តកម្ម និងការកែច្នៃអនុផលសត្វពាហនៈ។
- **ការលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជន៖** សម្រាប់ការចាប់ផ្តើមអាជីវកម្មខ្នាតធំដំបូង ទាំងការចិញ្ចឹមគោ ក្របី ជ្រូក និងមាន់ទា។
- **ការដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធ៖** រួមមាន (១) ផ្នែកបច្ចេកទេស ពិសេស ជម្ងឺមួយចំនួនបន្តមានអត្ថិភាពជាប្រចាំ កង្វះខាតស្មៅ និងប្រភពទឹក (អនុផលកសិកម្ម និងចំណីសត្វមិនអាចបំពេញតួនាទីជំនួសស្មៅបានទេ ដោយសារតែតម្លៃខ្ពស់ និង (២) ផ្នែកហិរញ្ញវត្ថុ ទាំងផ្នែកសាធារណៈ និងទាំងផ្នែកឯកជន ការវិនិយោគសាធារណៈទៅលើអនុផ្នែកចិញ្ចឹមសត្វនេះ នៅមានតិចតួចណាស់។
- **ចំណងជាក់ដងដៅក្នុងខ្សែច្រវាក់សាច់សត្វ៖** ដូចជាការបង្កាត់ពូជដែលមានវដ្តចិញ្ចឹមខ្លី (សត្វទំពារអៀង និងមាន់ទាក្នុងស្រុក) ការធានាការផ្គត់ផ្គង់ចំណីសត្វ ការធ្វើប្រព្រឹត្តកម្ម និងការកែច្នៃអនុផលសត្វពាហនៈ (ស្បែក ស្នែង ។ល។)។
- **ការពង្រីកការស្តារឡើងវិញនៃឧស្សាហកម្មសូត្រ៖** ការយកចិត្តទុកដាក់នឹងត្រូវធ្វើឡើងតាមរយៈការដាក់អោយប្រើប្រាស់បច្ចេកទេសទំនើបក្នុងការចិញ្ចឹមដង្កូវនាង និងឧបករណ៍តម្បាញដែលល្អប្រសើរជាងមុន។ អ្នកចិញ្ចឹមដង្កូវនាងខ្នាតតូចគួរទទួលបានការបណ្តុះបណ្តាលអំពីការដាំដើមមន។

## ៩.១៤. ការកសាងសមត្ថភាពស្ថាប័ន

យុទ្ធសាស្ត្រកំណែទម្រង់វិស័យកសិកម្មរៀបចំបានល្អ ប៉ុន្តែការអនុវត្តកាន់តែអសកម្មខ្លាំងឡើង។ កំណែទម្រង់បានដោះស្រាយបញ្ហាយន្តការទីផ្សារ កម្មសិទ្ធិដីធ្លីនិងសន្តិសុខនៃការកាន់កាប់សេរីភាវូបនីយកម្មតម្លៃ និងការអនុម័តច្បាប់ស្តីអំពីការបង្កើតវិនិយោគចម្រុះរវាងរដ្ឋ និងវិនិយោគិនបរទេស។ ក្រសួងកសិកម្មរុក្ខា

ប្រមាញ់និងនេសាទត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ ដោយមានជំនួយពីដៃគូអភិវឌ្ឍនានា។ ពូជស្រូវ ដែលសមរម្យសម្រាប់កម្ពុជាត្រូវបានធ្វើអត្តសញ្ញាណ ហើយការស្រាវជ្រាវនិងការផ្ទេរចំណេះធ្វើទៅដល់កសិករកំពុងត្រូវបានពន្លឿន។ ទោះបីយ៉ាងណា មានតម្រូវការក្នុងការកសាងសមត្ថភាពបន្ថែមទៀត ដើម្បីជំរុញផលិតភាពទៅដល់ស្តង់ដារតំបន់។

ផែនការសកម្មស្តីអំពីការកសាងសមត្ថភាពនឹងរួមបញ្ចូលនូវធាតុផ្សំដូចខាងក្រោម៖

- **ការពន្លឿនល្បឿនការងារ និងការកសាងសមត្ថភាពស្ថាប័ន៖** ស្របជាមួយនឹងគំនិតផ្តួចផ្តើមច្របាច់ការសម្របសម្រួលបញ្ចូលគ្នារវាងក្រសួងពាក់ព័ន្ធផ្សេងៗ ដើម្បីធានាការអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ដែលត្រូវបានអនុម័តថ្មីៗអាចសម្រេចទៅបាន។ វិធានការទាំងអស់នេះក៏មានគោលបំណងផងដែរដើម្បី (១) កសាងសមត្ថភាពស្ថាប័នក្នុងការធ្វើវិមជ្ឈការស្ថាប័នរដ្ឋដើម្បីបម្រើសហគមន៍ជនបទ និងគាំទ្រដល់ស្ថាប័នជនបទ (២) កសាងសមត្ថភាពនៅថ្នាក់មូលដ្ឋាន ដើម្បីអោយសហគមន៍ជនបទចេះកំណត់អាទិភាពរបស់ខ្លួន និងអាចទទួលបានជំនួយទៅតាមសេចក្តីត្រូវការរបស់ពួកគេ និង (៣)ជំរុញការគាំទ្រស្ថាប័នដល់ភ្នាក់ងារអាជីព ដែលលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្ម និងបង្កើតឱ្យមានការច្នៃផលិតផលនៅថ្នាក់ភូមិ (តាមទស្សនទាន "ភូមិមួយ ផលិតផលមួយ")។
- **ពិនិត្យឡើងវិញអំពីតួនាទីនិងការទទួលខុសត្រូវនៃស្ថាប័នសាធារណៈ៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ផ្តោតការយកចិត្តទុកដាក់លើការផ្គត់ផ្គង់ទំនិញសាធារណៈមិនត្រូវធ្វើអន្តរាគមន៍ដោយផ្ទាល់ទៅលើផលិតកម្មការចែកចាយធាតុចូល និងការលក់កសិផលនោះទេ។ ការវិភាគតាមមុខងារចាំបាច់ត្រូវធ្វើ ដើម្បីកំណត់អោយច្បាស់នូវតួនាទីនិងការទទួលខុសត្រូវរបស់ស្ថាប័នសាធារណៈ។
- **ការតម្រង់ប្រភពហិរញ្ញវត្ថុទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម៖** ការអភិវឌ្ឍជនបទ និងកសិកម្មកំពុងឋិតនៅពីក្រោយវិស័យអាទិភាពដទៃទៀត ដូចជាវិស័យអប់រំ និងសុខាភិបាលសាធារណៈ ។ ដរាបណាមានការកែលម្អការគាំទ្រផ្នែកគោលនយោបាយសារពើពន្ធ និងការគ្រប់គ្រងក្នុងវិស័យនេះ នោះនឹងស្ថិតនៅលើផ្លូវត្រូវ។
- **កំណែទម្រង់សហគ្រាសរដ្ឋ៖** សហគ្រាសរដ្ឋភាគច្រើនមិនមានការទទួលខុសត្រូវគ្រប់គ្រាន់ក្នុងការអនុវត្តនូវតួនាទីនៅឡើយ។ ដូច្នេះ ត្រូវពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ចរបស់សហគ្រាសរដ្ឋ ដើម្បីអោយមានសមត្ថភាពប្រកួតប្រជែងនឹងក្រុមហ៊ុនឯកជន។
- **ការកសាងសមត្ថភាពនៃមន្ត្រីរាជការក្នុងវិស័យកសិកម្ម៖** មន្ត្រីរាជការគួរត្រូវបានបណ្តុះបណ្តាលផ្នែកវិភាគ និងការរៀបចំគោលនយោបាយកសិកម្ម ការវិភាគអំពីសេដ្ឋកិច្ច-សង្គម និងការវិនិយោគ ការគ្រប់គ្រងធនធានធម្មជាតិ ការធ្វើទីផ្សារកសិផល និងការធ្វើពាណិជ្ជកម្មអន្តរជាតិ។
- **ការពង្រឹងស្ថាប័នសហគមន៍កសិករ៖** សកលភាវូបនីយកម្មនៃពាណិជ្ជកម្មជាបញ្ហាប្រឈមរបស់កសិករខ្នាតតូច។ ស្ថាប័នអង្គការកសិករចាំបាច់ត្រូវពង្រឹងបន្ថែម ដើម្បីអាចជួយដល់កសិករខ្នាតតូច ក្នុងការធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវផ្នែកផលិតកម្ម និងការលក់កសិផល ហើយអាចអោយអង្គការកសិករអាចពឹងពាក់ខ្លួនឯង និងមានចំណេះដឹងក្នុងស្វែងរកផលប្រយោជន៍ដល់សមាជិករបស់ពួកគេ។

- **ការផ្តល់អំណាចដល់កសិករ៖** ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃសកលភាវូបនីយកម្ម និងការពារផលប្រយោជន៍របស់ខ្លួន កសិករទាំងអស់ត្រូវធ្វើការរួមគ្នានៅក្នុងគ្រប់ទិដ្ឋភាពនៃផ្នែកផលិតកម្ម និងខ្សែច្រវាក់តម្លៃ ដូចជា ការទិញជីដុំ ការប្រវាស់សម្ភារៈ កសិកម្ម ការចែករំលែកព័ត៌មានកសិកម្ម ការកែច្នៃនិងការធ្វើទីផ្សារកសិផល។

## ៩.១៥. ការលើកកម្ពស់ការអភិវឌ្ឍជនបទចម្រុះនិងការបើកចំហរតំបន់ជនបទ

កង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសផ្លូវថ្នល់ បង្កអោយមានឧបសគ្គយ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍតំបន់ជនបទ ដោយសារតែបញ្ហានៃការស្តុកទុក និងការដឹកជញ្ជូនផលិតផល។ អាស្រ័យហេតុនេះ ការវិនិយោគអោយបានគ្រប់គ្រាន់លើហេដ្ឋារចនាសម្ព័ន្ធមានភាពចាំបាច់ ដើម្បីលើកស្ទួយសុខុមាលភាពប្រជាជនជនបទ ទាំងតាមរយៈគំនិតផ្តួចផ្តើមសាធារណៈ និងឯកជន។ ក៏ប៉ុន្តែដើម្បីអោយហេដ្ឋារចនាសម្ព័ន្ធផ្តល់អត្ថប្រយោជន៍បានពេញលេញ ចាំបាច់ត្រូវអភិវឌ្ឍន៍តាមអភិក្រមចម្រុះ។ ធាតុផ្សំនៃការអភិវឌ្ឍចម្រុះ គឺបញ្ចូលសេវាថែទាំសុខភាព ការកសាងផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម សេវាឥណទាន ការផ្គត់ផ្គង់ធាតុចូល និងការធ្វើទីផ្សារ។ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពដល់គំនិតផ្តួចផ្តើមនៅក្រោមការលើកកម្ពស់ការអភិវឌ្ឍចម្រុះ ដូចខាងក្រោម៖

- **ការកែលម្អផ្លូវថ្នល់ទៅសហគមន៍ជនបទ៖** ការកសាងផ្លូវជនបទនឹងជួយបង្កើនផលិតកម្មកសិកម្ម ទាំងតាមរយៈការពង្រីកផ្ទៃដីអាចដាំដុះ ឬទាំងការធ្វើប្រពលវប្បកម្មនៃការប្រើប្រាស់ដីដែលមានស្រាប់ ដែលនឹងអនុញ្ញាតអោយកសិករទទួលបានផលប្រយោជន៍ពីទីផ្សារថ្មីៗ និងច្របាច់បញ្ចូលគ្នាទំនាក់ទំនងនានារវាងសកម្មភាពកសិកម្ម និងក្រៅពីកសិកម្មនៅក្នុងតំបន់ជនបទ ព្រមទាំង រវាងតំបន់ជនបទ និងតំបន់ទីក្រុង។
- **ការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ចជនបទ៖** ដែលនឹងរួមចំណែកដល់ជីវភាពរស់នៅនៃសេដ្ឋកិច្ចជនបទ។ ប្រការនេះរួមមាន អគ្គិសនីភាវូបនីយកម្មជនបទ និងការផ្គត់ផ្គង់សេវាសង្គមបន្ថែម ដែលនឹងទាក់ទាញធនធានមនុស្សមានសមត្ថភាពចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងអនុញ្ញាតអោយសហគមន៍ជនបទអាចទទួលបានការអប់រំ ការថែទាំសុខភាព និងទឹកស្អាតប្រសើរជាងមុន។
- **ការបន្តនៃកម្មវិធីស្បៀងពលកម្ម៖** កម្មវិធីទាំងនេះមានសារសំខាន់ទាំងសម្រាប់ការស្តារ និងការថែរក្សាផ្លូវជនបទ រួមមានផ្លូវក្រាលគ្រួសក្រហម និងផ្លូវដី ព្រមទាំងធានាអោយមានការងារក្រៅកសិកម្ម ដែលចូលរួមចំណែកដល់សន្តិសុខស្បៀងនៅជនបទ។ កម្មវិធីទាំងនេះមានអត្ថប្រយោជន៍បន្ថែមទៀតក្នុងការបង្កើតយន្តការសង្គមប្រកបដោយអត្ថន័យល្អ ដើម្បីបង្វែរធនធានទៅអោយអ្នកក្រីក្របំផុតក្នុងចំណោមអ្នកក្រីក្រនៅក្នុងសង្គម។
- **ការកសាងសមត្ថភាពរបស់រដ្ឋក្នុងការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ៖** ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មដើរតួនាទីយ៉ាងសំខាន់ នៅក្នុងក្របខណ្ឌនៃប្រព័ន្ធអភិវឌ្ឍជនបទចម្រុះ។ ដើម្បីទទួលបាននូវជោគជ័យ រាជរដ្ឋាភិបាលត្រូវផ្តល់ធនធានចាំបាច់ ដែលជាចំណាយប្រចាំរបស់មន្ត្រីផ្សព្វផ្សាយ ដើម្បីអោយពួកគេអាចចល័ត និងមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់កសិករ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **ការសម្របសម្រួលបញ្ចូលគ្នានៃគម្រោងអភិវឌ្ឍ៖** ស្ថាប័ននិងក្រសួងប្រតិបត្តិត្រូវរៀបចំវេទនាសម្ព័ន្ធអោយបានល្អជាងមុន ដើម្បីធានាបានជោគជ័យនៃការអនុវត្តរួមបញ្ចូលគ្នាចំពោះគម្រោងអភិវឌ្ឍជនបទ។
- **ការលើកកម្ពស់ការយល់ដឹងរបស់សាធារណៈជន៖** ពាក់ព័ន្ធទៅនឹងកង្វះខាតអាហាររូបឧត្ថម្ភ កង្វះខាតជាតិដែក របបអាហារកុមារ និងអំបិលអ៊ីយ៉ូត តាមរយៈសិក្ខាសាលា កម្មវិធីបណ្តុះបណ្តាល និងគំនិតផ្តួចផ្តើមផ្សព្វផ្សាយដទៃទៀត។ មានបញ្ហានៅសល់ជាច្រើនដែលត្រូវដោះស្រាយ នៅក្នុងនោះ ផលិតកម្មអំបិលអ៊ីយ៉ូតក្នុងស្រុកគ្រប់ដណ្តប់ត្រឹមតែ២០% នៃតម្រូវការសរុបទូទាំងប្រទេស, មានកុមារអាយុពី ៦ដល់ ៥៩ខែ ត្រឹមតែ ៣៥% ប៉ុណ្ណោះដែលទទួលវីតាមីន A បន្ថែម, ហើយចំនួនម្តាយដែលអាចទទួលបាននូវការបន្ថែមជាតិដែកមានកម្រិតទាបណាស់ គឺត្រឹមតែ ២% ប៉ុណ្ណោះ។

## ៩.១៦. ការអភិវឌ្ឍប្រព័ន្ធហិរញ្ញប្បទានក្នុងសហគមន៍ជនបទ

ការពង្រឹងធនាគារជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍជនបទរបស់រាជរដ្ឋាភិបាល។ ដៃម្ខាងរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការផ្តល់ឥណទានដល់ផ្នែកឯកជន គឺធនាគារអភិវឌ្ឍន៍ជនបទ ដែលទទួលមូលនិធិពីថវិការដ្ឋ។ ក៏ប៉ុន្តែ ជាផ្នែកមួយនៃយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកំពុងលើកទឹកចិត្តដល់គ្រឹះស្ថានហិរញ្ញវត្ថុឯកជន ជាពិសេសគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អោយពង្រីកសកម្មភាពនៅតំបន់ជនបទ។ គំនិតផ្តួចផ្តើមសំខាន់ៗនៅក្នុងវិស័យហិរញ្ញវត្ថុជនបទរួមមាន៖

- **ការបង្កើតនិងការពង្រីងប្រសិទ្ធភាពបណ្តាញហិរញ្ញវត្ថុឯកជន៖** ពិសេសពិនិត្យ លទ្ធភាពកៀរគរប្រាក់សន្សំក្នុងស្រុក និងផ្តល់ឥណទានដោយប្រើប្រាស់វិធីសាស្ត្រថ្មីៗ ទៅដល់សហគមន៍ និងក្រុមនានាក្នុងតំបន់ជនបទ។ ប្រការនេះនឹងសម្រួលអោយមានអន្តរការីកម្មដីធ្លី និងបង្កើនការវិនិយោគលើវិស័យកសិកម្ម។
- **ការពង្រីកការគ្របដណ្តប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដល់កសិករ៖** ដើម្បីបង្កើនផលិតកម្ម និងសម្រួលដល់ការកែច្នៃកសិផល។
- **បុនហិរញ្ញប្បទាន (Re-financing) កម្ចីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដល់កសិករ៖** ដើម្បីបន្ទាបអត្រាការប្រាក់ទាបឱ្យទាបជាងអត្រាទីផ្សារក្រៅផ្លូវការ។
- **ការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម៖** អង្គការKfWកំពុងផ្តល់ជូននូវជំនួយឥតសំណងតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវទឹកប្រាក់ប្រហែលប្រាំបីលានដុល្លារ សម្រាប់កម្មវិធីអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម។ ធនាគារអភិវឌ្ឍន៍ជនបទបានផ្តល់ប្រាក់កម្ចីនៅក្រោមគំនិតផ្តួចផ្តើមនេះ ទៅដល់ធនាគារពាណិជ្ជដែលជាដៃគូ ផ្តល់ទៅអោយអ្នកខ្ចីចុងក្រោយ សម្រាប់ការអនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាតសាកល្បងនៅខេត្តតាកែវ។
- **ការលើកទឹកចិត្តធនាគារអភិវឌ្ឍជនបទអោយផ្តល់ឥណទានក្រៅដែនកំណត់នៃមូលនិធិខ្វះ៖** ដោយការផ្តល់ហិរញ្ញប្បទានរយៈពេលមធ្យម និង រយៈពេលវែងដល់អាជីវកម្មខ្នាតមីក្រូ ក្នុងអត្រាការប្រាក់ទាបសមរម្យ។

- **ការលើកទឹកចិត្តដល់ធនាគារ** អោយវិនិយោគលើការផ្គត់ផ្គង់ទឹកស្អាត និងអគ្គិសនីជនបទ និងលើសកម្មភាពកសិកម្មសម្រាប់ចំណីអាហារ។

## ៩.១៧. ការអភិវឌ្ឍផ្នែកឯកជននិងការចោរក្រៅកសិកម្មនៅទីជនបទ

ផ្នែកឯកជនគឺជាអ្នកទទួលផលដ៏សំខាន់នៃការអភិវឌ្ឍវិស័យកសិកម្ម ដូចនេះឯកជនត្រូវចូលរួមក្នុងការអភិវឌ្ឍនេះអោយបានទូលំទូលាយ។ ប៉ុន្តែផលវិនិយោគឯកជនក្នុងវិស័យនេះ មិនមានលក្ខណៈប្រាកដប្រជា ដោយផ្អែកលើហេតុផលមួយចំនួន ជាពិសេស កង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងស្ថាប័ន, ភាពទន់ខ្សោយនៃយន្តការច្បាប់និងនីតិប្រតិបត្តិ និងថ្លៃអគ្គិសនីខ្ពស់។ ដើម្បីលើកកម្ពស់ការវិនិយោគឯកជនក្នុងវិស័យកសិកម្ម គំនិតផ្តួចផ្តើមខាងក្រោមនេះកំពុងត្រូវបានអនុវត្តៈ

- **ការកែលម្អបរិយាកាសធុរកិច្ច** ដើម្បីទាក់ទាញវិនិយោគឯកជនក្នុងវិស័យកសិកម្ម។
- **ការអភិវឌ្ឍបច្ចេកវិទ្យា** និងការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាទាំងនោះអោយបានឆាប់រហ័សនៅក្នុងផលិតកម្មកសិកម្ម និងប្រព័ន្ធកែច្នៃ។
- **ការលើកស្ទួយគំនិតផ្តួចផ្តើម "ភូមិមួយ ផលិតផលមួយ"** ដើម្បីញ៉ាំងអោយមានគំនិតច្នៃប្រឌិត និងស្តារទំនុកចិត្តរបស់សហគមន៍ជនបទ។ គោលនយោបាយនេះផ្អែកទៅលើ (១) ជំរុញប្រើប្រាស់វិធីសាស្ត្រផលិតកម្មដែលសមស្របទៅតាមបរិស្ថាន និងតម្រូវការទីផ្សារ (២) សម្របសម្រួលកំណត់ពីទីផ្សារហិរញ្ញប្បទាននិងបច្ចេកទេសសមស្រប(៣)ការគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្ស និងការបណ្តុះបណ្តាលផ្នែកគ្រប់គ្រង និង (៤) ការសម្របសម្រួលបង្កើតសហគមន៍កសិកម្ម ដើម្បីលើកស្ទួយស្ថិរភាពតម្លៃកសិផល។
- **ការចាត់វិធានការកាត់បន្ថយថ្លៃដើមផលិតកម្ម** ជាពិសេសចំណាយក្នុងការដឹកជញ្ជូន និងថ្លៃអគ្គិសនី និង
- **ការពង្រឹងការគាំទ្រដល់សេវាសារវ័ន្ត** ដូចជាការកែលម្អលទ្ធភាពចូលទីផ្សារ និងការស្រាវជ្រាវព័ត៌មាន និងការរៀបចំអោយមានកិច្ចសហការរវាងកសិករនិងកសិករ។

## ៩.១៨. និរន្តរភាពនៃគម្រោងដែលឧបត្ថម្ភដោយម្ចាស់ជំនួយ

កម្មវិធីនានារបស់ម្ចាស់ជំនួយនៅក្នុងវិស័យនេះបានជួយកែលម្អការអនុវត្តនៅក្នុងវិស័យ ប៉ុន្តែដើម្បីទទួលបាននូវអត្ថប្រយោជន៍ជាអតិបរមាពីជំនួយទាំងអស់នេះ កម្មវិធីទាំងអស់នោះគប្បីត្រូវកែតម្រង់អោយបានជិតស្និតថែមទៀតស្របទៅនឹងអាទិភាព និងយុទ្ធសាស្ត្រនៅក្នុងវិស័យនេះ។ ការពិនិត្យឡើងវិញរហ័សអំពីកម្មវិធីរបស់ម្ចាស់ជំនួយក្នុងវិស័យកសិកម្មបង្ហាញដូចខាងក្រោមៈ

- **កម្មវិធីប្រាសាក់** (PRASAC) **ផ្តល់មូលនិធិដោយសហគមន៍អឺរ៉ុបៈ** កម្មវិធីនេះជាប់ទាក់ទងនឹងការវិនិយោគធំក្នុងវិស័យអាទិភាពនានា (ទឹកស្អាតតាមភូមិ ធារាសាស្ត្រ ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងឥណទាន) នៅក្នុងខេត្តចំនួនប្រាំមួយ។ ហានិភ័យនៅក្នុងគម្រោងនេះគឺនិរន្តរភាពនៃគំនិតផ្តួចផ្តើម រួមទាំងការប៉ាន់ស្មានទាបពេកពីតម្លៃថែរក្សា និងគ្រប់គ្រងហេដ្ឋារចនា-សម្ព័ន្ធ (ឧទាហរណ៍ ផ្នែកធារាសាស្ត្រ)។ បញ្ហានិរន្តរភាពមួយផ្សេងទៀតជាប់ពាក់ព័ន្ធទៅនឹងសមត្ថភាពរបស់ក្រសួងនានា ក្នុងការបន្តអនុវត្តគំនិតផ្តួចផ្តើមទាំងអស់នេះក្រោយពេលគម្រោងត្រូវបានបញ្ចប់។

- **កម្មវិធីកែលម្អផលិតភាពកសិកម្ម៖** ដែលទទួលមូលនិធិពីធនាគារពិភពលោក និងអង្គការ IFAD។ គោលបំណងនៃគម្រោងនេះ គឺអភិវឌ្ឍសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំផែនការ ការអភិវឌ្ឍ និងការអនុវត្តកម្មវិធីកសិកម្មនិងជនបទ។ ការយកចិត្តទុកដាក់នៃគម្រោងនេះ គឺការផ្តល់មូលនិធិដល់ការបណ្តុះបណ្តាលបុគ្គលិកនិងមន្ត្រី ក្នុងការសាងសង់ ឬការស្តារអគារ ការផ្គត់ផ្គង់បរិក្ខារ និងការផ្តល់ការគាំទ្រក្នុងការផ្តល់កម្ចី។ កម្មវិធីនេះកំពុងជួបប្រទះនូវបញ្ហាលំបាកក្នុងការអភិវឌ្ឍ ដោយសារការិយាល័យធិបតេយ្យ អសមត្ថភាពក្នុងសម្របសម្រួលរវាងសមាសភាពផ្សេងៗគ្នា និងកង្វះការគាំទ្ររបស់នាយកដ្ឋានមួយចំនួន។ កង្វះខាតនៃការសម្របសម្រួលរវាងថ្នាក់កណ្តាល និង ថ្នាក់ខេត្ត គឺជាបញ្ហាប្រឈមដ៏ចម្បងសម្រាប់ការអនុវត្ត និងការត្រួតពិនិត្យសកម្មភាព។
- **គម្រោង AQIP ឧបត្ថម្ភដោយទីភ្នាក់ងារសហប្រតិបត្តិការអូស្ត្រាលី** (AusAID)៖ មានគោលបំណងកែលម្អសន្តិសុខស្បៀង និងប្រាក់ចំណូលសម្រាប់កសិករ។ គម្រោងនេះមានប្រាំមួយសមាសភាព ដែលមានឈ្មោះដូចជា៖ ផលិតកម្មពូជស្រូវ បច្ចេកវិទ្យាក្រោយការប្រមូលផល ការធ្វើទីផ្សារបន្លែនិងផ្លែឈើ ការស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រ (តាមរយៈការផ្តល់មូលនិធិស្តារប្រឡាយទឹកតូចៗ ព្រមទាំងការបង្កើតសហគមន៍អ្នកប្រើប្រាស់ទឹក ដើម្បីគ្រប់គ្រងនិងថែរក្សា) និងការបណ្តុះបណ្តាល (តាមរយៈ ការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់កម្មវិធី "សាលាស្រែកសិករ") និងការគ្រប់គ្រងគម្រោង។ បទពិសោធន៍ដែលបានទទួលពីគម្រោងនេះ បានរួមចំណែកដល់ការធ្វើអោយប្រសើរឡើងដល់ការរៀបចំផែនការអភិវឌ្ឍន៍ថ្នាក់ភូមិ។
- **កម្មវិធីគ្រប់គ្រងសត្វល្អិតបែបចម្រុះ** (The Integrated Pest Management Program=IPM)៖ ដែលត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីអង្គការ FAO ដោយប្រើអភិក្រមបណ្តុះបណ្តាលកសិករតាមរបៀប "សាលាស្រែកសិករ"។ វិធីសាស្ត្រនេះ រួមមានការអង្កេតរបស់កសិករនៅលើវាលស្រែ ការបង្កើតគម្រោងសាកល្បង និងការផ្លាស់ប្តូរព័ត៌មានជាបន្តបន្ទាប់អំពីលទ្ធផល និងមធ្យោបាយនៃការគ្រប់គ្រង។ ប្រព័ន្ធនេះផ្អែកលើវិធីសាស្ត្រពីក្រោមឡើងលើ ហើយមិនស្ថិតនៅក្រោមគោលនយោបាយជាតិស្តីអំពីការផ្សព្វផ្សាយបច្ចេកទេស ដែលមានកំណត់គោលដៅជាមុននោះទេ។ វិធីសាស្ត្រ IPM រួមជាមួយបណ្តាញនៃអ្នកពាក់ព័ន្ធដែលមានកង្វល់រួម ទទួលបានការបណ្តុះបណ្តាល ក្នុងការដោះស្រាយបញ្ហាបច្ចេកទេសនៅក្នុងកម្រិតវាលស្រែ ព្រមទាំងបច្ចេកទេសនៃការដឹកនាំក្រុម និងផ្តល់ជូននូវមេរៀនដ៏មានតម្លៃសម្រាប់ការរៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្ម។
- **កម្មវិធីសិលា** (Seila)៖ គឺជាកម្មវិធីដែលមានទ្រង់ទ្រាយធំដំបូងគេ (ប្រាំមួយខេត្ត) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៦ ដើម្បីលើកស្ទួយដល់ការអភិវឌ្ឍនៅមូលដ្ឋាន និងស្ថាប័ននៅមូលដ្ឋាន។ នៅពេលចាប់ផ្តើមដំបូង កម្មវិធីនេះគឺជាការដកពិសោធន៍ពីការអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការ ហើយកម្មវិធីបានបង្កើតអោយមាននូវគំរូសម្រាប់អាជ្ញាធរផ្សេងៗ និងដៃគូអភិវឌ្ឍន៍ជាច្រើនក្នុងការរៀបចំគោលនយោបាយនិងកម្មវិធីអភិវឌ្ឍជនបទ។

# ផ្នែកទី ៤
# បញ្ហាប្រឈមនៃឧស្សាហូបនីយកម្ម

ជំពូកទី ១០. ទិដ្ឋភាពទូទៅនៃវិស័យឧស្សាហកម្ម

ជំពូកទី ១១. ការអភិវឌ្ឍវិស័យឯកជន

ជំពូកទី ១២. គោលនយោបាយឧស្សាហកម្ម

# ជំពូកទី ១០
# ទិដ្ឋភាពទូទៅនៃវិស័យឧស្សាហកម្ម

បន្ទាប់ពីទទួលបានឯករាជ្យនៅក្នុងឆ្នាំ១៩៥៣ កម្ពុជាអនុវត្តតាមគំរូសេដ្ឋកិច្ចចម្រុះដែលទាំងទ្រព្យសម្បត្តិរដ្ឋនិងឯកជនត្រូវបានគេទទួលស្គាល់និងអនុញ្ញាតឱ្យមានឡើងទាំងពីរ។ កសិកម្មឧស្សាហកម្មធុនស្រាលនិងសេវាកម្មពាណិជ្ជកម្មត្រូវបានគេទុកឱ្យវិស័យឯកជនចំណែកឯឧស្សាហកម្មធុនធ្ងន់និងហិរញ្ញវត្ថុត្រូវបានគ្រប់គ្រងដោយវិស័យសាធារណៈ។ សហគ្រាសរដ្ឋធំៗត្រូវបានបង្កើតឡើងនៅក្នុងទសវត្សរ៍ទី៦០។ នាពេលនោះកម្ពុជាបានអនុវត្តនយោបាយផលិតកម្មជំនួសការនាំចូលក្នុងឧស្សាហកម្មធុនស្រាលនិងឧស្សាហកម្មកែច្នៃផលិតផលកសិកម្មដែលទទួលបាននូវការការពារយ៉ាងរឹងមាំពីឧបត្ថម្ភធនរដ្ឋនិងជារឿយៗបានទទួលការអនុញ្ញាតឱ្យដំណើរការជាលក្ខណៈផ្តាច់មុខ។

## ១០.១. សហគ្រាសរដ្ឋ

រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៧៩បានទទួលមរតកពីរបបខ្មែរក្រហមនូវសេដ្ឋកិច្ចមួយដែលទ្រព្យសម្បត្តិឯកជនត្រូវបានបំផ្លាញចោលជាមួយនិងរចនាសម្ព័ន្ធផលិតកម្មភាគច្រើនស្ថិតក្នុងភាពហិនហោច។ សហគ្រាសឧស្សាហកម្មគឺជាទ្រព្យសម្បត្តិរដ្ឋ។ នៅដើមទសវត្សរ៍ទី៨០ ប្រព័ន្ធគ្រប់គ្រងមជ្ឈការត្រូវបានគេប្រែក្លាយឱ្យមានលក្ខណៈបត់បែនបន្តិចម្តងៗ រចនាសម្ព័ន្ធផលិតកម្មមានការវិវឌ្ឍជាមួយនិងទម្រង់ទីផ្សារហើយវិស័យឯកជនដែលត្រូវបានគេទទួលស្គាល់ជាផ្លូវការនៅក្នុងឆ្នាំ១៩៨៥ បានចាប់ផ្តើមមានតួនាទីកាន់តែសំខាន់ឡើងៗនៅក្នុងសេដ្ឋកិច្ច។ ជាមួយការងើបឡើងវិញរបស់វិស័យឯកជននៅដើមឆ្នាំ១៩៨៩ សហគ្រាសឧស្សាហកម្មខ្នាតធំនិងមធ្យមជិត៩០% បានចាប់ផ្តើមធ្វើការផលិតឡើងវិញ។ ទោះបីជាយ៉ាងណាក៏ដោយសហគ្រាសរដ្ឋបានបង្កើតជាចំណុចស្នូលនៃឧស្សាហកម្មកម្ពុជា។

នៅចុងឆ្នាំ១៩៨៩ អាជ្ញាធរសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កើតរបបថ្មីមួយនៃស្វ័យភាពហិរញ្ញវត្ថុសម្រាប់សហគ្រាសរដ្ឋដែលទាមទារឱ្យមានការគ្រប់គ្រងនិងផ្គត់ផ្គង់ហិរញ្ញវត្ថុដោយខ្លួនឯង។ នេះមានន័យថាពួកគេនិងមិនទទួលបានឧបត្ថម្ភធនសម្រាប់ប្រតិបត្តិការនិងមិនមានកម្ចីមូលធនទេ។ ទោះបីជាយ៉ាងណាក៏ដោយគេនឹងរក្សាទុកប្រាក់ចំណេញទាំងអស់ហើយនឹងសងទៅរដ្ឋតែពាក់កណ្តាលនៃបំណុលដែលត្រូវសងជាដំណាក់ដែលគេត្រូវសង។ ពួកគេនឹងខ្ចីពីធនគារតាមអត្រាទីផ្សារសម្រាប់ទុនវិនិយោគនិងតម្រូវការក្នុងការវិនិយោគ។ យោងតាមទ្រឹស្តីនេះ គេនិងដំណើរការដូចអាជីវកម្មពាណិជ្ជកម្មនៅក្នុងសេដ្ឋកិច្ចទីផ្សារដែរ។ លើសពីនេះទៅទៀតគេត្រូវតែបង់ពន្ធដូចអាជីវកម្មឯកជនដែរ។

ចាប់តាំងពីឆ្នាំ១៩៨៩ មករាជរដ្ឋាភិបាលបានប្រកាសកម្មវិធីរដ្ឋមិនពាក់ព័ន្ធនិងឧស្សាហកម្មដែលជាការលើកទឹកចិត្តឱ្យឯកជនភាវូបនីយកម្មនៅក្នុងគ្រប់វិស័យ។ គោលដៅរបស់នយោបាយនេះគឺការផ្តត់ផ្គង់ឱ្យអាជីវកម្មនូវដើមទុនដែលមានភាពចាំបាច់ដើម្បីមានទ្រង់ទ្រាយច្បាស់លាស់ធ្វើទំនើបកម្មនិងពង្រីកឱ្យធំនិងអនុញ្ញាតឱ្យពួកគេទទួលបានវិធីសាស្ត្រគ្រប់គ្រងនិងបច្ចេកទេសទំនើប។ លើសពីនេះទៅទៀតការជួលនិងផ្ទេរអាជីវកម្មគឺជាប្រភពចំណូលថវិកា។

*តារាង១០.១. សហគ្រាសរដ្ឋក្នុងឆ្នាំ២០០៨ (ជាលានរៀល)*

| លរ | ឈ្មោះសហគ្រាស | ទ្រព្យសកម្ម | ទុនផ្ទាល់ខ្លួន | បុគ្គលិក សរុប | ហិរញ្ញវត្ថុ ឆ្នាំ២០០៦ ចំណូលសរុប | ចំណាយ សរុប | ចំណេញ |
|---|---|---|---|---|---|---|---|
| ១ | ក្រុមហ៊ុនជំរុញកសិកម្ម | ២១.៩៤៨ | ២១.២៧៨ | ៤៩ | ២.៨២៧ | ២.៧៧៣ | ៥៤ |
| ២ | កំពង់ផែស្វយ័តក្រុងព្រះសីហានុ | ៩៧៣.១៨៧ | ៩៦៧.០៩៤ | ១.០៣២ | ៩៧.០១៥ | ៨៧.១៨១ | ៩.៨៣៤ |
| ៣ | កំពង់ផែស្វយ័តភ្នំពេញ | ១០៨.៩៧៣ | ១០៥.០១៧ | ៩៦៥ | ១៨.៩៦៩ | ១២.៧៧២ | ៥.៦៩៧ |
| ៤ | ក្រុមហ៊ុនដឹកជញ្ជូនកម្ពុជា | ២៤.៣៨៧ | ២២.៥៧៤ | ១៩៨ | ៩.០៩០ | ៤.៦៣០ | ៤.៤៦០ |
| ៥ | ក្រុមហ៊ុនហ្រ្គីនត្រេដ | ៤៥.២៧២ | ៩១.៨៥០ | ១៩៤ | ៧.១៥២ | ៧.១៨៤ | (៣២) |
| ៦ | ក្រុមហ៊ុនធានារ៉ាប់រងជាតិកម្ពុជា | ៣១.៩៣៣ | ២៩.៩៧០ | ៦០ | ៤.៥៤៧ | ៤.០៤៥ | ៥០២ |
| ៧ | រោងពុម្ព | ២៩.៣៦៧ | ២៩.១៥៤ | ១៤៥ | ១១.០៤៦ | ១០.១៣០ | ៩១៦ |
| ៨ | ទូរគមនាគមន៍កម្ពុជា | ២២៨.៦៣៣ | ១៨៥.៩៣៧ | ៦១៧ | ៨១.៩៨២ | ៥៥.៩៤៧ | ២៦.០៣៥ |
| ៩ | ក្រុមហ៊ុនផ្លូវដែកកម្ពុជា | ៣.៩៥១.៣២៩ | ៣.៩៤៨.១៥៩ | ១.៦០៩ | ៧.៨៣០ | ៩.២៩៤ | (១.៤៦៤) |
| ១០ | មន្ទីរពិសោធន៍វិស្វកម្មនិងសាធារណៈការ | ១.៧១៧ | ១.២៨៣ | ២៤ | ៤២២ | ៥០២ | (៨០) |
| ១១ | អាជ្ញាធររដ្ឋាករទឹកភ្នំពេញ | ៥៥៥.២១៨ | ៤៣៤.៦០៩ | ៥៦៨ | ៧៨.៥១២ | ៥៨.៦៥០ | ១៩.៨៦២ |
| ១២ | អគ្គិសនីកម្ពុជា | ៥៨៩.៤០៤ | ៣៩៨.២៩៧ | ២.១៨០ | ៦១៣.៦០០ | ៦០១.២៥៩ | ១២.៣៤១ |
| ១៣ | ធនាគារអភិវឌ្ឍន៍ជនបទ | ៦៥.០៥៧ | ៣០.៤១៦ | ៤៩ | ៤.០៤៣ | ២.៧០៨ | ១.៣៣៥ |
| | សរុបរួម | ៦.៦៣៥.៥៦៦ | ៦.១៩៥.០២០ | ១៩.១៤៩ | ១.១២៩.៩៣០ | ១.០០៨.៧៦៤ | ១២១.១៦៦ |

*ប្រភព:ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

នាពេលបច្ចុប្បន្ននេះមានសហគ្រាសរដ្ឋជាច្រើនប្រភេទ។ ដោយយោងទៅលើច្បាប់ស្តីអំពីលក្ខណៈទូទៅរបស់សហគ្រាសរដ្ឋដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី១៧ខែមិថុនាឆ្នាំ១៩៩៦ សហគ្រាសរដ្ឋត្រូវបានបែងចែកជាបីប្រភេទ:ក្រុមហ៊ុនរដ្ឋ (ទុនរដ្ឋ១០០%) គ្រឹះស្ថានសាធារណៈដែលមានគោលដៅសេដ្ឋកិច្ចនិងក្រុមហ៊ុនពាក់កណ្តាលសាធារណៈ (អាជីវកម្មរួមគ្នា) ដែលរដ្ឋឬក៏អាជីវកម្មដែលមានទុនសាធារណៈកាន់កាប់ដាច់ដោយឡែកពីគ្នាឬរួមគ្នាជាមួយនឹងស្ថាប័នសាធារណៈដទៃទៀតដែលមានទុនសង្គមនិងសិទ្ធិបោះឆ្នោតជាងពាក់កណ្តាល។

ស្ថាប័នសាធារណៈដែលមានគោលដៅខាងសេដ្ឋកិច្ចគឺជាស្ថាប័នសាធារណៈដែលបង្កើតឡើងស្របច្បាប់ជាមួយនឹងស្វ័យភាពហិរញ្ញវត្ថុដែលអនុវត្តសកម្មភាពជាគោលការណ៍និងផ្តាច់មុខក្នុងការផ្តល់ទំនិញនិងសេវាកម្មដើម្បីលក់។ ក្រុមហ៊ុនរដ្ឋគឺជាក្រុមហ៊ុនដែលដើមទុនគ្រប់គ្រងដោយរដ្ឋ។ លក្ខខណ្ឌដើម្បីបង្កើតក្រុមហ៊ុនរដ្ឋត្រូវបង្កើតឡើងដោយអនុក្រឹត្យតាមរយៈសំណើរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងឬអាជ្ញាធរពាក់ព័ន្ធ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងឆ្នាំ២០០៣ មានសហគ្រាសរដ្ឋចំនួន២៥គ្រឹះស្ថានសាធារណៈចំនួន៥និងក្រុមហ៊ុនពាក់កណ្តាលសាធារណៈចំនួន៩ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាក់ព័ន្ធចំនួន៩និងសាលាក្រុងចំនួន១ គឺកសិកម្មចំនួន១៤ ទូរគមនាគមន៍ចំនួន៧ សាធារណៈការនិងដឹកជញ្ជូនចំនួន៦ ហិរញ្ញវត្ថុចំនួន៤ ឧស្សាហកម្មចំនួន១ ពាណិជ្ជកម្មចំនួន១ អប់រំចំនួន២ សុខាភិបាលចំនួន១ ទីស្តីការគណៈរដ្ឋមន្ត្រីចំនួន១។ ដោយមានកម្រិតសាលារាជធានីមានសហគ្រាសរដ្ឋតែមួយប៉ុណ្ណោះគឺរដ្ឋាករទឹករាជធានីភ្នំពេញ។ នៅក្នុងឆ្នាំ២០០៨ ដោយមានការធ្វើឯកជនភាវូបនីយកម្មចម្ការកៅស៊ូចំនួនសហគ្រាសរដ្ឋបានចុះមកត្រឹម១៣ (តារាង១០.១)។ សហគ្រាសរដ្ឋមានតួនាទីនៅក្នុងវិស័យយុទ្ធសាស្ត្រនានាដូចជាអគ្គិសនីទឹកស្អាតកំពង់ផែសមុទ្រនិងទន្លេ ការធានារ៉ាប់រង ការទិញធានារ៉ាប់រង (reinsurance) ចម្ការកៅស៊ូមន្ទីរពេទ្យទូរគមនាគមន៍និងពាណិជ្ជកម្មខាងផលិតផលកសិកម្ម។

## ១០.២. រចនាសម្ព័ន្ធឧស្សាហកម្ម

ដំណើរការសេដ្ឋកិច្ចរបស់កម្ពុជាមានលក្ខណៈគួឱ្យចាប់អារម្មណ៍ណាស់ នៅចន្លោះឆ្នាំ១៩៩៨-២០០៨។ វិស័យឧស្សាហកម្មគឺជាក្បាលម៉ាស៊ីនយ៉ាងសំខាន់នៃកំណើន។ ផលិតផលក្នុងស្រុកសរុបឧស្សាហកម្មបានកើនឡើងជាមធ្យម១៦% ក្នុងមួយឆ្នាំ។ វិស័យនេះរួមមានជាសំខាន់ អនុវិស័យឧស្សាហកម្ម (៧៨, ៥%)និងអនុវិស័យសំណង់ (១៨,៨%)។

*តារាង១០.២. រចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា (ជាពាន់លានរៀល)*

| | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | % |
|---|---|---|---|---|---|---|---|
| រ៉ែ | ៥៨ | ៧៤ | ៩៧ | ១១៥ | ១៣៥ | ១៦៥ | ២% |
| ឧស្សាហកម្មផលិត | ៣.៣៧៤ | ៤.០២៧ | ៤.៥៨៥ | ៥.៥៤១ | ៦.០៧៤ | ៦.៤៤១ | ៦៩% |
| ម្ហូប ភេសជ្ជៈ ថ្នាំជក់ | ៤៨៨ | ៥០៥ | ៦០៨ | ៦៦៤ | ៧៥៧ | ៩២៤ | ១០% |
| វាយនភណ្ឌ | ២.២៩៤ | ២.៨៤៧ | ៣.១៥៨ | ៣.៨៦៩ | ៤.២៣៤ | ៤.៣១៥ | ៤៦% |
| ឈើ ក្រដាស និងការបោះពុម្ព | ១០៥ | ១១៩ | ១៤៨ | ១៧១ | ២០៣ | ២៣៩ | ៣% |
| ឧស្សាហកម្មផលិតកៅស៊ូ | ១១១ | ១២២ | ១២៦ | ១៤១ | ១៤៨ | ១៥៣ | ២% |
| ឧស្សាហកម្មផលិតដទៃទៀត | ៣៧៧ | ៤៣៣ | ៥៤៥ | ៦៥៧ | ៧៣២ | ៨១១ | ៩% |
| អគ្គិសនី ឧស្ម័ន ទឹក | ៩៣ | ១១០ | ១២៤ | ១៦៤ | ១៩៥ | ២១២ | ២% |
| សំណង់ | ១.១០៦ | ១.២៨៨ | ១.៦៣១ | ១.៩៩៥ | ២.៣៣៨ | ២.៥៧២ | ២៧% |
| ឧស្សាហកម្ម | ៤៦.៣៣១ | ៥.៤៩៨ | ៦.៤៣៦ | ៧.៨១៦ | ៨.៧៤១ | ៩.៣៨៩ | ១០០% |

*ប្រភព:ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

អនុវិស័យសម្លៀកបំពាក់និងវាយនភណ្ឌបាននាំឱ្យមានសន្ទុះនេះដែលបានបង្ហាញឱ្យឃើញថាមានភាពគួឱ្យកត់សម្គាល់។ ឧស្សាហកម្មសំលៀកបំពាក់កម្ពុជាបានបង្ហាញឱ្យឃើញនូវកំណើនយ៉ាងខ្លាំងបន្ទាប់ពីសហរដ្ឋអាមេរិកបានផ្តល់ឱ្យដល់ស្ថានភាពនោះឱ្យទទួលបានសិទ្ធិអនុគ្រោះខ្ពស់បំផុត (MFN)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងឆ្នាំ១៩៩៦ និងប្រព័ន្ធទូទៅស្តីពីការបន្ធូរពន្ធ (GSP) នៅក្នុងឆ្នាំ១៩៩៧។ ភាពមានការងារធ្វើនៅក្នុងសម្លៀកបំពាក់និងវាយនភ័ណ្ឌគឺជាកម្លាំងធ្វើឱ្យមានស្ថេរភាពយ៉ាងខ្លាំងសម្រាប់ប្រជាជននិងសេដ្ឋកិច្ចនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះដោយសារតែវិស័យនេះបានស្រូបយកកម្លាំងពលកម្មដែលមានជំនាញនិងពាក់កណ្តាលជំនាញយ៉ាងច្រើនជាពិសេសកម្មករស្ត្រីក្រីក្រដែលបើមិនធ្វើការនៅក្នុងវិស័យនេះទេគឺនឹងគ្មានការងារធ្វើតែម្តង។

*តារាង១០.៣. ការវិនិយោគតាមវិស័យ (គិតជាលានដុល្លារ)*

| | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | % |
|---|---|---|---|---|---|---|---|
| រ៉ែ | ២,២ | ០,៩ | ៦៣,៧ | ៥៧,១ | ១០១,៥ | ៩២,៦ | ៧% |
| ឧស្សាហកម្មផលិត | ១២១,៩ | ១៥៥,៥ | ៣៣៧,៨ | ៣៩១,១ | ៦២៤,២ | ៦០១,៣ | ៤៦% |
| ម្ហូប ភេសជ្ជៈ ថ្នាំជក់ | ២៨,០ | ១៩,០ | ២១,៩ | ៣៦,៧ | ៥១,៦ | ៥២,៤ | ៤% |
| វាយនភ័ណ្ឌ | ៦៦,៥ | ៩៥,៦ | ១១២,៣ | ១៦៣,៨ | ២៥០,១ | ២៤៧,១ | ១៩% |
| ឈើ ក្រដាស និងការបោះពុម្ព | ៧,៥ | ៦,៨ | ៧,៣ | ៩,៤ | ១២,៤ | ១៣,៧ | ១% |
| ឧស្សាហកម្មផលិតកៅស៊ូ | ៣,៣ | ៧,៦ | ១៣,២ | ១៤,៤ | ២២,៩ | ២១,៥ | ២% |
| ឧស្សាហកម្មផលិតដទៃទៀត | ១៦,៧ | ១៦,៥ | ១៨៣,២ | ១៦៦,៧ | ២៨៧,២ | ២៦៦,៧ | ២១% |
| អគ្គិសនី ឧស្ម័ន ទឹក | ៥៥,៤ | ៧០,៧ | ៨៦,៦ | ១០៧,៤ | ១៥០,៨ | ១៦៩,៩ | ១៣% |
| សំណង់ | ១៧៦,៣ | ១៧២,៥ | ១៩២,៧ | ២៧៧,៦ | ៣៨០,៣ | ៤៣៤,៨ | ៣៣% |
| ឧស្សាហកម្ម | ៣៥៥,៨ | ៣៨៩,៥ | ៦៨០,៩ | ៨៣៣,២ | ១.២៥៦,៩ | ១.២៩៨ | ១០០% |

*ប្រភពៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

ឧស្សាហកម្មនៅតែបន្តបង្ហាញនូវសន្ទុះដើបឡើងគួរឱ្យកត់សម្គាល់ដែលនេះ គឺជាលទ្ធផលយ៉ាងសំខាន់ដែលបានមកពីនយោបាយសេរីភាវូបនីយកម្មសេដ្ឋកិច្ចដែលកំពុងតែអនុវត្តឡើងដោយរាជរដ្ឋាភិបាល។ អត្រាកំណើនជាមធ្យមគឺ១២.៥% នៅក្នុងឆ្នាំ១៩៩៤-១៩៩៨ បន្តរហូតមកដល់ឆ្នាំ១៩៩៧ដែលធ្លាក់បន្តិចនៅក្នុងឆ្នាំ១៩៩៨ (-២.៥%) ដោយសារតែព្រឹត្តិការណ៍ផ្ទៃក្នុងរបស់កម្ពុជានិងដោយសាតែវិបត្តិហិរញ្ញវត្ថុក្នុងតំបន់។ កំណើនឧស្សាហកម្មមានសន្ទុះខ្លាំងនៅចន្លោះឆ្នាំ១៩៩៩-២០០២ (២០.២%)។ ការចូលរួមចំណែករបស់វិស័យនេះនៅក្នុងផលិតផលសរុបជាតិកើនឡើងពី១១.៦% នៅក្នុងឆ្នាំ១៩៩៣ ទៅ១៧% នៅក្នុងឆ្នាំ១៩៩៨ និង២៦.២% នៅក្នុងឆ្នាំ២០០៦ហើយធ្លាក់មកត្រឹម២២.៤% នៅក្នុងឆ្នាំ២០០៨។ ឧស្សាហកម្មចម្បងនៅក្នុងប្រទេសកម្ពុជាគឺ រ៉ែ ម្ហូបអាហារ ភេសជ្ជៈ ថ្នាំជក់ សម្លៀកបំពាក់ ឈើ ក្រដាស និងការបោះពុម្ពឧស្សាហកម្មកៅស៊ូអគ្គិសនីឧស្ម័ននិងទឹកស្អាតនិងសំណង់។ ឧស្សាហកម្មសំខាន់នៅក្នុងប្រទេសកម្ពុជាគឺវាយនភ័ណ្ឌដែលចូលរួមចំណែក៤៦% នៃទិន្នផលឧស្សាហកម្ម (២.៣ពាន់លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០៨) ដែលបន្ទាប់មកគឺសំណង់ (២៧%) ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ (១០%) ឈើ ក្រដាស និងការបោះពុម្ព (៣%) អគ្គិសនីឧស្ម័ននិងទឹកស្អាត (២%) និងរ៉ែ (២%)។ ផ្នែកនេះនឹងជួយពន្យល់នូវការវិភាគយ៉ាងពិស្តារទាក់ទងទៅនឹងតែឧស្សាហកម្មសំខាន់ៗ។

## ១០.៣. សម្លៀកបំពាក់និងវាយនភ័ណ្ឌ

ផ្នែកសម្លៀកបំពាក់ដែលគ្របដណ្តប់ជិតពាក់កណ្តាលលើវិស័យឧស្សាហកម្មគឺជាអនុវិស័យដែលមានសន្ទុះខ្លាំងបំផុតនៅក្នុងឧស្សាហកម្មជាមួយនិងកំណើនជាមធ្យមប្រចាំឆ្នាំ៥៨,៥% នៅក្នុងអំឡុងឆ្នាំ១៩៩៤-១៩៩៨។ កំណើននេះបានធ្លាក់ចុះនៅក្នុងឆ្នាំ១៩៩៩-២០០២ ជាមួយនឹងកំណើនជាមធ្យមតែ៣៥,៤% ជាមួយនឹងការប្រើប្រាស់ប្រព័ន្ធកូតានៅក្នុងទីផ្សារសហរដ្ឋអាមេរិក។ កម្ពុជាបានឆ្លើយតបជាវិជ្ជមានទៅនឹងតម្រូវការរបស់បរទេសដោយការគោរពទៅតាមការការពារសិទ្ធិសង្គមរបស់កម្មករនៅក្នុងវិស័យនេះ។ ការអនុវត្តស្តង់ដារការងារបានអនុញ្ញាតឱ្យកម្ពុជារក្សាបានកំណើនក្នុងការនាំចេញសម្លៀកបំពាក់ជាមួយនឹងកំណើនជាមធ្យមប្រចាំឆ្នាំ៤៥% ក្នុងអំឡុងពេលទសវត្សរ៍ពីឆ្នាំ១៩៩៤ និង២០០៤។ ទោះបីជាយ៉ាងណាក៏ដោយកំណើននៅក្នុងឧស្សាហកម្មបានបន្ថយល្បឿនមកកំណើនជាមធ្យមប្រចាំឆ្នាំ១២%ក្នុងអំឡុងពេលឆ្នាំ២០០៥-២០០៨។ ការរួមចំណែករបស់អនុវិស័យនៅក្នុងផលិតផលក្នុងស្រុកសរុបកើនពី១% នៅក្នុងឆ្នាំ១៩៩៣ ទៅ១៣% នៅក្នុងឆ្នាំ២០០៦ ប៉ុន្តែធ្លាក់មក១០,៣% នៅក្នុងឆ្នាំ២០០៨។

ទោះបីជាលក្ខខណ្ឌអាកាសធាតុនិងដីរបស់កម្ពុជាមានលក្ខណៈសមស្របសម្រាប់ការផលិតកប្បាសក៏ដោយវាមិនទាន់មានឧស្សាហកម្មផលិតអំបោះជាក់ស្តែងណាមួយនៅក្នុងប្រទេសកម្ពុជានោះទេ។ ឧស្សាហកម្មផលិតអំបោះនិងកប្បាសក្នុងស្រុកអាចផ្តល់កប្បាសតែ២០% នៃតម្លៃកប្បាសនាំចូល។ ទោះបីជាយ៉ាងណាក៏ដោយវាទាមទារឱ្យមានការវិនិយោគច្រើនថែមទៀតជាមួយនឹងហានិភ័យខ្ពស់។

*រូបភាព១០.១. ទំនោរឧស្សាហកម្មសំលៀកបំពាក់១៩៩៥-២០០៣*




*ប្រភព:ក្រសួងពាណិជ្ជកម្ម*

ផ្ទុយទៅវិញកម្ពុជាមានឯកទេសខាងកាត់ដេរ (Cut-Makr-Trim, CMT)។ បណ្តារោងចក្រកាត់ដេរធ្វើការងារតែខាងផ្នែកកាត់ដេរបង្ហើយនិងវេចខ្ចប់ចំណែកឯសាច់ក្រណាត់គឺនាំចូលពីបរទេស។ នៅពេលដែលឧស្សាហកម្មភាគច្រើនទុកឱកាសឱ្យដៃគូពាណិជ្ជកម្មរបស់ខ្លួននៅឯបរទេសធ្វើការចរចាជាមួយនិងអ្នកទិញ រោងចក្រសម្លៀកបំពាក់ប្រហែលជា២៥% គឺធ្វើតែការងារការផលិតសម្លៀកបំពាក់យ៉ាងពេញទំហឹងដែលរួមមានដូចជាការទិញសាច់ក្រណាត់ធ្វើការកាត់ដេរវេចខ្ចប់និងដឹកជញ្ជូនការបញ្ជាទិញទៅឱ្យអ្នកទិញ។ រោងចក្រមួយចំនួនគឺជាក្រុមហ៊ុនមៅការជាប់កុងត្រាគឺធ្វើតែការកាត់ដេរ។ ការចំណាយជាង៦០% លើផលិតកម្មនៅក្នុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិស័យសម្លៀកបំពាក់រួមមានសម្ភារៈនាំចូលនិងវត្ថុធាតុដើមដទៃទៀត។ ដូច្នេះវិស័យសម្លៀកបំពាក់មិនបានបង្កើតឱ្យមានឱ្យមានសកម្មភាពដទៃទៀតទេដោយសារតែភាពប្រទាក់ក្រឡាគ្នាមានភាពអន់ថយហើយឧស្សាហកម្មសម្លៀកបំពាក់កម្ពុជាត្រូវបានគេចាត់ទុកថាមានភាពខ្វះខាតការធ្វើសមាហរណកម្មរួមគ្នាជាប្រព័ន្ធ។ ទោះបីជាយ៉ាងណាក៏ដោយវានៅមានវិសាលភាពច្រើនសម្រាប់ឧស្សាហកម្មសេវាកម្មនិងគាំទ្របន្ទាប់បន្សំសម្រាប់គាំទ្រឧស្សាហកម្មសម្លៀកបំពាក់។

វិស័យសម្លៀកបំពាក់គឺជាឧស្សាហកម្មប្រើកម្លាំងពលកម្មច្រើនដែលស្រូបយកកម្លាំងពលកម្មភាគច្រើនជាស្ត្រីដែលមកពីទីជនបទ។ វិស័យនេះបានផ្តល់ការងារឱ្យដល់កម្មកររោងចក្រជាង៣៥០,០០០នាក់នៅក្នុងខែកញ្ញាឆ្នាំ២០០៨ ដោយឧបមាថាកម្មករម្នាក់ត្រូវទទួលបន្ទុកមនុស្សបួននាក់នេះ គឺជាចំណូលសម្រាប់ប្រជាជនកម្ពុជាជាងមួយលាននាក់។ ឧស្សាហកម្មសម្លៀកបំពាក់គឺជាកត្តារួមចំណែកយ៉ាងសំខាន់សម្រាប់រូបិយប័ណ្ណបរទេស។

*រូបភាព១០.២. ការនាំចេញសម្លៀកបំពាក់និងវាយនភ័ណ្ឌ (គិតជាលានដុល្លារ)*




| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| OTHERS | 0.5 | 3.8 | 4.8 | 4.4 | 7.3 | 14. | 17. | 28. | 78. | 131 | 135 | 174 | 235 | 334 |
| EU | 25. | 74. | 112 | 63. | 137 | 221 | 309 | 356 | 407 | 580 | 491 | 571 | 632 | 659 |
| USA | 0.4 | 1.5 | 110 | 292 | 516 | 751 | 829 | 954 | 112 | 1,2 | 1,5 | 1,9 | 1,9 | 1,9 |

*ប្រភព:ក្រសួងពាណិជ្ជកម្ម*

រហូតមកដល់ខែតុលាឆ្នាំ២០០៩ នៅមានរោងចក្រកាត់ដេរជាង២៨៣ ដែលប្រើកម្លាំងកម្មករជាង២៧៨, ០០០នាក់ នៅក្នុងប្រទេសកម្ពុជា។ ក្នុងពេលថ្មីៗនេះក្រុមហ៊ុនជាង៨% (១៥ក្រុមហ៊ុន) ទទួលបន្ទុកលើការនាំចេញសម្លៀកបំពាក់សរុបជាង៥០% ក្នុងចំណោមក្រុមហ៊ុនដែលដំណើរការនៅក្នុងប្រទេសកម្ពុជា។ ឧស្សាហកម្មសម្លៀកបំពាក់នៅក្នុងប្រទេសកម្ពុជាគ្របដណ្តប់យ៉ាងលើសលប់ដោយជនបរទេសជាជាងអ្នកវិនិយោគក្នុងស្រុក។ ជាពិសេសអ្នកវិនិយោគធំៗនៅក្នុងឧស្សាហកម្មនេះមកពីហុងកុង តៃវ៉ាន់ ចិន សិង្ហបុរី កូរ៉េខាងត្បូង និងសហរដ្ឋអាមេរិក។ ដូច្នេះវាពិតជាពិបាកណាស់ដើម្បីធ្វើការកំណត់ថាតើវាមានក្រុមហ៊ុនចម្រុះរួមប៉ុន្មានពិតប្រាកដនៅក្នុងប្រទេសកម្ពុជាវាហាក់ដូចជាមើលមិនឃើញថាវិស័យកាត់ដេរត្រូវបានគេចាត់ទុកថាមានឧបសគ្គ ក្នុងការចូលផ្តាច់មុខឬលក្ខខណ្ឌប្រឆាំងនឹងការប្រកួតប្រជែងណាមួយ។

វិស័យកាត់ដេរគឺជាកត្តាជំរុញគន្លឹះ សម្រាប់ការធ្វើសមាហរណកម្មកម្ពុជាចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក។ ឧស្សាហកម្មសម្លៀកបំពាក់ពឹងផ្អែកទៅលើការនាំចេញដូច្នេះវាងាយប្រឈមនឹងផលប៉ះពាល់ពីខាងក្រៅ។ ក្នុងចំណោមតម្លៃសរុបនៃការនាំចេញ ៤,៨៣ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០០៨ គឺ៦៥% ឬ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

២,៨៩ពាន់លានដុល្លារអាមេរិកបានមកពីឧស្សាហកម្មកាត់ដេរ។ តាមកំណត់ត្រាកំណើនឃើញថាមានទំហំច្រើនមែនទែន។ ការនាំចេញសម្លៀកបំពាក់កើនឡើងពី២០លានដុល្លារអាមេរិកនៅក្នុងឆ្នាំ១៩៩៥ មក ២,៨៩ពាន់លានដុល្លារនៅក្នុងឆ្នាំ២០០៨ ។ នៅក្នុងឆ្នាំ២០០៨ ផលិតផលសម្លៀកបំពាក់ប្រហែល៦៦% ត្រូវបាននាំចេញទៅសហរដ្ឋអាមេរិក២២% ទៅកាន់សហគមន៍អឺរ៉ុប៧% ទៅកាន់កាណាដាចំណែកឯ៥% ដែលនៅសល់គឺទៅប្រទេសជប៉ុននិងបណ្តាប្រទេសអាស៊ានផ្សេងទៀត។

*រូបភាព១០.៣. បំណែកទីផ្សារនាំចេញសម្លៀកបំពាក់*




*ប្រភព:ក្រសួងពាណិជ្ជកម្ម*

ឧស្សាហកម្មកាត់ដេរកម្ពុជាបានឆ្លងកាត់បញ្ហាប្រឈមបី៖

**ទីមួយ**គឺការកំណត់កូតានៅក្នុងទីផ្សារសហរដ្ឋអាមេរិកនៅក្នុងឆ្នាំ១៩៩៧។ កិច្ចព្រមព្រៀងវាយនភ័ណ្ឌទ្វេភាគីកម្ពុជា-សហរដ្ឋអាមេរិកឆ្នាំ១៩៩៩ បានផ្តល់ឱ្យកម្ពុជានូវកូតាក្នុងចំណែកទីផ្សារដែលអាចនាំឱ្យមានការកើនឡើងរហូតដល់ទៅ១៤% ក្នុងមួយឆ្នាំដោយឈរលើការប្រកាន់ខ្ជាប់ទៅនឹងលក្ខខណ្ឌការងារ។ ដោយប្រកាន់ខ្ជាប់នយោបាយការពារសិទ្ធិកម្មករនិងលក្ខខណ្ឌការងារបានធ្វើឱ្យវិស័យសម្លៀកបំពាក់និងវាយនភ័ណ្ឌរបស់កម្ពុជាមានការវិវឌ្ឍទៅជាវិស័យទំនើបមួយដែលត្រូវបានគេទទួលស្គាល់ថាមានលក្ខខណ្ឌការងារល្អប្រសើរ។ ដូច្នេះវិស័យកាត់ដេរបានត្រួសត្រាយឱ្យមាននូវទម្លាប់នៃការទទួលខុសត្រូវខាងផ្នែកសង្គមហើយបានបង្កប់គោលការណ៍ទាំងអស់នេះនៅក្នុងច្បាប់ការងារ។ ក្រសួងពាណិជ្ជកម្មទទួលខុសត្រូវលើការផ្តល់វិញ្ញាបនបត្រផលិតផលដើមទៅឱ្យប្រទេសនាំចូលដែលបញ្ជាក់ថាពិតប្រាកដណាមួយនិងធ្វើការគ្រប់គ្រងការបែងចែកកូតាត្រួតពិនិត្យមើលការអនុវត្តកូតាទាំងផ្នែកខាងភាគីកម្ពុជានិងខាងផ្នែកប្រទេសដែលជាទិសដៅនៃការនាំចេញត្រួតពិនិត្យមើលការអនុវត្តតាមការលើកលែងពន្ធគយនិងដើម្បីគ្រប់គ្រងគុណភាព។ អង្គការពលកម្មអន្តរជាតិ (ILO) មានភារកិច្ចពិនិត្យមើលការអនុវត្តតាមលក្ខខណ្ឌការងារ។ សហជីពនៅតែមានដើម្បីរៀបចំនិងថ្លែងឱ្យដឹងពីតម្រូវការរបស់កម្មករហើយសម្លេងរបស់សមាគមន៍រោងចក្រកាត់ដេរកម្ពុជា (GMAC) មានឥទ្ធិពលយ៉ាងខ្លាំងទៅលើគោលនយោបាយដែលគាំទ្រវិស័យនេះតាមរយៈវេទិការរដ្ឋាភិបាលនិងវិស័យឯកជន។ កូតាបន្ថែម (ជាង៦%) នឹងផ្តល់ឱ្យថែមទៀតប្រសិនបើការធ្វើសវនកម្មមួយដែលធ្វើឡើងដោយ ILO រកឃើញថាវាមានភាពប្រសើរឡើងក្នុងលក្ខខណ្ឌការងារ។

**ទីពីរ**ការដកចេញនូវកូតាវាយនភ័ណ្ឌនៅក្នុងសហរដ្ឋអាមេរិកកាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ នៅក្រោមកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកស្តីអំពីសម្លៀកបំពាក់និងវាយនភ័ណ្ឌ (ATC) មានន័យថាឧស្សាហកម្មវាយនភ័ណ្ឌកម្ពុជាត្រូវតែប្រកួតប្រជែងដោយចំហជាមួយនឹងប្រទេសប្រកួតប្រជែង

ដទៃទៀតដូចជាចិនជាដើម។ ដូច្នេះអត្ថប្រយោជន៍នៃទីផ្សារការពារដោយសហរដ្ឋអាមេរិកបានត្រូវចប់ជាធរមាន។ ក្រោយឆ្នាំ២០០៥ កម្ពុជាបានឈានចូលទៅទីផ្សារសហរដ្ឋអាមេរិកដោយឈរលើមូលដ្ឋានប្រទេសទទួលបានការអនុគ្រោះបំផុតជាមួយគ្នានឹងប្រទេសសមាជិកអង្គការពាណិជ្ជកម្មពិភពលោកដទៃទៀតដែលមិនត្រូវបានរឹតបន្តឹងដោយកូតា។ ប៉ុន្តែសហរដ្ឋអាមេរិកបានដាក់ចេញនូវបទបញ្ញត្តិការពារប្រឆាំងនឹងការនាំចូលរបស់ចិនដើម្បីការពារទីផ្សារក្នុងស្រុក។ លើសពីនេះទៀតរាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការដើម្បីកាត់បន្ថយចំណាយ រដ្ឋបាលធ្វើឱ្យនីតិវិធីនាំចេញនាំចូលមានភាពរលូនកាត់បន្ថយចំណាយក្រៅផ្លូវការនិងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគដើម្បីធានាបាននូវការរស់រានមានជីវិតនៃឧស្សាហកម្មកាត់ដេរនិងសម្លៀកបំពាក់។ កំណែទម្រង់ការសម្របសម្រួលពាណិជ្ជកម្មសំខាន់ៗបានត្រូវអនុវត្តដើម្បីធ្វើឱ្យលទ្ធភាពប្រកួតប្រជែងប្រសើរឡើងនិងកសាងទំនុកចិត្តរបស់វិនិយោគិនដោយកាត់បន្ថយចំណាយផលិតកម្មនិងកិច្ចការទីផ្សារ។ ក្រោយការបញ្ចប់កូតានៃវិស័យកាត់ដេរក្នុងឆ្នាំ២០០៥ ការបញ្ជាទិញសម្រាប់ការផ្គត់ផ្គង់ជាច្រើនកំពុងតែកើនឡើង។ ក្នុងការឆ្លើយតបទៅនឹងការបញ្ជាទិញដ៏ច្រើនក្រុមហ៊ុនកាត់ដេរប្រហែលជា៣០បានចាប់ផ្តើមពង្រីកទោះបីជាបរិក្ខារដែលមិនអាចផ្តល់ប្រាក់ចំណេញខ្លះមិនបានដំណើរការក៏ដោយ។ ការភ័យខ្លាចនៃការធ្លាក់ចុះដោយមិនអាចគ្រប់គ្រងបាននៃផលិតកម្មកម្ពុជានិងការនាំចេញវិស័យកាត់ដេរបានប្រែក្លាយទៅជាការគិតខុស។

**ឌីបី** វិបត្តិហិរញ្ញវត្ថុពិភពលោកបានបង្កើតឱ្យមានបញ្ហាប្រឈមមុខមួយចំពោះឧស្សាហកម្មសម្លៀកបំពាក់ក្នុងប្រទេសកម្ពុជា។ ឧស្សាហកម្មសម្លៀកបំពាក់នឹងប្រឈមមុខជាមួយបញ្ហាធំជាងមុននៅក្នុងបរិយាកាសក្រោយវិបត្តិដោយសារតែចំណាយផលិតកម្មសម្រាប់ឧស្សាហកម្មសម្លៀកបំពាក់កាត់ដេររបស់កម្ពុជាខ្ពស់ជាងចំណាយផលិតកម្មនៃប្រទេសប្រកួតប្រជែងរបស់ខ្លួនមួយចំនួនដូចជាចិននិងវៀតណាមជាដើម។ វិស័យសម្លៀកបំពាក់របស់ចិនមានទំហំធំជាងច្រើននិងក៏ត្រូវបានប្រទាក់ក្រឡាគ្នាយ៉ាងត្រឹមត្រូវ។ កម្ពុជាបានឆ្លើយតបដោយឈានទៅរកឱកាសក្នុងទីផ្សារជប៉ុននិងអាស៊ាន។ ដូច្នេះកម្ពុជានឹងចាំបាច់ត្រូវផ្តោតទៅលើការប្រកួតប្រជែងនៃថ្លៃចំណាយតាមរយៈការបង្កើនល្បឿនបន្ថែមទៀតលើកំណែទម្រង់ការសម្របសម្រួលពាណិជ្ជកម្មនិងតាមរយៈការបង្កើនតម្លៃបន្ថែម។ ប៉ុន្តែសហគ្រាសក្នុងប្រទេសកម្ពុជាបង់ពន្ធតិចជាងដោយសារតែការគ្រប់គ្រងសារពើពន្ធរបស់កម្ពុជាមានលក្ខណៈខ្សោយជាងការគ្រប់គ្រងសារពើពន្ធក្នុងប្រទេសចិននិងវៀតណាម។

*រូបភាព១០.៤. កម្លាំងពលកម្មនៃវិស័យសម្លៀកបំពាក់ (គិតជាពាន់)*




*ប្រភព:ក្រសួងពាណិជ្ជកម្ម*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១០.៤. សំណង់

វិស័យសំណង់មកទល់ពេលនេះ គឺជាវិស័យមួយនៃវិស័យសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជាដែលគ្របដណ្ដប់២៧% នៃវិស័យឧស្សាហកម្មនិង៣៣%នៃការវិនិយោគក្នុងវិស័យឧស្សាហកម្ម។ ក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះវិស័យសំណង់បានកើនឡើងក្នុងអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ១៧% ។ សកម្មភាពសាងសង់មានការប្រែប្រួលចុះឡើងយ៉ាងខ្លាំងទៅនឹងវដ្ដនៃសេដ្ឋកិច្ចដូចដែលបានបញ្ជាក់ដោយលទ្ធផលដ៏អាក្រក់ក្នុងឆ្នាំ១៩៩៧-៩៨ (ការធ្លាក់ចុះជាមធ្យមប្រចាំឆ្នាំ៩%) ដែលជាលទ្ធផលនៃឥរិយាបថរង់ចាំមើលរបស់វិនិយោគិនក្នុងទស្សនៈបង្ហាញពីភាពមិនច្បាស់លាស់ក្នុងស្ថានភាពក្នុងស្រុកនៃប្រទេសកម្ពុជានិងវិបត្តិហិរញ្ញវត្ថុអាស៊ី។

ការវិនិយោគលើសំណង់បានចាប់ផ្ដើមងើបឡើងវិញម្ដងទៀតក្នុងឆ្នាំ១៩៩៩ និង២០០០ (២៧,៤% និង៣៦% ជាបន្តបន្ទាប់) ប៉ុន្តែកំណើននេះបានថយចុះយឺតជាងមុនវិញក្នុងឆ្នាំ២០០១ (-១,៨%) មុនពេលកើនឡើងវិញក្នុងឆ្នាំ២០០២ (២៧,១%) ។ ក្នុងអំឡុងពេលឆ្នាំ២០០២ដល់ឆ្នាំ២០០៨សកម្មភាពសាងសង់បានកើនឡើងក្នុងអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ១៥% ខណៈពេលដែលការវិនិយោគក្នុងវិស័យសំណង់នេះមានចំនួនសរុប១,៨ពាន់លានដុល្លារអាមេរិក។ វិស័យសំណង់រួមចំណែកប្រហែល៦% ដល់ផលិតផលក្នុងស្រុកសរុប (GDP) ។

## ១០.៥. កសិ-ឧស្សាហកម្មៈចំណីអាហារនិងភេសជ្ជៈ

វិស័យកសិឧស្សាហកម្មមានទៅដោយសហគ្រាសខ្នាតតូចនិងមីក្រូសហគ្រាសមួយចំនួនធំ។ ការចែកចាយនៃផលិតកម្មត្រូវបានបាញ់ឆ្ពោះទៅរកឧស្សាហកម្មចំណីអាហារនិងភេសជ្ជៈទៅតាមចំនួនក្រុមហ៊ុន។ ក្នុងចំណោមក្រុមហ៊ុនអាជីវកម្មកសិកម្មជាង ៣០.០០០ ៩១% ជាសហគ្រាសធុនតូចដែលមានបុគ្គលិកតិចជាង៥នាក់និងមានដើមទុនតិចជាង១០០០ដុល្លារអាមេរិក។ អនុវិស័យ ចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់មានចំនួន១០% នៃផលិតកម្មឧស្សាហកម្មនិងមានតែ៤% នៃការវិនិយោគប៉ុណ្ណោះ។

ទោះបីជាមានឧត្តមភាពប្រៀបធៀបជាក់ស្ដែង ក្នុងវិស័យកសិឧស្សាហកម្មដែលត្រូវបានជំរុញដោយថ្លៃឈ្នួលពលកម្មទាបយ៉ាងខ្លាំង និងដីកសិកម្មដ៏សម្បូរក៏ដោយក៏តម្លៃបន្ថែមក្នុងវិស័យកសិឧស្សាហកម្មនៅមានកម្រិតទាបយ៉ាងខ្លាំង។ មួយភាគធំនៃវិស័យឯកជនមានទៅដោយក្រុមហ៊ុនក្នុងវិស័យចំណីអាហារហើយភាគច្រើននៃប្រជាជនក្រីក្ររកចំណូលបានមកពីសហគ្រាសដែលនៅឆ្ងាយពីស្រែចម្ការ។

សហគ្រាសចំណីអាហារនិងភេសជ្ជៈនៅតាមជនបទភាគច្រើនមិនមែនផ្លូវការទេសម្រាប់តែទីផ្សារក្នុងស្រុកឬឈ្មួញកណ្ដាលហើយមិនមានជំនាញត្រឹមត្រូវទេ។ ក្នុងខេត្តបាត់ដំបងដែលរួមទាំងចំនួនដ៏ច្រើននៃអ្នកធ្វើស្រូវនោះ៧០%នៃផលិតផលត្រូវបានលក់ផ្ទាល់ទៅឱ្យអ្នកប្រើប្រាស់និងផលិតផលនៅសល់លក់ទៅឱ្យសហគ្រាសខ្នាតតូចតាមមូលដ្ឋាន។ ការផ្លាស់ប្ដូរទំនាក់ទំនងគឺស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការព្រមព្រៀងនៅឡើយទេ។ កិច្ចការទីផ្សារលក់ដុំនិងការចែកចាយដ៏ប្រកួតប្រជែងពិតជាសំខាន់ខ្លាំងណាស់ចំពោះការងារនេះ។

ការផ្ដល់មូលនិធិពាណិជ្ជកម្មស្ទើរតែគ្មានសម្រាប់វិស័យកសិឧស្សាហកម្មដែលមានតែ៣% ប៉ុណ្ណោះនៃទុនបង្វិលដែលបានមកពីប្រភពពាណិជ្ជកម្មប៉ុន្តែការប្រើប្រាស់ទុនមិនទាន់គ្រប់គ្រាន់ទេ។ យុទ្ធសាស្ត្រស្នូលរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍវិស័យកសិឧស្សាហកម្ម ត្រូវបានផ្ដោតទៅលើទំហំនៃកម្មសិទ្ធិដីធ្លី។

គោលនយោបាយនេះផ្ដល់សម្បទានដល់សហគ្រាសលើគោលការណ៍រយៈពេលវែងនិងលើកទឹកចិត្តឱ្យមានការចូលរួមពីកម្មសិទ្ធិករដីធ្លីតូចៗតាមមូលដ្ឋានតាមរយៈការដាំដុះតាមកិច្ចសន្យាសម្រាប់រោងចក្រកែច្នៃក្នុងតំបន់។ ភាគច្រើនលើសលប់នៃវិស័យឯកជនដំណើរការដោយឈរលើមូលដ្ឋានផ្ទាស់ប្ដូរផ្ទាល់ខ្លួនជាមួយនឹងបុគ្គលឬជាមួយឈ្មួញ។ អត្ថប្រយោជន៍នៃការព្រមព្រៀងនេះ (ដែលមានដូចជាការធានាកម្មសិទ្ធិទ្រព្យសម្បត្តិភាពអាចរកទុនបាននិងភាពអាចឈានចូលទៅទីផ្សារបាន) ធម្មតាមិនកើនឡើងទៅលើវិស័យឯកជននោះទេ។

## ១០.៦. ឧស្សាហកម្មដទៃទៀតនិងការធ្វើពិពិធកម្មឧស្សាហកម្ម

### ១០.៦.១.អគ្គិសនីឧស្ម័ននិងទឹក

ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពប្រើប្រាស់សេវាអគ្គិសនីនិងទឹកដែលមានប្រសិទ្ធភាពនិងអាចរ៉ាប់រងបានអាចមានផលប៉ះពាល់ធំដល់ជីវភាពរស់នៅរបស់គ្រួសារនីមួយៗ។ ហេដ្ឋារចនាសម្ព័ន្ធដ៏មានប្រសិទ្ធភាពក៏មានសារៈសំខាន់ផងដែរដើម្បីបន្តចីរភាពនៃកំណើនសេដ្ឋកិច្ចនិងភាពប្រកួតប្រជែងឧស្សាហកម្មទូលំទូលាយជាងមុនដែលនាំឱ្យបង្កើតការងារនិងពង្រីកមូលដ្ឋានពន្ធរបស់ប្រទេសមួយ។

អគ្គិសនីឧស្ម័ននិងទឹកមានតែ២%ប៉ុណ្ណោះនៃផលិតកម្មឧស្សាហកម្មនិង១៣%នៃការវិនិយោគ។ ក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះអនុវិស័យនេះបានកើនឡើងក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ១២,៦%។ ប៉ុន្តែថ្លៃដើមខ្ពស់មើលទៅហាក់ដូចជាបញ្ហាដ៏ធំដែលវិស័យឯកជននិងគ្រួសារកំពុងប្រឈមមុខជាមួយ។ ទីណាដែលអគ្គិសនីទៅដល់ក្រុមហ៊ុននិងអ្នកប្រើប្រាស់ជាលក្ខណៈបុគ្គលតែងជួបប្រទះនឹងថ្លៃដើមថាមពលដ៏ខ្ពស់យ៉ាងខ្លាំង។

ដោយសារតែឧបសគ្គផ្នែកសារពើពន្ធដែលកំពុងតែកើតមានក្នុងរដ្ឋាភិបាលកម្ពុជាការបែងចែកសេវាកម្មនៃផ្នែកឯកជនគឺជាឧបករណ៍សំខាន់មួយក្នុងការទទួលបានគោលដៅចែកចាយសេវា។ វាមានការទទួលស្គាល់យ៉ាងច្រើនពីអត្ថប្រយោជន៍នៃការបែងចែកហេដ្ឋារចនាសម្ព័ន្ធឯកជនក្នុងប្រទេសកម្ពុជាដែលបទពិសោធន៍ដ៏សំខាន់ក្នុងភាពជាដៃគូរវាងផ្នែកឯកជននិងសាធារណៈ (PPP) អាចត្រូវបានទទួលក្នុងគ្រប់វិស័យទាំងអស់។ ភាពជាដៃគូរវាងផ្នែកឯកជននិងសាធារណៈនេះនឹងត្រូវលើកយកមកពិភាក្សាលម្អិតនៅក្នុងជំពូកបន្ទាប់។

### ១០.៦.២.ឧស្សាហកម្មរ៉ែ

កម្ពុជាគឺជាប្រទេសនាំចូលប្រេងសុទ្ធហើយស្ថានភាពនេះនឹងមិនត្រូវបានរំពឹងថានឹងផ្លាស់ប្ដូរនោះទេក្នុងពេលអនាគតដ៏ឆាប់ខាងមុខនេះ។ ប្រទេសនេះទើបតែបានចាប់ផ្ដើមធ្វើការសិក្សាស្រាវជ្រាវលើធនធានរ៉ែហើយសារធាតុខ្លះនៃរ៉ែបានត្រូវរកឃើញ។ មានសក្ដានុពលដ៏ល្អសម្រាប់ប្រេងនិងឧស្ម័នបុកស៊ីតមាសទង់ដែងនិងសារធាតុរ៉ែផ្សេងទៀត។ ថ្មកំបោរដែលត្រូវបានប្រើប្រាស់ដោយឧស្សាហកម្មស៊ីម៉ង់ត៍មាននៅខេត្តកំពត។ ប៉ុន្តែក្នុងដំណាក់កាលនេះឧស្សាហកម្មរ៉ែនៅតែតូចនៅឡើយលើកលែងតែការរុករកប្រេងនិងឧស្ម័ន។ ប៉ុន្តែក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះឧស្សាហកម្មរ៉ែបានរីកដុះដាលក្នុងអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ២០%។ ការវិនិយោគលើឧស្សាហកម្មរ៉ែបានកើនឡើងយ៉ាងគំហុកក្នុងឆ្នាំ២០០៥-២០០៨ ដែលជាមធ្យមមានទឹកប្រាក់៧៩លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។

### ១០.៦.៣. ការធ្វើពិពិធកម្មឧស្សាហកម្ម

ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកមិនបាននាំមកនូវលទ្ធភាពឈានចូល ទីផ្សារល្អប្រសើរជាងមុនខ្លាំងសម្រាប់ផលិតករកម្ពុជានោះឡើយ។ ដូចនេះឱកាសដែលផ្តល់ដោយអង្គការពាណិជ្ជកម្មពិភពលោកនឹងមិនបាននាំមកនូវកំណើននៃនិកម្មភាពនៃផលិតកម្មទេលុះត្រាតែឧបសគ្គនៃបរិយាកាសពាណិជ្ជកម្មត្រូវបានលុបបំបាត់ហើយស្ថាប័នសម្រាប់គាំទ្រដល់ទីផ្សារត្រូវបានរៀបចំឡើង។ ក្នុងន័យនេះវិធានការកែទម្រង់ត្រូវតែអនុវត្តដើម្បីធ្វើពិពិធកម្មរចនាសម្ព័ន្ធឧស្សាហកម្មរបស់កម្ពុជាដែលរួមមាន៖

- **បន្ធូរបន្ថយតម្រូវការធ្វើអាជ្ញាប័ណ្ណ៖** វិធានការនេះត្រូវបានតាក់តែងឡើងដើម្បីលុបបំបាត់ការព្រមព្រៀងពាណិជ្ជកម្មផ្តាច់មុខដែលបានដាក់កំណត់ដោយរដ្ឋនិងការផ្តាច់មុខក្នុងស្រុក។ នេះនឹងអាចធ្វើឱ្យប្រសើរឡើងនូវការបែងចែកផលិតផលកសិកម្មដែលរួមទាំងវត្ថុធាតុដើមផលិតផលសម្រេចនិងពាក់កណ្តាលសម្រេចដែលមានសារៈសំខាន់សម្រាប់អាជីវកម្មកសិ-ឧស្សាហកម្ម។
- **កាត់បន្ថយតម្រូវការត្រួតពិនិត្យ៖** ទោះបីជាការធានាបានពីគុណភាពគឺជាផ្នែកសំខាន់មួយនៃការការពារអ្នកប្រើប្រាស់ក៏ដោយក៏គោលនយោបាយសម្រាប់ធានាគុណភាពអាចជាឧបសគ្គមួយចំពោះការប្រកួតប្រជែងពេញលេញ។ ច្បាប់នាពេលបច្ចុប្បន្នហាមឃាត់មិនឱ្យធ្វើពាណិជ្ជកម្មលើផលិតផលណាដែលមិនទាន់បានត្រួតពិនិត្យ។ ប៉ុន្តែចំណាយសម្រាប់ត្រួតពិនិត្យមានកម្រិតខ្ពស់ហើយវាមិនអាចទៅរួចទេសម្រាប់រដ្ឋាភិបាលមួយក្នុងការត្រួតពិនិត្យរាល់សកម្មភាពពាណិជ្ជកម្មទាំងអស់។ ក្នុងន័យនេះបទបញ្ញត្តិត្រួតពិនិត្យគុណភាពអាចត្រូវបានប្រើប្រាស់ដើម្បីបញ្ឈប់អាជីវកម្មជាក់លាក់ណាមួយនិងធ្វើឱ្យការប្រកួតប្រជែងមានកំណត់។ ជាងនេះទៀតតម្រូវការត្រួតពិនិត្យអាចបង្កើតនូវបរិយាកាសមួយនៃការភ័យខ្លាច។

# ជំពូកទី ១១
# ការអភិវឌ្ឍវិស័យឯកជន

វិស័យឯកជនមានតួនាទីយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ការបង្កើត និងការប្រមូលទ្រព្យសម្បត្តិ។ នៅខណៈដែលវិស័យឯកជនសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម ការរីកចម្រើននេះមិនទាន់ឆ្លុះបញ្ចាំងឱ្យឃើញអស់សក្តានុពល នូវថាមភាពគំនិតផ្តួចផ្តើមឯកជន តាមរយៈសមិទ្ធផលសេដ្ឋកិច្ចលេចធ្លោ ដែលបណ្តាប្រទេសអាស៊ីអាគ្នេយ៍ទទួលបានក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងទៅនេះ។ តាមការពិត នៅមានឧបសគ្គមួយចំនួន ដែលរាំងស្ទះដល់វិស័យឯកជន និងរារាំងតួនាទីរបស់វិស័យនេះ នៅក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍។

និយាយជារួម សកម្មភាពកម្មន្តសាលស្ថិតនៅក្នុងវិស័យឯកជន។ កំណើនជាមធ្យមប្រចាំឆ្នាំនៃតម្លៃបន្ថែមឧស្សាហកម្មកម្មន្តសាលសម្រេចបាន ១៥.៩% នៅក្នុងអំឡុងឆ្នាំ១៩៩៤-២០០៨។ ប្រការនេះគឺវាផ្ទុយគ្នាទៅនឹងនិន្នាការសន្ទស្សន៍នៃផលិតកម្មសម្រាប់វិស័យផលិតកម្មក្នុងប្រព័ន្ធ ដែលមានការធ្លាក់ចុះនៅក្នុងរយៈពេលដូចគ្នានេះ។ គេអាចពន្យល់បាតុភាពនៅក្នុងរយៈពេលនេះបានថា វិស័យផលិតកម្មក្រៅប្រព័ន្ធបានចូលរួមទៅក្នុងដំណើរការផលិតកម្មនៃផលិតផលសរុបក្នុងស្រុក។

ទំហំសហគ្រាសអាចផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការវិភាគលើវិស័យធុរកិច្ចនៅកម្ពុជា។ យើងអាចបែងចែកសហគ្រាសជាបីប្រភេទធំៗ ទៅតាមទិដ្ឋភាពដូចតទៅនេះ៖ អាជីវកម្មធុនធំ អាជីវកម្មធុនតូចនិងមធ្យម និងមីក្រូអាជីវកម្មនៃវិស័យក្រៅប្រព័ន្ធ។ សហគ្រាសបីក្រុមដំបូង ពោលគឺ សហគ្រាសធុនធំ មធ្យម និងតូច បង្កើតបានជាវិស័យទំនើប ដែលគេឃើញមាននៅក្នុងអាជីវកម្មធំៗ។ ដូច្នេះ យើងអាចឱ្យនិយមន័យបែបទូលាយ និងកំណត់នូវបុគ្គលិកលក្ខណៈនៃក្រុមនីមួយៗ ដូចតទៅនេះ៖

**វិស័យទំនើប** (SME Development Framework, 2005, p. 13)៖

- **សហគ្រាសធុនធំ** ៖ គឺជាក្រុមហ៊ុនឯកជន ឬជាសហគ្រាសរដ្ឋ។ សហគ្រាសឯកជនធុនធំជាច្រើន គឺជាសាខា ឬ ក៏ជាដៃគូរបស់ក្រុមហ៊ុនបរទេស។ សហគ្រាសធុនធំត្រូវមានបុគ្គលិកអចិន្ត្រៃយ៍លើសពី ១០០នាក់ ឬមានទុនវិនិយោគច្រើនជាង ៥០០.០០០ ដុល្លារសហរដ្ឋអាមេរិក ដោយមិនគិតអំពីតម្លៃដី។
- **សហគ្រាសធុនមធ្យម** ៖ ជាទូទៅ សហគ្រាសប្រភេទនេះដំណើរការដោយទុនវិនិយោគគ្រួសារ ហើយរៀបចំតាមរបៀបទំនើបមួយ។ សហគ្រាសប្រភេទនេះជាទូទៅមានបុគ្គលិកពី ៥០ ទៅ ១០០ នាក់ ដោយមានចំណូលប្រចាំឆ្នាំពី ២៥០.០០០ ដុល្លារសហរដ្ឋអាមេរិកទៅដល់ ៥០០.០០០ ដុល្លារសហរដ្ឋអាមេរិក។ សហគ្រាសប្រភេទនេះអាចមានទីតាំងច្បាស់លាស់ និងពិតប្រាកដ ចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធ រៀបចំរបាយការណ៍គណនីជាប្រចាំ ហើយមានអត្តសញ្ញាណរបស់ខ្លួនដាច់ដោយឡែក ពីម្ចាស់មូលធន ឬ អ្នកជួយគាំទ្រ។
- **សហគ្រាសធំនើបធុនតូច** ៖ សហគ្រាសប្រភេទនេះត្រូវបានគេកំណត់ថាជាសហគ្រាសទាំងឡាយណា ដែលមានបុគ្គលិកពី ១១ ទៅ ៥០នាក់ ដែលមានទ្រព្យសកម្មពី ៥០.០០០ដុល្លារសហរដ្ឋអាមេរិក ទៅ ២៥០.០០០ដុល្លារសហរដ្ឋអាមេរិក។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

*តារាង១១.១ : ចំនួនសហគ្រាសដាក់តាមលំដាប់ខេត្តក្នុងឆ្នាំ២០០៩*




*ប្រភព:វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០០៩*

## វិស័យក្រៅប្រព័ន្ធ៖

- អាជីវកម្មក្រៅប្រព័ន្ធផលិតនូវផលិតផលប្រពៃណី ដូចជាឧស្សាហកម្មតូចតាចតាមផ្ទះ និងសិប្បកម្ម។ អាជីវកម្មប្រភេទនេះរួមមានសហគ្រាសមីក្រូ ដែលគេអាចចាត់ថ្នាក់បន្ថែមទៀតដោយឈរលើលក្ខណៈវិនិច្ឆ័យដូចជា៖ ទុនវិនិយោគ តម្លៃបន្ថែម សក្តានុពលសម្រាប់កំណើន ដើម្បីក្លាយទៅជាអាជីវកម្មទំនើប ឬទៅតាមជម្រើសផ្លូវដើរ និងសារតារបស់សហគ្រិន។ សហគ្រាសមីក្រូ គឺជាអាជីវកម្មទាំងឡាយណាដែលមានបុគ្គលិកតិចជាង ១០ នាក់ ដែលមានទ្រព្យសកម្មតិចជាង ៥០.០០០ ដុល្លារសហរដ្ឋអាមេរិក ដោយមិនរាប់បញ្ចូលតម្លៃដី។

ជាទូទៅ ក្រុមអាជីវកម្មនីមួយៗជួបប្រទះនឹងបញ្ហាប្រឈមពិសេស ដាច់ដោយឡែក ខុសពីក្រុមផ្សេងទៀត។

យោងតាមការអង្កេតសហគ្រាសនាពេលថ្មីៗនេះ ដែលរៀបចំឡើងដោយវិទ្យាស្ថានជាតិស្ថិតិ នៅកម្ពុជាមានសហគ្រាសចំនួន ៣៧៥.០៩៥ ហើយចំនួនសហគ្រាសក្នុងចំណោមមនុស្ស ១.០០០ នាក់ ស្មើនឹង ២៨,០ សហគ្រាស។ ដូច្នេះ កម្ពុជាមានសហគ្រាសតិច បើធៀបជាមួយនឹងចំនួនប្រជាជន (ឥណ្ឌូនេស៊ី ២២,៧ លានហើយមានអត្រា ១០២,៣ ឡាវមានសហគ្រាសចំនួន ២០៩ពាន់ និងមានអត្រា ៣៧,៤)។ និយាយជារួមសហគ្រាសទាំងអស់នេះគឺជាសហគ្រាសខ្នាតតូច និងក្រៅប្រព័ន្ធ។

ទន្ទឹមនឹងនេះ ខេត្តតូចជាងគេ គឺខេត្តកែប ដែលមានសហគ្រាសតែ ៧៨៩ ឬ០,២% ធៀបនឹងតួលេខសរុបរបស់ជាតិ ដែលប្រការនេះឆ្លុះបញ្ចាំងឱ្យឃើញថា ផ្ទៃដីខេត្តនេះតូចជាងគេ បើធៀបជាមួយនឹងខេត្តទាំងអស់ដទៃទៀត ហើយបន្ទាប់គឺខេត្តមណ្ឌលគិរី (១.៦៣៧ ឬ ០,៤%) ប៉ៃលិន (១.៩០៤ ឬ ០,៥%) ស្ទឹងត្រែង (២.៦៥៦ ឬ ០,៧%) ហើយនឹងឧត្តរមានជ័យ (៣.៦៨៣ ឬ ១,០%)។ ខេត្តទាំងប្រាំនេះស្ថិតនៅភាគខាងជើងនិងខាងកើតប្រទេស លើកលែងតែខេត្តកែបមួយ។ ទោះបីខេត្តកែបជាខេត្តតូចជាងគេក៏ដោយក៏ខេត្តនេះមានឧស្សាហកម្មខ្នាតធំបី គឺសណ្ឋាគារ សិប្បកម្មអំបិល និងទឹកត្រី។ នៅក្នុងខេត្តប៉ៃលិនមានឧស្សាហកម្មខ្នាតធំប្រាំ គឺកាស៊ីណូ ផ្ទះសំណាក់ ភោជនីយដ្ឋាន ត្បូងពេជ្រ និងការលក់ដូរសម្ភារៈសំណង់។ លើសពីនេះទៅទៀត ការផ្គត់ផ្គង់ចរន្តអគ្គិសនីគឺជាឧស្សាហកម្មដែលលេចធ្លោជាងគេ។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនកាស៊ីណូ ផ្ទះសំណាក់ និងភោជនីយដ្ឋានមានការធ្លាក់ចុះ។

ខេត្តដែលធំជាងគេដោយគិតទៅលើចំនួនសហគ្រាស គឺ ភ្នំពេញ ដែលមានសហគ្រាសចំនួន ៥៥.៨០២ ឬ ស្មើនឹង១៤,៩% ធៀបជាមួយនឹងចំនួនសហគ្រាសសរុបទាំងអស់របស់ប្រទេស ហើយខេត្តបន្ទាប់គឺខេត្តកំពង់ចាម (៤៣.៧៨៧ ឬ ១១,៧%) កណ្ដាល (៣៨.៧៩១ឬ១០,៣%) តាកែវ (២៧.៤៣១ឬ ៧,៣%) និងព្រៃវែង (២៦.៥៦៣ ឬ ៧,១%)។ ខេត្តទាំងប្រាំនេះស្ថិតនៅភាគខាងត្បូងប្រទេសហើយជាតំបន់ដែលមានផ្ទៃដីរាបស្មើដែលគ្របដណ្ដប់លើផ្ទៃដីសរុប៥០% នៃប្រទេសកម្ពុជា។

ភ្នំពេញបានអភិវឌ្ឍន៍ក្លាយខ្លួនជារាជធានីមួយ ហើយជាពិសេសឧស្សាហកម្មសេវាកម្មមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់។ លើសពីនេះទៅទៀត សំណង់អគារខ្ពស់ៗកំពុងតែមានការរីកចម្រើនហើយជាពិសេសតំបន់ពាណិជ្ជកម្មសេរីបានបញ្ចប់ផ្នែកខ្លះជាបណ្ដើរៗហើយ។ ខេត្តកំពង់ចាមមានឧស្សាហកម្មខ្នាតធំប្រាំ គឺ កៅស៊ូ ម្សៅមី ចំណីសត្វ ស្បែកជើង ឈើ និងឧស្សាហកម្មសម្លៀកបំពាក់។ នៅក្នុងខេត្តតាកែវមានឧស្សាហកម្មខ្នាតធំប្រាំ គឺម៉ាស៊ីនកិនស្រូវ ទឹកបរិសុទ្ធ សម្លៀកបំពាក់ សិប្បកម្មឥដ្ឋ និងការផ្គត់ផ្គង់ទឹក។ លើសពីនេះទៅទៀត វិស័យគ្រឿងសំណង់ ក៏ជាឧស្សាហកម្មលេចធ្លោផងដែរ។ នៅក្នុងខេត្តព្រៃវែង សម្លៀកបំពាក់ គឺជាឧស្សាហកម្មខ្នាតធំ។

## ១១.១. វិស័យទំនើប

សហគ្រាសនៅក្នុងវិស័យទំនើប (ធុនធំ មធ្យម និងតូច) គ្របដណ្ដប់ទៅលើឧស្សាហកម្ម ដែលប្រើប្រាស់វត្ថុធាតុដើម និងសេវាកម្មហិរញ្ញវត្ថុ។ អាជីវកម្មប្រភេទនេះត្រូវតែបំពេញឱ្យបាននូវបទដ្ឋាន និងស្តង់ដារអន្តរជាតិ។ វិស័យទំនើបមានតួនាទីយ៉ាងសកម្មនៅក្នុងវិស័យទេសចរណ៍ហិរញ្ញវត្ថុក៏ដូចជានៅក្នុងវិស័យកំពង់ផែនិងផ្លូវទឹក។ ការចូលរួមរបស់សហគ្រាសធុនតូច មធ្យម និងតូច នៅក្នុងសេដ្ឋកិច្ចរបស់កម្ពុជានៅមានកម្រិតនៅឡើយគឺ ប្រមាណជា ៨% នៃផលិតផលជាតិសរុប (GNP)។ ក្រុមហ៊ុនទាំងអស់នេះមានភាពចម្រុះ ទាំងប្រភពដើម ទាំងរូមទាំងក្រុមហ៊ុនដែលផ្តល់ហិរញ្ញប្បទានជាទុនបរទេសផងដែរ។ អាជីវកម្មឯកជនក៏ស្ថិតនៅក្នុងការប្រកបអាជីវកម្មប្រភេទនេះដែរ។

### ១១.១.១. លក្ខណសម្បត្តិនៃវិស័យឯកជនកម្ពុជា

ជាមធ្យមភាគច្រើនលើសលប់នៃវិស័យឯកជនកម្ពុជា គឺជាក្រុមហ៊ុនតូចៗ។ ក្នុងចំណោមសហគ្រាសទំនើបចំនួន ៦៣.៥០០ តាមនិយមន័យរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) នៅក្នុងឆ្នាំ ២០០៨ សហគ្រាសចំនួន ៦០% គឺជាសហគ្រាសដែលមានបុគ្គលិកដែលជាម្ចាស់តែម្នាក់ឯង ២២% មានបុគ្គលិកពី ១ ទៅ ៤ នាក់ ហើយ១,៥% មានបុគ្គលិកច្រើនជាង២០នាក់ (World Bank, 2009 Page 1)។ វិស័យឯកជនរបស់កម្ពុជាមានច្រើនទម្រង់ ដែលជាវិស័យក្រៅប្រព័ន្ធ ការអនុវត្តច្បាប់ស្តីពីសារពើពន្ធ និងការរៀបចំប្រព័ន្ធគណនីនៅមិនទាន់បានល្អ ហើយការប្រើប្រាស់ប្រព័ន្ធធនាគារនៅមានកម្រិត។

ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល (MIME) បានកំណត់ថា សហគ្រាសមីក្រូ គឺជាអាជីវកម្មដែលមាននិយោជិតតិចជាង ១០នាក់ ហើយសហគ្រាសខ្នាតតូចមាននិយោជិតពី ១១ទៅ ៥០នាក់ សហគ្រាសខ្នាតមធ្យមមានពី ៥១ទៅ១០០នាក់ ហើយសហគ្រាសខ្នាតធំ គឺមាននិយោជិតពី១០០នាក់ឡើងទៅ។

*តារាង១១.១. ការបែងចែកក្រុមហ៊ុន*

| | %គិតជាចំនួនក្រុមហ៊ុន | | | | %នៃGDP |
|---|---|---|---|---|---|
| | តូច | មធ្យម | ធំ | សរុប | |
| ឧស្សាហកម្មផលិត | ៤,៣ | ១,៧ | ២,៧ | ៨,៨ | ២៨,២ |
| ពាណិជ្ជកម្ម | ២៣,៣ | ៤,៥ | ១,០ | ២៨,៨ | ១៤,៥ |
| ទេសចរណ៍ | ១៨,៤ | ៥,៨ | ០,៤ | ២៤,៥ | ៧,០ |
| ផ្សេងៗ | ២៥,២ | ៩,៧ | ២,៩ | ៣៧,៨ | ៥០,៣ |
| សរុប | ៧១,២ | ៧១,៨ | ៧,០ | ១០០,០ | ១០០,០ |

*ប្រភព៖ ធនាគារពិភពលោកនិងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។ បរិយាកាសវិនិយោគល្អប្រសើរដើម្បីកំណើនប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។ សេចក្តីព្រាងសម្រាប់ពិភាក្សា ថ្ងៃទី៩ កុម្ភៈ ឆ្នាំ២០០៩។ ការបែងចែកដោយផ្អែកលើការប៉ាន់ស្មាន។ គំរូសម្រាប់ ICS ២០០៧ ទំព័រ២។*

តាមរយៈតារាងខាងលើនេះយើងអាចមើលឃើញថា មានក្រុមហ៊ុនកម្ពុជាតែ ៧%ប៉ុណ្ណោះដែលអាចចាត់ទុកថាជាក្រុមហ៊ុនធំ ហើយ ២១,៨%ទៀត ជាក្រុមហ៊ុនមធ្យម។ ក្រុមហ៊ុនឯកជនកម្ពុជាភាគច្រើនលើសលប់ (៧១,២%) ជាក្រុមហ៊ុនខ្នាតតូច ហើយដែលក្រុមហ៊ុន ២៨,៨% ស្ថិតក្នុងវិស័យពាណិជ្ជកម្មនិង ២៤,៥% ស្ថិតនៅក្នុងវិស័យទេសចរណ៍។ មានតែក្រុមហ៊ុន៨,៨%ប៉ុណ្ណោះ ជាក្រុមហ៊ុនស្ថិតក្នុងឧស្សាហកម្មកម្មន្តសាល ហើយ ៣០% នៃកម្មន្តសាល ជាពិសេស រោងចក្រកាត់ដេរ ដែលត្រូវបានគេចាត់ទុកថាជាក្រុមហ៊ុនធំ។

ក្នុងចំណោមអាជីវកម្មដែលបានចុះបញ្ជីជិតពាក់កណ្តាល (៤៨,២%) ស្ថិតនៅក្នុងផ្នែកពាណិជ្ជកម្ម បន្ទាប់មក គឺសេវាកម្ម (៤៥,៤%) កម្មន្តសាល និងសំណង់ (៥,៤%) និងធនធានធម្មជាតិ (១%)។ អាជីវកម្មទាំងអស់ដែលនៅក្នុងវិស័យពាណិជ្ជកម្មមានតែ ១% នៃក្រុមហ៊ុនទាំងនោះប៉ុណ្ណោះ ជាអាជីវកម្មលក់ដុំ ចំណែកឯ ៦៤% ទៀត ស្ថិតនៅក្នុងផ្នែកលក់រាយហើយ ៣៥% ស្ថិតនៅក្នុងជាប្រភេទហាងលក់ចាប់ហួយនិងអាជីវកម្មគ្រឿងទេស។ នៅក្នុងវិស័យសេវាកម្មដែលជាឧស្សាហកម្មធំបំផុតទីពីរ សេវាកម្មម្ហូបអាហារ (ភោជនីយដ្ឋាន បារ ហាងលក់ម្ហូបជាដើម) មានរហូតដល់ទៅ ៤៨% នៃសហគ្រាស សេវាជួសជុល គឺ ២២% សេវាកម្មវិជ្ជាជីវៈ ៥% និងសេវាដទៃទៀត ២៥%។ នៅក្នុងវិស័យកម្មន្តសាល និងសំណង់ កម្មន្តសាល (មិនរាប់បញ្ចូលការកែច្នៃម្ហូបអាហារ) មានចំនួន ៥៧% នៃសហគ្រាស ការកែច្នៃម្ហូបអាហារ ១៥% និងសំណង់ ២៨% (IFC និងមូលនិធិអាស៊ី ឆ្នាំ២០០៩ ទំព័រទី៦)។

ក្នុងចំណោមក្រុមហ៊ុនចុះបញ្ជី ៦៣.៥០៧ ក្រុមហ៊ុនចំនួន ៤៥% មានទីតាំងនៅក្នុងរាជធានីភ្នំពេញ។ បើនៅដាច់ឆ្ងាយពីទីក្រុងភ្នំពេញ ខេត្តដែលមានសកម្មភាពសេដ្ឋកិច្ចខ្លាំងជាងគេ គឺ បាត់ដំបង កណ្តាល និងសៀមរាប ដែលមានក្រុមហ៊ុនធំបំផុត ចំនួន ១០,៥%, ៧%, និង ៥% តាមលំដាប់លំដោយ។ ខេត្តដែលមានក្រុមហ៊ុនចុះបញ្ជីតិចតួចបំផុត គឺ កែប ស្ទឹងត្រែង និងព្រះវិហារ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សហគ្រាសមីក្រូមានចំនួន ៩៧% នៃអាជីវកម្មទាំងអស់ដែលបានចុះបញ្ជី។ អាជីវកម្មតែ២% ប៉ុណ្ណោះគឺជាសហគ្រាសខ្នាតតូច ហើយតិចជាង ១% នៃចំនួនសរុប គឺជាសហគ្រាសមធ្យម និងធំ។ បណ្តាខេត្រភាគច្រើនគ្មានសហគ្រាសធំ ឬ មធ្យមទេ។ សៀមរាប ភ្នំពេញ កែប និងក្រុងព្រះសីហនុមានសហគ្រាសខ្នាតតូចច្រើនជាង គឺ៩% ៣% និង៣%។ ដោយឡែក ខេត្រកោះកុង ក្រចេះ ព្រៃវែង ពោធិ៍សាត់ ស្ទឹងត្រែង ស្វាយរៀង តាកែវ និងប៉ៃលិន ខេត្រនីមួយៗមានតិចជាង ១% ធៀបនឹងសហគ្រាសខ្នាតតូចសរុបទូទាំងប្រទេស។

ភ្នំពេញស្រូបកម្លាំងពលកម្ម៥៥% បន្ទាប់មក គឺខេត្រកណ្តាល សៀមរាប និងបាត់ដំបង ដែលស្រូបយកកម្លាំងពលកម្ម ១៨%, ៨%, និង៥%។ ខេត្រទាំងនេះមានក្រុមហ៊ុនច្រើនជាងគេ (៦៧%) ហើយស្រូបយកចំនួនកម្លាំងពលកម្មច្រើនជាងគេបំផុត (៨៦%)។

អាជីវកម្មនៅកម្ពុជាគឺនៅថ្មីនៅឡើយ។ មានអាជីវកម្មតែ១៥%ប៉ុណ្ណោះ ដែលបានដំណើរការបានជាង១០ឆ្នាំ។ អាជីវកម្មភាគច្រើន (៦៤%) ទើបតែកើតមានក្នុងរយៈពេលមិនដល់ ៥ឆ្នាំផង ចំណែកឯ ៣១% ផ្សេងទៀត ក្នុងរយៈពេលតិចជាង២ឆ្នាំ។ ចាប់តាំងពីឆ្នាំ២០០៣ មក ក្រុមហ៊ុនភាគច្រើនបានចាប់ផ្តើមរីកចម្រើនយ៉ាងឆាប់រហ័ស ដោយសារតែមានកំណើនវិនិយោគផ្ទាល់មកពីបរទេស (FDI) និងកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព។

ដោយសារតែអាជីវកម្មភាគច្រើននៅក្នុងប្រទេសកម្ពុជាមានទំហំតូច ប្រើប្រាស់បុគ្គលិកតិច និងគ្រប់គ្រងជាលក្ខណៈគ្រួសារ ធ្វើឱ្យអាជីវកម្មជាង ៩៩% ផ្តោតការយកចិត្តទុកដាក់តែទីផ្សារក្នុងស្រុក។ ហើយមានក្រុមហ៊ុនប្រហែលជា ១% ប៉ុណ្ណោះ ក្នុងចំណោមក្រុមហ៊ុនទាំងអស់ ដែលផ្តោតលើទីផ្សារ ទាំងអន្តរជាតិ និង ទាំងទីផ្សារក្នុងស្រុក។

ការវាយតម្លៃបរិយាកាសវិនិយោគរបស់ធនាគារពិភពលោក និង IFC ឆ្នាំ២០០៩ ក៏បានចង្អុលបង្ហាញផងដែរថា៖ (១) ក្រុមហ៊ុនកម្ពុជាមានទំនាក់ទំនងកាន់តែច្រើនឡើង ជាមួយនឹងទីផ្សារពិភពលោក (២) បច្ចេកវិទ្យាព័ត៌មានវិទ្យាទំនើបបានផ្តល់នូវតួនាទីគ្រឹះយ៉ាងសំខាន់ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ (៣) គុណភាព (សមត្ថភាព) របស់កម្មករក៏មានការកើនឡើងជាលំដាប់ហើយ (៤) ក្រុមហ៊ុនកម្ពុជាកាន់តែមានការចូលរួមពីកម្មករជាស្ត្រី កាន់តែច្រើនឡើង។ ផលិតភាពរបស់កម្មករ គឺស្ថិតនៅពីលើប្រទេសបង់ក្លាដេស ហើយនៅពីក្រោម ប្រទេសឡាវ ប្រទេសស្រីលង្កា និងវៀតណាម។ ទោះបីជាយ៉ាងណាក៏ដោយគម្លាតប្រាក់បៀវត្សរ៍ គឺមានតិចតួច ដែលធ្វើឱ្យមានបញ្ហាចោទខ្លះសម្រាប់ភាពប្រកួតប្រជែងរបស់កម្ពុជា។

នាពេលបច្ចុប្បន្ននេះ អនុវិស័យឧស្សាហកម្មចំបង គឺវាយនភ័ណ្ឌ និងសម្លៀកបំពាក់ ផលិតផលលោហៈ ផលិតផលម្ហូបអាហារ និងសារធាតុគីមី ដែលតម្រូវសម្រាប់តែទីផ្សារក្នុងស្រុក លើកលែងតែ វាយនភ័ណ្ឌសម្លៀកបំពាក់ចេញដែលផលិតសម្រាប់នាំចេញ ហើយក៏ជាទិសដៅទាក់ទាញសហគ្រិនឯកជន និងទុនវិនិយោគ ដែលរួមទាំងវិនិយោគិនបរទេស។ វិស័យឯកជនបានរៀបចំជាសហគមន៍ទៅតាមជំនាញផលិតផល ដើម្បីការពារផលប្រយោជន៍និងលើកកម្ពស់កិច្ចសន្ទនាជាមួយនឹងដៃគូពាក់ព័ន្ធ ដូចជារដ្ឋាភិបាល និងកម្មករ។ សមាគមឧស្សាហកម្មកាត់ដេរកម្ពុជា (GMAC) គឺជាឧទាហរណ៍មួយ ដែលមានជោគជ័យនៅក្នុងការចរចាកិច្ចព្រមព្រៀងជាច្រើនជាមួយនឹងរដ្ឋាភិបាល ក៏ដូចជាជាមួយនឹងកម្មករ។

### ១១.១.២. បញ្ហាចោទក្នុងការពន្លឿនកំណើននៃវិស័យធំដើប

ការកែលម្អក្របខ័ណ្ឌគតិយុត្តិ និងនិយ័តកម្មមានតួនាទីសំខាន់ណាស់ សម្រាប់ការអភិវឌ្ឍវិស័យឯកជន និងជំរុញកំណើន។ ការអភិវឌ្ឍវិស័យឯកជនត្រូវបានរាំងស្ទះផងដែរ ដោយសារការខ្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវ កំពង់ផែ ការទទួលបានវត្ថុធាតុដើម) ការអនុវត្តច្បាប់មិនបានពេញលេញ ឧបសគ្គដើម្បីទទួលបានហិរញ្ញប្បទាន អំពើពុករលួយ ព័ត៌មានមានកំណត់ កង្វះខាតធនធានមនុស្សដែលមានគុណភាព និងថ្លៃអគ្គិសនី ទឹក និងទូរគមនាគមន៍ខ្ពស់ជាងប្រទេសជិតខាង។ ការវិនិយោគឯកជនក្នុងវិស័យកសិកម្មនៅមានកម្រិតនៅឡើយ ដោយសារភាពមិនច្បាស់លាស់ទាក់ទងនឹងកម្មសិទ្ធិដីធ្លី និងរបៀបរបបកាន់កាប់ដី។

អត្ថប្រយោជន៍ពីការលើកទឹកចិត្តសារពើពន្ធ សម្រាប់ការវិនិយោគវិស័យឯកជនមិនទាន់មានភាពច្បាស់លាស់នៅឡើយ ប៉ុន្តែរដ្ឋបង់ចំណូលដែលបណ្តាលមកពីការលើកទឹកចិត្តនេះ។ នៅក្នុងឆ្នាំ ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវការធ្វើវិសោធនកម្មច្បាប់វិនិយោគ ដើម្បីធ្វើសនិទានកម្មការលើកទឹកចិត្តសារពើពន្ធ។ វិធានការនេះរួមមាន៖

- ការដាក់ឱ្យអនុវត្តពន្ធលើប្រាក់ចំណេញ ក្នុងអត្រា ២០%។
- ការលុបចោលការលើកលែងពន្ធលើប្រាក់ចំណេញ ដែលយកមកវិនិយោគឡើងវិញ ហើយនិងការដាក់ឱ្យអនុវត្តប្រការថ្មីក្នុងច្បាប់ស្តីពីពន្ធដារ ដោយកាត់បន្ថយការលើកលែងពន្ធលើប្រាក់ចំណេញដែលយកមកវិនិយោគឡើងវិញ ឱ្យបានដល់កម្រិតតិចតួចបំផុត ដោយមិនគិតទៅលើគម្រោងការថ្មី ឬការពង្រីកគម្រោងការដែលមានស្រាប់ ហើយមិនគិតទៅលើប្រភពហិរញ្ញប្បទាន។
- ការដាក់ឱ្យអនុវត្តរូបមន្តថ្មី ដែលអនុញ្ញាតឱ្យមានការលើកលែងលែងពន្ធលើប្រាក់ចំណូល សម្រាប់អាជីវកម្មក្នុងរយៈពេល៣ឆ្នាំ បន្ទាប់ពីចាប់ផ្តើមសកម្មភាព ហើយអាចបន្ថែម ៣ឆ្នាំទៀត។
- លុបចោលសិទ្ធិក្នុងរួចពន្ធពីការផ្ទេរប្រាក់ចំណេញទៅក្រៅប្រទេស និងការផ្ទេរចំណូលដទៃទៀតដោយអាជីវកម្មដែលមានការអនុញ្ញាត។

ការអនុម័តនិងការអនុវត្តឱ្យបានជោគជ័យ នូវយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍវិស័យឯកជននឹងធ្វើឱ្យកម្ពុជាមានសេចក្តីសង្ឃឹមខ្លាំងសម្រាប់កំណើន និងការកាត់បន្ថយភាពក្រីក្រ។ កម្ពុជានឹងទទួលបានផលប្រយោជន៍កាន់តែច្រើន ពីសមាហរណកម្មទៅក្នុងតំបន់និងសកលភាវូបនីយកម្ម ទទួលបានផលប្រយោជន៍យ៉ាងពេញលេញពីសមិទ្ធផលម៉ាក្រូសេដ្ឋកិច្ច និងទីតាំងភូមិសាស្ត្រល្អប្រសើរនៅអាស៊ីខាងកើត និងការជ្រៀតចូលទីផ្សារនៅអឺរ៉ុប និងអាមេរិក។ មូលដ្ឋានគ្រឹះនៃយុទ្ធសាស្ត្រនេះមានដូចតទៅ៖

- ពង្រឹងចក្ខុវិស័យ និងទស្សនអនាគតអភិវឌ្ឍន៍រយៈពេលវែង
- បង្កើនប្រសិទ្ធភាពអន្តរាគមន៍របស់រដ្ឋ
- កសាងសមត្ថភាពវិស័យឯកជន។

ចក្ខុវិស័យរយៈពេលវែង សម្រាប់ការអភិវឌ្ឍវិស័យឯកជនឱ្យដល់កម្រិតគួរកត់សម្គាល់នោះអាចនឹងពឹងផ្អែកលើថាតើសហគ្រិនឯកជនអាចសម្របសម្រួលបានលឿនប៉ុណ្ណា ទៅនឹងការធ្វើសមាហរណកម្មរបស់កម្ពុជា ចូលក្នុងអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក។ ដំណើរការនេះបង្កើតឱ្យមានកាលានុវត្តភាព

ថ្មីៗ និងក៏បង្ហាញពីការគំរាមកំហែងជាក់ស្ដែងមួយចំនួន។ កម្ពុជាមានភាពល្អប្រសើរជាងគូប្រកួតប្រជែងរបស់ខ្លួនក្នុងផ្នែក២គឺ ៖ ប្រាក់ឈ្នួលទាប និងការអនុវត្តតាមបទដ្ឋានពលកម្មអន្តរជាតិ។ សហរដ្ឋអាមេរិក និងប្រទេសអឺរ៉ុបមិនចង់ទិញផលិតផលពី «ប្រទេសដែលមានលក្ខខណ្ឌពលកម្មមិនល្អ» ទៀតទេ ដែលក្នុងប្រទេសទាំងនោះ លក្ខខណ្ឌការងារអប្បបរមាមិនត្រូវធានាបាន។ កម្ពុជាបានទទួលយកតម្រូវការដើម្បីឈានចូលទីផ្សារនេះ និងបានដាក់ដំណើរការប្រព័ន្ធត្រីភាគីនៃការគ្រប់គ្រងផលិតកម្ម ដែលក្នុងនោះម្ចាស់អាជីវកម្ម កម្មករ និងរដ្ឋាភិបាល ក្រោមការត្រួតពិនិត្យរបស់អង្គការពលកម្មអន្តរជាតិ សហការគ្នានិងធានារួមគ្នាថាបទដ្ឋានពលកម្មអន្តរជាតិត្រូវបានបំពេញក្នុងដំណើរការផលិតកម្ម។ រាជរដ្ឋាភិបាលត្រូវផ្សព្វផ្សាយប្រព័ន្ធនេះថាជាឧត្តមភាពប្រៀបធៀប សម្រាប់កម្ពុជាក្នុងកិច្ចចរចានិងការពិភាក្សានានា។

អន្តរាគមន៍របស់រដ្ឋច្រើនពេកក្នុងអាជីវកម្មធ្វើឱ្យថ្លៃដើមអាជីវកម្មកើនឡើង ហើយវាគឺជាពន្ធលើការវិនិយោគ និងកំណើន។ ក្នុងប្រទេសកម្ពុជា ថ្លៃដើមសម្រាប់ចាប់ផ្ដើមអាជីវកម្មមួយ គឺស្មើនឹង ៦១៥ ដុល្លារអាមេរិក ដែលជាតម្លៃខ្ពស់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ប៉ុន្តែថ្លៃដើមនេះកម្រនឹងកើតមានណាស់ក្នុងការអនុវត្តន៍ដោយសារតែអាជីវកម្មថ្មីភាគច្រើនស្ថិតក្នុងវិស័យក្រៅផ្លូវការ។ក្រៅពីតម្រូវការនេះច្បាប់និងបទបញ្ញត្តិខ្លះៗទៀតត្រូវបានអនុវត្ត។ យោងទៅតាមរបាយការណ៍របស់ធនាគារពិភពលោក ច្បាប់និងបទបញ្ញត្តិច្រើនពេកនឹងកាត់បន្ថយការបង្កើតការងារធ្វើ សម្រាប់យុវជននិងស្ត្រី។ លើសពីនេះទៀត «ជាញឹកញាប់វាជាប់ទាក់ទងនឹងភាពគ្មានប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ (ការពន្យារពេលដ៏យូរជាងធម្មតា ថ្លៃដើមខ្ពស់ពេក) ជាប់ទាក់ទងនឹងការកើនឡើងនៃភាពគ្មានការងារ អំពើពុករលួយ ផលិតភាពនិងការធ្លាក់ចុះនៃការវិនិយោគទុន»។

របាយការណ៍នេះស្នើឡើងឱ្យមាននូវកំណែទម្រង់ជាបន្តបន្ទាប់ ដែល «ងាយស្រួលក្នុងការអនុវត្តន៍» គឺ ៖ កាត់បន្ថយបទបញ្ញត្តិផ្សេងៗ លុបចោលប្រាក់ឈ្នួលអប្បបរមា កែសម្រួលរយៈពេលធ្វើការងារចំពោះផ្នែកដែលមានសកម្មភាពខ្ពស់ ដែលនឹងអាចជៀសវាងការចំណាយសម្រាប់ម៉ោងបន្ថែម កែសម្រួលឱ្យនីតិវិធីបញ្ឈប់ការងារមានលក្ខណៈងាយស្រួល អន្តរាគមន៍តិចជាងមុនពីសំណាក់តុលាការមកលើបញ្ហាពាណិជ្ជកម្ម តម្លាភាពចំពោះព័ត៌មានស្ដីពីឥណទាន ការកែសម្រួលនីតិវិធីតុលាការសម្រាប់ការប្រមូលបំណុលឱ្យមានលក្ខណៈងាយស្រួល ការពង្រឹងការការពារតាមផ្លូវច្បាប់ចំពោះឥណទានយក កំណែទម្រង់ច្បាប់ក្ស័យធន និងការអនុវត្តកំណែទម្រង់ជាប្រចាំដូចភ្លៀងរលឹម។ ក៏ប៉ុន្តែ គេក៏ត្រូវពិចារណាពីផលប៉ះពាល់នៃអនុសាសន៍ទាំងនេះ ចំពោះបទដ្ឋានពលកម្មរបស់អង្គការពលកម្មអន្តរជាតិ និងចំពោះបទដ្ឋានអភិបាលកិច្ចទូទៅ មុននឹងអាចដាក់ឱ្យអនុវត្តវិធានការទាំងនេះ។

### ១១.១.៣. ការបង្កើនប្រសិទ្ធិភាពនៃអន្តរាគមន៍របស់រដ្ឋ

ផ្នែកខាងក្រោមនេះ គឺជាផ្នែកអាទិភាពក្នុងកំណែទម្រង់នៃអន្តរាគន៍របស់រដ្ឋក្នុងអាជីវកម្ម៖

- ក្របខ័ណ្ឌគតិយុត្តិ និង ប្រព័ន្ធយុត្តិធម៌
- ការធ្វើហិរញ្ញប្បទាន
- ការកាត់បន្ថយនីតិវិធីផ្សេងៗ
- សេរីភាវូបនីយកម្មនៃពាណិជ្ជកម្មនិងការកំណត់ថ្លៃនិងការជំរុញការប្រកួតប្រជែង
- កំណែទម្រង់រដ្ឋបាលសាធារណៈ
- គោលនយោបាយសារពើពន្ធនិងការគ្រប់គ្រងធនធានសាធារណៈ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១១.១.៣.១. ការបង្កើតក្របខ័ណ្ឌគតិយុត្តិ និងប្រព័ន្ធយុត្តិធម៌សម្រាប់ជំរុញគំនិតផ្តួចផ្តើមផ្នែកឯកជន

ការវិនិយោគឯកជននិងទីផ្សារអាចរីកចម្រើនបានតែក្នុងបរិយាកាស ដែលច្បាប់មានភាពច្បាស់លាស់ មានស្ថេរភាព និងត្រូវបានអនុវត្ត និងក្នុងបរិយាកាស ដែលការប្រកួតប្រជែងត្រូវបានធានាដោយមានប្រសិទ្ធភាព។ ក្របខណ្ឌគតិយុត្តិសម្រាប់អាជីវកម្មត្រូវធានាឱ្យបាននូវសិទ្ធិជាម្ចាស់កម្មសិទ្ធិ និងរៀបចំមូលដ្ឋានសុវត្ថិភាពសម្រាប់សកម្មភាពសេដ្ឋកិច្ច។ ជាងនេះទៀត ការកំណត់វិធាននៃល្បែងឱ្យមានសង្គតិភាពចំពោះប្រតិបត្តិករផ្សេងៗគ្នា និងការអនុវត្តច្បាប់ទាំងនេះប្រកបដោយប្រសិទ្ធភាព គឺជាបុរេលក្ខខណ្ឌសម្រាប់ការផ្នែកឯកជន និងដំណើរការទីផ្សារ។ ច្បាប់និងបទប្បញ្ញត្តិទាំងនេះត្រូវតែត្រូវបានធានាដោយប្រព័ន្ធតុលាការមួយ ដែលបំពេញមុខងារបានត្រឹមត្រូវ ស្មើភាព និងជឿទុកចិត្តបាន និងដែលឯករាជ្យពីស្ថាប័ននីតិបញ្ញត្តិនិងនីតិប្រតិបត្តិ។

ទំនាក់ទំនងរវាងក្របខ័ណ្ឌច្បាប់និងសេដ្ឋកិច្ចត្រូវរៀបចំឡើង ទាំងក្នុងបរិបទក្នុងប្រទេស និងសកលភាវូបនីយកម្ម។ ក្នុងបរិបទក្នុងប្រទេស ប្រព័ន្ធតុលាការមានឥទ្ធិពលលើអកប្បកិរិយារបស់ប្រតិបត្តិករសេដ្ឋកិច្ចក្នុងការរៀបចំដំណើរការអាជីវកម្ម និងប្រតិបត្តិការរបស់ពួកគេ។ ក្នុងទំនាក់ទំនងអន្តរជាតិ ក្របខ័ណ្ឌគតិយុត្តិមានឥទ្ធិពលជារួម ទៅលើការវាស់ស្ទង់ហានិភ័យក្នុងប្រទេសដោយវិនិយោគិន។ ទោះបីជា វិនិយោគិនមិនចាកចោលប្រទេសដែលមានហានិភ័យខ្ពស់ ពួកគេនឹងស្វះស្វែងរកលទ្ធភាពសម្រាប់រកប្រាក់ចំណេញខ្ពស់ក្នុងរយៈពេលខ្លី នៅក្នុងប្រទេសដែលមានហានិភ័យខ្ពស់។ បន្ថែមទៅលើទិដ្ឋភាពទូទៅទាំងនេះ គឺបញ្ហាជាក់ស្តែងផ្សេងៗ ដែលកើតមានឡើងចំពោះសេដ្ឋកិច្ចស្ថិតក្នុងដំណើរការកំណែទម្រង់។ តួនាទីដ៏មានប្រសិទ្ធភាពនៃសេដ្ឋកិច្ចទីផ្សារពឹងផ្អែកលើបរិយាកាសច្បាប់ ដែលនឹងធានានូវថាមភាព និងការគោរពច្បាប់។ ក្នុងន័យនេះ បរិយាកាសច្បាប់ក្នុងការកែទម្រង់សេដ្ឋកិច្ចត្រូវឆ្លើយតបទៅនឹងអាទិភាពជាក់លាក់៖ សម្រួលដល់ការបែងចែកទ្រព្យសកម្ម ដែលជាលទ្ធផលនៃកំណែទម្រង់សេដ្ឋកិច្ច និងការផ្លាស់ប្តូរ។

តាមការអង្កេតនិងស្ទង់មតិរបស់វិនិគិននាពេលថ្មីៗនេះ បានឆ្លុះបញ្ចាំងឱ្យឃើញនូវឧបសគ្គជាច្រើននៅក្នុងដំណើរការប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌ឱ្យមានប្រសិទ្ធភាព ដូចជា៖

- ប្រព័ន្ធការិយាធិបតេយ្យដែលមិនចាំបាច់ ការត្រួតពិនិត្យមិនចេះចប់មិនចេះហើយ បទប្បញ្ញត្តិដែលរៀបចំមិនបានល្អ និងមិនជាក់លាក់
- ភាពស្មុគស្មាញនៃការធ្វើនិយ័តកម្ម (ច្បាប់ ពន្ធ និងសង្គម)
- នីតិវិធីតុលាការយឺត ខ្វះខាតយុត្តាធិការ គុណភាពនៃច្បាប់ខ្លះ ដែលបង្កើតការបកស្រាយផ្សេងៗគ្នា
- ភាពស្មុកស្រពន់និងការមិនអាចព្យាករណ៍បាននៃប្រព័ន្ធតុលាការ។ តុលាការជារឿយៗខ្វះខាតធនធាន ដែលធ្វើឱ្យការកាត់ក្តីមានភាពយឺតយ៉ាវ។

កម្ពុជាមានការងារច្រើនណាស់ដែលត្រូវធ្វើ ដើម្បីកែលម្អប្រព័ន្ធតុលាការ។ វិនិយោគិនតែងតែត្អូញត្អែរពីភាពខ្វះខាតនៃចៅក្រម និងអសមត្ថភាពរបស់ចៅក្រមខ្លះ ហើយនឹងអំពើពុករលួយដែលនាំឱ្យមានការកាត់សេចក្តីដែលមិនអាចព្យាករណ៍បាន និងថែមទាំងមិនអាចទទួលយកបាន។ ម្យ៉ាងវិញទៀត វិនិយោគិនបាត់ជំនឿនៅក្នុងនីតិវិធីការទាបំណុលវិញ។

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តអនុវត្តកំណែទម្រង់ ក្នុងគោលដៅរៀបចំប្រព័ន្ធតុលាការ ដែលគ្រប់ជ្រុងជ្រោយនិងអំណោយផលដល់ការវិនិយោគ ដើម្បីសម្រួលដល់ធុរកិច្ច ដែលជាផ្នែកមួយនៃកាតព្វកិច្ចរបស់កម្ពុជា ក្នុងការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ កំណែទម្រង់នេះនឹងជួយដោះស្រាយបញ្ហា ដូចតទៅនេះ៖

- ពង្រឹងការការពារសិទ្ធិរបស់សាជីវកម្មក្នុងទំនាក់ទំនងជាមួយរដ្ឋ
- សម្រួលច្បាប់ឱ្យសមស្រមទៅនឹងតម្រូវការរបស់សាជីវកម្ម
- ធានានូវប្រសិទ្ធភាពនៃការអនុវត្តច្បាប់សាជីវកម្ម
- បង្កើតច្បាប់គ្រប់គ្រងកម្ចីនិងការប្រមូលបំណុលមកវិញបានដើម្បីឱ្យមានកំណើន
- គាំទ្រការលើកតម្កើងច្បាប់ពាណិជ្ជកម្ម។

ទន្ទឹមគ្នានោះផងដែរ រាជរដ្ឋាភិបាលនឹងលើកទឹកចិត្តឱ្យមាននីតិវិធីមជ្ឈត្តិកម្ម ដើម្បីដោះស្រាយ វិវាទ និងបង្កើនការបណ្តុះបណ្តាលចៅក្រមនិងក្រឡាបញ្ជី។ ជាសរុបមក ប្រព័ន្ធតុលាការនិងច្បាប់ កំពុងតែស្ថិតនៅក្រោមការធ្វើកំណែទម្រង់ ដែលគេសង្ឃឹមនឹងចូលរួមចំណែកធ្វើឱ្យប្រសើរឡើងដល់បរិយាកាសធុរកិច្ច។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាសំខាន់ គឺត្រូវពង្រឹងការធ្វើកំណែទម្រង់ និងដើម្បីធានាឱ្យបាន នូវដំណើរការនៃប្រព័ន្ធយុត្តិ និងការអនុវត្តច្បាប់ ដោយគ្មានចន្លោះប្រហោង។

ដើម្បីត្រួតពិនិត្យនិងសម្របសម្រួលកំណែទម្រង់នេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតកាលពីខែមិថុនា ឆ្នាំ២០០២ នូវក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងតុលាការ (CLJR) ដែលមានឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រីនិងប្រធានតុលាការកំពូល ជាសហប្រធាន។ កាលពីខែធ្នូឆ្នាំ២០០២ រាជរដ្ឋាភិបាលបានបង្កើតនាយកដ្ឋានគ្រប់គ្រងគម្រោង ដើម្បីរៀបចំយុទ្ធសាស្ត្រស្តីពីកំណែទម្រង់ច្បាប់និងតុលាការ។ ភារកិច្ច ដ៏សំខាន់របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងតុលាការរួមមាន៖ ការកែលម្អគុណភាពនៃសាលក្រមរបស់តុលាការ ការធានាឱ្យបាននូវការអនុវត្តឱ្យមានប្រសិទ្ធភាព និងតម្រូវការការគាំទ្រស្ថាប័ន ឧទាហរណ៍ ការជំរុញការប្រើប្រាស់កុំព្យូទ័រ។ លទ្ធផលដែលរំពឹងថានឹងទទួលបានគឺ៖

- បណ្តុះបណ្តាលនិងបង្រៀនចៅក្រមនិងក្រឡាបញ្ជី
- ការធ្វើឱ្យប្រសើរឡើងនូវតួនាទីរបស់តុលាការ
- ភាពដែលអាចទទួលបានរបស់ប្រជាជននៅក្រោមយុត្តាធិការតុលាការ។

សកម្មភាពដែលអនុវត្តដោយក្រុមប្រឹក្សាកំណែងទម្រង់ច្បាប់និងតុលាការនាពេលនេះរួមមាន៖ (១) គាំទ្រក្របខ័ណ្ឌស្ថាប័ន (២) គាំទ្រការធ្វើឱ្យប្រសើរឡើងនៃច្បាប់គ្រប់គ្រងសាជីវកម្ម និង (៣) គាំទ្រកំណែទម្រង់បន្ត និងការលើកកម្ពស់ច្បាប់ស្តីពីពាណិជ្ជកម្ម។ គោលដៅនៃកំណែទម្រង់ និងការពង្រឹងសមត្ថភាពរបស់ប្រព័ន្ធច្បាប់និងតុលាការ មានដូចតទៅ៖ (១) ការដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធតុលាការនិងការចំណាយទុនពាក់ព័ន្ធ (២) ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (៣) ប្រព័ន្ធដែលធ្វើឱ្យការធានាឥណទានធនាគារដំណើរការទៅបាន។ ដើម្បីគ្រប់គ្រងកំណែទម្រង់ឱ្យមានប្រសិទ្ធភាព នៅក្នុងវិស័យយុត្តិធម៌ រាជរដ្ឋាភិបាលបានបង្កើនធនធាន និងបុគ្គលិកនៅក្នុងវិស័យនេះ និងផ្តល់ការបណ្តុះបណ្តាល ជាពិសេស ក្នុងគោលដៅគ្រប់គ្រងបញ្ហាសេដ្ឋកិច្ចឱ្យបានល្អ។

### ១១.១.៣.២. ការកាត់បន្ថយនីតិវិធី

នីតិវិធីរដ្ឋបាលសាំញ៉ាំនិងមិនច្បាស់លាស់ គឺជាឧបសគ្គធ្ងន់ធ្ងរចំពោះការវិនិយោគឯកជន។ ដើម្បីសម្រេចឱ្យបាននូវកំណើនតាមការគ្រោងទុក (៦-៧% ក្នុងមួយឆ្នាំ) រាជរដ្ឋាភិបាលត្រូវធ្វើយ៉ាងណា ដើម្បីបង្កើនការវិនិយោគឯកជនឱ្យបានច្រើន។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាពីសំណាក់រាជរដ្ឋាភិបាល ការវិនិយោគឯកជននៅកម្ពុជានៅតែមិនមានកម្រិតនៅឡើយ។ ការវិនិយោគដោយផ្ទាល់ពីបរទេសមិនត្រឹមតែនាំមកនូវទុនប៉ុណ្ណោះទេ តែវានាំមកនូវការផ្លាស់ប្តូរបច្ចេកវិទ្យា និងការគ្រប់គ្រងផងដែរ។ ដូច្នេះ ប្រសិនបើកម្ពុជាមិនអាចទាក់ទាញវិនិយោគឯកជនឱ្យបានច្រើន នោះយើងមិនអាចអភិវឌ្ឍប្រទេសជាតិបានឡើយ។ បរិយាកាសធុរកិច្ចមានតួនាទីសំខាន់ណាស់សម្រាប់វិនិយោគិនបរទេស ដោយសារតែពួកគេមានជម្រើសច្រើន និងសិទ្ធិសេរីភាពពេញទីក្នុងការជ្រើសរើសយកប្រទេសណាមួយធ្វើការវិនិយោគ។ ឧបសគ្គមិនចាំបាច់និងការខ្វះតម្លាភាពក៏ជួយបង្កើតឱ្យមានអំពើមិនប្រក្រតីនិងអំពើពុករលួយផងដែរ។ កង្វះតម្លាភាពក្នុងការអនុវត្តច្បាប់និងការធ្វើនិយ័តកម្មអាចផ្តល់ផលប្រយោជន៍ដល់ឯកជន ដោយមិនគិតពីសុខុមាលភាពសាធារណៈ។

ដើម្បីធ្វើឱ្យប្រសើរឡើងបរិយាកាសធុរកិច្ច នៅក្នុងឆ្នាំ ២០០៤ រដ្ឋាភិបាលបានបង្កើតការិយាល័យច្រកចេញចូលតែមួយនៅឯក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយបានធ្វើវិសោធនកម្មច្បាប់វិនិយោគក្នុងឆ្នាំ ២០០៣ ដើម្បីធ្វើសនិទានកម្មប្រព័ន្ធលើកទឹកចិត្ត។ រហូតដល់ចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិមជ្ឈការសេចក្តីសម្រេចលើការវិនិយោគឱ្យដល់ខេត្ត ហើយបានបង្កើតមជ្ឈមណ្ឌលចុះបញ្ជីពាណិជ្ជកម្មច្រកចេញចូលតែមួយ ដើម្បីកែលម្អនីតិវិធី។ ទោះបីជាមានជំហានសំខាន់ទាំងអស់នេះក៏ដោយ វានៅមានកិច្ចការច្រើនណាស់ដែលត្រូវធ្វើបន្តទៀត ដើម្បីកែលម្អនីតិវិធីវិនិយោគ ពាណិជ្ជកម្ម និងពន្ធគយនៅកម្ពុជា និងដើម្បីធានាតម្លាភាព។ បញ្ហាការយឺតយ៉ាវ ចំណាយក្រៅផ្លូវការ និងការធ្វើឱ្យវិនិយោគិនឈឺក្បាល គឺជាបញ្ហាទូទៅរបស់ប្រទេស ដែលប្រើក្រមវិនិយោគដែលបង្កើតឡើង ដោយផ្អែកលើការលើកទឹកចិត្តសារពើពន្ធ ហើយកម្ពុជាមិនមែនជាប្រទេសតែមួយដែលធ្វើបែបនេះនោះទេ។

នីតិវិធីសម្រាប់ការចុះបញ្ជីនិងទទួលបានការអនុញ្ញាតវិនិយោគ ត្រូវបានគេចាត់ទុកថា មានលក្ខណៈផ្តាំផ្គងនិងសាំញ៉ាំ និងអស់ចំណាយច្រើន ជាមួយនឹងដំណាក់កាលផ្សេងៗគ្នាជាច្រើន ហើយដំណាក់កាលនីមួយៗ ដែលទាមទារឱ្យមានការអនុញ្ញាតរបស់មន្ត្រី ដោយទាមទារឯកសារគាំទ្រផ្សេងៗទៀត។ លទ្ធភាពទទួលបានដីនិងការអភិវឌ្ឍការដ្ឋានឧស្សាហកម្មក៏មានលក្ខណៈសាំញ៉ាំផងដែរ ដោយសារការពន្យារពេលយូរនិងអស់ចំណាយច្រើន។ដើម្បីបង្កើតបរិយាកាសធុរកិច្ច ដែលមានលក្ខណៈអនុគ្រោះជាងនេះ រាជរដ្ឋាភិបាលត្រូវរៀបចំនីតិវិធីសម្រាប់ការសម្រេចចិត្តរួមគ្នា និងការផ្តល់ការអនុញ្ញាត (អាជ្ញាប័ណ្ណ) ឱ្យមានលក្ខណៈសាមញ្ញ។ នេះគឺជាបញ្ហាដែលត្រូវលើកឡើងនៅក្នុងកំណែទម្រង់ទាក់ទងនឹងការកែសម្រួលនីតិវិធី។

### ១១.១.៣.៣.ការអនុវត្តច្បាប់ការងារ

ទោះបីជាច្បាប់ស្តីពីការងារត្រូវបានអនុម័តជាងមួយទសវត្សរ៍កន្លងមកហើយក៏ដោយ នៅថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ការអនុវត្តច្បាប់នេះគឺការងារដែលត្រូវជំរុញឱ្យមានប្រសិទ្ធភាពខ្ពស់។ ទោះបីជាការអនុវត្តច្បាប់នេះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះមានភាពរលូនក៏ដោយ ច្បាប់ស្តីពីការងារបានបង្កើតនូវភាពមិនប្រាកដប្រជាខ្លះ សម្រាប់បរិយាកាសធុរកិច្ចនៅកម្ពុជា ដោយសារតែភាគីពាក់ព័ន្ធមិនទាន់គោរពច្បាប់ឱ្យបានពេញលេញ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការសំខាន់ៗជាច្រើន ទាក់ទងនឹងច្បាប់ការងារ ដើម្បីរៀបចំជាមួយនឹងនិយោជក និងសហជីពកម្មករនូវយន្តការអនុវត្តឱ្យរលូន។ គោលដៅនៃវិធានការទាំងអស់នោះ គឺ៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ពង្រឹងភាពប្រកួតប្រជែងរបស់ធុរៈកិច្ច តាមរយៈការបង្កើនផលិតភាពពលកម្ម
- បង្កើនភាពទន់ភ្លន់ទាក់ទងនឹងការជួល និងការបញ្ឈប់ពលករ
- បង្ការការវិវាទសង្គមនៅក្នុងធុរកិច្ច តាមរយៈការបង្កើតវប្បធម៌សន្ទនានៅក្នុងសហគ្រាស រវាងរដ្ឋាភិបាល និយោជក និងសហជីពកម្មករ។

### ១១.១.៣.៤. បន្តកំណែទម្រង់រដ្ឋបាលសាធារណៈ

កំណែទម្រង់រដ្ឋបាលបានកើតឡើងពីភាពចាំបាច់ ដើម្បីឱ្យរដ្ឋអាចសម្របសម្រួលខ្លួន ទៅតាមការប្រែប្រួលនៃបរិស្ថានសង្គម និងការបង្កើនប្រសិទ្ធភាពនៃអន្តរាគមន៍របស់រដ្ឋ។ ការបែងចែកឡើងវិញនូវតួនាទីរបស់រដ្ឋនិងវិស័យឯកជនទាមទារឱ្យមានជំនាញខាងផ្នែកគ្រប់គ្រងរដ្ឋបាល ការបើកចិត្តឱ្យទូលាយ និងការចែករំលែកព័ត៌មាន ក្នុងគោលដៅឱ្យភាគីពាក់ព័ន្ធអាចបំពេញតួនាទីរបស់ខ្លួនបាន ក្នុងការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍។ ចាប់តាំងពីឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តកំណែទម្រង់ជាច្រើន ដើម្បីកែលម្អគុណភាពនៃសេវាសាធារណៈ។ ក៏ប៉ុន្តែ ចំណុចខ្សោយធំបំផុតនៅក្នុងរដ្ឋបាលសាធារណៈ គឺសមត្ថភាពគ្រប់គ្រងសម្រាប់ការអភិវឌ្ឍនៅខ្សោយ នីតិវិធីនៅវែងអន្លាយ និងមានមន្ត្រីអវត្តមានមិនមកធ្វើការច្រើន។ សភាពការណ៍នេះអាចបណ្ដាលមកពីការខ្វះខាតការលើកទឹកចិត្តរបស់មន្ត្រីរាជការ ហើយពួកគេខ្វះខាតមធ្យោបាយ សម្រាប់ការអនុវត្តការទទួលខុសត្រូវរបស់ខ្លួន រួមទាំងប្រាក់ខែទាបទៀតផង។

ចំណុចសំខាន់នៃកំណែទម្រង់រដ្ឋបាលថ្នាក់កណ្ដាល គឺការដែលធ្វើឱ្យរដ្ឋាភិបាលមានការយកចិត្តទុកដាក់ច្រើនថែមទៀត ទៅលើការគាំទ្រយុទ្ធសាស្ត្រអភិវឌ្ឍវិស័យឯកជន។ តួនាទីរបស់រដ្ឋាភិបាល គឺការធានាឱ្យបានថា វិស័យឯកជនអាចដំណើរការទៅបានដោយសេរី នៅក្នុងដែនកំណត់ និងយន្តការដែលកំណត់ច្បាស់លាស់ ដោយធានាឱ្យបាននូវតម្លាភាព គណនេយ្យភាព សវនកម្ម ការសរសើរ និងការដាក់ទណ្ឌកម្ម។ គោលដៅរបស់រដ្ឋាភិបាលគឺបង្កើនប្រសិទ្ធភាពសមិទ្ធផលនិងត្រួតពិនិត្យការបង់ថ្លៃបន្ថែម។ចំណាយទាំងអស់នេះរាប់បញ្ចូលផងដែរនូវអំពើពុករលួយ ដែលមានគ្រោះថ្នាក់បំផុត ដោយសារតែវានាំឱ្យមានការបែងចែកធនធានដោយគ្មានប្រសិទ្ធភាព។

ការខ្វះចន្លោះដ៏សំខាន់នៅក្នុងកំណែទម្រង់សាធារណៈ គឺរដ្ឋបាលមូលដ្ឋានគ្មានអំណាច។ ដើម្បីបំពេញឱ្យបានគ្រប់ជ្រុងជ្រោយនៃសហវិមជ្ឈការ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការ ដើម្បីធ្វើឱ្យមានតុល្យភាព រវាងរដ្ឋបាលថ្នាក់កណ្ដាលដែលខ្លាំងតែនៅឆ្ងាយ និងអាជ្ញាធរមូលដ្ឋានដែលនៅកៀកនឹងប្រជាជនតែគ្មានធនធាន។ ដំណោះស្រាយ គឺការប្រែក្លាយតំបន់ឱ្យទៅជាអាជ្ញាធរមូលដ្ឋាន ដែលសម្របសម្រួល។ នៅក្នុងដំណាក់កាលបច្ចុប្បន្ននៃការអនុវត្តកំណែទម្រង់នេះ ឧបសគ្គធំៗបណ្ដាលមកពីសមត្ថភាពគ្រប់គ្រងនៅខ្សោយ នៅកម្រិតតំបន់ និងប្រភពហិរញ្ញវត្ថុមូលដ្ឋាននៅមានកម្រិតទាប។ តាមការពិត ការគ្រប់គ្រងចំណូលពន្ធគួរតែផ្ដោតទៅលើសុខដុមនីយកម្មនៃវិធានការសារពើពន្ធ នៅថ្នាក់កណ្ដាល និងនៅមូលដ្ឋានដើម្បីជៀសវាងការដាក់បន្ទុកហួសហេតុលើវិស័យឯកជន។

### ១១.១.៣.៥. ការពង្រឹងគុណភាពនៃអន្តរកម្មហិរញ្ញវត្ថុ

វិស័យហិរញ្ញវត្ថុរឹងមាំនឹងមានឥទ្ធិពលជាវិជ្ជមានដ៏ខ្លាំងទៅលើកំណើនសេដ្ឋកិច្ច។ វិស័យហិរញ្ញវត្ថុដែលរឹងមាំគាំទ្រដល់ការកៀរគរធនធានក្នុងស្រុកពីវិស័យឯកជន ហើយជួយពង្រឹងប្រសិទ្ធភាព នៅក្នុងការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បែងចែកធនធាន តាមរយៈការជ្រើសរើសគម្រោងការសមស្របសម្រាប់ផ្តល់ហិរញ្ញប្បទាន។ រដ្ឋមានតួនាទីយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ការអភិវឌ្ឍស្ថាប័នពាក់ព័ន្ធនៅក្នុងហិរញ្ញប្បទានរយៈពេលវែង ដែលរួមមានស្ថាប័នឯកទេស ការដាក់ឱ្យអនុវត្តនិងផ្សព្វផ្សាយបទប្បញ្ញត្តិស្តីពីឧបករណ៍ហិរញ្ញវត្ថុ ដែលសមស្របនឹងតម្រូវការជាក់ស្តែងរបស់ទីផ្សារហិរញ្ញវត្ថុ (ការធានារ៉ាប់រង ទុនហានិភ័យ ភតិសន្យាហិរញ្ញវត្ថុជាដើម)។ រដ្ឋត្រូវដាក់ចេញនូវវិធានការ ដើម្បីកែលម្អក្របខ័ណ្ឌគតិយុត្តិនិងលិខិតបទដ្ឋាន ពាក់ព័ន្ធនឹងការប្រកួតប្រជែង វិធានប្រុងប្រយ័ត្ន ពន្ធ អត្រាការប្រាក់ សិទ្ធិទទួលឥណទាន និងច្បាប់ស្តីអំពីការទារបំណុល។ល។

ការលំបាករបស់សហគ្រាសតូចនិងមធ្យមនិងអាជីវកម្មថ្មីៗ ក្នុងការទទួលបានឥណទាននៅតែជាបញ្ហាចម្បងនៅឡើយ។ ថ្វីត្បិតតែជាគោលការណ៍ រដ្ឋមិនត្រូវធ្វើអន្តរាគមន៍ដោយផ្ទាល់ នៅក្នុងការគ្រប់គ្រងធនាគារឡើយ តែពេលខ្លះរដ្ឋចាំបាច់ត្រូវតែធ្វើអន្តរាគមន៍ ដើម្បីជួយកែតម្រូវបរាជ័យនៃទីផ្សារ។ ជារួមទីផ្សារហិរញ្ញវត្ថុអាចជួបបរាជ័យ ក្នុងការបែងចែកធនធានឱ្យបានគ្រប់គ្រាន់ ឱ្យទៅដល់វិស័យសហគ្រាសតូចនិងមធ្យម ដោយសារតែអាជីវកម្មទាំងអស់នេះមានហានិភ័យខ្ពស់។ ប្រសិនបើរដ្ឋាភិបាលមិនចូលអន្តរាគមន៍ក្នុងបរាជ័យទីផ្សារនេះទេវិស័យសហគ្រាសខ្នាតតូចនិងមធ្យមនឹងទទួលរងគ្រោះ។កិច្ចអន្តរាគមន៍ដែលអាចធ្វើទៅបាន រួមមានធនាគាររបស់រដ្ឋប្តេជ្ញាចិត្តឱ្យសហគ្រាសខ្នាតតូចនិងមធ្យមខ្ចីលុយ ប៉ុន្តែត្រូវពង្រឹងការគ្រប់គ្រងសហគ្រាសឯកជនទាំងនេះ ឱ្យមានតម្លាភាព ដែលជំរុញឱ្យមានភាពប្រកួតប្រជែងនៅក្នុងវិស័យហិរញ្ញ-វត្ថុ អនុញ្ញាតឱ្យផ្តលកម្ចីទៅឱ្យសហគ្រាសខ្នាតតូចនិងមធ្យម តាមអត្រាការប្រាក់ខ្ពស់ ដើម្បីកាត់បន្ថយហា-និភ័យ និងភ្ជាប់កម្ចីសហគ្រាសខ្នាតតូចនិងមធ្យម ទៅនឹងការគាំទ្រខាងជំនួយបច្ចេកទេស ដែលឧបត្ថម្ភទុនដោយមូលនិធិសាធារណៈ។

នៅក្នុងប្រទេសកម្ពុជា ការលំបាកនៅក្នុងការទទួលបានឥណទាន គឺជាឧបសគ្គធ្ងន់ធ្ងរបំផុតដែលវិស័យឯកជនជួបប្រទះ។ ជាទូទៅ សហគ្រាសខ្នាតតូចនិងមធ្យមមិនមានមូលដ្ឋានគ្រឹះទ្រព្យសកម្មរឹងមាំនោះទេ។ ដោយសារតែការឱ្យខ្ចីដោយស្ថាប័នហិរញ្ញវត្ថុ គឺទាមទារឱ្យមានការបញ្ចាំ សហគ្រាសខ្នាតតូចនិងមធ្យមភាគច្រើនជួបបញ្ហាពិបាកនៅក្នុងការរៀបចំឯកសារ ដែលទាមទារដោយធនាគារសម្រាប់ការពង្រីកកម្ចីរបស់ពួកគេ។ អាជីវកម្មភាគច្រើនក៏មានការរអ៊ូរទាំផងដែរអំពីភាពយឺតយ៉ាវនៃនីតិវិធីក្នុងការស្នើសុំកម្ចី។ ការរៀបចំឯកសារមិនបានល្អ ការខ្វះខាតឯកសារយោង ដូចជារបាយការណ៍ហិរញ្ញវត្ថុ (ជាពិសេស សម្រាប់អាជីវកម្មថ្មី) ហើយនឹងភាពមិនច្បាស់លាស់ ឬ ក៏កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ដែលអាចមាន "ហានិភ័យ" គឺសុទ្ធតែកត្តាដែលធ្វើឱ្យធនាគារបដិសេធការស្នើសុំកម្ចីរបស់សហគ្រាសខ្នាតតូចនិងមធ្យម។

អាជីវកម្មភាគច្រើនពេញចិត្តនឹងចំណុចខាងក្រោមនេះ៖

- ការបង្កើតមូលនិធិ ឬ យន្តការពិសេសនៃការធានាកម្ចី ឬការបញ្ចាំឬមូលនិធិជំនួយទៅវិញទៅមកជាក់លាក់ណាមួយ
- ការអភិវឌ្ឍផលិតផលហិរញ្ញវត្ថុណាមួយ ឬការបង្កើតឥណទានពិសេស ដែលគិតគូរពីខ្សែសង្វាក់ផលិតកម្ម និងភាពជាក់ស្តែងនៃសកម្មភាពរបស់សហគ្រាសទាំងនេះ (គ្រប់គ្រងឥណទានដោយភ្នាក់ងារឯកទេស)
- ជាទូទៅ ការបង្កឱ្យមានភាពងាយស្រួល ក្នុងការទទួលឥណទាន។

ការខ្វះខាតទុនវិនិយោគដើម្បីគាំទ្រគម្រោងថ្មីៗ (Venture capital) នៅតែជាបញ្ហាចម្បងនៅឡើយសម្រាប់អាជីវកម្មដែលទើបនឹងកកើត។ រដ្ឋត្រូវពិនិត្យរាល់វិធានការទាំងអស់ (ហេដ្ឋារចនាសម្ព័ន្ធគតិយុត្តិ និងលិខិតុបករណ៍) ដែលបង្កលក្ខណៈឱ្យមូលធនហានិភ័យគាំទ្រគម្រោងថ្មីៗ។ ដោយសារតែបញ្ហាលំបាក នៅក្នុងការទទួលហិរញ្ញប្បទាននៅតែជាបញ្ហាសំខាន់នៅឡើយសម្រាប់គម្រោងការខ្នាតតូច រដ្ឋត្រូវរិះរកវិធីងាយស្រួល ដើម្បីឱ្យសហគ្រាសទាំងនេះទទួលបានមូលនិធិ។

ចំណាយក្នុងការទទួលបានហិរញ្ញប្បទាន ត្រូវបានគេចាត់ទុកថាជាឧបសគ្គចម្បងសម្រាប់ការអភិវឌ្ឍវិស័យឯកជន។ អាជីវកម្មធំៗក៏ចាត់ទុកបញ្ហានេះថាជាឧបសគ្គសម្រាប់ការរីកចម្រើនរបស់ពួកគេដែរ ទោះបីជាពួកគេមានភាពងាយស្រួលនៅក្នុងការទទួលបានឥណទានជាងសហគ្រាសខ្នាតតូចនិងមធ្យមក៏ដោយ។

## ១១.២. វិស័យក្រៅប្រព័ន្ធ

កំណើនយ៉ាងឆាប់រហ័សនៃវិស័យក្រៅប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា នៅក្នុងរយៈកាលប៉ុន្មានឆ្នាំថ្មីៗនេះ គឺបានមកពីការអភិវឌ្ឍទីក្រុងយ៉ាងឆាប់រហ័ស និងការធ្វើចំណាកស្រុកពីជនបទ បន្ទាប់ពីការធ្វើសេរីភាវូបនីយកម្មនៅក្នុងទសវត្សរ៍ទី៨០ និង ៩០។ ប្រជាជនកម្ពុជាវ័យក្មេងភាគច្រើនមិនអាចស្វែងរកការងារធ្វើបាននៅក្នុងវិស័យក្នុងប្រព័ន្ធ។ ហេតុដូច្នេះ ពួកគេជាប់ពាក់ព័ន្ធនឹងការងារក្រៅប្រព័ន្ធ ហើយដែលចូលរួមចំណែកនៅក្នុងកំណើនទាំងអស់នេះ។ មូលហេតុសំខាន់ដែលសហគ្រាសភាគច្រើនទាំងនេះនៅបន្តដំណើរការក្នុងវិស័យក្រៅប្រព័ន្ធ ទោះបីជាពួកគេមានវិសាលភាពនិងឱកាសក្លាយទៅជាវិស័យក្នុងប្រព័ន្ធក៏ដោយ គឺមកពីសហគ្រាសទាំងនោះគ្រប់គ្រងតាមបែបបុរាណ ហើយមិនចង់អនុវត្តវិធានច្បាប់ និងបទប្បញ្ញត្តិពន្ធដែលសាំញ៉ាំ និងដើម្បីជៀសពីការគ្រប់គ្រងរបស់រដ្ឋ។ លក្ខណសម្បត្តិសំខាន់ៗខ្លះនៃប្រតិបត្តិការវិស័យក្រៅប្រព័ន្ធមានពិពណ៌នាដូចខាងក្រោមនេះ៖

**១.មានសហគ្រិននៅក្នុងវិស័យឯកជនតែមួយភាគបីប៉ុណ្ណោះ ដែលចេះអាននិងសរសេរ៖** ប្រការនេះ គឺជាមូលហេតុដែលធ្វើឱ្យពួកគេគេចចេញពីរដ្ឋបាលសាំញ៉ាំ និងបទបញ្ញាគ្រប់គ្រងរបស់ធុរកិច្ចតាមបែបទំនើប។

**២.សកម្មភាពច្រើនរបស់វិស័យឯកជន គឺនៅជនបទនិងក្រៅប្រព័ន្ធដែលស្រូបយកកម្លាំងពលកម្ម៧០%៖** វិស័យឯកជនទំនើបស្រូបកម្លាំងពលកម្មតែ១៥% ប៉ុណ្ណោះ។ អាជីវកម្មក្រៅប្រព័ន្ធបានដើរតួនាទីយ៉ាងលើសលប់ នៅក្នុងវិស័យកសិកម្ម និងសេវាកម្ម ពោលគឺនៅក្នុងវិស័យកសិកម្ម ពាណិជ្ជកម្ម និងដឹកជញ្ជូន។ ភាគច្រើននៃពាណិជ្ជកម្មលក់រាយ និងភាគច្រើននៃទំនិញប្រើប្រាស់នាំចូលត្រូវបានដំណើរការនៅក្នុងអាជីវកម្មក្រៅប្រព័ន្ធ។

**៣.ប្រសិនបើកសិកម្មមិនត្រូវបានគេរាប់បញ្ចូលទេនោះ វិស័យក្រៅប្រព័ន្ធនឹងត្រូវបានគ្របដណ្តប់ដោយអាជីវកម្មខ្នាតតូចនិងមីក្រូ ក្នុងការផ្តល់សេវាកម្មពាណិជ្ជកម្ម និងសេវាផ្សេងៗទៀត៖** អាជីវកម្មដែលពាក់ព័ន្ធនឹងការផ្តល់សេវាកម្មឱ្យដល់ពាណិជ្ជកម្មនាំចូលធំៗបានខិតខំប្រឹងប្រែងដើម្បីធ្វើទំនើបកម្ម ហើយបន្តិចម្តងៗពួកគេយកចិត្តទុកដាក់ ទៅលើសកម្មភាពឧស្សាហកម្មផលិតវិញ។ អ្នកគ្រប់គ្រងជាស្ត្រីនៃអាជីវកម្មក្រៅប្រព័ន្ធតែងតែទទួលបានជោគជ័យនៅក្នុងការនាំចូលហើយនៅក្នុងចំណោមពួកគេខ្លះមានទឹកចិត្តចាប់ផ្តើមអាជីវកម្មថ្មីខាងផ្នែកកម្មន្តសាល។អាជីវកម្មក្រៅប្រព័ន្ធក៏ត្រូវបានគេប្រទះឃើញនៅក្នុងវិស័យឧស្សាហកម្មដែរ ជាពិសេស គឺនៅក្នុងផលិតកម្មសិប្បកម្ម និងសំណង់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៤.សហគ្រិនវិស័យក្រៅប្រព័ន្ធ ដែលព្យាយាមឱ្យចានចូលទៅក្នុងវិស័យក្នុងប្រព័ន្ធ ប្រឈមមុខនឹងបញ្ហាលំបាកក្នុងឱ្យកាត់សម្គាល់ ក្នុងការគេចឱ្យផុតពីទំនាក់ទំនងមិនច្បាស់លាស់ជាមួយរដ្ឋ ជាពិសេសទាក់ទងនឹងការបង់ពន្ធ និងបទដ្ឋានការងារ។

៥.វិស័យក្រៅប្រព័ន្ធមានតួនាទីយ៉ាងសំខាន់ជាក់ស្ដែងការចូលរួមចំណែកទៅក្នុងផលិតផលសរុបក្នុងស្រុក និងការងារ៖ ប៉ុន្តែត្រូវបានគេចាត់ទុកថានៅមានផលិតភាពទាប និងមានទុនមិនគ្រប់គ្រាន់។

## ១១.២.១. ការលើកកម្ពស់សិប្បកម្ម

សិប្បកម្មផ្ដល់នូវប្រភពចំណូលយ៉ាងសំខាន់ ដល់អ្នកក្រីក្រនៅឯទីជនបទ និងសហគមន៍ជាយក្រុង ប៉ុន្តែគ្មានជវភាព ដោយសារកត្តដូចតទៅ៖ (១) ក្របខណ្ឌស្ថាប័នជាមូលដ្ឋាន និង ហេដ្ឋារចនាសម្ព័ន្ធនៅមានកម្រិត (២) គម្លាតរវាងធនធានសម្រាប់ដំណើរការ និងហិរញ្ញវត្ថុផ្ទាល់ខ្លួន ក៏ដូចជាកង្វះទីតាំងឧស្សាហកម្មដែលបំពាក់ទៅដោយឧបករណ៍សម្រាប់សិប្បករ (៣) ការលំបាកក្នុងការជ្រៀតចូលទីផ្សារ ជាពិសេសទីផ្សារសាធារណៈ (៤) លទ្ធភាពដើម្បីទទួលបានឥណទាននៅមានកម្រិត ដោយសារតែធនាគារភាគច្រើនទាមទារនូវរបស់បញ្ចាំ និងកង្វះខាតនូវរចនាសម្ព័ន្ធហិរញ្ញវត្ថុ ដែលសមស្របតាមតម្រូវការរបស់សិប្បកម្ម (៥) ការដែលអាចទទួលបានដោយមិនទៀងទាត់នៃធាតុចូល ប្រកបដោយគុណភាព។

ការអភិវឌ្ឍសិប្បកម្ម គឺជាធាតុផ្សំដ៏សំខាន់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរបស់រដ្ឋាភិបាល។ គំនិតផ្ដួចផ្ដើមនៃការអភិវឌ្ឍសិប្បកម្មលើកឡើងនូវគោលដៅដូចខាងក្រោមនេះ៖

- **នៅក្នុងផ្នែកផ្ដល់ហិរញ្ញប្បទាន៖** ភាពជោគជ័យគឺស្ថិតនៅលើរចនាសម្ព័ន្ធមូលនិធិមីក្រូហិរញ្ញវត្ថុ ដែលមានលក្ខណៈល្អប្រសើរ ទាំងបច្ចេកទេស និងហិរញ្ញវត្ថុដូចជា ស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលធ្វើយ៉ាងដូចនេះ ដើម្បីទទួលបានការជឿទុកចិត្តនិងការគាំទ្ររបស់សិប្បករ។
- **នៅក្នុងផ្នែកទីផ្សារនិងហាងលក់រាយ៖** កែលម្អគុណភាពផលិតផលសិប្បកម្មដើម្បីឱ្យមានភាពប្រកួតប្រជែងជាអន្តរជាតិ ធ្វើយ៉ាងដូចនេះពួកគេអាចទទួលបានផលប្រយោជន៍ពីការពង្រីកវិស័យទេសចរណ៍។ សម្រាប់សិប្បករ កត្តានេះនឹងធ្វើឱ្យពួកគេធ្វើការស្វែងយល់ពីការលក់ដូរបែបទំនើប និងពីបច្ចេកទេសនៃការនាំចេញ។
- **សេវាកម្មផ្ដល់ការបណ្ដុះបណ្ដាលទៅនឹងការផ្ទេរពីបច្ចេកទេសជំនើប៖** ប៉ុន្តែសាមញ្ញ សម្រាប់ការផលិតទីផ្សារការគ្រប់គ្រងសារគមនាគមន៍និងគ្រប់គ្រង។

ដើម្បីសម្រេចបាននូវគោលដៅទាំងនេះរាជរដ្ឋាភិបាលនិងប្រើយុទ្ធសាស្ត្រដូចខាងក្រោមនេះ៖

- **នៅក្នុងផ្នែកផ្ដល់ហិរញ្ញប្បទាន៖** កសាងសមត្ថភាពគ្រប់គ្រងនៃរចនាសម្ព័ន្ធហិរញ្ញវត្ថុមីក្រូតាមរយៈការបណ្ដុះបណ្ដាលមន្ត្រី និងការត្រួតពិនិត្យក្រោយការបណ្ដុះបណ្ដាលហើយធ្វើការកែតម្រូវប្រព័ន្ធហិរញ្ញវត្ថុរបស់ពួកគេ ឱ្យត្រូវទៅតាមភាពពិតជាក់ស្ដែងរបស់វិស័យ។
- **នៅក្នុងផ្នែកទីផ្សារនិងការលើកកម្ពស់ផលិតផលសិប្បកម្ម៖** ធ្វើឱ្យប្រសើរឡើងនូវគុណភាពផលិតផល បង្កើតប្រព័ន្ធចែកចាយឱ្យបានច្រើនទៅខាងក្រៅភូមិ ដែលឧស្សាហកម្មតាម

ផ្ទះតាំងនៅ និងបង្កើតមជ្ឈមណ្ឌលចែកចាយវិមជ្ឈការ។ ការធ្វើបែបនោះនឹងជួយលើកកម្ពស់ផលិតផលទាំងនេះផងដែរ នៅលើទីផ្សារជាតិនិងអន្តរជាតិ តាមរយៈការចូលរួមនៅក្នុងពិព័ណ៌ពាណិជ្ជកម្ម ការតាំងពិព័ណ៌ទិវាវប្បធម៌និងមហោស្រព។ល។

- **ដាក់ចេញនូវការបណ្ដុះបណ្ដាលនិងការទទួលបានភាពប៉ិនប្រសប់៖** ធ្វើឱ្យមានការចាប់អារម្មណ៍ពីម្ចាស់ជំនួយ ទាក់ទងនឹងភាពចាំបាច់នៃការផ្ដល់ការបណ្ដុះបណ្ដាលដល់សិប្បករ និងបុគ្គលិកគ្រប់គ្រងនៅក្នុងលក្ខណៈមួយប្រកបដោយចីរភាព ក៏ដូចជាការជួសជុលនិងធ្វើឱ្យប្រសើរឡើងនូវមជ្ឈមណ្ឌលបណ្ដុះបណ្ដាល។

## ១១.៣. ឧបសគ្គចំពោះការវិនិយោគនិងផលិតភាព

កម្ពុជាសម្រេចបាននូវសមិទ្ធផលគួរឱ្យកោតសរសើរ នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងអំឡុងពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ ដោយសារវិស័យឯកជនដែលពោរពេញទៅដោយថាមពល និងមានការគាំទ្រពីវិស័យសាធារណៈ។ ជាលទ្ធផល វិស័យឯកជនទំនើបមួយដែលពោរពេញទៅដោយថាមពលត្រូវបានបង្កើតឡើង និងមានការរីកចម្រើនលូតលាស់យ៉ាងខ្លាំង។ ភស្តុតាងនៃវិស័យធុរកិច្ចទំនើបទាំងអស់នោះ រួមមានចំនួនក្រុមហ៊ុនដែលចុះបញ្ជីមានការកើនឡើងជារៀងរាល់ឆ្នាំ (ពី ៧២០នៅក្នុងឆ្នាំ ២០០៣ ទៅដល់ ២៨៩០ នៅក្នុងឆ្នាំ២០០៧។ ក្រុមហ៊ុនដែលប្រើអ៊ីមែល និងគេហទំព័រក៏មានការកើនឡើង ហើយជាពិសេស កំណើនយ៉ាងឆាប់រហ័សនៃវិស័យដែលប្រើប្រាស់បច្ចេកវិជ្ជា ដូចជាទូរគមនាគមន៍ និងធនាគារ។ ឧស្សាហកម្មដែលប្រើទុនច្រើនខ្លះ ដូចជាអាលុយមីញ៉ូមក៏កំពុងតែលេចមានរូបរាងឡើងផងដែរ។

វិស័យឯកជនរបស់កម្ពុជាកំពុងត្រូវបានគេចាត់ទុកថា ជាវិស័យឯកជនដែលមានលក្ខណៈទំនើប និងសុទិដ្ឋិនិយម ប៉ុន្តែនៅមានពិពិធកម្មតិចតួចនៅឡើយ ហើយបន្តនៅជាលក្ខណៈវិស័យក្រៅប្រព័ន្ធភាគច្រើននៅឡើយ។ ក្រុមហ៊ុនភាគច្រើនជាសហគ្រាសខ្នាតតូចនិងមធ្យម ដែលដំណើរការជាលក្ខណៈសេដ្ឋកិច្ចក្រៅប្រព័ន្ធ ការគោរពតាមច្បាប់ពន្ធតិចតួច និងការប្រើប្រាស់ប្រព័ន្ធធនាគារនៅមានកម្រិត។

ផលិតភាពទូទៅនៅកម្រិតក្រុមហ៊ុននៅទាបនៅឡើយ ទោះបីជាប៉ះប៉ូវនឹងប្រាក់ខែទាប។ ក្រុមហ៊ុនខ្លះមានដំណើរការល្អ ដូចជានៅក្នុងវិស័យសម្លៀកបំពាក់ ប៉ុន្តែនៅមានគម្លាតធំរវាងក្រុមហ៊ុនដែលដំណើរការជាមធ្យម និងក្រុមហ៊ុនដែលជាប់លេខមួយ។ នៅក្នុងវិស័យសម្លៀកបំពាក់មានភាពប្រកួតប្រជែងខ្លាំង ថ្វីត្បិតតែប្រាក់បៀវត្សរ៍កើនឡើងលើសពីមធ្យមបន្តិច។ ផ្នែកសម្លៀកបំពាក់មានប្រសិទ្ធភាព និងផលិតភាពខ្ពស់។ ក្រុមហ៊ុនកម្ពុជាខ្លះចាប់ផ្ដើមមានទំនាក់ទំនងជាមួយនឹងទីផ្សារពិភពលោក ប៉ុន្តែការនាំចេញគឺមានតែសម្លៀកបំពាក់និងផលិតផលកសិកម្មនៅឡើយ។ ក្រុមហ៊ុនភាគច្រើនប្រែក្លាយទៅជាក្រុមហ៊ុនទំនើប (ប្រើបច្ចេកវិទ្យា ការបណ្ដុះបណ្ដាល)។ ប្រាក់ខែជាមធ្យមគឺប្រហែលជាង ១០០ ដុល្លារក្នុងមួយខែ ប៉ុន្តែតម្លៃបន្ថែម (តម្លៃបន្ថែមដកថ្លៃឈ្នួល) គឺមានកម្រិតខ្ពស់នៅក្នុងពាណិជ្ជកម្មលក់ដុំ និងការដឹកជញ្ជូន។

ការវាយតម្លៃបរិយាកាសវិនិយោគរបស់ធនាគារពិភពលោកឆ្នាំ ២០០៩ បានកំណត់បញ្ហាខាងក្រោមនេះថាជាឧបសគ្គចំពោះផលិតភាពនិងការវិនិយោគ៖

- **ការអាចទទួលបានហិរញ្ញវត្ថុនៅមានកម្រិតនិងមិនទាន់ល្អ៖** មានក្រុមហ៊ុនតែ១០% ប៉ុណ្ណោះ ប្រើប្រាស់ធនាគារដើម្បីបានទុនវិនិយោគ។ ទោះបីជាយ៉ាងណាក៏ដោយ មានក្រុមហ៊ុន ១ភាគ១០ មើលឃើញថាការទទួលបានទុនគឺជាឧបសគ្គធ្ងន់ធ្ងរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **ជំនាញចាប់ផ្ដើមត្រូវបានគេគិតថាជាកង្វល់ធំមួយ៖** កម្រិតជំនាញនៅទាបដែលពិបាកនឹងបត់បែនទៅនឹងតម្រូវការថ្មីពីវិស័យឯកជន។ ការដោះស្រាយបញ្ហានេះ គឺទាមទារពេលវេលានិងត្រូវការយុទ្ធវិធីឱ្យបានគ្រប់ជ្រុងជ្រោយ។ ប្រាក់ខែនៅមានលក្ខណៈប្រកួតប្រជែង ប៉ុន្តែមានការកើនឡើងយ៉ាងឆាប់រហ័ស។ បទបញ្ញាការងារមិនត្រូវបានគេគិតថាជាឧបសគ្គទេ។ ឧប្បត្តិហេតុវិវាទការងារកូដកម្ម និងការតវ៉ាផ្សេងៗមានការកើនឡើងគួរឱ្យកត់សម្គាល់។

- **ភាពជឿនលឿនក្នុងការធ្វើឱ្យប្រសើរឡើងនៃស្ថាប័នគយ ហេដ្ឋារចនាសម្ព័ន្ធ និង គុណភាពនៃឡូហ្សីស្ទីកដើម្បីទាក់ទាញឧស្សាហកម្មថ្មី៖** វិស័យឡូហ្សីស្ទីកខ្លះត្រូវបានកែលម្អ ដូចជាស្ថាប័នគយ តែកម្រិតតម្លាភាព និងប្រសិទ្ធភាពនៅទាបនៅឡើយ។ ចំណាយលើការដឹកជញ្ជូននៅខ្ពស់។ រាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពយ៉ាងធំធេង ក្នុងការសម្រួលពាណិជ្ជ-កម្ម។ ពេលវេលាក្នុងយកទំនិញចេញពីគយ (រវាងកំពង់ផែនិងរោងចក្រ) បានថយចុះសម្រាប់ការនាំចេញ គឺ ៤,៣ ថ្ងៃ និងសម្រាប់ការនាំចូល គឺ៥,១ថ្ងៃ។ នេះឆ្លុះបញ្ចាំងឱ្យឃើញការអនុវត្តផែនការសកម្មភាព ១២ ចំណុចស្ដីពីការសម្រួលពាណិជ្ជកម្ម ដែលបានអនុម័តនៅក្នុងឆ្នាំ ២០០៤។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលត្រូវពង្រឹងប្រសិទ្ធភាពរបស់កំពង់ផែ ឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀត។ ការផ្គត់ផ្គង់សេវាទាក់ទងនឹងពាណិជ្ជកម្ម នៅខ្សោយនៅឡើយ ហើយសេវាកម្ម ឡូហ្សីស្ទីកខាងដឹកជញ្ជូននៅមានកម្រិតនៅឡើយ។

- **នៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ បញ្ហាចម្បង គឺថាមពលអគ្គិសនី ដែលមានថ្លៃខ្ពស់ និងមិនអាចជឿទុកចិត្តបាន៖** ក្នុងន័យនេះ រដ្ឋត្រូវសាងសង់ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនីឱ្យបានគ្រប់គ្រាន់ និងកែលម្អក្របខ័ណ្ឌគតិយុត្តិនិងលិខិតបទដ្ឋាន ដើម្បីរក្សាតម្លៃឱ្យនៅទាប និងធ្វើឱ្យប្រសើរឡើងគុណភាពសេវា។

- **ទោះបីជាមានវឌ្ឍនភាពក៏ដោយ ការចាប់ផ្ដើមអាជីវកម្មនៅតែពិបាក៖** ការបង្កើតអាជីវកម្មត្រូវចំណាយជាមធ្យម ២៤០ដុល្លារ នៅក្រសួងពាណិជ្ជកម្ម ៣០០ដុល្លារសម្រាប់ការចុះបញ្ជីពន្ធ និងពន្ធលើតម្លៃបន្ថែម ហើយនិង ៦៣០ដុល្លារសម្រាប់ការចុះបញ្ជីការងារ។

- **ការជឿទុកចិត្តលើប្រព័ន្ធយុត្តិធម៌នៅមានកម្រិតនៅឡើយ៖** ក្ដីបារម្ភណ៍ទាក់ទងនឹងឧក្រិដ្ឋកម្ម និងសុវត្ថិភាពមានការកើនឡើងគួរឱ្យកត់សម្គាល់ តែក្រុមហ៊ុនបានធ្វើសេចក្ដីរាយការណ៍អំពីទំនាស់បន្តិចបន្តួចជាមួយរដ្ឋាភិបាល។ វិវាទភាគច្រើនទាក់ទងនឹងបញ្ហាបទបញ្ញត្តិកិច្ចសន្យា។

- **បញ្ហាអភិបាលកិច្ចនៅតែជាបញ្ហា។**

# ជំពូកទី ១២
# គោលនយោបាយឧស្សាហកម្ម

## ១២.១. បញ្ហាប្រឈមនិងកាលានុវត្តភាពនាពេលអនាគត

វិស័យវាយនភណ្ឌនិងសម្លៀកបំពាក់សម្រាប់ការនាំចេញ គឺមានតួនាទីជាសំខាន់ដើម្បីឱ្យមានកំណើនឧស្សាហកម្មខ្ពស់សម្រាប់ប្រទេសកម្ពុជាក្នុងមួយទសវត្សរ៍កន្លងទៅនេះ។កម្ពុជាទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារតែការធ្លាក់ចុះនៃការនាំចេញសម្លៀកបំពាក់ បណ្តាលមកពីវិបត្តិសេដ្ឋកិច្ចសកលលោកនៅចុងឆ្នាំ ២០០៨។ ការនាំចេញទៅកាន់សហរដ្ឋអាមេរិក ដែលជាទីផ្សារយ៉ាងសំខាន់សម្រាប់ការនាំចេញសម្លៀកបំពាក់បានធ្លាក់ចុះ។ កម្ពុជាជួបនូវបញ្ហាប្រឈមជាច្រើនទាក់ទងនឹងការលុបចោលកូតានាំចេញសម្លៀកបំពាក់រួមមាន៖ (១) ការធ្លាក់ចុះភាពប្រកួតប្រជែង (២) ការផ្តោតយ៉ាងខ្លាំងក្លាទៅលើការនាំចេញទៅកាន់ទីផ្សារតែមួយចំនួនតូច និង (៣) ការពឹងផ្អែកខ្លាំងពេកទៅលើការនាំចូលវត្ថុធាតុដើម។ និន្នាការនាពេលបច្ចុប្បន្ននៅក្នុងឧស្សាហកម្មសម្លៀកបំពាក់កម្ពុជាបង្ហាញឱ្យឃើញ នូវការធ្លាក់ចុះនៃកំណើនការនាំចេញ ដែលអាចធ្វើឱ្យឧស្សាហកម្មនេះជួបនឹងគ្រោះថ្នាក់ ប្រសិនបើរាជរដ្ឋាភិបាលមិនចាត់វិធានការណាមួយ ដើម្បីដោះស្រាយនិន្នាការធ្លាក់ចុះនេះទេ។

កម្ពុជាទទួលរងផលប៉ះពាល់ពីហេដ្ឋារចនាសម្ព័ន្ធ ដែលនៅមានកម្រិត និងតម្លៃសេវាសាធារណៈខ្ពស់។ ភាគីពាក់ព័ន្ធគួរយកចិត្តទុកដាក់ទៅលើតម្លៃពលកម្ម ដែលចេះតែមានការកើនឡើងជាប្រចាំ ដែលវាមិនស៊ីសង្វាក់គ្នាជាមួយនឹងការកើនឡើងនៃផលិតភាពការងារ។ តម្លៃអគ្គិសនី តម្លៃដឹកជញ្ជូន និងកំពង់ផែនៅក្នុងប្រទេសកម្ពុជាមានតម្លៃថ្លៃជាងបណ្តាប្រទេសដទៃទៀតនៅអាស៊ី។ ទោះបីជាកត្តាពលកម្មថោកជាការទាក់ទាញការវិនិយោគមកពីបរទេសក៏ដោយ កត្តានេះតែមួយមិនអាចគ្រប់គ្រាន់ ដើម្បីទាក់ទាញអ្នកវិនិយោគបរទេសដែលជាផលិតករធំៗ ឱ្យដូចនឹងប្រទេសឥណ្ឌា ឬ ចិន ដែលគេមានឧត្តមភាពប្រហាក់ប្រហែលបាននោះទេ។

វាជាកត្តាសំខាន់ណាស់ដែលកម្ពុជាត្រូវតែរក្សាឱ្យបាននូវឧត្តមភាពប្រកួតប្រជែងរបស់ខ្លួន ដែលជាមជ្ឈមណ្ឌលសម្រាប់ផលិតកម្មដែលចំណាយទាប តាមរយៈការដោះស្រាយតម្លៃខ្ពស់នៃការដឹកជញ្ជូនសេវាសាធារណៈ និងការលើកដាក់កុងតឺន័រនៅកំពង់ផែ។ យើងត្រូវយកចិត្តទុកដាក់ផងដែរ លើការបង្កើតឱ្យមានយន្តការមួយ ដែលចងការបង្កើនប្រាក់ឈ្នួល ជាមួយនឹងការបង្កើនផលិតភាពពលកម្ម។ នៅក្នុងឧស្សាហកម្មសម្លៀកបំពាក់ ការពង្រីកប្រភេទផលិតផល និងទីផ្សារមានសារៈសំខាន់ណាស់ ប្រសិនបើយើងចង់ឱ្យឧស្សាហកម្មនេះនៅមានជីវិតនិងរីកចម្រើន។ យើងត្រូវខិតខំប្រឹងប្រែងយកចិត្តទុកដាក់បន្ថែមទៀតផងដែរ ទៅលើការពង្រីកផលិតផលសម្លៀកបំពាក់នៅក្រៅប្រព័ន្ធកូតា។

ដើម្បីកាត់បន្ថយចំណាយដឹកជញ្ជូន យើងត្រូវយកចិត្តទុកដាក់ទៅលើការកែលម្អបណ្តាញផ្លូវនៅក្នុងប្រទេសទាំងមូលតែម្តង។ រាជរដ្ឋាភិបាលត្រូវបង្កើនការវិនិយោគឱ្យបានច្រើន ក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ផ្លូវខេត្ត និងផ្លូវជាតិ។ រាជរដ្ឋាភិបាលក៏បានធ្វើការសិក្សាផងដែរ ទៅលើចំណាយប្រតិបត្តិការជាពិសេសចំណាយនាំចេញ នាំចូល និងការលើកដាក់កុងតឺន័រ។ ម៉្យាងវិញទៀត រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវសកម្មភាពជាក់លាក់ ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ នៅតាមកំពង់ផែអន្តរជាតិ។

កម្ពុជានៅប្រឈមនឹងហានិភ័យអាក្រក់ជាច្រើន។ ដោយឆ្លុះបញ្ចាំងការធ្លាក់ចុះនៃបរិយាកាសសេដ្ឋកិច្ចពិភពលោក លទ្ធភាពធានាបានកំណើននៃការនាំចេញរបស់កម្ពុជាបានចុះខ្សោយជាងមុន។ ម្យ៉ាងវិញទៀត ទស្សនៈអនាគតរបស់កម្ពុជានឹងអាស្រ័យជាចម្បង លើការអភិវឌ្ឍបរិយាកាសនយោបាយ ក្នុងស្រុក និងស្ថានភាពសេដ្ឋកិច្ចពិភពលោក ដែលបច្ចុប្បន្ននេះត្រូវបានគេគិតថាមិនទាន់មានភាពប្រាកដប្រជានៅឡើយ។ ការវិនិយោគដោយផ្ទាល់ពីបរទេស និងការគាំទ្រពីម្ចាស់ជំនួយជាបន្តនឹងដើរតួនាទីដ៏សំខាន់ ដើម្បីសម្រេចកំណើនផលិតផលក្នុងស្រុកសរុប (GDP) តាមទិសដៅ ក្នុងអត្រា ៦-៧% ក្នុងមួយឆ្នាំជាមធ្យម។ ការទាក់ទាញការវិនិយោគដោយផ្ទាល់ពីបរទេសទាមទារឱ្យមានការកាត់បន្ថយ នូវឧបសគ្គជាច្រើនដែលធ្វើឱ្យភាពប្រកួតប្រជែងរបស់កម្ពុជាចុះខ្សោយ។ កម្ពុជានឹងត្រូវប្រកួតប្រជែងជាមួយនឹងប្រទេសដទៃទៀត ដើម្បីធ្វើឱ្យវិនិយោគិនបរទេសមានទំនុកចិត្ត។

ធនធានដ៏មានសក្តានុពលជាច្រើនសម្រាប់ឱ្យមានការរីកចម្រើន ត្រូវបានគេកំណត់អត្តសញ្ញាណរួមមានពិពិធកម្មនៃផលិតកម្ម និងការធ្វើឱ្យប្រសើរឡើងនៃវិស័យកសិកម្ម។ ផ្ទៃដីជាច្រើននៅមិនទាន់ប្រើប្រាស់នៅឡើយ។ កម្ពុជាមានសក្តានុពលក្នុងការបង្កើនទិន្នផលស្រូវ ការធ្វើឱ្យប្រសើរឡើងនៃសន្តិសុខស្បៀង និងការបង្កើនការនាំចេញស្រូវ។ កសិកម្មកែច្នៃ និងការចិញ្ចឹមត្រីអាចជាធនធានដ៏មានសក្តានុពលផងដែរ ដើម្បីឱ្យមានកំណើន។

នៅក្នុងរយៈពេលខ្លីនិងមធ្យម សេវាសាធារណៈនិងប្រព័ន្ធច្បាប់និងតុលាការត្រូវតែពង្រឹងឡើងវិញ ដើម្បីជួយសម្រួលដល់ការអនុវត្តកំណែទម្រង់អភិបាលកិច្ច និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសសម្រាប់ការវិនិយោគឯកជន ការកាត់បន្ថយចំណាយប្រតិបត្តិការពាណិជ្ជកម្ម ហើយជាទូទៅជួយជំរុញការអភិវឌ្ឍវិស័យឯកជននិងកំណើន ដែលកើតឡើងដោយសារពាណិជ្ជកម្ម។ វាសំខាន់ផងដែរដែលត្រូវធ្វើការកែលម្អ ហេដ្ឋា-រចនាសម្ព័ន្ធផ្លូវថ្នល់ ដើម្បីជួយសម្រួលដល់លទ្ធភាពចូលទៅកាន់ទីផ្សារ និងកាត់បន្ថយថ្លៃដឹកជញ្ជូន ក៏ដូចជាពង្រឹងការគ្រប់គ្រងកំពង់ផែ និងសេវាសាធារណៈ និងថាមពល ដើម្បីកាត់បន្ថយចំណាយផលិតកម្ម។

## ១២.២. ពិពិធកម្មនៃការអភិវឌ្ឍឧស្សាហកម្ម

ពិពិធកម្មនៅក្នុងឧស្សាហកម្មសម្លៀកបំពាក់ ក៏ដូចជាការអភិវឌ្ឍឧស្សាហកម្មថ្មីដទៃទៀត គឺជាជំហានសំខាន់មួយនៅក្នុង **យុទ្ធសាស្ត្រអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា**។ ទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍឧស្សាហកម្មថ្មីត្រូវតែមានយុទ្ធសាស្ត្រប្រកបដោយចីរភាព និងការវាយតម្លៃទៅលើផលប្រយោជន៍របស់វាសម្រាប់ប្រជាជនកម្ពុជា។ ការអភិវឌ្ឍផលិតផលដែលមានគុណភាពខ្ពស់ទាមទារឱ្យមានការវិនិយោគខាងបច្ចេកវិទ្យា ការបណ្តុះបណ្តាល និងការគ្រប់គ្រងគុណភាព។

វាសំខាន់ណាស់ដែលត្រូវលើកតម្កើងការអភិវឌ្ឍឧស្សាហកម្មបន្ទាប់បន្សំ ដើម្បីកាត់បន្ថយភាពពឹងផ្អែករបស់កម្ពុជាលើទំនិញនាំចូល។ ឧស្សាហកម្មគាំទ្រដែលផលិតគ្រឿងបន្ទាប់បន្សំ សម្លៀកបំពាក់ និងការកែច្នៃបឋមនៃសាច់ក្រណាត់នាំចូលអាចធ្វើឡើងនៅក្នុងស្រុកដោយខ្លួនឯង ដើម្បីសន្សំការនាំចូលនិងពង្រីកខ្សែសង្វាក់បច្ចេកវិទ្យា។

ទោះបីជាយើងមើលឃើញយ៉ាងច្បាស់ថា កម្ពុជាមានកម្លាំងពលកម្មច្រើនក៏ដោយ កម្មករទាំងអស់នោះមិនមានជំនាញក្នុងការប្រើប្រាស់គ្រឿងម៉ាស៊ីន ដែលមានបច្ចេកវិទ្យាខ្ពស់ដែលគេប្រើនៅក្នុងឧស្សា-ហកម្មនៅឡើយទេ។ រាជរដ្ឋាភិបាលចំណាយតិចតួចនៅឡើយ ទៅលើការបណ្តុះបណ្តាលបុគ្គលិកឱ្យមាន

ជំនាញដែលអាចធ្វើការផ្លាស់ប្តូរការងារបាននៅក្នុងឧស្សាហកម្មនោះ។ បុគ្គលិកដែលមានជំនាញល្អប្រសើរ នឹងមានការពេញចិត្តក្នុងការធ្វើការ ហើយនឹងមានផលិតភាពខ្ពស់។

លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាត្រូវតែជំរុញពិពិធកម្មឱ្យបានលឿនចំពោះឧស្សាហកម្មដទៃទៀត ដើម្បីកាត់បន្ថយការពឹងផ្អែករបស់ខ្លួន តែលើពាណិជ្ជកម្មវាយនភ័ណ្ឌនិងសម្លៀកបំពាក់។ រាជរដ្ឋាភិបាលកម្ពុជាយល់ដឹងយ៉ាងច្បាស់ពីភាពចាំបាច់ ដើម្បីធ្វើឱ្យមានពិពិធកម្មសេដ្ឋកិច្ចរបស់កម្ពុជា ហើយបានសង្កត់ធ្ងន់ថា ក្រៅពីការជួយសម្រួលនិងការអភិវឌ្ឍបន្ថែមឧស្សាហកម្មកាត់ដេរ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពទៅដល់ការអភិវឌ្ឍសហគ្រាសដែលត្រូវការកម្លាំងពលកម្មច្រើនដទៃទៀត ដូចជាប្រដាប់ក្មេងលេង ស្បែកជើង ការដំឡើងបរិក្ខារអគ្គិសនីសម្រាប់ការប្រើប្រាស់ ទាំងនៅក្នុងស្រុក និងក្រៅប្រទេស។ កត្តាទាំងអស់នេះនឹងផ្តល់ជាក្របខ័ណ្ឌសម្រាប់ឱ្យមានពិពិធកម្មនៃរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា។ ការផ្គត់ផ្គង់ទឹក និងអគ្គិសនីដែលមានតម្លៃទាប សេវាកម្មទូរគមនាគមន៍ ព័ត៌មាន និងហិរញ្ញវត្ថុដ៏មានប្រសិទ្ធភាព និងប្រកបដោយសក្តានុពល គឺជាអាទិភាពខ្ពស់បំផុតដើម្បីគាំទ្រពិពិធកម្មឧស្សាហកម្ម។

យើងអាចសង្ខេបពី ***យុទ្ធសាស្ត្រអភិវឌ្ឍវិស័យឧស្សាហកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា*** ដូចខាងក្រោមនេះៈ

***ទីមួយ***-បន្តអភិវឌ្ឍឧស្សាហកម្មអតិពលកម្ម ដូចជាឧស្សាហកម្មសម្លៀកបំពាក់ ប្រដាប់ក្មេងលេង និងស្បែកជើង។

***ទីពីរ***-លើកតម្កើងការអភិវឌ្ឍកសិឧស្សាហកម្ម តាមរយៈការពង្រឹងក្របខ័ណ្ឌគតិយុត្តិសម្រាប់ការគ្រប់គ្រងដីរយៈពេលវែង ផ្តល់ការអនុគ្រោះពន្ធសម្រាប់ការបង្កើតមធ្យោបាយកែច្នៃផលិតផលកសិកម្ម ដូចជា កប្បាស ក្រចៅ ស្ករស ប្រេងដូង គ្រាប់ស្វាយចន្ទី កៅស៊ូ ដំឡូងមី និងផ្លែឈើ។

***ទីបី***-អភិវឌ្ឍឧស្សាហកម្មដោយផ្អែកលើធនធានធម្មជាតិ ដែលមាននៅក្នុងស្រុក ដូចជាការកែច្នៃត្រី សាច់ ស៊ីម៉ងត៍ និងក្បឿង រួមទាំងឥដ្ឋផងដែរ។

***ទីបួន***-លើកស្ទួយសហគ្រាសខ្នាតតូចនិងមធ្យម សហគ្រាសមីក្រូ និងសិប្បកម្ម។

***ទីប្រាំ***-លើកស្ទួយឧស្សាហកម្មដែលផលិតបរិក្ខារអគ្គិសនី សម្រាប់ទាំងការប្រើប្រាស់ក្នុងគ្រួសារនិងឧស្សាហកម្ម និងបង្កើនគុណភាពផលិតផល ហើយវាជាកត្តាចាំបាច់ណាស់ដែលត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងគុណភាពសម្រាប់គ្រប់ផលិតផលឧស្សាហកម្មទាំងអស់ ជាពិសេសទំនិញនាំចេញ ដើម្បីឱ្យត្រូវទៅតាមស្តង់ដារអន្តរជាតិ និងការអនុវត្តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា។

***ទីប្រាំមួយ***-បង្កើតតំបន់ឧស្សាហកម្មនិងនាំចេញពិសេស តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាកម្ម និងការលើកទឹកចិត្តការវិនិយោគ។ តំបន់ទាំងអស់នេះអាចបង្កើតឡើងនៅជាយក្រុងភ្នំពេញ ក្រុងព្រះសីហនុ បន្ទាយមានជ័យ និងកោះកុង ហើយដែលនៅក្នុងតំបន់ទាំងនេះ រាជរដ្ឋាភិបាលនឹងសាងសង់បណ្តាញផ្លូវថ្នល់ ផ្តល់ការផ្គត់ផ្គង់ថាមពល និងទឹក ធានាឱ្យបានការគ្រប់គ្រងកាកសំណល់ និងការការពារបរិស្ថាន ផ្តល់ការអប់រំនិងការបណ្តុះបណ្តាលជំនាញ លើកកម្ពស់សេវាសុខភាពបង្កើតរោងជាង សម្រួលនីតិវិធីពន្ធគយ និងនីតិវិធីច្បាប់ដទៃទៀត ដើម្បីធានាដល់បរិយាកាសអនុគ្រោះដល់ការបង្កើតប្រាក់ចំណេញ និងកំណើនរបស់ធុរៈជន។

**ទីប្រាំពីរ**-លើកទឹកចិត្តការអភិវឌ្ឍផលិតផលជំនួសការនាំចូល (ក្រដាស និងឧស្សាហកម្មគីមី) ដូចជាការផលិតជីនិងអាស៊ីដ ក៏ដូចជាទំនិញសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃដូចជាសាប៊ូ ថ្នាំលាប បរិក្ខារអគ្គិសនី ម៉ាស៊ីនបូមទឹក និងឧបករណ៍កសិកម្មជាដើម។ល។ ហើយ

**ជាចុងបញ្ចប់**-លើកកម្ពស់ការអភិវឌ្ឍវិស័យទេសចរណ៍ធម្មជាតិនិងវប្បធម៌នៅក្នុងប្រទេសកម្ពុជា។

ការរីកចម្រើននៅក្នុងវិស័យទាំងអស់នេះនឹងជួយស្រូបយកកម្លាំងពលកម្មកម្ពុជា ដែលកំពុងតែកើនឡើងយ៉ាងខ្លាំង។ ដើម្បីឱ្យប្រជាជនក្រីក្រទទួលបានផលប្រយោជន៍ពីឱកាសទាំងអស់នេះ កម្មករត្រូវមានជំនាញច្បាស់លាស់និងសមស្រប ដើម្បីអាចឈានទៅមុខ ទៅកាន់វិស័យសេដ្ឋកិច្ចដែលមានសន្ទុះកំណើនខ្លាំងក្លា។

គោលនយោបាយឧស្សាហកម្មរបស់រាជរដ្ឋាភិបាលកម្ពុជាមានគោលដៅពីរ៖ ទីមួយ-ការគាំទ្រការអភិវឌ្ឍឧស្សាហកម្មសម្រាប់ការនាំចេញ និងទីពីរ-ការអភិវឌ្ឍផលិតកម្មជំនួសការនាំចូលលើមុខទំនិញប្រើប្រាស់មួយចំនួន។ គោលដៅទាំងអស់នេះអាចសម្រេចបានតាមរយៈការលើកស្ទួយ៖ (១) ឧស្សាហកម្មអតិពលកម្ម (២) ឧស្សាហកម្ម ដែលពឹងផ្អែកលើធនធានធម្មជាតិ (៣) សហគ្រាសខ្នាតតូចនិងមធ្យម (៤) កសិឧស្សាហកម្ម (៥) ការផ្ទេរបច្ចេកវិទ្យានិងលើកកម្ពស់គុណភាពផលិតផលឧស្សាហកម្ម (៦) ការបង្កើតតំបន់ឧស្សាហកម្ម (៧) ការអភិវឌ្ឍផលិតកម្មជំនួសការនាំចូល លើមុខទំនិញប្រើប្រាស់មួយចំនួន។ ទន្ទឹមនឹងចំណាត់ការទាំងអស់នេះ រាជរដ្ឋាភិបាលមានបំណងលើកដម្កើងការអភិវឌ្ឍវិស័យឯកជន តាមរយៈការជ្រើសរើស និងតាក់តែងគោលនយោបាយឧស្សាហកម្មដោយប្រុងប្រយ័ត្ន ដែលទាំងអស់នេះអាចសង្ខេបបានដូចខាងក្រោមនេះ៖

- លើកទឹកចិត្តការពង្រីកវិស័យសហគ្រាសខ្នាតតូចនិងមធ្យម ជាពិសេសតាមរយៈការផ្តល់ហិរញ្ញប្បទានរយៈពេលមធ្យមនិងវែង។
- ធ្វើឱ្យប្រសើរឡើងនូវដំណើរការរបស់សហគ្រាសរដ្ឋតាមរយៈកិច្ចសហប្រតិបត្តិការនិងឯកជនភាវូបនីយកម្ម។
- បញ្ឈប់ការហូរចូលនៃផលិតផលនាំចូលខុសច្បាប់។
- កាត់បន្ថយរបាំងនាំចេញ ដូចជាពន្ធនាំចេញ និងអប្រសិទ្ធភាពនៃសេវាកម្មសម្រួលពាណិជ្ជកម្ម។
- កាត់បន្ថយរបាំងសម្រាប់ការនាំចូលវត្ថុធាតុដើមសំខាន់ៗ។
- ផ្តល់ការការពារដល់ឧស្សាហកម្មក្មេងខ្ចី ដោយមានគំរូជ្រើសរើសប្រកបដោយការប្រុងប្រយ័ត្ន។
- ពង្រីកទំនាក់ទំនងរវាងសហគ្រាសខ្នាតតូចនិងមធ្យមជាមួយនឹងឧស្សាហកម្មខ្នាតធំ។
- លើកតម្កើងមជ្ឈមណ្ឌលផលិតភាពជាតិ ដែលនឹងជួយសហគ្រាសខ្នាតតូចនិងមធ្យមដើម្បីបង្កើនផលិតភាព និងកាត់បន្ថយចំណាយលើផលិតកម្ម។
- បង្កើតស្ថាប័នស្តង់ដារជាតិ ដើម្បីធានាឱ្យបានថាគុណភាពផលិតផលស្របតាមស្តង់ដារតំបន់និងអន្តរជាតិ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- បង្កើតមន្ទីរពិសោធន៍ជាតិដែលមានសមត្ថភាពបច្ចេកទេសធ្វើការត្រួតពិនិត្យបច្ចេកទេស អតិសុខុមជីវសាស្ត្រគីមី និងរូបវន្ត ដែលនឹងបង្កើតគុណភាពនិងលក្ខណៈលម្អិតរបស់ទំនិញទាំងនេះ។
- បង្កើតការិយាល័យកម្មសិទ្ធិទ្រព្យសម្បត្តិឧស្សាហកម្ម ដែលនឹងជួយការពារបច្ចេកវិទ្យារចនាម៉ូដ និងផលិតផលថ្មី ពីការលួចចម្លងដោយខុសច្បាប់។
- បង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈទាំងនៅក្នុងស្រុកនិងក្រៅប្រទេស។
- លើកកម្ពស់ក្របខ័ណ្ឌច្បាប់តាមផ្នែកដូចជាច្បាប់រោងចក្រ ច្បាប់តំបន់ឧស្សាហកម្ម ច្បាប់រចនាម៉ូដឧស្សាហកម្ម និងច្បាប់ប៉ាតង់ទម្ងន់ទំហំនិងសុវត្ថិភាពឧស្សាហកម្ម។

រាជរដ្ឋាភិបាលនឹងបន្តលើកដម្កើងឧស្សាហកម្មកម្មន្តសាលអតិពលកម្ម ដោយផ្តោតការយកចិត្តទុកដាក់ ទៅលើឧស្សាហកម្មសម្លៀកបំពាក់និងវាយនភ័ណ្ឌ ដែលត្រូវការការផ្គត់ផ្គង់ច្រើននៃកម្លាំងពលកម្មដែលនាំឱ្យមានភាពប្រកួតប្រជែង។ ទោះបីជាយ៉ាងណាក៏ដោយរដ្ឋាភិបាលទទួលស្គាល់ថាការរក្សា និងការបង្កើនទំហំទីផ្សារនៅក្នុងបរិយាកាសប្រកួតប្រជែងអន្តរជាតិ ដែលចេះតែមានការកើនឡើងទាមទារឱ្យមានការលើកកម្ពស់គុណភាពផលិតផល ក៏ដូចជាការធ្វើការបង្កើនផលិតភាព តាមរយៈបច្ចេកវិទ្យានិងការគ្រប់គ្រងកម្រិតពិភពលោក។ ការអភិវឌ្ឍទំនាក់ទំនងឧស្សាហកម្មល្អប្រសើរនៅក្នុងក្របខ័ណ្ឌច្បាប់ដែលបានបង្កើតគឺមានការចាំបាច់ផងដែរ ហើយក៏ជាវិធីសាស្ត្របង្កើនប្រសិទ្ធភាពឥទ្ធិពលសាយភាយរបស់ឧស្សាហកម្មផលិតសម្លៀកបំពាក់ដែលត្រូវការតាមដាន។ នាពេលបច្ចុប្បន្ននេះ វិស័យសម្លៀកបំពាក់ភាគច្រើនដំណើរការនៅលើមូលដ្ឋានផ្នែកកាត់ ផលិត និងដេរ ជាមួយនឹងក្រណាត់និងគ្រឿងបន្ទាប់បន្សំ (ខ្សែរូត ឡេវ និងអំបោះ) ដែលនាំចូល ហើយការទិញផលិតផលក្នុងស្រុកមានត្រឹមតែការដឹកជញ្ជូន សេវាកម្មរៀបចំនីតិវិធីដឹកជញ្ជូនសេវាសាធារណៈ ដើម្បីដំណើរការរោងចក្រ និងការសាងសង់រោងចក្រ។

ដើម្បីធ្វើឱ្យមានពិពិធកម្មនៃមូលដ្ឋាននាំចេញ ផលិតផលឧស្សាហកម្មរដ្ឋាភិបាលនឹងលើកទឹកចិត្តឱ្យមានការផលិតប្រដាប់ក្មេងលេង មិនថានៅក្រោមអាជ្ញាប័ណ្ណ ឬ តាមរយៈការវិនិយោគដោយផ្ទាល់ពីបរទេស ១០០% នោះឡើយ។ ការផលិតរបៀបនេះ គឺត្រូវបានគេគិតថាមានលក្ខណៈសមស្របបំផុតសម្រាប់ប្រទេសដែលមានកម្លាំងពលកម្មច្រើនតែមានជំនាញទាប។ វិស័យទីពីរដែលនឹងទទួលបានការលើកទឹកចិត្តផងដែរ គឺការបង្គុំនិងដំឡើងផលិតផលអគ្គិសនី ដែលគ្រប់ផ្នែក និងគ្រឿងផ្សំទាំងអស់ជាបឋមគឺត្រូវនាំចូល។

ការជំរុញឧស្សាហកម្មដែលអាស្រ័យលើធនធានធម្មជាតិដែលមាននៅក្នុងស្រុក និងផ្តោតទៅលើការរកឱ្យឃើញអត្តសញ្ញាណកម្ម និងការបង្កើតឱកាសនៅក្នុងការកែច្នៃធនធានធម្មជាតិ រួមមានដូចជាធនធានរ៉ែដែលមិនមែនជាលោហធាតុ ឈើ និងផលិតផលនេសាទ។ ការអភិវឌ្ឍការបង្កាត់ពូជសត្វនិងត្រីអាចជួយផ្គត់ផ្គង់ជាវត្ថុធាតុដើម សម្រាប់រោងចក្រធ្វើការកែច្នៃឡើងវិញ។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីរំពឹងដែលល្អបំផុតនៅក្នុងវិស័យនេះ គឺការកែច្នៃវត្ថុធាតុដើមមិនមែនលោហធាតុសម្រាប់ការផលិតសម្ភារសំណង់។

**យុទ្ធសាស្ត្រវិស័យថាមពលកម្ពុជា** (២០០១-២០០៥) បានកំណត់នូវអាទិភាពនិងកំណត់គម្រោងកម្មវិធីវិនិយោគ ដើម្បីបញ្ចុះតម្លៃអគ្គិសនី និងពង្រីកការផ្គត់ផ្គង់ថាមពលអគ្គិសនីដែលអាចទុកចិត្តបានជូនប្រជាជនកម្ពុជាឱ្យបានកាន់តែច្រើន។ កម្មវិធីវិនិយោគដែលបានគ្រោងទុករួមមាន៖ (១) ការអភិវឌ្ឍ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការផលិតថាមពលអគ្គិសនី និងខ្សែបញ្ជូនចរន្ត ដើម្បីភ្ជាប់ស្ថានីយផលិតថាមពលអគ្គិសនីរវាងភ្នំពេញជាមួយនឹងបណ្តាទីរួមខេត្ត (២) ផែនការអគ្គិសនីភាវូបនីយកម្មនៅតាមបណ្តាទីរួមខេត្ត ក្នុងគោលដៅស្តារឡើងវិញការផ្គត់ផ្គង់និង (៣) ការអភិវឌ្ឍនិងអនុវត្តផែនការអគ្គិសនីភាវូបនីយកម្មតាមទីជនបទ។ ការស្តារឡើងវិញ និងពង្រីកប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅទីក្រុងភ្នំពេញកំពុងតែត្រូវបានធ្វើបន្ត។ សមត្ថភាពផលិតថាមពលអគ្គិសនីក៏កំពុងត្រូវបានពង្រីកផងដែរ ជាមួយនឹងការតភ្ជាប់ជាមួយបណ្តាញផ្គត់ផ្គង់ថាមពលអគ្គិសនីវៀតណាមនិងថៃ ហើយនៅក្នុងរយៈពេលប្រាំឆ្នាំទៀតនឹងតភ្ជាប់ចេញពីរោងចក្រដែលដើរដោយធ្យូងថ្មនៅក្រុងព្រះសីហនុ។ ការអភិវឌ្ឍទាំងនេះនឹងធ្វើឱ្យមានសុវត្ថិភាពផ្គត់ផ្គង់ថាមពលប្រសើរជាង និងគួរឱ្យជឿទុកចិត្តបានទៅដល់តំបន់ក្រៅក្រុងភ្នំពេញ។

កម្មវិធីផលិតថាមពលអគ្គិសនីជាតិ និងខ្សែបណ្តាញបញ្ជូនចរន្តត្រូវបានចាប់ផ្តើមអនុវត្តក្នុង ឆ្នាំ ២០០០។ ដំណាក់កាលទីមួយនៃកម្មវិធីនេះ គឺការកសាងខ្សែបញ្ជូនអគ្គិសនីពីប្រទេសវៀតណាម មកកាន់រាជធានីភ្នំពេញ ដោយឆ្លងកាត់ខេត្តតាកែវ។ ដំណាក់កាលទីពីរ គឺការកសាងខ្សែបញ្ជូនចរន្តអគ្គិសនីពីខេត្តកំពតមកកាន់ខេត្តតាកែវ។ ដំណាក់កាលទីបី គឺការសាងសង់ខ្សែបញ្ជូនចរន្តអគ្គិសនីពីខេត្តព្រះសីហនុ ដើម្បីផ្តល់ការផ្គត់ផ្គង់ដល់បណ្តាទីរួមខេត្ត ពីក្រុងព្រះសីហនុ មកក្រុងភ្នំពេញហើយក៏ដើម្បីបង្កើនសមត្ថភាពផ្គត់ផ្គង់ថាមពលអគ្គិសនីដល់ទីក្រុងភ្នំពេញផងដែរ។ រាជរដ្ឋាភិបាលនឹងផលិតថាមពលអគ្គិសនីនៅខេត្តព្រះសីហនុដែលជារោងចក្រផលិតថាមពលដើរដោយឧស្ម័ន នោះការដឹកជញ្ជូនប្រេងតាមដងទន្លេមេគង្គនឹងត្រូវជៀសវាង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការហូរប្រេង និងខូចខាតដល់បរិស្ថាន។ បណ្តាញបញ្ជូនថាមពលអគ្គិសនីពីភ្នំពេញទៅកាន់ព្រំដែនវៀតណាម ឆ្លងកាត់ខេត្តតាកែវត្រូវបានសាងសង់ឡើង ដើម្បីនាំចូលចរន្តអគ្គិសនីពីប្រទេសវៀតណាមនៅក្នុងឆ្នាំ ២០០៣។ ការតភ្ជាប់បណ្តាញ២២០គីឡូវ៉ាត់ ពីវៀតណាមនឹងផ្គត់ផ្គង់ថាមពលដល់បណ្តាសហគមន៍នៅខាងកើតរាជធានីភ្នំពេញ និងបង្កើនសមត្ថភាពថាមពលដល់ទីនោះផងដែរ។

**កម្មវិធីអគ្គិសនីភាវូបនីយកម្មជនបទប្រាំឆ្នាំ** រួមមានថាមពលកកើតឡើងវិញ (renewable energy) ក៏នឹងត្រូវបានគេអនុវត្តផងដែរ។ តម្លៃសរុបនៃគម្រោងការជំហានទីមួយនៃការបញ្ជូនថាមពលនិងការផលិតអគ្គិសនីជនបទត្រូវបានគេប៉ាន់ប្រមាណចំណាយដល់ទៅ ៨៩ លានដុល្លារសហរដ្ឋអាមេរិក។ ហើយខ្សែបណ្តាញបញ្ជូនចែកចាយ ១១៥គីឡូវ៉ាត់ផ្សេងទៀតត្រូវបានគេបង្កើតឡើង ដើម្បីភ្ជាប់ពីប្រទេសថៃមកកាន់ខេត្តបន្ទាយមានជ័យ បាត់ដំបង និងខេត្តសៀមរាប ដើម្បីគាំទ្រកម្មវិធីអគ្គិសនីជនបទនិងខេត្ត។ ផែនការនេះរួមផងដែរទាំងការអភិវឌ្ឍស្ថានីយវារីអគ្គិសនីកំចាយ និងបន្ទាប់មកទៀតគឺស្ទឹងអាតៃ សេសាន និងឫស្សីជ្រំ។

ការសាងសង់ស្ថានីយ៍វារីអគ្គិសនីនៅក្នុងប្រទេសកម្ពុជាទាមទារឱ្យមានការថ្លឹងថ្លែង ដោយប្រុងប្រយ័ត្នរវាងគោលដៅនៃកំណើនសេដ្ឋកិច្ច ការការពារបរិស្ថាន និងសមធម៌សង្គម។ យើងត្រូវប្រឹងប្រែងដើម្បីជៀសវាងកំហុសដូចប្រទេសជិតខាង ដែលការអភិវឌ្ឍវារីអគ្គិសនីបណ្តាលឱ្យមានបញ្ហាបរិស្ថានសង្គម និងសេដ្ឋកិច្ច។ ប្រសិនបើការបង្កើតអគ្គិសនីជនបទគ្រាន់តែដើម្បីបម្រើឱ្យការបង្កើតការងារនៅជនបទទេ នោះយ៉ាងហោចណាស់ គេគួរគិតអំពីគោលដៅកំណើននិងសមធម៌សង្គម។

ទាក់ទងនឹងផលិតកម្មឧស្សាហកម្មខ្នាតតូច និងសិប្បកម្ម រាជរដ្ឋាភិបាលមានបំណងផ្តល់អាទិភាពដល់ការលើកតម្កើងជំនាញសិប្បកម្មនិងសិល្បៈប្រពៃណី សម្រាប់ទីផ្សារទេសចរណ៍ទាំងនៅក្នុងតំបន់ជនបទ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងទីប្រជុំជន។ វិស័យមួយទៀតដែលមានសក្តានុពលសម្រាប់ការពង្រីកផងដែរ គឺផលិតកម្មថ្នាំជក់ខ្នាតតូចដែលអាចចូលរួមចំណែកឱ្យមានការកើនឡើងការផ្គត់ផ្គង់វត្ថុធាតុដើមទៅដល់ឧស្សាហកម្មផលិតខ្នាតធំ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីទទួលបានជោគជ័យវាចាំបាច់ណាស់ដែលសហគ្រាសទាំងអស់នេះធានាឱ្យបានគុណភាពផលិតផលប្រកបដោយចីរភាព។ លើសពីនេះទៅទៀត ដោយសារតែពួកគេមិនអាចមានលទ្ធភាពទទួលបានឥណទានក្រៅតែពីអ្នកឱ្យខ្ចីលុយដែលមានការប្រាក់ខ្ពស់ ពួកគេនឹងត្រូវការការផ្តល់ឱ្យនូវឥណទានហិរញ្ញវត្ថុខ្នាតតូចដែលមានការប្រាក់សមស្រប។

**យុទ្ធសាស្ត្រល្អសម្រាប់ការអភិវឌ្ឍកសិឧស្សាហកម្ម** គឺការផ្តល់សម្បទានដីទៅឱ្យដល់ទាំងក្រុមហ៊ុនក្នុងស្រុកនិងបរទេស នៅលើមូលដ្ឋានរយៈពេលយូរហើយលើកទឹកចិត្តឱ្យមានការចូលរួមពីបណ្តាម្ចាស់ដីតូចៗនៅតាមមូលដ្ឋាន តាមរយៈការចុះកិច្ចសន្យាដាំដុះ ដើម្បីផ្គត់ផ្គង់ឱ្យរោងចក្រកែច្នៃនៅក្នុងតំបន់។ ការអភិវឌ្ឍគំនិតផ្តួចផ្តើមកសិឧស្សាហកម្មនឹងទាមទារនូវកិច្ចសម្របសម្រួលយ៉ាងជិតស្និទ្ធរវាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល និងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាជំនួយបច្ចេកទេស ដើម្បីវាយតម្លៃឱ្យបានហ្មត់ចត់នូវសក្តានុពលនៃការអភិវឌ្ឍនោះ។ ការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរវាងកសិកម្មនិងឧស្សាហកម្មនៅក្នុងបរិបទការគ្រប់គ្រងបរិស្ថានឱ្យបានល្អប្រសើរមានសារៈសំខាន់ដើម្បីបង្កើតការងារនិងចំណូលប្រកបដោយចីរភាព។

## ១២.៣. ការអភិវឌ្ឍរបៀងឧស្សាហកម្ម

ការអភិវឌ្ឍឧស្សាហកម្មគួរតែចាប់ផ្តើមតែម្តងនៅក្នុងតំបន់ណា ដែលមានសម្ភារៈគាំទ្រ និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់។ នៅលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតផែនការសម្រាប់លើកតម្កើងប៉ូលបីនៃការអភិវឌ្ឍ គឺភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ។

រាជរដ្ឋាភិបាលបានដាក់ចេញនូវទស្សនទាន **"របៀងកំណើនសេដ្ឋកិច្ច"** ក្នុងគោលដៅអភិវឌ្ឍតំបន់ទាំងនោះ ជាមួយនឹងខ្សែបណ្តាញផ្លូវជាតិតភ្ជាប់តំបន់ផ្សេងៗរបស់ប្រទេស ហើយប្រែក្លាយតំបន់ទាំងនោះឱ្យទៅជាតំបន់អភិវឌ្ឍន៍កសិកម្មឧស្សាហកម្ម ពាណិជ្ជកម្ម និងការវិនិយោគ។ របៀងកំណើននឹងទទួលបានអាទិភាពផងដែរ សម្រាប់ការប្រើប្រាស់ធនធានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាទូរគមនាគមន៍ ការផ្គត់ផ្គង់ទឹក អគ្គិសនី ក៏ដូចជាការអភិវឌ្ឍសេវាសាធារណៈដទៃទៀត និងរចនាសម្ព័ន្ធច្បាប់និងសង្គមផងដែរ។

### ១២.៣.១. *រូបភាពនៃការអភិវឌ្ឍរបៀងកំណើន*

តំបន់របៀងកំណើនរួមមាន អនុតំបន់ដាច់ដោយឡែកពីគ្នាចំនួនបី ជាមួយនិងលក្ខណៈផ្សេងៗគ្នា។ តារាងខាងក្រោមនេះនឹងពិពណ៌នាអំពីសេណារីយ៉ូ ទាំងបច្ចុប្បន្ន និងអនាគតនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់របៀងកំណើន។

#### ១២.៣.១.១. *គាំទ្រនិងពង្រីកភាពប្រកួតប្រជែងរបស់ឧស្សាហកម្មសម្លៀកបំពាក់*

##### ១២.៣.១.១.១. *យុទ្ធសាស្ត្ររយៈពេលខ្លី*

ចំនួនការងារសរុបនៅក្នុងឧស្សាហកម្មសម្លៀកបំពាក់ គឺមានប្រហែលជា ៣៥០.០០០ ការងារនៅ

ក្នុងវិស័យរបៀងកំណើន។ រហូតដល់ទៅ (៧៥%) នៃការនាំចេញសម្លៀកបំពាក់កម្ពុជា គឺទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។ ដូច្នេះ រាជរដ្ឋាភិបាលនឹងដាក់ចេញយុទ្ធសាស្ត្រនៃការនាំចេញ តាមរយៈការធ្វើពិពិធកម្មនៃទិសដៅសម្រាប់ការនាំចេញ ។ ពិពិធកម្មចាប់ផ្តើមពីក្រណាត់ដេរ (knitted fabrics) ទៅក្រណាត់ត្បាញ (woven fabrics) នឹងជួយបំពេញសេចក្តីត្រូវការសម្រាប់ទិសដៅនាំចេញផ្សេងៗគ្នា។ ការកែលម្អបច្ចេកវិទ្យា និងការត្រួតពិនិត្យគុណភាពនឹងជួយពង្រឹងការប្រកួតប្រជែងនៃវិស័យឧស្សាហកម្ម។ សេរីភាវូបនីយកម្មនៃការនាំចូលក្រណាត់និងសម្ភារៈបន្ទាប់បន្សំនិងការនាំចេញផលិតផលសម្រេចមានភាពចាំបាច់បំផុត។ការអភិវឌ្ឍធនធានមនុស្សនឹងកាន់តែចាំបាច់ថែមទៀត ដើម្បីទទួលបាននូវជោគជ័យក្នុងការងារនេះ។

១២.៣.១.១.២. *យុទ្ធសាស្ត្ររយៈពេលមធ្យម*

គោលដៅរយៈពេលមធ្យមនៃឧស្សាហកម្មសម្លៀកបំពាក់ គឺដើម្បីសម្រេចបាននូវបម្លាស់ប្តូររចនាសម្ព័ន្ធ ដ៏ធំមួយ។ វាជាការចាំបាច់ក្នុងការបង្កើនតម្លៃបន្ថែមនៃផលិតផល ដើម្បីធ្វើឱ្យផលិតផលទាំងនេះមានភាពប្រកួតប្រជែងក្នុងទីផ្សារថ្លៃមធ្យម។ ដោយសារគោលបំណងដូចនេះ ការអភិវឌ្ឍឧស្សាហកម្មសម្រាប់ផលិតកម្មនៃវត្ថុធាតុដើមចាំបាច់ ដូចជាបន្ទះក្រណាត់ ឡេវ កអាវ និងវត្ថុធាតុផ្សេងៗទៀតនៃសម្លៀកបំពាក់មានសារៈសំខាន់ណាស់។ ការគាំទ្រសម្រាប់ការបង្កើតអាជីវកម្មដោយគំនិតផ្តួចផ្តើមរបស់កម្ពុជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការពង្រីកមូលដ្ឋានឧស្សាហកម្មសម្លៀកបំពាក់កម្ពុជា និងចាំបាច់ក្នុងការពង្រីក និងពង្រឹងដំណើរការឧស្សាហូបនីយកម្ម។ ដូច្នេះ កម្ពុជាត្រូវងាកចេញពីផលិតកម្មផ្អែកលើកិច្ចសន្យានាពេលបច្ចុប្បន្ន ហើយបោះជំហានឆ្ពោះទៅរកការឈានចូលផ្ទាល់ ទៅកាន់ទីផ្សារនាំចេញដែលការពង្រឹងសមត្ថភាពកិច្ចការទីផ្សារ។ ដើម្បីសម្រេចគោលដៅនេះ កម្ពុជាត្រូវពឹងផ្អែកទៅលើតួនាទីដ៏សំខាន់នៃសហគ្រាសក្នុងស្រុកក្នុងការផលិតសម្លៀកបំពាក់ និងក្នុងវិស័យឧស្សាហកម្មគាំទ្រផ្សេងទៀត សម្រាប់ឱ្យឧស្សាហកម្មសម្លៀកបំពាក់នេះបន្តស្ថានភាពជាឧស្សាហកម្មឈានមុនគេនៃប្រទេសកម្ពុជា។

*តារាង១២.១. តារាងទិសដៅការអភិវឌ្ឍសេដ្ឋកិច្ច*

| **អនុតំបន់** | *(ឆ្នាំ២០០២) រយៈពេលខ្លី* | *(ដល់ឆ្នាំ២០០៨) រយៈពេលមធ្យមនិងវែង* | *(ដល់ឆ្នាំ២០១៥)* |
|---|---|---|---|
| **តំបន់ទីក្រុងធំ** | - សម្លៀកបំពាក់និងស្បែកជើង (ឧស្សាហកម្មអតិពលកម្ម)<br>- ផ្គត់ផ្គង់ផលិតផលកសិកម្មដល់ការប្រើប្រាស់នៅតាមទីក្រុង | - ការអភិវឌ្ឍឧស្សាហកម្មកែច្នៃកសិកម្ម<br>- ឧស្សាហកម្មផ្អែកលើព្រលានយន្តហោះ (ឧស្សាហកម្មអតិពលកម្ម មានតម្លៃបន្ថែមខ្ពស់) សម្ភារៈអគ្គិសនី ការដំឡើងគ្រឿងម៉ាស៊ីន និងដឹកជញ្ជូន | - ពង្រីកការផលិតឧស្សាហកម្មកែច្នៃកសិកម្ម<br>- ការអភិវឌ្ឍឧស្សាហកម្មផលិតផលជំនួសការនាំចូល<br>- បរិក្ខារអគ្គិសនី ដំឡើងគ្រឿងម៉ាស៊ីន ដឹកជញ្ជូន និងការផលិត<br>- ការអភិវឌ្ឍឧស្សាហកម្មព័ត៌មានវិទ្យា<br>- មជ្ឈមណ្ឌលគ្រប់គ្រងសម្ភារៈ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | | |
|---|---|---|---|
| **តំបន់ខេត្តព្រះសីហនុ** | - សម្លៀកបំពាក់និងស្បែកជើង (ឧស្សាហកម្មប្រើកម្លាំង)<br>- ការផលិតភេសជ្ជៈ<br>- កែច្នៃផលិតផលនេសាទសមុទ្រ<br>- កែលម្អកំពង់ផែ<br>- ឆ្នេរខ្សាច់សម្រាប់អ្នកទេសចរក្នុងស្រុក | - ការអភិវឌ្ឍឧស្សាហកម្មកែច្នៃផលិតផលនេសាទ<br>- ឧស្សាហកម្មផ្អែកលើកំពង់ផែ (ឧស្សាហកម្មធុនស្រាលនិងសម្លៀកបំពាក់)<br>- ពង្រីកការផលិតភេសជ្ជៈ<br>- ឧស្សាហកម្មទាក់ទងនឹងកំពង់ផែ (ជួសជុលនាវាធ្វើទូក)<br>- ទេសចរណ៍ឆ្នេរសមុទ្រសម្រាប់អ្នកទេសចរក្នុងស្រុក | - ការអភិវឌ្ឍឧស្សាហកម្មកែច្នៃផលិតផលនេសាទ<br>- ការអភិវឌ្ឍឧស្សាហកម្មផលិតផលជំនួសការនាំចូល<br>- ផលិតឬពាក់កណ្តាលដំឡើងចង្រ្កានអគ្គិសនី<br>- ពង្រីកការប្រើប្រាស់ម៉ាស៊ីនដែលប្រើហើយឱ្យប្រើឡើងវិញ ឬកែច្នៃឡើងវិញ<br>- នាំចេញផលិតផលភេសជ្ជៈ<br>- ទេសចរណ៍តាមឆ្នេសមុទ្រសម្រាប់អ្នកទេសចរក្នុងស្រុកនិងបរទេស |
| **តំបន់ផ្សេងៗ** | - ឧស្សាហកម្ម សិប្បកម្មនិងការផលិតតាមផ្ទះ<br>- ការផលិតបន្លែនិងផ្លែឈើ<br>- ចិញ្ចឹមសត្វ<br>- ចិញ្ចឹមត្រី | ពង្រីកការផលិតកសិកម្មជាយក្រុងសម្រាប់ផលិតផលជំនួសការនាំចូល<br>- ធ្វើទំនើបកម្មឧស្សាហកម្មតាមផ្ទះ<br>- លើកកម្ពស់ទេសចរណ៍តាមភូមិ<br>- កែច្នៃផលិតផលនេសាទ | - កែលម្អបន្ថែមទៀតការកែច្នៃផលិតផលនេសាទដើម្បីនាំចេញ |

*ប្រភព: អង្គការ JICA*

### *១២.៣.១.២. ការកែច្នៃឡើងវិញនៃគ្រឿងម៉ាស៊ីនប្រើប្រាស់រួច រថយន្ត ឧបករណ៍អគ្គិសនីនិងអេឡិចត្រូនិច*

បរិមាណមួយចំនួនធំនៃគ្រឿងម៉ាស៊ីនប្រើប្រាស់រួច ជាពិសេសគឺរថយន្ត ឧបករណ៍អគ្គិសនី និងកុំព្យូទ័រត្រូវបានគេបោះចោលក្រោយពេលប្រើប្រាស់រួចក្នុងប្រទេសជប៉ុន និងក្នុងប្រទេសអភិវឌ្ឍន៍ដទៃៗទៀត។ គ្រឿងម៉ាស៊ីនប្រើប្រាស់រួចអាចមានតម្លៃធំផង ប្រសិនបើគ្រឿងដែលអាចនៅប្រើប្រាស់បានត្រូវបានគេជ្រើសរើសជួសជុលកែលម្អ និងលក់វិញ។ គ្រឿងបន្លាស់ក៏អាចត្រូវបានដោះយកចេញនិងលក់បានដែរ។ គ្រឿងម៉ាស៊ីនឬគ្រឿងបន្លាស់ដែលកែច្នៃរួចអាចត្រូវបានលក់ក្នុងទីផ្សារកម្ពុជាឬនាំចេញទៅប្រទេសជិតខាង។ កម្ពុជាអាចជាកន្លែងសម្រាប់ធ្វើកិច្ចការទាំងនេះនិងដើរតួនាទីជាច្រកចេញទៅទីផ្សារនៅតណ្ឌចិនលើទំនិញកែលម្អរួចនិងការផ្គត់ផ្គង់គ្រឿងបន្លាស់។ តំបន់ពាណិជ្ជកម្មសេរីនិងផ្តល់ជាកន្លែងដ៏ល្អប្រសើរសម្រាប់តាំងបង្ហាញនិងលក់ទំនិញទាំងនោះ។ ក្នុងការសម្រេចបានគោលនយោបាយនេះគួរតែមានការប្រុងប្រយ័ត្នដើម្បីធានាថាការការពារបរិស្ថាននិងបទដ្ឋានសុវត្ថិភាពត្រូវបានឆ្លើយតប។

### *១២.៣.១.៣. ការជំរុញកសិឧស្សាហកម្ម*

កសិឧស្សាហកម្មឈរជាឧស្សាហកម្មវត្ថុធាតុដើមផង និងឧស្សាហកម្មកែច្នៃផង។ ការអភិវឌ្ឍកសិឧស្សាហកម្មនឹងបង្កើនតម្លៃបន្ថែមពីរ ទាំងកសិកម្មនិងឧស្សាហកម្ម ដោយសារតែផលិតផលកែច្នៃមាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តម្លៃជាងវត្ថុធាតុដើមមិនទាន់កែច្នៃ។ ផ្នែកដែលមានសក្តានុពលនៃកសិឧស្សាហកម្មគឺអាហារសមុទ្រដូចជាត្រី បង្គា មឹក និងខ្យងសមុទ្រ ផ្លែឈើ និងបន្លែ។

### ១២.៣.១.៤. *ការជំរុញឧស្សាហកម្មបង្គុំ*

ការបង្គុំ គឺជាឧស្សាហកម្មទាមទារកម្លាំងពលកម្មខ្លាំង ដែលត្រូវការកម្លាំងពលកម្មមានជំនាញ និងមានតម្លៃថោក។ បើគ្មានការកើនឡើងតម្លៃឧស្សាហកម្មក្នុងប្រទេសកម្ពុជា វាប្រហែលជាទៅមិនរួចនោះទេ ក្នុងការផលិតទំនិញជឿនលឿនពីបាតដៃទទេនោះ។ វិធីសាស្ត្រផ្សេងទៀត គឺអ្វីដែលត្រូវបានស្គាល់ថាជាផលិតកម្មដែលមានតម្លៃទាបជាងធម្មតា និងផលិតកម្មពាក់កណ្ដាលមានតម្លៃទាបជាងធម្មតា។ លទ្ធភាពនានារួមមានឧបករណ៍អគ្គិសនី ការដំឡើងគ្រឿងម៉ាស៊ីនសម្រាប់ដឹកជញ្ជូន និងខ្សែភ្លើងសម្រាប់រថយន្ត។ល។

### ១២.៣.១.៥. *ផលិតផលជំនួសការនាំចូល - ការជណ្ដើមយកទីផ្សារក្នុងស្រុក*

#### ១២.៣.១.៥.១. *ផលិតផលរ៉ែនិងផលិតផលផ្អែកលើកសិកម្ម*

កម្ពុជានាំចូលទំនិញប្រើប្រាស់ផ្សេងៗ រួមមានផលិតផលដែលវត្ថុធាតុដើមរបស់វាអាចរកបាននៅក្នុងស្រុក។ ទំនិញប្រើប្រាស់ផ្អែកលើកសិកម្ម ដូចជាអាហារកែច្នៃមានអត្រា៣%នៃការនាំចូលសរុបនិងផលិតផលរ៉ែ ដែលរួមមានស៊ីម៉ងត៍មានចំនួន៩%។ ជាមួយនឹងធនធានដ៏សម្បូរបែបក្នុងស្រុកក្នុងផ្នែកជលផលកសិកម្មយ៉ាងហោចណាស់ក៏មួយចំនួននៃអាហារកែច្នៃដែលត្រូវបាននាំចូល អាចត្រូវបានផលិតក្នុងស្រុកដើម្បីជំនួសឱ្យការនាំចូលទាំងនោះ។ សាច់កំប៉ុង ត្រីកំប៉ុង ផ្លែឈើកំប៉ុង ឬស្ងួត និងប្រេងឆា គឺជាទំនិញប្រើប្រាស់ផ្សេងទៀតក្នុងប្រភេទទំនិញដូចនេះ។ ការវាយតម្លៃដ៏ស៊ីជម្រៅមួយលើទាយជ្ជទាននៃធនធានចាំបាច់ត្រូវធ្វើឡើង ដើម្បីធានាថាគ្មានការនាំចូលមិនចាំបាច់។ ការជណ្ដើមយកទីផ្សារក្នុងស្រុក ដោយផលិតផលផលិតក្នុងប្រទេសកម្ពុជានឹងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនៃអតុល្យភាពពាណិជ្ជកម្ម និងការអភិវឌ្ឍមូលដ្ឋានមួយសម្រាប់ការនាំចេញនាពេលអនាគត។

#### ១២.៣.១.៥.២. *សម្ភារៈសំណង់*

វិស័យសំណង់រួមចំណែកប្រហែលជា៥% នៃផលិតផលក្នុងស្រុកសរុប។ វិស័យនេះអាចរួមចំណែកបន្ថែមទៀត ប្រសិនបើមួយផ្នែកតូចនៃសម្ភារៈសំណង់ត្រូវបានផលិតក្នុងស្រុក ដូចជាឥដ្ឋធម្មតាជាដើម។ នៅពេលដែលការពង្រីកតំបន់ទីក្រុង និងឧស្សាហកម្មអចលនទ្រព្យនៅតែកើតមាន តម្រូវការសម្រាប់សម្ភារសំណង់នឹងកើនឡើង។ ដើម្បីប្រែក្លាយតម្រូវការនេះឱ្យទៅជាចំណូល និងការបង្កើតការងារក្នុងស្រុក កម្ពុជាត្រូវពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការផលិតសម្ភារៈសំណង់ ដែលរួមមានផលិតផលបន្ទាប់បន្សំ ដូចជាបំពង់លូបេតុង បន្ទះបេតុង និងសន្លឹកបេតុង សន្លឹកដែកស័ង្កសី ឥដ្ឋជញ្ជាំង និងឥដ្ឋការ៉ូ។ សម្ភារៈសំណង់មានទំហំធំនិងធ្ងន់ពិបាកដឹកជញ្ជូន ដែលសំខាន់សម្រាប់ការផលិតជំនួសការនាំចូល។

### ១២.៣.១.៦. *ការជំរុញឧស្សាហកម្មស្បែកជើង*

ឧស្សាហកម្មផលិតស្បែកជើងត្រូវបានបង្កើតរួចហើយក្នុងប្រទេសកម្ពុជា ដែលមានការនាំចេញចំនួន ៨ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ឧស្សាហកម្មនេះគឺត្រូវការកម្លាំងពលកម្មច្រើន និងស័ក្តិសមសម្រាប់ការអភិវឌ្ឍក្នុងប្រទេស ដែលខ្វះខាតទុនដូចជាប្រទេសកម្ពុជា។ របបសេរីភាវូបនីយកម្មសម្រាប់ការនាំចូលការផ្គត់ផ្គង់ និងការនាំចេញ ដែលរួមជាមួយនឹងការអភិវឌ្ឍបច្ចេកវិទ្យា និងការត្រួតពិនិត្យគុណភាពនឹងផ្តល់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សន្ទុះជំរុញដែលចាំបាច់យ៉ាងខ្លាំង សម្រាប់កំណើននៃឧស្សាហកម្មនេះ។ ដើម្បីឱ្យមានចីរភាព ឧស្សាហកម្មនេះត្រូវមានឱកាសសម្រាប់បង្កើនផលិតកម្មនៃផលិតផល ដែលមានលក្ខណៈជឿនលឿន និងមានតម្លៃបន្ថែមខ្ពស់ជាងមុន។ ការធ្វើដូចនេះទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងពីសំណាក់ទាំងផ្នែកសាធារណៈ និងផ្នែកឯកជន។

### ១២.៣.១.៧. បង្កើនសមត្ថភាពឧស្សាហកម្មធុនតូច និងមីក្រូឧស្សាហកម្ម

សហគ្រាសធុនតូចនិងមីក្រូសហគ្រាស (សិប្បកម្ម) គឺមានដើមកំណើតក្នុងប្រទេសកម្ពុជា ដែលផ្តល់ការងារបានយ៉ាងច្រើន។ ទោះបីជាការរួមចំណែកនៃសហគ្រាសទាំងនេះក្នុងផលិតផលក្នុងស្រុកសរុបមិនទាន់មានកម្រិតខ្ពស់ក៏ដោយ ក៏អត្ថប្រយោជន៍របស់វាក្នុងការជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងសេដ្ឋកិច្ចក្នុងស្រុក តាមរយៈភាពជាម្ចាស់ទុននិងនិកម្មភាព និងសក្តានុពលភាពសម្រាប់ឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹងលក្ខខណ្ឌទីផ្សារដែលកំពុងប្រែប្រួលគ្រប់ពេល ដោយផ្តល់នូវអំណះអំណាងដ៏មានឥទ្ធិពលសម្រាប់គោលនយោបាយឧស្សាហកម្មដែលគាំទ្រដល់ការអភិវឌ្ឍរបស់ខ្លួន។ ជាទូទៅ បច្ចេកវិទ្យានៃសហគ្រាសធុនតូចនិងមីក្រូសហគ្រាសមានលក្ខណៈសាមញ្ញ និងបុរាណ ដែលនៅមានចន្លោះប្រហោងជាច្រើនសម្រាប់អភិវឌ្ឍន៍បន្ថែមទៀត។ ជំនាញគ្រប់គ្រងជាទូទៅមិនទាន់គ្រប់គ្រាន់ ដែលទាមទារឱ្យមានការគាំទ្រសម្រាប់បង្កើនសមត្ថភាព។

មេរៀនទទួលបានពីបទពិសោធន៍នៃរបៀបគាំទ្រខុសៗគ្នា ចំពោះសហគ្រាសទាំងនេះនិងការអភិវឌ្ឍវិស័យឯកជនផ្តោតសំខាន់លើ៖ (១) ការជំរុញគំនិតផ្តួតផ្តើមនៃសហគ្រិន (២) ការរៀបចំនិងសម្របសម្រួលលទ្ធភាពឈានចូលទៅរកបាននូវសេវាពិគ្រោះយោបល់ (៣) ការបង្កើតនូវប្រព័ន្ធគាំទ្រទូលំទូលាយ និងមានការសម្របសម្រួល (៤) ការធ្វើឱ្យមានបរិយាកាសងាយស្រួល សម្រាប់ការអភិវឌ្ឍសហគ្រាសនិង (៥) ការសម្របសម្រួលឱ្យមានការគាំទ្រអន្តរជាតិផ្ទាល់ចំពោះសហគ្រាស។ យុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍សហគ្រាសធុនតូចនិងមីក្រូសហគ្រាសនេះចាំបាច់ត្រូវពិចារណាលើចំណុចអាទិភាពទាំងនេះ។

*តារាង១២.២ ការប្រៀបធៀបថ្លៃសម្រាប់ FDI ក្នុងប្រទេសអាស៊ី*

| ប្រទេស | | កម្ពុជា | | ថៃ | ចិន | | វៀតណាម | |
|---|---|---|---|---|---|---|---|---|
| ទីក្រុង | | ភ្នំពេញ | ព្រះសីហនុ | បាងកក | សិនចិន | សៀងហៃ | ហាណូយ | ហូជីមិញ |
| ប្រាក់បៀវត្សប្រចាំខែ ($/ខែ) | កម្មករ (រួមទាំងប្រាក់បន្ថែម) | ៦០-៧០ | ៦០-៧០ | ១៩០ | ៩០-១១០ | ១៩០-២៨០ | ៧៥-១១៥ | ៩៥-១៩០ |
| | វិស្វករ/អ្នកត្រួតពិនិត្យ | ១០០-៥០០ | ១០០-៣០០ | ៣០០ | ១២០-២៥០ | ២៨០-៩៦០ | ១៩០-៣១០ | ១៥៥-២៩០ |
| | អ្នកគ្រប់គ្រង | ៥០០-២.៥០០ | n.a. | ៦២០ | ៣៩០-៧២០ | ៩៣០-៩១០ | ៩៧០-៥៩០ | ៩៧០-៦២០ |
| | ប្រាក់ឈ្នួលអប្បបរមាតាមច្បាប់ | ៤៥ | ៤៥ | ៣,៧១/ថ្ងៃ | ៦៩,៣៥ | ៥៩,២ | ៤១,៦ | ៤១,៦ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| តម្លៃដី/ការិយាល័យ | ទីតាំងរោងចក្រលក់ក្នុង IE ($/ម២) | ២០-៤០ (ក្រៅIE) | n.a. | ៣០-៧០ | ១៤ (៥០ឆ្នាំ) | ២៥ (៥០ឆ្នាំ) | ៨០ (៣០ឆ្នាំ) | ១០០ (៤០-៥០ឆ្នាំ) |
| | ទីតាំងរោងចក្រជួលក្នុង IE ($/ម២/ខែ) | ០,១-០,២ | n.a. | មិនដឹង | ០,២៤ | មិនមាន | ០,២២ | ០,២៣ |
| | ការិយាល័យ ($/ម២/ខែ) | ១០-២០ | ១០-២០ | ១០ | ១២-១៤,៥ | ៣០ | ២២ | ១៦ |
| | ផ្ទះអឺផាធឺមិន ($/ខែ) | ១.០០០-២.០០០ | ៨០០-១.៥០០ | ១.៣៥០-១៩៦០ | ៣៦០-៩៧០ | ២.១៥០-៤.០០០ | ១.៧០០ | ១.៨០០ |
| | អគ្គិសនី ($/គីឡូវ៉ាត់) | ០,២១ | ០,២១ | ០,០៤ | ០,០៩-០,០១២ | ០,០៧ | ០,០៧ | ០,០៧ |
| | ទឹក ($/ម៣) | ០,២០ | ០,២៥ | ០,២១-០,៣៦ | ០,២៣-០,២៩ | ០,១៥ | ០,២៣ | ០,២៣ |
| | ទូរស័ព្ទ ( ៣នាទីក្នុងប្រទេសជប៉ុន) | ៤,៨ | ៤,៨ | ២,៣ | ២,៩ | ២,៩ | ៦,៩ | ៦,៩ |
| ដឹកជញ្ជូន (កុងទីណ័រទំហំ៤០ហ្វីតទៅកំពង់ផែយូកូហាម៉ាប្រទេសជប៉ុន) | | ១.៨០០ | ១.៦០០ | ១.៤៥០ | ១.២៥០ | ៧០០ | ១.៥០០ | ១.៥០០ |

*ប្រភព: ទិន្នន័យសម្រាប់កម្ពុជាដោយការស្ទាបស្ទង់មតិនៃរោងចក្ររបស់ក្រុមសិក្សា។ ទិន្នន័យដទៃទាំងអស់ទៀតយកមកពី JETRO*

ពាក់ព័ន្ធជាមួយនឹងហិរញ្ញប្បទាន បទពិសោធន៍ដែលមានបច្ចុប្បន្នក្នុងការជំរុញសហគ្រាសធុនតូច និងមធ្យម (SMEs) និងមីក្រូសហគ្រាសចាំបាច់ត្រូវតែរួមបញ្ចូលគ្នា។ រាជរដ្ឋាភិបាលត្រូវពិនិត្យឡើងវិញ និងសម្រួលឱ្យមានភាពងាយស្រួលបន្ថែមទៀតសម្រាប់អតិថិជន នូវលក្ខខណ្ឌដែលជាញឹកញាប់ត្រូវបានដាក់ចេញដោយទាក់ទងនឹងកម្រិតនៃមូលនិធិផ្ទាល់ខ្លួន ហើយដែលបណ្ដាលឱ្យមានកម្រិតវត្ថុបញ្ចាំមិនសមហេតុផល និងការត្រួតពិនិត្យគុណភាពហួសហេតុ និងការពិនិត្យពិច័យលើពាក្យសុំខ្ចី ក្នុងគោលដៅកែលម្អបរិយាកាសវិនិយោគ។ វិធីសាស្ត្រចូលទៅជិត គឺជាវិធីសាស្ត្រមួយទៀតនៃការអភិវឌ្ឍស្ថាប័នមីក្រូហិរញ្ញវត្ថុ។

### *១២.៣.១.៨. ភាពចាំបាច់នៃការបង្កើតតំបន់ឧស្សាហកម្ម ដែលមានហេដ្ឋារចនាសម្ព័ន្ធប្រកួតប្រជែង*

ខណៈពេលដែលប្រទេសជិតខាងខ្លួន គឺថៃនិងវៀតណាមបានដំណើរការយ៉ាងសកម្មក្នុងអំឡុងទសវត្សរ៍ចុងក្រោយនេះ ក្នុងការបង្កើតតំបន់ឧស្សាហកម្ម ដែលមានហេដ្ឋរចនាសម្ព័ន្ធប្រកួតប្រជែង កម្ពុជានៅមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធសម្បូណ៌បែបនៅឡើយ ដើម្បីផ្ដល់ឱ្យវិនិយោគិនដែលមានសក្ដានុពល ក្នុងការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រកកន្លែងសម្រាប់ធ្វើជាទីតាំងផលិតកម្មរបស់ពួកគេក្នុងប្រទេសកម្ពុជា។ ថ្លៃដើមហេដ្ឋារចនាសម្ព័ន្ធមានកម្រិតខ្ពស់ ជាពិសេសថ្លៃអគ្គិសនី។ ថ្លៃដឹកជញ្ជូន គឺខ្ពស់ជាងយ៉ាងច្រើន បើប្រៀបធៀបថ្លៃដឹកជញ្ជូនក្នុងប្រទេសជិតខាងភាគច្រើន ជាពិសេសគឺក្នុងរាជធានីភ្នំពេញតែម្តង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលត្រូវខិតខំប្រឹងប្រែងបង្កើតតំបន់ឧស្សាហកម្ម ដែលមានហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាពខ្ពស់និងមានប្រសិទ្ធភាព។

### ១៤.៣.៤. ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស

**តំបន់សេដ្ឋកិច្ចពិសេស** (SEZs) គឺមានបំណងដើម្បីទាក់ទាញឧស្សាហកម្ម (ដូចជាល្បែងក្មេងលេង ឬឧស្សាហកម្មបង្គុំផ្សេងទៀត) ដែលដោយសារតែកំណើនប្រាក់ឈ្នួលមិនអាចដំណើរការទៀតបានក្នុងប្រទេសថៃម៉ាឡេស៊ីតៃវ៉ាន់ឬជប៉ុន។**តំបន់សេដ្ឋកិច្ចពិសេស**បានដើរតួនាទីសំខាន់ជាប្រវត្តិសាស្ត្រក្នុងប្រទេសថៃ តៃវ៉ាន់ ចិន ហុងកុង និងម៉ាឡេស៊ី ប៉ុន្តែការជោគជ័យដំបូងៗខ្លះក្នុង **តំបន់សេដ្ឋកិច្ចពិសេស** (រួមទាំងរបស់ប្រទេសថៃ) បានត្រូវជាប់ទាក់ទងយ៉ាងច្បាស់ជាមួយនឹងពន្ធគយ និងបរិយាកាសគោលនយោបាយ ដែលបានកើតមានក្នុងពាទសវត្សរ៍កន្លងមក ជាពិសេសពន្ធនាំចូលខ្ពស់។ **តំបន់សេដ្ឋកិច្ចពិសេស** និងតំបន់ផលិតកម្មពិសេសអាចត្រូវបានធ្វើឱ្យមានលក្ខណៈផ្សេងពីសេដ្ឋកិច្ចក្នុងស្រុក ដើម្បីផលិតទាំងស្រុងសម្រាប់ការនាំចេញដូច្នេះហើយមិនចាំបាច់មានរបបពន្ធនាំចូលនោះទេ។ ការចំណេញចម្បងពី **តំបន់សេដ្ឋកិច្ចពិសេស** គឺការបង្កើតការងារធ្វើ។

ការទាក់ទាញសំខាន់សម្រាប់តំបន់មួយ គឺបណ្តុំនៃហេដ្ឋារចនាសម្ព័ន្ធចាំបាច់ និងការអនុវត្តការសម្របសម្រួលពាណិជ្ជកម្ម ដែលផ្តល់ការអនុគ្រោះដល់អ្នកនាំចេញ និងពេលខ្លះការលើកលែងពន្ធដែលទាំងអស់នេះគឺជាការចំណាយច្រើនណាស់។ លើសពីនេះ រដ្ឋាភិបាលជាច្រើនក៏ឧបត្ថម្ភទុនដល់ការវិនិយោគក្នុងតំបន់របៀបនេះតាមរយៈការលើកទឹកចិត្តដោយមិនយកពន្ធ។

ដោយយល់ឃើញថា **តំបន់សេដ្ឋកិច្ចពិសេស** នឹងមានសារៈសំខាន់ដល់ពិពិធកម្មសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាកាលពីខែធ្នូឆ្នាំ ២០០៥ បានអនុម័តអនុក្រឹត្យស្តីពីការបង្កើតនិងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស (ដើម្បីរួមបញ្ចូលតំបន់កែច្នៃនាំចេញ និងតំបន់ពាណិជ្ជកម្មសេរី) ។ ចាប់ពីពេលនោះមករាជរដ្ឋាភិបាលបានសម្រេចឱ្យបង្កើតតំបន់សេដ្ឋកិច្ចពិសេសសរុបចំនួន ២១ ដែលមានទីតាំងតាមបណ្តោយព្រំដែនជាមួយថៃ និង វៀតណាម (កោះកុង ប៉ោយប៉ែត បាវិត ភ្នំឌិន) នៅខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។ តំបន់៦ នៃតំបន់ទាំង២១នេះ បានចាប់ផ្តើមដំណើរការរួចហើយ។

*តារាង១៤.៣. ប្រភេទឧស្សាហកម្ម/សេវាកម្មដែលត្រូវបានទាក់ទាញមកក្នុង SEZs*

| *ប្រភេទតំបន់* | *ប្រភេទឧស្សាហកម្មដែលរំពឹងទុក* | *ប្រភេទឧស្សាហកម្មជាក់លាក់* |
|---|---|---|
| តំបន់សេរី(FZ) | ឧស្សាហកម្មមិនមានលក្ខណៈប្រពៃណីមានគោលដៅសម្រាប់ការនាំចេញនិងប្រើប្រាស់ពលកម្មច្រើន | សម្លៀកបំពាក់/ក្រណាត់ (គុណភាពខ្ពស់ដល់មធ្យម) សម្លៀកបំពាក់កីឡា |
| | | គ្រឿងក្មេងលេង ឈើទន់ និងជ័រ |
| | | បរិក្ខារគ្រឿងម៉ាស៊ីន |
| | | គ្រឿងបន្លាស់ និងបរិក្ខាររថយន្តដូចជាខ្សែភ្លើងសម្រាប់រថយន្ត |

| | | |
|---|---|---|
| | | ផលិតផលសេរ៉ាម៉ិកៈ ឥដ្ឋសេរ៉ាម៉ិក ក្បឿង។ល។ |
| | | ផលិតផលជ័រៈ ស្រោមដៃជ័រសម្រាប់វះកាត់ និងពេទ្យ |
| | | ផលិតផលក្រដាសៈ វត្ថុធាតុសម្រាប់វេចខ្ចប់ និងសម្រាប់ទ្រាំការពារ |
| | | ផ្សេងៗ (គ្រឿងអលង្ការ។ល។) |
| | ឧស្សាហកម្មមានតម្លៃបន្ថែមខ្ពស់ មានទិសដៅសម្រាប់កែច្នៃ និងប្រើប្រាស់ពលកម្មច្រើន | រថយន្ត/ទោចក្រយានយន្តប្រើប្រាស់រួចនិងសំបកកង់ប្រើប្រាស់រួចៈសម្រាប់យកគំរូតាម ជួសជុលនិងកែច្នៃ |
| | អ្នកលក់ដុំអន្តរជាតិ | តួនាទីជាកន្លែងឆ្លងកាត់ៈ ស្តុកទំនិញមិនគិតថ្លៃសម្រាប់ការដឹកឆ្លងកាត់ |
| តំបន់លើកទឹកចិត្ត (PZ) | ប្រភេទមានគោលដៅសម្រាប់នាំចេញ (លក្ខណៈប្រពៃណី) និងប្រើប្រាស់ពលកម្មច្រើន | សម្លៀកបំពាក់ៈ សម្លៀកបំពាក់ខាងក្រៅ អាវខោសម្លៀកបំពាក់កូនក្មេងនិង |
| | | គ្រឿងសម្រាប់ពាក់នៅជើងៈស្បែកជើងធ្វើពីស្បែកនិងស្បែកជើងធ្វើពីសារធាតុគីមី |
| | ឧស្សាហកម្មមានគោលដៅសម្រាប់ការនាំចេញ សម្រាប់ជំនួសការនាំចូលមួយផ្នែកនិងពឹងផ្អែកលើធនធានក្នុងស្រុក | ផលិតផលកសិកម្មកែច្នៃៈ បន្លែផ្លែឈើនិងគ្រាប់ផ្លែឈើកំប៉ុង |
| | ឧស្សាហកម្មមានគោលដៅសម្រាប់ការនាំចេញ សម្រាប់ជំនួសការនាំចូលមួយផ្នែកនិងប្រើប្រាស់ពលកម្មច្រើន | ការដំឡើងឧបករណ៍អេឡិចត្រូនិចៈ ម៉ាស៊ីនបោកខោអាវទូរទឹកកក |
| | | ការដំឡើងគ្រឿងម៉ាស៊ីនៈ ម៉ាស៊ីនបូមតូចម៉ាស៊ីនភ្លើង |
| | | កែច្នៃលោហធាតុៈ សន្លឹកស័ង្កសី កាំបិត សមស្លាបព្រា ដែក សម្ភារៈសំណង់ |

*ប្រភពៈ JICA*

**តំបន់សេដ្ឋកិច្ចពិសេស** ផ្តល់នូវអត្ថប្រយោជន៍ដូចតទៅនេះ ៖ (១) «សេវាច្រកចេញចូលតែមួយ» សម្រាប់នាំចេញនាំចូល ដោយមានមន្ត្រីរដ្ឋាភិបាលនៅប្រចាំការនៅនឹងកន្លែងក្នុងការផ្តល់សេវារដ្ឋបាល។ ការដាក់ពាក្យសុំដើម្បីបង្កើតរោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេសត្រូវបានដោះស្រាយនៅនឹងកន្លែង ក៏ដូចជាការចំណាត់ការ និងលិខិតអនុញ្ញាតរដ្ឋបាលផ្សេងៗការលើកទឹកចិត្តផ្នែកសារពើពន្ធដែលរួមមានពន្ធប្រាក់ចំណូលពន្ធគយ និងការលើកលែងអាករលើតម្លៃបន្ថែម ទីតាំងនៅក្បែរបណ្តាញផ្លូវថ្នល់ អគាររោងចក្រដែលល្អ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រណិត ការផ្គត់ផ្គង់ទឹកបរិសុទ្ធ រោងចក្រចម្រាញ់ទឹក ការបណ្តុះបណ្តាលវិជ្ជាជីវៈ សេវាធនាគារ សេវាប្រៃសណីយ៍ និងទូរគមនាគមន៍ រោងចក្រថាមពលដើម្បីផលិតអគ្គិសនីខ្លួនឯងផ្ទាល់។

របៀងសេដ្ឋកិច្ចភ្នំពេញ-ព្រះសីហនុដែលមានរាជធានីភ្នំពេញ ខេត្តព្រះសីហនុនិងខេត្ត ៥ ទៀតតាមបណ្តោយផ្លូវជាតិលេខ៤ ដែលមានចំនួនប្រជាជន ៩,៨លាននាក់ និងផ្ទៃដីសរុប៣១.០០០ គ.ម។ មូលហេតុនៃការបង្កើតរបៀងនេះ គឺដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងបញ្ហាប្រឈមមុខនៃការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជា និងដើម្បីជំរុញការអភិវឌ្ឍដែលមានតម្រូវការកើនឡើង ដូចជាការជំរុញការកែច្នៃចំណីអាហារ និងការនាំចេញ។

ការសម្រេចគោលនយោបាយសំខាន់មួយ គឺដើម្បីបង្កើតតំបន់សេដ្ឋកិច្ចពិសេសដើម្បីទាក់ទាញវិនិយោគផ្ទាល់បរទេសមកខេត្តព្រះសីហនុ។ ប៉ុន្តែប្រការនេះគឺមិនគ្រប់គ្រាន់នោះទេ។ ក្របខណ្ឌការងារច្បាប់និងស្ថាប័នដ៏ល្អត្រឹមត្រូវមួយ គួរត្រូវបានបង្កើតឡើង ដើម្បីលើកទឹកចិត្តឱ្យមានការហូរចូលនៃវិនិយោគផ្ទាល់បរទេសមកក្នុងតំបន់សេដ្ឋកិច្ចពិសេស។ ជាងនេះទៀត ការអភិវឌ្ឍឧបករណ៍សម្រួលការងារនៅកំពង់ផែក៏ជាផ្នែកសំខាន់មួយផងដែរ ក្នុងការបង្ហាញថាខេត្តព្រះសីហនុជាច្រកចេញចូលអន្តរជាតិប្រកបដោយប្រសិទ្ធភាព។

ភាពប្រសើរឡើងនៃការតភ្ជាប់ផ្លូវថ្នល់ជាពិសេសផ្លូវជាតិលេខ៤៨ គឺមានសារៈសំខាន់សម្រាប់ការពង្រឹងទំនាក់ទំនងជាមួយប្រទេសថៃ និងផ្តល់នូវសន្ទុះសម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរនាថ្ងៃអនាគត។ ពេលនោះ **តំបន់សេដ្ឋកិច្ចពិសេស** អាចត្រូវបានប្រើប្រាស់ដើម្បីទាក់ទាញសហគ្រិនបរទេស ចូលទៅក្នុងការរៀបចំផ្គត់ផ្គង់ជាមួយសហគ្រិនក្នុងស្រុកសម្រាប់ផ្លែឈើ និងអាហារសមុទ្រដែលមានក្នុងស្រុកជាដើម។ ក្របខ័ណ្ឌ **តំបន់សេដ្ឋកិច្ចពិសេស** ដែលត្រូវបានបង្កើតយ៉ាងរឹងមាំសម្រាប់ខេត្តព្រះសីហនុនោះ នឹងបម្រើជាមូលដ្ឋានដើម្បីសម្រួលថែមទៀតដល់វិនិយោគពីបរទេស នៅក្នុងផលិតកម្មទំនិញដ៏សម្បូរបែប។

ក្នុងរយៈពេលវែង ការរីកសាយនៃនគរូបនីយកម្មនឹងនាំឱ្យមានតម្រូវការសម្រាប់ផលិតផលក្នុងស្រុក ដែលត្រូវបានផ្គត់ផ្គង់ភាគច្រើនដោយផលិតករ និងអ្នកផ្តល់សេវាកម្មកម្ពុជា។ សមត្ថភាពរបស់វិស័យបន្ទាប់បន្សំត្រូវអភិវឌ្ឍទន្ទឹមនឹងនគរូបនីយកម្ម ប្រសិនបើកម្ពុជាចង់បានអត្ថប្រយោជន៍ពីនគរូបនីយកម្មដែលកំពុងលូតលាស់នោះ។ ឧស្សាហូបនីយកម្មដ៏ឆាប់រហ័សនឹងមានការចំណាយផ្នែកបរិស្ថាន។ គោលនយោបាយត្រឹមត្រូវសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិគួរត្រូវបានបង្កើតឥឡូវនេះ ដើម្បីកុំឱ្យបរិស្ថានត្រូវបានបំផ្លាញមិនអាចជួសជុលបាន ពេលដែលការអភិវឌ្ឍឧស្សាហកម្មឈានមកដល់ ។

**តំបន់សេដ្ឋកិច្ចពិសេស** នៅក្រុងព្រះសីហនុនិងក្លាយជាតំបន់យុទ្ធសាស្ត្រមួយសម្រាប់កម្ពុជាដើម្បីបម្រើជាបឋមរូបសម្រាប់ពិពិធកម្មនៃការនាំចេញ និងការបង្កើតការតភ្ជាប់ទៅមករវាង **តំបន់សេដ្ឋកិច្ចពិសេស** និងតំបន់ដែលនៅសល់នៃសេដ្ឋកិច្ច។ ការសង្កត់ធ្ងន់ក្នុងការអភិវឌ្ឍ**តំបន់សេដ្ឋកិច្ចពិសេស** នៅខេត្តព្រះសីហនុ គឺផ្តោតទៅលើការជំរុញឧស្សាហកម្មនិងសេវាកម្ម ដែលមិនមាននៅកម្ពុជានាពេលបច្ចុប្បន្ន។ ដំណើរការនាំចេញលឿននិងប្រសិទ្ធផលជាងមុនក៏នឹងត្រូវបានរៀបចំឱ្យហើយនៅក្នុង **តំបន់សេដ្ឋកិច្ចពិសេស**។

ទិដ្ឋភាពមួយទៀតនៃគោលនយោបាយឧស្សាហកម្ម គឺការអភិវឌ្ឍ **តំបន់លើកកម្ពស់ផ្នែក**



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ឧស្សាហកម្ម** (Industrial promotion zones)។ ក្នុងតំបន់ទាំងនេះ ការសង្កត់ធ្ងន់នឹងផ្តោតទៅលើការអភិវឌ្ឍឧស្សាហកម្មបែបបុរាណដោយប្រើធនធានក្នុងប្រទេស និងបម្រើឱ្យទីផ្សារក្នុងស្រុក ដោយទាក់ទាញវិនិយោគពីក្រៅប្រទេស និងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ។ តារាងខាង១២.២ ខាងលើសង្ខេបលក្ខណៈសំខាន់ៗនៃ **តំបន់សេដ្ឋកិច្ចពិសេស** និង **តំបន់លើកកម្ពស់ឧស្សាហកម្ម**។

### ១២.៣.៣. ភាពជាដៃគូរដ្ឋនិងឯកជន

ដោយស្គាល់ពីប្រយោជន៍នៃការផ្តល់ជូននូវហេដ្ឋារចនាសម្ព័ន្ធពីផ្នែកឯកជននោះ រាជរដ្ឋាភិបាលកម្ពុជាបានអភិវឌ្ឍក្របខ័ណ្ឌគតិយុត្តិមួយសម្រាប់ **ភាពជាដៃគូរដ្ឋនិងឯកជន** (PPP) ខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធនៅគ្រប់វិស័យទាំងអស់ ក្នុងការផលិតនិងចែកចាយអគ្គិសនីតាមទីក្រុង និងជនបទ ការផ្តល់ការផ្គត់ផ្គង់ទឹកនៅជនបទ សេវាកម្មទូរគមនាគមន៍ អ៊ិនធឺណិត ខ្សែទូរស័ព្ទអចល័ត ចល័ត ផ្លូវជាតិ និងអាកាសយានដ្ឋាន និងសេវាកម្មប្រមូលនិងបញ្ចេញចោលកាកសំណល់ពីទីក្រុង។

តារាង ១២.៤ សង្ខេបពីកិច្ចសន្យា**ភាពជាដៃគូររដ្ឋឯកជន**សំខាន់ៗមកទល់ពេលបច្ចុប្បន្ននៅកម្ពុជា ដោយចែកពួកវាជាក្រុម តាមវិស័យ ដោយចង្អុលបង្ហាញអង្គភាពរដ្ឋ (ក្រសួង នាយកដ្ឋាន និង ភ្នាក់ងារនិយតកម្ម) ដែលទទួលខុសត្រូវជាផ្លូវការខាងផ្នែករដ្ឋបាល និង ការអនុម័តនានា សម្រាប់វិស័យនីមួយៗ និងអង្គភាពទាំងឡាយណា ដែលពាក់ព័ន្ធពិតប្រាកដជាមួយកិច្ចសន្យា**ភាពជាដៃគូររដ្ឋឯកជន** នីមួយៗ ដោយពិពណ៌នាពីទម្រង់ និងបែបបទនៃកិច្ចសន្យា **ភាពជាដៃគូររដ្ឋឯកជន** ដែលត្រូវបានប្រើក្នុងករណីនីមួយៗ និងតម្លៃទុននៃគម្រោងបើគេស្គាល់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ៥
# សេវាកម្មនិងហេដ្ឋារចនាសម្ព័ន្ធ


ជំពូកទី ១៣. វិស័យទេសចរណ៍

ជំពូកទី ១៤. ទូរគមនាគមន៍

ជំពូកទី ១៥. ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

ជំពូកទី ១៦. វិស័យថាមពល

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១៣
# វិស័យទេសចរណ៍

## ១៣.១. សារវគារ

កម្ពុជាគឺជាដែនដីមួយដែលពោរពេញទៅដោយធនធានធម្មជាតិនិងសម្បត្តិវប្បធម៌។ ក្នុងទសវត្សរ៍កន្លងមក ឧស្សាហកម្មទេសចរណ៍បានរីកចម្រើនគួរឱ្យកត់សម្គាល់ រហូតក្លាយជាសសរស្តម្ភមួយនៃកំណើនសេដ្ឋកិច្ច។ ការអភិវឌ្ឍវិស័យទេសចរណ៍យ៉ាងឆាប់រហ័ស កើតឡើងដោយសារកត្តាមួយចំនួនដូចជា ៖ (១) ការទទួលបានសន្តិភាពនិងស្ថេរភាពនៅកម្ពុជា ចាប់តាំងពីក្រោយទសវត្សរ៍ឆ្នាំ ១៩៩០ (២) ការទាក់ទាញទេសចរណ៍ ជាពិសេសប្រាសាទអង្គរវត្ត ដែលត្រូវបានចាត់ចូលជាបេតិកភ័ណ្ឌពិភពលោកតាំងពីឆ្នាំ ១៩៩២ (៣) ការកើនឡើងនៃការធ្វើដំណើរក្នុងស្រុកនិងអន្តរជាតិ និង (៤) គោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការអភិវឌ្ឍទេសចរណ៍ ដូចជាគោលនយោបាយបើកទូលាយជើងមេឃ ការផ្តល់ទិដ្ឋការនៅនឹងកន្លែង និងការលើកលែងទិដ្ឋាការសម្រាប់ជនកម្ពុជារស់នៅបរទេស (CDRI, 2007, p. 31)។

ទេសចរណ៍គឺជាផ្នែកដ៏ធំមួយនៃឧស្សាហកម្មសេវាកម្មរបស់កម្ពុជា។ ការជំរុញការអភិវឌ្ឍសេវាកម្មនេះកើតចេញពីការពង្រីកយ៉ាងឆាប់រហ័សនៃវិស័យទេសចរណ៍និងសណ្ឋាគារ ក្នុងអំឡុងឆ្នាំ ១៩៩៤-១៩៩៨។ វិស័យទេសចរណ៍បានដើរត្រឡប់ក្រោយ ២ ដង ដែលលើកទី ១ ក្នុងអំឡុងឆ្នាំ ១៩៩៧-១៩៩៨ ដោយសាររងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចអាស៊ាននិងស្ថានភាពជ្រួលច្របល់នៅក្នុងប្រទេស និងលើកទី២ ដោយសារការរីកសាយភាយនៃមេរោគ SARS ការទន្ទ្រានពីសំណាក់ប្រទេសថៃ និងអស្ថេរភាពនយោបាយបន្ទាប់ពីការបោះឆ្នោតនៅឆ្នាំ ២០០៣។

ទោះជាយ៉ាងណា រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមអនុវត្តគោលនយោបាយជាច្រើនភ្លាមៗ ដើម្បី៖ (១) លើកកម្ពស់ផលិតផលទេសចរណ៍និងមានសញ្ញាសម្គាល់ ដោយផ្តោតនៅទីក្រុងភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ (២) អភិវឌ្ឍផលិតផលដោយផ្តោតភ្លាមៗលើការលើកកម្ពស់ស្តង់ដាររបស់សណ្ឋាគារ ភោជនីយដ្ឋាន តំបន់ទេសចរណ៍ សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ (៣) កែលម្អច្រកចូល តាមរយៈទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា អាកាសយានដ្ឋាន និងការតភ្ជាប់កម្ពុជាទៅនឹងច្រកទេសចរណ៍អន្តរជាតិនៅក្នុងតំបន់អាស៊ីអគ្នេយ៍ ដូចជាទីក្រុងបាងកក គូឡាឡាំពួរ និងសិង្ហបុរី (៤) លើកកម្ពស់គុណភាពកម្លាំងពលកម្មរបស់កម្ពុជាតាមរយៈការបណ្តុះបណ្តាល និង (៥) ពង្រឹងការសម្របសម្រួលនិងការគ្រប់គ្រងវិស័យទេសចរណ៍ តាមរយៈការអភិវឌ្ឍស្ថាប័ននៅតាមក្រសួង និងភ្នាក់ងាររបស់រដ្ឋាភិបាល។

វិស័យទេសចរណ៍មានកំណើនយ៉ាងឆាប់រហ័ស ដោយមានអ្នកទេសចរណ៍បានមកដល់កម្ពុជារហូតដល់ជាង ២ លាននាក់នៅឆ្នាំ ២០០៨។

## ១៣.២. ការទាក់ទាញនិងសកម្មភាពអ្នកទេសចរ

កម្ពុជាបានទាក់ទាញអ្នកទេសចរ ដោយភ្ជាប់ជាមួយនឹងបរិស្ថានធម្មជាតិ ប្រវត្តិសាស្ត្រ និងវប្បធម៌៖

- **លក្ខណៈពិសេសផ្នែកវប្បធម៌ បុរាណវត្ថុ និង ប្រវត្តិសាស្ត្រ** - បរិវេណអង្គរនៃប្រាសាទអង្គរវត្ត អង្គរធំ ប្រាសាទដទៃទៀត និងបារាយណ៍ បង្កើតបានជាភាពទាក់ទាញដ៏ល្បីល្បាញជាអន្តរជាតិនិងសំខាន់បំផុតរបស់កម្ពុជា។ ប្រាសាទអង្គរវត្ត និង ប្រាសាទព្រះវិហារត្រូវបានចាត់ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **ប្រាសាទសំខាន់ៗផ្សេងទៀតនិងតំបន់បុរាណវត្ថុ** - ប្រាសាទផ្សេងទៀតដូចជាព្រះវិហារ បន្ទាយឆ្មារ ភ្នំពេញ អង្គរបុរី សំបូរព្រៃគុហ៍ ក៏ត្រូវបានចាត់ទុកជាតំបន់ទេសចរណ៍សំខាន់ផងដែរ។
- **សារមន្ទីរនិងបូជនីយដ្ឋាន** - សារមន្ទីរជាតិនៅភ្នំពេញ និង សារមន្ទីរជាតិអង្គរផ្តល់នូវការពិពណ៌នាយ៉ាងក្បោះក្បាយអំពីប្រវត្តិសាស្ត្រនិងវប្បធម៌ខ្មែរ។
- **ព្រះបរមរាជវាំងនិងអគារប្រវត្តិសាស្ត្រ** - ព្រះបរមរាជវាំងនិងអគារសម័យអាណានិគមបារាំងនៅភ្នំពេញនិងនៅតាមបណ្តាខេត្តនានា បានក្លាយជាភាពទាក់ទាញអ្នកទេសចរដ៏សំខាន់។
- **ភូមិបណ្តែតទឹក** - ភូមិបណ្តែតទឹក ជាពិសេសនៅលើដងទន្លេសាបបានទាក់ទាញអ្នកទេសចរជាច្រើន ឱ្យមកទស្សនាកម្ពុជា។
- **សិប្បកម្មប្រពៃណីនិងសិល្បៈសហសម័យ** - សិប្បកម្មនិងសិល្បៈកម្ពុជាមានលក្ខណៈគួរឱ្យពេញចិត្តនិងពិសេសជាខ្លាំង ដូចជា សូត្រខ្មែរ គ្រឿងប្រាក់ ចម្លាក់ឈើ ត្បូងមានតម្លៃ គ្រឿងអលង្ការ និងសេរ៉ាមិករបស់កម្ពុជា។
- **លក្ខណៈពិសេសធម្មជាតិ** - ឧទ្យានជាតិចំនួន ៧ និងតំបន់អភិរក្សសត្វព្រៃចំនួន ១០ ត្រូវបានកំណត់ថាជាតំបន់ការពារ ទេសភាពព្រៃភ្នំដ៏មានសោភ័ណភាព ទឹកជ្រោះ និងបឹងបួរ បានក្លាយជាតំបន់ទាក់ទាញអ្នកទេសចរ។ ខេត្តរតនគិរីនិងមណ្ឌលគិរីត្រូវបានកំណត់ថាជាគោលដៅទេសចរណ៍ធម្មជាតិ ដែលផ្តល់ភាពសម្បូរបែបដល់គម្រោងទេសចរណ៍។
- **ឆ្នេរខ្សាច់ តំបន់សមុទ្រ និង ទន្លេមេគង្គ** - ឆ្នេរខ្សាច់ដ៏អស្ចារ្យស្ថិតតាមបណ្តោយឆ្នេរ សមុទ្រកែប សមុទ្រកាម និង ក្រុងព្រះសីហនុ។ កោះនានាផ្តល់នូវឆ្នេរខ្សាច់ដែលត្រូវបានការពារយ៉ាងល្អ និងជាកន្លែងហែលទឹក។

## ១៣.៣. ទេសចរណ៍វប្បធម៌

ទេសចរណ៍វប្បធម៌ គឺជាសសរស្តម្ភមួយនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ ប្រាសាទអង្គរវត្តដែល ល្បីល្បាញពាសពេញសកលលោក គឺជាកេរ្តិ៍មរតកមួយដែលបន្សល់ទុក ដោយអ្នកមានទេពកោសល្យផ្នែកស្ថាបត្យកម្មព្រះបាទ **សូរ្យវរ្ម័នទីពីរ** (១១១៣-១១៥០) ដែលបានប្រែក្លាយទៅជាប្រភពដ៏ចម្បងមួយក្នុងការរកប្រាក់ចំណូលប្តូរជារូបិយប័ណ្ណបរទេសសម្រាប់កម្ពុជា ក្នុងយុគសម័យទំនើប។ ក្នុងរជ្ជកាលព្រះបាទ **សូរ្យវរ្ម័នទីពីរ** វិស្វកម្មខ្មែរបានឈានដល់កំពូលនៃភាពឥតខ្ចោះលើផ្នែកបច្ចេកទេសនិងគុណតម្លៃសិល្បៈ។ ការកសាងផ្ទាំងសីលាជាលក្ខណៈស្រទាប់ត្រួតស៊ីគ្នានៅលើពំនូកសិប្បនិមិត្តមួយ ប្រាសាទអង្គរវត្តជានិមិត្តរូបតំណាងឱ្យស្ថានកំពូល ជាទីដែលព្រះនិងមហាក្សត្រគង់នៅក្នុងបរមសុខនិងជាស្នាដៃឯកនៃស្ថាបត្យកម្មខ្មែរ។

អង្គរដែលជាតំបន់ទាក់ទាញភ្ញៀវទេសចរដ៏សំខាន់ក្នុងប្រទេសនោះ ធ្លាប់ជារាជធានីនៃអាណាចក្រខ្មែរ ចន្លោះសតវត្សទី ៩ និងទី ១៥។ ក្រៅពីប្រាសាទនានាក្នុងបរិវេណអង្គរនោះ នៅមានសំណង់ធំៗចំនួន ៤០ ផ្សេងទៀតជាមួយរចនាបទនិងរយៈកាលខុសៗគ្នាក្នុងតំបន់ជុំវិញអង្គរ។ ប្រាសាទទាំងនេះមានទីតាំងស្ថិតក្នុងកន្លែងធម្មជាតិដ៏ពិសេស រួមមានទន្លេ ព្រៃព្រឹក្សា និងវាលស្រែ។ ជាងនេះទៅទៀត អង្គរក៏ជាភូមិករមួយផងដែរ ដែលមានសហាគមន៍មួយចំនួនរស់នៅទីនោះ ដោយបានរក្សាប្រពៃណីដ៏មានប្រជាប្រិយឱ្យនៅរស់រវើក និងថែរក្សាកេរ្តិ៍មរតកដ៏ច្រើន ដែលបានបន្តពីជំនាន់មួយទៅជំនាន់មួយ តាមរយៈការនិយាយតគ្នា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អង្គការយូណេស្កូបានប្រកាសថា ប្រាសាទអង្គរជាបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ ១៩៩២ ហើយបានចាត់ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដែលរងខូចខាត។ គណៈកម្មាធិការបេតិកភ័ណ្ឌពិភពលោកបានលើកលែងលើចំណុចមួយចំនួនចំពោះលក្ខខណ្ឌតម្រូវ មុននឹងអនុម័តការដាក់បញ្ចូល ដោយថ្លែងថាការសម្រេចចិត្តគឺ "ឆ្លើយតបទៅនឹងស្ថានភាពពិសេសមិនធម្មតាមួយ"។ ការអភិរក្សតំបន់នោះបានក្លាយជាកង្វល់មួយសម្រាប់ពិភពលោកទាំងមូល។

នៅប្រាសាទបាយ័ន ទស្សនីយភាពនៃជីវិតពីអតីតកាលបានស្តែងចេញនៅក្នុងស្រមោលនៃកំពូលប្រាសាទទាំងឡាយដែលបង្ហាញពីទឹកមុខចម្លាក់ដ៏ធំៗ ជាមួយនឹងស្នាមញញឹមមិនចេះរីងស្ងួត។ នៅតាមថ្នាក់នីមួយៗ ដោយចាប់ផ្តើមពីពិភពព្រះអាទិទេពស្ថិតនៅពីលើពិភពនៃអង្គក្សត្រ ហើយនៅពីក្រោមមានពិភពមនុស្សលោកធម្មតា រាប់ចាប់ពីទាសីបម្រើអាហាររហូតដល់អ្នកឈរអមកំពុងមើលបញ្ចល់មាន់។ នៅមិនឆ្ងាយប៉ុន្មានពីប្រាសាទអង្គរដ៏ល្បីនោះ គឺប្រាសាទបន្ទាយស្រីដែលជាស្នាដៃសិល្បៈពីថ្មភក់ពណ៌ផ្កាឈូក និងចម្លាក់អប្សរានិងអ្នកចំបាំងវ័យក្មេង ដែលមានសោភណ្ឌមិនអាចប្រៀបបាន។ គួរឱ្យកត់សម្គាល់ផងដែរ ប្រាសាទព្រះបាទឡេស្ស័យដែលរុំព័ទ្ធដោយរុក្ខាសម្រស់នៃសុរិយាអស្តង្គតពីលើស្រះស្រង់ និង ប្រាសាទតាព្រហ្មជាមួយដើមឈើនិងវល្លិ៍ដុះលូតលាស់ទាំងខាងក្នុងនិងនៅពីលើផ្ទាំងសីលា ដែលជាភស្តុតាងបង្ហាញពីស្ថានភាពរបស់ប្រាសាទទាំងនេះដែលគេបានរកឃើញ មុននឹងការងារស្តារឡើងវិញបានចាប់ផ្តើមទៅទៀត។

១០ ឆ្នាំបន្ទាប់ពីយុទ្ធនាការអភិរក្សអង្គរបានចាប់ផ្តើម បញ្ហាធំៗនៅតាមតំបន់ដែលជានិមិត្តរូបរបស់វប្បធម៌ខ្មែរត្រូវបានដោះស្រាយ ដោយសារការខិតខំប្រឹងប្រែងរបស់សហគមន៍អន្តរជាតិ ដែលបានដាក់ការវិនិយោគជាង ៥០ លានដុល្លារ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជានិងការសម្របសម្រួលរបស់ដោយអង្គការយូណេស្កូ។ សមិទ្ធផលក្នុងរយៈពេល ១០ ឆ្នាំនេះមានដូចជាៈ គម្រោងស្តារនិងអភិវឌ្ឍន៍ប្រហែល ១០០ គម្រោងត្រូវបានបញ្ចប់គ្រាប់មីនច្រើនជាង ២៥,០០០ គ្រាប់ត្រូវបានកំទេច ដែលក្នុងនោះ ៣០០០ គ្រាប់ ត្រូវបានគេកប់នៅលើតំបន់បុរាណវត្ថុ និងគ្រាប់បែកនិងគ្រឿងផ្ទុះ ៨០,០០០ គ្រាប់ត្រូវបានបំផ្លាញចោល។ អង្គភាពនគរបាលបេតិកភណ្ឌមួយត្រូវបានបង្កើតឡើង បញ្ជីសារពើភណ្ឌកត់ត្រាវត្ថុបុរាណត្រូវបានរៀបចំឡើង និងយុទ្ធនាការបង្កើនការយល់ដឹងនានាត្រូវបានអនុវត្ត ដើម្បីរារាំងដល់ការជួញដូរទ្រព្យសម្បត្តិវប្បធម៌ និងការចូលលួចបុរាណវត្ថុក្នុងតំបន់ការពារ។

ក្រៅពីប្រតិបត្តិការអភិរក្សស្ថាបត្យកម្មនិងវត្ថុបុរាណ ដែលកំពុងត្រូវបានអនុវត្តដោយក្រុមជំនាញមកពីប្រទេសបារាំង ជប៉ុន អាល្លឺម៉ង់ អ៊ីតាលី ឥណ្ឌា និងចិននោះ ក៏មានការប្រែក្លាយសកម្មភាពឱ្យតម្រង់ទៅរកការអភិវឌ្ឍ តាមរយៈការពង្រីកដំណើរការជាមួយគម្រោង ដែលផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់សហគមន៍ក្នុងសហគមន៍។ ដើម្បីលើកកម្ពស់ការតភ្ជាប់រវាងតំបន់និងខេត្តផ្សេងៗក្នុងប្រទេសនោះ រដ្ឋាភិបាលបានធ្វើការប្តេជ្ញាចិត្តរយៈពេលយូរអង្វែងមួយក្នុងការស្ថាបនាអាកាសយានដ្ឋានថ្មីមួយ ដែលនៅដាច់ឆ្ងាយពីការដ្ឋានវត្ថុបុរាណ ការបង្កើនចរាចរតាមដងទន្លេពីរាជធានីភ្នំពេញនិងពីខេត្តបាត់ដំបង និងការស្តារឡើងវិញផ្លូវថ្នល់ភ្ជាប់ជាមួយប្រទេសថៃ ទន្ទឹមនឹងការអភិវឌ្ឍប្រព័ន្ធផ្លូវថ្នល់ក្នុងខេត្តផងដែរ។ គេសង្ឃឹមថា ការប្តេជ្ញាចិត្តនេះនឹងរួមចំណែកដល់ការពន្យារពេលស្នាក់នៅរបស់អ្នកទេសចរ ដោយជំរុញឱ្យអ្នកទេសចរបន្តធ្វើដំណើរកាន់តែជ្រៅនៅក្នុងតំបន់វប្បធម៌ និងកំសាន្តនៅតំបន់ដែលជាទីចាប់អារម្មណ៍របស់ខ្លួនជាច្រើនទៀត។

បញ្ហាប្រឈមមួយនៅក្នុងការអភិវឌ្ឍវិស័យទេសចរណ៍នោះគឺ ការគ្រប់គ្រងលំហូរដ៏លើសលប់នៃអ្នកទេសចរៈ អ្នកទេសចរច្រើនជាង ៣០០,០០០ នាក់ក្នុងឆ្នាំ ២០០៣ និងកើនឡើង ៣០% ក្នុងមួយឆ្នាំ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ ពីភាពចាំបាច់នៃការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយសីលធម៌និងនិរន្តរភាពនៅក្នុងតំបន់សៀមរាបអង្គរ ថាជាឧបករណ៍មួយសម្រាប់ការកាត់បន្ថយភាពក្រីក្រ។ រដ្ឋាភិបាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំពុងកៀរគរសហគមន៍មូលដ្ឋានដែលរស់នៅក្នុងតំបន់ជុំវិញបឹងទន្លេសាប ទន្ទឹមនឹងការលើកកម្ពស់គោលនយោបាយបង្ហាញនូវភាពសម្បូរបែបនៃធនធានវប្បធម៌របស់កម្ពុជា ទាំងរូបីយនិងអរូបីយ ដូច្នេះពួកគេអាចរកប្រាក់ចិញ្ចឹមជីវិតកាន់តែប្រសើរ។

## ១៣.៤. ទេសចរណ៍ជាប៉ូលនៃកំណើន

កំណើនរបស់វិស័យទេសចរណ៍មានផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់សេដ្ឋកិច្ចតាមរយៈការបង្កើតការងារ ការបង្កើតប្រាក់ចំណូល ការបណ្តុះបណ្តាលកម្លាំងការងារ ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ វិស័យទេសចរណ៍បានក្លាយជាប្រភពដ៏សំខាន់នៃកំណើនសេដ្ឋកិច្ច។ ទេសចរណ៍កំពុងនាំមកនូវការកើនឡើងខ្លាំងនៃផលទុនក្នុងស្រុកសរុបរបស់ប្រទេស។ វិស័យទេសចរណ៍នៅឈរលេខរៀងបន្ទាប់ពីការនេសាទ ក្នុងចំណោមអនុវិស័យ ដែលប្រមូលរូបិយវត្ថុបរទេសទៅក្នុងសេដ្ឋកិច្ចជាតិ។ ក្នុងឆ្នាំ ២០០៨ ចំណូលសរុបពីវិស័យទេសចរណ៍កើនទៅដល់ ១,៣ ពាន់លានដុល្លារ។ វត្ថុបំណងសំខាន់គឺការធានាសុវត្ថិភាពនិងទទួលបានភាគលាភពីសក្តានុពលទេសចរណ៍។

### ១៣.៤.១. ការមកដល់នៃអ្នកទេសចរ

ក្នុងឆ្នាំ ២០០៨ ចំនួនអ្នកទេសចរក្នុងស្រុកមាន ៦,៧៣ លាននាក់ ធៀបជាមួយនឹងឆ្នាំ ២០០៤ ចំនួន ៤,២៥ លាននាក់ ឆ្នាំ ២០០៣ មាន ១,៨២ លាននាក់ និងឆ្នាំ ១៩៩៣ មាន ០,២៦ លាននាក់។

ចំនួនអ្នកទេសចរបរទេសមកកម្ពុជាមាននិន្នាការឡើងចុះ អាស្រ័យលើស្ថានភាពក្នុងប្រទេស និងអន្តរជាតិ ប៉ុន្តែចំនួននេះមានការកើនឡើងតាំងពីឆ្នាំ ១៩៩៥។ អ្នកទេសចរអន្តរជាតិកើនដល់ ២,១២ លាននាក់ក្នុងឆ្នាំ ២០០៨ ធៀបនឹង ០,១២ លាននាក់នៅឆ្នាំ ១៩៩៣។ ប្រសិនបើធៀបនឹងឆ្នាំ ២០០០ ចំនួនអ្នកទេសចរកើនច្រើនជាង ៤ ដង។

ឧស្សាហកម្មទេសចរណ៍មួយផ្នែកធំផ្តោតលើទេសចរណ៍វប្បធម៌ ដែលស្មើនឹង ៥៨% នៃចំនួនអ្នកទេសចរបានមកដល់នៅឆ្នាំ ២០០៧ បន្ទាប់មក ២៧% ជាអ្នកទេសចររកស៊ី ៩% ជាអ្នកលេងល្បែង ៥% ជាអ្នកទេសចរមាត់សមុទ្រ និង ២% ជាអ្នកអេកូ-ទេសចរណ៍។ អេកូ-ទេសចរណ៍បានកើនឡើងយ៉ាងឆាប់រហ័ស ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធមិនទាន់ត្រូវបានអភិវឌ្ឍនៅឡើយ។

*រូបភាព ១៣.១. ចំនួនអ្នកទេសចរបានមកដល់និងផលទុនក្នុងស្រុកសរុប*




*ប្រភព៖ក្រសួងទេសចរណ៍*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អ្នកទេសចរភាគច្រើនចូលមកកម្ពុជាតាមផ្លូវគោក ឬ ផ្លូវទឹក ដូចជាមកពីប្រទេសថៃប្រើប្រាស់តាមផ្លូវជាតិលេខ ៥ បន្ទាប់មកពីប្រទេសវៀតណាមតាមផ្លូវជាតិលេខ ១។ ទន្លេមេគង្គគឺជាមធ្យោបាយធ្វើដំណើរដ៏មានប្រជាប្រិយភាពមួយទៀត ដែលអ្នកទេសចរបានប្រើប្រាស់ តាមរយៈផ្លូវជាតិលេខ ៨។

**រូបភាព១៣.២ ក ការមកដល់អ្នកទេសចរបរទេសតាមមធ្យោបាយដឹកជញ្ជូន**




| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|---|
| En bus et bateau | 104,836 | 114,704 | 196,642 | 263,646 | 245,042 | 361,238 | 476,479 | 564,286 | 455,609 | 621,822 |
| En avion | 262,907 | 351,661 | 408,377 | 531,199 | 455,972 | 626,121 | 856,621 | 1,027,064 | 1,030,938 | 1,016,413 |

**រូបភាព១៣.២ ខ ការមកដល់អ្នកទេសចរបរទេសតាមច្រកចូល**




ប្រភព៖ក្រសួងទេសចរណ៍

**រូបភាព១៣.៣ ការមកដល់អ្នកទេសចរបរទេសតាមច្រកព្រំដែន**




| | Route | | | | | | | | En bateau | |
|---|---|---|---|---|---|---|---|---|---|---|
| | No.1 Barvet | No.2 Phnom Penh | No.48 Cham Yeam | No.5 Poipet | No.68 Osmach | No.13 Dong | No.7 Dong Krabr | Drivers | Sihanouk Ville | Mekong Kaam Samor |
| 2003 | 35,837 | 664 | 17,111 | 167,654 | 2,026 | 0 | 3,134 | 0 | 1,330 | 17,238 |
| 2004 | 51,935 | 1,724 | 22,960 | 242,456 | 4,097 | 4,346 | 4,322 | 4,016 | 466 | 24,916 |
| 2005 | 77,620 | 2,475 | 29,688 | 284,865 | 8,979 | 21,386 | 7,753 | 12,252 | 1,813 | 29,848 |

ប្រភព៖ ក្រសួងទេសចរណ៍

អ្នកទេសចរបានប្រើប្រាស់គ្រប់មធ្យោបាយក្នុងការធ្វើដំណើរដូចជា ផ្លូវអាកាស ផ្លូវថ្នល់ និងផ្លូវទឹក។ ភាគរយអ្នកទេសចរធ្វើដំណើរតាមរថយន្តក្រុងធំៗក៏មានការកើនឡើងច្រើនផងដែរ ស្របគ្នាជាមួយនឹងការអភិវឌ្ឍផ្លូវជាតិក្នុងប៉ុន្មានឆ្នាំកន្លងមក។ អ្នកទេសចរជាង ២ ភាគ ៣ បានធ្វើដំណើរតាមផ្លូវអាកាស (នៅភ្នំពេញ និងសៀមរាប) និង ១ ភាគ ៣ ទៀតបានធ្វើដំណើរតាមរថយន្តក្រុង (ពីទីក្រុងហូជីមិញ និងទីក្រុងបាងកក) និងតាមកាណូត។

ដំណើរមកដល់កម្ពុជារបស់អ្នកទេសចរមកពីប្រទេសក្នុងអឺរ៉ុបនិងអាម៉េរិកខាងជើង បានផ្លាស់ប្តូរទៅជាមានការកើនឡើងនៃចំនួនអ្នកទេសចរមកពីទ្វីបអាស៊ី ជាពិសេសកូរ៉េ ជប៉ុន ចិន និងវៀតណាមទៅវិញ ក្នុងទសវត្សរ៍ឆ្នាំ ២០០០។ អ្នកទេសចរកូរ៉េមានចំនួនច្រើនជាងគេ បើបែងចែងតាមសញ្ជាតិ។ ការកើនឡើងយ៉ាងខ្លាំងនៃចំនួនអ្នកទេសចរកូរ៉េក្នុងអំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារការចាប់ផ្តើមជើងហោះហើរ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រង់ពីប្រទេសកូរ៉េ។ ដូច្នេះ វិបត្តិហិរញ្ញវត្ថុសកលពលោកដែលបានប៉ះពាល់ប្រទេសកូរ៉េយ៉ាងខ្លាំងនោះ ក៏បានជះឥទ្ធិពលមកលើឧស្សាហកម្មទេសចរណ៍ក្នុងប្រទេសកម្ពុជាផងដែរ។ បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុពិភពលោកមកមានការផ្លាស់ប្តូរមួយពីអ្នកទេសចរលំដាប់ខ្ពស់ មកជាអ្នកទេសចរលំដាប់ថ្នាក់កណ្តាល និងទាបវិញ ដែលបណ្តាលមកពីការធ្លាក់ចុះក្នុងការចាយវាយរបស់អ្នកទេសចរ។

## ១៣.៤.២. សណ្ឋាគារ និង ភោជនីយដ្ឋាន

រហូតមកដល់ចុងឆ្នាំ ២០០៨ កម្ពុជាមានកន្លែងស្នាក់អាស្រ័យចំនួន ១,៣២៣ កន្លែង បើប្រៀបធៀបនឹង ឆ្នាំ២០០០ កើនឡើងលើសពី ២ ដង ក្នុងនោះ ៣៩៨ ជាសណ្ឋាគារនិង ៩២៥ ជាផ្ទះសំណាក់។ ចំនួនបន្ទប់ក្នុងសណ្ឋាគារសរុប ២០,៦៧៨ បន្ទប់ កើនឡើង ៩៧% និងផ្ទះសំណាក់ ១២,១៨០ បន្ទប់កើនឡើង ២៧% បើប្រៀបធៀបទៅនិងរយៈពេលដូចគ្នាក្នុងឆ្នាំ២០០០។ការកើនឡើងនេះត្រូវបានបែងចែកជា ៣ ទីតាំងសំខាន់ៗនៃគោលដៅអ្នកទេសចរគឺ ភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ។ ភ្នំពេញមានសណ្ឋាគារ១៣៣ ត្រូវជា ៦,៧៨២ បន្ទប់ សៀមរាបមាន ១១២ សណ្ឋាគារត្រូវជា ៨,២៦៣ បន្ទប់ និងខេត្តព្រះសីហនុមាន ៥៦ សណ្ឋាគារត្រូវជា ១,៧៨២ បន្ទប់។ ក្នុងខេត្តផ្សេងៗទៀតមានសណ្ឋាគារ ១០៧ និងផ្ទះសំណាក់ ៣១៩ ដែលមានប្រមាណ ៨,០៨២ បន្ទប់ ដូចជានៅបាត់ដំបង បន្ទាយមានជ័យ កំពត កែប ព្រៃវែង កំពង់ចាម រតនគីរី កោះកុង ក្រចេះ និងខេត្តផ្សេងទៀត។ ជាសរុប ក្នុងទូទាំងប្រទេសមានបន្ទប់ស្នាក់នៅចំនួន ៣២,៨៥៨។

*តារាង១៣.១. កន្លែងស្នាក់នៅនិងចំនួនបន្ទប់ នៅកម្ពុជា*

| ខេត្ត | សណ្ឋាគារ | | ផ្ទះសំណាក់ | |
|---|---|---|---|---|
| | ២០០៨ | | ២០០៨ | |
| | ចំនួន | ចំនួនបន្ទប់ | ចំនួន | ចំនួនបន្ទប់ |
| ភ្នំពេញ | ១៣៣ | ៦៧៨២ | ២៨០ | ៣៦០៥ |
| សៀមរាប | ១១២ | ៨២៦៣ | ២១៦ | ២៧៩៦ |
| សីហនុ | ៥៦ | ១៧៨២ | ១១០ | ១៥៨៨ |
| ក្រចេះ | ៧ | ២៦៩ | ២២ | ២៥៥ |
| កំពត | ២ | ៨៨ | ២៦ | ៣៥៨ |
| ព្រះវិហារ | - | 0 | ១០ | ១២៧ |
| បន្ទាយមានជ័យ | ១៣ | ៥១៧ | ២៨ | ៥២៥ |
| រតនគីរី | ៨ | ២៥១ | ១១ | ៨៦ |
| ឧត្តរមានជ័យ | ៤ | ២១៥ | ១៤ | ១៨០ |
| កណ្តាល | - | 0 | ៣១ | ២៥៦ |
| តាកែវ | - | 0 | ១៣ | ២៣៦ |
| កោះកុង | ៧ | ២០៧ | ១៤ | ២០២ |
| កំពង់ឆ្នាំង | ៥ | ១២២ | ៨ | ៩៩ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | | | |
|---|---|---|---|---|
| បាត់ដំបង | ២២ | ១០៣៥ | ១៨ | ៣៨៥ |
| កំពង់ធំ | ៤ | ១៤៧ | ១០ | ២០៩ |
| ពោធិ៍សាត់ | ៤ | ៩៩ | ១៤ | ១៦៧ |
| កែប | ៦ | ១២២ | ១១ | ១៥០ |
| កំពង់ចាម | ៥ | ២០៨ | ៣០ | ២៤៨ |
| ស្វាយរៀង | ១ | ៦០ | ៩ | ៩៧ |
| ព្រៃវែង | ៨ | ១៧៥ | 2 | ២០ |
| កំពង់ស្ពឺ | - | 0 | ១១ | ៨៨ |
| មណ្ឌលគីរី | ២ | ៨៧ | ១៨ | ២៥៨ |
| ស្ទឹងត្រែង | ៥ | ១៧៤ | ១០ | ១៦០ |
| ប៉ៃលិន | ៤ | ៧៥ | ៩ | ១៤៥ |
| សរុប | ៣៩៨ | ២០៦៧៨ | ៩២៥ | ១២១៨០ |

*ប្រភព៖ ក្រសួងទេសចរណ៍*

រាជធានីភ្នំពេញមានសេវាភោជនីយដ្ឋានល្អជាងគេ បន្ទាប់មកខេត្តសៀមរាប និងខេត្តសៀមរាប។ ក្នុងឆ្នាំ ២០០៨ ភោជនីយដ្ឋានសរុប ៩៣៤ កន្លែង ក្នុងនោះ ២៨៤ នៅរាជធានីភ្នំពេញ ១១៣ នៅសៀមរាប និង ៧៨ នៅខេត្តព្រះសីហនុ។ ម្ហូបអាហារសម្បូរបែបអាចរកបាននៅតាមភោជនីយដ្ឋាននានាដូចជា ម្ហូបខ្មែរ បារាំង ចិន ជប៉ុន កូរ៉េ ឥណ្ឌា និងថៃ ។ល។

*រូបភាព១៣.៤. ភាគរយនៃសណ្ឋាគារនិងភោជនីយដ្ឋានក្នុងផលទុនក្នុងស្រុកសរុប*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ក្នុងកំឡុងទសវត្សរ៍កន្លងទៅ អនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋានបានកើនឡើងជាមធ្យមប្រចាំឆ្នាំ ១៥%។ ទោះជាយ៉ាងណា អនុវិស័យនេះងាយទទួលរងគ្រោះពីផលប៉ះទង្គិចខាងក្រៅ ដូចជាការធ្លាក់ចុះយ៉ាងគំហុកអំឡុងពេលវិបត្តិហិរញ្ញវត្ថុអាស៊ី (១៩៩៧-៩៨) ការរាតត្បាតជំងឺ SARS (២០០៣) ចលាចលនយោបាយក្នុងប្រទេសថៃ និងវិបត្តិហិរញ្ញវត្ថុពិភពលោក (២០០៨-២០០៩)។ ជារួម ចំណែកនៃអនុវិស័យសណ្ឋាគារ និង ភោជនីយដ្ឋាននៅក្នុងផលទុនក្នុងស្រុកសរុបបានកើនពី ២,៣% ក្នុងឆ្នាំ ១៩៩៣ ដល់ ៤,៥% ក្នុងឆ្នាំ២០០៨។

## ១៣.៤.៣. ការងារ

*តារាង១៣.២. ការងារទាក់ទងនឹងវិស័យទេសចរណ៍*

| *វិស័យ* | *ការងារដោយផ្ទាល់* | *%* |
| --- | --- | --- |
| ការស្នាក់អាស្រ័យ | ១៦.១១៧ | ២៩% |
| ភោជនីយដ្ឋាន | ៨.២៨៧ | ១៥% |
| ហាងទំនិញ | ៤.២១២ | ៨% |
| ដឹកជញ្ជូន | ១០.៤១៧ | ១៩% |
| មគ្គុទេសទេសចរណ៍ | ៥.២៧៤ | ១០% |
| បុគ្គលិកអាកាសយានដ្ឋាន | ៥.២៧៤ | ១០% |
| ភ្នាក់ងារទេសចរ | ២.៦៦០ | ៥% |
| មន្ត្រីរាជការទាក់ទងនឹងទេសចរណ៍ | ៤.៧៦៣ | ៩% |
| ផ្សេងៗ | ១.០០០ | ២% |
| សរុប | ៥៤.៩៦៥ | ១០០% |

*ប្រភព៖ កម្មវិធីអភិវឌ្ឍវិស័យឯកជនក្នុងមេគ្គង MPDF/IFC (2007)*

វិស័យទេសចរណ៍បានបង្កើតទាំងការងារដោយផ្ទាល់និងដោយប្រយោលប្រមាណ ៥៦៦,៨៤៤ ស្មើនឹង ៨,៣% នៃការងារសរុបក្នុងឆ្នាំ ២០០៤ និងត្រូវបានរំពឹងថាផ្តល់ការងារឱ្យមនុស្សចំនួន ១,១០៨,០០០ នាក់ ឬ ស្មើនឹង ១៥,៨% ក្នុងឆ្នាំ ២០០៧ ទាំងសកម្មភាពដោយផ្ទាល់និងដោយប្រយោល (WTTC, 2007)។ ការងារដោយផ្ទាល់គឺការងារទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងការស្នាក់នៅ អាហារនិងភេសជ្ជៈ ហាងទំនិញ ការដឹកជញ្ជូន មគ្គុទេសក៍ បុគ្គលិកអាកាសយានដ្ឋាន ភ្នាក់ងារទេសចរណ៍ និងមន្ត្រីរាជការមួយចំនួន។

យោងតាមការស្ទង់មតិរបស់ MPDF/IFC សណ្ឋាគារត្រូវបានចាត់ថ្នាក់ទី ១ ក្នុងការបង្កើតការងារដោយស្រូបយក ២៩% នៃកម្លាំងការងារក្នុងឧស្សាហកម្មទេសចរណ៍ បន្ទាប់មកការដឹកជញ្ជូន (១៩%) អាហារនិងភេសជ្ជៈ (១៥%) បុគ្គលិកអាកាសយានដ្ឋាន (១០%) ពាណិជ្ជកម្ម (៨%) ភ្នាក់ងារទេសចរណ៍ (៥%) និងមគ្គុទេសក៍ (៤%)។ ការស្ទង់មតិរបស់វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានរាយការណ៍ថាការងារសាងសង់បានបង្កើតការងារដោយប្រយោលធំបំផុត ក្នុងវិស័យទេសចរណ៍គឺស្មើនឹង ៣៨% នៃការងារទេសចរណ៍ដោយផ្ទាល់និងដោយប្រយោល។

### ១៣.៤.៤. ការវិនិយោគក្នុងវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន

ការវិនិយោគក្នុងវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន គឺជាកត្តាជំរុញដ៏ចម្បងនៅពីក្រោយការអភិវឌ្ឍគោលដៅទេសចរណ៍សំខាន់ៗរបស់កម្ពុជា ជាពិសេសក្នុងខេត្តសៀមរាប។ ការវិនិយោគក្នុងឧស្សាហកម្មសណ្ឋាគារ និងភោជនីយដ្ឋានបានកើនឡើងពី ១៣ លានដុល្លារក្នុងឆ្នាំ ១៩៩៣ ដល់ ១២០ លានដុល្លារក្នុងឆ្នាំ ២០០៨ ជាមធ្យមកើនឡើង ៥៦% ប្រចាំឆ្នាំ ជាមួយនិងការវិនិយោគសរុប ៧២០ លានដុល្លារ។ សមាមាត្រមួយភាគធំនៃការវិនិយោគនេះត្រូវបានធ្វើឡើងដោយវិនិយោគិនកម្ពុជា។

*រូបភាព១៣.៥. ការវិនិយោគក្នុងវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន (គិតជាលានដុល្លារសហរដ្ឋអាមេរិក)*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

### ១៣.៤.៥. ចំណាយលើវិស័យទេសចរណ៍

យោងតាមព័ត៌មានពីក្រសួងទេសចរណ៍ អ្នកទេសចរបរទេសម្នាក់ចំណាយជាមធ្យម ៩៥ ដុល្លារនៅកម្ពុជាក្នុងមួយថ្ងៃ។ សម្រាប់រយៈពេល ៦,៥ ថ្ងៃ ជាមធ្យមអ្នកទេសចរម្នាក់ចំណាយ ៦១៧,៥ដុល្លារ ក្នុងដំណើរកំសាន្តម្តងនៅកម្ពុជា។ ដោយធ្វើផលគុណជាមួយអ្នកទេសចរ ២,១៥ លាននាក់ មកទស្សនាកម្ពុជាក្នុងឆ្នាំ ២០០៨ នោះ ការរួមចំណែកនៃឧស្សាហកម្មទេសចរណ៍ដល់សេដ្ឋកិច្ចកម្ពុជាគឺ ១,៣ រយកោដដុល្លារ ឬស្មើនឹង១២,៨% នៃផលទុនក្នុងស្រុកសរុប។

## ១៣.៥. គោលនយោបាយវិស័យទេសចរណ៍

យុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍវិស័យទេសចរណ៍ថ្នាក់ជាតិ ឆ្នាំ ២០០១-២០០៥ ដែលបានរៀបចំក្នុងឆ្នាំ ២០០១ មានគោលបំណងពង្រឹងនូវអ្វីដែលបានអនុវត្តដោយជោគជ័យកន្លងមក ពោលគឺឱ្យជនជាតិកម្ពុជាពាក់ព័ន្ធក្នុងប្រតិបត្តិការរបស់វិស័យនេះ។ ចំណុចសំខាន់ៗរបស់ផែនការនេះរួមមាន ការអនុម័តនៃក្រមសីលធម៌អ្នកទេសចរ ការដាក់បង្ហាញតំបន់ថ្មីៗ ការអភិវឌ្ឍនិងពិពិធកម្មផលិតផលនិងទីផ្សារ រួមទាំងការលើកកម្ពស់វិស័យទេសចរណ៍កម្រិតខ្ពស់និងច្បាប់ទម្លាប់។ យុទ្ធសាស្ត្រនេះគួបផ្សំការលើកកម្ពស់ និងគាំទ្រវមណីយដ្ឋានកំសាន្តជាមួយនឹងការអភិវឌ្ឍពាណិជ្ជកម្មដែលទាក់ទងទៅនឹងសកម្មភាពកំសាន្ត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីអភិវឌ្ឍសហគ្រិន ភាគីពាក់ព័ន្ធ និងមន្ត្រីវប្បធម៌នៅក្នុងវិស័យទេសចរណ៍ រដ្ឋាភិបាលនឹងបង្កើតបរិយាកាសសារពើពន្ធនិងនីត្យានុកូលអនុគ្រោះមួយសម្រាប់ឧស្សាហកម្មទេសចរណ៍ ហើយនិងផ្ដល់ឋានៈអាជីពមួយឱ្យឧស្សាហកម្មនេះ។ កត្តានេះនឹងអនុញ្ញាតឱ្យមានការបង្កើតសមាគមឧស្សាហកម្មមួយចំនួនដែលនឹងត្រួតពិនិត្យដោយក្រសួងទេសចរណ៍។ សមត្ថភាពស្ថាប័នរបស់ក្រសួងទេសចរណ៍ក្នុងការដឹកនាំការអភិវឌ្ឍវិស័យទេសចរណ៍នឹងត្រូវបានពង្រឹង ហើយការគាំទ្រត្រូវបានផ្ដល់សម្រាប់ស្ថាប័នវប្បធម៌ ដើម្បីធ្វើសកម្មភាពវិជ្ជាជីវៈរបស់ខ្លួន។

វិស័យទេសចរណ៍ បានរួមចំណែកជាច្រើនដល់ការកាត់បន្ថយភាពក្រីក្រ ក្នុងអំឡុងឆ្នាំថ្មីៗនេះ។ រដ្ឋាភិបាលទទួលស្គាល់ពីសក្ដានុពលរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងរឹតតែជំរុញខ្លាំងឡើងនាពេលអនាគត ប្រសិនបើអាជ្ញាធរមូលដ្ឋានធ្វើការទន្ទឹមគ្នា ដើម្បីលើកកម្ពស់ឧស្សាហកម្មមួយនេះ។

គោលនយោបាយវិស័យទេសចរណ៍ត្រូវបានបង្កើតឡើង ឈរលើគោលការណ៍ ដូចខាងក្រោម៖

- **ការចូលរួមរបស់ក្នុងសង្គមជាតិ៖** ការបន្សីការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាពទៅក្នុងកម្មវិធីកាត់បន្ថយភាពក្រីក្រ និងផ្ទុយមកវិញ ការបញ្ចូលនូវវិធានការនានាក្នុងកាត់បន្ថយភាពក្រីក្រ ទៅក្នុងយុទ្ធសាស្ត្ររួមសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព។
- **សមាហរណកម្ម៖** អនុម័តអភិក្រមមួយដែលនឹងស្របគ្នាជាមួយវិស័យផ្សេងទៀត និងជៀសវាងការពឹងអាស្រ័យលើសលុបលើធនធានទេសចរណ៍សម្រាប់វិស័យពាក់ព័ន្ធទាំងអស់។
- **រចាយប្រកបដោយសមធម៌៖** សម្របយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ជាមួយនឹងរបាយនៃទ្រព្យសម្បត្តិនិងសេវាកម្មប្រកបដោយសមធម៌ ។
- **ការផ្តួចផ្តើមថ្នាក់មូលដ្ឋាន៖** ផ្តោតលើការផ្តួចផ្តើមនៅកម្រិតមូលដ្ឋានឬលើគោលដៅស្ថិតក្រោមគោលនយោបាយគាំទ្ររបស់ថ្នាក់ជាតិ។
- **រក្សាផលប្រយោជន៍ក្នុងប្រទេស៖** ដាក់កម្រិតលើលំហូរចូលក្នុងសេដ្ឋកិច្ចមូលដ្ឋាននិងបង្កើតទំនាក់ទំនងនៅខាងក្នុង ដោយផ្តោតអារម្មណ៍ទៅលើខ្សែសង្វាក់នៃការផ្គត់ផ្គង់ដែលគាំទ្រដល់វិស័យទេសចរណ៍។
- **ការប្តេជ្ញាចិត្ត៖** បង្កើតផែនការសកម្មភាពរយៈពេលវែង និងការបែងចែកធនធានសម្រាប់វិស័យទេសចរណ៍។
- **ការត្រួតពិនិត្យ៖** អភិវឌ្ឍសូចនាករនិងប្រព័ន្ធសមញ្ញ ដើម្បីវាយតម្លៃផលប៉ះពាល់នៃវិស័យទេសចរណ៍ទៅលើភាពក្រីក្រ។ល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ផែនទី១៣.១. ផែនទីទេសចរណ៍នៅកម្ពុជា*




*ប្រភព៖ ក្រសួងទេសចរណ៍*

កម្ពុជានៅមិនទាន់បានកេងយកផលពីសក្តានុពលវិស័យទេសចរណ៍នៃធនធានតំបន់ឆ្នេររបស់ខ្លួននៅឡើយ។ ការផ្តួចផ្តើមខាងក្រោមនេះនឹងត្រូវបានអនុវត្តដើម្បីបានសក្តានុពលនេះតាមមធ្យោបាយជាក់ស្តែងមួយ៖

- គម្រោងសាកល្បងដ៏ជោគជ័យនានានឹងត្រូវនាំចូលទៅក្នុងយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍវិស័យអេកូទេសចរណ៍។
- ការជះឥទ្ធិពលនៃវិស័យទេសចរណ៍តាមឆ្នេរសមុទ្រលើបរិស្ថាននឹងត្រូវបានកាត់បន្ថយតាមរយៈការពង្រឹងភាពជាដៃគូឯកជនសាធារណៈ។

គម្រោងសាកល្បងទាំងឡាយនឹងភ្ជាប់ប្រព័ន្ធគ្រប់គ្រងបរិស្ថានទៅក្នុងកន្លែងទេសចរណ៍តាមឆ្នេរអេកូទេសចរណ៍ក្នុងតំបន់ឆ្នេរនិងការគ្រប់គ្រងផ្កាថ្ម។ ការជំរុញជារួមនោះគឺការអភិរក្សប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរដោយការពង្រឹងធនធានស្ថាប័នរបស់រដ្ឋាភិបាលនិងរដ្ឋបាលតំបន់ដែលលើកកម្ពស់ភាពជាដៃគូឯកជនសាធារណៈក៏ដូចជាកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍសេដ្ឋកិច្ចរួមនៃតំបន់ឆ្នេរ។

រាជរដ្ឋាភិបាលប្តេជ្ញា (១) អនុវត្តគោលនយោបាយមុះមុតមួយសម្រាប់ការអភិវឌ្ឍតំបន់អ្នកទេសចរនិងឱកាសចូលទៅដល់តាមផ្លូវធ្វើដំណើររបស់គេ (២) លើកទឹកចិត្តការចូលរួមពីវិស័យឯកជនក្នុងប្រតិបត្តិការនិងការវិនិយោគវិស័យទេសចរណ៍តាមរយៈការបង្វឹកតម្រង់គោលដៅ (ការផ្តល់ហិរញ្ញវត្ថុការយកពន្ធអចលនទ្រព្យ។ល។) (៣) ផ្តួចផ្តើមគោលនយោបាយមួយនៃការដឹកជញ្ជូនតាមអាកាសដែលនាំទៅរកការអភិវឌ្ឍវិស័យនេះ (ឧ. បើកចំហជើងមេឃ) (៤) ធ្វើការលើកកម្ពស់ដ៏ខ្លាំងក្លាមួយនៃគោលដៅទេសចរណ៍ក្នុងការនាំទៅរកទីផ្សារទេសចរណ៍ចូលក្នុងប្រទេស(៥) បើកយុទ្ធនាការមួយដើម្បីជម្នះអសន្តិសុខនិងធានាបរិយាកាសសុវត្ថិភាពនិងល្អប្រសើរមួយសម្រាប់អ្នកទេសចរនិង (៦) ភ្ជាប់វិស័យទេសចរណ៍ទៅនិងការអភិវឌ្ឍកសិកម្ម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១៤
# ទូរគមនាគមន៍

**បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍**(ICT) សំដៅទៅលើបច្ចេកវិទ្យានានាទាក់ទងនឹងព័ត៌មាន និងទៅលើឧបករណ៍និងសេវាកម្មទូរគមនាគមន៍។ វិស័យបច្ចេកវិទ្យាទាំងពីរនេះត្រូវបានគេញែកដាច់ពីគ្នាយ៉ាងច្បាស់ ចាប់តាំងពីមានវត្តមាននៅក្នុងប្រទេសកម្ពុជា និងបានត្រូវបានគេប្រើប្រាស់រួមគ្នា ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។

ទិដ្ឋភាពផ្នែកទូរគមនាគមន៍នៅកម្ពុជាក្នុងទសវត្សរ៍ចុងក្រោយនេះ មានការផ្លាស់ប្តូររចនាសម្ព័ន្ធជាច្រើន ដែលគេហៅថាសម័យទីផ្សារសេរី និងការមកដល់នៃធាតុចូលថ្មីៗ។ ការបន្តអភិវឌ្ឍបណ្តាញ និងសេវាកម្មទូរគមនាគមន៍មានសារៈសំខាន់ណាស់ សម្រាប់សេដ្ឋកិច្ចរបស់កម្ពុជា។ នៅកម្រិតមីក្រូសេដ្ឋកិច្ច ទូរគមនាគមន៍បានក្លាយជាកត្តាអភិវឌ្ឍពេញលេញមួយនៃផលិតកម្ម។ នៅកម្រិតម៉ាក្រូសេដ្ឋកិច្ចវិញ ទូរគម-នាគមន៍និងកុំព្យូទ័របានក្លាយជាក្បាលម៉ាស៊ីនដ៏សំខាន់មួយនៃកំណើនសេដ្ឋកិច្ច។ តម្លៃបន្ថែមរបស់វិស័យទូរគមនាគមន៍មានច្រើនជាង ៤ ដង ដោយបានកើនពី ១៥,៦ លានដុល្លារឬស្មើនឹង ០,៥៦% នៃផលិតផលសរុបក្នុងស្រុក ក្នុងឆ្នាំ ២០០៤ ដល់ ៦៥,៥ លានដុល្លារ ឬស្មើនឹង០,៩% នៃផលិតផលសរុបក្នុងស្រុកក្នុងឆ្នាំ ២០០៦។ ការផ្លាស់ប្តូរនេះបានបង្កើតបញ្ហាជាហូរហែ សម្រាប់ការគ្រប់គ្រងកម្រិតគោលនយោបាយ។ ការទម្លាក់ថ្លៃសេវា និងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ (ដូចជា ADSL, VOIP) គឺជាបញ្ហា ២ យ៉ាងជាឧទាហរណ៍ស្រាប់។

ឆ្លើយតបទៅនឹងការអភិវឌ្ឍបច្ចេកវិទ្យា ជាពិសេសការរួមបញ្ចូលគ្នារវាងទូរគមនាគមន៍បច្ចេកវិទ្យាព័ត៌មាន និងការផ្សព្វផ្សាយ និងការទទួលស្គាល់សក្តានុពលអភិវឌ្ឍនៃឧស្សាហកម្មទូរគមនាគមន៍ ជាពិសេសអ៊ិនធឺណិតនោះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំច្បាប់ស្តីពីគមនាគមន៍ ដែលបានលើកឡើងនូវកម្មវត្ថុដូចខាងក្រោម៖

- អភិវឌ្ឍគោលនយោបាយផ្តោតលើការអភិវឌ្ឍវិស័យគមនាគមន៍ និងនិយតកម្ម និង
- បង្កើតក្របខណ្ឌនិយតកម្មទូទៅសម្រាប់បណ្តាញ និងសេវាគមនាគមន៍អេឡិចត្រូនិក។

## ១៤.១. ច្បាប់និងក្របខ័ណ្ឌនិយតកម្ម

មកទល់ដើមទសវត្សរ៍ឆ្នាំ ១៩៩០ ឧស្សាហកម្មទូរគមនាគមន៍ត្រូវបានមើលឃើញថាជា កិច្ចការផ្តាច់មុខរបស់រដ្ឋ។ ការគ្រប់គ្រងទូរគមនាគមន៍ ដែលមានន័យថាជា បណ្តាញទូរស័ព្ទរបស់ជាតិ រួមបញ្ចូលទាំងបណ្តាញទូរស័ព្ទក្នុងស្រុក និងតាមព្រំដែន ការបញ្ជូនទិន្នន័យនិងសេវាប្រៃសណីយ៍នោះ ត្រូវបានចាត់ចែងទាំងស្រុងដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (MPTC) ដែលបង្កើតឡើងក្នុងឆ្នាំ១៩៩៣។

សេរីភាវូបនីយកម្មវិស័យទូរគមនាគមន៍ ដែលកើតមានតាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មានបំណងបើកទូលាយទីផ្សារដល់វិស័យឯកជន ការប្រកួតប្រជែង និងទាក់ទាញការវិនិយោគក្នុងវិស័យនេះ។ ក្នុងឆ្នាំ១៩៩២ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងអាជីវកម្មចម្រុះ (joint venture) មួយចំនួនជាមួយក្រុមហ៊ុនទូរគមនាគមន៍បរទេសនានា ដោយផ្តល់ឱ្យពួកគេនូវសម្បទានប្រតិបត្តិការ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទទួលបន្ទុកខាងវិស័យប្រៃសណីយ៍ និងគមនាគមន៍ជារួម និង ជាទូទៅទទួលខុសត្រូវក្នុងការបង្កើត និងការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍នៅកម្ពុជា។ ក្រសួងក៏មានមុខងារជានិយតកររបស់វិស័យនេះរហូតទាល់តែអាជ្ញាធរនិយតកម្មជាតិស្វ័យតមួយត្រូវបានបង្កើតឡើង។

ការអភិវឌ្ឍបច្ចេកវិទ្យា និងគំនិតថ្មីៗក្នុងសេវាកម្មទូរគមនាគមន៍ បានកើនឡើងយ៉ាងឆាប់រហ័សតម្រូវឱ្យមានការឆ្លើយតបប្រកបដោយនិយ័តភាពមួយ។ នាពេលបច្ចុប្បន្ន កម្ពុជាកំពុងដំណើរការរៀបចំនិយ័តកម្មនិងច្បាប់នានា ដើម្បីគ្រប់គ្រងវិស័យគមនាគមន៍នេះ។ ក្របខណ្ឌនិយតកម្មថ្មីនេះនឹងផ្តោតលើការគ្រប់គ្រង ការប្រកួតប្រជែងក្នុងការរៀបចំបណ្តាញ និងទីផ្សារសេវាកម្មទូរគមនាគមន៍អេឡិចត្រូនិច ដែនប្រេកង់វិទ្យុទាក់ទង និងបណ្តុំខ្សែទូរស័ព្ទអប្បបរមា ដែលត្រូវជួលស្តង់ដារពិសេស និងបទដ្ឋានដែលពាក់ព័ន្ធ។

ក្នុងច្បាប់ស្តីពីគមនាគមន៍នេះ "**បណ្តាញគមនាគមន៍អេឡិចត្រូនិច**" សំដៅលើ (ក) ប្រព័ន្ធបញ្ជូន ដែលអនុញ្ញាតឱ្យមានការបញ្ជូនសញ្ញាផ្សេងៗ តាមមធ្យោបាយថាមពលអេឡិចត្រូនិក ម៉ាញេទិក ឬអេឡិចត្រូម៉ាញេទិក និង (ខ) រួមបញ្ចូល (១) ឧបករណ៍ដែលត្រូវបានប្រើប្រាស់ក្នុងប្រព័ន្ធនេះ និង (២) ឧបករណ៍ដែលប្រើសម្រាប់បញ្ជូនសញ្ញានានា។ "**សេវាកម្មគមនាគមន៍អេឡិចត្រូនិក**" មានន័យថាជា សេវាកម្មដែលបញ្ជូនសញ្ញានៅលើបណ្តាញគមនាគមន៍អេឡិចត្រូនិក។ សេវាកម្មគមនាគមន៍អេឡិចត្រូនិក មានដូចជា ប្រព័ន្ធទូរស័ព្ទ ការផ្ញើសារ តេឡេក្រាម ទូរសារ សំបុត្រអេឡិចត្រូនិក សារជាសំឡេង អ៊ិនធឺណែត វីដេអូ ការបញ្ជូនទិន្នន័យ ការរក្សាទុកទិន្នន័យ ពិធីសារនិងការ បម្លែងកូដ ដំណើរការទិន្នន័យ វិទ្យុ ការបញ្ជូន និងការកំណត់រលកកម្ពស់ប្រេកង់។

តាមគោលការណ៍នៃការបែងចែកមុខងាររបស់និយតកម្ម គោលនយោបាយ និងប្រតិបត្តិការនៃគមនាគមន៍អេឡិចត្រូនិកនោះ ការបែងចែកការងារត្រូវបានកំណត់ឡើង រវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អាជ្ញាធរគមនាគមន៍កម្ពុជា និងប្រតិបត្តិករបណ្តាញ និងសេវាកម្មគមនាគមន៍។

## ១៤.១.១. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទទួលបន្ទុកខាងការអភិឌ្ឍ និងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងផែនការនានា ដែលពាក់ព័ន្ធនឹងគមនាគមន៍អេឡិចត្រូនិក។ ក្រសួងមានការទទួលខុសត្រូវដូចខាងក្រោម៖

- រៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍវិស័យគមនាគមន៍
- បង្កើតគោលនយោបាយ និងផែនការសកម្មភាពដើម្បីធ្វើសមាហរណកម្មបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ចូលទៅក្នុងក្របខណ្ឌនិយ័តកម្មមួយ
- បង្កើតគោលនយោបាយនិយតកម្មស្តីពីសេវាកម្មបណ្តាញនិងគមនាគមន៍
- រៀបចំបញ្ញប់សេចក្តីណែនាំផ្លូវច្បាប់មួយ ទាក់ទងទៅនឹងការប្រកួតប្រជែង ក្នុងការផ្តល់សេវាកម្មគមនាគមន៍
- អនុវត្តគោលនយោបាយគ្រប់គ្រងលើការផ្តល់អាជ្ញាប័ណ្ណ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅពេលបច្ចុប្បន្ន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក៏កំពុងគ្រប់គ្រងការងារសម្បទាន តាមរយៈប្រព័ន្ធនៃការចេញអាជ្ញាប័ណ្ណ ដើម្បីអនុញ្ញាតឱ្យមានការឈានចូលដោយសេរីទៅក្នុងទីផ្សារ និងបង្កើតការប្រកួតប្រជែង។ ក្រសួងក៏កំពុងគ្រប់គ្រងជាបណ្តោះអាសន្នផងដែរ នូវប្រេកង់អេឡិចត្រូនិកនានា រួមមានប្រេកង់វិទ្យុ និងដែនអេឡិចត្រូនិករបស់វិទ្យុ ដោយសារពួកវាជាធនធានរបស់ជាតិ។ តួនាទីនេះនឹងត្រូវប្រគល់ជូនអាជ្ញាធរនិយ័តកម្មនៅពេលណាដែលវាត្រូវបានបង្កើត។

### ១៤.១.២. អាជ្ញាធរគមនាគមន៍កម្ពុជា

**អាជ្ញាធរគមនាគមន៍កម្ពុជា** (CCA) គឺជាអាជ្ញាធរនិយ័តកម្មជាតិ ដែលធានានិយតកម្មនៃសេវាកម្មគមនាគមន៍ ការស្ថាបនា និងប្រតិបត្តិការរបស់បណ្តាញគមនាគមន៍។ ជាគោលការណ៍អាជ្ញាធរ គមនាគមន៍កម្ពុជាត្រូវតែមានលក្ខណៈដាច់ពីគេ និងដំណើរការដោយឯករាជ្យពីស្ថាប័នដទៃទៀត ក្នុងការផ្តល់សេវាកម្មបណ្តាញ ឧបករណ៍ និងសេវាកម្មគមនាគមន៍អេឡិចត្រូនិក។ អាជ្ញាធរគមនាគមន៍កម្ពុជាត្រូវតែអនុវត្តអំណាចរបស់ខ្លួន ប្រកបដោយតម្លាភាព និងមិនលម្អៀង។

សហគ្រាសទាំងឡាយដែលផ្តល់សេវាកម្មបណ្តាញ និងគមនាគមន៍អេឡិចត្រូនិកត្រូវតែផ្តល់ព័ត៌មានទាំងអស់ រួមទាំងព័ត៌មានហិរញ្ញវត្ថុ ទៅឱ្យអាជ្ញាធរគមនាគមន៍កម្ពុជា ដើម្បីធានាបាននូវការគោរពតាមបញ្ញត្តិរបស់ច្បាប់ស្តីពីគមនាគមន៍។

ក្នុងនាមជានិយតករមួយ អាជ្ញាធរគមនាគមន៍កម្ពុជាទទួលខុសត្រូវលើការងារដូចខាងក្រោម៖

- លើកទឹកចិត្តការវិនិយោគប្រកបដោយប្រសិទ្ធភាព ក្នុងសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍
- ធានាថាការប្រកួតប្រជែងមានភាពយុត្តិធម៌ និងទីផ្សារដំណើរការដោយប្រសិទ្ធភាព
- ធានាបាននូវការការពារដល់អតិថិជនរបស់សេវាកម្មគមនាគមន៍
- ធានាបានភាពស៊ីសង្វាក់គ្នា ក្នុងការអនុវត្តនិយតកម្មនានាក្នុងវិស័យគមនាគមន៍៖

ក) ការរៀបចំនិងការអនុវត្តនៃក្របខណ្ឌនិយតកម្ម សម្រាប់ការតភ្ជាប់គ្នាទៅវិញទៅមកនិងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ

ខ) នីតិវិធីនិងលក្ខខណ្ឌទាក់ទងទៅនឹងការកំណត់ថ្លៃសេវាគមនាគមន៍

គ) ការរៀបចំបទដ្ឋាននានាសម្រាប់វិស័យទូរគមនាគមន៍

ឃ) ការគ្រប់គ្រងការផ្តល់ធនធានរបស់ជាតិចំពោះការដាក់លេខ ក៏ដូចជាការគ្រប់គ្រងផែនការជាតិសម្រាប់ការកំណត់លេខ និងការដាក់អាសយដ្ឋានអេឡិចត្រូនិក

ង) ការគ្រប់គ្រងប្រេកង់វិទ្យុ សម្រាប់អ្នកប្រើប្រាស់សេវាកម្មគមនាគមន៍អេឡិចត្រូនិក

ច) ការដោះស្រាយជម្លោះអាជីវកម្មនានា ដែលផ្តល់សេវាបណ្តាញ ឬ សេវាកម្មគមនាគមន៍អេឡិចត្រូនិក និងរវាងអាជីវកម្មនិងអ្នកប្រើប្រាស់

- ផ្តល់អាជ្ញាបណ្ណសម្រាប់ការផ្តល់នូវបណ្តាញនិងសេវាកម្មគមនាគមន៍។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១៤.២. លក្ខណៈពិសេសសំខាន់ៗនៃការអភិវឌ្ឍទីផ្សារ

*រូបភាព១៤.១. វិស័យទូរគមនាគមន៍នៅកម្ពុជា*




*ប្រភព៖ ទូរគមនាគមន៍កម្ពុជា*

វិស័យទូរគមនាគមន៍ធ្វើការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស អាស្រ័យនឹងការអនុវត្តនៅក្នុងទីផ្សារនិងបច្ចេកវិទ្យា។ ការប្រកួតប្រជែងបានជំរុញភាគីពាក់ព័ន្ធ ឱ្យវិនិយោគខាងបច្ចេកវិទ្យាថ្មីៗ ដើម្បីផ្តល់សេវាកម្មកាន់តែប្រសើរឡើង ដោយឈរលើការច្របាច់បញ្ចូលគ្នានៃបណ្តាញដែលមានល្បឿនលឿន ឧបករណ៍សម្លេង-រូបភាព និងឧបករណ៍អេឡិចត្រូនិកនានា ដូច្នេះអ្នកប្រើប្រាស់អាចទទួលបានការបញ្ជូនទិន្នន័យបានលឿន និងមានគុណភាពកាន់តែប្រសើរ។

ទីផ្សារទូរគមនាគមន៍នៅកម្ពុជាត្រូវបានកាន់កាប់ភាគច្រើនដោយក្រុមហ៊ុន CamGSM (Mobitel) ដែលស្មើនឹង ៦៦% នៃទីផ្សារ បន្ទាប់មកក្រុមហ៊ុន Camshin ១២% ក្រុមហ៊ុន Telekom Malaysia ១០% ក្រុមហ៊ុន Telecom Cambodia (TC) ១០% ក្រុមហ៊ុន Camintel ១% ក្រុមហ៊ុន Starcell ១% និងក្រុមហ៊ុន CADCOMMS(QB) ១%។

វិស័យទូរស័ព្ទចល័តគឺជា សមាសធាតុលេចធ្លោមួយនៃឧស្សាហកម្មទូរគមនាគមន៍ ដែលស្មើនឹង ៩៧% នៃចំនួនអ្នកជាវសេវាកម្មទូរស័ព្ទនៅកម្ពុជា។ ទូរស័ព្ទអចល័តមានតែ ៣% ប៉ុណ្ណោះក្នុងទីផ្សារ។

*រូបភាព១៤.២. បរិមាណចំណូលរបស់ក្រុមហ៊ុន Telecom*




*ប្រភព៖ទូរគមនាគមន៍កម្ពុជា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បរិមាណប្រាក់ចំណូលពីទីផ្សារទូរគមនាគមន៍នៅកម្ពុជាស្មើនឹង ៤២៩ លានដុល្លារក្នុងឆ្នាំ ២០០៨។ កំណើនប្រាក់ចំណូលរក្សាបានភាពរឹងមាំនៅកម្រិតខ្ពស់មួយគឺជាមធ្យម ៣១% ក្នុងមួយឆ្នាំ អស់រយៈពេល ៦ ឆ្នាំកន្លងទៅ។ ទូរស័ព្ទជាសំឡេងតាមអ៊ិនធឺណែត (VoIP) គឺជាកត្តាគំរាមគំហែងបន្ថែមមួយទៀត ដល់ចំណែកទីផ្សាររបស់អ្នកផ្តល់សេវាទូរស័ព្ទ ដែលធ្លាប់បានដំណើរការយ៉ាងល្អកន្លងមក។ នាថ្ងៃអនាគត តួលេខប្រាក់ចំណូលសម្រាប់សេវាកម្មគមនាគមន៍ តាមរយៈអ៊ិនធឺណិតត្រូវបានរំពឹងថានឹងកើនឡើងយ៉ាងខ្លាំង ដោយសារការជ្រៀតចូលក្នុងទីផ្សារពីសំណាក់អ្នកផ្តល់សេវាកម្ម។

*តារាង១៤.១. បរិមាណចំណូលរបស់ក្រុមហ៊ុន Telecom*

| ក្រុមហ៊ុន | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ |
|---|---|---|---|---|---|
| Telecom Cambodia | ១៩ ១៩២ ១១៦ | ១៨ ២៧៧ ៥៤៩ | ១៣ ៦៦៤ ៤៤០ | ១៦ ៥៥៧ ៣៩៣ | ២៥ ២២៩ ៥៩០ |
| Cam GSM | ៥២ ០៧៦ ៧១០ | ៧០ ៥០០ ៤២៤ | ៩៧ ៦៣៤ ៧៤៦ | ១២៦ ២០៩៩២៤ | ១៦៣ ៧១៥ ១៨៩ |
| Camshin | ១៥ ៩៦៨ ៦៧២ | ១ ៨៤០ ០៦១ | ២០ ៥០៧ ៧៩៨ | ២៩ ១១៥ ៨២៥ | ៣៩ ០៩៨ ០៣៥ |
| Telecom Malaysia | ១០ ៣៤១ ៣១១ | ១១ ៣៦៨ ៩៩១ | ១៤ ៥៦៣ ៩១០ | ២១ ៩៨៣ ០២២ | ៣០ ៩៩៧ ៥៣៩ |
| Camintel | ៣ ១៦១ ៤៧៦ | ៣ ០២៥ ៣២៦ | ៣ ០៧៧ ៨៦៤ | ៣ ៤៣៤ ៧២៥ | ៣ ៧៥២ ៥៩៣ |
| RTI (007 Gateway) | ៥ ៤៩០ ៥០៩ | ៥ ៧៨៩ ៣៤៦ | ១៨ ៧៧៤ ៩៧៣ | ១៨ ៣៥៤ ៥០២ | ១២ ៤១៩ ៤៤៧ |
| សរុប | ៨៧ ០៣៨ ៦៧៨ | ១០៩ ០៨៧ ១៩៨ | ១៥៤ ៥៥៩ ២៩១ | ១៩៩ ០៩៧ ៩៩៨ | ២៤៩ ៩៨២ ៨០៣ |

*ប្រភព៖ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

វិស័យទូរគមនាគមន៍កំពុងរីកដុះដាលនៅកម្ពុជា។ សេរីភាពមានតាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០ កំពុងតែបើកផ្នែកដ៏ធំមួយ ជាសក្តានុពលសម្រាប់ការប្រកួតប្រជែងដែលគួរឱ្យកត់សម្គាល់ នោះគឺទូរស័ព្ទចល័ត។ ប៉ុន្តែជំហរដ៏រឹងមាំនៃទូរគមនាគមន៍នៅកម្ពុជាជារួម មិនត្រូវលាក់បំពួនការប្រកួតប្រជែងដែលកំពុងប្រឈមមុខជាមួយវិស័យនេះ។ ទោះបីជាមានកំណែទម្រង់និងការប្រកួតប្រជែងក៏ដោយ ក៏ថ្លៃសេវាទូរស័ព្ទនៅតែខ្ពស់ពេក។

## ១៤.២.១. បដិបត្តិការទូរស័ព្ទអចល័ត

អំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ ទូរស័ព្ទអចល័តមានកំណើនយ៉ាងខ្លាំង នៅចន្លោះពី ២០% ទៅ ៥៤% ក្នុងមួយឆ្នាំ។ ទីផ្សារទូរស័ព្ទប្រើខ្សែបានធ្លាក់ចុះ ដោយមានកំណើនអ្នកប្រើប្រាស់តិចតួច ដោយសារតែមានការប្រកួតប្រជែងពីទូរស័ព្ទចល័ត។ ក្នុងការប្រកួតប្រជែងគួរតែជំរុញអ្នកផ្គត់ផ្គង់ ទាំងផ្នែកទូរស័ព្ទចល័ត និងទូរសព្ទ័ប្រើខ្សែ ឱ្យវិនិយោគលើបច្ចេកវិទ្យាថ្មីៗ ដើម្បីកាត់បន្ថយការចំណាយថ្លៃដើម និងមានជំហរផ្ទាល់ខ្លួនល្អប្រសើរមួយ ដែលអ្នកផ្តល់សេវាកម្មទាំងអស់ត្រូវគេរំពឹងថានឹងផ្តល់នូវគ្រប់សេវាកម្មទាំងអស់។

ទោះបីជាការប្រកួតប្រជែងកំពុងកើនឡើងយ៉ាងណាក៏ដោយ ក៏កំណើនចំនួនអ្នកប្រើប្រាស់ទូរស័ព្ទប្រើខ្សែមានតែ ១៥% ក្នុងឆ្នាំ ២០០០។ ចន្លោះឆ្នាំ ២០០០ និង ២០០៦ ចំនួនអ្នកប្រើប្រាស់សេវាកម្មអចល័តកើនជាមធ្យមត្រឹមតែ ៧,៦% ប៉ុណ្ណោះក្នុងមួយឆ្នាំ។ ឆ្នាំ ២០០៧ សេវានេះកើនត្រឹម ១% ប៉ុណ្ណោះ ស្ថានភាពនេះបណ្ដាលមកពីការអភិវឌ្ឍប្រព័ន្ធទូរស័ព្ទ VOIP។ ទីផ្សារភាគហ៊ុនស្មើនឹង ៦៨% នៃទីផ្សារទូរស័ព្ទប្រើខ្សែ។

*រូបភាព១៤.៣. បរិមាណនៃការជាវសេវាទូរស័ព្ទអចល័ត*




*ប្រភព៖ទូរគមនាគមន៍កម្ពុជា*

ក្នុងឆ្នាំ ២០០៨ កម្ពុជាមានខ្សែទូរស័ព្ទចំនួន ៣៥,៤១៥ ឬ ២,៤ ខ្សែក្នុងប្រជាជន ១០០ នាក់ (បើប្រៀបធៀបជាមួយប្រទេសថៃ ១២,៩ ខ្សែក្នុងប្រជាជន ១០០ នាក់)។ Telecom Cambodia មានអ្នកប្រើប្រាស់ ៤៩% ក្រុមហ៊ុន Camintel ៣៨% និងក្រុមហ៊ុន Camshin ១៣%។

Telecom Cambodia គឺជា ប្រតិបត្តិករសាធារណៈមួយលើសេវាទូរគមនាគមន៍ប្រើខ្សែ សេវាកម្មបញ្ជូនទិន្នន័យអចល័ត និងសេវាកម្មជួលខ្សែទូរស័ព្ទ។ ក្នុងឆ្នាំ ២០០៦ អាជីវកម្មនេះរកប្រាក់ចំណេញបាន ៣ លានដុល្លារ នៅក្នុងប្រាក់ចំណូល ២៥ លានដុល្លារ។ ទូរគមនាគមន៍កម្ពុជា គឺជាសហគ្រាសមួយរបស់រដ្ឋ។

Telecom Cambodia ក៏ធ្វើប្រតិបត្តិការ "ច្រកទូរគមនាគមន៍អន្តរជាតិ ០០១" ដែលត្រូវបានបង្កើតឡើងក្រោមរូបភាពសម្ព័ន្ធអាជីវកម្មមួយរវាងរាជរដ្ឋាភិបាលកម្ពុជានិងក្រុមហ៊ុន Telstra ហើយបានប្រគល់ជូនទៅរដ្ឋាភិបាលក្នុងខែ តុលា ឆ្នាំ ២០០០។ បន្ថែមពីនោះ ខ្សែកាបអុបទិកមួយខ្សែត្រូវបានតម្លើង ដោយមានជំនួយពីសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលតភ្ជាប់ពីភ្នំពេញទៅព្រំដែនថៃ។ ខ្សែកាបអុបទិកមួយខ្សែទៀតនឹងត្រូវតម្លើង ក្រោមហិរញ្ញប្បទានពីធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (JBIC) ដោយភ្ជាប់ពីភ្នំពេញទៅខេត្តព្រះសីហនុ និងទៅខេត្តកំពង់ចាម។ គម្រោងទូរគមនាគមន៍ GMS មួយ ក្រោមហិរញ្ញប្បទានកម្ចីពីប្រទេសចិន នឹងភ្ជាប់ខ្សែកាបអុបទិកក្នុងបណ្ដាខេត្តនៅជុំវិញបឹងទន្លេសាប។

នាពេលអនាគត ខ្សែកាបអុបទិកនឹងដើរតួរនាទីយ៉ាងសំខាន់ក្នុងការបញ្ជូនទិន្នន័យ។ ទូរគមនាគមន៍កម្ពុជាមានបំណងចង់ឱ្យមានអ្នកប្រើប្រាស់ប្រព័ន្ធទូរស័ព្ទប្រើខ្សែ ៩៥,០០០ នាក់ នៅត្រឹមឆ្នាំ ២០១០ ដែលហាក់បីដូចជាអាចទៅរួច តាមបទពិសោធពីអតីតកាល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១៤.២.២. ប្រតិបត្តិការសេវាកម្មទូរស័ព្ទចល័ត

គិតត្រឹមខែមីនា ឆ្នាំ២០០៩ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានផ្ដល់អាជ្ញាបណ្ណ ចំនួន ១១ បណ្ដាញ ដែលក្នុងនោះបណ្ដាញចំនួន ៨ បានចាប់ផ្ដើមប្រតិបត្តិការ ហើយបណ្ដាញ ៣ ទៀតកំពុងត្រៀមខ្លួនចូលក្នុងទីផ្សារ។ បណ្ដាញដែលកំពុងប្រតិបត្តិការមានដូចជា Hello GSM (TMIC), Mfone (Camshin), QB (Cadcomms), Star-Cell (Applifone), Excel, CamGSM, Metfone (Viettel), និងSmart Mobile (Latelz)។ ទោះបីសេដ្ឋកិច្ចពិភពលោកធ្លាក់ចុះក្ដី ក៏កំណើនវិស័យទូរគមនាគមន៍របស់កម្ពុជារក្សាបានភាពវិជ្ជមាន ដោយសារការវិនិយោគយ៉ាងខ្លាំងខាងហេដ្ឋារចនាសម្ព័ន្ធ។ ប៉ុន្តែក្នុងស្ថានភាពមិនហ្នឹងនរ និងតម្លៃប្រែប្រួលមិនទៀងនោះ ទីផ្សារទូរស័ព្ទចល័តគ្រាន់តែបំពេញទីផ្សារនិងតម្លៃក្នុងស្រុក ខណៈដែលផលប្រយោជន៍បានទៅអ្នកប្រើប្រាស់ដែលនឹងទាញ ឱ្យលទ្ធភាពរកប្រាក់ចំណេញធ្លាក់ចុះ។

*រូបភាព១៤.១. ទីផ្សារទូរស័ព្ទចល័ត*

| ប្រតិបត្តិករ | ប្រព័ន្ធលេខទូរស័ព្ទ |
|---|---|
| Mobitel (Royal Group) | 012, 092, 017 |
| Hello (Telekom Malaysia) | 015, 016, 081 |
| M-Fone (Camshin) | 011, 099, 085 |
| qb (Cadcomms) | 013 |
| Star-Cell (Applifone) | 098 |
| Excell (GT-Tell-Cambodia) | 018 |
| MetFone (Viettel) | 097 |
| Smart Mobile (Latelz) | 010, 093 |

*ប្រភព៖ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍*

ទីផ្សារទូរស័ព្ទចល័តនៅកម្ពុជាត្រូវបានគ្រប់ដណ្ដប់ភាគច្រើនដោយក្រុមហ៊ុន CamGSM ដែលកាន់កាប់ ៥៩% នៃទីផ្សារ បន្ទាប់មកក្រុមហ៊ុន Camshin ២៤% ក្រុមហ៊ុន Telekom Malaysia ១៥% និងក្រុមហ៊ុន Camintel ២%។ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទដៃនៅកម្ពុជាបានកើនឡើងយ៉ាងរហ័ស រហូតដល់ទៅ ១,២ លាននាក់ ឬ ក្នុងមនុស្ស ១០០ នាក់ទូរស័ព្ទដៃ ៨៣,៧ (បើប្រៀបធៀបនឹងប្រទេសថៃ ១០០ នាក់មានទូរស័ព្ទដៃ ៣០,៦)។ ចំនួនទូរស័ព្ទចល័តមានកំណើនជាមធ្យម ៤៩% ក្នុងមួយឆ្នាំក្នុងរយៈពេល ១២ ឆ្នាំកន្លងទៅ។ ដូច្នេះកំណើនដ៏យឺតយ៉ាវក្នុងការប្រើប្រាស់ទូរស័ព្ទអចល័តត្រូវបានជំនួស ដោយកំណើនដ៏ឆាប់រហ័សនៃអ្នកប្រើប្រាស់ទូរស័ព្ទចល័ត។ ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទចល័តនៅកម្ពុជាបានកើនឡើងជិត ១៥ % ក្នុងឆ្នាំ ២០០៨ ដោយមានអ្នកប្រើប្រាស់ ៣ លាននាក់គិតត្រឹមចុងឆ្នាំ ២០០៩។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សន្ទុះកំណើននៃការទំនាក់ទំនងតាមទូរស័ព្ទស៊ីគ្នានឹងកំណើនដ៏ខ្លាំងនៃប្រាក់ចំណូល (៣២% ក្នុងឆ្នាំ ២០០៧)។ ក្នុងឆ្នាំ ២០០៨ ប្រាក់ចំណូលស្មើនឹង ៨២៩ លានដុល្លារ។ ទោះជាយ៉ាងណាក្តី ចំណាយថ្លៃដើមរបស់ប្រព័ន្ធ Roaming អន្តរជាតិនៅតែមានកម្រិតខ្ពស់។ សេវាកម្មជំនាន់ទីបី (3G) កំពុងស្ថិតក្នុងដំណើរការនៃការអភិវឌ្ឍ។

*រូបភាព១៤.៤. ការប្រើប្រាស់ទូរស័ព្ទចល័ត*




*ប្រភព៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍*

ក្រុមហ៊ុន **CamGSM (Mobitel)** បានបង្កើតសម្ព័ន្ធជីវកម្មមួយក្នុងឆ្នាំ ១៩៩៦ រវាងក្រុមហ៊ុនស៊ុីសមួយឈ្មោះ Millicom International និងក្រុមហ៊ុនកម្ពុជាមួយឈ្មោះ Royal Group of Companies ដែលកំពុងដើរតួនាទីយ៉ាងលេចធ្លោមួយ ក្នុងទីផ្សារគមនាគមន៍ចល័តនៅកម្ពុជា។ អាជីវកម្មនេះបានទទួលសម្បទានរយៈពេល ២៥ ឆ្នាំ។ គិតត្រឹមចុងឆ្នាំ ២០០៦ ក្រុមហ៊ុន CamGSMមានអ្នកប្រើប្រាស់ប្រមាណ ៨៥៩,០០០ នាក់ស្មើនឹង ៦៩% នៃទីផ្សារ។ ការអភិវឌ្ឍទូរគមនាគមន៍នេះតម្រូវឱ្យមានការវិនិយោគដ៏ធំ។ ក្រុមហ៊ុន Mobitel បានបោះទុនច្រើនជាង ២០០ លានដុល្លារសម្រាប់ការស្ថាបនាបណ្តាញនិងការផ្តល់សេវាកម្ម។ ក្នុង ៤ ឆ្នាំកន្លងទៅ ប្រាក់ចំណូលរបស់ក្រុមហ៊ុន CamGSM បានកើនឡើង ជាមធ្យម ៣៣% បើប្រៀបធៀបជាមួយក្រុមហ៊ុនទូរគមនាគមន៍ ៣ ផ្សេងទៀត (Camshin, Malaysai Telekom, និងCamintel) ដែលមានតែ ២៦%។

ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០០ "ច្រកអន្តរជាតិទីពីរ" បានបើកដំណើរការ បន្ទាប់ពីការផ្តល់សម្បទានដល់ក្រុមហ៊ុន Royal Telecom International (RTI) ក្នុងខែមិថុនាឆ្នាំ ១៩៩៧។ ក្រុមហ៊ុន Millicom International និងក្រុមហ៊ុន Royal Group of Companies បានបោះទុន ១៥ លានដុល្លារក្នុងអាជីវកម្មនេះ។ ក្រុមហ៊ុន RTI នឹងផ្ទេរ ៥១% នៃចំណូលសរុបដល់រដ្ឋាភិបាល។ ច្រកទំនាក់ទំនងអន្តរជាតិនេះបានភ្ជាប់ទៅ ២២០ ប្រទេសតាមរយៈផ្កាយរណប ២ និងបណ្តាញខ្សែកាបអុបទិកក្រោមសមុទ្រ។

ក្រុមហ៊ុន Camshin ស្ថិតក្នុងលំដាប់ទី ២ ជាមួយនឹងចំណែកទីផ្សារ ១៨ %។

ក្រុមហ៊ុន Telekom Malaysia International Cambodia (TMIC) មានចំណែកទីផ្សារ ១៥% តាមពីក្រោយក្រុមហ៊ុន ២ ខាងលើ។ ក្រុមហ៊ុន TMIC ដាក់ឱ្យប្រើប្រាស់អត្តសញ្ញាណសាខាថ្មីមួយគឺ "Hello" ក្នុងខែវិច្ឆិកា ឆ្នាំ ២០០៧។ អំឡុងពេល១២ខែកន្លងទៅ ក្រុមហ៊ុននេះមានចំនួនអ្នកប្រើប្រាស់ស្ទើរតែទ្វេដង ហើយ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ឥឡូវនេះគឺជាប្រតិបត្តិករធំបំផុតទីបី។ ក្រុមហ៊ុន TMIC កំពុងវិនិយោគទឹកប្រាក់ ១៥០ លានដុល្លារនៅកម្ពុជា ដើម្បីលើកកម្ពស់សមត្ថភាពបណ្តាញនិងបន្ថែមស្ថានីយ៍ទទួលសេវា (BTS) ថ្មីចំនួន ៥០០ កន្លែងទៀតសម្រាប់ពង្រីកវិសាលភាពគ្របដណ្តប់នៅតំបន់ជនបទនិងខេត្តនានា។

ដើម្បីបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ដែលចេះតែកើនឡើង ក្រុមហ៊ុន Hello បានប្រកាសបើកលេខកូដតំបន់ថ្មីមួយ គឺ ០៨១។ អតិថិជនដែលប្រើប្រាស់លេខកូដតំបន់នេះនឹងនៅតែទទួលបានអត្ថប្រយោជន៍ដូចគ្នានឹងអតិថិជនមុនដែរ ដែលប្រើប្រាស់លេខតំបន់ ០១៥ និង ០១៦។ក្នុងខែ កុម្ភៈ ឆ្នាំ ២០០៩ ក្រុមហ៊ុននេះបានចាប់ដំណើរការសេវាជាកញ្ចប់ Roaming អន្តរជាតិមិនកំណត់មួយ។ សេវានេះ គឺជាសេវាកញ្ចប់ Roaming គ្មានដែនកំណត់មុនគេបង្អស់របស់កម្ពុជា ហើយវានឹងកាត់បន្ថយការចំណាយក្នុងការតភ្ជាប់នឹងបណ្តាញនៅពេលធ្វើដំណើរចេញពីកម្ពុជា។ គម្រោង Roaming ទិន្នន័យមិនកំណត់ប្រចាំថ្ងៃ មានគោលបំណងបម្រើដល់អ្នកប្រកបអាជីវកម្ម និងមន្ត្រីរដ្ឋាភិបាលមួយចំណែកតូច ដែលធ្វើដំណើរពាសពេញតំបន់និងមានបំណងប្រើប្រាស់អ៊ិនធឺណិតនៅក្រៅប្រទេស។

ក្រុមហ៊ុន Smart Mobile បានក្លាយជាអ្នកផ្តល់សេវាកម្មលេខ ៨ ក្នុងខែ មីនា ឆ្នាំ ២០០៩។ Smart Mobile មានក្រុមហ៊ុនមេរបស់រុស្ស៊ីមួយឈ្មោះ Latelz ដែលជាកម្មសិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Timeturns Holdings មានមូលដ្ឋាននៅប្រទេស Cyprus និង ត្រូវបានបង្កើតដោយភាគីភាគហ៊ុនសម្រាប់គ្រប់គ្រងនិងដំណើរការប្រតិបត្តិករ GSM/UMTS ជុំវិញពិភពលោក។ ជាមួយនឹងការលូតលាស់យ៉ាងឆាប់រហ័សរបស់វិស័យទូរគមនាគមន៍នៅកម្ពុជា ក្រុមហ៊ុន Smart Mobile មានការជឿជាក់ថា ខ្លួនអាចចាប់យកចំណែកទីផ្សារមួយភាគធំ និងកំពុងវិនិយោគយ៉ាងខ្លាំងខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធ។

ក្រុមហ៊ុន Smart Mobile បានរចនា Smart Store ដែលទាក់ទាញចិត្តអ្នកប្រើប្រាស់ និងមានបច្ចេកវិទ្យាខ្ពស់ នៅចំបេះដូងនៃទីក្រុងភ្នំពេញ ដែលបើកទូលាយដល់មនុស្សគ្រប់គ្នា។ ក្រុមហ៊ុន Smart Mobile មានគោលបំណងបង្កើតបច្ចេកវិទ្យាទូរស័ព្ទចល័តដែលមានគុណភាពមួយ សម្រាប់អតិថិជននៅទូទាំងកម្ពុជា។ អគារ Smart Store នៅតាមបណ្តោយមហាវិថីព្រះមុនីវង្ស ក្នុងរាជធានីភ្នំពេញ អាចអនុញ្ញាតឱ្យអ្នកប្រើប្រាស់បានយល់ដឹងអំពីក្រុមហ៊ុនផ្តល់សេវាកម្មទូរស័ព្ទចល័តថ្មីបំផុតរបស់កម្ពុជា និងការផ្តល់សេវារបស់ខ្លួន ការភ្ជាប់សេវាSmartMobileការបន្ថែមសេវាកម្មក្រៅពីកន្សោមសេវារបស់SmartMobileនិងការទទួលសេវាគាំទ្រនានា។ នៅខាងក្នុងអគារ មានផ្តល់សេវាអ៊ិនធឺណែតឥតគិតថ្លៃ មានស្តង់លេងហ្គេមកម្សាន្ត និងមានអេក្រង់វីដេអូដ៏ធំមួយ ដែលបង្កើតឡើងសម្រាប់ការបង្ហាញព័ត៌មានចម្រុះ រួមមានសិក្ខាសាលាស្តីពី 'Smart Living' ឬការប្រឡងលេងហ្គេម។

ក្រុមហ៊ុន Sotelco ជាក្រុមហ៊ុនរងរបស់ក្រុមហ៊ុន VimpelCom របស់រុស្ស៊ី បានចុះកិច្ចសន្យាមួយដើម្បីកសាងបណ្តាញ GSM មួយនៅកម្ពុជា ជាមួយបច្ចេកវិទ្យា Huawei របស់ចិន។ នៅក្នុងកិច្ចព្រមព្រៀងក្របខណ្ឌថ្មីនេះ Huawei នឹងដាក់ពង្រាយបណ្តាញទូរស័ព្ទចល័ត GSM ទូទាំងប្រទេសសម្រាប់ក្រុមហ៊ុន Sotelco នៅ ៥ ឆ្នាំខាងមុខ។ ក្រុមហ៊ុន Sotelco បានជ្រើសរើសក្រុមហ៊ុន Huawei សម្រាប់អនុវត្តគម្រោងដ៏សំខាន់នេះ ដោយសារតែ Huawei មានជំនាញរបស់ខ្លួននិងស្នាដៃ ក្នុងការផ្តល់បណ្តាញទូរស័ព្ទចល័តដែលមានគុណភាព។ ក្រុមហ៊ុន VimpelCom បានសន្យាចំណាយប្រហែល ២០០ លានដុល្លារ លើបណ្តាញរបស់ខ្លួន ក្នុងប្រទេសកម្ពុជា ក្នុងរយៈពេល ៣ ទៅ៤ ឆ្នាំដំបូង បន្ទាប់ពីការបើកពាណិជ្ជកម្មរបស់ខ្លួន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រុមហ៊ុន Viettel ជាអង្គភាពទូរគមនាគមន៍ ដែលកាន់កាប់ដោយក្រសួងការពារជាតិរបស់ប្រទេសវៀតណាម បានបើកសេវាកម្ម Metfone របស់ខ្លួនជាផ្លូវការនៅកម្ពុជាក្នុងខែ កុម្ភៈ ឆ្នាំ ២០០៩។ ក្រុមហ៊ុននេះបានស្រូបយកអ្នកប្រើប្រាស់យ៉ាងឆាប់រហ័ស ប្រមាណជាង ៥០០,០០០ នាក់ទូទាំងប្រទេស តាមរយៈការចែកជូនស៊ីមកាតដោយឥតគិតថ្លៃ និងកំពុងឈានទៅចាប់ទីផ្សារនៅតំបន់ជនបទរបស់កម្ពុជានិងការតភ្ជាប់សាលារៀនទៅនឹងប្រព័ន្ធអ៊ិនធឺណែត។ ក្រុមហ៊ុន Viettel បានផ្ដល់ឱ្យក្រសួងអប់រំ យុវជន និងកីឡានូវទឹកប្រាក់ ៥ លានដុល្លារ ដើម្បីតម្លើងខ្សែបញ្ជូនសេវា អ៊ិនធឺណិតកម្រិតទូលាយមួយដោយឥតគិតថ្លៃ នៅតាមសាលារៀនចំនួន ១,០០០ ក្នុងចំណោមសាលារៀនទូទាំងប្រទេស។ គម្រោងនេះនឹងត្រូវបានអនុវត្តនាពេល ៥ ឆ្នាំខាងមុខ។ ក្រុមហ៊ុនViettel បានតម្លើងស្ថានីយ៍បញ្ជូនចំនួន ១,០០០ កន្លែងនៅទូទាំងប្រទេសនិងខ្សែកាបអុបទិកប្រវែង៥,០០០ គ.ម ដោយគ្របដណ្ដប់ ២៤ រាជធានី ខេត្តទាំងអស់នៃប្រទេសកម្ពុជា។ ក្រុមហ៊ុននេះគ្រោងនឹងតម្លើងស្ថានីយ៍បញ្ជូននិងខ្សែកាបបន្ថែមទៀត ដើម្បីពង្រីកការគ្របដណ្ដប់របស់ខ្លួនទៅដល់តំបន់កោះនៃប្រទេសកម្ពុជា។

ក្រុមហ៊ុន Applifone ដែលគេស្គាល់តាមរយៈឈ្មោះយីហោ Star-Cell នោះគឺជា ប្រតិបត្តិករចល័ត GSM ឯកជនមួយនៅកម្ពុជា។ ក្រុមហ៊ុននេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៦ និងបើករកស៊ីក្នុងឆ្នាំ២០០៧។ ដើម្បីបង្កើនការគ្របដណ្ដប់របស់ខ្លួនដល់ ២៤ រាជធានី ខេត្តនោះ ក្រុមហ៊ុន Star-Cell បានច្របាច់បញ្ចូលជាមួយក្រុមហ៊ុន Ericsson ដើម្បីដាក់ឱ្យប្រើប្រាស់ស្ថានីយ៍ប្រើដោយថាមពលព្រះអាទិត្យនៅកម្ពុជា។ ការបញ្ជូនសេវាតាមផ្កាយរណបនឹងពង្រីកលទ្ធភាពឱ្យសេវាអាចគ្របដណ្ដប់ដល់តំបន់ដាច់ស្រយាល ខណៈដែលដំណោះស្រាយបញ្ជូនសេវាដទៃទៀតមិនធ្វើ ទៅរួច។ តាមរយៈការដាក់ទីតាំងប្រើថាមពលព្រះអាទិត្យរបស់ Ericsson រួមជាមួយនឹងការបញ្ជូនពីផ្កាយរណបនោះ ក្រុមហ៊ុន Applifone អាចពង្រីកសេវា ប្រកបដោយប្រសិទ្ធភាពចំណាយ ដល់តំបន់ជនបទ ភ្ជាប់ទំនាក់ទំនងមនុស្សជាលើកដំបូង និងផ្ដល់សេវាកម្មដែលមានតម្លៃសមរម្យ ដើម្បីលើកកម្ពស់គុណភាពនៃជីវិត។ ក្រុមហ៊ុន Star-Cell បានពង្រីកសេវាកម្មរបស់ខ្លួន ទៅតំបន់ភាគច្រើននៃប្រទេសកម្ពុជា។

ក្នុងវិស័យគមនាគមន៍ចល័តនេះ ទីផ្សារបន្តមានការលូតលាស់។ ប្រាក់ចំណូលបន្តកើនឡើងក្នុងអត្រាប៉ាន់ស្មានមួយគឺ ៣២% ក្នុងឆ្នាំ២០០៨។ ជាមធ្យម ទីផ្សារទូរស័ព្ទចល័តកើនឡើង ៣១% ក្នុងពេល ៥ ឆ្នាំកន្លងទៅ។ ផ្នែកនេះរកបាន ២៩៨ លានដុល្លារក្នុងឆ្នាំ ២០០៧។ ទោះជាយ៉ាងនេះក្ដី តម្លៃរបស់ប្រព័ន្ធ Roaming អន្តរជាតិនៅតែខ្ពស់។ បច្ចុប្បន្ន មានអ្នកផ្ដល់សេវាកម្មចល័តនេះពីរថែមទៀត។ ក្រុមហ៊ុន Star-Cell (០៩៨) និងក្រុមហ៊ុន CADCOMMS (០១៣) បានផ្ដល់សេវាកម្មទូរស័ព្ទចល័តជំនាន់ទីបី (3G)។ ការលេចឡើងនៃប្រព័ន្ធទូរស័ព្ទអ៊ិនធឺណោតនិងកញ្ចប់សេវាថ្មីៗដែលផ្ដល់ដោយប្រតិបត្តិករផ្សេងៗ បានចាប់ផ្ដើមកាត់បន្ថយចំណាយក្នុងការទំនាក់ទំនងជាច្រើន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រូបភាព១៤.៥. ភាគហ៊ុនទីផ្សារនៃអ្នកផ្តល់សេវាកម្មទូរស័ព្ទចល័ត*




*ប្រភព៖ទូរគមនាគមន៍កម្ពុជា*

ការប្រកួតប្រជែងខាងតម្លៃនិងគុណភាពសេវាមានសារៈសំខាន់កាន់តែខ្លាំងឡើង ក្នុងទីផ្សារទូរស័ព្ទចល័ត។ ការលេចឡើងនៃប្រព័ន្ធទូរស័ព្ទអ៊ិនធឺណិត និងកញ្ចប់សេវាថ្មីៗដែលផ្តល់ដោយប្រតិបត្តិករផ្សេងៗបានចាប់ផ្តើមកាត់បន្ថយចំណាយក្នុងការទំនាក់ទំនងជាច្រើន។

*រូបភាព១៤.៦. កំណើននៃវិស័យទូរស័ព្ទចល័ត*




*ប្រភព៖ទូរគមនាគមន៍កម្ពុជា*

## ១៤.២.៣. សេវាកម្មអ៊ិនធឺណិត

អ៊ិនធឺណិតតំណាងឱ្យការភ្ជាប់គ្នារវាងវិស័យ ២ ដែលវិស័យនីមួយៗបានអភិវឌ្ឍ ដើម្បីខិតឱ្យជិតនឹងវិស័យមួយទៀតគឺ វិស័យទូរគមនាគមន៍និងវិស័យដំណើរការទិន្នន័យអេឡិចត្រូនិក។ គំនិតបង្កើតថ្មី ដែលជំរុញដោយការប្រកួតប្រជែងនិងវឌ្ឍនភាពបច្ចេកវិទ្យានោះ កំពុងតែបង្កើនល្បឿននៃការតភ្ជាប់គ្នា។ ជាមួយនឹងការមកដល់នៃប្រព័ន្ធអ៊ិនធឺណិតនិង VOIP លើទីផ្សារទូរគមនាគមន៍នោះចំនួនអ្នកផ្តល់សេវាកម្មអ៊ិនធឺណិត (ISP) កំពុងតែកើនឡើងជាលំដាប់។

*រូបភាព១៤.៧. ភាគហ៊ុនទីផ្សារនៃអ្នកផ្ដល់សេវាកម្មអ៊ិនធឺណិត*




*ប្រភព៖ទូរគមនាគមន៍កម្ពុជា*

នៅពេលដែលចំនួនអ្នកផ្ដល់សេវាកម្មអ៊ិនធឺណិតលើទីផ្សារបានកើនឡើងនោះ ការចំណាយរបស់អ្នកប្រើប្រាស់បានធ្លាក់ចុះ ខណៈដែលល្បឿនបញ្ជូនបានកើនឡើង។ ប្រតិបត្តិករសេវាកម្មអ៊ិនធឺណិតមានដូចជា ក្រុមហ៊ុន Camnet (TC), ក្រុមហ៊ុន Online, ក្រុមហ៊ុន ISP CamGSM, ក្រុមហ៊ុន Camintel, ក្រុមហ៊ុន Camshin Internet, និង ក្រុមហ៊ុនTelekom Malaysia។ IP កំពុងក្លាយជាមធ្យោបាយជាស្តង់ដារក្នុងការផ្លាស់ប្តូរព័ត៌មាន សម្រាប់ប្រតិបត្តិការទាំងក្នុងស្រុកនិងអន្តរជាតិ។

*រូបភាព១៤.៨. អ្នកប្រើប្រាស់អ៊ិនធឺណិត*




*ប្រភព៖ ទូរគមនាគមន៍កម្ពុជា*

នៅចុងឆ្នាំ២០០៨ចំនួនចំណុចភ្ជាប់ទៅកាន់អ៊ិនធឺណិតមាន១២,៦៩៨កន្លែង។កំណើននេះរក្សាបានកម្រិតខ្ពស់បំផុតដោយសារតែ ការអភិវឌ្ឍនៃបច្ចេកវិទ្យាបញ្ជូនទិន្នន័យ ដែលមានល្បឿនលឿននិងការលេចចេញនៃប្រព័ន្ធទូរស័ព្ទលើអ៊ិនធឺណិត។ ការកែលម្អគុណភាពនៃការនិយាយតាមទូរស័ព្ទអ៊ិនធឺណិតនាពេលបច្ចុប្បន្ន បានផ្ដល់នូវអត្រាទាក់ទាញដ៏ខ្ពស់សម្រាប់អ្នកប្រើប្រាស់។

បច្ចុប្បន្ន កម្ពុជាពឹងផ្អែកយ៉ាងខ្លាំង ទៅលើផ្លូវបញ្ជូនទិន្នន័យពីប្រទេសវៀតណាម និងប្រទេសថៃ ហើយភាពពឹងផ្អែកនោះ ក៏ភ្ជាប់មកជាមួយចំណាយច្រើនផងដែរ។ ខណៈដែលតម្លៃលក់ដុំក្នុងប្រទេសវៀតណាមប្រហែល ៤០០ ដុល្លារសម្រាប់ការបញ្ជូនទិន្នន័យ ២ មេហ្គាបៃក្នុង ១ វិនាទីក្នុងមួយផ្លូវបញ្ជូន នោះ អ្នកផ្គត់ផ្គង់អ៊ិនធឺណិតនៅកម្ពុជាត្រូវតែចំណាយរវាងពី ១,៣០០ ដុល្លារទៅ ១,៤០០ដុល្លារ។ ជាមធ្យោបាយដោះស្រាយ ក្រុមហ៊ុនក្នុងស្រុក Telcotech បានឈ្នះការដេញថ្លៃមួយក្នុងឆ្នាំ ២០០៧ ក្នុងការតភ្ជាប់ប្រទេស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្ពុជា តាមរយៈខ្សែកាបក្រោមសមុទ្រមួយទៅនឹងច្រកអាស៊ី-អាមេរិក ដោយមិនបាច់ឆ្លងកាត់ប្រទេសជិតខាង និងភ្ជាប់កម្ពុជាដោយផ្ទាល់ទៅនឹង World Wide Web។

ការប្រកួតប្រជែងយ៉ាងខ្លាំងក្លានៅទីផ្សារក្នុងស្រុក តម្រូវឱ្យមានការទម្លាក់ថ្លៃថែមទៀត ការលើកកម្ពស់គុណភាព និងភាពសម្បូរបែបនៃសេវា។ ក្រៅពីការទម្លាក់ថ្លៃសេវា ភាពសំខាន់របស់អ៊ិនធឺណិត អាស្រ័យលើអ្នកពាក់ព័ន្ធច្រើននិងខុសប្លែកគ្នា ជាពិសេសអ្នកផ្តល់សេវាកម្ម។

បទប្បញ្ញត្តិស្តីពីសេវាអ៊ិនធឺណិត មានបំណងគាំទ្រដល់ការប្រកួតប្រជែង ដើម្បីអត្ថប្រយោជន៍របស់អ្នកប្រើប្រាស់ តាមរយៈការធានាបាននូវការប្រកួតប្រជែងដោយស្មើភាព និងជោគជ័យក្នុងទីផ្សារ។ សម្រាប់រាជរដ្ឋាភិបាលកម្ពុជា កត្តាសំខាន់គឺ ៖

### (១) លើកកម្ពស់ការបង្កើតបណ្តាញមានល្បឿនលឿនដែលអនុញ្ញាតឱ្យមានការដាក់ឱ្យដំណើរការសេវាកម្មច្នៃប្រឌិតជាជា

បណ្តាញមានល្បឿនលឿនតម្រូវឱ្យមានការវិនិយោគច្រើនសន្ធឹក រាប់ទាំងការរៀបចំហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និងការកែសម្រួលបណ្តាញដែលមានស្រាប់។ ជាមួយនឹងការកើនឡើងដ៏លឿននៃសមត្ថភាពរបស់បណ្តាញខ្សែកាបអុបទិកចម្ងាយឆ្ងាយនោះ ការដាក់ពង្រាយបណ្តាញល្បឿនលឿន នៅតាមខ្សែបំបែកល្បឿនលឿន និងល្បឿនមធ្យមក្នុងស្រុក គឺជាបញ្ហាប្រឈមមួយ។ កត្តានេះនឹងអនុញ្ញាតឱ្យប្រតិបត្តិករទាំងអស់ អាចផ្តល់សេវាកម្មផ្អែកលើបច្ចេកវិទ្យា xDSL។

ផ្លូវបញ្ជូនធំតម្រូវឱ្យមានហេដ្ឋារចនាសម្ព័ន្ធដែលមានល្បឿនលឿន និងអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ច ដោយពិចារណាអំពីការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពអ៊ិនធឺណិតលើផ្នែក ភាពពេញចិត្ត កម្មវិធី ល្បឿន និងសេវាកម្ម។ វិធានការទាំងនេះមានបំណងបង្កើនល្បឿននៃពង្រាយផ្លូវបញ្ជូនធំ នៅតាមបណ្តាញរួមបញ្ចូលទាំងបណ្តាញខ្សែកាប ប្រព័ន្ធឥតខ្សែ ខ្សែកាបអុបទិក និងការតភ្ជាប់ទៅនឹងផ្កាយរណប ក៏ដូចជាប្រព័ន្ធទូរគមនាគមន៍ចល័តសកល (UMTS) ដែលជាបច្ចេកវិទ្យាមួយ ក្នុងចំណោមបច្ចេកវិទ្យាទូរគមនាគមន៍ចល័តជំនាន់ទីបី (3G)។

បច្ចុប្បន្ននេះ បណ្តាញដែលអាចរកបានភាគច្រើនគឺ ADSL និង Modem ប្រើខ្សែ។ ទោះជាយ៉ាងណាក្នុងពេលអនាគត បណ្តាញខ្សែអុបទិកនឹងដើរតួនាទីដ៏សំខាន់ក្នុងទូរគមនាគមន៍អេឡិចត្រូនិក ជាមួយនឹងការកើនឡើង ក្នុងការផ្ទេរទិន្នន័យនៅកម្រិតក្រុមហ៊ុននិងបុគ្គល។ នៅពេលដែលកុំព្យូទ័រ និងបណ្តាញផ្សេងៗក្លាយជាផ្នែករួមគ្នាមួយនៃជីវិតនិងមុខរបរប្រចាំថ្ងៃនោះ សន្តិសុខទិន្នន័យក៏នឹងក្លាយជាកត្តាសំខាន់ផងដែរ។ បណ្តាញនិងប្រព័ន្ធព័ត៌មាន ដែលមានសុវត្ថិភាពមានសារៈសំខាន់ណាស់សម្រាប់ការធ្វើពាណិជ្ជកម្ម។

### (២) កែសម្រួលបទបញ្ញត្តិឱ្យស្របទៅនឹងការផ្លាស់ប្តូរក្នុងសេវាកម្មនិងបច្ចេកវិទ្យា

បទប្បញ្ញត្តិនាពេលបច្ចុប្បន្នត្រូវបានរៀបចំឡើង ដើម្បីបើកទូលាយវិស័យទូរគមនាគមន៍ក្នុងការប្រកួតប្រជែង សំដៅលើកកម្ពស់ភាពច្នៃប្រឌិតក្នុងសេវាកម្មទូរគមនាគមន៍ និងការកាត់បន្ថយតម្លៃ។ ឥឡូវនេះ បទប្បញ្ញត្តិទាំងនោះត្រូវតែសម្របទៅនឹងការប្រែប្រួល ដែលកើតមានក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ជាពិសេស ការកើនឡើងនៃសេវាកម្មនានាតាមអ៊ិនធឺណិត។ ការកែសម្រួលក្របខ័ណ្ឌនិយតកម្មត្រូវតែផ្អែកលើគោលការណ៍ ដូចខាងក្រោម៖

- ក្របខណ្ឌនិយតកម្មត្រូវតែលើកកម្ពស់ការពង្រាយបច្ចេកវិទ្យានិងសេវាកម្មប្រកបដោយការច្នៃប្រឌិត។

- បទបញ្ញត្តិត្រូវតែអព្យាក្រឹតលើផ្នែកបច្ចេកទេស ៖ សេវាកម្មដែលប្រកួតប្រជែងឬអាចជំនួសបាន ត្រូវតែអាស្រ័យលើបទបញ្ញត្តិស្រដៀងគ្នា ដោយមិនគិតពីមធ្យោបាយបច្ចេកវិទ្យារបស់ខ្លួន។
- អ្នកប្រើប្រាស់និងអ្នកវិនិយោគ ត្រូវតែទទួលបាននូវក្របខណ្ឌច្បាប់ដែលរឹងមាំនិងមានលំនឹងល្អ។
- បទបញ្ញត្តិត្រូវតែដាក់កំណត់ចំពោះអ្វីដែលជាមានសារៈសំខាន់ខ្លាំងនិងបង្កើតឱកាសសម្រាប់ធ្វើស្វ័យបញ្ញត្តិ។

### (៣) អ៊ិនធឺណែតពេលអនាគត

"ការតភ្ជាប់គ្នាដ៏អស្ចារ្យ" ដែលកំពុងដាក់ឱ្យស្ថិតក្រោមឆ័ត្រតែមួយរវាង វិទ្យាសាស្ត្រ កុំព្យូទ័រ ទូរគមនាគមន៍ និងបច្ចេកវិទ្យារូបភាព-សម្លេង។ ការរួមបញ្ចូលគ្នានៃបច្ចេកវិទ្យារូបភាព-សម្លេង និងអ៊ិនធឺណិតបានឈានទៅមុខកាន់តែល្អរួចមកហើយ តាមរយៈការបម្លែងរូបភាព-សម្លេង ឱ្យទៅជាឌីជីថល ប៉ុន្តែជំហានបន្ទាប់គឺ ការបង្កើតបច្ចេកវិទ្យាទូរទស្សន៍ឌីជីថល ដែលនឹងនាំមកនូវការច្របាច់បញ្ចូលគ្នាពិតប្រាកដមួយរវាងបណ្តាញរូបភាព-សម្លេងដែលមានស្រាប់ និងបណ្តាញទូរគមនាគមន៍។

"**អ៊ិនធឺណិតថ្ងៃអនាគត**"នឹងបង្រួមផលប្រយោជន៍ផ្សេងៗឱ្យទៅជាធាតុរួមតែមួយ ជាមួយនឹងលទ្ធភាពប្រើប្រាស់និងសេវាកម្ម ដែលលើសពីស្តង់ដារនិងការអនុវត្តនាពេលបច្ចុប្បន្ន។ ទោះយ៉ាងណាអ៊ិនធឺណិតថ្ងៃអនាគត ត្រូវតែបង្ហាញពីសមត្ថភាពរបស់ខ្លួន ក្នុងការធ្វើសមាហរណកម្មនៃការប្រែប្រួលបច្ចេកវិទ្យារូបភាព-សម្លេង ភ្ជាប់ព័ត៌មានជាមួយនិងការប្រើប្រាស់ គ្រប់គ្រងការបម្លាស់ទី ឬ Roaming និងផ្តល់បរិយាកាសសន្តិសុខមួយ សម្រាប់ប្រតិបត្តិការរបស់អ្នកប្រើប្រាស់។ អ៊ិនធឺណិតក៏នឹងត្រូវអភិរក្សនូវអ្វីដែលធ្វើឱ្យវាមានភាពជោគជ័យកន្លងមកដែរនោះ គឺ global village communitarian character របស់ខ្លួន និងការរួមបញ្ចូលគ្នានៃការច្នៃប្រឌិតខាងបច្ចេកវិទ្យា និងការច្នៃប្រឌិតខាងការប្រើប្រាស់។

## ១៤.៣. វឌ្ឍនភាពបច្ចេកវិទ្យានិងផលប៉ះពាល់របស់វាលើចំណូលគមនាគមន៍អេឡិចត្រូនិក

ការលេចឡើងនូវប្រព័ន្ធទូរស័ព្ទអ៊ិនធឺណិត និងគុណភាពនៃការហៅទូរស័ព្ទកាន់តែប្រសើរដោយសារតែបច្ចេកវិទ្យា នាំឱ្យចំណូលរបស់ប្រតិបត្តិករតាមខ្សែនិងសេវាទូរស័ព្ទចល័ត ដែលប្រកួតប្រជែងជាមួយគ្នានោះ មានការថយចុះ។ រដ្ឋាភិបាលត្រូវតែស្វែងរកប្រភពចំណូលផ្សេងទៀត ដើម្បីតបស្នងការបាត់បង់ប្រាក់ចំណូលផ្នែកទូរគមនាគមន៍ ដោយសារការធ្លាក់ចុះក្នុងតម្លៃនេះ។ ដូច្នេះ និតិវិធីនានាត្រូវដាក់ចេញដូចជាការដាក់ឱ្យដេញថ្លៃអាជ្ញាបណ្ណ និងរលកធាតុអាកាសវិទ្យុ ដែលត្រូវផ្តល់ដល់ប្រតិបត្តិករបណ្តាញនិងសេវាគមនាគមន៍អេឡិចត្រូនិក។ ជាឧទាហរណ៍ នៅប្រទេសម៉ូរ៉ូកូការដាក់ឱ្យដេញថ្លៃនូវអាជ្ញាបណ្ណទូរគមនាគមន៍អេឡិចត្រូនិក កំពុងនាំយកចំណូលរាប់លានដុល្លារចូលក្នុងហិបប្រាក់របស់ជាតិ។

ប្រតិបត្តិករត្រូវតែទទួលបានអាជ្ញាបណ្ណ សម្រាប់ការរៀបចំបណ្តាញទូរគមនាគមន៍និងការផ្តល់សេវាទូរគមនាគមន៍នានា។ កម្មវត្ថុនៃការចេញអាជ្ញាបណ្ណក៏ត្រូវអនុញ្ញាតឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍និងអាជ្ញាធរគមនាគមន៍កម្ពុជា ក្នុងការ៖

- លើកកម្ពស់ការអភិវឌ្ឍបណ្តាញទូរគមនាគមន៍អេឡិចត្រូនិក និងការផ្តល់សេវាកម្មទូរគមនាគមន៍អេឡិចត្រូនិក។
- ពង្រឹងការអនុវត្តបទប្បញ្ញត្តិ ដើម្បីធានាដំណើរការឧស្សាហកម្មគមនាគមន៍អេឡិចត្រូនិក ប្រព្រឹត្តទៅសមរម្យ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- អនុវត្តក្របខណ្ឌមួយ ដែលធានាបានការប្រកួតប្រជែងដ៏យុត្តិធម៌ ក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។
- ធានាបាននូវការការពារដល់អ្នកប្រើប្រាស់កាន់តែច្រើនជាងមុន។

## ១៤.៤. យុទ្ធសាស្ត្រនិងគោលនយោបាយសម្រាប់ការអភិវឌ្ឍវិស័យទូរគមនាគមន៍

ការលើកកម្ពស់សង្គមព័ត៌មានគឺជា កត្តាកំណត់មួយក្នុងការទទួលបានសង្គមទំនើបមួយ ជាមួយនឹងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ យុទ្ធសាស្ត្រចតុកោណបានសង្កត់ធ្ងន់លើតួនាទីដ៏សំខាន់របស់បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ សម្រាប់ការដើបឡើងនៃសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ។ កម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអភិវឌ្ឍវិស័យទូរគមនាគមន៍ ដើម្បីលើកទឹកចិត្តការវិនិយោគនិងការច្នៃប្រឌិត ជាមួយនឹងជម្រើសកាន់តែច្រើន គុណភាពកាន់តែប្រសើរ និងថ្លៃសេវាកាន់តែទាបសម្រាប់អ្នកប្រើប្រាស់ និងដើម្បីពង្រីកវិសាលភាពគមនាគមន៍ទៅដល់គ្រប់ផ្នែកនៃប្រទេស។

កម្ពុជាមានសក្តានុពល ក្នុងការបង្កើតមជ្ឈមណ្ឌលបច្ចេកវិទ្យាមួយដោយខ្លួនឯង ដោយទាញយកអត្ថប្រយោជន៍ពីទីតាំងភូមិសាស្ត្ររបស់ខ្លួន គុណភាពនៃហេដ្ឋារចនាសម្ព័ន្ធ និងប្រាក់ឈ្នួលប្រកួតប្រជែងបើប្រៀបធៀបទៅនឹងប្រទេសដទៃទៀតក្នុងតំបន់។ វត្ថុបំណង២ នៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងវិស័យទូរគមនាគមន៍គឺ ការរៀបចំបណ្តាញទូរគមនាគមន៍រួមបញ្ចូលគ្នាមួយ និងការលើកកម្ពស់ការអភិវឌ្ឍសេវាកម្មនៅកម្រិតទាបបំផុត ដែលអ្នកប្រើប្រាស់ទទួលយកបាន។ យុទ្ធសាស្ត្រនេះក៏ត្រូវតែធានាបាននូវលទ្ធភាពប្រើប្រាស់អ៊ិនធឺណែតកាន់តែលឿន និងតម្លៃសមរម្យ សម្រាប់បុគ្គលម្នាក់ៗក៏ដូចជាការប្រកបអាជីវកម្ម។

យុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងវិស័យទូរគមនាគមន៍ បានលើកឡើងនូវកម្មវត្ថុចម្បងៗ ដូចខាងក្រោម៖

- លើកទឹកចិត្តការវិនិយោគក្នុងសមាសធាតុហេដ្ឋារចនាសម្ព័ន្ធគោលនៃបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ជាពិសេសខាងបណ្តាញខ្សែកាបអុបទិកមានសមត្ថភាពខ្ពស់។
- លើកកម្ពស់ការប្រកួតប្រជែងក្នុងទីផ្សារបណ្តាញ និងក្នុងសេវាកម្មគមនាគមន៍អេឡិចត្រូនិក។
- បើកចំហរទីផ្សារឱ្យមានការប្រកួតប្រជែងដោយសេរី រវាងប្រតិបត្តិករផ្នែកឯកជននិងផ្នែកសាធារណៈ ដោយឈរលើការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះអង្គការ WTO ។
- តម្លើងបណ្តាញខ្សែអុបទិកក្នុងរយៈពេល ៥ ឆ្នាំខាងមុខ (១) តភ្ជាប់ពីរាជធានីភ្នំពេញទៅខេត្តកំពង់ចាម តាកែវ និងខេត្តព្រះសីហនុ (២) តភ្ជាប់ពីខេត្តកំពង់ចាមទៅខេត្តកំពង់ធំសៀមរាប និងស៊ីសុផុន (៣) តភ្ជាប់ពីខេត្តកំពង់ចាមទៅខេត្តក្រចេះនិងស្ទឹងត្រែងនិង (៤) តភ្ជាប់ពីខេត្តមណ្ឌលគិរីទៅខេត្តប៉ៃលិន ព្រះវិហារ និងឧត្តរមានជ័យ។
- ស្ថាបនាបណ្តាញគមនាគមន៍ក្នុងរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងសៀមរាប។
- បញ្ចប់ជាស្ថាពរនូវបទដ្ឋាន និងនិយាមជាតិនានាក្នុងប្រតិបត្តិការបណ្តាញនិងសេវាគមនាគមន៍អេឡិចត្រូនិក បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ និងអ៊ិនធឺណែត។
- ផ្សព្វផ្សាយអំពីឧបករណ៍ថ្មី និងការធ្វើសមាហរណកម្មទៅក្នុងជីវិតប្រចាំថ្ងៃ តាមរយៈរដ្ឋបាលតាមប្រព័ន្ធអ៊ិនធឺណិត (e-Government) និងការអប់រំតាមប្រព័ន្ធអ៊ិនធឺណិត (e-Learning)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- រៀបចំផែនការសកម្មភាពមួយ ដើម្បីពង្រីកលទ្ធភាពប្រើប្រាស់អ៊ិនធឺណិតឱ្យកាន់តែមានប្រសិទ្ធផល និងការពង្រីកលទ្ធភាពឱ្យប្រជាជនបានប្រើប្រាស់មធ្យោបាយនេះ ទន្ទឹមនឹងការធានាបាននូវ លទ្ធភាពទទួលបានផ្លូវបញ្ជូនព័ត៌មានច្រើន ពាសពេញប្រទេស ក៏ដូចជាសន្តិសុខបណ្តាញនិងព័ត៌មាន។
- អភិវឌ្ឍក្របខណ្ឌនិយត័កម្មមួយ អមដោយការជំរុញគោលនយោបាយមានស្រាប់ស្តីពីទូរគមនា-គមន៍ ពោលគឺក្របខណ្ឌនិយ័តកម្មថ្មីមួយ សម្រាប់សេវាកម្មគមនាគមន៍អេឡិចត្រូនិច និងបណ្តាញ (ដូចមាននៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីគមនាគមន៍) រួមមាន (១) អនុក្រឹតស្តីពីកាតព្វកិច្ចនៃសេវាកម្មសកល (២) អនុក្រឹតស្តីពីការគ្រប់គ្រងអ៊ិនធឺណិត (៣) គោលនយោបាយស្តីពីអ៊ិនធឺណិតនិង (៤) អនុក្រឹតស្តីពីការគ្រប់គ្រងរលកធាតុអាកាសវិទ្យុ។

## ១៤.៤.១. ការតភ្ជាប់គ្នា លទ្ធភាពនិងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួមគ្នា

មាត្រា ២២ នៃច្បាប់ស្តីពីគមនាគមន៍ បានចែងពីគោលបំណងនៃការតភ្ជាប់គ្នា លទ្ធភាព និងការប្រើប្រាស់រួមគ្នា ដូចខាងក្រោម៖

- ធានាការតភ្ជាប់គ្នារវាងបណ្តាញខុសៗគ្នា៖ អ្នកប្រើប្រាស់របស់ក្រុមហ៊ុនមួយត្រូវតែអាចទំនាក់ទំនងជាមួយមនុស្សគ្រប់គ្នាក្នុងដែនសេវាកម្ម រួមទាំងអ្នកប្រើប្រាស់របស់ប្រតិបត្តិករផ្សេងៗទៀត និងគួរមានលទ្ធភាពចូលទៅកាន់សេវាណាក៏បាន។
- អនុញ្ញាតឱ្យមានការប្រកួតប្រជែងរវាងប្រតិបត្តិករទូរគមនាគមន៍ទាំងឡាយ នៅម្រិតថ្នាក់ជាតិ។
- លើកទឹកចិត្តការវិនិយោគក្នុងវិស័យទូរគមនាគមន៍អេឡិចត្រូនិក។

ការតភ្ជាប់គ្នា គឺជា ការព្រមព្រៀងមួយក្នុងច្បាប់ឯកជនរវាងភាគីដែលចាប់អារម្មណ៍៖ វាគ្រប់ដណ្តប់សេវាកម្មនានារវាងប្រតិបត្តិករបណ្តាញ និងអ្នកផ្តល់សេវាកម្ម ហើយត្រូវបានគ្របដណ្តប់ក្នុងកិច្ចព្រមព្រៀងអាជីវកម្មរវាងភាគីពាក់ព័ន្ធទាំងឡាយ។ វាសំដៅលើកិច្ចសន្យាចូលកាន់បណ្តាញ (កិច្ចព្រមព្រៀងស្តីពីការតភ្ជាប់គ្នា) ដែលត្រូវបានយកមកពិចារណាក្រោមមាត្រា ២១-១ នៃច្បាប់ស្តីពីគមនាគមន៍។

ការតភ្ជាប់បណ្តាញអ៊ិនធឺណិត ត្រូវបានគេរំពឹងថានឹងបានទទួលនៅកម្រិត GIX (Global Internet eXchange) ឬ ក៏ចំណុចប្រសព្វគ្នាសម្រាប់ចរាចរអ៊ិនធឺណិត។ ទាំងនេះ គឺជាការតភ្ជាប់ ដែលអនុញ្ញាតឱ្យប្រតិបត្តិករ ២ ធ្វើការផ្លាស់ប្តូរចរាចររបស់ពួកគេ។ ឧទាហរណ៍ ការបង្កើត GIX នៅទីក្រុងភ្នំពេញមិនអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ២ រូបដែលតភ្ជាប់ជាមួយប្រតិបត្តិករខុសៗគ្នា ហើយធ្វើការទំនាក់ទំនងដោយ visiophony នោះមានចរាចរឆ្លងកាត់ទៅប្រទេសផ្សេងៗបានទេ។ ដូច្នេះ គុណភាពសេវាកម្មនៃការប្រើប្រាស់ពិតប្រាកដនោះត្រូវបានធ្វើឱ្យប្រសើរឡើង។

ក្រៅពីនេះ ការដោះដូរក្នុងស្រុកអាចកាត់បន្ថយការបញ្ជូនទិន្នន័យមិនចាំបាច់៖ ការដោះដូរនេះបានបង្កើនប្រសិទ្ធភាពជារួមនៃបណ្តាញ។ ទោះជាយ៉ាងណា ចាំបាច់ត្រូវការចំណាយលើការតម្លើង និងដំណើរការដែលជាបន្ទុករបស់ប្រតិបត្តិករ។ ការដោះដូរក្នុងស្រុកនេះគឺជា ឧទាហរណ៍នៃអត្ថប្រយោជន៍ ២ ដែលអាចកើតចេញពីប្រតិបត្តិការ ១ ៖

- គុណភាពសេវាកម្មមានភាពប្រសើរ ដោយសារការលុបបំបាត់នូវការផ្ទេរទិន្នន័យមិនចាំបាច់ចេញនិងចូលស្ថានីយ៍។

- កាត់បន្ថយចំណាយរបស់អ្នកផ្តល់សេវាអ៊ិនធឺណិត ដែលអាចផ្តល់អត្រាលក់រាយទាបជាងមុនសម្រាប់អ្នកប្រើប្រាស់។

ក្នុងមាត្រាទី ២៣ ចែងថាប្រតិបត្តិករទូរគមនាគមន៍ត្រូវតែ៖

- ធានានូវការតភ្ជាប់គ្នារវាងបណ្តាញគមនាគមន៍របស់ខ្លួន ជាមួយនិងបណ្តាញគមនាគមន៍របស់ប្រតិបត្តិករផ្សេងទៀត។
- ធានាបាននូវការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួមគ្នា ដែលពួកគេបានដំឡើងជាមួយប្រតិបត្តិករផ្សេងទៀត។
- អនុញ្ញាតឱ្យប្រតិបត្តិករផ្សេងទៀតមានលទ្ធភាពប្រើសេវាកម្មគមនាគមន៍។

មាត្រា ២៣ ចែងថាប្រតិបត្តិករទូរគមនាគមន៍ត្រូវតែ៖

- ធ្វើឱ្យប្រាកដនូវអន្តរបណ្តាញនៃបណ្តាញគមនាគមន៍របស់ខ្លួនជាមួយនឹងបណ្តាញគមនាគមន៍របស់ប្រតិបត្តិករផ្សេងទៀត។
- ធានាបាននូវការប្រើប្រាស់រួមគ្នានៃហេដ្ឋារចនាសម្ព័ន្ធ ដែលពួកគេបានបង្កើតជាមួយប្រតិបត្តិករផ្សេងទៀត។
- អនុញ្ញាតឱ្យប្រតិបត្តិករផ្សេងទៀតមានលទ្ធភាពប្រើសេវាកម្មគមនាគមន៍។

ច្បាប់នេះ ស្វែងរកការលើកកម្ពស់លទ្ធភាពស្មើគ្នា ចូលទៅកាន់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងលក្ខខណ្ឌសមហេតុផលនិងមិនរើសអើង។ គោលបំណងគឺដើម្បីអនុញ្ញាតឱ្យមានការចូលដល់ហេដ្ឋារចនាសម្ព័ន្ធ មិនគ្រាន់តែចំពោះបណ្តាញសកម្មប៉ុណ្ណោះទេ។ វានឹងលើកកម្ពស់ការប្រកួតប្រជែងតាមបណ្តាញ ដែលធ្វើឱ្យប្រសើរឡើងប្រកបដោយចីរភាពនូវការច្នៃប្រឌិត និងតម្លៃធ្លាក់ចុះចំពោះអ្នកប្រើប្រាស់។

មាត្រា ៥៩ (១) នៃច្បាប់នេះ ផ្តល់អំណាចឱ្យ**អាជ្ញាធរគមនាគមន៍កម្ពុជា** ដើម្បីបញ្ចប់ជម្លោះដែលទាក់ទងនឹងការចែករំលែកនៃបណ្តាញ និងហេដ្ឋារចនាសម្ព័ន្ធទាំងនេះ។ ដើម្បីធានាបានការប្រកួតប្រជែង និងចៀសវាងគ្រោះថ្នាក់ផ្នែកសីលធម៌នោះ អាជ្ញាប័ណ្ណសម្រាប់ការផ្តល់បណ្តាញនិងអាជ្ញាប័ណ្ណសម្រាប់ការផ្តល់នូវសេវាកម្មគមនាគមន៍ត្រូវតែចេញឱ្យដើម្បីញែកឱ្យដាច់អង្គភាពនានា។ ប្រតិបត្តិករមួយដែលទទួលបានអាជ្ញាប័ណ្ណសម្រាប់ការផ្តល់បណ្តាញគមនាគមន៍អេឡិចត្រូនិកមួយប្រហែលមិនអាចទទួលបានអាជ្ញាប័ណ្ណមួយទៀតសម្រាប់ការផ្តល់សេវាកម្មគមនាគមន៍បានទេ ឬក៏បញ្ច្រាសមកវិញនោះ។

## ១៤.៤.២. ការគ្រប់គ្រងជនជាតកម្រ៖ការកំណត់លេខនិងរលកធាតុអាកាស

មាត្រា ៣៩ (១) នៃច្បាប់គមនាគមន៍ចែងថា ផែនការជាតិសម្រាប់ការកំណត់លេខនឹងបង្កើតដោយ **អាជ្ញាធរគមនាគមន៍កម្ពុជា** ដើម្បី "ធានាបានការលទ្ធភាពចូលស្មើគ្នា និងតម្លាភាពសម្រាប់អ្នកប្រើប្រាស់របស់បណ្តាញនិងសេវាកម្មគមនាគមន៍ផ្សេងៗ" ។ ក្នុងបរិបទនៃការបើកចំហពេញលេញក្នុងការប្រកួតប្រជែងខាងវិស័យទូរគមនាគមន៍នោះ ការកំណត់លេខចាត់ទុកថាជាសមាសធាតុដ៏សំខាន់មួយ ជាពិសេសដើម្បីអាច



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យអ្នកជាវខ្សែចង្វាយលេកអាកាសក្នុងស្រុក ជ្រើសរើសប្រតិបត្តិកររយៈចម្ងាយឆ្ងាយរបស់គេបាន ។ **អាជ្ញាធរគមនាគមន៍កម្ពុជា** ត្រូវបានគេផ្តល់អំណាចដើម្បីកំណត់លក្ខខណ្ឌនិងនីតិវិធីសម្រាប់ការកំណត់លេខកូដមួយខ្ទង់ (លេខកូដសំដៅថាជា "E") និងបួនខ្ទង់ (លេខកូដរបស់ 16XY Format) សម្រាប់ការជ្រើសរើសការហៅទូរស័ព្ទពីមួយទៅមួយរបស់គមនាគមន៍រយៈចម្ងាយឆ្ងាយ។

អាជ្ញាធរនេះផ្តល់រលកធាតុអាកាសវិទ្យុ និងវិសាលគ.មអេឡិចត្រូនិកវិទ្យុ ទៅឱ្យប្រតិបត្តិករនានា។ អាជ្ញាធរនេះ ក៏ត្រូវតែរៀបចំផែនការជាតិមួយសម្រាប់រលកធាតុអាកាសវិទ្យុ ដោយពិចារណាទៅលើតម្រូវការសម្រាប់សន្តិសុខជាតិ សន្តិសុខអាកាសចរណ៍ ផ្ទៃសមុទ្រ និងសេវាកម្មគមនាគមន៍។

### ១៤.៤.៣. សេវាកម្មសកល

**សេវាកម្មសកល** គឺជាទម្រង់ដែលមានលទ្ធភាពមួយនៃសេវាកម្មសាធារណៈ។ សេវាកម្មទូរគមនាគមន៍សកល (UTS) រួមមាន៖

- លទ្ធភាពចូលដល់សេវាកម្មទូរស័ព្ទជាមូលដ្ឋានដែលមានគុណភាព។
- លទ្ធភាពចូលជាបន្ទាន់ដល់សេវាកម្មគមនាគមន៍។
- លទ្ធភាពចូលដល់សេវាកម្មគមនាគមន៍ក្នុងតំបន់ជនបទនិងដាច់ស្រយាល។

គំនិតនៃ"សេវាកម្មសកល"ត្រូវបានណែនាំឱ្យមានដើម្បីលើកទឹកចិត្តការស្ថាបនានិងការអភិវឌ្ឍនៃបណ្តាញគមនាគមន៍ពាសពេញប្រទេស។ អាជ្ញាធរនេះនឹងតែងតាំងប្រតិបត្តិករមួយឬច្រើនឱ្យទទួលបន្ទុកខាងសេវាកម្មសកលពីក្នុងចំណោមប្រតិបត្តិករនានាស្ថិតក្រោមលក្ខខណ្ឌតម្លាភាពនិងមិនរើសអើង។

គេរំពឹងថាហិរញ្ញប្បទាននៃការចំណាយសុទ្ធរបស់សេវាកម្មសកល នឹងត្រូវគ្របដណ្តប់តាមរយៈការបង្កើតនូវមូលនិធិសេវាកម្មទូរគមនាគមន៍សកលមួយ ដែលត្រូវបានកៀងគរពីការរួមចំណែក ពីប្រតិបត្តិករទូរគមនាគមន៍ទាំងអស់។ អាជ្ញាធរគមនាគមន៍កម្ពុជានឹងត្រូវបានផ្តល់អំណាច ដើម្បីកំណត់ពីបរិមាណនៃការរួមវិភាគទានរបស់ប្រតិបត្តិករនីមួយ។ គេនឹងកំណត់ទៅលើមូលដ្ឋានចំណែកសមាមាត្រនៃប្រាក់ចំណូលរបស់សេវាកម្មទូរគមនាគមន៍នានាដែលការរកកម្រៃបាននាពេលអនាគតពីការផ្តល់នូវសេវាកម្មសកលនោះនឹងត្រូវបានកាត់ចេញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី១៥
# ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

ក្នុងអំឡុងពេល១៥ឆ្នាំកន្លងទៅ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជាមូលដ្ឋានរបស់កម្ពុជា ដែលត្រូវបានបំផ្លាញក្នុងអំឡុងពេលសង្គ្រាមស៊ីវិល។ ដើម្បីសម្រេចបាននូវឧត្តមភាពក្នុងការប្រកួតប្រជែងការនាំចេញ លក្ខខណ្ឌចាំបាច់មិនអាចខ្វះបានរបស់កម្ពុជា គឺការធានាលទ្ធភាពដឹកជញ្ជូនទំនិញ លើរយៈចម្ងាយឆ្ងាយ ដែលមានការចំណាយសមរម្យ ។

ការវិនិយោគសាធារណៈខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធមានផលប៉ះពាល់លើការរីកចម្រើន ក្នុងសង្គម និងបរិថលសំខាន់ជាច្រើនទៀត។ ប៉ុន្តែ ការពឹងផ្អែកតែទៅលើហិរញ្ញវត្ថុរបស់វិស័យឯកជន ក្នុងការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធតែមួយនោះមិនមែនជាអភិក្រមដ៏មានប្រសិទ្ធភាពទេ ហើយជាលទ្ធផលនឹងបណ្តាលឱ្យការវិនិយោគក្នុងការអភិវឌ្ឍវិស័យដឹកជញ្ជូនមិនគ្រប់គ្រាន់។ វិស័យឯកជនគោរពតាមគោលការណ៍ផលប្រយោជន៍ឯកជន ដែលប្រហែលមិនចាប់អារម្មណ៍ខ្លាំងក្នុងវិស័យដឹកជញ្ជូនទេ បើប្រៀបធៀបជាមួយផលចំណេញពីការវិនិយោគក្នុងវិស័យផ្សេងទៀតនោះ។ ក្រៅពីនេះ ភាពមិនអាចចែកដាច់ពីគ្នាបានក្នុងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធតម្រូវឱ្យមានការវិនិយោគជាទ្រង់ទ្រាយធំ ដែលវិស័យឯកជនប្រហែលមិនអាច ឬមិនមានឆន្ទៈក្នុងការកៀរគរធនធានទេ។

តែទោះជាយ៉ាងណា រាជរដ្ឋាភិបាលអាចបង្កើនបរិមាណ និងប្រសិទ្ធផលនៃការវិនិយោគខាងសេវាកម្មមូលដ្ឋាន តាមរយៈការជំរុញវិស័យឯកជន ឯកជននីយកម្ម ឬការធ្វើកិច្ចសន្យាបន្ត។ ក្រៅពីនេះ ក្នុងការផ្តល់សេវាកម្មសាធារណៈដូចជាការដឹកជញ្ជូននិងអគ្គិសនី រដ្ឋត្រូវតែដើរតួជានិយ័តករដើម្បីធានាថា អ្នកប្រើប្រាស់ត្រូវបានការពារ។

ចំណុចខាងក្រោមនេះសង្ខេបសមាសធាតុសំខាន់ៗនៃហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា និងគុណវិបត្តិរបស់វា៖

- កំពង់ផែក្រុងព្រះសីហនុ គឺជាកំពង់ផែដែលត្រូវបានចាត់ថាមានការចំណាយសេវាកម្មខ្ពស់។
- បណ្តាញផ្លូវថ្នល់ ដែលការដឹកជញ្ជូនត្រូវបានគេចាត់ទុកថាមានការចំណាយអស់ច្រើនលើសលុប (ជាពិសេសការចំណាយក្រៅផ្លូវការ)។
- ប្រព័ន្ធផ្លូវរថភ្លើងមួយដែលទ្រុឌទ្រោម និងស្ទើរតែមិនមានដំណើរការ។
- អគ្គិសនីដែលមានតម្លៃខ្ពស់ពេក។

ចាប់តាំងពីឆ្នាំ ១៩៩២ រដ្ឋាភិបាលបានចាប់ផ្តើមកម្មវិធីអភិវឌ្ឍវិស័យដឹកជញ្ជូនដែលរំពឹងថា មានការវិនិយោគដើម្បីស្តារ និងពង្រីកសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធ ដោយផ្តោតលើកម្មវត្ថុចម្បងៗ ដូចខាងក្រោម៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- កាត់បន្ថយចំណាយដឹកជញ្ជូន។
- ពង្រឹងការគ្រប់គ្រងវិស័យដឹកជញ្ជូន។
- ទាក់ទាញវិស័យឯកជនក្នុងការចូលរួមអនុវត្តការស្ថាបនា និងការផ្តល់សេវាកម្មក្នុងវិស័យដឹកជញ្ជូន។
- រៀបចំរចនាសម្ព័ន្ធភ្នាក់ងារដឹកជញ្ជូនសាធារណៈសាជាថ្មី (ដូចជារាជាយស្ម័យយានកម្ពុជា)។

កម្ពុជាសម្រេចបានវឌ្ឍនភាពក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍវិស័យដឹកជញ្ជូនកន្លងមក ដែលរួមចំណែកក្នុងការសម្រេចបានកម្មវត្ថុខាងលើខ្លះៗ ប៉ុន្តែការសម្រេចកម្មវត្ថុទាំងអស់នេះឱ្យបានពេញលេញ គឺជាការពិបាកនឹងធ្វើបានណាស់។ ទោះបីទទួលបានសមិទ្ធផលសំខាន់ៗក្នុងវិស័យផ្លូវថ្នល់ក៏ដោយ ក៏កង្វះខាតត្រូវបានកត់សម្គាល់ក្នុងកម្រិតនៃការធ្វើផែនការ កម្មវិធី សកម្មភាព ការបែងចែក និងការកៀរគរធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់។ គួរឱ្យកត់សម្គាល់នោះគឺ ការថែទាំផ្លូវថ្នល់ ការគ្រប់គ្រងគុណភាពសាងសង់ និងការកាត់បន្ថយចំណាយលើការដឹកជញ្ជូនជើងគោក។ គុណវិបត្តិទាំងនេះជាមូលដ្ឋានបណ្តាលមកពីកង្វះខាតយន្តការសម្របសម្រួល រវាងក្រសួងពាក់ព័ន្ធ ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ។

ការមិនអាចសម្រេចបានកម្មវត្ថុទាំងនេះ អាចបណ្តាលមកពីកត្តាសំខាន់ៗដូចខាងក្រោម៖

- កង្វះទិន្នន័យដែលគួរឱ្យជឿជាក់បាន។ ឧទាហរណ៍ក្នុងអនុវិស័យផ្លូវថ្នល់ កង្វះទិន្នន័យដែលគួរឱ្យជឿជាក់ គឺជាប្រភពនៃកំហុសឆ្គងជាច្រើនក្នុងការបង្កើត ឬធ្វើកម្មវិធីការងារ ដែលមិនបានឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ភាគច្រើន ទោះជាក្នុងការវិនិយោគផ្លូវថ្មីៗ ឬការពង្រីកផ្លូវថ្នល់។
- តម្រូវការ គឺច្រើនលើសពីធនធានដែលមាន ឧទាហរណ៍ថវិកាធ្វើផ្លូវ។
- យុទ្ធសាស្ត្រដឹកជញ្ជូនរបស់រដ្ឋាភិបាលរំពឹងថានឹងសម្រេចបានកម្មវត្ថុដូចខាងក្រោម៖
- ធ្វើឱ្យប្រសើរឡើងបណ្តាញផ្លូវដែលមានស្រាប់។
- ការអភិវឌ្ឍបណ្តាញផ្លូវ ដែលប្រទាក់គ្នា និងមានសុខដុម ក្រោមផែនការមេតែមួយ។
- ទំនើបនីយកម្មរដ្ឋបាលដឹកជញ្ជូនផ្លូវគោក។

យុទ្ធសាស្ត្រនេះរួមមាន៖ (១) វិធានការពង្រឹងស្ថាប័ន និងធ្វើទំនើបនីយកម្មរចនាសម្ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធផលរបស់វិស័យនេះ កសាងសមត្ថភាពធ្វើផែនការ ការធ្វើកម្មវិធី បង្កើត និងគ្រប់គ្រងស្ថាប័ន (២) ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគស្ថាបនាជាថ្មីរួមទាំងផ្លូវដែក (៣) ពង្រឹងការចូលរួមរបស់វិស័យឯកជនក្នុងការគ្រប់គ្រង និងការវិនិយោគលើវិស័យនេះ (៤) អនុវត្តបញ្ចប់យុទ្ធសាស្ត្រដឹកជញ្ជូនជនបទ។

## ១៥.១. ស្ថានភាពផ្លូវថ្នល់បច្ចុប្បន្ននៅកម្ពុជា

ផ្លូវថ្នល់ដើរតួនាទីដ៏សំខាន់មួយក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅកម្ពុជា។ ក៏ប៉ុន្តែ កម្ពុជានៅពុំទាន់មានផ្លូវថ្នល់គ្រប់គ្រាន់នោះទេ។ ក្នុងប្រព័ន្ធដឹកជញ្ជូនរបស់កម្ពុជា អនុវិស័យផ្លូវថ្នល់ត្រូវបានចាត់ទុកថា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាការតភ្ជាប់សំខាន់បំផុត ដែលត្រូវបានប្រើប្រាស់ជាង ៩០% សំរាប់ការធ្វើដំណើរផ្ទាល់ខ្លួន និងការដឹកជញ្ជូនទំនិញ។

*តារាង១៥.១. ប្រវែងបណ្តាញផ្លូវថ្នល់ (ត្រឹមឆ្នាំ២០០៦)*

| ប្រភេទផ្លូវ | ប្រវែង (%) | ចំនួនស្ពាន (ប្រវែង) | សមត្ថកិច្ចគ្រប់គ្រង |
|---|---|---|---|
| ផ្លូវជាតិលេខមួយខ្ទង់ | ២,០៩៧.២៨០ km (៥.៣១%) | ៥៨៩ (១៧,៦៤៣ m) | ក្រសួងសាធារណៈការ |
| ផ្លូវជាតិលេខពីរខ្ទង់ | ២,៧០៤.៧៣៧ km (៦.៨៥%) | ៦៨ (១៥,៧១០ m) | |
| ផ្លូវខេត្ត | ៦,៦៩២.៤៨០km (១៦.៩៥%) | ៩០៤ (១៦,៣០៩ m) | |
| ផ្លូវជនបទ | ២៨,០០០ km (៧០.៨៩%) | N/A | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ប្រវែងសរុប | ៣៩,៤៩៤.៤៥៧ km (១០០.០%) | ២,១២១ (៥១,៩១៧ m) | |

*ប្រភព៖ LRCS Inventory, 2006 and MRD Inventory 2006*

បណ្តាញផ្លូវថ្នល់នៅកម្ពុជារួមមានផ្លូវសំខាន់ៗ ដែលគ្រប់គ្រងដោយក្រសួងសាធារណៈការ និងដឹកជញ្ជូន (MPWT) និងផ្លូវជនបទដែលគ្រប់គ្រងដោយក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ។ ការបែងចែកភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងផ្លូវថ្នល់នេះត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។

*ក្រាហ្វិក. ១៥.១a អនុបាតផ្លូវក្រាលកៅស៊ូ និង អនុបាតស្ពានអចិន្ត្រៃយ៍ (ត្រឹម ២០០៤)*




*ក្រាហ្វិក. ១៥.១b ស្ថានភាពផ្លូវក្រាលកៅស៊ូ តាមប្រភេទផ្លូវ (ត្រឹម 2004)*




*ប្រភព៖ ការសិក្សារបស់ JICA, LRCS inventory, 2004 និង MRD inventory*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បណ្តាញផ្លូវថ្នល់ជាតិត្រូវបានបង្ហាញក្នុងរូបភាពខាងក្រោម។

*ផែនទី១៥.១.បណ្តាញផ្លូវជាតិនៅកម្ពុជា*




*ប្រភព៖ទូរគមនាគមន៍កម្ពុជា*

បណ្តាញផ្លូវជាតិ ជាផ្លូវក្រាលកៅស៊ូ និងស្ថានភាពស្ពាននៅតាមផ្លូវជាតិត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។

*តារាង១៥.២. ស្ថានភាពផ្លូវក្រាលកៅស៊ូនៃផ្លូវជាតិលេខ១ខ្ទង់ (ឯកត្តា៖គ.ម)*

| No | AC | DBST | DBST (fair) | ដីក្រហម | ដី | សរុប | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|
| ផ្លូវជាតិលេខ.១ | ៧៩,១ | ៨៧,១ | 0,0 | 0,0 | 0,0 | ១៦៦,២ | រួមមាន ៥៦ km (កំពុងបន្ត) |
| ផ្លូវជាតិលេខ.២ | ៥៧,៨ | ១៤,៣ | ៤៧,៩ | 0,0 | 0,0 | ១២០,០ | រួមមាន ៥១,៧ km (បញ្ចប់) |
| ផ្លូវជាតិលេខ.៣ | ១២,៨ | ៥៤,៣ | ១៣៥,២ | 0,0 | 0,0 | ២០២,៣ | រួមមាន ៣២,៨ km (បញ្ចប់) |
| ផ្លូវជាតិលេខ.៤ | ២១៤,២ | 0,0 | 0,0 | 0,0 | 0,0 | ២១៤,២ | |
| ផ្លូវជាតិលេខ.៥ | ៥៩,៨ | ៣៤៦,៧ | 0,0 | 0,0 | 0,0 | ៤០៦,៥ | |
| ផ្លូវជាតិលេខ.៦ | ១៩០,០ | ២២៣,៤ | 0,0 | 0,0 | 0,0 | ៤១៥,៥ | |
| ផ្លូវជាតិលេខ.៧ | ៦១,១ | ៤០២,៤ | 0,0 | 0,0 | 0,0 | ៤៦៣,៥ | បញ្ចប់ |
| ផ្លូវជាតិលេខ.៨ | 0,0 | 0,0 | 0,0 | ២២,៤ | ៨១,៧ | ១០៩,០៨ | Nouvelle route nationale en cours |

*ប្រភព៖ As-built Drawings, Design Drawings and Tender Drawings Collected by JICA Study Team*

*តារាង១៥.២. ស្ថានភាពផ្លូវក្រាលកៅស៊ូនៃផ្លូវជាតិលេខ១ខ្ទង់ (ឯកត្តា៖គ.ម)*

| | | | | | | | |
|---|---|---|---|---|---|---|---|
| សរុប | ៦៧៤,៨ | ១១២៨,២ | ១៨៣,០ | ២៤,៥ | ៤១,៧ | ២០៩៧,២៨ | |
| | **៣២,៩%** | **៥៥,00%** | **៨,៩%** | **១,២%** | **២,0%** | **១00%** | |

*ប្រភព៖ As-built Drawings, Design Drawings and Tender Drawings Collected by JICA Study Team*

*ចំណាំ៖ រាល់ផ្លូវជាតិ១ខ្ទង់ទាំងអស់ យ៉ាងហោចណាស់មានពីរគន្លង ខណៈដែល ៣៧,៨% នៃផ្លូវជាតិ ២ ខ្ទង់ ១៥% នៃផ្លូវខេត្ត មានគន្លងពីរ ឬច្រើន។*

តារាងខាងក្រោមបង្ហាញពីគុណភាពបណ្តាញផ្លូវ ដែលបង្ហាញពីចំនួនគន្លងដែលមាន។

*រូបភាព១៥.២. ប្រវែងផ្លូវយោងទៅតាមទទឹងផ្លូវ (ត្រឹមឆ្នាំ២០០៤)*




*ប្រភព៖ ការសិក្សារបស់ JICA, LRCS inventory, 2004 និង MRD inventory*

*ចំណាំ៖ ផ្លូវជាតិលេខមួយខ្ទង់ ទិន្នន័យសម្រាប់ w≥9.0m ជាក់ស្តែងគឺជាទិន្នន័យសម្រាប់ w≥10.0m និង 6.5m≤ w ≤9.0m*

### ១៥.១.១. ផ្លូវអន្តរជាតិ

ផ្នែកមួយនៃផ្លូវជាតិលេខ១ និងលេខ៥ គឺជាផ្នែកមួយនៃបណ្តាញមហាវិថីអាស៊ានលេខ១ ហើយផ្លូវជាតិ លេខ៤ លេខ៦ និងលេខ៧ គឺជាផ្នែកមួយនៃមហាវិថីអាស៊ានលេខ ១១។ ផ្លូវជាតិលេខ៤៨ លេខ៣ និងលេខ៣៣ គឺជាផ្នែកមួយនៃមហាវិថីអាស៊ានលេខ ១២៣ ហើយផ្លូវជាតិលេខ៦៦ និងលេខ៧៨ គឺជាផ្នែកមួយនៃមហាវិថីនៃមហាអនុតំបន់ទន្លេមេគង្គ (GMS)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រវែងផ្លូវសរុបលើតំបន់មួយនៅកម្ពុជាខុសប្លែកតែបន្តិចបន្តួចប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងផ្លូវនៅក្នុងប្រទេសជិតខាង។ ប៉ុន្តែ ការអភិវឌ្ឍផ្លូវថ្នល់នៅកម្ពុជានៅមិនទាន់គ្រប់គ្រាន់ឡើយ បើឆ្លុះបញ្ចាំងពីភាគរយតិចតួចនៃផ្លូវក្រាលកៅស៊ូ ធៀបនឹងប្រវែងផ្លូវសរុបនៅកម្ពុជា។

ការតភ្ជាប់តាមតំបន់ទាំងនេះត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។

*តារាង១៥.៣. ផ្លូវអន្តរជាតិនៅកម្ពុជា*

| ឈ្មោះផ្លូវអន្តរជាតិ | | | ទីក្រុងដែលឆ្លងកាត់ | ប្រវែង (km) | ចំណាត់ថ្នាក់ផ្លូវអន្តរជាតិ | | | | | ចំណុចមិនបានតភ្ជាប់ | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|
| ផ្លូវ GMS | មហាវិថីអាស៊ី | មហាវិថីអាស៊ាន | | | សំខាន់បំផុត | ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | ទាបជាងក្រុមទី៣ | | |
| ច្រកផ្ទៃកណ្ដាល | AH ១ | AH ១ | ប៉ោយប៉ែត -ស៊ីសុផុន -ភ្នំពេញ -ស្វាយរៀង -បាវិត (NR.1, NR.5) | ៥៧២.៤ | - | - | ១១.២ | ៥៦១.២* | | - | *១៣៧ km កែលម្អឱ្យទៅជាក្រុមទី២ (ជប៉ុន [៥៦ km] និង ADB [៨៧km]) |
| តភ្ជាប់ច្រកអន្តរជាតិ | AH ១១ | AH ១១ | ព្រះសីហនុ -ភ្នំពេញ -កំពង់ចាម -ស្ទឹងត្រែង -ត្រពាំងក្រៀល (NR៤, NR ៦, NR៧ ) | ៧៥៥ | - | - | ៣៦៤ | ៣៩១.០** | | - | **រួមបញ្ចូល ១៩៣ km កំពុងបន្តការស្តារផ្លូវជាថ្មី NR7 (មូលនិធិរបស់ចិន) |
| ច្រកឆ្នេរសមុទ្រខាងត្បូង | | AH ១២៣ | ចាំយៀម -កោះកុង -វាលរិញ -ស្រែអំបិល -កំពត -លក (NR៤៨, NR៣, NR៣៣ ) | ១៦៣.៣ | - | - | ២.៤ | ៨.៧ | ១៥២.២ | - | NR៤៨ផ្តល់មូលនិធិដោយប្រទេសថៃ NR៣៣ ផ្តល់មូលនិធិដោយ ADB |

*ប្រភព៖ JICA Study & MPWT Updated*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាង១៥.៣. ផ្លូវអន្តរជាតិនៅកម្ពុជា*

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ប៉ែកខាងជើង | | | សៀមរាប<br>-ព្រះវិហារ<br>-ស្ទឹងត្រែង<br>-រតនគីរី<br>-ព្រំដែនអូយ៉ាដាវ<br>(NR៦៦, NR៧៨) | ៤៦៤.៩ | - | - | | | ៤៦៤.៩ | - | NR៧៨ ផ្តល់មូលនិធិដោយវៀតណាម |
| ប្រវែងសរុប (km) | | | | ១៩៥៥.៦ | - | - | ៣៧៧.៦ | ៩៦០.៩ | ៦១៧.១ | - | |

*ប្រភព៖ JICA Study & MPWT Updated*

ចំណាត់ថ្នាក់ផ្លូវអន្តរជាតិមានដូចខាងក្រោម (ស្តង់ដារអាស៊ាន)៖

- ផ្លូវ [សំខាន់បំផុត] ត្រូវបានប្រើប្រាស់ទាំងស្រុងដោយយានយន្ត/ AC ឬក្រាលកៅស៊ូ
- ផ្លូវ [ថ្នាក់លេខ១] មានគន្លង៤ ឬច្រើន / AC ឬក្រាលកៅស៊ូ
- ផ្លូវ [ថ្នាក់លេខ២] មានគន្លង២ ឬច្រើន / AC ឬក្រាលកៅស៊ូ
- ផ្លូវ [ថ្នាក់លេខ៣] មានគន្លងពីរចង្អៀត / ក្រាល DBST

*រូបភាព. ១៥.៣a.*

*ការប្រៀបធៀបជាអន្តរជាតិនៃដង់ស៊ីតេផ្លូវ*




*រូបភាព. ១៥.៣b.*

*ការប្រៀបធៀបជាអន្តរជាតិនៃដង់ស៊ីតេផ្លូវក្រាលកៅស៊ូហើយ*




*ប្រភព៖ រូបភាព ១-៤ និង ១-៥ ត្រូវបានរៀបចំឡើងផ្អែកលើការសិក្សារបស់ JICA*

*រូបភាព១៥.៤.ប្រវែងផ្លូវ និងដង់ស៊ីតេប្រជាជន (ត្រឹមឆ្នាំ២០០៤)*

| | | | | |
|---|---|---|---|---|
| **Road** | | | | |
| 1-digit NR | | 2,097.28 km | | |
| 2-digit NR | | 2,704.37 km | | |
| Prov. Road | | 6,692.44 km | | |
| | Rural Road (L1) | 28,000.00 km | | |
| | NR and PR (L2) | 11,494.09 km | | |
| | Total length (L3) | 39,494.09 km | | |
| Land areas (A) | | 181,035 sqkm | | |
| **Population, P (x1000)** | | (in 2005) | PxA | (PxA)^0.5 |
| Total population | | 13,800.00 mill. | 2498283000 | 49982.83 |
| Rural | | 11,592.00 mill. | | |
| Urban | | 2,208.00 mill. | | |
| **Road density and Road density index** | | | | |
| Road density, RD=L/A (km/sqkm) | | 0.218 | (all roads) | |
| | | 0.063 | (National & Provincial roads) | |
| | | 0.155 | (Rural roads) | |
| Road density Index, RDI | | 0.790 | (all roads) | |
| RDI=L/(PxA)^0.5 | | 0.230 | (National & Provincial roads) | |
| | | 0.560 | (Rural roads) | |
| Total population/Total road length | | 350.00 Person/km | | |
| Rural population/Rural road length | | 414.00 Person/km | | |

*ប្រភព៖ ធនាគារពិភពលោក*

រូបភាព ១៥.៣. ពិពណ៌នាពីប្រជាជនសរុបប្រៀបធៀបទៅនឹងប្រវែងផ្លូវសរុប និងប្រជាជនជនបទធៀបទៅនឹងប្រវែងផ្លូវជនបទ។ ជាទូទៅ ទោះបីមានការខ្វះខាតខាងមធ្យោបាយដឹកជញ្ជូន ដែលគួរឱ្យជឿជាក់ និងមានប្រសិទ្ធភាពក៏ដោយ អ្នកក្រីក្រ គឺឋិតក្នុងចំណោមក្រុមចល័តក្នុងសង្គមខ្លាំងបំផុតនៅកម្ពុជា។ ទោះបីជាពួកគេមានឧបសគ្គច្រើនក្នុងការធ្វើដំណើរក៏ដោយ អ្នកក្រីក្រនៅតែធ្វើដំណើររុករកគ្រប់លទ្ធភាពទាំងអស់សម្រាប់ការរស់រាន ទោះនៅទីកន្លែងណាក៏ដោយ។ អ្នកក្រីក្រច្រើនរស់នៅប្រមូលផ្តុំគ្នានៅតាមទីតាំងដាច់ស្រយាល។ ហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវថ្នល់ ផ្លូវរថភ្លើង និងមធ្យោបាយផ្សេងទៀតសម្រាប់ធ្វើដំណើរដើរតួនាទីសំខាន់ណាស់ ក្នុងការបើកទូលាយតំបន់ដាច់ស្រយាល ដើម្បីឱ្យមានការអភិវឌ្ឍ និងធ្វើសមាហរណកម្មតំបន់ទាំងនេះ ចូលទៅក្នុងសេដ្ឋកិច្ចជាតិ។ ការដឹកជញ្ជូនចូលរួមចំណែកដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ដែលក្នុងនោះ វាអនុញ្ញាតឱ្យអ្នកក្រីក្រមានលទ្ធភាពទទួលបានធនធានដែលមានស្រាប់ និងធនធានដែលមាននៅតាមទីតាំងផ្សេងពីកន្លែងដែលពួកគេរស់នៅ។ ទន្ទឹមនឹងនេះ ចំណាកស្រុកពីទីជនបទទៅកាន់ទីក្រុងនឹងបន្តកើតមានឡើង ដោយសារអ្នកក្រីក្រអាចបន្តចល័តទៅតំបន់ទីក្រុង។ ដូច្នេះ រាជរដ្ឋាភិបាលត្រូវបន្តគ្រប់គ្រងដំណើរការនេះឱ្យបានល្អ។ ទន្ទឹមនឹងនេះ យើងសង្កេតឃើញមានចំណាកស្រុកទៅតាមខេត្តផ្សេងៗ ដើម្បីរកដីថ្មីសម្រាប់បង្កបង្កើនផល។

នៅពេលដែលមានគមនាគមន៍រីកលូតលាស់រវាងទីក្រុង និងទីជនបទ នោះឧត្តមភាពរបស់ទីក្រុងខាងផ្នែកដឹកជញ្ជូននឹងត្រូវកាត់បន្ថយបន្តិចម្តងៗ ដោយសារការកើនឡើងនៃវិនិយោគនៅតាមតំបន់ដែលត្រូវបានបើកទូលាយ តាមរយៈការអភិវឌ្ឍវិស័យដឹកជញ្ជូននេះ។ ប្រការនេះ គឺជាលទ្ធផលដ៏គួរឱ្យចង់បាន ពីព្រោះវានឹងជួយបង្កើនជីវភាពរស់នៅរបស់ជនក្រីក្រ នៅតាមទីកន្លែងដែលពួកគេកំពុងរស់នៅ និងកាត់បន្ថយគំនាបនៅទីក្រុង ដែលបណ្តាលមកពីការធ្វើចំណាកស្រុកពីជនបទ មកកាន់ទីក្រុង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នាពេលបច្ចុប្បន្ន សេវាដឹកជញ្ជូននៅទីក្រុងក៏មិនទាន់គ្រប់គ្រាន់នៅឡើយ។ អ្នករស់នៅតាមជាយក្រុងមានការពិបាកក្នុងការធ្វើដំណើរគ្រប់ពេល ទាំងថ្ងៃ ទាំងយប់។ រាជរដ្ឋាភិបាលកំពុងគិតគូរពីបញ្ហានេះ និងកំពុងពិភាក្សាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនដើម្បីរកដំណោះស្រាយសមស្រប។

## ១៥.២. បញ្ហាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ រួមទាំងផ្លូវថ្នល់ គឺជាឧបសគ្គចម្បង ក្នុងការពង្រីកវិស័យឯកជនដែលកំពុងលូតលាស់រស់រវើក។ ក្នុងឆ្នាំ១៩៩៨ បញ្ជីសារពើភ័ណ្ឌបានបង្ហាញឱ្យឃើញថា ២៨%នៃផ្លូវក្រាលកៅស៊ូ និង ៨២%នៃផ្លូវមិនក្រាលកៅស៊ូស្ថិតនៅក្នុងស្ថានភាពយ៉ាប់យ៉ឺន។

គេត្រូវដោះស្រាយបញ្ហារាំងស្ទះដោយសារហេដ្ឋារចនាសម្ព័ន្ធជាបន្ទាន់។ ស្ថិតក្នុងបរិបទនេះហើយដែលនៅក្នុងពិធិសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវជាតិថ្មីៗម្តងៗ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាតែងតែរំលឹកឃ្លាមួយថា "មានផ្លូវហើយ..." ដែលជំរុញឱ្យមានក្តីសង្ឃឹមថា អនាគតនឹងភ្លឺថ្លា។ ការប្រដូចការតភ្ជាប់ជោគវាសនានៃប្រទេស ទៅនឹងការអភិវឌ្ឍបណ្តាញផ្លូវថ្នល់ មានភាពត្រឹមត្រូវ។

គោលនយោបាយដឹកជញ្ជូនជើងគោករបស់រដ្ឋាភិបាល គឺចង់សម្រេចឱ្យបានលទ្ធផលជាដុំកំភួនតាមផ្នែកមួយចំនួន។ គោលបំណងនោះ គឺការបង្កើតបណ្តាញដឹកជញ្ជូនដ៏មានប្រសិទ្ធភាពមួយ ដែលចំណាយតិច និងមានការប្រកួតប្រជែងអាចទ្រទ្រង់កំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ បង្កើនលទ្ធភាពធ្វើជំនួញ អភិវឌ្ឍវិស័យទេសចរណ៍ និងធ្វើសមាហរណកម្មចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ អាទិភាពក្នុងរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យដឹកជញ្ជូនជើងគោក រួមមាន៖

- ការស្តារ និងការជួសជុលផ្លូវជាតិ និងផ្លូវខេត្តសំខាន់ៗ និងផ្លូវលំដាប់ទី៣ ដើម្បីលើកកម្ពស់ការធ្វើដំណើរ និងលទ្ធភាពតភ្ជាប់ទូទាំងប្រទេស។
- លើកកម្ពស់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធផលនៃហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងស្ថាប័នក៏ដូចជាដំណើរការប្រតិបត្តិ។
- ស្ថាបនាផ្លូវតភ្ជាប់ទៅប្រទេសជិតខាង ដើម្បីលើកកម្ពស់សមាហរណកម្មទីផ្សារ និងវិស័យទេសចរណ៍ក្នុងតំបន់។
- បង្កើនការកៀរគរធនធានពីវិស័យដឹកជញ្ជូនផ្លូវគោក ដើម្បីគ្របដណ្តប់យ៉ាងហោចណាស់ចំណាយលើការថែទាំ និងប្រតិបត្តិការ។
- ពង្រឹងសមត្ថភាពស្ថាប័នក្នុងការធ្វើផែនការ និងការគ្រប់គ្រង។
- ធ្វើកម្មវិធីថែទាំផ្លូវប្រកបដោយចីរភាព និង
- លើកទឹកចិត្តវិស័យឯកជន ដែលផ្តល់ហិរញ្ញវត្ថុដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។

ការកែលម្អ និងការឈូសឆាយផ្លូវជាច្រើនធ្វើឡើងនៅចន្លោះឆ្នាំ១៩៩១ និង២០០៤ ទន្ទឹមនឹងគម្រោងថ្មីៗសម្រាប់ការពង្រីកផ្លូវជាតិ។ គម្រោងស្ថាបនាផ្លូវជាតិថ្មីៗ និងកែលម្អផ្លូវត្រូវបាន ចាប់ផ្តើមអំឡុងឆ្នាំ ២០០២-

២០០៨ រួមមានការស្តារផ្លូវជាតិលេខ១ ចម្ងាយ៦០គ.ម. ពីភ្នំពេញទៅអ្នកលឿង ផ្លូវជាតិលេខ៥ និងលេខ៦ ប្រវែង១៥៤គ.ម (ប៉ោយប៉ែត ស៊ីសុផុន សៀមរាប) និង ផ្លូវជាតិលេខ៧ ប្រវែង១៩៨គ.ម ពីក្រចេះទៅព្រំដែនឡាវ ជាមួយនិងការកសាងស្ពានឆ្លងកាត់ទន្លេសេកុងនៅក្នុងខេត្តស្ទឹងត្រែង។

ទន្ទឹមនឹងនេះ យើងបានសង្កេតឃើញថា ការអភិវឌ្ឍនៃការដឹកជញ្ជូនជើងគោកកំពុងជួបប្រទះ នឹងបញ្ហាមួយចំនួន។ ទោះបីជារាជរដ្ឋាភិបាលបានផ្តល់អាទិភាពក្នុងការបង្កើនថវិកាជាតិ ក្នុងការស្តាបនាផ្លូវជាតិ បណ្តាញផ្លូវជាតិផ្លូវខេត្តនិងផ្លូវលំនៅមិនទាន់គ្របដណ្តប់យ៉ាងទូលំទូលាយនៅឡើយ។ការកាត់ចេញទាំងស្រុង ឬមួយផ្នែកនៃតំបន់ដាច់ស្រយាល ជាពិសេសនៅតាមតំបន់ព្រំដែន គឺជាហេតុផលដ៏គួរឱ្យព្រួយបារម្ភមួយ។ ស្ថានភាពជាទូទៅនៃបណ្តាញផ្លូវជាតិនៅតាមទីជនបទនៅមិនទាន់ល្អគួរសមនៅឡើយ។ ស្ថានភាពនេះត្រូវកែលម្អបន្ថែមទៀត ជាពិសេសត្រូវបង្កើនចំណាយបម្រុងទុក និងពង្រឹងគុណភាពនៃសំណង់។

ក្រៅផ្លូវសម្រាប់ដឹកជញ្ជូនរ៉ែ ផ្លូវថ្នល់ភាគច្រើន គឺបម្រើការធ្វើដំណើរធម្មតា និងការធ្វើពាណិជ្ជកម្ម។ វិស័យឯកជនដែលគ្រប់គ្រងការដឹកជញ្ជូនបានរួមចំណែកដល់ការអភិវឌ្ឍចរាចរជើងគោក។ ក៏ប៉ុន្តែ វិស័យឯកជនចូលរួមចំណែកយ៉ាងតិចតួច ក្នុងការអភិវឌ្ឍន៍មធ្យោបាយធ្វើដំណើរជើងគោកដទៃទៀត (ការធ្វើដំណើរតាមផ្លូវដែក និងតាមទន្លេ)។ តែទោះជាយ៉ាងណា ប្រព័ន្ធដឹកជញ្ជូនផ្លូវគោកសម្រាប់ទំនិញ និងប្រជាជន នៅមានលក្ខណៈក្រៅផ្លូវការ និងទាមទារឱ្យមានការកែលម្អ។ ប្រភេទយានជំនិះដែលប្រើជាញឹកញាប់ នៅមិនបានបំពេញតាមតម្រូវការរបស់អ្នកប្រើប្រាស់នៅឡើយ ជាពិសេសសម្រាប់ទំនិញដែលងាយខូច។ ជាងនេះទៅទៀត នៅមិនទាន់មានការសម្របសម្រួលរវាងអ្នកបញ្ជូន និងអ្នកដឹកទំនិញ ដែលបណ្តាលឱ្យមិនមានភាពស៊ីគ្នារវាងតម្រូវការ និងសមត្ថភាព។

## ១៥.៣. ការផ្តល់មូលនិធិអភិវឌ្ឍន៍ផ្លូវថ្នល់

ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ មក ជំនួយបរទេស គឺជាប្រភពហិរញ្ញប្បទានដ៏សំខាន់ មួយសម្រាប់ការកែលម្អបណ្តាញផ្លូវថ្នល់។ កម្មវិធីនេះរួមមានការងារជួសជុលជាបន្ទាន់ និងការស្តារមួយលើកលើបណ្តាញផ្លូវថ្នល់ប្រវែង ៤.៨០០គ.ម. និងការថែទាំផ្លូវដែលជួសជុលរួច។ រាជរដ្ឋាភិបាលផ្តល់អាទិភាពដល់ការសាងសង់ផ្លូវជាតិសំខាន់ៗ (ផ្លូវជាតិលេខ១ ដល់ផ្លូវជាតិលេខ៧) និងផ្លូវខេត្តដែលតភ្ជាប់ប្រទេសកម្ពុជា ជាមួយប្រទេសជិតខាង និងផ្លូវដែលតភ្ជាប់ពីខេត្តមួយទៅខេត្តមួយទៀត។

ប្រទេសជប៉ុន គឺជាម្ចាស់ជំនួយនាំមុខគេក្នុងវិស័យផ្លូវថ្នល់នេះ។ គម្រោងសំខាន់ៗនៃជំនួយជប៉ុនរួមមានស្ពានមិត្តភាពកម្ពុជា-ជប៉ុននៅភ្នំពេញ ស្ពានគីហ្សូណានៅកំពង់ចាម និងស្ពានតឺស៊ឺបានៅអ្នកលឿង។ ជប៉ុនបានផ្តល់ទឹកប្រាក់ជិត ២៤២ លានដុល្លារអាមេរិកសម្រាប់ការដ្ឋានការងារទាំងនេះ។ ធនាគារអភិវឌ្ឍអាស៊ី គឺជាម្ចាស់ជំនួយទីពីរ ដោយផ្តល់ជំនួយ ១៦២ លានដុល្លារអាមេរិក បន្ទាប់មកធនាគារពិភពលោក (៣២លានដុល្លារ) កូរ៉េខាងត្បូង (២១ លានដុល្លារ) និងបារាំង (៣ លានអឺរ៉ូ) ។ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយជិត ១០០លានដុល្លារពីថវិកាជាតិទៅលើការថែទាំ និងការជួសជុលបណ្តាញផ្លូវ។

*តារាង១៥.៥. ចំណាយសម្រាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់*
*២០០១-២០០៤ (គិតជាលានដុល្លារ)*

| | ២០០១ | ២០០២ | ២០០៣ | ២០០៤ |
|---|---|---|---|---|
| សាធារណៈនិងដឹកជញ្ជូន | ១៣.៧២ | ២១.៦៩ | ១៩.០៤ | ១៨.០០ |
| ចំណាយចរន្ត | ១.៩៩ | ៣.១៤ | ៩.៨៣ | ១០.០០ |
| ចំណាយមូលធន | ១១.៧៣ | ១៨.៥៥ | ៩.២១ | ៨.០០ |
| អភិវឌ្ឍជនបទ | ៥.៩៥ | ១២.១៦ | ១៦.៩៦ | ៣៥.២៤ |
| ចំណាយចរន្ត | ០.៥៥ | ១.៣៨ | ១.៥ | ១.០០ |
| ចំណាយមូលធន | ៥.៤០ | ១០.៧៨ | ១៥.៤៦ | ៣៤.២៤ |
| ម្ចាស់ជំនួយ | ៥៩..៧១ | ៧៦.៤៣ | ១២១.៥៦ | ១១១.៥៥ |
| សរុប | ៧៩.៣៨ | ១១០.២៨ | ១៥៧.៥៦ | ១៦៤.៧៩ |

*ប្រភពៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ១៥.៣.១.គម្រោងអភិវឌ្ឍន៍ផ្លូវថ្នល់

សម្រាប់គោលដៅរៀបចំផែនការដឹកជញ្ជូន ប្រទេសកម្ពុជាត្រូវបានបែងចែកទៅជាតំបន់សេដ្ឋកិច្ចបីៈ ១). តំបន់ទេសចរណ៍ (ខេត្តសៀមរាប ឧត្តរមានជ័យ ព្រះវិហារ និងកំពង់ធំ) ២). តំបន់អេកូទេសចរណ៍ និងកសិឧស្សាហកម្ម (តំបន់ប៉ូព៌ានៃទន្លេមេគង្គ រួមមានខេត្តស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងក្រចេះ) និង៣). តំបន់ឧស្សាហកម្មដែលគ្របដណ្តប់តំបន់ឆ្នេរនៃភាគនីរតី ប្រទេស។ ស្ថានភាពភូមិសាស្ត្រអំណោយផល អាចបង្កលក្ខណៈឱ្យកម្ពុជាក្លាយទៅជាមជ្ឈមណ្ឌលដឹកជញ្ជូនមួយក្នុងមហាអនុតំបន់ទន្លេមេគង្គ។ ដូច្នេះ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់ដល់ការអភិវឌ្ឍបណ្តាញផ្លូវថ្នល់ឆ្លងកាត់ប្រទេស។ ផ្លូវជាតិសំខាន់ៗត្រូវចាត់ទុកថាជាមហាវិថីអាស៊ានក្នុងតំបន់ទាំងមូលដើម្បីលើកកម្ពស់ការដឹកជញ្ជូនពាណិជ្ជកម្មនិងទេសចរណ៍ឆ្លងកាត់ប្រទេស។ ផ្លូវបន្ទាប់បន្សំតាមខេត្ត និងជាតិផ្សេងៗទៀតចាត់ទុកថាមិនត្រឹមតែបម្រើជាផ្លូវតភ្ជាប់ទៅមហាវិថីអាស៊ានក្នុងតំបន់ ឬផ្លូវជាតិសំខាន់ៗផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងការតភ្ជាប់រវាងមជ្ឈមណ្ឌលសេដ្ឋកិច្ចផ្សេងៗរបស់ប្រទេសផងដែរ។

នៅក្នុងកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គនេះ គម្រោងស្តាបនាផ្លូវខាងក្រោមនឹងត្រូវបានអនុវត្តៈ

*តារាង១៥.៦. គម្រោងស្តាបនាផ្លូវដោយហិរញ្ញប្បទានក្រៅប្រទេស*

| ប្រភេទគម្រោង | ទំហំ | ប្រភព | ឆ្នាំចាប់ផ្តើម | ឆ្នាំបញ្ចប់ | តម្លៃគម្រោង |
|---|---|---|---|---|---|
| ការស្តារការខូចខាតផ្លូវឡើងវិញ | RN5 | ថៃ | ១៩៩២ | ១៩៩៣ | ៦,៤ |
| ការជួសជុលជាបន្ទាន់ | RN5 | PNUD | ១៩៩២ | ១៩៩៣ | ០,៤ |
| ការសាងសង់ស្ពានឡើងវិញ | RN 5, 6 | AusAID | ១៩៩២ | ១៩៩៦ | ៩ |
| ការស្តារការខូចខាតផ្លូវឡើងវិញa | RN 1,2,3,5,6,11 | ADB | ១៩៩៣ | ១៩៩៧ | ៦៧,៧ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

| | | | | | |
|---|---|---|---|---|---|
| ការស្តារការខូចខាតផ្លូវឡើងវិញ | Divers | Sida | ១៩៩៣ | ១៩៩៧ | ៥ |
| ការសាងសង់ផ្លូវឡើងវិញ | RN 4 | USAID | ១៩៩៤ | ១៩៩៦ | ៣០,៦ |
| ការសាងសង់ផ្លូវឡើងវិញ | RN 6,7 | ជប៉ុន | ១៩៩៤ | ១៩៩៩ | ១០៩ |
| ការស្តារការខូចខាតសាឡាង ឡើងវិញ | RN 1,2,5,6,7,11, 21, 41 | Danida | ១៩៩៥ | ១៩៩៩ | ២,៥ |
| ការកែលម្អ អាកាសយាន្តដ្ឋាន | សៀមរាប | ADB | ១៩៩៧ | ២០០៣ | ១៥ |
| ការសាងសង់ស្ពាន | RN 7 | ជប៉ុន | ១៩៩៨ | ២០០១ | ៥៣,២ |
| ការកែលម្អឡើងវិញ | RN 1 | ADB | ១៩៩៩ | ២០០៣ | ៥០,៥ |
| ការជួលជុលដោយទឹកជំនន់ ជាបន្ទាន់[a] | RN 1,2,5,6,7, 11, 21, 41 | ADB | ២០០០ | ២០០២ | ៦៥ |
| ការស្តារការខូចខាតផ្លូវឡើងវិញ | RN 5,6,7 | ADB | ២០០០ | ២០០៣ | ៧៤,៨ |
| ការធ្វើផ្លូវឱ្យប្រសើរឡើង | RN 6 | ជប៉ុន | ២០០១ | ២០០២ | ១០,៤ |
| ការកសាងស្ពានឡើងវិញ | RN 6 | ជប៉ុន | ២០០១ | ២០០២ | ១១,៣ |
| ការធ្វើផ្លូវឱ្យប្រសើរឡើង | RN 7 | ជប៉ុន | ២០០១ | ២០០៣ | ១៥,៤ |
| ទំនើបកម្មកំពុងផែ | ព្រះសីហនុ | ជប៉ុន | ២០០១ | ២០០៧ | - |
| ជួលជុលដោយទឹកជំនន់ ជាបន្ទាន់[a] | RN 11 | ADB | ២០០២ | ២០០៣ | ១៤ |
| ការស្តារការខូចខាតផ្លូវឡើងវិញ | RN 51 | ជប៉ុន | ២០០២ | ២០០៣ | ៥ |
| ការស្តារការខូចខាតផ្លូវឡើងវិញ | RN 2 | ជប៉ុន | ២០០២ | ២០០៣ | ១០ |
| ការជួលជុលដោយទឹកជំនន់ ជាបន្ទាន់[a] | Divers | ធានាគារ ពិភពលោក | ២០០២ | ២០០៤ | ៥០ |
| ការសាងសង់ផ្លូវ | RN 48 | ថៃ | ២០០២ | ២០០៤ | ៧,៦ |
| ការស្តារការខូចខាតផ្លូវឡើងវិញ | RN 3, 6 | ធានាគារ ពិភពលោក | ២០០២ | ២០០៤ | ៤៥ |
| ការស្តារការខូចខាតផ្លូវឡើងវិញ | RN 51 | ធានាគារ ពិភពលោក | ២០០២ | ២០០៤ | ៥ |
| ការធ្វើផ្លូវឱ្យប្រសើរឡើងវិញ | RN 1 | ជប៉ុន | ២០០៣ | ២០០៥ | ៣១,២ |
| ការសាងសង់ផ្លូវឡើងវិញ | RN 48 | ថៃ | ២០០៦ | ២០០៨ | - |
| ការស្តារការខូចខាតផ្លូវឡើងវិញ | RN 5,6,56,68 | ADB | ២០០៦ | ២០០៨ | ៦០ |
| ការកសាងស្ពាន | RN 1 | ជប៉ុន | ២០០៧ | ២០០៩ | - |
| ការថែទាំផ្លូវ | RN 33, 56, 68,72 | ADB | ២០០៨ | ២០១១ | - |
| សរុប | | | | | ៧៥៤ |

*ប្រភពៈក្រសួងសាធារណៈការ និងដឹកជញ្ជូន*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១). កសាងផ្លូវជាតិលេខ៦ឡើងវិញៈ កំពុងបន្តដើម្បីតភ្ជាប់សៀមរាប និងប្រាសាទអង្គរវត្តទៅនឹងភ្នំពេញ និងប៉ោយប៉ែត (នៅព្រំដែនខ្មែរ.ថៃ)។

២). កែលម្អផ្លូវជាតិលេខ១ និងលេខ៥ៈ ឋិតក្នុងដំណាក់ដំបូងនៃគម្រោងសាងសង់តភ្ជាប់ ទីក្រុងហូជីមិញ ភ្នំពេញ និងបាងកក (ច្រកផ្នែកកណ្ដាលនៃមហាអនុតំបន់ទន្លេមេគង្គ) កាត់កម្ពុជា។ ផ្លូវជាតិលេខ៤៨ លេខ៣ និងលេខ៣១ (ច្រកឆ្នេរខាងត្បូង) នឹងត្រូវបានស្ដារឡើងវិញ ដើម្បីភ្ជាប់ខេត្តសីហនុទៅនឹងកំពង់ផែបាងកក និងកំពង់ផែអន្តរជាតិផ្សេងទៀត។

៣). ដោយមានការគាំទ្រពីប្រទេសចិន ផ្លូវជាតិលេខ៧ នឹងត្រូវបានស្ដារឡើងវិញភ្ជាប់ភាគខាងត្បូងនៃប្រទេសឡាវមកខេត្តក្រចេះ ភ្នំពេញ និងខេត្តសីហនុឆ្លងផ្លូវជាតិលេខ៤ និងដោយការកសាងស្ពានឆ្លងទន្លេមេគង្គ នៅខេត្តកំពង់ចាម តាមរយៈជំនួយរបស់ប្រទេសជប៉ុន។

៤). ផ្លូវជាតិលេខ៤ នឹងត្រូវបានពង្រីកដើម្បីភ្ជាប់ខេត្តសីហនុ ដែលជាបេះដូងនៃតំបន់ពាណិជ្ជកម្ម និងឧស្សាហកម្មរបស់ប្រទេសទៅនឹងកំពុងផែបាងកក និងកំពុងផែអន្តរជាតិផ្សេងទៀត ដែលជួយសម្រួលការដឹកជញ្ជូនទំនិញ។ សរសៃឈាមនេះមានសក្ដានុពលបំផុតសម្រាប់ការពង្រីកពាណិជ្ជកម្មតំបន់។

៥). ក្រោមកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងកម្ពុជា និងថៃ ផ្លូវខេត្ត និងផ្លូវលំដាប់លេខ២ ដែលភ្ជាប់ទៅនឹងព្រំដែនកម្ពុជា-ថៃ (ផ្លូវជាតិលេខ៥៦ លេខ៥៧ លេខ៥៩ លេខ៦៨ លេខ៦៩ លេខ៦៤។ល។) នឹងត្រូវបានកែលម្អឡើងវិញ។ ការកែលម្អផ្លូវជាតិលេខ៧៨, លេខ៧៦A, លេខ៧៨B, លេខ៧៦, និង លេខ៧២ ឡើងវិញ ក៏ដូចជាផ្លូវខេត្ត (លេខ៣០៣A និង៣០៣B) ក្នុងខេត្តរតនគីរី និងមណ្ឌលគីរី នឹងជួយសម្រួលការដឹកជញ្ជូនទំនិញ និងចរាចរតាមព្រំដែន។

## ១៤.៣.២. ការថែទាំផ្លូវ

នាពេលបច្ចុប្បន្ន ផ្លូវសំខាន់ៗរបស់ប្រទេស ទាំងផ្លូវជាតិ និងខេត្តមានប្រវែង ៦,០០០គ.ម. ដែលក្នុងនោះពាក់កណ្ដាលនោះគឺបានចាក់កៅស៊ូ។ ផ្លូវជាតិប្រវែង ២,០០០គ.ម. ក្នុងនោះ៨០% ហើយ ដែលបានចាក់កៅស៊ូ ដែលក្នុងគីឡូម៉ែត្រនីមួយៗមានតម្លៃចន្លោះពី ២០,០០០ ដុល្លារដល់ ៣០០,០០០ដុល្លារ។ ការផ្ដល់មូលនិធិឱ្យបានគ្រប់គ្រាន់សម្រាប់ការថៃទាំផ្លូវមានសារសំខាន់ណាស់សម្រាប់កម្ពុជា ដើម្បីទទួលបានផលចំណេញពេញលេញពីផ្លូវដែលមានស្រាប់នេះ។ ធនធានចម្បងនៃមូលនិធិសម្រាប់ការថៃទាំបណ្ដាញផ្លូវនេះគឺបានមកពីប្រាក់ចេញអាជ្ញាប័ណ្ណយានយន្ត ពន្ធចតឆ្លងកាត់ ប្រាក់ធ្វើដំណើរឆ្លងកាត់អន្តរជាតិ ពន្ធប្រមូលបានពីប្រេងឥន្ធនៈ និងពន្ធផ្សេងទៀតដែលពាក់ព័ន្ធនឹងផ្លូវ។ មានការប៉ាន់ប្រមាណថា គេត្រូវការ ១០០លានដុល្លារក្នុងមួយឆ្នាំ សម្រាប់ការស្ដារឡើងវិញនូវបណ្ដាញផ្លូវចម្បង និងបន្ទាប់បន្សំរួមទាំងពី ៣០ ទៅ ៤០លានដុល្លារសម្រាប់ការថៃទាំ។ បន្ថែមពីនេះ គេត្រូវការប្រហែល ៥០ លានដុល្លារ ក្នុងមួយឆ្នាំសម្រាប់ការស្ដារឡើងវិញ និងការថៃទាំផ្លូវជនបទ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលត្រូវផ្ដល់អាទិភាពដល់តម្រូវការនេះ ហើយធ្វើគម្រោងលម្អិតសម្រាប់ការកែលម្អ និងការថៃទាំបណ្ដាញផ្លូវថ្នល់ទាំងនេះដែលជាទ្រព្យសម្បត្តិរបស់ជាតិ។ នៅក្នុងនីតិកាលទីបី (២០០៣-២០០៨) នៃរាជរដ្ឋាភិបាលកម្ពុជា រាជរដ្ឋាភិបាលបានផ្ដល់អាទិភាពដល់ការស្ដារ និងជួសជុលផ្លូវជាតិ និងផ្លូវសំខាន់ៗជាង ២,០០០គ.ម. និងផ្លូវខេត្តជាង ១,០០០គ.ម.។ ថវិកាគ្រប់គ្រង និងថែទាំផ្លូវថ្នល់សម្រាប់ឆ្នាំ ២០០៧ បានកើនឡើងទ្វេដង បើប្រៀបធៀបនឹងឆ្នាំ២០០៦ ដែលបង្ហាញឱ្យឃើញពីការយល់ដឹងកាន់តែខ្លាំងនៃសារៈសំខាន់ក្នុងការថែទាំផ្លូវ។

| រូបភាព. ១៥.៤.ក មូលនិធិថែទាំផ្លូវ | រូបភាព. ១៥.៤.ខ ថ្លៃថែទាំផ្លូវ |
|---|---|




| | Longueur | Coûts de l'entretien (103 Riels) | Coûts de l'entretien (US$) | Coût unitaire (US$/km) |
|---|---|---|---|---|
| Routes nationales | 1730,59 km | 19 730 359 | 4 812 283 | 2 780 |
| Routes urbaines | 238,46 km | 2 330 902 | 568 513 | 2 384 |
| Total | 1 969,05 km | 22 061 261 | 5 380 796 | 2 732 |

*ប្រភព៖ ក្រសួងសាធារណៈការ និងដឹកជញ្ជូន*

## ១៤.៣.៣. ស្ថានភាពបច្ចុប្បន្ននៃចរាចរផ្លូវគោក

ចំនួនយានយន្តដែលបានចុះបញ្ជីបាន និងកំពុងកើនឡើងតាមអត្រាប្រហែល ១០% ក្នុងមួយឆ្នាំ ហើយមានចំនួនលើសពី ៤៨០,០០០ គ្រឿងក្នុងឆ្នាំ ២០០៤។ ប្រហែល ៧០%នៃយានយន្តដែលបានចុះបញ្ជីទាំងអស់ គឺជាទោចក្រយានយន្ត។

| រូបភាព. ១៥.៥a. និន្នាការក្នុងចំនួនយានយន្តដែលចុះបញ្ជី | រូបភាព. ១៥.៥a. ការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ នៃចំនួនយានយន្តដែលបានចុះបញ្ជី |
|---|---|







*ប្រភព៖ ស្ថិតិប្រចាំឆ្នាំ ២០០៦, វិទ្យាស្ថានស្ថិតិជាតិ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១៤.៣.៤. សុវត្ថិភាពផ្លូវ

*រូបភាព. ១៥.៦a. ការវាយតម្លៃគ្រោះថ្នាក់នៅលើផ្លូវ*




*រូបភាព. ១៥.៦b. ការប្រៀបធៀបគ្រោះថ្នាក់លើដងផ្លូវ*




*ប្រភព៖ ការសិក្សារបស់ JICA, នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក និងគណៈកម្មការសុវត្ថិភាពផ្លូវ, ក្រសួងសាធារណៈការ និងដឹកជញ្ជូន*

ចំនួនមនុស្សដែលមានយានយន្តជាកម្មសិទ្ធិកាន់តែច្រើនឡើងៗ ក្នុងប៉ុន្មានឆ្នាំចុងក្រោយ នេះ។ ឆ្លុះបញ្ចាំងពីការកើនឡើងនៃដង់ស៊ីតេយានយន្តដែលចរាចរតាមដងផ្លូវ និងនិន្នាការនៃអ្នកបើកបរយានជំនិះដែលមិនគោរពច្បាប់ចរាចរនោះ អត្រាមរណៈដោយឧបទ្ទវហេតុក្នុង ១០.០០០ យានយន្តកំពុងកើនឡើង ហើយមានកម្រិតខ្ពស់ជាងប្រទេសជិតខាង។ អត្រាមរណៈនៅកម្ពុជាមានចំនួន ២១,៥ ករណីក្នុងយានយន្ត ១០.០០០គ្រឿង បើប្រៀបធៀបជាមួយវៀតណាមមានតែ ៨,៣៤ ករណី និងជាមួយថៃ មាន ៥,៩១ ករណី (ការប៉ាន់ស្មានឆ្នាំ ២០០៣) និងនៅជប៉ុនមានតែ ០,៩៥ករណី ។

*រូបភាព. ១៥.៧a. ចំនួនគ្រោះថ្នាក់តាមប្រភេទនាក់ប្រើប្រាស់ផ្លូវ (២០០៤)*




*រូបភាព. ១៥.៧b. មូលហេតុនៃគ្រោះថ្នាក់លើផ្លូវ (២០០៤)*




*ប្រភព៖ ការសិក្សារបស់ JICA, នាយកដ្ឋានដឹកជញ្ជូនផ្លូវគោក និងគណៈកម្មការសុវត្ថិភាពផ្លូវ, ក្រសួងសាធារណៈការ និងដឹកជញ្ជូន*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១៥.៤. ផ្លូវរថភ្លើងនៅកម្ពុជា

### ១៥.៤.១. ស្ថានភាពបច្ចុប្បន្ននៃផ្លូវរថភ្លើងនៅកម្ពុជា

ប្រព័ន្ធផ្លូវរថភ្លើងរបស់កម្ពុជាមានពីរខ្សែដែលមានគន្លងប្រវែង១ម៉ែត្រ៖ ខ្សែទី១ ភ្ជាប់ភ្នំពេញទៅនឹងស៊ីសុផុន និងខ្សែទី២ ភ្ជាប់ភ្នំពេញទៅនឹងខេត្តព្រះសីហនុ។ ផ្លូវរថភ្លើងទាំងនេះត្រូវបានកសាងក្នុងឆ្នាំ១៩២៩។ មុននឹងធ្វើការជួសជុល ផ្លូវនេះចាស់ទ្រុឌទ្រោមណាស់ហើយ គេអាចធ្វើដំណើរត្រឹមល្បឿនអតិបរិមា៣០-៣៥គ.ម/ម។ តួរថភ្លើងរួមមានក្បាលម៉ាស៊ីនរថភ្លើង១០ ទូអ្នកដំណើរ៥ស៊ីទែន ទូប្រេង៣៥ ទូដឹកទំនិញ៨០។

*តារាង ១៥.៧. ហេដ្ឋារចនាសម្ព័ន្ធផ្លូវរថភ្លើង*

| ប្រភេទ | ខ្សែរថភ្លើងខាងជើង (NL) | ខ្សែរថភ្លើងខាងត្បូង (SL) |
|---|---|---|
| ប្រវែង (km) | ៣៨៥ (រួមបញ្ចូល ៤៨km ដែលមិនបានតភ្ជាប់) | ២៦៤km |
| ផ្នែក | ភ្នំពេញ-ពោធិ៍សាត់-បាត់ដំបង-មង្គលបុរី-ប៉ោយប៉ែត | ភ្នំពេញ-តាកែវ-កំពត-ព្រះសីហនុ |
| ស្ថានីយ (ចំនួន) | ៤៩ (៧ កំពុងប្រតិបត្តិការ) | ២៧ (៥ កំពុងប្រតិបត្តិការ) |
| ឆ្នាំសាងសង់ | ១៩២៩ – ១៩៤២ | ១៩៦០ - ១៩៦៩ |

ការអភិវឌ្ឍប្រព័ន្ធផ្លូវរថភ្លើងចាប់ផ្តើមក្នុងឆ្នាំ១៩២៩ ពេលនោះការងារបានចាប់ផ្តើមលើខ្សែរថភ្លើងប្រវែង៣៨៦គ.ម. ពីភ្នំពេញទៅប៉ោយប៉ែត។ គំរោងនេះត្រូវបានបញ្ចប់ក្នុងឆ្នាំ១៩៤២។ តែទោះជាយ៉ាងណាខ្សែពីស៊ីសុផុនទៅប៉ោយប៉ែតត្រូវបានបំផ្លាញទាំងស្រុងក្នុងអំឡុងសង្គ្រាមក្នុង ទសវត្សរ៍ឆ្នាំ១៩៧០។ ខ្សែពីភ្នំពេញទៅក្រុងព្រះសីហនុត្រូវបានចាប់ផ្តើមក្នុងឆ្នាំ១៩៦០ និងបញ្ចប់ក្នុងឆ្នាំ១៩៦៩។ ជាអកុសល សង្គ្រាមជាច្រើនទសវត្សរ៍បានបន្សល់ទុកមកទល់សព្វថ្ងៃ នូវប្រព័ន្ធផ្លូវរថភ្លើងមួយដែលគ្មានការអភិវឌ្ឍ និងមិនមានប្រសិទ្ធភាព។

ទោះបីវាមានប្រវត្តិអាយុ ៧៥ឆ្នាំក៏ដោយ ផ្លូវដែកប្រទេសកម្ពុជាមិនបានតភ្ជាប់ទំនាក់ទំនងក្នុងប្រព័ន្ធផ្លូវរថភ្លើងដ៏សំខាន់របស់អាស៊ាន ពីសិង្ហបុរី ទៅគុនមីងទេ។

### ១៥.៤.២. ស្ថានភាពនៃការប្រើប្រាស់ផ្លូវដែក

សេវាកម្មរថភ្លើងបានចាប់ផ្តើមចុះថយក្នុងឆ្នាំ២០០២។ ក្នុងឆ្នាំ២០០៥ ជាអតិបរិមារថភ្លើងដំណើរការ៣ជើងក្នុងមួយថ្ងៃលើខ្សែរថភាគខាងជើង និង១ជើងតែប៉ុណ្ណោះក្នុងមួយថ្ងៃ លើខ្សែរថភាគខាងត្បូង។ បរិមាណនៃការដឹកជញ្ជូនទំនិញតាមផ្លូវដែកបានចាប់ផ្តើមធ្លាក់ចុះជាបន្តបន្ទាប់ ពីចំនួន៥៥៧.០០០ តោនក្នុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឆ្នាំ ២០០២ ដោយសារការប្រកួតប្រជែងជាមួយចរាចរផ្លូវគោក។ ខ្សែរថភាគខាងជើងភាគច្រើនដឹកស៊ីម៉ង់ត៍ ខណៈដែលខ្សែរថភាគខាងត្បូងភាគច្រើនដឹកស៊ីម៉ង់ត៍ និងផលិតផលប្រេង។

*រូបភាព. ១៥.៨. ចំនួនរថភ្លើងដែលដឹកជញ្ជូនក្នុងមួយឆ្នាំ ដោយរាជាយស្ម័យយាន*




| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|
| NL-Freight | 306 | 567 | 1,20 | 216 | 294 | 654 | 804 | 699 | 521 |
| SL-Freight | 485 | 482 | 504 | 919 | 779 | 351 | 428 | 409 | 522 |
| NL-Messenger | 474 | 344 | 242 | 345 | 356 | 244 | 48 | 46 | 26 |
| SL-Messenger | 294 | 301 | 299 | 255 | 0 | 0 | 0 | 0 | 0 |

*ប្រភព៖GMS Rehabilitation of the Railway in Cambodia, Final Report (volume 1),*

*November 2006, ADB TA6251-REG (Source:RRC)*

ចំនួនអ្នកធ្វើដំណើរតាមរថភ្លើងបានធ្លាក់ចុះយ៉ាងខ្លាំងបន្ទាប់ពីឆ្នាំ២០០០ នេះបណ្ដាលមកពីភាពប្រសើរឡើងនៃផ្លូវជាតិលេខ៥ និងលេខ៦។ ក្នុងឆ្នាំ២០០៥ ដំណើរការរថភ្លើងមានប្រហែលមួយភាគដប់នៃឆ្នាំ១៩៩៨ ដែលជាឆ្នាំដែលមានដំណើរការរថភ្លើងច្រើនបំផុត។ ខ្សែរថខាងត្បូងបានបញ្ឈប់ប្រតិបត្តិការដឹកអ្នកដំណើរក្នុងឆ្នាំ២០០៤។ នៅខ្សែរថខាងជើង ចំនួនសេវាកម្មដំណើរទៅមកត្រូវបានកាត់បន្ថយពីមួយដងក្នុងមួយថ្ងៃ ទៅមួយដងក្នុងមួយសប្ដាហ៍ ដោយសារតែការធ្លាក់ចុះនៃចំនួនអ្នកធ្វើដំណើរ។ បច្ចុប្បន្នរថភ្លើងមួយដែលមានទាំងទូអ្នកធ្វើដំណើរ និងទូដឹកទំនិញដំណើរការរវាងភ្នំពេញ និងបាត់ដំបង។

*រូបភាព. ១៥.៩a. និន្នាការចំនួនដឹកជញ្ជូនទំនិញតាមរថភ្លើង*




| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|
| Southern Line | 86,15 | 79,12 | 202,6 | 208,2 | 203,6 | 300,6 | 211,8 | 94,79 | 114,3 | 121,7 | 181,6 |
| Northern Line | 208,0 | 189,2 | 137,4 | 201,4 | 353,6 | 122,5 | 85,35 | 174,0 | 203,1 | 193,6 | 52,18 |

*រូបភាព. ១៥.៩b. និន្នាការនៃចំនួនដឹកជញ្ជូនតាមផលិតផល*




| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|
| NL-PP | 18,78 | 12,95 | 11,59 | 27,22 | 23,47 | 18,94 | 15,16 | 9,240 | 10,60 | 21,19 | 7,952 |
| NL-Cement | 184,0 | 157,0 | 26,62 | 78,52 | 230,0 | 43,67 | 48,14 | 159,4 | 18,40 | 171,6 | 33,87 |
| SL-PP | 20,08 | 14,00 | 12,87 | 35,09 | 80,81 | 114,8 | 117,9 | 69,88 | 62,64 | 61,40 | 42,87 |
| SL-Cement | 40,74 | 52,36 | 161,4 | 156,6 | 96,97 | 175,6 | 87,83 | 24,91 | 51,55 | 26,66 | 98,39 |

*ប្រភព៖ ត្រូវបានរៀបចំដោយផ្អែកទៅលើ ការសាងសង់ឡើងវិញផ្លូវរថភ្លើងក្នុងប្រទេសកម្ពុជា, ផែនការសកម្មភាពនិងរបាយការណ៍យុទ្ធសាស្ត្រ, ADB and GMS Rehabilitation of the Railway in Cambodia, របាយការណ៍បញ្ចប់ (លេខ II), វិច្ឆិកា 2006, ADB.*

ទោះបីមានអត្ថប្រយោជន៍ច្រើនពីប្រព័ន្ធផ្លូវរថភ្លើងនេះក៏ដោយ ក៏ប្រទេសកម្ពុជានៅតែមិនអាចប្រើប្រាស់សក្ដានុពលនេះ ឱ្យបានពេញលេញនៅឡើយ។ ផ្លូវរថភ្លើងស្ទើរតែគ្មានសកម្មភាពទៅហើយ ដូចត្រូវបានបង្ហាញក្នុងរូបភាព១៥.៩ រថភ្លើងអ្នកធ្វើដំណើរតែមួយគ្រឿងក្នុងមួយថ្ងៃជាមធ្យមក្នុងឆ្នាំ ២០០៤។ ការធ្វើ

ចរាចរតាមផ្លូវរថភ្លើងដែលមានសុវត្ថិភាព និងគួរឱ្យទុកចិត្តបាននឹងផ្តល់អត្ថប្រយោជន៍ដល់កម្ពុជាមួយចំនួនៈ (១) កាត់បន្ថយចរាចរយានយន្តធុនធំលើផ្លូវថ្នល់ ដូច្នេះនាំឱ្យកាត់បន្ថយការចំណាយលើការថែទាំ និងការពង្រីកផ្លូវថ្នល់ នាពេលអនាគត ក៏ដូចកាត់បន្ថយគ្រោះថ្នាក់ដែលអាចកើតមានជាយថាហេតុ (២) កាត់បន្ថយការដឹកជញ្ជូនប្រេង និងទំនិញគ្រោះថ្នាក់ផ្សេងៗតាមដងផ្លូវ ដូច្នេះ នាំឱ្យកាត់បន្ថយហានិភ័យចរាចរជើងគោក (៣) ផ្តល់នូវការដឹកជញ្ជូនថោកសម្រាប់ទំនិញដុល ដូចជាស៊ីម៉ង់ត៍ និងប្រេង ដូច្នេះនាំឱ្យកាត់បន្ថយចំណាយការនាំចូល និងចែកចាយផលិតផល ជាមូលដ្ឋាន និង (៤) បង្កើនគំនាបប្រកួតប្រជែងលើប្រព័ន្ធដឹកជញ្ជូនបច្ចុប្បន្នជាចម្បង គឺការដឹកជញ្ជូនជើងគោក និងកំពង់ផែក្រុងព្រះសីហនុ តាមរយៈការបង្កើតនូវច្រកផ្លូវ និងមធ្យោបាយដឹកជញ្ជូនផ្សេងៗ។ វានឹងជួយបន្ថយនូវការអនុវត្តការកំណត់តម្លៃផ្តាច់មុខ។ បន្ថែមពីនេះ វានឹងជួយជំរុញសមាហរណកម្ម និងពាណិជ្ជកម្មក្នុងតំបន់ ក៏ដូចជាវិស័យទេសចរណ៍ ទន្ទឹមនឹងការបង្កើតការងារបន្ថែមសម្រាប់ជនជាតិកម្ពុជា។

*រូបភាព. ១៥.១០. និន្នាការនៃចំនួនអ្នកដំណើរតាមរថភ្លើង និងប្រវែងជាមធ្យមនៃការធ្វើដំណើរ*




| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|
| NL-Passengers | 320,0 | 320,0 | 253,2 | 182,8 | 110,9 | 81,90 | 78,56 | 47,76 | 14,00 | 10,62 | 4,929 |
| SL-Passengers | 117,6 | 127,1 | 82,91 | 41,02 | 22,06 | 11,82 | 3,286 | 11 | 0 | 0 | 0 |
| NL-Trip Distance | 103.8 | 126.5 | 147.4 | 159.0 | 158.4 | 150.7 | 128,6 | 108.2 | 101.0 | 90.0 | 84.0 |
| SL-Trip Distance | 90.5 | 94.3 | 97.7 | 95.3 | 94.3 | 93.9 | 82.2 | 0.0 | 0.0 | 0.0 | 0.0 |

*ប្រភព៖ ត្រូវបានរៀបចំដោយផ្អែកទៅលើ ការសាងសង់ឡើងវិញផ្លូវរថភ្លើងក្នុងប្រទេសកម្ពុជា, ផែនការសកម្មភាពនិងរបាយការណ៍យុទ្ធសាស្ត្រ, ADB and GMS Rehabilitation of the Railway in Cambodia, របាយការណ៍បញ្ចប់ (លេខ II), វិច្ឆិកា 2006, ADB.*

## ១៩.៤.៣. ការស្តារផ្លូវរថភ្លើងឡើងវិញ

ការតភ្ជាប់ឡើងវិញនៃខ្សែរថភ្លើងរវាងស៊ីសុផុន-ប៉ោយប៉ែតប្រវែង ៤៨គ.ម. ដែលនឹងតភ្ជាប់ប្រព័ន្ធផ្លូវរថភ្លើងរវាងកម្ពុជានិងថៃ គឺជាគម្រោងអាទិភាពខ្ពស់មួយ។ គម្រោងនេះនៅតែបន្ត និងសង្ឃឹមថានឹងចប់សព្វគ្រប់នៅប៉ុន្មានឆ្នាំខាងមុខនេះ។ ប្រភពហិរញ្ញប្បទានបានមកពីកម្ចី ៤២ លានដុល្លារពីធនាគារអភិវឌ្ឍន៍អាស៊ី ១៣ លាន ដុល្លារពី OPEC ផ្លូវដែកចាស់មានតម្លៃ ២,៨លានដុល្លារបួលដោយប្រទេសម៉ាឡេស៊ី និងថវិកាបដិភាគ ១៥,២ លានដុល្លារពីរាជរដ្ឋាភិបាលកម្ពុជា។ ការស្តារឡើងវិញនេះនឹងត្រូវតាមនិយាមអន្តរជាតិ។ រថភ្លើងនឹងអាចធ្វើដំណើរ ៥០គ.ម./ម ហើយផ្លូវរថនឹងអាចផ្ទុកទូចំណុះពី ១៥ ទៅ ២០តោន។ គម្រោងនេះកំពុងត្រូវបានអនុវត្តដោយក្រុមហ៊ុនបារាំងTSO និងក្រុមហ៊ុន Nawarat ដែលមានមូលដ្ឋាននៅប្រទេសថៃក្រោមការប្រឹក្សាបច្ចេកទេសពី Nippon Koei Co. Ltd.។

ប្រទេសចិនបានធ្វើការសិក្សាការតភ្ជាប់ផ្លូវរថភ្លើងជាមួយនឹងប្រទេសវៀតណាម។ ខ្សែរថភ្លើងនេះឆ្លងកាត់ខេត្តកំពង់ចាម និងភ្ជាប់ជាមួយប្រព័ន្ធរបស់វៀតណាមដែលរត់រហូតដល់ឡុកនីញ។ ប្រវែងខ្សែរថភ្លើងដែលនឹងត្រូវស្ថាបនាពីភ្នំពេញទៅឡុកនីញមានប្រវែង ២៦០គ.ម.។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាក្នុងខែមីនា ឆ្នាំ២០០៧ លើគម្រោងស្តារឡើងវិញនូវផ្លូវរថភ្លើងនៅកម្ពុជាជាមួយនិងធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ទឹកប្រាក់៧៣លានដុល្លារ ដែលក្នុងនោះ រាជរដ្ឋាភិបាលកម្ពុជានឹងរួមចំណែក១៥លានដុល្លារ។ គម្រោងស្តារឡើងវិញនេះនឹងស្ថាបនាសារជាថ្មី ហើយជួសជុលខ្សែរថភ្លើងប្រវែង ៦៥២គ.ម. ពីខេត្តព្រះសីហនុទៅភ្នំពេញ និងពីភ្នំពេញទៅប៉ោយប៉ែត។ សម្តេចតេជោ នាយករដ្ឋមន្ត្រីក៏បានស្នើធនាគារអភិវឌ្ឍន៍អាស៊ី ធានាកម្ពុជាក្នុងការជួយឱ្យបានកម្ចីការប្រាក់ទាបចំនួន ៥០០ លានដុល្លារដើម្បីកសាងផ្លូវរថភ្លើងថ្មីមួយប្រវែង ២៥៧ គ.ម. ពីភ្នំពេញទៅឡុកនីញ ប្រទេសវៀតណាម ដោយបំពេញការតភ្ជាប់បណ្តាញផ្លូវរថភ្លើង សិង្ហបុរី-គុនមីងប្រវែង ៥,៥០០គ.ម។ ខ្សែរថភ្លើងថ្មីនេះ គឺជាអាទិភាពនៃការអភិវឌ្ឍរយៈពេលវែងសម្រាប់អាស៊ាន។

*រូបភាព. ១៥.២. ច្រកផ្លូវរថភ្លើងអាស៊ានទាំងមូលក្នុងប្រទេសកម្ពុជា*




*ប្រភព៖Report of the Overseas Information Gathering Survey by the Asia-Pacific Region H Group (Cambodia), March 2004, Japan Transport Cooperation Association*

ដើម្បីធានាមានការគ្រប់គ្រងល្អ ធនាគារអភិវឌ្ឍន៍អាស៊ីបានស្នើធ្វើឯកជននីយកម្មផ្លូវរថភ្លើងរបស់ប្រទេសកម្ពុជា។ យោងតាមសំណើនេះ ផ្លូវដែក ឧបករណ៍ និង អាគារនានានឹងបន្តជាកម្មសិទ្ធិរបស់រដ្ឋ ហើយត្រូវបានគ្រប់គ្រងដោយអាជ្ញាធរផ្លូវរថភ្លើងមួយ ដែលមានភាពស្វយ័តពេញលេញ។ ការគ្រប់គ្រងការថែទាំ និងការធ្វើទីផ្សារនឹងត្រូវបានប្រគល់ឱ្យប្រតិបត្តិករឯកជនដែលមានសមត្ថភាព និងជំនាញគ្រប់គ្រងដែលមានបទពិសោធន៍ តាមរយៈការដេញថ្លៃប្រកួតប្រជែង។

បន្ទាប់ពីដំណើរការដេញថ្លៃប្រកួតប្រជែងរួច រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា ក្នុងខែមិថុនា ឆ្នាំ ២០០៩ លើកិច្ចព្រមព្រៀងសម្បទានរយៈពេល ៣០ ឆ្នាំជាមួយក្រុមហ៊ុន Australian Toll Holdings Ltd. ដើម្បីធ្វើប្រតិបត្តិការផ្លូវរថភ្លើង ក្រោមកិច្ចព្រមព្រៀងភាពជាដៃគូឯកជននិងសាធារណៈ(PPP)។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវរថភ្លើង រួមបញ្ចូលទាំងដីនៃផ្លូវរថភ្លើងនឹងនៅតែជាទ្រព្យសម្បត្តិរបស់រដ្ឋ ក៏ប៉ុន្តែប្រតិបត្តិការត្រូវបានគ្រប់គ្រងដោយ Toll Holdings។ Toll Holdings នឹងចែករំលែកភាគលាភចំណេញតាមរយៈការបង់ប្រាក់សម្បទានមួយ ដែលនឹងត្រូវសងចាប់ផ្តើមក្នុងឆ្នាំទីប្រាំនៃប្រតិបត្តិការ។ បុគ្គលិកនៃរាជាយស្ម័យយានកម្ពុជាចំនួន ៦៧០នាក់នឹងត្រូវបានយកមកធ្វើការជាមួយក្រុមហ៊ុនToll Holdings។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការស្តារឡើងវិញ និងការធ្វើរចនាសម្ព័ន្ធផ្លូវរថភ្លើងជាថ្មីនឹងជំរុញសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវដែកឱ្យមានប្រសិទ្ធភាព ដោយធានានូវការដឹកជញ្ជូនតាមរថភ្លើងដែលថោក និងមានប្រសិទ្ធផល កាត់បន្ថយចំណាយខូចខាតពីការដឹកទំនិញធុនធ្ងន់លើបណ្តាញផ្លូវគោក ដោយបង្វែរការដឹកទំនិញធុនធ្ងន់ទៅផ្លូវដែក និងលើកកម្ពស់សុវត្ថិភាពចរាចរណ៍ ដោយអាចឱ្យមានការបង្ខៀងរវាងអ្នកធ្វើដំណើរ និងទំនិញគ្រោះថ្នាក់ពីការដឹកជញ្ជូនជើងគោក ទៅជាការដឹកជញ្ជូនតាមផ្លូវដែកដែលមានសុវត្ថិភាពជាង។ ក្នុងរយៈពេលយូរអង្វែង ការធ្វើរចនាសម្ព័ន្ធជាថ្មីនេះនឹងផ្តល់លទ្ធភាព សម្រាប់ការស្ថាបនានាថ្ងៃអនាគតនូវផ្លូវរថភ្លើងថ្មីៗទៀត រួមមានការតភ្ជាប់រវាងក្រុងភ្នំពេញនិងឡុកនីញ ប្រទេសវៀតណាម។

## ១៥.៥. នាវាចរ និង កំពង់ផែ

### ១៥.៥.១. ស្ថានភាពបច្ចុប្បន្ននៃកំពង់ផែ

*តារាង១៥.៨. សំណង់អាគារនៅកំពង់ផែខេត្តព្រះសីហនុនិងកំពង់ផែភ្នំពេញ*

| ឈ្មោះកំពង់ផែ | បណ្តាញ | កន្លែងចតនាវា ឈ្មោះ | រចនាសម្ព័ន្ធ | ប្រវែង | ជម្រៅ | ឆ្នាំ | ការសម្របសម្រួលដទៃទៀតនិងកំណត់សម្គាល់ |
|---|---|---|---|---|---|---|---|
| កំពុងផែ ព្រះសីហនុ | [បណ្តាញខាងត្បូង] ប្រវែង:៥.៥km ជម្រៅ:៨.៤m ទទឹង: ៨០-១០០km<br><br>[បណ្តាញខាងជើង] ប្រវែង:១km ជម្រៅ:១០m ទទឹង: ១៥០-២០០m | No. ១-២ | ស្ពានកំពង់ទឹកឆ្នេរសមុទ្រ | ២៩០m | ៩m | ១៩៦០ | [ឃ្លាំស្តុកទំនិញ] អគារចំនួន ៥, ៣៦,៦០០$m^2$ [ទូដាក់ទំនិញyard] ៣ yard ១១០,០០០ $m^2$ |
| | | No. ៣-៤ | ស្ពានកំពង់ទឹកឆ្នេរសមុទ្រ | ២៩០m | ៩m | ១៩៦០ | |
| | | No. ៥-៧ | - | ៣៥០m | ៧.៥m | ១៩៦៩ | |
| | | No. ៨-៩ | - | ៤០០m | ៩m | ២០០៦ | |
| | | (សំភារៈសម្រាប់សម្រួលដល់កន្លែងចតនាវាឯកជន) | | | | | |
| | | ស្វគីម៉ិច | ស្ពានកំពង់ទឹកឆ្នេរសមុទ្រ | ២០០m | ៩.២m | - | |
| | | - | ស្ពានបណ្តែត | ១១០m | ៦.៥m | - | |
| | | - | កំពង់ផែថ្ម | ៥៣m | ៤.២m | - | |
| កំពង់ផែ ភ្នំពេញ | ការថែរក្សាការបូមដីបាតទន្លេ (ចតុមុខ)<br><br>ប្រវែង:១,២៩០ km ជម្រៅ: ៧ km ទទឹង: ៦០m ចំនួន: ១៥៩៦៤៨$m^3$ | កំពង់ផែ No. ១ | | | | | yards] ២yards សម្រាប់ទូរដាក់ទំនិញ ដែលផ្ទុកទំនិញ ១ yards សម្រាប់ទូរដាក់ទំនិញដែលមិនផ្ទុកទំនិញ |
| | | No. ១ | ស្ពានកំពង់ទឹកឆ្នេរសមុទ្រ, ស្ពានថ្មទទឹង ២០m | សរុប 300m | - | - | |
| | | No. ២ | | | - | - | |
| | | No. ៣ | | | - | - | |
| | | កំពង់ផែ No. ២ (សម្រាប់អ្នកធ្វើដំណើរ) | | | | | ខ្សែទឹកខាងក្រោម ១ km ពីកំពង់ផែ No. ១ |
| | | No. ៥b | ស្ពានបណ្តែត | - | - | - | |
| | | No. ៥c | ស្ពានបណ្តែត | - | - | - | |
| | | (សំភារៈសម្រាប់សម្រួលដល់កន្លែងចតនាវាឯកជន) | | | | | រវាង 4 ទៅ ១៣km ខ្សែទឹកខាងលើពីភ្នំពេញ |
| | | | សំភារៈសម្រាប់សម្រួលដល់កន្លែងចតនាវាចំនួន៨សម្រាប់នាវាដឹកប្រេង | ទំហំនាវាចាប់ពី ៦០០-1000DWT | | | |

*ប្រភព៖ បង្កើតឡើងផ្អែកលើការសិក្សាស្តីពីផែនការមេសម្រាប់វិស័យសមុទ្រនិងកំពង់ផែក្នុងប្រទេសកម្ពុជា, មីនា 2007, JICA (ប្រភព៖ SPA & PPAP).*

**រូបភាព. ១៥.១១a. ចំនួនលើកដាក់ទំនិញប្រចាំឆ្នាំនៅកំពង់ផែអន្តរជាតិក្នុងប្រទេសកម្ពុជា (២០០៥)**




**រូបភាព. ១៥.១១b. ចំនួននាវាចូលមកកំពង់ផែអន្តរជាតិទាំងពីរក្នុងប្រទេសកម្ពុជាក្នុងមួយឆ្នាំ (តាមប្រភេទនាវា, ២០០៥)**




*ប្រភព៖បង្កើតឡើងផ្អែកលើការសិក្សាស្តីពីផែនការមេសម្រាប់វិស័យសមុទ្រនិងកំពង់ផែក្នុងប្រទេសកម្ពុជា, មីនា 2007, JICA (ប្រភព៖ SPA & PPAP).*

ក្នុងចំណោមកំពង់ផែនៅកម្ពុជា មានតែកំពង់ផែខេត្តព្រះសីហនុ និងកំពង់ផែភ្នំពេញទេ ដែលលើកដាក់កុងតឺន័រអន្តរជាតិបាន។ កំពង់ផែទាំងពីរនេះត្រូវបានគ្រប់គ្រងដោយសហគ្រាសរដ្ឋ ដែលមានឯករាជ្យខាងផ្នែកហិរញ្ញវត្ថុ និងគ្រប់គ្រងដោយស្វយ័ត។ កំពង់ផែខេត្តព្រះសីហនុត្រូវបានស្ថាបនាក្នុងឆ្នាំ ១៩៦១ ដោយជំនួយរបស់បារាំង។ ប្រទេសជប៉ុនកំពុងជួយអភិវឌ្ឍចំណតកុងតឺន័រជម្រៅ ១១ម និងប្រវែង ៤០០ម តាមបណ្តោយកំពង់ផែដែលចប់សព្វគ្រប់ក្នុងឆ្នាំ២០០៨។ កំពង់ផែភ្នំពេញមានកំពង់ផែប្រវែង៣០០ម និងកំពង់ផែប្រេងសាំងឯកជនមួយ។ ដោយមិនរួមបញ្ចូលកំពង់ផែប្រេងនៅក្រុងព្រះសីហនុ និងកំពង់ផែឧកញ៉ាម៉ុង (ឯកជន) ផែផ្សេងៗទៀតក្រៅពីកំពង់ផែស្វយ័តទាំងពីរនេះមានទំហំតូចៗណាស់។

**រូបភាព. ១៥.១២a. និន្នាការនៃចំនួនទូរដាក់ទំនិញនៅកំពង់ផែពាណិជ្ជកម្មអន្តរជាតិក្នុងប្រទេសកម្ពុជា**




**រូបភាព. ១៥.១២b. ផលធៀបនៃទូរដឹកទំនិញទទេ និងមានទំនិញ (២០០៦)**




*ប្រភព៖បង្កើតឡើងផ្អែកលើការសិក្សាស្តីពីផែនការមេសម្រាប់វិស័យសមុទ្រនិងកំពង់ផែក្នុងប្រទេសកម្ពុជា, មីនា 2007, JICA (ប្រភព៖ SPA & PPAP).*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១៥.៥.២. ស្ថានភាពនៃការប្រើប្រាស់កំពង់ផែ

កំពង់ផែខេត្តព្រះសីហនុមានសមត្ថភាពលើកដាក់ទំនិញបានប្រហែល១,៦លានតោន ហើយកំពង់ផែភ្នំពេញបានប្រហែល៧៤០,០០០តោន។ ផែទាំងពីរបាននឹងកំពុងពង្រីកសមត្ថភាពលើកដាក់របស់ខ្លួនជាបន្តបន្ទាប់ ជាពិសេសកុងតឺន័រ។ កំពង់ផែខេត្តព្រះសីហនុទទួលកប៉ាល់បានប្រហែល ៧០០គ្រឿងក្នុងឆ្នាំ ២០០៥ និងកំពង់ផែភ្នំពេញបាន ១.០៧០ គ្រឿង (ភាគច្រើនកប៉ាលតូចៗ)។ កប៉ាល់កុងតឺន័រមាន៦០%នៃកប៉ាល់ដឹកទំនិញទាំងអស់ដែលចូលមកកំពង់ផែក្រុងព្រះសីហនុ។ នៅកំពង់ផែខេត្តព្រះសីហនុ ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសទំហំ ៧០ហិចតា ដែលរួមបញ្ចូលជាមួយកំពង់ផែនេះ កំពុងតែធ្វើឡើងជាមួយជំនួយរបស់ជប៉ុន រួមបញ្ចូលជាមួយការអភិវឌ្ឍចំណតកុងតឺន័រមួយផងដែរ។ កំពង់ផែខេត្តព្រះសីហនុកំពុងធ្វើការរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍឧស្សាហកម្មប្រេង។ តំបន់ប្រេងលើសមុទ្រចំនួន ៦ កន្លែងកំពុងត្រូវបានអភិវឌ្ឍ ចេញពីឆ្នេរសមុទ្រក្រុងព្រះសីហនុ។ ជាមូលដ្ឋានផ្គត់ផ្គង់មួយសម្រាប់ការអភិវឌ្ឍរបស់ខ្លួននោះ សម្ភារៈ និងឧបករណ៍សម្រាប់ការរុករក និងខួងសាកល្បងត្រូវបានស្តុកទុក និងផ្គត់ផ្គង់នៅឯកំពង់ផែក្រុងព្រះសីហនុ។

រូបភាព. ១៥.១៣a. សមាសភាពនៃទំនិញដែលលើកដាក់នៅកំពង់ផែព្រះសីហនុ(២០០៦)

រូបភាព. ១៥.១៣b. សមាសភាពនៃទំនិញដែលលើកដាក់នៅកំពង់ផែភ្នំពេញ (២០០៥)







*ប្រភពៈការរៀបចំនេះផ្អែកលើការសិក្សាស្តីពីផែនការមេសម្រាប់វិស័យសមុទ្រនិងកំពង់ផែក្នុងប្រទេសកម្ពុជា, មីនា 2007, JICA (ប្រភពៈ SPA & PPAP).*

## ១៥.៦. ផ្លូវទឹកក្នុងប្រទេស

### ១៥.៦.១. ស្ថានភាពបច្ចុប្បន្ននៃជាវាចរនេះ

ផ្លូវទឹកក្នុងប្រទេសកម្ពុជាដែលអាចធ្វើនាវាចរបានមានប្រវែងសរុបចំនួន១.៧៥០គ.ម.ដែល ក្នុងនោះ ទន្លេមេគង្គមាន ៣០% នៃផ្លូវទឹកសរុប ទន្លេសាបមាន១៥% ទន្លេបាសាក់៥% និងដៃទន្លេមាន៥០%។ ផ្លូវទឹកសម្រាប់ការធ្វើនាវាចរពេញមួយឆ្នាំអាចដំណើរការបានតាមប្រវែង ៥៨០គ.ម.។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តារាង១៥.៩. ទំហំកប៉ាល់អតិបរិមាដែលអាចធ្វើនាវាចរណ៍បានក្នុងអាងទន្លេមេគង្គតាមផ្នែកតំបន់

| | ផ្នែកទន្លេ | ប្រវែង (ម៉ែត្រ) | អាចធ្វើនាវាចរណ៍ពេញមួយឆ្នាំ? | ទំហំកម្រិតរបស់កប៉ាល់ (DWT) ទឹកពាក់ | ទំហំកម្រិតរបស់កប៉ាល់ (DWT) ទឹកមធ្យម-ជ្រៅ |
|---|---|---|---|---|---|
| មេគង្គ | តំបន់ត្រីកោណមាស-ហ្លួងព្រះបាង | ៣៦២ | អាចធ្វើដំណើរបាន-ប៉ុន្តែវានៅមានកម្រិតដោយសារមានថ្មដោយកន្លែងនិងចរន្តទឹកខ្លាំង | | ៦០ |
| | ហ្លួងព្រះបាង-វៀងច័ន្ទ | ៤២៥ | អាចធ្វើដំណើរបាន-ប៉ុន្តែបានតែទូកតូចនិងត្រូវការអ្នកបើកបរមានជំនាញក្នុងរដូវវស្សាអាចធ្វើដំណើរបាន | ១៥ | ៦០ |
| | វៀងច័ន្ទ-សុវណ្ណខេត្ត | ៨៥៩ | | ២០០ | ៥០០ |
| | សុវណ្ណខេត្ត-ប៉ាក់សេ | ២៦១ | មិនអាចធ្វើដំណើរបាន-"ទឹកជ្រៅ"សម្រាប់ការធ្វើនាវាចរណ៍ | តិចជាង១០ | ៥០ |
| | ប៉ាក់សេ-កិញណាក់ | ១៥១ | អាចធ្វើដំណើរបាន | ៥០ | |
| | កិញណាក់-វ៉ាន់ណាខាម | ១៤ | មិនអាចធ្វើដំណើរបាន-ការធ្វើនាវាចរណ៍មិនអាចទៅរួចគ្រប់ពេលដោយសារតែទឹកធ្លាក់ល្បាក់ខោន | | |
| | វ៉ាន់ណាខាម-ស្ទឹងត្រែង | ៣០ | អាចធ្វើដំណើរបាន-ជាមួយទំហំនាវាដែលបានកំណត់ពេលទឹកពាក់ | ១៥ | ៥០ |
| | ស្ទឹងត្រែង-ក្រចេះ | ១២៨ | អាចធ្វើដំណើរបាន-ជាមួយទំហំនាវាដែលបានកំណត់ពេលទឹកពាក់ | ២០ | ៥០ |
| | ក្រចេះ-កំពង់ចាម | ១២១ | អាចធ្វើដំណើរបាន | ៨០ | ៤០០ |
| | កំពង់ចាម-ភ្នំពេញ | ១០០ | អាចធ្វើដំណើរបាន-អាចធ្វើនាវាចរណ៍បានដោយកប៉ាល់ធ្វើដំណើរតាមសមុទ្រ | ២០០០ | |
| | ភ្នំពេញ-ទីប្រសព្វវ៉ាមណៅផាស | ១៥៤ | អាចធ្វើដំណើរបាន-អាចធ្វើនាវាចរណ៍បានដោយកប៉ាល់ធ្វើដំណើរតាមសមុទ្រ | ៣០០០-៤០០០ | ៥០០០ |
| | វ៉ាមណៅផាស-សមុទ្រចិនខាងត្បូង | ១៩៤ | អាចធ្វើដំណើរបាន-អាចធ្វើនាវាចរណ៍បានដោយកប៉ាល់ធ្វើដំណើរតាមសមុទ្រ | ៣០០០-៤០០០ | ៣០០០-៤០០០ |
| ទន្លេបាសាក់ | ភ្នំពេញ-ទីប្រសព្វវ៉ាមណៅផាស | | អាចធ្វើដំណើរបាន-ប៉ុន្តែមិនអាចធ្វើដំណើរបានដោយកប៉ាល់ធ្វើដំណើរតាមសមុទ្រ | ២០ | ៥០ |
| | វ៉ាមណៅផាស-សមុទ្រចិនខាងត្បូង | ១៨៨ | អាចធ្វើដំណើរបាន-អាចធ្វើនាវាចរណ៍បានដោយកប៉ាល់ធ្វើដំណើរតាមសមុទ្រ | ៥០០០ | ៥០០០-៦០០០ |
| ទន្លេសាប (កម្ពុជា) | ភ្នំពេញ-៥km ខាងត្បូងកំពង់ចាម | ៩៤ | អាចធ្វើដំណើរបាន-អាចធ្វើនាវាចរណ៍បានដោយកប៉ាល់ធ្វើដំណើរតាមសមុទ្រ | ១០០០ | ២០០០ |
| | កំពង់ឆ្នាំង-ឆ្នុកទ្រូ | ៤៦ | អាចធ្វើដំណើរបាន-ជាមួយទំហំនាវាដែលបានកំណត់ពេលទឹកពាក់ | ២០ | ១៥០ |
| | ឆ្នុកទ្រូ-ចុងឃ្នាស១០៩ | ១០៩ | អាចធ្វើដំណើរបាន-ជាមួយទំហំនាវាដែលបានកំណត់ពេលទឹកពាក់ | ២០ | ១៥០ |

| | | | | | |
|---|---|---|---|---|---|
| ផ្លូវទឹកដីសណ្តមេគង្គ | បណ្តុំនៃបណ្តាញប្រឡាយដែលសាងសង់ឡើង ប្រឡាយទឹកធម្មជាតិនិងដៃទន្លេមេគ្គងដែលមានប្រវែងសម្រាប់នាវាចរសរុប ៤៧៨៥km | | ទំហំនាវាក្នុងបណ្តាញនេះដែលប្រែប្រួលពី 10-300DWT | | |
| | សេកុង-ដៃទន្លេមេគង្គ (កម្ពុជា-ឡាវ) | | អាចធ្វើដំណើរបាន-ផ្លូវទឹកនេះអាចធ្វើដំណើរបានរវាងប្រទេសឡាវនិងកម្ពុជាដោយផ្តល់នូវជម្រើសច្រកអន្តរជាតិដល់ទន្លេមេគង្គដែលមិនអាចធ្វើដំណើរតាមល្បាក់ខោន | | |

*ប្រភព៖ ផែនការមេសម្រាប់ការដឹកជញ្ជូនផ្លូវទឹកក្នុងប្រព័ន្ធទន្លេមេគ្គង, របាយការណ៍បញ្ចប់ (លេខ ១ របាយការណ៍មេ, ពង្រាង), កញ្ញា ២០០៦, សហប្រតិបត្តិការបច្ចេកទេសប៊ែលហ្ស៊ិក (Belgian Technial Cooperation)*

### *តារាង១៥.១០. ទំហំកប៉ាល់អតិបរមាដែលអាចធ្វើនាវាចរបានក្នុងអាងទន្លេមេគង្គតាមផ្នែកតំបន់*

| | ខ្សែទឹកមេទន្លេមេគង្គ ហូតដល់ភ្នំពេញ | ទន្លេមេគង្គ, ភ្នំពេញ ទៅកំពង់ចាម | ទន្លេមេគង្គ, ភ្នំពេញ ទៅសៀមរាប |
|---|---|---|---|
| ប្រេងឥន្ធនៈ | នាវាដឹកប្រេង នាវាផ្ទុកទំនិញ1,000 DWT / 4.0m រដូវប្រាំង | - | - |
| ទូរដាក់ទំនិញ | នាវាផ្ទុកទំនិញ1,900 DWT (120TEU) / រដូវប្រាំង 3.8m | - | - |
| Generak ទំនិញ | នាវាផ្ទុកទំនិញ1,500 DWT / រដូវប្រាំង 4.0m | - | - |
| នាវាខ្នាតធំដឹកអ្នកទេសចរណ៍ | អ្នកដំណើរ 50-65 រដូវប្រាំង 1.5m | - | អ្នកធ្វើដំណើរ ៥០-៦៥រដូវប្រាំង 1.5m |
| ទូកល្បឿនលឿន | អ្នកធ្វើដំណើរ 25 រូបរដូវប្រាំងទឹករាក់ | - | អ្នកធ្វើដំណើរ ២៥រដូវប្រាំងទឹករាក់ |

*ប្រភព៖ ផែនការមេសម្រាប់ការដឹកជញ្ជូនផ្លូវទឹកក្នុងប្រព័ន្ធទន្លេមេគ្គង, របាយការណ៍បញ្ចប់ (លេខ ១ របាយការណ៍មេ, ពង្រាង), កញ្ញា ២០០៦, សហប្រតិបត្តិការបច្ចេកទេសប៊ែលហ្ស៊ិក (Belgian Technial Cooperation)*

*រូបភាព. ១៥.៣. ទំហំកប៉ាល់អតិបរមាដែលអាចធ្វើនាវាចរណ៍បានក្នុងអាងទន្លេមេគង្គ*




*ប្រភពៈផែនការមេសម្រាប់ការដឹកជញ្ជូនផ្លូវទឹកក្នុងប្រព័ន្ធទន្លេមេគ្គង, របាយការណ៍បញ្ចប់ (លេខ ១ របាយការណ៍មេ, ពង្រាង),កញ្ញា ២០០៦, សហប្រតិបត្តិការបច្ចេកទេសប៊ែលហ្សិក(Belgian Technial Cooperation)*

## ១៥.៦.២. ស្ថានភាពបច្ចុប្បន្ននៃការដឹកជញ្ជូនតាមផ្លូវទឹកក្នុងប្រទេស

ទូកល្បឿនដឹកអ្នកដំណើរពីភ្នំពេញទៅខេត្តសៀមរាប តាមការធ្វើដំណើរឯកទិស មួយលើក ក្នុងមួយថ្ងៃ ក្នុងអំឡុងពេលប្រាំពីរខែ ចាប់ពីខែសីហា ដល់ខែកុម្ភៈ។ ចំនួនអ្នកធ្វើដំណើរដែលប្រើសេវាដឹកជញ្ជូនតាមផ្លូវទឹកក្នុងប្រទេសបានធ្លាក់ចុះពី ១២៩.០០០ នាក់ក្នុងឆ្នាំ២០០២ មកត្រឹម ៣៧.០០០នាក់ក្នុងឆ្នាំ ២០០៥ ដោយសារតែផ្លូវជាតិមានការកែលម្អ។ កប៉ាល់តូចៗដែលមានទំងន់ផ្ទុកចាប់ពី១០០ ទៅ ២០០ តោន (DWT) ត្រូវបានគេប្រើសម្រាប់ការដឹកជញ្ជូនទំនិញក្នុងស្រុក នៅកំពង់ផែភ្នំពេញ ហើយដឹកជាពិសេសគឺគ្រឿងឧបភោគបរិភោគ ដូចជាផលិតផលស្រស់ជាដើម ហើយនិងស៊ីម៉ង់ត៍។ បរិមាណនៃការលើក ដាក់ទំនិញបាននិងកំពុងធ្លាក់ចុះយ៉ាងខ្លាំងជារៀងរាល់ឆ្នាំ ហើយបានធ្លាក់ចុះដល់ប្រហែល ៥.៧០០តោន ក្នុងឆ្នាំ២០០៥។

## ១៥.៧. ការដឹកជញ្ជូនតាមផ្លូវអាកាស

## ១៥.៧.១. ស្ថានភាពបច្ចុប្បន្ននៃអាកាសយានដ្ឋាន

កម្ពុជាមានអាកាសយានដ្ឋានចំនួន១១ ប៉ុន្តែមានតែអាកាសយានដ្ឋានចំនួន ២ ប៉ុណ្ណោះដែលមានការហោះហើរជាទៀងទាត់នោះៈ គឺអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិសៀមរាប។ ក្រៅពីអាកាសយានដ្ឋានអន្តរជាតិទាំងពីរ ការហោះហើរក្នុងស្រុកតាមយន្តហោះជួល គឺមានតែអាកាសយានដ្ឋានខេត្តព្រះសីហនុប៉ុណ្ណោះ (ឆ្ពោះទៅកាន់ខេត្តសៀមរាប)។

The Société Concessionaire de l'Aéroport (SCA) បាននឹងកំពុងធ្វើការគ្រប់គ្រងផ្នែកប្រតិបត្តិការនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញតាំងពីឆ្នាំ ១៩៩៥ អាកាសយានដ្ឋានអន្តរជាតិសៀមរាបតាំងពី ឆ្នាំ២០០១ និងអាកាសយានដ្ឋានខេត្តព្រះសីហនុតាំងពីឆ្នាំ២០០៦ មក ក្រោមកិច្ចព្រមព្រៀង **កសាង-ដំណើរការ-ផ្ទេរ** ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

អាកាសយានដ្ឋានផ្សេងទៀតទាំងអស់ ត្រូវបានគ្រប់គ្រងដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល (SSCA) របស់រាជរដ្ឋាភិបាលកម្ពុជា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### តារាង១៥.១១. ស្ថានភាពប្រតិបត្តិការរបស់អាកាសយានដ្ឋាននៅកម្ពុជា

| ឈ្មោះព្រលានយន្តហោះ | ផ្លូវហោះហើរ (LxW, m) | ILS | តំបន់ (ហិចតា) | ម្ចាស់/អង្គភាពគ្រប់គ្រង | បើក/បិទ | កំណត់ចំណាំ |
|---|---|---|---|---|---|---|
| **អាកាសយាន្តដ្ឋានអន្តរជាតិ** | | | | | | |
| ភ្នំពេញ | 300x45/Aspahlt/4D | * | ៣៨៧ | RGC/SCA | បើក | ILS សម្រាប់ RWY ២០០៣ |
| សៀមរាប | 2550x45/Aspahlt/4C | - | ១៩៧ | RGC/SCA | បើក | ILSនឹងចាប់ផ្ដើមសេវាក្នុងដើមឆ្នាំ២០០៨ |
| **អាកាសយាន្តដ្ឋានក្នុងស្រុក** | | | | | | |
| ព្រះសីហនុ | 1795x34/Aspahlt/3C | - | ១២៣.៨៤ | RGC/SCA | បើក | បើកជាថ្មីនៅថ្ងៃទី ១៥ មករា ២០០៧ |
| កំពង់ឆ្នាំង | 2400x45/Concret/4C | - | ២០១១ | RGC (ទាហាន) | បិទ | តំបន់នេះរួមបញ្ចូលដីដែលទាហានប្រើប្រាស់ |
| បាត់ដំបង | 1600x34/ Bitumen /4C | - | ១២៨.៦៨ | RGC | បើក | បើកជាធម្មតានិងជួល |
| ស្ទឹងត្រែង | 1300x20-29/Bitumen/3C | - | ១១២.៥ | RGC | បើក | |
| រតនគីរី | 1300x30/Laterite/3C | - | ៥៨.៥៧ | RGC | បើក | ស្ថិតក្រោមគម្រោង ADB |
| កោះកុង | 1300x30/Laterite/3C | - | ១២៥.៣១ | RGC | បើក | បើកជាធម្មតានិងជួល |
| មណ្ឌលគីរី | 1500x30/Laterite/3C | - | ៨៦.២៧ | RGC | បិទ | បិទបណ្ដោះអាសន្ន ១៧ កក្កដា ២០០៧ |
| ព្រះវិហារ | 1400x30/Laterite/3C | - | ១៦៥.២៨ | RGC | បិទ | |
| ក្រចេះ | 1200x30/Laterite/3C | - | ១១២.៥ | RGC | បិទ | |

## ១៥.៧.២. ស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់អាកាសយានដ្ឋាន

រូបភាព. ១៥.១៥a. អ្នកដំណើរដែលប្រើប្រាស់អាយានដ្ឋានអន្តរជាតិកម្ពុជា




| | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|
| No of Passengers Phnom Penh | 860,168 | 1,010,02 | 1,052,26 | 1,284,57 | 1,598,42 | 1,691,87 |
| No of Passengers Siem Reap | 544,102 | 806,912 | 1,014,13 | 1,348,95 | 1,732,42 | 1,531,82 |
| Growth Rate Phnom Penh | | 17.4% | 4.2% | 22.1% | 24.4% | 5.8% |
| Growth Rate Siem Reap | | 48.3% | 25.7% | 33.0% | 28.4% | -11.6% |

រូបភាព. ១៥.១៥b. ជើងហោះហើរដែលមកដល់ និងចាកចេញពីអាកាសយានដ្ឋានអន្តរជាតិកម្ពុជា




| | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|
| Int. Flight Phnom Penh | 11,292 | 13,832 | 13,574 | 15,766 | 16,092 | 16,253 |
| Dom. Flight Phnom Penh | 6,438 | 4,837 | 4,158 | 3,658 | 4,789 | 4,130 |
| Int. Flight Siem Reap | 7,154 | 10,442 | 12,832 | 14,724 | 16,924 | 15,431 |
| Dom. Flight Siem Reap | 5,439 | 5,515 | 4,285 | 4,693 | 5,088 | 4,551 |

*ប្រភព៖ ការរៀបចំនេះផ្អែកលើឯកសាររបស់ SSCA*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំនួនជើងហោះហើរក្នុងមួយឆ្នាំប្រែប្រួលបន្តិចបន្តួច ពីមួយឆ្នាំទៅមួយឆ្នាំ។ ប៉ុន្តែ ចន្លោះឆ្នាំ ២០០៣ និង២០០៦វាកើនឡើងប្រហែល១.៤ដងនៅឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញនិងប្រហែល២.១ដងនៅឯអាកាសយានដ្ឋានអន្តរជាតិសៀមរាប។ ផ្ទុយទៅវិញចំនួនជើងហោះហើរក្នុងស្រុកបានធ្លាក់ចុះ។

| *រូបភាព. ១៥.១៥a. អ្នកដំណើរដែលប្រើប្រាស់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ* | *រូបភាព. ១៥.១៥b. អ្នកដំណើរដែលប្រើប្រាស់អាកាសយានដ្ឋានអន្តរជាតិសៀមរាប* |
|---|---|




| | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|
| Dom. Arr. Phnom Penh | 95,620 | 97,413 | 80,796 | 78,973 | 88,314 | 76,609 |
| Dom. Dep. Phnom Penh | 95,443 | 90,283 | 72,786 | 75,271 | 90,632 | 80,052 |
| Int. Arr. Phnom Penh | 322,854 | 401,647 | 455,979 | 569,606 | 701,898 | 754,060 |
| Int. Dep. Phnom Penh | 333,419 | 416,702 | 457,470 | 560,729 | 717,580 | 781,149 |




| | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|
| Dom. Arr. Siem Reap | 85,852 | 95,023 | 77,215 | 80,817 | 90,677 | 83,347 |
| Dom. Dep. Siem Reap | 85,864 | 88,158 | 71,039 | 77,101 | 93,983 | 86,929 |
| Int. Arr. Siem Reap | 188,651 | 320,174 | 438,193 | 599,007 | 774,338 | 681,209 |
| Int. Dep. Siem Reap | 184,085 | 303,665 | 427,685 | 592,029 | 773,430 | 680,335 |

*ប្រភព៖ ការរៀបចំនេះផ្អែកលើឯកសាររបស់ SSCA.( សារតារគម្រោង និងវឌ្ឍនភាព (អាកាសចរណ៍ស៊ីវិល), SSCA)*

ចំនួនអ្នកដំណើរអន្តរជាតិបាននិងកំពុងកើនឡើងជារាល់ឆ្នាំ នៅឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ហើយឈានដល់ ១.១៧លានអ្នកក្នុងឆ្នាំ២០០៦។ ពេលដែលបញ្ចូលគ្នាជាមួយចំនួនអ្នកដំណើរក្នុងស្រុក នោះអាកាសយានដ្ឋាននេះមានអ្នកដំណើរប្រមាណ១.៣លាននាក់ក្នុងមួយឆ្នាំ។ អ្នកដំណើរក្នុងស្រុកបាននឹងកំពុងធ្លាក់ចុះជាច្រើនតាំងពីឆ្នាំ២០០៥ ប៉ុន្តែចំនួននេះ បាននៅរក្សាថេរតាំងពីឆ្នាំ២០០៦មក។ នៅឯអាកាសយានដ្ឋានអន្តរជាតិសៀមរាបវិញ ចំនួនអ្នកដំណើរជើងអន្តរជាតិវិញ បាននិងកំពុងកើនឡើងយ៉ាងឆាប់រហ័សក្នុងឆ្នាំថ្មីៗនេះ។ ក្នុងឆ្នាំ២០០៦ វាបម្រើឱ្យចំនួនអ្នកដំណើរច្រើនបំផុតក្នុងចំណោមអាកាស-យានដ្ឋានទាំងអស់នៅកម្ពុជា ដោយលើសពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញទៅទៀត។ តែទោះជាយ៉ាងណាដូចអាកាសយានដ្ឋានអន្តរជាតិភ្នំពេញដែរចំនួនអ្នកដំណើរក្នុងស្រុកបាននិងកំពុងធ្លាក់ចុះ។

## ១៥.៨. បញ្ហាគោលនយោបាយក្នុងហេដ្ឋារចនាសម្ព័ន្ធជើងគោក

ជារួមមករបៀបនៃការដឹកជញ្ជូននៅកម្ពុជារួមមាន បណ្តាញផ្លូវថ្នល់ផ្លូវទឹកក្នុងប្រទេស និងការដឹកជញ្ជូនជើងអាកាស។ ការដឹកជញ្ជូនជើងគោកមានចំណែកធំជាងគេបង្អស់នៃបរិមាណសរុបរបស់អ្នកធ្វើដំណើរនិងទំនិញ។ តែទោះជាយ៉ាងណា ស្ថានភាពផ្លូវថ្នល់ត្រូវបានប្រឈមមុខជាមួយបញ្ហាដូចខាងក្រោម៖ (១) ស្ថានភាពក្រាលផ្លូវចុះខ្សោយ (២) ទំហំទទឹងផ្លូវមិនគ្រប់គ្រាន់ (៣) ស្តង់ដារផ្លូវមិនគ្រប់គ្រាន់សម្រាប់ច្រកអន្តរ-ជាតិ (៤) ការការពារជម្រាលផ្លូវមិនគ្រប់គ្រាន់ ទប់ទល់នឹងទឹកជំនន់និងបញ្ហាតំហែទាំផ្លូវ។ តំហែទាំផ្លូវបានក្លាយជាបញ្ហាដ៏សំខាន់បំផុត ពីព្រោះវាជាគន្លឹះដើម្បីឱ្យផ្លូវនៅល្អបាន យូរហើយការខ្វះខាតតំហែទាំផ្លូវបានបណ្តាលឱ្យមានស្ថានភាពរឹតតែអាក្រក់ចំពោះផ្លូវភាគច្រើន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តែទោះជាយ៉ាងណាផ្លូវរថភ្លើងនិងផ្លូវទឹកក្នុងប្រទេសមានប្រសិទ្ធផលនៃការប្រើប្រាស់ថាមពលខ្ពស់ជាងក្នុងមួយឯកត្តានៃបរិមាណដែលត្រូវបានដឹកជញ្ជូន ជាងការដឹកជញ្ជូនជើងគោក និងមានឧត្តមភាពជាងចំពោះការដឹកបរិមាណច្រើនរយៈចម្ងាយឆ្ងាយ។ ពួកវាភ្ជាប់មជ្ឈមណ្ឌលសំខាន់ៗរបស់កម្ពុជា និងផ្ដល់ការតភ្ជាប់ជាមួយបណ្ដាញជើងគោក។ ជាងនេះទៅទៀត ការអភិវឌ្ឍផ្លូវដែកនិងផ្លូវទឹកក្នុងប្រទេស នឹងជួយសម្រាលផលប៉ះពាល់អវិជ្ជមាននានារបស់ការដឹកជញ្ជូនជើងគោកផងដែរ ដូចជា៖ ការកើនឡើងក្នុងការចំណាយលើតំហែទាំដែលបណ្ដាលដោយការខូចខាត ការក្រាលផ្លូវ ការស្ទះចរាចរ ឧបទ្ទវហេតុចរាចរនិងផលប៉ះពាល់បរិស្ថានអវិជ្ជមាននានា (សំឡេងការបំពុលខ្យល់និងរំញ័រ)។

រាជរដ្ឋាភិបាលកម្ពុជាបានណែនាំអភិក្រមច្នៃប្រឌិតខ្លះៗ ក្នុងការដឹកជញ្ជូនតាមជើងអាកាសដោយសង្កត់ធ្ងន់លើភាពជាដៃគូឯកជនសាធារណៈ (PPP) ក្នុងការស្ដាបនាឡើងវិញ និងការគ្រប់គ្រងនូវអាកាសយានដ្ឋាន។ នេះនឹងអនុញ្ញាតឱ្យកម្ពុជា ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជើងអាកាសបានយ៉ាងឆាប់រហ័ស ជាពិសេសក្នុងមជ្ឈមណ្ឌលទេសចរណ៍សំខាន់ៗ។ តែទោះជាយ៉ាងណា ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជើងអាកាសនៅតាមខេត្តដាច់ស្រយាល ដែលមានសកម្មភាពពាណិជ្ជកម្មមិនច្រើននោះនៅតែស្ថិតក្នុងសភាពព្រងើយកន្តើយ។

បញ្ហាគោលនយោបាយផ្សេងៗទៀតនោះ គឺការផ្ដល់ជូននូវមធ្យោបាយសម្រួលសុវត្ថិភាពចរាចរចុះខ្សោយដោយមិនមានបណ្ដាញ ផ្លូវខ្លះគុណភាពផ្លូវចាក់កៅស៊ូភាពងាយរងគ្រោះចំពោះទឹកជំនន់ឧបទ្ទវហេតុតាមដងផ្លូវកើនឡើងនិងការកកស្ទះចរាចរក្នុងទីក្រុងនិងតំបន់សំខាន់ៗ។

ហេដ្ឋារចនាសម្ព័ន្ធគឺជាលក្ខខណ្ឌចាំបាច់ដាច់ខាត ប៉ុន្តែមិនគ្រប់គ្រាន់ដើម្បីទាក់ទាញការវិនិយោគទុនបរទេសទេ។ ហេដ្ឋារចនាសម្ព័ន្ធទុនបច្ចុប្បន្ន ដើរតួនាទីយ៉ាងសំខាន់មួយក្នុងការអភិវឌ្ឍវិស័យសង្គមសេដ្ឋ-កិច្ច។ ដូច្នេះ បន្ថែមទៅនឹងការវិនិយោគទុនខាងហេដ្ឋារចនាសម្ព័ន្ធរឹងនោះកំណែទម្រង់ខាងហេដ្ឋារចនាសម្ព័ន្ធទុនដូចជាការសម្របសម្រួលពាណិជ្ជកម្ម ការគ្រប់គ្រងការឆ្លងកាត់ព្រំដែនដ៏មានប្រសិទ្ធផល និងការអភិវឌ្ឍប្រព័ន្ធធានារ៉ាប់រងឆ្លងព្រំដែននឹងមានសារៈសំខាន់ខ្លាំង ក្នុងការអភិវឌ្ឍច្រករបៀងឧស្សាហកម្មនៅកម្ពុជា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១៦
# វិស័យថាមពល

## ១៦.១. ទិដ្ឋភាពរួម

ការផ្គត់ផ្គង់ថាមពល គឺជាកត្តាដ៏សំខាន់ក្នុងការអភិវឌ្ឍ ដោយសារថាមពល គឺជាតម្រូវការដ៏ចាំបាច់បំផុតរបស់ប្រជាពលរដ្ឋ នៅក្នុងសង្គមទំនើប និងជាកត្តាផលិតកម្មមួយដែលមិនអាចខ្វះបាន ហើយចំណាយលើថាមពលជះឥទ្ធិពលដោយផ្ទាល់លើការប្រកួតប្រជែងរបស់ប្រទេស ក្នុងការផលិតទំនិញ និងផ្តល់សេវាដ៏សម្បូរបែប និងចូលរួមជាធាតុចូលដោយផ្ទាល់ និងដោយប្រយោលទៅក្នុងថ្លៃដើមទំនិញ និងសេវា។ យើងនៅមិនទាន់សិក្សាឱ្យបានអស់ពីសក្តានុពលខាងផ្នែកថាមពលរបស់កម្ពុជានៅឡើយ។ ក្នុងន័យនេះ កម្ពុជាត្រូវធ្វើការសិក្សាស៊ីជម្រៅ តាមរយៈការស្រាវជ្រាវរុករក និងការរៀបផែនទីនៃរបាយទីតាំងភូមិសាស្ត្រនៃប្រភពថាមពល ដែលមានទាំងអស់នៅក្នុងប្រទេស ក្នុងគោលដៅធានាឱ្យបាននូវការអភិវឌ្ឍជាលក្ខណប្រព័ន្ធក្នុងវិស័យថាមពល។ លទ្ធភាពអាចរកបានថាមពលដែលមានតម្លៃសមរម្យ គឺជាគ្រឿងផ្សំដ៏សំខាន់មួយនៃការអភិវឌ្ឍជនបទ ជាពិសេសក្នុងសកម្មភាពនានា ដូចជាការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ការកែច្នៃផលិតផលកសិកម្ម និងការអភិវឌ្ឍសហគ្រាសតូចនិងមធ្យម។ ថ្លៃអគ្គិសនីខ្ពស់នៅតាមទីជនបទ គឺជាឧបស័គ្គដ៏ចម្បងដែលរារាំងការអភិវឌ្ឍដ៏យឺតយ៉ាវនៃសេដ្ឋកិច្ចជនបទនៅក្នុងប្រទេសកម្ពុជា។

### ១៦.១.១. យុទ្ធសាស្ត្រវិស័យថាមពល

**យុទ្ធសាស្ត្រវិស័យថាមពលកម្ពុជា** (២០០១-២០០៥) បានកំណត់អាទិភាពនានា និងកម្មវិធីវិនិយោគ ក្នុងគោលដៅកាត់បន្ថយថ្លៃភ្លើង និងធានាការផ្គត់ផ្គង់អគ្គិសនីជូនប្រជាជនកម្ពុជា ឱ្យកាន់តែជឿទុកចិត្តកាន់តែច្រើនជាងមុន។ កម្មវិធីវិនិយោគនេះរួមមាន៖ (១) ការអភិវឌ្ឍប្រព័ន្ធផលិត និងចែកចាយថាមពល ដើម្បីតភ្ជាប់ស្ថានីយផលិតថាមពលធំៗ ជាមួយទីក្រុងភ្នំពេញនិងទីរួមខេត្តនានា (២) ការស្តារឡើងវិញនៃប្រព័ន្ធចែកចាយថាមពលក្នុងទីរួមខេត្ត និង (៣) ការអភិវឌ្ឍ និងការអនុវត្តផែនការអគ្គិសនីតាមជនបទ។ ការស្តារឡើងវិញ និងការពង្រីកប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញកំពុងត្រូវបានបន្ត។ សមត្ថភាពផលិតថាមពលក៏កំពុងត្រូវបានពង្រីក ជាមួយនឹងការបង្កើតបណ្តាញបញ្ជូនថាមពល ដែលតភ្ជាប់ជាមួយវៀតណាម និងតភ្ជាប់ជាមួយស្ថានីយផលិតថាមពលដើរដោយកម្តៅក្នុងតំបន់ឆ្នេរ នៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។ ការពង្រឹងសមត្ថភាពផលិតនិងបញ្ជូនចែកចាយនេះ នឹងធានាឱ្យមានការផ្គត់ផ្គង់អគ្គិសនីដែលគួរឱ្យជឿទុកចិត្ត និងផ្តល់សុវត្ថិភាព ដល់តំបន់ខាងក្រៅរាជធានីភ្នំពេញ ដែលនឹងជួយពង្រាយការអភិវឌ្ឍឧស្សាហកម្ម។

កម្មវិធីស្តីពីការបង្កើតបណ្តាញផលិតនិងចែកចាយថាមពលជាតិ បានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ ២០០០។ ដំណាក់កាលដំបូងនៃកម្មវិធីនេះ គឺការកសាងខ្សែបញ្ជូនថាមពលពីវៀតណាមមកភ្នំពេញ កាត់តាមខេត្តតាកែវ។ ដំណាក់កាលទីពីរ គឺការកសាងខ្សែបញ្ជូនថាមពលពីខេត្តព្រះសីហនុ ទៅខេត្តកំពត។ ប្រការនេះនឹងលើកទឹកចិត្តឱ្យមានការដាក់ទុនវិនិយោគ ក្នុងការផលិតថាមពលនៅតាមតំបន់ឆ្នេរ ដើម្បីផ្គត់ផ្គង់ថាមពលដល់ខេត្ត ដែលស្ថិតនៅចន្លោះពីខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ ហើយក៏បង្កើនសមត្ថភាពផ្គត់ផ្គង់

អគ្គិសនីនៅភ្នំពេញដែរ។ តាមរយៈការបង្កើតសមត្ថភាពផលិតថាមពលក្នុងតំបន់ផ្ទេរ នោះវានឹងកាត់បន្ថយតម្រូវការដឹកជញ្ជូនប្រេងលើដងទន្លេមេគង្គ ដែលអាចកាត់បន្ថយគ្រោះថ្នាក់នៃការកំពប់ប្រេងនិងការខូចខាតផ្នែកបរិស្ថាន។ រាជរដ្ឋាភិបាលបានចាប់ផ្តើមសាងសង់មុនគេនូវបណ្តាញបញ្ជូនអគ្គិសនីពីភ្នំពេញទៅព្រំដែនវៀតណាម កាត់តាមខេត្តតាកែវ ដើម្បីជំរុញការនាំចូលអគ្គិសនីពីវៀតណាម។ បណ្តាញបញ្ជូនអគ្គិសនី ២២០គីឡូវ៉ាត់ពីវៀតណាមនឹងផ្គត់ផ្គង់អគ្គិសនី ដល់សហគមន៍នៅភាគខាងត្បូង និងបង្កើនសមត្ថភាពផ្គត់ផ្គង់ថាមពលដល់ក្រុងភ្នំពេញ។

យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍវិស័យថាមពល បានដាក់ចេញនូវអាទិភាពដូចខាងក្រោម៖ (១) ការពង្រីកសមត្ថភាពផលិត (ការលើកកម្ពស់ភាពទាក់ទាញចិត្ត ដើម្បីផ្តល់ការលើកទឹកចិត្តដល់វិនិយោគទុនក្នុងការផលិតអគ្គិសនី) (២) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មថាមពល តាមរយៈការចូលរួមពីវិស័យឯកជន (៣) ការផ្តល់ហិរញ្ញប្បទានដើម្បីអភិវឌ្ឍវិស័យថាមពល (៤) ការធ្វើពិពិធកម្មនៃប្រភពថាមពល (៥) ការលើកកម្ពស់ និងការធានាសុវត្ថិភាពថាមពលជូនប្រជាជន ជាពិសេសចំពោះប្រេងឥន្ធនៈក្នុងស្រុក និង (៦) ការលើកកម្ពស់អគ្គិសនីភាវូបនីយកម្មតាមជនបទ។

## ១៦.១.២. អគ្គិសនីភាវូបនីយកម្មតាមជនបទ

រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងអនុវត្ត **កម្មវិធីអគ្គិសនីភាវូបនីយកម្មតាមជនបទក្នុងរយៈពេល៥ឆ្នាំ** រួមទាំងថាមពលកកើតឡើងវិញ។ ចំណាយសរុបនៃផ្នែកទីមួយនៃគម្រោងសាងសង់បណ្តាញបញ្ជូនចែកចាយ និងអគ្គិសនីភាវូបនីយកម្មតាមទីជនបទ ត្រូវបានប៉ាន់ស្មានអស់ ៨៩ លានដុល្លារ។ បណ្តាញបញ្ជូនអគ្គិសនីកម្លាំង ១១៥ គីឡូវ៉ុលមួយទៀត ក៏ត្រូវបានសាងសង់ឡើង ដើម្បីតភ្ជាប់ប្រទេសថៃទៅខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ដើម្បីគាំទ្រដល់កម្មវិធីអគ្គិសនីភាវូបនីយកម្មតាមទីជនបទ និងតាមខេត្ត។ ផែនការទាំងនេះ ក៏រួមបញ្ចូលផងដែរនូវការអភិវឌ្ឍគម្រោងវារីអគ្គិសនីទីមួយនៅកម្ពុជា គឺស្ថានីយវារីអគ្គិសនីកំចាយ ហើយបន្ទាប់មក គឺការសាងសង់ស្ថានីយវារីអគ្គិសនីនៅតាមស្ទឹងបាត់ដំបង ស្ទឹងអាតៃ និងឫស្សីជ្រុំ។

ការសាងសង់ស្ថានីយវារីអគ្គិសនីនៅកម្ពុជាទាមទារឱ្យរក្សានូវតុល្យភាពជាចាំបាច់ រវាងកម្មវត្ថុនៃកំណើនសេដ្ឋកិច្ច បរិស្ថាន និងសមធម៌ក្នុងសង្គម។ កម្ពុជាត្រូវខិតខំប្រឹងប្រែង ដើម្បីជៀសវាងកំហុសឆ្គងដូចប្រទេសជិតខាង ដោយសារការអភិវឌ្ឍថាមពលវារីអគ្គិសនី បានបង្កើតឡើងនូវបញ្ហាបរិស្ថាន សេដ្ឋកិច្ច និងសង្គម។ កម្មវិធីអគ្គិសនីភាវូបនីយកម្មទីជនបទត្រូវមានគោលដៅបង្កើនការបង្កើតការងារនៅតាមទីជនបទ និងបង្កើតចំណូលកាន់តែខ្ពស់សម្រាប់ប្រជាជនក្រីក្រ។

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត **មូលនិធិអគ្គិសនីជនបទ** (REF) ក្នុងឆ្នាំ២០០៤ ដោយមានការគាំទ្រពីធនាគារពិភពលោក ដែលមានគោលដៅបង្កើតលទ្ធភាពផ្គត់ផ្គង់អគ្គិសនី តាមថ្លៃសមរម្យ ជូនប្រជាជនដែលរស់នៅតាមទីជនបទ សម្រាប់ការប្រើប្រាស់ខាងផ្នែកសង្គម និងសេដ្ឋកិច្ច។ **មូលនិធិអគ្គិសនីជនបទ** ទទួលនូវហិរញ្ញប្បទានតាមរយៈជំនួយឥតសំណងការឧបត្ថម្ភធននិងការខ្ចីបុល។យន្តការ "ការឧបត្ថម្ភធនឆ្លាតវៃ" ដែលត្រូវអនុវត្តក្នុងក្របខណ្ឌនៃ **មូលនិធិអគ្គិសនីជនបទ** នឹងលើកទឹកចិត្តដល់សហគ្រិនឱ្យវិនិយោគក្នុងការផលិត និងការចែកចាយអគ្គិសនីតាមជនបទ ជាពិសេសគម្រោងថាមពលកកើតឡើងវិញ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១៦.២. ការផលិតអគ្គិសនី

ក្រុមហ៊ុនអគ្គិសនីកម្ពុជា (EDC) គឺជាសហគ្រាសរដ្ឋ បង្កើតឡើងក្នុងឆ្នាំ១៩៩២ ក្នុងគោលដៅធានាការផលិត និងចែកចាយអគ្គិសនី។ ក្នុងខែមីនាឆ្នាំ ១៩៩៦ EDC ត្រូវបានបង្កើតទៅជាក្រុមហ៊ុនរដ្ឋ ដែលមានបេសកកម្មចម្បង គឺការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនីទូទាំងប្រទេសកម្ពុជា។ ទោះបីជា EDC បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ក្នុងការបំពេញបេសកកម្មនេះក៏ដោយ ក៏កម្ពុជានៅតែមិនទាន់ផ្គត់ផ្គង់អគ្គិសនីជូនប្រជាពលរដ្ឋបានតាមសេចក្ដីត្រូវការនៅឡើយ។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យ៉ាងច្បាស់នូវរបៀបវារៈសម្រាប់ពេលអនាគត។ ជាដំបូង គឺត្រូវធានានូវការទុកចិត្តក្នុងការផ្គត់ផ្គង់អគ្គិសនី ហើយការផលិតថាមពលត្រូវទទួលបាននូវផលចំណេញ ដើម្បីទាក់ទាញការវិនិយោគ។ ក្នុងន័យនេះ បញ្ហាជាអាទិភាព គឺកម្មវិធីអគ្គិសនីភាវូបនីយកម្មជនបទ ការកសាងសមត្ថភាពស្ថាប័ន EDC និងការពង្រឹងស្វ័យភាពហិរញ្ញវត្ថុក្នុងវិស័យថាមពល។

### ១៦.២.១. សមត្ថភាពផលិតថាមពល

រូបភាព១.២.១.បង្ហាញពីសមត្ថភាពផលិតថាមពលនៅកម្ពុជា។ សមត្ថភាពផលិតថាមពលនៅកម្ពុជាបានកើនឡើងពី ៨៩ MW ក្នុង១៩៩៨ ទៅដល់ ១២៩ MW ក្នុងឆ្នាំ២០០២ និងទៅដល់ ១៥៧.៤MW ក្នុងឆ្នាំ២០០២ និងបន្ទាប់មកដល់ ២៨៤.៥MW ក្នុងឆ្នាំ ២០០៧។

*ក្រាហ្វិក. ១៦.១. សមត្ថភាពផលិតអគ្គិសនី*




*ប្រភព៖ អគ្គិសនីកម្ពុជា*

ដើម្បីបំពេញកង្វះខាតរវាងតម្រូវការនិងការផ្គត់ផ្គង់ កម្ពុជាកំពុងទិញថាមពលអគ្គិសនីពីប្រទេសជិតខាង គឺ ពីថៃ និងវៀតណាម។ ដូចនេះ សមត្ថភាពផ្គត់ផ្គង់ថាមពលរបស់កម្ពុជាបានកើនឡើងដល់ ៣៩០ MW ក្នុងឆ្នាំ២០០៧។ នៅក្នុងនោះ សមត្ថភាពផលិតផ្ទាល់របស់ EDC មាន ២០% ផលិតករថាមពលឯករាជ្យ (IPP) មានចំនួន ៥៣% និងការនាំថាមពលចូលមានចំនួន ២៧%។ ថាមពលអគ្គិសនីត្រូវបានបញ្ជូន តាមរយៈបណ្ដាញបញ្ជូនអគ្គិសនី និងចែកចាយ ដែលបែងចែកថាមពលអគ្គិសនីទៅតាមតំបន់ទីក្រុងជាអាទិភាព។ ចំណែកឯនៅតាមទីជនបទ ដែលការផ្គត់ផ្គង់អគ្គិសនីនៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ នោះអ្នកប្រើប្រាស់ខ្លះបានប្រើប្រាស់ម៉ាស៊ីនភ្លើង ដើម្បីបំពេញសេចក្ដីត្រូវការខាងផ្នែកថាមពល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១៦.២.២. ការផលិតអគ្គិសនី

ការផលិតអគ្គិសនីនៅកម្ពុជាបានកើនឡើងពី ៥៤៨ GWh (ជីហ្គាវ៉ាត់ម៉ោង) ក្នុងឆ្នាំ២០០២ ដល់១,៣៧៨ GWh ក្នុងឆ្នាំ២០០៧។ ភ្នំពេញគឺជាមជ្ឈមណ្ឌលផលិតអគ្គិសនីនាំមុខគេ ជាមួយនឹង៩០%នៃការផលិតថាមពលថ្នាក់ជាតិ។ ផលិតផលអគ្គិសនីរបស់ផលិតករភ្លើងឯករាជ្យមានចំនួន ៨១% នៃផលិតផលសរុប បន្ទាប់មកគឺការផលិតអគ្គិសនីដោយ EDC (១៣%) និងការនាំចូល (៦%)។ ថ្លៃដើមផលិតក្នុងមួយគីឡូវ៉ាត់ម៉ោង គឺ០.១៥ ដុល្លារដែលជាថ្លៃខ្ពស់បំផុត បើប្រៀបធៀបជាមួយប្រទេសផ្សេងទៀតក្នុងតំបន់។ មូលហេតុចម្បងនៃតម្លៃខ្ពស់នេះគឺៈ រោងចក្រផលិតថាមពលអគ្គិសនីតូច ការប្រចាប់ប្រភពថាមពលបញ្ចូលគ្នាមិនបានល្អប្រសើរ សមត្ថភាពទាប រោងចក្រផលិតថាមពលអគ្គិសនីប្រើប្រាស់ប្រេងម៉ាស៊ូត និងថ្លៃដើមគ្រប់គ្រងខ្ពស់។ ដោយសារចំណាយខ្ពស់ទាំងអស់នេះ វិស័យថាមពលបង្ករជាឧបសគ្គចម្បងមួយ ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាទូទៅ និងដោយឡែកសម្រាប់វិស័យឯកជន។

*រូបភាព ១៦.២. ផលិតផលអគ្គិសនី(GWh)*




| | 2002 | 2003 | 2004 | 2005 | 2006 | 2007 |
|---|---|---|---|---|---|---|
| Imported | 3 | 8 | 14 | 24 | 42 | 83 |
| EDC | 171 | 211 | 326 | 275 | 210 | 178 |
| IPP | 374 | 413 | 422 | 607 | 854 | 1117 |
| Total | 548 | 632 | 761 | 906 | 1106 | 1378 |

*ប្រភព៖ អគ្គិសនីកម្ពុជា*

ដើម្បីដោះស្រាយបញ្ហាតម្លៃខ្ពស់នៃការផ្គត់ផ្គង់ថាមពលនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ វិធានការជ្រើសរើសអ្នកផលិតអគ្គិសនីឯករាជ្យ តាមរយៈនីតិវិធីដេញថ្លៃប្រកួតប្រជែង និងកំពុងលើកកម្ពស់ការវិនិយោគនិងការចូលរួមពីវិស័យឯកជនក្នុងការចែកចាយអគ្គិសនី នៅតាមមជ្ឈមណ្ឌលខេត្តនិងតាមទីក្រុងធំៗ និងតាមតំបន់ជនបទ។ គំនិតផ្ដួចផ្ដើមទាំងនេះ បានជួយបង្កើនការផលិតអគ្គិសនីសរុបក្នុងរាជធានីភ្នំពេញ និងក្នុងទីរួមខេត្តពី ៩១៤.៩GWh ក្នុងឆ្នាំ១៩៩៨ ដល់ ១,៣៧៨GWh ក្នុងឆ្នាំ២០០៧ ឬសម្រេចបាននូវកំណើនប្រចាំឆ្នាំជាមធ្យម៣៣%។ ការបង្កើនផលិតអគ្គិសនីបានកាត់បន្ថយថ្លៃដើមឯកតាបន្ថែម មួយកម្រិតថែមទៀត បើប្រៀបធៀបនឹងថ្លៃផលិតថាមពលជាមធ្យម។ ជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍន៍របស់កម្ពុជា និងវិស័យឯកជន គម្រោងការផលិតថាមពលមួយចំនួនត្រូវបានអនុវត្តចប់សព្វគ្រប់ ឬកំពុងស្ថិតនៅក្នុងដំណាក់កាលអនុវត្ត។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានរៀបផែនការអភិវឌ្ឍគម្រោងថ្មីៗមួយចំនួនទៀត។ គម្រោងអភិវឌ្ឍវិស័យថាមពល ដែលត្រូវបានអនុវត្តចប់សព្វគ្រប់ រួមមាន៖


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- បណ្តាញចែកចាយអគ្គិសនីក្នុងតំបន់ជាយក្រុងភ្នំពេញបួនកន្លែង បានបញ្ចប់ក្នុងឆ្នាំ ២០០១ ដែលនាពេលបច្ចុប្បន្ននេះកំពុងបម្រើឱ្យអ្នកប្រើប្រាស់ថ្មីចំនួនប្រមាណ ១០,០០០នាក់។ គម្រោងនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយប្រទេសជប៉ុន (២៦.៨ លានដុល្លារសហរដ្ឋអាមេរិក)។
- ការកសាងស្ថានីយវារីអគ្គិសនីគិរីរម្យ១ កម្លាំង១២MW និងខ្សែបញ្ជូនតភ្ជាប់ស្ថានីយនេះជាមួយទីក្រុងភ្នំពេញ ដែលបានបញ្ចប់ក្នុងឆ្នាំ២០០២ ក្រោមកិច្ចព្រមព្រៀងសាងសង់-ប្រតិបត្តិការ-ផ្ទេរ (BOT) ជាមួយក្រុមហ៊ុនចិន CETIC។
- ការសាងសង់រោងចក្រអគ្គិសនី ១០MW ថ្មីមួយក្នុងខេត្តសៀមរាបបានបញ្ចប់ក្នុងខែមីនាឆ្នាំ ២០០៤ មានតម្លៃ ១៧.០៤លានដុល្លារដែលផ្តល់ហិរញ្ញប្បទានដោយប្រទេសជប៉ុន។

ម្ចាស់ជំនួយដែលផ្តោតលើការស្តារឡើងវិញវិស័យអគ្គិសនីនេះ រួមមានអូស្ត្រាលី ធនាគារអភិវឌ្ឍអាស៊ី ធនាគារពិភពលោក បារាំង ជប៉ុន និង ស៊ុយអែត។ ការរួមចំណែកពីសំណាក់វិស័យឯកជនកំពុងកើនឡើង ដូចជាការកសាងស្ថានីយអគ្គិសនីនៅភ្នំពេញ IPP1-CUPL (៣៥MW) ដែលបានបញ្ចប់ក្នុងឆ្នាំ១៩៩៦ និង IPP2-Jupiter ដែលមានសមត្ថភាពផលិត (១៥MW)។ អគ្គិសនីកម្ពុជាក៏បានចុះកិច្ចព្រមព្រៀងស្តីពីការកសាងរោងចក្រអគ្គិសនី IEP (៣០MW) ក្នុងឆ្នាំ២០០៥។ ការកសាងឡើងវិញនៃបណ្តាញបញ្ជូនអគ្គិសនីនៅក្នុងទីរួមខេត្តទាំងប្រាំបីត្រូវបានបញ្ចប់ត្រឹមឆ្នាំ ២០០៥។ គម្រោងក្នុងទីក្រុងចំនួនប្រាំពីរ (កំពត ព្រៃវែង បន្ទាយមានជ័យ រតនគិរី កំពង់ស្ពឺ តាកែវ និងស្វាយរៀង) ត្រូវបានផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍអាស៊ី តាមរយៈកម្ចីចំនួន ១៨.៦ លានដុល្លារអាមេរិក។ គម្រោងទីប្រាំបីក្នុងក្រុងស្ទឹងត្រែងត្រូវបានផ្តល់ហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍ (AFD) ក្នុងទឹកប្រាក់ចំនួន ៣.៧៥ លានអឺរ៉ូ។

*តារាង ១៦.៣. ការលក់អគ្គិសនី ១៩៩៨-២០០៧*




*ប្រភពៈអគ្គិសនីកម្ពុជា*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១៦.២.៣. ការលក់អគ្គិសនី

ការលក់អគ្គិសនីបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយសម្រេចបានប្រហែល ៥៣៧ GWh ក្នុងឆ្នាំ ២០០៧ ដោយតម្រូវការថាមពលបានកើនឡើងយ៉ាងឆាប់រហ័ស ជាមធ្យមតាមអត្រា ១៥-២០% ក្នុងមួយឆ្នាំ។ ចំនួនអតិថិជនរបស់ EDC ក៏បានកើនឡើងយ៉ាងឆាប់រហ័សផងដែរ។

*ក្រាហ្វិក. ១៦.៤. កំណើនអតិថិជន EDC ១៩៩៥-២០០៧*




*ប្រភព៖ អគ្គិសនីកម្ពុជា*

ក្នុងឆ្នាំ ២០០៧ ឱនភាពថាមពលអគ្គិសនីនៅក្នុងប្រទេសកម្ពុជាបានកើនឡើងដល់ ៣០MW។ EDCបានពន្យល់ថាឱនភាព បណ្តាលមកពីសមត្ថភាពផលិតថាមពលមានមិនគ្រប់គ្រាន់ កំណើនខ្លាំងខាងតម្រូវការ ដោយសារការតភ្ជាប់បណ្តាញថ្មី និងការយឺតយ៉ាវក្នុងកៀរគរធនធានហិរញ្ញវត្ថុចាំបាច់សម្រាប់ការបញ្ចប់ការវិនិយោគថ្មីៗ។ កម្ពុជាបន្តខ្វះថាមពលអគ្គិសនីនេះតទៅទៀត ដែលនឹងនាំឱ្យមានការដាច់ភ្លើងជារឿយៗ ហើយអ្នកប្រើប្រាស់ច្បាស់ជាត្រូវទិញម៉ាស៊ីនភ្លើង ដែលមានថ្លៃដើមផលិតខ្ពស់ និងដែលប្រើប្រេងម៉ាស៊ូតដែលគ្មានប្រសិទ្ធផល ក្នុងគោលដៅទទួលបានការផ្គត់ផ្គង់ថាមពល ដែលមិនមានការរំខាន។

ចំណែកនៃផលិតផលប្រេង និងអគ្គិសនី ក្នុងចំណាយសរុបនៃក្រុមហ៊ុនអគ្គិសនីកម្ពុជាមានកម្រិតខ្ពស់ ដោយសារតែការយកពន្ធខ្ពស់លើការនាំចូលនូវផលិតផលតលសិលា ដើម្បីយកមកផលិតថាមពលអគ្គិសនី និងដោយសារដំណើរការផលិតនេះមានប្រសិទ្ធភាពទាប។ ចំណាយលើថ្លៃដើមខ្ពស់នេះបានកាត់បន្ថយភាពប្រកួតប្រជែងរបស់ក្រុមហ៊ុនអគ្គិសនីកម្ពុជាជាខ្លាំង។ ម្យ៉ាងវិញទៀត ថ្លៃអគ្គិសនីខ្ពស់នឹងធ្វើឱ្យប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនកម្ពុជា និងធ្វើឱ្យរំខានជាខ្លាំងដល់ ស្ថាប័នរដ្ឋបាលសាធារណៈ ការធ្វើអាជីវកម្មពាណិជ្ជកម្ម និងវិស័យសុខាភិបាល។

កំណែទម្រង់នៃវិស័យថាមពលមានគោលបំណងធានាឱ្យបាននូវការផ្គត់ផ្គង់អគ្គិសនី ជូនដល់សហគមន៍ និងអាជីវករ ក្នុងតម្លៃមួយសមរម្យ និងបង្កើនល្បឿននៃអគ្គិសនីហូបនីយកម្ម ទាំងនៅទីក្រុង ទាំងនៅតាមទីជនបទ។ កំណែទម្រង់នេះមានគោលដៅបំបែកបន្តិចម្តងៗនូវមុខងារនៃការផលិត ការបញ្ជូន និងការចែកចាយដើម្បីជម្រុញការប្រកួតប្រជែង។ ដើម្បីសម្រេចបានគោលដៅនេះ រាជរដ្ឋាភិបាលបានរៀបចំក្របខ័ណ្ឌគតិយុត្តិ ក្នុងការរៀបចំបទបញ្ញា និងធ្វើវចនាសម្ព័ន្ធឡើងវិញក្នុងវិស័យនេះ ដែលឈានទៅរកការបង្កើតអាជ្ញាធរអគ្គិសនីកម្ពុជាផងដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## តារាង ១៦.១. សមត្ថភាពដំឡើងនិងផលិតផលអគ្គិសនីអតិបរិមា (គិតជាMW)

| Lieu | | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|---|
| **PHN** | | **66.60** | **85.00** | **100.50** | **95.00** | **101.00** | **101.00** | **121.40** | **141.90** | **192.40** | **200.49** |
| **EDC** | EDC | 41.60 | 59.00 | 55.50 | 50.00 | 50.00 | 50.00 | 58.40 | 43.00 | 42.60 | 42.60 |
| **IPP-1** | IPP | 5.00 | 6.00 | 0.00 | - | - | - | - | - | - | - |
| **CUPL** | IPP | - | - | - | 30.00 | 30.00 | 30.00 | 31.00 | 31.90 | 31.90 | 31.99 |
| **JUPITER** | IPP | - | - | 5.00 | 15.00 | 15.00 | 15.00 | 22.00 | 22.00 | - | - |
| **Tang Heang** | IPP | - | - | - | - | - | - | - | - | - | 8.00 |
| **CITEC** | IPP | - | - | - | - | 6.00 | 6.00 | 10.00 | 10.00 | 11.00 | 11.00 |
| **KEP** | IPP | - | - | - | - | - | - | - | 30.00 | 45.00 | 45.00 |
| **City Power** | IPP | - | - | - | - | - | - | - | 5.00 | 6.90 | 6.90 |
| **CEP** | IPP | - | - | - | - | - | - | - | - | 45.00 | 45.00 |
| **COLBEN** | IPP | - | - | - | - | - | - | - | - | 10.00 | 10.00 |
| **SRP** | | **2.40** | **2.80** | **2.80** | **4.00** | **6.90** | **6.90** | **10.50** | **10.50** | **15.00** | **58.80** |
| | IPP | - | 1.45 | 1.45 | 4.00 | 6.90 | 6.90 | - | - | 4.50 | 8.30 |
| | EDC | 2.40 | 1.35 | 1.35 | - | - | - | 10.50 | 10.50 | 10.50 | 10.50 |
| | IMP | - | - | - | - | - | - | - | - | - | 40.00 |
| **SHV** | | **8.94** | **7.80** | **7.80** | **7.00** | **7.00** | **7.00** | **6.30** | **6.20** | **6.20** | **13.20** |
| | IPP | - | - | - | - | - | - | - | - | - | 7.00 |
| | EDC | - | - | - | 7.00 | 7.00 | 7.00 | 6.30 | 6.20 | 6.20 | 6.20 |
| **KGC** | IPP | .44 | .66 | .66 | 2.00 | 2.00 | 2.00 | 4.26 | 4.26 | 1.90 | 1.90 |
| **PKK** | IMP | - | - | - | - | 0.70 | 0.70 | 0.70 | 2.00 | 2.00 | 5.00 |
| **MMT** | IMP | - | - | - | - | 1.75 | 1.75 | 1.75 | 3.00 | 3.00 | 5.00 |
| **TKO** | | **-** | **-** | **0.90** | **-** | **-** | **-** | **-** | **1.50** | **1.50** | **1.50** |
| | IPP | - | - | .90 | - | - | - | - | - | - | - |
| | EDC | - | - | - | - | - | - | - | 1.50 | 1.50 | 1.50 |
| **BTB** | | **6.00** | **-** | **-** | **3.50** | **5.00** | **5.00** | **5.10** | **6.50** | **6.50** | **26.90** |
| | IPP | 6.00 | - | - | 2.70 | 4.20 | 4.20 | 4.30 | 5.70 | 5.70 | 6.10 |
| | EDC | - | - | - | 0.80 | 0.80 | 0.80 | 0.80 | 0.80 | 0.80 | 0.80 |
| | IMP | - | - | - | - | - | - | - | - | - | 20.00 |
| **BVT** | IMP | - | - | - | - | 0.80 | 0.80 | 0.80 | 2.00 | 2.00 | 5.00 |
| **KGT** | IMP | - | - | - | - | - | 1.00 | 1.00 | 1.00 | 1.00 | 3.00 |
| **KPT** | | - | - | - | - | - | - | - | 3.00 | 3.00 | 3.00 |
| | IPP | - | - | - | - | - | - | - | - | - | - |
| | EDC | - | - | - | - | - | - | - | 3.00 | 3.00 | 3.00 |
| **PRV** | | - | - | - | - | - | - | - | 2.35 | 1.50 | 1.50 |
| | IPP | - | - | - | - | - | - | - | 0.85 | - | - |
| | EDC | - | - | - | - | - | - | - | 1.50 | 1.50 | 1.50 |
| **SVR** | IMP | - | - | - | - | - | - | - | 2.00 | 7.50 | 7.50 |
| **BTC** | | - | - | - | - | - | - | - | 3.00 | 3.00 | 23.00 |
| | EDC | - | - | - | - | - | - | - | 3.00 | 3.00 | 3.00 |
| | IMP | - | - | - | - | - | - | - | - | - | 20.00 |
| **STR** | EDC | - | - | - | - | - | - | - | 1.50 | 1.50 | 1.50 |
| **RTK** | | - | - | - | - | - | - | 1.36 | 1.36 | 1.36 | 1.76 |
| | IPP | - | - | - | - | - | - | 0.40 | 0.40 | 0.40 | 0.80 |
| | EDC | - | - | - | - | - | - | 0.96 | 0.96 | 0.96 | 0.96 |
| **TOTAL** | EDC | 4.00 | 60.35 | 6.85 | 57.80 | 57.80 | 57.80 | 76.96 | 1.96 | 71.56 | 71.56 |
| | IEP | 2.44 | 29.11 | 9.01 | 53.70 | 64.10 | 64.10 | 71.96 | 110.11 | 162.30 | 181.99 |
| | IMP | - | - | - | - | 3.25 | 4.25 | 4.25 | 10.00 | 15.50 | 105.50 |
| | TOTAL | 76.44 | 9.46 | 105.86 | 111.50 | 125.15 | 126.15 | 153.17 | 192.07 | 249.36 | 359.05 |

ប្រភព៖ អគ្គិសនីកម្ពុជា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១៦.៣. ផែនការអភិវឌ្ឍន៍វិស័យថាមពល

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលដៅសំខាន់ៗដូចតទៅ៖ ធ្វើការផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យបានគ្រប់គ្រាន់ តាមថ្លៃសមល្មម ធានាការផ្គត់ផ្គង់ថាមពលអគ្គិសនី គួរឱ្យជឿទុកចិត្ត និងមានសុវត្ថិភាព និងលើកកម្ពស់ការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព។

### ១៦.៣.១. ការព្យាករណ៍តម្រូវការថាមពល

យោងតាមផែនការស្តីពីការអភិវឌ្ឍវិស័យថាមពលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ តម្រូវការថាមពលអគ្គិសនីនឹងកើនឡើងយ៉ាងខ្លាំង ក្នុងរយៈពេល ១៤ ឆ្នាំខាងមុខ។ តាមការព្យាករណ៍ ការផលិតអគ្គិសនីនៅកម្ពុជានឹងកើនឡើងពី ៣២៩ MW និង ១,៥៤៨ GWh ក្នុងឆ្នាំ ២០០៦ ដល់១,៥៣៩ MW និង ៨,១៧៦ GWh ក្នុងឆ្នាំ ២០២០។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ *ផែនការអភិវឌ្ឍន៍វិស័យថាមពលសម្រាប់ឆ្នាំ ២០០៨-២០២១*។

តារាងខាងក្រោមបង្ហាញពីការព្យាករណ៍នៃការផលិតថាមពលអគ្គិសនី ដែលគេរំពឹងទុកថានឹងកើនឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

*តារាង ១៦.២. ការព្យាករណ៍នៃការផលិតថាមពលអគ្គិសនី*

| ឆ្នាំ | ២០០៩ | ២០១០ | ២០១៥ | ២០២០ |
|---|---|---|---|---|
| កំលាំង, MW | ៨០៨ | ១០១៥ | ១,៩១៥ | ៣៨,៦៧ |
| ថាមពល, GWh | ១,៥៥០ | ១,៨៩៥ | ៣,៥០០ | ៨,៣០០ |

*ប្រភព៖ អគ្គិសនីកម្ពុជា*

### ១៦.៣.២. ផែនការមេស្តីពីការផលិតថាមពល

ផែនការមេផលិតថាមពលត្រូវបានរៀបចំដោយឈរលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖ (១)រោងចក្រផលិតថាមពលអគ្គិសនីបន្ទុកខ្ពស់ ដោយប្រើប្រេងឥន្ធនៈនៅភ្នំពេញ (២) រោងចក្រប្រើប្រេងម៉ាស៊ូតខ្នាតតូច និងមធ្យមសម្រាប់ការផលិតថាមពលអគ្គិសនី បន្ទុកមូលដ្ឋាន និងបន្ទុកខ្ពស់ក្នុងទីរួមខេត្ត និងនៅក្រុងនិង (៣) ការអភិវឌ្ឍស្ថានីយវារីអគ្គិសនី ដែលផ្អែកជាបឋមលើស្ថានីយវារីអគ្គិសនីខ្នាតតូច ដូចជា នៅគិរីរម្យ កំចាយ ហើយនៅដំណាក់កាលបន្ទាប់ គឺការសាងសង់ស្ថានីយវារីអគ្គិសនីខ្នាតមធ្យមដូចជា ស្ទឹងអាតៃ ស្ទឹងឫស្សីជ្រុំកណ្តាល បាត់ដំបង ទន្លេស្រែពកក្រោម២ ឬទន្លេសេសានក្រោម។ ស្ថានីយវារីអគ្គិសនីកំចាយ ដែលមានសមត្ថភាពផលិតចំនួន ១៩៣ MW ត្រូវបានសាងសង់រួចក្នុងឆ្នាំ ២០១០ ដោយឈរលើគោលការណ៍ BOT។

ផែនការនេះត្រូវបានរៀបចំឡើង ដោយឈរលើយុទ្ធសាស្ត្រខាងក្រោម៖ (១) កាត់បន្ថយការពឹងផ្អែកលើប្រេងនាំចូលសម្រាប់ការផលិតថាមពល (ភាពសម្បូរបែបនៃប្រភពថាមពល) (២) បង្កើនប្រសិទ្ធភាពផ្នែកប្រតិបត្តិការរបស់ប្រព័ន្ធ (បន្ថយការខាតបង់) (៣) លើកទឹកចិត្តការអភិវឌ្ឍស្ថានីយដែលមានតម្លៃទាបបំផុតនៃមជ្ឈមណ្ឌលបន្ទុក នៅតាមខេត្តដោយ តាមរយៈការបញ្ចូលគ្នា រវាងការពង្រីកប្រព័ន្ធបញ្ជូនចែកចាយ និងការផលិតថាមពលដោយក្រុមហ៊ុនឯកជនក្នុងស្រុក និង (៤) បង្កើនការប្រកួតប្រជែងខាងការផលិតថាមពលដោយផ្តល់លទ្ធភាពដល់ប្រភពថាមពលពីក្រៅ ដែលមានតម្លៃប្រកួតប្រជែងពីវៀតណាម ថៃ និងឡាវ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាង ១៦.៣. ផែនការផលិតថាមពលសម្រាប់ឆ្នាំ ២០០៨-២០២១*

| *ឆ្នាំ* | *ឈ្មោះគម្រោង* | | *High case* | |
|---|---|---|---|---|
| | | *ប្រភេទបណ្តាញ* | *ផ្នែក (mm2)* | *Ling length* |
| ២០០៨ | សាងសង់ 230kV វៀតណាម-ភ្នំពេញតភ្ជាប់ S/S * | D-C | ៦៣០,៤០០ | ១១១ |
| ២០១០ | 230kV តាកែវ-កំពត | D-C | ៤០០ | ១០០ |
| ២០១១ | 115kV កំពង់ចាម-ក្រចេះ | D-C | ៦៣០ | ៨៧ |
| ២០១០ | 115kV ឡាវ-ស្ទឹងត្រែង | D-C | ២៤០ | ៥៦ |
| ២០១០ | 115kV វៀតណាម-សួង-ក្រែក-កំពង់ចាម | D-C | ៤០០ | ៦៤ |
| ២០១០ | 230kV កំពត-សីហនុ | D-C | ៦៣០ | ៨២ |
| ២០១១ | 230kV កំពត-តភ្ជាប់ស្ថានីយវារីអគ្គិសនីកំចាយ | D-C | ៦៣០ | ២០ |
| ២០១១ | 115kV ស្ទឹងត្រែង – ក្រចេះ | D-C | ៤០០ | ១៣០ |
| ២០១២ | 230kV WPP-កំពង់ឆ្នាំង-ពោធិ៍សាត់-បាត់ដំបង | D-C | ៦៣០*២B | ៣១០ |
| ២០១២ | 230kV ពោធិ៍សាត់-អូរសោម | D-C | ៦៣០ | ៨០ |
| ២០១២ | 115kV អូរសោម-អាតៃរួមបញ្ចូល S/S | D-C | ៦៣០ | ៣០ |
| ២០១២ | 115kV GS1-NPP-WPP | D-C | ២៥០*២B | ២៨ |
| ២០១២ | 115kVGS2-SPP- WPP | D-C | 250*2B | ២៥ |
| ២០១២ | 115/230kV NPP-កំពង់ចាម | D-C | ២៥០*២B | ១២០ |
| ២០១៣ | 230kV ឫស្សីជ្រុំលើនិងក្រោម- អូរសោម | D-C | ៦៣០ | ៣០ |
| ២០១៣ | 230kV WPP-SHV រួមបញ្ចូលវាលរិញ S/S | D-C | ៦៣០ | ២២០ |
| ២០១៤ | 115kV SPP-EPP-NPP | D-C | ២៥០ | ២០ |
| ២០១៤ | 115kV EPP-នាក់លឿង-ស្វាយរៀងតភ្ជាប់ S/S | D-C | ២៥០*២B | ១២២ |
| ២០១៧ | 230kV ក្រចេះ-សេសានក្រោម2 - វៀតណាម | D-C | ៦៣០ | ៩០ |
| ២០១៧ | 230kV WPP-NPP | D-C | ៦៣០ | ២៥ |
| ២០១៧ | 230kV NPP-កំពង់ចាម-ក្រចេះ-សេសាន2-វៀតណាម | D-C | ៦៣០ | ៣០០ |
| ២០១៨ | 230kV ស្រែអំបិល-កោះកុង-អូរសោម | D-C | ៤០០ | ២០០ |
| ២០១៩ | ២៣០kV សម្បូរ – ក្រចេះ | D-C | ៦៣០ | ៣០ |
| ២០២១ | ២៣០kV កំពង់ចាម-កំពង់ធំ-សៀមរាប-បាត់ដំបង-ថៃ | D-C | ៦៣០ | ៣៥០ |

*ប្រភព៖ អគ្គិសនីកម្ពុជា*

កម្ពុជាមានសក្តានុពលជាច្រើនសម្រាប់ការផលិតថាមពលវារីអគ្គិសនីដែលអនុញ្ញាតឱ្យប្រទេសនេះផលិតអគ្គិសនីនៅតម្លៃកាន់តែទាបដើម្បីលើកកម្ពស់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ផែនទី ១៦.១. បង្ហាញពីសក្តានុពលវារីអគ្គិសនីក្នុងប្រទេសកម្ពុជា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ផែនទី ១៦.១. សក្តានុពលវារីអគ្គិសនីរបស់កម្ពុជា*

Hydro Potential (greater than 10MW) (3)




Source: MIME

## ១៦.៣.៣. ខ្សែបញ្ជូនថាមពល

### *១៦.៣.៣.១. ការតភ្ជាប់ថាមពលជាមួយប្រទេសថៃ*

កម្ពុជាបានចុះកិច្ចព្រមព្រៀងស្តីពីការយោគយល់គ្នា សម្រាប់កិច្ចសហប្រតិបត្តិការថាមពលជាមួយប្រទេសថៃ នៅថ្ងៃទី៣ ខែកុម្ភៈឆ្នាំ២០០០។ នាពេលបច្ចុប្បន្ន ថាមពលអគ្គិសនីរវាងកម្ពុជា និងថៃត្រូវបានបញ្ជូនតាមបណ្តាញដែលមានតង់ស្យុងពី ២២ ទៅ ១១៥kV។ កម្ពុជាបានចុះកិច្ចព្រមព្រៀងជាមួយខេត្តត្រាត (ថៃ) ដើម្បីផ្គត់ផ្គង់ថាមពលទៅខេត្តកោះកុង និងប៉ោយប៉ែត (កម្ពុជា) ដោយប្រើខ្សែបញ្ជូនដែលមានតង់ស្យុង ២២kV។ តំបន់ខាងលើត្រូវបានតភ្ជាប់តាំងពីឆ្នាំ២០០១ មកម្ល៉េះ។ បណ្តាញបញ្ជូនអគ្គិសនី ដែលមានតង់ស្យុង ១១៥kV ដែលតភ្ជាប់ស្ថានីយរងនៅអារញ្ញប្រាថេតប្រទេសថៃ ទៅនឹងខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាបត្រូវបានសាងសង់ឡើងក្នុងឆ្នាំ ២០០៧។

### *១៦.៣.៣.២. ការតភ្ជាប់ថាមពលជាមួយប្រទេសវៀតណាម*

កិច្ចសហប្រតិបត្តិការថាមពលជាមួយប្រទេសវៀតណាម ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៩។ ចាប់តាំងពីឆ្នាំ ២០០២ EDC បាននាំចូលថាមពលពី PC2 ដើម្បីផ្គត់ផ្គង់ដល់ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ស្រុកស្នួល ខេត្តក្រចេះ ស្រុកមេមត់ និងពញាក្រែក ខេត្តកំពង់ចាម បាវិត ខេត្តស្វាយរៀង ជ្រៃធំ ខេត្តកណ្តាល និងកំពង់ត្រាច ខេត្តកំពត។ សម្រាប់តំបន់កោះរការ ខេត្តព្រៃវែង និងភ្នំដិន ខេត្តតាកែវនោះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការតភ្ជាប់ត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០០៨។ គម្រោងខ្សែបញ្ជូនថាមពលអគ្គិសនីនាំចូល ពីវៀតណាមមកភ្នំពេញកម្លាំង២៣០គីឡូវ៉ាត់ត្រូវបានចាប់ផ្តើមសាងសង់ក្នុងឆ្នាំ២០០៩។ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា និងប្រទេសវៀតណាមបានរៀបចំគម្រោងសាងសង់ខ្សែបញ្ជូនថាមពលអគ្គិសនី កម្លាំង១១៥គីឡូវ៉ាត់ រវាងខេត្តកំពង់ចាម និងខេត្តតាយនិញ ប្រទេសវៀតណាម។

*តារាង ១៦.៤. ផែនការបញ្ជូនថាមពល២០០៨-២០២១*

| ឆ្នាំ | ឈ្មោះគម្រោង | High case | | |
|---|---|---|---|---|
| | | ប្រភេទបណ្តាញ | ផ្នែក (mm2) | Ling length |
| ២០០៨ | បង្កើត 230kV វៀតណាម-ភ្នំពេញតភ្ជាប់ S/S * | D-C | ៦៣០,៤០០ | ១១១ |
| ២០១០ | 230kV តាកែវ-កំពត | D-C | ៤០០ | ១០០ |
| ២០១១ | 115kV កំពង់ចាម-ក្រចេះ | D-C | ៦៣០ | ៨៧ |
| ២០១០ | 115kV ឡាវ-ស្ទឹងត្រែង | D-C | ២៤០ | ៥៦ |
| ២០១០ | 115kV វៀតណាម-ស្វង-ក្រែក-កំពង់ចាម | D-C | ៤០០ | ៦៤ |
| ២០១០ | 230kV កំពត-សីហនុ | D-C | ៦៣០ | ៨២ |
| ២០១១ | 230kV កំពត-តភ្ជាប់វារីអគ្គិសនីកំចាយ | D-C | ៦៣០ | ២០ |
| ២០១១ | 115kV ស្ទឹងត្រែង – ក្រចេះ | D-C | ៤០០ | ១៣០ |
| ២០១២ | 230kV WPP-កំពង់ឆ្នាំង-ពោធិ៍សាត់-បាត់ដំបង | D-C | ៦៣០*២B | ៣១០ |
| ២០១២ | 230kV ពោធិ៍សាត់-អូរសោម | D-C | ៦៣០ | ៨០ |
| ២០១២ | 115kV អូរសោម-អាតៃរួមបញ្ចូល S/S | D-C | ៦៣០ | ៣០ |
| ២០១២ | 115kV GS1-NPP-WPP | D-C | ២៥០*២B | ២៨ |
| ២០១២ | 115kVGS2-SPP- WPP | D-C | 250*2B | ២៥ |
| ២០១២ | 115/230kV NPP-កំពង់ចាម | D-C | ២៥០*២B | ១២០ |
| ២០១៣ | 230kV ឫស្សីជ្រុំលើនិងក្រោម- អូរសោម | D-C | ៦៣០ | ៣០ |
| ២០១៣ | 230kV WPP-SHV រួមបញ្ចូលវាលរិញ S/S | D-C | ៦៣០ | ២២០ |
| ២០១៤ | 115kV SPP-EPP-NPP | D-C | ២៥០ | ២០ |
| ២០១៤ | 115kV EPP-នាក់លឿង-ស្វាយរៀងតភ្ជាប់ S/S | D-C | ២៥០*២B | ១២២ |
| ២០១៧ | 230kV ក្រចេះ-សេសានក្រោម2 - វៀតណាម | D-C | ៦៣០ | ៩០ |
| ២០១៧ | 230kV WPP-NPP | D-C | ៦៣០ | ២៥ |
| ២០១៧ | 230kV NPP-កំពង់ចាម-ក្រចេះ-សេសាន2-វៀតណាម | D-C | ៦៣០ | ៣០០ |
| ២០១៨ | 230kV ស្រែអំបិល-កោះកុង-អូរសោម | D-C | ៤០០ | ២០០ |
| ២០១៩ | ២៣០kV សម្បូរ – ក្រចេះ | D-C | ៦៣០ | ៣០ |
| ២០២១ | ២៣០kV កំពង់ចាម-កំពង់ធំ-សៀមរាប-បាត់ដំបង-ថៃ | D-C | ៦៣០ | ៣៥០ |

*ផែនទី ១៦.២. ការផលិតថាមពលនិងខ្សែចម្លងថាមពលក្នុងឆ្នាំ២០២១*




## ១៦.៣.៣.៣. ការតភ្ជាប់ថាមពលជាមួយប្រទេសឡាវ

កិច្ចសហប្រតិបត្តិការថាមពលជាមួយប្រទេសវៀតណាមត្រូវបានចុះហត្ថលេខានៅថ្ងៃទី២១ខែតុលាឆ្នាំ១៩៩៩។ កិច្ចព្រមព្រៀងនេះ មានបំណងចង់បានកិច្ចសហប្រតិបត្តិការខាងវិស័យថាមពលរវាងប្រទេសទាំងពីរ។ ការផ្គត់ផ្គង់ថាមពលដល់តំបន់តាមព្រំដែនដោយការតភ្ជាប់នឹងខ្សែកម្លាំងវ៉ុលមធ្យម (២២kV) រវាងបណ្ដាញវ៉ុលខ្ពស់ក៏ត្រូវបានលើកទឹកចិត្តផងដែរ។ ប្រទេសទាំងពីរបានពិភាក្សានិងអនុម័តលើការតភ្ជាប់ថាមពលពីភាគខាងត្បូងប្រទេសឡាវ (បានហាតខេត្តចាំផាសាក់) ទៅខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា តាមខ្សែកម្លាំង១១៥kV។

## ១៦.៣.៣.៤. ការតភ្ជាប់អនុតំបន់

ការតភ្ជាប់រវាងខ្សែបញ្ជូនរបស់ប្រទេស ក្នុងអាងទន្លេមេគង្គ (កម្ពុជាឡាវថៃវៀតណាមយុនណានប្រទេសចិននិងភូមា) ឬសូម្បីតែការពង្រីកថែមទៀតនៃខ្សែនេះ ដើម្បីរួមបញ្ចូលម៉ាឡេស៊ីនិងសិង្ហបុរីត្រូវបានអាស្រ័យលើការស្រាវជ្រាវមួយចំនួនដែលមានបំណងចង់លើកកម្ពស់ការប្រើប្រាស់ធនធានថាមពល។ ផែនការមេការតភ្ជាប់អាស៊ានត្រូវបានទទួលយកក្នុងឆ្នាំ២០០២ដើម្បីអភិវឌ្ឍន៍ខ្សែថាមពលអាស៊ាន(APG)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ៦
# ការអភិវឌ្ឍធនធានមនុស្ស

ជំពូកទី ១៧. ស្ថានភាពនៃភាពក្រីក្រ

ជំពូកទី ១៨. ការអប់រំ

ជំពូកទី ១៩. សុខាភិបាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១៧
# ស្ថានភាពនៃភាពក្រីក្រ

នៅចុងបញ្ចប់នៃសម័យខ្មែរក្រហម ប្រជាជនកម្ពុជាទាំងមូលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។ សេរីភាវូបនីយកម្មសេដ្ឋកិច្ចក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ បានធ្វើឱ្យកម្ពុជាត្រឡប់មករកសភាពធម្មតាវិញ និងមានការអភិវឌ្ឍទៅមុខក្នុងអំឡុងជាង ២ ទសវត្សរ៍មកនេះ ជាពិសេសបានលើកកម្ពស់ស្ថានភាពនៃភាពក្រីក្រ។ អត្រានៃភាពក្រីក្របានថយចុះពី ៤៧% ក្នុងឆ្នាំ ១៩៩៣/១៩៩៤ មកនៅត្រឹម ៣០% ក្នុងឆ្នាំ ២០០៧ និង ១៩% នាពេលបច្ចុប្បន្ន។

## ១៧.១. និដ្ឋភាព និងចរិតលក្ខណៈនៃភាពក្រីក្រ

### ១៧.១.១. ការធ្វើបច្ចុប្បន្នភាពបន្ទាត់នៃភាពក្រីក្រ

បន្ទាត់នៃភាពក្រីក្ររបស់ប្រទេសកម្ពុជាត្រូវបានវាស់វែងតាមរយៈ បន្ទាត់នៃភាពក្រីក្រអាហារថ្នាក់ជាតិតែមួយ (ដោយផ្អែកលើរបបអាហារមិនផ្លាស់ប្តូរ) និងការចំណាយមិនមែនអាហារ នៅក្នុងតំបន់ទាំង ៣។ បន្ទាត់នៃភាពក្រីក្ររបស់កម្ពុជា ត្រូវបានឱ្យនិយមន័យថាជា កម្រិតនៃការចំណាយលើអាហារ និងមិនមែនអាហារប្រចាំថ្ងៃរបស់មនុស្សម្នាក់ក្នុងតម្លៃបច្ចុប្បន្ន នៅតាមតំបន់នីមួយៗ (ឧទាហរណ៍ ភ្នំពេញ ប្រជុំជន និងជនបទ)។

#### *១៧.១.១.១. បច្ចុប្បន្នភាពបន្ទាត់នៃភាពក្រីក្រផ្អែកលើរបបអាហារ*

បន្ទាត់នៃភាពក្រីក្រផ្អែកតាមរបបអាហារសម្រាប់តំបន់នីមួយៗ ត្រូវបានវាស់វែងតាមរយៈ ការប៉ាន់ស្មានចំណាយលើរបបអាហារនៅកម្រិតថ្នាក់ជាតិ ដែលផ្តល់ជាថាមពលទ្រទ្រង់ជាមធ្យមស្មើនឹង ២១០០ គីឡូកាឡូរីក្នុង ១ ថ្ងៃ (របបអាហារជាមធ្យមសម្រាប់មនុស្សគ្រប់វ័យនិងភេទ)។ វិធីសាស្ត្រ ៣ ខុសគ្នាត្រូវបានយកមកគណនា ដើម្បីធ្វើបច្ចុប្បន្នភាពបន្ទាត់នៃភាពក្រីក្រ នៅឆ្នាំ ២០០៤ និង ២០០៧ គឺ ទី១) ការប្រើប្រាស់ទិន្នន័យតម្លៃអាហារនៅកម្រិតភូមិ ដែលមាននៅក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជា តាមតំបន់ទាំង ៣ (ភ្នំពេញ តំបន់ប្រជុំជន និងជនបទ) និងបរិមាណជារង្វាស់ទម្ងន់នៃរបបអាហារ ដោយយកឆ្នាំ ១៩៩៣/១៩៩៤ ជាមូលដ្ឋាន ដើម្បីវាស់វែងពីភាពខុសគ្នានៃតម្លៃអាហារក្នុងឆ្នាំ ២០០៤ និង ២០០៧។ ទី២) ការប៉ាន់ស្មានអតិផរណាតម្លៃអាហារក្នុងទីក្រុងភ្នំពេញ ដោយប្រើប្រាស់សន្ទស្សន៍ថ្លៃទំនិញនៅទីក្រុងភ្នំពេញ និងបរិមាណទម្ងន់អាហារ ដោយយករបបអាហារឆ្នាំ ១៩៩៣/១៩៩៤ ជាមូលដ្ឋាន និងទី៣) ការបូកបញ្ចូលសន្ទស្សន៍តម្លៃជាក់ស្តែងនៅទីក្រុងភ្នំពេញ ជាមួយនឹងសន្ទស្សន៍តម្លៃតាមតំបន់ ដើម្បីទទួលបានសន្ទស្សន៍តម្លៃជាក់ស្តែងសម្រាប់តំបន់ ២ ផ្សេងទៀត។

បន្ទាត់នៃភាពក្រីក្រ ត្រូវបានឱ្យនិយមន័យថា ស្ថានភាពរស់នៅក្នុងភាពក្រីក្រនៅពេលប្រាក់ចំណូលរបស់គ្រួសារ ឬមនុស្សម្នាក់ស្ថិតនៅក្រោមកម្រិតមួយកំណត់។ បន្ទាត់នៃភាពក្រីក្ររបស់មនុស្សម្នាក់ ត្រូវបានកំណត់ដោយរដ្ឋាភិបាល ដោយផ្អែកលើចំណាយដើម្បីទទួលបានអាហារចាំបាច់ក្នុងបរិមាណ ២១០០ គីឡូកាឡូរីក្នុង១ថ្ងៃ រួមផ្សំទាំងមុខចំណាយមិនមែនអាហារ ក្នុងកម្រិតអប្បបរមា អាស្រ័យទៅតាមស្ថានភាពអភិវឌ្ឍរបស់ឃុំ សង្កាត់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តារាង១.១.១.១. បង្ហាញពីបច្ចុប្បន្នភាពបន្ទាត់នៃភាពក្រីក្រ ក្នុងឆ្នាំ ២០០៧ ដោយយកបន្ទាត់នៃភាពក្រីក្រផ្អែកតាមរបបអាហារ ក្នុងឆ្នាំ ២០០៤ (ជួរឈរទី ១) គុណនឹងសន្ទស្សន៍តម្លៃអាហារក្នុងឆ្នាំ ២០០៧។

*តារាង ១៧.១. បច្ចុប្បន្នភាពបន្ទាត់នៃភាពក្រីក្រ ឆ្នាំ២០០៤និង២០០៧*

| តំបន់ | ២០០៤* | ២០០៧* |
|---|---|---|
| ភ្នំពេញ | ១,៧៨២ | ២,៤៤៥ |
| តំបន់ប្រជុំជនផ្សេងទៀត | ១,៥៦៨ | ២,២៧៤ |
| ជនបទ | ១,៣៨៩ | ១,៩៦៥ |

*ប្រភព៖WB (2009). Poverty Profile and Trend in Cambodia*

**ប្រអប់១៧.១. ភាពក្រីក្រក្នុងទសវត្សឆ្នាំ១៩៩០**

ផ្អែកតាមទិន្នន័យឆ្នាំ ១៩៩៩ ស្ថានភាពនៃភាពក្រីក្ររបស់ប្រទេសកម្ពុជាបានបង្ហាញថា ប្រជាជនប្រមាណ ៣៥,៩% ជាប្រជាជនក្រីក្រ។ អត្រាភាពក្រីក្រនៅតំបន់ជនបទ (៤០%) ខ្ពស់ជាងបួនដងធៀបនឹងអត្រានៅទីក្រុងភ្នំពេញ (១០%)។ គ្រួសាររស់នៅជនបទ ៩០% ជាគ្រួសារក្រីក្រ ជាពិសេសគ្រួសារដែលប្រកបរបរកសិកម្មជាប្រភពចម្បងនៃប្រាក់ចំណូលរបស់គេ។

ប្រជាជនក្រីក្រជាទូទៅរស់នៅក្នុងគ្រួសារដែលមានសមាជិកច្រើន ។ អត្រានៃភាពក្រីក្រកើនឡើងពី ២៥% ចំពោះគ្រួសារដែលមានសមាជិក ៤ នាក់ ទៅដល់ ៤៥% គ្រួសារមានសមាជិក ១០ នាក់។ គ្រួសារក្រីក្រភាគច្រើនមានកូនចៅច្រើន។ អត្រានៃភាពក្រីក្រកើនឡើងពី ២៧% ចំពោះគ្រួសារដែលមានកូន ១ នាក់ ទៅដល់ ៤៩% គ្រួសារមានកូនច្រើនជាង ៣ នាក់។

អត្រានៃភាពក្រីក្រកើនឡើងអាស្រ័យនឹងអាយុ ជាពិសេសគ្រួសារមានអាយុក្នុងចន្លោះ ៣៦ ដល់ ៤០ ឆ្នាំ ហើយក្រុមអាយុបន្ទាប់អត្រាបានថយចុះវិញ។ គ្រួសារមានអាយុ ៥០-៦០ ឆ្នាំនិងលើសពីនេះ មានអត្រានៃភាពក្រីក្រទាប ដែលអាចបញ្ជាក់បានថា មកពីការសន្សំទុកទ្រព្យសម្បត្តិឬក៏មានសមាជិកគ្រួសារស្ថិតក្នុងវ័យក្មេង ដែលស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេអាចទ្រទ្រង់បានសម្រាប់មនុស្សចាស់នៅក្នុងគ្រួសារ។

មរតកដែលបន្សល់ពីសង្គ្រាមនិងជម្លោះប្រដាប់អាវុធនៅកម្ពុជា នោះគឺប្រជាជនមួយភាគធំបានរស់នៅក្រោមបន្ទុករបស់មេគ្រួសារជាស្ត្រីប្រមាណ ១៧%។ ទោះជាយ៉ាងណា អត្រានៃភាពក្រីក្ររបស់គ្រួសារដែលមានបុរសឬស្ត្រីជាមេគ្រួសារ មិនមានភាពខុសប្លែកគ្នាទេ ថ្វីបើស្ត្រីជួបប្រទះភាពក្រីក្រធ្ងន់ធ្ងរជាងបុរស ដោយសារតែបន្ទុកជាច្រើនក្នុងការចញ្ចឹមបីបាច់កូន ការងារក្នុងផ្ទះ ត្រូវធ្វើការរកចំណូល និងការចូលរួមក្នុងសកម្មភាពសហគមន៍ក៏ដោយ។ ជាងនេះទៅទៀត ក្នុងតំបន់ប្រជុំជន គ្រួសារដែលមានស្ត្រីជាមេគ្រួសារ តែងជួបការលំបាកជាងគ្រួសារដែលមានបុរសជាមេគ្រួសារ។ តាមបទពិសោធន៍នៃភាពក្រីក្រ ស្ត្រីមានផលវិបាកដូចជាការបន្តភាពក្រីក្រទៅឱ្យកូនៗ ជាពិសេសក្មេងស្រី ដូចជាក្មេងស្រីត្រូវធ្វើការជំនួសលើកិច្ចការផ្ទះ និងការវិនិយោគតិចតួចឱ្យទទួលការអប់រំនិងសុខភាព ជាពិសេសបើមានស្ថានភាពថ្លឹងថ្លែងតទល់នឹងតម្រូវការរស់រានរបស់គ្រួសារ។

សមាជិកគ្រួសារដែលមានមេគ្រួសាជាជនរងគ្រោះដោយសារសង្គ្រាមនិងពិការដោយគ្រាប់មីន ត្រូវបានចាត់ទុកជាគ្រួសារក្រីក្របំផុតនៅកម្ពុជា។ ប្រជាជនទាំងនោះជាក្រុមជនដែលត្រូវទទួលបានការយកចិត្តទុកដាក់ជាពិសេស ដោយសារតែស្ថានភាពជីវភាពរបស់ពួកគេធ្លាក់ចុះទាបជាងបន្ទាត់នៃភាពក្រីក្រ និងសមត្ថភាពក្នុងការចូលរួមសកម្មភាពសេដ្ឋកិច្ចនៅមានកម្រិតដោយសារតែភាពពិការ។

### ១៧.១.១.២. បច្ចុប្បន្នភាពមុខចំណាយមិនមែនអាហារ

តារាង ១៧.២ បង្ហាញពីមុខចំណាយមិនមែនអាហារ ដោយធ្វើការកែសម្រួលតាមតម្លៃ អតិផរណា និងបន្ទាត់នៃភាពក្រីក្ររួម (ការបូកបញ្ចូលបច្ចុប្បន្នភាពបន្ទាត់នៃភាពក្រីក្រក្នុងតារាងទី ១ និងបច្ចុប្បន្នភាពមុខចំណាយមិនមែនអាហារ)។

*ក្រាហ្វិក. ១.១.១.២. បបច្ចុប្បន្នភាពមុខចំណាយមិនមែនអាហារ និងបន្ទាត់នៃភាពក្រីក្ររួម (គិតជា រៀល សម្រាប់មនុស្សម្នាក់ ក្នុង ១ ថ្ងៃ) ឆ្នាំ ២០០៤ និង ឆ្នាំ ២០០៧*

| តំបន់ | ២០០៤* | ២០០៧* |
|---|---|---|
| ចំណាយមិនមែនអាហារ (គិតជា រៀល) | | |
| ភ្នំពេញ | ៥៦៩ | ៦៤៧ |
| ទីប្រជុំជនផ្សេងទៀត | ៣៨៤ | ៤៣០ |
| ជនបទ | ៣៦៤ | ៤០២ |
| បច្ចុប្បន្នភាពបន្ទាត់នៃភាពក្រីក្ររួម (= បន្ទាត់ភាពក្រីក្រតាមរបបអាហារ + ចំណាយមិនមែនអាហារ) | | |
| ភ្នំពេញ | ២,៣៥១ | ៣,០៩២ |
| ទីប្រជុំជនផ្សេងទៀត | ១,៩៥២ | ២,៧០៤ |
| ជនបទ | ១,៧៥៣ | ២,៣៦៧ |

*ប្រភព៖WB (2009). Poverty Profile and Trend in Cambodia*

### ១៧.១.២. ស្ថានភាពនៃភាពក្រីក្រក្នុងទសវត្សរ៍ឆ្នាំ១៩៩០

ការកំណត់ឃុំ សង្កាត់ដែលរងប៉ះពាល់ពីអសន្តិសុខស្បៀង បានផ្អែកលើព័ត៌មានដែលទទួលបានពីអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ១៩៩៩ ជំរឿនប្រជាជនឆ្នាំ ១៩៩៨ និងការវាស់វែងភាពក្រីក្រឆ្នាំ ១៩៩៩ របស់កម្មវិធីស្បៀងអាហារពិភពលោក។ នៅឆ្នាំ ១៩៩៩ ក្នុងចំណោមប្រជាជន ១៣ លាននាក់ ប្រជាជន ៣៦% រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ក្នុងនោះ ៤៣% ស្ថិតក្នុងអាយុក្រោម ១៤ ឆ្នាំ ដែលជាក្រុមអាយុមិនបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេស។ ប្រជាជនប្រមាណ ៨៥%រស់នៅតំបន់ជនបទ និងប្រកបរបរកសិកម្មដែលជាប្រភពដ៏សំខាន់សម្រាប់ការទទួលទាននិងចំណូលសម្រាប់គ្រួសារ។ កុមារអាយុក្រោម ៥ ឆ្នាំប្រមាណ ៥០% រងគ្រោះពីការអភិវឌ្ឍមិនប្រក្រតី និង ២០% កង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។

## ១៧.២. ការកំណត់លក្ខណៈនៃភាពក្រីក្រ

ជាធម្មតា ភាពក្រីក្របង្កឡើងដោយសង្គ្រាម ជម្លោះផ្ទៃក្នុង និងវិបត្តិសេដ្ឋកិច្ច ដែលបានកាត់ផ្តាច់លទ្ធភាពស្វែងរកធនធានសម្រាប់ជីវភាពរស់នៅរបស់គ្រួសារ ជាពិសេសអ្នកដែលងាយរងគ្រោះ។ ប្រជាជនដែលមានមិនធនធានផ្ទាល់ខ្លួន និងមានតែកម្លាំងកាយ បានជំរុញឱ្យស្ថានភាពរស់នៅរបស់ពួកគេកាន់តែដុនដាប កើតឡើងនូវវិសមភាព ទុរគិតភាព និងភាពទីទ័លក្រ។ ការបាត់បង់ភាពចេះជួយគ្នាទៅវិញទៅមក

និងសាមគ្គីភាពនៅក្នុងសហគមន៍ដែលមានជាយូរលង់មកហើយ ដោយសារតែការផ្លាស់ប្តូររបប វប្បធម៌ និងសីលធម៌ បានធ្វើឱ្យចំណងទាក់ទងនៅក្នុងសង្គមត្រូវបែកបាក់ និងប្រែក្លាយឱ្យទៅជាក្រុមជួបការលំបាកជាងគេបំផុតនៅក្នុងប្រទេស។

សញ្ញាណដែលបង្ហាញពីភាពក្រីក្រមានដូចជា ៖ អសន្តិសុខស្បៀងដោយសារការបាត់បង់លទ្ធភាពរកប្រាក់ចំណូល ភាពគ្មានការងារធ្វើ និងខ្វះការថែទាំសុខភាព ការអប់រំ និងមានគេហដ្ឋានសមស្រប។ ដូច្នេះ យុទ្ធសាស្ត្រអាទិភាពដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនោះគឺ (១) ការបង្កើតការងារសម្រាប់មនុស្សវ័យក្មេង (២) ការទទួលបានសេវាថែទាំសុខភាពជាមូលដ្ឋាន និង (៣) ការទទួលបានសេវាអប់រំរបស់កុមារ។

ការកើនឡើងនៃភាពក្រីក្រក៏ដោយសារការខូចខាតប្រព័ន្ធអេកូឡូស៊ី និងផលវិបាកនានាដែលមានពីការខូចខាតនេះ។ ប្រជាជនរងគ្រោះ បានលើកឡើងពីកត្តាធម្មជាតិដែលកើតឡើងជាញឹកញាប់ មានដូចជាៈ (១) គ្រោះមហន្តរាយធម្មជាតិដូចជាទឹកជំនន់ និងភាពរាំងស្ងួតជាបន្តបន្ទាប់ (២) ការធ្លាក់ចុះនៃគុណភាពដីដែលកាន់តែគ្មានជីវជាតិបណ្តាលឱ្យទទួលបានទិន្នផលទាប និង (៣) ការប្រើប្រាស់ធនធានធម្មជាតិមិនមាននិរន្តរភាព។

ហេតុផលផ្សេងទៀតដែលនាំឱ្យមានភាពក្រីក្រ ជាពិសេសនៅទីក្រុងនោះ ក៏បណ្តាលមកពីដំណើររបស់ធម្មជាតិ មរណភាព ការចូលនិវត្តន៍ ការបាត់បង់ការងាររបស់អ្នករកប្រាក់កម្រៃ ក៏ដូចជាពិការភាពផ្នែករាងកាយ ដែលបណ្តាលមកពីជរាភាព ឬ ជំងឺចុះខ្សោយផ្នែករាងកាយ។

## ១៧.២.១. ក្រុមមនុស្សដែលងាយរងគ្រោះបំផុត

នៅកម្ពុជា ក្រុមមនុស្សជួបការលំបាកខ្លាំង រួមមាន ប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងស្រុក និងជនភៀសខ្លួនមាតុភូមិនិវត្តន៍ ស្ត្រីមេម៉ាយដោយសារសង្គ្រាម ក្មេងតាមចញ្ចើមថ្នល់ មនុស្សរស់នៅដោយគ្មានការអនុញ្ញាត ជនពិការ និងជនជាតិភាគតិចនៅដាច់ឆ្ងាយពីគេ។ ពួកគេមានលទ្ធភាពតិចតួចទទួលបានសេវាអប់រំ ការបណ្តុះបណ្តាល និងឱកាសការងារ។

មកទល់បច្ចុប្បន្ន មនុស្សជាច្រើនបានធ្វើការបម្លាស់ទីដោយសារតែជម្លោះប្រដាប់អាវុធ។ ចន្លោះឆ្នាំ ១៩៩២ និង ១៩៩៣ បន្ថែមពីលើចំនួនជនភៀសខ្លួន ៣៧០,០០០នាក់ ដែលបានធ្វើមាតុភូមិនិវត្តន៍ពីជំរុំព្រំដែនថៃមកកម្ពុជាវិញនោះ មនុស្សផ្លាស់ទីលំនៅក្នុងស្រុកចំនួន ១៨០,០០០ នាក់ ត្រូវបានបញ្ជូនត្រឡប់ទៅទីកន្លែងដើមរបស់គេវិញផងដែរ។ ប្រជាជនទាំងនោះភាគច្រើនមានស្ត្រីជាមេគ្រួសារនិងកូនតូច។ ពួកគេភាគច្រើនមិនមានជំនាញសមស្រប និងទទួលបានការគាំទ្រផ្នែកសីលធម៌និងសម្ភារៈតិចតួចណាស់។

សង្គ្រាមស៊ីវិលនិងរបបប្រល័យពូជសាសន៍ បណ្តាលឱ្យមានស្ត្រីមេម៉ាយនិងក្មេងកំព្រាជាច្រើន។ កត្តានេះមានផលប៉ះពាល់ដល់កុមារ ដែលមានចំនួនជិតពាក់កណ្តាលនៃប្រជាជនកម្ពុជាទាំងមូល ដូចជាក្នុងករណីធ្ងន់ធ្ងរ ធ្វើឱ្យពួកគេគ្មានផ្ទះសម្បែង ពិការ ឬក្លាយជាឧក្រិដ្ឋជនប្រព្រឹត្តបទល្មើស។ ជាងនេះទៀត ពួកគេអាចនឹងស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន។

អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ១៩៩៩ បានប៉ាន់ស្មានថា ប្រជាជនពិការមាន ១៦៩,០០០ នាក់ ត្រូវជា ១,៥% នៃប្រជាជនទាំងអស់ ដែលក្នុងនោះ ២០% រស់នៅក្នុងតំបន់ប្រជុំជន និង ៨០% ក្នុងបណ្តាភូមិនានា។ ប្រជាជនពិការ ៤៤% បាត់បង់អវយវៈ ឬមិនអាចប្រើអវយវៈមួយឬច្រើនដោយសារការរងរបួសអំឡុងពេល

ជម្លោះស៊ីវិល។ សុខភាពទន់ខ្សោយនិងជម្ងឺគឺជា បុព្វហេតុចម្បងនៃពិការភាព។ ១ ភាគ ៥ នៃជនពិការ ជាជនពិការពីកំណើត។ ប្រជាជនពិការ ១១% រងគ្រោះដោយសារបន្ទុះគ្រាប់មីន។ ប្រជាជនពិការលើសពី ១០% រងគ្រោះដោយសារសង្គ្រាមឬជម្លោះប្រដាប់អាវុធ។

ជនជាតិដើមភាគតិចរស់នៅដាច់ឆ្ងាយពីគេមានពី ៣០ ទៅ ៣៥ ក្រុមកុលសម្ព័ន្ធ ដែលរស់នៅក្នុងតំបន់ភ្នំនិងខ្ពង់រាបក្នុងប្រទេសកម្ពុជា។ ការរស់នៅដាច់ឆ្ងាយពីគេ និងភាពលំបាកក្នុងការរស់នៅរបស់ពួកគេបានបង្កើនភាពងាយរងគ្រោះ និងបណ្តាលឱ្យមានភាពក្រីក្រជាខ្លាំង។

### ១៧.២.២. ការលាដុវត្តិភាពសេដ្ឋកិច្ច/ចំណូលមិនគ្រប់គ្រាន់

ក្នុងទសវត្សរ៍ចុងក្រោយនេះ អត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យមប្រហែល ៩,៤%។ កំណើនក្នុងរង្វង់ដ៏ខ្ពស់នេះ ធ្វើឱ្យចំណូលពិតប្រាកដនិងភាពមានការងារធ្វើរបស់ប្រជាជនម្នាក់បានប្រសើរឡើង។ ជាងនេះទៀត កំណើនដែលកើតមាននេះ ភាគច្រើនកើតមានក្នុងឧស្សាហកម្មកាត់ដេរនិងទេសចរណ៍។ ជាមួយគ្នានេះវិសមភាពនៃប្រាក់ចំណូលក៏បានកើតឡើងផងដែរ។

កំណើនដែលប្រកបដោយសមធម៌មិនទាន់កើតមាននៅឡើយទេ។ គួរឱ្យកត់សម្គាល់ដែរថា កំណើនជាមធ្យមប្រចាំឆ្នាំក្នុងវិស័យកសិកម្មគឺ ៤,៦% អំឡុងឆ្នាំ ១៩៩៤-២០០៨ ដែលកំណើននេះខ្ពស់ជាងកំណើនប្រជាជនបន្តិចសម្រាប់រយៈពេលដូចគ្នានេះ។ កំណើនផ្នែកកសិកម្មមានភាពផុយស្រួយ ដោយសារតែផលិតភាពនៅទន់ខ្សោយ ការប្រកួតប្រជែងមិនសមល្មមក្នុងការផ្គត់ផ្គង់ធាតុចូល និងភាពងាយរងគ្រោះដោយសារឥទ្ធិពលពីខាងក្រៅ (ភាពរាំងស្ងួត ការប្រែប្រួលតម្លៃទំនិញ)។ ស្ថានភាពរបស់វិស័យកសិកម្មមិនទៀងទាត់ គួបផ្សំនឹងភាពស្ពឹកស្រពន់នៃភាពមិនអាចប្រកួតប្រជែងបានរបស់វិស័យឧស្សាហកម្ម ព្រមទាំងអសមត្ថភាពក្នុងការស្រូបយកកម្លាំងពលកម្មពីតំបន់ជនបទដែលកាន់តែកើនឡើងបាន កត្តាទាំងនេះបង្កើតឱ្យមានជាឧបសគ្គក្នុងការបង្កើតការងារនិងការបង្កើនប្រាក់ចំណូល ដែលកាន់តែធ្វើឱ្យជីវភាពរបស់គ្រួសារនៅតំបន់ជនបទកាន់តែដុនដាប។ ជាងនេះទៅទៀត ភាពទន់ខ្សោយនិងកង្វះភាពសម្បូរបែបក្នុងការនាំផលិតចេញក្រៅ (វិស័យកាត់ដេរ ៦០-៧០% នៃការនាំចេញសរុប) បន្តធ្វើឱ្យរាំងដល់សក្តានុពលកំណើនរបស់ប្រទេសប្រកបដោយនិរន្តរភាព។ វិស័យកសិកម្មដែលរំពឹងតែទឹកភ្លៀងមួយមុខគត់ ធ្វើឱ្យមានភាពស្រពេចស្រពិល និងមិនបានលើកទឹកចិត្តដល់ការវិនិយោគនានាក្នុងតំបន់ជនបទ ដែលជាកត្តាតែមួយគត់ក្នុងការបង្កើតផលិតភាពនិងចំណូល។

ទោះបីជាក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនាពេលបច្ចុប្បន្នមានមូលដ្ឋានឈរជើងរឹងមាំក៏ដោយ ក៏មិនទាន់បង្ហាញច្បាស់អំពីលទ្ធភាពរបស់ប្រជាជនក្រីក្រ ក្នុងការទទួលបានធនធានហិរញ្ញវត្ថុនិងធនធានដទៃទៀត ដែលនឹងនាំទៅរកការបង្កើនផលិតភាពនិងការងារដែលមានកម្រៃខ្ពស់។ ការអភិវឌ្ឍសហគ្រាសធុនតូច និង វិស័យក្រៅផ្លូវការនៅមានតិចតួច។ កត្តាទី ២ ដែលចាត់ទុកជាឱកាសបង្កើតការងារផងដែរនោះគឺ ការបង្កើតការងារសម្រាប់មន្ត្រីរាជការ ដែលមិនមានការកើនឡើងទេក្នុងប៉ុន្មានឆ្នាំមកនេះ ម្យ៉ាងទៀតការជ្រើសរើសការងារក្នុងវិស័យផ្លូវការមានការឈានឡើងយឺត។

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ពីសារៈសំខាន់នៃការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងសកម្មភាពសេដ្ឋកិច្ចសំដៅកាត់បន្ថយភាពក្រីក្រ។ កង្វះផ្លូវថ្នល់និងកំពង់ផែបានធ្វើឱ្យចំណាយដឹកជញ្ជូនកាន់តែខ្ពស់។ កង្វះគុណភាពនិងបរិមាណក្នុងការផ្គត់ផ្គង់អគ្គិសនីចាត់ទុកថាជាឧបសគ្គដ៏



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចម្បងមួយទៀត។ តាមសេចក្តីរាយការណ៍ ប្រជាជនប្រមាណ ៣០% មានលទ្ធភាពប្រើប្រាស់អគ្គិសនី ទោះបីជានៅតាមទីក្រុងធំៗ សេចក្តីត្រូវការត្រូវបានបំពេញនិងបានគ្រប់គ្រាន់ក៏ដោយ។ ការដោះស្រាយកង្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ។

**ប្រអប់១៧.២. អាទិភាពនៃការងារដ៏មានផ្លែផ្កា**

ខណៈដែលការសង្កត់ធ្ងន់ទៅលើការវិនិយោគក្នុងតំបន់ជនបទគួរតែបន្តនោះ ការវិនិយោគក្នុងទីក្រុងក៏អាចជាអត្ថប្រយោជន៍ដល់អ្នកក្រីក្រផងដែរ ប្រសិនបើវាបង្កើតការងារដ៏មានផ្លែផ្កាសម្រាប់កម្លាំងពលកម្មនៅជនបទដែលច្រើនលើសលប់នោះ ដែលធ្វើចំណាកស្រុកមកតំបន់ទីក្រុងដើម្បីរកការងារនោះ។ កំណើននៃការផលិតអតិពលកម្មដូចជាផលិតផលកាត់ដេរជាឧទាហរណ៍ មានឥទ្ធិពលទ្វេរដងទៅលើភាពក្រីក្រ។ ការប្រកួតប្រជែងបច្ចុប្បន្ននៃវាយនភ័ណ្ឌនិងការនាំចេញសម្លៀកបំពាក់របស់កម្ពុជា អាចផ្តល់នូវមូលដ្ឋានរឹងមាំមួយសម្រាប់ការបង្កើនប្រាក់ចំណូលពិតប្រាកដក្នុងមនុស្សម្នាក់ ដូច្នេះនាំឱ្យកាត់បន្ថយភាពក្រីក្របាន។ បន្ថែមពីនេះ ការអភិវឌ្ឍន៍ការផលិតអតិពលកម្មដោយការទាញយកពលកម្មពីតំបន់ជនបទអាចបង្កើតកំណើន ក្នុងលទ្ធភាពផលិតកម្មកសិកម្មជាមធ្យមនិងប្រាក់ចំណូលក្នុងក្រុមគ្រួសារនៅជនបទ ដូច្នេះនាំឱ្យកាត់បន្ថយភាពក្រីក្របានកាន់តែខ្លាំងក្លា។

ការបង្កើតការងារគឺជាអាទិភាពមួយ ពីព្រោះប្រហែល ២៥០,០០០ការងារត្រូវតែបង្កើតក្នុងមួយឆ្នាំៗ ដើម្បីយកមនុស្សទីផ្សារពលកម្មថ្មីៗឱ្យចូលបម្រើការងារ ដែលត្រូវបានបន្ថែមទៅដល់អ្នកស្វែងរកការងារធ្វើថ្មីៗទាំងនោះ ដែលត្រូវបានបង្កើតដោយការរំសាយតាមផែនការក្នុងសេវាកម្មកងទ័ពនិងកំណែទម្រង់រដ្ឋបាលសាធារណៈ។

កម្លាំងពលកម្មជនបទកំពុងតែកើនលូតលាស់យ៉ាងលឿន ច្រើនជាងផលិតកម្មពិតប្រាកដក្នុងវិស័យកសិកម្មទៅទៀត ដែលបណ្តាលឱ្យមានការធ្លាក់ចុះក្នុងលទ្ធភាពផលិតកម្មពលកម្មផ្នែកកសិកម្ម។ កសិករកាន់តែក្រទៅ ដោយសារទំហំនៃដីស្រែក្នុងមួយគ្រួសារបានថយចុះ ធ្វើឱ្យពួកគេងាយរងគ្រោះកាន់តែច្រើនផងដែរដល់អសន្តិសុខស្បៀង។ រាជរដ្ឋាភិបាលកម្ពុជា និងភ្នាក់ងារម្ចាស់ជំនួយត្រូវផ្តោតអារម្មណ៍លើការបង្កើនប្រាក់ចំណូលក្នុងគ្រួសារតាមជនបទ តាមរយៈការបង្កើនសមត្ថភាពផលិតកម្មវិស័យកសិកម្ម។ យុទ្ធសាស្ត្រនេះលើកកម្ពស់ផងដែរនូវកំណើនឱកាសការងារក្រៅពីស្រែចម្ការ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវតម្រូវការសម្រាប់ទំនិញនិងសេវាកម្មមិនទាក់ទងនឹងស្រែចម្ការ។

## ១៧.៣. យុទ្ធសាស្ត្រ គោលនយោបាយ និង ស្ថានភាពនៃភាពក្រីក្រ

កម្ពុជាត្រូវដោះស្រាយក្តីបារម្ភមួយចំនួនក្នុងការកាត់បន្ថយភាពក្រីក្ររួមមាន ៖ (១) ការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាលត្រឹមឆ្នាំ ២០១៥ ស្របជាមួយនឹងគោលដៅផ្សេងៗទៀត ជាពិសេសក្នុងផ្នែកសុខាភិបាលនិងការអប់រំ (២) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន (៣) ធានាអភិបាលកិច្ចល្អ សន្តិភាព និងការទប់ស្កាត់ជម្លោះ (៤) ការអភិវឌ្ឍវិស័យកសិកម្ម (៥) ការកសាងសមត្ថភាពតាមរយៈបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ (៦) ការអភិរក្សវប្បធម៌ និង (៧) ការឈានចូលក្នុងទីផ្សាររបស់ប្រទេសឧស្សាហកម្មធំៗ។

យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា ត្រូវបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រចតុកោណនិងទិសដៅយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០។ សមាសធាតុទូទៅរបស់យុទ្ធសាស្ត្រនេះមានដូចជា ៖ (១) ការលើកកម្ពស់អភិបាលកិច្ចល្អនិងការពង្រឹងនីតិរដ្ឋ (២) ការពង្រឹងការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អភិវឌ្ឍមូលដ្ឋាន តាមរយៈជំរុញការងាររិមជ្ឈការនិងអភិបាលកិច្ចល្អ (៣) ការបង្កើនល្បឿនអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដើម្បីពង្រីកឱកាសទទួលបានសេវាសង្គមមូលដ្ឋានសម្រាប់ទាំងអស់គ្នា សំដៅចាប់យកតម្លៃកាន់តែច្រើនជាងមុនពីមូលធនមនុស្ស (៤) ការបង្កើនវិនិយោគនិងកសាងភាពប្រកួតប្រជែងក្នុងប្រព័ន្ធផលិតកម្ម ជាពិសេសតាមរយៈការបង្កើតហេដ្ឋារចនាសម្ព័ន្ធគាំទ្រគ្រប់គ្រាន់សម្រាប់ផលិតកម្ម (៥) ការបន្តពង្រឹងសមាហរណកម្មក្នុងអនុតំបន់និងកិច្ចសហប្រតិបត្តិការអន្តរជាតិ (៦) ការផ្សព្វផ្សាយព័ត៌មានដើម្បីអភិវឌ្ឍនិងលើកកម្ពស់ការប្រើប្រាស់លទ្ធផលស្រាវជ្រាវនិងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ថ្មីៗ (៧) ការបន្តគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និង (៨) ការពង្រឹងការគ្រប់គ្រងក្រុមមនុស្សងាយរងគ្រោះ តាមរយៈការលើកកម្ពស់សមត្ថភាពផលិតកម្មរបស់ពួកគេ និងកាត់បន្ថយគម្លាតយេនឌ័រ។

វិបត្តិហិរញ្ញវត្ថុពិភពលោកនាពេលបច្ចុប្បន្ន ត្រូវបានរំពឹងថាមានផលប៉ះពាល់ដល់ការកាត់បន្ថយភាពក្រីក្រ។ ដើម្បីធានាវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព គេត្រូវរក្សាកំណើនសេដ្ឋកិច្ចជាមធ្យមពី ៧% ទៅ ៨% ក្នុងរយៈពេលមធ្យម។ ទោះជាយ៉ាងណា កំណើននេះប្រហែលជាមិនគ្រប់គ្រាន់ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជននៅតំបន់ជនបទនោះទេ។ ដូច្នេះ យុទ្ធសាស្ត្រនេះត្រូវតែសង្កត់ធ្ងន់លើការអភិវឌ្ឍវិស័យកសិកម្ម និងការរួមចំណែករបស់យុទ្ធសាស្ត្រចំពោះកំណើនផលទុនសរុបក្នុងស្រុក។

### ១៧.៣.១. យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ

យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រមានន័យថា៖(១)ការលើកកម្ពស់កាលានុវត្តភាពសម្រាប់ការបង្កើតធនធានក្នុងប្រទេសកម្ពុជា (២) ការបង្កើតភាពស្មើភាពនៅក្នុងគោលបំណងដើម្បីនាំមកនូវឱកាសទាំងនេះតាមរយៈការកសាងសមត្ថភាពដល់សហគមន៍ក្រីក្រ និង (៣) ការធានានូវការការពារដល់ក្រុមងាយរងគ្រោះ។ ចំណុចទាំងអស់នេះក៏ជាគោលការណ៍មូលដ្ឋាននៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រ។ យុទ្ធសាស្ត្រនេះក៏មានគោលបំណងបង្កើតឱ្យមានការគ្រប់គ្រងដ៏ប្រសើរមួយ សម្រាប់លំនាំប្រជាសាស្ត្រមិនអំណោយផល ស្របជាមួយនឹងសេចក្តីប្រកាសគោលនយោបាយប្រជាជន ដែលត្រូវបានកែលម្អក្នុងឆ្នាំ ២០០៣។ ដូចគ្នានេះដែរ វប្បធម៌សន្តិភាព ភាពអត់ធ្មត់ និងសាមគ្គីភាពត្រូវតែជាតម្លៃរួមមួយសម្រាប់សង្គមកម្ពុជា ដើម្បីបង្ការភាពដោយឡែកនិងការលំបាករបស់ជនជាតិភាគតិច។

ដើម្បីសម្រាលដល់ការរងទុក្ខវេទនារបស់ប្រជាជនដែលគ្មានធនធាន និងលើកកម្ពស់សមាហរណកម្មសង្គម សម្រាប់ក្រុមជួបការលំបាកនិងងាយរងគ្រោះ និងអនុក្រុមនានា គោលនយោបាយរបស់រដ្ឋាភិបាលមានគោលបំណង (១) លើកកម្ពស់ឋានៈសង្គមសម្រាប់ក្រុមងាយរងគ្រោះនិងជួបការលំបាក (២) សម្របសម្រួល និងផ្តល់លទ្ធភាពដល់ប្រជាជនក្រីក្រឱ្យទទួលបានសេវាសង្គម ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារមូលដ្ឋាន (៣) អនុវត្តកម្មវិធីបង្កើតធនធានដែលសមស្របទៅនឹងក្រុមគោលដៅទាំងនេះ ជាពិសេសតាមរយៈមីក្រូហិរញ្ញវត្ថុ និង (៤) លើកកម្ពស់ការអភិវឌ្ឍសហគមន៍។

ដើម្បីសម្រេចវត្ថុបំណងទាំងនេះ រដ្ឋាភិបាលនឹងធ្វើការ (១) បង្រួបបង្រួមនិងពង្រឹងកម្មវិធីនិងគម្រោងវិនិយោគសង្គម (២) បង្កើតប្រព័ន្ធមួយដើម្បីត្រួតពិនិត្យផលប៉ះពាល់គម្រោងជាមួយនឹងសហគមន៍នៅមូលដ្ឋាន (៣) កសាងសមត្ថភាពដល់អង្គការសហគមន៍ ដើម្បីលើកសំណើគម្រោង ការផ្តល់អាទិភាព និងការអនុវត្តគម្រោងនានា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អភិក្រមនេះត្រូវបានគាំទ្រដោយ (១) ការបន្តធ្វើឱ្យប្រសើរឡើងនូវមុខងាររបស់ប្រព័ន្ធគាំពារសុខភាពបឋម និងសមត្ថភាពរបស់ប្រព័ន្ធ ក្នុងការផ្តល់លទ្ធភាពឱ្យកុមារដែលមកពីគ្រួសារក្រីក្រ ទទួលបានសេវាពីបរិក្ខារគាំពារសុខភាពកាន់តែទូលាយជាងមុន មានគុណភាពល្អ និងថ្នាំព្យាបាលដែលមានតម្លៃសមរម្យ (២) ការលើកកម្ពស់ការអប់រំសុខភាពសម្រាប់មាតានិងកូននៃគ្រួសារក្រីក្រ និង (៣) ការរក្សាបានជោគជ័យនៃកម្មវិធីសុខាភិបាលនៅថ្នាក់ជាតិដូចជា ការពង្រីកកម្មវិធីស្តីពីប្រព័ន្ធស៊ាំនឹងមេរោគ (EPI) និងកម្មវិធីជាតិស្តីពីអាហារូបត្ថម្ភ (NNP)។

ការវិភាគអំពីមូលហេតុ កត្តាកំណត់ និងលក្ខខណ្ឌជាក់ស្តែងរបស់អ្នកក្រីក្រនៅកម្ពុជាបានបង្ហាញថាភាពក្រីក្រអាចត្រូវបានដោះស្រាយ តាមរយៈកត្តាគន្លឹះ ៤ យ៉ាងគឺៈ ការបង្កើតធនធាន ការកសាងសមត្ថភាពនិងការលើកកម្ពស់សេវាកម្មសង្គមមូលដ្ឋាន ការលើកកម្ពស់ជីវភាពរស់នៅរបស់ក្រុមមនុស្សងាយរងគ្រោះនិងអភិក្រមទូលំទូលាយមួយក្នុងការអនុវត្ត ការត្រួតពិនិត្យនិងការវាយតម្លៃគម្រោងផ្អែកលើគោលការណ៍វិមជ្ឈការ។ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា សង្កត់ធ្ងន់លើការប្រើប្រាស់ត្រឹមត្រូវនៃកត្តាគន្លឹះទាំងអស់នេះ។

បទពិសោធន៍របស់ប្រទេសនៅអាស៊ីបូព៌ាបានបង្ហាញថា កំណើនប្រកបដោយនិរន្តរភាពពាក់ព័ន្ធទៅនិងការបង្កើតមូលធនមនុស្ស។ ដូចគ្នាផងដែរ មូលធនសង្គម (ដូចជា អភិបាលកិច្ចល្អ និងការធ្វើវិមជ្ឈការ ។ល។) និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព បានដើរតួរនាទីដ៏សំខាន់ក្នុងការទ្រទ្រង់កំណើន។ ហេតុផលទាំងនេះហើយ កម្ពុជាត្រូវសង្កត់ធ្ងន់លើការកសាងសមត្ថភាពនិងការបង្កលទ្ធភាពទទួលបានសេវាសង្គមជាមូលដ្ឋាន ដែលជាជ្រុងដ៏សំខាន់នៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ យុទ្ធសាស្ត្រនេះក៏បានទទួលស្គាល់ថា ដើម្បីទទួលបានកំណើនប្រកបដោយចីរភាព ធនធានមនុស្ស ធនធានសង្គម និងធនធានធម្មជាតិគួរត្រូវបានអភិវឌ្ឍក្នុងលក្ខណៈមួយដែលស្របជាមួយតម្រូវការរបស់សហគមន៍។ ជាងនេះទៅទៀតសហគមន៍ត្រូវតែចូលរួមក្នុងការគ្រប់គ្រងកិច្ចការនានានៅក្នុងសហគមន៍របស់ពួកគេ តាមរយៈកំណែទម្រង់នានា ដូចជាគោលនយោបាយស្តីពីការអភិវឌ្ឍមូលដ្ឋាននិងការធ្វើវិមជ្ឈការរដ្ឋបាល។

កិច្ចការពារក្រុមងាយរងគ្រោះ (ដូចជា កុមារ ស្ត្រី ជនពិការ មនុស្សចាស់ និងយុវជន) គឺជាមធ្យោបាយប្រកបដោយសក្តានុពល ក្នុងការដោះស្រាយភាពក្រីក្រនៅតាមមូលដ្ឋាន។ រដ្ឋាភិបាលកំពុងអនុវត្តកម្មវិធីជាក់លាក់ជាច្រើន ដើម្បីសម្រាលភាពនៅដាច់ដោយឡែកពីសង្គមដូចជា យេនឌ័រ វ័យ ពិការភាពផ្នែករាងកាយ ឬកាលៈទេសៈមិនអំណោយផល (ដូចជា ជនរងគ្រោះដោយសារទឹកជំនន់ ភាពរាំងស្ងួត ឬជម្លោះសង្គមនិងនយោបាយ)។ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រគួរតែតម្រង់ទៅសម្រេចនូវផលសម្រេចដូចជា ៖ (១) ការលើកកម្ពស់កាលានុវត្តភាពសម្រាប់ការបង្កើតធនធានក្នុងប្រទេសកម្ពុជា (២) ការបង្កើតស្មើភាព នៅក្នុងគោលបំណងដើម្បីនាំមកនូវឱកាសទាំងនេះ តាមរយៈការកសាងសមត្ថភាពដល់សហគមន៍ក្រីក្រ និង (៣) ធានានូវការការពារដល់ក្រុមងាយរងគ្រោះ។ ការរៀបចំ ការគ្រប់គ្រង និងការពិនិត្យតាមដាន វាយតម្លៃ កម្មវិធីប្រឆាំងនឹងភាពក្រីក្រទាំងអស់ នឹងដើរតាមអភិក្រមមួយដែលទទួលស្គាល់និងដោះស្រាយរាល់បញ្ហាទាំងអស់នៃស្ថានភាពដោយឡែកពីសង្គម រួមទាំងកត្តាយេនឌ័រផងដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១៧.៣.២. កំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ

ជារួម កំណើនសេដ្ឋកិច្ចក្នុងទសវត្សរ៍កន្លងមក បានលើកកម្ពស់ជីវភាពរស់នៅនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ តាមរយៈការប្រៀបធៀបសំណាកគំរូតាងភូមិសាស្ត្រ អត្រាភាពក្រីក្រថ្នាក់ជាតិបានថយចុះច្រើនជាង ១៥% ក្នុងអំឡុង ១៥ ឆ្នាំកន្លងមក គឺពីរង្វង់ ៤៥-៥០% ក្នុងឆ្នាំ១៩៩៣-១៩៩៤ មកនៅត្រឹម ៣៤,៨% ក្នុងឆ្នាំ២០០៤ និងបន្ទាប់មកនៅត្រឹម ៣០,១% ក្នុងឆ្នាំ២០០៧។

*រូបភាព ១៧.១. ការជួបប្រទះភាពក្រីក្របាននឹងកំពុងធ្លាក់ចុះ*




*ចំណាំ: កម្រិតនៃភាពក្រីក្រគិតជាភាគរយនៃប្រជាជន ត្រូវបានវាស់វែងដោយប្រើប្រាស់បន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ។*

*ប្រភព៖ WB (2009), Sustaining Rapid Growth in a Challenging Environment. Cambodia*

ភាពក្រីក្រនៅភ្នំពេញបានថយចុះពី ៤,៦% ក្នុងឆ្នាំ២០០៤ មក ០,៨% ក្នុងឆ្នាំ២០០៧ ខណៈពេលដែលភាពក្រីក្រក្នុងតំបន់ជនបទបានថយចុះពី ៣៩,១% ក្នុងឆ្នាំ២០០៤ មក ៣៤,៧% ក្នុងឆ្នាំ២០០៧។ អត្រាភាពក្រីក្រក្នុងតំបន់ប្រជុំជនផ្សេងទៀតក៏ថយចុះផងដែរពី ២៥,៨% ក្នុងឆ្នាំ២០០៤ មក ២១,៩% ក្នុងឆ្នាំ២០០៧។

នៅពេលទន្ទឹមគ្នានេះ វិសមភាពនៅកម្ពុជាបានកើនឡើងក្នុងអំឡុងទសវត្សរ៍កន្លងទៅ។ មេគុណ Gini coefficient ស្តីពីការប្រើប្រាស់ក្នុងគ្រួសារក្នុងមនុស្សម្នាក់កើនឡើងពី ០,៣៥ ទៅ ០,៤០ អំឡុងឆ្នាំ ១៩៩៤-២០០៧។ វិសមភាពបាននិងកំពុងកើនឡើងក្នុងអំឡុងពេលប៉ុន្មានឆ្នាំនេះ លើទិដ្ឋភាពមួយចំនួន ដូចជា រវាងអ្នកក្រ និងអ្នកមាន រវាងខេត្តនិងខេត្ត រវាងតំបន់ជនបទនិងតំបន់ប្រជុំជន និងនៅក្នុងតំបន់ជនបទខ្លួនឯងផងដែរ។

ស្តង់ដារជីវភាពរស់នៅជាមធ្យមរបស់ក្រុមអ្នកមានបំផុតក្នុងឆ្នាំ ២០០៤ គឺ ៤៥% ខ្ពស់ជាងកាលពីទសវត្សរ៍កន្លងទៅ ប៉ុន្តែជីវភាពរស់នៅសម្រាប់អ្នកក្រីក្របំផុតបានកើនឡើងតែ ៨% ប៉ុណ្ណោះ។

**រូបភាព. ១៧.២. កំណើនសេដ្ឋកិច្ច ការបង្កើតការងារ និងការកាត់បន្ថយភាពក្រីក្រ**




*ប្រភព៖ ធនាគារពិភពលោក ២០០៩*

បន្ថែមពីនេះ កម្ពុជាមានបទពិសោធន៍ក្នុងការកាត់បន្ថយភាពក្រីក្ររវាងខេត្តនិងខេត្ត និងរវាងតំបន់ជនបទនិងទីប្រជុំជន។ ក្នុងតំបន់ប្រជុំជន ដូចជារាជធានីភ្នំពេញនិងតំបន់មាត់សមុទ្រ ភាពក្រីក្របានធ្លាក់ចុះយ៉ាងលឿន ជាងតំបន់ផ្សេងទៀតរបស់ប្រទេសកម្ពុជា។ នៅតំបន់ភ្នំនិងតំបន់ដាច់ស្រយាលមួយចំនួន ភាពរងគ្រោះដោយសារក្រីក្ររឹតតែកើនឡើង។

ដូច្នេះ កំណើនដែលស្មើភាពគ្នានិងមានចីរភាព គឺជាបុព្វលក្ខខណ្ឌជាមូលដ្ឋានមួយសម្រាប់ការកាត់បន្ថយភាពក្រីក្រ។ កំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ៩,៤% ក្នុងទសវត្សរ៍កន្លងទៅ បានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ដោយបានបង្កើតការងារធ្វើ និងបង្កើនប្រាក់ចំណូលក្នុងមនុស្សម្នាក់។ អំឡុងឆ្នាំ ១៩៩៨-២០០៧ ការងារសរុបចំនួន ១៧៣,៥៩៣ ត្រូវបានបង្កើតក្នុងមួយឆ្នាំ ក្នុងនោះ ៩៨,៣៩៦ លើវិស័យសេវាកម្មនិង ៨៤,៦៥៨ លើវិស័យឧស្សាហកម្ម ខណៈដែលការបាត់បង់ការងារក្នុងវិស័យកសិកម្មមាន ៩,៤៦២ ក្នុងមួយឆ្នាំ។ ចំណូលក្នុងមនុស្សម្នាក់បានកើនឡើង ៨,៣% អំឡុងឆ្នាំ ១៩៩៨-២០០០ ៦,៤% អំឡុងឆ្នាំ២០០០-២០០៤ និង ១០,២% អំឡុងឆ្នាំ ២០០៤-២០០៧។ វត្ថុបំណងរបស់កម្ពុជាគឺ ក្នុងរយៈពេលមធ្យម ត្រូវសម្រេចកំណើនប្រកបដោយចីរភាពក្នុងកម្រិតយ៉ាងហោចណាស់ ៧-៨%ក្នុងមួយឆ្នាំ។ដើម្បីសម្រេចបានវត្ថុបំណងនេះ ទាមទារឱ្យមានកំណើនក្នុងការវិនិយោគផ្នែកឯកជននិងផ្នែកសាធារណៈ ការកើនឡើងនៃជំនួយអភិវឌ្ឍផ្លូវការ ការហូរចូលនៃវិនិយោគទុនដោយផ្ទាល់ពីបរទេស ការកំណត់គោលដៅបានប្រសើរនៃគម្រោងអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចដើម្បីបានជាប្រយោជន៍ដល់ក្រុមងាយរងគ្រោះ បង្កើនប្រសិទ្ធភាពវិនិយោគ និងលើកកម្ពស់សមិទ្ធផលកសិកម្ម។

ការសន្សំទុននឹងជួយរួមចំណែកដល់កំណើនប្រកបដោយចីរភាព ប៉ុន្តែវាគួរតែត្រូវបានប្រើប្រាស់ឱ្យមានប្រសិទ្ធភាព។ វត្ថុបំណងសំខាន់មួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ គឺការបង្កើតបរិយាកាសមួយដែលអំណោយផលដល់ការវិនិយោគឯកជន។ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចអមដោយកំណែទម្រង់ក្នុងផ្នែកផ្សេងៗរួមមាន៖ ឯកជននីយកម្ម សមភាពក្នុងទីផ្សារ ពាណិជ្ជកម្មបរទេស ទីផ្សារពលកម្មនិងហិរញ្ញវត្ថុក្របខណ្ឌគតិយុត្តិ និងប្រព័ន្ធតុលាការ ជាកត្តាសំខាន់ដើម្បីទាក់ទាញវិនិយោគទុនឯកជន។ លក្ខខណ្ឌចាំបាច់មួយទៀតសម្រាប់កំណើននេះគឺ ការកៀរគរធនធានក្នុងស្រុកឱ្យបានគ្រប់គ្រាន់ តាមរយៈវិស័យសាធារណៈ ក្នុងការផ្តល់ជូននូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមកិច្ចដ៏ប្រសើរមួយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំណើននេះនឹងមានឥទ្ធិពលលើភាពក្រីក្រតាមរយៈផលប៉ះពាល់សន្សឹមៗ។ ប៉ុន្តែវាអាចចំណាយពេលយូរពេកនិងមិនគួរឱ្យប្រាថ្នាពីសង្គម។ កំណើនដែលមានឥទ្ធិពលភ្លាមៗទៅលើភាពក្រីក្រ យុទ្ធសាស្ត្រអភិវឌ្ឍគួរត្រូវផ្តោតលើការបង្កើនប្រាក់ចំណូលរបស់អ្នកក្រីក្រ តាមរយៈការបង្កើតកាលានុវត្តភាពការងារឱ្យបានបរិបូណ៌។ ការវិនិយោគត្រូវតែផ្តោតក្នុងតំបន់ និងវិស័យណាដែលអ្នកក្រីក្រនិងក្រុមមនុស្សងាយរងគ្រោះរស់នៅ។ មានន័យថាត្រូវផ្តល់អាទិភាពកាន់តែខ្ពស់ដល់វិនិយោគ នៅតំបន់ជនបទ និងការបែងចែកធនធានដើម្បីអភិវឌ្ឍនៅតំបន់ដាច់ស្រយាល និងផ្តល់ការលើកទឹកចិត្តដល់ការវិនិយោគទុនបែបនេះ។ ដូច្នេះកំណើនដែលតម្រង់ចំពោះអ្នកក្រីក្រ ត្រូវតែសង្កត់ធ្ងន់លើតំបន់ជនបទ ជំរុញផលិតភាពនិងប្រាក់ចំណូលពីវិស័យកសិកម្ម និងប្រើពលកម្មច្រើន។

តួនាទីនៃវិស័យឯកជនក្នុងការកាត់បន្ថយភាពក្រីក្រមានសារៈសំខាន់ណាស់។ ការវិនិយោគរបស់ផ្នែកសាធារណៈតែឯងមិនអាចទ្រទ្រង់បន្ទុកក្នុងការស្រូបយកកម្លាំងពលកម្មបន្ថែម ដោយសារតែកំណើនប្រជាជននិងការកើនឡើង ចំនួនយុវជនក្នុងចំណោមប្រជាជនទាំងអស់ ដោយសារតែការប្រែប្រួលផ្នែកប្រជាសាស្ត្រ។ រាជរដ្ឋាភិបាលត្រូវគាំទ្រវិស័យឯកជន តាមរយៈគោលនយោបាយ ដែលលើកទឹកចិត្តដល់ការភ្ជាប់អ្នកក្រីក្រទៅនឹងសកម្មភាពរបស់ផ្នែកឯកជន ដូចជាការនាំចេញ និងការកែច្នៃផលិតផលកសិកម្មសម្រាប់ទីផ្សារក្នុងស្រុក។ ជារួម ការលើកទឹកចិត្តទាំងអស់គួរត្រូវបានផ្តល់ដល់វិស័យឯកជនឱ្យបង្កើនការវិនិយោគ។

## ១៧.៣.៣.ការប្រើប្រាស់ក្នុងគ្រួសារ

### *១៧.៣.៣.១. ការប៉ាន់ស្មានតាមតំបន់*

ទិន្នន័យបានបង្ហាញថា ការប្រើប្រាស់ពិតប្រាកដរបស់មនុស្សម្នាក់បានកើនឡើងរវាងឆ្នាំ ២០០៤ និង ២០០៧ នៅគ្រប់តំបន់ ទោះបីក្នុងតំបន់ជនបទកើនឡើងតិចតួចក៏ដោយ។

*រូបភាព ១៧.៣. តម្លៃជាមធ្យមភាគគំរូនៃការប្រើប្រាស់របស់គ្រួសារប្រចាំថ្ងៃ ក្នុងតម្លៃថេរ តាមតំបន់ (តម្លៃជាមធ្យមនៅភ្នំពេញគិតជារៀល ក្នុងឆ្នាំ ២០០៤)*




*ប្រភព៖ ធនាគារពិភពលោក ២០០៩*

## ១៧.៣.៣.២. ការប៉ាន់ស្មានចំណែកនៃការហូបចុកក្នុងការប្រើប្រាស់របស់គ្រួសារសរុប

*រូបភាព ១៧.៤. តម្លៃជាមធ្យមគំរូនៃការប្រើប្រាស់របស់គ្រួសារប្រចាំថ្ងៃ ក្នុងតម្លៃថេរ គិតតាមចំណែកនៃការប្រើប្រាស់នីមួយៗ នៅឆ្នាំ ២០០៤ និង ២០០៧ (តម្លៃជាមធ្យមនៅភ្នំពេញគិតជារៀល ក្នុងឆ្នាំ ២០០៤)*




*ប្រភព៖ ធនាគារពិភពលោក ២០០៩*

ក្នុងរយៈពេល ១០ ឆ្នាំមុន ការប្រើប្រាស់ពិតប្រាកដរបស់មនុស្សម្នាក់ត្រូវបានប៉ាន់ស្មានថា កើនឡើងតែ ៨% ប៉ុណ្ណោះ នៅក្នុងក្រុមមនុស្សក្រីក្របំផុត ខណៈដែលក្រុមមនុស្សមានបំផុត កើនឡើង ៤៥%។ តាមការប្រៀបធៀប ការកើនឡើងប្រាក់ចំណូលអំឡុងឆ្នាំ ២០០៤ ដល់ ២០០៧ មានរបាយស្មើភាពជាងអំឡុងឆ្នាំ ១៩៩៣/៩៤ ដល់ឆ្នាំ ២០០៤។ ធាតុពិតនៃការកើនឡើងប្រាក់ចំណូលក្នុងចន្លោះឆ្នាំ ២០០៤ និង២០០៧ មានរបាយស្មើភាពជាងការកើនឡើងប្រាក់ចំណូលពិតប្រាកដ គឺបណ្តាលមកពីតម្លៃអាហារមានអត្រាអតិផរណាខ្ពស់ជាងតម្លៃមិនមែនអាហារ ក្នុងរយៈពេលដូចគ្នានេះ ដែលជះឥទ្ធិពលខ្លាំងដល់ក្រុមមនុស្សក្រីក្របំផុត ជាងក្រុមមនុស្សមានបំផុត។

## ១៧.៣.៣.៣. ការប៉ាន់ស្មានវិសមភាពរួមក្នុងការប្រើប្រាស់របស់គ្រួសារនីមួយៗ

រូបភាព ១៧.៥. បានបង្ហាញថារវាងឆ្នាំ ២០០៤ និង ២០០៧ តម្លៃពិតរបស់បរិមាណអាហារបានថយចុះនៅគ្រប់តំបន់និងគ្រប់ក្រុមមនុស្ស រួមបញ្ចូលទាំងក្រុមមនុស្សក្រីក្របំផុតទាំង ២ ប្រភេទផងដែរ។ អ្វីដែលបានកើតឡើងគឺថា ដើម្បីឆ្លើយតបនឹងការកើនឡើងនៃតម្លៃពិតរបស់ប្រាក់ចំណូលនិងតម្លៃអាហារ អ្នកប្រើប្រាស់ជាជនជាតិកម្ពុជា នៅគ្រប់កម្រិតនៃប្រាក់ចំណូល បានចំណាយលើមុខចំណាយមិនមែនអាហារ ជំនួសឱ្យអាហារ ដែលជាហេតុធ្វើឱ្យតម្លៃពិតរបស់បរិមាណអាហារបានធ្លាក់ចុះ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រូបភាព ១៧.៥. ការចំណាយលើអាហារជាភាគរយនៃការចំណាយក្នុងគ្រួសារសរុប តាមតំបន់ ក្នុងឆ្នាំ ២០០៤-២០០៧*




*ប្រភព៖ធនាគារពិភពលោក២០០៩*

### ១៧.៣.៣.៤. ការប៉ាន់ស្មានវិសមភាពរួមក្នុងការប្រើប្រាស់របស់គ្រួសារនីមួយៗ

កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សចន្លោះឆ្នាំ ២០០៤ និង ២០០៧ មានការពាក់ព័ន្ធមិនត្រឹមតែដល់ការថយចុះនៃភាពក្រីក្រទេ ប៉ុន្តែក៏ពាក់ព័ន្ធដល់ការកើនឡើងនៃវិសមភាពផងដែរ។ ស្របពេលដែលការប្រើប្រាស់ក្នុងមួយឯកតារបស់ក្រុមមនុស្សទាំង ៥ ប្រភេទនិងគ្រប់តំបន់ មានការកើនឡើង អត្រានៃការកើនឡើងទាំងនេះមានភាពខុសគ្នាខ្លាំង។ ការកាត់បន្ថយភាពក្រីក្រអាចនឹងបានល្អជាងនេះ ប្រសិនបើកំណើនប្រាក់ចំណូលពិតប្រាកដ មិនឡើងខ្ពស់ពេកក្នុងក្រុមមនុស្សមានបំផុតនិងក្នុងតំបន់ទីក្រុង (ជាពិសេសភ្នំពេញ) ធៀបនឹងក្រុមមនុស្សមិនសូវមាន និងក្នុងតំបន់ជនបទ។

*តារាង ១៧.៣. ការប៉ាន់ស្មានមេគុណ Gini តាមតំបន់ ក្នុងឆ្នាំ ២០០៤ និង ២០០៧*
*(តួលេខក្នុងវង់ក្រចក ជាការប៉ាន់ស្មាន standard errors)*

| តំបន់ | ២០០៤ | ២០០៤* | ២០០៧ |
|---|---|---|---|
| ភ្នំពេញ | 0.៣៦៧ | 0.៣៦៧ | 0.៣៨០ |
| | (0.០១៤) | (0.០១៧) | (0.០២០) |
| ប្រជុំជនដទៃទៀត | | | |
| 0.៤៣៥ | 0.៤៣១ | 0.៤៦៨ | |
| | (0.០១៦) | (0.០១៩) | (0.០៦០) |
| ជនបទ | 0.៣៤២ | 0.៣៣៤ | 0.៣៦០ |
| | (0.០១០) | (0.០០៧) | (0.០៣១) |
| កម្ពុជា | 0.៣៩៦ | 0.៣៩៣ | 0.៤៣១ |
| | (0.០០៨) | (0.០០៨) | (0.០២៨) |

*ប្រភព៖ធនាគារពិភពលោក២០០៩*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តារាង ១៧.៣ បានបង្ហាញអំពី ការប៉ាន់ស្មានមេគុណ Gini នៃការប្រើប្រាស់របស់មនុស្សម្នាក់តាមតំបន់ នៅឆ្នាំ ២០០៤ និង ២០០៧ (រួមបញ្ចូលទាំង សំណាកគំរូរងរបស់ភូមិ នៅឆ្នាំ២០០៤ ដែលអាចប្រៀបធៀបបានជាមួយភូមិក្នុងសំណាកគំរូរបស់ការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ ២០០៧)។ ការប៉ាន់ស្មានគម្លាត standard errors ត្រូវបានបង្ហាញនៅក្នុងរង្វង់ក្រចក និងស្ថិតនៅពីក្រោមការប៉ាន់ស្មានមេគុណ Gini នីមួយៗ។ មេគុណ Gini ត្រូវបានគេប្រើប្រាស់ទូទៅក្នុងការវាស់វែងវិសមភាពនៃប្រាក់ចំណូល។ មេគុណនេះមានតម្លៃពី ០ (វិសមភាពខ្លាំងនៃរបាយបាក្រ់ចំណូល) ដល់ ១ (សមភាពខ្លាំងនៃរបាយប្រាក់ចំណូល)។ គេប្រើមេគុណនេះសម្រាប់វាស់វែងវិសមភាពនៃការប្រើប្រាស់ឬប្រាក់ចំណូលរបស់បុគ្គលម្នាក់ៗ។

*រូបភាព ១៧.៦. មេគុណ Gini នៃវិសមភាពប្រាក់ចំណូលតាមតំបន់ ឆ្នាំ២០០៤ និង២០០៧*




*ប្រភព៖ ធនាគារពិភពលោក WB (2009), 2004 and 2007 CSES*

ក្នុងសំណាកគំរូភូមិប្រៀបធៀប មេគុណរួម Gini របស់កម្ពុជាបានកើនឡើងពី ០.៣៩ ទៅ ០.៤៣ ទោះបីការប៉ាន់ស្មាននេះមានកម្រិតជឿជាក់ក្នុងកម្រិត ០.១០ ក៏ដោយ។ វិសមភាពប្រាក់ចំណូលនៅភ្នំពេញត្រូវបានគេប៉ាន់ស្មានថាបានធ្លាក់ចុះ ក្នុងអំឡុងពេលដូចគ្នា ថ្វីបើការប៉ាន់ស្មានមានកម្រិតជឿជាក់មិនសូវសំខាន់ក៏ដោយ។

*រូបភាព ១៧.៧. បម្រែបម្រួលនៃខ្សែកោង Lorenz សម្រាប់កម្ពុជា ចន្លោះឆ្នាំ២០០៤និង២០០៧*






fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្សែកោង Lorenz បង្ហាញពីភាពខុសគ្នារវាងតំបន់នានា លើរបាយនៃទំហំការប្រើប្រាស់ពិតប្រាកដក្នុងមនុស្សម្នាក់នៅឆ្នាំ ២០០៧ ខណៈដែល រូបភាព ១៧.៧ បង្ហាញពីការផ្លាស់ប្តូរនៃខ្សែកោង Lorenz តាមតំបន់ចន្លោះឆ្នាំ ២០០៤ និង ២០០៧។

### ១៧.៣.៣.៥. ការប៉ាន់ស្មានភាពក្រីក្រ

នៅកម្ពុជា ការវាស់វែងភាពក្រីក្រ ត្រូវបានគណនាដោយប្រៀបធៀប ការប៉ាន់ស្មាននៃការចំណាយប្រចាំថ្ងៃរបស់មនុស្សម្នាក់ជាប្រាក់រៀល ទៅនឹងបន្ទាត់នៃភាពក្រីក្រដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់តំបន់ ដែលមនុស្សម្នាក់ៗរស់នៅ។ អត្រាភាពក្រីក្រខុសៗគ្នា ៣ ប្រភេទត្រូវបានគេគណនា (គិតជាភាគរយ) ឧទាហរណ៍ សន្ទស្សន៍នៃភាពក្រីក្រប្រជាជនម្នាក់ (the poverty headcount index) ជាភាគរយប្រជាជនដែលការចំណាយក្នុងមួយនាក់ស្ថិតក្រោមបន្ទាត់ភាពក្រីក្រ សន្ទស្សន៍គម្លាតនៃភាពក្រីក្រ (the poverty gap index) ដែលជាភាគរយគម្លាតជាមធ្យមរវាងការប្រើប្រាស់របស់មនុស្សម្នាក់និងបន្ទាត់នៃភាពក្រីក្រ (ជាមួយតម្លៃសូន្យដែលត្រូវបានកំណត់ចំពោះបុគ្គលនៅពីលើបន្ទាត់នៃភាពក្រីក្រ) និងសន្ទស្សន៍កម្រិតធ្ងន់ធ្ងរនៃភាពក្រីក្រ (the poverty severity index (P2)) ជាគម្លាតនៃភាពក្រីក្រដែលត្រូវបានលើកជាស្វ័យគុណមុននឹងវាត្រូវបានគណនាជាមធ្យមធៀបនឹងប្រជាជន ដូច្នេះវាផ្តល់នូវទម្ងន់រឹតតែខ្លាំងចំពោះគម្លាតនៃភាពក្រីក្រកាន់តែធំ។

ការប៉ាន់ស្មានភាពក្រីក្របានបង្ហាញថា សន្ទស្សន៍នៃភាពក្រីក្រប្រជាជនម្នាក់ ធៀបនិងបន្ទាត់នៃភាពក្រីក្រជារួមសម្រាប់កម្ពុជាបានធ្លាក់ចុះពី ៣៤,៨% ក្នុងឆ្នាំ២០០៤ (ក្នុងភូមិប្រហាក់ប្រហែលគ្នា) មកត្រឹម៣០,១% ក្នុងឆ្នាំ២០០៧។ សន្ទស្សន៍នៃភាពក្រីក្រប្រជាជនម្នាក់ ធៀបនឹងបន្ទាត់នៃភាពក្រីក្រអាហាររបស់ កម្ពុជាក៏បានថយចុះផងដែរក្នុងរយៈពេលនេះ ប៉ុន្តែពី ១៩,៧% ក្នុងឆ្នាំ២០០៤ (ក្នុងភូមិប្រហាក់ប្រហែលគ្នា) មកត្រឹមតែ ១៨,០% ប៉ុណ្ណោះ។ អតិផរណាខ្ពស់ក្នុងតម្លៃម្ហូបអាហារក្នុងរយៈពេលនេះ បណ្តាលឱ្យមានភាពខុសប្លែកគ្នានេះ។ លទ្ធផលក៏បង្ហាញផងដែរថា សន្ទស្សន៍នៃភាពក្រីក្រប្រជាជនម្នាក់ ធៀបទៅនឹងបន្ទាត់នៃភាពក្រីក្រជារួមនិងបន្ទាត់នៃភាពក្រីក្រអាហារបានថយចុះនៅគ្រប់តំបន់។ ការថយចុះនៃភាពក្រីក្រអំឡុងឆ្នាំ២០០៤-២០០៧ គឺមានតុល្យភាពគ្រប់តំបន់។ សន្ទស្សន៍គម្លាតនៃភាពក្រីក្រ និងសន្ទស្សន៍កម្រិតធ្ងន់ធ្ងរនៃភាពក្រីក្រក្រក្រ ក៏ត្រូវបានសន្និដ្ឋានដូចគ្នានេះដែរ។

របាយការណ៍ធនាគារពិភពលោករកឃើញថា ការកាត់បន្ថយភាពក្រីក្រដែលត្រូវបានអង្កេតជាងមួយទសវត្សរ៍មុន (១៩៩៤-២០០៤) បានបន្តធ្លាក់ចុះក្នុងរយៈពេល ២០០៤-២០០៧ ផងដែរ។ សន្ទស្សន៍នៃភាពក្រីក្រប្រជាជនម្នាក់ ធៀបនឹងបន្ទាត់នៃភាពក្រីក្រជារួមបានធ្លាក់ចុះពី ៣៤,៨% ក្នុងឆ្នាំ ២០០៤ មកត្រឹម ៣០,១% ក្នុងឆ្នាំ២០០៧។ ការថយចុះនៃភាពក្រីក្រក្នុងរយៈពេលនេះ បានឆ្លុះបញ្ចាំងពីកំណើននៃការចំណាយតាមគ្រួសារ យ៉ាងខ្លាំងនិងយ៉ាងសំខាន់ (រង្វាស់នៃជីវភាពរស់នៅដែលត្រូវបានប្រើក្នុងប្រទេសកម្ពុជា)។ ការកើនឡើងនេះ (ជាមធ្យម២១% សម្រាប់ប្រជាជនទាំងមូល) ត្រូវបានជំរុញដោយអត្រានៃកំណើនសេដ្ឋកិច្ច ក្នុងអំឡុងឆ្នាំទាំងនេះ ដែលកើនហួស ១០% ក្នុងមួយឆ្នាំ។

### ១៧.៣.៣.៦. សូចនាករសង្គមសេដ្ឋកិច្ច

ការសន្មតិដែលថាភាពក្រីក្របានបន្តធ្លាក់ចុះនោះ ត្រូវបានគាំទ្រដោយសូចនាករផ្សេងៗទៀត។ សូចនាករទាំងនេះរួមមាន ការប្រែប្រួលក្នុងភាពជាម្ចាស់នៃអ្នកប្រើប្រាស់ ក្នុងចំណោមគ្រួសារនៃក្រុមប្រជាជនក្រីក្រទាំង ២ កម្រិត (ឧទាហរណ៍ ក្រុមប្រជាជនក្រីក្រដែលត្រូវជា ៤០% នៃប្រជាជនសរុប ដូចដែលបានធ្វើ

ចំណាត់ថ្នាក់ដោយការប្រើប្រាស់ក្នុងគ្រួសារនីមួយៗ)។ ការសន្ទតិនេះក៏គាំទ្រដោយ ការកើនឡើងជាលំដាប់នៃទំហំនិងគុណភាពរបស់គេហដ្ឋាន។

ភាពប្រសើរឡើងផ្នែកសុខមាលភាពក្នុងចំណោមក្រុមប្រជាជនក្រីក្រទាំង ២ កម្រិត ត្រូវបានលើកកម្ពស់ តាមរយៈការកែលម្អអថេរមួយចំនួនធំ ដែលទាក់ទងទៅនឹងផលសម្រេចនៃការផ្តល់សេវា និងការអភិវឌ្ឍធនធានមនុស្ស។

វិស័យអប់រំ សុខាភិបាល និងអាហារូបត្ថម្ភមានការកើនឡើងគួរឱ្យកត់សម្គាល់។ បរិមាណនៃការទទួលបានសេវាសាធារណៈត្រូវបានបង្កើន ដូចជា ចម្ងាយជាមធ្យមដើម្បីទៅដល់មណ្ឌលសុខភាពឬសាលារៀនដែលជិតបំផុត ការកែលម្អបណ្តាញផ្លូវថ្នល់ និងការកើនឡើងចំណូលពិត។ កត្តាទាំងអស់នេះជាហេតុផលធ្វើឱ្យអត្រានៃការសិក្សានិងឥរិយាបថ ក្នុងការស្វែងរកសេវាសុខភាពកើនឡើង។

### ១៧.៣.៤. ការអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ

គោលនយោបាយចម្បងៗ ដែលរាជរដ្ឋាភិបាលកម្ពុជានឹងបន្តអនុវត្តក្នុងការកាត់បន្ថយភាពក្រីក្ររួមមាន៖

- ការបង្រួបបង្រួមសន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម
- ការកៀរគរធនធានក្នុងស្រុក
- ការលើកកម្ពស់ការវិនិយោគទុន
- ការបែងចែកការវិនិយោគទៅលើវិស័យអាទិភាព រួមមានការអប់រំ សុខាភិបាល និងកសិកម្ម
- ការកសាងសមត្ថភាពស្ថាប័ននិងការពង្រឹងអភិបាលកិច្ចល្អ
- សមាហរណកម្មនៃសេដ្ឋកិច្ចកម្ពុជាចូលទៅក្នុងតំបន់និងពិភពលោក
- ការអភិវឌ្ឍធនធានមនុស្ស
- ការពង្រឹងភាពជាដៃគូជាមួយសហគមន៍ម្ចាស់ជំនួយ និងសង្គមស៊ីវិល

**ទីមួយ**-ការបង្រួបបង្រួមសន្តិភាពស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម កំពុងត្រូវបានបន្តអនុវត្តដោយការចាត់វិធានការរឹងមាំ ដើម្បីពង្រឹងនីតិរដ្ឋ ប្រកាន់ខ្ជាប់សិទ្ធិមនុស្ស និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យជាមួយនិងទិដ្ឋភាពក្នុងការបង្កើតបរិយាកាសសន្តិសុខ និងនយោបាយអនុគ្រោះ សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព រយៈពេលយូរអង្វែង។

**ទីពីរ**-វិធានការនានាកំពុងបន្តធ្វើ ដើម្បីបង្កើនការកៀរគរធនធានក្នុងស្រុកនិងអនុវត្តកំណែទម្រង់ថវិកាដោយមានបំណងធ្វើឱ្យប្រសើរឡើង និងធ្វើសនិទានកម្មការចំណាយសាធារណៈ។ គេត្រូវការបង្កើនកម្មវិធីប្រយុទ្ធប្រឆាំងភាពក្រីក្រ។ ទាំងវិស័យឯកជននិងសាធារណៈត្រូវតែចូលរួមគ្នាក្នុងការបង្កើនអត្រាសន្សំសំចៃថ្នាក់ជាតិ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ទីបី**-ការលើកកម្ពស់និងសម្របសម្រួលការវិនិយោគនឹងនៅបន្តជាអាទិភាព។ កម្ពុជាត្រូវការការចាក់បញ្ចូលនូវការវិនិយោគដ៏ច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដើម្បីផលិតបានកំណើនតាមការកំណត់ទុក។ ការវិនិយោគភាគច្រើននឹងត្រូវបានកៀរគរពីបរទេស ដោយសារធនធានក្នុងស្រុករបស់កម្ពុជានៅមានកំណត់។ ពេលវេលានេះផ្តល់ភាពងាយស្រួល ដើម្បីបង្កើនជំនួយបរទេសមកកាន់កម្ពុជាមិនមែនបង្រួមវាឱ្យតិចវិញនោះទេ។ តែទោះជាយ៉ាងណា កម្ពុជាក៏គួរផ្តោតអារម្មណ៍ចំពោះការធានាបរិយាកាសមួយដែលនាំមកនូវស្ថេរភាព សន្តិសុខ តម្លាភាព ទំនួលខុសត្រូវ និងលទ្ធភាពដែលអាចទស្សទាយបាន ដែលនឹងគាំទ្រនិងលើកកម្ពស់ការវិនិយោគក្នុងប្រទេសកម្ពុជា។

**ទីបួន**-ការអភិវឌ្ឍដែលគាំទ្រដល់អ្នកក្រីក្រ មានន័យថា បង្វែរការចំណាយទៅលើវិស័យអាទិភាពដែលផលត្រឡប់ចំពោះការកាត់បន្ថយភាពក្រីក្រនឹងមានជាអតិបរិមា។ ការពង្រឹងនិងអភិវឌ្ឍសេវាកម្មគាំទ្រផ្នែកកសិកម្មដ៏មានប្រសិទ្ធភាព រួមមានការស្រាវជ្រាវផ្នែកកសិកម្ម ការពង្រីកការគ្រប់គ្រងទឹកលើវាលស្រែ ការផ្គត់ផ្គង់ និងបែងចែកធាតុចូលផ្នែកគុណភាព ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសមស្របដូចជា គ្រឿងបរិក្ខារប្រព័ន្ធស្រោចស្រពដែលគ្រប់គ្រងពីកសិករខ្នាតតូច គ្រឹះស្ថានហិរញ្ញវត្ថុខ្នាតតូច និងផ្លូវពីស្រែទៅទីផ្សារ ការបង្កើតនិងការអនុវត្តកម្មវិធីគ្រប់គ្រងធនធានទឹកបានទូលំទូលាយ ការប្រយុទ្ធប្រឆាំងការចាប់យកដី និងការគ្មានដីរស់នៅ ការអភិវឌ្ឍនិងការអនុវត្តសិទ្ធិកាន់កាប់ដីធ្លី និងគោលនយោបាយប្រើប្រាស់ដី និងការការពារបរិស្ថាន គឺជាឧទាហរណ៍នៃការផ្តួចផ្តើមគាំទ្រដល់អ្នកក្រីក្រដែលអាចត្រូវបានបង្កើនល្បឿន តាមរយៈការវិភាជន៍ធំជាងនេះ។

**ទីប្រាំ**- ការកសាងសមត្ថភាពស្ថាប័ននិងការពង្រឹងអភិបាលកិច្ចល្អគឺ មានសារសំខាន់ណាស់ចំពោះទស្សនទាននៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងសមធម៌ និងជាអាទិភាពកំពូលមួយសម្រាប់រាជរដ្ឋាភិបាល។ការងារនេះក៏ភ្ជាប់ទៅនឹងការបង្កើតនីតិរដ្ឋ ការបន្តកំណែទម្រង់រដ្ឋបាល ការលើកកម្ពស់តម្លាភាព និងទំនួលខុសត្រូវ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលនឹងមានឥទ្ធិពលដោយផ្ទាល់ទៅលើការកាត់បន្ថយភាពក្រីក្រ។

**ទីប្រាំមួយ**- ការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ទៅក្នុងតំបន់និងពិភពលោក កំពុងត្រូវបានធ្វើជាបន្តយ៉ាងខ្លាំងក្លា ខណៈដែលកម្ពុជាមានទំហំសេដ្ឋកិច្ចតូចនោះ តម្រូវការចូលទៅកាន់ទីផ្សារធំជាងនេះសម្រាប់ប្រសិទ្ធភាពសេដ្ឋកិច្ច។ កម្ពុជាត្រូវការក្លាយជាអ្នកផលិតដែលមានប្រសិទ្ធភាពមួយ ប្រសិនបើចង់កាត់បន្ថយភាពក្រីក្រ តាមរយៈគោលនយោបាយសេដ្ឋកិច្ចតម្រង់ទៅរកទីផ្សារ។ សុខមាលភាពសាធារណៈក៏នឹងទទួលផលពីកត្តាចលករ និងការនាំចូលដែលមានតម្លៃទាប ដែលនឹងនាំទៅរកសមាហរណកម្មក្នុងតំបន់និងសកលលោក។

**ទីប្រាំពីរ**-បទពិសោធន៍ពីប្រទេសកំពុងអភិវឌ្ឍមួយចំនួនបង្ហាញថា ការវិនិយោគលើមូលធនមនុស្សជាពិសេសក្នុងវិស័យអប់រំ ការស្រាវជ្រាវកសិកម្ម ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការបង្កើតការងារ និងសុខាភិបាលគឺជាគន្លឹះដល់ការធានាបាននូវជោគជ័យសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ។ កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្ររបស់កម្ពុជានឹងបន្តរួមបញ្ចូលសមាសធាតុទាំងនេះ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ជីទ្រាំបី-** ការរក្សានិងការពង្រឹងភាពជាដៃគូជាមួយសហគមន៍ម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលក៏មានសារៈសំខាន់ផងដែរ សម្រាប់ភាពជោគជ័យក្នុងការប្រយុទ្ធនិងភាពក្រីក្រ។ កម្ពុជាបានប្ដេជ្ញាក្នុងការធ្វើកំណែទម្រង់ និងទទួលបានការគាំទ្រសុឆន្ទៈយ៉ាងខ្លាំងពីសហគមន៍ម្ចាស់ជំនួយនិងសង្គមស៊ីវិល។ កម្ពុជានឹងកសាងនៅលើមូលដ្ឋាននេះនិងប្រមូលផ្ដុំគ្រប់ធនធានដែលអាចរកបានទាំងអស់ដើម្បីកាត់បន្ថយភាពក្រីក្រ។

### ១៧.៣.៤.១. *ការលើកកម្ពស់កាលានុវត្តិភាព*

ផ្នែកនេះគូសបញ្ជាក់ពីផ្នែកសំខាន់ៗ សម្រាប់ជាវិធានការកាត់បន្ថយភាពក្រីក្រ ដូចបានសង្ខេបក្នុងតារាង ១៧.៤។ បន្ថែមពីនេះទៀត បញ្ហាឆ្លងផ្នែកសំខាន់ៗមួយចំនួន ដូចជាការកៀរគរចំណូលនិងទំនាក់ទំនងជាមួយម្ចាស់ជំនួយ ក៏នឹងត្រូវបង្ហាញនៅចុងបញ្ចប់នៃសៀវភៅនេះផងដែរ។

អភិក្រមជាមូលដ្ឋានចំពោះការលើកកម្ពស់កាលានុវត្តិភាព គឺតាមរយៈការពង្រឹងសមិទ្ធកម្មម៉ាក្រូសេដ្ឋកិច្ច ការបង្កើនល្បឿនកំណើនសេដ្ឋកិច្ច ការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការពង្រឹងវិស័យថាមពល ការធានាការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃវិស័យកសិកម្ម ការលើកកម្ពស់ការគ្រប់គ្រងធនធានទឹក ការជំរុញការអភិវឌ្ឍជនបទនិងវិមជ្ឈការ ការធានាបាននូវការគ្រប់គ្រងធនធានធម្មជាតិដ៏មានប្រសិទ្ធភាព ការលើកទឹកចិត្តសកម្មភាពបង្កើតប្រាក់ចំណូល កំណែទម្រង់ដីធ្លី និងការបង្កើនលទ្ធភាពទទួលបានមីក្រូហិរញ្ញវត្ថុសម្រាប់អ្នកក្រ។ ទោះបីជា កម្មវិធីបានដៅសម្រាប់តំបន់ជនបទ ដែលអាចមានឥទ្ធិពលយ៉ាងឆាប់រហ័សលើប្រជាជននៅជនបទក៏ដោយ ក៏យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រគួរសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍវិស័យសេវាកម្មនិងឧស្សាហកម្មដែរដែលចាំបាច់ចំពោះដំណោះស្រាយរយៈពេលយូរអង្វែងចំពោះភាពក្រីក្រ។

#### ១៧.៣.៤.១.១. *ការជំរុញស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច*

ការគ្រប់គ្រងវិស័យម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្នគួបផ្សំជាមួយការបើកទូលាយសេដ្ឋកិច្ច និងការតម្រង់ទិសទីផ្សារនោះ គឺជាចំណុចស្នូលនៃកម្មវិធីកាត់បន្ថយភាពក្រីក្រ។ កម្ពុជាត្រូវបន្តធ្វើសមាហរណកម្មកាន់តែជ្រៅជាមួយ និងសេដ្ឋកិច្ចក្នុងតំបន់និងពិភពលោក និងរក្សាការឆ្ពោះទៅខាងក្រៅនិងសេដ្ឋកិច្ចបើកចំហគោលនយោបាយពាណិជ្ជកម្មនិងហិរញ្ញវត្ថុ រួមបញ្ចូលទាំងការរក្សាគោលនយោបាយអត្រាប្ដូរប្រាក់ផ្អែកលើទីផ្សារនិងប្រព័ន្ធប្ដូរប្រាក់សេរីមួយ។ កំណែទម្រង់ពាណិជ្ជកម្មក៏នឹងបន្តអនុវត្តក្នុងបរិបទនៃ AFTA និង WTO។ ការផ្ដោតលើការកសាងសមត្ថភាពបន្ថែមទៀត ដើម្បីធានាបានបរិយាកាសម៉ាក្រូសេដ្ឋកិច្ចមួយដែលមានស្ថេរភាព និងអំណោយផលដល់កំណើនសេដ្ឋកិច្ច។

#### ១៧.៣.៤.១.២. *ការបង្កើនល្បឿនកំណើនសេដ្ឋកិច្ច*

ក្រៅពីការបង្កើនការវិនិយោគទុន ការបង្កើនល្បឿននៃកំណើននឹងតម្រូវឱ្យមានការយកចិត្តទុកដាក់ចំពោះបញ្ហាមួយចំនួនរួមមាន ការអភិវឌ្ឍស្ថាប័ននយោបាយ សង្គមកិច្ច និងសេដ្ឋកិច្ចឱ្យបានខ្លាំងក្លាជាងនេះ ដើម្បីទទួលបានអភិបាលកិច្ចដ៏ប្រសើរនៅកម្ពុជា។ កំណើនដ៏ទូលំទូលាយក៏នឹងត្រូវដើរស្របគ្នានឹងការលើកកម្ពស់លទ្ធភាពរបស់អ្នកក្រីក្រទទួលបានឥណទាន ការអប់រំ សុខភាព និងហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជា

ទឹកស្អាតនិងអនាម័យ។ កម្មវិធីផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលដែលនឹងជួយលើកកម្ពស់ការតម្រង់ទិសនៃវិនិយោគទុនគាំទ្រដល់អ្នកក្រីក្រ រួមមានការកសាងផ្លូវនៅជនបទ ការផ្ដល់ព័ត៌មាននិងការអភិវឌ្ឍទីផ្សារនៅជនបទ។

### ១៧.៣.៤.១.៣. *ការសម្របសម្រួលការអភិវឌ្ឍវិស័យឯកជន*

រាជរដ្ឋាភិបាលកម្ពុជាមានការប្ដេជ្ញាចិត្ត ដើម្បីអភិវឌ្ឍនិងពង្រឹងក្របខណ្ឌច្បាប់និងបទបញ្ញត្តិ និងសមត្ថភាពស្ថាប័នដែលមានអំណោយផលដល់ការវិនិយោគរបស់ផ្នែកឯកជន និងសកម្មភាពអាជីវកម្មក្នុងប្រទេសកម្ពុជា។ ការអភិវឌ្ឍវិស័យឯកជនត្រូវបានរាំងខ្ទប់ ដោយការខ្វះខាតស្ថាប័នច្បាប់និងបទបញ្ញត្តិដ៏រឹងមាំ និងប្រភពហិរញ្ញវត្ថុមានកម្រិត។ កម្មវិធីរបស់រាជរដ្ឋាភិបាលដែលជួយដល់ការអភិវឌ្ឍវិស័យឯកជនរួមមានការធ្វើសុខដុមនីយកម្មច្បាប់និងបទបញ្ញត្តិ ការអនុម័តច្បាប់ពាណិជ្ជកម្មទូលំទូលាយ ការពង្រឹងនីតិរដ្ឋនិងអភិបាលកិច្ចល្អ ការរក្សាភាពប្រកួតប្រជែងរបស់កម្ពុជាប្រៀបធៀបជាមួយតំបន់ និងការលើកកម្ពស់គុណភាពប្រព័ន្ធតុលាការ។ សមាសធាតុចម្បងៗនៃច្បាប់ពាណិជ្ជកម្មថ្មីត្រូវបានដាក់ជូនទីស្ដីការគណៈរដ្ឋមន្ត្រី។

### ១៧.៣.៤.១.៤. *ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន*

ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បានជួយកាត់បន្ថយឧបសគ្គនានា ដល់ការចូលរួមរបស់អ្នកក្រីក្រក្នុងសកម្មភាពសេដ្ឋកិច្ច។ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ គួបផ្សំជាមួយលទ្ធភាពកាន់តែច្រើនរបស់អ្នកក្រីក្រ ដើម្បីចូលទៅក្នុងទីផ្សារ ឥណទាន ការអប់រំ និងសុខាភិបាលនឹងធានាបានថាឥទ្ធិពលនៃកំណើនជាវិជ្ជមាននឹងកើតឡើងសន្សឹមៗដល់អ្នកក្រីក្រ។ អាទិភាពក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗរួមមាន ការបង្កើតវិស័យថាមពលដ៏មានប្រសិទ្ធភាពមួយ ប្រព័ន្ធអគ្គិសនីតាមជនបទ ការជួសជុលនិងថែទាំប្រព័ន្ធផ្លូវជាតិ ការកែលម្អប្រព័ន្ធទឹកស្អាតនិងអនាម័យ ទូរគមនាគមន៍ល្អប្រសើរ ការបង្កើតផែនការមេរបស់ទីក្រុង/ខេត្ត ការរៀបចំផែនទីវិស័យរដ្ឋបាល និងសណ្ឋានដី និងការអភិវឌ្ឍលំនៅឋានតាមជនបទ។ ហេដ្ឋារចនាសម្ព័ន្ធវិស័យកសិកម្មដូចជា ផ្លូវជនបទ ប្រព័ន្ធស្រោចស្រព ប្រព័ន្ធលូ និងទីផ្សារក៏ជាផ្នែកមួយនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែរ។ ដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញនៃការវិនិយោគ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគួរដើរទន្ទឹមគ្នាជាមួយការកសាងសមត្ថភាពសម្រាប់ការផ្ដល់ជូនយ៉ាងប្រសើរនៃសេវាកម្ម គាំទ្រវិស័យកសិកម្ម រួមមានការស្រាវជ្រាវផ្នែកកសិកម្ម ការត្រួតពិនិត្យនិងវាយតម្លៃផែនការគោលការផ្ដល់ធាតុចូលផ្នែកកសិកម្ម និងការផ្ទេរបច្ចេកវិទ្យានិងចំណេះដឹងទៅឱ្យកសិករ។

### ១៧.៣.៤.១.៥. *ការពង្រឹងវិស័យថាមពល*

នៅតំបន់ជនបទមានគ្រួសារតែ ២% ប៉ុណ្ណោះ ដែលមានលទ្ធភាពទទួលបានអគ្គិសនីតាមប្រព័ន្ធខ្សែភ្លើង ខណៈដែល ៥,៤% ទៀតប្រើប្រាស់អគ្គិសនីដែលផលិតដោយផ្នែកឯកជន។ គុណភាពនៃការអប់រំនិងការថែរក្សាសុខភាពក្នុងតំបន់ជនបទ ត្រូវបានរារាំងដោយការខ្វះខាតនូវលទ្ធភាពទទួលបានអគ្គិសនី ដែលបណ្ដាលឱ្យភាពក្រីក្រនៅតែបន្តកើតមាន។ ប្រព័ន្ធអគ្គិសនីតាមជនបទមានសារៈសំខាន់សម្រាប់ការលើកកម្ពស់គុណភាពសេវាសង្គមដល់អ្នកក្រីក្រ និងការជំរុញផលិតកម្មពលកម្មក្នុងវិស័យកសិកម្ម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១៧.៣.៤.១.៦. *ការលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព*

កម្មវិធីសំខាន់ៗមានដូចជា ៖ (១) ការពន្លឿនអភិវឌ្ឍប្រព័ន្ធស្រោចស្រពឯកជនដែលមានរយៈពេលអភិវឌ្ឍខ្លី ប្រសិទ្ធភាពចំណាយ និងទ្រង់ទ្រាយតូច ដូចជាអណ្តូងលូរាក់ៗ និងអណ្តូងស្នប់ (២)ការធ្វើឱ្យប្រសើរឡើងនៃផលិតភាពស្រូវ (៣) ការលើកកម្ពស់ប្រព័ន្ធធ្វើស្រែចម្ការ រួមទាំងពិពិធកម្មនិងប្រពលវប្បកម្មដំណាំ (៤) ការពង្រីកនិងធ្វើឱ្យប្រសើរឡើងផលិតកម្មបសុសត្វនិង (៥) កសិរុក្ខសាស្ត្រតាមសហគមន៍។ប្រព័ន្ធស្រោចស្រពដែលគ្រប់គ្រងដោយកសិករខ្នាតតូចផ្តល់នូវនិទស្សន៍ដ៏ល្អបំផុតនៃកំណើនដ៏ឆាប់រហ័សក្នុងផលិតភាពកសិកម្ម។ ការចិញ្ចឹមសត្វក៏អាចត្រូវបានធ្វើឱ្យប្រសើរឡើងដែរដើម្បីផ្តល់ផលប្រយោជន៍ដល់អ្នកក្រីក្រជនបទភាគច្រើន។ ការចិញ្ចឹមសត្វមាន់និងសត្វជ្រូកនៅក្រោយផ្ទះ ការអភិវឌ្ឍបរិក្ខារដំណើរការចិញ្ចឹមសត្វ និងវារីវប្បកម្មតាមគ្រួសាររួមមាន ការចិញ្ចឹមត្រីក្នុងវាលស្រែលិចទឹក គឺជាកម្មវិធីមួយប្រភេទទៀតក្នុងការកាត់បន្ថយភាពក្រីក្រ។

### ១៧.៣.៤.១.៧. *ការលើកកម្ពស់ការគ្រប់គ្រងធនធានទឹក*

កង្វះលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់គឺជា រូបភាពមួយទៀតនៃភាពក្រីក្រនៅជនបទនិងទីក្រុង។ ស្រទាប់ជលសិលាជ្រៅនិងរាក់ក្នុងប្រទេសអាចត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រពនិងការផ្គត់ផ្គង់ទឹកក្នុងស្រុក។ កន្លែងណាដែលអាចធ្វើបានតាមបច្ចេកទេសនិងសេដ្ឋកិច្ចនោះ ការស្តារឡើងវិញនូវបរិក្ខារសម្រួលប្រព័ន្ធស្រោចស្រពមានស្រាប់នឹងអាចត្រូវបានអនុវត្ត ដើម្បីផ្តល់នូវភាពស្មើគ្នាក្នុងការទទួលបានទឹកស្រោចស្រពនិងដើម្បីជំរុញផលិតកម្មកសិកម្មក្នុងតំបន់អសន្តិសុខស្បៀង។

### ១៧.៣.៤.១.៨. *ការជំរុញអភិវឌ្ឍជនបទនិងវិមជ្ឈការ*

ការសង្កត់ធ្ងន់គឺនៅលើការអភិវឌ្ឍជនបទតាមបែបវិមជ្ឈការ មានការចូលរួម សមាហរណកម្ម និងពីក្រោមឡើងលើ។ ការអនុញ្ញាតឱ្យមានការចូលរួមពីសហគមន៍យ៉ាងសកម្មក្នុងស្ថាប័នថ្នាក់ក្រោម និងបង្កើនភាពជាម្ចាស់នៃគម្រោងអភិវឌ្ឍ ដោយបង្វែរការសម្រេចចិត្តនិងទំនួលខុសត្រូវកាន់តែជិតទៅបុគ្គលម្នាក់ៗ គ្រួសារ និងសហគមន៍នានា។ រាជរដ្ឋាភិបាលគ្រោងនឹងធ្វើវិមជ្ឈការថែមទៀតនូវប្រព័ន្ធរដ្ឋបាលរបស់ខ្លួន និងចាប់ផ្តើមប្រគល់អំណាចផ្នែកហិរញ្ញវត្ថុដល់ថ្នាក់ក្រោម។

### ១៧.៣.៤.១.៩. *ការធានានូវការគ្រប់គ្រងធនធានធម្មជាតិឱ្យបានត្រឹមត្រូវ*

ភាពក្រីក្រអាចត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈការពង្រីកលទ្ធភាពរបស់ពួកគេ ឱ្យទទួលបានធនធានទឹក ជលផល និងព្រៃឈើតាមវិធីប្រកបដោយនិរន្តរភាពភាពមួយ។ ដូច្នេះ កម្មវិធីកាត់បន្ថយភាពក្រីក្រនឹងអាចត្រូវបានតម្រឹមតាមស្ថានភាពជាក់លាក់ ដែលអ្នកក្រីក្រកំពុងប្រឈមមុខនៅគ្រប់ទិសទីក្នុងខេត្តផ្សេងៗ។ ឧទាហរណ៍ ការធានាបានលទ្ធភាពកាន់កាប់ធនធានព្រៃឈើដោយក្រុមកុលសម្ព័ន្ធនៅខ្ពង់រាប ដែលស្របនឹងទម្លាប់ធ្វើកសិកម្មផ្នែកលើព្រៃឈើរបស់ពួកគេ គឺមានសារៈសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រក្នុងភាគឦសាននៃប្រទេសកម្ពុជា។ ការផ្តល់លទ្ធភាពទទួលបានធនធានជលផលនិងទឹកគឺ មានសារៈសំខាន់ណាស់ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនដែលរស់នៅតាមតំបន់ទន្លេសាប។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៧.៣.៤.១.១០. *ការអនុវត្តគោលនយោបាយដីធ្លី*

កម្មវិធីស្នូលនៃកំណែទម្រង់ដីធ្លី រួមមានការអភិវឌ្ឍគោលនយោបាយដីធ្លីថ្នាក់ជាតិមួយ ការកែលម្អការគ្រប់គ្រងស្តុកដីធ្លីថ្នាក់ជាតិ ការចាប់ផ្តើមចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ កំណែទម្រង់យកពន្ធដី ការបង្កើតក្របខ័ណ្ឌច្បាប់មួយដើម្បីជំរុញសិទ្ធកាន់កាប់ទ្រព្យសម្បត្តិ រួមមានច្បាប់ភូមិបាលថ្មី និងការអនុវត្តប្រព័ន្ធចុះបញ្ជីដីធ្លីថ្នាក់ជាតិ ការបង្កើតផែនការមេ និងកំណត់តំបន់ថ្នាក់ជាតិក្រុងនិងខេត្ត និងការអភិវឌ្ឍលំនៅឋានតាមជនបទ។ ការចាត់ថ្នាក់នៃការប្រើប្រាស់ដីធ្លីនឹងត្រូវបានគេកំណត់សម្រាប់ការកម្រិតប្រភេទដីផ្សេងៗពីគ្នាដូចជាដីព្រៃអចិន្ត្រៃយ៍ ឡូនេសាទ និងដីកសិកម្មផ្សេងៗទៀតដែលអាចជួយអ្នកក្រីក្រ ដើម្បីមានលទ្ធភាពទទួលបានដីធ្លី លើកកម្ពស់ការកាន់កាប់ដីធ្លី និងចូលរួមក្នុងការនេសាទជាលក្ខណៈប្រពៃណី។

## ១៧.៣.៤.២.*ការបង្កើតសន្តិសុខប្រាក់ចំណូល*

កម្មវិធីនានាបានដោះស្រាយដោយផ្តល់ជាឥណទាន សម្រាប់សកម្មភាពបង្កើតប្រាក់ចំណូលនិងការកាត់បន្ថយនូវភាពងាយរងគ្រោះ ចំពោះការឡើងចុះខាងប្រាក់ចំណូល ដែលជាបុព្វហេតុចម្បងសម្រាប់ការលក់ដីធ្លីដើម្បីដោះទ័ល។ ការផ្តល់ជូនការធានារ៉ាប់រងតាមជនបទ និងការបង្កើតសមាគមន៍សន្សំប្រាក់សម្រាប់ការផ្តល់ជូនកម្ចីដើម្បីប្រើប្រាស់ គឺមានប្រសិទ្ធភាពក្នុងលំហូរនៃការប្រើប្រាស់ដ៏រលូន។ សុវត្ថិភាពអាចត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈការពង្រីកកម្មវិធីសំណាញ់សុវត្ថិភាព ការលើកកម្ពស់ការការពារបរិស្ថាន និងការបោសសម្អាតមីន។

១៧.៣.៤.២.១. *លទ្ធភាពទទួលបានសេវាមីក្រូឥណទានសម្រាប់អ្នកក្រីក្រ*

ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុរបស់អង្គការមិនមែនរដ្ឋាភិបាល គឺជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុតែមួយគត់ក្នុងតំបន់ជនបទ។ ធនាគារពាណិជ្ជនានាមិនមានដំណើរការច្រើនទេក្នុងប្រតិបត្តិការតាមជនបទកន្លងមក។ ជារួម គម្លាតឥណទានជនបទត្រូវបានប៉ាន់ស្មានថាមានពី ៦០-៧០លានដុល្លារអាមេរិកប្រចាំឆ្នាំ។ កម្មវត្ថុចម្បងរបស់ធនាគារអភិវឌ្ឍជនបទ គឺត្រូវធានានូវការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃមីក្រូហិរញ្ញវត្ថុ។ ហិរញ្ញវត្ថុរបស់ធនាគារអភិវឌ្ឍធនបទកំពុងត្រូវបានពង្រឹង ក្នុងគោលដៅធ្វើឱ្យមានការចូលរួមកាន់តែខ្លាំងក្នុងការអភិវឌ្ឍមីក្រូឥណទាន។

១៧.៣.៤.២.២. *ការដោះស្រាយជាមួយសកលភាវូបនីយកម្ម*

កម្ពុជាបន្តពង្រឹងទំនាក់ទំនងជាអន្តរជាតិរបស់ខ្លួននិងបន្ថែមការប្តេជ្ញារបស់ខ្លួន ដើម្បីបើកទូលាយទីផ្សារនិងពាណិជ្ជកម្មក្នុងនាមជាសមាជិករបស់អាស៊ាន។ រាជរដ្ឋាភិបាលនឹងបង្កើនការចូលរួមរបស់ខ្លួននៅក្នុងគណៈកម្មការទន្លេមេគង្គ អនុតំបន់ទន្លេមេគង្គ និងអាស៊ាន។ ខណៈដែល សកលភាវូបនីយកម្មបាននាំមកនូវកាលានុវត្តភាពសេដ្ឋកិច្ចកាន់តែច្រើនជាងមុន ជាពិសេសដល់ស្ត្រីមួយចំនួនក្នុងឧស្សាហកម្មកាត់ដេរ និងវាយណភណ្ឌនោះ ប្រជាជនដទៃទៀតត្រូវបានគេរើសអើង ដោយសារតែវិសមភាពកាន់តែខ្លាំងក្នុងចំណោមប្រទេសនានា និងនៅក្នុងប្រទេសផ្ទាល់តែម្តង។ រាជរដ្ឋាភិបាលនឹងដោះស្រាយបញ្ហានេះ តាមរយៈកម្មវិធីនានាដើម្បីផ្តល់ការបណ្តុះបណ្តាល ការលើកកម្ពស់បំណិនជីវិតនិងពង្រីកលទ្ធភាពទទួលបានឥណទាន និងអាចឱ្យក្រុមប្រជាជនដែលងាយទទួលរងគ្រោះបានប្រកួតប្រជែងក្នុងបណ្តាញពិភពលោក។

##### ១៧.៣.៤.២.៣. *កម្មវិធីសំណាញ់សុវត្ថិភាព*

កំណើនសេដ្ឋកិច្ចដែលបង្កើនកម្រិតប្រើប្រាស់ពិតប្រាកដរបស់អ្នកក្រីក្រនោះ អាចមានឥទ្ធិពលខ្លាំងទៅលើការកាត់បន្ថយភាពក្រីក្រ។ កម្មវិធីមួយចំនួននឹងផ្តល់អត្ថប្រយោជន៍ដល់អ្នកក្រីក្រ ក្នុងទម្រង់នៃការបន្ថែមដើមទុនរូបវន្តនិងដើមទុនមនុស្សរបស់គេ និងតាមរយៈអន្តរាគមន៍នានា ដែលលើកកម្ពស់ការតបស្នងដែលពួកគេទទួលបានពីដើមទុនទាំងនោះ។

##### ១៧.៣.៤.២.៤. *ការការពារបរិស្ថាន*

កម្មវិធីការពារបរិស្ថានជាអាទិភាពរួមមាន ៖ ការអភិវឌ្ឍនិងការការពារតំបន់ឆ្នេរ ការលើកកម្ពស់ការគ្រប់គ្រងបរិស្ថាន រួមមានប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប និងការការពារទីជម្រាលសំខាន់ៗ ការគ្រប់គ្រងការសឹករិចរិល ការគ្រប់គ្រងការបំពុលផ្នែកឧស្សាហកម្មនិងទីក្រុង ការពង្រឹងសមត្ថភាពសម្រាប់ការគ្រប់គ្រងតំបន់ការពារ ការកសាងសមត្ថភាពសម្រាប់ការធ្វើផែនការបរិស្ថាន និងការគ្រប់គ្រងធនធាន និងការបង្កើតអង្គការសហគមន៍ផ្សេងៗ រួមមានសហគមន៍ព្រៃឈើ សហគមន៍អ្នកនេសាទ សមាគមន៍អ្នកប្រើប្រាស់ទឹក និងសហគមន៍ថែទាំផ្លូវជនបទ។

##### ១៧.៣.៤.២.៥. *ការបោសសម្អាតមីន*

កិច្ចខិតខំប្រឹងប្រែងរួមគ្នាមានលក្ខណៈជាប្រព័ន្ធជាមួយ និងដោយមានជំនួយពីសហគមន៍អ្នកផ្តល់ជំនួយកំពុងត្រូវអនុវត្ត ដើម្បីបោសសម្អាតមីនក្នុងដីស្រែកសិកម្ម បង្កើនការយល់ដឹងពីគ្រោះថ្នាក់នៃគ្រាប់មីនក្នុងដី ផ្តល់ការបណ្តុះបណ្តាលស្តីពីការកម្ទេចគ្រាប់មីន និងបង្កើនការឧបត្ថម្ភដល់ជនរងគ្រោះដោយសារមីន។

#### ១៧.៣.៤.៣. *ការពង្រឹងសមត្ថភាព*

កម្មវិធីនានាដោះស្រាយការលើកកម្ពស់ការផ្តល់សេវាកម្ម និងការកសាងសមត្ថភាពស្ថាប័នក្នុងតំបន់។ ការផ្តោតអារម្មណ៍គឺទៅលើគុណភាព និងលទ្ធភាពទទួលបានសេវាកម្មសម្រាប់អ្នកក្រីក្រនិងការរៀបចំកម្មវិធីនានាដែលរក្សាបានអត្ថប្រយោជន៍ប្រៀបធៀបរបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារឯកជនក្នុងការផ្តល់នូវសេវាទាំងនេះឱ្យមានប្រសិទ្ធភាព។ ខណៈដែល រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តចំពោះប្រព័ន្ធវិមជ្ឈការ ជំហាននេះនឹងត្រូវបន្តឱ្យស្របទៅជាមួយវឌ្ឍនភាព ក្នុងការកសាងសមត្ថភាពស្ថាប័ននានានៅមូលដ្ឋាន។

##### ១៧.៣.៤.៣.១. *សុខាភិបាល*

កម្មវិធីសំខាន់ៗរួមមាន៖ (១) ការលើកកម្ពស់សុខភាពកុមារនិងស្ត្រី តាមរយៈការផ្តល់សេវាគាំពារជាមូលដ្ឋានសម្រាប់ស្ត្រីទាំងអស់ (២) ការកាត់បន្ថយឧបត្តិហេតុនៃជម្ងឺឆ្លងដូចជា ៖ គ្រុនចាញ់ គ្រុនឈាម របេងជម្ងឺរាគ ការឆ្លងតាមប្រព័ន្ធដង្ហើមធ្ងន់ធ្ងរ និងជម្ងឺឆ្លងតាមការរួមភេទ ជាពិសេសមេរោគអេដស៍ (៣) ការលើកកម្ពស់វិសាលភាពនៃគុណភាពសេវាកម្ម (៤) ការបំប៉នជំនាញដល់បុគ្គលិកសុខាភិបាល (៥) ការផ្តល់ថ្នាំសង្កូវ ឧបករណ៍ និងសម្ភារៈ (៦) ការពង្រឹងសមត្ថភាពនៃមន្ទីរពេទ្យបង្អែក តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងបច្ចេកទេសគ្រប់គ្រង (៧) ការសម្របសម្រួលការអភិវឌ្ឍនៃវិស័យសុខាភិបាលឯកជន និង(៨) ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីអនាម័យនិងសម្អាតភាពកខ្វក់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៧.៣.៤.៣.២. *ទឹក និង ភាពមានអនាម័យ*

ការងារត្រៀមលក្ខណៈកំពុងត្រូវបានអនុវត្ត ដើម្បីបង្កើតក្របខណ្ឌគោលនយោបាយស្តីពីអនាម័យ និងការផ្គត់ផ្គង់ទឹក ដោយផ្តោតទៅលើស្វ័យភាពហិរញ្ញវត្ថុ ការកែសម្រួលពន្ធភាសីដើម្បីទទួលបានការប្រមូលការចំណាយមកវិញ ការចូលរួមពីវិស័យឯកជន ការសម្របសម្រួលពីម្ចាស់ជំនួយ ការបែងចែកធនធានទឹក និងទំនួលខុសត្រូវតាមផ្លូវច្បាប់។ ការអនុម័តភ្លាមៗនិងការអនុវត្តគោលនយោបាយនេះ នឹងជួយលើកកម្ពស់គុណភាពសេវាដល់អ្នកក្រីក្រ។ ការយកចិត្តទុកដាក់នាពេលថ្មីៗនេះ ត្រូវបានផ្តោតលើការប្រើប្រាស់បានល្អប្រសើរនៃធនធានទឹកដែលកំពុងមានស្រាប់ ការពង្រឹងសមត្ថភាពស្ថាប័ន ការឈានទៅដល់កម្រិតផលិតកម្មនៃរោងចក្រផលិតទឹកស្អាតដែលមានស្រាប់ដើម្បីអភិវឌ្ឍសមត្ថភាពផលិត ការលើកកម្ពស់ការអនុវត្ត និងពង្រីកការតភ្ជាប់ទៅដល់អ្នកប្រើប្រាស់ពិតប្រាកដ។ អណ្តូងទឹកតាមជនបទកំពុងត្រូវបានពង្រីកតាមរយៈការបែងចែកថវិកាជាតិកាន់តែច្រើននិងការឧបត្ថម្ភពីម្ចាស់ជំនួយ ជាមួយនិងការចូលរួមដ៏សកម្មពីអ្នកទទួលផលជាពិសេសស្ត្រី ដែលជាអ្នកប្រមូលនិងអ្នកប្រើប្រាស់ទឹកដ៏ចម្បងក្នុងប្រតិបត្តិការនិងតំហែរទាំរបស់គេ។

១៧.៣.៤.៣.៣. *គោលនយោបាយអប់រំ*

កម្មវិធីគន្លឹះរបស់រាជរដ្ឋាភិបាលដែលធានានូវលទ្ធភាពទទួលបានសេវាអប់រំស្មើភាពគ្នា និងការលើកកម្ពស់គុណភាពក្នុងវិស័យអប់រំនោះ គឺកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នា ដែលខិតខំផ្តល់ការអប់រំជាមូលដ្ឋាន រយៈពេល៩ឆ្នាំដល់កុមារទាំងអស់ជាពិសេសក្មេងស្រីត្រឹមឆ្នាំ២០១០។សម្រាប់ការអប់រំក្រោយកម្រិតមូលដ្ឋានវិញ អាទិភាពរបស់រាជរដ្ឋាភិបាលគឺធានាលទ្ធភាពទទួលបានកាន់តែស្មើភាពថែមទៀត សម្រាប់អ្នកក្រីក្របំផុត ទន្ទឹមនឹងការកើនឡើងភាពជាដៃគូ ឯកជន-សាធារណៈ នៅក្នុងហិរញ្ញប្បទាននិងការគ្រប់គ្រងអប់រំ។ អាទិភាពឆ្លងវិស័យគឺ ការពង្រឹងក្របខណ្ឌច្បាប់និងបទបញ្ញត្តិ សម្រាប់ការធានាគុណភាព និងការពិនិត្យ តាមដានការបំពេញការងារនៅគ្រប់អនុវិស័យ។ គេទទួលស្គាល់ថា ការចំណាយសាធារណៈ ទៅលើការអប់រំបានថយចុះក្រោមកម្រិតចាំបាច់ ដើម្បីសម្រេចវត្ថុបំណងគោលនយោបាយទាំងនេះ។ រាជរដ្ឋាភិបាលកម្ពុជាមានគម្រោងនឹងបង្កើនថវិកាវិស័យអប់រំច្រើនជាងទ្វេដងនៅបីឆ្នាំខាងមុខ ដែលជាជំហានចាប់ផ្តើមមួយក្នុងធានាបានការអនុវត្តគោលនយោបាយនឹងតម្រង់ទៅរកការគាំទ្រគ្រួសារក្រីក្រ ដូចជា ការកាត់បន្ថយការចំណាយដោយផ្ទាល់ និងដោយប្រយោលរបស់ឪពុកម្តាយ (ដែលជាឧបសគ្គចម្បងក្នុងការទទួលបានសេវាអប់រំ) តាមរយៈការបង្កើនប្រាក់បៀវត្សគ្រូបង្រៀនផ្អែកលើការបំពេញការងារ។ គេក៏បានស្នើឱ្យបង្កើនថវិកាដំណើរការសាលារៀនផងដែរ ដែលនឹងលើកកម្ពស់ការគ្រប់គ្រងនៅកម្រិតខេត្ត ស្រុក និងសាលារៀន។

## *១៧.៣.៤.៤.ការបង្កើនភាពអង់អាច*

១៧.៣.៤.៤.១. *អភិបាលកិច្ចល្អ*

កម្មវិធីអាទិភាពរួមមាន ៖ ការបង្កើតគំនិតផ្តួចផ្តើមផ្តល់បៀវត្សផ្អែកលើគុណសម្បត្តិ (Merit Based Pay Initiative (MBPI)) និងក្រុមការងារកន្សោមអាទិភាព (Priority Mission Groups (PMG)) ដល់មន្ត្រីរាជការដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវានិងបង្កើនផលិតភាព ការដាក់ឱ្យអនុវត្តប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការប្រព័ន្ធរដ្ឋបាលដើម្បីបង្កើនលទ្ធភាពទទួលបាននូវសេវាសំខាន់ៗដល់ប្រជាជន ការបង្កើនល្បឿនការ

អភិវឌ្ឍប្រព័ន្ធរំសាយកងទ័ព កំណែទម្រង់សារពើពន្ធនិងរដ្ឋបាល កំណែទម្រង់ស៊ីជម្រៅប្រព័ន្ធតុលាការនិងការបង្កើតកម្មវិធីជាតិមួយសម្រាប់កំណែទម្រង់តុលាការ និងអនុវត្តវិធានការនានា ដូចបានលើកឡើងក្នុងផែនការសកម្មភាពអភិបាលកិច្ច។

១៧.៣.៤.៤.២. *ការពង្រឹងច្បាប់*

កង្វល់នាពេលបច្ចុប្បន្ននោះគឺ ច្បាប់និងបទបញ្ញានានាមានការលំអៀងប្រឆាំងនឹងអ្នកក្រីក្រ។ កត្តានេះទាមទារឱ្យមានការពិនិត្យឡើងវិញនូវច្បាប់និងបទបញ្ញត្តិ ដែលអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អ្នកក្រីក្រនិងកំណត់នូវវិធានការនានាដើម្បីកែតម្រូវ រួមមានបញ្ហាកំណែទម្រង់ដីធ្លី សិទ្ធិកាន់កាប់ដីធ្លី លទ្ធភាពមានដីធ្លីសមភាពយេនឌ័រនិងនីតិរដ្ឋ។ ការអន្តរាគមន៍ជាអាទិភាពក្នុងកំណែទម្រង់ដីធ្លីមានគោលដៅពង្រឹង បទបញ្ញត្តិ និងសមត្ថភាពអនុវត្ត និងប្រសិទ្ធភាព និងការបង្កើតដំណើរការដោះស្រាយជម្លោះប្រកបដោយ សមត្ថភាពរួមទាំងការកំណត់អត្តសញ្ញាណប្រជាជនដែលគ្មានដីធ្លី ការពង្រីកដីកសិកម្ម តាមរយៈការឈូស ឆាយដី និងការការពារ ការដណ្តើមយកដីដែលទន្ទ្រានពីក្រុមមានឥទ្ធិពល និងការប្រមូលផ្តុំដីធ្លីដោយម្ចាស់កម្មសិទ្ធិតែម្នាក់។ រដ្ឋបាលសូរិយោដីនឹងត្រូវពង្រឹង តាមរយៈការធានាអនុម័តនិងអនុវត្តដោយម៉ឺងម៉ាត់ច្បាប់ភូមិបាលថ្មី ការបង្កើតប្រព័ន្ធប្រកបដោយតម្លាភាព ក្នុងការចេញប័ណ្ណកម្មសិទ្ធិនិងការចុះបញ្ជីដីធ្លី ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពស្ថាប័នរដ្ឋបាលដីធ្លីនិងការការពារដីរដ្ឋ។

១៧.៣.៤.៤.៣. *ការលើកទឹកចិត្តឱ្យមានបរិយាកាសអនុគ្រោះសម្រាប់អង្គការមិនមែនរដ្ឋាភិបាល*

អង្គការមិនមែនរដ្ឋាភិបាលអាចជាដៃគូក្នុងការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រជាមួយរាជ-រដ្ឋាភិបាលនៅគ្រប់ជាន់ថ្នាក់។ ក្របខណ្ឌប្រកបដោយតម្លាភាពនិងគាំទ្រមួយ នឹងត្រូវបង្កើតឡើងសម្រាប់កិច្ចសហការ។ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល នឹងផ្តល់ជាមគ្គុទេសក៍ច្បាស់លាស់ចំពោះសកម្មភាពនានារបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីឱ្យបរិយាកាសប្រតិបត្តិការមានតម្លាភាព។ ច្បាប់នេះនឹងអាចឱ្យអង្គការមិនមែនរដ្ឋាភិបាលមានលទ្ធភាពរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ដោយអនុញ្ញាតឱ្យពួកគេឆ្លើយតបបានឆាប់រហ័ស ប្រកបដោយការច្នៃប្រឌិតចំពោះស្ថានភាពបញ្ហាដែលកើតឡើង។ បទបញ្ញត្តិរបស់រាជរដ្ឋាភិបាល នឹងរចនាឡើងនូវក្របខណ្ឌមួយដែលនឹងផ្តល់ព័ត៌មានបានគ្រប់គ្រាន់ស្តីពីសកម្មភាពអភិវឌ្ឍនានានិងផលប៉ះពាល់សារពើពន្ធរបស់អង្គការមិនមែនរដ្ឋាភិបាលទៅលើការអភិវឌ្ឍរបស់ប្រទេស។ ក្របខណ្ឌនេះក៏នឹងលើកទឹកចិត្តដល់ស្វ័យត្រួតពិនិត្យផងដែរ។

# ជំពូកទី ១៨
# វិស័យអប់រំ

ការអភិវឌ្ឍធនធានមនុស្ស គឺជាផលសម្រេចនិងជាកត្តាជំរុញនៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេសមួយ។ ប្រជាជនមានជំនាញ មានគុណតម្លៃ និងមានឥរិយាបទល្អ ពិតជាមានសារៈសំខាន់ណាស់ដើម្បីបង្កើនផលិតភាព។ កត្តានេះមិនទាន់គ្រប់គ្រាន់នៅឡើយទេ ដោយហេតុថា "ផលិតភាព គឺអាស្រ័យទៅតាមសុខភាព និងអាហារូបត្ថម្ភរបស់កម្លាំងការងារ។ មនុស្សត្រូវការស្ថេរភាពផ្នែករាងកាយនិងផ្លូវចិត្ត ដោយចាប់ផ្តើមពីការរៀនចេះជំនាញសម្រាប់កំណើនសេដ្ឋកិច្ច បន្ទាប់មកត្រូវប្រើប្រាស់ជំនាញទាំងនេះនៅកន្លែងធ្វើការ"។ នៅពេលដែលប្រទេសមួយកំពុងអភិវឌ្ឍ ធនធានកាន់តែច្រើននឹងត្រូវបន្ថែមទៅក្នុងការអភិវឌ្ឍមនុស្ស។ បញ្ហាប្រឈមក្នុងការអភិវឌ្ឍគឺ បង្កើតវដ្តនេះប្រកបដោយគុណធម៌។

## ១៨.១. សាវតារ

កិច្ចការសំខាន់បំផុតក្នុងការអភិវឌ្ឍនោះ គឺការផ្តល់នូវការអប់រំបឋមសិក្សាសម្រាប់ទាំងអស់គ្នា។ ការវិនិយោគលើបឋមសិក្សាអាចមានអត្ថប្រយោជន៍យ៉ាងខ្លាំង រួមបញ្ចូលទាំងផលិតភាព ដែលមានអត្រាខ្ពស់ និងជាមូលដ្ឋានគ្រឹះសម្រាប់ការអប់រំនៅឧត្តមសិក្សា ដែលជាវិស័យសំខាន់សម្រាប់កំណើន និងនវានុវត្តន៍។ ប្រជាជនដែលទទួលបានការអប់រំល្អ ក៏មានឥទ្ធិពលដល់ការវិវឌ្ឍសង្គម និងមិនឈានដល់ការប្រើប្រាស់អំពើហឹង្សា។

ឧបសគ្គ ៣ យ៉ាងដែលត្រូវជម្នះឱ្យបានក្នុងការផ្តល់សេវាអប់រំមានដូចជា ៖ កាលានុវត្តភាពសេវាអប់រំនៅមានកម្រិត ឱកាសមិនស្មើគ្នាក្នុងការទទួលបានកាលានុវត្តភាពទាំងនេះ និងគុណភាពបង្រៀននៅមានកម្រិត។ ការអប់រំ គឺជាឧបករណ៍ដ៏ចម្បងមួយ ដើម្បីបំបែកវដ្តនៃភាពក្រីក្រ ដែលកើតមានចំពោះប្រជាជននៅតាមជនបទ។

ប្រព័ន្ធអប់រំរបស់កម្ពុជាត្រូវបានស្តាបនាឡើងវិញទាំងស្រុងក្នុងឆ្នាំ១៩៧៩ជាមួយនឹងការបង្កើតឡើងនូវក្រសួងសិក្សាធិការជាតិ។ សាលាបឋមសិក្សាដំបូងគេ ត្រូវបានបើកឡើងវិញក្នុងរាជធានីភ្នំពេញនៅខែកញ្ញា ឆ្នាំ ១៩៧៩ បន្ទាប់មកគឺការបើកឡើងវិញនូវវិទ្យាល័យស៊ីសុវត្ថិ។ នៅឧត្តមសិក្សា មហាវិទ្យាល័យឱសថសាស្ត្រ គឺជាមហាវិទ្យាល័យដំបូង គេត្រូវបានបើកឡើងវិញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រាប់ការស្តាបនាឡើងវិញរបស់ប្រទេសកម្ពុជា។

ទោះជាយ៉ាងណា នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ វិស័យអប់រំបានប្រឈមមុខជាមួយនឹងសេវាអប់រំជាតិដែលមិនស៊ីសង្វាក់គ្នា។ ការផ្តល់សេវាអប់រំមិនមានសមភាពគ្រប់គ្រាន់ និងមិនបានផ្តល់នូវការគ្របដណ្តប់ពេញលេញទេ (Quinn, ២០០៩a, ទំព័រ៣)។

កំណែទម្រង់វិស័យអប់រំកម្ពុជាបានចាប់ផ្តើមក្នុងឆ្នាំ ១៩៩៩ ។ ជំហានដំបូងគឺ ការបង្កើតក្របខណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្រអប់រំ ដែលនឹងបង្ហាញអាទិភាពនានារបស់វិស័យអប់រំ គោលដៅរបស់អនុ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិស័យ និងក្របខណ្ឌសម្រាប់ការបែងចែកថវិកាក្នុងរយៈពេលមធ្យម។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំដែលបានរៀបចំឡើងក្នុងឆ្នាំ ២០០១ បានធ្វើការពិនិត្យឡើងវិញតាមដំណាក់កាល ដើម្បីកែសម្រួលកម្មវិធីនានាឱ្យមានប្រសិទ្ធភាព ដោយអនុលោមទៅតាមអាទិភាពជាយុទ្ធសាស្ត្រ។ តាមរយៈការវាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ កម្មវិធីគាំទ្រវិស័យអប់រំត្រូវបានរៀបចំឡើង ក្នុងគោលបំណងសម្រាប់អនុវត្តផែនការសកម្មភាពរួមគ្នាជាមួយអ្នកពាក់ព័ន្ធទាំងអស់ ជាពិសេស រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល។ កំណែទម្រង់នេះបានផ្តោតលើការអប់រំបឋមសិក្សា និងមធ្យមសិក្សា។ ចំណុចសំខាន់ៗនៃកំណែទម្រង់មានដូចខាងក្រោម (Quinn, ២០០៩a, ទំព័រ៤, ESP ២០០១-២០០៥)៖

- បង្កើតឡើងវិញតួនាទីរបស់រដ្ឋ ក្នុងការផ្តល់សេវាអប់រំប្រកបដោយសមធម៌
- ពង្រឹងរចនាសម្ព័ន្ធទំនួលខុសត្រូវក្នុងវិស័យអប់រំជូនសាធារណៈជន ដែលក្រសួងត្រូវទទួលខុសត្រូវខ្លាំងបំផុត ក្រោមគោលការណ៍លទ្ធិប្រជាធិបតេយ្យថ្មី និងកំពុងលេចជារូបរាងរបស់ប្រទេសជាតិ
- ពង្រីកនិងផ្តល់ជាសកលនូវសេវាអប់រំឥតបង់ថ្លៃ និងប្រកបដោយសមធម៌នៅបឋមសិក្សា និងកម្រិតមូលដ្ឋាន អនុលោមទៅតាមការប្តេជ្ញាចិត្តរបស់ប្រទេស
- បង្កើតយន្តការនានា ដែលធានាធនធានគ្រប់គ្រាន់សម្រាប់ការផ្តល់សេវាអប់រំ ឱ្យដល់កន្លែងដែលត្រូវការពិតប្រាកដ
- គ្រប់គ្រងនិងតម្រែតម្រង់ការបែងចែកធនធានមនុស្ស និងហិរញ្ញវត្ថុទាំងផ្ទៃក្នុងនិងផ្ទៃក្រៅ តាមបែបបទ មានផែនការច្បាស់លាស់ និងលំដាប់លំដោយ ព្រមទាំងស្របជាមួយនឹងអាទិភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិវឌ្ឍតម្រង់ទៅរកអ្នកក្រីក្រ
- បង្កើតយន្តការវាយតម្លៃការអនុវត្តនិងការទទួលខុសផ្ទៃក្នុង ដើម្បីពង្រឹងដំណើរការគ្រប់គ្រងប្រសិទ្ធភាពប្រព័ន្ធនិងការគ្រប់គ្រងការអនុវត្ត
- កែទម្រង់រចនាសម្ព័ន្ធស្ថាប័ននិងការគ្រប់គ្រងផ្ទៃក្នុង ដើម្បីបង្កើតបរិយាកាសអំណោយផលមួយសម្រាប់គាំទ្ររបៀបវារៈកំណែទម្រង់ ដែលកំពុងលេចចេញជារូបរាងនិងត្រូវបានរំពឹងទុក។

ឆ្លើយតបទៅនឹងកំណែទម្រង់នេះ ក្នុងឆ្នាំ ២០០០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្តណែនាំ **កម្មវិធីសកម្មភាពជាអាទិភាព** (PAP) ដើម្បីបង្វែរអាទិភាពចំណាយពីវិស័យសន្តិសុខ និងយោធា ទៅវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ចវិញ ដូចជាក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ នីតិវិធីថវិកាកម្មវិធីសកម្មភាពជាអាទិភាពបានផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

- ថវិកាត្រូវបានបែងចែកនិងផ្តល់ជូនដោយផ្ទាល់ទៅដល់សាលារៀន តាមរយៈគណៈគ្រប់គ្រងថវិកា (BMC) នៅថ្នាក់ស្រុក
- មាតិកាថវិកាត្រូវបានលុបចោលនិងជំនួសមកវិញដោយថវិកាមួយកញ្ចប់ ដែលមានតែបន្ទាត់ថវិកាមួយ ប៉ុណ្ណោះ (ជំពូក១២) ដើម្បីផ្តល់នូវភាពបត់បែនក្នុងការចំណាយ

- ធានានូវការផ្លាស់ប្តូរផ្នែកគុណភាព ដោយការកាត់បន្ថយការគ្រប់គ្រងមុនចំណាយ និងប្តូរទៅជាការធ្វើសវនកម្មក្រោយពេលចំណាយ ដើម្បីសម្រេចបានគោលនយោបាយក្នុងការនាំការអភិវឌ្ឍឱ្យទៅដល់ថ្នាក់ស្រុកនិងឃុំ
- ការបើកប្រាក់តាមរយៈប្រព័ន្ធទំនើបមួយ ត្រូវបានផ្តល់ជូនដោយរតនាគារជាតិនៅថ្នាក់កណ្តាលរៀងរាល់ត្រីមាស។ ចំណាយត្រូវបានសម្រេច ដោយគណៈកម្មការគ្រប់គ្រងថវិការួមជាមួយនិងរតនាគារខេត្ត
- ការដេញថ្លៃផ្គត់ផ្គង់ត្រូវបានធ្វើវិមជ្ឈការដល់កម្រិតសាលារៀន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀន។

ខណៈដែលការផ្តល់សេវាអប់រំកម្រិតមូលដ្ឋាន គឺជាអាទិភាពខ្ពស់ក្នុងវិស័យអប់រំនោះ រាជរដ្ឋាភិបាលក៏បានផ្តល់សារៈសំខាន់ទៅដល់ការអប់រំឧត្តមសិក្សាផងដែរ (ការអប់រំមធ្យមសិក្សា ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា) ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់កំណើនប្រកបដោយនិរន្តរភាព។ ការអនុវត្តអភិក្រមរួមមួយចំពោះការអភិវឌ្ឍវិស័យអប់រំនោះ គឺជាលក្ខណៈពិសេសមួយនៃគោលនយោបាយអប់រំរបស់រដ្ឋាភិបាល។

ដើម្បីលើកកម្ពស់សមភាពសង្គម ស្របនឹងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ រដ្ឋាភិបាលនឹងផ្តោតលើការពង្រីកសេវាអប់រំសម្រាប់ក្រុមជួបការលំបាក (ជាពិសេស ក្នុងសហគមន៍ពាក់កណ្តាលទីក្រុងនិងជនបទ និងក្រុមកុលសម្ព័ន្ធភ្នំ) រួមទាំងអ្នកក្រីក្រ និងយុវជនរស់នៅតំបន់ដាច់ស្រយាលនានា។ ដើម្បីពង្រីកលទ្ធភាពទទួលបានការអប់រំ គោលនយោបាយអប់រំរបស់រដ្ឋាភិបាលកំពុងសង្កត់ធ្ងន់លើការកាត់បន្ថយចំណាយក្នុងការចូលរៀន តាមរយៈការលុបបំបាត់វិភាគទានពីសំណាក់ឪពុកម្តាយនៅបវេសនកាល និងចំណាយក្រៅផ្លូវការផ្សេងៗទៀត។ រដ្ឋាភិបាលក៏បានផ្តល់អាទិភាពដល់ការពង្រីកលទ្ធភាពទទួលបានការអប់រំសម្រាប់កុមារីនិងស្ត្រី តាមរយៈការលើកកម្ពស់បរិយាកាសសិក្សាឱ្យមានភាពអនុគ្រោះដល់កុមារី និងកម្មវិធីបង្កើនការយល់ដឹងសម្រាប់ឪពុកម្តាយចំពោះសមភាពយេនឌ័រ។

## ១៨.២. ការបំពេញការខារទស័យអប់រំ

គម្លាតនានានៅក្នុងប្រព័ន្ធអប់រំកំពុងរារាំងសមិទ្ធផលដ៏រលូនរបស់ការអភិវឌ្ឍ។ មូលនិធិសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងប្រទេសកម្ពុជា គឺមិនទាន់គ្រប់គ្រាន់ទេ ដែលជាប់ចំណាត់ថ្នាក់ទាបជាងគេនៅក្នុងប្រព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេស បើប្រៀបធៀបជាមួយការអប់រំនៅមហាវិទ្យាល័យនិងសាកលវិទ្យាល័យ។ កម្លាំងពលកម្មកម្ពុជាមួយចំនួនធំមិនមានសមត្ថភាពផ្នែកបច្ចេកទេស ដែលធ្វើឱ្យផលិតភាពផ្នែកឧស្សាហកម្មនៅមានកម្រិត។ ម៉្យាងវិញទៀត ប្រជាជនដែលមានតែសញ្ញាបត្រទុតិយភូមិមិនអាចរកការងារធ្វើការបានទេ។ ស្ថានភាពនេះបានបង្ហាញអំពីភាពមិនសព្វគ្រប់ជ្រុងជ្រោយ ក្នុងការបែងចែកធនធានចំពោះវិស័យអប់រំ។ ប្រព័ន្ធអប់រំគួរត្រូវពិនិត្យឡើងវិញ ដែលនឹងធ្វើឱ្យកង្វល់ទាំងឡាយ ដែលទាក់ទងទៅនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈអាចត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយអប់រំ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការអប់រំឧត្តមសិក្សានៅកម្ពុជា ត្រូវបានគេចាត់ទុកថាជាច្រកមួយដើម្បីក្លាយជាមន្ត្រីរាជការ។ ប៉ុន្តែដោយសារតែមានការកែសម្រួលកម្មវិធីមួយចំនួន និងការថយចុះក្នុងការជ្រើសរើសមន្ត្រីរាជការ ធ្វើឱ្យក្ដីរំពឹងបម្រើការក្នុងរដ្ឋាភិបាលនៅមានកម្រិត។ តែទោះជាយ៉ាងណាក៏ដោយ ការចូលរៀននៅសាកលវិទ្យាល័យបានបន្តកើនឡើង។ សេចក្ដីសន្និដ្ឋាន ២ យ៉ាងមានដូចជា ៖ (១) ការអភិវឌ្ឍវិស័យឯកជន ពិតជាមានសារៈសំខាន់ណាស់ ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការរបស់អ្នកបញ្ចប់ការសិក្សា និង (២) ការអប់រំត្រូវតែធ្វើកំណែទម្រង់ ដើម្បីកសាងយុវជនឱ្យបំពេញតាមតម្រូវការនៃវិស័យឯកជន។ កំណែទម្រង់នោះ ត្រូវតែអនុវត្តស្របជាមួយនិងការចូលរួមពីអាជ្ញាធរមូលដ្ឋាន ក្រុមគ្រួសារ និងដៃគូអភិវឌ្ឍ។

គោលនយោបាយអប់រំរបស់រដ្ឋាភិបាលមានគោលបំណង ជំរុញការចូលរៀន កាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា (សិស្សដែលចាកចេញពីសាលារៀន ដោយសារគ្មានលទ្ធភាពបង់ថ្លៃការសិក្សា) តាមរយៈការបង្កើនប្រាក់ខែគ្រូបង្រៀន ការផ្ដល់សម្ភារៈនិងបរិក្ខារសាលារៀន ការកសាងសាលារៀន ការលុបបំបាត់ចំណាយ ទាំងផ្លូវការ និងមិនផ្លូវការពីឪពុកម្ដាយសិស្ស ការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងការកសាងអន្តេវាសិកដ្ឋានសម្រាប់កុមារី។ ក្រសួងអប់រំ យុវជន និងកីឡាមានក្ដីបារម្ភអំពីការបណ្ដុះបណ្ដាលនិងវិក្រឹតការគ្រូបង្រៀន និងអធិការអប់រំឱ្យបានគ្រប់គ្រាន់ និងកសាងកម្មវិធីសិក្សានិងផ្ដល់សម្ភារៈសិក្សាឱ្យបានពេញលេញ ដែលនឹងលើកកម្ពស់គុណភាពនៃការអប់រំ។ ទោះជាយ៉ាងណា ប្រាក់ខែគ្រូបង្រៀនដែលមានកម្រិតទាប ដែលស្ថិតក្នុងថវិកាត្បិតត្បៀតខ្លាំងនោះ ធ្វើឱ្យគុណភាពនៃការបង្រៀន និងការបន្តនិរន្តភាពនៃសេវាអប់រំចុះខ្សោយ។ ចំណាយក្រៅផ្លូវការរបស់គ្រួសារចំពោះគ្រូបង្រៀន គឺជាបន្ទុកមួយទៀតសម្រាប់អ្នកក្រីក្រ។ បញ្ហាសំខាន់នេះកំពុងត្រូវបានលើកយកមកដោះស្រាយ។

## ១៨.២.១.ការអប់រំកម្រិតមូលដ្ឋាន

ការអប់រំកម្រិតមូលដ្ឋានសម្រាប់ទាំងអស់គ្នា រួមបញ្ចូលទាំងអក្ខរកម្មសម្រាប់យុវជននិងជនពេញវ័យ គឺជាកម្មវិធីសំខាន់បំផុតក្នុងវិស័យអប់រំ។ ការអប់រំកម្រិតមូលដ្ឋានរួមបញ្ចូលទាំង មត្តេយ្យសិក្សា បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ។ ការអប់រំកម្រិតមូលដ្ឋានមានពីរផ្នែក គឺការអប់រំបឋមសិក្សា ៦ ឆ្នាំ និងមធ្យមសិក្សាបឋមភូមិ ៣ ឆ្នាំ។ កម្មវិធីអប់រំនៅកម្រិតនេះនឹងត្រូវបញ្ចប់នៅពេលសិស្សបានចូលរៀនរយៈពេល ៩ ឆ្នាំ។

កំណែទម្រង់អប់រំកំពុងដោះស្រាយបញ្ហាសមធម៌និងនិងប្រសិទ្ធភាព តាមរយៈការបង្កើនម៉ោងសិក្សាក្នុង ១ ថ្ងៃ ការបង្កើនការផ្គត់ផ្គង់សម្ភារៈបង្រៀន និងការបង្កើនប្រាក់ខែគ្រូបង្រៀន។ ការលុបបំបាត់វិភាគទានពីឪពុកម្ដាយ ការបង្កើនថវិកាដំណើរការសាលារៀន និងការបង្រៀនថ្នាក់បំប៉នបន្ថែម សុទ្ធតែជាសកម្មភាពមានសារៈប្រយោជន៍។

គោលនយោបាយអប់រំមិនគួរផ្ដោតតែទៅលើការផ្ដល់ចំណេះដឹងតែមួយមុខប៉ុណ្ណោះទេ ប៉ុន្តត្រូវរៀបចំសិស្សឱ្យមានលទ្ធភាពចូលរួមក្នុងទីផ្សារការងារ បន្ទាប់ពីពួកគេបញ្ចប់ការសិក្សាផងដែរ។ ជាទូទៅ ការអប់រំមិនត្រូវញែកដាច់ចេញពីបញ្ហាដែលកើតឡើងរបស់ពិភពលោកនោះទេ។ អន្តរទំនាក់ទំនងរវាងការអប់រំ និងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចផ្សេងទៀត ក៏ដូចជាផ្នែកឯកជន គួរត្រូវបានយកចិត្តទុកដាក់ នៅក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាង ១៨.១. សូចនាករសមិទ្ធផលនៃវិស័យអប់រំ*

| | 200 | 2001 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|
| ការចំណាយលើការអប់រំគិតជា % នៃ GDP | 1,18 | 1,36 | 1,49 | 1,41 | 1,45 | 1,64 |
| ថវិកាអប់រំធៀបនឹងថវិកាចរន្តរបស់រដ្ឋាភិបាល | 13,6 | 15,0 | 18,8 | 17,2 | 16,1 | 16,6 |
| ថវិកាសម្រាប់បឋមសិក្សាធៀបនឹងថវិកាអប់រំ | - - - | 76,6 | 49,4 | 53,4 | 46,5 | 38,5 |
| អត្រារួមចូលរៀនថ្មី | 109,8 | 125,1 | 122,7 | 121,90 | 120,2 | 125,4 |
| -អត្រារួមចូលរៀនថ្មី (សិស្សស្រី) | 103,2 | 118,1 | 119,3 | 120,4 | 118,2 | 122,6 |
| អត្រាបញ្ចប់ការសិក្សា (តាមរូបមន្ត កូហាត) | 83,8 | 87,0 | 92,1 | 93,3 | 94,4 | 94,8 |
| អត្រាបញ្ចប់ការសិក្សា (សិស្សស្រី) | 80,7 | 84,2 | 91,0 | 93,3 | 94,0 | 94,6 |
| អត្រាបញ្ចប់ការសិក្សា<br>(អត្រារួមចូលរៀនថ្មីថ្នាក់ទី ៦) | - - - | - - - | 52,5 | 59,3 | 61,7 | - - - |
| អត្រាបញ្ចប់ការសិក្សា<br>(អត្រារួមចូលរៀនថ្មីថ្នាក់ទី ៦)<br>អត្រាបញ្ចប់ការសិក្សា (សិស្សស្រី) | - - - | - - - | 55,4 | 61,4 | 63,7 | - - - |
| អត្រាត្រួតថ្នាក់<br>(%នៃសិស្សត្រួតធៀបនឹងសិស្សសរុប) | 52,6 | 58,9 | 90,1 | 86,2 | 85,6 | 83,2 |
| ចំនួនសិស្សចូលរៀន (គិតជា ពាន់នាក់) | - - - | - - - | 89,6 | 88,0 | 85,7 | 83,6 |
| ចំនួនសិស្សចូលរៀន(សិស្សស្រី)(គិតជា ពាន់នាក់) | 10,4 | 10,3 | 10,6 | 10,1 | 8,9 | - - - |
| ផលធៀបសិស្ស - គ្រូ | 2 708 | 2 705 | 2 461 | 2 311 | 2 262 | 2 240 |
| % នៃសេវាអប់រំឯកជន | 1 113 | 1 257 | 1 161 | 1 094 | 1 073 | 1 070 |
| | 53,3 | 56,8 | 51,3 | 49,3 | 49,7 | 49,2 |

*ប្រភព៖ WB, FTI Country Information Form*

កម្ពុជាសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ ក្នុងការបង្កើនលទ្ធភាពទទួលបានសេវាអប់រំស្ថិតក្រោម **ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា** (EFA)។ យុទ្ធនាការអក្ខរកម្មថ្នាក់ជាតិបានផ្តល់នូវលទ្ធផលគួរឱ្យពេញចិត្ត។ ចំនួនសិស្សចូលរៀននៅបឋមសិក្សាបានកើនឡើងចាប់ពីឆ្នាំ ២០០០ រៀងមកដោយសារតែការអនុវត្តដ៏ជោគជ័យនៃកម្មវិធីសកម្មភាពជាអាទិភាព (PAP)។ កំណែទម្រង់មានឥទ្ធិពលជាវិជ្ជមាន ក្នុងការលើកកម្ពស់អត្រាចុះឈ្មោះចូលរៀន ទាំងលើទិដ្ឋភាពស្ថានភាពគ្រួសាររបស់សិស្ស និងយេនឌ័រ។ ថ្វីបើអត្រាចុះឈ្មោះចូលរៀនបានកើនឡើងដល់ ៨៦% សម្រាប់កុមារមានអាយុពី ៦ ទៅ ១០ ឆ្នាំក៏ដោយ ក៏អត្រានេះនៅទាបជាងគេ បើប្រៀបធៀបក្នុងតំបន់។ ជាងនេះទៅទៀត អត្រាបញ្ចប់ការសិក្សាក៏នៅតែមានកម្រិតទាប។ រដ្ឋាភិបាលកំពុងលើកទឹកចិត្តឱ្យគ្រួសារ និងសហគមន៍យកចិត្តទុកដាក់ដល់ការគាំពារនិងអភិវឌ្ឍកុមារតូច។ ការឆ្លើយតបជាវិជ្ជមាននៃកត្តាខាងលើនេះ នឹងរួមចំណែកដល់ការបង្កើនសមិទ្ធិផលនៅបឋមសិក្សា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំនួនសិស្សចូលរៀនសរុបនៅមត្តេយ្យសិក្សាបានកើនឡើងពី ៧៧,៨៩៩ នាក់ ក្នុងឆ្នាំសិក្សា ២០០៦-២០០៧ ដល់ ៧៩,៥៩៩ នាក់ (ស្រី ៣៩,៩៩៦ នាក់) ក្នុងឆ្នាំសិក្សា ២០០៧-២០០៨ ដែលមានកំណើនប្រមាណ ២%។ សមភាពយេនឌ័រនៅក្នុងកម្មវិធីមត្តេយ្យសិក្សាមានកម្រិតខ្ពស់ ដោយសារចំនួនកុមារា និងកុមារីបានចូលរៀនស្មើគ្នា។ ចំនួនសាលាមត្តេយ្យរដ្ឋបានកើនឡើងពី ១,៥២៤ សាលា ដល់ ១,៦៣៤ សាលា ឬ (កំណើន ៧,២%) ពោលគឺស្ទើរតែគ្រប់ឃុំ សង្កាត់នីមួយៗមានសាលាមត្តេយ្យមួយឬពីរ។ លើសពីនេះ ការអប់រំកុមារតូចនៅតាមសហគមន៍ និងផ្នែកឯកជនក៏មានកំណើនខ្ពស់ផងដែរ នៅតាមសាលាមត្តេយ្យសិក្សាសហគមន៍ ការអប់រំកុមារតូចតាមផ្ទះ និងសាលាមត្តេយ្យសិក្សាឯកជន។

*រូបភាព ១៨.១. អត្រារួមនិងអត្រាពិតនៃការសិក្សានៅបឋមសិក្សា*




*ប្រភព៖ WB and UNICEF. FTI.*

**អត្រារួមនៃការសិក្សា** (GER) (រាប់បញ្ចូល ចំនួនកុមារទាំងអស់ដែលបានចូលរៀន ជាពិសេសកុមារលើសអាយុសិក្សា) នៅកម្រិតបឋមសិក្សាបានកើនឡើងពី ១១០% ក្នុងឆ្នាំសិក្សា ២០០០-២០០១ ដល់ ១១៨% ក្នុងឆ្នាំសិក្សា ២០០២-២០០៣។ កំណើនដែលគួរកត់សម្គាល់គឺ នៅក្នុងក្រុមប្រជាជនក្រីក្របំផុតមានអត្រាកំណើន ៣,៥% និងបន្ទាប់មកនៅក្នុងក្រុមប្រជាជនក្រីក្រតិចតួច មធ្យម និងមានមធ្យម ដោយឡែកក្រុមប្រជាជនមានបំផុតមានអត្រាកំណើនអវិជ្ជមាន -២.៣%។ ភាគរយសិស្សក្នុងក្រុមប្រជាជនក្រីក្របំផុតបានកើនឡើងពី ១៥.១% ក្នុងឆ្នាំសិក្សា ១៩៩៩-២០០០ ដល់ ១៧.១% ក្នុងឆ្នាំសិក្សា ២០០២-២០០៣។ ចំនួនសិស្សចូលរៀននៅបឋមសិក្សាមកពីសហគមន៍គ្រួសារក្រីក្រ (ក្រីក្របំផុត ក្រីក្រតិចតួច និងមធ្យម) ខ្ពស់ជាងសិស្សមកពីសហគមន៍គ្រួសារដែលមានជីវភាពល្អប្រសើរ។ និន្នាការនេះនៅតែបន្ត និងក្នុងឆ្នាំ២០០៦ អត្រារួមនៃការសិក្សា បានកើនឡើងដល់ ១២៤% ដែលក្នុងនោះអត្រារបស់សិស្សស្រីកើនឡើងដល់ ១១៨.៦%។ ជាទូទៅ អត្រារួមនៃការសិក្សា កើនឡើងរហូតដល់កម្រិតមួយដែលកុមារលើសអាយុទាំងអស់បានចូលរៀន និងបន្ទាប់មកធ្លាក់ចុះបន្តិចម្តងៗមកត្រឹម ១០០% នៅពេលដែលកុមារលើសអាយុទាំងអស់បានឡើងថ្នាក់ និងឆ្លងទៅភូមិសិក្សាមួយទៀត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កុមារជួបការលំបាកបានទទួលនូវអត្ថប្រយោជន៍ជាច្រើន ពីគោលនយោបាយរដ្ឋាភិបាលលើវិស័យអប់រំ ដូចជាការសាងសង់សាលារៀននៅតំបន់ដាច់ស្រយាល និងការផ្តល់អាហារូបករណ៍។ ទោះជាយ៉ាងនេះក្តី ស្ថានភាពរបស់សាលារៀនគួរត្រូវបានលើកកម្ពស់ថែមទៀត ដើម្បីសម្រួលការអប់រំសម្រាប់កុមារី។

**អត្រាពិតនៃការសិក្សា** (NER) នៅបឋមសិក្សាក្នុងចន្លោះឆ្នាំ ១៩៩៧ និង ២០០៥ បានបង្ហាញពីកំណើនយឺត ព្រមទាំងមានការថយចុះតិចតួចនៅឆ្នាំ ២០០៥ ផងដែរ។ អត្រាពិតនៃការសិក្សា ត្រូវបានគណនាដោយយកចំនួនសិស្សក្នុងវ័យសិក្សា (អាយុពី ៦ ដល់ ១១ ឆ្នាំ នៅបឋមសិក្សា) ចែកជាមួយនឹងចំនួនប្រជាជនក្នុងចន្លោះអាយុដូចគ្នាគិតជាភាគរយ។ ជាបទពិសោធន៍ទូទៅបានបង្ហាញថាប្រទេសជាតិមួយដែលឈានទៅសម្រេចការប្រមូលកុមារចូលរៀនបានទាំងអស់គ្នា ត្រូវការឱ្យមានការចំណាយកាន់តែខ្ពស់ ជាពិសេសចំណាយទៅលើកុមារមិនទាន់បានចូលរៀន។ កម្ពុជាប្រហែលជាត្រូវជ្រើសយកអន្តរាគមន៍ផ្នែកគោលនយោបាយ ១ ឬ ២ (ឧទាហរណ៍ ការបង្កើនអត្រាឡើងថ្នាក់ឬកាត់បន្ថយការបោះបង់ការសិក្សា) ដើម្បីឱ្យកម្ពុជាអាចសម្រេចបានតាមចំណុចដៅ (ប្រភព៖ WB and UNICEF, 2006, p. 13)។ ដូចបង្ហាញក្នុងរូបភាព១៨.១ ខាងលើ អត្រារួមនៃការសិក្សានៅបឋមសិក្សាបង្ហាញពីនិន្នាការកំណើនខ្ពស់ជាងអត្រាពិតនៃការសិក្សា ជាពិសេសនៅតំបន់ជនបទដាច់ស្រយាល។

ជាងនេះទៅទៀត គម្លាតយេនឌ័រត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ នៅសាលាបឋមសិក្សានិងអនុវិទ្យាល័យ ដោយសារតែវឌ្ឍនភាព នៅក្នុងការលើកកម្ពស់ការចូលរៀនរបស់សិស្សស្រី។ ជាក់ស្តែង អត្រានៃការសិក្សារបស់សិស្សស្រីខ្ពស់ជាងសិស្សប្រុស ពោលគឺ ២៧% សម្រាប់សិស្សស្រី និង ២២% សម្រាប់សិស្សប្រុស។

ចំនួនសិស្សចូលរៀននៅបឋមសិក្សាបានកើនឡើងពី ២.៣ លាននាក់ក្នុងឆ្នាំ ២០០១ ដល់ ២.៧ លាននាក់ក្នុងឆ្នាំ ២០០២ ប៉ុន្តែបានថយចុះមកត្រឹម ២.៥ លាននាក់ក្នុងឆ្នាំ ២០០៦។ ក្នុងឆ្នាំសិក្សា ២០០៨-២០០៩ កុមារអាយុចន្លោះពី ៧ ទៅ ១០ ឆ្នាំស្ទើរតែទាំងអស់បានចូលរៀនក្នុងសាលា (Quinn, 2009c, p. 7)។

ចំនួនសិស្សបញ្ចប់ការសិក្សានៅបឋមសិក្សាបានកើនឡើងពី ៦៥.៩% ក្នុងឆ្នាំ ២០០៣ ដល់ ៩០.៣% ក្នុងឆ្នាំ ២០០៦។ ក្នុងឆ្នាំ២០០៨ ចំនួនកុមាររៀនដល់ថ្នាក់ទី ៦ មាន ២៩៣,៦៣២ នាក់ (ស្រី ១៤២,៥៥៥ នាក់) កើនឡើង ១០០,០០០ នាក់បើប្រៀបធៀបនឹងឆ្នាំ ២០០០។ កុមារកម្ពុជា ៨៦% (ស្រី ៨៨%) បានទទួលបានបញ្ចប់ការសិក្សានៅបឋមសិក្សា (Quinn, 2009c, p. 8)។ អត្រាត្រួតថ្នាក់មានកម្រិតខ្ពស់ ២.៨% ក្នុងឆ្នាំ២០០៦។

ការកើនឡើងនៃអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា ស្របជាមួយនឹងការកើនឡើងចំនួនសិស្សចូលរៀននៅបឋមសិក្សា នឹងធ្វើឱ្យចំនួនសិស្សឆ្លងទៅមធ្យមសិក្សាបឋមសិក្សាកើនឡើង។

### ១៨.២.២. ការអប់រំមធ្យមសិក្សា

នៅកម្រិតមធ្យមសិក្សារួមមាន ការអប់រំមធ្យមសិក្សាចំណេះទូទៅនិងការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ។ អាទិភាពរបស់រដ្ឋាភិបាលចំពោះការអប់រំមធ្យមសិក្សាចំណេះទូទៅមានដូចជា ៖ (ក) ការលើកកម្ពស់ការពង្រីកសម្ភារៈបរិក្ខារ តាមរយៈការផ្តល់ហិរញ្ញវត្ថុក្នុងការកសាងអគារសិក្សាថ្មីនៅតាមស្រុកទាំងអស់ ការពង្រីក ឬ ការស្តារឡើងវិញសម្ភារៈបរិក្ខារឧបទេសដែលមានស្រាប់ និងការអនុវត្តអភិក្រមនានាដូចជា ការបង្រៀនពីរវេន ដើម្បីបង្កើនចំនួនសិស្សចូលរៀន (ខ) ការផ្តល់ធនធានសាធារណៈឱ្យបានគ្រប់គ្រាន់ចំពោះ

សម្ភារៈបរិក្ខារនៅតាមសាលារៀន (គ) ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធអប់រំ តាមរយៈការពង្រឹងការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន និងការផ្តល់សម្ភារៈបង្រៀនគ្រប់គ្រាន់ (សៀវភៅសិក្សាគោល និងឧបករណ៍ ។ល។)។

កំណែទម្រង់នាពេលបច្ចុប្បន្នបានផ្តោតការយកចិត្តទុកដាក់លើ ការកាត់បន្ថយប្រាក់បង់ថ្លៃសាលាជាពិសេសសម្រាប់កុមារី ការបង្កើនស្តង់ដារសិក្សា និងការកាត់បន្ថយចំនួនក្មេងស្រីដែលរៀនត្រួតថ្នាក់ តាមរយៈការធ្វើឱ្យប្រសើរឡើងជាបន្តនៃគុណភាពអប់រំ។ ការទទួលសេវាអប់រំរបស់កុមារីកាន់តែប្រសើរឡើងជាក់ស្តែង សិស្សស្រីបានចូលរៀនស្មើនឹង ១ ភាគ ៣ នៃសិស្សសរុប។ កិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយគម្លាតយេនឌ័រនឹងនៅតែបន្តធ្វើ។ កំណែទម្រង់វិស័យអប់រំក៏បានលើកឡើងពីការបង្កើនការបង្រៀននៅមធ្យមសិក្សាទុតិយភូមិ នៅតាមតំបន់ដែលមិនមានសេវានៅកម្រិតនេះគ្រប់គ្រាន់ ការបង្កើនចំនួនមុខវិជ្ជាត្រូវបង្រៀន ការកៀរគរថវិកាសម្រាប់ដំណើរការ និងវិធានការដើម្បីធានាឱកាសទទួលបានសេវាអប់រំស្មើៗគ្នាសម្រាប់គ្រួសារក្រីក្របំផុត។

*រូបភាព ១៨.២. អត្រារួមនិងអត្រាពិតនៃការសិក្សា នៅមធ្យមសិក្សាបឋមភូមិ*




*ប្រភព៖ WB and UNICEF. FTI*

សកម្មភាពជាច្រើនកំពុងគាំទ្រដល់ការអប់រំនៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ មានដូចជា៖ ការផ្តល់អាហារូបករណ៍សម្រាប់សិស្សជួបការលំបាក ដែលអាចជួយបង្កើនចំនួនសិស្សចូលរៀននិងបានបន្តការសិក្សានៅក្នុងសាលារៀន ជាពិសេសសហគមន៍ជួបការលំបាក។ រដ្ឋាភិបាលក៏បានសម្របសម្រួលឱ្យមានការចូលរួមពីវិស័យឯកជន ក្នុងការផ្តល់សេវាអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិផងដែរ ។

អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ១៥% នៅឆ្នាំ ១៩៩៧ ដល់ ១៩% នៅឆ្នាំ ២០០១ និងកើនដល់ ៣១% នៅឆ្នាំ ២០០៥។ គោលបំណងរបស់រដ្ឋាភិបាលគឺបង្កើនអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ យ៉ាងហោចឱ្យដល់ ៦៥% នៅឆ្នាំ ២០១៥។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

*រូបភាព ១៨.៣. អត្រាចុះឈ្មោះចូលរៀនសុទ្ធនិងសរុបថ្នាក់មធ្យមសិក្សាទុតិយភូមិ*




*ប្រភព៖ WB and UNICEF. FTI.*

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ រាប់បញ្ចូលទាំងសិស្សលើសអាយុ បានកើនឡើងលឿនជាងអត្រាពិតនៃការសិក្សា ដែលមានលំនាំដូចនៅកម្រិតបឋមសិក្សាដែរ។ អត្រារួមនៃការសិក្សាកើនពី ២៧% នៅឆ្នាំសិក្សា ២០០០-២០០១ ដល់ ៥០% នៅឆ្នាំ ២០០៥។ ការសម្រេចបានតាមចំណុចដៅ ១០០% នៅឆ្នាំ ២០១៥ គឺជាបញ្ហាប្រឈមមួយ។

ការអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិក៏មានភាពអស្ចារ្យផងដែរ។ ក្នុងឆ្នាំ ២០០៨ ចំនួនសិស្សរៀនថ្នាក់ទី ៩ មាន ១៦៥,៣៨២ នាក់ (ស្រី ៧៦,៦៨១ នាក់) ដែលចំនួននេះកើនលើសចំនួនសិស្សថ្នាក់ទី ៩ នៅឆ្នាំ ២០០០ រហូតដល់ទៅ ១០០,០០០ នាក់ ។ ស្ថានភាពនេះបញ្ជាក់ថា កុមារកម្ពុជា ៤៤% (ស្រី ៤២%) នៃកុមារសរុបបានបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (Quinn, 2009c, p. 9)។

សមភាពក៏កំពុងមានភាពល្អប្រសើរផងដែរ ក្នុងការផ្តល់សេវាអប់រំមធ្យមសិក្សា។ ការចូលរៀនសរុបបានកើនឡើង ៣០% ក្នុងឃុំ សង្កាត់ក្រីក្រ និង ១០% ក្នុងឃុំ សង្កាត់ផ្សេងទៀត។ ទោះយ៉ាងណា កុមារក្នុងឃុំ សង្កាត់ក្រីក្របំផុតមានតែ ៦.៧% នៃសិស្សមធ្យមសិក្សាបឋមភូមិ និង ១,៨% នៃសិស្សមធ្យមសិក្សាទុតិយភូមិ បើប្រៀបធៀបទៅនឹងសិស្សក្នុងឃុំ សង្កាត់ធូធារ ៣៥% នៅមធ្យមសិក្សាបឋមភូមិ និង ៥២% នៅមធ្យមសិក្សាទុតិយភូមិ។

វិសមភាពនៃការទទួលបានការអប់រំនៅមធ្យមសិក្សាមានកម្រិតខ្ពស់ ដែលក្នុងនោះសិស្សមកពីគ្រួសារធូធារមានរហូតដល់ ៥២% នៃសិស្សសរុប និង សិស្ស ១,៨% ប៉ុណ្ណោះមកពីគ្រួសារក្រីក្របំផុត។ តុល្យភាពយេនឌ័រក៏មិនមានផងដែរ។ កុមារីកម្ពុជា ៣៣% នៃកុមារីដែលមានអាយុស្ថិតក្នុងវ័យមធ្យមសិក្សាប៉ុណ្ណោះបានចូលរៀន។ សិស្សស្រីបានចូលរៀននៅការបណ្តុះបណ្តាលវិជ្ជាជីវៈនិងឧត្តមសិក្សាមានតែ ២៥ ទៅ ៣០% ប៉ុណ្ណោះ។

ការអប់រំមធ្យមសិក្សាទុតិយភូមិមានការរីកចម្រើននិងពង្រីកខ្លួនយ៉ាងឆាប់រហ័ស ជាលទ្ធផលមួយនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតវិទ្យាល័យនៅគ្រប់ស្រុកទាំងអស់។ សិស្សចូលរៀននៅ

មធ្យមសិក្សាទុតិយភូមិបានកើនពី ១០៥,០៨៦ នាក់ (ស្រី ៣៣,៤៦៥ នាក់) ក្នុងឆ្នាំសិក្សា ២០០០-២០០១ ដល់ ២៩២,៤២៣ នាក់ (ស្រី ១២៣,៣៣៤ នាក់) ក្នុងឆ្នាំសិក្សា ២០០៨-២០០៩។ ចំនួនសិស្សប្រឡងជាប់ថ្នាក់ទី ១២ បានកើនឡើងពី ១៧,៧១៣ នាក់ (ស្រី ៥,៧៨៦ នាក់) ក្នុងឆ្នាំសិក្សា ២០០០-២០០១ ដល់ ៥១,៥៦៥ នាក់ (ស្រី ២២,៣៩៤នាក់) ក្នុងឆ្នាំសិក្សា ២០០៨-២០០៩ (Quinn, 2009c, p. 10)។

ឧបសគ្គចម្បងចំពោះការចូលរៀនរបស់សិស្សស្រី រួមមាន ៖ កង្វះអនុវិទ្យាល័យនិងវិទ្យាល័យក្នុងស្រុក និងឃុំ សង្កាត់ក្រីក្រ និងកម្រិតនៃភាពក្រីក្រដែលរារាំងក្មេងស្រីពីការចូលរៀន ពីព្រោះពួកគេត្រូវជួយទទួលខុសត្រូវក្នុងគ្រួសារនៅឯផ្ទះ។ ដូច្នេះ រដ្ឋាភិបាលកំពុងផ្តល់អាទិភាពចំពោះការសាងសង់អគារសិក្សាថ្មីៗ ក្នុងស្រុកទាំងអស់ និងផ្តល់អាហារូបករណ៍បន្ថែមទៀតឱ្យចំគោលដៅសិស្សក្រីក្រ ជាពិសេសកុមារី។

### ១៨.២.៣. ការអប់រំបច្ចេកទេសនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ

ការខ្វះខាតការអប់រំបច្ចេកទេសនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បានបង្អាក់ការបង្កើនផលិតភាព។ ទោះជាយ៉ាងណា ការទាមទារឱ្យរដ្ឋដើរតួជាបុរេសកម្ម ក្នុងការផ្តល់ការអប់រំបច្ចេកទេស និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ មិនមែនជាការងាយស្រួលដូចបន្ទុកក្នុងការផ្តល់ការអប់រំកម្រិតមូលដ្ឋាននោះទេ តាមទ្រឹស្តី អាជីវកម្មគួរតែចំណាយចំពោះការបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួន និងបុគ្គលិកអាចមានឆន្ទៈក្នុងការចំណាយសម្រាប់ការបណ្តុះបណ្តាលដោយខ្លួនឯង។ទោះជាយ៉ាងនេះក្តីគម្លាតនៅក្នុងប្រតិបត្តិការទីផ្សារ(កង្វះព័ត៌មាននិងហិរញ្ញប្បទានផលប៉ះពាល់មកពីក្រៅភាពមិនអាចចែកដាច់បាន។ល។)អាចបណ្តាលឱ្យលទ្ធភាពផ្តល់ការបណ្តុះបណ្តាលមិនគ្រប់គ្រាន់។ការអប់រំបច្ចេកទេសនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបានដើរតួនាទីដ៏សំខាន់មួយក្នុង "ភាពមហាអស្ចារ្យ" របស់អាស៊ី។ កម្ពុជាអាចទទួលបានអត្ថប្រយោជន៍ពីបទពិសោធន៍នៃប្រទេសជិតខាងរបស់ខ្លួន។ ជាពិសេស កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវការភាពបត់បែននិងឆ្លើយតបទៅនឹងការរំពឹងទុកនៃទីផ្សារការងារ។

នៅកម្ពុជា ការអប់រំបច្ចេកទេសនិងការបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈត្រូវបានចាត់ទុកថាជាអនុវិស័យមួយនៃការអប់រំ។ ការអប់រំនេះរួមបញ្ចូលទាំង "ការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈជាន់ខ្ពស់" និង "ការអប់រំបច្ចេកទេស និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ថ្នាក់មធ្យមសិក្សានិងកណ្តាល"។ ក្នុងអាណត្តិទីបីនៃរាជរដ្ឋាភិបាលកម្ពុជា (២០០៣ ដល់ ២០០៨) ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានបង្កើតឡើងដែលទទួលបន្ទុកលើការបង្កើតការងារនិងការបណ្តុះបណ្តាលបច្ចេកទេសនិងជំនាញវិជ្ជាជីវៈ។ផែនការអភិវឌ្ឍការបណ្តុះបណ្តាលបច្ចេកទេស និងជំនាញវិជ្ជាជីវៈថ្នាក់ជាតិ សម្រាប់ឆ្នាំ២០០៨ ត្រូវបានពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពនៅដើមឆ្នាំ ២០០៨ និងត្រូវបានតម្រឹមយ៉ាងល្អជាមួយផែនការយុទ្ធសាស្ត្ររបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (២០០៦-២០១០)។

ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មក នៅក្នុងវិស័យឯកជន ការផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរយៈពេលខ្លីមានការកើនឡើងយ៉ាងខ្លាំង (៦ខែ ១ឆ្នាំ ឬ២ឆ្នាំ) នៅស្ទើរគ្រប់មុខព្រួញនៃសកម្មភាពសេដ្ឋកិច្ចទាំងអស់ (ពាណិជ្ជកម្ម ការគ្រប់គ្រង គណនេយ្យ ធុរកិច្ច វិទ្យាសាស្ត្រកុំព្យូទ័រ និងទេសចរណ៍)។ ទោះជាយ៉ាងណា ការបន្តអភិវឌ្ឍជំនាញនៅតែជាបញ្ហា លើកលែងតែនិយោជិកដែលមានធនធានហិរញ្ញវត្ថុសម្រាប់ចំណាយលើការបណ្តុះបណ្តាលផ្ទាល់ខ្លួនរបស់គេ នៅតាមទីកន្លែងរៀនសូត្របង់ថ្លៃក្នុងស្រុក។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គោលនយោបាយថ្មីស្តីពីការបណ្តុះបណ្តាលកំពុងស្ថិតនៅក្នុងការពិចារណា សម្រាប់លើកកម្ពស់ការងារក្នុងវិស័យឯកជន។ គោលនយោបាយថ្មីនេះនឹងរួមបញ្ចូលសមាសធាតុដូចខាងក្រោម៖

- ***សន្និធានកម្មនៃហិរញ្ញប្បទានដល់ការអប់រំបច្ចេកទេសនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ***។ ការសម្របសម្រួលធនធាន ដែលអាចរកបានសម្រាប់ការអប់រំបច្ចេកទេសនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពីរដ្ឋ សហគ្រាសឯកជន និងដៃគូអភិវឌ្ឍ គឺមានសារសំខាន់ណាស់ដើម្បីចៀសវាងការខ្ជះខ្ជាយ។។
- ***ការអភិវឌ្ឍកម្មវិធីដាច់ដោយឡែកសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ*** គួរប្រព្រឹត្តទៅស្របគ្នាជាមួយការអប់រំនៅសាកលវិទ្យាល័យ ដូច្នេះសិស្សនឹងមិនខាតបង់ពេលវេលាក្នុងការបន្តការសិក្សាទាំងពីរផ្នែកតាមលំដាប់។ ការចូលរួមរបស់វិស័យឯកជនក្នុងអភិក្រមថ្មីនេះ មានលក្ខណៈសមហេតុផល ពីព្រោះក្រៅពីការរួមចំណែកផ្នែកសង្គម វាក៏កំពុងជួយបង្កើនប្រាក់ចំណេញផងដែរដោយ ធ្វើការបណ្តុះបណ្តាលកម្លាំងការងារក្នុងអំឡុងពេលសាកល្បង ឬ ក៏នៅមុនពេលដែលនិយោជិក ត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារជាផ្លូវការ។

នៅក្នុងវិស័យការអប់រំបច្ចេទកទេស និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ រដ្ឋាភិបាលនឹងធ្វើពិពិធកម្មកម្មវិធីរបស់ខ្លួន និងលើកកម្ពស់គុណភាពនិងការគ្រប់គ្រងរបស់កម្មវិធីទាំងនោះ។ រដ្ឋាភិបាលក៏នឹងលើកកម្ពស់ប្រព័ន្ធអប់រំ និងការអប់រំបច្ចេទកទេសនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ នៅកម្រិតសាលាមធ្យមសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារដែលកំពុងលេចឡើង។ អភិក្រមនេះតម្រូវឱ្យមានការសម្របសម្រួលយ៉ាងជិតស្និទ្ធ រវាងរដ្ឋាភិបាលនិងវិស័យឯកជន។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានវិទ្យាស្ថាននិងមជ្ឈមណ្ឌល ចំនួន ៣៨ កន្លែងក្នុង ២៤ រាជធានី ខេត្ត និងកំពុងផ្តល់នូវកម្មវិធីនានាចាប់ពីការបណ្តុះបណ្តាលជំនាញមូលដ្ឋានរហូតដល់កម្រិតជាន់ខ្ពស់។ ទីតាំងទាំងនោះបានបណ្តុះបណ្តាលមនុស្សប្រហែល ៥,០០០ នាក់ក្នុងមួយឆ្នាំអាស្រ័យដោយថវិការដ្ឋមានកម្រិត។ ក្រសួងកិច្ចការនារីមានមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី ១១ កន្លែង ដែលផ្តល់នូវកម្មវិធីជាប្រពៃណីមួយចំនួន។ សិក្ខាកាមបញ្ចប់ការសិក្សាប្រហែល៣,០០០ នាក់ក្នុងមួយឆ្នាំ។ សាលាឯកជនមានប្រមាណ ៣០០ កន្លែង ដែលភាគច្រើនក្នុងការអប់រំបច្ចេកវិទ្យាព័ត៌មាននិងផ្នែកយន្តសាស្ត្រ ហើយបច្ចុប្បន្នមិនទាន់ត្រូវបានចុះបញ្ជីនៅឡើយ។ គេប៉ាន់ស្មានថា សិក្ខាកាមប្រហែល ២០,០០០ នាក់បញ្ចប់ការសិក្សា ក្នុងឆ្នាំសិក្សានីមួយៗពីកន្លែងផ្តល់ជំនាញឯកជននានា។ វិស័យផ្លូវការបានបង្កើតការងារថ្មីៗប្រហែល ៥០,០០០ កន្លែងរៀងរាល់ឆ្នាំ ទន្ទឹមនិងកម្លាំងការងារកើនឡើង៣០០,០០០ នាក់ក្នុងមួយឆ្នាំ។ ជារួម កម្មវិធីទីផ្សាការងារសកម្មនៅមានកម្រិតនៅឡើយ។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈកំពុងស្វែងរកយុទ្ធសាស្ត្រផ្សេងៗ ដើម្បីអភិវឌ្ឍជំនាញនិងភ្ជាប់ពួកគេទៅនឹងការងារដែលជាវិធានការដើម្បីពង្រឹងបទដ្ឋានគតិយុត្តិស្តីពីទីផ្សាពលកម្ម។ក្របខ័ណ្ឌគុណវុឌ្ឍិថ្នាក់ជាតិ គឺការទទួលស្គាល់វគ្គសិក្សាការអប់រំបច្ចេកទេសនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈកំពុងត្រូវបានអភិវឌ្ឍ ហើយទីភ្នាក់ងាររកការងារធ្វើថ្នាក់ជាតិមួយកំពុងត្រូវបានបង្កើតឡើង។ ជាងនេះទៅទៀត កម្មវិធីសាកល្បងនានាកំពុងត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយកម្លាំងពលកម្មដែលចេះតែកើនឡើង ជាពិសេសយុវជនក្រោមអាយុ ៣០ ឆ្នាំដែលគ្របដណ្តប់ប្រហែល ៧០% នៃប្រជាជនសរុប។

### ១៨.២.៤. ការអប់រំឧត្តមសិក្សា

កម្ពុជាបានប្រឈមមុខជាមួយនឹងបញ្ហាប្រឈមខាងការអភិវឌ្ឍថ្មីៗមួយចំនួនដូចជា សកលភាវូបនីយកម្មសេដ្ឋកិច្ច និងការកើនឡើងនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជាពិសេសវិទ្យាសាស្ត្រកុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មាននៅក្នុងជីវិតរស់នៅ។ ដើម្បីរក្សាប្រព័ន្ធអប់រំរបស់កម្ពុជាដែលមានភាពប្រកួតប្រជែង រួមបញ្ចូលទាំងការអប់រំបច្ចេកទេសនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការយកចិត្តទុកដាក់ទៅលើ ការផ្តល់ចំណេះដឹង ទៅដល់ប្រជាជននៅគ្រប់ផ្នែកសម្រាប់ការរស់រាន នៅក្នុងពិភពសម័យទំនើប ក៏ដូចជា ការលើកកម្ពស់ គុណភាពអប់រំ។ កម្មវិធីសិក្សានៅគ្រប់កម្រិតនៃការអប់រំ គួរត្រូវបានពិនិត្យឡើងវិញជាបន្តបន្ទាប់ និងធ្វើការ កែលម្អ ដើម្បីឆ្លុះបញ្ចាំងពីចំណេះដឹងថ្មីៗដែលកំពុងលេចឡើងជាបន្តបន្ទាប់។ សហគមន៍បណ្តុះបណ្តាលនិងអប់រំ ត្រូវតែចូលរួមឱ្យបានពេញលេញ ដើម្បីបញ្ជ្រាបចំណេះដឹងនិងការអភិវឌ្ឍថ្មីៗជាបន្តបន្ទាប់។ បញ្ហាប្រឈមមានច្រើន ប៉ុន្តែមិនមានជម្រើសសម្រាប់កម្ពុជា ដែលត្រូវតែតាមឱ្យទាន់ជាមួយពិភពលោកខាងក្រៅក្នុងផ្នែកអប់រំ។ ស្ថាប័នឧត្តមសិក្សាក៏ត្រូវតែស្វែងរកតុល្យភាពត្រឹមត្រូវរវាងគោលបំណង ៣ គឺៈការដោះស្រាយការសិក្សានៅឧត្តមសិក្សា លទ្ធភាពហិរញ្ញវត្ថុ និងការថែរក្សាគុណតម្លៃខាងប្រពៃណី។

ដើម្បីបំពេញតាមតម្រូវការរបស់អ្នកបញ្ចប់ការសិក្សានៅឧត្តមសិក្សា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយលើកទឹកចិត្តដល់គ្រឹះស្ថានអប់រំឧត្តមសិក្សាឯកជន។ ជាលទ្ធផល ចំនួនសាកលវិទ្យា-ល័យ និងវិទ្យាស្ថានថ្នាក់ឧត្តមសិក្សាបានកើនឡើងយ៉ាងឆាប់រហ័ស។ ទោះជាយ៉ាងណា គុណភាពសិក្សារបស់និស្សិតឧត្តមសិក្សានៅមានកម្រិតទាប ហើយមិនត្រូវបានទទួលការពេញចិត្តច្រើនពីទីផ្សារការងារទេ។ឆ្លើយតបទៅនឹងបញ្ហានេះរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា (ACC) ដែលទទួលខុសត្រូវវាយតម្លៃពីខាងក្រៅ លើគុណភាពរបស់គ្រឹះស្ថានឧត្តមសិក្សា។ កិច្ចការជាច្រើនដែលត្រូវបន្តអនុវត្ត ដើម្បីបង្កើនមធ្យមភាគរបស់សាកលវិទ្យាល័យនិងវិទ្យាស្ថានថ្នាក់ឧត្តមសិក្សាឱ្យឡើងដល់កម្រិតថ្នាក់តំបន់។

## ១៨.៣. យន្តការផ្តល់មូលនិធិដល់វិស័យអប់រំ

ដើម្បីដោះស្រាយកង្វល់ថវិកាមិនគ្រប់គ្រាន់ក្នុងវិស័យអប់រំនិងអនុញ្ញាតឱ្យកម្មវិធីនានា ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពសមស្របនោះ ការបែងចែកថវិកាសម្រាប់វិស័យអប់រំត្រូវបានប៉ាន់ស្មានថា គួរតែត្រូវបានបង្កើនបន្តិចម្តងៗរហូតដល់ ១៥% ទៅ១៨% នៃការចំណាយសាធារណៈ។

*រូបភាព ១៨.៣. ការចំណាយលើវិស័យអប់រំ (គិតជាពាន់លានរៀល)*




*ប្រភពៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំបានកើនពី ១% នៃ ផសស ក្នុងឆ្នាំ ១៩៩៦ ដល់ ២% ក្នុងឆ្នាំ ២០០២។ ថវិកាវិស័យអប់រំស្មើនឹង ១៨,៣% នៃការចំណាយចរន្តរបស់រដ្ឋាភិបាលក្នុងឆ្នាំ ២០០៨ បើប្រៀបធៀបទៅនឹង ៩% ក្នុងឆ្នាំ ១៩៩៧។ ប្រសិនបើរាប់បញ្ចូលចំណាយវិនិយោគទៀតនោះ វិស័យអប់រំនឹងក្លាយជាខ្ទង់ចំណាយធំបំផុតរបស់រដ្ឋ និងច្រើនជាងវិស័យការពារជាតិ។ ការពង្រីកចំណាយសារពើពន្ធបានដើរទន្ទឹមនឹងការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ដោយផ្តោតជាពិសេសទៅលើអ្នកក្រីក្របំផុត ក្នុងចំណោមប្រជាជនក្រីក្រជាមួយនឹងថវិកាច្រើនជាង ៦០% ត្រូវបានផ្តល់សម្រាប់ការអប់រំកម្រិតបឋមសិក្សា។ ទោះជាយ៉ាងណាក៏ដោយ វិស័យអប់រំទទួលរងផលប៉ះពាល់ នៅពេលដែលមានការពន្យារពេលក្នុងការបញ្ចេញសាច់ប្រាក់ចេញទៅតាមកញ្ចប់ថវិកាដែលត្រូវបានបែងចែកនោះ រួមបញ្ចូលទាំង ថវិកាកម្មវិធី សកម្មភាពអាទិភាព ផងដែរ។

ចំណាយវិស័យអប់រំបានកើនពី ៦២ ពាន់លានរៀលក្នុងឆ្នាំ ១៩៩៤ រហូតដល់ ៦២២ ពាន់លានរៀលក្នុងឆ្នាំ ២០០៨។ ថវិកាសម្រាប់ការអប់រំបានកើនឡើងខ្លាំងចាប់តាំងពីឆ្នាំ ១៩៩៩ មក ដែលជាលទ្ធផលមួយនៃគោលនយោបាយកំណែទម្រង់វិស័យអប់រំរបស់រាជរដ្ឋាភិបាលកម្ពុជា។ ថវិកាវិស័យអប់រំក្នុងឆ្នាំ ១៩៩៩ បានកើន ៤៧% បើប្រៀបធៀបទៅនឹងឆ្នាំ ១៩៩៨។ អំឡុងទសវត្សរ៍ចុងក្រោយនេះ ការចំណាយវិស័យអប់រំបានកើនឡើងបួនដងនិងឈានដល់ ៦២២ ពាន់លានរៀល (១៥២លានដុល្លារ) ក្នុងឆ្នាំ ២០០៨។ បន្ថែមពីលើថវិការបស់រដ្ឋាភិបាល ជំនួយពីសំណាក់ដៃគូអភិវឌ្ឍចំពោះវិស័យអប់រំបានកើនដល់ប្រហែល ៥០ ទៅ ៦០ លានដុល្លារក្នុងមួយឆ្នាំ។ បដិភាគរបស់រដ្ឋក្នុងការចំណាយលើវិស័យអប់រំ មានតែ ៥០% ប៉ុណ្ណោះ ឪពុកម្តាយចូលរួម ៣៥% (៤០,០០០រៀលជាមធ្យមសម្រាប់កុមារម្នាក់ក្នុងមួយឆ្នាំនៅកម្រិតបឋមសិក្សា និង ៣០០,០០០ រៀល នៅកម្រិតមធ្យមសិក្សា) និង ១៥% ទៀតបានមកពីការចូលរួមរបស់ជំនួយបរទេស។

*តារាង ១៨.២. ចំណាយលើកម្មវិធីវិស័យអប់រំ (គិតជាលានដុល្លារ)*

| | ២០០៦ | ២០០៧e | ២០០៨e | ២០០៩e | ២០១០e |
|---|---|---|---|---|---|
| ចំណាយកម្មវិធីអប់រំ | ៣៤៣.១ | ៣៣០.១ | ៣៣៨.២ | ៣៤៧.១ | ៣៥៧.៣ |
| ការផ្តល់មូលនិធិក្នុងស្រុក | ១៦៦.២ | ១៨៥.១ | ១៩៧.៩ | ១៥០.០ | ១៦៦.៥ |
| នៃការគាំទ្រថវិការជាទូទៅ | ០ | ៧ | ៧ | ៧ | 0 |
| ការគាំទ្រខាងក្រៅ | ៦០.៣ | ៥១.៤ | 28.9 | ២៣.៤ | ១៩.៦ |
| គម្លាតមូលនិធិ | ១១៦.៦ | ៩៣.៦ | 111.4 | ១៧៣.៧ | ១៧១.២ |
| ចំណាយកម្មវិធីអប់រំមូលដ្ឋាន | ២៨៩.២ | ២៨៩.២ | ២៨៩.២ | ២៨៩.២ | ២៨៩.២ |
| ការផ្តល់មូលនិធិក្នុងស្រុក | ១១៣.០ | ១២៦.៨ | ១៣៦.៦ | ១០៥.០ | ១១៨.២ |
| ការគាំទ្រពីក្រៅ | ៥៤.៨ | ៤៤.១ | ២២.៨ | ១៧.៦ | ១២.២ |
| គម្លាតការផ្តល់មូនិធិ | ១២១.៤ | ១១៨.២ | ១២៩.៩ | ១៦៦.៥ | ១៥៨.៨ |
| ការគាំទ្រថវិការទូទៅ | | ៣៥.០ | ៣៥.០ | ៣៥.០ | ៣៥.០ |

*Note: e for estimated.*

*ប្រភព៖ WB, FTI Country Information For .*

ទោះជាយ៉ាងណា គេបានប៉ាន់ប្រមាណថា គម្លាតថវិកាក្នុងវិស័យអប់រំប្រហាក់ប្រហែល ១០០ លានដុល្លារក្នុង១ឆ្នាំ។ ហិរញ្ញប្បទានសម្រាប់វិស័យអប់រំស្ថិតក្នុងសភាពតឹងតែង ជាពិសេសនៅពេលមានការពង្រីក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេវាអប់រំនិងការចូលរៀន ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ការប៉ាន់ស្មានថ្លៃចំណាយក្នុង១ឯកតាបង្ហាញថា ថ្លៃចំណាយក្នុង១ឯកតានៅកម្រិតបឋមសិក្សាប្រហែល ២៨ ដុល្លារ សម្រាប់កុមារម្នាក់ក្នុង១ឆ្នាំ ៧០ ដុល្លារសម្រាប់មធ្យមសិក្សាបឋមភូមិ និង ៨០ ដុល្លារសម្រាប់មធ្យមសិក្សាទុតិយភូមិ (Quinn, 2009a, p. 13)។

ដើម្បីបំពេញគម្លាតថវិកានោះ រាជរដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ និងទទួលហិរញ្ញប្បទានបន្ថែមក្រោមការផ្តួចផ្តើមជាសកលសម្រេចបានគោលដៅអប់រំ fast tract initiative (FTI) ដើម្បីបង្កើនការចំណាយលើវិស័យអប់រំសម្រាប់ឆ្នាំ ២០០៧-២០០៩។

គម្លាតថវិកាខាងលើគឺជាការប៉ាន់ស្មានធនធានដែលត្រូវការ ដើម្បីអនុវត្តកំណែទម្រង់វិស័យអប់រំឱ្យបានពេញលេញ ក្រោមការផ្តួចផ្តើមជាសកលសម្រេចបានគោលដៅអប់រំ។ ចំណាយលើកម្មវិធីអប់រំត្រូវបានផ្អែកលើគំរូមួយ ដែលត្រូវបានប្រើប្រាស់ ដើម្បីគណនាតម្រូវការធនធានសម្រាប់ការអនុវត្តផែនការវិស័យអប់រំ។

## ១៨.៤. សេចក្តីសន្និដ្ឋាន

រដ្ឋាភិបាលទទួលស្គាល់ថា ការពង្រីកសេវាអប់រំដោយសមធម៌ ការលើកកម្ពស់គុណភាពអប់រំគឺមានសារៈសំខាន់ណាស់ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តភាព។ អាទិភាពគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីដើម្បីសម្រេចបានគោលបំណងដែលបានលើកឡើងខាងលើ ត្រូវបានគូសបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP)និងកម្មវិធីគាំទ្រវិស័យអប់រំ (ESSP) ឆ្នាំ ២០០៦-២០១០។ ច្បាប់ស្តីពីការអប់រំ ដែលបានអនុម័តនៅឆ្នាំ២០០៧ បានរួមចំណែកដ៏សំខាន់ដល់ការពង្រីកកាលានុវត្តភាព សម្រាប់ការអប់រំប្រកបដោយសមធម៌ ការលើកកម្ពស់គុណភាពអប់រំ និងគុណភាពនៃការផ្តល់សេវា។ ការអនុវត្តថវិកាកម្មវិធី (PB) ក្នុងវិស័យអប់រំបានបង្កើនកាលានុវត្តភាពសម្រាប់ភ្ជាប់ជាប្រព័ន្ធរវាងការអនុវត្តថវិកា និងសមិទ្ធិកម្មកម្មវិធីប្រកបដោយសមភាព និងការលើកកម្ពស់គុណភាពអប់រំនិងការផ្តល់ជូនសេវារបស់ខ្លួន។ ការអនុវត្តនូវការបែងចែក **ថវិកាកម្មវិធី** (PB) ក្នុងវិស័យនេះបានបង្កើនកាលានុវត្តភាពសម្រាប់ការអនុវត្តថវិកាតភ្ជាប់ជាប្រព័ន្ធនិងសមិទ្ធផលកម្មវិធី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១៩
# សុខាភិបាល

## ១៩.១. សាវតារ

វិស័យសុខាភិបាលនៅកម្ពុជាបានដំណើរការទៅមុខស្ថិតក្រោមស្ថានភាពហេដ្ឋារចនាសម្ព័ន្ធមិនទាន់សម័យ និងគុណភាពនៃសេវានៅមានកម្រិត។ ការផ្គត់ផ្គង់បុគ្គលិកសុខាភិបាលមិនទាន់គ្រប់គ្រាន់ ដោយសារតែការពង្រាយបុគ្គលិកមិនបានស្មើសាច់ល្អ និងបុគ្គលិកមួយចំនួនមិនចង់ទៅបម្រើនៅតាមតំបន់ជនបទដាច់ស្រយាល។ មធ្យោបាយសម្រាប់ដឹកជញ្ជូនអ្នកជម្ងឺមានតិចតួច ជាពិសេសនៅតំបន់ដាច់ស្រយាលក្រខ្សត់។ ការអះអាងនិងវាយតម្លៃបែបនេះ អាស្រ័យទៅលើលទ្ធផលនៃការស្ទាបស្ទង់មតិរបស់សហគមន៍ស្ដីពីឱកាសទទួលបានសេវានិងគុណភាពនៃការថែទាំសុខភាព។ បញ្ហាប្រឈមជាច្រើននឹងត្រូវដោះស្រាយ ដើម្បីលើកកម្ពស់លក្ខខណ្ឌសុខភាពនិងអនាម័យរបស់ប្រជាជនភាគច្រើន ឱ្យឈានដល់កម្រិតដែលអាចទទួលយកបាន ជាពិសេសក្នុងតំបន់ជនបទ។ ការប្រើប្រាស់បរិក្ខារវេជ្ជសាស្ត្រនិងថែទាំសុខភាពពីផ្នែកសាធារណៈនៅមានកម្រិតទាប ដោយសារតែប្រាក់ចំណូលទាបនិងហេដ្ឋារចនាសម្ព័ន្ធនិងបុគ្គលិកសុខាភិបាលមានមិនគ្រប់គ្រាន់។

រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់អាទិភាពខ្ពស់ ចំពោះការផ្ដល់សេវាសុខាភិបាលភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណ ដោយសារតែអ្នកក្រីក្រខ្វះលទ្ធភាពទទួលបានសេវាសុខាភិបាល និងភាពក្រីក្រប្រាក់ចំណូល។ ប្រាក់ចំណូលទាបបានកំហិតលទ្ធភាពទទួលបានសេវាថែទាំសុខភាព។ ផ្ទុយទៅវិញ សុខភាពទន់ខ្សោយបានកំហិតដល់សមត្ថភាពផ្នែកបញ្ញានិងរាងកាយរបស់មនុស្សម្នាក់ ដែលនាំទៅរកការបាត់បង់សក្ដានុពលរកប្រាក់ចំណូលនិងឈានធ្លាក់ចូលទៅក្នុងសភាពក្រីក្រ។ ដូច្នេះហើយ ទើបវិស័យសុខភាពត្រូវបានចាត់ចូលជា គោលដៅអភិវឌ្ឍសហស្សវត្សរ៍ ដោយអង្គការសហប្រជាជាតិ។

វិស័យសុខាភិបាលក៏សម្រេចបានជោគជ័យមួយចំនួនផងដែរនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេស ការលុបបំបាត់ជម្ងឺស្វិតដៃជើង ការធ្លាក់ចុះនៃអត្រាអ្នកស្លាប់ពីជម្ងឺគ្រុនចាញ់ និងការពង្រីកបរិធានគាំពារសុខភាពនៅទូទាំងប្រទេស។ ទោះយ៉ាងនេះក្ដី កម្ពុជាកំពុងប្រឈមមុខជាមួយនឹងបញ្ហាមួយចំនួននៅក្នុងវិស័យសុខាភិបាល។ ការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃមេរោគអេដស៍និងជម្ងឺអេដស៍នៅកម្ពុជាមានវឌ្ឍនភាពយ៉ាងឆាប់រហ័សក្នុងការសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍។ អត្រាប្រេវាឡង់នៃមេរោគអេដស៍និងជម្ងឺអេដស៍នៅកម្ពុជាបានធ្លាក់ចុះជិត ១ ភាគ ៣ ជាក់ស្ដែងអត្រានេះបានធ្លាក់ចុះពី ៣,៩% នៃប្រជាជនក្នុងឆ្នាំ ១៩៩៧ មកត្រឹម ១,២% ក្នុងឆ្នាំ ២០០៣ និងបន្តធ្លាក់មកនៅត្រឹម ០,៩% ក្នុង ឆ្នាំ២០០៧។ ប៉ុន្តែសមិទ្ធិផលនេះមិនទាន់រាប់បញ្ចូលអំពីការកើនឡើងនៃការចម្លងជម្ងឺនេះពីប្ដីទៅប្រពន្ធ និងពីម្ដាយទៅកូននិងការកើនឡើងអត្រាប្រេវាឡង់មេរោគអេដស៍និងជម្ងឺអេដស៍ក្នុងចំណោមមនុស្សវ័យក្មេង ជាពិសេសក្រុមងាយរងគ្រោះ នៅឡើយទេ។ ដើម្បីប្រយុទ្ធប្រឆាំងនឹងនិន្នាការនេះ រដ្ឋាភិបាលកំពុងផ្ដោតលើការធ្វើតេស្តរកមេរោគការផ្ដល់ប្រឹក្សាខាងផ្លូវចិត្ត និងការការពារការចម្លងពីម្ដាយទៅកូនដោយយកចិត្តទុកដាក់ ជាពិសេសចំពោះមនុស្សវ័យក្មេង យុវវ័យ និងស្ត្រី។

កង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារអាយុក្រោម ៥ ឆ្នាំនៅតែបន្តជាបញ្ហាសុខភាពសាធារណៈដ៏ចម្បងមួយ។ ក្នុងឆ្នាំ ២០០៦ កុមារអាយុក្រោម ៥ ឆ្នាំប្រមាណ ៣៦ % មានសភាពក្រិនឬខ្វះទម្ងន់ ដែលបង្ហាញពីសញ្ញាខ្វះអាហារូបត្ថម្ភឬស្គមស្គាំងរ៉ាំរ៉ៃ។ អត្រាមរណភាពក្នុងចំណោមកុមារអាយុក្រោម ៥ ឆ្នាំនិង អត្រាមរណភាពរបស់ទារកបានធ្លាក់ចុះជាខ្លាំងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែនៅតែស្ថិតក្នុងកម្រិតខ្ពស់ បើប្រៀបធៀបទៅនិងប្រទេសផ្សេងៗក្នុងតំបន់។ ដូច្នេះ កម្ពុជាទំនងជាមិនអាចសម្រេចបានគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ក្នុងការកាត់បន្ថយអត្រាមរណភាពរបស់មាតាបានទេ ដោយសូចនាករនេះនៅមានកម្រិតខ្ពស់នៅឡើយ។

អាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យសុខាភិបាលរួមមាន ការអនុវត្តកម្មវិធីបង្ការ ការគ្រប់គ្រងជម្ងឺឆ្លង ការលើកកម្ពស់សុខភាពកុមារនិងមាតា និងការពង្រឹងសេវាកម្មសង្គ្រោះបន្ទាន់ ការអប់រំសុខភាពនិងការបង្កើនការយល់ដឹង ជាពិសេសក្នុងសហគមន៍ជនបទ។ អ្នកក្រីក្របំផុតនឹងទទួលបានសេវាព្យាបាលដោយឥតគិតថ្លៃ នៅតាមមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាពនានា។ កម្មវិធីធានារ៉ាប់រងសុខភាពតាមសហគមន៍ ត្រូវបានរៀបចំឡើង ដើម្បីសម្រាលបន្ទុកបញ្ហាសុខភាពរបស់អ្នកក្រីក្រ។ មូលនិធិសមធម៌ ក៏ត្រូវបានបង្កើតឡើង និងត្រូវបានពង្រឹងនិងពង្រីកបន្ថែមទៀត ដើម្បីសម្រួលដល់អ្នកក្រីក្រឱ្យមានលទ្ធភាពទទួលបានការគាំពារព្យាបាលដែលមានគុណភាព។ រដ្ឋាភិបាលនឹងអនុម័តនិងពង្រឹងច្បាប់និងបទបញ្ញត្តិស្ដីពីការថែទាំសុខភាព ដើម្បីធានាថាសេវាកម្មនិងការប្រតិបត្តិថែទាំសុខភាពមានគុណភាពខ្ពស់ ដូចគ្នាដែរចំពោះសន្តិសុខស្បៀង។ រដ្ឋាភិបាលនឹងបន្តលើកកម្ពស់ការព្យាបាលដោយប្រើប្រាស់ឱសថបុរាណ ជាមួយនឹងការផ្ដល់ព័ត៌មាននិងការធ្វើអធិការកិច្ចដ៏សមស្រប រួមជាមួយនឹងការប្រើប្រាស់ឱសថសម័យទំនើប។

## ១៩.២. យុទ្ធសាស្ត្រគាំពារសុខភាពថ្នាក់ជាតិ

ក្នុងឆ្នាំ ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តឯកសារយុទ្ធសាស្ត្រមួយចំនួនក្នុងគោលបំណងលើកកម្ពស់ការផ្ដល់សេវាថែទាំសុខភាពនិងផ្ដល់អាហារូបត្ថម្ភ រួមមានផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ៥ ឆ្នាំ (២០០៣-២០០៧) និងផែនការជាតិសម្រាប់ការវិនិយោគលើអាហារូបត្ថម្ភ (២០០៣-២០០៧)។

ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៣-២០០៧ បានសង្កត់ធ្ងន់លើការផ្ដល់សេវាសុខាភិបាលដែលមានគុណភាពខ្ពស់ ការបង្កើតមូលនិធិសមធម៌ដើម្បីជួយសម្រាលដល់ការបង់ថ្លៃពីសំណាក់អ្នកក្រីក្រ ការផ្លាស់ប្ដូរអាកប្បកិរិយារបស់បុគ្គលិកសុខាភិបាល ការបង្កើនតម្លាភាពស្ថាប័នទទួលខុសត្រូវការគ្រប់គ្រង ការថែរក្សា ការកៀរគរធនធាន រួមបញ្ចូលទាំងបុព្វលាភធានារ៉ាប់រងឯកជន និងការធានារ៉ាប់រងសហគមន៍ផ្អែកលើការបង់ថ្លៃជាមុន។ គោលការណែនាំសម្រាប់អនុវត្តគោលនយោបាយទាំងនេះ បានគូសបញ្ជាក់ពីតម្រូវការក្នុងការផ្ដល់អត្ថប្រយោជន៍ដល់ក្រុមងាយរងគ្រោះ ការឆ្លើយតបនឹងតម្រូវការរបស់សាធារណៈជន ហិរញ្ញប្បទានប្រកបដោយនិរន្តរភាព ការចូលរួមពីសហគមន៍ជនបទ ការកសាងនិងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ក៏ដូចជាភាពជាដៃគូផងដែរ។

គោលនយោបាយរបស់រដ្ឋាភិបាលស្ដីពីការថែទាំសុខភាព បានផ្អែកលើអាទិភាពដូចខាងក្រោម៖ ការផ្ដល់នូវការគាំពារសុខភាពជាមូលដ្ឋានសម្រាប់ប្រជាជនកម្ពុជាទាំងអស់ ការផ្ដល់ជូនសេវាឯកទេសជំនាញសំខាន់ៗ ហិរញ្ញប្បទានតាមបែបវិមជ្ឈការនិងវិសហវិមជ្ឈការ ការធ្វើផែនការនិងមុខងាររដ្ឋបាលក្នុង វិស័យថែទាំសុខភាព ការលើកកម្ពស់ធនធានមនុស្ស ការបង្ការនិងគ្រប់គ្រងជម្ងឺឆ្លងនិងជម្ងឺមិនឆ្លង ការគាំពារមាតា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងទារកដែលមានគុណភាព ការពង្រឹងច្បាប់ពាក់ព័ន្ធនិងសុខភាព ការលើកកម្ពស់អាកប្បកិរិយាសកម្ម ដែលនាំទៅរកការរស់នៅល្អឬមានសុខភាពល្អរបស់ប្រជាជន ការផ្តល់សេវាប្រកបដោយគុណភាព ប្រសិទ្ធភាពនិងប្រសិទ្ធផល ការលើកកម្ពស់ភាពជាដៃគូឯកជននិងសាធារណៈប្រកបដោយប្រសិទ្ធភាពដើម្បីធ្វើឱ្យវិស័យថែទាំសុខភាពបានប្រសើរ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានសុខាភិបាលឱ្យមានប្រសិទ្ធភាពដើម្បីធានាដល់ការអនុវត្តការពិនិត្យតាមដាននិងវាយតម្លៃផ្នែកលើការបំពេញការងារ និងលទ្ធផលក្នុងវិស័យសុខាភិបាល និងការលើកកម្ពស់លទ្ធភាពទទួលបានសេវាសុខាភិបាលអាទិភាពមួយចំនួនប្រកបដោយសមធម៌ ជាពិសេសសម្រាប់អ្នកក្រីក្រ។

ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ដំណាក់កាលថ្មី ២០០៨-២០១៥ ត្រូវបានអនុម័តនៅឆ្នាំ២០០៨ និងបានកំណត់កម្មវត្ថុជាយុទ្ធសាស្ត្រ ដូចជា ៖ ការកាត់បន្ថយបន្ទុកសេដ្ឋកិច្ច សង្គមកិច្ច និងបន្ទុកសុខភាពនៃជម្ងឺឆ្លងនានា ការប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍និងមេរោគអេដស៍ ជម្ងឺរបេងនិងគ្រុនចាញ់ ការការពារនិងកាត់បន្ថយមេរោគ ពិការភាព និងមរណភាពមុនអាយុកាលដែលបណ្តាលមកពីជម្ងឺរ៉ាំរ៉ៃ លក្ខខណ្ឌមិនឆ្លង វិកលចរិត អំពើហិង្សា ការរងរបួស និងការចុះខ្សោយផ្នែកចក្ខុ ការកាត់បន្ថយរោគាព្យាធិនិងមរណភាព និងការលើកកម្ពស់សុខភាពអំឡុងពេលដំណាក់កាលសំខាន់របស់ជីវិត រួមមាន ការមានផ្ទៃពោះ ការប្រសូត្របុត្រ រយៈពេលកូនខ្ចី កុមារភាព និងវ័យជំទង់ និងការលើកកម្ពស់សុខភាពបន្តពូជនិងផ្លូវភេទ និងការធ្វើឱ្យប្រសើរឡើងភាពសកម្មនិងសុខភាពល្អសម្រាប់មនុស្សចាស់ជរា ការកាត់បន្ថយផលវិបាកផ្នែកសុខភាពនៃការសង្គ្រោះបន្ទាន់ មហន្តរាយ វិបត្តិ និងជម្លោះ និងការបន្ថយផលប៉ះពាល់ផ្នែកសង្គម-សេដ្ឋកិច្ច ការលើកកម្ពស់បរិស្ថានប្រកបដោយសុខភាពល្អ បង្កើនការបង្ការបឋម លើកកម្ពស់សន្តិសុខស្បៀង សុវត្ថិភាពអាហារ និងអាហារូបត្ថម្ភ ការលើកកម្ពស់សេវាសុខាភិបាលតាមរយៈអភិបាលកិច្ចល្អ ហិរញ្ញប្បទាន ការផ្តល់និងការគ្រប់គ្រងបុគ្គលិក និងការធានាលទ្ធភាពទទួលបានសេវា គុណភាពសេវា និងការប្រើប្រាស់ផលិតផលនិងបច្ចេកវិទ្យាវេជ្ជសាស្ត្រ។

វត្ថុបំណងរបស់យុទ្ធសាស្ត្រសុខាភិបាលគឺ លើកកម្ពស់សូចនាករសុខភាពរបស់ប្រជាជនកម្ពុជាជាមួយនិងការផ្តោតជាពិសេសលើអ្នកក្រីក្របំផុត។ សូចនាករទាំងនោះទាក់ទងនឹងការកាត់បន្ថយមរណភាពមាតានិងទារក ការគ្រប់គ្រងជម្ងឺឆ្លង និងការលើកកម្ពស់អាហារូបត្ថម្ភសម្រាប់ស្ត្រីនិងកុមារ។ ការលើកកម្ពស់សូចនាករទាំងនេះនឹងសម្រេចបាន តាមរយៈការពង្រីកលទ្ធភាពទទួលបានសេវាថែទាំសុខភាព និងលើកកម្ពស់ការយល់ដឹងនិងជំនាញរបស់មាតាបិតានិងអ្នកមើលថែទាំកុមារ និងការលើកទឹកចិត្តការប្រសូត្របុត្រដែលមានជំនួយពីបុគ្គលិកមានជំនាញ។ សកម្មភាពដែលត្រូវអនុវត្តមានដូចជា អន្តរាគមន៍ផ្នែកបច្ចេកទេសដែលផ្តោតលើបុព្វហេតុចម្បងៗនៃមរណភាព ដូចជា កង្វះអាហារូបត្ថម្ភ ជម្ងឺរាគរូស ជម្ងឺនានាដែលអាចការពារបានតាមរយៈការចាក់វ៉ាក់សាំងបង្ការ ការឆ្លងពីប៉ារ៉ាស៊ីត និងជម្ងឺនានា។ ប្រសិទ្ធផលនៃសកម្មភាពទាំងនេះអាស្រ័យទៅលើប្រព័ន្ធនិងរចនាសម្ព័ន្ធសេវាថែទាំសុខភាពនិងព្យាបាលទាំងផ្នែកសាធារណៈនិង ឯកជនដែលមានប្រសិទ្ធភាពមួយនិងហិរញ្ញប្បទានបានគ្រប់គ្រាន់។

## ១៩.៣. ការអនុវត្តរបស់វិស័យសុខាភិបាល

ការលើកកម្ពស់ស្ថានភាពសុខភាពនៅកម្ពុជាបានបង្ហាញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មក។ សូចនាករសុខាភិបាលសំខាន់ៗ ត្រូវបានបង្ហាញឡើង តាមរយៈការអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ឆ្នាំ ២០០០ និងឆ្នាំ ២០០៥។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១៩.៣.១. ស្ថានភាពសុខភាពទូទៅរបស់ប្រជាជន

ការអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជាឆ្នាំ ២០០៥ បានផ្តល់ទិន្នន័យដែលគួរឱ្យជឿជាក់និងបច្ចុប្បន្នភាពស្តីពី អាយុរស់ សុខភាពមាតានិងទារក អាហារូបត្ថម្ភ ជំងឺគ្រុនចាញ់ ប្រេវាឡង់មេរោគនិងជម្ងឺអេដស៍ ស្ថានភាពរបស់ស្ត្រី និងអំពើហិង្សាក្នុងគ្រួសារ។

*តារាង ១៩.១. សូចនាករសុខភាព*

| | CDHS ២០០២ | CDHS ២០០៥ |
|---|---|---|
| អាយុសង្ឃឹមរស់ជាមធ្យម (ឆ្នាំ) | | |
| ស្រី | ៥៨ | ៦៤ |
| ប្រុស | ៥៤ | ៥៨ |
| អត្រាមរណភាព (ក្នុងការផ្តល់កំណើត ១,០០០នាក់ ) | | |
| អត្រាមរណភាពទារក | ៩៥ | ៦៦ |
| អត្រាមរណភាពកុមារ | ៣៣ | ១៩ |
| អត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ | ១២៤ | ៨៣ |
| មរណភាពមាតា (ក្នុងការផ្តល់កំណើត ១០០,០០០ ) | ៤៣៧ | ៤៧២ |

*ប្រភព ៖ Cambodia Demographic and Health Survey 2005; NIS.*

អាយុសង្ឃឹមរស់មធ្យមបានកើនពី ៥៨ ឆ្នាំសម្រាប់ស្ត្រី និង ៥៤ ឆ្នាំសម្រាប់បុរសក្នុងឆ្នាំ ១៩៩៨ ទៅដល់ ៦៤ ឆ្នាំនិង ៥៨ ឆ្នាំ ក្នុងឆ្នាំ២០០៥។ អត្រាមរណភាពរបស់ទារក កុមារ និងក្មេងអាយុក្រោម៥ឆ្នាំបានធ្លាក់ចុះយ៉ាងខ្លាំង ដែលឆ្លុះបញ្ចាំងពីការកើនឡើងហិរញ្ញប្បទានលើផ្នែកសុខាភិបាលក្នុងទសវត្សរ៍កន្លងទៅ។ អត្រាមរណភាពទារកបានធ្លាក់ចុះពី ៩៥ នាក់ក្នុងការប្រសូត្រ ១,០០០ នាក់នៅឆ្នាំ ១៩៩៨ មកនៅត្រឹម៦៦ នាក់ក្នុងឆ្នាំ ២០០៥ និងអត្រាមរណភាពកុមារបានធ្លាក់ពី ៣៣ នាក់មកត្រឹម ១៩ នាក់ក្នុងរយៈពេលដូចគ្នា។ មរណភាពកុមារអាយុក្រោម ៥ ឆ្នាំបានធ្លាក់ចុះយ៉ាងខ្លាំងពី ១២៤ នាក់ក្នុងការប្រសូត្រ ១,០០០ នាក់ក្នុងឆ្នាំ ១៩៩៨ មកត្រឹម ៨៣ នាក់ក្នុងឆ្នាំ ២០០៥។ ទោះជាយ៉ាងណាក្តី បញ្ហាប្រឈមនៅតែមានដូចជាមរណភាពមាតានៅតែមានកម្រិតខ្ពស់គឺ ៤៧២ នាក់ក្នុងការប្រសូត្រ ១០០,០០០ នាក់ក្នុងឆ្នាំ ២០០៥។ ការបន្តកែលម្អនៅគ្រឹះស្ថានឧត្តមសិក្សាផ្នែកសុខាភិបាលគឺទាមទារឱ្យមានផលប៉ះពាល់ពិតប្រាកដល់ស្ថានភាពសុខភាពរបស់ស្ត្រីនៅកម្ពុជា។

### ១៩.៣.២. មេរោគនិងជម្ងឺអេដស៍ របេង និង គ្រុនចាញ់

ប្រទេសកម្ពុជាទទួលបានជោគជ័យ នៅក្នុងប្រយុទ្ធប្រឆាំងនឹងការរាលដាលនៃមេរោគនិងជម្ងឺអេដស៍។ អត្រាប្រេវាឡង់របស់មេរោគនិងជម្ងឺអេដស៍បានធ្លាក់ចុះពី ៣,៩% នៃចំនួនប្រជាជនក្នុងឆ្នាំ ១៩៩៧មកត្រឹម ១,២% ក្នុងឆ្នាំ ២០០៣ និងមកនៅត្រឹម ០,៩% ក្នុងឆ្នាំ ២០០៧ ដោយសារតែការអនុវត្តផែនកា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យុទ្ធសាស្ត្រថ្នាក់ជាតិស្តីពីមេរោគនិងជម្ងឺអេដស៍ឆ្នាំ ២០០៦-២០១០។ ក្នុងឆ្នាំ ២០០៧ ក្រសួងកិច្ចការនារីបានកសាងផែនការយុទ្ធសាស្ត្រប្រាំឆ្នាំរបស់ខ្លួនស្តីពី ស្ត្រី កុមារី និងមេរោគនិងជម្ងឺអេដស៍ឆ្នាំ២០០៨-២០១២។ ស្ត្រីប្រមាណ ៨៨% បានទទួលការផ្តល់ប្រឹក្សាពីសំណាក់មន្ទីរព្យាបាលរបស់រដ្ឋនិងអង្គការមិនមែនរដ្ឋាភិបាលនានា។ លទ្ធភាពទទួលបានសេវាថែទាំនិងព្យាបាលគឺជាក្តីបារម្ភណ៍ដ៏ចម្បងមួយនៅតំបន់ជនបទ ដោយសារតែភាពស្មុគស្មាញនៃសេវាព្យាបាលដោយឱសថប្រឆាំងនិងមេរោគអេដស៍ (ART)។ ភាគរយប្រជាជនមានផ្ទុកវីរុសហ៊ីវធ្ងន់ធ្ងរនិងទទួលបានការព្យាបាលដោយការផ្សំឱសថប្រឆាំងមេរោគអេដស៍ មានភាពល្អប្រសើរជាងមុន។ ចំនួនមនុស្សពេញវ័យដែលទទួលបានការព្យាបាលនេះ កើនឡើងពី ១៨,៣៩៤ នាក់ក្នុងឆ្នាំ ២០០៦ ដល់ ២៤,១២៣ នាក់ (ស្ត្រី ៥១,២%) ក្នុងឆ្នាំ ២០០៧។ ចំនួនកុមារដែលទទួលបានការព្យាបាលក៏បានកើនឡើងដែរពី ១,៧៨៧ នាក់ក្នុងឆ្នាំ ២០០៦ ដល់ ២,៥៤១ នាក់ (ក្មេងស្រី៤៧%) ក្នុងឆ្នាំ ២០០៧។ ប្រជាជនផ្ទុកមេរោគអេដស៍ចំនួន ១១,២៣៥ នាក់ផ្សេងទៀត (រួមទាំងកុមារ ១,៨៤០នាក់) កំពុងទទួលបានវិធីបង្ការការឆ្លងរោគឱកាសនិយម (OI) និងស្រុកប្រតិបត្តិការចំនួន ៣៩ កន្លែងបានផ្តល់ការថែរក្សាពេញលេញ។ សមមាត្រនៃមនុស្សពេញវ័យដែលអាចរស់បាន ១២ ខែបន្ទាប់ពីចាប់ផ្តើមទទួលសេវាព្យាបាលមានប្រមាណ ៨៧,៦% ធៀបនឹងចំណុចដៅ ៨៥% ក្នុងឆ្នាំ ២០០៧។ ចំនួនមណ្ឌលដែលផ្តល់សេវាការពារការឆ្លងពីម្តាយទៅកូនបានកើនដល់ ៩៩ កន្លែងក្នុងឆ្នាំ ២០០៧ ដោយគ្របដណ្តប់គ្រប់ខេត្តទាំងអស់ និងចំនួនស្រុកប្រតិបត្តិដែលយ៉ាងហោចណាស់មានបរិក្ខារសុខភាពសម្រាប់ផ្តល់សេវាបែបនេះបានកើនឡើងពី ៣៩ ទៅ ៥៩ កន្លែងក្នុងរយៈពេលដូចគ្នានេះ។

ប៉ុន្តែសមិទ្ធិផលនេះមិនបានលើកឡើងនូវការកើនឡើងជាខ្លាំង ក្នុងករណីនៃការចម្លងជម្ងឺពីប្តីទៅប្រពន្ធនិងពីម្តាយទៅកូន និងការកើនឡើងប្រេវាឡង់មេរោគនិងជម្ងឺអេដស៍ក្នុងចំណោមប្រជាជនវ័យក្មេងជាពិសេសក្រុមងាយរងគ្រោះ។ ឆ្លើយតបនឹងនិន្នាការនេះ រដ្ឋាភិបាលបានរៀបចំវិធានការមួយចំនួនដោយផ្តោតលើការធ្វើតេស្តរកមេរោគ ការប្រឹក្សាផ្លូវចិត្ត និងការការពារនៃការចម្លងពីម្តាយទៅកូន ជាពិសេសចំពោះមនុស្សវ័យក្មេង យុវវ័យ និងស្ត្រី។

ផែនការយុទ្ធសាស្ត្រសុខាភិបាលថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងជម្ងឺរបេង ឆ្នាំ ២០០៦-២០១០ មានគោលបំណងកាត់បន្ថយប្រេវាឡង់ជម្ងឺរបេង និងចំនួនអ្នកស្លាប់ដោយជម្ងឺរបេង។ ក្នុងឆ្នាំ ២០០៧ មណ្ឌលសុខភាពចំនួន ៩៥៧ កន្លែងនិងមន្ទីរពេទ្យបង្អែកចំនួន ៧៤ កន្លែងផ្តល់នូវកម្មវិធី DOTS ពេញលេញ (កម្មវិធីរយៈពេលខ្លីព្យាបាលដោយការអង្កេតផ្ទាល់) សម្រាប់ព្យាបាលអ្នកជម្ងឺរបេងដោយឥតគិតថ្លៃ។ ភាគរយករណីរកឃើញជម្ងឺរបេងវិជ្ជមានពីកំហាកបានកើនពី ៦០% ក្នុងឆ្នាំ ២០០៣ ដល់ ៦៥,៤% ក្នុងឆ្នាំ ២០០៧ ដែលនឹងឈានទៅសម្រេចចំណុចដៅ ៧០% របស់ពិភពលោក និងមានភាពល្អប្រសើរប៉ុន្មានឆ្នាំកន្លងមកជាងចំណុចដៅរបស់អង្គការសុខភាពពិភពលោក ៨៥% ព្យាបាលបានជោគជ័យ។ មណ្ឌលសុខភាពដែលផ្តល់សេវាព្យាបាលជម្ងឺរបេងនិងអេដស៍ បានកើនឡើងពី ២២២ កន្លែងក្នុងឆ្នាំ ២០០៦ ដល់ ៥២២ កន្លែងក្នុងឆ្នាំ ២០០៧។

ចន្លោះឆ្នាំ ២០០៦ និង ២០០៧ ចំនួនករណីគ្រុនចាញ់បានធ្លាក់ចុះពី ១០០,០០០ ករណីមកនៅត្រឹម ៥៩,០០០ ករណី ដែលជាលទ្ធផលមួយនៃយុទ្ធសាស្ត្រទប់ស្កាត់ ដែលបានអនុវត្តដោយមជ្ឈមណ្ឌលជាតិគ្រប់គ្រងជម្ងឺគ្រុនចាញ់ (NCPEM) និងដៃគូនានា។ ចំនួនអ្នកស្លាប់ដោយសារជម្ងឺគ្រុនចាញ់បានធ្លាក់ចុះពី ២,៨១% មកត្រឹម ១,៦៨% ក្នុងចំណោមមនុស្ស ១០០,០០០ នាក់ អាស្រ័យដោយមានការអប់រំសុខភាពល្អប្រសើរ ការចែកចាយមុងជ្រលក់ថ្នាំកម្ចាត់សត្វល្អិត និងការបណ្តុះអ្នកស្ម័គ្រចិត្តផ្នែកសុខាភិបាលតាមភូមិដើម្បីធ្វើតេស្តឈាមនិងផ្តល់ការព្យាបាល។ ភូមិស្ថិតក្នុងតំបន់គ្រុនចាញ់ប្រមាណ ៨១% បានទទួលសេវាព្យាបាលនិងមុងជ្រលក់ថ្នាំកម្ចាត់សត្វល្អិត នៅឆ្នាំ ២០០៧។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១៩.៣.៣. កង្វះអាហារូបត្ថម្ភ

សន្តិសុខស្បៀងនិងរបបអាហារក៏មានផលប៉ះពាល់ទៅលើស្ថានភាពសុខភាពរបស់ប្រជាជនក្រីក្រ។ ស្ទើរតែពាក់កណ្តាលនៃកុមារកម្ពុជាទទួលទានអាហារមិនគ្រប់គ្រាន់ កុមារទាំងនោះ ១ ភាគ ៨ ស្លាប់មុនអាយុ៥ ឆ្នាំ ភាគច្រើនស្លាប់ដោយសារជម្ងឺដែលអាចជៀសវាងបាន។ ៥០% នៃប្រជាជនកម្ពុជា ១៣ លាននាក់ស្ថិតក្រោមអាយុ ១៨ ឆ្នាំ។ ដើម្បីធានាថាពួកគេនឹងមានសុខភាពល្អ បញ្ហាប្រឈមមួយគឺធានាថាមនុស្សពេញវ័យមានរាងកាយមាំមួនដើម្បីរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់ប្រទេស។

កង្វះអាហារូបត្ថម្ភ ជាមួយនិងឥទ្ធិពលរបស់វាទៅលើប្រព័ន្ធស៊ាំនឹងជម្ងឺ រឹតតែធ្វើឱ្យមានហានិភ័យក្នុងការធ្លាក់ខ្លួនឈឺនិងការឆ្លងរោគ។ រួមផ្សំជាមួយកត្តាផ្សេងៗទៀត កង្វះអាហារូបត្ថម្ភគឺជាបុព្វហេតុនៃការស្លាប់របស់ទារកច្រើនជាងពាក់កណ្តាល។ ដោយហេតុនេះហើយ ទើបរដ្ឋាភិបាលជាមួយនឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូទ្វេភាគីនិងពហុភាគីបានសន្យា លើកកម្ពស់សន្តិសុខស្បៀងសម្រាប់ប្រជាជនកម្ពុជាទាំងនៅក្នុងសហគមន៍ជនបទនិងទីក្រុង ដោយប្រើកម្មវិធីជាក់លាក់ដើម្បីលើកកម្ពស់របបអាហារបំប៉នសុខភាពសម្រាប់ម្តាយនិងទារក។

កង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារអាយុ ៥ ឆ្នាំនៅតែជាបញ្ហាសុខភាពសាធារណៈមួយ។ ទោះជាយ៉ាងណា ស្ថានភាពកង្វះអាហារូបត្ថម្ភរបស់កុមារមានភាពប្រសើរឡើងក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅនេះ។ បច្ចុប្បន្ន កុមារ ៣៧% មានភាពគ្រិននិង ៧% មានភាពស្គមស្គាំង បើប្រៀបធៀបជាមួយនឹង ៤៥% នៃកុមារមានភាពគ្រិននិង ១៥% មានភាពស្គមស្គាំងក្នុងឆ្នាំ ២០០០ (អង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ឆ្នាំ ២០០៥)។ ជាទូទៅ ភាពគ្រិនបានរកឃើញក្នុងខេត្តពោធិ៍សាត់ (៦២%) និងឃើញមានតិចបំផុតក្នុងទីក្រុងភ្នំពេញ (២២%)។ ស្ត្រីក៏ទទួលរងពីភាពខ្វះខាតអាហារូបត្ថម្ភដែរ។ ស្ត្រី ៥៧% មានរោគសញ្ញាជម្ងឺស្លេកស្លាំង (ខ្វះឈាម)។ ស្ត្រីកម្ពុជាអាយុពី ១៥ ទៅ ៤៩ ឆ្នាំចំនួន ២០% ត្រូវបានចាត់ទុកមានភាពស្គមស្គាំងខណៈដែល ១០% ទៀតលើសទម្ងន់។

### ១៩.៣.៤. លទ្ធភាពទទួលបានសេវាថែទាំសុខភាព

ជារួម វិសាលភាពនៃសេវាថែទាំសុខភាពមូលដ្ឋាន ក្នុងតំបន់ដាច់ស្រយាលមានភាពប្រសើរឡើង ប៉ុន្តែដំណើរការប្រព្រឹត្តទៅមានភាពយឺតយ៉ាវ។ ចំនួនមណ្ឌលសុខភាពដែលមានបុគ្គលិកមានសមត្ថភាពនិងឧបករណ៍គ្រប់គ្រាន់បានកើនពី ៦៧៨ កន្លែងក្នុងឆ្នាំ ២០០០ ដល់ ៦៧៨ កន្លែងក្នុងឆ្នាំ ២០០៧។ ប៉ុន្តែក្នុងចំណោមមណ្ឌលសុខភាព ៩៩១ កន្លែងក្នុងប្រទេសមានតែ ៨២% តែប៉ុណ្ណោះដែលអាចផ្តល់ការគាំពារជាមូលដ្ឋាននិងផ្តល់ជូននូវកញ្ចប់សកម្មភាពអប្បបរមា។ បច្ចុប្បន្ននេះ មន្ទីរពេទ្យស្រុកចំនួន ១០ កន្លែង (ក្នុងចំណោម ១៧១ កន្លែង) កំពុងដំណើរការករណីវះកាត់មានភាពស្មុគស្មាញ ប្រហាក់ប្រហែលនឹងសេវានៅមន្ទីរពេទ្យឯកទេសដែរ។ ចំនួននេះមិនទាន់គ្រប់គ្រាន់សម្រាប់តំបន់ដាច់ស្រយ៉ាលរបស់ប្រទេសកម្ពុជាទេ។ ជាងនេះទៅទៀត ប្រជាជនរស់នៅក្នុងរង្វង់ ១០ គីឡូម៉ែត្រពីមណ្ឌលសុខភាពសាធារណៈតិចជាង ៥៥% អាចពន្យល់បានពីហេតុផលដែលមណ្ឌលសុភាពទាំងនេះមិនត្រូវបានប្រើប្រាស់ដោយប្រជាជនក្រីក្រ។

ប្រព័ន្ធសុខាភិបាលបានឈានទៅដល់កុមារកាន់តែច្រើន។ មណ្ឌលសុខភាពដែលកំពុងអនុវត្តការគ្រប់គ្រងរួមបញ្ចូលគ្នានៃជម្ងឺកុមារ (IMCI) បានកើនឡើងពី ៤៥៦ កន្លែងក្នុងឆ្នាំ ២០០៦ ទៅដល់ ៥៣៣ កន្លែងក្នុងឆ្នាំ ២០០៧។ ក្នុងចន្លោះឆ្នាំ ២០០៦-២០០៧ កម្មវិធីជាច្រើនបានកើតមានឡើងដូចជា

ការការពារកុមារអាយុក្រោម ៣ ឆ្នាំ ពីបញ្ហាកង្វះអាហារូបត្ថម្ភមីក្រូសារជាតិ ការបង្កើតភាពសាំពេញលេញ (បីដង) សម្រាប់ជម្ងឺខាន់ស្លាក់ ខ្អកមាន់ និងតេតាណូស (DPT3) បានកើនពី ៨០% ទៅដល់ ៨២% និងការចាក់វ៉ាក់សាំងបង្ការជម្ងឺកញ្រ្ជិលបានកើនពី ៧៨% ទៅដល់ ៧៩%។ វិសាលភាពនៃការផ្តល់គ្រាប់ថ្នាំវីតាមីន "អា" សម្រាប់កុមារអាយុ ៦ ដល់ ៥៩ ខែបានកើនឡើងពី៧៨% ក្នុងឆ្នាំ ២០០៦ ទៅដល់ ៨៦% ក្នុងឆ្នាំ ២០០៧។

មណ្ឌលសុខភាពសាធារណៈភាគច្រើន ត្រូវបានប្រើប្រាស់ក្នុងតំបន់ជនបទនិងទីប្រជុំជន។ មណ្ឌលសុខភាពក្នុងតំបន់ជនបទទំនងជាត្រូវបានប្រើប្រាស់ទ្វេដង សម្រាប់ការព្យាបាលលើកដំបូងជាងមណ្ឌលសុខភាពក្នុងតំបន់ប្រជុំជន (១៥% ទល់នឹង ៨%)។ ទោះជាយ៉ាងណា កត្តានានាដែលរារាំងការប្រើប្រាស់សេវាថែទាំសុខភាពសាធារណៈ រួមមាន ៖ មណ្ឌលសុខភាពមានទីតាំងនៅឆ្ងាយពេក គ្មានផ្លូវតភ្ជាប់ពីភូមិទៅមណ្ឌលសុខភាពចំណាយក្នុងការធ្វើដំណើរខ្ពស់(ការដឹកជញ្ជូននិងពេលវេលា)ថ្លៃសេវាកម្មខ្ពស់ជាពិសេសថ្នាំសង្កូវនិងការស្នាក់នៅក្នុងមន្ទីរពេទ្យ នីតិវិធីទទួលបានបន្ទុកចំណាយត្រឡប់មានភាពស្មុគ្រស្មាញ កង្វះបុគ្គលិកមានសមត្ថភាពក្នុងមណ្ឌលសុខភាព និងហេដ្ឋារចនាសម្ព័ន្ធមិនល្អ។ ឱសថស្ថានឯកជនទំនងជាត្រូវបានប្រើប្រាស់ច្រើន សម្រាប់ការព្យាបាលដំបូងក្នុងតំបន់ប្រជុំជនជាងតំបន់ជនបទ (២៥% ទល់នឹង ៧%)។ ជាទូទៅ បុគ្គលិកពេទ្យនិងគិលានុបដ្ឋាយិកាដែលមានការបណ្តុះបណ្តាល ត្រូវបានគេស្វះស្វែងរកសម្រាប់ការព្យាបាលដំបូង នៅតាមតំបន់ជនបទ ជាងនៅតាមតំបន់ប្រជុំជន (អង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជាឆ្នាំ២០០៥)។

ដើម្បីបង្កើនវិសាលភាពនៃសេវាថែទាំសុខភាព អាទិភាពមួយចំនួនត្រូវយកចិត្តទុកដាក់ដូចជា ការពង្រឹងការអនុវត្តកញ្ចប់សកម្មភាពអប្បបរមា (MPA) និងកញ្ចប់សកម្មភាពបំពេញបន្ថែម (CPA) នៅទូទាំងប្រទេស និងការបង្កើតប្រព័ន្ធចែកចាយនិងផ្គត់ផ្គង់ឯកសារ ឱសថ និងឧបករណ៍ឱ្យមានប្រសិទ្ធភាព។ ក្នុងក្របខ័ណ្ឌនៃការពង្រឹងសេវាថែទាំសុខភាពមាតានិងកុមារ (MCH) ការយកចិត្តទុកដាក់នឹងត្រូវផ្តោតលើការអនុវត្តសេវាព្យាបាលជម្ងឺរបស់កុមារ (IMCI) ជាមួយនឹងតុល្យភាពស្មើគ្នារវាងសេវាការពារនិងព្យាបាល។ យន្តការតម្រង់ទិសនឹងត្រូវពង្រឹង ដើម្បីសម្រួលដល់លទ្ធភាពទទួលបានសេវាថែទាំសុខភាព ជាពិសេសអ្នកក្រីក្របំផុត។ រាជរដ្ឋាភិបាលបានកែសម្រួលអង្គភាពនិងស្ថាប័នចាំបាច់មួយចំនួនដូចជា ការធ្វើសមាហរណកម្មកម្មវិធីជាតិមួយចំនួនជាពិសេសនៅថ្នាក់តំបន់និងថ្នាក់ខេត្ត ការអភិវឌ្ឍអភិក្រមមួយផ្អែកលើគុណភាពនិងអន្តរាគមន៍តាមការចាំបាច់ និងការលើកស្ទួយទាំងវិស័យឯកជននិងការចូលរួមពីសហគមន៍មូលដ្ឋាន ក្នុងការកសាងផែនការនិងអនុវត្តការថែទាំព្យាបាល។

នៅក្នុងបរិបទនៃការផ្លាស់ប្តូរអាកប្បកិរិយានិងការទំនាក់ទំនង ការយកចិត្តទុកក្នុងការពង្រឹងក្រមសីលធម៌សម្រាប់បុគ្គលិកសុខាភិបាលគឺជាកិច្ចការសំខាន់។ ការបណ្តុះបណ្តាលស្តីពីការទំនាក់ទំនង ជាពិសេសការទំនាក់ទំនងជាមួយក្រុមគោលដៅ (ដូចជា ម្តាយ កុមារ និងក្មេងជំទង់) នឹងត្រូវធ្វើឡើង ដើម្បីលើកកម្ពស់គុណភាពសេវាសុខភាព សម្រាប់សមាសភាព MCH និងសម្រាប់មនុស្សវ័យក្មេង។ ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាសម្រាប់ទាំងអស់គ្នា ជាពិសេសអ្នកក្រីក្របំផុតនោះ ការកសាងភាពជឿជាក់របស់អ្នកប្រើប្រាស់សេវាថែទាំសុខភាពគឺជារឿងសំខាន់ តាមរយៈការជូនដំណឹងដល់អ្នកទាំងនោះអំពី វិសាលភាពសេវាសុខាភិបាលនៅក្នុងតំបន់រស់នៅរបស់ពួកគេ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីលើកកម្ពស់គុណភាពសេវាសុខាភិបាលទូទាំងវិស័យ សកម្មភាពជាអាទិភាពមានដូចជា ការរៀបចំ ការអនុវត្ត និងការប្រើប្រាស់យន្តការទទួលស្គាល់គុណភាពសម្រាប់បុគ្គលិក និងស្ថាប័នសុខាភិបាល។ ការធានានូវការចូលរួមពីសំណាក់ក្រុមអ្នកប្រើប្រាស់ ក្នុងការផ្តួចផ្តើមលើកកម្ពស់គុណភាព ដែលនឹងក្លាយជា សមាសធាតុយុទ្ធសាស្ត្រដ៏សំខាន់មួយដើម្បីពង្រឹងសេវាថែទាំសុខភាព។ ការផ្តល់ប្រាក់លើកទឹកចិត្តផ្អែកលើគុណសម្បត្តិ (MBPI) និងក្រុមការងារអាទិភាព (PMG) ធ្លាប់បានអនុវត្តក្នុងវិស័យសុខាភិបាល ដើម្បីផ្តល់ការលើកទឹកចិត្តដល់អ្នកបម្រើការសុខាភិបាល។

ការលើកទឹកចិត្តក្នុងក្រុមការងារ ជាពិសេសការបង្កើតយន្តការគ្រប់គ្រងវិន័យ និងរង្វាន់គឺជាអាទិភាពមួយ។ ជម្រើសមួយដែលរដ្ឋាភិបាលនឹងពិចារណានោះគឺ ការផ្តល់ប្រាក់រង្វាន់ទៅដល់បុគ្គលិកដែលស្ម័គ្រចិត្តបម្រើការនៅតំបន់ដាច់ស្រយាល ក៏ដូចជាការកែសម្រួលបរិក្ខារបណ្តុះបណ្តាល ដើម្បីឱ្យសម្រេចបាននូវតម្រូវការរបស់ប្រជាជនរស់នៅក្នុងតំបន់ដាច់ស្រយាល។ យុទ្ធសាស្ត្រពន្លឿនក្នុងការពង្រាយឆ្មបទៅកាន់តំបន់ជនបទនិងតំបន់ដាច់ស្រយាល នឹងត្រូវសិក្សា។

## ១៩.៤. ហិរញ្ញប្បទានសម្រាប់ប្រព័ន្ធថែទាំសុខភាព

ដើម្បីធានាបានការអនុវត្តគោលនយោបាយសុខភាព រាជរដ្ឋាភិបាលនឹងបង្កើនការបែងចែកថវិកាសម្រាប់វិស័យសុខាភិបាលនិងបន្តលើកកម្ពស់ការចូលរួមពីវិស័យឯកជននិងសហគមន៍អន្តរជាតិ ដើម្បីបង្កើនការវិនិយោគក្នុងវិស័យនេះ។ ការកែលម្អការគ្រប់គ្រងនិងការបង្កើនលទ្ធភាពហិរញ្ញវត្ថុសម្រាប់ប្រព័ន្ធសុខភាពសាធារណៈគឺជាចំណុចអាទិភាព។

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីហិរញ្ញប្បទានសុខាភិបាល ២០០៨-២០១៥ ត្រូវបានអនុម័តក្នុងឆ្នាំ២០០៨ ដើម្បីធានាការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាលដំណាក់កាលទីពីរ២០០៨-២០១៥ បានជោគជ័យ។ ក្របខ័ណ្ឌនេះមានគោលបំណងដាក់បញ្ចូលរាល់ទម្រង់ហិរញ្ញប្បទានសម្រាប់វិស័យសុខាភិបាល ដែលមានក្នុងពេលបច្ចុប្បន្ន ឱ្យស្ថិតក្រោមផែនការតែ ១។ ហិរញ្ញប្បទានរបស់ប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសកម្ពុជាមានប្រភពចម្បងៗ ៣ គឺ ៖ រដ្ឋាភិបាល (១២% នៃថវិកាជាតិឬច្រើនជាង ១% នៃផលទុនសរុបក្នុងស្រុក ចំណាយ ៦ ដុល្លារក្នុងមនុស្សម្នាក់ក្នុង ១ ឆ្នាំនៅឆ្នាំ ២០០៧) ការឧបត្ថម្ភពីម្ចាស់ជំនួយ (១០៣ លានដុល្លារអាមេរិក ឬ ចំណាយ ៧ ដុល្លារក្នុងមនុស្សម្នាក់ក្នុង ១ ឆ្នាំនៅឆ្នាំ ២០០៧) និងការបង់ថ្លៃរបស់អ្នកជម្ងឺដោយផ្ទាល់ (២ ភាគ ៣ នៃការចំណាយថ្លៃសុខភាពទាំងអស់ ឬ ចំណាយ ២៥ ដុល្លារក្នុងមនុស្សម្នាក់ក្នុង ១ ឆ្នាំ)។ ការចំណាយក្រៅហោប៉ៅសំដៅទៅលើចំណាយរបស់អ្នកប្រើប្រាស់នៅទីកន្លែងសាធារណៈឬវិស័យឯកជន។ ការសម្រេចបានវត្ថុបំណងនៃការថែទាំសុខភាពថ្នាក់ជាតិ តម្រូវឱ្យមានធនធាននិងកិច្ចសហប្រតិបត្តិការ ខ្លាំងក្លារវាងអាជ្ញាធរជាតិ អង្គការពហុភាគី ប្រទេសផ្តល់ជំនួយ សហគមន៍ វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងៗ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីហិរញ្ញប្បទានសុខាភិបាល ២០០៨-២០១៥ ឈរលើម៉ូដែលចម្រុះដូចជា៖ (១) ក្រុមប្រជាជនសម្បូរធនធានចំណាយថវិការបស់ពួកគេលើការព្យាបាលជាលក្ខណៈឯកជនតាមតម្រូវការជាក់លាក់របស់ខ្លួននិងទិញសេវាធានារ៉ាប់រងសុខភាពឯកជន ក្នុងករណីចាំបាច់ (២) មន្ត្រីរាជការ និង និយោជិកក្រុមហ៊ុនឯកជនដែលបម្រើការក្នុងវិស័យការងារផ្លូវការ នឹងត្រូវរ៉ាប់រងដោយកម្មវិធីធានារ៉ាប់រងសុខភាពសង្គម (៣) ក្រុមប្រជាជនមានធនធានមធ្យម (ប្រជាជនរស់នៅពីលើបន្ទាត់នៃភាពក្រីក្របន្តិច) នឹងការពារខ្លួនពួកគេ តាមរយៈការធានារ៉ាប់រងសុខភាពតាមសហគមន៍ (CBHI) និង (៤) ប្រជាជនក្រីក្របំផុត (ប្រជាជន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ) និងត្រូវបានការពារ តាមរយៈវិធានការគាំពារសង្គមមួយចំនួនរួមមានការលើកលែងមិនយកប្រាក់ មូលនិធិសមភាពសុខភាព (HEF) និងការឧបត្ថម្ភធនផ្សេងៗសម្រាប់ការចំណាយថៃទាំសុខភាព ដូចជាកម្មវិធីសក្ខីបត្រយល់ព្រមជាដើម។ ក្របខណ្ឌនេះមានវត្ថុបំណងជាយុទ្ធសាស្ត្រដូចជា ៖ (១) បង្កើនថវិការដ្ឋាភិបាលនិងបង្កើនប្រសិទ្ធភាពក្នុងការបែងចែកធនធានសម្រាប់វិស័យសុខាភិបាល (២) តម្រឹមរាល់មូលនិធិរបស់ម្ចាស់ជំនួយជាមួយនឹងយុទ្ធសាស្ត្រផែនការ និងអាទិភាពរបស់ក្រសួងសុខាភិបាល និងពង្រឹងកិច្ចសម្របសម្រួលមូលនិធិម្ចាស់ជំនួយសម្រាប់ផ្នែកសុខាភិបាល (៣) បំបាត់នូវឧបសគ្គផ្នែកហិរញ្ញវត្ថុនៅក្នុងការរៀបចំនិងដំណើរការយន្តការកិច្ចគាំពារសុខភាពសង្គម (៤) ប្រើប្រាស់ធនធានវិស័យសុខាភិបាលប្រកបដោយប្រសិទ្ធភាពនៅកម្រិតផ្តល់សេវា និង(៥) លើកកម្ពស់ការផលិតនិងការប្រើប្រាស់ព័ត៌មាននិងភស្តុតាងក្នុងការអភិវឌ្ឍគោលនយោបាយហិរញ្ញប្បទានវិស័យសុខាភិបាល។

## ១៩.៤.១. ការចំណាយរបស់រាជរដ្ឋាភិបាលលើផ្នែកសុខភាព

បប្រសិទ្ធផលរបស់ប្រព័ន្ធថៃទាំសុខភាព អាស្រ័យទៅលើការផ្តល់ហិរញ្ញប្បទានឱ្យបានគ្រប់គ្រាន់។ ការចំណាយសាធារណៈសម្រាប់ការថៃទាំសុខភាពបានកើនឡើងយ៉ាងខ្លាំងពោលគឺ ច្រើនជាង ៥ ដងក្នុងអំឡុងពេលមួយទសវត្សរ៍កន្លងទៅ ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំប្រហែល ៥៤% ស្មើនឹងទឹកប្រាក់ ៤០៥ ពាន់លានរៀលក្នុងឆ្នាំ ២០០៨ បើប្រៀបធៀបទៅនឹងឆ្នាំ ១៩៩៩ មានតែ ៧៥ ពាន់លានរៀល។ ធៀបជាមួយនឹងផលទុនក្នុងស្រុកសរុប ចំណាយសាធារណៈសម្រាប់ផ្នែកសុខភាពបានកើនពី 0.៤% ក្នុងឆ្នាំ ១៩៩៨ ដល់១.0៨% ក្នុងឆ្នាំ ២០០៨។ គិតជាចំណាយក្នុងមនុស្សម្នាក់វិញ ចំណាយបានកើនពី ១ ដុល្លារក្នុងឆ្នាំ ១៩៩៨ ដល់ ៣ ដុល្លារក្នុងឆ្នាំ ២០០៣ និងកើនដល់ ៦ ដុល្លារក្នុងឆ្នាំ ២០០៨។ ថវិកាវិស័យសុខាភិបាលប្រមាណ ២៧% ត្រូវបានបែងចែកទៅឱ្យមន្ទីរសុខាភិបាលខេត្ត (PHD)។

រដ្ឋាភិបាលមានគោលបំណងសម្រេចឱ្យបានសេណារីយ៉ូករណីខ្ពស់ ក្នុងការផ្តល់មូលនិធិដល់វិស័យសុខាភិបាល។ សូម្បីតែនៅក្នុងករណីទាបនោះ អាទិភាពខ្ពស់បំផុតគឺត្រូវលើកកម្ពស់វិសាលភាពនិងគុណភាពនៃសេវាកម្មក្នុងតំបន់ដាច់ស្រយាល។ សមាភាពក្នុងការផ្តល់ជូនការថៃទាំសុខភាពបឋម គឺជាបញ្ហាសំខាន់មួយទៀត។ ដើម្បីសម្រេចឱ្យបានករណីនេះ ការសិក្សាអំពីបញ្ហានានាដែលនាំទៅរកវិសមភាពក្នុងការទទួលបាននិងការប្រើប្រាស់សេវាសុខាភិបាលនឹងត្រូវធ្វើឡើង រួមទាំងកំណត់អំពីក្រុមប្រជាជនជួបការលំបាកផងដែរ

ក្នុងឆ្នាំ ២០០០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់ធនធានហិរញ្ញវត្ថុបំពេញបន្ថែមមួយចំនួនដើម្បីការអនុវត្តកម្មវិធីសកម្មភាពអាទិភាព (PAP) សម្រាប់សកម្មភាពថៃទាំសុខភាពក្នុងខេត្ត ក្រុងចំនួន ៧ និងកម្មវិធីថ្នាក់ជាតិចំនួន ៨។ ធនធានក៏ត្រូវបានបែងចែកដល់ស្រុកចំនួន ៣២ ដើម្បីលើកស្ទួយការថៃទាំសុខភាព ដែលស្ថិតក្រោមកម្មវិធីពន្លឿនការអភិវឌ្ឍស្រុក (ADD)។

រូបភាព ១៩.១. ការចំណាយសម្រាប់ការថែទាំសុខភាព (គិតជាពាន់លានរៀល)




*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ប្រជាជនកម្ពុជា ៩០% រស់នៅតាមខេត្ត ដែលនៅទីនោះមន្ទីរសុខាភិបាលខេត្តទទួលថវិកា ៩៥% នៃថវិកាសុខាភិបាលសរុប ទោះបីមានស្ថានភាពអំណោយផលជាច្រើនដែលប្រជាជនទទួលបានក៏ដោយ។ នៅកម្រិតផ្តល់សេវាសុខាភិបាលស្រុកប្រតិបត្តិការទទួលបាន៧%មន្ទីរពេទ្យបង្អែក២៦%និងមណ្ឌលសុខភាព ៣២% នៃថវិការដ្ឋសម្រាប់វិស័យសុខាភិបាល។

ចំណាយលើប្រាក់បៀវត្សស្ថិតក្រោម ១២% នៃចំណាយចរន្តរបស់រដ្ឋាភិបាលសម្រាប់វិស័យសុខាភិបាល។ ប្រាក់បៀវត្សទាបបណ្តាលឱ្យបុគ្គលិករដ្ឋមួយចំនួនបម្រើការនៅក្នុងវិស័យឯកជន។ ជាងនេះទៅទៀត ថវិកាមួយភាគធំដែលបែងចែកសម្រាប់ការថែទាំសុខភាពនោះ ត្រូវបានបញ្ចេញក្នុងខែធ្នូតែប៉ុណ្ណោះ ដោយសារតែនីតិវិធីលទ្ធកម្មសាធារណៈសម្រាប់ទិញឱសថមានការយឺតយ៉ាវ។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តផ្អែកលើស្នាដៃការងារ និងក្រុមបេសកកម្មអាទិភាព ដើម្បីផ្តល់ការលើកទឹកចិត្តបន្ថែមទៀតទៅដល់បុគ្គលិកសុខាភិបាល ជាពិសេសបុគ្គលិកដែលបម្រើការនៅតំបន់ជនបទ។

រដ្ឋាភិបាលមានការបារម្ភយ៉ាងខ្លាំងចំពោះការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង។ ដើម្បីបញ្ឈប់លំហូរចេញនៃប្រជាជននៅជនបទ ការផ្តួចផ្តើមដ៏សំខាន់មួយគឺត្រូវលើកកម្ពស់បរិក្ខារសុខាភិបាលនៅតំបន់ជនបទ។ តាមរយៈ ការបង្កើនប្រាក់ខែនិងការដាក់ឱ្យអនុវត្តប្រព័ន្ធផ្តល់ប្រាក់រង្វាន់តាមតំបន់ភូមិសាស្ត្រសម្រាប់ការបម្រើការនៅតំបន់ជួបការលំបាកនិងក្នុងចំណោមសហគមន៍ដែលងាយរងគ្រោះ នោះការផ្តល់សេវាសុខាភិបាលដល់អ្នកក្រីក្រអាចនឹងត្រូវបានលើកកម្ពស់។

យុទ្ធសាស្ត្រផ្តល់ការលើកទឹកចិត្តផ្សេងៗដើម្បីលើកកម្ពស់ការផ្តល់សេវាសុខាភិបាល រួមមានអត្ថប្រយោជន៍មិនមែនហិរញ្ញវត្ថុ ដូចជា ការបណ្តុះបណ្តាលនៅពេលកំពុងបម្រើការនិងកាលានុវត្តភាពសម្រាប់ការឡើងតំណែងនិងការផ្ទេរតំណែង។ ការជ្រើសរើសនិងបណ្តុះបណ្តាលធនធានមនុស្សដែលរស់នៅក្នុងតំបន់ដាច់ស្រយាល និងយល់ព្រមបម្រើការនៅក្នុងតំបន់ស្រុកកំណើតរបស់ពួកគេ ក៏ជាជម្រើសមួយដ៏ល្អផងដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អំឡុងឆ្នាំ ២០០៤-២០០៨ រដ្ឋាភិបាលបានផ្ដោតការយកចិត្តទុកដាក់ជាខ្លាំង លើកំណែទម្រង់វិស័យសុខាភិបាល។ ការផ្ដួចផ្ដើមដ៏សំខាន់មួយគឺ ការធ្វើវិមជ្ឈការធនធាននិងដំណើរការធ្វើការសម្រេចចិត្តនៅថ្នាក់ស្រុក។ ការចូលរួមរបស់ប្រជាជននៅមូលដ្ឋានក្នុងការកសាងផែនការនិងការផ្ដល់សេវាថែទាំសុខភាពនោះ នឹងធានាបានថាសេវាសុខាភិបាលបានផ្អែកទៅលើតម្រូវការ និងអ្នកផ្ដល់សេវាមានការទទួលខុសត្រូវចំពោះប្រជាជនដែលមកទទួលសេវាទាំងនេះ។

ប្រព័ន្ធប្រាក់បៀវត្ស ប្រាក់កម្រៃ និងកិច្ចសន្យាបម្រើការងារ ដែលផ្សារភ្ជាប់ទៅនឹងការបំពេញការងារ និងការគ្រប់គ្រងផ្អែកលើលទ្ធផល ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ ២០០០ មក។ កិច្ចសន្យាបម្រើការងារគឺជា កិច្ចព្រមព្រៀងរវាងក្រសួងសុខាភិបាល និងមន្ទីរពេទ្យស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ដែលជាអ្នកផ្ដល់សេវាសុខាភិបាល។ កិច្ចសន្យាទាំងនេះបានកំណត់នូវវត្ថុបំណងនិងផលសម្រេចរំពឹងទុក សម្រាប់អំឡុងពេលណាមួយ។ កិច្ចសន្យាទាំងនេះត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានអាទិភាពដែលត្រូវបានកំណត់នៅកម្រិតគោលនយោបាយ បេសសកម្មរបស់អង្គការមិនមែនរដ្ឋាភិបាល និងពិដានថវិកា។

### ១៩.៤.២. ការចំណាយផ្នែកសុខភាពដែលផ្ដល់ពីដៃគូអភិវឌ្ឍ

ចំណាយសម្រាប់ការថែទាំសុខភាព ដែលជាបន្ទុករបស់ជំនួយអន្តរជាតិមានប្រហែល ៧ ដុល្លារក្នុងមនុស្សម្នាក់ក្នុង ១ ឆ្នាំ និងបានកើនឡើងពី ៤ ដុល្លារតាំងពីឆ្នាំ ២០០៣។ សរុបមក ការចំណាយផ្នែកសុខភាពក្នុងមនុស្សម្នាក់ ដែលត្រូវបានផ្ដល់ហិរញ្ញវត្ថុដោយរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍបានកើនដល់ ១៣ដុល្លារអាមេរិក។

ទោះបីជា ការបែងចែកថវិការបស់រដ្ឋាភិបាលមានការកើនឡើងខ្ពស់ នាពេលថ្មីៗនេះក៏ដោយក៏វិស័យថែទាំសុខភាពនៅតែមានការខ្វះខាតផ្នែកហិរញ្ញវត្ថុដដែល។ សមត្ថភាពក្នុងការផ្ដល់ថវិកាដល់វិស័យថែទាំសុខភាពពាក់ព័ន្ធនឹង ភាពជោគជ័យក្នុងការកៀរគរធនធាន ការកែលម្អប្រសិទ្ធភាពក្នុងការបែងចែកធនធាន និងលទ្ធភាពជំនួយបរទេសសម្រាប់វិស័យនេះ។ ហេតុដូចនេះ កម្ពុជាត្រូវបានចាត់ទុកថាមានភាពពឹងផ្អែកខ្ពស់ទៅលើមូលនិធិដៃគូអភិវឌ្ឍសម្រាប់ការថែទាំសុខភាព ដែលឈានដល់ ១០៣ លានដុល្លារក្នុងឆ្នាំ ២០០៧។

ជាលទ្ធផលនៃភាពពឹងផ្អែកនេះ យន្តការហិរញ្ញវត្ថុផ្នែកសុខាភិបាលជាច្រើនបានលេចចេញឡើង៖ មូលនិធិដៃគូ មូលនិធិដៃគូជាកញ្ចប់ (គម្រោងគាំទ្រវិស័យសុខាភិបាល និង SwiM) កម្រៃបានពីអ្នកជម្ងឺនៅតាមគ្រឹះស្ថានសាធារណ: ការលើកលែងមិនយកកម្រៃសម្រាប់អ្នកក្រីក្រ ការចុះកិច្ចសន្យានៃការផ្ដល់ជូនសាធារណ: (កិច្ចសន្យាជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬកិច្ចសន្យាជាមួយមន្ទីរពេទ្យបង្អែកនៅតាមខេត្ត) មូលនិធិសមធម៌សុខភាព ការធានារ៉ាប់រងសុខភាពតាមសហគមន៍ និងការស្នើសុំគម្រោងសម្រាប់កម្មវិធីធានារ៉ាប់រងសុខភាពសង្គមដទៃទៀត។

### ១៩.៤.៣. មូលនិធិសមធម៌សុខភាព

គ្រួសារកម្ពុជាទទួលរងបន្ទុកជាទម្ងន់ទៅលើការចំណាយផ្នែកសុខភាព ដោយការចំណាយថែទាំសុខភាពដែលគ្រួសារនានាបានជួបប្រទះនោះត្រូវបានប៉ាន់ស្មានថាអស់ប្រហែល ២៥ ដុល្លារក្នុង ១ ឆ្នាំ ដែលនាំ ឱ្យការចំណាយសរុបផ្នែកសុខភាពក្នុងប្រទេសកម្ពុជាឈានដល់ ៣៨ ដុល្លារក្នុងមនុស្សម្នាក់ក្នុង ១ ឆ្នាំ។ ក្នុងថវិកាចំណាយ ២៥ ដុល្លារនោះ មានតែ ០,៨ ដុល្លារប៉ុណ្ណោះដែលចំណាយលើវិស័យសុខាភិបាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាធារណៈ។ ដូច្នេះប្រសិនបើមានករណីធ្ងន់ធ្ងរណាមួយ ដែលតម្រូវឱ្យមានការចំណាយទឹកប្រាក់យ៉ាងច្រើនលើការព្យាបាលនោះ អ្នកក្រីក្រពុំមានអ្វីមួយពឹងផ្អែកឡើយ ក្រៅតែពីការលក់ទ្រព្យសម្បត្តិតិចតួច ដែលពួកគេមានរួមទាំង ដីធ្លីផងដែរ ដែលរឹតតែធ្វើឱ្យពួកគេកាន់តែដុនដាបមួយកម្រិតថែមទៀត។ គេប៉ាន់ប្រមាណថា ២៦% នៃអ្នកជម្ងឺត្រូវខ្ចីប្រាក់គេ ឬលក់ទ្រព្យសម្បត្តិ ដើម្បីបង់ថ្លៃចំណាយលើការព្យាបាល។

ដើម្បីបំពេញបន្ថែមដល់ការចំណាយផ្នែកសុខភាពសាធារណៈ ចាប់ពីឆ្នាំ ២០០០ មក មណ្ឌលសុខភាពសាធារណៈបានធ្វើការប្រមូលកម្រៃពីអ្នកជម្ងឺ។ កត្តានេះបានជះឥទ្ធិពលដល់ការកាត់បន្ថយលទ្ធភាពទទួលបានសេវាសុខភាពសាធារណៈរបស់អ្នកក្រីក្រ ។ ដើម្បីដោះស្រាយបញ្ហានេះ មូលនិធិសមធម៌សុខភាពត្រូវបានធ្វើការសាកល្បង ដើម្បីផ្តល់ជូនអ្នកក្រីក្រនូវការលើកលែងមិនយកកម្រៃ។ តាំងពីឆ្នាំ ២០០៥ មកមូលនិធិនេះបានទទួលការឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍និងរដ្ឋាភិបាល ខណៈដែលអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានចុះកិច្ចសន្យាដើម្បីត្រួតពិនិត្យកម្មវិធីលើកលែងមិនយកកម្រៃពីអ្នកជម្ងឺ។ ប្រព័ន្ធស្តីពីអត្តសញ្ញាណកម្មក្រីក្រ ត្រូវបានយកមកប្រើប្រាស់ដើម្បីសម្របសម្រួលកិច្ចការនេះ។ ក្នុងឆ្នាំ ២០០៧ ប្រជាជនកម្ពុជាប្រហែល ១,៣ លាននាក់ ត្រូវបានលើកលែងមិនយកកម្រៃ នៅតាមមណ្ឌលសុខភាពសាធារណៈនានា។

បច្ចុប្បន្ននេះ អត្ថប្រយោជន៍នៃការថែទាំសុខភាពមិនសូវបានទៅដល់ឱ្យអ្នកក្រីក្រប៉ុន្មានទេ។ ក្រុមប្រជាជនមានជីវភាពមធ្យមទទួលបានចំណែកអត្ថប្រយោជន៍ច្រើនជាងគេ។ ប្រជាជនក្រីក្របំផុត ៤០% ប្រើប្រាស់អស់តែ ៣០% ចំណាយសាធារណៈសម្រាប់ការថែទាំសុខភាព។ ការលើកកម្ពស់ប្រសិទ្ធផលនៃប្រព័ន្ធសុខាភិបាលអាស្រ័យនឹងការបង្កើនប្រាក់បៀវត្សបុគ្គលិក ការលើកលែងមិនយកកម្រៃប្រឹក្សាយោបល់ចំពោះសម្រាប់ ៣០% នៃប្រជាជនរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ និងការផ្តល់អាទិភាពថវិកាសម្រាប់ការលើកកម្ពស់បរិក្ខារសុខភាពនៅតាមមូលដ្ឋាន។

### ១៩.៤.៤. អ្នកផ្តល់សេវាសុខភាពឯកជន

កំណើននៃការវិនិយោគវិស័យឯកជន ក្នុងហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាពបានធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការថែទាំក្នុងប្រទេស ជាពិសេសក្នុងវិស័យថ្នាក់ឧត្តម (មន្ទីរពេទ្យនិងមន្ទីរព្យាបាលឯកទេសជាន់ខ្ពស់)។ វិស័យឯកជនផ្តល់នូវលក្ខខណ្ឌការងារនិងប្រាក់បៀវត្សដែលមានភាពទាក់ទាញជាង ប៉ុន្តែកត្តានេះរឹតតែធ្វើឱ្យអាក្រក់ទៅ នូវការខ្វះខាតបុគ្គលិកថែរក្សានិងព្យាបាលក្នុងគ្រឹះស្ថានវិស័យឯកជននិងក្នុងសហគមន៍ជនបទនានាដែលជាទីពំនឹងតែមួយគត់ដែលមានចំពោះអ្នកក្រ។

បទប្បញ្ញត្តិរបស់សេវាកម្មក្នុងវិស័យឯកជនឱសថស្ថាននិងមន្ទីរព្យាបាលត្រូវបានពង្រឹង ដើម្បីធានាបាននូវការគោរពទៅតាមច្បាប់ដែលបច្ចុប្បន្នកំពុងមាននិងប្រើប្រាស់។ ទោះបីជាមានបទបញ្ញានេះក៏ដោយ ចំនួនឱសថស្ថាននិងមន្ទីរព្យាបាលដែលកំពុងប្រតិបត្តិការដោយខុសច្បាប់នៅតែមានកម្រិតខ្ពស់។ គេប៉ាន់ស្មានថាបច្ចុប្បន្នមានទីតាំង១,៨៧៦កន្លែងដែលកំពុងផ្តល់សេវាកម្មសុខាភិបាលឯកជន រួមមានការថែរក្សាព្យាបាលការថែរក្សាធ្មេញការធ្វើតេស្តឈាមនិងការវះកាត់កែសម្ផស្ស។ ប្រហែល៨០%នៃមន្ទីរព្យាបាលទាំងនេះកំពុងធ្វើប្រតិបត្តិការដោយខុសច្បាប់។ មានមន្ទីរព្យាបាលឯកជនទាំងអស់ចំនួន១១៤កន្លែងដែលមានគ្រែសរុបចំនួន៥០០គ្រែ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី ៧
# ហិរញ្ញវត្ថុសាធារណៈ

ជំពូកទី ២០.ប្រព័ន្ធពន្ធដារ

ជំពូកទី ២១.ថវិការដ្ឋ

# ជំពូកទី ២០
# ប្រព័ន្ធសារពើពន្ធ

គេអាចប្រមូលពន្ធបាន ទាល់តែមានចែងក្នុងច្បាប់ (មាត្រា ៥៧ និង ៩០ ថ្មីនៃរដ្ឋធម្មនុញ្ញ) ។

«ពន្ធអាករ និងចំណូលសារពើពន្ធផ្សេងៗ ត្រូវកំណត់ដោយច្បាប់ និងត្រូវប្រមូល និងត្រួតពិនិត្យដោយរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អត្រាពន្ធ អាករ មូលដ្ឋានជាប់ពន្ធ ការលើកលែងពន្ធ និង វិវាទដែលទាក់ទងនឹងការកំណត់ការប្រមូល និង ការត្រួតពិនិត្យពន្ធ ត្រូវកំណត់នៅក្នុងក្របខ័ណ្ឌ និងតាមបែបបទដែលមានចែងនៅក្នុងច្បាប់ដែលទាក់ទងដល់ប្រភេទពន្ធ និង អាករនីមួយៗ» (មាត្រា ១៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។

អ្នកជាប់ពន្ធទាំងឡាយត្រូវមានកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ ថ្ងៃក្រោយមានសកម្មភាពសេដ្ឋកិច្ច ។ ជាការអនុវត្ត អ្នកជាប់ពន្ធនៅព្រះរាជាណាចក្រកម្ពុជាមានពីរប្រភេទគឺ អ្នកជាប់ពន្ធ តាម ***របបស្វ័យប្រកាស*** និង អ្នកជាប់ពន្ធតាម ***របបម៉ៅការ*** ។

## ២០.១. របបស្វ័យប្រកាស

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស គឺជានីតិបុគ្គលទាំងឡាយដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា និងបុគ្គលទាំងឡាយ ដែលប្រកបធុរកិច្ចដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៥០០ លានរៀល ឡើងទៅសម្រាប់ការផ្គត់ផ្គង់ទំនិញ ចាប់ពី ២៥០ លានរៀលឡើងទៅសម្រាប់ការផ្គត់ផ្គង់សេវា និងចាប់ពី ១២៥ លានរៀលឡើងទៅសម្រាប់ការធ្វើកិច្ចសន្យាជាមួយរដ្ឋ ។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ ដោយខ្លួនឯង ។ ក្នុងអំឡុងពេលមួយមានកំណត់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសនឹងត្រូវបានទទួលការធ្វើសវនកម្មពីមន្ត្រីសវនកម្មពន្ធដារ ដើម្បីធានាភាពត្រឹមត្រូវនៃការប្រកាសរបស់ខ្លួន ។

នៅចុងឆ្នាំ ២០០៨ មានអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានចំនួន ១២.០៨៩ សហគ្រាស ក្នុងនោះមាន សហគ្រាសជាអ្នកជាប់ពន្ធធំចំនួន ១.១៧១ សហគ្រាសនៅទូទាំងប្រទេស និងអ្នកជាប់ពន្ធមធ្យមចំនួន ៩.១៤៤ សហគ្រាស នៅភ្នំពេញ ១.៧៧៤ នៅតាមខេត្ត-ក្រុងទាំង ២៤ ។ ចំណូលដែលទទួលបានពីអ្នកជាប់ពន្ធទាំងនេះមាន ចំនួនប្រមាណ ៨៥% នៃចំណូលពន្ធដារសរុបដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន ។

ប្រព័ន្ធនេះមានអត្ថប្រយោជន៍ដូចខាងក្រោម ៖

- បុគ្គលមានកាតព្វកិច្ចត្រូវទទួលខុសត្រូវចំពោះព័ត៌មានដែលមាននៅក្នុងប្រតិវេទន៍ពន្ធរបស់ពួកគេ។
- ពួកគេដាក់ស្នើនូវប្រតិវេទន៍ពន្ធរបស់ខ្លួន ដោយស្ម័គ្រចិត្តនិងធ្វើការបង់ពន្ធដែលត្រូវបានគណនាចេញពីព័ត៌មានដែលបានប្រកាសនោះ។
- ការចំណាយផ្នែករដ្ឋបាលត្រូវបានកាត់បន្ថយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

- អាជ្ញាធរពន្ធដារមានពេលវេលាច្រើន ដើម្បីត្រួតពិនិត្យលើមនុស្សដែលត្រូវបង់ពន្ធក្នុងការរំលោភបទប្បញ្ញត្តិ (សកម្មភាពដែលមិនបានប្រកាសឬការប្រើប្រាស់បណ្ដាញគេចពន្ធចាត់តាំងណាមួយ)។

នៅចុងឆ្នាំ២០០៨ ប្រទេសកម្ពុជាមានក្រុមហ៊ុនសរុបចំនួន១១,១៩៦ក្រុមហ៊ុន។ ២,៩៣៣ក្រុមហ៊ុនក្នុងចំណោមនោះគឺជាក្រុមហ៊ុនដែលមានសកម្មភាពខ្នាតតូចខ្នាតមធ្យមនិងខ្នាតធំ (ហើយដែលបានដាក់ជូនប្រតិវេទន៍ពន្ធរបស់ខ្លួនទៅកាន់នាយកដ្ឋានពន្ធដារ)។ ពួកវាត្រូវបានបែងចែកទៅជា១,៧៩៣ក្រុមហ៊ុនជាខ្នាតធំនិង៩,៤០៣ក្រុមហ៊ុនជាខ្នាតតូចនិងមធ្យម។ របបម៉ៅការបច្ចុប្បន្ន កំពុងលាតសន្ធឹងទូទាំងខេត្តទាំងអស់និងស្រុកចំនួន៧ក្នុងទីក្រុងភ្នំពេញ។ ចំណូលដែលចេញពីពន្ធរបស់អ្នក ត្រូវបង់ដែលជួបនឹងរបបម៉ៅការនេះមាន៩០%នៃចំណូលសរុបរបស់នាយកដ្ឋានពន្ធដារចំពោះពន្ធលើប្រាក់ចំណេញផ្នែកឧស្សាហកម្ម។

## ២០.២. របបម៉ៅការ

អ្នកជាប់ពន្ធតាមរបបម៉ៅការ គឺជាអ្នកជាប់ពន្ធតូចៗ ដែលស្ថិតក្រោមកម្រិតអប្បបរមា ដែលត្រូវចុះបញ្ជីជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវបានកំណត់ឱ្យបង់ប្រាក់ពន្ធជាស្ថេរវន្ត ក្នុងរយៈពេលកំណត់ណាមួយ (៣ ខែ ឬ ៦ ខែ) នៃឆ្នាំប្រតិទិន ។ នៅក្នុងរបបនេះ មានសហគ្រាសចំនួន ៩៨.៥១០ ។ ចំណូលពន្ធ ដែលប្រមូលបានពីសហគ្រាសតាមរបបម៉ៅការមានប្រមាណ ១៥% នៃចំណូលពន្ធ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន។ នៅក្នុងប្រព័ន្ធនេះ អគ្គនាយកដ្ឋានពន្ធដារផ្ទាល់បានរៀបចំមូលដ្ឋានត្រូវបង់ពន្ធ ស្របតាមបញ្ជីទាំងឡាយដែល ប្រគល់មកដោយការប៉ាន់ប្រមាណ ។ ជាក់ស្តែងណាស់ដែលថាប្រព័ន្ធនេះ នឹងត្រូវចំណាយច្រើន ដើម្បីគ្រប់គ្រងអោយបានប្រសើរឡើង។

## ២០.៣. ប្រភេទពន្ធ និង អាករ

យើងអាចធ្វើចំណាត់ថ្នាក់ពន្ធ ទៅតាមភ្នាក់ងារសេដ្ឋកិច្ច ដែលត្រូវបង់ពន្ធទាំងនោះដូចខាងក្រោម ៖

- ភ្នាក់ងារទាំងឡាយ ដែលយកពន្ធនៅលើទីផ្សារកត្តា ឬ ទីផ្សារផលិតកម្ម
- ភ្នាក់ងារទាំងឡាយ ដែលយកពន្ធលើអ្នកទិញ និង អ្នកលក់នៅទីផ្សារ
- ភ្នាក់ងារទាំងឡាយ ដែលយកពន្ធលើគ្រួសារ ឬ សហគ្រាស

យើងអាចធ្វើចំណាត់ថ្នាក់ពន្ធ ទៅតាមការគិតគូរលើប្រភេទពន្ធសំខាន់ៗ ដូចខាងក្រោម ៖

- ពន្ធលើបុគ្គល ដែលអាស្រ័យលើលទ្ធភាពរបស់អ្នកបង់ពន្ធអាចបង់បាន និង តាមឯកតាពន្ធ ឬ ពន្ធលើប្រតិបត្តិការ និងសកម្មភាពនានា ដូចជា ការទិញ លក់ ឬ ការកាន់កាប់ទ្រព្យសម្បត្តិ ។

- ពន្ធផ្ទាល់ និង ពន្ធប្រយោល
- ពន្ធវិជ្ជមាន និង ពន្ធអវិជ្ជមាន

ពន្ធផ្ទាល់ នៅកម្ពុជារួមមាន ៖

- ពន្ធលើប្រាក់ចំណេញ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

• ពន្ធលើប្រាក់បៀវត្ស និង

• ពន្ធលើការជួលទ្រព្យសម្បត្តិ

• ពន្ធលើជំនិះយានយន្ត

• ពន្ធប្រថាប់ត្រា

នៅកម្ពុជាមាន ពន្ធប្រយោល ដូចខាងក្រោម ៖

• ពន្ធលើផលរបរ

• អាករលើតម្លៃបន្ថែម

• អាករពិសេសលើផលិតផលមួយចំនួន

• ពន្ធគយលើការនាំចូល

ការបង្វែរ ឬ ការទូទាត់ជំនួយដោយរដ្ឋាភិបាលអាចចាត់ទុកជាពន្ធអវិជ្ជមាន ដោយសារការបង្វែរផ្តល់ត្រលប់មកវិញជាចំណូលទៅកាន់អង្គភាពនានា ខណៈដែលពន្ធដកយកចំណូលពីអង្គភាពទាំងនោះវិញ។ ឧទាហរណ៍ វិភាគទានសន្តិសុខសង្គម ត្រូវបានគិតជាពន្ធលើប្រាក់ចំណូលអវិជ្ជមាន ហើយឧបត្ថម្ភកធនដល់អាជីវកម្មអាចគិតថាជាពន្ធលើអាជីវកម្មអវិជ្ជមាន ។

បណ្តាពន្ធដែលត្រូវបង់ចូលថវិការដ្ឋ មានដូចតទៅ៖

• ពន្ធលើប្រាក់ចំណេញ

• ពន្ធកាត់ទុក

• ពន្ធអប្បបរមា

• ពន្ធលើប្រាក់បៀវត្ស

• អាករលើតម្លៃបន្ថែម

• អាករពិសេសលើទំនិញនិងសេវាមួយចំនួន

បណ្តាពន្ធដែលត្រូវបង់ចូលថវិកាខេត្ត-ក្រុង មានដូចតទៅ៖

• អាករសម្រាប់បំភ្លឺសាធារណៈ

• អាករលើការស្នាក់នៅ

• ពន្ធប៉ាតង់

• ពន្ធលើដីទំនេរ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

• ពន្ធប្រថាប់ត្រា

• ពន្ធសត្តឃាត

• ពន្ធតែមប្រ៍

• ពន្ធលើមធ្យោបាយដឹកជញ្ជូន ។ល។

លក្ខណៈសំខាន់ៗនៃរចនាសម្ព័ន្ធសារពើពន្ធល្អមានដូចខាងក្រោម លក្ខណៈសំខាន់ៗនៃរចនាសម្ព័ន្ធសារពើពន្ធល្អ មានដូចខាងក្រោម (Musgrave, 2004) ៖

• ចំណូលដែលប្រមូលបានត្រូវតែគ្រប់គ្រាន់

• ការបែងចែកបន្ទុកពន្ធត្រូវតែប្រកបដោយសមធម៌

• អ្វីដែលសំខាន់នោះមិនមែនស្ថិតនៅលើមុខសញ្ញាយកពន្ធទេ តែអ្នកណាដែលត្រូវរងបន្ទុកពន្ធ

• ត្រូវជ្រើសរើសពន្ធណា ដែលកាត់បន្ថយអាយេដល់កម្រិតអប្បបរមា នូវអន្តរាគមន៍ជាមួយនឹងការសម្រេចចិត្តខាងផ្នែកសេដ្ឋកិច្ច នៅក្នុងបរិការណ៍ទីផ្សារមានប្រសិទ្ធភាព ។ ត្រូវកាត់បន្ថយ ជាអតិបរិមានូវ «បន្ទុកបន្ថែម» ។

• រចនាសម្ព័ន្ធពន្ធត្រូវជួយសម្រួលដល់ការអនុវត្តគោលនយោបាយសារពើពន្ធ ដើម្បីឱ្យមានស្ថិរភាព និង កំណើន

• ប្រព័ន្ធសារពើពន្ធត្រូវមានរដ្ឋបាលប្រកបដោយភាពយុត្តិធម៌ ឥតលំអៀង ហើយងាយយល់សម្រាប់អ្នកបង់ពន្ធ

• តម្លៃរដ្ឋបាល និង តម្លៃអនុវត្តច្បាប់ត្រូវតែមានកម្រិតទាបសមស្រប ។

## ២០.៤. ការពិពណ៌នាអំពីប្រភេទពន្ធនៅកម្ពុជា

### ២០.៤.១. ពន្ធដែលត្រូវបង់ចូលថវិកាជាតិ

#### *២០.៤.១.១. ពន្ធលើប្រាក់ចំណូល*

១.១. **ពន្ធលើប្រាក់បៀវត្ស៖** ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលរូបវន្តបុគ្គលបានទទួល ក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ ។ រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស។ រូបវន្តបុគ្គល អនិវាសនជនត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់បៀវត្សប្រភពកម្ពុជា។ សហគ្រាសដែលជានិយោជកត្រូវមានកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស នៅមុនពេលបើកប្រាក់បៀវត្សឱ្យដល់និយោជិត និងបង់ប្រាក់ពន្ធនេះ ជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតនៅថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលប្រាក់បៀវត្សត្រូវបានបើក ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុក តាមអត្រាកំណើនតាមថ្នាក់។

សម្រាប់និយោជិតអនិវាសនជន ពន្ធលើប្រាក់បៀវត្សត្រូវបានកាត់ទុកតាមអត្រា ២០% នៃទឹកប្រាក់ត្រូវបើកឱ្យមុនការកាត់ទុក។ ពន្ធកាត់ទុកនេះគឺជាពន្ធចុងក្រោយនៃប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស។

ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែ សហគ្រាស ក្រុមហ៊ុន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា ២០% នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឱ្យនិយោជិតទាំងអស់។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សារ រួមទាំងពន្ធអាករទាំងអស់។

### ២០.៤.១.២. *ពន្ធប្រាក់ចំណេញ*

**ពន្ធលើប្រាក់ចំណេញ៖** ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជន ចំពោះ ប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស ។ សំរាប់អ្នកជាប់ពន្ធអនិវាសនជនពន្ធលើប្រាក់ចំណេញកំណត់តែលើ ប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ ។

| *ចំណូលប្រចាំខែដែលជាប់ពន្ធ* | | | *អត្រាពន្ធ* |
|---|---|---|---|
| *ពី ០.០០ រៀល* | *រហូតដល់* | *៥០០,០០០ រៀល* | *០%* |
| *ពី ៥០០,០០១ រៀល* | *រហូតដល់* | *១,២៥០,០០០ រៀល* | *៥%* |
| *ពី ១,២៥០,០០១ រៀល* | *រហូតដល់* | *៨,៥០០,០០០ រៀល* | *១០%* |
| *ពី ៨,៥០០,០០១ រៀល* | *រហូតដល់* | *១២,៥០០,០០០ រៀល* | *១៥%* |
| *លើសពី ១២,៥០០,០០០ រៀល* | | | *២០%* |

**ប្រាក់ចំណេញជាប់ពន្ធ**-ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងចំណេញមូលធនដែលសម្រេចបានក្នុងពេលកំពុង ប្រកបអាជីវកម្ម ឬ នៅពេលបញ្ចប់អាជីវកម្ម ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគ ការប្រាក់ ថ្លៃឈ្នួល និងសួយសារផង ។ ប្រាក់ចំណេញជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវ ចំណេញមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យវិនិយោគ ដែលសម្រេចបានមកពីប្រតិបត្តិការនានាក្រៅពីប្រតិបត្តិការអាជីវកម្ម ។

#### ២០.៤.១.២.១. *អាត្រាពន្ធប្រាក់ចំណេញ*

អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ មានដូចតទៅ៖

១- ២០ ភាគរយ ចំញេះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល ។

២- ៣០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផល ប្រេងកាត និង ឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែមាស ឬ ត្បូងថ្មមានតម្លៃនានា ។

៣-៩ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់រយៈពេលអន្តរកាល ៥ ឆ្នាំ ដោយគិតចាប់ផ្តើមពីថ្ងៃប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

៤-០ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ ដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

៥-តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណេញដែលសម្រេចបាន ដោយរូបវន្តបុគ្គលនិង ចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមអាជីវកម្មដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ៖

៦-ចំពោះសហគ្រាសដែលមានសកម្មភាពជាសំខាន់ ក្នុងការធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជិវិតទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ខាងក្រោម ៖

ក. ៥% នៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ ចំពោះការធានារ៉ាប់រង ឬ ធានារ៉ាប់រងបន្តនូវហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា។

ខ. តាមអត្រាទាំងឡាយដូចមានចែងក្នុងចំណុច ១-២-៣-៤ និង ៥ ខាងលើចំពោះសកម្មភាពដទៃទៀត ដែលមិនមែនជាការធានារ៉ាប់រងឬធានារ៉ាប់រងបន្ត។

២០.៤.១.២.២. *ពន្ធកាត់ទុកលើការបែងចែកភាគលាភ*

**ពន្ធកាត់ទុកលើការបែងចែកភាគលាភ**-នៅពេលបែងចែកភាគលាភ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបង់ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ ដូចតទៅ៖

១-ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ២០ ភាគរយ នៃទឹកប្រាក់ត្រូវបែងចែកចំពោះ ៖

ក. ការបែងចែកប្រាក់ចំណេញរក្សាទុក ឬ ប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំ ដែលបាន បង់ពន្ធលើប្រាក់ចំណេញ តាមអត្រា ០ ភាគរយ ។

ខ. ការបែងចែកដទៃទៀត វៀរលែងតែការបែងចែកដែលបានកំណត់ក្នុងចំណុច ២ និង ចំណុច ៣ ខាងក្រោមនេះ និងការបង់សងវិញនូវមូលធន ។

២-ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ១១ ភាគ ៨១ នៃទឹកប្រាក់ត្រូវបែងចែកចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធ ធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬ ប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើ ប្រាក់ចំណេញតាមអត្រា ៩ ភាគរយ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣- ពន្ធលើប្រាក់ចំណេញបន្ថែមមិនត្រូវអនុវត្តទេ ចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬ ប្រាក់ចំណេញប្រចាំឆ្នាំ ក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើអ្នកជាប់ពន្ធធ្វើការបែងចែកប្រាក់ ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ ភាគរយ ឬអត្រា ៣០ ភាគរយ ។

### ២០.៤.១.៣. ពន្ធអប្បបរមា និង ប្រាក់រំដោះពន្ធប្រាក់ចំណេញ

**ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ៖** អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស រួមទាំងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩% ត្រូវមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែ តាមអត្រា ១% នៃផលរបរ គិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ វៀរលែងតែអាករលើតម្លៃបន្ថែម ដែលសម្រេចបានក្នុងខែមុន យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ផលរបរនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធត្រូវបានលើកលែងពីការបង់ប្រាក់រំដោះនេះ ។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ នឹងត្រូវបានយកទៅកាត់កងពីពន្ធលើប្រាក់ចំណេញ នៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

**ពន្ធអប្បបរមា** ជាពន្ធមួយដាច់ដោយឡែកនិងផ្សេងពីពន្ធលើប្រាក់ចំណេញ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស លើកលែងតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមអត្រា ១ ភាគរយ លើផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។ ពន្ធនេះត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ហើយអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ។

### ២០.៤.១.៤. ពន្ធកាត់ទុកលើនិវាសនជន

**ពន្ធកាត់ទុកលើនិវាសនជន៖** អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុឱ្យដល់អ្នកជាប់ពន្ធនិវាសនជនត្រូវកាត់ទុកនិង បង់ប្រាក់ពន្ធទៅតាមអត្រាដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ ៖

ក. អត្រា ១៥% ចំពោះ៖

- ប្រាក់ចំណូល ដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬ ការពិគ្រោះយោបល់ ឬ សេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអរូបីនិងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធ និវាសនជន ដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន

ខ. អត្រា ១០% ចំពោះប្រាក់ចំណូលពីការឱ្យជួលចលនឬ អចលនទ្រព្យ

គ. អត្រា ៦% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ជ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់

ឃ.អត្រា ៤% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ ពន្ធនិវាសនជន ដែលមានគណនីសន្សំគ្មានកាលកំណត់។

ការកាត់ទុកខាងលើនេះមិនត្រូវអនុវត្តទេចំពោះការប្រាក់ដែលបង់ទៅឱ្យធនាគារ និងស្ថាប័នសញ្ញ័យក្នុងស្រុក និង ការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា ៩ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ។

### ២០.៤.១.៥. *ពន្ធកាត់ទុកលើអនិវាសនជន*

**ពន្ធកាត់ទុកលើអនិវាសនជន៖** អ្នកជាប់ពន្ធនិវាសនជន ដែលប្រកបអាជីវកម្មដែលធ្វើការ ទូទាត់ប្រាក់ចំណូលដូចខាងក្រោមនេះឱ្យទៅអ្នកជាប់ពន្ធអនិវាសនជនត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធតាមអត្រា ១៤% នៃទឹកប្រាក់ត្រូវបើក ៖

ក- ការប្រាក់

ខ- សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗ ទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ

គ- ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា

ឃ-ភាគលាភ ។

សហគ្រាស ក្រុមហ៊ុន ត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធដែលបានកាត់ទុកក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយដំណាច់ខែដែលមានការកាត់ទុក ។ ពេលកាត់ទុក គឺជាពេលដែលចំណាយត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យ ។

### ២០.៤.១.៦. *អាករលើតម្លៃបន្ថែម* (VAT)

**អាករលើតម្លៃបន្ថែម៖** អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ត្រូវមានកាតព្វកិច្ចចុះបញ្ជីអាករលើតម្លៃបន្ថែម និងប្រមូលអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឬសេវាឱ្យអតិថិជន ។

ទំនិញ សំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លី និងប្រាក់កាស រីឯសេវាសំដៅដល់ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស ។

ការផ្គត់ផ្គង់ជាប់អាករ សំដៅដល់ ៖

- ការផ្គត់ផ្គង់ទំនិញ ឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ
- ការផ្តល់ជាអំណោយ ឬការផ្គត់ផ្គង់ក្រោមតម្លៃពិតនូវទំនិញ ឬសេវាដោយបុគ្គលជាប់អាករ
- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា ។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការផ្គត់ផ្គង់មិនជាប់អាករមានដូចតទៅ ៖

- សេវាប្រៃសណីយ៍សាធារណៈ
- សេវារបស់មន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រនិងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ ដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ
- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ
- សេវាធានារ៉ាប់រង
- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ការនាំចូលនិងការទិញទំនិញសម្រាប់ ឬដោយបេសកកម្មទូត និងកុងស៊ុលបរទេសអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារ ជាផ្លូវការរបស់ខ្លួន ។

អត្រាអាករលើតម្លៃបន្ថែមមាន ៖

- ១០% សម្រាប់ការនាំចូល ឬការផ្គត់ផ្គង់ទំនិញឬសេវាក្នុងព្រះរាជាណាចក្រកម្ពុជា
- ០% សម្រាប់ការនាំចេញ ។

ការគណនាប្រាក់អាករត្រូវបង់ ៖

- ប្រាក់អាករដែលបានបង់នៅពេលនាំចូលទំនិញ ឬប្រាក់អាករដែលបានបង់លើការទិញ ទំនិញឬសេវា សម្រាប់ប្រកបអាជីវកម្ម ហៅថា «អាករលើធាតុចូល»
- ប្រាក់អាករដែលបានគិតយកពីអតិថិជនពីការផ្គត់ផ្គង់ទំនិញឬសេវាហៅថា «អាករលើធាតុ-ចេញ» ប្រាក់អាករត្រូវបង់ × អាករលើធាតុចេញ - អាករលើធាតុចូល ។

អាករលើធាតុចូលដែលមិនអាចកាត់កងបានរួមមានប្រាក់អាករដែលបានបង់លើ ៖

- ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករមានអាជីវកម្មជាអ្នកផ្គត់ផ្គង់ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ ។
- ការទិញឬការនាំចូលរថយន្ត លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការទិញឬការនាំចូលផលិតផលគេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អាករប្រកបអាជីវកម្ម ជាអ្នកផ្គត់ផ្គង់ផលិតផលគេលសិលាទាំងនោះ ។

អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវា ត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់ ។

### ២០.៤.១.៧. អាករលើផលរបរ

**អាករលើផលរបរ៖** អាករលើផលរបរអាជីវកម្មប្រចាំខែ ត្រូវអនុវត្តលើបុគ្គលទាំងឡាយនៅក្រោមរបបមៅការ។ កសិផលលក់ដោយផលិតករដំបូងគេ (ប៉ុន្តែមិនមែនជាឈ្មួញ) និងឈ្មួញចល័ត និងការកសាងអចិន្ត្រៃយ៍ខ្នាតតូច ដែលត្រូវបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងសហគ្រាសដែលធ្វើប្រតិបត្តិការដោយច្បាប់ស្តីពីវិនិយោគ ដែលនឹងត្រូវគិតអត្រាពន្ធតែមួយ ២% ។

### ២០.៤.១.៨. ពន្ធលើការជួលកម្មសិទ្ធិ

**ពន្ធលើការជួលកម្មសិទ្ធិបុទ្រព្យសម្បត្តិ៖** អាជីវកម្ម (ក្រៅពីអាជីវកម្មទាំងឡាយដែលស្ថិតនៅក្នុងរបបស្វ័យប្រកាស) ការជួលដីធ្លី អាគារ សម្ភារៈ ឃ្លាំង ជាដើម ត្រូវជាប់ពន្ធលើការជួលកម្មសិទ្ធិទាំងអស់។ ពន្ធ ដែលត្រូវគិតនៅអត្រា ១០% លើតម្លៃជួល។ ពន្ធនេះគិតដោយផ្ទាល់លើម្ចាស់កម្មសិទ្ធិ ប៉ុន្តែមិនកាត់យកពីការទូទាត់ ប្រាក់ជួល ដែលធ្វើឡើងដោយសហគ្រាសស្ថិតនៅក្រោមរបបស្វ័យប្រកាសឡើយ។ ម្ចាស់កម្មសិទ្ធិដែលមានប្រាក់ចំណូលប្រចាំខែ បានមកពីការជួលតិចជាង ៥០០.០០០ រៀល ត្រូវទទួលបានការអនុគ្រោះពន្ធ ។

### ២០.៤.១.៩. អាករពិសេសលើទំនិញនិងសេវាមួយចំនួន

**អាករពិសេសលើទំនិញនិងសេវាមួយចំនួន៖** ពន្ធលើផលិតផលមួយចំនួនទាំងផលិតនៅក្នុងស្រុកនិងនាំចូល និងសេវាផ្សេងៗ។ ការបង់ពន្ធអាករពិសេសលើបារីត្រូវបានធានាដោយការបិទតែម។

ទំនិញដែលត្រូវជាប់អាករពិសេសលើទំនិញ និង សេវាមួយចំនួន៖

- រថយន្ត (៣០%) គ្រឿងបន្លាស់ (២០%) ម៉ូតូ និង គ្រឿងបន្លាស់ (១០%) ផលិតផលគេលសិលា (២០%) ភេសជ្ជៈ និង គ្រឿងស្រវឹង (១០%) ស្រាបៀរ (២០%)។
- សេវាខាងក្រោមនេះត្រូវជាប់អាករលើសេវាកម្ម ៖ សេវាកំសាន្ត (១០%) សេវាដឹកជញ្ជូនអ្នកដំណើរតាមអាកាស និង សេវាទូរស័ព្ទ (១០%)។

## ២០.៤.២. ពន្ធដែលត្រូវបង់ចូលថវិកាខេត្តក្រុង

### ២០.៤.២.១. ពន្ធលើដីទំនេរមិនប្រើប្រាស់

**ពន្ធលើដីទំនេរ៖** ពន្ធលើដីធ្លី ដែលមាននៅក្នុងទីក្រុង និង តំបន់ ដែលពុំមានសំណង់ ឬ មានសំណង់ប៉ុន្តែមិនបានប្រើប្រាស់។ ពន្ធត្រូវបានគណនានៅអត្រា ២% នៃតម្លៃដី ដែលត្រូវបានវាយតម្លៃដោយគណៈកម្មការវាយតម្លៃដីទំនេរនៅថ្ងៃទី ៣០ មិថុនា ជារៀងរាល់ឆ្នាំ។ ដីមានទំហំ ១.២០០ ម៉ែត្រការ៉េពុំត្រូវបានគិតពន្ធឡើយ ។ ម្ចាស់ដីត្រូវបានតម្រូវឱ្យបង់ពន្ធនៅរៀងរាល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ជារៀងរាល់ឆ្នាំ។

### ២០.៤.២.២. ពន្ធប្រថាប់ត្រា

**ពន្ធប្រថាប់ត្រា**៖(ពន្ធលើការផ្ទេរកម្មសិទ្ធិ) មានឯកសារមួយចំនួនទាក់ទងនឹងការបង្កើត ការរំលាយ ឬ បង្រួមចូលគ្នានៃអាជីវកម្ម ឬ ការផ្ទេរឈ្មោះកម្មសិទ្ធិទ្រព្យសម្បត្តិមួយចំនួន (ដូចជា ដី សំណង់អាគារ ជំនិះ យានយន្ត និង នាវា) នឹងត្រូវជាប់ពន្ធប្រថាប់ត្រា ។ ពន្ធនេះនឹងត្រូវគិតលើអត្រា ៤% នៃតម្លៃត្រូវផ្ទេរ ។

ការផ្ទេរកម្មសិទ្ធិ ដែលបញ្ញាដោយរដ្ឋត្រូវបានអនុគ្រោះពន្ធ ដូចជាការផ្ទេររបស់រដ្ឋាភិបាល ការប្រើប្រាស់សាធារណៈ និង អង្គការសប្បុរសធម៌នានា ។ ការលក់យានជំនិះក៏ត្រូវបានអនុគ្រោះពន្ធដែរ ប្រសិនបើអ្នកលក់ត្រូវបង់ពន្ធលើផលរបរ ឬ ពន្ធលើប្រាក់ចំណេញ ។

### ២០.៤.២.៣. ពន្ធប៉ាតង់

**ពន្ធប៉ាតង់**៖ ការចុះបញ្ជីប្រចាំឆ្នាំ ឬ តម្លៃអជ្ញាប័ណ្ណ ត្រូវបានគិតពន្ធលើគ្រប់អាជីវកម្មឧស្សាហកម្ម និង សេវាកម្ម (ទាំង អ្នកបង់ពន្ធរបបស្វ័យប្រកាស និង របបមៅការ)។ មូលដ្ឋានគិតពន្ធគឺ ផលរបរពីឆ្នាំមុន ឬ ការប៉ាន់ប្រមាណលើផលរបរ។ អាជីវកម្មថ្មីត្រូវបានគិតពន្ធលើមូលដ្ឋាននៃការប៉ាន់ប្រមាណ។ កសិករ និង គ្រួសារ ធ្វើអាជីវកម្មត្រូវបានទទួលការអនុគ្រោះពន្ធប៉ាតង់។ ប្រកាសនីយប័ត្រពន្ធប៉ាតង់ត្រូវបានបង្ហាញនៅបរិវេណ ឬ ទីតាំងអាគារអាជីវកម្ម។ អ្នកបង់ពន្ធត្រូវបញ្ជូនបញ្ជីពន្ធប៉ាតង់ និងទូទាត់ពន្ធនេះនៅចុងខែ មីនា ជារៀងរាល់ឆ្នាំ ។ ចំពោះអាជីវកម្ម និង ឧស្សាហកម្ម និង ចំពោះសេវាកម្ម ពន្ធប៉ាតង់ត្រូវបានគិតតាមផលរបរប្រចាំ ។

### ២០.៤.២.៤. ពន្ធលើសត្តឃាត (១៩៩១)

ពន្ធនេះយកពីមណ្ឌលសត្វឃាតនានាផ្អែកតាមតម្លៃនៃបសុសត្វ។ ពន្ធសត្វឃាតត្រូវបានលើកលែងចំពោះ ៖ សត្តឃាតដើម្បីអបអរពិធីបុណ្យប្រពៃណី សត្តឃាតសម្រាប់គោលដៅស្រាវជ្រាវ និង សត្វសម្លាប់ដោយគ្រោះថ្នាក់។ អត្រាពន្ធតែមួយ ៣% ត្រូវបានកំណត់យកលើតម្លៃសត្វមួយក្បាលៗ។

### ២០.៤.២.៥. ពន្ធលើជំនិះយានយន្ត

ពន្ធលើជំនិះយានយន្តត្រូវបានយកពីរថយន្ត និង ទូកជាប្រចាំឆ្នាំតាមការកំណត់ទៅលើ៖ រថយន្តសណ្តោង ឡាន(តាមកម្លាំងសេះ) ម៉ូតូ ទូកកម្លាំងតូច នាវាដឹកទំនិញ នាវានេសាទសមុទ្រ។

### ២០.៤.២.៦. ពន្ធលើស្រានិងថ្នាំជក់

ពន្ធនេះយកចំនួន ១០% ២០% និង៣០%ទៅលើស្រា ១០%ទៅលើបារី និង ២៥%ទៅលើស៊ីហ្គា (ដែលនាំចូលឬផលិតក្នុងប្រទេសកម្ពុជា)។

### ២០.៤.២.៧. ពន្ធតែមប្រ៍ (មាត្រា ៤៦ ឆ្នាំ ១៩៩៤)

ពន្ធតែមប្រ៍ ពន្ធអាចយកបានតាមរយៈតែមប្រ៍ ដែលបិទភ្ជាប់ទៅនឹងឯកសារផ្លូវការនានា និង បដាផ្សាយពាណិជ្ជកម្មធំៗ ។ អត្រាពន្ធមានខុសៗគ្នាទៅតាមកត្តាកំណត់ផ្សេងៗដូចជាទីតាំងដាក់បដា ការតាំងភ្លើង បំភ្លឺ និង ការប្រើប្រាស់ភាសា (ភាសាបរទេស ឬ ភាសាខ្មែរ) ។

## ២០.៥. សមិទ្ធិកម្មសារពើពន្ធនៅកម្ពុជា

### ២០.៥.១. គោលនយោបាយសារពើពន្ធ

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកំណែទម្រង់សារពើពន្ធយ៉ាងទូលំទូលាយ ហើយចំណូលពន្ធដែលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារបានកើនឡើងចំនួន ១១ ដងក្នុងរយៈពេល ១១ ឆ្នាំកន្លងទៅនេះ ពី ១៥១,៨ ពាន់លានរៀលនៅក្នុងឆ្នាំ ១៩៩៨ ដល់ ១,៧៣៥ ពាន់លានរៀល នៅក្នុងឆ្នាំ ២០០៨។

ចំណូលពន្ធ បានកើនឡើងជាប្រចាំបន្ទាប់ពីការដាក់អាយេអនុវត្តនូវអាករលើតម្លៃបន្ថែម ចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ ១៩៩៩ ដែលដាក់អាយេអនុវត្តចំពោះសហគ្រាសដែលស្ថិតនៅក្នុងរបបស្វ័យប្រកាស។ នាពេលបច្ចុប្បន្ននេះ អាករលើតម្លៃបន្ថែម កំពុងអនុវត្តចំពោះសហគ្រាសធំ និង មធ្យម ។

*តារាង ២០.១. ចំណូលពន្ធប្រមូលដោះអគ្គនាយកដ្ឋានពន្ធដារ (ពាន់លានរៀល)*

| ឆ្នាំ | ១៩៩៨ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់ចំណូលពន្ធ | ១៥១.៨ | ១៨៥.១ | ២៧០.៩ | ២៩២.៩ | ៣១៨.៨ | ៣៨៤.៣ | ៤៨១.១ | ៦៣៤.៣ | ៨៨៥៦ | ១,២៥៩ | ១,៧៣៥ |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច្ច និងហិរញ្ញវត្ថុ*

នៅក្នុងឆ្នាំ ២០០០ ឆ្នាំ ២០០៣ និង ឆ្នាំ ២០០៥ អគ្គនាយកដ្ឋានពន្ធដារបានអនុវត្តនូវការប្រមូលពន្ធតាមរបបពិត ចំពោះសហគ្រាសធុនមធ្យមក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងខ័ណ្ឌទាំង ៧ នៃរាជធានីភ្នំពេញ។ នៅចុងឆ្នាំ ២០០៨ កន្លងទៅនេះ មានសហគ្រាសចុះបញ្ជីចំនួន ១១.១៩៦ ដែលក្នុងនោះ សហគ្រាសចំនួន ១.៧៩៣ ជាសហគ្រាសធុនធំ នៅក្នុងខេត្ត-ក្រុងចំនួន ១៦។ សហគ្រាសទាំងអស់ដែលស្ថិតនៅក្នុងរបបស្វ័យប្រកាសត្រូវបង់អាករលើតម្លៃបន្ថែម។ នាពេលបច្ចុប្បន្ននេះ របបស្វ័យប្រកាសត្រូវបានអនុវត្តនៅក្នុងគ្រប់ខេត្តទាំងអស់ទូទាំងសហគ្រាសធុនធំ និង សហគ្រាសចំនួន ៩.៤០៣ ជាសហគ្រាសធុនតូចនិងមធ្យម។

នៅក្នុងឆ្នាំ ២០០៣ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ ជាពិសេស លើបទប្បញ្ញត្តិដែលញក់ព័ន្ធនឹងច្បាប់ស្តីពីវិនិយោគ ដោយផ្តោតជាសំខាន់លើចំណុចមួយចំនួនដូចតទៅ៖

- ការធ្វើវិសោធនកម្មលើរយៈពេលលើកលែងពន្ធ ចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលទទួលការលើកលែងពន្ធ ។
- ការដាក់អោយអនុវត្តនូវអត្រារំលស់ពិសេសចំនួន ៤០% ចំពោះគម្រោងវិនិយោគណាដែលមិន ចង់អនុវត្តនូវរយៈពេលលើកលែងពន្ធលើពន្ធលើប្រាក់ចំណេញ ។
- ការកែប្រែនូវប្រព័ន្ធរំលស់ដោយអនុវត្តនូវវិធីសាស្ត្ររំលស់ស្មើភាគ (Straight line method) ចំពោះអាគារ និង វិធីសាស្ត្ររំលស់ថយចុះជាលំដាប់ (Declining balance method) ចំពោះទ្រព្យសកម្មផ្សេងទៀត ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការដាក់ឱ្យអនុវត្តនូវពន្ធកាត់ទុកលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ។
- ការកាត់បន្ថយនូវអត្រាពន្ធកាត់ទុកលើអនិវាសនជន។
- ការកាត់បន្ថយនូវអត្រាពន្ធកាត់ទុកលើនិវាសនជន ដែលអត្រាត្រូវបានកាត់បន្ថយពី ១៥% មកនៅត្រឹមអត្រា ៦% ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់ និង កាត់បន្ថយពី ៥% មកនៅត្រឹមអត្រា ៤% ចំពោះការប្រាក់ ដែល ធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីសន្សំគ្មានកាល កំណត់ ។
- បង្កើនអត្រាពន្ធលើប្រាក់បៀវត្សសម្រាប់អនិវាសនជន ពី ១៥% ដល់អត្រា ២០%។
- ការឈប់អនុវត្តនូវពន្ធអប្បបរមា និង លើកលែងពីការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែតាមអត្រា ១% នៃផលរបរចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធ។
- ការកែលម្អនូវវិធានមួយចំនួន ដើម្បីពង្រឹងការប្រមូលពន្ធ។

អគ្គនាយកដ្ឋានពន្ធដារបានបង្កើតឡើងនូវការិយាល័យសហគ្រាសធុនធំ ដើម្បីធានាអោយបាននូវការគ្រប់គ្រងអោយបានល្អប្រសើរនូវសហគ្រាសចំនួន ៦០០ ដោយតម្រូវឱ្យសហគ្រាសទាំងនេះបង់ពន្ធតាមប្រព័ន្ធធនាគារនៃធនាគារជាតិនៃកម្ពុជា។ ការិយាល័យនេះប្រមូលចំណូលពន្ធបានចំនួន ៨០% នៃចំណូលពន្ធសរុបដែលអគ្គនាយកដ្ឋានប្រមូលបាន។ ការិយាល័យសហគ្រាសតូច និង មធ្យមក៏ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងអោយបានជិតដល់នូវសហគ្រាសទាំងនេះ។

### ២០.៩.២. វដ្តចាលសារពើពន្ធ

អគ្គនាយកដ្ឋានពន្ធដារបានកែលម្អនូវសេវាសម្រាប់អ្នកបង់ពន្ធ ដោយបង្កើតឡើងនូវអង្គភាពនៅតាមខេត្ត-ក្រុង ដើម្បីកែលម្អនូវសេវា និង ទំនាក់ទំនងជាមួយអ្នកបង់ពន្ធ ។ អគ្គនាយកដ្ឋានពន្ធដារបានពង្រឹងនូវសវនកម្មលើសហគ្រាសធំ និង មធ្យម និង បង្កើនការផ្លាស់ប្តូរ ព័ត៌មានរវាងនាយកដ្ឋានដែលមានការពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏ដូចជាជាមួយក្រសួង-ស្ថាប័នផ្សេងទៀត ដើម្បីកែលម្អនូវការធ្វើសវនកម្មនៃសហគ្រាសទាំងនេះ។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋាន បានបង្កើនចំនួនសវនកម្ម និង សហគ្រាសដែលត្រូវធ្វើសវនកម្ម។ នាយកដ្ឋានក៏បានរៀបចំនូវវិសោធនកម្ម នៃលិខិតបទដ្ឋាន និង កម្មវិធីសវនកម្មពន្ធចំពោះសហគ្រាសទាំងនេះផងដែរ។

អគ្គនាយកដ្ឋានពន្ធដារបានបណ្តុះបណ្តាលនូវមន្ត្រី ខាងផ្នែកមុខវិជ្ជាគណនេយ្យទូទៅ ភាសាអង់គ្លេស កុំព្យូទ័រ និង អនុញ្ញាអន្តរជាតិស្តីពីសារពើពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបានពង្រឹងនូវប្រព័ន្ធព័ត៌មានវិទ្យា ដោយបង្កើតនូវប្រព័ន្ធទិន្នន័យអ្នកជាប់ពន្ធ ការបំពាក់នូវកំព្យូទ័រនៅតាមសាខាពន្ធដារខេត្ត-ក្រុង ដើម្បីប្រមូលទិន្នន័យ និង លិខិតប្រកាសសារពើពន្ធនៃសហគ្រាសដែលអនុវត្តនូវរបបស្វ័យប្រកាស ។

*តារាង ២០.២. លទ្ធផលនៃសវនកម្មពន្ធសម្រាប់សហគ្រាសខ្នាតមធ្យមនិងធំ ឆ្នាំ១៩៩៨ដល់២០០៨ (គិតជាពាន់លានរៀល)*

| ឆ្នាំ | ១៩៩៨ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|---|---|---|---|---|
| លទ្ធផលនៃសវនកម្មពន្ធ | ៣.៦ | ១៣.១ | ២៦.៤ | ១២២.៥ | ៧៣.៤ | ១០៤.៥ | ១៩៨.៣ | ៣៥១.៨ | ៩៨៧.៥ | ៩៦៧.៥ | ៧៥១.៧ |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច្ និងហិរញ្ញវត្ថុ*

នាយកដ្ឋានបានពង្រឹងវិធានការប្រមូលពន្ធក្នុងការអនុវត្តច្បាប់ពន្ធដារ ទៅលើសហគ្រាសដែលជំពាក់ប្រាក់រដ្ឋ។ វិធានការទាំងនោះរួមមានការបង្កកគណនីនៅឯធនាគារជាតិ និងរតនាគារជាតិការបញ្ឈប់ប្រតិបត្តិការនាំចេញ / នាំចូលដោយនាយកដ្ឋានគយការលុបចោលអាជ្ញាប័ណ្ណការបញ្ឈប់ការរួចពន្ធសម្រាប់គម្រោងដែលដាក់ជូនដោយ CDC ការហាមឃាត់មិនឱ្យចូលរួមក្នុងការផ្គត់ផ្គង់សាធារណៈ។ល។

*តារាង ២០.៣. លទ្ធផលនៃការប្រមូលពន្ធចន្លោះឆ្នាំ ១៩៩៨ ដល់ ២០០៨*

| ឆ្នាំ | ១៩៩៨ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|---|---|---|---|---|
| លទ្ធផលនៃការប្រមូលពន្ធ | 0.5 | 10.9 | 33.4 | 15.3 | 33.0 | 70.8 | 41.0 | 39.4 | 56.4 | 53.9 | 44.5 |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០៨ អគ្គនាយកដ្ឋានពន្ធដារបានបណ្តុះបណ្តាលមន្ត្រីរាជការជាង ១,៨០០ នាក់ នៅក្នុងផ្នែកគណនេយ្យទូទៅ ភាសាអង់គ្លេស វិទ្យាសាស្ត្រកុំព្យូទ័រ និងអនុសញ្ញាអន្តរជាតិស្តីពីពន្ធ។ល។ នាយកដ្ឋាននេះក៏បានរើសមន្ត្រីរាជការ ៖ ២៩ នាក់ក្នុងឆ្នាំ ២០០១, ១៦០ នាក់ ក្នុងឆ្នាំ២០០៣, និង ២១២ នាក់ក្នុងឆ្នាំ ២០០៧។

ប្រព័ន្ធព័ត៌មានរបស់នាយកដ្ឋានត្រូវបានពង្រឹង តាមរយៈការបង្កើតនូវប្រព័ន្ធអង្កេតការ និងការកត់ត្រាទិន្នន័យថ្មីមួយ។ ការិយាល័យមួយចំនួនរបស់នាយកដ្ឋាន និងអង្គភាពខេត្តត្រូវបានបំពាក់ដោយកុំព្យូទ័រដើម្បីប្រមូលទិន្នន័យ និងប្រតិវេទន៍ពន្ធពីសហគ្រាស ដែលជួបនិងប្រព័ន្ធយកពន្ធនៃរបបពិត។

### ២០.៤.៣. ការវិភាគប្រៀបធៀបនៃរដ្ឋបាលពន្ធដារ

ក្រុមអធិការកិច្ចហិរញ្ញវត្ថុនៃប្រទេសបារាំងបានធ្វើការសិក្សាប្រៀបធៀបមួយ ស្តីពីការប្រព្រឹត្តទៅនៃរដ្ឋបាលពន្ធដារក្នុងប្រទេសចំនួនប្រាំបួន ក្នុងគោលដៅកំណត់គំរូនានានៃរចនាសម្ព័ន្ធចាត់តាំង ការអនុវត្តនិងការចំណាយ (www.finances.gouv.fr/actualites)។

ចំណុចមួយចំនួនដែលយើងអាចដកស្រង់ចេញពីការសិក្សានេះមានដូចតទៅៈ

សញ្ញាណនៃ "**ការគោរពដោយស្ម័គ្រចិត្តនិងដោយឯកឯង**" ទៅតាមច្បាប់ពន្ធដារត្រូវបានប្រើនៅស្ទើរតែគ្រប់រដ្ឋបាលពន្ធដារទាំងអស់។ គេអាចធ្វើការបែងចែករវាងអ្នកបង់ពន្ធដែលគោរពច្បាប់ស្តីពីពន្ធដារ និងអ្នកទាំងឡាយណា ដែលមិនគោរពច្បាប់ ហើយគេអាចធ្វើសេចក្តីសន្និដ្ឋានបានថា ការគោរពដោយស្ម័គ្រចិត្តនៃច្បាប់ពន្ធដារ គឺមានប្រសិទ្ធភាពជាងវិធានការគាបសង្កត់ ដូចជាសវនកម្មពន្ធជាដើម។ ប្រការនេះកំណត់ទិសដៅថ្មីមួយ តាមរយៈការជំនួសវប្បធម៌សង្ស័យ ដោយអនុវត្តអភិក្រមដែលលើកទឹកចិត្តឱ្យមានការទទួលយកការគោរពដោយស្ម័គ្រចិត្តនូវច្បាប់ពន្ធដារ (ដោយកែលម្អសេវាកម្មដែលផ្តល់ជូនអ្នកបង់ពន្ធ) និងការបង្វែរទិសសវនកម្ម ដែលផ្តោតលើតែអ្នកបង់ពន្ធមានហានិភ័យខ្ពស់ប៉ុណ្ណោះ។

ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគឺជាចំណុចស្នូលនៃយុទ្ធសាស្រ្តតាមរយៈការពង្រឹងសេវាកម្មព័ត៌មានពន្ធដារ ដូចជាការវិវត្តៈ

- ពីអង្គភាពមួយដែលផ្តោតទៅលើប្រភេទពន្ធ ទៅជាអង្គភាពផ្តោតលើក្រុមគោលដៅ។
- ពីការផ្តោតទៅលើអង្គភាពផ្ទៃក្នុង ទៅជាផ្តោតទៅលើតម្រូវការ និងប្រភេទអ្នកជាប់ពន្ធ។
- ពីឯកសារជាក្រដាស ទៅជាឯកសារអេឡិចត្រូនិក។
- ពីដំណើរការបណ្តុំទិន្នន័យកុំព្យូទ័រ ទៅជាដំណើរការរកទិន្នន័យតាមពេលវេលាដែលកើតឡើង។
- ពីដំណើរទូទៅ ទៅជាដំណើរជ្រើសរើសផ្អែកលើហានិភ័យ។

ការធ្វើកំណែទម្រង់នៃអង្គភាពពន្ធដារត្រូវផ្តោតទៅរកគំរូល្អៗ តាមរយៈការជំរុញការធ្វើទំនើបកម្មនៃរដ្ឋបាលពន្ធដារ។ គំរូដែលល្អ គឺជាអង្គភាពដែនដីដែលមាននាយកដ្ឋានទទួលបន្ទុកក្រុមហ៊ុនធំៗ។ រដ្ឋបាលពន្ធដារខ្លះអនុវត្តការប្រមូលពន្ធ ជំនួសមុខឱ្យអាជ្ញាធរដែនដីឬតំបន់។ ប្រទេសខ្លះរៀបចំរដ្ឋបាលពន្ធដាររបស់ខ្លួន ដោយផ្តោតលើគំរូរបៀបជាទីភ្នាក់ងារ ដែលផ្តាច់ចេញពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានស្វ័យភាពលើការគ្រប់គ្រង និងផ្តល់អំណាចដល់ការគ្រប់គ្រងដែលមានប្រសិទ្ធភាពជាងការប្រមូលផ្តុំអំណាច។ គំរូនេះផ្តល់នូវគណនេយ្យភាព និងការទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចតាមគោលដៅដែលបានដាក់ចេញ។ ថ្លៃចំណាយគ្រប់គ្រងសម្រាប់រដ្ឋបាលពន្ធដារប្រែប្រួលចន្លោះពី ០.៥ ទៅ ១.៧% នៃចំណូលដែលប្រមូលបាន (១.១% ជាមធ្យម)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូក ២១
# ថវិការដ្ឋ

ថវិកា គឺជាឧបករណ៍ដែលរដ្ឋាភិបាលប្រើប្រាស់សម្រាប់អនុវត្តគោលនយោបាយសារពើពន្ធ។ ថវិកាអនុវត្តនូវមុខងារហិរញ្ញវត្ថុសំខាន់ៗបួនយ៉ាងរបស់រដ្ឋគឺៈ (១) ការកៀរគរធនធាន (២) ការបែងចែកធនធាន (៣) ការបែងចែកយុត្តិធម៌ និង (៤) ការធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។

ប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា មានប្រភពមកពីប្រព័ន្ធនៃប្រទេសបារាំងមុនឆ្នាំ ១៩៧០ និងដែលត្រូវបានរៀបរយដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។ ច្បាប់នេះត្រូវបានជំនួសដោយ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលត្រូវបានអនុម័តកាលពីថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០០៨ និងដែលត្រូវបានប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រមលេខ ន.ស./រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨។

## ២១.១. ក្របខ័ណ្ឌបច្ចេកទេសនៃថវិការដ្ឋ

យោងតាមមាត្រា ៥ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈ ថវិកាត្រូវមានគោលការណ៍គន្លឹះ ១១ យ៉ាងដែលត្រូវអនុវត្តដាច់ខាតគឺៈ ភាពជាអាជ្ញា ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ ភាពគ្រប់ជ្រុងជ្រោយ ឯកត្តភាព សកលភាព វិសេសភាព តុល្យភាព គណនេយ្យភាព តម្លាភាព ស្ថិរភាព និងសមិទ្ធកម្ម ។

ក៏ប៉ុន្តែ គោលការណ៍ជាសារវ័ន្តដែលត្រូវអនុវត្តជាចាំបាច់មានដូចតទៅៈ ការិយបរិច្ឆេទមានកាលកំណត់ មួយឆ្នាំ ឯកត្តភាព សកលភាព វិសេសភាព និង តុល្យភាព ។

១.១. **ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំៈ** គោលការណ៍នៃការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំមានចែងក្នុងមាត្រា ៩ នៃច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដូចតទៅ ៖ «ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំគ្រោង និងអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុកដែលត្រូវចំណាយសរុបរបស់រដ្ឋដើម្បីបម្រើឱ្យរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមដោយគិតគូរដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និងរូបិយវត្ថុជាសារវ័ន្ត ពិសេស តាមរយៈការធានាឱ្យបាននូវតុល្យភាពថវិកា»។ ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ (មាត្រា ៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ)។ ប្រសិនបើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំមិនត្រូវបានអនុម័តមុនថ្ងៃទី ០១ ខែ មករា នៃឆ្នាំការិយបរិច្ឆេទទេនោះ ថវិកាឆ្នាំមុនត្រូវបានបន្តដោយមានលក្ខខណ្ឌមួយចំនួន។

១.២. **ឯកត្តភាពៈ** គោលការណ៍ឯកកត្តភាពថវិកាមានន័យថាៈ ទីមួយ-ចំណូលទាំងអស់ និងចំណាយទាំងអស់ត្រូវតែដាក់អោយរដ្ឋសភាអនុម័តសម្រាប់ឆ្នាំខាងមុខ និង ទីពីរ-ចំណូល និង ចំណាយទាំងនេះត្រូវតែបង្ហាញ ដោយព្រមៗគ្នាតែម្តង ដើម្បីបង្ហាញពីការខិតខំប្រឹងប្រែងក្នុងការប្រមូលចំណូល និងការអនុវត្តចំណាយ និង ឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៃតុល្យភាពនៃថវិកា ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**១.៣. សកលភាព៖** គោលការណ៍សកលភាពមានន័យថា៖ ទីមួយ-មិនត្រូវយកចំណូល ទៅកាត់កងជាមួយចំណាយឡើយ (ដោយកត់ត្រាតែផលសងនៅក្នុងថវិកា) ដែលជាគោលការណ៍នៃការមិនកាត់កង (Principe de non-contraction) និង ទីពីរ- គោលការណ៍នៃការមិនវិភាជន៍សម្រាប់តែមុខសញ្ញាពិសេស (Principe de la non-affectation) បានចែងថា ៖ «ចំណូលទាំងមូលត្រូវវិភាជន៍សម្រាប់រាលមុខសញ្ញាចំណាយទាំងអស់ ។

**១.៤.វិសេសភាព៖** ចំណូល និង ចំណាយថវិកាត្រូវបង្ហាញអាចេដាក់ដោយឡែកពីគ្នានៅក្នុងថវិកាតាមមាតិកាថវិកាដែលកំណត់ដោយរដ្ឋសភា ។ មាត្រា ១៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈបែងចែកធនធានអចិន្ត្រៃយ៍របស់រដ្ឋតាមក្រុម និងប្រភេទចំណូល ហើយមាត្រា ២២ បែងចែកចំណាយតាមក្រុម និងប្រភេទចំណាយ ។

**១.៥. តុល្យភាព៖** ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសអាយេប្រើអាយេព្រះរាជក្រមលេខ សន/រកម/០៥០៨ /០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ បានចែងយ៉ាងច្បាស់លាស់ពីគោលការណ៍តុល្យភាពនៃថវិកា។ មាត្រា ៤៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានចែងថា ៖ «សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភា ត្រូវភ្ជាប់មកជាមួយនូវ ... របាយការណ៍វិភាគពីនិន្នាការ និងការវិវត្តរួមនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្ន និងការវិភាគលើចរិតលក្ខណៈនៃថវិកាថ្មី ព្រមទាំងបញ្ជាក់អំពីការរក្សា ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សមតាហិរញ្ញវត្ថុ និងរូបិយវត្ថុជាសារវន្ត ពិសេសតុល្យភាពថវិកា» ។

**១.៦. ប្រព័ន្ធគ្រប់គ្រង និង ប្រព័ន្ធការិយបរិច្ឆេទ៖** ប្រព័ន្ធថវិកាមានពីរប្រភេទ គឺ៖

១.៦.១. ប្រព័ន្ធគ្រប់គ្រង៖ ប្រព័ន្ធគ្រប់គ្រងជាប្រព័ន្ធដែលឈរលើមូលដ្ឋាននៃគណនេយ្យបេឡា (Cash accounting)។ នៅក្នុងប្រព័ន្ធគ្រប់គ្រង ចំណូល និង ចំណាយថវិកា គឺជា ចំណូលជាសាច់ប្រាក់ដែលបានបង់ និង ចំណាយដែលបានចេញជាអាណត្តិបើកប្រាក់ ក្នុងរយៈពេលដប់ពីរខែនៃឆ្នាំថវិកា ។

១.៦.២. ប្រព័ន្ធការិយបរិច្ឆេទ៖ ប្រព័ន្ធការិយបរិច្ឆេទ ជាប្រព័ន្ធថវិកាដែលឈរលើមូលដ្ឋាននៃគណនេយ្យបង្គរ (Accrual accounting)។ នៅក្នុងប្រព័ន្ធការិយបរិច្ឆេទ ចំណូល និង ចំណាយថវិកា គឺជាចំណូល និង ចំណាយថវិកា ដែលកើតមានឡើង នៅក្នុងរយៈពេលដែលបង្កើតឱ្យមានចំណូល និងចំណាយនេះឡើង ដោយមិនផ្សារភ្ជាប់ទៅនឹងការបង់ចំណូលជាសាច់ប្រាក់ចូលក្នុងបេឡា ឬ ការបើកផ្តល់ចំណាយឡើយ ដែលជាគោលការណ៍នៃគណនេយ្យបង្គររបស់សហគ្រាស ។

**២. ការលើកលែងមិនអនុវត្តគោលការណ៍គន្លឹះនៃថវិកា៖** ក្នុងការអនុវត្តជាក់ស្តែង គេឃើញមានការលើកលែងមួយចំនួន ដូចជា ការលើកលែងមិនអនុវត្តគោលការណ៍ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ គោលការណ៍ឯកត្តភាព គោលការណ៍សកលភាព គោលការណ៍វិសេសភាព គោលការណ៍តុល្យភាព និងការលើកលែងមិនអនុវត្តប្រព័ន្ធគ្រប់គ្រង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២១.២. ការរៀបចំថវិកា

### ២១.២.១. ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (មីនាដល់ឧសភា)

នៅសប្តាហ៍ទី១នៃខែមីនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលមានសង្គតិភាពទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។ នៅសប្តាហ៍ទីមួយនៃខែមេសា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលបានកំណត់ដោយរាជរដ្ឋាភិបាល។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចក្ខុវិស័យ គោលបំណង គោលដៅនៃកម្មវិធី និងផែនការសកម្មភាពជាអទិភាពរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបម្រើឱ្យនយោបាយជាអាទិភាពរបស់វិស័យ និងគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍ។ ផែនការយុទ្ធសាស្ត្រថវិកាទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹម ថ្ងៃទី ១៥ ខែ ឧសភា ។

### ២១.២.២. ការរៀបកញ្ចប់ថវិកា (មិថុនាដល់កញ្ញា)

នៅសប្តាហ៍ទី១នៃខែមិថុនារដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំសេចក្តីព្រាងសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំថវិកា ដោយបញ្ជាក់ជូននូវទម្រង់ និងនីតិវិធីនៃការរៀបចំគម្រោងថវិកា ព្រមទាំងធ្វើកំណត់បង្ហាញនិងឯកសារញក់ព័ន្ធ ដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ហើយផ្ញើជូនក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំគម្រោងចំណូល ចំណាយថវិកាលម្អិតរបស់ខ្លួន។ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំនូវគម្រោងចំណូលចំណាយថវិកាលម្អិតរបស់ខ្លួន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និងអាទិភាពនៃគោលនយោបាយរបស់ខ្លួន។ គម្រោងថវិកាទាំងនេះ ត្រូវផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងយឺត បំផុតត្រឹមថ្ងៃទី ១៥ ខែកក្កដា។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងចំណូល ចំណាយថវិការបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល ខេត្ត និង រាជធានីដែលបានស្នើឡើង ។

នៅក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអញ្ជើញរដ្ឋមន្ត្រី ប្រធានគ្រប់ស្ថាប័ន និងប្រធានអង្គភាពប្រហាក់ប្រហែលព្រមទាំងអភិបាលខេត្តគ្រប់និងរាជធានីមកពិភាក្សាការញរគម្រោងថវិការបស់ខ្លួន ដើម្បីសម្របសម្រួលនូវគម្រោងចំណូល ចំណាយថវិកាទាំងនោះអោយបានសមស្របទៅតាម បទប្បញ្ញត្តិនៃការណែនាំដោយមានការកាត់បន្ថយចំណាយដែលមិនចាំបាច់ និងបង្កើនចំណូល អោយបានសមស្រប។ នៅក្នុងអំឡុងខែកញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការបូកសរុបចំណូល ចំណាយរដ្ឋទាំងមូល ដើម្បីតុល្យភាពថវិកាឡើងវិញ រួចរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ។

### ២១.២.៣. ការអនុម័តថវិកា (តុលាដល់ធ្នូ)

នៅសប្តាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបញ្ជូនសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទីមួយនៃខែវិច្ឆិកា ដើម្បីពិនិត្យអនុម័ត និងដាក់ជូនព្រឹទ្ធសភា នៅសប្តាហ៍ទីមួយនៃ ខែធ្នូ ដើម្បីឱ្យសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័តជាស្ថាពរ មុនថ្ងៃទី ២៥ ខែធ្នូ ។

### ២១.២.៤. ការធ្វើចំណាត់ថ្នាក់មុខងាររបស់រដ្ឋាភិបាល

រចនាសម្ព័ន្ធនៃរដ្ឋាភិបាលប្រែប្រួលទៅតាមពេលវេលា និងស្ថានភាពនៃប្រទេសនីមួយៗ។ ករណីនេះ ធ្វើអោយមានការលំបាក ក្នុងការប្រៀបធៀបប្រទេសតែមួយ ពីពេលមួយទៅពេលមួយទៀត និង ក្នុងការប្រៀបធៀប ពីប្រទេសមួយទៅប្រទេសមួយទៀត។ ដើម្បីដោះស្រាយបញ្ហាលំបាកទាំងនេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានបង្កើតចំណាត់ថ្នាក់មុខងារនៃរដ្ឋបាលសាធារណៈ ដែលជាភាសាអង់គ្លេសហៅថា (Classification of Functions of Government—COFOG)។ ចំណាត់ថ្នាក់នេះត្រូវបានយកមកសម្រិតសម្រាំងអោយលម្អិតដោយអង្គការសហប្រជាជាតិ។ ចំណាត់ថ្នាក់មុខងារនៃរដ្ឋបាលសាធារណៈគឺ ការរៀបចំមុខងាររដ្ឋបាលសាធារណៈ អោយមានលក្ខណៈសកល និងជាអចិន្ត្រៃយ៍។

### ២១.២.៥. ការរៀបចំថវិកាតាមកម្មវិធីនិងតាមសកម្មភាព

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ ន.ស./រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ បានជំនួសទាំងស្រុងនូវច្បាប់ស្តីពីប្រព័ន្ធ ហិរញ្ញវត្ថុ ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣។ មាត្រា ២៥ លើកឡើងថាៈ «ឥណទានថវិកា ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានបែងចែកលម្អិតនៅក្នុងផ្ទៃក្នុងប្រភេទនីមួយៗនៅតាមលក្ខណៈ និងគោលដៅនៃឥណទានថវិកា ។ ឥណទានទាំងនេះ អាចធ្វើជាកម្មវត្ថុសម្រាប់ការរៀបចំថវិកាតាមកម្មវិធី និង ការប្រមូលផ្តុំតាមវិស័យផងដែរ ។ ការរៀបចំថវិកាតាមកម្មវិធីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» ។

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ មាត្រា ១៧ អនុញ្ញាតអោយច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំបែងចែកឥណទាន ទៅតាមលក្ខណៈ ឬគោលដៅសេដ្ឋកិច្ចរបស់វា ពោលគឺតាមជំពូក ប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ដែលជា «មធ្យោបាយ»នៃថវិកា។ ការបែងចែកឥណទានថវិកាតាមគោលដៅសេដ្ឋកិច្ចដូច្នេះមិនបានផ្តល់នូវព័ត៌មានអាយោបានគ្រប់គ្រាន់សម្រាប់ការវិភាគការប្រើប្រាស់ថវិកាឡើយ។ ដូច្នេះហើយ កំណែទម្រង់មាតិកាថវិកា និងមាតិកាគណនីជាពិសេស ប្លង់គណនីថ្មី ដែលត្រូវបានដាក់អនុវត្តជាមួយនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ មានដាក់ចេញនូវលេខកូដនៃមាតិកាថវិកា ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងប្លង់គណនីនៃវិស័យឯកជនដែរ ដោយមានការគិត គូបន្ថែមនូវលក្ខណៈពិសេសរបស់រដ្ឋ ។

**បេសកកម្ម៖** គឺជាគោលនយោបាយធំៗរបស់រដ្ឋ ។ បេសកកម្មត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល ដែលអាចគ្របដណ្តប់ក្រសួង-ស្ថាប័នតែមួយ ឬ អាចជាបេសកម្មកម្មអន្តរក្រសួង ។ បេសសកម្មគ្របដណ្តប់កម្មវិធីមួយចំនួន។

**កម្មវិធី៖** កំណត់នូវក្របខ័ណ្ឌដើម្បីអនុវត្តនូវគោលនយោបាយសាធារណៈ។ កម្មវិធី គឺជាក្រុមនៃអនុកម្មវិធី ឬ/និង ក្រុមនៃចង្កោមសកម្មភាពដែលមានលក្ខណៈឯករាជ្យ តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយត្រូវបានរៀបចំឡើង ដើម្បីរួមចំណែកសម្រេចបាននូវគោលបំណងគោលនយោបាយរួមមួយ និងមានបញ្ជាក់ពីសកម្មភាព ដែលត្រូវអនុវត្តលទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ ព្រមទាំងសូចនាករដែលជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី។ កម្មវិធី អាចត្រូវបានបែងចែកជាអនុកម្មវិធី។ កម្មវិធីត្រូវតែស្ថិត នៅក្រោមការគ្រប់គ្រងរបស់មន្ត្រីគ្រប់គ្រងកម្មវិធីម្នាក់។ កម្មវត្ថុដែលឆ្លើយតបទៅនឹងកម្មវិធីមួយ ត្រូវតែអភិវឌ្ឍនិងព្យាករណ៍លទ្ធផលហើយការវាយតម្លៃរបស់លទ្ធផលទាំងនេះ ត្រូវតែពន្យល់ឱ្យបានលម្អិតច្បាស់។

### ២១.២.៥.១. *ការរៀបចំថវិកាតាមកម្មវិធី សកម្មភាពនិងតាមផ្នែក ព្រមទាំងចំណាយ*

**កម្មវិធី** ត្រូវតែបែងចែកតាមសកម្មភាពលម្អិតថែមទៀត។ ការវិភាគប្រភេទនៃចំណាយត្រូវធ្វើឡើងដោយអនុលោមតាមចំណាត់ថ្នាក់តាមមាតិកាសេដ្ឋកិច្ច និង វិធានថវិកា។ ការជ្រើសរើសគោលដៅ ត្រូវតែឆ្លុះបញ្ចាំងនូវអាទិភាពនៃគោលយោបាយ និង យុទ្ធសាស្ត្ររបស់ក្រសួងនីមួយៗ ។

#### ២១.២.៥.១.១. *ការរៀបចំថវិកាតាមផ្នែក*

**ផ្នែក** នីមួយៗឆ្លុះបញ្ចាំងពីមុខងារនៃការអនុវត្តនូវគោលនយោបាយ និង ការផ្តល់សេវា ក៏ដូចជាមុខងារនៃការគ្រប់គ្រងមធ្យោបាយដែលមិនអាចត្រូវបានកំណត់ក្រោមទម្រង់ជាកម្មវិធី។ ផ្នែកទាំងនេះមានគោលដៅជួយដល់ការអនុវត្តកម្មវិធី ឬ ត្រូវបានបែងចែកទាំងស្រុង ឬ តាមផ្នែកខ្លះៗនៃកម្មវិធី ។

#### ២១.២.៥.១.២. *គោលដៅ*

**គោលដៅ** មានលក្ខណៈច្បាស់លាស់ជាង គោលបំណងទូទៅនៃគោលនយោបាយ ហើយអាចប្រែប្រួលទៅតាមពេលវេលា។ គោលដៅត្រូវបានកំណត់ឱ្យបានច្បាស់លាស់ ដើម្បីអាចឱ្យយើងវាស់វែងនូវលទ្ធផល ដែលត្រូវសម្រេចឱ្យបាន។ គោលដៅមានតួនាទីប្រែក្លាយអាទិភាព អោយទៅជាសកម្មភាព។ ដូច្នេះ គោលដៅត្រូវតែផ្សារភ្ជាប់ជាមួយនឹងសូចនាករលទ្ធផល។ គោលដៅ អាចវាស់វែងបានដោយសារតែសូចនាករលទ្ធផលទាំងនេះ ដែលបង្ហាញពីកម្រិតនៃការអនុវត្ត ដោយធៀបនឹងចំណុចដៅដែលត្រូវសម្រេចបាន ក្នុងរយៈពេលមួយសមស្រប។ ដើម្បីវាស់វែងសមិទ្ធកម្ម គោលដៅជាយុទ្ធសាស្ត្រកំណត់ដោយកម្មវិធី ត្រូវបំបែកចេញជា គោលដៅប្រតិបត្តិ សម្រាប់អ្នកទទួលខុសត្រូវតាមសកម្មភាព។ ការជ្រើសរើសកម្មវត្ថុត្រូវតែឆ្លុះបញ្ចាំងពីអាទិភាពគោលនយោបាយនិងយុទ្ធសាស្ត្ររបស់ក្រសួង។ គោលដៅ សូចនាករ និង ចំណុចដៅ ត្រូវបានវាយតម្លៃដោយឈរលើសមិទ្ធកម្ម ក្រោមទិដ្ឋភាពផ្សេងៗ៖ ប្រសិទ្ធិភាពសេដ្ឋកិច្ច-សង្គម គុណភាព សម្រាប់អ្នកប្រើប្រាស់ និង ប្រសិទ្ធភាពនៃការគ្រប់គ្រង។

២១.២.៥.១.៣. *សូចនាករ*

យើងអាចតាមដានការអនុវត្ត និងវាយតម្លៃអំពីសមិទ្ធកម្មនៃកម្មវិធី តាមរយៈសូចនាករនានា។ សូចនាករទាំងនេះអាចត្រូវបានកំណត់ ដោយឈរលើមូលដ្ឋាននៃកត្តាវបិយវត្ថុ (ឧទាហរណ៍ ចំណូល និង ចំណាយ) ឬ ដោយឈរលើមូលដ្ឋាននៃកត្តាគុណភាព (ឧទាហរណ៍ កង្វះខាតស្បៀង ឬ កត្តាពេញចិត្ត)។ យើងអាចប្រមូលទិន្នន័យពាក់ព័ន្ធនឹងសូចនាករទាំងនេះ ដោយប្រើប្រាស់ប្រព័ន្ធរដ្ឋបាល ឬ ប្រព័ន្ធស្ថិតិ ឬ តាមរយៈការអង្កេត (ការអង្កេតប្រជាជន ជំរឿន ការអង្កេតលើការពេញចិត្ត) ។

សូចនាករ ត្រូវតែមានលក្ខណៈត្រឹមត្រូវ អាចយល់បាន គួរឱ្យទុកចិត្តបាន សាមញ្ញ បង្ហាញពីសភាពការណ៍ មានសត្យានុម័ត ប្រែប្រួលទៅតាមព្រឹត្តការណ៍ដែលយើងវាស់វែង មានលក្ខណៈជាក់លាក់ ស្មោះត្រង់ អាចផ្ទៀងផ្ទាត់បាន ព្រមទាំងអាចរកបាន អាចចែករំលែក និងទទួលស្គាល់ដោយភាគីដែលមានការញក់ព័ន្ធ ដោយគ្រាន់តែត្រូវចំណាយដ៏សមរម្យ ។

## ២១.២.៦. កម្មវិធីនិងគម្រោង

ថវិកាជាតិតែងតែបញ្ចូលនូវបញ្ជីគម្រោងវិនិយោគ ដែលធ្វើហិរញ្ញប្បទានដោយថវិការដ្ឋ ដោយថវិការដ្ឋ និងថវិការបស់ដៃគូអភិវឌ្ឍន៍ និង ដោយដៃគូអភិវឌ្ឍន៍ផ្ទាល់តែម្តង ។

ជាគោលការណ៍ គម្រោងនីមួយៗមានលក្ខណៈពិសេសខុសពីគេៈ ដូចជាការសាងសង់សាលារៀន។ ដូច្នេះកម្មវិធីគឺជាសកម្មភាពរួមដែលអូសបន្លាយអស់រយៈពេលដ៏យូរ ដូចជាកម្មវិធីសាងសង់សាលារៀនជាដើម ដែលអាចជាកម្រងនៃកម្មវិធីមួយចំនួន ។

គម្រោងមួយមិនមែនផ្តោតទៅលើតែការវិនិយោគប៉ុណ្ណោះទេ។ គម្រោងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយប្រព័ន្ធព័ត៌មានវិទ្យា និង គម្រោងដាក់អោយអនុវត្តថវិកាតាមកម្មវិធី គឺជាគម្រោង ដែលផ្តោតទៅលើសកម្មភាពជាប្រចាំរបស់រដ្ឋបាលសាធារណៈ ពោលគឺ ដើម្បីផ្តល់នូវការព្យាបាល បង្រៀនសិស្ស ថែទាំផ្លូវ ។ ល។ ដែលរួមបញ្ចូលផងដែរនូវសញ្ញាណគម្រោង ។

## ២១.២.៧. កម្មវិធីសកម្មភាពអទិភាព (PAP)

នៅក្នុងឆ្នាំ ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវក្របខ័ណ្ឌ និង យន្តការដើម្បីអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព (Priority Action Program) ដែលជាកម្មវិធីកំណែទម្រង់ថវិកាមួយដើម្បីធានានូវការអនុវត្ត អោយមានប្រសិទ្ធភាពនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ និង បង្កើតបាននូវល័ក្ខខ័ណ្ឌគ្រប់គ្រាន់សំរាប់ការហក់ឡើងនៃសេដ្ឋកិច្ចជាតិ និង ធានាអោយបាននូវការបែងចែកប្រកបដោយសមធម៌ នូវផ្លែផ្កាដែលបានមកពីកំណើនសេដ្ឋកិច្ចនេះ ។

កម្មវិធីសកម្មភាពជាអាទិភាព ធានាអោយបាននូវការផ្លាស់ប្តូរប្រកបដោយគុណភាពតាមរយៈការបន្ថយការត្រួតពិនិត្យហិរញ្ញវត្ថុមុនចំណាយ (Ex-ante control )និង ពង្រឹងការត្រួតពិនិត្យក្រោយចំណាយ (Ex-post audit) ដើម្បីអនុវត្តអោយបានសម្រេចតាមគោលនយោបាយជំរុញកិច្ចអភិវឌ្ឍន៍អោយបានដល់ភូមិ-ឃុំ។ វិធានការទាំងនេះ គឺ ការកំណត់នូវបទដ្ឋានបច្ចេកទេសក្នុងការពិនិត្យ និង តាមដានការចំណាយថវិកាអោយចំទិសដៅអាទិភាពរបស់វិស័យនីមួយៗ និង អោយបានដល់អង្គភាពមូលដ្ឋាននៅតាមស្រុក ភូមិ និង ឃុំ ដោយបានកាត់បន្ថយនូវនីតិវិធីក្នុងការបើកផ្តល់ថវិកាសំរាប់វិស័យអាទិភាព ដោយធ្វើឱ្យមន្ទីរជំនាញ និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អង្គភាពថ្នាក់កណ្តាលដែលជ្រើសរើសដើម្បីអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ដំណើរការជាអង្គភាពគ្រប់គ្រងថវិកា (Budget Management Center-BMC) ដែលអាចគ្រប់គ្រងថវិកាដោយខ្លួនឯងផ្ទាល់ នៅក្នុងក្រសួងដែលអនុវត្តនូវកម្មវិធីសកម្មភាពជាអាទិភាព ក្នុងគោលដៅសម្រួលដល់ការតាមដានការអនុវត្តកម្មវិធី។ ក្នុងន័យនេះ មានការដាក់ឱ្យអនុវត្តនូវការត្រួតពិនិត្យលទ្ធផលដែលសម្រេចបានក្រោយចំណាយ ដោយប្រៀបធៀបនឹងគោលដៅ ។

ក៏ប៉ុន្តែ ប្រាំពីរឆ្នាំក្រោយការអនុវត្ត PAP ប្រព័ន្ធក្រោយសវនកម្មនៅមិនទាន់ត្រូវបានបង្កើតឡើង ហើយប្រព័ន្ធ PAP ត្រូវបានអ្នកគ្រប់គ្រងយល់ឃើញថា ជាការចំណាយមួយដែលគ្មានដាន ជាក្រដាសស្នាម និងការធ្វើសវនកម្ម។ ប្រការនេះធ្វើឱ្យប្រព័ន្ធ PAP ក្លាយទៅជាប្រព័ន្ធមួយដែលឃ្លាតចេញពីគោលការណ៍គណនេយ្យសាធារណៈ។

ទោះជាយ៉ាងណាក៏ដោយ PAP បានឆ្លុះបញ្ចាំងឱ្យឃើញថាការគ្រប់គ្រងមានការផ្លាស់ប្តូរ ដែលមានសារៈសំខាន់ណាស់សម្រាប់កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ PAP គឺជាឧទាហរណ៍នាំផ្លូវមួយសម្រាប់រៀបចំកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)។ ស្របជាមួយនឹងការធ្វើវិមជ្ឈការថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសម្រេចចិត្តធ្វើវិមជ្ឈការអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ នៅតាមក្រសួងចំណាយ ដើម្បីកាត់បន្ថយនីតិវិធីថវិកា និងបង្កើនល្បឿនការបើកផ្តល់ថវិកា។

## ២១.៣. ការបែងចែកឥណទានថវិកា

### ២១.៣.១. ការបែងចែកឥណទាន

ឥណទានថវិកា ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានបែងចែកលម្អិតនៅក្នុងផ្ទៃក្នុងប្រភេទនីមួយៗទៅតាមលក្ខណៈ និងគោលដៅនៃឥណទានថវិកា ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។ បន្ទាប់ពីច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំចូលជាធរមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំអនុក្រឹត្យបែងចែកឥណទានថវិកាតាមជំពូក ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខា។ ការបែងចែកឥណទានត្រៀមបម្រុង (ចំណាយចរន្ត «បន្ទុកហិរញ្ញវត្ថុ» និង «ចំណាយមិនបានគ្រោងទុក» ដែលទុកសម្រាប់សងការប្រាក់នៃប្រាក់ខ្ចី និងបន្ទុកហិរញ្ញវត្ថុផ្សេងៗ ព្រមទាំងឥណទានត្រៀមបម្រុងសម្រាប់ចំណាយផ្សេងៗ លើមុខសញ្ញាដែលកើតឡើងជាយថាហេតុ) តាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលនីមួយៗត្រូវធ្វើឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ ការរៀបចំថវិកាតាមកម្មវិធី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្លង់គណនីថ្មី និង និងមាតិកាថវិកាថ្មីដែលឆ្លុះបញ្ចាំងនូវប្លង់គណនីនេះ មានគោលដៅដូចតទៅ៖

- បែកចែកចំណាយថវិកាតាម ចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក ៦០-ការទិញ ជំពូក ៦១- ៦២-សេវាខាងក្រៅផ្សេងៗ ជំពូក ៦៣-ពន្ធ និងអាករ ជំពូក ៦៤-បន្ទុកបុគ្គលិក ជំពូក ៦៥-ឧបត្ថម្ភកធន និងជំនួយសង្គម ) ។ ចំណាត់ថ្នាក់មាតិកាថ្មីឆ្លុះបញ្ចាំងពីគណនីនៃគណនេយ្យជាតិ និងប្លង់គណនីថ្មី។

- បែងចែកចំណាយថវិកា តាមចំណាត់ថ្នាក់មុខងារ (រដ្ឋបាលទូទៅ រដ្ឋបាលសង្គមកិច្ច រដ្ឋបាលហិរញ្ញវត្ថុ ការពារជាតិ និងសន្តិសុខ)។ នៅក្នុងផ្នែកនីមួយៗ ឥណទានថវិកាត្រូវបានបែងចែកតាមក្រសួង-ស្ថាប័ន ។

- បែងចែកចំណាយថវិកា ទៅតាមកម្មវិធី ។

ការបែងចែកឥណទានថវិកានៅក្នុងជំពូកនីមួយៗ ទៅតាមគណនី និង អនុគណនី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បន្ទាប់ពីអនុក្រឹត្យបែងចែកឥណទានថវិកា ត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំប្រកាស បែងចែកឥណទានថវិការបស់ក្រសួង ស្ថាប័ន តាមគណនី អនុគណនី តាមរដ្ឋបាលកណ្តាល និង រដ្ឋបាលខេត្ត-ក្រុង។

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមខ្សែបណ្តោយដែលស្ថិតក្រោមឱវាទ។ អាណាប័កដើមខ្សែជាអ្នកបញ្ជាចំណូល និងបញ្ជាចំណាយថវិកាតាមផ្នែករៀងៗខ្លួន ។

រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែល អាចប្រគល់សិទ្ធិជូនអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និង ប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនប្រធានអង្គភាពក្រោមឱវាទប្រធានមន្ទីរជំនាញខេត្ត និងរាជធានី ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកា បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ២១.៣.២. ការធ្វើវិសោធនកម្មលើការបែងចែកឥណទាន

ដោយសារតែការព្យាករណ៍ចំណូល និងចំណាយមិនបានសុក្រឹត ដែលបង្កើតឱ្យមានភាព មិនច្បាស់លាស់នៅក្នុងការអនុវត្តថវិកា ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានបើកច្រកអោយរាជរដ្ឋាភិបាលអោយមានការកែប្រែការបែងចែកឥណទាន នៅពេលអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ។

ការផ្ទេរឥណទានពីក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុកែតម្រូវ។ ប៉ុន្តែការផ្ទេរឥណទានពីក្រសួងមួយ ពីស្ថាប័ន ឬ ពីអង្គភាពសាធារណៈប្រហាក់ប្រហែលមួយទៅមួយទៀត ដោយភាពចាំបាច់នៃការងារពិនិត្យឡើងវិញ ឬ ពង្រឹងរចនាសម្ព័ន្ធ ឬ រដ្ឋបាលរបស់រាជរដ្ឋាភិបាល អាចប្រព្រឹត្តទៅបានដោយអនុក្រឹត្យ ក្នុងករណីការផ្ទេរឥណទាននេះ មិនកែប្រែមុខចំណាយ និងការបែងចែកឥណទានតាមជំពូកនីមួយៗទេ។ ការផ្ទេរឥណទានថវិកា គឺជាការកែប្រែឡើងវិញនូវមុខសញ្ញាចំណាយនៃឥណទានថវិកានោះ។ ដូច្នេះហើយ ទើបច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈតម្រូវអោយការផ្ទេរឥណទានថវិកានេះត្រូវអនុម័តដោយអនុក្រឹត្យ ដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

ការបង្វែរឥណទានពីជំពូកមួយទៅជំពូកមួយ នៅផ្ទៃក្នុងថវិការបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈ ប្រហាក់ប្រហែលត្រូវធ្វើឡើងដោយអនុក្រឹត្យ ក្នុងករណីមិនកែប្រែឥណទានចំណាយមូលធន


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់វិនិយោគ ទៅជាឥណទានចំណាយចរនសម្រាប់ដំណើរការ។ ទន្ទឹមនឹងនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចធ្វើសំណើអនុក្រឹត្យបែងចែកឥណទានថវិកា ដែលកត់ត្រានៅក្នុងចំណាយមិនបានគ្រោងទុក ក្រោមរូបភាពនៃឥណទានបន្ថែមជាគុណប្រយោជន៍ដល់ជំពូកផ្សេងៗរបស់ក្រសួង ស្ថាប័ន ឬ អង្គភាពសាធារណៈប្រហាក់ប្រហែលនានា ដើម្បីទូទាត់ចំណាយដែលមិនបានគ្រោងទុក។

ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យបន្ថែមឥណទាន ដើម្បីអោយក្រសួង ស្ថាប័នប្រើប្រាស់ ក្នុងករណីដែលមានគ្រោះធម្មជាតិ ឬ ភាពចាំបាច់ជាបន្ទាន់ដល់ផលប្រយោជន៍ជាតិ ដោយផ្អែកលើរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ឥណទាននេះ ត្រូវអនុម័តដោយច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលរាជរដ្ឋាភិបាលត្រូវសុំការយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភាភ្លាម នៅពេលដែលស្ថានការណ៍ពិសេសទាំងនេះត្រូវបានចប់សព្វគ្រប់ ។

ការបង្វែរឥណទានពីគណនីមួយទៅគណនីមួយ ឬ ពីអនុគណនីមួយទៅអនុគណនីមួយនៅក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ឥណទានដែលលែងមានមុខសញ្ញាប្រើប្រាស់ នៅក្នុងការិយបរិច្ឆេទនៃឆ្នាំថវិកា អាចត្រូវបានលុបចោលដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីបានទទួលព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទន្ទឹមនឹងនេះ នៅពេលដែលការវិវត្តនៃចំណូល និងចំណាយស្តែងចេញឱ្យឃើញនូវការបាត់តុល្យភាពថវិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញជាប្រកាស ដើម្បីបង្កកមួយចំណែក ឬ ទាំងស្រុងនៃប្រភេទឥណទានមួយចំនួន ដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ។ ក្នុងករណីដែលការបាត់តុល្យភាពនេះមានលក្ខណៈធ្ងន់ធ្ងររាជរដ្ឋាភិបាល អាចធ្វើនីតិវិធីតាមអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយលុបចោលមួយចំណែក ឬ ទាំងស្រុងនៃប្រភេទឥណទានមួយចំនួន ដែលបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុបានបើកច្រកអោយធ្វើនិយ័តភាវូបនីយកម្មនៃការប្រែប្រួលឥណទានថវិកា នៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំបន្ទាប់ ប្រសិនបើច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុពុំអាចធ្វើទៅកើតក្នុងត្រីមាសទី ៤ នៃការិយបរិច្ឆេទនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ។

### ២១.៣.៣. ប្រភេទនៃឥណទានថវិកា

ដោយយោងទៅតាមការប្រើប្រាស់របស់វា ឥណទានថវិកាចរន្ត អាចត្រូវបានបែងចែកជា៖

**ឥណទានបណ្តោះអាសន្ន** (Credits provissonnels)៖ មាត្រាទី១៧នៃច្បាប់លេខ៩៣-០១ចុះថ្ងៃទី២៨ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីច្បាប់ហិរញ្ញវត្ថុនិងប្រព័ន្ធថវិកាបានចែងថា មូលនិធិបម្រុងមិនត្រូវបានបែងចែកអោយក្រសួងណាមួយឡើយ។ មូលនិធិបម្រុងត្រូវបានគ្រោងទុកសម្រាប់ចំណាយផ្សេងៗ ដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ឥណទានបណ្តោះអាសន្នត្រូវបានផ្តល់ជូនសម្រាប់ចំណាយទាំងឡាយ ដែលមិនអាចកំណត់អោយបានច្បាស់ នៅពេលអនុម័តថវិកា។ ការបែងចែកឥណទានបណ្តោះអាសន្ន ត្រូវធ្វើដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប្រការនេះមានន័យថា បរិមាណឥណទានបែបនេះមានលក្ខណៈប៉ាន់ស្មាន។ ឧទាហរណ៍ប្រសិនបើចាំបាច់ ក្នុងករណីមានគ្រោះថ្នាក់ធម្មជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចបំពេញបន្ថែមបឥណទានទាំងនោះ ពីមូលនិធិបម្រុង ដោយចេញអនុក្រឹត្យមួយស្តីពីឥណទានបំពេញបន្ថែម (decret d’advance)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ឥណទានមានកម្រិត** (credits limitatifs) : មាត្រាទី១៨នៃច្បាប់ស្តីពីប្រព័ន្ធថវិកាចែងថា សម្រាប់ឥណទានមានកម្រិត ការធានាចំណាយ (Spending Commitments) និងអាណត្តិបើកប្រាក់ត្រូវបានកម្រិតកំណត់ ដោយច្បាប់ថវិកា។ ឥណទានប្រភេទនេះ អាចបន្ថែមបាន ដោយអនុម័តច្បាប់ហិរញ្ញវត្ថុកែតម្រូវ។ ឧទាហរណ៍ឥណទានសម្រាប់កិច្ចប្រតិបត្តិការនិងការថែទាំ(O&M) ត្រូវបានចាត់ទុកថា ជាឥណទានថវិកាមានកម្រិត។

**ឥណទានប៉ាន់ស្មាន** (Credits evaluatifs) : មាត្រាទី១៨នៃច្បាប់ស្តីពីប្រព័ន្ធថវិកាចែងថា ឥណទានប៉ាន់ស្មានសំដៅលើប្រភេទចំណាយណាដែលចាំបាច់ តែមិនអាចគ្រោងទុកឱ្យបានគ្រប់គ្រាន់ នៅពេលរៀបចំថវិកា។ ប្រការនេះមានន័យថា បរិមាណនៃឥណទានប៉ាន់ស្មានមានភាពបណ្តោះអាសន្ន ហើយឥណទានថវិកានេះ គ្រាន់តែជាការប៉ាន់ស្មានប៉ុណ្ណោះ។ ចំណាយនៃឥណទានប៉ាន់ស្មាន អាចត្រូវបានបង្កើនលើសពីឥណទាន ដែលសភាបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ឥណទានប៉ាន់ស្មានសំដៅទៅលើចំណាយលើការសងបំណុលសាធារណៈ ប្រាក់បៀវត្ស ឬ ចំណាយណាមួយដែលកំណត់ដោយច្បាប់ហិរញ្ញវត្ថុ។

មាត្រាទី២០នៃច្បាប់ស្តីពីប្រព័ន្ធថវិកាចែងថា ថវិកាមូលធនអាចបែងចែកជាបីប្រភេទ ៖

**ឥណទានកម្មវិធី** (Credits de programme)៖ ឥណទាននៃកម្មវិធី គឺជាឥណទានថវិកាដែលឆ្លុះបញ្ចាំងនូវតម្លៃសរុបនៃគម្រោងវិនិយោគតែម្តង។ ឥណទាននៃកម្មវិធី គឺជាឥណទានថវិកា បែងចែកតាមគម្រោងចំណាយមូលធននៃថវិកាទូទៅរបស់រដ្ឋ ដែលអនុម័តដោយរដ្ឋសភា (តារាង គ១) ។ ឥណទាននេះឆ្លុះបញ្ចាំងនូវតម្លៃសរុបនៃគម្រោង ចំណាយមុនឆ្នាំថវិកា កម្រិតទុន វិនិយោគចែកតាមឆ្នាំនីមួយៗ និងទុនសល់សម្រាប់ពេលក្រោយ ។

**ឥណទានភ្ជាប់សន្យា** (Credits d'engagement)៖ ឥណទានភ្ជាប់សន្យា គឺជាឥណទានវិនិយោគដែលអនុញ្ញាតអោយរាជរដ្ឋាភិបាលធ្វើការសន្យា និង អនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់នៅក្រោមអាណាប័ក សម្រាប់ចំណាយចាំបាច់ក្នុងការអនុវត្តកិច្ចវិនិយោគ (មាត្រា ២៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។ ឥណទានភ្ជាប់សន្យាអាចមានតម្លៃគ្មានកំណត់ពេល។ ឥណទាននេះត្រូវបានយោងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ការលុបបំបាត់ជាយថាហេតុ។

**ឥណទានទូទាត់** (Credits de paiement)៖ ឥណទានទូទាត់ គឺជាឥណទានដែលត្រូវបានប្រើប្រាស់សម្រាប់ចេញអាណត្តិ ដែលជាបន្ទុករបស់រដ្ឋ នៅក្នុងកម្រិតនៃឥណទានភ្ជាប់សន្យា។ ឥណទានទូទាត់ដែលមិនបានប្រើនៅពេលបិទការគ្រប់គ្រង (បញ្ចប់ឆ្នាំ) ត្រូវបានលុបចោល និង អាចអនុញ្ញាតឥណទានថ្មីសម្រាប់ឆ្នាំបន្ទាប់ ។ ដូច្នេះ ឥណទានទូទាត់មានតួនាទីធានាបាន នូវការគោរពតាមគោលការណ៍ការិយបរិច្ឆេទមានកាលកំណត់មួយឆ្នាំ ។

### ២១.៣.៤. ច្បាប់ថវិកាកែតម្រូវ

ទោះបីជាការរៀបចំថវិកាមានលក្ខណៈសុក្រឹតយ៉ាងណាក៏ដោយ ការអនុវត្តថវិកាទាមទារ អោយមានការធ្វើវិសោធនកម្មនៃច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ដើម្បីអោយថវិកាឆ្លុះបញ្ចាំងនូវទិដ្ឋភាពប្រាកដនិយម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការធ្វើវិសោធនកម្មត្រូវធ្វើឡើងទៅតាមគោលការណ៍ «អ្នកដែលអនុម័តថវិកា គឺជាអ្នកត្រូវអនុម័តលើវិសោធនកម្មថវិកា» ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយវិភាជន៍ឥណទានថវិកាតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដោយឆ្លុះបញ្ចាំងនូវថវិកាឧបសម្ព័ន្ធ និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ទៅតាមប្រភេទចំណាយចរន្ត និងចំណាយមូលធន ដូចមាននៅក្នុងតារាង «ខ» ចំណាយថវិកាទូទៅរបស់រដ្ឋ តារាង «គ១» ចំណាយជាមូលធននៃថវិកាទូទៅរបស់រដ្ឋ (ឥណទាននៃកម្មវិធី) តារាង «គ២» ចំណាយមូលធននៃថវិកាទូទៅរបស់រដ្ឋ (ឥណទាននៃកម្មវិធី) តារាង «គ៣» ចំណាយមូលធននៃថវិកាទូទៅរបស់រដ្ឋ (ឥណទាននៃកម្មវិធី និង ឥណទានភ្ជាប់សន្យា) តារាង «ឃ» ចំណាយមូលធននៃថវិកាទូទៅរបស់រដ្ឋ (ឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់) ដែលជាតារាងភ្ជាប់ជាមួយនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ។

ការកែប្រែផ្សេងៗទៀតលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្រៅពីអ្វីដែលបានលើកឡើងនៅក្នុងផ្នែក ទី២ ដែលពាក់ព័ន្ធនឹងវិសោធនកម្មលើការបែងចែកឥណទានថវិកា អាចធ្វើទៅបាននៅក្នុងអំឡុងពេលនៃឆ្នាំថវិកាតាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភាអនុម័ត ដូចការអនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដែរ (មាត្រា ៦២នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។

## ២១.៤. គោលការណ៍គណនីសាធារណៈ

### ២១.៤.១. *វិសមិតភាពរវាងអាណាប័ក និងគណនេយ្យករ*

អាណាប័កនិងគណនេយ្យករជាមុខងារពីរដែលចូលរួមក្នុងការអនុវត្តថវិកា។មុខងារទាំងពីរនេះមានវិសមិតភាពនឹងគ្នា។ គោលការណ៍នៃវិសមិតភាពនេះត្រូវបានលើកលែងក្នុងករណីខ្លះនៅពេលអនុវត្ត ដែលជាការលើកលែងជាបទប្បញ្ញត្តិ ដូចជាក្នុង ការអនុវត្តរជ្ជទេយ្យ និង ការលើកលែងជាក់ស្តែង ដូចជាក្នុងករណីការគ្រប់គ្រងតាមព្រឹត្តិការណ៍។

#### ២១.៤.១.១. *អាណាប័ក*

**អាណាប័ក** អាចជាអាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធ ហើយអាចប្រគល់សិទ្ធអំណាចរបស់ខ្លួន ឬ រកអ្នកជំនួសក្នុងករណីអាណាប័កអវត្តមាន ឬ មានធុរៈ (មាត្រាទី ៤ អនុក្រឹត្យលេខ ៨២) ។

អាណាប័កតាមការប្រទានសិទ្ធ ឬ តាមការជំនួស អនុវត្តតាមការផ្ទេរសិទ្ធដោយមានការចុះហត្ថលេខា មិនមែនផ្អែកលើសមត្ថភាព (ឬអំណាច) ឡើយ។ អាណាប័ក ដែលអនុវត្តតាមការផ្ទេរសិទ្ធ ដែលផ្អែកលើសមត្ថភាពមានឈ្មោះថា អាណាប័កទីពីរ (Ordonnateur secondaire)។ ការអនុវត្តបែបនេះមិនអាចធ្វើបានឡើយ ក្នុងក្របខ័ណ្ឌនៃអនុក្រឹត្យ លេខ ៨២ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ក៏ប៉ុន្តែ មាត្រា ៤៨ ថ្មីនៃច្បាប់ ៩៣-១ ចុះថ្ងៃទី ២៨ ខែ ធ្នូ ស្តីពីច្បាប់ហិរញ្ញវត្ថុ និងប្រព័ន្ធថវិកា ដែលបានកែសម្រួលដោយច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០០ មាត្រា ៨ បានចែងថា ៖ «រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាព

សាធារណៈប្រហាក់ប្រហែល អាណាប័កដើមខ្សែនៃថវិការបស់ខ្លួន អាចប្រគល់សិទ្ធិជូនអភិបាលរដ្ឋបាលថ្នាក់ក្រោមជាតិជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការនៃថវិកា ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋមន្ត្រី ប្រធាន ស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលជាអាណាប័កដើមខ្សែនៃថវិការបស់ខ្លួនអាចប្រគល់សិទ្ធិជូនប្រធានអង្គភាពក្រោមឱវាទ ប្រធានមន្ទីជំនាញ ខេត្ត និងរាជធានី ជាអាណាប័កផ្ទេរសិទ្ធិសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកា បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» ។

**អាណាប័កដើមខ្សែ** អាចជាមន្ត្រីគ្រប់គ្រងថវិការដ្ឋ (រដ្ឋមន្ត្រី ប្រធានរដ្ឋបាលសាធារណៈស្វ័យត ឬ ប្រធានស្ថាប័ន) ឬ មន្ត្រីគ្រប់គ្រងថវិកាវិមជ្ឈការៈ ថវិការបស់គ្រឹះស្ថានសាធារណៈ ថវិកាខេត្ត-ក្រុង (អភិបាល) ថវិកាឃុំ-សង្កាត់ (មេឃុំ ឬ ចៅសង្កាត់) ។

**អាណាប័កតាមការប្រទានសិទ្ធិ** អាចជាមន្ត្រីគ្រប់គ្រងថវិការដ្ឋ (ប្រធានរដ្ឋបាលកណ្តាល ឬ រដ្ឋបាល វិមជ្ឈការ អភិបាលខេត្ត-ក្រុង ដែលទទួលបន្ទុកខាងផ្នែកហិរញ្ញវត្ថុនៅក្នុងរដ្ឋបាលខេត្ត-ក្រុង) ។

### *២១.៤.១.២. គណនេយ្យករសាធារណៈ*

“ គណនេយ្យករសាធារណៈត្រូវទទួលខុសត្រូវលើការងារគណនេយ្យ ”។ រាល់ការងារគណនេយ្យត្រូវប្រគល់ការទទួលខុសត្រូវដល់គណនេយ្យករតែម្នាក់គត់។ “ គណនេយ្យករអាចប្រគល់អំណាចរបស់គេទៅឱ្យអ្នកទទួលសិទ្ធិម្នាក់ ឬ ច្រើននាក់ដែលត្រូវបានប្រគល់សិទ្ធិឱ្យដើរតួជំនួសខ្លួន ហើយខ្លួនជាអ្នកទទួលខុសត្រូវ។ ” (មាត្រាទី១៨នៃក្រិតលេខ៨២)។

«គណនេយ្យករសាធារណៈ ត្រូវបានតែងតាំង ដោយមានសេចក្តីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាចាំបាច់។ លិខិតតែងតាំងត្រូវបានផ្សព្វផ្សាយ។ មុននឹងចូលបំពេញការងារគណនេយ្យករសាធារណៈត្រូវធ្វើសច្ចាប្រណិធាន។ គណនេយ្យករទាំងនេះតែងតាំងឡើងសំរាប់អម អាណាប័ក ហើយក្នុងករណីខ្លះ អមគណនេយ្យករសាធារណៈដ៏ទៃទៀតដែលខ្លួនមានការទាក់ទង។ គណ-នេយ្យករសាធារណៈត្រូវផ្តល់របាយការណ៍ យ៉ាងតិចមួយឆ្នាំម្តង» (មាត្រា ១៥ អនុក្រឹត្យលេខ ៨២) ។ គណនេយ្យករសាធារណៈមានពីរប្រភេទ៖ គណនេយ្យករផ្ទាល់របស់រតនាគារ និង គណនេយ្យកររដ្ឋបាល ហិរញ្ញវត្ថុ» (មាត្រា ១៨ អនុក្រឹត្យលេខ ៨២) ។

### *២១.៤.១.៣. ការបែងចែកមុខងារ*

#### ២១.៤.១.៣.១. *កម្រិតអាណាប័ក៖ ដំណាក់កាលរដ្ឋបាល*

«អាណាប័កបញ្ជានូវការអនុវត្តចំណូល និងចំណាយថវិកា» (មាត្រា ៣ អនុក្រឹត្យលេខ ៨២)។ ខាងផ្នែកចំណូល អាណាប័ក (នៅក្នុងដំណាក់កាលរដ្ឋបាល) កំណត់ចំណូល ហើយបន្ទាប់មកដាក់ចេញនូវវិធានការដើម្បីប្រមូលចំណូល ។ ខាងផ្នែកចំណាយ អាណាប័ក ធានាចំណាយ ជម្រះបញ្ជីចំណាយ និង ចេញអាណត្តិបើកប្រាក់ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ក. ចំណូល

«ចំណូលរបស់រដ្ឋរួមមានពន្ធអាករ សិទ្ធិ និងចំណូលប្រហាក់ប្រហែលផ្សេងៗទៀត ផលិតផលនៃទ្រព្យសម្បត្តិរដ្ឋ ការផាកពិន័យទោសទណ្ឌជាប្រាក់កាសផ្សេងៗ និងផលិតផលផ្សេងៗទៀតដែលអនុញ្ញាតដោយច្បាប់» (មាត្រា ២៦ អនុក្រឹត្យលេខ ៨២) ។

«ចំណូលត្រូវកត់ត្រាចូលទាំងស្រុងនូវពន្ធអាករ និង ផលិតផលឯទៀត ដោយគ្មានការកាត់កងរវាងចំណូល និង ចំណាយឡើយ» (មាត្រា ២៧ អនុក្រឹត្យលេខ ៨២)។ ប្រការនេះ គឺជាការអនុវត្តនូវគោលការណ៍សកលភាពថវិកា ។

«ក្នុងលក្ខខណ្ឌដែលបានចែងសំរាប់ចំណូលនីមួយៗ ចំណូលត្រូវបានជម្រះបញ្ជីជាមុនសិន មុននឹងត្រូវបានប្រមូល ។ ឥណទេយ្យដែលបានជម្រះបញ្ជីហើយត្រូវចេញដីការចំណូល។ ការជម្រះបញ្ជី គឺការកំណត់ចំនួនទឹកប្រាក់នៃបំណុលរបស់អ្នកជាប់អាករ» (មាត្រា ២៧ អនុក្រឹត្យលេខ ៨២) ។

ការបញ្ជូនដីកាចំណូលទៅអោយគណនេយ្យករទទួលបន្ទុកប្រមូលចំណូល គឺជាការរៀបចំប្រមូលចំណូល។ ជាធម្មតាការបញ្ជូនដីការចំណូលត្រូវភ្ជាប់មកជាមួយនូវ ដីការអមមួយដែលត្រូវបានប្រើប្រាស់ដើម្បីចុះបញ្ជីការក្នុងគណនេយ្យរដ្ឋបាល (ដោយ អាណាប័ក) ដែលនឹងបញ្ជូនបន្តទៅអោយគណនេយ្យករនៃរតនាគារជាតិដើម្បីចុះបញ្ជីការ។ ដីការអមនេះត្រូវមាន លិខិតយុត្តិការភ្ជាប់មកជាមួយ។

### ខ. ចំណាយ

«ចំណាយថវិការដ្ឋ ត្រូវតែគ្រោងនៅក្នុងថវិកា ហើយត្រូវអនុលោមតាមច្បាប់ និងបទបញ្ជាជាធរមាន» (មាត្រា ៨៥ អនុក្រឹត្យលេខ ៨២) ។

«មុនពេលធ្វើការទូទាត់ ចំណាយត្រូវតែបានធ្វើធានាចំណាយជម្រះបញ្ជី និង ចេញអាណត្តិបើកប្រាក់» (មាត្រា ៨៦ អនុក្រឹត្យ ៨២) ។

**I.** *ការធានាចំណាយ (commitment)*

«ការធានាចំណាយ គឺជាប្រតិបត្តិការដែលរដ្ឋបង្កើត ឬ ទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួន ដែលនឹងនាំអោយមានចំណាយថវិកា» (មាត្រា ៨៧ អនុក្រឹត្យលេខ ៨២) ។

«គ្មានចំណាយសាធារណៈណាមួយក្នុងថវិកាជាតិ ឬ ក្នុងគណនីពិសេសរបស់រតនាគារ អាចយល់ព្រម ឬ ទទួលឱ្យចាប់ផ្តើមអនុវត្តបាន ដោយអាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ បើគ្មានការស្នើសុំជាលាយលក្ខ័អក្សរ និងមានទិដ្ឋាការយល់ព្រមពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ» (មាត្រា៣ អនុក្រឹត្យ លេខ៨១)។

គេតែងតែចោទសួរជារឿយៗថា៖ «តើទំហំទឹកប្រាក់ដែលត្រូវធានាចំណាយមានប៉ុន្មាន ដើម្បីអោយគណនេយ្យនៃការធានាចំណាយឆ្លុះបញ្ចាំង អោយបានត្រឹមត្រូវនូវការធានាចំណាយគតិយុត្តិ ?

គោលការណ៍ទាំងឡាយនៃការធានាចំណាយ និង ការចុះបញ្ជីការគណនេយ្យ បង្កើតជាសំណួរថា៖ តើគេអាចធ្វើការកែតម្រូវសាច់ប្រាក់ តាមរយៈការធានាចំណាយបានដែរឬទេ ?

បទប្បញ្ញត្តិនៃមាត្រា ៨៩ នៃអនុក្រឹត្យលេខ ៨២ បានចែងថា៖ «សង្វាក់នៃការធានាចំណាយប្រចាំខែត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមស្ថានភាពនៃការប្រមូលចំណូលថវិកា» អាចយកទៅបំភ្លឺបញ្ហាដែលបានលើកឡើងខាងលើ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**II.** *ការជម្រះបញ្ជី*

«មុននឹងធ្វើការទូទាត់ ចំណាយត្រូវតែមានការធានាចំណាយ ការជម្រះបញ្ជី និង ចេញអាណត្តិបើកប្រាក់ ជាមុនសិន» (មាត្រា ៤៦ អនុក្រឹត្យលេខ ៨២) ។

«ការជម្រះបញ្ជី មានគោលដៅផ្ទៀងផ្ទាត់ភាពពិតប្រាកដនៃបំណុល និងបញ្ឈប់ទឹកប្រាក់ចំណាយ ។ ការជម្រះបញ្ជីនេះត្រូវធ្វើឡើង ក្រោយពីបានឃើញមូលបត្រ បញ្ជាក់ពីសិទ្ធិរបស់ឥណទាយក» (មាត្រា ៥១ អនុក្រឹត្យ លេខ ៨២) ។

ចំណុចសំខាន់នៃការជម្រះបញ្ជី គឺ ការបញ្ជាក់ពី «សេវាដែលបានផ្គត់ផ្គង់» គោលការណ៍ទូទៅ គឺថា ការទូទាត់អាចអនុវត្តបាន បន្ទាប់ពីសេវាត្រូវបានផ្គត់ផ្គង់ (បៀវត្សរ៍ ការផ្គត់ផ្គង់ទំនិញ និងសេវា ។ល។) ។ នៅក្នុងពេលជម្រះបញ្ជី អាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ ត្រូវផ្ទៀងផ្ទាត់ថា ឥណទាយក (អ្នកផ្គត់ផ្គង់) បានបំពេញកាតព្វកិច្ចទាំងឡាយរបស់ខ្លួន ដូចដែលបានចែងនៅក្នុងបញ្ជាចំណាយៈ បរិមាណ ផ្តល់គុណភាព ការគោរពពេលវេលា ។ បន្ទាប់មក អាណាប័កកំណត់ទំហំទឹកប្រាក់ចំណាយ ។

**III.** *ការចេញអាណត្តិបើកប្រាក់*

«មុននឹងធ្វើការទូទាត់ ចំណាយត្រូវតែ មានការធានាចំណាយ ការជម្រះបញ្ជី និង ចេញអាណត្តិបើកប្រាក់ ជាមុនសិន» (មាត្រា ៤៦ អនុក្រឹត្យលេខ ៨២) ។

«ការចេញអាណត្តិបើកប្រាក់ គឺជាប្រតិបត្តិការរដ្ឋបាល ដែលបញ្ជាអោយរដ្ឋសងបំណុលរបស់ខ្លួន ដោយស្របតាមលទ្ធផលនៃការជម្រះបញ្ជី» (មាត្រា ៥៣ អនុក្រឹត្យលេខ ៨២) ។

«ចំណាយថវិកាត្រូវតែមាន អាណត្តិបើកប្រាក់ ដែលចេញដោយអាណាប័ក។ ក្នុងន័យនេះ អាណាប័កត្រូវចេញអាណត្តិបើកប្រាក់ ដើម្បីទូទាត់ចំណាយថវិកា។ អាណត្តិបើកប្រាក់ដែលចេញដោយអាណាប័កដើមខ្សែ ត្រូវកត់ត្រាតាមប្រភេទនៃឥណទាន ដែលបានផ្តល់ជូនតាមខ្ទង់ថវិកា។ អាណត្តិចេញដោយអាណាប័កផ្ទេរសិទ្ធិ ត្រូវកត់ត្រាតាមប្រភេទនៃឥណទាន ដែលប្រគល់ដោយអាណាប័កដើមខ្សែ តាមរយៈប្រកាសផ្ទេរសិទ្ធិ» (មាត្រា ៥៤ អនុក្រឹត្យលេខ ៨២) ។

«អាណត្តិ និង ប្រកាសផ្ទេរសិទ្ធិលើឥណទាន ត្រូវឆ្លងទិដ្ឋាការជាមុនពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ...» (មាត្រា ៥៥ អនុក្រឹត្យលេខ ៨២) ។

«អាណត្តិចេញដោយរដ្ឋមន្ត្រីក្នុងនាមជាអាណាប័កដើមខ្សែ និង ចេញដោយប្រធាននៃរដ្ឋបាលកណ្តាលក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ ត្រូវបានចាត់ចែងដោយគណនេយ្យករមុខការរបស់រតនាគារជាតិ។ អាណត្តិចេញដោយអភិបាលខេត្ត-ក្រុង ក្នុងនាមអាណាប័កផ្ទេរសិទ្ធិ ត្រូវបានចាត់ចែងដោយគណនេយ្យកររងរបស់រតនាគារ ខេត្ត-ក្រុង ដែលជាមណ្ឌលរបស់អភិបាលខេត្ត-ក្រុងនោះ» (មាត្រា ៥៦ អនុក្រឹត្យលេខ ៨២) ។

ដើម្បីងាយស្រួលតាមដានការចេញអាណត្តិបើកប្រាក់ ជាទូទៅ អាណត្តិទាំងនេះត្រូវបញ្ជូនទៅគណនេយ្យករ ដោយមានកំណត់ហេតុ និង លិខិតយុត្តិការ ភ្ជាប់ជាមួយ ។ គណនេយ្យករទទួលអាណត្តិបើកប្រាក់ទាំងនេះដើម្បីធ្វើការទូទាត់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

IV. *ការទូទាត់*

បន្ទាប់ពីបានពិនិត្យភាពប្រក្រតីនៃអាណត្តិបើកប្រាក់គណនេយ្យករសាធារណៈក្នុងនាមជាបេឡាករ ចាប់ផ្តើមទូទាត់ «ការទូទាត់ គឺជាប្រតិបត្តិការ ដែលរដ្ឋបានសងបំណុលរបស់ខ្លួន» (មាត្រា ៥៧ អនុក្រឹត្យ ៨២)។

«លើកលែងតែក្នុងករណីដែលបានចែងដោយច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ ការទូទាត់មិនអាចឡើងមុនរយៈពេលត្រូវសងបំណុល ឬ មុនការផ្គត់ផ្គង់សេវាឡើយ។ ក៏ប៉ុន្តែ គេអាចផ្តល់នូវការទូទាត់រំដោះ ឬ ផ្តល់បុរេប្រទានឱ្យសហគ្រិន ឬអ្នកផ្គត់ផ្គង់បាន ក្នុងលក្ខខណ្ឌដែលចែងដោយលិខិតបទដ្ឋានជាធរមាន» (មាត្រា ៥៧ អនុក្រឹត្យលេខ ៨២) ។

«គណនេយ្យករមុខការ...ចាប់ផ្តើមរៀបចំទូទាត់អាណត្តិបើកប្រាក់។ ការទូទាត់ត្រូវធ្វើឡើងដោយប្រគល់សាច់ប្រាក់ប្រាក់ មូលប្បទានប័ត្រ ឬ ដោយបង្វែរ » (មាត្រា ៥៨ អនុក្រឹត្យលេខ ៨២) ។

«...រាល់ការបើកផ្តល់ដែលមានទឹកប្រាក់លើសពី២,៥លានរៀលឡើងទៅអាចធ្វើការទូទាត់តាមរយៈធនាគារ ឬ មូលប្បទានប័ត្រ» ប្រការ ៨ ប្រកាសលេខ ៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។

«នៅពេលអនុវត្តការត្រួតពិនិត្យ...បើកត់សម្គាល់ឃើញភាពមិនត្រឹមត្រូវ នោះគណនេយ្យករសាធារណៈត្រូវព្យួរទុកការទូទាត់ ហើយត្រូវផ្តល់ព័ត៌មានដល់អាណាប័ក ។ ការទូទាត់ក៏អាចព្យួរទុកបានដែរ កាលណាគណនេយ្យករសាធារណៈបានពិនិត្យឃើញសេចក្តីបញ្ជាក់ (សេវាដែលបានផ្គត់ផ្គង់) ពុំមានភាពត្រឹមត្រូវ» (មាត្រា ៥៩ អនុក្រឹត្យលេខ ៨២) ។

### ២១.៤.១.៤. *ការងាររបស់គណនេយ្យករ៖ ដំណាក់កាលគណនេយ្យ*

«គណនេយ្យករសាធារណៈ ជាអ្នកទទួលបន្ទុក៖

- ការទទួលខុសត្រូវក្នុងការប្រមូលចំណូល ដែលអាណាប័កបានប្រគល់ឱ្យប្រមូលឥណទេយ្យតាមកិច្ចសន្យា មូលបត្រកម្មសិទ្ធិ ឬ មូលបត្រផ្សេងៗទៀត ដែលគណនេយ្យករត្រូវធានារក្សាទុកដាក់ ព្រមទាំងបញ្ចូលក្នុងបេឡា នូវប្រាក់ពន្ធបង់ដល់ដៃ និងចំណូលគ្រប់ប្រភេទទាំងអស់ ដែលរដ្ឋមាននីតិសម្បទាទទួល
- ទូទាត់ចំណាយ តាមបញ្ជាអាណាប័ក
- ការពារ និងរក្សាទុកនូវមូលនិធិ ទ្រព្យសម្បត្តិនានារបស់រដ្ឋ និងរបស់គ្រឹះស្ថានសាធារណៈផ្សេងៗ
- កាន់កាប់មូលនិធិ និងចលនាគណនីប្រាក់ទំនេរ
- រក្សាទុកដាក់លិខិតយុត្តិការនៃប្រតិបត្តិការចំណូល-ចំណាយ និងឯកសារគណនេយ្យ
- កាន់បញ្ជីគណនី តាមដំណែងរបស់ខ្លួន (មាត្រា ១២ អនុក្រឹត្យលេខ ៨២) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខាងផ្នែកចំណូល និងចំណាយ គណនេយ្យករទទួលបន្ទុកចុះកិច្ចបញ្ជីការប្រតិបត្តិការ បន្ទាប់មកចាត់ការប្រមូលចំណូល ឬ ទូទាត់ចំណាយ បន្ទាប់ពីបានធ្វើការត្រួតពិនិត្យតាមសមត្ថកិច្ចរបស់ខ្លួន ។

**ក. ចំណូល**

*១. ការកំណត់ចំណូល*

បន្ទាប់ពីបានទទួលដីកាចំណូល គណនេយ្យករត្រួតពិនិត្យអត្តសញ្ញាណរបស់ឥណាយិក ពិនិត្យមើលលិខិតយុត្តិការ និង «ពិនិត្យភាពត្រឹមត្រូវនៃដីកាចំណូល» (មាត្រា ១៣ នៃអនុក្រឹត្យ ៨២)។

*២. ការប្រមូលចំណូល*

គណនេយ្យករសាធារណៈត្រូវអោយដំណឹងទៅអោយឥណាយិក នូវទំហំទឹកប្រាក់ដែលត្រូវទូទាត់ និង ទទួលសាច់ប្រាក់នៅពេលទូទាត់ ។

«ប្រសិនបើការប្រមូលចំណូលមិនអាចធ្វើទៅបានដោយស្រុះស្រួលទេ ឥណទេយ្យនឹងត្រូវប្រមូលដោយចាប់បង្ខំ ទៅតាមផ្លូវច្បាប់ ទៅតាមដីកាដែលចាប់បង្ខំអោយធ្វើ» (មាត្រា ៣០ អនុក្រឹត្យ លេខ ៨២) ។

នៅពេលខ្លះ ការបង់ប្រាក់ និង ការកត់ត្រាចំណូលអាចធ្វើឡើងខុសពេលគ្នា ។ ក្នុងករណីនេះ គណនេយ្យករសាធារណៈទទួលសាច់ប្រាក់ចំណូល ហើយដាក់ចូលក្នុងបេឡា បន្ទាប់មកទើបផ្តល់ព័ត៌មានទៅអោយអាណាប័ក និង ស្នើសុំអោយអាណាប័កចេញដីកាចំណូលដើម្បីធ្វើនិយ័តភាពជាក្រោយ ។

**ខ. ការចំណាយ**

*១. ការកត់ត្រាចំណាយ*

គណនេយ្យករសាធារណៈមានមុខងារពីរ ៖

- មុខងារជាអ្នកទូទាត់: ជាអ្នកត្រួតពិនិត្យ និង
- មុខងារជាបេឡាករ: គឺជាអ្នកធ្វើការទូទាត់បំណុលរបស់រដ្ឋ ដោយទូទាត់ឱ្យម្ចាស់បំណុល ដើម្បីអោយរួចផុតពីកាតព្វកិច្ចរបស់រដ្ឋ ដែលជំពាក់បំណុល ។

ផ្ទុយពីការអនុវត្តខាងផ្នែកចំណូល អនុក្រឹត្យលេខ ៨២ មិនបានចែងជាផ្លូវការពីការកំណត់ចំណាយទេ។ ក៏ប៉ុន្តែ អនុក្រឹត្យនេះហាក់ដូចជាបានសង្កត់ថា៖ គណនេយ្យករ ដែលទទួលអាណត្តិពីអាណាប័កត្រូវត្រួតពិនិត្យ និង សម្រេចថាបដិសេធ (បញ្ជូនត្រលប់ទៅវិញ) ឬ ចុះកិច្ចបញ្ជីការចំណាយ ។

«គណនេយ្យករសាធារណៈមានភារៈកិច្ច... ខាងផ្នែកចំណាយ ត្រួតពិនិត្យ ៖

- លក្ខណៈសម្បត្តិរបស់អាណាប័ក ឬ អាណាប័កផ្ទេរសិទ្ធ
- សំណល់ទំនេរនៃឥណទាន
- ការកំណត់ត្រឹមត្រូវពិតប្រាកដខ្ទង់ចំណាយតាមជំពូក ដែលញក់ព័ន្ធដល់រូបធាតុ និងមុខសញ្ញារបស់វា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការបញ្ជាក់ត្រឹមត្រូវអំពីសេវា ដែលបានធ្វើហើយ និងភាពប្រាកដប្រជានៃការគណនាជម្រះឥណទេយ្យ
- ការបញ្ជាក់ទិដ្ឋាការរបស់អភិបាលហិរញ្ញវត្ថុ លើកិច្ចសន្យា និងអាណត្តិ
- ផលិតកម្មលិខិតយុត្តិការនៃឥណទេយ្យ
- ការអនុវត្តវិធានស្តីពីអាជ្ញាយុកាល និងឥណទេយ្យដែលផុតកាលកំណត់ (មាត្រា១៣ អនុក្រឹត្យលេខ ៨២។

## ២១.៤.២. ការអនុវត្តផ្ទុយនឹងគោលការណ៍វិសមិតភាពរវាងអាណាប័កនិងគណនេយ្យករ

ការអនុវត្តផ្ទុយនឹងគោលការណ៍វិសមិតភាពរវាងអាណាប័ក និងគណនេយ្យករគឺ ៖ ទី ១ ការចាប់បង្ខំ និង ទី ២ រដ្ឋទេយ្យករ។ ករណីទាំងពីរនេះសុទ្ធតែត្រូវទទួលការអនុញ្ញាត តែករណីទី ២ គឺជាការគ្រប់គ្រងតាមសភាពការណ៍ជាក់ស្តែង (ករណីពិសេស)។

### ២១.៤.២.១. ចាប់បង្ខំ

តើមានអ្វីកើតឡើងបើគណនេយ្យករបដិសេធមិនទូទាត់ ?

«...នៅពេលដែលគណនេយ្យករព្យួរទុកការទូទាត់ចំណាយណាមួយ...អាណាប័កអាចចាប់បង្ខំជាលាយល័ក្ខអក្សរ...អាយេគណនេយ្យករធ្វើការទូទាត់ក្រោមការទទួលខុសត្រូវរបស់ខ្លួន» (មាត្រា ៨ អនុក្រឹត្យលេខ ៨២) ។

«...នៅពេលដែលអាណាប័កទាមទារបង្ខំអោយគណនេយ្យករធ្វើការទូទាត់នោះ គណនេយ្យករព្រមអនុវត្តតាមបទបញ្ជា រួចហើយរាយការណ៍ជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ បញ្ជាចាប់បង្ខំអោយទូទាត់ ចេញដោយអាណាប័ក នឹងត្រូវបានបញ្ជូនទៅតុលាការគណនី (អាជ្ញាធរសវនកម្មជាតិ) ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» (មាត្រា ៦០ អនុក្រឹត្យលេខ ៨២) ។

«...គណនេយ្យករត្រូវបដិសេធបញ្ជាចាប់បង្ខំអាយេទូទាត់ នៅពេលដែលការព្យួរទុកនៃការទូទាត់នោះ បណ្តាលមកពីមូលហេតុ ដូចខាងក្រោម ៖

- ភាពមិនទំនេរនៃឥណទាន
- ពុំមានទិដ្ឋាការលើអាណត្តិ ដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
- ពុំមានលិខិតយុត្តិការ (ការបញ្ជាក់) ពីសេវាដែលបានផ្គត់ផ្គង់
- ការទូទាត់ដែលមានលក្ខណៈមិនអោយរួចបំណុល

ក្នុងករណីបដិសេធបញ្ជាចាប់បង្ខំអោយទូទាត់ គណនេយ្យករត្រូវរាយការណ៍ភ្លាមជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីដែលពាក់ព័ន្ធ» (មាត្រា ៦១ អនុក្រឹត្យលេខ ៨២) ។

### ២១.៤.២.២. រដ្ឋទេយ្យ និង រដ្ឋទេយ្យករ

នៅពេលខ្លះ បុគ្គលតែម្នាក់អាចមានមុខងារជាអាណាប័កផង និងជាគណនេយ្យករផង: រដ្ឋទេយ្យករ គឺជាភ្នាក់ងារដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាណាប័ក (ដែលផ្ទុយពីគណនេយ្យករសាធារណៈ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និងអាចអនុវត្តប្រតិបត្តិការប្រមូលចំណូល និងទូទាត់ចំណាយ ។

សម្រាប់ការបើកប្រាក់គឺជារដ្ឋទេយ្យចំណូលសម្រាប់ការទូទាត់ចំណាយគឺជារដ្ឋទេយ្យបុរេប្រទាន។

«រដ្ឋទេយ្យចំណូល និងរដ្ឋទេយ្យបុរេប្រទាន ត្រូវបានបង្កើតឡើងដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ។ គណនេយ្យករសាធារណៈរបស់រដ្ឋ ដែលរដ្ឋទេយ្យករធ្វើប្រតិបត្តិការជំនួសហៅថា គណនេយ្យករមុខការរបស់អាណាប័ក ដែលរដ្ឋទេយ្យនោះនៅក្រោមចំណុះ» (មាត្រា ២៣ អនុក្រឹត្យ លេខ ៨២) ។

នៅព្រះរាជាណាចក្រកម្ពុជា រដ្ឋទេយ្យករត្រូវបានតែងតាំងដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ ។ នៅប្រទេសបារាំង រដ្ឋទេយ្យករត្រូវបានតែងតាំងដោយប្រកាសរបស់អាណាប័ក ដោយផ្អែកលើការពិគ្រោះអនុលោម (Avis conforme) របស់គណនេយ្យករមុខការ ។

«រដ្ឋទេយ្យករចំណូល និង និងរដ្ឋទេយ្យករបុរេប្រទាន ស្ថិតក្រោមការត្រួតពិនិត្យរបស់អាណាប័ករបស់ខ្លួន និង គណនេយ្យករមុខការ » (មាត្រា ២៤ អនុក្រឹត្យលេខ ៨២) ។

### ២១.៤.២.៣. គណនីចំណូល និងគណនីបុរេប្រទាន

#### ២១.៤.២.៣.១.*គណនីចំណូល (Revenne Account)*

មន្ត្រីទទួលបន្ទុកគណនីចំណូលអាចទទួលប្រាក់ចំណូល ដោយចេញបង្កាន់ដៃទទួលប្រាក់ ហើយយកចំណូលទាំងនេះទៅដាក់ក្នុងគណនីចំណូល។ឧទាហរណ៍: “ប្រាក់ពិន័យនិងបទល្មើសផ្សេងៗទាក់ទងនឹងការរំលោភច្បាប់ចរាចរ ត្រូវបានប្រមូលទុកដោយនគរបាលតាមបុស្តិ៍ ហើយបង់ចូលគណនីចំណូល ដែលត្រូវបានគេបង្កើតឱ្យទៅជាគណនេយ្យចំណូល បង្កើតឡើងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ មន្ត្រីប៉ូលីសដែលកត់ត្រារាល់ព័ត៌មានផ្ទាល់ខ្លួនត្រូវធ្វើរបាយការណ៍ស៊ើបអង្កេតបទល្មើសដល់អ្នកប្រព្រឹត្តបទល្មើស នៅពេលដែលអញ្ជើញបុគ្គលនោះឱ្យមកបង់ប្រាក់ពិន័យដែលបានពិន័យទៅលើគាត់។” (មាត្រាទី៣នៃសារាចរលេខ៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ឱ្យអនុវត្តក្រឹត្យលេខ៨២ចុះថ្ងៃទី១៦ខែវិច្ឆិកាឆ្នាំ១៩៩៥ ស្តីអំពីច្បាប់ទូទៅនៃគណនេយ្យសាធារណៈ)។

“ មន្ត្រីទទួលបន្ទុកគណនីចំណូល ត្រូវបង់សាច់ប្រាក់ក្នុងគណនីចំណូល យ៉ាងហោចណាស់នៅរៀងរាល់ថ្ងៃទី២៥ នៃខែនីមួយៗ និងនៅថ្ងៃទី៣១ខែធ្នូ ព្រមទាំងនៅពេលណាមួយដែលសាច់ប្រាក់ក្នុងដៃរបស់ពួកគេកើនលើសពីចំនួនខ្ពស់បំផុត ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច។” (មាត្រាទី៤នៃប្រកាសលេខ ៤)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ២១.៤.២.៣.២. *គណនីបុរេប្រទាន (និងមន្ត្រីបើកផ្តល់)*

" ... សម្រាប់ការចំណាយប្រភេទខ្លះ និង សម្រាប់ចំណាយទៅលើការទិញទំនិញ និងការថែទាំក្រោម ៥០០,០០០រៀល គេត្រូវបង្កើតគណនីមួយឡើង។ ម្យ៉ាងវិញទៀត ការបើកប្រាក់បៀវត្ស និងចំណាយទៅលើតាវកាលិកសន្តិសុខសង្គម និងតាវកាលិកអសុពលភាព (invalidity benefits) ត្រូវបានទូទាត់តាមរយៈមន្ត្រីបើកផ្តល់ ...។" (មាត្រាទី៩នៃប្រកាសលេខ ៤)។

"ដរាបណាគ្មានការលើកលែងពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានតែចំណាយដូចខាងក្រោមនេះទេ ដែលអាចត្រូវបានទូទាត់តាមរយៈគណនីបុរេប្រទាន៖ ចំណាយលើគ្រឿងបរិក្ខារធុនតូច (Petty equiment) ដែលតម្លៃរបស់វាមិនលើសពីចំនួន កំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រាក់បៀវត្សបុគ្គលិក ចំណាយពិសេស និង ចំណាយមិនបានគ្រោងទុក ព្រមទាំងចំណាយលើការធ្វើដំណើរ និង ប្រាក់ឧបត្ថម្ភសម្រាប់បេសកកម្ម។" (មាត្រាទី៦៤នៃអនុក្រិតលេខ៨២)។

គណនីបុរេប្រទានដែលគ្រប់គ្រងដោយមន្ត្រីបើកផ្តល់ ត្រូវបានបង្កើតឡើងដោយគណនេយ្យករដែលមន្ត្រីនោះត្រូវរាយការណ៍ជូន៖ "គណនីបុរេប្រទានត្រូវបង្កើតឡើងសម្រាប់មន្ត្រីបើកផ្តល់នីមួយៗ។ បរិមាណនៃមូលនិធិនោះត្រូវកំណត់ឡើងដោយក្របខ័ណ្ឌគតិយុត្តិ ដែលបង្កើតគណនី។ លើកលែងតែមានការលើកលែងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បរិមាណនៃការទូទាត់សម្រាប់បុរេប្រទានជុំនីមួយៗ មិនត្រូវអោយលើសពីមួយភាគប្រាំបីនៃចំណាយប៉ាន់ស្មានប្រចាំឆ្នាំ ដែលត្រូវទូទាត់ដោយមន្ត្រីបើកផ្តល់បុរេប្រទាននេះ។ គណនេយ្យករដែលបានចាត់តាំងឡើងតាមសំណូមពររបស់មន្ត្រីបើកផ្តល់ ត្រូវផ្ទេរសាច់ប្រាក់នេះ ដោយការឯកភាពពីអាណាប័ក។" (មាត្រាទី៦៦នៃអនុក្រឹត្យលេខ៨២)។

មន្ត្រីបើកផ្តល់ជាអ្នកអនុវត្តចំណាយ ដែលត្រូវបានកំណត់ដោយប្រកាស ដែលបង្កើតគណនីនេះ៖ "នៅក្រោមលក្ខខណ្ឌដូចគ្នាដូចបានចែងសម្រាប់គណនេយ្យករសាធារណៈ មន្ត្រីបើកផ្តល់ត្រូវធ្វើការទូទាត់ចំណាយ ដោយការផ្ទេរប្រាក់ ឬ ដោយមូលប្បទានប័ត្រ ទៅចូលគណនីរបស់ពួកគេនៅរតនាគារជាតិ ឬជាសាច់ប្រាក់សុទ្ធ។" (មាត្រាទី៦៦នៃអនុក្រឹត្យ លេខ៨២)។

ជារឿយៗ មន្ត្រីបើកផ្តល់ដាក់ជូនគណនេយ្យករ នូវសក្ខីប័ត្រសម្រាប់ការទូទាត់ចំណាយផ្សេងៗ ក្នុងគោលដៅបំពេញបុរេប្រទាននេះឡើងវិញ៖ មន្ត្រីបើកផ្តល់ដាក់ជូននូវសក្ខីប័ត្រ ដើម្បីទូទាត់ចំណាយ និង រាយការណ៍ជូនអាណាប័ក ក្នុងរយៈពេលយ៉ាងយូរបំផុត មួយខែរាប់ចាប់ពីថ្ងៃទូទាត់លើចំណាយ។ មន្ត្រីរូបនេះមានសិទ្ធិចេញអាណត្តិជម្រះបញ្ជីចំណាយ (expenditure clearance order = mandat de regularisation) សម្រាប់ចំណាយដែលបានផ្ទៀងផ្ទាត់រួច ដើម្បីជាប្រយោជន៍ដល់មន្ត្រីបើកផ្តល់។

រដ្ឋទេយ្យបុរេប្រទាន ត្រូវបំពេញក្នុងមួយលើកៗ តាមទំហំនៃអាណត្តិចំណាយ ដែលត្រូវបានជម្រះបញ្ជីរួច ហើយដែលផ្តល់ជាការបង្កើនឥណទានចូលគណនី ដែលគ្រប់គ្រងដោយមន្ត្រីបើកផ្តល់ និងដែលស្ថិតនៅក្នុងគណនីរបស់គណនេយ្យករ ដែលទទួលបានការចាត់តាំង។ (មាត្រាទី៦៧នៃអនុក្រឹត្យ លេខ៨២)។ នៅពេលបិទគណនី មន្ត្រីបើកផ្តល់ត្រូវពន្យល់អោយគេយល់ នូវប្រតិបត្តិការចំណាយនេះ និងទទួលបាននូវការយល់ព្រមចំពោះប្រតិបត្តិការនេះ ហើយទទួលបាននូវវិញ្ញាបនបត្រស្តីពីការទូទាត់ ប្រសិនបើគណនីនោះគ្មានតុល្យការឥណពន្ធ ឬ តុល្យការឥណទាន។

## ២១.៤.៣. ការមិនអនុវត្តផ្សេងៗទៀតនូវគោលការណ៍ធានាចំណាយជាមុន ការជម្រះបញ្ជី និង ការចេញអាណត្តិបើកប្រាក់

### ២១.៤.៣.១. ការធានាចំណាយ៖ ការមិនអនុវត្តគោលការណ៍

«គ្មានចំណាយជាសាធារណៈណាមួយក្នុងថវិកាជាតិ ឬ ក្នុងគណនីពិសេសរបស់រតនាគារ (ឬក្នុងថវិកាឧបសម្ព័ន្ធ) អាចយល់ព្រម ឬ ទទួលឱ្យចាប់ផ្តើមអនុវត្តបានដោយអាណាប័កដើមខ្សែ ឬ ដោយអាណាប័កផ្ទេរសិទ្ធ បើគ្មានការស្នើសុំជាលាយលក្ខអក្សរ និងមានទិដ្ឋាការយល់ព្រម ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេនោះ» (មាត្រា ៣ អនុក្រឹត្យលេខ ៨១) ។

ចំណាយជារដ្ឋទេយ្យអាចចាត់ទុកថា ជាចំណាយដែលមិនបានអនុវត្តនូវគោលការណ៍ធានាចំណាយជាមុន។ ដូចគ្នានេះដែរ ការបញ្ជាដែលត្រូវបានធានាចំណាយ និង ចេញអាណត្តិក្នុងពេលដំណាលគ្នា (មានន័យថា ការបញ្ជានេះមិនមានការធានាចំណាយជាមុនទេ ហើយវិក្កយប័ត្រត្រូវបានទទួល) ។ អនុក្រឹត្យលេខ ៨១ បានចែងផងដែរពីការលើកលែងទិដ្ឋាការ ៖

«ត្រូវបានលើកលែងទិដ្ឋាការចំពោះ ៖

ទីមួយ-ចំណាយដែលមានលក្ខណៈមិនទៀងទាត់ ដែលមានទឹកប្រាក់កំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចាត់ទុកជាចំណាយមិនទៀងទាត់ គឺចំណាយមិនប្រក្រតី ហើយមិនអាចប្រមូលផ្តុំ ទៅលើការងារផ្គត់ផ្គង់ ឬ សេវាកម្ម។ ចំណាយទាំងនេះត្រូវបានកត់ត្រាទុកដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ក្រោយពីបានចុះកិច្ចសន្យា ។

ទីពីរ-ចំណាយផ្តល់តាមបុរេប្រទាន ។

ទីបី-ចំណាយដែលទាក់ទងនឹងករណីដោយឡែក ដែលប៉ះពាល់ដល់វិស័យយោធា-សន្តិសុខជាតិ ហើយត្រូវរក្សាការសម្ងាត់» (មាត្រា ១១ អនុក្រឹត្យ ៨១) ។

«ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ នៃឆ្នាំនីមួយៗ និងកម្រិតមួយភាគដប់ពីរ នៃឥណទានប្រចាំឆ្នាំកំពុងអនុវត្ត ការធានាចំណាយជាប្រក្រតីអាចធ្វើបាន ក្នុងករណីមានភាពប្រញាប់ដែលទាមទារឱ្យធ្វើការធានាចំណាយនៃឥណទាននៃឆ្នាំបន្ទាប់។ ការធានាចំណាយនេះមានន័យថា សេវាមិនអាចផ្គត់ផ្គង់មុនថ្ងៃទី ០១ មករា បានឡើយ» (មាត្រា ១១០ អនុក្រឹត្យលេខ ៨២)។ ត្រង់ចំណុចនេះហើយ ដែលគោលការណ៍ថវិកាប្រចាំឆ្នាំមិនត្រូវបានអនុវត្ត ។

### ២១.៤.៣.២. ការជម្រះបញ្ជី៖ ការមិនអនុវត្តតាមគោលការណ៍

ការមិនអនុវត្តតាមគោលការណ៍ គឺនៅក្នុងករណីដែលមានការទូទាត់ជាមុនមុនពេលផ្គត់ផ្គង់ទំនិញ និង សេវា ឬ ការទូទាត់ជាដំណាក់កាល នៅក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ។

#### ២១.៤.៣.៣. *ការចេញអាណត្តិបើកប្រាក់៖ ការមិនអនុវត្តតាមគោលការណ៍*

ប្រទេសមួយចំនួនមិនអនុវត្តនូវនីតិវិធីចេញអាណត្តិបើកប្រាក់ នៅក្នុងករណីចំណាយលើសេវាបំណុល ចំណាយប្រាក់បៀវត្សរ៍ និង ប្រាក់សោធននិវត្តន៍។

ម៉្យាងវិញទៀត ចំណាយលើសោហ៊ុយធនាគារត្រូវបានកាត់ទុកដោយគ្មានការធានាចំណាយ និងដោយមិនបានចេញអាណត្តិបើកប្រាក់។ ធនាគារត្រូវផ្តល់ព័ត៌មាននេះដល់អាណាប័ក ដើម្បីធ្វើនិយ័តភាព។

## **២១.៥. ការត្រួតពិនិត្យហិរញ្ញវត្ថុ**

តួអង្គទីបីនៃការគ្រប់គ្រងចំណាយសាធារណៈ ដែលបានពិភាក្សារួចមកហើយនោះ គឺជាការត្រួតពិនិត្យហិរញ្ញវត្ថុ។ អនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល ចែងថា «...ការត្រួតពិនិត្យហិរញ្ញវត្ថុ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» ។

«ការត្រួតពិនិត្យហិរញ្ញវត្ថុមានមុខងារសំខាន់ ក្នុងការត្រួតពិនិត្យជាមុន នូវសក្ខីប័ត្រចំណាយថវិកាជាតិ និង គណនីពិសេស។ ម៉្យាងទៀត ការត្រួតពិនិត្យហិរញ្ញវត្ថុអាចជួយក្នុងការផ្ទៀងផ្ទាត់ពេលក្រោយ នៅនឹងកន្លែង លើការអនុវត្តចំណាយសាធារណៈ» (មាត្រា ១ អនុក្រឹត្យលេខ ៨១) ។

«ការត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅរដ្ឋបាលកណ្តាល និងអង្គភាពនានាក្នុងខេត្ត-ក្រុង ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងនៅអង្គការសាធារណៈរដ្ឋបាល» (មាត្រា ២ អនុក្រឹត្យលេខ ៨១) ។

### ២១.៥.១. *តួនាទីរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ*

តួនាទីរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ គឺ ដើម្បីត្រួតពិនិត្យ និងចុះបញ្ជីកាគណនេយ្យ រាល់កិច្ចសន្យា និងអាណត្តិបើកប្រាក់ ផ្តល់ព័ត៌មានដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការគ្រប់គ្រងរដ្ឋបាល ដែលខ្លួនត្រួតពិនិត្យ និង ផ្តល់យោបល់ដល់អាណាប័កលើការគ្រប់គ្រងហិរញ្ញវត្ថុ និងបញ្ហានានាញក់ព័ន្ធដល់ការសម្រេចចិត្ត ។

#### ២១.៥.១.១. *ការត្រួតពិនិត្យមុនចំណាយ*

##### ២១.៥.១.១.១. *ទិដ្ឋាការធានាចំណាយ*

យើងបានឃើញរួចមកហើយនៅក្នុងផ្នែកធានាចំណាយ ដែលបានចែងថា «គ្មានចំណាយសាធារណៈណាមួយក្នុងថវិកាជាតិ ឬ ក្នុងគណនីពិសេសរបស់រតនាគារ អាចយល់ព្រម ឬ ទទួលអោយចាប់ផ្តើមបានដោយអាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធ បើគ្មានការស្នើសុំជាលាយល័ក្ខអក្សរ និងមានទិដ្ឋាការយល់ព្រមពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេនោះ» (មាត្រា ៣ អនុក្រឹត្យលេខ ៨១) ។

«មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុពិនិត្យពីភាពត្រឹមត្រូវនៃការស្នើសុំចំណាយ ហើយការពិនិត្យនេះផ្អែកលើកត្តាដូចខាងក្រោមនេះ ៖

- កម្មវត្ថុនៃចំណាយ
- បន្ទុកចំណាយនៃថវិកា ដែលត្រឹមត្រូវតាមបទបញ្ជាផ្សាយចេញពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រភេទនៃចំណាយ ស្របតាមការកំណត់នៃសៀវភៅថវិកា ដែលមានចែងជាឥណទានថវិកា
- ភាពត្រឹមត្រូវក្នុងការវាយតម្លៃនៃចំណាយ
- ភាពទំនេរនៃឥណទាន
- ការអនុវត្តត្រឹមត្រូវទៅតាមបទប្បញ្ញត្តិច្បាប់ហិរញ្ញវត្ថុ ព្រះរាជក្រឹត្យ ព្រះរាជក្រម និងបទបញ្ជាផ្សេងៗជាធរមាន
- ចំណាយត្រូវធ្វើអាយេបានត្រឹមត្រូវទៅនឹងកិច្ចការរៀបចំថវិកា (មាត្រា ៤ អនុក្រឹត្យលេខ ៨១) ។

«មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានរយៈពេល ៤ ថ្ងៃធ្វើការដើម្បីរៀបចំយោបល់របស់ខ្លួន ។ ផុតរយៈពេលនេះ ចាត់ទុកថាមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុយល់ព្រមដោយស្វ័យប្រវត្តិ ហើយចំណាយត្រូវបានចាប់ផ្តើមអនុវត្ត» (មាត្រា ៧ អនុក្រឹត្យលេខ ៨១) ។

«ក៏ប៉ុន្តែ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអាចសុំធ្វើការបំភ្លឺផ្តល់ព័ត៌មាន ឬ សេចក្តីបញ្ជាក់បន្ថែម បើយល់ថាជាការចាំបាច់ ។ ក្នុងករណីនេះ រយៈពេលកំណត់ខាងលើត្រូវផ្អាកជាបណ្តោះអាសន្ន រហូតដល់ពេលការផ្តល់ឯកសារនានាបានចប់សព្វគ្រប់ » (មាត្រា ៧ អនុក្រឹត្យលេខ ៨១) ។

«ក្នុងរយៈពេលនេះ គ្មានអន្តរាគមន៍ណាមួយ ដែលអាចរំលងទិដ្ឋាការរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុបានទេ ក្រៅពីសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» មាត្រា ៨ អនុក្រឹត្យលេខ ៨១ ។

«ទិដ្ឋាការត្រូវបានផ្តល់ដោយផ្ទាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំពោះចំណាយទាំងឡាយ ដែលមានទឹកប្រាក់លើសពីទឹកប្រាក់កំណត់ដោយអនុក្រឹត្យ» (មាត្រា ១០ អនុក្រឹត្យលេខ ៨១) ។

### ២១.៥.១.១.២. *ទិដ្ឋាការលើអាណត្តិបើកប្រាក់ និងលើប្រកាសសិទ្ធិប្រទានឥណទាន*

«អាណត្តិ និងប្រកាសសិទ្ធិប្រទានឥណទាន ត្រូវឆ្លងទិដ្ឋាការជាមុនពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ» (មាត្រា ៥៥ អនុក្រឹត្យលេខ ៨២) ។

ទិដ្ឋាការនេះ អាចអោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទទួលបានព័ត៌មានចាំបាច់ទាំងអស់ ដើម្បីគ្រប់គ្រងបញ្ជីគណនេយ្យ ការចេញអាណត្តិ ធៀបនឹងឥណទានដែលបានធានាចំណាយរួម និង អាចឱ្យចេញអាណត្តិ ដោយអនុលោមតាមការធានាចំណាយដែលនឹងត្រូវជម្រះ ទាំងស្រុង ឬ មួយផ្នែក ។ អនុក្រឹត្យលេខ ៨១ មិនបានចែងលម្អិតត្រង់ចំណុចនេះឡើយ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២១.៥.២. ការមិនអនុវត្តតាមគោលការណ៍

### ២១.៥.២.១. វដ្តទេយ្យបុរេប្រទាន

យើងបានដឹងពីខាងលើរួចមកហើយ ក្នុងក្របខណ្ឌវដ្តទេយ្យ ដែលបានមិនបានអនុវត្តគោលការណ៍ធានាចំណាយជាមុន (Engagement préalable) ។ ការមិនអនុវត្តផ្សេងៗទៀតតាមគោលការណ៍ មានការផ្តល់ការធានាចំណាយសរុប (Engagement global) និង ការធានាចំណាយបណ្តោះអាសន្ន (Engagement prévisionnel) ។

### ២១.៥.២.២. ការធានាចំណាយសរុប

«អាណាប័កដើមខ្សែឬផ្ទេរសិទ្ធិអាចផ្តល់ការធានាចំណាយសរុបចំពោះចំណាយដែលមានលក្ខណៈដដែលៗ នៅដើមឆ្នាំថវិកា ឬ នៅពាក់កណ្តាលឆ្នាំថវិកា។ ទិដ្ឋាការនៃការធានាចំណាយសរុប ដែលផ្តល់ដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ គ្របដណ្តប់ទំហំទឹកប្រាក់សរុប និង គ្របដណ្តប់ចំណាយទាំងអស់នៃបន្ទាត់ថវិកាតែម្តង ហើយអាណាប័កមិនចាំបាច់ឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីទទួលបាននូវការធានាចំណាយដាច់ដោយឡែក សម្រាប់ចំណាយមួយលើកៗឡើយ» (មាត្រា ១២ អនុក្រឹត្យលេខ ៨១) ។

«នីតិវិធីនៃការធានាចំណាយសរុបត្រូវអនុវត្តជាអាទិ៍ចំពោះចំណាយដូចតទៅ៖ ចំណាយលើបៀវត្សរ៍ និងប្រាក់បំណាច់បន្ទាប់បន្សំ ចំណាយមានលក្ខណៈជាប្រក្រតី ប្រាក់ឈ្នួល ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល ចំណាយសំរាប់សងបំណុលសាធារណៈ ការបង់វិភាគទានអង្គការអន្តរជាតិ ចំណាយដែលត្រូវផ្តល់ក្នុងក្របខណ្ឌលទ្ធកម្មសាធារណៈ (មាត្រា ១៣ អនុក្រឹត្យលេខ ៨១) ។

### ២១.៥.២.៣. ការធានាចំណាយបណ្តោះអាសន្ន

«អាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ អាចសុំចុះធានាចំណាយបណ្តោះអាសន្ន ចំពោះចំណាយ...៖ ចំណាយលើសម្ភារៈ និង ការគ្រប់គ្រង ចំណាយលើការសងថ្លៃឈ្នួល និង ចំណាយអន្តរាគមន៍សាធារណៈក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌» (មាត្រា ១៥ អនុក្រឹត្យលេខ ៨១)។

«ចំណាយបណ្តោះអាសន្នអនុញ្ញាតអោយអាណាប័កសុំ តាមរយៈមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងខ្ទង់ថវិកានីមួយៗ មួយចំណែកនៃឥណទាន កំណត់ដោយច្បាប់ហិរញ្ញវត្ថុ ជាគោលការណ៍ស្មើមួយភាគបួននៃថវិកាផ្តល់ប្រចាំឆ្នាំ។ ចំនួននេះអាចបន្ថែម ឬ បន្ថយបានដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមប្រភេទចំណាយ និង ស្ថានភាពសាច់ប្រាក់របស់រដ្ឋ» (មាត្រា ១៦ អនុក្រឹត្យលេខ ៨១)។ «សំណើតំបូងនៃធានាចំណាយបណ្តោះអាសន្ន មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវតែផ្តល់ទិដ្ឋាការជូន ទោះបីជាអាណាប័កមិនបានភ្ជាប់មកជាមួយនូវសក្ខីប័ត្រគ្រប់គ្រាន់ក៏ដោយ។ សំណើបន្ទាប់នៃការធានាចំណាយបណ្តោះអាសន្ន ត្រូវភ្ជាប់មកជាមួយនូវ សក្ខីប័ត្រនៃសំណើលើកមុន ហើយត្រូវបានចុះទិដ្ឋាការជូនត្រឹមចំនួនទឹកប្រាក់ដែលមានសក្ខីប័ត្រប៉ុណ្ណោះ» (មាត្រា ១៧ អនុក្រឹត្យលេខ ៨១) ។

## ២១.៦. ការត្រួតពិនិត្យខាងក្រៅ

ការផ្លាស់ប្តូរព័ត៌មានជាបន្តបន្ទាប់រវាងអាជ្ញាធរសវនកម្មជាតិនិងគ្រឹះស្ថានដែលត្រូវធ្វើសវនកម្ម។

## ២១.៧. ថវិការបស់ខេត្តនិងរាជធានី

តាំងពីឆ្នាំ ១៩៩៣ មក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានធ្វើការលើកកំណែទម្រង់ថវិកា។ កំណែទម្រង់លើកទីមួយបានទទួលជោគជ័យ ក្នុងការប្រមូលផ្តុំរាល់ចំណូល និង ចំណាយថវិកាជាតិឱ្យបិតនៅក្រោមថវិការួមគ្នាមួយ។ ការផ្តល់សេវាតាមវិស័យនៅតាមខេត្តត្រូវមានថវិកាមួយកញ្ចប់ ដែលជាថវិការបស់ក្រសួងតាមវិស័យនីមួយៗ។ នៅក្នុងក្របខ័ណ្ឌនេះ រដ្ឋបាលខេត្តក្រុង ត្រូវបានគេចាត់ទុកថា ជាការផ្តល់សេវារបស់រដ្ឋ ដោយគ្រប់គ្រងថវិកាថ្នាក់កណ្តាលនៅក្នុងរដ្ឋបាលខេត្ត ក្រុងតែប៉ុណ្ណោះ មានន័យថាពួកគេគឺជារដ្ឋបាលវិមជ្ឈការ។ រដ្ឋបាលទាំងនេះគ្មានអំណាចអ្វីលើសអំណាច ដែលបានធ្វើប្រតិភូកម្មដល់ពួកគេដោយរដ្ឋាភិបាលថ្នាក់កណ្តាល ហើយពួកគេក៏គ្មានថវិកា ឬ ធនធានផ្ទាល់ណាមួយរបស់ខ្លួនដែរ។

ជាការពិតណាស់ ខេត្ត ក្រុងមានតម្រូវការលើសពីធនធាន ដែលរដ្ឋបាលថ្នាក់កណ្តាលតាមវិស័យបានផ្តល់ជូន។ ចំណាយទាំងអស់នោះ គឺដើម្បីបម្រើផលប្រយោជន៍របស់ខេត្តនោះ។ ជាជាងប្រមូលផ្តុំចំណាយទាំងនោះ ការធ្វើវិមជ្ឈការ ដើម្បីអោយខេត្ត ឬ ក្រុងពាក់ព័ន្ធដោះស្រាយបញ្ហាតាមមូលដ្ឋានរបស់ពួកគេ នឹងបង្កើនប្រសិទ្ធិភាពនៃចំណាយសាធារណៈ។ បញ្ជីគម្រោងបែបនេះអាចត្រូវបានពង្រីក ឬ កាត់បន្ថយ អាស្រ័យលើលទ្ធភាពនៃធនធានតាមមូលដ្ឋាន។ ក៏ប៉ុន្តែ អាជ្ញាធរមូលដ្ឋានត្រូវផ្តល់សេវាកម្មកម្រិតអប្បបរមា ផ្តល់ព័ត៌មានរដ្ឋបាលដល់ប្រជាពលរដ្ឋ ជួយសម្រួលដល់ជីវភាពរបស់ប្រជាជនតាមមូលដ្ឋាន ពង្រឹងសាមគ្គីភាព និងពង្រីកសេវាសាធារណៈអោយបានដល់ប្រជាពលរដ្ឋមូលដ្ឋាន។ល។

ក្នុងគោលដៅឆ្លើយតបទៅនឹងតម្រូវការចំណាយទាំងអស់នេះ ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ បានចាប់ផ្តើមធ្វើវិមជ្ឈការជំហានដំបូង ក្នុងគោលដៅផ្តល់អោយខេត្ត និង ក្រុងនានាចាប់ផ្តើមគិតគូពីសកម្មភាព ដែលមូលដ្ឋានអាចផ្តល់ជូនបន្ថែមលើសេវាសាធារណៈជាប្រពៃណីរបស់ក្រសួងថ្នាក់កណ្តាល។ ច្បាប់ថវិកាផ្តល់ឱ្យខេត្ត និង ក្រុងនូវធនធានផ្ទាល់មួយចំនួន ដើម្បីបម្រើអោយការអភិវឌ្ឍមូលដ្ឋាន។

ច្បាប់ស្តីអំពីហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង (ក្រមលេខ០២៩៨-០៣ CSDR ចុះថ្ងៃទី២៥ខែកុម្ភៈ ឆ្នាំ១៩៩៨) បានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធថវិកាវិមជ្ឈការដ៏ប្រុងប្រយ័ត្នមួយ។ ច្បាប់ស្តីពីថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ បានបង្កើតអោយមានថវិកាខេត្តនិងក្រុង ដោយផ្ទេរប្រភពចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធមួយចំនួន ក្នុងគោលដៅធានាអោយខេត្ត និង ក្រុងមានចំណូលផ្ទាល់។ ច្បាប់លេខ ២៩៨ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត-ក្រុង បានចែងក្នុងមាត្រា ទី ២ ថា «ខេត្ត និងក្រុង ជានីតិបុគ្គលនៃច្បាប់សាធារណៈ ។ ខេត្ត-ក្រុង...មានថវិកា និងទ្រព្យសម្បត្តិទាំងឡាយដែលកំណត់ដោយច្បាប់» ។

«ថវិកាស្វយ័តត្រូវបំពេញដោយចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ» (មាត្រា ៧)។ «គម្រោងថវិកាខេត្ត-ក្រុង...ត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ...យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១ ខែ កញ្ញា

នៃឆ្នាំនីមួយៗ...។ គម្រោងថវិកាខេត្ត-ក្រុងទាំងអស់ ជាកញ្ចប់រួមដែលត្រូតពិនិត្យ និងអនុម័តដោយសភាជាតិក្នុងក្របខ័ណ្ឌនៃថវិកាទូទៅរបស់រដ្ឋ។ កញ្ចប់នេះ ត្រូវបានបែងចែករវាងខេត្ត-ក្រុង តាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពី បានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ» (មាត្រា ១៨)។

«ឥណទានដែលបានបម្រុងដោយរដ្ឋ សម្រាប់កម្មវិធីអភិវឌ្ឍន៍...និងគម្រោងថ្នាក់ខេត្ត...ត្រូវបានផ្ទេរទៅអោយថវិកាខេត្ត-ក្រុង និងត្រូវចាត់ទុកជាប្រភពធនធាន និងចំណាយផ្ទាល់ ដោយអនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុ» (មាត្រា ១៩) ។

«ត្រូវបានបង្វែរពីថវិការដ្ឋ ចូលទៅថវិកាខេត្ត-ក្រុង នូវចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធដូចខាងក្រោម៖ (១) ចំណូលសារពើពន្ធ៖ ពន្ធលើដី-ធ្លី ដែលមិនបានប្រើប្រាស់ ពន្ធប្រថាប់ត្រា ពន្ធប៉ាតង់ ពន្ធលើសត្តឃាតដ្ឋានពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ(២)ចំណូលមិនមែនសារពើពន្ធ៖ ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាតនៅក្នុងខេត្ត ផលទុននៃរដ្ឋាករទឹកនៅខេត្ត-ក្រុង ចំណូលពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ផ្សារ ចំណតរថយន្ត កំពង់ចំលង-សាឡាង កន្លែងលក់ ដេញថ្លៃ) និង ចំណូលមិនិមែនសារពើពន្ធផ្សេងៗទៀតរបស់ខេត្ត។

«រដ្ឋប្រគល់អាយេខេត្ត-ក្រុងនីមួយៗ នូវសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិសាធារណៈអចលនៈវត្ថុមួយចំនួន ដែលស្ថិតនៅក្នុងមណ្ឌលដែនដីនៃខេត្ត-ក្រុង...» (មាត្រា ៩)។

## ២១.៨. ថវិកាឃុំ

ពាក់ព័ន្ធទៅនឹងវិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ដូចខាងក្រោមត្រូវបានដាក់ឱ្យអនុវត្ត ៖

- ច្បាប់ស្តីអំពីរដ្ឋបាលនិងការគ្រប់គ្រងឃុំនិងសង្កាត់ (ក្រមលេខ៣០១/០៥ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០១)
- អនុក្រឹត្យចុះថ្ងៃទី១៦ខែកុម្ភៈឆ្នាំ ២០០២ ស្តីអំពីការបង្កើតមូលនិធិឃុំ/សង្កាត់
- អនុក្រឹត្យចុះថ្ងៃទី២៦ខែមេសាឆ្នាំ ២០០២ ស្តីអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ។

«ឃុំមានធនធានហិរញ្ញវត្ថុផ្ទាល់ ថវិកា និង បេតិកភ័ណ្ឌ» (មាត្រា ៧៣) ។ «ឃុំ-សង្កាត់ មានសិទ្ធិទទួលចំណូលផ្ទាល់ ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ និង ចំណូលផ្សេងៗសម្រាប់សេវាដែលបានផ្តល់ ។ ចំណូលទាំងនេះនឹងត្រូវទទួលបាន ក្នុងពេលជាមួយគ្នានឹងការទទួលពន្ធលើដី-ធ្លី ពន្ធលើអចលនទ្រព្យ និងពន្ធលើការជួល ។

នៅពេលដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់ពីឃុំ-សង្កាត់ ការប្រមូលនេះត្រូវធ្វើឡើងក្នុងនាមឃុំ-សង្កាត់។ ប្រភេទនៃចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ទំហំទឹកប្រាក់ របៀបទទួល និងចំណូលផ្សេងៗទៀតលើសេវាដែលបានផ្តល់ ត្រូវតែកំណត់ដោយច្បាប់» (មាត្រា ៧៤)។ «ឃុំ-សង្កាត់អាចទទួលការវិភាជន៍បន្ថែមពីរដ្ឋ ។ ការវិភាជន៍នេះមានប្រភពមកពី៖

- ការបង្វែរដោយផ្នែកនៃចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធរបស់រដ្ឋ
- ទាយជ្ជទាន និង ឧបត្ថម្ភកធន ឬ ឧបត្ថម្ភមករដ្ឋ
- ធនធាន ដែលបានបញ្ជាក់ខាងលើ ត្រូវបង្វែរទៅឃុំ-សង្កាត់ តាមរយៈរតនាគារខេត្ត
- ការរៀបចំ និងនីតិវិធីនៃការបង្វែរធនធាន ត្រូវកំណត់ដោយអនុក្រឹត្យ» (មាត្រា ៧៥)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

«ឃុំ-សង្កាត់នីមួយៗមានសិទ្ធិទទួលធនធានសំរាប់ការប្រតិបត្តិលើបេសកកម្ម ដែលបានប្រគល់អោយដោយរដ្ឋ ឬស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងនាមជាភ្នាក់ងាររដ្ឋ។ ចំណូលនេះជាធនធានបន្ថែម ដែលបំពេញលើការវិភាជន៍ដែលឃុំបានទទួលពីរដ្ឋ។ រដ្ឋាភិបាល និង ក្រសួង ឬ ស្ថានប័ននានា ដែលប្រើប្រាស់សេវារបស់ឃុំ-សង្កាត់ ត្រូវផ្តល់កម្រៃសមស្របសំរាប់ការអនុវត្តបេសកកម្មដែលបានកំណត់ខាងលើ។ ក្នុងករណីដែលការផ្ទេរភារកិច្ចពីរដ្ឋមានលក្ខណៈអចិន្ត្រៃយ៍ រដ្ឋាភិបាលត្រូវលៃទុកធនធានហិរញ្ញវត្ថុដើម្បីធានាការបង្វែរជូនឃុំ-សង្កាត់សម្រាប់រយៈពេលវែង។ របៀបនៃការទូទាត់ ត្រូវបានចែងតាមរយៈអនុក្រឹត្យ » (មាត្រា ៧៦) ។

«ជារៀងរាល់ឆ្នាំ ឃុំ-សង្កាត់ត្រូវរៀបចំ និង អនុម័តថវិការបស់ខ្លួន។ ថវិកាឃុំ-សង្កាត់ត្រូវតែរៀបចំនិងអនុម័ត ដោយស្របតាមប្រព័ន្ធថវិកាជាតិ ។ ថវិកាឃុំ-សង្កាត់ត្រូវឈរលើតុល្យភាពទូទៅ។ ឃុំ-សង្កាត់អាចបង្កើនចំណាយរបស់ខ្លួន តែត្រូវបង្កើនផងដែរនូវចំណូល ដើម្បីប៉ះប៉ូវគ្នា។ ថវិកាឃុំ-សង្កាត់ត្រូវឆ្លុះបញ្ចាំងពីអាទិភាព និងគំរូការនៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ឃុំ។ នីតិវិធីនៃការរៀបចំ និងការអនុម័តថវិកាឃុំ-សង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យ» (មាត្រា ៧៩) ។

មូលនិធិឃុំ-សង្កាត់មួយត្រូវបានបង្កើតឡើង ដើម្បីជំរុញការអភិវឌ្ឍតាមមូលដ្ឋាន។ «មូលនិធិនេះជាកម្មវត្ថុនៃការបង្វែរចំណូលជាតិ ឬប្រភពធនធានផ្សេងទៀត ចូលទៅថវិកាឃុំ-សង្កាត់...» (មាត្រា ៧៧ ) ។ «មូលនិធិឃុំ-សង្កាត់ ត្រូវបំពេញដោយ ៖

- ការវិភាជន៍មួយផ្នែកផ្ទាល់ពីថវិកាប្រចាំរបស់រដ្ឋ ដែលកំណត់ដោយអនុក្រឹត្យ
- ទាយជ្ជទាន និងការសុំខ្ចីក្នុងស្រុក ឬក្រៅស្រុក
- ការបែងចែកធនធានប្រចាំឆ្នាំដល់ឃុំ-សង្កាត់ តាមរយៈមូលនិធិឃុំ-សង្កាត់ ត្រូវធ្វើឡើងតាមរបៀបមួយ ដែលកំណត់ដោយអនុក្រឹត្យ ។

«ឃុំ-សង្កាត់អាចទទួលការបង្វែរទ្រព្យមួយផ្នែកពីរដ្ឋ...ឃុំ-សង្កាត់អាចប្រើផលពីទ្រព្យដែលរដ្ឋប្រគល់អោយជាធនធាន។ ...ឃុំ-សង្កាត់មិនមានសិទ្ធិលក់ ឬផ្ទេរសិទ្ធិលើការប្រើប្រាស់ទ្រព្យទាំងនេះ ដោយមិនមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឡើយ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួង មហាផ្ទៃ» (មាត្រា ៨៣) ។ «ឃុំ-សង្កាត់មិនអាចធ្វើការសុំខ្ចីបានឡើយ ។ ឃុំ-សង្កាត់មិនអាចធានាការខ្ចី ឬ សញ្ញាប័ណ្ណហិរញ្ញវត្ថុ ដែលមានលក្ខណៈកម្ចីបានឡើយ » (មាត្រា ៨០) ។

## ២១.៩. ការគ្រប់គ្រងវិនិយោគសាធារណៈ

ចំណាយមូលធនសម្រាប់វិនិយោគសាធារណៈបានកើនឡើងពី ៥,៥%នៃផសស ក្នុងឆ្នាំ ១៩៩៤ ដល់ ៦,១%នៃផសស ក្នុងឆ្នាំ ២០០៨ ដែលស្មើនឹង ១.៧៨៥ ញន់លានរៀល ឬ ៥,៧៣%នៃផសស ដែលមានចំនួន ៣១.១៣៧ ពាន់លានរៀល ក្នុងឆ្នាំ ២០០៧ ពេលសម្រេចបានកំណើនចំនួន ៦,៥% តាមថ្លៃថេរ។ គិតជាភាគរយនៃចំណាយសរុប ចំណាយមូលធនកើនឡើងពី ៣៣,៦%នៃចំណាយថវិកាសរុប នៅក្នុងឆ្នាំ ១៩៩៤ ដល់ ៣៧,៦%នៃចំណាយថវិកាសរុប នៅក្នុងឆ្នាំ ២០០៥ និងដល់ ៣៨,៦២%នៃចំណាយថវិកាសរុប នៅក្នុងឆ្នាំ ២០០៧ ។ ដូច្នេះ បន្តិចម្តងៗ ចំណាយវិនិយោគសាធារណៈបានក្លាយទៅជាសមាសភាគមួយយ៉ាងសំខាន់នៃចំណាយថវិកា ជាពិសេសក្នុងការបង្កើនកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ថ្វីត្បិតតែនៅក្នុងពេលបច្ចុប្បន្ន និង នៅពេលខាងមុខតទៅទៀត ធនធានថវិកាក្នុងស្រុកសម្រាប់ហិរញ្ញប្បទាននៃការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិនិយោគសាធារណៈ នៅមានសមាមាត្រទាបនៅឡើយ បើប្រៀបធៀបនឹងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍អន្តរជាតិក្រោមរូបភាពជាជំនួយជាគម្រោង។ ជំនួយជាគម្រោង មានសមាមាត្រស្មើនឹង ៧៧%នៃចំណាយវិនិយោគនៃថវិកាឆ្នាំ ១៩៩៤ ហើយថយ ចុះមកនៅត្រឹម ៧៣%នៅក្នុងឆ្នាំ ២០០៥ តែកើនដល់ ៨០%វិញនៅក្នុងឆ្នាំ ២០០៧ ។

## ២១.៩.១. ហិរញ្ញប្បទានក្រៅប្រទេសដោយផ្ទាល់

ការបញ្ចូលនៅក្នុងថវិកាជាតិនូវវិនិយោគសាធារណៈដោយហិរញ្ញប្បទានដោយផ្ទាល់ពីក្រៅប្រទេសធ្វើឡើងដោយកត់ត្រានៅក្នុងថវិកាជាតិ នូវការព្យាករណ៍នៃទឹកប្រាក់សរុបនៃហិរញ្ញប្បទានដោយផ្ទាល់ពីក្រៅប្រទេស។ ការព្យាករណ៍នេះមិនមែនជាឥណទានថវិកា ដែលត្រូវអនុវត្តតាមនីតិវិធីចំណាយតាមច្បាប់ជាធរមានឡើយ។ការកត់ត្រានូវវិនិយោគសាធារណៈដោយហិរញ្ញប្បទានដោយផ្ទាល់ពីក្រៅប្រទេស មិនទាមទារអោយមានទិដ្ឋាការពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឡើយ ដោយសារទឹកប្រាក់នេះគ្រាន់តែជាការព្យាករណ៍នៃចំណាយដែលអាចនឹងត្រូវអនុវត្ត តាមប្រភពនៃហិរញ្ញប្បទានក្រៅប្រទេសនៅក្នុងឆ្នាំថវិកាតែប៉ុណ្ណោះ ។

ដៃគូអភិវឌ្ឍន៍ផ្តល់ការសន្យាប្រចាំឆ្នាំនូវជំនួយផ្លូវការដើម្បីអភិវឌ្ឍន៍ នៅក្នុងឱកាសវេទិកាអភិវឌ្ឍន៍កម្ពុជា ដែលជាវេទិកាផ្លាស់ប្តូរយោបល់រវាងរាជរដ្ឋាភិបាលកម្ពុជា និង ដៃគូអភិវឌ្ឍន៍លើគោលនយោបាយសំខាន់ៗនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ បន្ទាប់មកដៃគូអភិវឌ្ឍន៍មួយចំនួនធ្វើការពិគោះយោបល់ជាមួយ រាជរដ្ឋាភិបាលកម្ពុជា ពីគោលនយោបាយតាមវិស័យ និង បែងចែកការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍តាមវិស័យ ដែលខ្លួនមានឧត្តមភាពប្រៀបធៀប។ ដៃគូអភិវឌ្ឍន៍ចុះហត្ថលេខាជាមួយរាជរដ្ឋាភិបាលលើអនុស្សរណៈ ស្តីពីការផ្តល់ហិរញ្ញប្បទាន។ ដោយឈរលើមូលដ្ឋាននៃទិន្នន័យខាងលើនេះ ក៏ដូចជាការអនុវត្តនូវគម្រោងនៅក្នុងឆ្នាំកន្លងទៅ យើងធ្វើការប៉ាន់ស្មាននូវជំនួយជាគម្រោង។

ដូច្នេះ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ បានព្យាករណ៍ចំណាយវិនិយោគដោយហិរញ្ញប្បទានពីក្រៅប្រទេសសរុបចំនួន ១.១១០ ពាន់លានរៀល ដែលជាជំនួយជាគម្រោង។ បន្ទាប់ពីការព្យាករណ៍ស្តីពីចំណាយវិនិយោគត្រូវបានដាក់បញ្ចូលក្នុងថវិកាប្រចាំឆ្នាំ និង ការអនុម័តថវិកាដោយរដ្ឋសភា និង ពិនិត្យដោយព្រឹទ្ធសភា គម្រោងទាំងនេះនឹងត្រូវអនុវត្តដោយដៃគូអភិវឌ្ឍន៍ទាំងអស់ ។

## ២១.៩.២. ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស

ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានចែកចេញជាពីរផ្នែក ៖

ទីមួយ-ចំណាយវិនិយោគដែលធ្វើហិរញ្ញប្បទានដោយថវិកាជាតិដោយផ្ទាល់ ដោយប្រើប្រាស់នូវធនធានក្នុងស្រុក ដែលជាអតិរេកនៃថវិកាចរន្ត ដើម្បីយកទៅបង្កើននូវការអនុវត្តគម្រោងវិនិយោគសំខាន់ៗមួយចំនួន ដែលជាអាទិភាពនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ទីពីរ-ចំណាយវិនិយោគថវិកា ដែលជាមូលនិធិបដិភាគរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមអនុវត្តនូវគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក ដែលទាមទារឱ្យមានការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជា ទោះបីជាទឹកប្រាក់ទាំងនោះនៅមានកម្រិតជានិមិត្តរូបក៏ដោយ ដើម្បីបង្ហាញជាភាពជាម្ចាស់ របស់កម្ពុជាលើការងារអភិវឌ្ឍប្រទេសជាតិ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាការពិតណាស់ ទំហំទឹកប្រាក់វិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសនៅមានកម្រិតនៅឡើយ ដោយសារតែចំណាយចរន្តចេះតែកើនជាលំដាប់ ថ្វីត្បិតតែចំណូលសរុបបានកើនឡើងដល់ ១២,១%នៃ ផសស នៅក្នុងឆ្នាំ ២០០៨ កន្លងទៅនេះក៏ដោយ។ ក៏ប៉ុន្តែ ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសបានកើនឡើងយ៉ាងខ្លាំង។ វិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកដើរតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយសារតែថវិកាជាតិមានភាពទន់ភ្លន់ អាចអោយរាជរដ្ឋាភិបាលអាចមានភាពទន់ភ្លន់ ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងរៀបចំផែនការវិនិយោគសាធារណៈ ដែលឆ្លុះបញ្ចាំងទាំងស្រុងនូវអាទិភាពរបស់ខ្លួន តាមរយៈការប្រមូលផ្តុំចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក ទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសផ្លូវខេត្ត ផ្លូវលំ និងផ្លូវជនបទ ការថែទាំខួប ឬ ប្រចាំ ការជួសជុលធំ ឬ ការជួសជុលឡើងវិញនូវផ្លូវជាតិ ការសាងសង់ផ្លូវថ្មី ការសាងសង់ និង ជួសជុលនូវប្រព័ន្ធធារាសាស្ត្រជាដើម។

ចាប់តាំងពីអាណត្តិទីពីរនៃរដ្ឋសភាក្នុងឆ្នាំ ១៩៩៩ មក រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតអាទិភាពទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្លូវថ្នល់ និង ប្រព័ន្ធធារាសាស្ត្រ ដែលចូលរួមវិភាគទានយ៉ាងសំខាន់ក្នុងការផ្សារភ្ជាប់សេដ្ឋកិច្ចជាតិ អោយក្លាយជាសរីរាង្គតែមួយ ពង្រីកទីផ្សារក្នុងស្រុក បង្កើនផលិតភាពកសិកម្ម និង ដោះស្រាយបានយ៉ាងស័ក្តិសិទ្ធិនូវហានិភ័យនៃគ្រោះរាំងស្ងួត។ ប្រការនេះ បានចូលរួមចំណែកក្នុងការ កាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ចំនួន ១% ក្នុងមួយឆ្នាំ។ ជារួម ថវិកាវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក បានក្លាយទៅជាសរសរទ្រូងនៃការអនុវត្តគោលនយោបាយវិនិយោគជាតិ តាមរយៈការបង្កើត និង ការពង្រីកសញ្ច័យជាតិ និង ការកសាងសមត្ថភាពស្ថាប័ន ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍប្រទេសជាតិ។ ចំណាយថវិកាវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុកត្រូវបានអនុវត្ត ដោយគោរពតាមនីតិវិធីថវិកាជាតិជាធរមាន។

## ២១.៩.៣. ការទ្រទ្រង់ថវិកា

ការទ្រទ្រង់ថវិកា គឺជារូបភាពមួយនៃការផ្តល់ហិរញ្ញប្បទានពីក្រៅប្រទេសដោយដៃគូអភិវឌ្ឍន៍ (ទាំងដៃគូពហុភាគី ដែលជាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ទាំងដៃគូទ្វេភាគី) ដោយផ្តល់ការគាំទ្រដោយផ្ទាល់ ជារូបិយប័ណ្ណ និង ជាទំនិញ ដល់ថវិការបស់ប្រទេស ដែលទទួលហិរញ្ញប្បទាននេះ។ ការទ្រទ្រង់ថវិកា អាចជាជំនួយឥតសំណង ឬ ជា កម្ចី ។

### ២១.៩.៣.១. ជំនួយទ្រទ្រង់ថវិកាដោយផ្ទាល់

ដោយឈរលើមូលដ្ឋាននៃការគិតគូរខាងលើ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ ក្នុងការអនុវត្តនូវជំនួយទ្រទ្រង់ថវិកា។ ជំនួយទ្រទ្រង់ថវិកាដោយផ្ទាល់ គឺជាការផ្តល់នូវថវិកាជាសាច់ប្រាក់ចូលទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅក្នុងរតនាគារជាតិតែម្តង ហើយរាជរដ្ឋាភិបាលអាចយកមូលនិធិនេះ ទៅប្រើប្រាស់ជាចំណាយចរន្ត ឬ ជាចំណាយជាមូលធន ដោយមិនភ្ជាប់ទៅនឹងគម្រោងណាមួយឡើយ។ ជំនួយទ្រទ្រង់ថវិកាដោយផ្ទាល់មាន លក្ខណៈជាកម្មវិធី ដូចជា «ប្រតិបត្តិការការបន្ថយភាពក្រីក្រ និងកំណើន» (PRGO) ដែលមានដៃគូអភិវឌ្ឍន៍ចំនួនបួនចូលរួម គឺធនាគារពិភពលោក (១៥លានដុល្លារអាមេរិក) ទីភ្នាក់ងារ DFID របស់អង់គ្លេស (៣លានដុល្លារអាមេរិក) អង្គការ JICA របស់ជប៉ុន (១០ លានដុល្លារអាមេរិក) និង សហគមន៍អ៊ឺរ៉ុប (២លានដុល្លារអាមេរិក)។ កម្មវិធីកំណែទម្រង់ចែកចេញជាបីផ្នែក គឺ៖ ទីមួយ-កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ទីពីរ-កំណែទម្រង់អភិវឌ្ឍន៍ផ្នែកឯកជន និង ទីបី-កំណែទម្រង់ការគ្រប់គ្រងដីធ្លី ។

### ២១.៩.៣.២. ជំនួយទ្រទ្រង់ថវិកាជាទំនិញ (ជំនួយជាទំនិញ)

ជំនួយទ្រទ្រង់ថវិកាជាទំនិញ គឺជាប្រភេទជំនួយមួយទៀត ដើម្បីបង្កើនចំណូលរបស់រាជរដ្ឋាភិបាល។ ដៃគូអភិវឌ្ឍន៍ផ្តល់ជំនួយជាទំនិញ ដែលត្រូវលក់លើទីផ្សារក្នុងស្រុក ហើយយកថវិកាជាប្រាក់រៀល ដើម្បីដាក់ចូលជាចំណូលថវិកា។ ប្រភេទនៃជំនួយទ្រទ្រង់ថវកានេះត្រូវបានអនុវត្តដោយប្រទេសជប៉ុន ក្នុងក្របខ័ណ្ឌនៃកម្មវិធីសង្គ្រោះបន្ទាន់ដើម្បីនីតិសម្បទាកម្ពុជា។ ជប៉ុនផ្តល់ជំនួយជាជីគីមី ឬ ជាដែកថែប ដែលត្រូវបានយកទៅដេញថ្លៃ លក់លើទីផ្សារក្នុងស្រុក ហើយប្រមូលចំណូលចូលថវិការរដ្ឋ។ ជំនួយប្រភេទនេះជួយដល់រាជរដ្ឋាភិបាល ក្នុងការផ្គត់ផ្គង់ទំនិញយុទ្ធសាស្រ្តផង និង ប្រមូលប្រាក់រៀលចូលក្នុងរតនាគារជាតិផង ក្នុងទិសដៅគ្រប់គ្រងអតិផរណា អោយនៅទាប។

## ២១.១០. សហគ្រាសរដ្ឋ

សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬ ភាគច្រើនជារបស់រដ្ឋ។ សហគ្រាសសាធារណៈមានបេសកកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និង ការបង្កើនអាជីព (ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ជស/រកម/០៦៩៦/០៣ មាត្រា ២)។ សហគ្រាសសាធារណៈ គឺជានីតិបុគ្គលដែល មានដែលមានស្វ័យភាពហិរញ្ញវត្ថុ។ សហគ្រាសសាធារណៈ មានទម្រង់ជា៖ គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និង ក្រុមហ៊ុនចម្រុះដែលក្នុងនោះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬ ដោយប្រយោលលើសពី ៥១%នៃដើមទុនក្រុមហ៊ុន ឬ សិទ្ធិបោះឆ្នោត ។

ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ កំណត់នូវប្រភេទគតិយុត្តិនៃសហគ្រាសសាធារណៈ ដែលមានទម្រង់ជា «គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច» ក្រុមហ៊ុនរដ្ឋ និង ក្រុមហ៊ុនចម្រុះ ។

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ជានីតិបុគ្គលនៃនីតិសាធារណៈ ដែលមានស្វ័យភាពហិរញ្ញវត្ថុ (មាត្រា ២៦ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/០៦៩៦/០៣)។ របបហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ត្រូវបានកំណត់ដោយលក្ខន្តិកៈរបស់គ្រឹះស្ថាននោះ។

ក្រុមហ៊ុនរដ្ឋ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពីកម្មវត្ថុរបស់ក្រុមហ៊ុន ទម្រង់គតិយុត្តិ ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែលត្រូវអនុវត្ត សមាសភាព របស់ក្រុមប្រឹក្សាភិបាល។ លក្ខខន្តិកៈរបស់ក្រុមហ៊ុនរដ្ឋកំណត់ជាអាទិ៍អំពីចំនួនទឹកប្រាក់ និង ប្រភេទនៃភាគទុន ការរៀបចំរដ្ឋបាល និង ហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនចម្រុះ គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍ និង តាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដែលដើមទុនត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬ រូបវន្តបុគ្គលឯកជន និង នីតិបុគ្គលរដ្ឋ ។ កាលណាភាគកម្មសាធារណៈលើសពី ៥១%នៃដើមទុន ឬ សិទ្ធបោះឆ្នោត ក្រុមហ៊ុនចម្រុះត្រូវបាន ចាត់ទុកជាសហគ្រាសសាធារណៈ ។

*តារាងលេខ 21. 1. សហគ្រាសសាធារណៈដែលគ្រប់គ្រងដោយក្រសួង ស្ថាប័ន*

| ចំនួនសហគ្រាសរដ្ឋ | ក្រុមហ៊ុនរដ្ឋ | គ្រឹះស្ថានសាធារណៈ | ក្រុមហ៊ុនសេដ្ឋកិច្ចចម្រុះ | សរុប |
|---|---|---|---|---|
| ក្រសួងកសិកម្ម | 9 | 3 | 2 | 14 |
| ក្រសួងសាធារណៈការ | 6 | | | 6 |
| ក្រសួងហិរញ្ញវត្ថុ | 4 | | | 4 |
| ក្រសួងឧស្សាហកម្ម | 1 | | | 1 |
| ក្រសួងពាណិជ្ជកម្ម | 1 | | | 1 |
| ក្រសួងអប់រំ | 1 | 1 | | 2 |
| ក្រសួងទូរគមនាគមន៍ | 1 | | 6 | 7 |
| ក្រសួងសុខាភិបាល | | | | 1 |
| ទីស្តីការគណៈរដ្ឋមន្ត្រី | | 1 | 1 | 1 |
| កម្រិតថ្នាក់ក្រុង | | | | |
| រាជធានីភ្នំពេញ | 1 | | | 1 |
| សរុប | 24 | 5 | 9 | 38 |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

ក្រុមហ៊ុនពាក់កណ្តាលសាធារណៈ ត្រូវបានកំណត់ឱ្យមានការត្រួតពិនិត្យដោយសវនករម្នាក់ដែលមានក្នុងលក្ខន្តិកៈដូចគ្នាទៅនឹងករណីរបស់គ្រឹះស្ថានសេដ្ឋកិច្ចសាធារណៈឬក្រុមហ៊ុនរដ្ឋដែរ។ “ របាយការណ៍ហិរញ្ញវត្ថុដែលរួមមានតារាងតុល្យការ របាយការណ៍ចំណេញខាត និងការវិភាគនៃគណនី ” ត្រូវបានត្រួតពិនិត្យដោយអាជ្ញាធរសវនកម្មជាតិ (មាត្រាទី៥នៃច្បាប់លេខ១០ ចុះថ្ងៃ៣ ខែមីនា ឆ្នាំ២០០០ ដែលបានចែងអំពីសវនកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា) (ក្រឹត្យលេខ៩៧-៩១និងលេខ៩២សរាចរលេខ៥ចុះថ្ងៃ២៧ខែវិច្ឆិកា ឆ្នាំ២០០៧)។

## ២១.១១. កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ចក្ខុវិស័យនៃកំណែទម្រង់ គឺសំដៅដាក់ចេញកម្រិតស្តង់ដារនៃការគ្រប់គ្រង និង គណនេយ្យភាពឱ្យកាន់តែខ្ពស់ថែមទៀត ក្នុងការកៀរគរប្រភពចំណូលចរន្ត និង មូលធនរបស់រាជរដ្ឋាភិបាល ព្រមទាំងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនូវបណ្តាធនធានទាំងនេះ ក្នុងកិច្ចប្រតិបត្តិការអនុវត្តយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និង កម្មវិធីជាអាទិភាពផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូច្នេះ កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលបានរៀបចំឡើងនេះ នឹងត្រូវកសាងឡើងជាជំហានៗយ៉ាងខ្ជាប់ខ្ជួន ដោយផ្អែកលើរបៀបវារៈសំខាន់ៗបួនដែលបានកំណត់អាទិភាព និង ដំណាក់កាលអនុវត្តន៍ ច្បាស់លាស់ គឺៈ

ទីមួយ-ថវិកាដែលកាន់តែអាចជឿទុកចិត្តបាន

ទីពីរ-គណនេយ្យភាពហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព

ទីបី-របៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ត្រូវបានកំណត់ជាអាទិភាពត្រឹមត្រូវ និង ទទួលបានលទ្ធភាពពេញលេញ

ទីបួន- មន្ត្រីគ្រប់គ្រងរបស់រាជរដ្ឋាភិបាល នឹងមានគណនេយ្យភាពពេញលេញចំពោះលទ្ធផលនៃការអនុវត្តន៍កម្មវិធី ។

និយាយជារួម ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ដែលចង់បាន គឺជាប្រព័ន្ធមួយបំពេញបានតាមគោលការណ៍សំខាន់ៗ រួមមានសង្គតិភាពទៅនឹងនិយាម និងទំលាប់ប្រតិបត្តិល្អៗ។ ប្រព័ន្ធរួមនេះនឹងមានអនុប្រព័ន្ធនានាពាក់ព័ន្ធនឹងប្រតិបត្តិការ ការពិនិត្យតាមដាន និង ការវាយតម្លៃ ។

## ៦១.១១.១. វិធីសាស្ត្រថ្មីមួយក្នុងការរៀបចំថវិកាក្រសួង រចនាសម្ព័ន្ធកម្មវិធីនិងសកម្មភាព

ការធ្វើឱ្យប្រសើរឡើងនូវហិរញ្ញវត្ថុសាធារណៈ គឺជាដំណើរការមួយដែលមានរយៈពេលយូរហើយទាមទារឱ្យមានការប្តេជ្ញាខាងនយោបាយសម្រាប់វិន័យថវិកា។ សហប្រតិបត្តិការនៃក្រសួងពាក់ព័ន្ធនានា គឺជាឧត្តមភាពសម្រាប់ការធានាបាននូវជោគជ័យនៃកំណែទម្រង់នេះ។ ដើម្បីធ្វើកំណែទម្រង់និងទំនើបភាវូបីយកម្មលើយន្តការថវិការបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងដាក់ឱ្យអនុវត្តនូវវិធានការដូចខាងក្រោម នៅក្នុងដំណើរការអនុវត្តថវិកា ៖

- ក្របខ័ណ្ឌថវិការយៈមធ្យម
- ការព្យាករណ៍សេដ្ឋកិច្ចដោយប្រុងប្រយ័ត្ន
- ការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរបស់រតនាគារ
- បង្កើតឱ្យមានស្មារតីគណនេយ្យភាពក្នុងការគ្រប់គ្រងមូលនិធិសាធារណៈ
- ការយកចិត្តទុកដាក់លើលទ្ធផលសម្រេចបាន
- តម្លាភាពថវិកា
- វិធីសាស្ត្របែបទំនើបក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។

នៅក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអនុវត្តនូវកំណែទម្រង់លើប្រព័ន្ធថវិកាដោយការផ្លាស់ប្តូរពីថវិកាតាមបន្ទាត់ថវិកា (Budget lines) ទៅជាការរៀបចំថវិកាតាមកម្មវិធី។ ប្រការនេះមានន័យថាផ្លាស់ គឺជាការផ្លាស់ប្តូរពីថវិកាសម្រាប់ជាមធ្យោបាយ ទៅជាថវិកាសម្រាប់បង្កើតលទ្ធផល។ការរៀបចំថវិកាថ្មី ដែលបានស្នើសុំនេះនឹងបិតនៅក្នុងកម្រិតពីរ ៖ កម្មវិធី (បេសកកម្ម) និង សកម្មភាព។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## កម្មវិធី

ដូចដែលបានថែងនៅកម្រិតក្រសួង កម្មវិធីដាក់បញ្ចូលរួមគ្នានូវប្រាក់វិភាជ ដែលមានទំនាក់ទំនងជាមួយនយោបាយសាធារណៈ។ កម្មវិធីត្រូវដាក់ចេញនូវគោលដៅប្រតិបត្តិការ ដែលអាចវាស់វែងបានមួយ ដែលគោលដៅនេះ នឹងត្រូវបានសម្រេចបានក្នុងឆ្នាំសារពើពន្ធ និងគោលដៅដែលទាមទារនូវថវិកា និងបុគ្គលិក។ កម្មវិធីនីមួយៗត្រូវឆ្លើយតបទៅនឹងសកម្មភាពទាក់ទងគ្នានានា ដែលត្រូវបានប្រគល់ជូនដល់មន្ត្រីទទួលខុសត្រូវម្នាក់ ដែលបានចាត់តាំងឡើងដោយរដ្ឋមន្ត្រី ហើយឱ្យឈ្មោះថា "អ្នកសម្របសម្រួលកម្មវិធី "។ មន្ត្រីរូបនេះទទួលកញ្ចប់ថវិកា ដែលអនុញ្ញាតឱ្យមន្ត្រីនោះធ្វើការជ្រើសរើសមធ្យោបាយ ដែលសមស្របបំផុត ដើម្បីសម្រេចគោលដៅដែលបានកំណត់។

## សកម្មភាព

គឺជាភាគតូចៗនៃកម្មវិធីដែលនៅក្នុងនោះចំណាយនានា ត្រូវបានបែងចែកទៅតាមផ្នែកនីមួយៗ។ សកម្មភាពមានសារៈសំខាន់ណាស់ សម្រាប់ការសម្រេចបាននូវគោលដៅនិងគោលបំណងនៃកម្មវិធី។ សកម្មភាពបញ្ជាក់នូវព័ត៌មានស្តីអំពីគោលដៅនៃការប្រើប្រាស់ថវិកា។ នៅក្នុងកម្រិតសកម្មភាព ចំណាយទាំងអស់ត្រូវបានគ្រោងទុក ហើយរៀបចំប្រព័ន្ធត្រួតពិនិត្យការអនុវត្តថវិកាៈ អ្នកសម្របសម្រួលកម្មវិធីត្រូវដឹកនាំការអនុវត្តសកម្មភាពជាបន្តបន្ទាប់។

## វិធីសាស្ត្រថ្មីៗនៃការគ្រប់គ្រង

រួមបញ្ចូលតារាងកម្មវិធីជាតិមួយដែលត្រូវបានធ្វើវិមជ្ឈការ (ថវិកាសម្រាប់ប្រតិបត្តិការកម្មវិធី) និងការពិភាក្សាផ្នែកគ្រប់គ្រង រវាងរដ្ឋបាលថ្នាក់កណ្តាល និង មន្ទីរដែលបានធ្វើវិមជ្ឈការ (ការត្រួតពិនិត្យការគ្រប់គ្រងនីតិវិធីនៃរបាយការណ៍។ល។)។ ការប្រមូលរៀបចំជាក្រុមថ្មីមួយ នឹងអនុញ្ញាតឱ្យមានភាពខុសប្លែកគ្នាកម្រិតនៃការប្រតិបត្តិទីតាំង តាមខេត្ត និងមុខងារសេដ្ឋកិច្ចដែលពាក់ព័ន្ធ។ ឧទាហរណ៍លេខកូដដែលមានពីរខ្ទង់ពិពណ៌នាអំពីជំពូកលេខកូដដែលមានបីខ្ទង់ពិពណ៌នាអំពីគណនី ហើយលេខកូដបួនខ្ទង់ពិពណ៌នាអំពីអនុគណនី។ អាស្រ័យហេតុនេះអត្ថន័យនៃមាត្រា ជំពូក កឋាខណ្ឌ និង អនុកឋាខណ្ឌរលាយបាត់ដោយជំនួសមកវិញដោយជំពូកគណនី និង អនុគណនី។

ជាមួយការបោះឆ្នោតលើប្រាក់វិភាជកថវិកាដោយចេតនាក្រោមកញ្ចប់សរុប ហើយមិនមែនគ្រាន់តែដោយសារជាតិនៃចំណាយនិយមន័យ នៃលទ្ធផលរំពឹងទុកដែលបានវាស់វែងដោយសូចនាករមានចុះលេខអនុញ្ញាតឱ្យមានការប្រព្រឹត្តទៅបានក្នុងការផ្លាស់ប្តូការគ្រប់គ្រងរដ្ឋាភិបាល ពីមធ្យោបាយឡូស៊ិកទៅជាលទ្ធផលឡូស៊ិក។

អត្តសញ្ញាណនៃសូចនាករ ដែលពាក់ព័ន្ធនិងអាចទុកចិត្តបាននឹងកំពុងធ្វើឱ្យវាអាចប្រព្រឹត្តទៅបានជាបន្តបន្ទាប់ដើម្បីបង្កើតនូវគោលដៅសម្រាប់នយោបាយរបស់ក្រសួង។ សកលភាវូនីយកម្មនិងភាពអាចជំនួសបាន (Symmetric fungibility) នៃថវិកាផ្តល់ជូននូវសេរីភាពថ្មីៗទៀតដល់អ្នកគ្រប់គ្រង។ ផ្ទុយទៅវិញប្រការនេះនឹងនាំឱ្យមានការបង្កើតលទ្ធផល និង ផ្តល់នូវគណនេយ្យភាពមួយក្នុងរបាយការណ៍អំពីប្រតិបត្តិការដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃនយោបាយសាធារណៈ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២១.១១.២. ការដាក់អោយអនុវត្តគណនេយ្យបង្គរ ( Accrual Accounting )

កំណែទម្រង់គណនេយ្យមានជាប់ទាក់ទងនឹងសេចក្តីផ្តើមនៃគណនេយ្យបង្គរ និងដំណើរផ្លាស់ប្តូរនៃក្របខ័ណ្ឌទស្សននិងទម្លាប់គណនេយ្យដោយផ្អែកលើតារាងគណនេយ្យក្រុមហ៊ុន ដែលត្រូវបានកែសម្រួលទៅតាមតម្រូវការជាក់លាក់របស់រដ្ឋ។ ជាមួយគ្នានេះដែរវាស្តែងចេញនូវការផ្លាស់ប្តូរដ៏ចាំបាច់មួយនៅក្នុងតួនាទីរបស់គណនេយ្យករសាធារណៈ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងរំកិលខ្លួនឆ្ពោះទៅកាន់វិធីសាស្រ្តគណនេយ្យបង្គរ (Double-entry accrual basis) ។ នេះគឺជាកំណែទម្រង់ដែលមិនរាថយមួយ ជាមួយនឹងការបង្កើនកម្រិតនៃគណនេយ្យរដ្ឋឱ្យឈានដល់ស្តង់ដារអន្តរជាតិ ៖

- បំណុលនឹងត្រូវកត់ចូលនៅថ្ងៃដែលកើតមាន ហើយនឹងត្រូវបានបញ្ចូលនៅក្នុងឆ្នាំសារពើពន្ធដែលបង្ហាញពីរូបរាងរបស់ពួកវាថា ជាបំណុលដែលត្រូវទារ ឬ បំណុលដែលត្រូវសង។

  - ចំណូលដែលប្រមូលបាន តាមរយៈចំណូលពន្ធ ឬ មិនមែនសារពើពន្ធ ជំនួយឥតសំណង ជាទំនិញ ឬ ជាសេវា អំណោយជាសម្ភារៈបរិក្ខារ តាមរយៈជំនួយអន្តរជាតិនឹងត្រូវដាក់បញ្ចូលទៅក្នុងគណនេយ្យរដ្ឋាភិបាល។

  - សម្រាប់ចំណាយវិញ និយាមគណនេយ្យនឹងត្រូវបានបង្កើតឡើងសារជាថ្មី ដើម្បីឱ្យបានដឹងរៀងរាល់ពេលអំពីស្ថានភាពនៃបំណុលរបស់ “ អ្នកផ្គត់ផ្គង់ ” មានន័យថាជា “ អាណត្តិទូទាត់ប្រាក់ជំពាក់ដែលនៅសល់ ។ ”

បញ្ហារសើបបំផុតនៅក្នុងករណីនៃបុរេប្រទានដែលបានផ្តល់ទៅឱ្យក្រសួងនានា ដើម្បីប្រតិបត្តិលើចំណាយមានការជាប់ទាក់ទិនទៅនឹងកម្មវិធីសកម្មភាពអទិភាព (PAP) ដែលត្រូវបានគេចាត់ទុកថាជាអាណត្តិឱ្យទូទាត់ដោយគ្មានក្រដាស។ ការចាកចេញពីច្បាប់គណនេយ្យសាធារណៈបច្ចុប្បន្ននេះត្រូវបានគេផ្តល់សិទ្ធិអំណាចឱ្យដើម្បីធ្វើការទូទាត់នូវចំណាយអាទិភាពឱ្យឆាប់រហ័ស។ វាក៏ជាមធ្យោបាយមួយដែរក្នុងការធ្វើឱ្យតុល្យភាពថវិការបស់ក្រសួងមួយចំនួន ដើម្បីកុំឱ្យឥណទានទាំងនោះ នឹងបាត់បង់នៅឆ្នាំបន្ទាប់។

- បេតិកភណ្ឌភាវូនីយកម្មនៃបំណុលនិងការវិនិយោគ នឹងត្រូវបានធានាឱ្យស្របជាមួយនឹងលក្ខខណ្ឌដើម្បីបង្កើតស្លាកស្នាមជាលិខិតស្នាម ស្តីអំពីការប្រគល់សិទ្ធិនិងការទូទាត់និងការរៀបចំរបាយការណ៍ទ្រព្យសកម្មនិងបំណុលដោយរួមបញ្ចូលនូវការចុះបញ្ជីគណនេយ្យរបស់ទ្រព្យសកម្មជាប់លាប់ (fixed assets) ទ្រព្យសម្បត្តិ (property) និងមូលធនបត្រ (securities) និងបំណុលរយៈខ្លីនិងរយៈវែង។

- មាតិកាគណនេយ្យមួយដោយផ្អែកលើតារាងគណនេយ្យរបស់បារាំង ដែលឆ្លើយតបទៅនឹងនិយាមអន្តរជាតិនឹងត្រូវបានអនុម័ត។ គណនេយ្យប្រភេទទី៤និងទី៥ត្រូវបានអនុម័តនិងដាក់ឱ្យប្រើប្រាស់រួចហើយតាំងពីខែមករាឆ្នាំ២០០៥។ ការងារនៃការបង្កើតប្រភេទទី១គឺគណនេយ្យមូលធន (capital accounts) ប្រភេទទី២ គឺទ្រព្យសកម្មជាប់លាប់ប្រភេទទី៦ការចំណាយថវិកានិងប្រភេទទី៧គឺចំណូលថវិកាបានបញ្ចប់រួចជាស្ថាពរហើយ។

### ២១.១១.៣. ប្រព័ន្ធព័ត៌មានថ្មី

ការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មាន (FMIS) នឹងត្រូវបានបង្កើតនៅគ្រប់រដ្ឋបាលថ្នាក់កណ្តាលទាំងអស់ស្របជាមួយការបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងតាមក្រសួង។ កំណែទម្រង់នេះផ្អែកទៅលើការសាកល្បងដោយជោគជ័យ ការផ្លាស់ប្តូរព័ត៌មាន និង ជំនាញដ៏សម្បូរបែបនិងដ៏ច្បាស់លាស់។ កំណែទម្រង់នេះនឹងស្តែងចេញឱ្យឃើញនូវវប្បធម៌ថ្មីមួយនៃការអនុវត្ត និងការវាស់វែង ដ៏មានប្រសិទ្ធិភាពដែលមាននៅក្នុងច្បាប់ថវិកា ហើយដែលនឹងអាចនាំទៅរកការធ្វើវិសោធនកម្មរបស់វា។ ដើម្បីអនុវត្តកំណែទម្រង់នេះប្រកបដោយប្រសិទ្ធិភាពក្រសួងនានា ត្រូវតែរៀបចំរចនាសម្ព័ន្ធនៃការពិភាក្សាការគ្រប់គ្រងរវាង អ្នកសម្របសម្រួលកម្មវិធី និងផ្នែកប្រតិបត្តិការស្តីអំពីថវិកាប្រតិបត្តិការរបស់កម្មវិធី។

### ២១.១១.៤. ដំហានជាជានៃកំណែទម្រង់

ផែនការសម្រាប់កំណែទម្រង់មានដូចតទៅ ៖

- ការអភិវឌ្ឍផ្លូវច្បាប់និងការធ្វើបច្ចុប្បន្នកម្មនីតិបញ្ញត្តិដែលពាក់ព័ន្ធនឹងច្បាប់ថវិកាដោយនាយកដ្ឋានថវិកា។
- ការពិនិត្យមើលឡើងវិញនូវការធ្វើវិសោធនកម្មច្បាប់។
- ការបង្កើតគំរូថវិកាថ្មីមួយដោយនាយកដ្ឋានថវិកា។
- ការងារលើផ្នែកគណនេយ្យដែលត្រូវបញ្ចប់ក្នុងឆ្នាំ២០០៦។
- សម្រាប់ផ្នែកថវិកាការអនុវត្តនៃគំរូថ្មីនេះនឹងចាប់ផ្តើមនៅក្នុងឆ្នាំ២០០៧។
- ការអភិវឌ្ឍនៃសូចនាករការអនុវត្ត ដើម្បីវាយតម្លៃផលប៉ះពាល់នៃនយោបាយសាធារណៈដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីទាំងនេះ។
- ការបណ្តុះបណ្តាលរាល់បុគ្គលិកទាំងអស់ ដែលពាក់ព័ន្ធក្នុងដំណាក់កាលនានានៃការរៀបចំនិងអនុវត្តថវិកា។

# ផ្នែកទី ៨
# ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ

ជំពូកទី ២២. ពាណិជ្ជកម្មក្រៅប្រទេស

ជំពូកទី ២៣. បំណុលក្រៅប្រទេស

ជំពូកទី ២៤. សមាហរណកម្មក្នុងតំបន់

# ជំពូកទី ២២
# ពាណិជ្ជកម្មក្រៅប្រទេស

## ២២.១. សេរីភាវូបនីយកម្មនៃពាណិជ្ជកម្មក្រៅប្រទេស

គោលដៅចម្បងបំផុតនៃនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជា គឺការពង្រីក និង ពង្រឹងនូវទំនាក់ទំនងសេដ្ឋកិច្ច និង កិច្ចសហប្រតិបត្តិការអន្តរជាតិ តាមរយៈការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាចូលទៅក្នុងសេដ្ឋកិច្ចតំបន់និងពិភពលោក។ គោលដៅនេះត្រូវបានកំណត់ឡើង ដើម្បីប្រើប្រាស់គុណប្រយោជន៍នៃការបែងចែកកម្លាំងពលកម្មអន្តរជាតិ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និង លើកកម្ពស់សុខមាលភាពរបស់ប្រជាជន។

ចាប់តាំងពីចុងទសវត្សរ៍៨០ ហើយជាពិសេសនៅដើមទសវត្សរ៍៩០ កម្ពុជាបានចាប់ផ្តើមសេរីភាវូបនីយកម្មពាណិជ្ជកម្ម និង ការធ្វើសមាហរណកម្ម។ វិស័យឯកជនអាចមានលទ្ធភាពបង្កើតទៅជាក្រុមហ៊ុនចម្រុះ ដោយមានការចូលរួមពីបរទេសជាអតិបរមា ៤៩ ភាគរយ។ ចាប់តាំងពីឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានលុបចោលនូវការចេញអាជ្ញាប័ណ្ណទូទៅសម្រាប់ការនាំចូល និងការនាំចេញទំនិញ ដោយទាមទារឱ្យក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្មជំនួសវិញ។

### ២២.១.១. តួនាទីរបស់ពន្ធគយ

សេដ្ឋវិទូបានផ្តល់នូវអំណះអំណាងមួយចំនួន ដើម្បីគាំទ្រដល់ពន្ធគយ ៖

- ដើម្បីបង្កើនជាអតិបរមានូវផលប្រយោជន៍ពីការប្រើប្រាស់ជាយុទ្ធសាស្ត្រនៃពន្ធគយ។ ពន្ធគយអាចជួយលើកកម្ពស់សុខុមាលភាពសង្គមរបស់ប្រទេស តាមរយៈការប្រមូលចំណូលពីការនាំចូល និង ការនាំចេញទំនិញ និងសេវា ដោយសារតែប្រាក់ចំណេញត្រូវបានផ្ទេរពីក្រុមហ៊ុនបរទេស មកក្រុមហ៊ុនក្នុងស្រុកវិញ។
- ជាឧបករណ៍សម្រាប់ការពារជាបណ្តោះអាសន្ន សម្រាប់ឧស្សាហកម្មទុនខ្សោយមួយចំនួន។ គេបានអះអាងថា ឧស្សាហកម្មខ្លះៗមិនអាចរកចំណេញបានទេពីពេលដំបូង។ ក៏ប៉ុន្តែ នៅក្នុងរយៈពេលវែង ឧស្សាហកម្មទាំងនេះនឹងមានភាពប្រកួតប្រជែង (តាមថ្លៃពិភពលោក) ពីព្រោះថ្លៃដើមផលិតកម្មនឹងធ្លាក់ចុះ តាមរយៈយុទ្ធវិធីរៀនចេះពីការធ្វើ។
- ដើម្បីប្រមូលចំណូលថវិកា។ ទោះបីជាយ៉ាងណាក៏ដោយ ពន្ធលើពាណិជ្ជកម្ម មិនមែនជាឧបករណ៍ដ៏មានប្រសិទ្ធភាព ដើម្បីសម្រេចបាននូវគោលដៅប្រមូលចំណូលឡើយ ដោយសារតែពន្ធទាំងនេះធ្វើឱ្យប៉ះពាល់ដល់ផលិតកម្ម និងការប្រើប្រាស់។ ឧបករណ៍ដ៏ល្អបំផុតសម្រាប់ប្រមូលចំណូល គឺជាពន្ធ ដូចជាពន្ធទៅលើប្រាក់ចំណូល ឬ ក៏ពន្ធលើទំនិញប្រើប្រាស់ (អាករពិសេស និង អាករលើតម្លៃបន្ថែម) ដែលអាចអនុវត្តបាន ដោយគ្មានការរើសអើង ទៅលើទាំងទំនិញផលិតនៅក្នុងស្រុក និង ទំនិញនាំចូល។
- កាត់បន្ថយការនាំចូល ដើម្បីធ្វើឱ្យប្រសើរឡើងនូវតុល្យភាពនៃជញ្ជីងទូទាត់។

### ៤២.១.២. អត្ថប្រយោជន៍នៃពន្ធគយរួម

អត្ថប្រយោជន៍នៃពន្ធគយរួម មានដូចខាងក្រោមនេះ ៖

- **ភាពងាយស្រួលខាងរដ្ឋបាល៖** ប្រសិនបើមានពន្ធគយរួមលើទំនិញ នោះនឹងគ្មានការលើកទឹកចិត្តណាមួយ ឱ្យមានការវាយការណ៍ទំនិញបន្លំឡើយ។ កត្តានេះអាចធ្វើឱ្យរដ្ឋបាលគយ និងរដ្ឋាករអាចជឿជាក់ថា អ្នកនាំចូលនឹងមិនបន្ថយតម្លៃទំនិញនាំចូល ហើយប្រការនេះអាចកាត់បន្ថយអំពើពុករលួយក្នុងការនាំចូល។ កត្តាទាំងអស់នេះនឹងធ្វើឱ្យមានការកាត់បន្ថយតម្លៃរដ្ឋបាល ក្នុងការធ្វើពាណិជ្ជកម្ម។
- **កាត់បន្ថយអំពើរត់គេចពន្ធ៖** អត្រាពន្ធគយច្រើនផ្តល់ការលើកទឹកចិត្ត ឱ្យមានការរត់គេចពន្ធចំពោះទំនិញណា ដែលត្រូវបង់ពន្ធខ្ពស់។ ប្រសិនបើអនុវត្តពន្ធគយរួម នោះគ្មានការលើកទឹកចិត្តខ្លាំងក្លា អោយមានអំពើរត់គេចពន្ធរបៀបនេះឡើយ។

បទពិសោធន៍ទូទាំងពិភពលោក ក្នុងរយៈពេល ៥០ ឆ្នាំកន្លងមកនេះ បានបង្ហាញឱ្យឃើញនូវអត្ថប្រយោជន៍នៃរបបពាណិជ្ជកម្មបើកចំហ។ ក៏ប៉ុន្តែ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដំបូងឡើយបានខិតខំជំរុញឧស្សាហូបនីយកម្ម តាមរយៈការបង្កើតរបាំងពន្ធគយយ៉ាងខ្ពស់ ដើម្បីការពារទំនិញក្នុងស្រុក។ ក៏ប៉ុន្តែក្នុងទសវត្សរ៍កន្លងទៅនេះ មានភស្តុតាងជាច្រើនបង្ហាញថា របាំងការពារកាន់តែខ្ពស់ នឹងកាន់តែធ្វើឱ្យការអភិវឌ្ឍសេដ្ឋកិច្ចកាន់តែធ្លាក់ចុះ។ ផ្ទុយទៅវិញ របបពាណិជ្ជកម្មបើកចំហបង្កើតនូវលក្ខខណ្ឌអំណោយផលច្រើនសម្រាប់កំណើនសេដ្ឋកិច្ច (ធនាគារពិភពលោក២០០២:៥២៦)។

ប្រទេសដែលទទួលបានជោគជ័យ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច គឺប្រទេសដែលសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ តាមរយៈកំណើនយ៉ាងខ្លាំងក្លានៃការនាំចេញផលិតផលឧស្សាហកម្ម។ ហើយការនាំចេញទទួលបានជោគជ័យផងដែរ ដោយសារតែរបាំងពន្ធគយសម្រាប់ការនាំចូលមានកម្រិតទាប ឬ ក៏អាចនិយាយម្យ៉ាងទៀតបានថា របបពាណិជ្ជកម្មក្រៅប្រទេសផ្តល់ការលើកទឹកចិត្តដល់អ្នកនាំចេញ។

### ៤២.១.៣. អំណោះអំណាងក្នុងការរៀបចំពន្ធគយរួម ហើយទាប

គោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាមានគោលដៅសម្រេចឱ្យបាន នូវកំណើននៃផលិតផលឧស្សាហកម្មក្នុងអត្រាខ្ពស់ និង ការអភិវឌ្ឍ ដោយឈរលើមូលដ្ឋាននៃការពង្រីកមូលដ្ឋាន និងការធ្វើពិពិធកម្មនៃការនាំចេញ និង ការពង្រឹងនូវភាពប្រកួតប្រជែងរបស់កម្ពុជាជាមួយនឹងផលិតផលឧស្សាហ-កម្មនាំចូល។ ក្នុងគោលដៅសម្រេចឱ្យបាននូវចក្ខុវិស័យនេះ កម្ពុជាត្រូវខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់ធនធានទាំងឡាយរបស់ខ្លួនឱ្យអស់លទ្ធភាពរបស់វា ក្នុងវិស័យផលិតកម្ម។

ដើម្បីឱ្យវិស័យឯកជនដើរតួនាទីឈានមុខ ក្នុងការបែងចែកធនធាន ការលើកទឹកចិត្តខាងផ្នែកគោលនយោបាយ មិនត្រូវឱ្យប៉ះពាល់ដល់ការវាយតម្លៃទាក់ទងនឹងជម្រើសវិនិយោគរបស់ពួកគេ។ ពោល គឺរាជរដ្ឋាភិបាលត្រូវដាក់ចេញនូវវិធានការ ដើម្បីកាត់បន្ថយ និងឈានទៅបំបាត់នូវអត្រាការពារ ដែលមានកម្រិតយ៉ាងខ្ពស់ដូចលើកឡើងខាងលើ។ ប្រការនេះមានន័យថា រាជរដ្ឋាភិបាលត្រូវធ្វើកំណែទម្រង់អត្រាពន្ធគយដែលមានច្រើនគន្លាក់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គោលដៅជាសារវន្តនៃគោលនយោបាយប្រព័ន្ធពន្ធគយ គឺការអនុមតិនូវរចនាសម្ព័ន្ធអត្រាពន្ធរួមមានអត្រាទាប ដែលមានចំនួនអត្រាពន្ធគយ (tariff band) មួយចំនួនប៉ុណ្ណោះ។ ពោលគឺ ប្រព័ន្ធនេះមានចំនួនអត្រាពន្ធមួយចំនួន តែត្រូវអនុវត្តសម្រាប់ការនាំចូលទាំងអស់ ឬ ស្ទើរតែទាំងអស់ ហើយប្រព័ន្ធនេះនឹងសម្រួលឱ្យមានការអនុវត្តច្បាប់យ៉ាងតឹងរឹង មិនលើកទឹកចិត្តឱ្យមានការរត់ពន្ធទំនិញនាំចូលគេចពន្ធ និង កាត់បន្ថយចំណាយការិយាធិបតេយ្យ។ ការកំណត់កម្រិតសមស្របនៃអត្រាពន្ធគយ មានគោលដៅធ្វើយ៉ាងណាឱ្យសម្រេចបាននូវការកៀរគរចំណូលថវិកា។ ក្នុងន័យនេះ អត្រាពន្ធគយទាបដែលមានលក្ខណៈដូចគ្នាទៅលើការនាំចូលទាំងអស់ ឬ ស្ទើរតែទាំងអស់នៃសម្ភារៈប្រើប្រាស់សម្រាប់ផលិតកម្ម វត្ថុធាតុដើម និង ផលិតផលសម្រេចនឹងធានាឱ្យបានថា អ្នកផលិតក្នុងស្រុកនឹងមិនទទួលរងគ្រោះ ក្នុងការប្រកួតប្រជែងជាមួយទំនិញនាំចូល។

## ២២.២. ការកាត់បន្ថយពន្ធគយ (Tariff Restructuring)

### ២២.២.១. របាំងពន្ធគយ

គោលនយោបាយពាណិជ្ជកម្មដ៏មានប្រសិទ្ធភាព គឺមានសារៈសំខាន់ណាស់សម្រាប់ការធ្វើសមាហរណកម្មរបស់កម្ពុជាចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក។ "គោលនយោបាយពាណិជ្ជកម្មបង្កើតជាយន្តការចម្លង ដែលពាណិជ្ជកម្មអន្តរជាតិជះឥទ្ធិពលមកលើការបែងចែកធនធានក្នុងស្រុក ការបង្កើតនូវឧស្សាហកម្ម និង កសិកម្ម ដែលប្រកួតប្រជែង និងមានប្រសិទ្ធភាព ការទទួលបានបច្ចេកវិទ្យាចម្រុះនិងថ្មី ការជំរុញការលើកទឹកចិត្តដល់អ្នកនាំចេញ និង ការកាត់បន្ថយការគេចពន្ធ ការស្វែងរកផលប្រយោជន៍ និង អំពើពុករលួយ តាមរយៈការអនុវត្តពន្ធគយ (WB. ២០០២:៥២៦)។

គោលនយោបាយពន្ធគយ គឺជាចំណុចស្នូលនៃគោលនយោបាយពាណិជ្ជកម្មនៅក្នុងប្រព័ន្ធទីផ្សារ។ ក្នុងន័យនេះ ពន្ធគយ គឺជាឧបករណ៍គោលនយោបាយ ដែលប្រទេសកំពុងអភិវឌ្ឍអាចប្រើប្រាស់បានសម្រាប់ការការពារនៅក្នុងក្របខ័ណ្ឌ **កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម** និង **អង្គការពាណិជ្ជកម្មពិភពលោក** (GATT / WTO)។ ពន្ធគយមានឧត្តមភាពជាងជម្រើសឧបករណ៍សម្រាប់ការពារផ្សេងទៀត ដូចជារបាំងមិនមែនពន្ធគយ (NBTs) មានជាអាទិ៍ កូតា អាជ្ញាប័ណ្ណ និង របាំងបច្ចេកទេសពាណិជ្ជកម្ម។

គោលនយោបាយពាណិជ្ជកម្ម ជាពិសេសពន្ធគយ ជះឥទ្ធិពលមកលើថ្លៃទំនិញក្នុងស្រុក ហើយកត្តានេះវាជះឥទ្ធិពលត្រឡប់ទៅវិញ គឺការសម្រេចចិត្តក្នុងការវិនិយោគ និង ផលិតកម្ម។ ឧស្សាហកម្មដែលមិនប្រកួតប្រជែងជាមួយនឹងការនាំចូល ដោយសារតែពន្ធគយ ការឧបត្ថម្ភធន និង ការកំណត់បរិមាណនាំចូលមានការលើកទឹកចិត្តជំរុញការផលិតសម្រាប់ទីផ្សារក្នុងស្រុក ហើយមិនមែនសម្រាប់ការនាំចេញទេ។ ជួនកាលមានមតិជំទាស់ថា ប្រទេសមួយអាចការពារឧស្សាហកម្មដែលមានប្រកួតប្រជែង ពីទំនិញនាំចូលមួយចំនួន ដោយសារក្នុងពេលជាមួយគ្នានោះ ប្រទេសនោះអនុញ្ញាតឱ្យអ្នកនាំចេញអាចទិញវត្ថុធាតុដើមដែលនាំចូល តាមថ្លៃប្រកួតប្រជែងកម្រិតពិភពលោក តាមរយៈការអនុវត្តនូវកម្មវិធីឱ្យរួចពន្ធផ្សេងៗ។ គោលនយោបាយនេះធ្វើឱ្យគេបាញ់ព្រួញមួយបានសត្វពីរ ដោយសម្រេចបានគោលដៅពីរយ៉ាង គឺជំរុញការនាំចេញ និង ការបង្កើតឧស្សាហកម្មដែលអាចប្រកួតប្រជែងជាមួយការនាំចូល។

មុនពេលមានការអនុវត្តនូវកំណែទម្រង់ពន្ធគយ កម្មវិធីពន្ធគយរបស់កម្ពុជាមានបន្ទាត់ពន្ធគយ ៦,៨២១ ចែកជា ១២ ចង្កោមៈ ០ភាគរយ ០,៣ភាគរយ ៧ភាគរយ ១០ភាគរយ ១៥ភាគរយ ២០ភាគរយ ៣០ភាគរយ ៣៥ភាគរយ ៤០ភាគរយ ៥០ភាគរយ ៩០ភាគរយ និង១២០ភាគរយ។ អត្រាពន្ធគយបីចង្កោម គឺ ៤០ភាគរយ ៩០ភាគរយ និង១២០ភាគរយ ត្រូវអនុវត្តសម្រាប់យានយន្ត។ ចង្កោមអត្រា៥០ភាគរយ គឺសម្រាប់បារី ផលិតផលប្រេងឥន្ធនៈ ភេសជ្ជៈ និង គ្រឿងបន្លាស់យានយន្ត។ ការនាំចូលភាគច្រើនរបស់កម្ពុជាគឺស្ថិតនៅក្នុងចង្កោម៧ភាគរយ ១៥ភាគរយ ២០ភាគរយ និង៥០ភាគរយ។

អត្រាកំណត់ពន្ធជាង៩០ភាគរយស្ថិតនៅក្នុងចង្កោមបី ៖ ៧ភាគរយ ១៥ភាគរយ និង៣៥ភាគរយ។ នេះមានន័យថា ការកែសម្រួលណាក៏ដោយដែលរក្សាទុកចង្កោមពន្ធ៧ភាគរយ ១៥ភាគរយ និង៣៥ភាគរយ នឹងមិនមានផលប៉ះពាល់ខ្លាំងលើប្រាក់ចំណូលទេ។ ហេតុដូចនេះហើយការកែសម្រួលពន្ធគយដែលធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានសម្រួលអត្រាពន្ធគយ ដែលនៅលើកម្រិត៣៥ភាគរយ មកត្រឹម ៣៥ ភាគរយ ដោយច្របាច់បញ្ចូលគ្នាអត្រាពន្ធគយបីកម្រិតគឺ ១០ភាគរយ ១៥ភាគរយ និង ២០ភាគរយ មកនៅកម្រិត១៥ភាគរយ ហើយរក្សា៧ភាគរយនៅដដែល និងបញ្ចូលគ្នាពី ០.៣ភាគរយនិង០ភាគរយមក០ភាគរយ។

ទោះបីជាយ៉ាងណាក៏ដោយ ការកែសម្រួលពន្ធគយរបៀបនេះវានឹងនាំឱ្យមានការបាត់បង់ចំណូលពីប្រភពដូចខាងក្រោមនេះ ៖ បាត់បង់ពន្ធនាំចូលបាត់បង់អាករពិសេស និង បាត់បង់ពន្ធលើតម្លៃបន្ថែម។ គួរឱ្យកត់សម្គាល់ផងដែរថា អាករពិសេស និង អាករលើតម្លៃបន្ថែម ត្រូវបានគេគណនាដោយឈរលើមូលដ្ឋានតម្លៃពន្ធគយ បូកនឹងពន្ធគយនិងអាករ។ ហើយតាមការប៉ាន់ស្មានឃើញថា ការកែសម្រួលនេះនឹងធ្វើឱ្យខាតបង់ពី ៤០ ទៅ ៥០ ពាន់លានរៀល (billion CRs )។

ជាវិធានការប៉ះប៉ូវការបាត់បង់ចំណូលថវិកា ដោយសារការអនុវត្តកំណែទម្រង់ពន្ធគយនេះ រាជរដ្ឋាភិបាលបានបង្កើនអត្រាអាករពិសេសលើទំនិញសំខាន់ទាំងនេះ។ សារៈសំខាន់នៃការផ្លាស់ប្តូរពីពន្ធគយទៅការប្រើប្រាស់អាករពិសេសនេះ គឺជាវិធានការបង្កើនចំណូល ដោយជៀសវាងនូវផលប៉ះពាល់ជាអវិជ្ជមាននៃពន្ធគយខ្ពស់លើការបែងចែកធនធាននៅក្នុងស្រុក ពីព្រោះថាអាករពិសេសត្រូវបានអនុវត្តដោយស្មើភាពគ្នា ទាំងទំនិញផលិតនៅក្នុងស្រុក ទាំងលើទំនិញនាំចូល។

ទោះបីជាយ៉ាងណាក៏ដោយ មិនមែនទំនិញនិងផលិតផលទាំងអស់ត្រូវតែអនុវត្តអាករពិសេសនោះទេ។ ដូច្នេះហើយដើម្បីធានាឱ្យបាននូវការកើនឡើងចំណូលបន្ទាប់ពីមានការកែសម្រួលនេះ រដ្ឋាភិបាលបានសម្រេចចិត្តបង្កើនអត្រាអាករពិសេសទៅលើផលិតផលខ្លះ ជាជាងការកាត់បន្ថយអត្រាពន្ធគយ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានបង្កើនអត្រាអាករពិសេសទូទៅផងដែរលើទំនិញផលិតក្នុងស្រុកដែលអាចយកអាករបាន ដើម្បីរក្សាអត្រាអាករពិសេសរួមមួយ ទៅលើគ្រប់ទំនិញទាំងអស់ដោយមិនគិតពីប្រទេសដើម។

### ២២.២.២. កំណែទម្រង់ពន្ធគយ

នៅថ្ងៃទី២៥ខែឧសភាឆ្នាំ២០០១ រាជរដ្ឋាភិបាលបានកាត់បន្ថយចង្កោមពន្ធគយពី ១២ មកនៅ ៤ ដែលមានអត្រាខ្ពស់បំផុតធ្លាក់ពី ១២០ ភាគរយមកត្រឹម ៣៥% (ណារ៉ុន២០០១) ។ ចង្កោមពន្ធគយ ៣៥ ភាគរយនេះជួយការពារដល់ទំនិញប្រើប្រាស់ និង ទំនិញពាក់កណ្តាលសម្រេចយ៉ាងច្រើនដូចជា ផលិតផលសាច់កែច្នៃ និង ផលិតផលទឹកដោះ បន្លែ និង ផ្លែឈើកែច្នៃ ម្សៅស្រូវសាឡី ភេសជ្ជៈ និងផលិតផលថ្នាំជក់ វាយនភ័ណ្ឌ និង សម្លៀកបំពាក់ ក្តារបន្ទះ និងគ្រឿងអលង្ការ។ ក្រោមចង្កោមពន្ធនេះវាគ្របដណ្តប់លើមួយភាគប្រាំនៃគ្រប់ទំនិញនាំចូលទាំងអស់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅចុងឆ្នាំ២០០២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានកាត់បន្ថយអត្រាពន្ធគយមធ្យមនីមួយៗឱ្យស្ថិតនៅក្រោម១៥ភាគរយ។ បរិមាណនៃអត្រាកាន់តែតិច គម្លាតនៃអត្រាកាន់តែតូច និង អត្រាជាមធ្យមកាន់តែទាប នៅពេលនោះ ចំណាយក្នុងការយកពន្ធគយនឹងតិចជាងមុន សម្រាប់សេដ្ឋកិច្ចជាតិ ដោយសារការបែងចែកធនធានខុសទិសដៅ។

បន្ថែមលើពន្ធគយ ពន្ធប្រយោលពីរទៀតត្រូវបានអនុវត្ត ដោយឈរលើមូលដ្ឋានតម្លៃនាំចូល គឺ អាករពិសេស និង អាករលើតម្លៃបន្ថែម។ ជាទូទៅ ប្រទេសកម្ពុជាប្រមូលចំណូលពន្ធ ប្រហែលជា ៧៦.៥១ ភាគរយនៃចំណូលពន្ធគយសរុបរបស់ខ្លួនពីការនាំចូល ដែលក្នុងនោះ ចំណូលពីពន្ធប្រយោលមានចំនួន ៥១ ភាគរយ នៃពន្ធទាំងអស់នៃការនាំចូលក្នុងឆ្នាំ ២០០១។

អាករពិសេសបានមកពីទំនិញ៥ក្រុមគឺៈ ភេសជ្ជៈ (ទឹកសុទ្ធ) ផលិតផលថ្នាំជក់ យានជំនិះធ្វើដំណើរ ម៉ូតូ និង ផលិតផលប្រេង។ អាករលើតម្លៃបន្ថែមត្រូវអនុវត្ត ១០ ភាគរយដូចគ្នា។ ដោយមានការលើកលែងបន្តិចបន្តួចប៉ុណ្ណោះ ពន្ធទាំងពីរនេះត្រូវអនុវត្តលើការនាំចូល ដោយឈរលើលក្ខខណ្ឌ និង អត្រាដូចគ្នាទៅនឹងទំនិញក្នុងស្រុកដែរ។ អ្នកនាំចូលទទួលបានអត្រាអាករលើតម្លៃបន្ថែម ០ភាគរយ សម្រាប់នាំចូលវត្ថុធាតុដើមទាំងឡាយណា ដើម្បីយកមកប្រើប្រាស់ក្នុងការផលិតជាទំនិញនាំចេញ។

ជាការពិតណាស់ ទម្រង់នៃការការពារមានការទាក់ទងទៅនឹងពន្ធគយទាប សម្រាប់ទំនិញមិនទាន់កែច្នៃ និង វត្ថុធាតុដើម ហើយពន្ធខ្ពស់សម្រាប់ផលិតផលសម្រេចចុងក្រោយ។ កម្មវិធីពន្ធគយរបស់កម្ពុជាត្រូវបានគេចាត់ទុកថាមានពន្ធគយទាបទៅលើទំនិញសម្រេច ដែលបានជ្រើសរើសឱ្យជាប់ពន្ធជាមធ្យមនិងខ្ពស់ ដែលនេះគេអាចហៅបានថាបង្កើនពន្ធគយ។ កត្តានេះបណ្តាលឱ្យមានការបែងចែកធនធានមិនមានប្រសិទ្ធភាព។

នៅក្នុងរយៈពេលវែង រចនាសម្ព័ន្ធអត្រាពន្ធកើនឡើង ដែលផ្តោតទៅលើផលិតកម្មទំនិញសម្រេចចុងក្រោយ ដែលធ្វើឱ្យខូតខាតដល់ផលិតកម្មពាក់កណ្តាលសម្រេច លើកទឹកចិត្តសកម្មភាពអាជីវកម្មប្រភេទតំឡើង ប៉ុន្តែមិនបានលើកទឹកចិត្តដល់ផលិតកម្មទំនិញពាក់កណ្តាលសម្រេចឡើយ។

ភាគច្រើនកំណើនយ៉ាងឆាប់រហ័សនៅក្នុងវិស័យឧស្សាហកម្ម គឺដោយសារការនាំចេញ ជាពិសេស វាយនភ័ណ្ឌហើយថ្មីៗនេះទៀតគឺស្បែកជើង។ ផ្ទុយទៅវិញ កំណែទម្រង់ពន្ធគយកាន់តែច្រើននឹងបង្កើតឱ្យមានផលចំណេញកាន់តែខ្ពស់នៅក្នុងរយៈពេលខ្លី។ អត្រាពន្ធគយរួម និង ទាបមួយជាសញ្ញាណបង្ហាញទៅអ្នកវិនិយោគថា កម្ពុជាមានបំណងធ្វើជាកន្លែងវិនិយោគនៅក្នុងវិស័យណា ដែលកម្ពុជាមានគុណសម្បត្តិប្រៀបធៀបខ្ពស់។ កត្តានេះនឹងជួយទាក់ទាញអ្នកវិនិយោគដោយផ្ទាល់ពីបរទេស (Foreign Direct Investment) មកក្នុងវិស័យនេះ។

អត្រាពន្ធគយរួមនិងទាបមួយធ្វើឱ្យអ្នកវិនិយោគអាចទិញវត្ថុធាតុដើម តាមតម្លៃពិភពលោក (ឬ ក្នុងកម្រិតពិភពលោក) ហើយកត្តានេះនាំឱ្យមានការធានាបានថា អ្នកផលិតសម្រាប់ផ្គត់ផ្គង់ឱ្យទីផ្សារក្នុងស្រុក (រួមទាំង សហគ្រាសតូចនិងមធ្យម) នឹងមិនទទួលរងគ្រោះ ដោយសារតែការនាំចូល។ ប៉ុន្តែផ្ទុយទៅវិញ វាជួយជំរុញឱ្យមានការអភិវឌ្ឍឧស្សាហកម្មប្រកួតប្រជែងជាមួយការនាំចូល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ១២.២.៣. ថ្លៃដែលត្រូវបង់ក្នុងការអនុវត្តកំណែទម្រង់ពន្ធគយ

ប្រទេសដែលមានការបើកចំហរបបនយោបាយពាណិជ្ជកម្ម តែងតែជួបប្រទះនឹងការខាតបង់រយៈពេលខ្លី ដោយសារការអនុវត្តកំណែទម្រង់នេះ។ ជាពិសេស ប្រទេសដែលធ្លាប់បានប្រើពន្ធគយ និងរបាំងមិនមែនពន្ធគយយ៉ាងទូលំទូលាយ ដើម្បីការពារមូលដ្ឋានឧស្សាហកម្មដែលមិនមានប្រសិទ្ធភាពរបស់ពួកគេ តែងតែខាតបង់ច្រើនដោយសារកំណែទម្រង់។ ជាទូទៅ ថ្លៃដែលត្រូវបង់ទាំងអស់នេះ រួមមានការអត់ការងារធ្វើក្នុងរយៈពេលខ្លី ក្នុងកម្រិតខ្ពស់ ដោយសារតែមានការកែសម្រួលឡើងវិញនៅផ្នែកណា ដែលមិនទាន់មានប្រសិទ្ធភាព ហើយធនធានត្រូវបានគេយកទៅប្រើឱ្យមានប្រសិទ្ធភាពជាងមុន។

ការខាតបង់សំខាន់បំផុតក្នុងកំណែទម្រង់របស់កម្ពុជា គឺផលប៉ះពាល់នៃកំណែទម្រង់ពន្ធគយទៅលើចំណូលថវិកា។ ដើម្បីធ្វើការប្រៀបធៀបផលប៉ះពាល់នេះ យើងត្រូវធ្វើការវិភាគការប្រមូលចំណូលពីពន្ធនាំចូល អាករលើតម្លៃបន្ថែម អាករពិសេស និងពន្ធលើផលរបរ នៅក្នុងឆមាសទី១ ឆ្នាំ ២០០២ ដោយធ្វើការប្រៀបធៀបជាមួយនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០០១។ ចំណូលលើពន្ធទាំងនេះមានការកើនឡើង១,៦ភាគរយ គឺ ដល់ ៤៧៧.៧ពាន់លានរៀល (ពន្ធនាំចូល ១៧៨.៩ពាន់លាន អាករលើតម្លៃបន្ថែម ២០៥.៧ពាន់លាន អាករពិសេស ៨៩.៧ ពាន់លាន ពន្ធលើផលរបរ ៣.៤ពាន់លាន) នៅក្នុងឆមាសទីមួយឆ្នាំ២០០២ ជាមួយនឹង ៤៧០.៣ពាន់លានរៀល (ពន្ធនាំចូល ១៩៥.៧ពាន់លានរៀល អាករលើតម្លៃបន្ថែម ២០៥.០ពាន់លានរៀល អាករពិសេស ៦៣.៧ពាន់លានរៀល ពន្ធលើផលរបរ ៥.៩ពាន់លានរៀល) នៅឆមាសទីមួយឆ្នាំ២០០១។

យើងរំពឹងថា កំណែទម្រង់ពន្ធគយនឹងធ្វើឱ្យបាត់បង់ចំណូល ពីប្រភពខាងក្រោមនេះ គឺបាត់បង់ចំណូលពីពន្ធនាំចូល អាករពិសេស និង អាករលើតម្លៃបន្ថែម។ យើងអាចមើលឃើញថាពន្ធនាំចូលបានធ្លាក់ចុះ១៦.៨ពាន់លានរៀល ប៉ុន្តែអាករពិសេសបានកើនឡើង២៦ពាន់លានរៀល។ ការប្រមូលអាករលើតម្លៃបន្ថែមបានកើន ០.៧ ពាន់លាន។ ទោះបីយ៉ាងណាក៏ដោយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានប្រឹងប្រែងដើម្បីពង្រឹងការប្រមូលពន្ធតាមរបបពិត នៅក្នុងខេត្តចំនួន៥ និង ពង្រីកមូលដ្ឋានប្រមូលពន្ធនៅក្រុងភ្នំពេញ។ ជាមួយគ្នានោះផងដែរ ចំណូលពន្ធលើបផលរបរបានធ្លាក់ចុះ២.៥ពាន់លានរៀល ដោយសារតែអ្នកបង់ពន្ធខ្លះបានផ្ទេរ ពីការបង់ពន្ធតាមរបបមៅការ ទៅកាន់ការប្រមូលពន្ធតាមរបបពិត។

ប្រសិនបើយើងដកចេញពីការគណនារបស់យើង នូវអាករលើតម្លៃបន្ថែម និង ពន្ធលើផលរបរ យើងអាចសន្និដ្ឋានបានថា កំណែទម្រង់ពន្ធគយនាំឱ្យមានចំណូលកើនឡើងប្រហែល ១១ ពាន់លានរៀល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាង២២.២ពន្ធគយសង្ខេបរបស់កម្ពុជា២០០៩*

| ផ្នែក/អត្រាគោល | ចំនួនបន្ទាត់ពន្ធគយ | | | | សរុប |
|---|---|---|---|---|---|
| | ០% | ៧% | ១៥% | ៣៥% | |
| សត្វនិងផលិតផលសត្វ | ២៧ | ៦ | ១៦៨ | ១២៥ | ៣៨៨ |
| ផលិតផលបន្លែ | ៣៨ | ១៩៦ | ១០៩ | ៥២ | ៣៩១ |
| ខ្លាញ់និងប្រេង | ០ | ១៥០ | ០ | ០ | ១៥០ |
| អាហារវេចខ្ចប់ | ០ | ១១៦ | ៨៧ | ១៨៣ | ៣៨៦ |
| ផលិតផលរ៉ែ | ២១ | ៩២ | ៧១ | ១៣ | ១៩៧ |
| ផលិតផលគីមីឬពាក់ព័ន្ធនិងឧស្សាហកម្ម | ១៥៣ | ៦៩៥ | ៧៦ | ១៧៨ | ១០៩៨ |
| ផ្លាស្ទិក | ៩៨ | ១៥៩ | ៦៧ | ៦៨ | ៣៩២ |
| ស្បែកសត្វ | ០ | ៤២ | ៥ | ៣៨ | ៨៥ |
| ឈើនិងផលិតផលធ្វើពីឈើ | ០ | ៦៤ | ៥៣ | ១៩ | ១៣៦ |
| ក្រដាសនិងប្រដាប់ធ្វើក្រដាស | ៩ | ២១១ | ០ | ៤ | ២២៤ |
| វាយនភ័ណ្ឌនិងផលិតផលពាក់ព័ន្ធ | ០ | ៥៩៨ | ៨៦ | ២៤៣ | ៩២៧ |
| ស្បែកជើង | ០ | ២១ | ៣២ | ១០ | ៦៣ |
| ថ្ម/ ស៊ីម៉ង់ត៍/ សេរ៉ាមិក | ០ | ១១៥ | ៥២ | ១៨ | ១៨៥ |
| ត្បូង | ១៣ | ៦២ | ០ | ០ | ៧៥ |
| សម្ភារៈធ្វើពីលោហៈធាតុឬលោហៈធាតុ | ១២៥ | ៤៧៤ | ១២៧ | ១០០ | ៨២៦ |
| គ្រឿងម៉ាស៊ីននិងបរិក្ខារអគ្គិសនី | ៣៨ | ១៥៩ | ១៣៤០ | ២៦៦ | ១៨០៣ |
| យានយន្ត | ៣៣ | ៨ | ៣១៩ | ៦៧ | ៤២៧ |
| ផ្នែកចក្ខុវេជ្ជសាស្ត្រនិងឧបករណ៍តន្ត្រី | ១៨ | ៥៣ | ២២១ | ៤៧ | ៣៣៩ |
| អាវុធ | ៦ | ០ | ០ | ២២ | ២៨ |
| ទំនិញឧស្សាហកម្មផ្សេងៗ | ៤៣ | ៤៥ | ៧៥ | ៤៩ | ២១២ |
| វត្ថុបុរាណនិងវត្ថុសិល្បៈ | ១០ | ០ | ០ | ០ | ១០ |
| បន្ទាត់ពន្ធគយសរុប | ៦២៨ | ៣២៦៦ | ២៩០៦ | ១៩៩៨ | ៨២៩៨ |
| ភាគរយនៃបន្ទាត់ពន្ធគយ | ៧,៥៧% | ៣៩,៣៦% | ៣៥,០២% | ១៨,០៥% | ១០០% |

*ប្រភព ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហេតុដូច្នេះ កម្ពុជាមិនប្រឈមមុខនឹងការខាតបង់រយៈពេលខ្លី ពីកំណែទម្រង់ ដូចដែលប្រទេសខ្លះបានជួបប្រទះ នៅពេលដែលគេធ្វើសេរីភាវូបនីយកម្មរចនាសម្ព័ន្ធពាណិជ្ជកម្មរបស់គេនោះទេ។ មូលហេតុ គឺថាកម្ពុជាមិនមានវិស័យឧស្សាហកម្មដែលគ្មានប្រសិទ្ធភាព ដែលស្ថិតនៅក្រោមពន្ធគយខ្ពស់នោះទេ។ សម្រាប់សកម្មភាពភាគច្រើន អត្រាពន្ធគយខ្ពស់គឺគ្មានប្រយោជន៍ឡើយ ដោយសារតែសកម្មភាពអាជីវកម្មក្នុងស្រុកប្រភេទនេះ នៅមានកម្រិតនៅឡើយ ឬក៏ដោយសារតែការរត់គេចពន្ធទំនិញ ដែលធ្វើឱ្យតម្លៃនៅក្នុងស្រុកប្រហាក់ប្រហែលនឹងតម្លៃពិភពលោក។

រចនាសម្ព័ន្ធពន្ធគយរបស់កម្ពុជា គឺពឹងផ្អែកលើចង្កោមពន្ធគយដ៏ទូលំទូលាយទាំង ៤ ដែលឆ្លើយតបទោះតិច ឬ ច្រើនមិនថាជាទំនិញសម្រេចចុងក្រោយ ឬ វត្ថុធាតុដើមឡើយ។ រចនាសម្ព័ន្ធអត្រាពន្ធគយធ្លាក់ចុះដោយអត្រាខ្ពស់សម្រាប់ទំនិញសម្រេច និង អត្រាទាបសម្រាប់ទំនិញពាក់កណ្ដាលសម្រេច និង វត្ថុធាតុដើម។ វិស័យសំខាន់ជាច្រើនដូចជា ម្ហូបអាហារ និង ភេសជ្ជៈ សម្លៀកបំពាក់ និង វាយនភ័ណ្ឌ ផលិតផលលោហធាតុមានរចនាសម្ព័ន្ធពន្ធគយទាបដាច់ដោយឡែក។

- អត្រា០ភាគរយ៖ ត្រូវបានអនុវត្តសម្រាប់សត្វចិញ្ចឹម គ្រាប់ពូជ បន្លែ និង ឱសថពិសេស។
- អត្រា៧ភាគរយ៖ ត្រូវបានអនុវត្តសម្រាប់វត្ថុធាតុដើមគីមី វត្ថុធាតុដើមសម្រាប់វាយនភ័ណ្ឌ និង សម្លៀកបំពាក់ (នៅក្នុងការអនុវត្តជាក់ស្តែង ត្រូវបានលើកលែងសម្រាប់រោងចក្រវាយនភ័ណ្ឌ) រ៉ែដែក ឈើមិនទាន់កែច្នៃ រោមសត្វ និង ជីគីមី។
- អត្រា១៥ភាគរយ៖ ត្រូវបានអនុវត្តចំពោះគ្រឿងចក្រ សម្រាប់ធ្វើការផលិតក្បាលម៉ាស៊ីនរថភ្លើង គ្រឿងម៉ាស៊ីន បរិក្ខារអគ្គិសនី ផលិតផលឧស្សាហកម្មសម្រេច និងផលិតផលកសិកម្មពាក់កណ្ដាលសម្រេច។
- អត្រា៣៥ភាគរយ៖ ត្រូវបានអនុវត្តចំពោះផលិតផលកសិកម្មសម្រេច ផលិតផលឧស្សាហកម្មសម្រេច ត្បូងមានតម្លៃ លោហៈធាតុមានតម្លៃ រថយន្ត និងផលិតផលប្រេង។

រចនាសម្ព័ន្ធពន្ធគយធ្លាក់ចុះមានតួនាទីយ៉ាងសំខាន់ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចដែលពឹងផ្អែកលើការនាំចេញរបស់រដ្ឋាភិបាលនិងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ តាមរយៈការកំណត់អត្រាពន្ធគយខ្ពស់ទៅលើទំនិញប្រើប្រាស់ និងទំនិញកែច្នៃ ប្រជាជនកម្ពុជាត្រូវបង់លើសពីតម្លៃអន្តរជាតិ សម្រាប់តម្រូវការមូលដ្ឋាន។ តែទំនិញនាំចូលគេចពន្ធអាចជួយសម្រួលដល់តម្លៃខ្ពស់ទាំងនេះបាន។ ដើម្បីលើកតម្កើងឧស្សាហកម្មវាយនភ័ណ្ឌ រាជរដ្ឋាភិបាលបានផ្តល់ការលើកលែងពន្ធដល់ការនាំចូលវត្ថុធាតុដើម សម្រាប់ផលិតសម្លៀកបំពាក់ ដោយអនុលោមតាមច្បាប់ស្តីពីការវិនិយោគ។

ដោយសារតែរចនាសម្ព័ន្ធពន្ធគយរបៀបនេះ អ្នកប្រើប្រាស់ផលិតផលដែលស្ថិតនៅក្នុងសង្វាក់ផលិតកម្មខាងក្រោម ត្រូវតែបង់ថ្លៃខ្ពស់សម្រាប់ផលិតផលពាក់កណ្ដាលសម្រេច ដែលជាគ្រឿងផ្សំដ៏សំខាន់សម្រាប់ការផលិតទំនិញរបស់ពួកគេ។ ថ្លៃដើមខ្ពស់ក្នុងការផលិតក៏ជះឥទ្ធិពលផងដែរដល់អ្នកប្រើប្រាស់តាមរយៈតម្លៃលក់រាយខ្ពស់។ ដូច្នេះអ្នកដែលខាតបង់ដោយសារតែតម្លៃពន្ធគយខ្ពស់ គឺ អ្នកប្រើប្រាស់ផលិតផល។

## ២២.៣. របាំងមិនមែនពន្ធគយ

របាំងមិនមែនពន្ធគយភាគច្រើនចំពោះពាណិជ្ជកម្មត្រូវបានគេលប់ចោល។ ហើយអ្វីដែលនៅសល់ គឺជាការរឹតបន្តឹងការនាំចេញជាបណ្ដោះអាសន្ន លើផលិតផលស្រូវ និង អាជ្ញាប័ណ្ណនាំចូលឱសថ។ គេអនុវត្ត កូតាលើការនាំចេញផលិតផលឈើប្រចាំឆ្នាំ និង តាមរយៈការផ្ដល់អាជ្ញាប័ណ្ណមិនស្វ័យប្រវត្តិ។ ដោយសារ តែអត្រាពន្ធគយមានកម្រិតទាប កម្ពុជាបានក្លាទៅជាមជ្ឈមណ្ឌលសម្រាប់ផ្លាស់ប្ដូរពាណិជ្ជកម្មនៅក្នុងតំបន់ ជាពិសេសជាមួយនឹងប្រទេសវៀតណាម។ ទោះបីជាយ៉ាងណាក៏ដោយ ការនាំចេញទៅកាន់វៀតណាមបាន ធ្លាក់ចុះបន្តិចម្ដងៗ ចាប់តាំពីឆ្នាំ ២០០៦ ដោយសារតែការបើកចំហរបស់វៀតណាមចំពោះទីផ្សារពិភពលោក។

### ២២.៣.១. ការត្រួតពិនិត្យនិងការរឹតបន្តឹងការនាំចូល

ជាមួយនឹងការលើកលែងខ្លះ នៅក្នុងឆ្នាំ១៩៩៤ កម្ពុជាបានលប់ចោលអស់នូវការរឹតបន្តឹងបរិមាណ លើការនាំចូល ដែលជាផ្នែកមួយនៃកម្មវិធីស៊ីជម្រៅនៃវិធានការកំណែទម្រង់ពាណិជ្ជកម្ម។ ប្រព័ន្ធអាជ្ញាប័ណ្ណនាំ ចូលក៏បានលប់ចោលផងដែរនៅក្នុងឆ្នាំ១៩៩៤ លើកលែងតែទំនិញកំណត់ខ្លះ ដូចជាផលិតផលឱសថ ប្រាក់ និង មាស អាវុធយុទ្ធភណ្ឌ និង គ្រឿងផ្ទុះ និង សម្ភារៈវេជ្ជសាស្ត្រ និង វប្បធម៌ដទៃទៀត។ ដើម្បីនាំចូលទំនិញទាំង អស់នេះបាន គឺត្រូវទាមទារការអនុញ្ញាតពីក្រសួងពាក់ព័ន្ធនានា។ ការហាមឃាត់នៅតែរក្សាទុកសម្រាប់ទំនិញ នាំចូលខ្លះៗ។ ជាឧទាហរណ៍ការហាមឃាត់ទំនិញនាំចូលនាពេលបច្ចុប្បន្ននេះ មានដូចជាសាច់ជ្រូក សម្បក កង់ម៉ូតូ ដែលប្រើហើយ រថយន្តចង្កូតស្ដាំ និង ស្បែកជើងជជុះ។

ផ្ទុយទៅវិញ ក្រុមហ៊ុននឹងមិនប្រឈមការរឹតបន្តឹងការនាំចូលទំនិញ នៅពេលណាដែលក្រុមហ៊ុននាំ ចូលនោះ ជាក្រុមហ៊ុនចុះបញ្ជីនៅក្រោមច្បាប់របស់កម្ពុជា។ ក្រុមហ៊ុនពាណិជ្ជកម្មក្រៅប្រទេសមានសិទ្ធិ ដំណើរការដោយសេរីនៅក្នុងប្រទេសកម្ពុជា ដរាបណាក្រុមហ៊ុននោះដំណើរការទៅតាមច្បាប់របស់កម្ពុជា ហើយបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។ នៅខណៈដែលក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋខ្លះនៅបន្តដំណើរការ ក្រុមហ៊ុនទាំងនេះភាគច្រើន ប្រកួតប្រជែងជាមួយនឹងក្រុមហ៊ុនពាណិជ្ជកម្មឯកជន នៅក្នុងទីផ្សារដូចគ្នា។

### ២២.៣.២. ការហាមឃាត់ការនាំចេញ និង កូតានាំចេញ

ការផ្ដល់អាជ្ញាប័ណ្ណ គឺត្រូវបានគេប្រើដើម្បីគ្រប់គ្រងកូតា និង ការហាមឃាត់ប្រកបដោយលក្ខខណ្ឌ ទៅលើទំនិញនាំចេញជាក់លាក់ណាមួយ។ វិធានការទាំងនេះត្រូវបានគេអនុវត្ត ដោយសារហេតុផលសុខភាព សាធារណៈ និង សន្តិសុខ ក៏ដូចជាដើម្បីអនុវត្តនូវកិច្ចព្រមព្រៀងជាមួយនឹងដៃគូពាណិជ្ជកម្ម។ ហើយអ្វីដែលគួរ ឱ្យយកចិត្តទុកដាក់បំផុត គឺ វាយនភ័ណ្ឌនិងសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក និង សហគមន៍អឺរ៉ុប។

ក្នុងពេលថ្មីៗនេះ កម្ពុជាបានហាមឃាត់ទាំងស្រុងលើការនាំចេញឈើហ៊ុប។ មានទំនិញខ្លះត្រូវមាន អាជ្ញាប័ណ្ណនាំចេញដូចជា (១) ផលិតផលឈើកែច្នៃ (រួមមានគ្រឿងសង្ហារឹម ផលិតផលសិប្បកម្មធ្វើពីឈើជា ដើម (២) អាវុធ (៣) យានយន្តនិងគ្រឿងម៉ាស៊ីនគ្រប់ប្រភេទដែលបម្រើឱ្យវិស័យទ័ព (៤) សម្ភារៈឱសថ សាស្ត្រ និង វេជ្ជសាស្ត្រ។ ការអនុញ្ញាតពីក្រសួង គឺជាការចាំបាច់ណាស់សម្រាប់ការនាំចេញទំនិញប្រភេទ នេះ។

### ៤២.៣.៣. កូតានាំចេញសម្លៀកបំពាក់

កូតាត្រូវបានអនុវត្តលើការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិកចាប់តាំងពីឆ្នាំ១៩៩៩។ ការកំណត់កូតាត្រូវបានប្រើទៅលើផលិតផលសម្លៀកបំពាក់ចំនួន១២ប្រភេទ។ កិច្ចព្រមព្រៀងកូតាមានប្រសិទ្ធភាពជាបឋម សម្រាប់រយៈពេល៣ឆ្នាំ ដែលបានបញ្ចប់កាលពីខែធ្នូឆ្នាំ២០០១។ នៅក្រោមកិច្ចព្រមព្រៀងនោះ ការកំណត់កូតានឹងត្រូវបានកាត់បន្ថយ៦ភាគរយក្នុងមួយឆ្នាំ។

ហើយកម្ពុជាអាចទទួលបាននូវកូតានាំសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិច ចំនួន ១៤ ភាគរយបន្ថែមទៀត ប្រសិនបើកម្ពុជាអនុវត្តឱ្យបានល្អ ទៅតាមលក្ខខណ្ឌការងារជាក់លាក់ រួមទាំងអនុលោមទៅតាមច្បាប់ការងាររបស់កម្ពុជា និង អនុសញ្ញាសំខាន់ៗទាំង៩របស់អង្គការពលកម្មអន្តរជាតិ។ ដោយយោងទៅលើការវាយតម្លៃលក្ខខណ្ឌការងាររបស់កម្ពុជា រដ្ឋាភិបាលសហរដ្ឋអាមេរិកបានបង្កើនកូតាឱ្យកម្ពុជា៩ភាគរយ ដែលមានប្រសិទ្ធភាពពីឆ្នាំ២០០២។

រាជរដ្ឋាភិបាលបានអនុវត្តប្រព័ន្ធកូតាដែលអាចប្រែប្រួលបាន ដោយកូតា៨០ភាគរយនឹងផ្តល់ឱ្យក្រុមហ៊ុនទាំងឡាយណា ដែលដំណើរការនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៨ ហើយក៏អាស្រ័យផងដែរទៅលើប្រវត្តិនាំចេញ និង សមត្ថភាពផលិតរបស់ក្រុមហ៊ុន។ កូតា១០ភាគរយទៀតអាចត្រូវបានផ្តល់ជារង្វាន់សម្រាប់ឱ្យដល់អ្នកនាំចេញ ដោយឈរលើស្នាដៃនាំចេញនាពេលបច្ចុប្បន្ន និង ការគោរពច្បាប់ការងាររបស់កម្ពុជា។ ចំណែកឯ១០ភាគរយផ្សេងទៀត ត្រូវបានដាក់ឱ្យដេញថ្លៃទៅឱ្យអ្នកផលិតសម្លៀកបំពាក់ទាំងអស់តាមរយៈការដេញថ្លៃប្រកួតប្រជែង។ រាជរដ្ឋាភិបាលកំណត់យកថ្លៃសេវាជាក់លាក់មួយ (តម្លៃទិដ្ឋាការ) ក្នុងមួយឡូសម្លៀកបំពាក់ ដែលបានលក់នៅក្រោមកូតាទៅកាន់សហរដ្ឋអាមេរិក និង អឺរ៉ុប។

ការរៀបចំកូតាសម្លៀកបំពាក់ បានបង្កើតឱ្យមាននូវឱកាសប្រកួតប្រជែងរយៈពេលវែងដ៏សំខាន់មួយ។ ជាបឋម ការរៀបចំស្ថាប័នពលកម្មដូចជាប្រាក់បៀវត្សអប្បបរមា និង ការកំណត់វេនការងារ ក៏ដូចជាចំណាយសម្រាប់អនុវត្តឱ្យស្របតាមស្តង់ដារទាំងនេះ គឺវានឹងកាន់តែបង្កើនការចំណាយនៅក្នុងផ្នែកសម្លៀកបំពាក់។ ការរឹតបន្តឹងស្ថាប័នទាំងនេះវានឹងបន្ទុចបង្អាក់ដល់ការអភិវឌ្ឍវិស័យនាំចេញដ៏មានសក្តានុពលដទៃទៀត ដោយសារតែការរឹតបន្តឹងទាំងអស់នោះ ការបង្កើតឱ្យមានការចំណាយខ្ពស់នៅក្នុងវិស័យដែលត្រូវការពលកច្រើន ដែលប្រទេសកម្ពុជាមានលក្ខណៈប្រកួតប្រជែងប្រសើរ។

ការសម្រួលការនាំចេញ និង ដំណើរការនីតិវិធី ឯកសារភាគច្រើន គឺវិលចុះវិលឡើងជាមួយនឹងការធានាឱ្យបានថាការនាំចេញសម្លៀកបំពាក់កម្ពុជាបំពេញបាននូវគោលការណ៍ច្បាប់ដើម (Rules of Origin)។ ជាឧទាហរណ៍ អ្នកនាំចេញសម្លៀកបំពាក់ ត្រូវបំពេញឯកសារចំនួន១១ ពីក្រសួង ៣ និងនាយកដ្ឋាន ៥ ពាក់ព័ន្ធ មុនពេលដែលទំនិញរបស់គេត្រូវបានគេអនុញ្ញាតឱ្យចេញពីកំពង់ផែ។

ដំណើរការខាងលើ និង ការបំពេញបែបបទឯកសារទាំងអស់នេះ គឺចំណាយច្រើន និងត្រូវការពេលវេលា ដោយសារតែការងារនេះទាមទារការត្រួតពិនិត្យជារូបវន្តទៅលើទំនិញទាំងអស់ដោយភ្នាក់ងារបី។ ហើយដំណើរការការងារទាំងអស់នេះ វាងាយស្រួលនឹងបើកឱកាសឱ្យមន្ត្រីតូចតាចឆ្លៀតឱកាសឆបោក។

កូតានាំចេញសម្លៀកបំពាក់ត្រូវបានលុបចោលនៅក្នុងខែមករាឆ្នាំ២០០៥ នៅពេលដែលកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកស្តីអំពីវាយនភ័ណ្ឌនិងសម្លៀកបំពាក់ (ATC) បានបញ្ចប់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២២.៤. កម្ពុជានិងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន

កម្ពុជាបានក្លាយជាសមាជិកទី១០របស់អាស៊ាននៅខែមេសាឆ្នាំ១៩៩៩។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបំពេញឱ្យបានទៅតាមការទាមទារជាសមាជិកភាពរបស់អាស៊ាន ចាប់តាំងពីការផ្លាស់ប្ដូរច្បាប់ រហូតដល់ការកែសម្រួលប្រព័ន្ធហិរញ្ញវត្ថុ វិនិយោគ និង ពាណិជ្ជកម្ម ដើម្បីឱ្យស៊ីគ្នាជាមួយនឹងស្តង់ដារអាស៊ាន។ នៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន កម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីធ្វើការកាត់បន្ថយបន្ទាត់ពន្ធគយរបស់ខ្លួន ឱ្យដល់៥ភាគរយ និង ទាបជាងនេះនៅឆ្នាំ២០១០ ហើយបន្ទាត់ពន្ធគយដទៃទៀតដែលនៅសល់ (ដែលភាគច្រើន ជាផលិតផលកសិកម្មដែលមានលក្ខណៈរសើប) នៅឆ្នាំ ២០១៧ នៅក្នុងក្របខ័ណ្ឌ កិច្ចព្រមព្រៀងស្តីពីការអនុវត្តអត្រាពន្ធគយអនុគ្រោះរួម (CEPT)។

### ២២.៤.១. ការអនុវត្តការអនុគ្រោះពន្ធគយរួមនៅក្នុងប្រទេសកម្ពុជា (CEPT)

ដំណើរការរបស់ CEPT ទាមទារឱ្យកម្ពុជាធ្វើការបែងចែកបន្ទាត់ពន្ធគយរបស់ខ្លួន ឬ ចំណាត់ថ្នាក់ឱ្យចូលទៅក្នុងតារាង១ ក្នុងចំណោមតារាងទាំង៤ ៖

- **បញ្ជីដាក់បញ្ចូល** (IL)៖ ទំនិញទាំងឡាយណាដែលមានអត្រាអនុគ្រោះពន្ធគយរួមនឹងត្រូវបានកាត់បន្ថយតាមលក្ខណៈធម្មតាឬលឿន
- **បញ្ជីលើកលែងបណ្តោះអាសន្ន** (TEL)៖ ទំនិញទាំងឡាយណាដែលពិនិត្យទៅឃើញថាមានវេទយិទភាពខ្លាំងដោយសាតែការកាត់បន្ថយអត្រាជាបន្ទាន់
- **បញ្ជីទំនិញដែលមានវេទយិទភាព**(SL)៖ទំនិញដែលប្រកាសថាមានលក្ខណៈវេទយិទភាពត្រូវការពេលវេលាយូរដើម្បីបញ្ចូលទៅក្នុងតារាងបញ្ជីដាក់បញ្ចូលហើយនិង
- **បញ្ជីលើកលែងទូទៅ** (GEL)៖ បញ្ចូលតែមុខទំនិញក្នុងបរិមាណបន្តិចបន្តួចដោយសារតែពាណិជ្ជកម្មលើទំនិញប្រភេទនេះ ត្រូវបានគេរឹតបន្តឹង ដោយយោងលើហេតុផលវប្បធម៌ និងសុវត្ថិភាព។

រាជរដ្ឋាភិបាលកម្ពុជាបានពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រ និង ទម្រង់ពាណិជ្ជកម្មរបស់ខ្លួន ហើយបានអនុវត្តតារាងរួចពន្ធដូចខាងក្រោម ៖

- **ជាបឋម**- ៩៦ភាគរយនៃបន្ទាត់ពន្ធគយទាំងអស់គឺស្ថិតនៅក្នុងបញ្ជីដាក់បញ្ចូល។ ទំនិញមួយភាគធំស្ថិតនៅក្នុងបញ្ជីលើកលែងបណ្តោះអាសន្ន។ ចំណែកឯបន្ទាត់ពន្ធដែលនៅសល់២.៧ភាគរយផ្សេងទៀត ស្ថិតនៅក្នុងបញ្ជីវេទយិទភាព និងបញ្ជីលើកលែងទូទៅ។
- **ទីពីរ**-ការកាត់បន្ថយអត្រាពន្ធគយនឹងធ្វើឡើងយ៉ាងយឺត។ ទំនិញដែលស្ថិតនៅក្នុងបញ្ជីដាក់បញ្ចូលនឹងមិនឱ្យមានលក្ខណៈសេរីពេញលេញ ពី ០ទៅ៥ភាគរយ រហូតដល់ឆ្នាំ២០០៧។ លើសពីនេះទៅទៀត ទំនិញដែលស្ថិតនៅក្នុងបញ្ជីលើកលែងបណ្តោះអាសន្ននឹងត្រូវបញ្ចូលទៅក្នុងបញ្ជីដាក់បញ្ចូលនៅចន្លោះ រវាងឆ្នាំ២០០៣ និង២០០៧ ដោយមានការប្តេជ្ញាចិត្តថាអត្រាពន្ធគយទាំងអស់នេះនឹងស្ថិតនៅចន្លោះរវាងពី ០ ទៅ ៥ ភាគរយនៅឆ្នាំ ២០១០។

- វាជាការសំខាន់ណាស់ ដែលត្រូវធ្វើការកត់សម្គាល់ថា ទំនិញដែលស្ថិតនៅក្នុងបញ្ជីលើកលែងបណ្តោះអាសន្ននឹងមិនអាចទទួលបានអត្រាអនុគ្រោះពន្ធទាប ប្រសិនបើនាំចេញទៅកាន់រដ្ឋជាសមាជិកអាស៊ានដទៃទៀត។ លើសពីនេះទៅទៀតកម្ពុជាអាចមានជម្រើសដើម្បីពន្លឿនការកាត់បន្ថយពន្ធរបស់ខ្លួននៅពេលណាមួយក៏បាន។

មានហេតុផលដ៏ល្អសម្រាប់កម្ពុជាដើម្បីផ្ទេរទំនិញស្ទើរតែទាំងអស់ ពីបញ្ជីលើកលែងបណ្តោះអាសន្នទៅបញ្ជីដាក់បញ្ចូលយ៉ាងលឿន និង ពន្លឿនការកាត់បន្ថយពន្ធមកត្រឹម០.៥ភាគរយមុនឆ្នាំ២០០៧។

**ទីមួយ**- ការពន្លឿនការកាត់បន្ថយពន្ធគយនឹងធ្វើឱ្យកម្ពុជាក្លាយជាមូលដ្ឋានដ៏ជោគជ័យ សម្រាប់នាំចេញទៅកាន់សមាជិកអាស៊ានដទៃផ្សេងទៀត។ ទោះបីជាយ៉ាងណាក៏ដោយកម្ពុជានៅតែជាកន្លែងមានសក្តានុពលសម្រាប់ការវិនិយោគសម្រាប់អាស៊ាន គឺសម្រាប់តែទំនិញទាំងឡាយណាដែលអាចនាំចេញទៅកាន់ប្រទេសជាសមាជិកដែលមានអត្រាអនុគ្រោះពន្ធគយរួមទាប។ ដើម្បីឱ្យការងារនេះអាចដំណើរការទៅបានទំនិញនោះត្រូវតែស្ថិតនៅក្នុងបញ្ជីដាក់បញ្ចូល ហើយអត្រាអនុគ្រោះពន្ធគយរួមអន្តរការត្រូវតែស្ថិតនៅត្រឹម២០ភាគរយឬទាបជាងនេះ។ មធ្យោបាយដ៏មានប្រសិទ្ធភាព ដើម្បីធ្វើឱ្យកម្ពុជាក្លាយជាកន្លែងវិនិយោគដ៏មានសក្តានុពល គឺជាការធានាថាបន្ទាត់ពន្ធភាគច្រើនត្រូវតែដាក់ជាបន្ទាន់ឱ្យស្ថិតទៅក្នុងបញ្ជីដាក់បញ្ចូល ហើយអត្រាខ្ពស់បំផុតត្រូវកាត់បន្ថយមិនឱ្យនៅលើស២០ភាគរយហើយបើទាបជាងនេះកាន់តែប្រសើរ។

**ហេតុផលទីពីរ** សម្រាប់ការងារជាបន្ទាន់ លើការសម្រួលពន្ធនិងកាត់បន្ថយពន្ធគយគឺការប្រកួតប្រជែងដ៏ខ្លាំងពីសមាជិកអាស៊ានថ្មីដទៃទៀត។ វិនិយោគិនមានដែលបំណងបោះទីតាំងនៅតំបន់អាស៊ានគឺមានបំណងជ្រើសរើសតំបន់មួយណាដែលជាប្រទេសសមាជិកថ្មីហើយប្រាក់ខែទាប។ ហេតុដូចនេះការពន្យារពេលការកាត់បន្ថយពន្ធគយ ធ្វើឱ្យកម្ពុជាមិនទទួលបានផលប្រយោជន៍ពីដំណើរការនេះទេ។

## ២២.៤.២. យុទ្ធសាស្ត្រអនុគ្រោះពន្ធគយរួមសម្រាប់កម្ពុជា

សម្រាប់កម្ពុជា ដើម្បីឱ្យក្លាយទៅជាទិសដៅទាក់ទាញវិនិយោគមួយ គឺវាទាមទារឱ្យកម្ពុជាធ្វើសមាហរណកម្មឱ្យបានលឿន និង ស៊ីជម្រៅចូលទៅក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងការអនុគ្រោះពន្ធគយរួម។ ការធ្វើដូច្នេះដើម្បីធានាឱ្យបាននូវលទ្ធភាពល្អប្រសើរសម្រាប់ទាក់ទាញការវិនិយោគដែលផ្តោតលើទីផ្សារអាស៊ានឱ្យមានប្រៀបជាងប្រទេសជិតខាងរបស់ខ្លួន។ ការងារនេះទាមទារឱ្យមានការពន្លឿនការកាត់បន្ថយពន្ធគយ។

ហេតុផលទីបី ដើម្បីពន្លឿនការអនុវត្តអត្រាពន្ធគយអនុគ្រោះរួម គឺទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើយ៉ាងណាដាក់ចេញនូវគោលនយោបាយពាណិជ្ជកម្មរបស់ខ្លួនប្រកបដោយភាពជឿជាក់។ រាជរដ្ឋាភិបាលសង្ឃឹមថាទំនិញភាគច្រើននឹងស្ថិតនៅក្នុងអត្រាពន្ធគយអនុគ្រោះរួមចន្លោះពី០-៥ភាគរយនៅត្រឹមឆ្នាំ២០១០។ ទោះបីជាយ៉ាងណាក៏ដោយ រយៈពេលចន្លោះ៨ឆ្នាំ គឺជារយៈពេលយូរមួយហើយការកំណត់មិនច្បាស់លាស់នៅក្នុងដំណើរការកែសម្រួលពន្ធនោះនឹងធ្វើឱ្យបាត់បង់ជំនឿរបស់អ្នកវិនិយោគ។ ស្ថេរភាព និង តម្លាភាពគឺជាលក្ខណសម្បត្តិសំខាន់ពីរនៃយុទ្ធសាស្ត្រប្រសិទ្ធភាពឧស្សាហូបនីយកម្ម។ ទោះបីជាយ៉ាងណាក៏ដោយការអនុវត្តប្រព័ន្ធអនុគ្រោះពន្ធគយ រួមប្រឈមនឹងបញ្ជីលើកលែងបណ្តោះអាសន្នធំមួយ ហើយទម្រង់របៀបនេះអាចបង្កើតឱ្យមានអស្ថេរភាពនិងភាពមិនច្បាស់លាស់យ៉ាងធំធេង នៅក្នុងក្របខ័ណ្ឌគោលនយោបាយជាពិសេសនៅក្នុងអំឡុងពេលពី ៤ទៅ ៨ ឆ្នាំទៀត នៅពេលដែលទំនិញទាំងអស់នេះត្រូវបានដាក់បញ្ចូលទៅក្នុងតារាងបញ្ចូល។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការអនុវត្តអត្រាពន្ធគយ អនុគ្រោះរួមនឹងមានអត្ថប្រយោជន៍ប្រសិនបើភាពផ្សេងគ្នារវាងអត្រាអនុគ្រោះពន្ធគយរួម និង អត្រាអនុគ្រោះខ្ពស់បំផុត (MFN) របស់កម្ពុជាសម្រាប់ប្រទេសផ្សេងទៀតនៅលើពិភពលោកនៅទាប។ ហេតុផលគឺថាប្រសិនបើអត្រាពីរនេះខុសគ្នាខ្លាំង វានឹងមានឱកាសច្រើន ដែលតំបន់ពាណិជ្ជកម្មអនុគ្រោះនេះនឹងទាក់ទាញពាណិជ្ជកម្មរបស់កម្ពុជា ពីប្រទេសដទៃទៀតនៅក្នុងពិភពលោកមកកាន់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ជាជាងបង្កើតដៃគូពាណិជ្ជកម្មថ្មីសម្រាប់កម្ពុជា។ ការវិភាគថ្មីៗនេះបានបង្ហាញឱ្យឃើញថា ប្រសិនបើដូចអ្វីខាងលើនេះកើតមានមែន អត្ថប្រយោជន៍របស់កម្ពុជានៅក្នុងការចូលរួមទៅក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ានមានតិច។ តាមការពិត ការបង្កើនទំហំពាណិជ្ជកម្មរបស់កម្ពុជា គឺធ្វើជាមួយនឹងដៃគូនៅខាងក្រៅអាស៊ាន។ លើសពីនេះទៅទៀត ការនៅមានភាពខុសគ្នាខ្លាំងរវាងអត្រាអនុគ្រោះ ពន្ធគយរួម និងការអនុគ្រោះខ្ពស់បំផុត ជំរុញឱ្យក្រុមហ៊ុនកម្ពុជាទទួលយកវត្ថុធាតុដើម ដែលមានតម្លៃខ្ពស់ពីអ្នកផលិតអាស៊ាន។ ហេតុដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាអាចពិចារណារកវិធីសាស្ត្រ ដើម្បីកាត់បន្ថយអត្រាអនុគ្រោះបំផុត ឱ្យស្របគ្នាទៅនឹងអត្រាអនុគ្រោះពន្ធគយរួម ដើម្បីរក្សាភាពផ្សេងគ្នានូវអត្រាទាបទាំងពីរនេះ។ នេះគឺអាចទទួលយកបាន នៅក្រោមលក្ខខណ្ឌរបស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន។

កម្ពុជាបានប្តេជ្ញាចិត្តផងដែរក្នុងការជំរុញយន្តការផ្សេងៗទៀត នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដូចជាតំបន់វិនិយោគអាស៊ាន (ASEAN Investment Area) សេរីភាវូបនីយកម្មពាណិជ្ជកម្មខាងផ្នែកសេវាកម្ម និង ប្រព័ន្ធកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឧស្សាហកម្មអាស៊ាន (AICO) ។ ក្នុងនាមជាអ្នកចូលរួមនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន កម្ពុជាអាចបង្កើនភាពប្រកួតប្រជែងរបស់ខ្លួន ទប់ទល់ជាមួយនឹងបណ្តាក្រុមប្រទេសនៅតំបន់ផ្សេងទៀត អាចបង្កើនការវិនិយោគនិងពាណិជ្ជកម្មជាមួយនឹងបណ្តាប្រទេសជាសមាជិកអាស៊ាន និង ប្រទេសទីបី ហើយជាចុងបញ្ចប់អាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់។ លើសពីនេះទៅទៀត កម្ពុជាទទួលផលប្រយោជន៍ពីពាណិជ្ជកម្មទ្វេភាគីដូចជាប្រព័ន្ធទូទៅស្តីពីការបន្ធូរពន្ធ (GSP) ដែលផ្តល់ឱ្យដោយសហរដ្ឋអាមេរិក និង គោលការណ៍អនុគ្រោះច្បាប់ដើម (Preferential Rules of Origin) សម្រាប់ប្រទេសជាសមាជិកអាស៊ាន ដែលផ្តល់ឱ្យដោយសហភាពអឺរ៉ុបនៅក្នុងឆ្នាំ១៩៩៩។

## ២២.៥. សេរីភាវូបនីយកម្មលើសេវាកម្មហិរញ្ញវត្ថុក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម (AFAS)

### ២២.៥.១. សេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម

សេរីភាវូបនីយកម្មពាណិជ្ជកម្មជាប់ទាក់ទងនឹងការផ្តល់លទ្ធភាពកាន់តែច្រើនថែមទៀត ឱ្យក្រុមហ៊ុនបរទេសចូលមកក្នុងទីផ្សារ ដោយការបន្ធូរបន្ថយរបាំងពាណិជ្ជកម្ម។ ទោះបីយ៉ាងណាក៏ដោយ វាមានលក្ខណៈសាំញ៉ាំបន្តិចសម្រាប់សេវាកម្ម ដោយសារតែពាណិជ្ជកម្ម និង ប្រភេទរបាំងមានភាពខុសគ្នាខ្លាំងពេក។ មានមធ្យោបាយចំនួនបួនយ៉ាងក្នុងការផ្គត់ផ្គង់ពាណិជ្ជកម្មសេវាកម្ម ដែលឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងហោចណាស់នូវទំនាក់ទំនងខ្លះរវាងអតិថិជននិងអ្នកផលិតសេវាកម្ម ៖

- **ពាណិជ្ជកម្មឆ្លងដែន** - ទំនាក់ទំនងឆ្លងកាត់ព្រំដែនជារូបវន្ត ឬ តាមអេឡិចត្រូនិកដូចជាការដឹកជញ្ជូនតាមអាកាស ឬ ផ្លូវទឹកហើយនិងពាណិជ្ជកម្មហិរញ្ញវត្ថុ (មធ្យោបាយទី១)

- **ការប្រើប្រាស់នៅឯបរទេស** - បំលាស់ទីរបស់អ្នកប្រើប្រាស់ទៅកាន់បរទេស ដោយសារហេតុផលផ្សេងៗ ដូចជាទេសចរណ៍ ឬ ការសិក្សា (មធ្យោបាយទី២)
- **វត្តមានពាណិជ្ជកម្ម** - ការវិនិយោគដោយផ្ទាល់ ក្នុងគោលបំណងចែកចាយសេវាកម្ម ដូចជាទូរគមនាគមន៍ ឬ អគ្គិសនីក្នុងស្រុក (មធ្យោបាយទី៣)
- **វត្តមានបុគ្គលដោយផ្ទាល់** - បំលាស់ទីជាបណ្តោះអាសន្នរបស់អ្នកផលិត ដើម្បីផ្តល់សេវាកម្ម ដូចជា ការប្រឹក្សាយោបល់ ឬ ការសាងសង់ (មធ្យោបាយទី៤)

វត្តមានពាណិជ្ជកម្មគឺជាមធ្យោបាយគ្របដណ្តប់លើការផ្គត់ផ្គង់ទាំងអស់ លើកលែងតែការដឹកជញ្ជូន និង សេវាកម្មទេសចរណ៍ ហើយពាណិជ្ជកម្មឆ្លងដែនមានសារៈសំខាន់បំផុតឈរនៅបន្ទាប់។ ពាណិជ្ជកម្មតាមរយៈការមានវត្តមានដោយផ្ទាល់របស់វិនិយោគិន គឺនៅមានចំនួនតិចតួចណាស់សម្រាប់គ្រប់វិស័យហើយការប្រើប្រាស់នៅឯបរទេស គឺមានលក្ខណៈគួរឱ្យកត់សម្គាល់សម្រាប់តែទេសចរណ៍ប៉ុណ្ណោះ។

របាំងពាណិជ្ជកម្ម គឺជាទម្រង់និយ័តកម្មដែលរួមមានមធ្យោបាយដូចជាការរឹតបន្តឹង ការចូលមកកាន់ទីផ្សាររបស់ក្រុមហ៊ុនបរទេស (ជាឧទាហរណ៍ការបម្រុងទុកការផ្គត់ផ្គង់សម្រាប់ផ្តាច់មុខជាសាធារណៈ ឬ តាមរយៈការមិនទទួលស្គាល់គុណភាពវិជ្ជាជីវៈ) ឬ តាមរយៈការរើសអើងប្រឆាំងនឹងក្រុមហ៊ុនបរទេសនៅពេលណា ដែលក្រុមហ៊ុនមាននៅលើទីផ្សារ ដូចជាតាមរយៈការកំណត់បែបបទពន្ធផ្សេងគ្នា ឬ ការរឹតបន្តឹងកម្ចីសម្រាប់ក្រុមហ៊ុនបរទេស។

ដូច្នេះសេរីភាវូបនីយកម្មពាណិជ្ជកម្ម ក្នុងសេវាកម្មពាក់ព័ន្ធនឹងការកាត់បន្ថយរបាំងនិយ័តកម្មក្នុងការអនុញ្ញាតឱ្យចូលទីផ្សារ និង បែបបទជាតិដែលមានការរើសអើងសម្រាប់មធ្យោបាយផ្គត់ផ្គង់ទាំងបួនប្រភេទ។

សេរីភាវូបនីយកម្មពាណិជ្ជកម្មត្រូវធានាឱ្យបានថានិយ័តកម្ម ដែលមានស្រាប់មិនមានការរើសអើងប្រឆាំងនឹងការចូលរួមពីបរទេសនៅក្នុងទីផ្សារ។ សេរីភាវូបនីយកម្មពាណិជ្ជកម្មគឺស្របគ្នាជាមួយនឹងនិរន្តរភាពរបស់ប្រទេសដើម្បីធ្វើនិយ័តកម្មឧស្សាហកម្ម សម្រាប់គោលបំណងនៃការការពារអ្នកប្រើប្រាស់ការគ្រប់គ្រងសេដ្ឋកិច្ចដោយប្រុងប្រយ័ត្នការពិនិត្យលើភាពផ្តាច់មុខនៃធនធានឬការសម្រេចគោលដៅសង្គម។

ផ្នែកនយោបាយដ៏សំខាន់មួយទៀតដែលស្ថិតនៅក្នុងចំណុចស្នូលនៃសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម គឺប្រព្រឹត្តកម្មចំពោះការវិនិយោគដោយផ្ទាល់ពីបរទេស។ វត្តមានពាណិជ្ជកម្មគឺជាមធ្យោបាយគន្លឹះនៃការផ្គត់ផ្គង់សេវាកម្ម ហើយប្រទេសកំពុងអភិវឌ្ឍន៍មានប្រវត្តិសាស្ត្រដាក់ការគៀបសង្កត់ខ្លាំងលើវិនិយោគដោយផ្ទាល់ពីបរទេស ដើម្បីលើកទឹកចិត្តម្ចាស់មូលធនក្នុងស្រុក រឹតបន្តឹងការបញ្ជូនប្រាក់ចំណេញទៅប្រទេសដើម និង បង្កើនទំនាក់ទំនងក្រុមហ៊ុនពហុជាតិជាមួយនឹងអ្នកផ្គត់ផ្គង់ខ្សែបណ្តោយ។ សេរីភាវូបនីយកម្មពេញលេញនៃវត្តមានពាណិជ្ជកម្មផ្គត់ផ្គង់នឹងធ្វើឱ្យវិធានការភាគច្រើននេះ នៅក្នុងវិស័យសេវាកម្មខុសច្បាប់។ ការបង្កើតបរិយាកាសសមស្របសម្រាប់ការវិនិយោគពីបរទេស គឺមានលើសពីភាពជាក់លាក់នៃនិយតកម្មទៅទៀតដោយរួមបញ្ចូលផងដែរ នូវការពង្រឹងប្រព័ន្ធច្បាប់ស្ថេរភាពបរិយាកាសម៉ាក្រូសេដ្ឋកិច្ច ហើយនិងការអនុញ្ញាតឱ្យមានការផ្ទេរប្រាក់ចំណេញទៅប្រទេសដើមរបស់គេ។

### ១២.៤.២. លំដាប់ព្រឹត្តិការណ៍និងការកំណត់ពេលវេលាសេរីភាវូបនីយកម្ម

នៅពេលណាដែលមូលដ្ឋានគ្រឹះសម្រាប់សេរីភាវូបនីយកម្មត្រូវបានកំណត់ជំហានបន្ទាប់ គឺត្រូវបង្កើតយុទ្ធសាស្ត្រសេរីភាវូបនីយកម្មពាណិជ្ជកម្ម ក្នុងគោលបំណងបង្កើនប្រាក់ចំណេញនិងបន្ថយចំណាយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យុទ្ធសាស្ត្រចំបាច់ ត្រូវរៀបចំឡើងឱ្យបានលម្អិតនៅលំដាប់សកម្មភាពនិងការកំណត់ពេលវេលាសម្រាប់គ្រប់ផ្នែកផ្សេងទៀតទាំងអស់ដូចជាមធ្យោបាយផ្គត់ផ្គង់និងរបាំងការពារចំនួនពីរក្រុម (លទ្ធភាពចូលទីផ្សារនិងប្រព្រឹត្តកម្មរបស់ជាតិ)។ វាចាំបាច់ផងដែរដែលត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើអ្វីដែលជាកិច្ចសម្បទានដែលដៃគូពាណិជ្ជកម្មចង់បានសម្រាប់គ្រប់ផ្នែកទាំងអស់។ ការប្រុងប្រយ័ត្នក្នុងកម្រិតណាមួយត្រូវតែមាននៅពេលដែលរៀបចំដំណើរការសេរីភាវូបនីយកម្ម ដោយសារតែថាមានកត្តាគន្លឹះខ្លះៗមានផលប៉ះពាល់ខ្លាំងទៅលើដំណើរការសេដ្ឋកិច្ចដែលកំពុងតែមាន។

លំដាប់សកម្មភាព និង ការកំណត់ពេលវេលាសេរីភាវូបនីយក្នុងវិស័យសេវាកម្មផ្សេងៗទៀត វានឹងអាស្រ័យលើផ្នែកខ្លះនៃភាពជឿនលឿន នៅក្នុងការកំណត់មូលដ្ឋានគ្រឹះរបស់ស្ថាប័នសម្រាប់កំណែទម្រង់។ ភាពសាំញ៉ាំនៅក្នុងដំណាក់កាលនេះ អាចជះឥទ្ធិពលទៅលើលទ្ធភាពកំណែទម្រង់នៅខាងមុខ។ យកល្អកំណែទម្រង់គួរកំណត់ទិសដៅជាបឋមទៅលើវិស័យណាដែលរំពឹងថា នឹងនាំផលចំណេញបំផុតសម្រាប់ប្រទេស។

ទាំងអស់នេះរួមមាន សេវាកម្មទាំងឡាយណាដែលផ្តល់ការចូលរួមចំណែកអន្តរការីសំខាន់ទៅដល់ផ្នែកផ្សេងទៀតនៃសេដ្ឋកិច្ចឬវិស័យជាក់លាក់ណាមួយ ដែលប្រទេសចង់ជំរុញឬក៏វិស័យណាមួយដែលការការពារនាំឱ្យមានការខាតបង់ធ្ងន់ធ្ងរដល់សង្គម។ វិស័យដែលមានផលប៉ះពាល់ដល់សេដ្ឋកិច្ចដូចជាវិស័យទូរគមនាគមន៍ ការដឹកជញ្ជូនហិរញ្ញវត្ថុ និង អគ្គិសនីនឹងនាំឱ្យមានផលចំណេញច្រើនដល់កិច្ចខិតខំប្រឹងប្រែងសេរីភាវូបនីយកម្ម។ វាក៏ជាការចូលរួមចំណែកនៅក្នុងវិស័យសេវាកម្មដទៃទៀតដែលជោគជ័យនៃសេរីភាវូប-នីយកម្មលើវិស័យទាំងអស់នេះ អាចអាស្រ័យជាចម្បងទៅលើការធ្វើសេរីភាវូបនីយកម្មជាមុននៃសេវាអន្តរការី។

ជម្រើសបន្ទាប់ គឺជាមធ្យោបាយផ្គត់ផ្គង់មួយណាគួរបើកចំហ ហើយរបាំងមួយណាគួរដកចេញ។ ដំណើរការនេះអាចធ្វើទៅបានយ៉ាងស្រួល ដោយគ្រាន់តែលុបចោលមធ្យោបាយខាងបច្ចេកទេសណាមួយដែលអាចធ្វើទៅបាន។ ប្រសិនបើសេរីភាវូបនីយកម្មមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើវិស័យនេះ មធ្យោបាយគ្របដណ្តប់នៃការផ្គត់ផ្គង់គួរតែបើកចំហឡើង។ នៅក្នុងករណីជាច្រើន វាគឺជាមធ្យោបាយវត្តមានពាណិជ្ជកម្មដែលនៅក្នុងករណីខ្លះ វាជាទិសដៅសម្រាប់សេរីភាវូបនីយកម្ម ដោយសារតែការចំណេញច្រើននិងការចំណាយសម្របសម្រួលទាប។

ទោះបីជាយ៉ាងណាក៏ដោយ ការបើកចំហវិស័យមួយឱ្យដល់វត្តមានពាណិជ្ជកម្ម វាមិនមែនជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត សម្រាប់គ្រប់ករណីទាំងអស់នោះទេ។ ប្រសិនបើទីផ្សារក្នុងស្រុកមានទំហំកំណត់ ហើយប្រសិនបើសេដ្ឋកិច្ចមាត្រដ្ឋាន (scale economics) នៅមានកម្រិត នោះការបើកចំហវត្តមានពាណិជ្ជកម្មអាចនឹងគាបសង្កត់យ៉ាងខ្លាំងលើការប្រកួតប្រជែង និងភាពចម្រុះនៃផលិតផល ដែលនាំឱ្យផលចំណេញពីពាណិជ្ជកម្មមានកម្រិត។ នៅក្នុងករណីនេះ ការបើកឱ្យមានការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន គឺមានភាពចាំបាច់ ដើម្បីទទួលបានផលចំណេញប្រកបដោយសក្តានុពល។

ការមិនមានធនធានមនុស្សគ្រប់គ្រាន់នៅក្នុងប្រទេស ក៏អាចរឹតត្បិតផលចំណេញពីការបើកចំហវត្តមានពាណិជ្ជកម្មផងដែរ។ ជាឧទាហរណ៍ សេរីភាវូបនីយកម្មលើវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាបង្កើតឱ្យមានតម្រូវការបន្ថែមនូវបុគ្គលិកដែលមានជំនាញ។ ក្នុងករណីនេះ សេរីភាវូបនីយកម្មនៃលំហូរផ្គត់ផ្គង់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មនុស្សធ្វើឱ្យមានការហូរចូលអ្នកមានជំនាញពីបរទេស ហើយអាចរារាំងដល់អតិផរណាខ្លាំងនៃប្រាក់បៀវត្ស។ ជំហានទៅកាន់សេរីភាវូបនីយកម្មពាណិជ្ជកម្មពេញលេញ អាចត្រូវធ្វើឡើងជាដំណាក់កាល ដោយផ្ដោតទៅលើកត្តាសំខាន់ពីរយ៉ាង គឺការប្រកួតប្រជែង និង ភាពជាកម្មសិទ្ធិរបស់បរទេស។

### ២២.៤.៣. សេរីភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងអាស៊ានស្ដីពីសេវាកម្ម (AFAS)

បន្ទាប់ពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្ដីពីសេវាកម្ម នៅក្នុងឆ្នាំ ១៩៩៥ រហូតមកដល់ពេលនេះកិច្ចព្រមព្រៀងលើកញ្ចប់សេវាកម្មចំនួន ៧ ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន។ កិច្ចព្រមព្រៀងកញ្ចប់សេវាកម្មហិរញ្ញវត្ថុចំនួន ៣ ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន និង កិច្ចព្រមព្រៀងកញ្ចប់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសចំនួន ២ ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន។ គេរំពឹងថា នៅដំណាច់ឆ្នាំ២០០៩ និង ២០១០ នឹងមានការចុះហត្ថលេខាបន្ថែមទៀតលើកញ្ចប់កិច្ចព្រមព្រៀងក្រមខ័ណ្ឌអាស៊ានស្ដីពីសេវាកម្ម ដោយរដ្ឋមន្ត្រីដឹកជញ្ជូន និង សេដ្ឋកិច្ចអាស៊ានជាបន្តបន្ទាប់។ លើសពីនេះទៅទៀត វាមានកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក (Mutual Recognition Arrangements)ចំនួន៧ ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ហើយនិងកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកចំនួន១ ដែលត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន (M-ATM) ។ ម្យ៉ាងវិញទៀត ផែនការសហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community Blueprint) ក៏អំពាវនាវឱ្យមានការអនុវត្តឱ្យទាន់ពេលវេលា នូវវិធានការសមាហរណកម្មសេដ្ឋកិច្ចដ៏ទៃទៀត (រួមទាំងវិស័យសេវាកម្ម) នៅឆ្នាំ ២០១៥ ដែលនៅសល់ពេលតែ ៦ ឆ្នាំទៀតប៉ុណ្ណោះ។ ការអនុវត្តវិធានការផែនការ (Blueprint) ជាបញ្ហាប្រឈម សម្រាប់ប្រទេសជាសមាជិកអាស៊ានភាគច្រើន។

សេរីភាវូបនីយកម្មសេវាកម្មនឹងជួយបំពេញបន្ថែមការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានផងដែរ ដោយសារតែភាពប្រកួតប្រជែងរបស់ឧស្សាហករផលិតកម្មម្ហូបអាហារ និង វត្ថុធាតុដើមអាស៊ាន មានភាពប្រសើរឡើងដោយសារប្រព័ន្ធហិរញ្ញវត្ថុ ទូរគមនាគមន៍ និង ដឹកជញ្ជូននៅក្នុងតំបន់ខ្លាំង។

ក្នុងចំណោមគុណប្រយោជន៍ដែលនឹងទទួលបានពីសេរីភាវូបនីយកម្មសេវាកម្ម គឺការទាក់ទាញអ្នកវិនិយោគបរទេសនៅក្នុងវិស័យសេវាកម្ម ជាពិសេសអ្នកវិនិយោគមកពីបណ្ដាប្រទេសអាស៊ានដទៃទៀត។ ដោយសារតែការវិនិយោគមានជាប់មកជាមួយនូវបច្ចេកវិជ្ជាថ្មីៗ ការវិនិយោគទាំងនេះនឹងនាំឱ្យមានការផ្ទេរបច្ចេកវិជ្ជានិងជំនាញ ហើយវានឹងមានតួនាទីជាចលករជំរុញការអភិវឌ្ឍវិស័យសេវាកម្មសំខាន់ៗដូចជា ហិរញ្ញវត្ថុ ទូរគមនាគមន៍ និង ដឹកជញ្ជូន។

សេរីភាវូបនីយកម្មសេវាកម្មនាពេលអនាគត ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្ដីពីសេវាកម្ម ស្ថិតនៅក្រោមគោលដៅនៃលំហូរសេវាកម្មដោយសេរីនៅឆ្នាំ២០១៥។ ប៉ុន្តែសេរីភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុគួរត្រូវអនុវត្តបានបន្តិចម្ដងៗ ដោយគិតទៅលើកម្រិតនានានៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសនីមួយៗ ក៏ដូចជាតម្រូវការទាមទារនិយតកម្ម ដែលមានលក្ខណៈប្រុងប្រយ័ត្ន ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និង ការអភិវឌ្ឍសមត្ថភាពដើម្បីនាំទៅរកការអនុវត្តសេរីភាវូបនីយកម្មពេញលេញមួយ។

ប្រទេសជាសមាជិកអាស៊ាន អាចមានសិទ្ធិធ្វើការផ្លាស់ប្តូរក្នុងការកំណត់ពេលវេលាសេរីភាវូបនីយកម្មលើអនុវិស័យសេវាកម្មហិរញ្ញវត្ថុរបស់ពួកគេបាន ក៏ដូចជានៅក្នុងការដកចេញការដាក់កំហិតទៅលើមធ្យោបាយផ្គត់ផ្គង់ទាំងបួននៅក្រោមអនុវិស័យនីមួយៗ ដូចបានណែនាំដោយលក្ខខណ្ឌរបស់កិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធគយនិងពាណិជ្ជកម្ម (GATS) ស្តីពីលទ្ធភាពចូលទីផ្សារប្រព្រឹត្តិកម្មជាតិនិងគោលការណ៍សិទ្ធក្នុងការទទួលលក្ខខណ្ឌអនុគ្រោះខ្ពស់បំផុត (MFN) ។ សមាជិកអាស៊ានបានកំណត់គោលដៅឱ្យមានកិច្ចចរចាសាជាថ្មីរៀងរាល់បីឆ្នាំម្តងដើម្បីរក្សាភាពជឿនលឿនរហូតដល់ឆ្នាំ២០២០។

អាស៊ានបានកំណត់អនុវិស័យរួមដើម្បីធ្វើសេរីភាវូបនីយកម្មបន្ថែមទៀតដូចខាងក្រោម ៖

*សេវាកម្មធានារ៉ាប់រងនិងសេវាកម្មទាក់ទង*

ក. ការធានារ៉ាប់រងដោយផ្ទាល់ (រួមមានសហធានារ៉ាប់រង) :

- ជីវិត
- មិនមែនជីវិត

ខ. ការធានារ៉ាប់រងបន្ត និង ផ្តល់ធានារ៉ាប់រងត្រឡប់វិញ (Reinsurance and retrocession)

គ. អន្តរកម្មធានារ៉ាប់រង ដូចជា ឈ្មួញកណ្តាល និងទីភ្នាក់ងារនិង

ឃ. សេវាកម្មដែលជំនួយឱ្យការធានារ៉ាប់រងដូចជា ក្រុមហ៊ុនពិគ្រោះយោបល់ការវាយតម្លៃហានិភ័យ និងសេវាកម្មដោះស្រាយការទាមទារសំណង

*សេវាកម្មធនាគារ និង ហិរញ្ញវត្ថុដទៃទៀត (រួមទាំងការធានារ៉ាប់រង)*

ក. ការទទួលប្រាក់បញ្ញើ និង មូលនិធិ ដែលទូទាត់ឱ្យវិញដទៃទៀតពីសាធារណជន

ខ. ផ្តល់កម្ចីគ្រប់ប្រភេទ រួមមានឥណទានសម្រាប់អតិថិជន ឥណទានអចលនទ្រព្យ និង ផ្តល់ឥណទានសម្រាប់ប្រតិបត្តិការពាណិជ្ជកម្ម

គ. ភតិសន្យាហិរញ្ញវត្ថុ

ឃ. គ្រប់ការទូទាត់ និង សេវាកម្មចរាចរសាច់ប្រាក់ រួមមានប័ណ្ណឥណទាន ប័ណ្ណបន្ទុក និងឥណពន្ធ (charge and debit card) មូលប្បទានប័ត្រទេសចរណ៍ (travelers′ cheque) និងរូបិយាណត្តិធនាគារ (bankers′ draft)

ង. ការធានា និង កាតព្វកិច្ច

ច. ពាណិជ្ជកម្មសម្រាប់គណនីផ្ទាល់ខ្លួន ឬ សម្រាប់គណនីអតិថិជនទោះបីជាពាណិជ្ជកម្មដោះដូរនៅក្នុងទីផ្សារលក់ផ្ទាល់ឬផ្សេងពីនេះ (whether on an exchange , in an over-the- counter market or otherwise) ដែលមានដូចខាងក្រោម ៖

- លិខិតូបករណ៍ទីផ្សាររូបិយវត្ថុ (រួមមានមូលប្បទានបត្រវិក្កយបត្រលិខិតបញ្ញើ)
- ការផ្លាស់ប្តូររូបិយប័ណ្ណបរទេស

- អត្រាការប្រាក់និងលិខិតូបករណ៍នៃអត្រាប្តូរប្រាក់រួមមានផលិតផលដូចជា ការដោះដូរនិងកិច្ចព្រមព្រៀងអត្រាដែលរៀបចំជាមុន
- មូលប័ត្រដែលអាចផ្ទេរបាន (transferable securities)

ឆ. ការចូលរួមនៅក្នុងការចេញមូលប័ត្រគ្រប់ប្រភេទ ដោយរួមទាំងការទទួលខុសត្រូវខាងហិរញ្ញវត្ថុលើការខាតបង់ឬខូចខាត (underwriting) និងការធ្វើជាភ្នាក់ងារ (ជាសាធារណៈឬឯកជន) និងលក្ខខណ្ឌសេវាកម្មទាក់ទងនឹងបញ្ហានេះ

ជ. ការគ្រប់គ្រងទ្រព្យសកម្មដូចជាសាច់ប្រាក់ ការគ្រប់គ្រងផលប័ត្រការគ្រប់គ្រងការវិនិយោគរួមគ្រប់ទម្រង់ការគ្រប់គ្រងមូលនិធិសោធន ការថែរក្សា សេវាកម្មបញ្ញើនិងឯកាធិកម្មនិងការប្រឹក្សាយោបល់អន្តរកម្ម និង សេវាកម្មហិរញ្ញវត្ថុជំនួយដទៃទៀតរួមមានសេចក្តីបញ្ជាក់ឥណទាន និងការវិភាគនិងការស្រាវជ្រាវផលប័ត្រ និង ការណែនាំអំពីការទិញបន្ថែមនិងអំពីការកែសម្រួលរួមឡើងវិញនិងយុទ្ធសាស្ត្រ។

## ២២.៦. សមាជិកភាពរបស់កម្ពុជានៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក

កម្ពុជាបានស្នើសុំចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក នៅក្នុងខែ ធ្នូ ឆ្នាំ១៩៩៤ ក្រោមមាត្រាទី៧នៃកិច្ចព្រមព្រៀង Marrkech ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក។ នៅក្នុងខែមិថុនា ឆ្នាំ ១៩៩៩ កម្ពុជាបានដាក់អនុស្សរណៈស្តីអំពីរបបពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួន ឱ្យទៅក្រុមការងារអង្គការពាណិជ្ជកម្មពិភពលោក។ នៅខែឧសភាឆ្នាំ ២០០១ កិច្ចប្រជុំលើកដំបូងរបស់ក្រុមការងារបានចាប់ផ្តើមឡើង ដែលបើកផ្លូវឱ្យមាននូវកិច្ចចរចារសុំចូលពិស្តារ ដែលកិច្ចចរចារនេះបានបញ្ចប់ ដោយប្រើរយៈពេលជាង ២ ឆ្នាំ រហូតដល់ចុង ខែកក្កដា ឆ្នាំ២០០៣។

នៅថ្ងៃទី២២ ខែកក្កដាឆ្នាំ២០០៣ កម្ពុជាបានដាក់ជូននូវលិខិតទទួលស្គាល់លក្ខខណ្ឌរបស់សមាជិកភាព ដែលបានចែងនៅក្នុងពិធីសារនៃការចូលរួម (Accession Protocol) ដែលបានអនុម័តដោយសន្និសីទថ្នាក់រដ្ឋមន្ត្រីអង្គការពាណិជ្ជកម្មពិភពលោកនៅទីក្រុង Cancun កាលពីថ្ងៃទី១១ខែកញ្ញាឆ្នាំ ២០០៣ ដែលកម្ពុជាត្រូវធ្វើសច្ចាប័ន។ ប៉ុន្តែរហូតទាល់តែបន្ទាប់ពីធ្វើសច្ចាប័នលើកិច្ចព្រមព្រៀងសមាជិកភាពនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០១០ ទើបកម្ពុជាបានក្លាយទៅជាសមាជិកទី ១៤៨ របស់អង្គការពាណិជ្ជកម្មពិភពលោក។ កម្ពុជា និង នេប៉ាល់ គឺជាប្រទេសអភិវឌ្ឍន៍តិចតួចដំបូងគេ ដែលទទួលបានជោគជ័យ ចូលទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកចាប់តាំងពីការបំលែងខ្លួនរបស់អង្គការពាណិជ្ជកម្មពិភពលោក ចេញពីកិច្ចព្រមព្រៀងទូទៅស្តីអំពីតារាងពន្ធគយ និង ពាណិជ្ជកម្ម (GATT) នៅឆ្នាំ១៩៩៥។

អត្ថប្រយោជន៍ដែលរំពឹងនឹងទទួលបានពីសមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក ៖

- ធានាឱ្យបានថា នៅក្រោយថ្ងៃទី១ខែមករាឆ្នាំ២០០៥ ប្រទេសនាំចេញសម្លៀកបំពាក់និងវាយនភ័ណ្ឌនឹងមានលទ្ធភាពនាំចូលទៅកាន់ទីផ្សារសហរដ្ឋអាមេរិក សហគមន៍អ៊ឺរ៉ុប និង សមាជិកអង្គការពាណិជ្ជកម្មពិភពលោកដទៃទៀត ដោយគ្មានការកំណត់។
- មានសិទ្ធិចូលរួមជាមួយនឹងប្រព័ន្ធច្បាប់ពាណិជ្ជកម្មអន្តរជាតិ ជាមួយនឹងលក្ខខណ្ឌរបស់ MFN

សម្រាប់ទំនិញគ្រប់ប្រភេទ ជាមួយនឹងសិទ្ធិធានាអាចព្យាករណ៍បាន និងលទ្ធភាពចូលទៅកាន់ទីផ្សាររបស់ប្រទេសជាដៃគូចំនួន១៤៧ ផ្សេងទៀត ដោយគ្មានការរើសអើង។

- លើកកម្ពស់បរិយាកាសវិនិយោគក្នុងស្រុក ដោយឈរលើសេរីភាវូបនីយកម្មសេវាកម្មនិងទំនិញ។
- ជាឱកាសដើម្បីងាកចេញពីវិធីសាស្ត្របន្ថែមតម្លៃ ទៅជាឱកាសមួយដែលមានកំណែទម្រង់សេដ្ឋកិច្ច រចនាសម្ព័ន្ធយុត្តិធម៌ និង ហិរញ្ញវត្ថុ ដើម្បីជំរុញការវិនិយោគដោយផ្ទាល់ពីបរទេស ក៏ដូចជាការវិនិយោគក្នុងស្រុក។
- មានសិទ្ធិចូលរួមក្នុងយន្តការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក ដើម្បីការពារសិទ្ធិរបស់ប្រទេសនិងទទួលបានការការពារពីការដាក់ទណ្ឌកម្មពាណិជ្ជកម្មជាឯកតោភាគីណាមួយ។

## ២២.៦.១. ដំណើរការច្បាប់ក្នុងការគាំទ្រការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីចូលទៅក្នុង WTO រាជរដ្ឋាភិបាលបានអនុម័តយកផែនការសកម្មភាពច្បាប់(Legislation Action Plan) (២០០១-២០០៤) រយៈពេលវែងប្រកបដោយឆន្ទៈខ្ពស់ ដែលបានដាក់ចេញនូវរបៀបវារៈច្បាប់ថ្នាក់ជាតិ ក្នុងការគាំទ្រសមាជិកភាពកម្ពុជា។ របៀបវារៈនេះរួមបញ្ចូលច្បាប់ឬបទបញ្ញត្តិប្រមាណ៥៥ដែលនឹងត្រូវអនុម័ត ដើម្បីបំពេញក្របខ័ណ្ឌច្បាប់ជាពិសេសមានដូចជា ៖ ច្បាប់ពន្ធដារ ច្បាប់សហគ្រាសអាជីវកម្ម ច្បាប់តុលាការពាណិជ្ជកម្ម ច្បាប់កិច្ចសន្យាពាណិជ្ជកម្ម ច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាមួយចំនួន ច្បាប់ស្តីពីប្រភពដើមទំនិញវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃនិងការតបត និងច្បាប់ទាក់ទងនឹងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មនិងច្បាប់ស្តីពីអនាម័យនិងភូតគាមអនាម័យ។ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ ក្នុងគោលបំណងដែលគួរឱ្យកត់សម្គាល់ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុម័តយកច្បាប់និងបញ្ញត្តិពាណិជ្ជកម្មផ្សេងៗនិង ដើម្បីធានាបាននូវការគោរពតាមកាតព្វកិច្ចដទៃៗទៀតរបស់ WTO ដូចជាតម្រូវការផ្នែកតម្លាភាពដូចដែលមានចែងក្នុងមាត្រាទី១០នៃ GATT និងបទបញ្ញត្តិនៃការពិនិត្យឡើងវិញនៃតុលាការឯករាជ្យមួយ។ ក្នុងដំណើរការរៀបចំនិងអនុម័តក្រសួងនិងភ្នាក់ងាររដ្ឋាភិបាលនានា ត្រូវបានតម្រូវឱ្យធានាបាននូវការអនុវត្តពេញលេញនៃច្បាប់កម្ពុជាស្របទៅតាមកិច្ចព្រមព្រៀងផ្សេងៗរបស់ WTO ។ ដើម្បីបង្កើនល្បឿនដំណើរការចរចាកម្ពុជាបានដាក់ជូនលេខាធិការដ្ឋានរបស់ WTO នូវច្បាប់ពង្រាងច្បាប់និងបញ្ញត្តិឧបករណ៍ផ្សេងៗចំនួនជាង៨៥។ ដោយសារតែប្រវត្តិសាស្ត្ររបស់កម្ពុជាតម្រូវឱ្យក្របខ័ណ្ឌច្បាប់របស់ខ្លួន ត្រូវតាក់តែងឡើងវិញពីបាតដៃទទេ នោះការធ្វើឱ្យច្បាប់របស់ប្រទេសនេះស្របទៅតាមច្បាប់របស់ WTO គឺជាការងារដ៏លំបាកស្មុគស្មាញបំផុតមួយដែលកម្ពុជាត្រូវតែធ្វើឱ្យបាន។

## ២២.៦.២. ការអនុវត្តច្បាប់ជាជាតាក់ងជ័ងីជ័អង្គការពាណិជ្ជកម្មពិភពលោក

ចាប់តាំងពីក្លាយជាសមាជិកមួយរបស់ WTO កិច្ចខិតខំប្រឹងប្រែងជាច្រើនរបស់រដ្ឋាភិបាលត្រូវបានចំណាយទៅលើកិច្ចការបង្កើនល្បឿនរបៀបវារៈអនុម័តច្បាប់របស់ខ្លួន។ ទាក់ទងនឹងការអភិវឌ្ឍវិស័យហិរញ្ញ

វត្ថុ ច្បាប់នានាស្តីពីប្រតិបត្តិការពាណិជ្ជកម្ម ដែលមានដូចជាគណនេយ្យបីយាណត្តិអាចដោះដូរជាប្រាក់បាន (nogotiable instruments) ប្រតិបត្តិការដែលមានកិច្ចធានា សហគ្រាសពាណិជ្ជកម្ម ការក្ស័យធន និង កិច្ចសន្យា ត្រូវបានផ្តល់អាទិភាពជាចម្បង។ ច្បាប់គណនេយ្យ និងសវនកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ក្ស័យធន ត្រូវបានប្រកាសឱ្យប្រើប្រាស់ដើម្បីធ្វើឱ្យមានការអភិវឌ្ឍទីផ្សារមូលធន។ស្របជាមួយនឹងការអនុម័តក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ច្បាប់ស្តីពីរូបីយាណត្តិអាចដោះដូរជាប្រាក់បាន ត្រូវបានអនុម័ត ដើម្បីគាំទ្រដល់សកម្មភាពពាណិជ្ជកម្ម និងប្រតិបត្តិការហិរញ្ញវត្ថុ។ រដ្ឋាភិ-បាលបានអនុម័តច្បាប់ស្តីពីមូលបត្ររដ្ឋ និង ច្បាប់ស្តីពីការបោះផ្សាយនិងធ្វើពាណិជ្ជកម្មមូលបត្រឯកជន ដើម្បីដំណើរការទីផ្សារមូលធន។ ច្បាប់កម្មសិទ្ធិបញ្ញាសំខាន់ៗដូចជា ច្បាប់សញ្ញាពាណិជ្ជកម្ម ច្បាប់សិទ្ធិអាជីវកម្ម និង ច្បាប់សិទ្ធិអ្នកនិពន្ធត្រូវបានអនុម័ត ស្របទៅនឹងគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលក្នុងការជំរុញវិស័យនេះ ។

ច្បាប់ស្តីពីបទដ្ឋាន និង មាត្រសាស្ត្រត្រូវបានអនុម័ត ដើម្បីអនុវត្តតាមបទបញ្ញត្តិជាច្រើននៃកិច្ចព្រមព្រៀងរបស់ WTO ស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ហើយចំពោះបញ្ហានេះអាចបង្កើតជារបាំងមិនចាំបាច់ថ្មីមួយដល់ក្រុមហ៊ុននាំចេញរបស់កម្ពុជា។ ភាពជឿនលឿនគួរឱ្យកត់សម្គាល់ក៏ត្រូវបានសម្រេចបានផងដែរនៅក្នុងផ្នែកសម្របសម្រួលពាណិជ្ជកម្ម។ ច្បាប់ពន្ធដារត្រូវបានអនុម័ត ដែលផ្តល់ក្របខ័ណ្ឌច្បាប់សម្រាប់រដ្ឋាភិបាលដាក់ឱ្យប្រើប្រាស់ឯកសាររដ្ឋបាលតែមួយ (Single Administrative Document) ដើម្បីផ្តល់ភាពងាយស្រួលដល់ការធ្វើឯកសារពន្ធដារដើម្បីសាកល្បងប្រើ ASYCUDA នៅកំពង់ផែក្រុងព្រះសីហនុនិងបង្កើតអង្គភាពគ្រប់គ្រងហានិភ័យ នៅតាមទីស្នាក់ការកណ្តាលពន្ធដារ។ ក្នុងការធ្វើដំណើរឆ្ពោះទៅមុខរដ្ឋាភិ-បាលនឹងចាំបាច់ត្រូវតែបន្តអនុវត្តការប្តេជ្ញាចិត្តផ្នែកសេដ្ឋកិច្ចពាណិជ្ជកម្មនិងច្បាប់ដែលបានធ្វើឡើងក្រោមកិច្ចព្រមព្រៀងចូលជាសមាជិក WTO របស់ខ្លួន។ ការប្តេជ្ញាចិត្តទាំងនេះរួមមាន សេចក្តីជូនដំណឹងពីការអនុវត្តតាមស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម (TBTs) ការវាយតម្លៃពន្ធដារបទដ្ឋានអនាម័យនិងភូតគាមអនាម័យ (SPS) និងរបាំងមិនមែនពន្ធគយសំខាន់ៗដទៃទៀត (NTBs) ។ ជាចុងក្រោយកម្ពុជានៅតែប្តេជ្ញាចិត្តទៅនឹងកម្មវិធីកំណែទម្រង់មួយ ដែលត្រូវបានផ្តោតទៅលើការធ្វើពិពិធកម្មសេដ្ឋកិច្ច ដើម្បីបង្កើនល្បឿននៃការសម្រេចបានការសន្យាជាមួយ WTO ។ គោលបំណងនៃកិច្ចការកំណែទម្រង់ទាំងនេះគឺដើម្បីគាំទ្រដល់យុទ្ធសាស្ត្រចតុកោណ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ របស់រដ្ឋាភិបាល។ ភាពជោគជ័យនៃកំណែទម្រង់ក្នុងផ្នែកទាំងនេះ មានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ ការបន្តកំណើន ការបង្កើតការងារ ហើយកត្តានេះនឹងនាំមកនូវការកាត់បន្ថយភាពក្រីក្រ។

## ២២.៧. សមត្ថភាពពាណិជ្ជកម្មក្រៅប្រទេស

### ២២.៧.១. តួនាទីនៃគោលនយោបាយពាណិជ្ជកម្ម

ពាណិជ្ជកម្មក្រៅប្រទេស បានជួយឱ្យប្រទេសកម្ពុជាទទួលបានឱកាសលើសពីអ្វីដែលអាចវាយតម្លៃដោយផ្អែកទៅលើតែលក្ខខណ្ឌទីផ្សារក្នុងស្រុក។ ជាពិសេសការនាំចេញធ្វើឱ្យការប្រើប្រាស់ដីធ្លីនិងកម្លាំងពលកម្មមានប្រសិទ្ធភាព ដែលមកដល់ពេលនេះមិនទាន់បានប្រើប្រាស់អស់លទ្ធភាព ដោយសារតែតម្រូវការក្នុងស្រុកនៅខ្សោយ។ ការនាំចូលបានធ្វើឱ្យអ្នកប្រើប្រាស់កម្ពុជាអាចទិញផលិតផលមានគុណភាពខ្ពស់ ក្នុងតម្លៃថោកជាង ហេតុដូចនេះវាបានបង្កើនសុខុមាលភាពសេដ្ឋកិច្ច។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពាណិជ្ជកម្មក្រៅប្រទេស បានជួយឱ្យវិស័យឯកជនរីកដុះដាល និង ជាអ្នកផ្តល់ការងារដ៏សំខាន់នៅក្នុងតំបន់ទីក្រុង ប៉ុន្តែអាចដើរតួនាទីមួយដ៏ខ្លាំងក្លាជាងមុន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ យុទ្ធសាស្ត្រនានាគួរឆ្លើយតបទៅនឹងបញ្ហានានា ដូចជាការធ្វើឱ្យប្រព័ន្ធព័ត៌មានសម្រាប់ទីផ្សារប្រសើរឡើង ការធ្វើពិពិធកម្មទីផ្សារនៃផលិតផលនាំចេញនាំចូល ភាពអាចរកបានប្រសើរជាងមុនសម្រាប់អ្នកប្រើប្រាស់ចំពោះទំនិញសំខាន់ៗជាមូលដ្ឋាន ការបង្កើននិងរួមចំណែកពីវិស័យឯកជនក្នុងការរកទីផ្សារសម្រាប់ទំនិញនិងសេវាកម្មដែលបានផលិតក្នុងស្រុក។

ការបើកទូលាយជាងមុនចំពោះបច្ចេកវិទ្យាទំនើប កំពុងតែធ្វើឱ្យកម្ពុជាទទួលបានអត្ថប្រយោជន៍ដ៏សំខាន់ក្នុងលទ្ធភាពផលិតកម្មតាមរយៈការផ្ទេរបច្ចេកវិទ្យា ដោយមិនចាំបាច់ពឹងផ្អែកតែទៅលើធនធានក្នុងស្រុកសម្រាប់ការកែច្នៃនិងការអភិវឌ្ឍបច្ចេកវិទ្យា។ ក្នុងឆ្នាំ១៩៩៦ ក្រោយពេលកំណែទម្រង់សេរីដែលធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និង ក្រោយការភ្ជាប់ទំនាក់ទំនងក្រៅប្រទេសឡើងវិញ សហរដ្ឋអាមេរិកបានផ្តល់ឱ្យកម្ពុជានូវឋានៈជាប្រទេសទទួលការអនុគ្រោះបំផុត។ ចាប់តាំងពីឆ្នាំ១៩៩៧កម្ពុជាក៏បានទទួលផលប្រយោជន៍ពីប្រព័ន្ធអនុគ្រោះទូទៅ (GSP)ផងដែរ។ កម្ពុជាមិនបានទទួលផលប្រយោជន៍ពីការផ្តល់អត្រាពន្ធសូន្យភាគរយដូចដែលអាមេរិកផ្តល់ឱ្យទៅបណ្តាប្រទេសនៃទ្វីបអាហ្វ្រិកនិងតំបន់ការ៉ាប់ប៊ីនៅឡើយទេ។

កម្ពុជាក៏បានពង្រឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយសហគមន៍អឺរ៉ុប (EU) ផងដែរដែលបានផ្តល់ឱ្យកម្ពុជានូវប្រព័ន្ធអនុគ្រោះទូទៅ (GSP) ក្នុងឆ្នាំ១៩៩៤ និង បានធ្វើឱ្យកម្ពុជាទទួលផលប្រយោជន៍ពីគំនិតផ្តួចផ្តើម “ ការអនុគ្រោះរាល់ទំនិញនាំចូលលើកលែងតែសព្វាវុធ ” (EBA) ក្នុងឆ្នាំ២០០១។ កិច្ចព្រមព្រៀងទាំងនេះបានធ្វើឱ្យកម្ពុជាទទួលបានការបន្ថយពន្ធគយ ២០% លើការនាំចេញសម្លៀកបំពាក់ទៅសហគមន៍អឺរ៉ុបដែលត្រូវបានអនុវត្តស្របតាមបទបញ្ញត្តិប្រភពដើមនៃទំនិញជាក់លាក់មួយចំនួន។ ឧស្សាហកម្មនាំចេញសម្លៀកបំពាក់របស់កម្ពុជាដែលក្រណាត់ គឺជាវត្ថុធាតុដើមសំខាន់មួយមិនអាចទទួលផលប្រយោជន៍ទេដោយសារតែតម្រូវការនៃបទបញ្ញត្តិប្រភពដើមទំនិញ។ ដើម្បីទទួលបានអត្ថប្រយោជន៍ពីបទបញ្ញត្តិប្រភពដើមទំនិញរបស់សហគមន៍អឺរ៉ុប កម្ពុជាចាំបាច់ត្រូវតែផលិតក្រណាត់ផងដែរ (តម្បាញចាក់ និង សម្រេច) ។ មានតែ ប្រហែល ២៧% នៃការនាំចេញរបស់កម្ពុជា ដែលទទួលបានការផ្តល់អត្រាពន្ធសូន្យភាគរយ ក្នុងការនាំចូលទៅទីផ្សារសហគមន៍អឺរ៉ុប។ ឧទាហរណ៍ចាប់តាំងពីខែកញ្ញា ឆ្នាំ ២០០៩ ការនាំចេញអង្ករពីប្រទេសកម្ពុជាទទួលបានការផ្តល់អត្រាពន្ធសូន្យភាគរយ ក្នុងការនាំចូលទៅទីផ្សារសហគមន៍អឺរ៉ុប។

## ២២.៧.២. តុល្យភាពពាណិជ្ជកម្ម

កម្ពុជាបានមើលឃើញកំណើនដ៏ឆាប់រហ័សក្នុងពាណិជ្ជកម្មក្រៅប្រទេស។ បរិមាណសរុបនៃពាណិជ្ជកម្ម (នាំចេញ + នាំចូល) កើនឡើងជាង១៤ដង ដែលកើនពី ៧៦៩ លានដុល្លារអាមេរិកឬ២១% នៃផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ១៩៩៣ មកដល់ ១១ ពាន់លានដុល្លារអាមេរិក ឬ ១០៧% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០០៨។

*រូបភាព២២.១. ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា (គិតជាលានដុល្លារអាមេរិក)*




*ប្រភព ៖ ធនាគារជាតិនៃកម្ពុជា*

ក្នុងរយៈពេល ១៦ ឆ្នាំចុងក្រោយចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០៨ បរិមាណសរុបនៃពាណិជ្ជកម្មបានកើនឡើងជាមធ្យម១៩.៧%។ វាមានកត្តាពីរ ដែលបណ្តាលឱ្យមានកំណើនដូចនេះ គឺកំណើនទាំងការនាំចូល និង ការនាំចេញ។

## ២២.៧.៣. ការនាំចូល

ចំពោះការគណនាធម្មតា ការនាំចូលបានកើនឡើងពី ៤៨៦ លានដុល្លារអាមេរិក ឬ ១៩.៦% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ១៩៩៣ មកដល់ ៦.៦ពាន់លានដុល្លារអាមេរិក ឬ ៦៤.៤% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០០៨ ដែលក្នុងកម្រិតកំណើនជាមធ្យមប្រចាំឆ្នាំគឺ ១៩%។ ក្នុងចំនួនទឹកប្រាក់ ៦,៦ ពាន់លានដុល្លារអាមេរិកនៃការនាំចូលក្នុងឆ្នាំ ២០០៨ ដែលក្នុងនោះ ៦.៥ ពាន់លានដុល្លារអាមេរិក គឺជាការនាំទំនិញចូលប្រើប្រាស់ក្នុងស្រុក ហើយ ១២០ លានដុល្លារអាមេរិកត្រូវបាននាំចេញបន្តទៅកាន់ប្រទេសជិតខាង។ កម្ពុជាបាននាំចូលទំនិញពីហុងកុង (១៩%) ចិន (១៦%) ថៃ (១៤%) តៃវ៉ាន់ (១១%) សិង្ហបុរី (១០%) វៀតណាម (៩%) កូរ៉េខាងត្បូង (៥%) ជប៉ុន (៤%) ឥណ្ឌូណេស៊ី (៣%) បារាំង (២%) សហរដ្ឋអាមេរិក (១%) និងដទៃទៀត (៦%) ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រូបភាព២២.២. ប្រភពទំនិញនាំចូលមកកម្ពុជាក្នុងឆ្នាំ២០០៧ (%)*




*ប្រភព ៖ ធនាគារជាតិនៃកម្ពុជា ជញ្ជីងទូទាត់។*

មុខទំនិញនាំចូលសំខាន់ៗគឺៈ ផលិតផលប្រេង (៣១%នៃការនាំចូលសរុប) វត្ថុធាតុដើមសម្រាប់ផលិតកម្មក្រណាត់ និង សម្លៀកបំពាក់ (២០%) ឧបករណ៍ និង វត្ថុធាតុដើមទាក់ទងនឹងការវិនិយោគ និង ទំនិញផ្សេងទៀត ដូចជា រថយន្ត ផលិតផលអេឡិចត្រូនិក និង ចំណីអាហារ។ល។

តម្លៃប្រេងនៅដែលកំពុងកើនឡើងយ៉ាងលឿន ផ្តល់ផលប៉ះពាល់អវិជ្ជមានដល់កំណើនសេដ្ឋកិច្ចកម្ពុជាពីព្រោះកម្ពុជាគឺជាប្រទេសនាំចូលប្រេងសុទ្ធ។ តម្រូវការជាសាកលសម្រាប់វត្ថុធាតុដើមកំពុងកើនឡើងយ៉ាងគំហុក ដែលមួយផ្នែកបណ្តាលមកពីការឆ្លៀតឱកាសកេងចំណេញ។ ប្រទេសមហាអំណាចថ្មីៗដូចជាចិន និងឥណ្ឌា ប្រេស៊ីល និងរុស្ស៊ីកំពុងប្រមូលទុកនូវការផ្គត់ផ្គង់នានាដែលអាចរកបាន។ និន្នាការរយៈពេលវែងនោះគឺធ្វើឱ្យតម្លៃប្រេងនិងទំនិញដទៃទៀតកើនឡើង។ ការប្រែប្រួលរបៀបនេះនឹងធ្វើឱ្យការគ្រប់គ្រងតុល្យភាពទូទាត់របស់កម្ពុជាជួបការលំបាកស្មុគស្មាញ។ កម្ពុជាអនុវត្តគោលនយោបាយដោយយកតម្លៃអន្តរជាតិមកអនុវត្តបន្តលើអ្នកប្រើប្រាស់របស់ខ្លួន។ កម្ពុជាអនុញ្ញាតឱ្យនាំទំនិញចូលមិនគិតពន្ធបើការនាំចូលនោះជាការវិនិយោគបរទេសផ្ទាល់។ ការនាំចូលរួចពន្ធមានចំនួន៦០% នៃតម្លៃទំនិញនាំចូល។

## ២២.៧.៤. ការនាំចេញ

ការនាំចូលបានកើនឡើងពី ២៨៣ លានដុល្លារអាមេរិក ឬ ១១,៩% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ១៩៩៣ មកដល់ ៥,៤ ពាន់លានដុល្លារអាមេរិក ឬ ៥៣% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០០៨ ដែល ក្នុងកម្រិតកំណើនជាមធ្យមប្រចាំឆ្នាំគឺ ១៥% ចំពោះការគណនាធម្មតា។ ការនាំចេញសម្លៀកបំពាក់បានកើនឡើងពី ៤ លានដុល្លារអាមេរិកក្នុងឆ្នាំ ១៩៩៤ មកដល់ ២.៩ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០៨ ដែលកំណើនជាមធ្យមប្រចាំឆ្នាំគឺ ៣១%។ ការនាំចេញសម្លៀកបំពាក់បានចាប់ផ្តើមកើនឡើងក្នុងឆ្នាំ ១៩៩៥ ក្រោយពេលកម្ពុជាត្រូវបានផ្តល់ឱ្យនូវប្រព័ន្ធអនុគ្រោះ MFN/GSP ដោយសហរដ្ឋអាមេរិក និង សហគមន៍អឺរ៉ុប។ ប្រព័ន្ធអនុគ្រោះ GSP អនុញ្ញាតឱ្យទំនិញកម្ពុជាចូលទៅទីផ្សារប្រទេសអភិវឌ្ឍន៍ ជាមួយនឹងអត្រាពន្ធគយទាប។

លើសពីនេះទៅទៀត កិច្ចព្រមព្រៀងវាយនភ័ណ្ឌទ្វេភាគីសហរដ្ឋអាមេរិក-កម្ពុជាឆ្នាំ ១៩៩៩ បានផ្តល់ឱ្យកម្ពុជានូវកូតាក្នុងចំណែកទីផ្សារដែលអាចត្រូវបានបង្កើនដល់ទៅ១៤% ក្នុងមួយឆ្នាំដោយផ្អែកលើការអនុវត្តតាមកម្រងបទដ្ឋានពលកម្មជាកំណត់មួយ។ ក្រោមកិច្ចព្រមព្រៀងពហុវាយនភ័ណ្ឌ (Multi-fiber Agreement) របបកូតាមួយបានត្រូវអនុវត្តរហូតដល់ថ្ងៃទី០១ខែមករាឆ្នាំ២០០៥ ដើម្បីអាចឱ្យឧស្សាហកម្មវាយនភ័ណ្ឌរបស់ប្រទេសអភិវឌ្ឍន៍ ស៊ីគ្នាទៅនឹងការប្រកួតប្រជែងពីប្រទេសអភិវឌ្ឍន៍តិចតួច ដែលតម្លៃពលកម្មរបស់គេនៅទាប។ វិនិយោគិនក្នុងប្រទេសមួយចំនួន ដែលត្រូវបានកាត់បន្ថយកូតានាំចេញ បានបង្វែរផលិតកម្មរបស់ពួកគេមកប្រទេសកម្ពុជា ដែលទទួលផលប្រយោជន៍ពីប្រព័ន្ធអនុគ្រោះ MFN និង GSP។ ៩០% នៃសហគ្រាសកាត់ដេរនៅកម្ពុជាត្រូវបានគ្រប់គ្រងដោយទុនបរទេស។ ប្រការនេះបាននាំឱ្យមានកំណើនយ៉ាងខ្លាំងនៃការនាំចេញលើសកូតា ដែលមានចំនួន៩០% នៃការនាំចេញសម្លៀកបំពាក់របស់កម្ពុជា។

*រូបភាព២២.២. ប្រភពទំនិញនាំចូលមកកម្ពុជាក្នុងឆ្នាំ២០០៧ (%)*




*ប្រភព ៖ ធនាគារជាតិនៃកម្ពុជា ជញ្ជីងទូទាត់។*

ការយកចិត្តទុកដាក់យ៉ាងខ្លាំងនៃពាណិជ្ជកម្ម លើចំនួនផលិតផលដែលមានដែនកំណត់គឺជាសញ្ញាអវិជ្ជមាននៃសមត្ថភាពផ្គត់ផ្គង់ដ៏ខ្សោយនៅប្រទេសកម្ពុជា និងការមិនសូវមានតម្រូវការផ្សេងៗច្រើនទេសម្រាប់ការនាំចេញ។ ពាក់ព័ន្ធជាមួយតម្លៃការនាំចេញមានជាប់ទាក់ទងតែជាមួយផលិតផល៧ប្រភេទសំខាន់ៗប៉ុណ្ណោះ។ ក្រណាត់ និង សម្លៀកបំពាក់មានចំនួនជាង៦៥%នៃការនាំចេញរបស់កម្ពុជាក្នុងឆ្នាំ២០០៨។

សហរដ្ឋអាមេរិកគ្របដណ្តប់ជាង ៥២% នៃការនាំចេញពីប្រទេសកម្ពុជា។ ចំណែកនេះបានកើនឡើងយ៉ាងគំហុកក្នុងរយៈពេលមួយទស្សវត្សរ៍ចុងក្រោយនេះ ហើយបច្ចុប្បន្នវាហាក់ដូចជាមានស្ថេរភាពហើយ។ ប្រទេសធំទី២សម្រាប់បរិមាណនាំចេញ គឺហុងកុងដែលទទួលបាន១៧% នៃការនាំចេញពីកម្ពុជា បន្តមកទៀតគឺ អាល្លឺម៉ង់ (៧%) ចក្រភពអង់គ្លេស (៥%) កាណាដា (៣%) សិង្ហបុរី (៣%) បារាំង (២%) វៀតណាម (២%) ជប៉ុន (១%) និងប្រទេសផ្សេងៗទៀត (៨%)។

ទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីជាមួយនឹងប្រទេសថៃកំពុងកើនឡើងខ្លាំងជាងមុន។ កម្ពុជានាំចូលផលិតផលមានតម្លៃប្រហែលជាពីរពាន់លានដុល្លារអាមេរិក ពីប្រទេសថៃ និងនាំចេញទៅប្រទេសថៃវិញចំនួន ៩០លានដុល្លារអាមេរិកដែលមួយចំនួនធំ គឺជាផលិតផលកសិកម្ម។ពាណិជ្ជកម្មរវាងកម្ពុជា-ថៃត្រូវបានចុះបញ្ជីក្រោមពាណិជ្ជកម្មតាមព្រំដែន ហើយមិនត្រូវបានរាប់បញ្ចូលឱ្យបានពេញលេញក្នុងស្ថិតិពាណិជ្ជកម្មផ្លូវការនោះទេ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថៃបានអនុម័តតារាងបញ្ជីទំនិញចំនួន៣០ប្រភេទ ដែលត្រូវផ្តល់ឱ្យកម្ពុជាក្នុងក្របខ័ណ្ឌប្រព័ន្ធសមាហរណកម្មអនុគ្រោះអាស៊ាន ដើម្បីជំរុញកំណើនពាណិជ្ជកម្មជាមួយកម្ពុជា។ ក្រោមគោលនយោបាយពាណិជ្ជកម្មសេរីច្រកតែមួយឬការនាំចូលរួចពន្ធរបស់ ACMECS ថៃបានបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការទិញផលិតផលកសិកម្មរបស់កម្ពុជាមួយចំនួន រួមមានសណ្តែកសៀង ពោត គ្រាប់ល្ហុងខ្វង ដំឡូងបារាំង ស្វាយចន្ទី ដើមប្រេងខ្យល់ និងគ្រាប់សណ្តែកដី។ គំនិតផ្តួចផ្តើម ACMECS ផ្សេងៗទៀតរួមមាន ៖ ការសិក្សាពីលទ្ធភាពក្នុងការបង្កើតទីផ្សារនាំចេញ / បោះដុំក្នុងប្រទេសកម្ពុជានិងការសិក្សាពីលទ្ធភាពក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅកោះកុង ប៉ោយប៉ែត និងប៉ៃលិន។ប៉ុន្តែកិច្ចសហប្រតិបត្តិការ ACMECS ស្ទើរតែត្រូវបានបញ្ឈប់ក្រោយពេលរដ្ឋប្រហារបានទម្លាក់លោកថាក់ស៊ីនក្នុងឆ្នាំ២០០៦ ហើយទំនងថាគម្រោងនានារបស់ ACMECS នឹងជួបការលំបាកក្នុងការអនុវត្តដោយសារតែជម្លោះនយោបាយថ្មីៗនេះរវាងកម្ពុជានិងថៃ។

ក្នុងឆ្នាំ២០០២ កម្ពុជា និង វៀតណាមបានបន្តកិច្ចព្រមព្រៀងស្តីពីទំនិញឆ្លងកាត់ ដើម្បីជំរុញការនាំចេញពីប្រទេសកម្ពុជាទៅកាន់ប្រទេសទី៣ដោយឆ្លងកាត់ប្រទេសវៀតណាម។ ក្នុងឆ្នាំ២០០១ ប្រទេសទាំងពីរនេះបានចុះកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ដើម្បីអាចឱ្យមានពាណិជ្ជកម្មលើទំនិញសម្រាប់ជីវភាពប្រចាំថ្ងៃរវាងប្រជាជននៃប្រទេសទាំងពីរដែលរស់នៅតាមព្រំដែន។ កម្ពុជានាំចូលផលិតផលមានតម្លៃជាងពីរពាន់លានដុល្លារអាមេរិកពីប្រទេសវៀតណាម។ នៅពេលដែលទំនាក់ទំនងជាមួយថៃមានភាពជូរចត់ បរិមាណពាណិជ្ជកម្មជាមួយនឹងវៀតណាមកើនឡើងយ៉ាងរហ័ស។

ដើម្បីរក្សាការរួមចំណែករបស់ការនាំចេញក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ការយកចិត្តទុកដាក់ដ៏ពិសេសនឹងត្រូវផ្តល់ទៅលើការបង្កើនចំណែកនៃតម្លៃបន្ថែម ដែលប្រមូលបានពីក្នុងស្រុកលើមុខទំនិញទាំងអស់ដែលត្រូវនាំចេញនិងទៅលើឱកាសនៃការបង្កើតទីផ្សារនាំចេញថ្មីៗ។ ក្នុងន័យនេះការដាំដុះឈើឧស្សាហកម្ម និងការប្រមូលផលឈើជាក់លាក់ ចំណីអាហារកសិកម្មការចិញ្ចឹមត្រីនិងការកែច្នៃត្រីជាមួយនឹងសេវាកម្មផ្សេងៗដែលតម្រូវឱ្យមានធនធានពលកម្មជំនាញ (ដូចជាការបង្កើតកម្មវិធីកុំព្យូទ័រ) គឺជាផ្នែកដែលមានសក្តានុពលល្អ។ បន្ថែមលើការបង្កើនចំណែកនៃតម្លៃបន្ថែមសម្រាប់នាំចេញកម្ពុជា ក៏ចាំបាច់ត្រូវតែធ្វើតំបន់ភាវូនីយកម្មនិងវិមជ្ឈការផលិតកម្មនាំចេញរបស់ខ្លួន ដើម្បីឱ្យអត្ថប្រយោជន៍នៃសាកលភាវូបនីយកម្មត្រូវបានបែកចែងស្មើៗគ្នានៅទូទាំងប្រទេស។

ការសិក្សាជាច្រើនត្រូវបានធ្វើឡើងក្នុងកំឡុងពេល៥ឆ្នាំចុងក្រោយនេះ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា ៖ ការអភិវឌ្ឍច្រករបៀងក្រុងភ្នំពេញ-ខេត្តព្រះសីហនុការធ្វើឱ្យប្រសើរឡើង នូវយន្តការសម្រាប់កិច្ចការទីផ្សារនិងត្រួតពិនិត្យគុណភាពស្រូវក្រោយពេលប្រមូលផល ការសិក្សាពីលទ្ធភាពក្នុងការបង្កើតទីផ្សារស្រូវ ការវាយតម្លៃលើផ្នែកឯកជននិងការអភិវឌ្ឍនៃសហគ្រាសខ្នាតតូច និង មធ្យម ការវាយតម្លៃលើវិស័យកសិឧស្សាហកម្មនៅកម្ពុជា កម្មវិធីកាត់បន្ថយភាពក្រីក្រផ្អែកលើការនាំចេញ (Export-Based Poverty Reduction Program) ការសិក្សាលើសមត្ថភាពផ្គត់ផ្គង់នៃកសិកម្មចម្រុះ និង ចំណីអាហារកសិកម្ម យុទ្ធសាស្ត្រតភ្ជាប់គម្លាតដោយប្រើមធ្យោបាយពាណិជ្ជកម្មអេឡិចត្រូនិក (E-Commerce) និងផលប៉ះពាល់នៃតំបន់លើកស្ទួយការនាំចេញដើម្បីការកាត់បន្ថយភាពក្រីក្រ។ លទ្ធផលនៃការសិក្សាទាំងនេះនឹងត្រូវបានសិក្សាដើម្បីបន្តពង្រឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសជិតខាង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ២៣
# បំណុលក្រៅប្រទេស

## ២៣.១. និយមន័យ

### ២៣.១.១. បំណុលរដ្ឋ

បំណុលរដ្ឋត្រូវបានចែកចេញជា ៖

- តាមនិយមន័យចង្អៀត៖
    - កម្ចីក្នុង និង ក្រៅប្រទេសរបស់រដ្ឋ
    - កម្ចីក្នុង និង ក្រៅប្រទេសដែលរដ្ឋធានា
    - ប័ណ្ណរតនាគារ (និងសញ្ញាប័ណ្ណរដ្ឋឯទៀត)
    - បំណុលរតនាគារចំពោះធនាគារជាតិនៃកម្ពុជា
- តាមនិយមន័យទូលាយ៖
    - បញ្ញើនៅរតនាគារ (បញ្ញើតតិយជន ក្រុមហ៊ុន និង ស្ថាប័នដែលត្រូវបានអនុញ្ញាតអោយដាក់ប្រាក់បញ្ញើនៅរតនាគារ)
    - បំណុលចំណាយកកស្ទះ ។

ការគ្រប់គ្រងបំណុលនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកតាមផ្នែកដូចតទៅ៖

- អគ្គនាយកដ្ឋានរតនាគារជាតិ ទទួលខុសត្រូវចំពោះបំណុលក្នុងស្រុក លើកលែងតែបំណុលជារូបិយប័ណ្ណ ដែលគ្រប់គ្រងដោយនាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិ
- អង្គភាពគ្រប់គ្រងបំណុលនៃនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុកគ្រប់គ្រងបំណុលក្រៅប្រទេស ដោយរួមទាំងបំណុលក្នុងស្រុកជារូបិយប័ណ្ណ
- ធនាគារជាតិនៃកម្ពុជា - ទទួលខុសត្រូវចំពោះកម្ចីនៃមូលនិធិរូបិយវត្ថុអន្តរជាតិ។

### ២៣.១.២. បំណុលក្រៅប្រទេស

បំណុលក្រៅប្រទេស គឺជាសំណុំនៃបំណុលរយៈពេលវែង ដែលនិវាសនជននៃប្រទេសមួយជំពាក់អនិវាសនជន។ និយមន័យនេះ គឺជានិយមន័យបំណុលរបស់ធនាគារពិភពលោក។ និយមន័យនេះមានសារសំខាន់ណាស់ ដោយសារទិន្នន័យស្តីពីបំណុលអនុញ្ញាតឱ្យយើងវាយតម្លៃពីសមត្ថភាពជំពាក់បំណុល (Indebtedness) របស់ប្រទេសមួយ និង ដែលជាទិន្នន័យចាំបាច់សម្រាប់ការគណនាជញ្ជីងទូទាត់ ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បំណុលរយៈពេលវែង គឺជាបំណុលដែលមានរយៈពេលសងលើសពីមួយឆ្នាំ។ ការគណនារយៈពេលសងបំណុល គឺជារយៈពេលរវាងកាលបរិច្ឆេទនៃកិច្ចសន្យាផ្តល់កម្ចី (កាលបរិច្ឆេទសន្យា) និង កាលបរិច្ឆេទនៃការទារ ការទូទាត់បំណុលចុងក្រោយ។

ប្រទេសមួយចំនួនចាត់ថ្នាក់បំណុលរយៈពេលខ្លី ជាបំណុលដែលរយៈពេលសងដំបូង មិនលើសពី ២ ឆ្នាំ ដែលខុសពីប្រទេសខ្លះ ដែលចាត់ទុកថាបំណុលរយៈពេលខ្លី គឺបំណុលដែលមានរយៈពេលសងតិចជាង ១ ឆ្នាំ។ ក៏ប៉ុន្តែ និយមន័យរបស់ធនាគារពិភពលោក ដែលចាត់ទុកថា «បំណុលរយៈពេលវែង គឺជាបំណុលដែលមានរយៈពេលសងលើសពីមួយឆ្នាំ» គឺជានិយមន័យ ដែលប្រើប្រាស់សម្រាប់រៀបចំនូវស្ថិតិអន្តរជាតិ។

អនិវាសនជន គឺជាបុគ្គល ឬ អង្គការដែលគ្មានវត្តមានជាក់ស្តែងនៅក្នុងប្រទេសនោះ ដូចជា រូបវន្តបុគ្គល អនិវាសនជន ក្រុមហ៊ុនបរទេស (លើកលែងតែសាខារបស់ក្រុមហ៊ុននៅក្នុងប្រទេសមួយចំនួន) និង អង្គការអន្តរជាតិ ។ និយមន័យនេះមានសង្គតិភាពជាមួយសៀវភៅណែនាំរបស់មូលនិធិរូបិយវត្ថុអន្តរជាតិស្តីពីជញ្ជីងទូទាត់។

បំណុលក្រៅប្រទេសរយៈពេលវែងត្រូវបានចែកចេញជាពីរប្រភេទ គឺ ៖ បំណុលសាធារណៈ និង បំណុលឯកជន។

បំណុលសាធារណៈក្រៅប្រទេសចែកចេញជា ៖

- បំណុលក្រៅប្រទេសនៃផ្នែកសាធារណៈ និង
- បំណុលក្រៅប្រទេសនៃផ្នែកឯកជន ដែលរដ្ឋធានា ។

បំណុលទាំងនេះត្រូវបានត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ ដោយអង្គភាពគ្រប់គ្រងបំណុលរបស់នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចាប់តាំងពីពេលករកើតបំណុល រហូតដល់ពេលបំណុលទាំងនេះត្រូវបានសងរួច។ បំណុលនីមួយៗមានតារាងឯកសារតាមដានរបស់ខ្លួន ។

បំណុលក្រៅប្រទេសរបស់ផ្នែកឯកជន មិនអាចឱ្យយើងតាមដានបានគ្រប់ជ្រុងជ្រោយបានឡើយ។ ដូច្នេះហើយ ចាំបាច់យើងត្រូវអោយនិយមន័យអោយចំនូវផ្នែកសាធារណៈ។

ផ្នែកសាធារណៈ រួមមាន ៖

ក- រដ្ឋ៖ រដ្ឋាភិបាល ដែលមានក្រសួង និង ស្ថាប័ន។ បំណុលក្រៅប្រទេសរបស់រដ្ឋងាយស្រួលនឹងស្រង់ និង ត្រួតពិនិត្យ ដោយសារតែបំណុលទាំងនេះត្រូវបានកត់ត្រាទុកនៅក្នុងចំណូលថវិកានៅពេលខ្ចី និង កត់ត្រាជាចំណាយថវិកាសម្រាប់សេវាការប្រាក់ និងការសងដើមបំណុល។

ខ- ខេត្ត-ក្រុង៖ បន្ទាប់ពីការដាក់អោយអនុវត្តនូវច្បាប់អង្គការស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ស្រុក ខ័ណ្ឌ ខេត្ត-ក្រុង គឺជានីតិបុគ្គលនៃនីតិសាធារណៈ។ ក៏ប៉ុន្តែ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ខេត្ត-ក្រុង មិនអាចជាភាគីមួយនៃកម្ចីបានឡើយ។

គ- ធនាគារកណ្តាល៖ ធនាគារជាតិនៃកម្ពុជា។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឃ-ស្ថាប័នសាធារណៈស្វយ័តៈ ដូចជា គ្រឹះស្ថានសាធារណៈ។

ង- សហគ្រាសាធារណៈ៖ ដូចជា គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចម្រុះដែលក្នុងនោះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬ ដោយប្រយោលលើសពី ៥១%នៃដើមទុនក្រុមហ៊ុន ឬ សិទ្ធិបោះឆ្នោត។

បំណុលដែលរដ្ឋធានា គឺជាបំណុលនៃក្រុមហ៊ុនឯកជន ដែលរដ្ឋ ឬ ស្ថាប័នសាធារណៈបានធ្វើការធានាថា នឹងធ្វើការទូទាត់ការប្រាក់ និង សងដើមបំណុលប្រសិនបើឥណាយិក (Debtor) មិនអាចសងបំណុលនេះបាន។ រដ្ឋត្រូវមានការប្រយ័ត្នប្រយែង ក្នុងការធានាបំណុលឯកជន បើពុំនោះសោតការធានានេះមានន័យថា ធានាអោយក្រុមហ៊ុនឯកជនតែម្តង។

ការធានារបស់រដ្ឋច្រើនតែអនុវត្តចំពោះកម្ចីរបស់សហគ្រាសសាធារណៈ ជាពិសេសក្រុមហ៊ុនរដ្ឋ និង ក្រុមហ៊ុនចម្រុះរដ្ឋ-ឯកជន នៅពេលដែលឥណទាយក (Creditor) ទាមទារអោយរដ្ឋផ្តល់នូវការធានានេះក្នុង គោលដៅកាត់បន្ថយអត្រាការប្រាក់អោយនៅទាប។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា បំណុលទាំងអស់ គឺជាបំណុលដែលដៃគូអភិវឌ្ឍន៍ពហុភាគី និង ទ្វេភាគីផ្តល់ជូនរដ្ឋដោយផ្ទាល់។ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែម្នាក់គត់ ដែលមានសម្បទានអាចចុះកិច្ចព្រមព្រៀងកម្ចីបាន តាមការប្រទានសិទ្ធិរបស់នាយករដ្ឋមន្ត្រី ដោយមិនឱ្យលើសពី ២០០ លាន SDR ក្នុងមួយឆ្នាំ។ ក៏ប៉ុន្តែរដ្ឋសភាបានអនុម័តធានាការវិនិយោគរបស់ក្រុមហ៊ុនឯកជនរបស់សាធារណៈរដ្ឋប្រជាមានិតចិន ដែលដាក់ទុនវិនិយោគក្នុងការសាងសង់ស្ថានីយវ៉ារីអគ្គិសនី ដូចជាស្ថានីយវ៉ារីអគ្គិសនីគីរីរម្យ និង ស្ថានីយវ៉ារីអគ្គិសនីកំចាយ ជាដើម។

## ២៣.២. ការគ្រប់គ្រងបំណុលក្រៅប្រទេស

### ២៣.២.១. អង្គភាពគ្រប់គ្រងបំណុល

អង្គភាពគ្រប់គ្រងបំណុល គឺជាអង្គភាពមួយនៃនាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកខាងផ្នែកគ្រប់គ្រងបំណុលក្រៅប្រទេស។ ការគ្រប់គ្រងបំណុលក្រៅប្រទេស គឺជាការងារដែលមានបច្ចេកទេសជំនាញពិសេស ដែលទាមទារឱ្យមន្ត្រីដែលទទួលបន្ទុកត្រូវឆ្លងកាត់នូវវគ្គបណ្តុះបណ្តាលពិសេស ។

អង្គភាពនេះត្រូវតែស្ថិតនៅក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងគោលដៅធានាអោយបាននូវការគ្រប់គ្រងបំណុលប្រកបដោយប្រសិទ្ធភាព។ ជារួម ថវិកាជាតិគ្រោងទៅក្នុងចំណាយចរន្ត នូវចំណាយសម្រាប់សងការប្រាក់ និង នៅក្នុងចំណាយមូលធន នូវចំណាយសម្រាប់សងដើមកម្ចី។

ថ្វីត្បិតតែអង្គភាពគ្រប់គ្រងបំណុល ជាអង្គភាពមួយមានឯកទេសពិសេស អង្គភាពនេះត្រូវទំនាក់ទំនង និង សហការយ៉ាងជិតស្និទ្ធជាមួយគ្រប់ស្ថាប័ន និង នាយកដ្ឋានទាំងអស់ដែលទទួលបន្ទុកខាងគ្រប់គ្រងបំណុល ដូចជានាយកដ្ឋានថវិកា អគ្គនាយកដ្ឋានរតនាគារជាតិ និង ធនាគារជាតិនៃកម្ពុជា។

ការទទួលខុសត្រូវរបស់អង្គភាពគ្រប់គ្រងបំណុលអាចចែកចេញជាមុខងារបីសំខាន់ៗ គឺៈ មុខងាររដ្ឋបាល មុខងារគណនេយ្យ និង មុខងារស្ថិតិ ។

### ២៣.២.១.១. មុខងាររដ្ឋបាល

ការទទួលខុសត្រូវចំពោះមុខរបស់អង្គភាពគ្រប់គ្រងបំណុល គឺការតាមដាន និង ត្រួតពិនិត្យការសងការប្រាក់ និង ប្រាក់ដើម ទៅតាមកាលបរិច្ឆេទ ដើម្បីជៀសវាងការយឺតយ៉ាវនាំអោយមានពិន័យ។ ដើម្បីបំពេញមុខងារនេះ ៖

ទីមួយ-អង្គភាពគ្រប់គ្រងបំណុលត្រូវដឹងទាំងអស់ពីកិច្ចសន្យាកម្ចី ដែលរាជរដ្ឋាភិបាលបានចុះហត្ថលេខា។

ទីពីរ-មន្ត្រីរៀបចំថវិកាត្រូវគ្រោងចំណាយសងបំណុលនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ

ទីបី-រតនាគារជាតិ និង ធនាគារជាតិនៃកម្ពុជាត្រូវពិនិត្យអោយបានហ្មត់ចត់ ដើម្បីធានានូវការទូទាត់បំណុល និង ការផ្ទេរប្រាក់ទៅឥណទាយក។

### ២៣.២.១.២. មុខងារគណនេយ្យ

អង្គភាពគ្រប់គ្រងបំណុលត្រូវបើកគណនីសម្រាប់រាល់កម្ចីទាំងអស់ និង កត់ត្រារាល់ប្រតិបត្តិការទាំងអស់ ដែលពាក់ព័ន្ធនឹងកម្ចី ។

ដំណាក់កាលទី ១ គឺ ត្រូវកត់ត្រានូវបរិមាណនៃកម្ចីដែលបានចុះកិច្ចសន្យា ការប៉ាន់ស្មានបើកផ្តល់ក្នុងឆ្នាំ កាលបរិច្ឆេទដែលត្រូវសងដើម និង ការប្រាក់។ បន្ទាប់មក ត្រូវកត់ត្រានូវការអនុវត្តបើកផ្តល់សាច់ប្រាក់បំណុល។ នៅពេលដែល កាលបរិច្ឆេទសងការប្រាក់ ឬ សងដើមកម្ចីបានមកដល់ ត្រូវកត់ត្រាទុកនូវនីតិវិធីទូទាត់សងនៅក្នុងគណនីកម្ចី។ ហើយចុងបញ្ចប់ ប្រសិនបើមានការយឺតយ៉ាវក្នុងការសងការប្រាក់ក្តី ឬ ក្នុងការសងដើមបំណុលក្តី ទំហំទឹកប្រាក់នៃការយឺតយ៉ាវនេះ ត្រូវតែចុះកិច្ចបញ្ជិការ និង តាមដានដោយផ្ទាល់នៅក្នុងគណនីកម្ចី។

### ២៣.២.១.៣. មុខងារស្ថិតិ

ស្ថិតិបំណុលរៀបចំឡើង ដោយឈរលើមូលដ្ឋាននៃការចុះបញ្ជីកាគណនេយ្យ។ កាលបរិច្ឆេទស្ថិតិនេះមានថេរវេលាចំនួនមួយឆ្នាំ យ៉ាងច្រើនបំផុត។ ទិន្នន័យស្ថិតិសាមញ្ញអាចបោះផ្សាយក្នុងមួយត្រីមាសម្តង។

ដោយសារការដាក់អោយអនុវត្តនូវកម្មវិធីព័ត៌មានវិទ្យា ការគ្រប់គ្រងបំណុល ដែលធ្លាប់តែជាការងារមួយទាមទារនូវពេលវេលាច្រើន និង មានលក្ខណៈស្មុគស្មាញ ឥឡូវនេះអាចអនុវត្តបានយ៉ាងភ្លាមៗតែម្តង។

## ២៣.២.២. ការគ្រប់គ្រងរដ្ឋបាលនៃបំណុល

### ២៣.២.២.១. ការតាមដានត្រួតពិនិត្យការសន្យាបើកផ្តល់កម្ចី

ដំណាក់កាលទីមួយ គឺត្រូវរៀបចំនូវតារាងកត់ត្រាកម្ចីទាំងអស់ ដែលឆ្លើយតបទៅនឹងនិយមន័យនៃបំណុលសាធារណៈ។ បន្ទាប់មក អង្គភាពគ្រប់គ្រងបំណុលត្រូវសហការអោយបានជិតស្និទ្ធជាមួយការិយាល័យ ដែលទទួលបន្ទុកចរចាយកកម្ចីថ្មី និង ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំនូវតារាងបំណុលនេះ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ក. ការបង់លេខ

កម្ចីនីមួយៗត្រូវមានលេខកូដសម្គាល់ ដើម្បីងាយស្រួលនឹងគ្រប់គ្រង។ គេអាចដាក់ឱ្យអនុវត្តនូវប្រព័ន្ធលេខកូដ សម្រាប់បញ្ជូនព័ត៌មានទៅធនាគារពិភពលោក (ដែលទាមទារអោយមានប្រព័ន្ធលេខកូដតែមួយ) ឬ អាចអនុវត្តនូវប្រព័ន្ធលេខកូដផ្សេងទៀត។

## ខ. ការបង្កើតបញ្ជីកម្ចី

កម្ចីនីមួយៗត្រូវមានបញ្ជីរបស់វា ដែលត្រូវបែងចែកជាឯកសារពីរផ្នែក ៖

ទីមួយ-បញ្ជីឯកសារទីមួយត្រូវមានច្បាប់ដើមនៃកិច្ចសន្យាកម្ចី ឬ យ៉ាងហោចណាស់ក៏ច្បាប់ចម្លងនៃកិច្ចសន្យានេះដែរ និងឯកសារ និងសក្ខីប័ត្រផ្សេងៗទៀត ដែលបញ្ជាក់បំពេញបន្ថែមឬបំភ្លឺពីលក្ខខណ្ឌនៃកម្ចី។ ឯកសារទាំងនេះត្រូវរក្សាទុកជាប្រចាំ ឬ យ៉ាងហោចណាស់ក៏រហូតដល់ពេលដែលការទូទាត់សងបំណុលត្រូវបានចប់សព្វគ្រប់(រយៈពេលសងកម្ចីរបស់ធនាគារពិភពលោកនិងធនាគារអភិវឌ្ឍន៍អាស៊ីមានថេរៈវេលាចំនួន ៤០ ឆ្នាំ)។

ទីពីរ-បញ្ជីឯកសារទីពីរ គឺសំណុំលិខិតឆ្លងឆ្លើយ របាយការណ៍ស្តីពីស្ថានភាពបំណុល លិខិតជូនព័ត៌មាន ពីកាលបរិច្ឆេទត្រូវសងបំណុល ។ល។ ឯកសារទាំងនេះត្រូវមានចំណាត់ថ្នាក់ជាកម្រងឯកសារប្រចាំឆ្នាំ ដែលត្រូវ មានប័ណ្ណសារសម្រាប់រយៈពេល ៣ ទៅ ៤ ឆ្នាំ។

## គ. កម្ចីឯកជនធានាដោយរដ្ឋ

កម្ចីឯកជនដែលរដ្ឋធានាត្រូវតែតាមដានត្រួតពិនិត្យដោយអង្គភាពគ្រប់គ្រងបំណុល ដូចកម្ចីធម្មតាដែរ៖ ដោយមានលេខកូដ និង មានឯកសារសម្រាប់កម្ចីនីមួយៗ។ ក៏ប៉ុន្តែ ព័ត៌មានញក់ព័ន្ធនឹងកម្ចីនេះ (ការបើកផ្តល់កម្ចី ការទូទាត់សងការប្រាក់ ឬ ដើមបំណុល) មិនត្រូវបានផ្តល់អាយេអង្គភាពដោយផ្ទាល់ទេ។ ព័ត៌មានទាំង នេះត្រូវទទួលយកពីសហគ្រាស ដែលទទួលកម្ចីទាំងនេះផ្ទាល់។

## ឃ. ការតាមដានការបើកផ្តល់កម្ចី

អង្គភាពត្រូវតាមដានការបើកផ្តល់កម្ចីជារៀងរាល់ថ្ងៃ ឬ យ៉ាងហោចណាស់ក៏ជារៀងរាល់ខែដែរ។ អង្គភាពគ្រប់គ្រងបំណុលត្រូវកំណត់នូវទឹកប្រាក់សរុបដែលនៅសល់សម្រាប់កម្ចីនីមួយៗ (កម្ចីដែលសន្យា-ការបើកផ្តល់)។ ទឹកប្រាក់ និង កាលបរិច្ឆេទនៃការបើកផ្តល់កម្ចីមានសារសំខាន់ណាស់ ដើម្បីគណនារកការប្រាក់ដែលត្រូវសងទៅឥណទាយក។

ការតាមដានការបើកផ្តល់កម្ចី គឺជាភារកិច្ចមួយដ៏សំខាន់ និង ដ៏លំបាកផងដែររបស់អង្គភាព។ ចំនួន និងការបរិច្ឆេទការសងក៏មានភាពចាំបាច់ផងដែរ ដើម្បីធ្វើការគណនាការប្រាក់ដែលត្រូវឱ្យទៅឱ្យអ្នកឱ្យខ្ចី។ ការត្រួតពិនិត្យការសង គឺជាការងារទាមទារបំផុតមួយ ដោយសាតែបញ្ហានេះមានលក្ខណៈខុសគ្នាទៅតាមប្រភេទកម្ចី៖

- កម្ចីជាសាច់ប្រាក់ (ការសងត្រូវធ្វើជាសាច់ប្រាក់)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ឥណទានសម្រាប់ការនាំចេញ (កម្ចីសម្រាប់នាំចូលទំនិញ)
- កម្ចីសម្រាប់ទំនិញ (កម្ចីសម្រាប់នាំចូលជំនួយ)
- កម្ចីសម្រាប់គម្រោង។

*១.កម្ចីបើកផ្តល់សាច់ប្រាក់*

កម្ចីបើកផ្តល់ជាសាច់ប្រាក់ងាយស្រួលនឹងគ្រប់គ្រង ដោយសារតែការបើកផ្តល់ត្រូវបានធនាគារបានកត់ត្រាទុកយ៉ាងលម្អិត និង មានព័ត៌មានច្បាស់លាស់ (ឧទាហរណ៍ ឥណទានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ)។

*២.ឥណទានសម្រាប់ការនាំចេញ*

ធនាគារបរទេសផ្តល់ឥណទានដល់អ្នកទិញកម្ពុជា ដើម្បីអោយអ្នកទិញនោះអាចសងជាសាច់ប្រាក់ដល់អ្នកផ្គត់ផ្គង់របស់ខ្លួន (ជាទូទៅគឺជាក្រុមហ៊ុននៃប្រទេសដែលធនាគារនោះស្ថិតនៅ)។ ប្រការនេះគេហៅថា ឥណទានអ្នកទិញ (Buyer credit)។ ការប្រមូលទិន្នន័យមានលក្ខណៈស្មុគ្រស្មាញ។ កាលបរិច្ឆេទនៃការបើកផ្តល់កម្ចី គឺជាកាលបរិច្ឆេទនៃផ្គង់ផ្គង់ទំនិញ ឬ សេវា។ ជាញឹកញយ អង្គភាពគ្រប់គ្រងបំណុលមិនបានទទួលព័ត៌មានអំពីការផ្គត់ផ្គង់នេះទេ។ អង្គភាពត្រូវទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុន ដែលទទួលបាននូវការផ្គត់ផ្គង់ទំនិញ និង សេវានេះ។ អ្នកផ្គត់ផ្គង់បរទេសអាចស្នើសុំដោយផ្ទាល់ អោយធនាគារផ្តល់ឥណទានអោយខ្លួន ដែលក្នុងករណីនេះ ហៅថា ឥណទានអ្នកលក់ (Seller credit)។ អ្នកផ្គត់ផ្គង់ត្រូវកំណត់នូវលក្ខខណ្ឌទូទាត់ដល់អ្នកទិញកម្ពុជា ដែលត្រូវទូទាត់នៅពេលក្រោយ។ អ្នកផ្គត់ផ្គង់ខ្លួនឯងក៏អាចផ្តល់ឱ្យអ្នកទិញកម្ពុជានូវលទ្ធភាពទូទាត់នៅពេលក្រោយដោយមិនចាំបាច់ទៅរកឥណទានពីធនាគារ។

*៣. ឥណទានតាមរយៈការនាំចូលទំនិញ*

ជាញឹកញយ ឥណទាយកផ្តល់ឥណទានជាទំនិញ ដែលត្រូវនាំចូលយកមកលក់នៅក្នុងប្រទេសកម្ពុជា។ ការលក់នេះទទួលបានជាសាច់ប្រាក់បដិភាគ ត្រូវត្រូវបានយកមកធ្វើជាជំនួយទ្រទ្រង់ថវិកាសម្រាប់រាជរដ្ឋាភិបាល។ អង្គភាពគ្រប់គ្រងបំណុលត្រូវទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយស្ថាប័នទទួលបន្ទុកអនុវត្តនូវការធ្វើហិរញ្ញប្បទានបែបនេះ។

*៤. ឥណទានគម្រោង*

ជាទូទៅ អង្គភាពគ្រប់គ្រងបំណុលអាចប្រមូលទិន្នន័យ ពីការបើកផ្តល់កម្ចីពីអង្គភាពគ្រប់គ្រងគម្រោង ឬ អង្គភាពអនុវត្តគម្រោង ដែលត្រូវបានបង្កើតនៅតាមក្រសួង ដែលទទួលនូវគម្រោងទាំងនោះ។

ចំពោះកម្ចីរបៀបនេះមាននីតិវិធីចំនួន៣ប្រភេទក្នុងការបើកផ្តល់កម្ចី។ ចាំបាច់ត្រូវបញ្ជាក់អាយេបានច្បាស់ក្នុងករណីនីមួយៗ នូវកាលបរិច្ឆេទនៃការបើកផ្តល់កម្ចី ដែលត្រូវកត់ត្រាទុកក្នុងតារាងគ្រប់គ្រងបំណុលៈ

- ក្នុងករណីនៃការអនុវត្តនូវនីតិវិធីទូទាត់ដោយផ្ទាល់ ឥណទាយកទូទាត់ត្រង់ដោយផ្ទាល់អោយអ្នកផ្គត់ផ្គង់ ហើយការទូទាត់នេះត្រូវបានចាត់ទុកថាជាការបើកផ្តល់កម្ចី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ក្នុងករណីនៃការអនុវត្តនូវនីតិវិធីបុរេប្រទាន ឥណទាយកបើកផ្ដល់បុរេប្រទានដល់អ្នកផ្គត់ផ្គង់ក្នុងគណនី ដែលគ្រប់គ្រងដោយ អង្គភាពអនុវត្តគម្រោង។ អង្គភាពអនុវត្តគម្រោង ចាប់ផ្ដើមបញ្ជាទិញទូទាត់អ្នកផ្គត់ផ្គង់ ហើយបន្ទាប់មកទើបទាមទារអោយទូទាត់បុរេប្រទាន។ ការបើកផ្ដល់កម្ចី គឺជាកាលបរិច្ឆេទនៃការ ទូទាត់បុរេប្រទាន។

ជារួម ការបើកផ្ដល់កម្ចី គឺជាកាលបរិច្ឆេទបើកផ្ដល់កម្ចី ក្នុងនាមឥណាយិក។ ឥណទាយករៀបចំតារាងស្ថានភាពបើកផ្ដល់កម្ចីជារៀងរាល់ខែ ដើម្បីផ្ញើទៅអោយអង្គភាពគ្រប់គ្រងបំណុល។

### ២៣.២.២.២. *ការតាមដានត្រួតពិនិត្យការទូទាត់សេវាបំណុល*

ការទទួលខុសត្រូវមួយដ៏សំខាន់របស់អង្គភាពគ្រប់គ្រងបំណុល គឺការធានានូវការទូទាត់សេវាបំណុល (ការប្រាក់ និង ប្រាក់ដើម) អោយបានទាន់ពេលវេលា។

- ឥណទាយកត្រូវផ្ដល់ព័ត៌មានស្ដីពីកាលបរិច្ឆេទសងបំណុល ទៅឱ្យអង្គភាពគ្រប់គ្រងបំណុល។
- ទោះបីជាឥណទាយកមានភារកិច្ចក្នុងការផ្ដល់ព័ត៌មានស្ដីពីកាលបរិច្ឆេទសងបំណុលក្ដី ក៏អង្គភាពគ្រប់គ្រងបំណុល នៅតែមានកាតព្វកិច្ចក្នុងការត្រួតពិនិត្យកាលបរិច្ឆេទសងបំណុលដដែល។ អង្គភាពត្រូវ ទំនាក់ទំនងជាមួយឥណទាយក ប្រសិនបើគេមិនបានទទួលព័ត៌មានស្ដីពីកាលបរិច្ឆេទសងបំណុលទេនោះ យ៉ាងហោចណាស់ មួយខែមុនពេលដែលត្រូវទូទាត់។
- អង្គភាពគ្រប់គ្រងបំណុលទទួលខុសត្រូវក្នុងការរៀបចំអាណត្តិបើកប្រាក់ ដាក់អាណត្តិបើកប្រាក់ឆ្លងថ្នាក់ដឹកនាំ និង អនុវត្តនូវនីតិវិធីដើម្បីផ្ទេរប្រាក់ទៅឱ្យធនាគារជាតិនៃកម្ពុជា។
- អង្គភាពគ្រប់គ្រងបំណុលត្រូវកត់ត្រានូវប្រតិបត្តិការខាងលើនេះ នៅក្នុងប្រព័ន្ធគណនេយ្យរបស់ ខ្លួនពីពេលចេញអាណត្តិបើកប្រាស់ ដល់ពេលទូទាត់។
- អង្គភាពត្រូវផ្ទៀងផ្ទាត់ជាប្រចាំនូវការកត់ត្រាបញ្ជីគណនេយ្យនៃកម្ចីនីមួយៗ ជាមួយនឹងព័ត៌មានដែលទទួលបានពីឥណទាយក។

នីតិវិធីថវិកាក្នុងការទូទាត់សេវាបំណុល គឺជានីតិវិធីសាមញ្ញ។ នៅក្នុងនីតិវិធីធម្មតានៃការត្រួតពិនិត្យចំណាយថវិកា គេត្រូវឆ្លងឯកសារពីរដងដើម្បីឱ្យមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុផ្ដល់ទិដ្ឋាការ៖ លើកទីមួយ មុនពេលធានាចំណាយ ដើម្បីបញ្ជាក់ពីភាពទំនេរនៃឥណទានថវិកា និង លើកទីពីរ នៅពេលផ្ដល់ទិដ្ឋាការលើអាណត្តិបើកប្រាក់។

ចំពោះនីតិវិធីនៃការទូទាត់សេវាបំណុលវិញ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុផ្ដល់ទិដ្ឋាការលើអាណត្តិតែមួយលើកប៉ុណ្ណោះ។ ជាការពិត ឥណទានថវិកាសម្រាប់ការទូទាត់សេវាបំណុល គឺជាប្រភេទឥណទានដែលវាយតម្លៃបាន គឺ មិនមែនជាឥណទានមានកំហិតដូចឥណទានថវិកាចរន្តទូទៅឡើយ។ ទោះបីជាគ្មានឥណទានថវិកាក៏ដោយ ក៏គេត្រូវតែទូទាត់បំណុលដែរ នៅពេលដែលបំណុលនោះដល់ពេលត្រូវសងដោយសារតែចំណាយនេះ ជាប្រភេទចំណាយចាំបាច់។ ដូច្នេះ ការទូទាត់សេវាបំណុលអាចអនុវត្តលើសពីឥណទានថវិកាដែលមាន។ ក៏ប៉ុន្តែ ដើម្បីឱ្យការអនុវត្តថវិកាប្រព្រឹត្តទៅប្រកបដោយតុល្យភាព នៅពេលដែលអស់ឥណទាន ចាំបាច់ត្រូវផ្ទេរឥណទានថវិកាពីមុខសញ្ញាចំណាយផ្សេង ដើម្បីយកមកបំពេញឥណទានថវិកាសម្រាប់សេវាបំណុល។

មូលហេតុមួយទៀត គឺការទូទាត់ចំណាយការប្រាក់ និង ចំណាយទូទាត់ប្រាក់ដើម មិនមែនជាការធានាចំណាយថ្មីឡើយ។ តាមទិដ្ឋភាពគតិយុត្តិ ការធានាចំណាយចាប់ផ្តើមនៅពេលដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចី។ ដូច្នេះ កាតព្វកិច្ចដែលបង្កើតឡើងដោយកិច្ចសន្យាកម្ចី មិនមែនការធានា ចំណាយថ្មីឡើយ។

ទោះបីជាចំណាយទូទាត់សេវាការប្រាក់និងទូទាត់ប្រាក់ដើមអាចអនុវត្តលើសពីឥណទានដែលមានក៏ដោយ ឥណទានថវិកាសម្រាប់ការទូទាត់បំណុលត្រូវតែប្រើប្រាស់ដោយប្រុងប្រយ័ត្ន និង ដោយយកចិត្តទុកដាក់បំផុត។

ជាបឋម ឥណទាននេះត្រូវតែប៉ាន់ស្មានអោយបានត្រឹមត្រូវ និង ដាក់លាក់នៅពេលរៀបចំថវិកា។ អង្គភាពគ្រប់គ្រងបំណុលជាអ្នកទទួលខុសត្រូវដោយផ្ទាល់ ក្នុងការប៉ាន់ស្មានឥណទានថវិកាសម្រាប់ទូទាត់បំណុល ដោយសារអង្គភាពមានទិន្នន័យគណនេយ្យទាំងអស់ សម្រាប់ការប៉ាន់ស្មានចំណាយប្រភេទនេះអោយបានត្រឹមត្រូវ។

ទោះបីជាឥណទានថវិកាសម្រាប់ទូទាត់បំណុលមិនគ្រប់គ្រាន់ក៏ដោយ ការទូទាត់បំណុលត្រូវតែអនុវត្ត។ ក៏ប៉ុន្តែ ការអនុវត្តលើសពីឥណទានថវិកាដែលមាន នាំអោយថវិកាបាត់បង់នូវតុល្យភាព។ ក្នុងករណីនេះ អង្គភាពត្រូវស្នើសុំរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបង្កើនឥណទានថវិកាសម្រាប់ទូទាត់បំណុល តាមរយៈការផ្ទេរឥណទានថវិកាពីជំពូកផ្សេង ឬ ត្រូវពិនិត្យឡើងវិញនូវចំណាយថវិកា តាមរយៈការរៀបចំ និង ការអនុម័តនូវច្បាប់ស្តីពីហិរញ្ញវត្ថុកែតម្រូវ។

អង្គភាពគ្រប់គ្រងបំណុលមិនត្រូវចាត់ទុកថាភារកិច្ចរបស់ខ្លួនចប់សព្វគ្រប់ នៅពេលដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចុះហត្ថលេខាលើអាណត្តិបើកប្រាក់ហើយនោះទេ។ អង្គភាពត្រូវតាមដានឯកសារនោះ រហូតដល់ពេលដែលធនាគារជាតិនៃកម្ពុជាធ្វើការទូទាត់ តាមបញ្ជារបស់រតនាគារជាតិ (ឬ តាមបញ្ជារបស់នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិ)។ អគ្គនាយកដ្ឋានរតនាគារជាតិ និង នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការអន្តរជាតិ ត្រូវចាត់ទុកថាការទូទាត់សេវាបំណុល គឺជាអាទិភាពធំជាងគេបំផុត បើប្រៀបធៀបទៅនឹងចំណាយផ្សេងៗទៀត។

ការទូទាត់សេវាបំណុលអោយបានទាន់ពេលវេលានឹងជួយពង្រឹងកិត្យានុភាព និង ភាពគួរអោយទុកចិត្តបានរបស់ប្រទេសដែលខ្ចីប្រាក់នៅចំពោះមុខដៃគូអភិវឌ្ឍន៍។ផ្ទុយទៅវិញការទូទាត់បំណុលដោយយឺតយ៉ាវនឹងធ្វើអោយដៃគូអភិវឌ្ឍន៍បាត់ជំនឿ និង ធ្វើឱ្យការចរចាដើម្បីទទួលបាននូវបំណុលថ្មីនឹងមានភាពស្មុគ្រស្មាញជាងមុន។ ការយឺតយ៉ាវក្នុងការទូទាត់បំណុលអាចនាំឱ្យឥណទាយកព្យួរការបើកផ្តល់កម្ចី។ ប្រការនេះនឹងត្រូវធ្វើឱ្យការអនុវត្តគម្រោងមានការយឺតយ៉ាវ។

## ២៣.២.៣. មុខងារគណនីនៃអង្គភាពគ្រប់គ្រងបំណុល

មុខងារគណនេយ្យញក់ព័ន្ធទៅនឹងមុខងាររដ្ឋបាល ដែលយើងបានសិក្សាពីពេលមុនមក។ មុខងារគណនេយ្យទាមទារអោយកត់ត្រានូវទិន្នន័យមួយចំនួន តាមលំដាប់លំដោយនៃកាលបរិច្ឆេទ លើឯកសារកម្ចីនីមួយៗ ដើម្បីអាចអោយអង្គភាពប្ញកសរុបនូវស្ថានភាពបំណុល ដែលឥណាយិកជំពាក់ឥណទាយក ក៏ដូចជាស្ថានភាពនៃការអនុវត្តនីតិវិធីទូទាត់ការប្រាក់ និង/ឬ ប្រាក់ដើមនៃបំណុល។

ការកត់ត្រានេះ មិនមែនជាការចុះកិច្ចបញ្ជិការគណនី តាមវិធានគណនីទ្វេភាគឡើយ ដោយគ្រាន់តែចុះកិច្ចបញ្ជីកាគណនី តាមវិធានគណនីឯកកត្តភាគជាការស្រេច។ ឯកសារកម្ចីអាចជាឯកសារក្រដាស ដែលអាចបំពេញដោយដៃ ឬ មួយជាឯកសារគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា។

នៅលើកដំបូង នៅពេលដែលកម្ចីមានចំនួនតិច យើងអាចប្រើវិធីកត់ត្រាដោយដៃលើឯកសារកម្ចីនីមួយៗ ដោយមិនចាំបាច់ប្រើប្រាស់នូវកម្មវិធីកុំព្យូទ័រស្មុគស្មាញ។ ការកត់ត្រាដោយដៃ ក៏ជាវិធីមួយដែលគួរអនុវត្តនៅពេល ដែលអង្គភាពចាំផ្ដើមដាក់អាយេអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងបំណុល តាមប្រព័ន្ធព័ត៌មានវិទ្យា។ ជារួម ការងារគ្រប់គ្រងបំណុល គឺជាការងារដែលត្រូវធ្វើបណ្ដើរ រៀនសូត្របណ្ដើរ។ ការកត់ត្រាលើឯកសារកម្ចីនីមួយៗ ទោះបីជាប្រើប្រាស់របៀបកត់ត្រាដោយដៃ ឬ ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងដោយព័ត៌មានវិទ្យាក៏ដោយ ក៏អាចជួយសម្រួលដល់ការរៀបចំរបាយការណ៍ស្ដីពីស្ថានភាពបំណុលរបស់ប្រទេសផងដែរ ។

### ២៣.២.៤. មុខងារស្ថិតិនៃអង្គភាពគ្រប់គ្រងបំណុល

ការត្រួតពិនិត្យតាមដានការបំណុលយ៉ាងលម្អិត និង មានលក្ខណៈខ្ជាប់ខ្ជួន អាចអោយអង្គភាពគ្រប់គ្រងបំណុលរៀបចំបានយ៉ាងងាយស្រួល នូវទិន្នន័យ និង ស្ថិតិស្ដីពីស្ថានភាពបំណុលរបស់ព្រះរាជាណាចក្រកម្ពុជា ដោយមានការវិភាគជាអនុបាទ ឬ ក្រាហ្វិកផ្សេងៗ។

## ២៣.៣. ក្លឹបទីក្រុងប៉ារីស និង ការចរចាបំណុលឡើងវិញ

វិបត្តិបំណុលនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ជាពិសេសនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប គឺជាបញ្ហាមួយដ៏សំខាន់នៃការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងពិភពលោក នៅក្នុងអំឡុងពេលបួនទស្សវត្សចុងក្រោយនេះ។ ដើម្បីប្រឈមមុខនឹងវិបត្តិបំណុល ដែលតែងតែកើតឡើងជារឿយៗនៅក្នុងប្រទេសឥណាយិក ប្រទេសឥណទាយកបានរៀបចំនូវវេទិកាសំខាន់ៗចំនួនពីរ គឺៈ

**ទីមួយ-ក្លឹបទីក្រុងប៉ារីស** ដែលប្រមូលផ្ដុំឥណទាយកសាធារណៈ (រដ្ឋ និង នីតិបុគ្គលនៃនីតិសាធារណៈ) ដែលបានផ្ដល់កម្ចីអោយរដ្ឋ ឬ អោយនីតិបុគ្គលនៃនីតិសាធារណៈ ឬ អោយសហគ្រាសឯកជនដោយមានការធានារបស់រដ្ឋ។

**ទីពីរ-ក្លឹបទីក្រុងឡុងដ៍** ដែលប្រមូលផ្ដុំឥណទាយកឯកជន (ធនាគារពាណិជ្ជ) ដែលផ្ដល់កម្ចីអោយរដ្ឋ ឬ អោយនីតិបុគ្គលនៃនីតិសាធារណៈ ឬ អោយសហគ្រាសឯកជន ដោយមានការធានារបស់រដ្ឋ។

ក្លឹបទាំងពីរនេះ ដែលជាឥណទាយកសាធារណៈ និង ឯកជន ទាមទារអោយប្រទេសឥណាយិកចុះកិច្ចព្រមព្រៀងជាបឋមជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ។

ក្លឹបទីក្រុងប៉ារីស មិនមែនជាអង្គការផ្លូវការទេ តែជាក្រុមក្រៅផ្លូវការនៃប្រទេសឥណទាយក ដែលជួបជុំគ្នានៅទីក្រុងប៉ារីសមួយដង ក្នុងមួយខែជាមធ្យម ដើម្បីពិនិត្យបញ្ហាចរចាឡើងវិញនូវបំណុលក្រៅប្រទេសរបស់ប្រទេសឥណាយិក ដែលដាក់ពាក្យស្នើសុំធ្វើការចរចាបំណុលឡើងវិញ។

ក្លឹបទីក្រុងប៉ារីស គ្មានមូលដ្ឋានគតិយុត្តិ ឬ វិធានសម្រាប់ទទួលសមាជិក ហើយក៏គ្មានរចនាសម្ព័ន្ធស្ថាប័ន ឬ គ្មានបុគ្គលិកអ្វីឡើយ។ ក្លឹបទីក្រុងប៉ារីសជួបប្រជុំក្រោមអធិបតីភាពរបស់អគ្គនាយករតនាគារ

បារាំង។ ការិយាល័យនៃរតនាគារបារាំងត្រូវបានតែងតាំង ជាលេខាធិការដ្ឋាននៃក្លឹបប៉ារីស។ ប្រទេសឥណាយិកជាច្រើន បានមកក្លឹបប៉ារីសជាច្រើនដង។ ក្លឹបប៉ារីសបានធ្វើការចរចាឡើងវិញនូវបំណុល ដែលធ្លាប់ចរចាឡើងវិញរួចមកហើយ។

សមាជិកអចិន្ត្រៃយ៍នៃក្លឹបទីក្រុងប៉ារីស មានប្រទេស អាទ្បីម៉ាញ អូស្ត្រាលី អូទ្រីស បែលហ្ស៊ិក កាណាដា ដាណឺម៉ាក អេស្ប៉ាញ សហរដ្ឋអាមេរិក ហ្វាំងឡង់ បារាំង អៀឡង់ អ៊ីតាលី ជប៉ុន ន័រវ៉េ ហូឡង់ អង់គ្លេស ស៊ុយអែត និង ស្វីស។ ក្លឹបទីក្រុងប៉ារីស មិនមែនបិទទ្វារមិនទទួលសមាជិកថ្មីឡើយ ហើយសមាជិកមិនមែនសុទ្ធតែជាប្រទេសឧស្សាហកម្មជឿនលឿនទេ។ ប្រទេសកំពុងអភិវឌ្ឍខ្លះ ដែលជាឥណទាយកធ្លាប់បានចូលរួមក្នុងអង្គប្រជុំនៃក្លឹបទីក្រុងប៉ារីស រួចមកហើយ។ ប្រទេសរុស្ស៊ីបានចូលជាសមាជិកនៃក្លឹបទីក្រុងប៉ារីស នៅក្នុងឆ្នាំ ១៩៩៧ ជាប្រទេសឥណទាយក បន្ទាប់ពីបានចូលរួមការចរចា ក្នុងឋានជាប្រទេសឥណាយិករួចមក។

ម្យ៉ាងវិញទៀត ក្លឹបទីក្រុងប៉ារីស បើកទ្វារសម្រាប់ស្ថាប័នរូបិយវត្ថុពហុភាគី ដែលមានការពាក់ព័ន្ធ។ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិបានធ្វើការវិភាគពីកម្មវិធីកំណែតម្រូវរចនាសម្ព័ន្ធ និង ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសឥណាយិក។ ធនាគារពិភពលោកបានវាយតម្លៃពីប្រសិទ្ធភាពនៃគោលនយោបាយវិនិយោគ វិធានការតាមផ្នែក និង ទស្សនវិស័យរយៈពេលមធ្យម និង រយៈពេលវែង។ ធនាគារក្នុងតំបន់ដើម្បីអភិវឌ្ឍន៍ អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅអ៊ឺរ៉ុប គណៈកម្មាធិការនៃសហគមន៍អ៊ឺរ៉ុប និង សន្និសិទអង្គការសហប្រជាជាតិដើម្បីពាណិជ្ជកម្ម និង ការអភិវឌ្ឍ អាចចូលរួមក្នុងអង្គប្រជុំបាន និង ផ្តល់នូវមតិយោបល់របស់គេ។

ប្រទេសឥណាយិកតែងតែចាត់តាំងរដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុរបស់គេ អមដោយមន្ត្រីជំនាញ អោយចូលរួមប្រជុំជាតំណាង ដើម្បីពិភាក្សាករណីរបស់ប្រទេសនោះ។ កិច្ចប្រជុំត្រូវបានរៀបចំឡើងនៅទីក្រុងប៉ារីស តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្លឹបទីក្រុងប៉ារីស។ កិច្ចប្រជុំប្រព្រឹត្តទៅជាភាសាបារាំង និង អង់គ្លេស ដែលមានអ្នកបកប្រែភ្លាមៗពីភាសាមួយ ទៅភាសាមួយទៀត។

៩. បំណុលក្រៅប្រទេសរបស់កម្ពុជា

ក្លឹបទីក្រុងប៉ារីស បានជជែកពិភាក្សាលើករណីបំណុលក្រៅប្រទេសរបស់កម្ពុជា នៅថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៥ ។

### ២៣.៣.១. គោលការណ៍គ្រឹះ

- **គោលការណ៍កុងសង់ស៊ីស៖** រាល់សេចក្តីសម្រេចចិត្តត្រូវធ្វើឡើងជាឯកច្ឆ័ន្ទដែលមានន័យថា ត្រូវមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំង និង ត្រូវមានសុច្ឆន្ទៈពីគ្រប់អ្នកចូលរួម ដើម្បីសម្រេចបញ្ហាបាន។ ជាញឹកញយ កិច្ចព្រមព្រៀងស្តីពីលក្ខខណ្ឌនៃការចរចាបំណុលឡើងវិញត្រូវបានចុះហត្ថលេខានៅពេលថ្ងៃ។
- **គោលការណ៍ប្រព្រឹត្តកម្មដូចគ្នា៖** ការខិតខំប្រឹងប្រែងរបស់ប្រទេសឥណទាយក ដើម្បីចរចាបំណុលឡើងវិញ មិនត្រូវប្រើប្រាស់ដើម្បីកេងយកចំណេញពីឥណទាយកផ្សេងទៀតឡើយ។ ការខិតខំប្រឹងប្រែងនៃឥណទាយក ទាំងអស់ត្រូវធ្វើឡើងប្រហាក់ប្រហែលគ្នា។

### ២៣.៣.២. វិធាននៃកិច្ចដំណើរការ

វិធាននៃកិច្ចដំណើរការ គឺជាវិធានជាក់ស្តែង ដែលងាយស្រួលអនុវត្ត និង សម្របសម្រួលទៅតាមសេចក្តីត្រូវការនៃករណីនីមួយៗ មានសភាពហ្មឺងម៉ាត់ តែមានការវិវត្តឥតឈប់ឈរ។ ពីមួយឆ្នាំ ទៅមួយឆ្នាំ យើងសង្កេតឃើញថា វិធានទាំងនេះមានការវិវត្តជាវិជ្ជមានសម្រាប់ប្រទេសឥណាយិក។

### ២៣.៣.៣. ដំហាំនៃការកែតម្រូវរចនាសម្ព័ន្ធបំណុល

ការកែតម្រូវរចនាសម្ព័ន្ធបំណុលមិនគ្របដណ្តប់លើបំណុលទាំងអស់របស់ប្រទេសឥណទាយកឡើយ។ ក្លឹបនៃទីក្រុងប៉ារីសពិនិត្យតែសេវាបំណុលមួយផ្នែក ដែលប្រទេសមួយមិនអាចដោះស្រាយ នៅក្នុងដំណាក់កាលណាមួយនោះ ដែលហៅថាដំណាក់កាលកែតម្រូវរចនាសម្ព័ន្ធបំណុល។ ការកែតម្រូវរចនា-សម្ព័ន្ធបំណុលត្រូវបានអនុវត្តតែ ចំពោះដើមបំណុល ហើយប្រសិនបើចាំបាច់ ចំពោះការប្រាក់ដែលត្រូវសងនៅក្នុងរយៈពេលនោះ។ ដំណាក់កាលកែតម្រូវរចនាសម្ព័ន្ធបំណុល គឺជាដំណាក់កាលដែលត្រូវបើកដោយមានកិច្ចព្រមព្រៀងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ និង មានតែដំណាក់កាលនេះទេ ដែលមានការប្រែប្រួលៈ មួយឆ្នាំ ពីរឆ្នាំ ឬ លើសពីនេះ។ នៅក្នុងករណីនៃប្រទេសកម្ពុជា ដំណាក់កាលកែតម្រូវរចនាសម្ព័ន្ធបំណុលមានថេរវេលាចំនួនពីរឆ្នាំកន្លះ គឺចាប់តាំងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៥ ដល់ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៥។

គេអាចយកបំណុលរ៉ាំរ៉ៃដែលមានស្រាប់ នៅពេលចាប់ផ្តើមនៃដំណាក់កាលកែតម្រូវរចនាសម្ព័ន្ធបំណុល ដើម្បីយកមកចរចាឡើងវិញបាន។ ចំពោះករណីកម្ពុជា បំណុលដែលមិនទាន់បានសងទាំងអស់នៅត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានយកមកចរចាឡើងវិញ។

អត្រានៃការចរចាឡើងវិញតែងតែខុសគ្នា ពីប្រទេសមួយទៅប្រទេសមួយទៀត ដែលឆ្លុះបញ្ចាំងពីតម្រូវការជាក់ស្តែងក្នុងការធ្វើហិរញ្ញប្បទាន និង សមត្ថភាពសងរបស់ប្រទេសឥណទាយកដែលមានការពាក់ព័ន្ធ។

ការទូទាត់នៃបំណុលរយៈពេលខ្លីមិនត្រូវបានបញ្ចូលក្នុងការចរចាឡើងវិញទេ ដើម្បីទុកលទ្ធភាពអោយប្រទេសនោះ អាចស្វែងរកហិរញ្ញប្បទានថ្មីរយៈពេលខ្លី។ គោលការណ៍នេះត្រូវបានយកមកអនុវត្តផងដែរ ចំពោះបំណុលរយៈពេលវែង (ដែលមានរយៈពេលច្រើនជាងមួយឆ្នាំ) ហើយដែលកើតមានឡើងក្រោយកាលបរិច្ឆេទបិទបញ្ជី (Cut off date or date butoir)។ ឥណទានដែលផ្តល់មុន កាលបរិច្ឆេទបិទបញ្ជី នឹងត្រូវចរចាឡើងវិញទៅតាមលក្ខខណ្ឌនៃក្លឹបទីក្រុងប៉ារីស (ដែលមានលក្ខខណ្ឌសងសម្បទាន គឺរយៈពេលសងវែង ហើយការប្រាក់ទាប)។ ចំណែកឯឥណទានដែលផ្តល់ក្រោយ កាលបរិច្ឆេទបិទបញ្ជី នឹងត្រូវចរចាឡើងវិញតាមលក្ខខណ្ឌ របស់ ក្លឹបទីក្រុងប៉ារីស ដែលមានអត្រាការប្រាក់ទីផ្សារ និង ទៅតាមតារាងសងប្រាក់ដែលបានកំណត់។

គួរគូសបញ្ជាក់ថា មានតែបំណុលទ្វេភាគីប៉ុណ្ណោះ ដែលអាចចរចាឡើងវិញបាន។ ចំណែកឯ ឥណទានពហុភាគីដែលជាឥណទានផ្តល់ដោយមូលនិធិហិរញ្ញវត្ថុអន្តរជាតិ ឥណទានផ្តល់ដោយធនាគារពិភព-លោក និង ធនាគារអភិវឌ្ឍន៍អាស៊ី មិនអាចយកមកចរចាឡើងវិញបានឡើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ២៣.៣.៤. ប្រព្រឹត្តិកម្មនៃបំណុលដែលត្រូវចរចាឡើងវិញ

ប្រមុខរដ្ឋនៃប្រទេសអភិវឌ្ឍន៍ជឿនលឿន បានកំណត់នូវគោលការណ៍ធំៗនៃការចរចាឡើងវិញ ដែលរៀបចំឡើងនៅក្នុងឱកាសនៃជំនួបកំពូលជាច្រើនលើកមកហើយ។ នៅក្នុងឱកាសជំនួបកំពូលនៅទីក្រុងតូរ៉ុនតូ នៅក្នុងឆ្នាំ ១៩៩៨ ប្រមុខរដ្ឋទាំងនោះបានអនុម័តនូវប្រព្រឹត្តកម្មមួយសម្រាប់ ប្រទេសអភិវឌ្ឍយឺតបំផុត (ដែលជាប្រទេសដែលទទួលនូវកម្ចីសម្បទានពីធនាគារពិភពលោក) ។ ប្រទេសឥណទាយកអាចជ្រើសរើសជម្រើសមួយ ក្នុងចំណោមប្រព្រឹត្តកម្មចំនួន ៣ ដើម្បីដាក់នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគី៖

- ការលុបចោលមួយភាគបីនៃបំណុលដែលត្រូវចរចាឡើងវិញ
- ការកាត់បន្ថយអត្រាការប្រាក់
- ការបង្កើនរយៈពេលសងសេវាបំណុល រហូតដល់ ២៥ ឆ្នាំ ដែលក្នុងនោះ រយៈពេលអនុគ្រោះ (Grace period) មានចំនួន ១៤ ឆ្នាំ។

ជម្រើសខាងលើនេះត្រូវបានកែលម្អជាបន្តបន្ទាប់ តាមរយៈការអនុម័តនូវលក្ខខណ្ឌឡុងដ្រ៍ និង លក្ខខណ្ឌទ្រីនីដាត នៅក្នុងឆ្នាំ ១៩៩១ និង លក្ខខណ្ឌណាភើល (Naples Terms)នៅក្នុងឆ្នាំ ១៩៩៤។

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសទីមួយដែលទទួលបាននូវប្រព្រឹត្តកម្មបំណុលតាម លក្ខខណ្ឌណាភើល ដែលផ្តល់នូវ៖ ការលុបចោលបំណុលចំនួន ៧០% និង ការអនុវត្ត រយៈពេលសងសេវាបំណុល ៤០ ឆ្នាំ។

## ២៣.៤. ការពិពណ៌នាពីបំណុលសាធារណៈក្រៅប្រទេសរបស់កម្ពុជា

ទស្សនវិស័យនៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាអាស្រ័យ ក្នុងចំណែកមួយយ៉ាងធំ លើសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកៀងគរនូវធនធានក្នុង និង ក្រៅប្រទេស ដើម្បីធ្វើហិរញ្ញប្បទានការអភិវឌ្ឍ។ ការកៀរគរធនធានក្រៅប្រទេសត្រូវបានផ្តោតកាន់តែខ្លាំងឡើងលើកម្ចី។ ដូច្នេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបង្កើនការយកចិត្តទុកដាក់ លើការវាយតម្លៃនៃសមត្ថភាពសងបំណុលរបស់កម្ពុជា ដោយឈរលើមូលដ្ឋាននៃទំហំបំណុល និង សមត្ថភាពសេវាបំណុល។ ម្យ៉ាងវិញទៀត សមត្ថភាពសងបំណុលរបស់កម្ពុជាអាស្រ័យលើលទ្ធផលនៃការចរចា ដើម្បីដោះស្រាយបំណុលជាមួយសហព័ន្ធរុស្ស៊ី និង សហរដ្ឋអាមេរិក ជាពិសេសលក្ខខណ្ឌនៃការចរចាឡើងវិញ ដូចជា អត្រាការប្រាក់ រយៈពេលអនុគ្រោះ និង រយៈពេលសងសេវាបំណុល។

### ២៣.៤.១. ការវិភាគរចនាសម្ព័ន្ធបំណុល

នៅត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ទំហំនៃបំណុលសរុបរបស់កម្ពុជា ដោយរួមទាំង ការប្រាក់ទោសទ័ណ្ឌស្មើនឹង ៣,១៥ ពាន់លានដុល្លារ ឬ ៤៣,៣%នៃ ផលិតផលសរុបក្នុងស្រុក (ផសស)។ ឥណទាយកសំខាន់ពីររបស់កម្ពុជា គឺ សហព័ន្ធរុស្ស៊ី និង សហរដ្ឋអាមេរិក។ ក្រោយពីការចរចាឡើងវិញជាមួយឥណទាយកទាំងពីរ បំណុលក្រៅប្រទេសរបស់កម្ពុជានឹងត្រូវស្មើនឹង ២,១ ពាន់លានដុល្លារ ឬ ២៩% នៃ ផសស។

### ២៣.៤.១.១. បំណុលពហុភាគី

បំណុលដែលកម្ពុជាជំពាក់ឥណទាយកពហុភាគី (ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអន្តរជាតិដើម្បីការអភិវឌ្ឍកសិកម្ម និង អង្គការនៃប្រទេសនាំចេញប្រេង) មានចំនួន ១,១ ពាន់លានដុល្លារ ឬ ៥២% នៃបំណុលសរុប។ បំណុលទាំងនេះ ជាប្រភេទបំណុលសម្បទាន ដែលកម្ពុជាចាប់ផ្ដើមខ្ចីចាប់តាំងពីឆ្នាំ ១៩៩៣ មក ហើយចេះតែកើនឡើងជាលំដាប់។

បំណុលដែលកម្ពុជាជំពាក់ មូលនិធិរូបិយវត្ថុអន្តរជាតិ មិនបានគិតបញ្ចូលក្នុងការគិតគូខាងលើទេ។ កម្ចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ គឺសម្រាប់ទ្រទ្រង់ជញ្ជីងទូទាត់។ កម្ពុជាធ្លាប់អនុវត្តនូវកម្មវិធីជាមួយ នឹងមូលនិធិរូបិយវត្ថុអន្តរជាតិចំនួនបីលើក ដើម្បីទទួលបាននូវកម្ចី ដែលមានទឹកប្រាក់សរុបចំនួន ១០៣ លានដុល្លារ នៅក្នុងឆ្នាំ ២០០៣ ដែលជាឆ្នាំចុងក្រោយនៃការអនុវត្តគម្រោងជាមួយនឹងស្ថាប័ននេះ។

- កម្ចីដើម្បីបម្លែងប្រព័ន្ធសេដ្ឋកិច្ច (Systemic Transformation Facility-STE)- ដែលអនុម័តនៅក្នុង ខែតុលា ឆ្នាំ ១៩៩៣ ដែលមានទឹកប្រាក់ចំនួន ៦,២៥ លាន SDR ដែលមានការប្រាក់ចំនួន ៥,៧២%។
- កម្ចីដើម្បីពង្រឹងកំណែតម្រូវរចនាសម្ព័ន្ធសេដ្ឋកិច្ច (Enhanced Structural Adjustment Facility-ES-AF)- ដែលអនុម័តនៅក្នុង ខែ ឧសភា ឆ្នាំ ១៩៩៤ ដែលមានទឹកប្រាក់ចំនួន ៨៤ លាន SDR (ប្រមាណជា ១២០ លានដុល្លារអាមេរិក) ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកំណែតម្រូវរចនាសម្ព័ន្ធ និង កំណែទម្រង់សេដ្ឋកិច្ច ក្នុងរយៈពេល ៣ ឆ្នាំ។ កម្ចីនេះត្រូវបានចែកចេញជាបីដុំប្រចាំឆ្នាំ ដែលមានទឹកប្រាក់ក្នុងមួយឆ្នាំចំនួន ២៨ លាន SDR។ មកទល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦ មូលនិធិរូបិយវត្ថុអន្តរជាតិបានបើកផ្ដល់នូវទឹកប្រាក់ជាងពាក់ កណ្ដាលស្មើនឹង ៤២ លាន SDR (ប្រមាណ ជា ៦០ លានដុល្លារអាមេរិក)។ ដោយសារតែមានបញ្ហាក្នុង កំណែទម្រង់វិស័យព្រៃឈើ កម្ចីដែលនៅសល់ត្រូវបានលុបចោល។ លក្ខខណ្ឌនៃកម្ចីនេះ គឺ អត្រាការប្រាក់ សម្បទាន ០,៥% រយៈពេលសងសេវាបំណុលចំនួន ១០ ឆ្នាំ និង រយៈពេលអនុគ្រោះចំនួន ៥,៥ ឆ្នាំ។
- កម្ចីដើម្បីកាត់បន្ថយភាពក្រីក្រ និង កំណើន (Poverty Reduction and Growth Facility-PRGF)- ដែលអនុម័តនៅក្នុងឆ្នាំ ១៩៩៩ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់សម្រាប់ឆ្នាំ ១៩៩៩-២០០៣ ដោយមានអត្រាការប្រាក់សម្បទាន ០,៥% រយៈពេលសងសេវាបំណុលចំនួន ១០ ឆ្នាំ និង រយៈពេលអនុគ្រោះ ចំនួន ៥,៥ ឆ្នាំ។ កម្ពុជាបានឆ្លងកាត់នូវការពិនិត្យឡើងវិញនៃកម្មវិធី កម្ចីដើម្បីកាត់បន្ថយភាពក្រីក្រ និង កំណើននេះចំនួន ៦ លើក ហើយទទួលបានកម្ចីចំនួន ៥៨,៥ លាន SDR (៨០ លានដុល្លារអាមេរិក)។

ដោយសារតែកម្ចីនេះមានគោលដៅទ្រទ្រង់ជញ្ជីងទូទាត់ ធនាគារជាតិនៃកម្ពុជាជាស្ថាប័នដែលគ្រប់គ្រងកម្ចីនេះ ក្នុងគោលដៅពង្រឹងស្ថានភាពទុនបម្រុង ដើម្បីប្រើប្រាស់ជាមធ្យោបាយទូទាត់ជាមួយបរទេស។ ធនាគារជាតិនៃកម្ពុជាទទួលខុសត្រូវក្នុងការសងសេវាបំណុល និង ការប្រាក់។ ដូច្នេះ ចំណាយសេវាបំណុលដែលកម្ពុជាជំពាក់មូលនិធិរូបិយវត្ថុអន្តរជាតិ មិនបានបញ្ចូលក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុប្រចាំឆ្នាំឡើយ តែទិន្នន័យនេះត្រូវបានបញ្ចូលទៅក្នុងទិន្នន័យស្ថិតិបំណុល។

នៅក្នុងខែ មិថុនា ឆ្នាំ ២០០៥ ក្រុមប្រទេសឧស្សាហកម្មចម្រើនជឿនលឿនចំនួន ៨ (G-8) បានដាក់ចេញនូវសំណើអោយស្ថាប័នរូបិយវត្ថុអន្តរជាតិចំនួនបី គឺ មូលនិធិរូបិយវត្ថុអន្តរជាតិសមាគមអន្តរជាតិដើម្បីអភិវឌ្ឍន៍នៃធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាហ្វ្រិក លុបចោលទាំងស្រុងនូវបំណុលរបស់ប្រទេសដែលបានបំពេញតាមលក្ខខណ្ឌ ឬ ដែលនឹងបំពេញតាមលក្ខខណ្ឌនៃ «ការផ្តួចផ្តើមគំនិតប្រទេសក្រីក្រដែលជំពាក់បំណុលខ្លាំង» (Heavily Indebted Poor Country (HIPC) Initiative) ដែលគ្រប់គ្រងរួមគ្នាដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក។ «ការផ្តួចផ្តើមគំនិតប្រទេសក្រីក្រដែលជំពាក់បំណុលខ្លាំង» ត្រូវអនុវត្តដោយឈរលើមូលដ្ឋាននៃការអនុវត្តផែនការសកម្មភាពរួមគ្នារវាងប្រទេសញក់ព័ន្ធ និងស្ថាប័នរូបិយវត្ថុអន្តរជាតិ ដើម្បីឱ្យបំណុលនៃប្រទេសក្រីក្រដែលជំពាក់បំណុលខ្លាំងឈានទៅរកកម្រិតមួយដែល មានចីរភាព។ «ការផ្តួចផ្តើមគំនិតលុបចោលបំណុលពហុភាគី» (Multilateral Debt Relief Initiative -MDRI) គឺជាការផ្តួចផ្តើមគំនិត ដែលកាន់តែឈានមុខជាងគេ ដោយស្នើសុំអោយលប់ចោលនូវបំណុលទាំងស្រុង ដើម្បីអោយប្រទេសក្រីក្រ អាចយកធនធានពីការលុបបំណុលនេះ ទៅវិនិយោគដើម្បីសម្រេចបាននូវ «គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍» (MDG) ។

ដើម្បីទទួលបាននូវការលុបចោលបំណុលនេះ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ប្រទេសក្រីក្រនោះត្រូវមានកម្មវិធីជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ និង សម្រេចបាន នូវសមិទ្ធិផលល្អក្នុងវិស័យបីដូចខាងក្រោម៖ (១) គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច (២) ការអនុវត្តយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ និង (៣) ការគ្រប់គ្រងចំណាយថវិកា។ ក្រុមប្រឹក្សាភិបាលនៃមូលនិធិរូបិយវត្ថុអន្តរជាតិបានសម្រេចថា ប្រទេសក្រីក្រចំនួន ១៩ អាចទទួលបាននូវការលុបបំណុលចោលភ្លាមៗ ក្នុងក្របខ័ណ្ឌនៃ «ការផ្តួចផ្តើមគំនិតលុបចោលបំណុលពហុភាគី»។

នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៥ មន្ត្រីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិបានសម្រេចថាកម្ពុជាបានបំពេញតាមគ្រប់លក្ខណៈវិនិច្ឆ័យ ដូចបានថៃងខាងលើ ហើយអាចទទួលបាននូវការលុបបំណុលក្នុងក្របខ័ណ នៃ «ការផ្តួចផ្តើមគំនិតលុបចោលបំណុលពហុភាគី»។ ចាប់តាំងពីឆ្នាំ ១៩៩៩ មក កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ អតិផរណាទាប វឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រ កែលម្អការគ្រប់គ្រងចំណាយថវិកា និងបានអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការអនុវត្តនូវយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ។

នៅក្នុងខែ មករា ឆ្នាំ ២០០៦ ដោយអនុលោមតាម «ការផ្តួចផ្តើមគំនិតលុបចោលបំណុលពហុភាគី» មូលនិធិរូបិយវត្ថុអន្តរជាតិបានអនុម័តលុបចោលបំណុលដែលកម្ពុជាជំពាក់ខ្លួនមុនថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥ ទាំង ១០០ ភាគរយ ។ បំណុលទាំងអស់នេះដែលមានទឹកប្រាក់សរុបចំនួន ៨២ លានដុល្លារអាមេរិក នឹងត្រូវផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើនការវិនិយោគក្នុងគោលដៅសម្រេចអោយបាននូវ «គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍» (MDG) ។

### ២៣.៤.១.២. *បំណុលទ្វេភាគី*

បំណុលទ្វេភាគីភាគច្រើនជាបំណុលចាស់ ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងចរចាឡើងវិញជាមួយឥណនាយកចំនួនពីរ គឺ៖ សហព័ន្ធរុស្ស៊ី និង សហរដ្ឋអាមេរិក ។ បំណុលទ្វេភាគីត្រូវបានចែកចេញជា៖

- បំណុលចាស់ ដែលភាគច្រើនកំពុងតែចរចា៖ បំណុលដែលជំពាក់មុនឆ្នាំ ១៩៧៥ ជារូបិយប័ណ្ណ និង បំណុល ដែលខ្ចីនៅក្នុងអំឡុងទសវត្សរ៍ទី ៨០ ជាលុយរូបដែលអាចប្តូរបាន (Convertible rouble)។
- បំណុលទ្វេភាគីថ្មី ដែលកម្ពុជាខ្ចីក្រោយពេលចុះកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅក្នុងឆ្នាំ ១៩៩១។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ក. ឥណទាយកនៃក្លឹបទីក្រុងប៉ារីស

បំណុលជារូបិយប័ណ្ណដែលខ្ចីមុនឆ្នាំ ១៩៧៥ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាសិក្សា និង ស្រង់ជាតារាងយ៉ាងម៉ត់ចត់នៅក្នុងឆ្នាំ ១៩៩៤ ។ ដោយសារតែឯកសារបំណុលទាំងនេះត្រូវបានបំផ្លាញ នៅពេលដែលស្រុកមានសង្គ្រាម ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានស្នើសុំអោយឥណទាយកធំៗផ្ដល់នូវឯកសារ ដើម្បីបញ្ជាក់ពីបំណុលទាំងនេះ។ ប្រទេសចំនួនប្រាំបានឆ្លើយតបទៅនឹងសំណើរនេះ មាន សហរដ្ឋអាមេរិក បារាំង អាឡឺម៉ាញ ជប៉ុន និង អ៊ីតាលី។

នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៤ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជាបានផ្ញើលិខិតទៅប្រធានក្លឹបទីក្រុងប៉ារីស ដើម្បីស្នើសុំការកាត់បន្ថយបំណុលរបស់កម្ពុជា។ តំណាងនៃប្រទេសទាំងប្រាំខាងលើបានឆ្លើយតបទៅនឹងសំណើរនេះ និង បានកោះប្រជុំ នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ (តំណាងកម្ពុជាមិនបានចូលរួមប្រជុំទេ) ហើយបានសម្រេចថានឹងផ្ដល់អនុសាសន៍ដល់ប្រទេសរបស់ខ្លួន ដើម្បីលុបចោលនូវបំណុលរបស់កម្ពុជា តាមរយៈការចរចាបំណុលឡើងវិញ ឬ តាមរយៈបុនហិរញ្ញប្បទានតាមលក្ខខណ្ឌដូចតទៅ ៖

### ទីមួយ-ផែនអនុវត្តនៃការចរចាបំណុលឡើងវិញ៖

រាល់ការសងនូវដើមបំណុល ឬ ការប្រាក់នៃឥណទានពាណិជ្ជកម្ម ឬ ឥណទានរដ្ឋាភិបាល ដែលមានរយៈពេលជាងមួយឆ្នាំ ដែលផ្ដល់ជូនរាជរដ្ឋាភិបាលកម្ពុជា ឬ ផ្នែកសាធារណៈកម្ពុជា ឬ ដែលត្រូវបានផ្ដល់ការធានារបស់រដ្ឋ មុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៨៥ (កាលបរិច្ឆេទ បិទបញ្ជី-Cut off date) ៖

-បំណុលចំនួន ១០០ ភាគរយ ទាំងដើមបំណុល ទាំងការប្រាក់ មុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤។

-បំណុលចំនួន ១០០ ភាគរយ ទាំងដើមបំណុល ទាំងការប្រាក់ ដែលត្រូវសងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៥ ដល់ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៧។

ដូច្នេះ ផែនអនុវត្តនៃការចរចាបំណុលឡើងវិញនេះគ្របដណ្ដប់នូវបំណុលទ្វេភាគីជារូបិយប័ណ្ណទាំងអស់របស់កម្ពុជា លើកលែងតែបំណុលដែលពាក់ព័ន្ធនឹងឥណទានបីនៃសហរដ្ឋអាមេរិក។

### ទីពីរ-លក្ខខណ្ឌនៃការចរចាបំណុលឡើងវិញ៖

-**បំណុលពាណិជ្ជកម្ម** (ឥណទាយកពាក់ព័ន្ធ គឺ បារាំង និង អាឡឺម៉ាញ) ចំនួន ៦៧%ត្រូវបានលុបចោល និង ៣៣% ទៀតត្រូវសងក្នុងរយៈពេល ៤៦ ឆមាស (២៣ ឆ្នាំ) ដោយមានរយៈពេលអនុគ្រោះចំនួន ៦ ឆ្នាំ និង អនុលោមតាមតារាងសងបំណុលដែលមានអត្រាកើនឡើង ពី ០,១២%នៃដើម សម្រាប់កាលបរិច្ឆេទទីមួយ និង ៧,៩៦%នៃដើម សម្រាប់កាលបរិច្ឆេទចុងក្រោយ។ អត្រាការប្រាក់លើទឹកប្រាក់ដែលចរចាឡើងវិញនឹងត្រូវចរចា ជាទ្វេភាគី ដោយឈរលើមូលដ្ឋាននៃអត្រាទីផ្សារ។

-**កម្ចីជា «ជំនួយសាធារណៈដើម្បីអភិវឌ្ឍន៍»** (ឥណទាយក: សហរដ្ឋអាមេរិក បារាំង អាឡឺម៉ាញ និង ជប៉ុន)។ រយៈពេលសងសេវាបំណុលនៃបំណុលទាំងអស់ស្មើនឹង ៨០ ឆមាស (៤០ ឆ្នាំ) ដោយមានរយៈពេលអនុគ្រោះ ១៦ ឆ្នាំ និង អនុលោមតាមតារាងសងបំណុលដែលមានអត្រាកើនឡើង ពី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

០,៥៣%នៃដើម សម្រាប់កាលបរិច្ឆេទទីមួយ និង ៥,២៦%នៃដើម សម្រាប់កាលបរិច្ឆេទចុងក្រោយ។ អត្រាការប្រាក់លើទឹកប្រាក់ ដែលចរចាឡើងវិញនឹងត្រូវចរចា ជាទ្វេភាគី ក៏ប៉ុន្តែ យ៉ាងហោចណាស់ត្រូវតែមានលក្ខណៈអំណោយផល ដូចអត្រាការប្រាក់សម្បទានផងដែរ។

លក្ខខណ្ឌនៃការចរចាបំណុលឡើងវិញនេះគឺជាការអនុវត្តលើកទី ១ នូវ **លក្ខខណ្ឌណាភើល** (Naples Terms) ដែលប្រមុខរដ្ឋនៃប្រទេសឧស្សាហកម្មចម្រើនជឿនលឿន បានអនុម័តទៅទីក្រុង **ណាភើល** នៅក្នុង ឆ្នាំ ១៩៩៤ ដើម្បីលប់បំណុលប្រទេសកំពុងអភិវឌ្ឍ ហើយនៅពេលនោះត្រូវបានគេចាត់ទុកថាជាលក្ខខណ្ឌលុបចោលបំណុលដែលអនុគ្រោះជាងគេ។

ក្លឹបទីក្រុងប៉ារីសបានកំណត់នូវកាលបរិច្ឆេទបិទបញ្ជី ដើម្បីធានាអោយបាននូវការធានាការសងបំណុលនៅថ្ងៃអនាគត។ សម្រាប់កម្ពុជា កាលបរិច្ឆេទបិទបញ្ជី នេះត្រូវបានកំណត់យក ខែ ធ្នូ ឆ្នាំ ១៩៨៥។

បន្ទាប់ពីរដ្ឋាភិបាលទទួលយកនូវសំណើររបស់ឥណទាយកនៃក្លឹបទីក្រុងប៉ារីស ការចរចាទ្វេភាគីអាចចាប់ផ្តើមជាមួយប្រទេសឥណទាយកបាន។

*(ក) បារាំង*

បំណុលសាធារណៈដែលកម្ពុជាជំពាក់បារាំងមានប្រភពមកពីបារាំងបានផ្តល់ហិរញ្ញប្បទាន ដើម្បីសាងសង់នូវគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងអំឡុងទស្សវត្សរ៍ទី ៦០ ដូចជាការសាងសង់កំពង់ផែក្រុងព្រះសីហនុ ផ្លូវដែកពីភ្នំពេញទៅខេត្តព្រះសីហនុ និង ឧបករណ៍បំពាក់ផ្លូវដែកនោះ ការសាងសង់រោងចក្រចម្រាញ់ប្រេងកាតនៅខេត្តព្រះសីហនុ និង ការសាងសង់ទំនប់ព្រែកត្នោត ។ល។

ចាប់តាំងពីឆ្នាំ ១៩៧៥ មកដល់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលជាកាលបរិច្ឆេទចុងក្រោយដែលកំណត់ដោយក្លឹបទីក្រុងបារីស កម្ពុជាមិនបានទូទាត់បំណុលឡើយ ទាំងឥណទានអ្នកទិញ ទាំងឥណទានរដ្ឋាភិបាលបារាំង ដោយរួមទាំងកិច្ចព្រមព្រៀងចំនួន ៣ ដើម្បីចរចាបំណុលឡើងវិញ។ បំណុលទាំងអស់ដែលត្រូវចរចាឡើងវិញ សុទ្ធសឹងតែជាបំណុលដែលមិនបានសងទាំងអស់។

បន្ទាប់ពីគណប្រតិភូកម្ពុជាដែលបានទៅបំពេញបេកសកម្មនៅប្រទេសបារាំង បានពិនិត្យឯកសារដើមយ៉ាងល្អិតល្អន់រួចមក ការចរចាបានចាប់ផ្តើម និង ឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៥។ ភាគីបារាំងក៏បានសម្រេចលប់ចោលនូវបំណុលពាណិជ្ជកម្មចំនួន ៦៧% ស្មើនឹង ១០៧ លានហ្វ្រង់ ប្រមាណជា ២១ លានដុល្លារ។ ទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់បារាំងមានចំនួន ២១ លានដុល្លារ មកទល់នឹងចុងឆ្នាំ ២០០៦ នេះ។

*(ខ) អាឡឺម៉ាញ*

បំណុលដែលកម្ពុជាជំញក់អតីតសហព័ន្ធអាឡឺម៉ង់ (អាឡឺម៉ាញខាងលិច) ត្រូវបានលុបចោលទាំងស្រុង ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៩៤ មុនកិច្ចប្រជុំនៃក្លឹបទីក្រុងប៉ារីស។ បំណុលទាំងនេះកើតឡើងដោយធនាគារ KfW បានផ្តល់ឥណទានចំនួន ២៖ ឥណទានទីមួយផ្តល់ជូនធនាគារជាតិនៃកម្ពុជា និង ឥណទានទីពីរ ផ្តល់ជូនព្រះរាជអាយស្ម័យានកម្ពុជា ដោយមានការធានារបស់រដ្ឋ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បំណុលដែលកម្ពុជាជំពាក់អតីតសាធារណរដ្ឋប្រជាធិបតេយ្យអាឡឺម៉ង់ ដែលជាឥណទានប្រភេទពាណិជ្ជកម្ម ត្រូវបានកាត់បន្ថយ និង ចរចាឡើងវិញ ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី ៧ ខែ មិនា ឆ្នាំ ១៩៩៦ ដោយមានលក្ខខណ្ឌដូចតទៅ ៖

- ការផ្ទេរពីបំណុលជារូបប្តូរបាន (Convertible rouble) ចំនួន ១៥,៩ លានរូប អោយទៅជាបំណុលជាម៉ាកអាឡឺម៉ង់ ចំនួន ១០៨ ម៉ាក តាមអត្រា ១ ម៉ាក × ០,៦៨ រូប។
- ការលប់ចោលបំណុលចំនួន ៦៧%។
- ការកំណត់បំណុលឡើងវិញ (Rescheduling) នៃចំនួន ៣៣% ដែលនៅសល់ ដោយអនុលោមតាមលក្ខខណ្ឌនៃក្លឹបប៉ារីស ។
- អត្រាការប្រាក់ចំនួន ៤%។

ទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់សាធារណៈរដ្ឋសហព័ន្ធអាឡឺម៉ាញមានចំនួន ២១ លានដុល្លារ មកទល់នឹងចុងឆ្នាំ ២០០៦ នេះ។

*(គ) ជប៉ុន*

បំណុលដែលកម្ពុជាជំពាក់ជប៉ុនមានប្រភពមកពីការចុះកិច្ចព្រមព្រៀងកម្ចីពីរ លេខ CP-1 ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៦៩ និង CP-2 ចុះថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ១៩៧១ ដោយ Overseas Economic Cooperation Fund (OECF) ដើម្បីធ្វើហិរញ្ញប្បទានសាងសង់គម្រោងទំនប់វារីអគ្គីសនី និង ទំនប់ធារាសាស្រ្តព្រែកត្នោត។

ទឹកប្រាក់សរុបដែលកម្ពុជាជំពាក់ OECF គឺសុទ្ធសឹងតែជាបំណុលរាំរ៉ៃះ

- បំណុលជាប្រាក់ដើម និង ជាការប្រាក់ ពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩០ ដែលជាកាលបរិច្ឆេទចុងក្រោយ ស្មើនឹងទឹកប្រាក់សរុបចំនួន ១.៦១២,៦ លានយ៉េន
- ការប្រាក់ទោសទ័ណ្ឌដោយសារការខកខានមិនបានសងបំណុលខាងលើមានចំនួន ៨០៣,៣ លានយ៉េន
- ដូច្នេះទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់ជប៉ុន មានចំនួន ២.៤១៥,៩ លានយ៉េន ដែលស្មើនឹង ២៤ លានដុល្លារ។

បំណុលទាំងអស់ត្រូវបានដោះស្រាយរួចរាល់តាមរយៈកិច្ចព្រមព្រៀងចំនួនពីរលើក នៅខែ មេសា និង ខែ ឧសភា ឆ្នាំ ១៩៩៦ ដែលមានទឹកប្រាក់សរុបចំនួន ១៥,២ លានយ៉េន ឬ ១.៦១២,៦ លានយ៉េន។ ការទូទាត់នេះធ្វើ ឡើងតាមរយៈមូលនិធិថវិកាជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលធ្វើហិរញ្ញប្បទានដោយជំនួយឥតសំណងរបស់ប្រទេសជប៉ុន (ជំនួយជាទំនិញ) ។

ការប្រាក់ទោសទណ្ឌចំពោះការយឺតយ៉ាវមិនបានសងបំណុលចំនួន ៨០៣,៣ លានយ៉េន ត្រូវបានចរចាឡើងវិញ (Consolidation) និង ត្រូវបានកំណត់ឡើងវិញ (Rescheduling) ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងខែ តុលា ឆ្នាំ ១៩៩៦ តាមលក្ខខណ្ឌដូចតទៅះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- រយៈពេលសងសេវាបំណុលចំនួន ១៥ ឆ្នាំ ដែលមានរយៈពេលអនុគ្រោះចំនួន ៧ ឆ្នាំ។
- អត្រាការប្រាក់ ចំនួន ៣,៥%។

ទឹកប្រាក់សរុបនៃបំណុលទ្វេភាគីដែលកម្ពុជាជំពាក់ជប៉ុន ដែលសុទ្ធសឹងតែឥណទានផ្តល់ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ មានចំនួន ៨៣ លានដុល្លារ មកទល់ នឹងចុងឆ្នាំ ២០០៦ នេះ។

*(ឃ) អ៊ីតាលី*

បំណុលដែលកម្ពុជាជំញក់អ៊ីតាលីត្រូវបានដោះស្រាយក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីពីការកាត់បន្ថយ និង ការចរចាបំណុលឡើងវិញ តាមលក្ខខណ្ឌដូចតទៅ៖

- ការលុបចោលបំណុលចំនួន ៧០% ឬ ១,៥ លានដុល្លារ។
- ការកំណត់បំណុលឡើងវិញនូវទឹកប្រាក់ដែលនៅសល់ចំនួន ៣០% ដោយប្រើអត្រាការប្រាក់ចំនួន ០%។

ក្រោយពីបានកំណត់បំណុលឡើងវិញ បំណុលដែលកម្ពុជាជំពាក់អ៊ីតាលីទាំងអស់ស្មើនឹង ០,៥ លានដុល្លារ។

## ខ. បំណុលជារូបប្លូរចាន

បំណុលជា **រូបប្លូរចាន** (Convertible rouble) គឺជាប្រភេទបំណុលដែលកើតមកពីឥណទាន ដែលអតីតសហភាពសូវៀត និង ប្រទេសប្លុកខាងកើតបានផ្តល់ឱ្យកម្ពុជានៅក្នុងអំឡុងទស្សវត្សទី ៨០។ រាជរដ្ឋាភិបាលកម្ពុជាបាន និង កំពុងចរចាដោះស្រាយបំណុលដែលកម្ពុជាជំពាក់ប្រទេសនៃអតីតប្លុកលោកខាងកើត។

*រូបភាព២៣.១. លក្ខខណ្ឌនៃកិច្ចព្រមព្រៀង Naples*

*ក្នុងខែធ្នូ ឆ្នាំ១៩៩៤ ដោយប្រឈមមុខនឹងវិបត្តិបំណុលដែលកាន់តែអាក្រក់ទៅៗ ប្រទេសឥណទាយកបានដោះស្រាយបញ្ហាបន្ទាន់បំផុតនានា ដោយអនុម័តលក្ខខណ្ឌកិច្ចព្រមព្រៀង Naples។ ប្រទេសទទួលផល គឺជាប្រទេសដែលទទួលហិរញ្ញប្បទានអនុគ្រោះ IDA (ច្រកទ្វារកម្ចីមានការប្រាក់ទាបរបស់ ធនាគារពិភពលោក) និង មានចំណូលជាមធ្យមប្រចាំឆ្នាំក្នុងប្រជាជនម្នាក់ៗទាប (៧៥៥ដុល្លារ ឬ ទាប ជាង)។ ប្រសិនបើលក្ខខណ្ឌនេះត្រូវបានបំពេញ ឥណទាន ដែលមិនមែនជាជំនួយផ្លូវការសម្រាប់ការអភិវឌ្ឍត្រូវបានលុបចោលក្នុងកម្រិត៥០% ឬ ៦៧% (៦៧% ចាប់តាំងពីខែកញ្ញាឆ្នាំ១៩៩៩)។ សម្រាប់ឥណទានជាជំនួយផ្លូវការសម្រាប់ការអភិវឌ្ឍ បំណុលត្រូវបានពិនិត្យឡើងវិញឱ្យមានរយៈពេលជាង ៤០ឆ្នាំ រួមទាំងរយៈពេលអនុគ្រោះ ១៦ឆ្នាំ។*

*(ក) សាធារណរដ្ឋស្លូវ៉ាគី*

បំណុលដែលបរទេសជំពាក់អតីតសាធារណរដ្ឋសង្គមនិយមឆេកូស្លូវ៉ាគី ត្រូវបានបែងចែកជាពីរ៖ មួយភាគបីត្រូវបានបែងចែកអោយសាធារណរដ្ឋស្លូវ៉ាគី និង ពីរភាគបីត្រូវបានបែងចែកឱ្យសាធារណរដ្ឋឆែក។ ទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់សាធារណរដ្ឋស្លូវ៉ាគីស្មើនឹង ២៦៨.២៥៩ ដុល្លារ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*(ខ) សាធារណរដ្ឋឆែក*

ទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់សាធារណរដ្ឋឆែកត្រូវបានចរចាឡើងវិញ ហើយស្មើនឹង ៧៦៦.៥១៨ ដុល្លារ។

*(គ) ប៉ូឡូញ*

ទឹកប្រាក់សរុបនៃបំណុលដែលកម្ពុជាជំពាក់ប៉ូឡូញត្រូវបានចរចាឡើងវិញ ហើយស្មើនឹង ១.៩៥៥.៨១៩ រូប ឬ ១,៦ លានដុល្លារ តាមអត្រាប្តូរប្រាក់ ១ រូប × ០,៨ ដុល្លារ ។ ប្រទេសប៉ូឡូញបានសម្រេចបង្វែរបំណុលនេះ អោយទៅជាជំនួយដើម្បីជួសជុលព្រះបរមរាជវាំង។ រដ្ឋាភិបាលទាំងពីរបានចុះកិច្ចព្រមព្រៀង ដើម្បីប្រគល់ការងារអោយក្រុមហ៊ុនប៉ូឡូញមួយបំពេញការងារជួសជុលព្រះបរមរាជវាំង។

## គ. បំណុលកំពុងចរចា

*(ក) សហព័ន្ធរុស្ស៊ី*

បំណុលដែលកម្ពុជាជំពាក់រុស្ស៊ីមានប្រភពមកពីកិច្ចព្រមព្រៀងផ្តល់ឥណទានចំនួន ១៥ ដែលកម្ពុជាបានចុះ ជាមួយអតីតសហភាពសូវៀតចាប់តាំងពីឆ្នាំ ១៩៨០ ដល់ ឆ្នាំ ១៩៩០ ដែលត្រូវបានចរចាឡើងវិញក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៩១ រវាងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃសហភាពសូវៀត និង ធនាគារពាណិជ្ជកម្មក្រៅប្រទេសកម្ពុជា។ លក្ខខណ្ឌនៃការចរចាឡើងវិញមានដូចតទៅ៖

- ការទូទាត់ក្រោមរូបភាពជាការផ្គត់ផ្គង់ទំនិញ តាមការព្រមព្រៀងរវាងភាគីទាំងពីរ។ កម្ពុជាអាចជ្រើសរើសយកការទូទាត់ផ្សេងទៀត តាមការព្រមព្រៀងរវាងភាគីទាំងពីរ។
- រយៈពេលសងសេវាបំណុលមានចំនួន ២០ ឆ្នាំ ៖
  - ឆ្នាំ ១៩៩១ ចំនួន ៦២ លានរូប
  - ឆ្នាំ ១៩៩២ ចំនួន ៦៦ លានរូប
  - ពីឆ្នាំ ១៩៩៣ ដល់ ឆ្នាំ ២០០០ ចំនួន ៦៥ លានរូប
  - ពីឆ្នាំ ២០០០ ដល់ ឆ្នាំ ២០១១ ចំនួនពី ១៦ ដល់ ៤ លានរូប
- កិច្ចព្រមព្រៀងបានកំណត់ថាកាលបរិច្ឆេទឆ្នាំ ១៩៩១ អាចនឹងត្រូវចរចាឡើងវិញតាមការព្រមព្រៀងរវាងភាគីទាំងពីរ។
- កម្ចីនេះគ្មានការប្រាក់ឡើយ។

ក្រៅពីបំណុលដែលចរចាឡើងវិញនៅក្នុងឆ្នាំ ១៩៩១ រុស្ស៊ីបានផ្តល់ឥណទានពីរទៀតឱ្យកម្ពុជា៖

- បំណុលដែលមានប្រភពពីឥណទានក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីពីការអភិវឌ្ឍកិច្ចសហប្រតិបត្តិការក្នុងវិស័យផលិតផលកៅស៊ូធម្មជាតិ ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ១៩៨៣។

- ការប្រាក់ជំពាក់នៅក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៨៥។ បំណុលនេះត្រូវបានចរចាឡើងវិញរហូតដល់ឆ្នាំ ១៩៩១ ហើយត្រូវសងវិញជាការផ្គត់ផ្គង់កៅស៊ូធម្មជាតិ។

កម្ពុជា និង រុស្ស៊ីបានព្រមព្រៀងគ្នាថា ទឹកប្រាក់សរុបនៃបំណុលចរចាឡើងវិញស្មើនឹង ៩១៤,៧ លានរូប។បំណុលនេះត្រូវបានភាគីទាំងពីរលើកយកមកពិភាក្សាក្នុងគោលដៅកាត់បន្ថយនិងកំណត់ឡើងវិញ ដោយអនុលោមតាម **លក្ខខណ្ឌណាភើល** (Naples Terms) នៃក្លឹបប៉ារីស ដែលមានលក្ខខណ្ឌដូចតទៅ៖

ទីមួយ-គណនាឡើងវិញនូវបំណុលជាប្រាក់រូប ដែលមានទឹកប្រាក់សរុបចំនួន ៩១៤,៧ លានរូប អោយទៅជាបំណុលជាប្រាក់ដុល្លារ ដែលមានទឹកប្រាក់សរុបចំនួន ១.៥២៥ លានដុល្លារ (តាមអត្រាប្តូរប្រាក់ ១ ដុល្លារ × ០,៨១២៩ រូប)។ បន្ទាប់មក បំណុលជាប្រាក់ដុល្លារចំនួន ៧០%នឹងត្រូវបានលុបចោល ហើយទឹកប្រាក់បំណុល ដែលនៅសល់មានចំនួន ៤៥៧ លានដុល្លារ។

ទីពីរ-ដោយអនុលោមតាមសៀវភៅបន្ទុកនៃក្លឹបប៉ារីស ទឹកប្រាក់បំណុលដែលនៅសល់ចំនួន ៤៥៧ លានដុល្លារនឹងត្រូវបែងចែកជាពីរផ្នែក៖ ផ្នែកទីមួយ គឺជាឥណទានដែលផ្តល់មុនកាលបរិច្ឆេទបិទបញ្ជី និង ផ្នែកទីពីរ គឺ ឥណទានដែលផ្តល់ក្រោយកាលបរិច្ឆេទបិទបញ្ជី៖ (Post cut off date)។

ទីបី-ឥណទានដែលផ្តល់មុនកាលបរិច្ឆេទបិទបញ្ជី នឹងត្រូវបានកំណត់ឡើងវិញតាមលក្ខខណ្ឌសម្បទានដូចតទៅ៖ អត្រាការប្រាក់ ០,៨១២៩% រយៈពេលសងសេវាបំណុល ៣៣ ឆ្នាំ ដោយគ្មានរយៈពេលអនុគ្រោះ។

ទីបួន-ឥណទានដែលផ្តល់ក្រោយកាលបរិច្ឆេទបិទបញ្ជី នឹងត្រូវចរចាជាទ្វេភាគីក្រៅក្របខ័ណ្ឌនៃក្លឹបប៉ារីស ដែលផ្តល់លទ្ធភាពអោយកម្ពុជាអាចចរចាជាមួយសហព័ន្ធរុស្ស៊ី ដើម្បីទទួលបាននូវលក្ខខណ្ឌកំណត់បំណុលឡើងវិញដែលមានភាពអនុគ្រោះ។

ក៏ប៉ុន្តែ កម្ពុជា និង រុស្ស៊ីនៅមិនទាន់ព្រមព្រៀងគ្នាលើចំណុចសំខាន់ដូចខាងក្រោម៖

- លក្ខខណ្ឌនៃការកំណត់បំណុលឡើងវិញចំពោះឥណទានដែលផ្តល់ក្រោយ កាលបរិច្ឆេទបិទបញ្ជី ជាពិសេស រយៈពេលសងសេវាបំណុល រយៈពេលអនុគ្រោះ និង អត្រាការប្រាក់។ រាជរដ្ឋាភិបាលកម្ពុជា ចង់បាននូវអត្រាការប្រាក់ទាប រយៈពេលសងសេវាបំណុលវែង និង មានរយៈពេលអនុគ្រោះ ដើម្បីកាត់បន្ថយ នូវ «តម្លៃបច្ចុប្បន្នសុទ្ធ» (Net Present Value) នៃបំណុល។
- ការចុះបំណុលចំនួន ៤០ លានដុល្លារ ដែលភាគីកម្ពុជាយល់ឃើញថា ជាឥណទានមុនកាលបរិច្ឆេទបិទបញ្ជី ដែលត្រូវអនុវត្តតាមលក្ខខណ្ឌអនុគ្រោះ។

*(ខ) សហរដ្ឋអាមេរិក*

បំណុលផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាចំពោះសហរដ្ឋអាមេរិកមានប្រភពមកពីកម្ចីចំនួន៣ ដែលត្រូវបានផ្តល់សម្រាប់ទិញផលិតផលកសិកម្ម (កប្បាស ថ្នាំជក់ ស្រូវ ប្រេងឆា និងស្រូវសាលី) ក្នុងឆ្នាំ ១៩៧២ ១៩៧៣ និង១៩៧៤។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តារាង២៣.១. បំណុលក្រៅប្រទេសរបស់កម្ពុជា (គិតជាដុល្លារអាមេរិក)

| | | គិតត្រឹមថ្ងៃទី៣១ ខែធ្នូឆ្នាំ២០០៦ | ក្រោយការចរចាឡើងវិញ ខែធ្នូឆ្នាំ២០០៦ | ក្រោយការចរចាឡើងវិញ ថ្ងៃទី០៩ខែមិថុនា | % នៃផលិតផលក្នុងស្រុកសរុប |
|---|---|---|---|---|---|
| I | **អ្នកផ្តល់ឥណទានពហុភាគី** | **១,០៨៣,៥១២,០៦៣** | **១,០៨៣,៥១២,០៦៣** | **១,៤២៥,១៨៥,២៨៧** | **១៣.០៣%** |
| | ធនាគារអភិវឌ្ឍន៍អាស៊ី | ៥៧៩,៩៥៦,០៩៦ | ៥៧៩,៩៥៦,០៩៦ | ៨២៦,៨៩៦,៨៥៣ | ៧.៥៦ % |
| | ធនាគារពិភពលោក | ៤៥១,៧០៤,៦៣១ | ៤៥១,៧០៤,៦៣១ | ៥៣១,៦២៥,២៨៥ | ៤.៨៦% |
| | IFAD | ២៦,៥៣២,៤៥០ | ២៦,៥៣២,៤៥០ | ៣៨,២៣៨,៤៧៧ | ០.៣៥% |
| | NDF | | - | ៨,០២៥,២៣៣ | ០.០៧% |
| | OPEC | ១៥,៣១៨,៩៣៦ | ១៥,៣១៨,៩៣៦ | ២០,៤៤៩,៤៣៩ | ០.១៩% |
| II | **អ្នកផ្តល់ឥណទានទ្វេភាគី** | **២៥៣,១៤០,១៤៧** | **២៥៣,១៤០,១៤៧** | **២៥៣,១៤០,១៤៧** | **៣.៤៨%** |
| | បារាំង | ២១,១៥៦,៤៨៥ | ២១,១៥៦,៤៨៥ | ២៥,៤៨០,១២៦ | ០.២៣% |
| | អាឡឺម៉ង់ | ២,០៧៤,៣០៦ | ២,០៧៤,៣០៦ | ២,៥២៦,៩០៤ | ០.០៣% |
| | ជប៉ុន | ៤៣,២៣៧,៣៩៨ | ៤៣,២៣៧,៣៩៨ | ៩៣,៥២៧,៥៤៣ | ០.៨៦% |
| | ស្លូវ៉ាគី | ២៦៨,២៥៩ | ២៦៨,២៥៩ | ១៦៨,៥៩៣ | ០.០០% |
| | សាធារណរដ្ឋឆេក | ៧៦៦,៥១៨ | ៧៦៦,៥១៨ | - | - |
| | ម៉ាឡេស៊ី | ៧,០០០,០០០ | ៧,០០០,០០០ | ១,៤៩២,៧៩៥ | ០.០១% |
| | ចិន | ១០២,៥៧៦,៥៥៤ | ១០២,៥៧៦,៥៥៤ | ៣៤០,៦៧២,១០៣ | ៣.១១% |
| | សាធារណរដ្ឋកូរ៉េ | ៥៧,៦៧៤,៤៣៦ | ៥៧,៦៧៤,៤៣៦ | ៩៧,៨២៩,៥៤០ | ០.៨៩% |
| | ឥណ្ឌា | ៤,៧៧១,១៨៥ | ៤,៧៧១,១៨៥ | ១២,៧៣២,១៥០ | ០.១២% |
| | ថៃ | ១៣,០៦២,១៨១ | ១៣,០៦២,១៨១ | ៥៨,៤៨៨,៥៧០ | ០.៥៣% |
| | វៀតណាម | ៥៥២,៨២៥ | ៥៥២,៨២៥ | ១៣,៤៤០,៣៥១ | ០.១២% |
| | ប៉ូឡូញ | ៩៧៦,៧៩២ | ៩៧៦,៧៩២ | ៩៧៦,៧៩២ | ០.០១% |
| | **រុស្ស៊ី និង អាមេរិក** | **១,៨១២,៨៦៥,៦២០** | **៧៤៩,៥៨៥,៧៥១** | **៧៨៨,៥២០,៣២២** | ៧.២១% |
| | រុស្ស៊ី | ១,៥២៥,០០០,០០០ | ៤៥៧,៥៨៥,៧៥១ | ៤៥៧,៧៧៦,៣៣២ | ៤.១៩% |
| | -មុនបិទបញ្ជី | | ២១០,៧៨៨,៥៣៨ | ២១០,៩៧៩,១១៨ | ១.៩៣% |
| | -ក្រោយបិទបញ្ជី | ២៨៧,៨៦៥,៦២០ | ២៤៦,៧៩៧,២១៣ | ២៤៦,៧៩៧,២១៣ | ២.២៦% |
| | សហរដ្ឋអាមេរិក | | ២៩២,០០០,០០០ | ៣៣០,៧៤៣,៩៩០ | ៣.០២% |
| III | **បំណុលសរុប** | **៣,១៥១,៥៦១,៨៣៥** | **២,០៨៨,២៨១,៩៦៦** | **២,៨៦១,០៤១,០៧៥** | **២៦.១៦%** |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខែឧសភាឆ្នាំ២០០៧*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យោងតាមក្រសួងកសិកម្មរបស់អាមេរិក ទឹកប្រាក់សរុបចំនួន២២៧លានដុល្លារអាមេរិកបានត្រូវទូទាត់ឱ្យដែលឆ្លើយតបទៅនឹងតម្លៃតាមកិច្ចសន្យាចំនួន៣២២លានដុល្លារ។

អនុលោមតាមកិច្ចព្រមព្រៀងកម្ចីចំណូលដែលបានមកដោយការលក់មុខទំនិញទាំងនេះនឹងត្រូវប្រើប្រាស់ដោយរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវផលិតកម្ម ការស្តុកទុក និងកិច្ចការទីផ្សារនៃផលិតផលកសិកម្ម។

លក្ខខណ្ឌកម្ចីមានលក្ខណអនុគ្រោះ៖

- អត្រាការប្រាក់២% ក្នុងរយៈពេលបន្ថែមនិង ៣% ក្នុងរយៈពេលក្រោយមក។
- ការទូទាត់សងវិញនៃប្រាក់សំណងប្រចាំឆ្នាំ៣១ឆ្នាំ ដោយចាប់ផ្តើមក្រោយរយៈពេលបន្ថែមដែលមានរយៈពេល១០ឆ្នាំ ។

ការកំណត់បង់ប្រាក់ដើម និង ការប្រាក់បានបញ្ចប់ក្នុងឆ្នាំ១៩៧៥។ ដោយសារតែកង្វះខាតឯកសារពាក់ព័ន្ធ រដ្ឋាភិបាលទាំងពីរបានព្រមព្រៀងសម្រួលចំនួនឥណទាន ១៦២លានដុល្លារអាមេរិក ជាប្រាក់ដើម។ ដោយរួមទាំងការប្រាក់ បំណុលរបស់កម្ពុជាចំពោះសហរដ្ឋអាមេរិកមានចំនួនសរុប ៣៣០លាន ដុល្លារអាមេរិក។

### ឃ. បំណុលទ្វេភាគីថ្មីដែលផ្តល់ក្រោយឆ្នាំ១៩៩៣

ចាប់តាំងពីឆ្នាំ ១៩៩៣ មក រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាស្តីពីកម្ចីទ្វេភាគីជាមួយប្រទេសមួយចំនួនដូចជា ចិន ម៉ាឡេស៊ី សាធារណៈរដ្ឋកូរ៉េ ឥណ្ឌា ថៃឡង់ វៀតណាម និង មូលនិធិអភិវឌ្ឍន៍ណ័រឌីក។

*(ក) ចិន*

ចិនបានលុបចោលនូវបំណុលដែលកម្ពុជាខ្ចី មុនឆ្នាំ ១៩៩១ ដែលមានទឹកប្រាក់សរុបចំនួន ៥៨ លានដុល្លារ។ ចំនួនទឹកប្រាក់នៃបំណុលសរុបដែលកម្ពុជាជំពាក់ចិនមានចំនួន ១០២ លានដុល្លារ នៅចុងឆ្នាំ ២០០៦។

*(ខ) ម៉ាឡេស៊ី*

ម៉ាឡេស៊ីបានផ្តល់ឥណទាន នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៥ ចំនួន ៣៥ លានរីងហ្គីត (ប្រមាណជា ១៤ លានដុល្លារ) តាមរយៈធនាគារនីហាវ៉ែណអាហាវ៉ែណម៉ាឡេស៊ី ដើម្បីស្តារ និង កសាងឡើងវិញនូវអង្គភាព នៃកងនាវាចរណ៍នៃកងយោធពលខេមរភូមិន្ទ។ រយៈពេលសងសេវាបំណុលមានចំនួន ១០ ឆ្នាំ រយៈពេលអនុគ្រោះ ៥ ឆ្នាំ និង អត្រាការប្រាក់ចំនួន ៣% ។

## ២៣.៥. សមត្ថភាពសងបំណុលរបស់កម្ពុជា

នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ការអនុវត្តនូវតុល្យភាពរវាងសញ្ច័យ និង វិនិយោគអាចសម្រេចបានយ៉ាងកម្រណាស់ ដោយសារតែកង្វះខាតនូវសញ្ច័យ។ ទន្ទឹមនឹងនេះ ប្រទេសកំពុងអភិវឌ្ឍត្រូវការនូវទំហំវិនិយោគយ៉ាងច្រើន។ ឱនភាពថវិកា ដែលជាផលដករវាងចំណូល និង ចំណាយ ដាក់សម្ពាធលើសមត្ថភាពវិនិយោគរបស់រាជរដ្ឋាភិបាល។ ឱនភាពនេះអាចធ្វើហិរញ្ញប្បទានបានបួនយ៉ាង៖



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ការបោះផ្សាយក្រដាសប្រាក់ ដែលនាំឱ្យមានអតិផរណា។
- ការបង្កើនសញ្ច័យក្នុងស្រុក (គ្រួសារ និង សហគ្រាស) ក៏ប៉ុន្តែ សមត្ថភាពសញ្ច័យនៅទាប នៅក្នុងប្រទេសកំពុងអភិវឌ្ឍ។
- ហិរញ្ញប្បទានពីក្រៅប្រទេស ក្រោមរូបភាពជាជំនួយឥតសំណង តែនៅមានកម្រិត។
- កម្ចីក្រៅប្រទេស។

ការបង្កើនបំណុលក្រៅប្រទេស គឺជាសមាសធាតុយ៉ាងសំខាន់នៃគោលនយោបាយអភិវឌ្ឍ ដែលអនុញ្ញាតអោយរដ្ឋទិញនូវទំនិញ និង សេវាពីក្រៅប្រទេស ទោះបីជាទុនបម្រុងអន្តរជាតិជារូបិយប័ណ្ណបរទេសរបស់ប្រទេសនៅមានកម្រិតនៅឡើយ។ ក៏ប៉ុន្តែ ឥណទាយកតែងតែចង់គ្រប់គ្រងអោយបាននូវហានិភ័យដោយវាយតម្លៃយ៉ាងម៉ត់ចត់នូវស្ថានភាពរបស់ឥណាយិក។ ការវាយតម្លៃនូវសមត្ថភាពរបស់ឥណាយិកក្នុងការសងបំណុល គឺជាកត្តាកំណត់ក្នុងការសម្រេចចិត្តអោយខ្ចី។

ដើម្បីវាយតម្លៃពីសមត្ថភាពរបស់ប្រទេសក្នុងការខ្ចីឥណទាន សេដ្ឋវិទូបានបង្កើតឡើងនូវអនុបាទ ឬសូចនាករជាច្រើន។ អនុបាតដែលត្រូវបានប្រើប្រាស់ជាអន្តរជាតិទាំងនេះអនុញ្ញាតអោយយើងប្រៀបធៀបស្ថានភាពនៃប្រទេសផ្សេងៗ។

ក្នុងការគណនាធម្មតា នៅដំណាច់ឆ្នាំ២០០៨ បំណុលក្រៅប្រទេសសរុបរបស់កម្ពុជាមានចំនួនស្មើនឹង២៦%នៃផលិតផលក្នុងស្រុកសរុប គិតតាមតម្លៃធម្មតា និងស្មើនឹង ២០% បើគណនាតាមតម្លៃបច្ចុប្បន្នសុទ្ធ (Net Present Value-NPV)។ ក៏ប៉ុន្តែ ប្រសិនបើកំណើនសេដ្ឋកិច្ចធ្លាក់ចុះ ហើយហិរញ្ញប្បទានពីក្រៅប្រទេសនឹងកើនឡើង ដោយសារតែវិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ ២០០៩ បំណុលក្រៅប្រទេស និង បំណុលធានាដោយរដ្ឋ (PPG) ត្រូវបានព្យាករណ៍ថានឹងកើនដល់២៩% នៃផលិផលក្នុងស្រុកសរុបនៅចុងឆ្នាំ ២០០៩។

*តារាង២៣.២. កម្ពុជា៖សូចនាករបំណុលសាធារណៈក្រៅប្រទេសនៅដំណាច់ឆ្នាំ២០០៨*

| | កម្រិតបំណុលត្រូវព្រួយបារម្ភ | ដំណាច់ឆ្នាំ ២០០៨ |
|---|---|---|
| តម្លៃបច្ចុប្បន្នសុទ្ធនៃបំណុលជាភាគរយនៃ៖ | | |
| - ផលិផលក្នុងស្រុកសរុប | ៣០ | ១៩,៨ |
| - ការនាំចេញ | ១០០ | ៣៦,៧ |
| - ចំណូល | ២០០ | ១៦៤,៩ |
| សេវាការប្រាក់ជាភាគរយនៃ៖ | | |
| - ការនាំចេញ | ១៥ | ០,៩ |
| - ចំណូល | ២៥ | ៤,២ |
| *ប្រភព៖មូលនិធិរូបិយវត្ថុអន្តរជាតិ-ធនាគារពិភពលោក DSA* | | |

ការវិភាគស្តីពីនិរន្តរភាពនៃបំណុល (DSA) បង្ហាញថា សូចនាករកាតព្វកិច្ចសងបំណុលក្រៅប្រទេសមិនបានកើនឡើងហួសពីកម្រិតដែលត្រូវព្រួយបារម្ភឡើយ បើគិតតាមសេណារីយ៉ូជាមូលដ្ឋាននោះ។ តម្លៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បច្ចុប្បន្នសុទ្ធនៃបំណុលក្រៅប្រទេសធៀបនឹងផលិតផលសរុបក្នុងស្រុក ត្រូវបានព្យាករថា នឹងស្ថិតនៅក្រោមចំណុចដៅ ៣០ ភាគរយ។ ក៏ប៉ុន្តែ នៅពេលធ្វើតេស្តដើម្បីគណនាបំណុលនៅពេលមានវិបត្តិ បំណុលនឹងកើនឡើងលើសពីចំណុចដៅនេះ ក្នុងករណីពីរយ៉ាង៖ ទីមួយ នៅពេលដែលមានកំណើនខ្លាំង ក្នុងការនាំចូលទំនិញ និង ទីពីរ ក្នុងករណីដែលអត្រាការប្រាក់បាត់បង់តម្លៃ ៣០ ភាគរយ។

## ២៣.៤.១. អនុបាតបំណុលចែកនឹងផលិតផលសរុបក្នុងស្រុក

អនុបាទនេះមានគោលដៅបញ្ជាក់ពីសមត្ថភាពក្នុងការសង ទោះបីជាយើងមិនឃើញពីទំនាក់ទំនងដោយផ្ទាល់រវាងសមត្ថភាពក្នុងការសង និង បំណុលចែកនឹងផលិតផលសរុបក្នុងស្រុក (ផសស) ក៏ដោយ។ ចំពោះប្រទេសកម្ពុជា ទឹកប្រាក់បំណុលសរុបនៃផ្នែកសាធារណៈថយចុះពី ៣៣%នៃផសស នៅចុងឆ្នាំ ២០០៦ មកនៅត្រឹម ៣០%នៃផសស នៅចុងឆ្នាំ ២០០៧។ «តម្លៃបច្ចុប្បន្នសុទ្ធ» (Net Present Value) នៃបំណុលផ្នែកសាធារណៈបានធ្លាក់ចុះពី ២៣%នៃផសស នៅក្នុងឆ្នាំ ២០០៧ មកនៅត្រឹម ៨%នៃផសស នៅក្នុងឆ្នាំ ២០២៦ ដែលឆ្លុះបញ្ចាំងពីភាពសម្បទាននៃបំណុលនាពេលបច្ចុប្បន្ន។

អនុបាត «បំណុល/ការនាំចេញនៃទំនិញ និង សេវា» គឺជារង្វាស់នៃសមត្ថភាពសងបំណុលរបស់ប្រទេស ដោយយកសន្និទ្ធិបំណុល (បំណុលសរុប) មកចែកនឹងលំហូរ (ការនាំចេញ) ។ តម្លៃបច្ចុប្បន្នសុទ្ធនៃបំណុល/ការនាំចេញនៃទំនិញ និង សេវា-ស្មើនឹង ៣២% ក្នុងឆ្នាំ ២០០៧-ស្ថិតនៅក្រោមសូចនាករគោលចំនួន ១០០% នៅឡើយ។ ក៏ប៉ុន្តែ សមត្ថភាពសងបំណុលប្រកបដោយចីរភាពរបស់កម្ពុជាងាយនឹងរងគ្រោះនៅពេលមានវិបត្តិពីក្រៅប្រទេស។ ការធ្លាក់ចុះនៃកំណើនការនាំចេញអាចនាំឱ្យ «តម្លៃបច្ចុប្បន្នសុទ្ធ» នៃអនុបាទ បំណុល/ផសស កើនឡើងយ៉ាងខ្លាំង។

*រូបភាព២៣.១. អនុបាតតម្លៃបច្ចុប្បន្នសុទ្ធនៃបំណុលចែកនឹង ផសស (គិតជាភាគរយ)*




*ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២៣.៤.២. អនុបាតបំណុលចែកនឹងការនាំចេញទំនិញនិងសេវា

*រូបភាព២៣.២. អនុបាតតម្លៃបច្ចុប្បន្នសុទ្ធនៃបំណុលចែកនឹងការនាំចេញ*




*ប្រភពៈមូលនិធិរូបិយវត្ថុអន្តរជាតិ*

## ២៣.៤.៣. អនុបាតសេវាបំណុលចែកនឹងការនាំចេញទំនិញ និង សេវា

អនុបាទសេវាបំណុលចែកនឹងការនាំចេញវាស់សមត្ថភាពរបស់ប្រទេស ក្នុងការស្វែងរករូបិយប័ណ្ណ ដើម្បីទូទាត់បំណុល។ សេវាបំណុលស្ថិតនៅក្នុងកម្រិត ១%នៃការនាំចេញនៃទំនិញ និង សេវា។

## ២៣.៤.១. សេវាអត្រាការប្រាក់/បំណុល

អនុបាតនេះអនុញ្ញាតអោយយើងវាយតម្លៃពីកម្រិតនៃសម្បទានរបស់បំណុល ។

*រូបភាព២៣.៣. អនុបាតការទូទាត់សងការប្រាក់ចំពោះការនាំចេញ*




*ប្រភព៖មូលនិធិរូបិយវត្ថុអន្តរជាតិ*

*១) ការសាកល្បងនៃវិបត្តិខ្លាំងបំផុត គឺជាការសាកល្បងដែលនាំឱ្យមានអនុបាតខ្ពស់បំផុតក្នុងឆ្នាំ២០០៧សម្រាប់ការប្រៀបធៀបនីមួយៗ។*

## ២៣.៤.២. អនុបាតការប្រាក់ចំពោះបំណុល

អនុបាតនេះផ្តល់លទ្ធភាពក្នុងការវាយតម្លៃចំពោះកម្រិតនៃសម្បទានភាពរបស់បំណុល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ២៤
# សមាហរណកម្មនៅក្នុងតំបន់

## ២៤.១. សមាហរណកម្មកម្ពុជានៅក្នុងតំបន់

ក្នុងខែមេសា ឆ្នាំ១៩៩៩ កម្ពុជាបានក្លាយជាសមាជិក **សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍** ដែលហៅកាត់ថា **អាស៊ាន**។ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅក្នុងអាស៊ានបាននាំឆ្ពោះទៅរកការបង្កើតតំបន់ពាណិជ្ជកម្មសេរី។ កម្ពុជាក៏ជាផ្នែកមួយនៃ**មហាអនុតំបន់មេគង្គ** (GMS)។ សកម្មភាពកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់របស់កម្ពុជាឥឡូវនេះ រួមមានក្រុមតំបន់ថ្មីដែលសំដៅទៅលើ "**អាស៊ាន+៣**" ដែលនៅក្នុងក្រុមនេះរួមមានចិន ជប៉ុន និងកូរ៉េខាងត្បូង ក៏ដូចជា **វេទិកាតំបន់អាស៊ាន**(ARF) ដែលការពិភាក្សាផ្តោតទៅលើបញ្ហាសន្តិសុខក្នុងតំបន់។ នៅក្នុងឆ្នាំ២០០៤ កម្ពុជាបានក្លាយទៅជាសមាជិក **អង្គការពាណិជ្ជកម្មពិភពលោក** (WTO) ហើយបានចាប់ផ្តើមចូលរួមនៅក្នុងកិច្ចប្រជុំផ្សេងៗ រួមមាន**កិច្ចប្រជុំអាស៊ី-អ៊ឺរ៉ុប** (ASEM)។

ក្នុងនាមជាប្រទេសសមាជិកថ្មីមួយ កម្ពុជាអាចទទួលបានអត្ថប្រយោជន៍ពីគំនិតផ្តួចផ្តើមមួយចំនួនដែលបង្កើតឡើងដោយដៃគូដែលមានការអភិវឌ្ឍខ្ពស់ជាង សម្រាប់ប្រទេសជាសមាជិកថ្មីនិងប្រទេសជាសមាជិក ដែលមានការអភិវឌ្ឍតិចតួចរបស់អាស៊ាន រួមមាន **ប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន** (AISP) (៣៨៩មុខ)។ កិច្ចព្រមព្រៀងក្របខ័ណ្ឌដទៃទៀតជាមួយនឹងដៃគូអាស៊ាន ក៏បាននាំមកនូវផលប្រយោជន៍សម្រាប់កម្ពុជា ដែលក្នុងចំណោមផលប្រយោជន៍ទាំងអស់នេះ រួមមាន **ពន្ធគយអនុគ្រោះពិសេស** (SPT) ជាមួយនឹងប្រទេសចិន (២៩៧មុខ) **ប្រព័ន្ធអនុគ្រោះពន្ធទូទៅ** (GSP) ជាមួយប្រទេសជប៉ុន (២២៦មុខ) និងសាធារណរដ្ឋកូរ៉េ (៧៨មុខ)។ កម្ពុជាបានបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីចាប់យកឱកាសការអភិវឌ្ឍពាណិជ្ជកម្មខាងត្បូង-ខាងត្បូង (South-South) នៅក្នុងអាស៊ាន ហើយជាមួយនឹងប្រទេសមិនមែនជាសមាជិក។ នាពេលថ្មីៗនេះ រដ្ឋាភិបាលកំពុងតែសិក្សាលើសក្តានុពល ក្នុងការធ្វើសមាហរណកម្មប្រព័ន្ធអនុគ្រោះពន្ធគយពិភពលោក ក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានបំណងចង់ជំរុញលំហូរពាណិជ្ជកម្ម។

នៅពេលដែលកម្ពុជាបានក្លាយជាសមាជិកអាស៊ាន កម្ពុជាបានក្លាយជាផ្នែកមួយនៃ**តំបន់ពាណិជ្ជកម្មសេរីអាស៊ាន** (AFTA)។ កិច្ចព្រមព្រៀង AFTA ត្រូវបានចុះហត្ថលេខានៅសិង្ហបុរី កាលពីថ្ងៃទី២៨ ខែមករាឆ្នាំ ១៩៩២ នៅក្នុងអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ានលើកទីបួន ដើម្បីដាក់ចេញនូវគោលការណ៍គ្រឹះនៃទីផ្សាររួម។ វិសាលភាពរបស់កិច្ចព្រមព្រៀងគ្របដណ្តប់ទៅលើផលិតផល ដែលបានកំណត់តាមវិស័យជាមួយនឹងតម្លៃបន្ថែមជាក់លាក់ ហើយមានប្រភពក្នុងតំបន់ពាណិជ្ជកម្មសេរី។ ការបង្កើតតំបន់ពាណិជ្ជកម្មសេរី គឺជាបញ្ហាប្រឈមទីមួយរបស់កម្ពុជា នៅក្នុងដំណើរដ៏វែងឆ្ងាយក្នុងការធ្វើសមាហរណកម្មជាមួយនឹងអាស៊ាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

យន្តការគន្លឹះដើម្បីអនុវត្ត AFTA គឺការអនុគ្រោះពន្ធគយរួម។ នៅក្រោមកិច្ចព្រមព្រៀងនេះ ប្រទេសជាសមាជិកបានឯកភាពកាត់បន្ថយពន្ធគយទៅលើទំនិញ ដែលនាំចូលពីប្រទេសអាស៊ានដទៃទៀត នៅក្នុងអត្រាពី ០ និង ៥% នៅក្នុងកាលកំណត់១៥ឆ្នាំ។ ទំនិញអាទិភាព១៥មុខ ការកាត់បន្ថយពន្ធគយនឹងត្រូវបានពន្លឿនតាម**យន្តការលឿន** (Fast-Track, FT)។ សម្រាប់ផលិតផល FT កាលកំណត់សម្រាប់អនុវត្ត គឺថ្ងៃទី ០១ ខែមករា ឆ្នាំ២០០១។

គំនិតផ្តួចផ្តើមគន្លឹះមួយចំនួនរបស់អាស៊ានរួមមាន "**កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន-ចិនស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ**" "**កិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយអាស៊ាន-ជប៉ុន**" "**កិច្ចព្រមព្រៀងក្របខ័ណ្ឌឥណ្ឌា-អាស៊ានស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ**" **តំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាននិងសាធារណរដ្ឋកូរ៉េ** ហើយនិង តំបន់ពាណិជ្ជកម្មសេរី AFTA-CER (**ជំនាក់ទំនងសេដ្ឋកិច្ចជិតស្និទ្ធជាមួយនឹងអូស្ត្រាលីនិងណូវែលហ្សេឡង់**)។ ការបង្កើនការវិនិយោគ ផលិតកម្ម និងការប្រើប្រាស់ ដែលបានមកពីកត្តាទាំងអស់នេះនឹងផ្តល់ផលប្រយោជន៍ដល់កម្ពុជាថែមទៀត ក្នុងនាមជាសមាជិកអាស៊ាន។ ជាឧទាហរណ៍ ពាណិជ្ជកម្មរវាងចិននិងអាស៊ានបានកើនឡើងជិតទ្វេដងគឺ ពី ៥៥ ពាន់លានដុល្លារសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ ២០០១ ដល់ ១០០ ពាន់លានដុល្លារសហរដ្ឋអាមេរិកនៅក្នុងឆ្នាំ ២០០៥។ ការនាំចេញជាសំខាន់របស់អាស៊ានទៅកាន់ប្រទេសចិនគឺផលិតផលពាក់កណ្តាលសម្រេចនិងវត្ថុធាតុដើម ដូចជាបរិក្ខារអេឡិចត្រូនិក និងអគ្គិសនី ប្រេងឥន្ធនៈ ផ្លាស្ទិក វត្ថុគីមី និងក្រដាស។ ចិននាំចេញមកអាស៊ានមានដូចជា បរិក្ខារអេឡិចត្រូនិក និង អគ្គិសនី វាយនភ័ណ្ឌ និងផលិតផលលោហៈឧស្សាហកម្ម។

បច្ចុប្បន្ននេះ តំបន់ពាណិជ្ជកម្មសេរីទូលំទូលាយមួយកំពុងតែត្រូវបានបង្កើតឡើង រវាងអាស៊ាននិងចិន ដោយអនុលោមទៅតាម "ក្របខ័ណ្ឌកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ" ដែលបានចុះហត្ថលេខារវាងអាស៊ាននិងចិន នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០២ នៅភ្នំពេញនៅក្នុងកំឡុងពេលកិច្ចប្រជុំកំពូលអាស៊ានលើកទី៨។ អាស៊ាននិងចិនបានឯកភាពគ្នាបង្កើតតំបន់ពាណិជ្ជកម្មសេរី នៅឆ្នាំ ២០១០ ដោយភ្ជាប់ចិនជាមួយនឹងប្រទេសអភិវឌ្ឍន៍ជាងគេ ៦ (អាស៊ាន-៦) ហើយត្រឹមឆ្នាំ២០១៥ នឹងធ្វើជាមួយនឹងប្រទេសដែលនៅសល់ដទៃទៀត ដែលរួមទាំងកម្ពុជាដែរ។ ក្នុងនាមជាប្រទេសដែលមានចំណែកនៅក្នុងកិច្ចសហប្រតិបត្តិការអាស៊ាន-ចិន ការតភ្ជាប់បណ្តាញផ្លូវដែកសឹង្ហបុរី-គុនម៉ីង និងផ្លូវហាយវេបាងកក-គុនម៉ីង ដែលជាគម្រោងការដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ **មហាអនុតំបន់មេគង្គ**(GMS) នឹងត្រូវបានជំរុញឱ្យលឿនផងដែរ។

នៅក្នុងកិច្ចប្រជុំកំពូលរបស់ថ្នាក់ដឹកនាំ នៅក្នុងទីក្រុងបាលី ក្នុងឆ្នាំ ២០០៣ អាស៊ានបានកំណត់គោលដៅរបស់ខ្លួន ក្នុងការបង្កើត **សហគមន៍អាស៊ាន** ត្រឹមឆ្នាំ២០២០ ដោយឈរលើសសរទ្រូងបី (១) **សហគមន៍នយោបាយនិងសន្តិសុខអាស៊ាន** (ASC) (២) **សហគមន៍សេដ្ឋកិច្ចអាស៊ាន** (AEC) និង (៣) **សហគមន៍វប្បធម៌និងសង្គមកិច្ចអាស៊ាន** (ASCC)។ គោលដៅរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន គឺដើម្បីបង្កើតទីផ្សារ និងតំបន់ពាណិជ្ជកម្មរួមមួយ សម្រាប់ប្រជាជនជាង៥០០លាននាក់ ដែលមានផលិតផលសរុបក្នុងស្រុកជាង ៦០០ ពាន់លាន ដុល្លារសហរដ្ឋអាមេរិកនៅក្នុងឆ្នាំ ២០០២។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមក្នុងអនុតំបន់ ដែលគួរឱ្យកត់សម្គាល់ផ្សេងទៀត រួមមាន៖ **មហាអនុតំបន់មេគង្គ** គំនិតផ្តួចផ្តើមអភិវឌ្ឍន៍រួមនៅក្រោម "**យុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉ាយ៉ាវាឌី-ចៅប្រាយ៉ា-មេគង្គ**" (ACMECS) រវាងកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម **តំបន់ត្រីកោណមរកត** កម្ពុជា-ឡាវ-ថៃ និង **តំបន់ត្រីកោណអភិវឌ្ឍន៍** វៀតណាម-ឡាវ-កម្ពុជា។

**តំបន់ត្រីកោណអភិវឌ្ឍន៍** មានបំណងបង្កើតនូវយន្តការ ដើម្បីភ្ជាប់តំបន់ដែលជាប់គ្នានៅក្នុងប្រទេសបី។ ទស្សនទាននេះឈរលើទ្រឹស្តីបទឧត្តមភាពប្រៀបធៀប។ ដូច្នេះតាមរយៈការភ្ជាប់តំបន់ជាច្រើននៅតាមព្រំដែនជាប់គ្នា និង កៀរគរឧត្តមភាពប្រៀបធៀប ប្រទេសក្នុងតំបន់ពិតជាអាចលើកកម្ពស់ផលិតកម្មទូទៅ តាមរយៈការកាត់បន្ថយអប្រសិទ្ធភាព និងភាពមិនចាំបាច់។ ដើម្បីឱ្យតំបន់អភិវឌ្ឍត្រីកោណទទួលជោគជ័យ ប្រទេសក្នុងតំបន់ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន រួមមាន៖

- ការប្តេជ្ញាចិត្តខាងនយោបាយយ៉ាងមុតមាំ ជាពិសេសតាមរយៈកិច្ចព្រមព្រៀងក្នុងកម្រិតកំពូល។
- កត្តាបំពេញបន្ថែមត្រូវតែមានលក្ខណៈល្អប្រសើរ៖ ពាណិជ្ជកម្មអាចកើតមានឡើងប្រសិនបើមានទំនិញដែលត្រូវធ្វើពាណិជ្ជកម្ម។
- លំហូរចូលវិនិយោគបរទេស គឺទាមទារឱ្យមានស្ថេរភាពនយោបាយដ៏រឹងមាំ។
- ប្រទេសដែលជាប់ពាក់ព័ន្ធត្រូវមានសមត្ថភាពធ្វើផែនការអភិវឌ្ឍន៍។

## ២៤.២. សមាហរណកម្មនៅក្នុងអាស៊ាន

អាស៊ានឥឡូវនេះកំពុងតែស្ថិតនៅលើផ្លូវបំបែកជាប្រវត្តិសាស្ត្រមួយ។ អាស៊ានត្រូវតែពង្រឹងសមាហរណកម្មរបស់ខ្លួន ដើម្បីឱ្យប្រទេសអាចរក្សាបានជំហរយុទ្ធសាស្ត្ររបស់ខ្លួននៅក្នុងអាស៊ីខាងកើត។ ទន្ទឹមនឹងនេះ អាស៊ានត្រូវមានលទ្ធភាពដោះស្រាយបញ្ហាប្រឈមដែលកើតឡើង ដោយសារការងើបឡើងរបស់ចិន និងឥណ្ឌា ដែលកំពុងតែទាក់ទាញអ្នកវិនិយោគផ្ទាល់ពីបរទេស ក្នុងចំនួនច្រើន ហើយកំពុងតែធ្វើការលុកលុយចូលទៅក្នុងទីផ្សារ ដែលពីមុននេះបម្រុងសម្រាប់តែប្រទេសអាស៊ាន។

វិបត្តិហិរញ្ញវត្ថុអាស៊ីបានជួយឱ្យអ្នកធ្វើគោលនយោបាយនៅក្នុងបណ្តាប្រទេសអាស៊ាន ចិន កូរ៉េខាងត្បូង និងជប៉ុន (អាស៊ាន+៣) ដឹងថាសេដ្ឋកិច្ចរបស់ពួកគេបានធ្វើសមាហរណកម្មចូលគ្នាយ៉ាងជ្រៅ។ ពោលគឺប្រសិនបើវិបត្តិសេដ្ឋកិច្ចហូរចូលប្រទេសណាមួយនៅក្នុងតំបន់ ការរាលដាលនឹងប៉ះពាល់ដល់ប្រទេសផ្សេងទៀត។ ចាប់តាំងពីវិបត្តិហិរញ្ញវត្ថុអាស៊ី១៩៩៧-១៩៩៨ ប្រទេសនៅក្នុងតំបន់អាស៊ីខាងកើតបានប្រែក្លាយយ៉ាងជោគជ័យ ពីការគំរាមកំហែង ឱ្យទៅជាឱកាស។ ចាប់តាំងពីពេលនោះមក ប្រទេសទាំងអស់នេះបានអភិវឌ្ឍនូវគំនិតផ្តួចផ្តើមមួយចំនួន ដើម្បីបង្ការស្ថានការណ៍ធ្ងន់ធ្ងរណាមួយពីការអភិវឌ្ឍ ហើយបានបង្កើតនៅនឹងកន្លែង នូវកញ្ចប់ជំនួយហិរញ្ញវត្ថុតំបន់ សម្រាប់ករណីមានវិបត្តិខ្វះសាច់ប្រាក់ (liquidity crisis)។

អាស៊ានបានក្លាយទៅជាតំបន់ភូមិសាស្ត្រយុទ្ធសាស្ត្រ ដែលដើរតួនាទីជាស្ពានរវាងអាស៊ីនិងអ៊ឺរ៉ុប។ នៅក្នុងឆ្នាំ ២០០៥ កំណើនសេដ្ឋកិច្ចអាស៊ានបានឡើងដល់៧ %។ គំនិតផ្តួចផ្តើមនៅក្នុងតំបន់មួយចំនួនត្រូវបានបង្កើតឡើង ដើម្បីរុញសមាហរណកម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងអាស៊ាននិងអាស៊ីខាងកើត។ ថ្វីបើមានការរីកចម្រើនក៏ដោយ អាស៊ាននៅមានផ្លូវវែងឆ្ងាយថែមទៀត ដើម្បីសម្រេចនៅគ្រប់គោលដៅដែលខ្លួនបានកំណត់។

## ២៤.២.១. ក្របខ័ណ្ឌច្បាប់របស់អាស៊ាន

អាស៊ានត្រូវបានបង្កើតឡើងជាសំខាន់ ដើម្បីបង្កើតឱ្យមានសន្តិសុខនយោបាយសម្រាប់អាស៊ាន។ ដោយសារតែអាស៊ានមានការវិវត្តិឈានទៅមុខ បន្ទាប់មក ទិដ្ឋភាពសេដ្ឋកិច្ចបានក្លាយទៅជាគោលដៅជាបន្ទាន់នៃសមាហរណកម្មក្នុងតំបន់។ របៀបវារៈបច្ចុប្បន្នរបស់អាស៊ានបានសង្កត់ធ្ងន់ទៅលើស្ថេរភាពសង្គម និងសេដ្ឋកិច្ចនៅក្នុងតំបន់ ដើម្បីលើកកម្ពស់វិបុលភាព ក្នុងចំណោមប្រទេសជាសមាជិកទាំងអស់។

នៅក្នុងខែកុម្ភៈ ឆ្នាំ ១៩៧៦ នៅឯសន្និសីទក្រុងបាលី ប្រទេសដែលជាសមាជិកអាស៊ានបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍នៃកិច្ចព្រមព្រៀង (កិច្ចព្រមព្រៀងបាលី១) ស្តីពី **សន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការ** (TAC) និង កិច្ចព្រមព្រៀងស្តីពីការបង្កើតអគ្គលេខាធិការអាស៊ាន។ សេចក្តីថ្លែងការណ៍នៃកិច្ចព្រមព្រៀងបានបញ្ជាក់ឡើងវិញយ៉ាងច្បាស់ នូវគោលការណ៍ក្នុងការស្វែងរកដំណោះស្រាយសន្តិភាពចំពោះជម្លោះរវាងប្រទេសជាសមាជិក។ លើសពីនេះទៅទៀត ប្រទេសជាសមាជិកអាស៊ានបានឯកភាពគ្នា ឱ្យមានការសម្របសម្រួលគម្រោងការវិនិយោគ ដើម្បីឱ្យរចនាសម្ព័ន្ធសេដ្ឋកិច្ចខុសៗគ្នារបស់ប្រទេសនីមួយៗមានលក្ខណបំពេញគ្នាទៅវិញទៅមក។

ឆ្លើយតបទៅនឹងការដកថយរបស់ប្រទេសមហាអំណាចធំៗពីតំបន់អាស៊ាន ដែលបណ្តាលមកពីការដួលរលំនៃសហភាពសូវៀត និងការដកកងទ័ពវៀតណាមចេញពីកម្ពុជា ក៏ដូចជាការដកទ័ពរបស់សហរដ្ឋ-អាមេរិកចេញពីប្រទេសហ្វីលីពីន ប្រទេសសមាជិកអាស៊ានបានបង្កើត **វេទិកាតំបន់អាស៊ាន** (ARF) នៅក្នុងឆ្នាំ១៩៩៣ ដើម្បីពង្រឹងជំនឿទុកចិត្ត និងជំរុញវិស័យការទូត ដើម្បីការពារទុកជាមុន។

**សេចក្តីថ្លែការណ៍នៃក្រុងបាងកក** (១៩៦៧) បានដាក់ចេញគោលបំណងរបស់អាស៊ាន៖ ជំរុញកំណើនសេដ្ឋកិច្ចសង្គម ការអភិវឌ្ឍវប្បធម៌ លើកកម្ពស់ស្ថេរភាព និងសន្តិភាពក្នុងតំបន់។ **សន្ធិសញ្ញាមិត្តភាពនិងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍** (TAC) កំណត់គោលការណ៍របស់អាស៊ាន៖ ការគោរពឯករាជ្យភាព អធិបតេយ្យភាព បូរណៈភាពទឹកដី និងសន្តិសុខជាតិរបស់ប្រទេសជាសមាជិកទាំងអស់ ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ ការដោះស្រាយវិវាទដោយសន្តិវិធី ការមិនគម្រាមកំហែង និងការមិនប្រើប្រាស់កម្លាំង។

នៅក្នុងទសវត្សរ៍ទី៨០ ប្រទេសនៅក្នុងអាស៊ានមានការប្រុងប្រយ័ត្នពីការប្រកួតប្រជែងពីក្រុមខាងក្រៅដូចជា សហភាពអឺរ៉ុប និង តំបន់ពាណិជ្ជកម្មសេរីអាមេរិកខាងជើង (NAFTA)។ កត្តាទាំងអស់នោះនាំឱ្យមានការស្នើបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA)។

**ចក្ខុវិស័យអាស៊ាន២០២០** ដែលបានអនុម័តក្នុងឆ្នាំ ១៩៩៧ មានបំណងដើម្បីពង្រឹងចំណងសេដ្ឋកិច្ចរបស់បណ្តាប្រទេសជាសមាជិក និងដើម្បីធ្វើឱ្យសេដ្ឋកិច្ចអាស៊ានជឿនលឿន មានស្ថេរភាព និងភាពប្រកួតប្រជែងជាងមុនថែមទៀត។ ផែនការណ៍សកម្មភាពហាណូយ ត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៨ ដើម្បីប្រតិបត្តិចក្ខុវិស័យនេះ ហើយនឹងដើម្បីនាំទៅរកភាពជោគជ័យនៅចុងបញ្ចប់។

ការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ត្រូវបានបញ្ជាក់ឡើងវិញក្នុងអំឡុងពេលដែលថ្នាក់ដឹកនាំអាស៊ានបានអនុម័តកាលពីខែវិច្ឆិកា ឆ្នាំ២០០១ នូវសេចក្តីថ្លែងការណ៍អាស៊ានស្តីអំពីសកម្មភាពរួម ដើម្បីប្រយុទ្ធប្រឆាំងនឹងភេរវកម្ម។ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ប្រទេសអាស៊ានបាន

ប្តេជ្ញាចិត្តៈ (១) ពង្រឹងយន្តការជាតិដើម្បីប្រយុទ្ធនឹងភេរវកម្ម (២) អនុវត្តគ្រប់អនុសញ្ញានិងពិធីសារពាក់ព័ន្ធនឹងការប្រឆាំងនឹងភេរវកម្មទាំងអស់នៅក្នុងតំបន់ដើម្បីប្រយុទ្ធនឹងភេរវកម្ម(៣)ពង្រឹងទំនាក់ទំនងក្នុងចំណោមផ្នែកត្រួតពិនិត្យរបស់ប្រទេសជាសមាជិក (៤) ផ្លាស់ប្តូរព័ត៌មានអំពីភេរវជននិងអង្គការភេរវជនចលនានិងមូលនិធិរបស់ពួកគេ (៥) កិច្ចសហប្រតិបត្តិការនៅក្នុងទស្សនៈដើម្បីពង្រឹងសមត្ថភាពរបស់ប្រទេសជាសមាជិក។

កិច្ចប្រជុំខ្ពស់បំផុតរបស់អាស៊ាន គឺជាកិច្ចប្រជុំកំពូលប្រចាំឆ្នាំរបស់បណ្តាប្រមុខរដ្ឋនិងប្រមុខរដ្ឋាភិបាល។ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីត្រូវបានប្រារព្ធធ្វើឡើងជាទៀងរាល់ឆ្នាំនៅក្នុងវិស័យដូចខាងក្រោមៈ កិច្ចការបរទេស ហិរញ្ញវត្ថុ សេដ្ឋកិច្ច និងឧស្សាហកម្ម។

### ២៤.២.២. ជម្ពុញអាស៊ាន

អាស៊ាននៅខ្វះធម្មនុញ្ញ។ អាស៊ានត្រូវការធម្មនុញ្ញ ដើម្បីប្រែក្លាយខ្លួនទៅជាអង្គការមួយដែលមានប្រសិទ្ធភាព។ ដូចហេតុផលខាងក្រោមនេះៈ

អាស៊ានមានលក្ខណៈសម្បត្តិប្រតិបត្តិនិងរបៀបពិសេស ដែលខុសពីគំរូរបស់បណ្តាតំបន់ដទៃទៀតដូចជាសហភាពអឺរ៉ុបនិង Mercosur ជាដើម។ អាស៊ានត្រូវបានគេមើលឃើញថាជាអង្គការដែលមានលក្ខណៈបត់បែន និងសម្រេចចិត្តដោយ **កុងសង់ស៊ុស** ជាមួយនឹងរចនាសម្ព័ន្ធ ដែលអាចអនុវត្តតាមបាន និង មិនប៉ះពាល់ធ្ងន់ធ្ងរដល់អធិបតេយ្យជាតិ។ ដំណើរការក្នុងការធ្វើសេចក្តីសម្រេចចិត្ត មិនបង្កើតជាកាតព្វកិច្ចសម្រាប់ប្រទេសជាសមាជិក។ វិធីនេះសម្រួលឱ្យមានយុទ្ធវិធីសម្របសម្រួល នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តតាមការសម្របសម្រួលនិងដោយ **កុងសង់ស៊ុស**។ ទោះបីជាយ៉ាងនេះក្តី អភិក្រម**កុងសង់ស៊ុស**អាចជោគជ័យទៅបានទាមទារឱ្យមានការផ្លាស់ប្តូរយោបល់ ប្រកបដោយការគាំទ្រ ដោយឈរលើការគោរពគ្នាទៅវិញទៅមក។ ដោយទទួលស្គាល់នូវចំណុចខ្សោយនៃអភិក្រម **កុងសង់ស៊ុស** ក្នុងការដោះស្រាយបញ្ហារសើបនិងបន្ទាន់ វិធាន "១០- x" ត្រូវបានបង្កើតឡើង។

**ស្មារតីអាស៊ាន** គឺ ជាគោលការណ៍សហប្រតិបត្តិការអន្តរប្រទេស ដោយឈរលើមូលដ្ឋាននៃការជឿទុកចិត្តគ្នា ក្នុងចំណោមអ្នកដឹកនាំ។ យន្តការស្ថាប័នអាស៊ាន ត្រូវបានបង្កើតឡើង តាមរយៈគោលនយោបាយនិងការអនុវត្តក្រៅប្រព័ន្ធ។ ប្រការនេះឆ្លុះបញ្ចាំងឱ្យឃើញនូវបញ្ហាប្រឈម ក្នុងការគ្រប់គ្រងសាកលភាវូបនីយកម្មដែលមានទាំង ឱកាស និងឧបសគ្គ។

អគ្គលេខាធិការអាស៊ានមិនមានអំណាច ដើម្បីដាក់ការទាមទារណាមួយទៅលើប្រទេសសមាជិកនិងទាមទារអនុវត្តកិច្ចព្រមព្រៀងអាស៊ានណាមួយឡើយ ហើយក៏មិនមានអំណាចផ្លូវច្បាប់ឬឋានៈដើម្បីអនុវត្តកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាដែរ។ លេខាធិការដ្ឋានមិនមានធនធាន និង បុគ្គលិកគ្រប់គ្រាន់ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព និង ប្រសិទ្ធផល។

ដើម្បីជម្នះបញ្ហាប្រឈម ដែលអាស៊ាននឹងជួបប្រទះនាពេលអនាគត ថ្នាក់ដឹកនាំអាស៊ានបានបង្កើតអនុសាសន៍ដូចខាងក្រោម ដើម្បីគោរពគោលដៅ និង គោលការណ៍សំខាន់ៗរបស់សមាជិកទាំងអស់ៈ

- លើកកម្ពស់ស្ថេរភាពនិងសន្តិភាព ដោយការពង្រឹងតម្លៃប្រជាធិបតេយ្យ អភិបាលកិច្ចល្អ បដិសេធចោលរាល់ការផ្លាស់ប្តូររដ្ឋាភិបាលមិនអាស្រ័យតាមធម្មនុញ្ញ និងមិនប្រជាធិបតេយ្យ ការគោរពនីតិរដ្ឋ សិទ្ធិមនុស្ស និងសេរីភាពសំខាន់ៗ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- លើកកម្ពស់វិបុលភាព និងភាពធន់របស់អាស៊ាន តាមរយៈកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មជិតស្និទ្ធតាមរយៈគំនិតផ្តួចផ្តើម ដូចជាការបង្កើតសហគមន៍អាស៊ាន ទីផ្សាររួម សេដ្ឋកិច្ចរីកចម្រើន និងការភ្ជាប់ទំនាក់ទំនងក្នុងតំបន់ និងបង្រួមគម្លាតនៃការអភិវឌ្ឍ។

- លើកកម្ពស់ការឆ្លើយតបឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលារបស់អាស៊ាន ទៅនឹងបញ្ហាប្រឈមឆ្លងដែនមិនប្រពៃណី និងវិបត្តិផ្សេងៗ តាមរយៈការជួយគ្នាទៅវិញទៅមក កិច្ចសហប្រតិបត្តិការអន្តរជាតិនិងតំបន់។ អាស៊ានគួរតែកំណត់ឱ្យបានច្បាស់ នូវគោលនយោបាយតាមទម្លាប់របស់ខ្លួននៃការមិនជ្រៀតជ្រែកផ្ទៃក្នុង នៅក្នុងវិស័យណា ដែលផលប្រយោជន៍រួមទាមទារឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធថែមទៀត។

- លើកកម្ពស់អត្តសញ្ញាណអាស៊ាន តាមរយៈការពង្រីកបេតិកភណ្ឌវប្បធម៌របស់អាស៊ាន ការវិនិយោគនៅក្នុងវិស័យអប់រំ និងប្តេជ្ញាសហការជាមួយនឹងសង្គមស៊ីវិល។

- ការប្តេជ្ញាក្នុងការបង្កើតឱ្យចេញជារូបរាងសហគមន៍អាស៊ាន ហើយពិសេសបំផុតគឺសហភាពអាស៊ាន។

## ២៤.៣. ក្របខណ្ឌកច្ចសហប្រតបត្តការសេដ្ឋកច្ច

តំបន់ពាណិជ្ជកម្មសេរី ដែលបង្កើតឡើងនៅក្រោមការអនុគ្រោះពន្ធគយរួម គឺជាជំហានទីមួយនៅក្នុងសមាហរណកម្មតំបន់។ ប្រទេសសមាជិកលុបបំបាត់ពន្ធគយលើការនាំចូលពីសមាជិកអាស៊ានដទៃទៀត។ ទោះបីជាយ៉ាងណាក៏ដោយ សមាហរណកម្មសេដ្ឋកិច្ចនៅក្នុងអាស៊ាន ត្រូវបានគេរំពឹងថាវានឹងទៅហួសពីតំបន់ពាណិជ្ជកម្មសេរីនេះ គឺសំដៅទៅលើតំបន់ពាណិជ្ជកម្មសេរីបន្ថែម (AFTA Plus)។ តំបន់ពាណិជ្ជកម្មសេរីបន្ថែម ផ្តោតលើពាណិជ្ជកម្មទំនិញ ក៏ដូចជាសេវាកម្ម និង លំហូរហិរញ្ញវត្ថុវិនិយោគដោយផ្ទាល់ពីបរទេស និងវិនិយោគផលបត្រ។ គោលបំណងសំខាន់បំផុតក្នុងការបង្កើត AFTA Plus គឺដើម្បីពង្រីកលំហូរពាណិជ្ជកម្មក្នុងវិស័យជាច្រើន និង បង្កើនសុខមាលភាពសេដ្ឋកិច្ចនៅក្នុងតំបន់។

កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីបានកំណតបញ្ជីផលិផលចំនួនបួន ដើម្បីកាត់បន្ថយពន្ធគយៈ

**បញ្ជីដាក់បញ្ចូល** (Inclusive List) ដែលរួមបញ្ចូលទំនិញទាំងអស់ ដែលមិនស្ថិតនៅក្នុងតារាងវេទយិតភាពនិងតារាងអនុគ្រោះទូទៅ។ វាមានវិធីពីរក្នុងការកាត់បន្ថយពន្ធ (Track)ៈ

- **ផ្លូវធម្មតាៈ** ដោយយោងទៅលើពន្ធគយនៃផលិផលក្នុងបញ្ជីដាក់បញ្ចូល (IL) នឹងត្រូវកាត់បន្ថយមកនៅ០និង៥ភាគរយ និងចាប់ផ្តើមអនុវត្តក្នុងឆ្នាំ ២០០២ សម្រាប់ប្រទេសអាស៊ានចាស់៦ (ប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី និងថៃ (អាស៊ាន-៦) នៅក្នុងឆ្នាំ ២០០៥ សម្រាប់វៀតណាម ឆ្នាំ២០០៨ សម្រាប់ឡាវនិងមីយ៉ាន់ម៉ា និងក្នុងឆ្នាំ២០១០សម្រាប់កម្ពុជា។

- **ផ្លូវលឿនៈ** សម្រាប់ផលិតផលប្រេងខ្លាញ់ ផលិតផលរ៉ែ សារធាតុគីមី ស្បែក និង ផលិតផលធ្វើអំពីស្បែក ផលិតផលក្រដាស វាយនភ័ណ្ឌ សម្លៀកបំពាក់ ស៊ីម៉ងត៍ ត្បូងមានតម្លៃ ផលិតផលធ្វើពីលោហៈធាតុ គ្រឿងម៉ាស៊ីន គ្រឿងបរិក្ខារ អគ្គិសនី និងផលិតផលរោងចក្រដទៃទៀតដែល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការកាត់បន្ថយពន្ធគយនឹងត្រូវធ្វើជាបន្ទាន់ ២០% ហើយនឹងធ្លាក់មកដល់ ០-៥% នៅខែមករា ឆ្នាំ២០០០ សម្រាប់សមាជិកប្រទេសចាស់ ឆ្នាំ២០០២ សម្រាប់វៀតណាម ២០០៦ សម្រាប់ឡាវនិង មីយ៉ាន់ម៉ា និងឆ្នាំ២០០៧ សម្រាប់កម្ពុជា។

ទោះបីជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីមានការពារមួយដែលអាចឱ្យរដ្ឋសមាជិកពន្យារពេលជាបណ្ដោះអាសន្ននៅក្នុងការអនុវត្ត ប្រសិនបើទុនបម្រុងបរទេសរបស់ខ្លួនស្ថិតក្នុងគ្រោះថ្នាក់ ឬ ក៏ប្រសិនបើសន្តិសុខជាតិរបស់ខ្លួនមានការគម្រាមកំហែង។

នៅចុងឆ្នាំ ២០០៦ ប្រទេសសមាជិកចាស់ទាំង៦ (អាស៊ាន៦) ដែលបានចុះកិច្ចព្រមព្រៀងអនុគ្រោះពន្ធគយរួមបានសង្កេតឃើញថា ទំនិញភាគច្រើនរបស់ប្រទេសទាំងនេះ បានស្ថិតនៅក្នុងបញ្ជីដាក់បញ្ចូល។ ៩៩.៧៧ភាគរយក្នុងចំណោមទំនិញទាំងនេះ អត្រាពន្ធគយមានកម្រិតពី០-៥%។ កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) មានទំនិញ៩១ភាគរយ ស្ថិតនៅក្នុងបញ្ជីដាក់បញ្ចូល ហើយ៧៧%នៃទំនិញនេះមានអត្រាពន្ធគយ០-៥%។ អត្រាពន្ធគយនៅក្នុងឆ្នាំ២០០៦ ជាមធ្យមគឺ ២.៨២% សម្រាប់ប្រទេសអាស៊ានទាំង១០ ហើយ១.៧៤% សម្រាប់អាស៊ានចាស់ទាំង៦ និង៤.៦៥% សម្រាប់កម្ពុជា វៀតណាម ឡាវ និងភូមា។ ការអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីឥឡូវនេះ កំពុងតែស្ថិតនៅក្នុងដំណាក់កាលចុងក្រោយ។

**បញ្ជីទំនិញដែលមានវេទយិតភាព** (SL)៖ គឺសម្រាប់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដែលប្រទេសជាសមាជិកគិតថាមានវេទយិតភាពសម្រាប់ពួកគេ។ ផលិតផលនៅលើតារាងនេះនឹងត្រូវផ្ទេរបញ្ចូលទៅក្នុងបញ្ជីដាក់បញ្ចូលនៅក្នុងរយៈពេល១៥ឆ្នាំ ប្រហែលជាឆ្នាំ២០១០។

**បញ្ជីអនុគ្រោះទូទៅ** (GEL)៖ សម្រាប់ផលិតផលទាំងឡាយណា ដែលស្ថិតនៅក្រៅកិច្ចព្រមព្រៀង ពីព្រោះទំនិញទាំងនេះអាចបង្កគ្រោះថ្នាក់ដល់សុខភាពសាធារណៈ សន្តិសុខជាតិ ឬ ក៏សម្បត្តិវប្បធម៌របស់ប្រទេសនីមួយៗ។ មិនមានគម្រោងកម្មវិធីណាមួយ សម្រាប់កាត់បន្ថយពន្ធគយលើទំនិញទាំងនេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសជាសមាជិកខ្លះបានដាក់បញ្ចូលផលិផលខ្លះដូចជា ថ្នាំជក់និង ភេសជ្ជៈមានជាតិអាល់កុល គ្រឿងបន្លាស់រថយន្ត និង ផលិផលប្រេង ទៅក្នុងតារាងនេះ។ ដោយសារហេតុនេះ បណ្ដាប្រទេសអាស៊ានបានពិនិត្យឡើងវិញ នូវបញ្ជីអនុគ្រោះពន្ធទូទៅ ដើម្បីឱ្យវាស្របទៅតាមគំនិតដើម។

**បញ្ជីអនុគ្រោះបណ្ដោះអាសន្ន** (TEL)៖ បញ្ជីនេះគឺកើតឡើងចេញពី បញ្ជីដាក់បញ្ចូល (IL) និងបញ្ជីវេទយិទភាព (SL)។ នៅក្នុងបញ្ជីនេះ គឺជាទំនិញដែលនឹងត្រូវផ្ទេរចូលទៅក្នុងបញ្ជីដាក់បញ្ចូល បន្ទាប់ពីពេលវេលាសម្របសម្រួល ត្រូវបានអនុញ្ញាតឱ្យសម្រាប់ប្រទេសនីមួយៗ។ ផលិតផលនៅក្នុងបញ្ជីនេះចែកចេញជា៥ក្រុម ដែលពន្ធគយត្រូវតែកាត់បន្ថយជា៥ដំណាក់កាល។ ពន្ធគយសម្រាប់ទំនិញក្នុងតារាងនេះនឹងត្រូវកាត់បន្ថយមក ០-៥% ទៅតាមកាលកំណត់របស់ប្រទេសនីមួយៗ។ នៅក្នុងពេលនេះ ប្រទេសចាស់ទាំង ៦ ប្រទេសឡាវនិងវៀតណាមមិនបានដាក់ផលិតផលណាមួយនៅក្នុងបញ្ជីនេះទេ។ កម្ពុជាបានផ្ទេរផលិតផលដែលនៅសេសសល់របស់ខ្លួន នៅក្នុងបញ្ជីអនុគ្រោះបណ្ដោះអាសន្ន ដាក់ទៅក្នុងបញ្ជីដាក់ញ្ចូលនៅឆ្នាំ ២០០៧។ ហើយមីយ៉ាន់ម៉ាក៏បានធ្វើដូច្នេះដែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*តារាង២៤.១. វិសាលភាពនៃទំនិញតាមប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន*

| *ប្រទេសផ្ដល់ការអនុគ្រោះ* | *ប្រទេសដែលទទួលផលប្រយោជន៍ពីការអនុគ្រោះ* | | | | *ពន្ធគយនៃប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន* |
|---|---|---|---|---|---|
| | *កម្ពុជា* | *ឡាវ* | *មីយ៉ាន់ម៉ា* | *វៀតណាម* | |
| ប្រ៊ុយណេ | ៨ | ១៤ | ៧៩ | ១ | 0% |
| ឥណ្ឌូនេស៊ី | ៤០ | ២១ | ២៦២ | ៧១ | 0-៥% |
| ម៉ាឡេស៊ី | ១៧៤ | ៨២ | ២៨៤ | ២៣៤ | 0% |
| ហ្វីលីពីន | ៦៤ | ៧៦ | ២០៦ | ៧៩ | 0% |
| សឹង្ហបុរី | - | - | - | - | - |
| ថៃ | ៣៤០ | ៣០០ | ៨៥០ | - | 0-៥% |
| សរុប | ៦៣១ | ៤៩៣ | ១.៦៨១ | ៥៣៥ | |

*ប្រភព:ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

បណ្ដាប្រទេសរបស់អាស៊ានបានឯកភាពគ្នាថា ផលិតផលមួយអាចចាត់ទុកថាមានប្រភពដើមមកពីប្រទេសអាស៊ាន លុះត្រាតែគ្រឿងផ្សំរបស់វា៤០% មានប្រភពមកពីប្រទេសជាសមាជិក លើកលែងតែផលិតផលកសិកម្ម។ បណ្ដាប្រទេសអាស៊ានកំពុងតែពិនិត្យឡើងវិញនូវ **វិធានប្រភពទំនិញ** (Rules of Origin) នៅក្រោមកិច្ចព្រមព្រៀងអនុគ្រោះពន្ធគយរួម ដើម្បីធ្វើសុខដុមនីយកម្មច្បាប់នេះជាមួយនឹងច្បាប់ដទៃទៀតរបស់តំបន់ពាណិជ្ជកម្មសេរីទ្វេភាគី។

ដើម្បីបង្កើនល្បឿនកាត់បន្ថយគម្លាតអភិវឌ្ឍន៍ សមាជិកចាស់ទាំង៦បានផ្ដល់ប្រព្រឹត្តកម្មពាណិជ្ជកម្មពិសេសនិងផ្សេងៗគ្នា ទៅឱ្យដល់សមាជិកថ្មីដែលឱ្យឈ្មោះថា **ប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន** (AISP)។

ការអនុវត្តការប្រើប្រាស់ប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន (AISP) គឺនៅទាបនៅឡើយ ឧទាហរណ៍លំហូរពាណិជ្ជកម្មរវាងសមាជិកចាស់ និង សមាជិកថ្មីរបស់អាស៊ានកើតឡើងនៅក្រៅប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន (AISP)។

ពាណិជ្ជកម្មគឺជាសសរទ្រូងនៃកំណើនសេដ្ឋកិច្ចសម្រាប់ប្រទេសអាស៊ាន។ នៅក្នុងឆ្នាំ២០០៥ ការនាំចេញរបស់អាស៊ានបានកើនឡើង១៣.៥ % ធៀបនឹងឆ្នាំ២០០៤ នៅខណៈដែលការនាំចូលកើន ១៥.៤%។ ជប៉ុនគឺជាដៃគូពាណិជ្ជកម្មធំបំផុតរបស់អាស៊ានជាមួយនឹងទំហំពាណិជ្ជកម្ម១២.៦%។ សហរដ្ឋអាមេរិកគឺជាដៃគូពាណិជ្ជកម្មធំទីពីរ ដែលមានទំហំពាណិជ្ជកម្ម១២.៥% បន្ទាប់មកគឺសហភាពអឺរ៉ុប១១.២% ចិនលំដាប់លេខ៤ គឺ៩.៣%។ មានកំណើនគួរឱ្យកត់សម្គាល់នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មរវាងចិននិងអាស៊ាន។ នាពេលថ្មីៗនេះ ចិនសង្ឃឹមថានឹងក្លាយទៅជាដៃគូពាណិជ្ជកម្មធំបំផុតរបស់អាស៊ាននៅក្នុងរយៈពេលប៉ុន្មានឆ្នាំទៀតនេះ។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែង ដើម្បីជំរុញសមាហរណកម្មតំបន់ទៅមុខ ពាណិជ្ជកម្មរវាងប្រទេសអាស៊ានមានចំណែកត្រឹមតែ ២៥% នៅក្នុងឆ្នាំ២០០៥ ដែលនេះមានការកើនឡើងបន្តិចបើធៀបនឹង ២៤.៣% នៅក្នុងឆ្នាំ២០០៤។ ដូច្នេះបណ្តាប្រទេសរបស់អាស៊ានពឹងផ្អែកលើទីផ្សារ ក្រៅអាស៊ានសម្រាប់ពាណិជ្ជកម្ម ការវិនិយោគ មូលធន និងបច្ចេកវិទ្យា។

បណ្តាសមាជិករបស់អាស៊ានក៏បានដាក់ចេញវិធានការលុបបំបាត់ឧបសគ្គមិនមែនពន្ធគយ សម្រាប់ពាណិជ្ជកម្ម ធ្វើឱ្យមានសុខដុមនីយកម្មតារាងពន្ធគយ វិធានកំណត់តម្លៃ និងនីតិវិធីគយ ក៏ដូចជាបទដ្ឋាន និងច្បាប់ពាក់ព័ន្ធនឹងផលិតផល និងកែលម្អវិធានប្រភពទំនិញសម្រាប់ការអនុគ្រោះពន្ធគយរួម (CEPT rules of origin)។ ប្រទេសជាសមាជិកមានពេល៥ឆ្នាំ ដើម្បីលុបបំបាត់បន្តិចម្តងៗ ការកម្រិតបរិមាណ (QRs)និងរបាំងមិនមែនពន្ធគយ នៅពេលដែលប្រទេសទាំងនោះទម្លាក់ពន្ធគយរបស់ខ្លួនមកដល់៥% ឬទាបជាងនេះ។ បណ្តាប្រទេសអាស៊ានរៀបចំកម្មវិធីលុបបំបាត់របាំងមិនមែនពន្ធគយ ដើម្បីបង្កើនពាណិជ្ជកម្មនៅក្នុងបណ្តាប្រទេសជាសមាជិក។ របាំងមិនមែនពន្ធគយរួមមានៈ ច្បាប់និងបទដ្ឋានគតិយុត្តិ ការអនុវត្តពាណិជ្ជកម្មទំនៀមទម្លាប់ បច្ចេកវិទ្យា រូបិយវត្ថុ នីតិវិធីសារពើពន្ធ នីតិវិធីអន្តោប្រវេសន៍ និងការប្រើប្រាស់រូបិយប័ណ្ណបរទេសក្នុងការទូទាត់។

នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់របាំងមិនមែនពន្ធគយ បណ្តាប្រទេសអាស៊ានចាំបាច់ត្រូវចុះកិច្ចព្រមព្រៀងស្តីពីបញ្ហាពន្ធដារ ហិរញ្ញវត្ថុ និងបទដ្ឋានគតិយុត្តិ។ ជាមួយគ្នានេះដែរ សមាហរណកម្មសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយទាមទារឱ្យមានវិធានការធ្វើសុខុដុមនីយកម្មនៃនីតិវិធីបច្ចេកវិទ្យា ការកំណត់ស្តង់ដារ និងការវាយតម្លៃលើការអនុវត្តតាមច្បាប់ ការអនុវត្តគោលនយោបាយរួមស្តីពីការប្រកួតប្រជែង ពន្ធដារ របបសារពើពន្ធ និងការវិនិយោគ។ អាស៊ានសម្រេចបានការរីកចម្រើនក្នុងការធ្វើសុខុដុមនីយកម្មនៃស្តង់ដារ និងនីតិវិធីបច្ចេកវិទ្យាសម្រាប់ផលិតផលអគ្គិសនី គ្រឿងសម្អាង ឧសថបុរាណ និងការគ្រប់គ្រងម្ហូបអាហារ។

បណ្តាប្រទេសអាស៊ានបានដឹងថា ការសម្រួលពាណិជ្ជកម្មនឹងធ្វើឱ្យអាស៊ានអាចកាត់បន្ថយបានចំណាយប្រតិបត្តិការ និងពង្រឹងភាពប្រកួតប្រជែង ដើម្បីប្រែក្លាយអាស៊ានទៅជាកន្លែងសមាហរណកម្មទំនិញ សេវាកម្ម និងទីផ្សារវិនិយោគ និងជំរុញការបង្កើតបណ្តាញផលិតកម្មតំបន់។ ប៉ុន្តែ អាស៊ាននៅមានផ្លូវវែងឆ្ងាយណាស់ដែលត្រូវធ្វើដំណើរ។ ការអនុវត្តតាមកាលកំណត់ជូនកាលមិនអាចធ្វើទៅបានគឺនៅតែបន្តមានរបាំងមិនមែនពន្ធគយច្រើននៅឡើយ ហើយស្តង់ដារជាតិក៏មិនទាន់ស៊ីចង្វាក់គ្នា។ រដ្ឋាភិបាល កំពុងរុញយ៉ាងខ្លាំង ដើម្បីធ្វើសមាហរណកម្ម ចំណែកឯផ្នែកឯកជននៅមិនទាន់បានចូលរួមឱ្យបានពេញលេញនៅក្នុងសកម្មភាពសមាហរណកម្មនៅឡើយទេ។ ទោះបីជាមានបញ្ហាខ្លះក៏ដោយ តំបន់ពាណិជ្ជកម្មសេរីអាស៊ាននៅតែជាឧបករណ៍សំខាន់ ដើម្បីផ្តល់ជាកម្លាំងដល់អាស៊ាន ហើយរុញច្រានអាស៊ានឆ្ពោះទៅរកសមាហរណកម្មស៊ីជម្រៅជាងនេះ។

សមាហរណកម្មសេដ្ឋកិច្ចក្នុងអាស៊ានត្រូវបានបង្កើនល្បឿនតាមរយៈការអនុម័ត កាលពីខែវិច្ឆិកា នូវកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីអំពីការធ្វើសមាហរណកម្មអាស៊ានលើវិស័យអាទិភាព ដើម្បីធ្វើឱ្យក្លាយជាសហគមន៍សេដ្ឋកិច្ចអាស៊ាន ដូចដែលបានឯកភាពនៅឯកិច្ចប្រជុំកំពូលក្រុងបាលី ឆ្នាំ២០០៣។ វិស័យអាទិ-ភាពចំនួន១១ រួមមានបរិក្ខារអគ្គិសនី e-ASEAN សុខភាពសាធារណៈ ផលិតផលធ្វើអំពីឈើ យានយន្ត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផលិតផលកែច្នៃចេញពីជ័រកៅស៊ូ វាយនភ័ណ្ឌ និងសម្លៀកបំពាក់ ផលិតផលកសិកម្ម ផលិតផលនេសាទ ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍ដែលចូលរួមចំណែក ៥០% នៃពាណិជ្ជកម្មក្នុងរង្វង់អាស៊ាន។ ផែនទីបង្ហាញផ្លូវត្រូវបានគេអនុម័តដើម្បី(១)ពង្រឹងភាពប្រកួតប្រជែងរបស់អាស៊ាន(២)ពន្លឿនសមាហរណកម្មតំបន់ ដោយអនុវត្តវិធានការណ៍សេរីភាវូបនីយកម្ម និងសម្រួលពាណិជ្ជកម្មនិងការផ្សព្វផ្សាយ និង (៣) លើកទឹកចិត្តវិស័យឯកជន ឱ្យចូលរួមក្នុងសមាហរណកម្មនៃវិស័យអាទិភាព។

អាស៊ានបានអនុមតិវិធានការ ដើម្បីធ្វើសមាហរណកម្មវិស័យអាទិភាពផ្សេងៗរួមមានៈ (១) សេរីភាវូបនីយកម្ម (នៃពាណិជ្ជកម្មទំនិញ សេវាកម្ម និងការវិនិយោគ) (២) ការលុបបំបាត់ចោលរបាំងពាណិជ្ជកម្មទាំងអស់ (៣) ការសម្របសម្រួលពាណិជ្ជកម្មនិងវិនិយោគ (វិធានប្រភពដើមទំនិញ នីតិវិធីពន្ធគយ បទដ្ឋានផ្សេងៗ សេវាកម្មភស្តុភារ និងការសម្របសម្រួលទេសចរណ៍) (៤) លំហូរនៃពាណិជ្ជករ ជំនាញការ និង អ្នកមានវិជ្ជាជីវៈ (៥) ការជំរុញ និងត្រួតពិនិត្យ (ការជំរុញពាណិជ្ជកម្ម និងវិនិយោគ) និង (៦) ផ្នែកសមាហរណកម្មដទៃទៀត (កម្មសិទ្ធិឧស្សាហកម្ម ការអភិវឌ្ឍវិស័យអាទិភាព (កម្មសិទ្ធិបញ្ញា និងការអភិវឌ្ឍធនធានមនុស្ស) ។

ក្នុងឆ្នាំ១៩៩៥ ប្រទេសជាសមាជិកអាស៊ានបានចុះហត្ថលេខាលើ**កិច្ចព្រមព្រៀងជាក្របខ័ណ្ឌស្តីពីសេវាកម្ម** (AFAS) ដើម្បីលុបចោលការដាក់កម្រិតលើពាណិជ្ជកម្មសេវាកម្ម និងដើម្បីពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យសេវាកម្ម។ ក្រោមក្របខ័ណ្ឌការងារនេះ អាស៊ានបានចរចាសេរីភាវូបនីយកម្មក្នុងវិស័យអាទិភាពចំនួន៧ មានដូចជាៈ សេវាអាជីវកម្មនៃការដឹកជញ្ជូនតាមអាកាស សំណង់ ហិរញ្ញវត្ថុ ការដឹកជញ្ជូនតាមផ្លូវទឹក ទូរគមនាគមន៍ និងទេសចរណ៍។ ពិធីសារដើម្បីអនុវត្តការសន្យាជាដំបូងលើសេវាកម្មចំនួន ៥ (ការដឹកជញ្ជូនតាមអាកាស សេវាអាជីវកម្ម ការដឹកជញ្ជូនតាមផ្លូវទឹក ទូរគមនាគមន៍ និងទេសចរណ៍) បានចូលជាធរមាននៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨។ ពិធីសារដើម្បីអនុវត្តការសន្យាដំណាក់កាលទី២ និង ទី៣ ដែលផ្តោតលើសេវាអាទិភាព ៧ បានចូលជាធរមាននៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៩ និងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០២ ជាបន្តបន្ទាប់។ ការចរចាជុំទី៣បានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៤។ ភាពជឿនលឿនគួរឱ្យកត់សម្គាល់បានត្រូវសម្រេចបាន នៅឯការចរចាជុំទី៤ ដែលបានចប់ក្នុងខែតុលាឆ្នាំ២០០៦។ ប្រទេសជាសមាជិកអាស៊ានបានយល់ព្រមលុបចោលទម្រង់នៃការដាក់កម្រិតទាំងអស់ ដែលប៉ះពាល់ដល់ប្រព្រឹត្តិកម្មជាតិ និងលទ្ធភាពចូលទីផ្សារក្នុងវិស័យសេវាកម្ម ឱ្យបានមុនឆ្នាំ ២០១៥។

**កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីតំបន់វិនិយោគអាស៊ាន** (AIA) ដែលបានចុះហត្ថលេខាក្នុងឆ្នាំ១៩៩៨ បើកឱ្យមានលំហូរវិនិយោគឆ្លងកាត់តាមព្រំដែនដ៏សេរីមុនឆ្នាំ ២០២០។ កិច្ចព្រមព្រៀងនេះ រួមបញ្ចូលការវិនិយោគផ្ទាល់ក្នុងឧស្សាហកម្ម ផលិតកម្ម ជលផល រុក្ខាប្រមាញ់ ឧស្សាហកម្មរុករករ៉ែ កសិកម្ម និងសេវាកម្ម ជាប់ទាក់ទងនឹងសកម្មភាពទាំងនេះ។ ខដាក់លក្ខខណ្ឌ ដែលបានត្រូវបញ្ជាក់ច្បាស់ដោយប្រទេសសមាជិកទាំងនោះ និងបានត្រូវដាក់ក្នុងតារាងបញ្ជីលើកលែងបណ្តោះអាសន្ន នឹងត្រូវបានបញ្ចប់មុនឆ្នាំ២០១៥ ចំពោះវិនិយោគិនអាស៊ាន និងមុនឆ្នាំ២០២០ ចំពោះវិនិយោគិនដទៃទៀត។ សមាជិកស្ថាបនិកទាំង ៦ បានសម្រេចពន្លឿនដំណើរការនេះ ដោយបញ្ចប់ការដាក់លក្ខខណ្ឌ ចំពោះឧស្សាហកម្មផលិតកម្ម ក្នុងឆ្នាំ ២០០៣ សម្រាប់វិនិយោគិនអាស៊ាន និងក្នុងឆ្នាំ២០១០ សម្រាប់វិនិយោគិនដទៃទៀត។ ក្នុងឆ្នាំ២០០៣ ប្រទេសមីយ៉ាន់ម៉ា បានបញ្ចប់ការដាក់លក្ខខណ្ឌរបស់ខ្លួនចំពោះឧស្សាហកម្មផលិតកម្មសម្រាប់វិនិយោគិនអាស៊ាន។


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាស៊ានកំពុងសិក្សារកមធ្យោបាយដទៃទៀត ក្នុងការបង្កើនសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ដែលរួមមានវិធានការបន្ថែមក្នុងការលុបបំបាត់ឧបសគ្គ ដែលនៅមានចំពោះពាណិជ្ជកម្មទំនិញនិងសេវាកម្ម និងចំពោះការវិនិយោគដោយពន្លឿនសមាហរណកម្មក្នុងវិស័យអាទិភាពចំនួន១១ (ការដឹកជញ្ជូនតាមអាកាស ឧស្សាហកម្មរថយន្ត កសិឧស្សាហកម្ម គ្រឿងអេឡិចត្រូនិក ជលផល ផលិតផលសុខាភិបាល បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ផលិតផលធ្វើពីកៅស៊ូ ក្រណាត់ និងសម្លៀកបំពាក់ ទេសចរណ៍ និងឧស្សាហកម្មឈើ) និងដោយការដាក់ឱ្យអនុវត្តយន្តការដោះស្រាយជម្លោះដ៏មានប្រសិទ្ធភាព ដែលយកគំរូតាមយន្តការរបស់ WTO ដើម្បីធានាឱ្យមានការអនុវត្តតាម។ វិធានការទាំងនេះបានត្រូវដាក់ឱ្យអនុវត្តជា ដំណាក់ៗ ដោយបានចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៤។

### ២៤.៤. ការបង្រួមគម្លាតអភិវឌ្ឍន៍

អាស៊ានគឺជាបណ្តុំនៃប្រទេសដែលមានកម្រិតអភិវឌ្ឍន៍ខុសៗគ្នា។ លើកលែងតែប្រទេសសិង្ហបុរីចេញប្រទេសជាសមាជិកអាស៊ាន ជាទូទៅជាប្រទេសដែលមានសេដ្ឋកិច្ចទាប ឬមធ្យមដែលមានលក្ខណៈពិសេសមួយចំនួនដូចគ្នា។ ប៉ុន្តែពួកគេមានគម្លាតសេដ្ឋកិច្ចគួរឱ្យចាប់អារម្មណ៍ ក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន។ គម្លាតអភិវឌ្ឍន៍រវាងសមាជិកចាស់ ៦ (អាស៊ាន-៦) និងសមាជិកថ្មី (CLMV) គឺមានទំហំធំ និងខុសគ្នាតាមលក្ខណៈរបស់ពួកគេ។ ការបង្រួមគម្លាតអភិវឌ្ឍន៍តម្រូវឱ្យមានកំណែទម្រង់សេដ្ឋកិច្ចនិងសង្គមជាក់ស្តែងពីសំណាក់ប្រទេសសមាជិកថ្មី និងការគាំទ្រពេញលេញពីសំណាក់ប្រទេសសមាជិកដែលមានការអភិវឌ្ឍខ្ពស់ជាង។

ជាមធ្យោបាយកាត់បង្រួមគម្លាតអភិវឌ្ឍន៍ក្នុងអាស៊ាន និងជួយប្រទេសសមាជិកថ្មីរបស់អាស៊ាន ដែលមានកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) ក្នុងដំណើរការសមាហរណកម្មក្នុងតំបន់ អាស៊ានបានប្រកាសនូវការផ្តួចផ្តើមគំនិតស្តីពីសមាហរណកម្មអាស៊ាន (IAI) ក្នុងខែវិច្ឆិកា ឆ្នាំ២០០០ នៅឯកិច្ចប្រជុំកំពូលអាស៊ានលើកទី៤។ ការផ្តួចផ្តើមគំនិតដើម្បីសមាហរណកម្មអាស៊ាន (IAI) ឈរលើគោលការណ៍ «ដោយជួយធ្វើឱ្យប្រទេសជិតខាងរីកចម្រើន អាស៊ាននឹងរីកចម្រើន» ។ ផែនការសកម្មភាព និងគម្រោងជាក់ស្តែងនានាត្រូវបានរៀបចំឡើង និងត្រូវបានអនុម័តដោយកិច្ចប្រជុំកំពូលអាស៊ានលើកទី៦ នារាជធានីភ្នំពេញក្នុងខែវិច្ឆិកាឆ្នាំ ២០០២ ដើម្បីអនុវត្តគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI) ។ ផែនការសកម្មភាពនោះបានផ្តោតលើវិស័យអាទិភាព៤៖ ហេដ្ឋារចនាសម្ព័ន្ធ (ការដឹកជញ្ជូននិងថាមពល) ការអភិវឌ្ឍធនធានមនុស្ស (ការកសាងសមត្ថភាពនៃវិស័យសាធារណៈ កម្លាំងពលកម្ម និកម្មភាព និងឧត្តមសិក្សា) បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និង ការជំរុញសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ (ពាណិជ្ជកម្មទំនិញនិងសេវាកម្ម ពន្ធគយបទដ្ឋាន និងការវិនិយោគ) ក្នុងប្រទេសសមាជិកអាស៊ានថ្មី CLMV ។ គម្រោងនៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI) សរុបមានចំនួន ៨៥ ប៉ុន្តែមានតែ ៦១ គម្រោងទេ ដែលរកបានប្រភពមូលនិធិ ដែលក្នុងនោះ ២១ គម្រោងបានបញ្ចប់រួចហើយ ១៣ គម្រោងកំពុងដំណើរការ និង២៦គម្រោងកំពុងតែត្រូវបានរៀបចំ។ ប្រទេសសមាជិកអាស៊ានចាស់ទាំង៦បានផ្តល់ទឹកប្រាក់ ៣.៦ លានដុល្លារអាមេរិក ដើម្បីធ្វើហិរញ្ញប្បទានគម្រោងទាំងនេះ។ គំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI) គឺជាកម្មវិធីប្រកបដោយមហិច្ឆតា។ ក្នុងចំណោមគម្រោងនានា មានគម្រោងមួយដែលជាគម្រោងសាងសង់ផ្លូវដែកឆ្លងកាត់អាស៊ី រវាងសិង្ហបុរី និងគុនម៉ិញ ដែលនឹងតភ្ជាប់សឹង្ហបុរី ម៉ាឡេស៊ី ថៃ កម្ពុជា វៀតណាម និងចិន។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្រទេសបូកបី មានសារៈសំខាន់ខ្លាំងណាស់ សម្រាប់អនុវត្តគម្រោងនានារបស់អាស៊ាន។ ម្ចាស់ជំនួយទ្វេភាគី និងពហុភាគីដូចជាអង្គការ JICA UNDP និងដៃគូអភិវឌ្ឍន៍ដទៃទៀតបានសន្យារួចហើយថា នឹងផ្តល់មូលនិធិដល់គម្រោងរបស់ IAI មួយចំនួន។ ដើម្បីបំពេញកង្វះខាតនៃធនធានអាស៊ានបានបង្កើតមូលនិធិអភិវឌ្ឍន៍ ដើម្បីទទួលវិភាគទានពីសំណាក់ប្រទេសសមាជិកទាំងអស់។

## ២៤.៥. សមាហរណកម្មហិរញ្ញវត្ថុក្នុងអាស៊ាន

### ២៤.៥.១. ផែនទីបង្ហាញផ្លូវសម្រាប់សមាហរណកម្មហិរញ្ញវត្ថុអាស៊ាន

**កម្មវិធីសកម្មភាពវៀងច័ន្ទ** (VAP) ដែលយល់ព្រមដោយមេដឹកនាំអាស៊ានក្នុងឆ្នាំ២០០៤ មានរយៈពេល៦ឆ្នាំ និងមានគោលបំណង ដើម្បីដាក់ដំណើរការសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលផ្អែកលើសសរស្តម្ភចំនួន៣ គឺៈ កិច្ចសហប្រតិបត្តិការនយោបាយនិងសន្តិសុខ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការសង្គមនិងវប្បធម៌។

កម្មវិធីសកម្មភាពវៀងច័ន្ទ (VAP) នេះគិតគូរលើជំហានសំខាន់ ទាក់ទងនឹងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ដែលយកមកពីផែនទីបង្ហាញផ្លូវសម្រាប់សមារណកម្មហិរញ្ញវត្ថុ និង រូបិយវត្ថុអាស៊ាន (RMFMIA) ។ ផែនទីបង្ហាញផ្លូវសម្រាប់សមារណកម្មហិរញ្ញវត្ថុ និង រូបិយវត្ថុអាស៊ាន (RMFMIA) មានគោលដៅបង្កើនសមត្ថភាពអភិវឌ្ឍនៃទីផ្សារហិរញ្ញវត្ថុក្នុងតំបន់ តាមរយៈកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីអាស៊ាន សម្រាប់បង្កើនសមត្ថភាពគ្រប់គ្រង និង ត្រួតពិនិត្យទីផ្សារហិរញ្ញវត្ថុ។ គំនិតផ្តួចផ្តើមទាំងនេះនឹងជួយដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការអនុវត្ត និងបទដ្ឋានទីផ្សារ ដែលរួមមាន ការគ្រប់គ្រងហានិភ័យ និងការបង្កើនសាច់ប្រាក់ងាយស្រួល។

អាស៊ានក៏មានគោលបំណងជំរុញសមាហរណកម្មបន្ថែមទៀតលើទីផ្សារហិរញ្ញវត្ថុ ដោយតភ្ជាប់ផ្សារហ៊ុនអាស៊ានមុនឆ្នាំ២០១០ ឱ្យទៅជាបណ្តាញដ៏រលូន និង ស្អិតរមួតមួយ។ សមាហរណកម្មនេះនឹងត្រូវសម្រេចបានតាមរយៈការធ្វើសុខដុមនីយកម្មនៃបទដ្ឋាន ការអនុវត្តល្អ ការសម្របសម្រួលការទិញភាគហ៊ុនឆ្លងកាត់ព្រំដែន និងការរៀបចំស្តង់ដារអាស៊ានសម្រាប់វិនិយោគលើទ្រព្យសកម្ម។ ដើម្បីអនុវត្តដំណើរការសមាហរណកម្ម បណ្តារដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានបានរៀបចំអង្គសិក្ខាសាលាជាបន្តបន្ទាប់ ដើម្បីបើកដំណើរការសន្ទស្សន៍ ពីរគឺៈ សន្ទស្សន៍ FTSE/ASEAN ដែលមានស្ថាប័ន៨០ ដែលដើរតួនាទីជាស្ថាប័នមូលដ្ឋានសម្រាប់ផ្សារហ៊ុនក្នុងតំបន់ និងសន្ទស្សន៍ទីផ្សារ FTSE/ASEAN 40 ដែលកើតឡើងពីសហគ្រាសធំបំផុតចំនួន៤០ ដែលបានចុះបញ្ជីក្នុងផ្សារហ៊ុនអាស៊ាន។

ក្រុមការងារពីរបានត្រូវបង្កើតឡើង ដើម្បីសិក្សាពីមធ្យោបាយក្នុងការឈានដល់គោលដៅនេះ។ ក្រុមទី១សិក្សាលើការរួមបញ្ចូល និងការតភ្ជាប់រវាងផ្សារហ៊ុនអាស៊ាន ហើយក្រុមទី២ពិនិត្យលើរបៀបពង្រីកការតភ្ជាប់ក្នុងចំណោមផ្សារមូលបត្រអាស៊ាន។

### ២៤.៥.២. សេរីភាវូបនីយកម្មនៃគណនីមូលធនអាស៊ាន

ដំណើរការកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ានមានទិសដៅ ធ្វើសេរីភាវូបនីយកម្មនៃគណនីមូលធនតាមលំដាប់លំដោយ ក្នុងគោលបំណងគាំទ្រកំណើនសេដ្ឋកិច្ច និងធានាបាននូវស្ថេរភាពហិរញ្ញវត្ថុ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងម៉ាក្រូសេដ្ឋកិច្ច។ ចក្ខុវិស័យអាស៊ាន គឺបង្កើតឱ្យបានមុនឆ្នាំ២០២០នូវលំហូរទុនដ៏សេរីឆ្លងកាត់ព្រំដែន ដែលអាចជួយធ្វើឱ្យប្រសើរឡើង នូវប្រសិទ្ធភាពនិងសុខុមាលភាពសេដ្ឋកិច្ចក្នុងតំបន់។ ខណៈពេលជាមួយគ្នានេះប្រទេសជាសមាជិកអាស៊ានបានយល់ពីហានិភ័យដ៏សម្បើម ដែលកើតឡើងជាមួយសេរីភាវូបនីយកម្ម ប្រសិនបើទីផ្សារក្នុងស្រុកណាមួយខ្វះខាតសមត្ថភាពផ្នែកស្ថាប័ន និងធនធានមនុស្សក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុ។

Mongrué និង Robert (២០០៥) បង្ហាញថា សេរីភាវូបនីយកម្មនៃគណនីមូលធនផ្តល់នូវអត្ថប្រយោជន៍មួយចំនួនដល់ប្រទេសកំពុងតែរីកចម្រើន។ សេរីភាវូបនីយកម្មនេះជួយពន្លឿនចលនាប្រមូលផ្តុំសេដ្ឋកិច្ច ដោយផ្តល់ភាពអាចប្រើប្រាស់បានចំពោះប្រាក់សន្សំជាសកល។ ដំណើរការនេះក៏ជួយបង្កើនភាពធន់នៃសេដ្ឋកិច្ច នៅពេលដែលប្រឈមជាមួយបម្រែបម្រួលដ៏ធំមកពីខាងក្រៅប្រព័ន្ធ ដោយសម្របសម្រួលភាពខុសគ្នាតាមវិស័យ។ ដំណើរការនេះរួមចំណែកដល់ការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធធនាគារ ដោយពង្រឹងការប្រកួតប្រជែងនិងជាហេតុនាំឱ្យថ្លៃនៃការផ្តល់ហិរញ្ញប្បទានទាបជាងមុន។ ជាងនេះទៀត វិនិយោគបរទេសផ្ទាល់ជួយដល់ការផ្ទេរបច្ចេកវិទ្យា។ ក្រៅពីនេះទៀត សេរីភាវូបនីយកម្មនៃគណនីមូលធននឹងអាចឱ្យប្រទេសជាសមាជិកអាស៊ានបញ្ជូនប្រាក់ចូលទៅដាក់ក្នុងប្រាក់សន្សំក្នុងតំបន់ ហើយវិនិយោគប្រាក់នោះនៅកន្លែងផ្សេងទៀតក្នុងពិភពលោក។

មេរៀនសំខាន់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ១៩៩៧-១៩៩៨ គឺថា ការធ្វើទំនើបកម្មប្រព័ន្ធហិរញ្ញវត្ថុគឺជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការបើកគណនីមូលធន។ លក្ខខណ្ឌចាំបាច់សម្រាប់ធ្វើសេរីភាវូបនីយកម្មគណនីមូលធនតាមលំដាប់លំដោយមានដូចខាងក្រោម៖

- របបអត្រាប្តូរប្រាក់ត្រូវតែមានភាពអាចប្រែប្រួលបាន។
- បរិយាកាសម៉ាក្រូសេដ្ឋកិច្ចចាំបាច់ត្រូវតែមានស្ថេរភាព។
- ប្រព័ន្ធហិរញ្ញវត្ថុចាំបាច់ត្រូវតែអាចដើរតួនាទីរបស់ខ្លួនក្នុងការធ្វើអន្តរការីកម្ម និងវាយតម្លៃហានិភ័យរបស់ខ្លួនទៅនឹងហានិភ័យឥណទាន (កម្រិតអប្បបរមានៃការគ្រប់គ្រងនិងត្រួតពិនិត្យបទដ្ឋានតឹងរ៉ឹងក្នុងការធ្វើសវនកម្មគណនី តម្លាភាព និងការប្រកាសជាសាធារណៈនៃព័ត៌មានហិរញ្ញវត្ថុ) ។
- បរិធានទីផ្សារចាំបាច់ត្រូវតែបង្កើតឡើងក្នុងកម្រិតសមល្មមមួយ ជាពិសេសសម្រាប់បំណុលសាធារណៈនិងការគ្រប់គ្រងទីផ្សាររូបិយប័ណ្ណ។
- បរិបទនយោបាយក៏ចាំបាច់ទាមទារឱ្យមានការគិតគូរផងដែរ ជាពិសេសហានិភ័យ ក្រមសីលធម៌ដែលអាចកើតមានខណៈពេលដែលជួយសង្គ្រោះធនាគារដែលបានដួលរលំ។

ប្រទេសសមាជិកអាស៊ានជឿជាក់ថា សេរីភាវូបនីយកម្មនៃទីផ្សារហិរញ្ញវត្ថុនឹងអាចជួយឱ្យមានប្រសិទ្ធភាពសេដ្ឋកិច្ច ពីព្រោះការត្រួតពិនិត្យទប់ស្កាត់ល្អ អភិបាលកិច្ចនៃសាជីវកម្មល្អ សិទ្ធិរបស់ឥណទាយកត្រូវបានការពារបទដ្ឋានគណនេយ្យ និងសវនកម្មមានតម្លាភាព និងនីតិវិធីក្ស័យធន និងអសាធភាពត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដោយគិតពិចារណាលើទម្រង់សេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុដែលខុសៗគ្នានៃប្រទេសជាសមាជិករបស់ខ្លួន អាស៊ានបានអនុម័តយកវិធីសាស្ត្រដែលអាចបត់បែនបានមួយ ក្នុងការអនុវត្តសេរីភាវូបនីយកម្មគណនីមូលធន។ ទោះបីជាប្រទេសជាសមាជិកបានយល់ស្របថា សេរីភាវូបនីយកម្មនៃគណនីមូលធនត្រូវតែធ្វើឡើងក្នុងលក្ខណលំដាប់លំដោយ និងក្នុងជំហានជាមួយសេរីភាវូបនីយកម្មហិរញ្ញវត្ថុ ប្រទេសនីមួយៗមានសេរីភាពក្នុងការតាក់តែងកម្មវិធីសេរីភាវូបនីយកម្មគណនីមូលធនផ្ទាល់ខ្លួន ដើម្បីជៀសវាងផលប៉ះពាល់ដែលអាចបង្កគ្រោះថ្នាក់នៃការដកមូលធនចេញ ដែលបានកើតឡើងក្នុងកំឡុងពេលវិបត្តិហិរញ្ញវត្ថុអាស៊ី។ គេហទំព័រស្តីពីរបបគណនីមូលធនអាស៊ានត្រូវបានដាក់ឱ្យដំណើរការក្នុងខែមេសាឆ្នាំ២០០៦ ក្នុងកំឡុងពេលនៃកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១០ ដើម្បីអាចឱ្យប្រទេសសមាជិកនីមួយៗគិតឃើញនូវប្រព័ន្ធមួយស័ក្តិសមបំផុតសម្រាប់ខ្លួន និងចាត់វិធានការសម្រាប់កំណែទម្រង់ស្ថាប័នហិរញ្ញវត្ថុនិងការប្រព្រឹត្តទៅនៃអាជ្ញាធរដែលជានិយ័តករចំពោះសេរីភាវូបនីយកម្មគណនីមូលធន។

## ២៤.៥.៣. សេរីភាវូបនីយកម្មនៃសេវាកម្មហិរញ្ញវត្ថុក្នុងអាស៊ាន

សេវាកម្មហិរញ្ញវត្ថុនៃប្រទេសជាសមាជិកអាស៊ាន បានត្រូវធ្វើសេរីភាវូបនីយកម្មបន្តិចម្តងៗក្រោមកិច្ចព្រមព្រៀង AFAS ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាននៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៥។ ផ្អែកលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ កិច្ចចរចាចាំបាច់ត្រូវតែធ្វើឡើងដើម្បីបំពេញការប្តេជ្ញានៃប្រទេសសមាជិកចំពោះការសន្យារបស់ពួកគេ ក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ។

កិច្ចចរចាជុំទី១ ដែលមានគោលដៅធ្វើសេរីភាវូបនីយកម្មនៃពាណិជ្ជកម្មសេវាកម្មហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង ក្រោមការគាំទ្ររបស់គណៈកម្មាធិការសម្របសម្រួលសេវាកម្មអាស៊ាន។ ប៉ុន្តែក្នុងខែមិថុនាឆ្នាំ ១៩៩៩ រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានបានសម្រេចផ្ទេរក្របខ័ណ្ឌការងារចរចាស្តីពីសេវាកម្មហិរញ្ញវត្ថុទៅឱ្យរដ្ឋមន្ត្រីហិរញ្ញវត្ថុវិញ។ កិច្ចចរចាស្តីពីសេរីភាវូបនីយកម្មនៃសេវាកម្មហិរញ្ញវត្ថុបច្ចុប្បន្នត្រូវបានអនុវត្តក្រោមការគាំទ្ររបស់កិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន។ ក្រុមការងារមួយសម្រាប់កិច្ចការសេរីភាវូបនីយកម្មហិរញ្ញវត្ថុអាស៊ាន ក្រោមកិច្ចព្រមព្រៀងជាក្របខ័ណ្ឌស្តីពីសេវាកម្មអាស៊ាន (AFAS) បានត្រូវបង្កើតឡើង ដើម្បីដឹកនាំកិច្ចការដ៏សំខាន់នេះ។ អញ្ញត្តិរយៈពេលខ្លីនិងវែងចំពោះសេរីភាវូបនីយកម្មត្រូវបានបង្កើតឡើង។

ទាក់ទងនឹងអញ្ញត្តិរយៈពេលខ្លី ប្រទេសជាសមាជិកអាស៊ានបានឈានដល់កិច្ចព្រមព្រៀងមួយដើម្បីស្នើឡើងនូវការប្តេជ្ញាយ៉ាងតិចបំផុតក្នុងមួយអនុវិស័យ សម្រាប់ការចរចាជុំនីមួយៗ។ សម្រាប់ប្រទេសជាសមាជិក WTO ការប្តេជ្ញាទាំងនេះត្រូវតែលើសពីការប្តេជ្ញាក្រោមកិច្ចព្រមព្រៀង GATS ហើយការប្តេជ្ញាទាំងនេះមានលក្ខណអនុគ្រោះជាងរបបបច្ចុប្បន្ន ចំពោះប្រទេសមិនមែនជាសមាជិក WTO ។

អញ្ញត្តិរយៈពេលវែងសម្រាប់នាំផ្លូវដំណើរការសេរីភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុមានដូចខាងក្រោម៖

- សេរីភាវូបនីយកម្មនៃសេវាកម្មហិរញ្ញវត្ថុត្រូវធ្វើស្របទៅតាមទិសដៅ «លំហូរសេវាកម្មដោយសេរីមុនឆ្នាំ២០២០» ។ ប៉ុន្តែការធ្វើសេរីភាវូបនីយកម្មសេវកម្មហិរញ្ញវត្ថុត្រូវធ្វើឡើងជាដំណាក់ ដោយគិតគូរពីកម្រិតខុសៗគ្នានៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់ប្រទេសនីមួយៗនិងតម្រូវការក្នុងការពង្រឹងបទបញ្ញត្តិប្រុងប្រយ័ត្ន ការត្រួតពិនិត្យដែលមានប្រសិទ្ធភាព និងសមត្ថភាពស្ថាប័ន។

- ប្រទេសជាសមាជិកមានសេរីភាពក្នុងការរៀបចំដំណាក់កាលសម្រាប់សេរីភាវូបនីយកម្ម អនុវិស័យ និងក្នុងការលុបចោលការដាក់កំហិត ដោយគោរពទៅតាមវិធីទាំង៤នៃការផ្ដល់សេវា អនុវត្តតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀង GATS ស្ដីពីការចូលទីផ្សារ ប្រព្រឹត្តកម្មជាតិ និងគោលការណ៍នៃប្រទេសទទួលការអនុគ្រោះបំផុត (MFN) ។
- ដំណាក់ការទាំងនេះ នឹងត្រូវកំណត់ម្ដងក្នុងរយៈពេល៣ឆ្នាំសម្រាប់ការចរចាជុំថ្មី ដោយគិតគូរពីលទ្ធផលនៃជុំនីមួយៗ ដើម្បីរក្សាល្បឿននៃការធ្វើសេរីភាវូបនីយកម្មរហូតដល់ឆ្នាំ ២០២០។
- ការពិនិត្យឡើងវិញនឹងត្រូវធ្វើឡើងដើម្បីធានាថា ការប្ដេជ្ញាក្រោមកិច្ចព្រមព្រៀងAFAS ធ្វើបានដូចការគ្រោងទុកនិងស្របទៅតាមគោលដៅរយៈពេលវែងនៃលំហូរសេវាកម្មដោយសេរី។
- ការប្ដេជ្ញាទាំងអស់គឺជាកាតព្វកិច្ចផ្លូវច្បាប់។

ជាមួយកិច្ចព្រមព្រៀងលើអញ្ញត្តិរយៈពេលខ្លីនិងវែង កិច្ចចរចារជុំទីស្ដីពីសេរីភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុក្រោមកិច្ចព្រមព្រៀង AFAS បានត្រូវចាប់ផ្ដើមក្នុងឆ្នាំ ២០០១ និងបញ្ចប់ក្នុងឆ្នាំ ២០០២។ ពិធីសារអនុវត្តការប្ដេជ្ញាគម្រោងទី ២ បានត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០០២ នាទីក្រុងយ៉ាងហ្គូន ប្រទេសមីយ៉ាន់ម៉ា។ កិច្ចចរចាជុំទី៣បានចាប់ផ្ដើមក្នុងឆ្នាំ២០០៣ ហើយពិធីសារអនុវត្តការប្ដេជ្ញាគម្រោងទី៣បានត្រូវចុះហត្ថលេខានៅឯកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុលើទី៩ក្នុងខែមេសា ឆ្នាំ២០០៥ នាទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។ កិច្ចចរចាជុំទី៤ស្ដីពីសេរីភាវូបនីយកម្ម សេវាកម្មហិរញ្ញវត្ថុបានចាប់ផ្ដើមនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ នាក្រុងសៀមរាប។ កិច្ចចរចាជុំនេះផ្អែកលើវិធីសាស្ត្រតារាងវិជ្ជមាន និងបានត្រូវគ្រោងបញ្ចប់មុនចុងឆ្នាំ២០០៧។

## ២៤.៩.៤. ការពង្រីកកិច្ចសហប្រតិបត្តិការរូបិយវត្ថុ

ដើម្បីការពារទុកជាមុន ចំពោះការវាយប្រហារមកលើរូបិយប័ណ្ណក្នុងតំបន់ និងដើម្បីបង្កើតប្រព័ន្ធសហប្រតិបត្តិការហិរញ្ញវត្ថុទៅវិញទៅមកក្នុងតំបន់ ប្រទេសសមាជិកអាស៊ានបានដាក់ឱ្យដំណើរការក្នុងឆ្នាំ២០០២ នូវមូលនិធិផ្លាស់ប្ដូរ (SWAP) របស់អាស៊ាន ដែលបានក្លាយជាមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន។ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការនេះ ប្រទេសជាសមាជិកអាស៊ានបានបង្កើនទំហំទឹកប្រាក់នៃកញ្ចប់ថវិកាបង្វិលរបស់អាស៊ានពីមួយពាន់លានដុល្លារអាមេរិក ដល់ពីរពាន់លានដុល្លារអាមេរិកនៅឯកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១០ ក្នុងខែមេសា ឆ្នាំ២០០៦។ ប្រសិនបើវិបត្តិហិរញ្ញវត្ថុកើតឡើងដែល បណ្ដាលឱ្យមានកង្វះខាតសាច់ប្រាក់ងាយស្រួល ដោយសារតែមានការដកចេញវិញនៃទុនបរទេស ប្រទេសសមាជិកអាស៊ានអាចស្នើសុំមូលនិធិផ្លាស់ប្ដូររបស់អាស៊ាន មុនពេលដែលរកជំនួយពីមូលនិធិផ្លាស់ប្ដូរទ្វេភាគីពីប្រទេសបូក៣។ ក្រៅពីនេះលេខាធិការដ្ឋានអាស៊ានកំពុងរៀបចំរបាយការណ៍ត្រួតពិនិត្យអាស៊ានដែលបានរៀបចំឡើង ដើម្បីសម្របសម្រួលការពិភាក្សាលើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិក។

## ២៤.៦. ទំនាក់ទំនងការបរទេសអាស៊ាននិងយន្តការពិគ្រោះយោបល់

### ២៤.៦.១. សន្និសីទក្រោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេស និងភាពជាដៃគូសន្ទនា

រដ្ឋមន្ត្រីការបរទេសអាស៊ានរៀបចំកិច្ចពិគ្រោះយោបល់ប្រចាំឆ្នាំ នៅឯសន្និសីទក្រោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេស ជាមួយនឹងរដ្ឋមន្ត្រីការបរទេសនៃប្រទេសដៃគូសន្ទនា (អូស្ត្រាលី កាណាដា ចិន សហគមន៍អឺរ៉ុប ឥណ្ឌា ជប៉ុន ណូវែលហ្សេឡង់ រុស្ស៊ី សហរដ្ឋអាមេរិក ប៉ាហ្គីស្តង់ កូរ៉េខាងត្បូង និងអង្គការ UNDP)។ សន្និសីទក្រោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេស ត្រូវបានធ្វើឡើង ក្រោយកិច្ចប្រជុំឧត្តមមន្ត្រីនិងកិច្ចប្រជុំឧត្តមមន្ត្រីការបរទេស។

សន្និសីទក្រោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេស គឺជាកម្រិតជំនួបដ៏សំខាន់ដែលបញ្ហាក្នុងតំបន់ទាក់ទងនឹងអាស៊ីអាគ្នេយ៍ ដែលពិភាក្សាលើបញ្ហាដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក។ សន្និសីទក្រោយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសមានពីរផ្នែកគឺ៖ កិច្ចប្រជុំពេញអង្គ ដែលចូលរួមដោយប្រទេសជាសមាជិកអាស៊ានទាំងអស់ និងដៃគូសន្ទនារបស់ខ្លួន ដែលជាតំណាងកម្រិតថ្នាក់រដ្ឋមន្ត្រី និងកិច្ចប្រជុំ «១០+១» ជាបន្តបន្ទាប់រវាងអាស៊ាន និងប្រទេសដៃគូសន្ទនានីមួយៗ។

### ២៤.៦.២. កិច្ចប្រជុំវេទិកាតំបន់អាស៊ាន

**កិច្ចប្រជុំវេទិកាតំបន់អាស៊ាន** (ARF) បានត្រូវបង្កើតឡើងក្នុងឆ្នាំ១៩៩៤ ដើម្បីរក្សាសន្តិភាពនិងស្ថេរភាព និងជម្រុញការអភិវឌ្ឍនិងវិបុលភាពក្នុងតំបន់។ កិច្ចប្រជុំវេទិកាតំបន់អាស៊ាន (ARF) ត្រូវបានបង្កើតឡើងដោយប្រទេសសមាជិកអាស៊ានទាំង១០ និងភាគីចូលរួម១៥ ដែលមានឥទ្ធិពលលើសន្តិសុខក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិចដែលមានប្រទេស៖ អូស្ត្រាលី កាណាដា ចិន ទីម័រខាងកើត សហគមន៍អឺរ៉ុប ឥណ្ឌា ជប៉ុន ម៉ុងហ្គោលី ណូវែលហ្សេឡង់ ប៉ាហ្គីស្តង់ ប៉ាពួញូហ្គីនី សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋប្រជាមានិតកូរ៉េ រុស្ស៊ី និងសហរដ្ឋអាមេរិក។ ARF ផ្តល់វេទិកាសម្រាប់គោលនយោបាយនិងសន្តិសុខក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច។

គោលបំណងសំខាន់នៃ ARF គឺប្រើប្រាស់កិច្ចសន្ទនាដោយចំហ ដើម្បីកាត់បន្ថយការគំរាមកំហែងចំពោះសន្តិសុខ ដែលរួមទាំងផ្នែកយោធា សេដ្ឋកិច្ច នយោបាយ និងសង្គម។ ARF កំពុងតែមានការជឿនលឿនលើមុខព្រួញ៣ ដែលនោះគឺ៖ ការកសាងទំនុកចិត្ត កិច្ចការការទូតសម្រាប់បង្ការជម្លោះ និងការបង្កើតឡើងនូវយន្តការដោះស្រាយជម្លោះនានា។ ARF មានសក្តានុពលភាពជាយន្តការគំរូមួយសម្រាប់ការជំរុញគោលដៅក្នុងផ្នែកសន្តិសុខសាកលរួមមាន ការប្រឆាំងអំពើភេរវកម្ម សន្តិសុខប្រជាជន ការមិនឱ្យរីកសាយភាយអាវុធបរមាណូ និងអាវុធគីមី ការគ្រប់គ្រងសព្វាវុធ និងការកាត់បន្ថយអាវុធ និងការបង្ការមិនឱ្យមានជម្លោះ។

## ២៤.៧. ការបង្កើតសហគមន៍អាស៊ាន

Balassa (ឆ្នាំ១៩៦១) បានពណ៌នាពីដំណាក់កាល៥ ទាក់ទងនឹងសមាហរណកម្មសេដ្ឋកិច្ច៖ (១) តំបន់ពាណិជ្ជកម្មសេរី (លុបបំបាត់ចោលពន្ធគយក្នុងចំណោមប្រទេសសមាជិក) (២) សហគមន៍គយ (អនុម័តយកអត្រាពន្ធគយរួមសម្រាប់ការនាំចូលពីខាងក្រៅសហគមន៍)(៣) ទីផ្សាររួម(លំហូរដ៏សេរីនៃពលកម្ម និងមូលធន) (៤) សហគមន៍សេដ្ឋកិច្ច (សម្របសម្រួលគោលនយោបាយសេដ្ឋកិច្ច) និង (៥) សមាហរណកម្ម

សេដ្ឋកិច្ចទាំងស្រុង (រូបិយប័ណ្ណរួម និងប្រព័ន្ធថវិការួមបញ្ចូលគ្នា) ។ អ្នកនិពន្ធខ្លះលើកឡើងអំពីសហគមន៍នយោបាយថាជាដំណាក់កាលទី៥នៃសមាហរណកម្មក្នុងតំបន់។

ប៉ុន្តែសមាហរណកម្មក្នុងអាស៊ានមិនចាំបាច់ត្រូវតែយកតាមដំណាក់កាលចាស់ ដូចដែលបានរៀបរាប់ដោយ Balassa នោះទេ។ សមាហរណកម្មក្នុងអាស៊ានមិនត្រូវបានគាត់តែងឡើង ដោយប្រើប្រាស់គំរូរបស់អឺរ៉ុបទេ ហើយនិងដំណើរការក្នុងល្បឿនមួយស្របតាមវប្បធម៌អាស៊ី ដោយប្រើប្រាស់វិធីមិនបង្ខំ។ ចុងក្រោយការសម្រេចបាននូវ AFTA, AFTA Plus, IAI, និង AIA នឹងបង្កើតលទ្ធភាពសម្រាប់ដាក់ឱ្យដំណើរការសហគមន៍ក្នុងតំបន់មួយ ដែលមានសមត្ថភាពប្រឈមមុខនឹងបញ្ហាប្រឈមមុខនានាក្នុងពេលអនាគត។ ការសម្រេចចិត្តក្នុងការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ានមុនឆ្នាំ ២០២០ គឺជាជំហានមួយក្នុងទិសដៅសមាហរណកម្មសេដ្ឋកិច្ច។

## ២៤.៧.១. សហគមន៍នយោបាយនិងសន្តិសុខអាស៊ាន (ASEAN Political-Security Community)

គោលការណ៍ទាំង១២នៃ **សហគមន៍នយោបាយនិងសន្តិសុខអាស៊ាន** មានគោលដៅពង្រឹងការអនុវត្តលិខិតតូបករណ៍នយោបាយ ដែលមានស្រាប់៖ **សន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការ** (TAC) **សេចក្តីថ្លែងការណ៍ស្តីពីតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹតភាព** (ZOPFAN) និង **សន្ធិសញ្ញាស្តីពីអាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ** (SEANWFZ) ដែលកំពុងបន្តដើរតួនាទីឈានមុខ ក្នុងការពង្រឹងការកសាងទំនុកចិត្ត ការទូតបង្ការជម្លោះ និងដំណោះស្រាយវិវាទដោយសន្តិវិធី។ សហគមន៍នយោបាយ-សន្តិសុខអាស៊ានក៏មានបំណងពង្រឹងផងដែរ នូវសមត្ថភាពជាតិដល់ប្រទេសជាសមាជិក ដើម្បីប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនដទៃទៀត។

បណ្តាញសហប្រតិបត្តិការយោធារវាងប្រទេសអាស៊ាន និងបណ្តាប្រទេសដទៃទៀតនៃអាស៊ីខាងកើត និងអាស៊ីខាងត្បូង បានបើកចំហរនូវសករាជ្យថ្មីមួយនៃសហប្រតិបត្តិការសន្តិសុខ ដោយឆ្លុះបញ្ចាំងនូវសហប្រតិបត្តិការក្នុងបណ្តាប្រទេសនានា ដើម្បីដោះស្រាយការគំរាមកំហែងពីប្រភពមិនមែនបែបប្រពៃណី ដូចជាភេរវកម្មអន្តរជាតិ និងការបះបោរ និងដើម្បីថែរក្សាសន្តិភាពនិងស្ថេរភាពក្នុងតំបន់។

ទោះជាយ៉ាងណាក៏ដោយ សហគមន៍នយោបាយ-សន្តិសុខអាស៊ានទទួលស្គាល់ នូវសិទ្ធិរបស់ប្រទេសជាសមាជិក ក្នុងការអនុវត្តនូវគោលនយោបាយការបរទេស និងយោធារបស់ខ្លួន ដោយពិចារណាទៅលើទំនាក់ទំនងអន្តរប្រតិសកម្ម រវាងកត្តានយោបាយ សេដ្ឋកិច្ច និងសង្គម។ ដូចគ្នាផងដែរ ក្រុមប្រឹក្សាជាន់ខ្ពស់នៃសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការ នឹងក្លាយទៅជាធាតុផ្សំដ៏ចម្បងមួយរបស់សហគមន៍ ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវការប្តេជ្ញាចិត្តរបស់អាស៊ាន ដើម្បីដោះស្រាយជម្លោះឬវិវាទជាមួយគ្នាដោយសន្តិវិធី។ ក្នុងន័យនេះ **វេទិកាតំបន់អាស៊ាន** (ASEAN Regional Forum) នឹងនៅតែជាវេទិការមួយ សម្រាប់ការផ្លាស់ប្តូរយោបល់លើបញ្ហាសន្តិសុខក្នុងតំបន់ ដោយមានអាស៊ានអ្នកដើរតួនាទីជាអ្នកដឹកនាំ និងទាក់ទងជាមួយប្រទេសជាមិត្តទាំងអស់ជាដៃគូសន្ទនា និងជាអង្គការសហប្រជាជាតិ ដើម្បីជាប្រយោជន៍នៃការលើកស្ទួយសន្តិភាពនិង ស្ថេរភាពក្នុងតំបន់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ២៤.៧.២. សហគមន៍សេដ្ឋកិច្ចអាស៊ាន ( ASEAN Economic Community )

គោលដៅនៃ**សហគមន៍សេដ្ឋកិច្ចអាស៊ាន** គឺការសម្រេចបាននូវសមាហរកម្មសេដ្ឋកិច្ចដ៏ពេញលេញរបស់អាស៊ាន ដោយមានចរាចរដោយសេរីនៃទំនិញ សេវាកម្ម ការវិនិយោគ មូលធន និងពលករដែលមានជំនាញ។ សហគមន៍សេដ្ឋកិច្ចអាស៊ានមានគោលសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយសមធម៌ និងកាត់បន្ថយភាពក្រីក្រ និងគម្លាតសេដ្ឋកិច្ច-សង្គម នៅក្នុងតំបន់ត្រឹមឆ្នាំ ២០២០។

សហគមន៍សេដ្ឋកិច្ចអាស៊ានក៏មានគោលបំណងផងដែរ ក្នុងការបង្កើតទីផ្សាររួម និងមូលដ្ឋានផលិតកម្មរួមនៅក្នុងអាស៊ាន ដោយការកែប្រែគម្លាតអភិវឌ្ឍក្នុងតំបន់ ឱ្យទៅជាកាលានុវត្តិភាពក្នុងការធ្វើអាជីវកម្ម និងធ្វើឱ្យអាស៊ានមានភាពប្រកួតប្រជែងជាងមុន។ ហេតុដូច្នេះហើយ សហគមន៍សេដ្ឋកិច្ចអាស៊ានបានមកដល់ពាក់កណ្ដាលផ្លូវ ក្នុងដំណើរការសម្រេចឱ្យបាននូវទីផ្សារតែមួយនេះ។ ដើម្បីអនុវត្តនូវសហគមន៍សេដ្ឋកិច្ចអាស៊ាន ប្រទេសជាសមាជិករបស់អាស៊ានបានឯកភាពបង្កើតនូវគំនិតផ្ដួចផ្ដើមសេដ្ឋកិច្ច ដែលមានស្រាប់ដូចជា **តំបន់ពាណិជ្ជកម្មសេរី** (AFTA) **កិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានលើសេវាកម្ម** (ASEAN Framework Agreement on Services) និង **តំបន់វិនិយោគអាស៊ាន** (AIA) ពន្លឿននូវយន្តការអភិវឌ្ឍន៍ក្នុងចំណោមសមាជិកស្ថាបនិក និងសមាជិកថ្មីរបស់អាស៊ាន។

ការបង្កើតសហគមន៍សេដ្ឋកិច្ចសមាហរណកម្មមួយ ទាមទារឱ្យមានសកម្មភាពនៅក្នុងវិស័យដូចតទៅ៖ ការអភិវឌ្ឍធនធានមនុស្ស ការប្រឹក្សាដ៏ជិតស្និទ្ធរវាងសមាជិកនានាស្ដីអំពីគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការសម្រួលពាណិជ្ជកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍ល្អប្រសើរ ការអភិវឌ្ឍនៃប្រតិបត្តិការអេឡិចត្រូនិក តាមរយៈគម្រោងអ៊ី-អាស៊ាន (e-ASEAN) ការលើកស្ទួយឧស្សាហ៍កម្ម និង ការពង្រឹងផ្នែកឯកជន។

### ២៤.៧.៣. សហគមន៍សង្គម-វប្បធម៌អាស៊ាន ( ASEAN Socio-Cultural Community )

គោលបំណងនៃ**សហគមន៍សង្គម-វប្បធម៌អាស៊ាន** គឺលើកស្ទួយសហប្រតិបត្តិការអភិវឌ្ឍន៍សង្គម ជាមួយនឹងទស្សនៈ ដើម្បីលើកតម្កើងកម្រិតជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសស្ត្រី កុមារ និងសហគមន៍ក្នុងស្រុក តាមរយៈការវិនិយោគច្រើនជាងមុនលើការអប់រំជាមូលដ្ឋាន និងឧត្តមសិក្សា ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការបង្កើតការងារ និងសុខុមាលភាពសង្គម។

សហគមន៍សង្គមវប្បធម៌អាស៊ានមានគោលបំណងពន្លឿនសហប្រតិបត្តិការ ក្នុងវិស័យសុខភាពសាធារណៈ ដោយរួមមាន ការការពារនិងការត្រួតពិនិត្យជម្ងឺឆ្លង ដូចជាជម្ងឺអេដស៍និងមេរោគអេដស៍ និងជម្ងឺផ្ដាសាយបក្សី។ សហគមន៍សង្គមនិងវប្បធម៌អាស៊ានលើកទឹកចិត្តឱ្យមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកក្នុងចំណោមបញ្ញវន្ត អ្នកនិពន្ធ វិចិត្រករ និងអ្នកមានអាជីពក្នុងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងអាស៊ាន ដើម្បីអភិរក្សនិងលើកស្ទួយពិពិធកម្មវប្បធម៌ ហើយរក្សាបាននូវអត្តសញ្ញាណតំបន់របស់អាស៊ាន។

នៅក្នុងកិច្ចប្រជុំកំពូលលើកទី១០ នៅទីក្រុងវៀងច័ន្ទ មេដឹកនាំអាស៊ានទាំងអស់អនុម័តកម្មវិធីសកម្មភាពក្រុងវៀងច័ន្ទ (Vientiane Action program)។ កម្មវិធីនេះនឹងត្រូវបានអនុវត្តក្នុងរយៈពេលជាង០៦ឆ្នាំ ហើយវាគឺជាកម្មវិធីបន្តវេនពីផែនការសកម្មភាពក្រុងហាណូយ (Hanoi Action Plan)។ គោលបំណងរបស់វាគឺសម្រេចឱ្យបាននូវទស្សនទានអាស៊ាន២០២០ (ASEAN Vision ២០២០) និងសេចក្តីប្រកាសរបស់អាស៊ាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(កិច្ចព្រមព្រៀងលើកទីពីរនៅទីក្រុងបាលី "Bali Accord II")។ កម្មវិធីសកម្មភាពក្រុងវៀងច័ន្ទនេះមានគោលបំណងអនុវត្តនូវផែនការសកម្មភាពនៃសសរគ្រឹះទាំងបីនៃសេចក្តីប្រកាសរបស់អាស៊ាន (Bali Accord II) និងនូវការពង្រឹងសមាហរណកម្មតំបន់ ព្រមជាមួយនឹងការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍនៅក្នុងអាស៊ាន។

## ២៤.៨. បញ្ហាប្រឈមនៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន

អាស៊ានមានរចនាសម្ព័ន្ធស្ថាប័ន ដែលធូររលុង។ ប្រទេសជាសមាជិកទាំងអស់គ្មានបំណងប្រែក្លាយអាស៊ាន ឱ្យទៅជាស្ថាប័នមួយឡើយ។ ពួកគេបានគាំទ្រឱ្យមានសហប្រតិបត្តិការ តែគ្មានចេតនាក្នុងការបង្កើតទីភ្នាក់ងារនៅពីលើប្រទេស (Supranational)។ ក៏ប៉ុន្តែ រចនាសម្ព័ន្ធដែលធូររលុងនេះ បានធ្វើឱ្យវាមានភាពប្រកួតប្រជែង ដើម្បីសម្របសម្រួលឱ្យមានការអនុវត្តនៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម និង គម្រោងសមាហរណកម្មនានា។ គុណវិបត្តិនៃរចនាសម្ព័ន្ធនេះ ធ្វើឱ្យមានការកើនឡើងនូវកង្វល់ដ៏ជ្រាលជ្រៅមួយសម្រាប់ការពង្រឹងភាពប្រកួតប្រជែងរបស់អាស៊ាន ប្រៀបធៀបទៅនឹងសម្ព័ន្ធភាពនយោបាយផ្សេងៗនិងប្រទេសធំៗ ដូចជា ចិន និងឥណ្ឌា។

ដោយសារតែរចនាសម្ព័ន្ធដែលធូររលុង អាស៊ានបានរៀបចំកិច្ចប្រជុំ និងសន្និសីទជាច្រើនស្តីពីបញ្ហាអាទិភាព និង សកម្មភាពស្នូលរបស់ខ្លួន។ អាស៊ានបានរៀបចំកិច្ចប្រជុំជាង ៧០០ ជារៀងរាល់ឆ្នាំ។ ចំណុចខ្សោយខាងផ្នែកស្ថាប័នរបស់អាស៊ាន គឺការមិនស៊ីចង្វាក់គ្នាទៅនឹងតម្រូវការការកើនឡើង ដើម្បីពន្លឿនដំណើរការសមាហរណកម្ម។ ដើម្បីឱ្យគេជឿទុកចិត្តបាន និងដើម្បីឱ្យសមាគមនេះរក្សានូវភាពចាំបាច់ អាស៊ានត្រូវតែក្លាយជាសហគមន៍មួយ ដែលមានអំណាច និងបង្កើតរចនាសម្ព័ន្ធមួយមានលក្ខណៈផ្លូវការជាងមុន ក្នុងគោលដៅធានាបាននូវការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព សម្រាប់ការអនុវត្តនៃគំនិតផ្តួចផ្តើមសមាហរណកម្ម។

អាស៊ាននៅតែត្រូវបានគេមើលឃើញថា ជាការប្រមូលផ្តុំប្រទេសចំនួន ១០ ដែលមានពាណិជ្ជកម្មតាមព្រំដែនរប៉ាត់រប៉ាយ ដោយសារតែមានឧបសគ្គឆ្លងដែនជាច្រើន រវាងបណ្តាប្រទេសសមាជិកអាស៊ានទាំង១០។រចនាសម្ព័ន្ធរបស់បណ្តាប្រទេសជាសមាជិកមានលក្ខណៈប្រកួតប្រជែង ជាជាងការបំពេញឱ្យគ្នាទៅវិញទៅមក។ ប្រទេសអាស៊ានទាំងអស់មិនទាន់បានប្រមូលផ្តុំ ទៅលើចំណុចខ្លាំងនៃសេដ្ឋកិច្ចក្នុងតំបន់អាស៊ីអគ្នេយ៍នៅឡើយទេ។ វិនិយោគិននានានៅមិនទាន់មានការជឿជាក់ខ្លាំង ដោយសារមានបញ្ហាផ្សេងៗ ដែលបណ្តាលមកពីដំណើរការសមាហរណកម្មរបស់អាស៊ាននៅមានកម្រិត ហើយពួកគេមិនទាន់ចាត់ទុកថាអាស៊ាន ជាទីផ្សារតែមួយនៅឡើយ។

ទីផ្សារអាស៊ានដែលមានទំហំតូច ហើយរប៉ាត់រប៉ាយមិនមានលក្ខណៈទាក់ទាញដល់វិនិយោគិន បើប្រៀបធៀបទៅនឹងទីផ្សាចិនដ៏ធំសម្បើម និងទីផ្សារនៃតំបន់ដទៃទៀតនៅក្នុងពិភពលោក ដែលសមាហរណ-កម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ពួកគេមានភាពស៊ីជម្រៅជាង។ ឧបសគ្គជាច្រើនចំពោះពាណិជ្ជកម្មនៅតែមាននៅឡើយ ដែលបញ្ហានេះធ្វើឱ្យរាំងស្ទះដល់អាជីវកម្មនានារបស់អាស៊ាន ពីការចាប់យកឯកទេសកម្ម និងផលប្រយោជន៍ ពីមាត្រដ្ឋានពាណិជ្ជកម្មនៃការផ្គត់ផ្គង់ទៅលើទីផ្សារដ៏ធំមួយ។

ថ្លៃដើមនៃអាជីវកម្មនៅអាស៊ានមានតម្លៃខ្ពស់។ ឧទាហរណ៍ ក្រុមហ៊ុនផលិតសម្ភារៈប្រើប្រាស់ត្រូវចំណាយថ្លៃដើមដែលមិនចាំបាច់រហូតដល់ទៅ១៥ភាគរយនៃប្រាក់ចំណូលរបស់ពួកគេ ដោយសារតែភាពខុសគ្នានៃស្តង់ដារផលិតផល និងការិយាល័យធិបតេយ្យផ្នែករដ្ឋបាលគយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រសិនបើគេអាចជម្នះឧបសគ្គទាំងនោះបាន អាស៊ាននឹងមានសក្តានុពលសេដ្ឋកិច្ចដ៏គួរឱ្យទាក់ទាញ។ អាស៊ានមានធនធានទាំងអស់ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ ទីផ្សាររបស់អាស៊ានមានទំហំប្រហាក់ប្រហែលទៅនឹងតំបន់ឆ្នេរខាងកើតនៃប្រទេសចិន។ ទំនិញនាំចេញជាង ៧៥ ភាគរយពីអាស៊ានមានប្រភពមកពីវិស័យ ដែលមានកំណើនខ្ពស់។

កម្មវិធីសមាហរណកម្មសេដ្ឋកិច្ចរបស់អាស៊ានអាចត្រូវបានពន្លឿន តាមរយៈការដាក់ចេញវិធានការដូចខាងក្រោម៖

- ចរាចរដោយសេរីនៃទំនិញ សេវាកម្ម មូលធន និងកម្មករជំនាញ។
- សុខដុមនីយកម្មនៃពន្ធនាំចូលសម្រាប់ទំនិញ ដែលនាំចូលអាស៊ាន។
- ការអនុវត្តគោលនយោបាយប្រកួតប្រជែងដោយយុត្តិធម៌។
- ការគាំទ្របច្ចេកទេសដ៏មានប្រសិទ្ធភាព សម្រាប់សមាជិកដែលមានការអភិវឌ្ឍទាបជាងគេ។

ការពន្លឿនសមាហរណកម្មសេដ្ឋកិច្ចរបស់អាស៊ានទាមទារឱ្យអនុវត្តវិធានការពីរយ៉ាង៖

- ការអនុវត្តគ្រប់ជ្រុងជ្រោយនៃសមាហរណកម្ម នៅក្នុងវិស័យចំនួន ១១ (ការដឹកជញ្ជូនតាមអាកាស ឧស្សាហ៍កម្មរថយន្ត កសិឧស្សាហ៍កម្ម អេឡិចត្រូនិក នេសាទ ផលិតផលថែទាំសុខុមាលភាព បច្ចេកវិទ្យាព័ត៌មានវិទ្យា ផលិតផលកៅស៊ូ វាយនភ័ណ្ឌ និងកាត់ដេរ ទេសចរណ៍ និង ឧស្សាហ៍កម្មឈើ)។
- ការពង្រឹងស្ថាប័នអាស៊ានឱ្យមានភាពកាន់តែអាចទុកចិត្តបានជាងមុនៗ មានយន្តការឯករាជ្យដែលអាចដឹកនាំដំណើរការសមាហរណកម្ម អាចរៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រសមាហរណកម្ម ក្នុងគោលដៅតាមដានប្រកបដោយប្រសិទ្ធភាពនៃការអនុវត្តគម្រោងអាស៊ាននានា និងការកសាងទំនុកចិត្តរបស់វិនិយោគិនលើការដោះស្រាយវិវាទ។

ប្រទេសអាស៊ានទទួលស្គាល់ថា សមាហរណកម្មតំបន់ដែលស៊ីជម្រៅជាងមុននឹងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ខ្លួន ហើយនឹងជាប្រភពមួយនៃអត្ថប្រយោជន៍សេដ្ឋកិច្ចនិងនយោបាយជានិរន្តន៍របស់ខ្លួន។ ជាពិសេសទៅទៀត៖

- សមាហរណកម្មស៊ីជម្រៅជាងមុននឹងកាត់បន្ថយថ្លៃដើមនៃការធ្វើអាជីវកម្ម សម្រួលឱ្យមានការវិនិយោគថ្មីៗ លើកកម្ពស់ការអនុវត្តល្អក្នុងការធ្វើអាជីវកម្ម និងលើកទឹកចិត្តឱ្យមាននវានុវត្តភាព និងគំនិតច្នៃប្រឌិតថ្មី និង ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងបណ្តាប្រទេសអាស៊ាន។
- សមាហរណកម្មនឹងក្លាយជាកាតាលីករ សម្រាប់ការកែលម្អគោលនយោបាយក្នុងស្រុក (បទប្បញ្ញត្តិប្រសើរជាងមុន សម្រាប់ផលិតផល និងទីផ្សារ ការអនុវត្តច្បាប់ប្រឆាំងនឹងការស៊ីគ្រលំរវាងក្រុមហ៊ុន (antitrust law) ការប្រមូលពន្ធ កំណែទម្រង់ទីផ្សារដីធ្លី និង ការជំរុញឱ្យអនុវត្តច្បាប់ និងដីការតុលាការ)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- ប្រទេសទាំងអស់នឹងទទួលអត្ថប្រយោជន៍ ពីសមាហរណកម្មនេះ។ បទពិសោធន៍របស់ប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង (NAFTA) និងសហគមន៍អ៊ឺរ៉ុបបានបង្ហាញថា ប្រទេសដែលមានកម្រិតអភិវឌ្ឍទាបបំផុតនឹងទទួលបានអត្ថប្រយោជន៍ ច្រើនជាងប្រទេស ដែលមានការអភិវឌ្ឍខ្ពស់។

- សមាហរណកម្មសេដ្ឋកិច្ចស៊ីជម្រៅជាងមុននឹងបង្កើតស្មារតីសាមគ្គីភាពខ្លាំងជាងមុន ហើយប្រការនេះអាចជួយអាស៊ានឱ្យជម្នះនូវរាល់បញ្ហាប្រឈមនានាដូចជា បញ្ហាសន្តិសុខ និង បរិស្ថាន។ សមាហរណកម្មនឹងអាចពង្រឹងអនុភាពចរចា (bargaining power) របស់អាស៊ាន ក្នុងពាណិជ្ជកម្មអន្តរជាតិ ហើយជាទូទៅអាចបង្កើនឥទ្ធិពលភូមិសាស្ត្រ-នយោបាយរបស់អាស៊ាន ក្នុងវេទិកាអន្តរជាតិដូចជា អង្គការពាណិជ្ជកម្មពិភពលោក (WTO) និងសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីភិច (APEC)។

## ២៤.៩. ការបង់ថ្លៃផ្នែកសង្គមកច្ចសម្រាប់ដំណើរការសមាហរណកម្ម

ការបង្កើតប្រព័ន្ធសន្តិសុខនិងសុខុមាលភាពសង្គមមានសារៈសំខាន់ណាស់ ដើម្បីគ្រប់គ្រងផលប៉ះពាល់នៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន កែលម្អចីរភាពអេកូឡូស៊ី និង ពង្រឹងមូលដ្ឋានគ្រឹះសម្រាប់អត្តសញ្ញាណ ការឯកភាព និងសាមគ្គីភាពក្នុងសង្គមនៅកម្រិតតំបន់។ នាពេលបច្ចុប្បន្ន យន្តការសមាហរណកម្មអាស៊ានមិនបានចែងពីបញ្ញត្តិតម្រូវឱ្យមានសំណងដល់ប្រទេសជាសមាជិកណាមួយ ដែលអាចទទួលរងផលប៉ះពាល់អវិជ្ជមានពីសមាហរណកម្មនេះឡើយ។

អាស៊ានគប្បីផ្តោតការចាប់អារម្មណ៍ឱ្យបានខ្លាំងក្លាជាងមុនផងដែរ ដល់កិច្ចការពារ និង ការគ្រប់គ្រងរោគឆ្លង ការប្រឆាំងភេរវកម្ម ការជួញដូរថ្នាំញៀន និងគ្រឿងញៀន ការញៀនថ្នាំ និងការជួញដូរមនុស្ស ព្រមទាំងការកាត់បន្ថយភាពក្រីក្រ។ រាល់ជំងឺសង្គមទាំងអស់នេះ មានជាប់ទាក់ទងទៅនឹងផលប៉ះពាល់អវិជ្ជមានមកពីខាងក្រៅ ដែលត្រូវតែដោះស្រាយក្នុងកម្រិតតំបន់ ទើបទទួលបានជោគជ័យ។ ហិរញ្ញប្បទានសម្រាប់គម្រោងអាស៊ានអាចជាបញ្ហាសម្រាប់បណ្តាប្រទេសអាស៊ានដែលថវិកាមានកម្រិត ដែលតម្រូវឱ្យមានការគាំទ្រពីអាស៊ាន ដើម្បីអនុវត្តន៍នូវគំនិតផ្តួចផ្តើមដែលពាក់ព័ន្ធទាំងនោះ។

## ២៤.១០. ឆ្ពោះទៅសហគមន៍អាស៊ាន

គំនិតផ្តួចផ្តើមសំខាន់ៗដែលនឹងត្រូវបានអនុវត្តរួមមាន៖

- ការប្រជុំជាប្រចាំច្រើនជាងមុនរបស់មេដឹកនាំអាស៊ាន ដើម្បីផ្តល់នូវសន្ទុះផ្នែកនយោបាយខ្លាំងជាងមុន ដល់ការកសាងសហគមន៍អាស៊ាន។ កិច្ចប្រជុំកំពូលអាស៊ាននឹងត្រូវបន្ត តែត្រូវបន្ថែមដោយ "កិច្ចប្រជុំក្រុមប្រឹក្សាអាស៊ាន" ដើម្បីឱ្យមេដឹកនាំទាំងអស់អាចជួបគ្នា ក្នុងមួយឆ្នាំយ៉ាងហោចណាស់ឱ្យបានពីរដង។

- ការបង្កើតក្រុមប្រឹក្សានយោបាយ-សន្តិសុខ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងក្រុមប្រឹក្សាសង្គម-វប្បធម៌ ថ្នាក់រដ្ឋមន្ត្រី ដែលស្ថិតនៅក្រោមឆ័ត្ររបស់មេដឹកនាំអាស៊ាន មានគោលដៅជានាឱ្យមានការអនុវត្តនូវសសរស្តម្ភសំខាន់ៗនៃការកសាងសហគមន៍អាស៊ាន (ដែលពាក់ព័ន្ធទៅនឹងទិដ្ឋភាពនយោបាយ

សន្តិសុខ សេដ្ឋកិច្ច និងសង្គមកិច្ច) និងការរិះរកមធ្យោបាយ ដើម្បីដោះស្រាយបញ្ហានានា ដែលឋិតនៅក្រោមការសម្របសម្រួលអន្តរវិស័យ។

- ការបង្កើតទីផ្សាររួម ដែលទំនិញ សេវាកម្ម និងពលកម្មជំនាញអាចចរាចរដោយសេរី ការធ្វើសុខដុមនីយកម្មនៃនយោបាយសេដ្ឋកិច្ចក្នុងតំបន់ និងការពង្រឹងការតភ្ជាប់ក្នុងតំបន់។

## ២៤.១០.១. ការកៀរគរធនធាននិងការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍ

ត្រូវពន្លឿនការអនុវត្តគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI) ដោយអនុម័តនូវវិធីសាស្ត្រដូចខាងក្រោម៖

- គោរពនូវគោលការណ៍ចូលរួមវិភាគទានស្មើគ្នា ទន្ទឹមនឹងការផ្តល់ប្រព្រឹត្តិកម្មស្មើភាពគ្នារបស់ប្រទេសជាសមាជិក។
- បង្កើតមូលនិធិពិសេសសម្រាប់កាត់បន្ថយគម្លាតនៃការអភិវឌ្ឍ (Special Fund for Narrowing Development Gap) ដើម្បីផ្តល់ឱ្យអាស៊ាននូវមធ្យោបាយ ដែលរកបានពីប្រភពផ្ទាល់របស់ខ្លួន ក្នុងការអនុវត្តនូវគម្រោងសហប្រតិបត្តិការនានា។
- ធ្វើការកៀរគរមូលនិធិ និងការគាំទ្រពីផ្នែកឯកជនរបស់ប្រទេសជាសមាជិក។
- បង្កើតយន្តការដោះស្រាយវិវាទមួយ សម្រាប់គ្រប់វិស័យសហប្រតិបត្តិការទាំងអស់ នៅក្នុងអាស៊ាន ដោយរួមបញ្ចូលការត្រួតពិនិត្យឱ្យស្របទៅនឹងយន្តការពិគ្រោះយោបល់ និងយន្តការអនុវត្តដែលមានចែងក្នុងគោលការណ៍គ្រឹះនៃកិច្ចព្រមព្រៀង។
- លេខាធិការដ្ឋានអាស៊ានត្រូវតែទទួលបាននូវសិទ្ធិអំណាចធំជាងមុន ក្នុងការត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងអាស៊ាន និងផែនការសកម្មភាពនានា ហើយអគ្គលេខាធិការអាស៊ានត្រូវធ្វើរបាយការណ៍ជាប្រចាំ ជូនដល់ក្រុមប្រឹក្សានានា និងក្រុមប្រឹក្សាសហគមន៍អាស៊ាន។
- អាស៊ានត្រូវមានសមត្ថកិច្ច ក្នុងការចាត់វិធានការនានា ដើម្បីដោះស្រាយករណីផ្សេងៗពាក់ព័ន្ធទៅនឹងការរំលោភធ្ងន់ធ្ងរនៃគោលបំណង គោលការណ៍គន្លឹះ និងកាតព្វកិច្ចនានាដែលមានចែងក្នុងកិច្ចព្រមព្រៀងជាមូលដ្ឋាន។ ការខកខានក្នុងការអនុវត្តសេចក្តីសម្រេចនៃយន្តការដោះស្រាយវិវាទ គប្បីត្រូវបានរាយការណ៍ជូនក្រុមប្រឹក្សាអាស៊ាន។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាអាស៊ានគ្មានអំណាចបណ្តេញប្រទេសជាសមាជិក ចេញពីអាស៊ានទេ។

## ២៤.១០.២. ការពង្រឹងប្រសិទ្ធភាពរបស់សមាគមន៍

ប្រសិនបើអាស៊ានពិតជាត្រូវបង្កើតឱ្យទៅជាអង្គការមួយ ដែលមានប្រសិទ្ធភាពមែន និងចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដែលនឹងនាំអាស៊ានឆ្ពោះទៅរកគោលដៅរបស់ខ្លួន នោះអាស៊ានត្រូវហ៊ានធ្វើកំណែទម្រង់រចនាសម្ព័ន្ធស្ថាប័នរបស់ខ្លួន ដូចខាងក្រោម៖

- អគ្គលេខាធិការដ្ឋានត្រូវមានសិទ្ធិអំណាច ដើម្បីដើរតួនាទីឱ្យខ្លាំងក្លាជាងមុន ក្នុងដំណើរការនៃសមាហរណកម្មតំបន់ និងសហប្រតិបត្តិការអន្តរជាតិ។

- អគ្គលេខាធិការអាស៊ាន អមដោយអគ្គលេខាធិការរងចំនួនបួនរូប ជាជំនួយការ នៅក្នុងវិស័យៈ នយោបាយនិងសន្តិសុខ ទំនាក់ទំនងសេដ្ឋកិច្ច សហប្រតិបត្តិការសង្គមកិច្ច-វប្បធម៌ និងកិច្ចការអន្តរជាតិ រដ្ឋបាល និង ថវិកា។

- តំណាងអចិន្ត្រៃយ៍នៃប្រទេសជាសមាជិក ត្រូវបានតែងតាំងអមលេខាធិការដ្ឋានអាស៊ាន ក្នុងទីក្រុងហ្សាកាតា។

- រៀបចំ និង កាត់បន្ថយចំនួនកិច្ចប្រជុំអាស៊ាន ដើម្បីបង្កើនប្រសិទ្ធភាព។

- អាស៊ាន គឺជានីតិបុគ្គល និងមានអំណាច ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

- **មូលនិធិអាស៊ាន** (ASEAN Foundation) នឹងត្រូវបានពង្រឹង និងធ្វើឱ្យមានដំណើរការឡើងវិញ ដើម្បីដើរតួនាទីសកម្មជាងមុន និងធ្វើឱ្យសាធារណៈជនយល់ដឹងពីអាស៊ាន។

- បង្កើតវិទ្យាស្ថានអាស៊ានសម្រាប់គាំទ្រដល់អគ្គលេខាធិការ ក្នុងការស្រាវជ្រាវ ការវិភាគនយោបាយ ការរៀបចំផែនការយុទ្ធសាស្ត្រ និង ទំនាក់ទំនងជាមួយបញ្ញវន្ត/បណ្ឌិតសភា តាមផ្លូវទី២ ("Track II" Scholars/academics)។

- ការសម្រេចចិត្ត តាមរយៈការពិគ្រោះយោបល់ និងដោយមានកុងសង់ស៊ុស គឺជាវិធានសម្រាប់ដោះស្រាយបញ្ហាសំខាន់ៗ និងរសើបទាំងអស់។

- អនុវត្តដោយទន់ភ្លន់នូវរូបមន្ត "អាស៊ាន+X" ឬ "2+X" ក្នុងការសម្រេចចិត្ត ដោយអនុលោមតាមឆន្ទានុសិទ្ធិនៃក្រុមប្រឹក្សាសហគមន៍អាស៊ាន។

- ពង្រឹងអាស៊ានឱ្យទៅជាសមាគម ដោយប្រជាជន និង ដើម្បីប្រជាជន និងបណ្តុះឱ្យប្រជាជនអាស៊ានមានស្មារតីដែលបង្ហាញពីភាពជាម្ចាស់ និងមានគំនិតរួមរស់ក្នុងគ្រួសារតែមួយ តាមរយៈការសម្រួលឱ្យមានការចូលរួម និង ការជួបសន្ទនារវាងអ្នកដឹកនាំអាស៊ាន ជាមួយបណ្តាតំណាងរបស់ប្រទេសសមាជិកអាស៊ាន តំណាងរបស់អង្គការសង្គមស៊ីវិល និង ក្រុមប្រឹក្សាធុរៈកិច្ច អង្គការសិទ្ធិមនុស្ស គ្រឹះស្ថានសិក្សា និងតួអង្គដទៃទៀតនៅក្នុងអាស៊ាន។

- ស្ថាប័នសំខាន់ៗរបស់អាស៊ានត្រូវរៀបចំការពិគ្រោះយោបល់ជាប្រចាំ ជាមួយភាគីទាំងអស់ ដែលបានរៀបរាប់ខាងលើ។

កំណែទម្រង់ទាំងអស់ដូចបានរៀបរាប់ខាងលើនេះ បង្កើតនូវមូលដ្ឋានគ្រឹះនៃរដ្ឋធម្មនុញ្ញអាស៊ាន (ASEAN Charter)។ ប៉ុន្តែ អាស៊ានត្រូវតែដោះស្រាយបញ្ហា ដែលមិនទាន់បានដោះស្រាយជាច្រើន មុនពេលដាក់រដ្ឋធម្មនុញ្ញចូលជាធរមានៈ

- **ទីមួយ** អាស៊ានត្រូវតែកំណត់ឱ្យបានច្បាស់លាស់ នូវដំណាក់កាលនានាដែលចាំបាច់ ដើម្បីបង្កើតនូវទីផ្សាររួម និង លក្ខខណ្ឌដែលមានអំណោយផលដល់ការចរាចរដោយសេរី នូវកត្តាផលិតកម្មនៅក្នុងអាស៊ាន។ អាស្រ័យហេតុនេះ វាមានសារៈសំខាន់ណាស់ ដែលត្រូវរៀបចំស្ថាបត្យកម្មនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ានបូក (ASEAN Plus Free Trade Area "AFTA Plus")។

- **ទីពីរ** ការធ្វើឱ្យសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ចេញជារូបរាង នឹងបណ្តាលឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រទេសជាសមាជិកអាស៊ាន។ ប្រទេសសមាជិកត្រូវតែគិតគូរពីអត្ថប្រយោជន៍តំបន់ ហើយរៀបចំខ្លួនទទួលផលចំណេញពីសមាហរណកម្ម ព្រមទាំងផលប៉ះពាល់អវិជ្ជមាននានា ដែលបណ្តាលមកពីសមាហរណកម្មក្នុងតំបន់។ បញ្ហាសំខាន់មិនមែនការកំណត់កាលបរិច្ឆេទនៅឆ្នាំ២០១៥ ឬឆ្នាំ២០២០ ដើម្បីបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាននោះឡើយ ប៉ុន្តែ គឺ ធ្វើយ៉ាងណាឱ្យសមាហរណកម្មតំបន់នោះអាចអនុវត្តបាន ដោយភាពជឿជាក់ និងមានចីរភាព។
- **ទីបី** ត្រូវកំណត់ឱ្យបានច្បាស់នូវអាទិភាពរបស់តំបន់ ទាក់ទងទៅនឹងសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅក្នុងអាស៊ាន។ សមាជិកអាស៊ានទាំងអស់មានការប្តេជ្ញាចិត្ត បង្កើតតំបន់ពាណិជ្ជកម្មសេរី (FTAs) ដោយរួមទាំងតំបន់ពាណិជ្ជកម្មទ្វេភាគី ជាមួយដៃគូក្រៅតំបន់។ យើងត្រូវការតំបន់ពាណិជ្ជកម្មទាំងអស់នោះ ដើម្បីឱ្យអាស៊ានអាចពង្រឹងទំនាក់ទំនងរបស់ខ្លួន ជាមួយប្រទេសក្រៅ។ ប៉ុន្តែ សមាជិកអាស៊ានក៏ត្រូវផ្តោតការយកចិត្តទុកដាក់ផងដែរ លើការអនុវត្តវិធានការនានា ដើម្បីធ្វើឱ្យសមាហរណកម្មទីផ្សារនៅក្នុងតំបន់ មានលក្ខណៈស៊ីជម្រៅជាងមុន។
- **ទីបួន** ខណៈដែលការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ានសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ សេរីភាវូបនីយកម្មនៃពាណិជ្ជកម្មទំនិញ និងសេវាកម្មនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ដើម្បីឱ្យអាស៊ានអាចសម្រេចបានចរាចរដោយសេរីនៃកម្មករជំនាញនិងមូលធន អាស៊ានត្រូវជម្នះឱ្យបាននូវបញ្ហាប្រឈមធំៗជាច្រើន។ អ្នកវិនិយោគទុននៅតែចាត់ទុកអាស៊ានថា ជាសមាគមនៃប្រទេសចំនួនដប់ ដោយប្រទេសនីមួយៗមានច្បាប់ លិខិតបទដ្ឋានរៀងៗខ្លួន។ នោះគឺជាចំណុចសំខាន់នៃបញ្ហាប្រឈម ដែលអាស៊ានត្រូវតែដោះស្រាយ ដើម្បីប្រឈមមុខជាមួយការប្រកួតប្រជែងដែលកើនឡើង ពីប្រទេសចិននិងឥណ្ឌា។
- **ទីប្រាំ** អាស៊ានត្រូវពិនិត្យឡើងវិញជាប្រចាំ នូវការលើកទឹកចិត្តដល់ការវិនិយោគក្នុងតំបន់ ដោយធ្វើការប្រៀបធៀបជាមួយបណ្តាប្រទេសលើពិភពលោក។ អាស៊ានត្រូវផ្តល់ការលើកចិត្តពិសេសសម្រាប់សាជីវកម្ម ឬ អង្គភាពអាជីវកកម្មចម្រុះវិស័យ (conglomerate) ដែលនឹងត្រូវបានបង្កើតឡើងនៅក្នុងអាស៊ាន។
- **ទីប្រាំមួយ** អាស៊ានត្រូវមានប្រព័ន្ធហិរញ្ញវត្ថុ ដែលមានសមាហរណកម្មនឹងគ្នា និងដំណើរការដោយរលូន សម្រាប់ការដំណើរការនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន និង ដើម្បីឱ្យអាស៊ានអាចសម្រេចបានតាមចក្ខុវិស័យ ធ្វើឱ្យអាស៊ីអគ្នេយ៍ក្លាយជាតំបន់ប្រកបដោយវិបុលភាព និង សន្តិភាព។
- **ជាចុងក្រោយ** អាស៊ានត្រូវផ្តោតការយកចិត្តទុកដាក់ខ្លាំង ចំពោះប្រទេសដែលជាសមាជិកថ្មី គឺ កម្ពុជា ឡាវ ភូមា និង វៀតណាម (CLMV) ដើម្បីកុំឱ្យប្រទេសទាំងនោះស្ថិតនៅក្រោយការអភិវឌ្ឍខ្លាំងពេក។ អាស្រ័យហេតុនេះ អាស៊ានត្រូវខិតខំបន្ថែមទៀត ដើម្បីបង្រួមនូវគម្លាតនៃការអភិវឌ្ឍតាមរយៈការអនុវត្តនូវកម្មវិធីជំនួយបច្ចេកទេស ការផ្ទេរបច្ចេកវិទ្យា ការអប់រំ និងការបណ្តុះបណ្តាលនៅក្នុងប្រទេសទាំងបួននោះ។

## ២៤.១១. សមាហរណកម្មសេដ្ឋកិច្ចនៅក្នុងអាស៊ីបូព៌ា

### ២៤.១១.១. ក្រុមទស្សនវិស័យអាស៊ីបូព៌ា (East Asia Vision Group- EAVG)

តាមគំនិតផ្តួចផ្តើមរបស់ឯកឧត្តម **គីម ដេជុង** (Kim Dae Jung) ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ ប្រទេសអាស៊ាន+៣ (ASEAN+3) បានបង្កើតឡើងក្នុងឆ្នាំ១៩៩៩ នូវ **ក្រុមទស្សនវិស័យអាស៊ីខាងកើត** (EAVG)សម្រាប់ផ្តល់អនុសាសន៍ស្តីអំពីទិសដៅអនាគតនៃសហប្រតិបត្តិការនៅក្នុងអាស៊ីខាងកើត។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០១ EAVG បានដាក់ជូននូវអនុសាសន៍នានា ដល់មេដឹកនាំអាស៊ាន+៣ នៅក្នុងកិច្ចប្រជុំកំពូលនៅរាជធានីភ្នំពេញ។

របាយការណ៍ចុងក្រោយរបស់ក្រុម **ក្រុមទស្សនវិស័យអាស៊ីខាងកើត** រួមមាន វិធានការនានាសម្រាប់កិច្ចសហប្រតិបត្តិការរយៈពេលខ្លី មធ្យម និង វែង៖

#### ២៤.១១.១.១. *សហប្រតិបត្តិការសេដ្ឋកិច្ច*

- បង្កើន **តំបន់ពាណិជ្ជកម្មសេរីអាស៊ីខាងកើត**។
- ពង្រីកដែនប្រតិបត្តិ **កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីអំពីតំបន់វិនិយោគអាស៊ាន** ដល់ប្រទេសទាំងអស់របស់អាស៊ីខាងកើត។
- លើកស្ទួយការអភិវឌ្ឍនិងសហប្រតិបត្តិការបច្ចេកវិទ្យាក្នុងចំណោមប្រទេសនៅក្នុងតំបន់ ហើយជាពិសេសផ្តល់នូវជំនួយដល់ប្រទេសដែលមានការអភិវឌ្ឍតិចបំផុត។
- ប្រតិបត្តិនូវសេដ្ឋកិច្ចដែលផ្អែកលើចំណេះដឹងនិងបង្កើតនូវចរន្តសម្ព័ន្ធដែលបើកចំហ។

#### ២៤.១១.១.២. *សហប្រតិបត្តិការហិរញ្ញវត្ថុ*

- បង្កើតមណ្ឌលគាំទ្រហិរញ្ញវត្ថុក្នុងតំបន់មួយ។
- បង្កើតប្រព័ន្ធសម្របសម្រួលមួយដល់ការគ្រប់គ្រងរូបិយវត្ថុបរទេស ដែលមានអំណោយផលដល់ស្ថេរភាពហិរញ្ញវត្ថុនិងការអភិវឌ្ឍសេដ្ឋកិច្ច។
- ជំរុញឱ្យអនុវត្តដំណើរត្រួតពិនិត្យនិងឃ្លាំមើលក្នុងតំបន់នៅក្នុងអាស៊ីខាងកើតឱ្យស្របទៅតាមការឃ្លាំមើលជាសាកលរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF)។

#### ២៤.១១.១.៣. *សហប្រតិបត្តិការនយោបាយនិងសន្តិសុខ*

- បង្កើតនិយាមនីតិវិធីនិងយន្តការនានា ដើម្បីឱ្យប្រសើរឡើងនូវទំនាក់ទំនងនៅក្នុងតំបន់លើគោល-ការភាពជាអ្នកជិតខាងល្អ ការជឿជាក់ទៅវិញទៅមក និងសាមគ្គីភាព។
- បង្កើតនិងលើកស្ទួយយន្តការនានា ដើម្បីដោះស្រាយការគំរាមកំហែងដល់សន្តិភាពក្នុងតំបន់។
- បង្កើនសម្លេងរបស់អាស៊ីខាងកើតលើកិច្ចការអន្តរជាតិនិងពង្រឹងតួនាទីរបស់អាស៊ីខាងកើតក្នុងការកសាង និងឆ្ពោះទៅមុខឈានទៅរកសណ្តាប់ធ្នាប់ថ្មីក្នុងពិភពលោក។

### ២៤.១១.១.៤. សហប្រតិបត្តិការលើវិស័យបរិស្ថាន

- រៀបចំស្ថាប័នសម្រាប់សហប្រតិបត្តិការទ្វេភាគីលើផ្នែកបរិស្ថានជាលក្ខណៈតំបន់និងពិភពលោក។
- លើកស្ទួយកម្មវិធីផ្សព្វផ្សាយ និងអប់រំក្នុងផ្នែកបរិស្ថាន និងជំរុញឱ្យអង្គការក្រៅរដ្ឋាភិបាលមានការពាក់ព័ន្ធចូលរួមក្នុងដំណើរការនេះ។
- គ្រប់គ្រងធនធានទឹកនិងនេសាទឱ្យមានប្រសិទ្ធភាព។
- អភិវឌ្ឍន៍រួមគ្នានិងស្វែងរកប្រភពធនធានថ្មីៗនៅក្នុងតំបន់ និងលើកស្ទួយការប្រើប្រាស់ថាមពលនេះឱ្យមានប្រសិទ្ធភាព។

### ២៤.១១.១.៥. សហប្រតិបត្តិការសង្គមនិងវប្បធម៌

- បង្កើតកម្មវិធីកាត់បន្ថយភាពក្រីក្រ ដោយមានប្រទេសមានទ្រព្យធនផ្ដល់ជំនួយដល់ប្រទេសក្រីក្រក្នុងការប្រយុទ្ធប្រឆាំងទៅនឹងភាពក្រីក្រ ភាពមិនចេះអក្សរ និងជំងឺដម្កាត់ផ្សេងៗ។
- អនុម័តនូវកម្មវិធី ដើម្បីពង្រីកច្រកចូលដល់សេវាថែរក្សាសុខុមាលភាព។
- បង្កើតកម្មវិធីសម្រាប់បណ្ដុះបណ្ដាលធនធានមនុស្ស ដោយការយកចិត្តទុកដាក់ ជាពិសេសទៅលើការអប់រំជាមូលដ្ឋាន ការបណ្ដុះបណ្ដាល និងការកសាងសមត្ថភាព។
- លើកស្ទួយអត្តសញ្ញាណនិងការយល់ដឹងរបស់តំបន់ ស្របជាមួយនឹងសហប្រតិបត្តិការលើគម្រោងអភិរក្សនិងផ្សព្វផ្សាយពីសិល្បៈ និងវប្បធម៌របស់អាស៊ីខាងកើត។
- បង្កើតនូវមូលនិធិអប់រំសម្រាប់អាស៊ីខាងកើត ដើម្បីលើកស្ទួយការអប់រំជាមូលដ្ឋាននិងការបណ្ដុះបណ្ដាលនៅក្នុងតំបន់។

### ២៤.១១.១.៦. សហប្រតិបត្តិការកម្រិតស្ថាប័ន

- បន្ថែមលើកិច្ចប្រជុំកំពូលប្រចាំឆ្នាំអាស៊ាន+៣ (Asean +3) ឱ្យមានកិច្ចប្រជុំកំពូលអាស៊ីបូព៌ា។
- បង្កើតវេទិកាអាស៊ីខាងកើត (East Asia Forum) ដែលមានតំណាងរបស់ខ្លួនមកពីរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលមកពីផ្នែកផ្សេងៗឱ្យទៅជាយន្តការគ្រឹះស្ថានមួយ ដើម្បីលើកស្ទួយការទំនាក់ទំនងរវាងគូអង្គសំខាន់ៗ។

ផ្អែកលើអនុសាសន៍របស់ក្រុមទស្សនវិស័យអាស៊ីខាងកើត (East Asia Vision Group) មន្ត្រីជាន់ខ្ពស់របស់អាស៊ាន+៣បានបង្កើតឡើងនូវក្រុមសិក្សាអាស៊ីខាងកើត (East Asia Study Group) ដើម្បីសិក្សាឱ្យស៊ីជម្រៅ និងដាក់ជាអាទិភាពនូវអនុសាសន៍ទាំងនោះ។ ក្រុមនេះបានស្នើឡើងនូវវិធានការជាអាទិភាព ចំនួន ១៧ សម្រាប់អនុវត្តរយៈពេលខ្លី និង វិធានការចំនួន៩ សម្រាប់អនុវត្តរយៈពេលមធ្យម និង រយៈពេលវែង។

## ២៤.១១.២. ក្របខ័ណ្ឌសហប្រតិបត្តិការអាស៊ានបូកបី

នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ៨០ ក្រុមហ៊ុនជប៉ុននានាបានបង្វែរទីតាំងផលិតកម្មរបស់ខ្លួន ទៅកាន់បណ្តាលប្រទេសអាស៊ាន ជាពិសេសប្រទេសសិង្ហបុរី ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ថៃឡង់ដ៍ និងប្រទេសហ្វីលីពីន។ ក្នុងទសវត្សរ៍ឆ្នាំ៩០ និង ឆ្នាំ២០០០ ក្រុមហ៊ុនជប៉ុនបានបង្វែរទីតាំងផលិតកម្មភាគច្រើនរបស់ខ្លួន ទៅកាន់ប្រទេសចិន។ ប្រទេសចិនបានក្លាយទៅជាទីតាំងកណ្តាលដ៏សំខាន់មួយ សម្រាប់ពាណិជ្ជកម្មផ្នែកតម្លើងគ្រឿងអេឡិចត្រូនិកនៅក្នុងតំបន់ សម្រាប់នាំចេញទៅកាន់សហរដ្ឋអាមេរិក។

ក្រោយវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុអាស៊ីឆ្នាំ ១៩៩៧-១៩៩៨ វាមានកម្លាំងរុញច្រានដ៏ខ្លាំងក្លាមួយសម្រាប់សមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុងក្របខ័ណ្ឌអាស៊ាន+៣។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ២០០០ ការនាំចូលពីបណ្តាលប្រទេសអាស៊ានទៅកាន់ប្រទេសចិនបានកើនឡើង ដែលនាំឱ្យមានការកើនឡើងយ៉ាងខ្លាំងនៃការនាំចេញពីប្រទេសចិនទៅកាន់សហរដ្ឋអាមេរិក។ ការអភិវឌ្ឍដ៏អស្ចារ្យរបស់ប្រទេសចិនក៏បានបង្កើតឱ្យមានផងដែរ នូវតម្រូវការដ៏ខ្លាំងក្លាលើទំនិញពាក់កណ្តាលសម្រេចរបស់ជប៉ុន។ ប្រទេសជប៉ុនបានឆ្លងកាត់ការធ្លាក់ចុះនៃសេដ្ឋកិច្ចអស់រយៈពេលមួយទសវត្សរ៍ បានទទួលនូវកំណើនសេដ្ឋកិច្ចពីរភាគរយនៅឆ្នាំ២០០៥ នៅពីក្រោយមានកំណើននៃការនាំចេញពីជប៉ុនទៅកាន់ប្រទេសចិន។ សមាហរណកម្មខាងផ្នែកពាណិជ្ជកម្មនៅក្នុងអាស៊ីខាងកើត បានពង្រឹងដល់ការពឹងពាក់គ្នាទៅវិញទៅមកក្នុងការផលិត រវាងសេដ្ឋកិច្ចក្នុងអាស៊ាន+៣។ ទោះបីជាប្រទេសចិនបានឆ្លងកាត់អតិរេកពាណិជ្ជកម្ម (Trade Surplus) ជាមួយសហរដ្ឋអាមេរិក ប្រទេសចិនក៏បានជួបប្រទះនូវឱនភាពពាណិជ្ជកម្ម ជាមួយបណ្តាប្រទេសអាស៊ានដែរ។

សហប្រតិបត្តិការរបស់អាស៊ានជាមួយប្រទេសទាំងបីនៃអាស៊ីខាងកើត គឺប្រទេសចិន កូរ៉េខាងត្បូង និងប្រទេសជប៉ុន មានសន្ទុះកើនឡើងខ្លាំងចាប់តាំងពីឆ្នាំ១៩៩៧ ដោយការរៀបចំឱ្យមានស្ថាប័នក្នុងការចរចារវាងបណ្តាមេដឹកនាំរបស់អាស៊ាន ប្រទេសចិន កូរ៉េខាងត្បូង និងប្រទេសជប៉ុន នៅឯកិច្ចប្រជុំកំពូលអាស៊ាន+៣ និង កិច្ចប្រជុំកំពូលអាស៊ាន+ ១។

ដំណើរការអាស៊ាន+៣កំពុងតែដំណើរការទៅមុខ។ នៅក្នុងវិស័យប្រតិបត្តិការហិរញ្ញវត្ថុ អាស៊ាន+៣ បានបង្កើតឡើងនូវប្រព័ន្ធឃ្លាំមើលក្នុងតំបន់និងផ្គត់ផ្គង់ហិរញ្ញវត្ថុ ដោយមានកិច្ចព្រមព្រៀងដោះដូរទ្វេភាគីក្នុងទឹកប្រាក់ ៧៨ ពាន់លានដុល្លារអាមេរិក ដើម្បីទប់ស្កាត់វិបត្តិហិរញ្ញវត្ថុ ដែលអាចកើតឡើងជាយថាហេតុ។ ក្នុងកំឡុងកិច្ចប្រជុំប្រចាំឆ្នាំ រដ្ឋមន្ត្រីការបរទេសអាស៊ាន+៣ប្រទេសទាំងនេះពិភាក្សានូវបញ្ហានយោបាយនិងសន្តិសុខដែលកំពុងកើតមានឡើង។ សហប្រតិបត្តិការអាស៊ាន+៣កំពុងតែពង្រីកទៅដល់វិស័យដទៃទៀតផងដែរ។

### ២៤.១១.២.១. កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

ផលប៉ះពាល់នៃសមាហរណកម្មនេះ ជាធម្មតាត្រូវបានវាស់វែង ដោយគិតទៅលើការបង្កើតពាណិជ្ជកម្ម និង ការបង្វែរពាណិជ្ជកម្ម ក្រោយពេលដែររបាំងពន្ធនាំចូលនិងមិនមែនពន្ធនាំចូលត្រូវបានលុបបំបាត់។ ប្រសិនបើគោលដៅនោះគ្រាន់តែកាត់បន្ថយពន្ធនាំចូលទៅដល់សូន្យ ពីព្រោះកម្រិតពន្ធនាំចូលសម្រាប់ប្រទេសភាគច្រើនមានកម្រិតទាបរួចទៅហើយ ហេតុដូច្នេះផលប៉ះពាល់សរុបនៃតំបន់ពាណិជ្ជកម្មសេរីនឹងមានទ្រង់ទ្រាយតូច។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Sa, Bonzom និង Strauss-Kahn (ឆ្នាំ២០០៥) មានមតិថា ដោយសារតែកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ (RTA) ធ្វើឱ្យមានការរើសអើងជាក់ស្តែង ចំពោះប្រទេសដែលមិនមែនជាសមាជិក គេតែងតែសង្ស័យថា កិច្ចព្រមព្រៀងទាំងនេះបានបង្កើតឱ្យមានការបង្វែរពាណិជ្ជកម្ម ជាជាងការបង្កើតឱ្យមានពាណិជ្ជកម្ម។ ប៉ុន្តែ តាមរយៈការសិក្សាលើលទ្ធផលជាក់ស្តែង (Empirical Study) បានបង្ហាញថា កិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ធ្វើការបង្កើនពាណិជ្ជកម្មច្រើនជាងការបង្វែរពាណិជ្ជកម្ម។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលមានស្រាប់សម្រេចបានលទ្ធផល លើសពីការកាត់បន្ថយរបាំងពន្ធគយ និងរបាំងមិនមែនពន្ធគយ ហើយកិច្ចព្រមព្រៀងនោះគ្របដណ្តប់លើការវិនិយោគពាណិជ្ជកម្មអេឡិកត្រូនិច កម្មសិទ្ធិបញ្ញា សេវាកម្មទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ ព្រមទាំងវិស័យផ្សេងៗដូចជា វិស័យធនាគារ សេវាកម្មប្រឹក្សា និងផ្លូវច្បាប់...។ល។ កិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ដ៏ស្មុគស្មាញទាំងនេះ ដោះស្រាយនូវបញ្ហាជាច្រើនប្រភេទ ដែលត្រូវបានរៀបចំឡើង ដើម្បីបង្កើតការវិនិយោគដោយផ្ទាល់ពីបរទេស ការកាត់បន្ថយថ្លៃដើមនៃប្រតិបត្តិការ ការលើកស្ទួយសុខដុមនីយកម្មនៃស្តង់ដារផលិតផល ការទទួលស្គាល់ទៅវិញទៅមកនៃការពិសោធន៍គុណភាពទំនិញ និងការទទួលស្គាល់ទៅវិញទៅមកលើសញ្ញាប័ត្រនិងវិញ្ញាបនប័ត្រផ្សេងៗ។

ដោយហេតុផលនេះ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកំពុងត្រូវបានប្រើប្រាស់ ដើម្បីពន្លឿនសមាហរណកម្មតំបន់ និងដើម្បីទំនាក់ទំនងពាណិជ្ជកម្មក្នុងបណ្តាប្រទេស ដែលកំពុងចូលរួម។ វិធានការជាច្រើនទៀតនឹងត្រូវបានអនុមតិ ដោយរួមទាំងការកាត់បន្ថយពន្ធនាំចូល ការធ្វើសុខដុមនីយកម្ម និងការកែសម្រួលច្បាប់ ព្រមទាំងការធ្វើឱ្យមានរូបរាងនៃសហគមន៍អាស៊ាន ជាមួយការចរាចរដោយសេរីនូវទំនិញ សេវាកម្មមូលធន និងពលករជំនាញ នឹងបង្កើតនូវថាមវន្ត ដើម្បីពង្រឹងសមាហរណកម្មក្នុងតំបន់។

### ២៤.១១.២.២. *សហប្រតិបត្តការអាស៊ាន-ចិន*

នៅក្នុងបរិបទនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (Framework Agreement on Comprehensive Economic Corporation) រវាងអាស៊ាននិងចិន ដែល ចុះហត្ថលេខាក្នុងឆ្នាំ ២០០២ អាស៊ានកំពុងស្ថិតនៅក្នុងដំណើរការចរចាជាមួយប្រទេសចិន ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីត្រឹមឆ្នាំ ២០១០ សម្រាប់សមាជិកស្ថាបនិកទាំងអស់ និងត្រឹមឆ្នាំ២០១៥ សម្រាប់សមាជិកដទៃទៀត។

ការអនុវត្តផែនការសកម្មភាព ក្រោមកម្មវិធីភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន សម្រាប់សន្តិភាពនិងភាពរីកចម្រើន (Asean-China Strategic Partnership for Peace and Prosperity) បានជួយពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងចូលរួមនៅគ្រប់វិស័យទាំងអស់ដែលរួមមាន នយោបាយ សេដ្ឋកិច្ច និងវប្បធម៌ ហើយអាស្រ័យហេតុនេះ បានជួយធ្វើឱ្យប្រសើរឡើងនូវសន្តិសុខ និងការអភិវឌ្ឍតំបន់ ទាំងពេលបច្ចុប្បន្ន និងទៅអនាគត។

អាស៊ាននិងប្រទេសចិន បានចុះហត្ថលេខាផងដែរ លើសេចក្តីប្រកាសស្តីអំពីការប្រព្រឹត្តទៅនៃភាគីទាំងអស់ ក្នុងតំបន់សមុទ្រចិនខាងត្បូង (Declaration of the Conduct of Parties in the South China Sea-DOC) និងសេចក្តីប្រកាសរួមអំពីកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខមិនប្រពៃណី (Joint Declaration on Cooperation in the Field of Non-Traditional Security)។ រាល់គំនិតផ្តួចផ្តើមទាំងនេះបានជួយកសាងទំនុក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចិត្ត និងជួយលើកស្ទួយសន្តិភាពនិងការរីកចម្រើន ដែលជាមូលដ្ឋានដ៏សមរម្យមួយសម្រាប់សន្តិភាព និងការចែករំលែករីកចម្រើននៅក្នុងតំបន់។

ភាពជាដៃគូរបស់អាស៊ាន-ចិនត្រូវបានក៏សាងឡើង ដោយផ្អែកលើគោលការណ៍ជាផលប្រយោជន៍រួម។ ប្រទេសចិននិងអាស៊ាន បានបង្កើតនូវសេដ្ឋកិច្ចដែលមានជវភាព នៅក្នុងទ្វីបអាស៊ីនិងតំបន់ប៉ាស៊ីហ្វិក។ ផលប៉ះពាល់នៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសចិនកំពុងបង្កើត និងពង្រីកកាលានុវត្តន៍ភាពថ្មីៗ និង សំខាន់សម្រាប់តំបន់និងពិភពលោកទាំងមូល។ អាស៊ានដែលស្ថិតនៅជិតប្រទេសចិន គឺជាអ្នកទទួលផលប្រយោជន៍ដ៏ចម្បងពីសហប្រតិបត្តិការនេះដែរ។

ពាណិជ្ជកម្មរវាងអាស៊ាននិងប្រទេសចិនបានកើនឡើងយ៉ាងឆាប់រហ័ស តាំងពីឆ្នាំ២០០២ បន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាក្របខ័ណ្ឌនាឆ្នាំ២០០២ (2002 Framework Agreement)។ វាក៏នៅមានការរីកចម្រើនជាបន្តបន្ទាប់លើវិស័យវិនិយោគពីប្រទេសចិន ជាពិសេស វិស័យហេដ្ឋារចនាសម្ព័ន្ធនៃប្រទេសដែលមានការអភិវឌ្ឍតិចបំផុតរបស់អាស៊ាន ហើយដែលបានផ្តល់មូនិធិតាមរយៈជំនួយឥតសំណងទ្វេភាគីនិងកម្ចីមានការប្រាក់ទាប។ ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអាស៊ាន-ចិនបានត្រូវពង្រីកយ៉ាងឆាប់រហ័សទៅដល់វិស័យចំនួន ១០។

ការអនុវត្តកិច្ចព្រមព្រៀងជាក្របខ័ណ្ឌឆ្នាំ ២០០២ សម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទន។ នៅកិច្ចប្រជុំកំពូលអាស៊ានលើកទី១២ នាឆ្នាំ២០០៧ នៅទីក្រុងសេប៊ូនៃប្រទេសហ្វីលិពីន អាស៊ាន និង ចិនបានចុះពិធីសារលើកទីពីរ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងប្រទេសចិន (the second Protocol on to Amend the Framework Agreement on the Comprehensive Economic Cooperation between ASEAN and China) កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេរីផ្នែកសេវាកម្ម(Agreement on Trade in Services) កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីអំពីសមាហរណកម្មវិស័យអាទិភាពទាំងដប់មួយ (The ASEAN Framework Agreement on Integration of Eleven Priority Sectors) និងពិធីសារលើវិសោធនកម្មនៃសមាហរណកម្មតាមវិស័យ (the Sectoral Integration (Amendment) Protocol)។ ក្នុងឆ្នាំ២០១០ តំបន់ពាណិជ្ជកម្មសេរីមួយរវាងអាស៊ាននិង ប្រទេសចិន ដែលមានពលរដ្ឋសរុបពីរពាន់លាននាក់បានចេញជារូបរាង ហើយនឹងដាក់អាស៊ីខាងកើតនៅលើផ្លូវមួយដែលមានការរីកចម្រើនខ្ពស់ជានិរន្តរ។

## ២៤.១១.២.៣. កិច្ចសហប្រតិបត្តិការអាស៊ាន-កូរ៉េខាងត្បូង

សាធារណរដ្ឋកូរ៉េ(ROK)បានក្លាយទៅជាដៃគូសន្ទនារបស់អាស៊ានតាំងពីឆ្នាំ១៩៩១។ក្នុងឆ្នាំ២០០៤ កូរ៉េបានចូលរួមក្នុងសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការ (Treaty of Amity and Cooperation= TAC)។ ក្នុងឆ្នាំ ២០០៥ អាស៊ាននិងសាធារណរដ្ឋកូរ៉េបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីអំពីភាពជាដៃគូរវាងអាស៊ាននិងសាធារណៈរដ្ឋកូរ៉េ និង លើផែនការសកម្មភាពអាស៊ាន-សាធារណរដ្ឋកូរ៉េ ដើម្បីអនុវត្តសេចក្តីប្រកាសរួមស្តីអំពីភាពជាដៃគូសេដ្ឋកិច្ច ដើម្បីលើកស្ទួយទំនាក់ទំនងសេដ្ឋកិច្ចដែលជិតស្និទ្ធជាងមុន ដោយរួមទាំង ការបង្កើតតំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាននិងសាធារណរដ្ឋកូរ៉េ (AKTFA)។ អាស៊ាន និង សាធារណរដ្ឋកូរ៉េក៏បានយល់ព្រមបង្កើនល្បឿននៃការចរចាដែលបានចាប់ផ្តើមកាលពីឆ្នាំ២០០៥ ដើម្បីបង្កើត

តំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាននិងសាធារណៈកូរ៉េ។ នៅពេលដែលតំបន់ពាណិជ្ជកម្មសេរីនេះបានចាប់ផ្តើមដំណើរការសហប្រតិបត្តិការ យ៉ាងហោចណាស់ទំនិញ៨០ភាគរយនឹងត្រូវបានកាត់បន្ថយពន្ធនាំចូលដល់សូន្យត្រឹមឆ្នាំ២០០៩។ ហើយលក្ខខណ្ឌដែលមានអំណោយផលជាងនេះនឹងត្រូវបានដាក់ឱ្យអនុវត្តដល់ប្រទេសថ្មីៗ ដែលជាសមាជិករបស់អាស៊ាន។ ក្នុងខែសីហាឆ្នាំ២០០៦ នៅទីក្រុងកូឡាឡាំពួរ អាស៊ាននិងសាធារណរដ្ឋកូរ៉េ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មលើទំនិញ ក្រោមកិច្ចព្រមព្រៀង ក្របខ័ណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច។

បន្ថែមលើនេះទៅទៀត សាធារណរដ្ឋកូរ៉េបានសម្រេចចិត្តបង្កើនការចូលរួមចំណែករបស់ខ្លួនដល់មូនិធិសហប្រតិបត្តិការពិសេសរវាងអាស៊ាន-សាធារណរដ្ឋកូរ៉េ (ASEAN–ROK Special Cooperation Fund) និងដល់មូលនិធិគម្រោងសហប្រតិបត្តិការផ្តោតលើអនាគតអាស៊ានសាធារណៈកូរ៉េ (ASEAN-ROK Future Oriented Cooperation Project Fund) ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តដ៏មុតមាំរបស់ខ្លួន ដើម្បីពង្រឹងភាពជាដៃគូនិងការសន្ទនា។ ប្រទេសកូរ៉េក៏គាំទ្រផងដែរដល់ការបង្កើតនូវគម្រោងចំនួនប្រាំនៅក្រោម IAI ដោយរួមមាន (១) ការសិក្សាអំពីសក្តានុពលតាមផែនការលើការសាងសង់កំណាត់ផ្លូវរថភ្លើង នៅប្រទេសកម្ពុជា ឡាវ ភូមា និងវៀតណាម ដើម្បីតភ្ជាប់ផ្លូវរថភ្លើងពីសិង្ហបុរីទៅកាន់ទីក្រុងគុនមិញ (Kunming) និង (២) ការកសាងសមត្ថភាពលើការធ្វើពាណិជ្ជកម្មទំនិញ និង សេវាកម្ម។

### ២៤.១១.២.៤. កិច្ចសហប្រតិបត្តិការអាស៊ានជប៉ុន

ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ពីប្រទេសជប៉ុនបានដើរតួនាទីដ៏គន្លឹះមួយក្នុងការអភិវឌ្ឍអាស៊ី។ ក្នុងមួយទសវត្សរ៍ចុងក្រោយនេះ ជំនួយអភិវឌ្ឍន៍របស់ជប៉ុនដល់អាស៊ានមានចំនួនប្រហែល ២៤ ពាន់លានដុល្លារអាមេរិក ស្មើនឹង ៣០ ភាគរយនៃបរិមាណជំនួយផ្លូវការសរុបទាំងអស់របស់ជប៉ុន។

ក្នុងឆ្នាំ២០០២ នាយករដ្ឋមន្ត្រីជប៉ុនលោក **ជូនីឈីរ៉ូ កូអ៊ីហ្សូមិ** (Junichiro Kuizumi) បានស្នើឡើងនូវគោលការ **អនុវត្តរួមគ្នា ធ្វើដំណើរឆ្ពោះទៅមុខរួមគ្នា** និង ភាពជាដៃគូមួយដ៏ស្មោះត្រង់និងបើកចំហក្នុងទំនាក់ទំនងរវាងប្រជាជនជប៉ុន និងប្រជាជនអាស៊ាន។ គោលបំណងនៃភាពជាដៃគូរនេះ គឺត្រូវធ្វើឱ្យអាស៊ីខាងកើតក្លាយទៅជាសហគមន៍បើកទូលាយមួយ ដែលចែករំលែកភាពរុងរឿង សន្តិភាព និងការជឿជាក់។ ភាពជាដៃគូនេះជំរុញឱ្យមានសេរីភាវូបនីកម្មវិនិយោគ និងការធ្វើពាណិជ្ជកម្មទំនិញ និងសេវាកម្ម ព្រមទាំងពង្រីកសហប្រតិបត្តិការ ដែលគ្របដណ្តប់លើសកម្មភាពជាច្រើនបែប រួមទាំង វិស័យទេសចរណ៍ ការអភិវឌ្ឍធនធានមនុស្ស និងការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម (SME) ។ វាក៏នឹងជួយពង្រឹងផងដែរដល់ទំនាក់ទំនងនយោបាយ និងមនុស្សធម៌ និងជួយធ្វើឱ្យអាស៊ីខាងកើតងើបឡើងវិញតាមរយៈការប្រកួតប្រជែងដ៏ត្រឹមត្រូវ។

ភាពជាដៃគូសេដ្ឋកិច្ចរវាងអាស៊ាននិងជប៉ុនត្រូវតែមានការពង្រឹង ដែលនាំឱ្យមានការផ្លាស់ប្តូរគំនិតគ្នា ចលនាមនុស្សនិងសេវាកម្ម និងការវិនិយោគក្នុងអាស៊ីខាងកើត។ សេដ្ឋកិច្ចអាស៊ាននិងជប៉ុនមានការពឹងផ្អែកទៅលើគ្នាកាន់តែខ្លាំងឡើងៗ។ អាស៊ាន គឺជាដៃគូពាណិជ្ជកម្មធំបំផុតទីពីររបស់ជប៉ុន ដោយមានទំហំពាណិជ្ជកម្មលើសពី១១០ពាន់លានដុល្លារអាមេរិក្នុងមួយឆ្នាំ។មិនតែប៉ុណ្ណោះការវិនិយោគផ្ទាល់របស់ជប៉ុននៅអាស៊ានមានបរិមាណលើសពី១១០ពាន់លានដុល្លារអាមេរិក។ ការវិនិយោគបន្ថែមទៀតពីប្រទេសជប៉ុន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងប្រទេសកម្ពុជា ឡាវ ភូមា និងវៀតណាម នឹងជួយដល់ការតភ្ជាប់គម្លាតនៃការអភិវឌ្ឍនៅក្នុងតំបន់។ ប៉ុន្តែ ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអាជីវកម្មនៅក្នុងប្រទេសជាម្ចាស់ផ្ទះ គឺជាលក្ខខណ្ឌដំបូងបំផុតសម្រាប់ការបង្កើនការវិនិយោគរបស់ជប៉ុននៅក្នុងតំបន់។

អាស៊ាននិងជប៉ុនបានសម្រេចបាននូវវឌ្ឍនភាពជាច្រើន ក្នុងការអនុវត្តផែនការសកម្មភាព ដែលជាមគ្គុទេសក៍មួយ សម្រាប់ភាពជាដៃគូអាស៊ាន-ជប៉ុន និងជាក្របខ័ណ្ឌទូលំទូលាយមួយ សម្រាប់សហប្រតិបត្តិការដែលបានកំណត់នៅថ្នាក់តំបន់ ជាពិសេសពាក់ព័ន្ធទៅនឹងសហប្រតិបត្តិការហិរញ្ញវត្ថុ និងរូបិយវត្ថុ ដោយរួមបញ្ចូលទាំងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ សេរីភាវូបនីយកម្មនៃគណនីមូលធន និងសហប្រតិបត្តិការរូបិយវត្ថុ។ មូលនិធិអភិវឌ្ឍន៍អាស៊ាន (ASEAN Development Fund) និងមូលនិធិសហប្រតិបត្តិការអាស៊ាន-ជប៉ុន (ASEAN-Japan Cooperation Fund) បានចូលរួមចំណែក ក្នុងការអនុវត្តកិច្ចសហប្រតិបត្តិការនេះ។

អាស៊ាននិងជប៉ុនកំពុងធ្វើការងារលើការរៀបចំនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ សម្រាប់ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (Framework Agreement for Comprehensive Economic Partnership) រវាងអាស៊ាន និងជប៉ុន ដែលត្រូវបានកំណត់ឱ្យមានការឯកភាពត្រឹមឆ្នាំ២០១០។ ការប្រតិបត្តិនៃកិច្ចព្រមព្រៀងនេះនឹងជួយលើកស្ទួយសេរីភាវូបនីយកម្មនៃការវិនិយោគ និងការធ្វើពាណិជ្ជកម្មលើទំនិញ និងសេវាកម្ម។ ដូចគ្នាផងដែរ វានឹងពង្រឹងកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យជាច្រើន រួមទាំងវិស័យទេសចរណ៍ ការអភិវឌ្ឍធនធានមនុស្ស និង សហគ្រាសធនតូចនិងមធ្យម (SME)។

កម្ពុជាបានទទួលអត្ថប្រយោជន៍ជាច្រើនពីជំនួយរបស់ប្រទេសជប៉ុន ក្រោមក្របខ័ណ្ឌរបស់ GMS នៅក្នុងវិស័យសំខាន់ៗ ដោយរួមទាំងសុខដុមនីយកម្មនៃគ្រឹះស្ថាននិងស្តង់ដារ ព្រមទាំងការសម្របសម្រួលឱ្យមានចរាចរដោយសេរីលើផ្នែកមនុស្សនិងទំនិញ។ ប្រទេសជប៉ុនក៏បានផ្តល់ជូននូវការគាំទ្រ សម្រាប់ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដោយរួមទាំងផ្លូវថ្នល់ ស្ពាន កំពង់ផែ ផ្លូវរថភ្លើង សហប្រតិបត្តិការលើផ្នែកអគ្គិសនី បច្ចេកវិទ្យា ព័ត៌មានវិទ្យា និងការគ្រប់គ្រងធនធានទឹក។ ប្រទេសជប៉ុនក៏កំពុងផ្តល់ជូនផងដែរនូវការបណ្តុះបណ្តាលដល់សហគ្រិន ដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែងនៅក្នុងសហគមន៍អាជីវកម្មក្នុងស្រុក។ មជ្ឈមណ្ឌលសហប្រតិបត្តិការជប៉ុន-កម្ពុជា (Japan-Cambodia Center for Cooperation) ត្រូវបានបង្កើតឡើង ជាការទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់ជប៉ុន ដែលត្រូវដើរនៅក្នុងការអភិវឌ្ឍរបស់កម្ពុជា។

### ២៤.១១.២.៥. កិច្ចសហប្រតិបត្តិការអាស៊ាន-ឥណ្ឌា

ប្រទេសឥណ្ឌាបានក្លាយទៅជាដៃគូសន្ទនាពេញសិទ្ធិរបស់អាស៊ានក្នុងខែធ្នូ ឆ្នាំ១៩៩៥ ហើយទំនាក់ទំនងរវាងអាស៊ាន និងឥណ្ឌាកំពុងរីកលូតលាស់ ដោយមានសហប្រតិបត្តិការដ៏ជិតដិតក្នុងវិស័យកសិកម្ម សុខភាពសាធារណៈ ការអភិវឌ្ឍធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យាព័ត៌មានវិទ្យា វិទ្យាសាស្ត្រ និងនយោបាយ។

កិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌាលើកដំបូងត្រូវបានប្រារព្ធឡើងក្នុងឆ្នាំ២០០២ នារាជធានីភ្នំពេញដែលនោះបានគូសបង្ហាញនូវរបត់ថ្មីមួយនៃទំនាក់ទំនងរវាងដៃគូទាំងពីរ។ អាស៊ាន និង ឥណ្ឌាបានចាប់ផ្តើមកិច្ចចរចានៅឆ្នាំ២០០៤ ដើម្បីបង្កើតឡើងនូវតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌានិង ដើម្បីបង្កើតភាពជាដៃគូ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេដ្ឋកិច្ចអាស៊ាន-ឥណ្ឌាដ៏ទូលំទូលាយមួយ សម្រាប់សមាជិកដទៃទៀត។ នៅឆ្នាំ២០០៤ ភាគីទាំងពីរបានចុះហត្ថលេខាលើ **ភាពជាដៃគូអាស៊ាន-ឥណ្ឌា ដើម្បីសន្តិភាពវឌ្ឍនភាព និងភាពរុងរឿង** (ASEAN-India Partnership for Peace, Progress and Shared Prosperity) និង កិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីអំពីសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (Framework Agreement on Comprehensive Economic Cooperation)។

### ២៤.១១.២.៦. កិច្ចសហប្រតិបត្តិការអាស៊ាន-អូស្ត្រាលី និងណូវ៉ែលហ្សេឡង់

សហប្រតិបត្តិការរបស់អាស៊ាន ជាមួយប្រទេសអូស្ត្រាលីនិងណូវ៉ែលហ្សេឡង់កំពុងមានភាពខ្លាំងក្លាជាពិសេសនៅក្នុងវិស័យនានាដូចជា ហេដ្ឋារចនាសម្ព័ន្ធគតិយុត្តិសម្រាប់ពាណិជ្ជកម្មអេឡិចត្រូនិក ការទទួលទៅវិញទៅមកនៃសញ្ញាប័ត្រ ប្រព័ន្ធទទួលស្គាល់គុណភាពផ្លែឈើនិងបន្លែ និងប្រព័ន្ធធានាគុណភាពនិងសុវត្ថិភាពត្រីនិងផលិតធ្វើពីត្រី ការកែឆ្នៃផលិតផលទាំងនោះ និងការវេចខ្ចប់។

ប្រទេសទាំងអស់នៃអាស៊ាន ប្រទេសអូស្ត្រាលី និង ណូវ៉ែលហ្សេឡង់កំពុងធ្វើការចរចាលើការបង្កើតឱ្យមានតំបន់ពាណិជ្ជកម្មសេរីមួយដោយផ្អែកទៅលើកិច្ចព្រមព្រៀង AFTA-CER ដែលមានស្រាប់តាំងពីឆ្នាំ២០០២។ វិស័យសហប្រតិបត្តិការដែលបានស្នើឡើងរួមមាន ការសម្រួលផ្នែកពាណិជ្ជកម្មនិងវិនិយោគ ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព។ ការចរចាទាំងនោះត្រូវបានដឹកនាំដោយគោលការដូចតទៅៈ (១) តំបន់ពាណិជ្ជកម្មសេរីគប្បីមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយគ្របដណ្ដប់ទៅលើការធ្វើពាណិជ្ជកម្មទំនិញ សេវាកម្ម និងការវិនិយោគ (២) គោលបំណងរបស់វា គឺជំរុញឱ្យមានសមាហរណកម្មសេដ្ឋកិច្ចក្នុងចំណោមតំបន់ទាំងពីរ តាមរយៈការដកចេញបន្តិចម្ដងៗ នូវរបាំងដល់ការធ្វើពាណិជ្ជកម្ម ទំនិញ សេវាកម្ម និងការវិនិយោគ និងតាមរយៈការសម្រួលពាណិជ្ជកម្ម និងការវិនិយោគ (៣) តំបន់សេដ្ឋកិច្ចសេរី នឹងត្រូវអនុលោមតាមកាតព្វកិច្ចនៃអង្គការពាណិជ្ជកម្មពិភពលោករបស់ប្រទេសសមាជិក (៤) វានឹងពិចារណានូវកម្រិតខុសៗគ្នានៃការអភិវឌ្ឍនិងសមត្ថភាពក្នុងប្រទេសជាសមាជិក ដើម្បីចែករំលែកសេរីភាវូបនីយកម្មនៃពាណិជ្ជកម្មនិងការវិនិយោគ ដោយការផ្ដល់ជូនសមាជិកថ្មីរបស់អាស៊ាននូវប្រព្រឹត្តិកម្មពិសេស និង ផ្សេងៗគ្នា (៥) ជំនួយបច្ចេកទេសនឹងត្រូវបានផ្ដល់ជូនដល់ប្រទេស ដែលមានការអភិវឌ្ឍតិចបំផុត ដើម្បីឱ្យពួកគេអាចទទួលបាននូវអត្ថប្រយោជន៍ពីតំបន់សេដ្ឋកិច្ចសេរី និង (៦) តំបន់សេដ្ឋកិច្ចសេរីនឹងត្រូវបានបង្កើតឡើងក្នុងរយៈពេល១០ ឆ្នាំ នាំក្រោយហើយការចរចានឹងត្រូវបញ្ចប់ត្រឹមឆ្នាំ២០០៧។

### ២៤.១១.២.៧. កិច្ចសហប្រតិបត្តិការអាស៊ាន-អាមេរិក

ក្នុងកិច្ចខិតខំដើម្បីដោះស្រាយនូវដំណើរការយឺតយ៉ាវ ក្នុងការបញ្ចប់នូវកិច្ចចរចា Doha Round សហរដ្ឋអាមេរិកបានអនុវត្តគំនិតផ្ដួចផ្ដើមពាណិជ្ជកម្ម ដែលជាជម្រើសជាច្រើនបែប ដោយរួមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្នាក់តំបន់ និងទ្វេភាគី។ សហរដ្ឋអាមេរិកបានដាក់សំណើជាកិច្ចព្រមព្រៀងជាក្របខ័ណ្ឌពាណិជ្ជកម្មនិងការវិនិយោគអាស៊ាន-អាមេរិក (ASEAN-USA Trade and Investment Framework Agreement=TIFA) នៅក្រោម Enterprise for ASEAN Initiatives (EAI) ដែលបានប្រកាសដោយសហរដ្ឋអាមេរិកនៅឯកិច្ចប្រជុំកំពូលប្រចាំឆ្នាំ APEC ក្នុងខែតុលា ឆ្នាំ២០០២។ ប្រធានាធិបតី **ប៊ូស** បានបង្ហាញនូវបំណងប្រាថ្នារបស់លោកថា កិច្ចចរចាគប្បីបន្តជាមួយនឹងទស្សនវិស័យ ដែលនាំឱ្យមានការចុះហត្ថលេខាលើ

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយបណ្តាប្រទេសអាស៊ាននៅក្រោម EAI។ នៅក្រោមកិច្ចព្រមព្រៀងនេះ រាល់ប្រទេសសមាជិកពាណិជ្ជកម្មសេរីក្នុងពេលអនាគតទាំងអស់មិនមែនគ្រាន់តែ ជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកប៉ុណ្ណោះទេ តែគឺជាភាគីហត្ថលេខីនៃ TIFA ជាមួយសហរដ្ឋអាមេរិកទៀតផង។

សហរដ្ឋអាមេរិកចាត់ទុកថាការចុះហត្ថលេខាលើកិច្ចព្រមព្រៀង TIFA មានសារៈសំខាន់យ៉ាងខ្លាំង ពីព្រោះ (១) វាជួយសម្រួលនិងពង្រីកការចូលទៅដល់ទីផ្សារ (២) វាដាក់ឱ្យអនុវត្តនូវការត្រួតពិនិត្យដែលប្រសើរជាងមុននៃការអនុវត្តពាណិជ្ជកម្មនិងកិច្ចព្រមព្រៀងពហុភាគី ហើយ (៣) វារៀបចំឱ្យមានមូលដ្ឋានគ្រឹះសម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនាពេលអនាគត។

#### *២៤.១១.២.៨. កិច្ចសហប្រតិបត្តិការអាស៊ាន-សហគមន៍អឺរ៉ុប*

អាស៊ានកំពុងសហប្រតិបត្តិការជាមួយសហគមន៍អឺរ៉ុប នៅក្នុងវិស័យការសម្រួលពាណិជ្ជកម្ម ស្តង់ដារឧស្សាហកម្ម ផលិតផលចំណីអាហារ និងការលើកស្ទួយការវិនិយោគ នៅក្រោមគំនិតផ្តួចផ្តើមពាណិជ្ជកម្មឆ្លងតំបន់សហគមន៍អឺរ៉ុប-អាស៊ាន(Tran-regional EU-ASEAN Trade Initiatives=TREATI) ។

### ២៤.១២.កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ានបូកបី

ក្រោយពេលមានវិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ១៩៩៧-១៩៩៨ ភ្លាម ប្រទេសអាស៊ាន+៣បានបង្កើតចេញជាសំណើសុំឱ្យមានសមាហរណកម្មតំបន់ ដែលត្រូវបានរៀបចំឡើង ដើម្បីការពារវិបត្តិហិរញ្ញវត្ថុនាពេលអនាគត ព្រមទាំងហានិភ័យនៃស្ថេរភាពក្នុងទីផ្សារហិរញ្ញវត្ថុរបស់អាស៊ី។ គំនិតផ្តួចផ្តើមទាំងអស់នេះមានគោលបំណងជៀសវាងពីភាពមិនស៊ីគ្នាទ្វេដងនៃប្រតិបត្តិការហិរញ្ញវត្ថុដូចជា ការពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទកំណត់ (ទ្រព្យសកម្មរយៈពេលវែង តែបំណុលមានរយៈពេលខ្លី) និង រូបិយវត្ថុចម្រុះ (ទ្រព្យសកម្មចារិកជារូបិយវត្ថុក្នុងស្រុក ក៏ប៉ុន្តែ បំណុលគិតជារូបិយប័ណ្ណបរទេស) ដែលនោះគឺជាមូលហេតុដ៏សំខាន់បំផុត ដែលធ្វើឱ្យមានវិបត្តិហិរញ្ញវត្ថុឆ្នាំ១៩៩៧-១៩៩៨។

កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន+៣ និង កិច្ចប្រជុំថ្នាក់អនុរដ្ឋមន្ត្រី និងទេសាភិបាលរងសម្រេចបានវឌ្ឍនភាពលើកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងអាស៊ីបូព៌ា ដើម្បីសម្រេចឱ្យបាននូវគោលដៅដូចខាងក្រោម៖

- ថែរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចនៃទីផ្សារហិរញ្ញវត្ថុ។
- លើកកម្ពស់សមិទ្ធផលម៉ាក្រូសេដ្ឋកិច្ចនៅក្នុងតំបន់។
- ទប់ស្កាត់ និង គ្រប់គ្រងវិបត្តិនានានៅពេលអនាគត។

ចាប់តាំងពីឆ្នាំ១៩៩៩ បណ្តាប្រទេសអាស៊ានបូកបីបានធ្វើការងារ ដើម្បីបង្កើតស្ថាបត្យកម្មហិរញ្ញវត្ថុក្នុងតំបន់មួយជាមួយធាតុផ្សំដូចតទៅ៖

- **គំនិតផ្តួចផ្តើមឈាងម៉ៃ** (The Chiang Mai Initiative=CHI) ដោយផ្អែកលើកិច្ចព្រមព្រៀងផ្លាស់ប្តូរទ្វេភាគី (bilateral swap agreement)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

- **កិច្ចសន្ទនាលើបញ្ហាសេដ្ឋកិច្ច និងគោលនយោបាយអាស៊ាន+៣** (ASEAN+3 Economic Review and Policy Dialogue) ថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារកណ្តាលអាស៊ាន+៣ (ASEAN+3 Finance Ministers, Deputy Finance Ministers and Center Bank Deputy Governors)។
- **គំនិតផ្តួចផ្តើមទីផ្សារមូលប័ត្រអាស៊ាន** (Asian Bond Market Initiative=ABMI) ដើម្បីបង្កើតទីផ្សារមូលប័ត្រ ដែលមានប្រសិទ្ធភាព និង ងាយប្តូរទៅជាសាច់ប្រាក់នៅអាស៊ី ដែលអនុញ្ញាតឱ្យមានការប្រើប្រាស់កាន់តែប្រសើរ នូវប្រាក់សន្សំនៅក្នុងប្រទេសអាស៊ាន+៣ សម្រាប់ការវិនិយោគផ្នែកឧស្សាហកម្មនិងហេដ្ឋារចនាសម្ព័ន្ធ។

## ២៤.១២.១. គំនិតផ្តួចផ្តើមឈាងម៉ៃ

នៅឯកិច្ចប្រជុំប្រចាំឆ្នាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងខែឧសភា ឆ្នាំ ២០០០ នាខេត្តឈាងម៉ៃ ប្រទេសអាស៊ាន+៣ បានឯកភាពគ្នាបង្កើតគំនិតផ្តួចផ្តើមឈាងម៉ៃ (CMI) ដែលជាប់ពាក់ព័ន្ធនឹងការបង្កើតមជ្ឈមណ្ឌលសម្រាប់គាំទ្រដល់ហិរញ្ញវត្ថុតំបន់ នៅពេលមានវិបត្តិសាច់ប្រាក់។ នៅឆ្នាំ២០០១ បណ្តាប្រទេសអាស៊ាន+៣ បានចរចានិងអនុមតិគោលការណ៍ប្រតិបត្តិការរបស់ CMI ដែលផ្តល់ឱកាសឱ្យពួកគេចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្លាស់ប្តូរទ្វេភាគី (ការដោះដូររូបិយប័ណ្ណបរទេសរវាងធនាគារកណ្តាលរបស់ប្រទេសដែលពាក់ព័ន្ធ) ក្នុងករណីដែលមានវិសមតាបណ្តោះអាសន្ន (Temporary disequilibrium) នៃជញ្ជីងទូទាត់។

CMI ព្យាករណ៍មើលថា ក្នុងករណីមានវិបត្តិ ខ្សែការពារជួរទីមួយរបស់បណ្តាប្រទេសអាស៊ាន គឺជាកិច្ចព្រមព្រៀងផ្លាស់ប្តូរអាស៊ាន (ASA) ដែលពាក់ព័ន្ធនឹងប្រទេសជាសមាជិកទាំង១០របស់អាស៊ាន ក្នុងទឹកប្រាក់មួយពាន់លានដុល្លារអាមេរិក។ ប្រសិនបើការផ្លាស់ប្តូរទាំងនេះមិនគ្រប់គ្រាន់ទេនោះ បណ្តាប្រទេសអាស៊ានអាចមានឧបករណ៍ជាខ្សែការពារជួរទីពីរមួយទៀត ដែលនោះគឺ ការផ្លាស់ប្តូរទ្វេភាគីជាមួយប្រទេសចិន កូរ៉េខាងត្បូង និងជប៉ុន។ ការបើកប្រាក់ស្វ័យប្រវត្តិ (automatic disbursement) ត្រូវបានកំណត់ត្រឹម ១០% នៃបរិមាណសរុបរបស់ឥណទាននេះ។ ប្រទេសដែលជួបវិបត្តិអាចខ្ចីសមតុល្យ ៩០% ទៀត ដែលនៅសេសសល់ ទាល់តែប្រទេសជាសមាជិកនោះមានកម្មវិធី IMF។

គោលបំណងចម្បងបំផុតនៃឥណទាននេះគឺ ការប៉ះប៉ូវនូវកង្វះខាតសាច់ប្រាក់បណ្តោះអាសន្ន ហើយដោយហេតុផលនេះ វាបានទប់ស្កាត់វិបត្តិហិរញ្ញវត្ថុកុំឱ្យមានការកើនឡើង។ ប្រសិនបើបរិមាណ ១០ ភាគរយនៃការបើកប្រាក់ស្វ័យប្រវត្តិមិនគ្រប់គ្រាន់ទេ បញ្ហាសេដ្ឋកិច្ចនឹងមានវិសាលភាពជារចនាសម្ព័ន្ធ។ ដូច្នេះ ហើយ ប្រទេសនោះចាំបាច់ត្រូវមានកម្មវិធី IMF ក្នុងគោលដៅអនុវត្តការកែសម្រួលដែលចាំបាច់។ នៅពេល ដែលនិតិវិធីនៃការផ្លាស់ប្តូរទ្វេភាគី ដែលត្រូវបានអនុម័តដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន+៣ បានត្រូវគេពិនិត្យ សាឡើងវិញនៅ ខែឧសភាឆ្នាំ ២០០៦ បរិមាណស្វ័យប្រវត្តិត្រូវបានបង្កើនដល់២០ ភាគរយ ដើម្បីធ្វើឱ្យ ឥណទាននេះ មានភាពទន់ភ្លន់ជាងមុន និងដើម្បីផ្តល់ការឆ្លើយតបដ៏ឆាប់រហ័សជំនួសឱ្យការបាត់បង់ពេល វេលាយូរ ក្នុងការចរចារៀបចំកម្មវិធីជាមួយ IMF។ បញ្ហានៃការលើកទឹកចិត្តឱ្យធ្វើខុស ដោយអាងតែមាន ឥណទាន ត្រូវបានកាត់បន្ថយ ដោយសារតែនីតិវិធីនៃការផ្លាស់ប្តូរទ្វេភាគី សម្រាប់ចាប់ផ្តើមដំណើការឥណទាន ទាមទារឱ្យមានការសម្រេចចិត្តជាក្រុម។ គិតត្រឹមចុងឆ្នាំ ២០០៦ ទំហំនៃកិច្ចព្រមព្រៀងផ្លាស់ប្តូរទ្វេភាគីបាន កើនឡើងដល់ ១៦ ក្នុងចំណោមប្រទេសចំនួន ៨ ហើយមានទឹកប្រាក់សរុបចំនួន ៧៧ ពាន់លានដុល្លារអាមេរិក។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីពង្រឹងយន្តការឃ្លាំមើល បណ្តាប្រទេសអាស៊ាន+៣ បានបង្កើតក្រុមជំនាញការមួយ (Group of Experts) ដែលមានតួនាទីធ្វើការសិក្សាស៊ីជម្រៅ លើបញ្ហាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុងតំបន់។ បន្ថែមលើនេះទៀត ក្រុមការងារបច្ចេកទេសខាងផ្នែកត្រួតពិនិត្យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (Technical Working Group on Economic and Financial Monitoring) ត្រូវបានបង្កើតឡើង ដើម្បីបំពេញបន្ថែមនូវការឃ្លាំមើលនៅកន្លែង។ បណ្តាប្រទេសអាស៊ាន+៣បានឯកភាពគ្នាអនុវត្តការសិក្សា ក្នុងគោលដៅប្រែក្លាយកិច្ចព្រមព្រៀងឥណទានទ្វេភាគី ឱ្យទៅជាឥណទានពហុភាគីវិញ នៅក្រោមគំនិតផ្តួចផ្តើមឈាងម៉ៃ (CMI)។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការឃ្លាំមើលនៅក្នុងតំបន់ និងកាត់បន្ថយអស្ថេរភាពនៃអត្រាប្តូរប្រាក់រវាងរូបិយប័ណ្ណនៃបណ្តាប្រទេសអាស៊ាន+៣ ធនាគារអភិវឌ្ឍន៍អាស៊ីបានប្រកាស កាលពីខែឧសភាឆ្នាំ ២០០៦ នៅឯកិច្ចប្រជុំប្រចាំឆ្នាំនៅទីក្រុង Hyderabad អំពីការដាក់ឱ្យប្រើប្រាស់នូវឯកតារូបិយប័ណ្ណអាស៊ី (Asia Currency Unit = ACU) ដែលជាសន្ទស្សន៍នៃរូបិយប័ណ្ណអាស៊ាន+៣។ គោលបំណងនៃរូបិយប័ណ្ណអាស៊ាន+៣ គឺ ដើម្បីបង្កើតគំរូមួយ សម្រាប់ការគ្រប់គ្រងការឡើងចុះនៃអត្រាប្តូរប្រាក់បរទេស ក្នុងបណ្តាប្រទេសជាសមាជិក។ តែកិច្ចការនេះមិនបានសម្រេចតាមការគ្រោងឡើយ។

### ៤៤.១២.២. កិច្ចសន្ទនាលើបញ្ហាសេដ្ឋកិច្ច និងគោលនយោបាយអាស៊ានបូកបី

បណ្តាប្រទេសអាស៊ាន+៣បានដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌផ្លាស់ប្តូរទស្សនវិស័យនិងព័ត៌មាន ដែលផ្តោតលើបញ្ហាសេដ្ឋកិច្ចនៅក្នុងប្រទេសអាស៊ាន+៣នីមួយៗ។ **កិច្ចសន្ទនាលើបញ្ហាសេដ្ឋកិច្ចនិងគោលនយោបាយ**នេះមានបំណងបំពេញបន្ថែម ដោយដាក់សម្ពាធពីបណ្តាមិត្ត ដោយបង្កើតឱ្យមានវេទិកាផ្លាស់ប្តូរយោបល់ស្តីពីគោលនយោបាយ សម្រាប់ចែករំលែកបទពិសោធន៍ស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាចំនុចខ្សោយ។ គោលបំណងនៃកិច្ចសន្ទនានេះ មានដូចខាងក្រោម៖

- តាមការចាំបាច់ ត្រូវមានការវាយតម្លៃពីភាគីទីបីលើបញ្ហាក្នុងតំបន់ ដើម្បីបំពេញបន្ថែមលើការវាយតម្លៃរបស់ IMF និងគ្រឹះស្ថានក្នុងតំបន់ដទៃទៀត។
- កំណត់និងវិភាគបញ្ហានានានៅក្នុងតំបន់ ដែលជាកង្វល់របស់ប្រទេសអាស៊ាន+៣ទាំងអស់។ ការដោះស្រាយដែលបានស្នើឡើង នឹងបំពេញបន្ថែមដំណើរការឃ្លាំមើល ដែលបានបង្កើតឡើងដោយគ្រឹះស្ថានដទៃទៀតក្នុងតំបន់។

ការធ្វើឱ្យប្រសើរនូវ **កិច្ចសន្ទនាលើបញ្ហាសេដ្ឋកិច្ចនិងគោលនយោបាយ** អាចដំណើរការជាពីរដំណាក់កាល។ ដំណាក់កាលទី១ គឺពង្រឹងនូវដំណើរការកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលរងនៃធនាគារកណ្តាលអាស៊ាន+៣ (ASEAN+3 Finance and Central Bank Deputies′ Meeting= AFDM+3)។ បែបផែននៃកិច្ចពិភាក្សាលើគោលនយោបាយសេដ្ឋកិច្ចមានដូចខាងក្រោម៖

- ការពិភាក្សារយៈពេលមួយថ្ងៃស្តីពីបញ្ហាសេដ្ឋកិច្ច និងគោលនយោបាយសាធារណៈ នៅឯកិច្ចប្រជុំ AFDM+3។
- កិច្ចប្រជុំក្រៅផ្លូវការរបស់អនុរដ្ឋមន្ត្រីនិងទេសាភិបាលរងធនាគារកណ្តាលអាស៊ាន+៣ (ASEAN+3 Deputy Ministers and Central Bank Deputy Governors) ដែលបានរៀបចំឡើងនៅពាក់កណ្តាលឆ្នាំ។

បណ្តាប្រទេសអាស៊ាន+៣ កំពុងធ្វើការងារលើដំណាក់កាលទីពីរជាមួយនឹងវិធានការ ដែលបានស្នើឡើងដូចខាងក្រោមៈ

- បង្កើតដំណើរការឃ្លាំមើលក្នុងតំបន់ ដែលអាចទុកចិត្តបាន ដើម្បីបញ្ចប់នូវគំនិតផ្តួចផ្តើមឈៀងម៉ៃ (Chiang Mai Initiatives) ដោយដាក់ឱ្យអនុវត្តនូវប្រព័ន្ធប្រកាសអាសន្នជាដំបូងសម្រាប់តំបន់។ នាពេលបច្ចុប្បន្ននេះ បែបផែនរបស់ AFDM+3 ត្រូវបានបង្កើតឡើងពីរ: (១) ការពិភាក្សាមួយស្តីអំពីស្ថានភាពនិងបញ្ហាសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននិង (២) ការជ្រើសរើសប្រធានបទ ដែលជាអត្ថប្រយោជន៍រួម សម្រាប់តំបន់ ដើម្បីធ្វើការពិភាក្សាឱ្យស៊ីជម្រៅ។ តួនាទីរបស់ AFDM+៣ គឺ ត្រូវកំណត់នូវបញ្ហានិងភាពដែលងាយរងគ្រោះកំពុងកើតឡើង ដែលបញ្ហានេះអាចបង្កើតឱ្យទៅជាវិបត្តិដ៏ធ្ងន់ធ្ងរក្នុងរយៈពេល ៦ ទៅ ១២ ខែខាងមុខ។
- រៀបចំការសិក្សានិងអនុវត្តការស្រាវជ្រាវលើបញ្ហានានាក្នុងតំបន់ ដែលនឹងផ្តល់ជូននូវប្រភពអនុសាសន៍ជំនាញបន្ថែមទៀត សម្រាប់ជាប្រយោជន៍របស់ប្រទេសជាសមាជិក។
- ពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យនៅក្នុងប្រទេសជាសមាជិក ដោយធ្វើការរៀបចំការសិក្សាស្តីអំពីហានិភ័យនិងភាពងាយរងគ្រោះរបស់ប្រទេសជាសមាជិក។

ក្រុមស្រាវជ្រាវអាស៊ាន+៣ (ASEAN+3 Research Group) មួយត្រូវបានបង្កើតឡើងដោយ AFDM+3 ដើម្បីរ៉ាប់រងការសិក្សាស្តីអំពីប្រធានបទផ្សេងៗ ដែលជាអត្ថប្រយោជន៍រួម។ គ្រឹះស្ថានស្រាវជ្រាវនានានៅក្នុងបណ្តាប្រទេសអាស៊ាន+៣ត្រូវបានជ្រើសរើសឱ្យចូលរួមនៅក្នុងក្រុមស្រាវជ្រាវនេះ។ អ្នកឯកទេសទាំងនោះបង្ហាញនូវលទ្ធផលនៃការស្រាវជ្រាវនិងសិក្សារបស់ពួកគេនៅឯកិច្ចប្រជុំ AFDM+3។ បណ្តាប្រទេសអាស៊ានបូកបីបានបង្កើតឱ្យមានមូលនិធិសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣ (ASEAN+3 Finance Cooperation Fund) ដើម្បីផ្តល់មូលនិធិដល់ការស្រាវជ្រាវនេះ។

## ២៤.១២.៣. គំនិតផ្តួចផ្តើមជីផ្សារមូលប័ត្រអាស៊ី( Asian Bond Market Initiative= ABMI )

បទពិសោធន៍សំខាន់បំផុតដែលទទួលបានពីវិបត្តិហិរញ្ញវត្ថុអាស៊ីក្នុងឆ្នាំ១៩៩៧-១៩៩៨ស សម្រាប់អាស៊ីខាងកើតគឺ (១) ភាពមិនស៊ីគ្នានៃរូបិយប័ណ្ណ និង កាលបរិច្ឆេទសងបំណុលនៃប្រតិបត្តិការហិរញ្ញវត្ថុគឺជាហានិភ័យជាប្រព័ន្ធ ហើយបង្កើតជាផ្កាភ្លើងដែលនាំឱ្យមានវិបត្តិនាពេលអនាគត (២) សេរីភាវូបនីយកម្មនៃគណនីមូលធន ត្រូវរៀបចំឱ្យមានសណ្តាប់ធ្នាប់ល្អ ហើយត្រូវកើតឡើង ក្រោយពីមានការពង្រឹងសមត្ថភាពរបស់គ្រឹះស្ថានត្រួតពិនិត្យ និង និយ័តកម្មតែប៉ុណ្ណោះនិង (៣) ភាពពឹងផ្អែកដ៏ខ្លាំងក្លានៃការវិនិយោគទៅលើកម្ចីធនាគារអាចជាហានិភ័យ សម្រាប់ស្ថេរភាពហិរញ្ញវត្ថុ។ លិខិតូបករណ៍ហិរញ្ញវត្ថុដូចជា ប័ណ្ណភាគហ៊ុននិងមូលប័ត្រអាចត្រូវបានរៀបចំឡើង ដើម្បីបញ្ចូលបទពិសោធន៍ទាំងអស់នោះ។

សំណើរបស់អាស៊ាន+៣លើគំនិតផ្តួចផ្តើមទីផ្សារមូលប័ត្រអាស៊ី (ABMI) មានបំណងលើកទឹកចិត្តដល់ការវិនិយោគនៃប្រាក់សន្សំក្នុងតំបន់លើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង ឧស្សាហកម្មនៅក្នុងបណ្តាប្រទេសអាស៊ី។ គួរកត់សម្គាល់ថា សព្វថ្ងៃនេះប្រទេសអាស៊ីនាំចេញមូលធនដែលមានការធានា (Securitized Capital) ជាទម្រង់នៃការវិនិយោគដោយធនាគារកណ្តាលនៃទុនបម្រុងបរទេសរបស់ខ្លួន ទៅក្នុងទ្រព្យសកម្ម



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់ប្រទេសអភិវឌ្ឍន៍ ជាពិសេស មូលប័ត្ររតនាគាររបស់សហរដ្ឋអាមេរិក ហើយនាំចូលមូលធនដែលមានហានិភ័យជាការវិនិយោគជាមូលប័ត្រ (Portfolio Investment)។ ប្រការនេះបានបណ្ដាលឱ្យមានការកើនឡើងនៃអតុល្យភាពសកលដ៏ខ្លាំងក្លា ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។ ABMI នឹងកាត់បន្ថយនូវអតុល្យភាពទាំងនោះ។ បន្ថែមពីលើនេះទៅទៀត បញ្ហាមូលប័ត្រសាច់ប្រាក់នៅក្នុងស្រុកត្រូវបានគេរំពឹងថានឹងកាត់បន្ថយភាពងាយរងគ្រោះនៃសេដ្ឋកិច្ចរបស់អាស៊ាន+៣ ដែលកើតឡើងចេញពីការពឹងផ្អែកជ្រុលពេកលើកម្ចីធនាគារនិងហានិភ័យភាពមិនស៊ីគ្នាទ្វេដង។

អាស៊ាន+៣បានបង្កើតក្រុមការងារចំនួន០៦ ដើម្បីបង្កើតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍទីផ្សារមូលប័ត្រនៅក្នុងតំបន់។ ក្រុមការងារទាំង០៦នោះមានដូចខាងក្រោម៖

**ក្រុមការងារទី១: ការបង្កើតលិខិតូបករណ៍បំណុលដែលមានការធានាថ្មី** (Creating New Securitized Debt Instruments)

(**ប្រធាន: ប្រទេសថៃ**)

គោលបំណងនៃក្រុមការងារនេះគឺ សម្រួលការចេញលក់នៃមូលប័ត្ររបស់រដ្ឋាភិបាលនៅក្នុងបណ្ដាប្រទេសអាស៊ាន+៣ក្នុងដំណាក់កាលទី១។ ដំណាក់កាលទី២ និងដោះស្រាយការបង្កើតនៃលិខិតូបករណ៍ដែលមានការធានានិងមូលប័ត្រសាជីវកម្ម។ មូលប័ត្រប្រភេទនេះ អាចត្រូវបានចេញលក់ក្នុងប្រភេទជារូបិយវត្ថុក្នុងស្រុកនិងរូបិយប័ណ្ណបរទេសដែលមានឥទ្ធិពល។

អាស៊ាន+៣បានឯកភាពគ្នាថា បណ្ដាប្រទេសអាស៊ីចាំបាច់ត្រូវដាក់ឱ្យអនុវត្តក្របខ័ណ្ឌនិងហេដ្ឋា-រចនាសម្ព័ន្ធផ្លូវច្បាប់ ដើម្បីអភិវឌ្ឍន៍ទីផ្សារមូលប័ត្រជាតិនៅក្នុងប្រទេសនីមួយៗ មុនពេលតភ្ជាប់ទីផ្សារនោះជាមួយទីផ្សារដទៃទៀតនៅក្នុងបណ្ដាញតំបន់របស់ទីផ្សារមូលប័ត្រអាស៊ី។ មិនតែប៉ុណ្ណោះ ប្រទេសទាំងអស់នោះទទួលស្គាល់នូវកម្រិតខុសគ្នានៃការអភិវឌ្ឍរបស់ទីផ្សារមូលប័ត្រនៅក្នុងសេដ្ឋកិច្ចនីមួយៗរបស់ពួកគេ។

ក្របខ័ណ្ឌសហប្រតិបត្តិការអាស៊ាន+៣ កំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងពិសេសទៅលើផ្នែកផ្គត់ផ្គង់មូលប័ត្រ ដែលនោះគឺការចេញលក់មូលប័ត្រដោយអាជ្ញាធរជាតិ។ ក្រុមការងារនេះក៏កំពុងធ្វើការផងដែរជាមួយធនាគារកណ្ដាលនានា ដើម្បីកសាងនូវតម្រូវការចំពោះមូលប័ត្រទាំងអស់នេះ ដោយការបង្កើតការធានារ៉ាប់រងជីវិតប្រព័ន្ធសោធននិងការផ្តល់មូលនិធិដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធ។

**ក្រុមការងារទី២: យន្តការនៃការធានាឥណទាននិងវិនិយោគ** (Credit Guarantee and Investment Mechanisms)

(**ប្រធាន: ប្រទេសកូរ៉េនិងប្រទេសចិន**)

ដោយត្រូវបានបង្កើតនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៣ នាទីក្រុងតូក្យូ ក្រុមការងារនេះត្រូវបានចាត់តាំងឱ្យបង្កើតនូវយន្តការធានាឥណទានមួយសម្រាប់លិខិតូករណ៍បំណុលដែលមានការធានា។

**ក្រុមការងារទី៣: ប្រតិបត្តការរូបិយប័ណ្ណបរទេសនិងបញ្ហានៃការទូទាត់** (Foreign Exchange Transactions and Settlement Issues)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(**ប្រធាន: ប្រទេសម៉ាឡេស៊ី**)

ក្រុមការងារទី៣នេះបានដាក់សំណើសម្រាប់ការរៀបចំការសិក្សាចំនួនពីរ: (១) ការសិក្សាទៅលើប្រតិបត្តិការនិងការទូទាត់ (២) ការសិក្សាទៅលើឧបសគ្គនានាចំពោះការបង្កើតនូវប្រព័ន្ធជម្រះបញ្ជីនិងការទូទាត់ ជាពិសេស លើបញ្ហានៃការគ្រប់គ្រងរូបិយវត្ថុបរទេស សន្តិសុខ បទបញ្ញត្តិ និងបញ្ហាពន្ធ។ គោលបំណងនៃការសិក្សាទាំងអស់នេះគឺ ដើម្បីបង្កើតឱ្យមានប្រព័ន្ធប្រតិបត្តិការឆ្លងដែនមួយដែលផ្អែកលើថ្លៃដើមទាបបំផុតនិងដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាក្នុងការអនុវត្តប្រតិបត្តិការហិរញ្ញវត្ថុ។

ប្រទេសជាសមាជិក ត្រូវផ្តល់ជាអាទិភាពដល់ការបង្កើតប្រព័ន្ធជម្រះបញ្ជីរបស់ជាតិនិងត្រូវឱ្យផ្នែកឯកជនមានការពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមនេះ។

**ក្រុមការងារទី៤**: **ការចេញលក់មូលប័ត្រចារឹកជារូបិយវត្ថុក្នុងស្រុកដោយធនាគារអភិវឌ្ឍពហុភាគី** (Issuance of Bonds Denominated in Local Currency by Multilateral Development Banks)

(**ប្រធាន: ប្រទេសចិន**)

ចាប់តាំងពីការបង្កើតមក ក្រុមការងារនេះបានស៊ើបអង្កេតលើក្របខ័ណ្ឌនិតិបញ្ញត្តិ ដើម្បីលើកស្ទួយដល់ការចេញលក់នៃមូលប័ត្រនៅកម្រិតតំបន់។ ក្រុមការងារនេះកំពុងធ្វើការងារលើបញ្ហាជាច្រើនប្រភេទ ដោយរួមមានខ្សែកោងនៃទិន្នផល (Yield Curve) ដែលនឹងត្រូវបានប្រើប្រាស់ធ្វើជាគំរូមួយសម្រាប់ការបោះផ្សាយមូលប័ត្រ ការកៀរគរប្រាក់សន្សំជាតិ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការផ្ទេរសមត្ថភាព និងការធ្វើឱ្យប្រសើរឡើងនៃក្របខ័ណ្ឌគតិយុត្តិ។

ដើម្បីដោះស្រាយហានិភ័យនៃលំហូរចេញមូលធន ក្រុមការងារនេះក៏នឹងពិនិត្យមើលផងដែរនូវបញ្ហាផ្សេងៗពាក់ព័ន្ធទៅនឹងអនិយតកម្ម អត្រាការប្រាក់ និយ័តកម្មនៃការវិនិយោគ និងការចេញលក់ ការពង្រឹងប្រព័ន្ធទូទាត់ និងកិច្ចព្រមព្រៀងដោះដូរ ព្រមទាំងការថែរក្សាស្ថេរភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ក្រុមការងារទី៥**: **ប្រព័ន្ធចំណាត់ថ្នាក់និងការផ្សព្វផ្សាយព័ត៌មានស្តីអំពីទីផ្សារមូលប័ត្រ** (Rating Systems and Information Dissemination on Bond Markets)

(**ប្រធាន: ប្រទេសសិង្ហបុរីនិងជប៉ុន**)

ក្រុមការងារនេះបានរៀបចំកិច្ចពិភាក្សាមួយចំនួនជាមួយអាជ្ញាធរនិយ័តកម្ម ទីផ្សារមូលធន និងទីភ្នាក់ងារដាក់ចំណាត់ថ្នាក់ក្នុងតំបន់និងអន្តរជាតិ រួមមានក្រុមហ៊ុន S&P (S&P Company) និងសមាគមន៍ទីភ្នាក់ងារចំណាត់ថ្នាក់នៃការទទួលស្គាល់ក្នុងអាស៊ី (the Association of Credit Rating Agencies in Asia = ACRAA) ។ សេចក្តីបញ្ចប់នៃកិច្ចពិភាក្សាទាំងអស់នេះ ត្រូវបានបោះពុម្ពផ្សាយលើគេហទំព័ររបស់ធនាគារអភិវឌ្ឍអាស៊ី។

**ក្រុមការងារទី៦**: **សហប្រតិបត្តិការជំនួយបច្ចេកទេស** (Technical Assistance Cooperation)

(**ប្រធាន: ប្រទេសឥណ្ឌូនេស៊ីម៉ាឡេស៊ីនិងហ្វីលីពីន**)

ក្រុមការងារទី៦នេះត្រូវបានបង្កើតឡើង ដើម្បីកំណត់អត្តសញ្ញាណនៃជំនួយបច្ចេកទេសសម្រាប់បណ្តាប្រទេសអាស៊ាន+៣ និងជំនួយបច្ចេកទេសពី ADB សម្រាប់រៀបចំឱ្យប្រទេសអាស៊ានជួយដល់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មជ្ឈមណ្ឌល។ ប្រទេសជប៉ុនបានផ្តល់ជំនួយបច្ចេកទេសដល់ប្រទេសកម្ពុជានិងប្រទេសឡាវ។ ប្រទេសវៀតណាមក៏បានទទួលជំនួយបច្ចេកទេសពី ADB និងជប៉ុនផងដែរ។

ក្រុមការងារទាំងអស់បានលើកទឹកចិត្តឱ្យមន្ត្រីនៃបណ្តាប្រទេសអាស៊ានបូកបីប្រើប្រាស់ការលើកទឹកចិត្តខាងពន្ធ (ឧទាហរណ៍:ការលើកលែងពន្ធចំពោះប្រតិបត្តិការហិរញ្ញវត្ថុ) ដើម្បីលើកស្ទួយទីផ្សារមូលប័ត្រសំខាន់និងបន្ទាប់បន្សំ (primary and secondary markets) ។ គោលបំណងរបស់គេគឺដើម្បីលើកស្ទួយនូវលទ្ធភាពសងនៃមូលប័ត្រទាំងអស់នេះនិងធ្វើឱ្យប្រសើរឡើងនូវភាពទាក់ទាញរបស់ពួកគេក្នុងនាមជាលិខិតូបករណ៍ប្រាក់សន្សំហិរញ្ញវត្ថុ។

## ២៤.១៣. កិច្ចប្រជុំកំពូលអាស៊ីបូព៌ា

អាស៊ីបូព៌ារួមមាន ប្រទេសជប៉ុន កូរ៉េខាងត្បូង និង កូរ៉េខាងជើង ចិន និង ប្រទេសទាំង ១០ របស់អាស៊ាន។ វាមានចំនួនប្រជាជនស្មើនឹងជិតមួយភាគបីនៃប្រជាជនពិភពលោក និងមានផលិតផលក្នុងស្រុកសរុបស្មើនឹងមួយភាគបួននៃផលិតផលក្នុងស្រុករបស់ពិភពលោក។

តាំងពីយូរយារណាស់មកហើយ អាស៊ីបូព៌ាត្រូវបានគេចាត់ទុកថាជាតំបន់មួយដែលមានប្រទេសវប្បធម៌ និង តម្លៃផ្សេងៗគ្នា។ មានកត្តាពីរដែលធានាដល់ការងើបឡើងវិញនៃសេដ្ឋកិច្ច និង ការពឹងពាក់គ្នាទៅវិញទៅមកនៃអាស៊ីបូព៌ា៖ (១) សម្ព័ន្ធមិត្តផ្នែកសន្តិសុខរវាងប្រទេសជប៉ុននិងសហរដ្ឋអាមេរិកដែលកសាងមូលដ្ឋានគ្រឹះសម្រាប់ស្ថេរភាពនយោបាយក្នុងតំបន់និង (២) ការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការដោយប្រទេសជប៉ុនទៅកាន់ប្រទេសនានាក្នុងតំបន់។

ប្រទេសជប៉ុនបានក្លាយទៅជាអ្នកសម្របសម្រួល ក្នុងការធ្វើឱ្យអាស៊ីខាងកើតក្លាយទៅជាតំបន់ដែលមានថាមពលខ្លាំងក្លាខាងសេដ្ឋកិច្ចនៅក្នុងតំបន់។ ការផ្ទេរផ្នែកឧស្សាហាកម្ម និងបច្ចេកវិទ្យាពីប្រទេសជប៉ុនដល់បណ្តាលប្រទេសឧស្សាហាកម្មថ្មីៗរបស់អាស៊ី (ប្រទេសកូរ៉េខាងត្បូង ហុងកុង និង តៃវ៉ាន់) ក្នុងទសវត្សរ៍ឆ្នាំ៨០ ហើយបន្តទៅដល់អាស៊ានក្នុងទសវត្សរ៍ឆ្នាំ៩០ និងបន្តដោយប្រទេសចិននាពេលបច្ចុប្បន្ននេះមានមូលដ្ឋានទៅលើការបែងចែកកម្លាំងពលកម្មជាអន្តរជាតិ ដែលជំរុញដោយទ្រឹស្តីបទ "ក្ងានព្រៃហោះ" ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ប្រទេសជប៉ុនមានឯកទេសក្នុងការនាំចេញផលិតផលកម្មន្តសាល ដែលមានកម្រិតបច្ចេកវិទ្យាខ្ពស់ រីឯប្រទេសដទៃទៀតរបស់អាស៊ីកំពុងយកចិត្តទុកដាក់លើផលិតផលអន្តរការី និងកម្មន្តសាល ដែលពាក់ព័ន្ធនឹងថ្លៃដើមពលកម្មទាប។

បច្ចុប្បន្ននេះ អាស៊ីខាងកើតកំពុងឆ្លងកាត់ការប្រែប្រួលដែលមិនអាចត្រឡប់ក្រោយបាន និង ការពង្រីកសេដ្ឋកិច្ចជាថាមវន្ត។ ជំនួយផ្លូវការដើម្បីអភិវឌ្ឍ និងការវិនិយោគរបស់ជប៉ុនបានកែប្រែមុខមាត់ និងធ្វើទំនើបភាវូបនីយកម្មសេដ្ឋកិច្ចនៃអាស៊ីអាគ្នេយ៍។ ជប៉ុនក៏បានចែករំលែកជាមួយប្រទេសទាំងអស់នៅក្នុងតំបន់នូវគំរូនៃការអភិវឌ្ឍរបស់ខ្លួន ដោយផ្អែកលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ធនធានមនុស្ស។

ទស្សនៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ត្រូវបានលើកឡើងជាលើកដំបូងដោយបណ្តាមេដឹកនាំរបស់អាស៊ាន+៣ នៅឯកិច្ចប្រជុំកំពូលប្រទេសសិង្ហបុរី។ នៅឆ្នាំ២០០១ ក្រុមទស្សនវិស័យអាស៊ីបូព៌ា (the East Asia Vision Group) បានផ្តល់អនុសាសន៍ដល់បណ្តាមេដឹកនាំរបស់អាស៊ាន+៣ ថាកិច្ចប្រជុំកំពូលអាស៊ានបូកបីគួរគប្បីកែប្រែឱ្យទៅជាកិច្ចប្រជុំកំពូលអាស៊ីបូព៌ា។ អនុសាសន៍នេះត្រូវបានទទួលយកថាជាវិធានការដែលមានអាទិភាពខ្ពស់និងយូរអង្វែង។

ហេតុដូច្នេះហើយ នៅឯកិច្ចប្រជុំកំពូលអាស៊ាន+៣ កាលពីខែវិច្ឆិកាឆ្នាំ ២០០៤ ក្នុងទីក្រុងវៀងច័ន្ទ មេដឹកនាំទាំងអស់បានឯកភាពថា កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី១ និងត្រូវប្រារព្ធឡើងក្នុងទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ីក្នុងខែធ្នូ ឆ្នាំ២០០៥ ហើយនឹងត្រូវរួមបញ្ចូលបណ្តាប្រទេសរបស់អាស៊ាន អូស្ត្រាលី ប្រទេសចិន កូរ៉េខាងត្បូង ជប៉ុន ណូវែលហ្សេឡង់ និងប្រទេសរុស្ស៊ី។

ប្រទេសជាសមាជិករបស់អាស៊ានគប្បីឆ្លើយតបនឹងលក្ខណវិនិច្ឆ័យដូចខាងក្រោម ដើម្បីចូលទៅក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា៖ (១) ធ្វើជាដៃគូពិភាក្សាពេញសិទ្ធិមួយរបស់អាស៊ាន (២) បានចូលរួម ឬ មានបំណងចូលរួមនៅក្នុងសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការ (TAC) និង (៣) មានទំនាក់ទំនងជានិរន្តរជាមួយអាស៊ាន។ អាស៊ានដើរតួនាទីដ៏សំខាន់នៅក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ដោយធ្វើជាគណៈអធិបតីរបស់កិច្ចប្រជុំនោះ។ កិច្ចប្រជុំកំពូលអាស៊ីបូព៌ានឹងក្លាយជាវេទិកាមួយ សម្រាប់ការពិភាក្សាលើបញ្ហាជាយុទ្ធ-សាស្ត្រនយោបាយ និងសេដ្ឋកិច្ច ដែលជាអត្ថប្រយោជន៍ទៅវិញទៅមក ជាមួយនឹងគោលបំណងចុងក្រោយ គឺការលើកស្ទួយសន្តិភាព ស្ថេរភាព និងសហប្រតិបត្តិការសេដ្ឋកិច្ចនៅអាស៊ីបូព៌ា។ កិច្ចខិតខំទាំងឡាយនៃកិច្ចប្រជុំកំពូល ដើម្បីលើកស្ទួយសហគមន៍អាស៊ីបូព៌ាត្រូវស្របគ្នាទៅនឹងការអនុវត្តនៃសហគមន៍អាស៊ាន ហើយត្រូវតែជាផ្នែកមួយនៃស្ថាបត្យកម្មក្នុងតំបន់។ រហូតទាល់តែទស្សនទាននេះត្រូវបានគេទទួលស្គាល់ កិច្ចប្រជុំកំពូលអាស៊ាន+៣ត្រូវតែប្រារព្ធឡើង ដើម្បីពិភាក្សាជាក់ស្តែងលើបញ្ហាពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការដែលនឹងនាំមកនូវលទ្ធផលល្អ។

មេដឹកនាំទាំងអស់បានផ្តល់ការយកចិត្តទុកដាក់យ៉ាងពិសេស ចំពោះសហប្រតិបត្តិការជាមួយអាស៊ីបូព៌ានៅក្នុងវិស័យចំនួន១៧៖ ការប្រឆាំងភេរវកម្ម សន្តិសុខផ្លូវទឹក អភិបាលកិច្ចល្អ និងការប្រឆាំងអំពើពុករលួយ ស្ថេរភាពហិរញ្ញវត្ថុ និងការលើកទឹកចិត្តផ្នែកពន្ធ ដើម្បីទាក់ទាញវិនិយោគ សន្តិសុខថាមពល លំហូរចូលនៃពាណិជ្ជកម្ម និងការវិនិយោគតំបន់ពាណិជ្ជកម្មសេរីសម្រាប់អាស៊ីទាំងមូល (pan-Asian) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការផ្ទេរបច្ចេកវិទ្យា ការកាត់បន្ថយភាពក្រីក្រ ការបង្រួមគម្លាតនៃការអភិវឌ្ឍ និងការកសាងសមត្ថភាព ការការពារបរិស្ថាន ការគ្រប់គ្រងគ្រោះថ្នាក់ធម្មជាតិ ជំងឺឆ្លង ការដោះដូរ និងការពិភាក្សាលើបញ្ហាវប្បធម៌ ទំនាក់ទំនងក្នុងបណ្តាប្រជាជន និងការលើកស្ទួយសហប្រតិបត្តិការជាមួយវេទិកាតំបន់និងអន្តរជាតិ។

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា សមាហរណកម្មដ៏ជោគជ័យរបស់កម្ពុជាជាមួយតំបន់និងពិភពលោកនឹងជួយបង្កើតបរិយាកាសសមស្របមួយ សម្រាប់កំណើនប្រកបដោយចីរភាព។ ក្នុងការជំរុញឱ្យមានសមាហរណកម្មស៊ីជម្រៅរបស់កម្ពុជា ចូលទៅក្នុងតំបន់ គឺអាទិភាពកំពូល ដែលផ្តោតលើការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងប្រទេសជាសមាជិករបស់អាស៊ាន។ ដើម្បីពន្លឿនដំណើរការនេះ កម្ពុជានឹងពង្រឹងសមត្ថភាពស្ថាប័នរបស់ខ្លួន ដើម្បីអនុវត្តគំនិតផ្តួចផ្តើមរួមគ្នាជាមួយប្រទេសជិតខាងរបស់ខ្លួន ដូចជា គំនិតផ្តួចផ្តើម "ប្រទេសបួន-សេដ្ឋកិច្ចមួយ" ការអភិវឌ្ឍន៍នៃយុទ្ធសាស្ត្រត្រីកោណកំណើនសេដ្ឋកិច្ច និងការបង្កើតតំបន់ពាណិជ្ជកម្មសេរីឆ្លងដែន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី៩
# សេចក្តសន្និដ្ឋាន

## ជំពូកទី២៥.ការពន្លឿនការអភវឌ្ឍស្ថាប័ន ឥជាកូនសោរឆ្ពោះទៅវឌ្ឍនភាព



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី២៥
# ការពន្លឿនការអភិវឌ្ឍស្ថាប័ន-កូនសោរឆ្ពោះទៅវឌ្ឍនភាព

## ២៥.១. ក្របខ័ណ្ឌនៃការអភិវឌ្ឍទូទៅ

នៅក្នុងអំឡុងពេលនីតិកាលទីពីររបស់រាជរដ្ឋាភិបាល ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្ត **យុទ្ធសាស្ត្រត្រីកោណ** ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការសម្រេចឱ្យបានសន្តិភាព ស្ថេរភាព និងធ្វើប្រក្រតីកម្មទំនាក់ទំនងជាមួយនឹងប្រទេសដទៃទៀតនៅជុំវិញពិភពលោក និងកៀរគរធនធាន ដើម្បីពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចនិងប្រយុទ្ធនឹងភាពក្រីក្រ។ យុទ្ធសាស្ត្រនេះ គឺនាំមកនូវភាពជោគជ័យ នៅក្នុងការបង្កើតឱ្យមានបរិយាកាសអំណោយផលដល់ភាពជឿនលឿន នាំកម្ពុជាឱ្យស្ថិតនៅផ្លូវនៃការធ្វើកំណែទម្រង់ និង ការអភិវឌ្ឍប្រកបដោយចីរភាព។ កម្ពុជាបានប្រែក្លាយខ្លួន ពីប្រទេសអន់ថយប្រឈមនឹងអនាគតមិនច្បាស់លាស់ ខ្ទេចខ្ទាំដោយសង្គ្រាម ជម្លោះ និងអស្ថិរភាព ទៅជាតំបន់មួយដែលមានស្ថេរភាពសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។

តែទោះបីជាយ៉ាងណាក៏ដោយ ភាពក្រីក្រនិងអតុល្យភាពក្នុងការបែងចែកចំណូលបានក្លាយជាបញ្ហាប្រឈមដ៏ចម្បងរបស់កម្ពុជា។ ដើម្បីដោះស្រាយឱ្យបានលឿននូវបញ្ហាក្រីក្រនេះ និង សម្រេចឱ្យបាន **គោលដៅអភិវឌ្ឍន៍សហស្សវត្ស** (MDGs) រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យប្រើប្រាស់ កាលពីខែមីនា ឆ្នាំ ២០០៣ នូវយុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រ ជាមួយនឹងគោលដៅដូចខាងក្រោម៖

- ពង្រឹងសន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម តាមរយៈការអនុវត្តនូវវិធានការច្បាស់លាស់ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនីតិរដ្ឋ និង លើកតម្កើងការគោរពសិទ្ធិមនុស្ស និង ប្រជាធិបតេយ្យ និងបង្កើតក្របខ័ណ្ឌសន្តិសុខ និង នយោបាយល្អប្រសើរ ដើម្បីបន្តការអភិវឌ្ឍន៍។
- ធានាឱ្យបានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព ៦-៧% ជាមធ្យមក្នុងមួយឆ្នាំ។
- ធានាឱ្យបាននូវការបែងចែកស្មើភាពនៃផលដែលបានមកពីកំណើនសេដ្ឋកិច្ច រវាងអ្នកមាននិងអ្នកក្រ ទីក្រុងនិងជនបទ ស្ត្រីនិងបុរស។
- លើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថានប្រកបដោយចីរភាព។

*របៀបវារៈ*របស់រាជរដ្ឋាភិបាលកម្ពុជា គឺ មិនមែនត្រឹមតែការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រទេ។ ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល គឺ ការពង្រឹងកោសិកាសង្គមឱ្យមានភាពសុខដុមរមនា ដោយមានប្រព័ន្ធអប់រំទំនើប និង សម្បត្តិវប្បធម៌សម្បូរបែប។ ការប្រែក្លាយ **ចក្ខុវិស័យ** ឱ្យទៅជាការពិតជាក់ស្តែង វាទាមទារការគោរពយ៉ាងខ្ជាប់ខ្ជួន នូវតម្លៃនៃយុត្តិធម៌សង្គម ផលប្រយោជន៍របស់ប្រជាជន និងការអភិវឌ្ឍដើម្បីប្រជាជន ការបង្កើតការងារធ្វើ និងការអនុវត្តគោលនយោបាយស៊ីជម្រៅដើម្បីកាត់បន្ថយភាពក្រីក្រ ក្នុងគោលដៅធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និង មានអភិបាលកិច្ចល្អ។

ដើម្បីសម្រេចឱ្យបាននូវ **ចក្ខុវិស័យ** នេះ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន** បានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីខែកក្កដា ឆ្នាំ ២០០៤ នូវ "**យុទ្ធសាស្ត្រចតុកោណ** សម្រាប់ **កំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព**" ដែលជាកម្មវិធីនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលនីតិកាលទីបីនៃរដ្ឋសភាជាតិ។ យុទ្ធសាស្ត្រនេះ គ្របដណ្តប់លើធាតុផ្សំសំខាន់ៗនៃ **គោលដៅអភិវឌ្ឍន៍សហស្សវត្ស** (MDG) **ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម** ឆ្នាំ ២០០១-២០០៥ (SEDP2) និង **កម្មវិធីកាត់បន្ថយភាពក្រីក្រជាតិ** ឆ្នាំ ២០០៣-២០០៥ (NPRP) និងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីកំណែទម្រង់ដទៃទៀត។ គោលដៅនៃចក្ខុវិស័យនេះ គឺជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ការបង្កើតការងារសម្រាប់កម្លាំងពលករកម្ពុជា ការធានាឱ្យមានសមធម៌ និង យុត្តិធម៌សង្គម និង ធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាពនៃវិស័យសាធារណៈ តាមរយៈការអនុវត្ត **ផែនការសកម្មភាពអភិបាលកិច្ច** ដើម្បីឱ្យមានកំណែទម្រង់ស៊ីជម្រៅ ស៊ីចង្វាក់ និងប្រទាក់ក្រឡាគ្នា នៅគ្រប់កម្រិត និង នៅក្នុងគ្រប់វិស័យ។

**យុទ្ធសាស្ត្រចតុកោណ** គឺជារចនាសម្ព័ន្ធរាងជាបុប្ផារីកក្រពុំ ដែលមានចតុកោណបួនប្រទាក់ក្រឡាគ្នាយ៉ាងចាក់ស្រេះ ដូចដែលឃើញនៅក្នុងរូបភាព ២៥.១។

*រូបភាព២៥.១. យុទ្ធសាស្ត្រចតុកោណ*




លទ្ធផលវិជ្ជមាន ដែលទទួលបាននៅក្នុងការអនុវត្ត យុទ្ធសាស្ត្រចតុកោណ បានពង្រឹងជំនឿទុកចិត្តជាទូទៅនៅក្នុងអនាគតមួយដ៏ត្រចះត្រចង់សម្រាប់កម្ពុជា។ មូលដ្ឋានគ្រឹះត្រូវបានគេរៀបចំឡើង ដើម្បីអភិវឌ្ឍវិស័យឯកជន ពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍ ជាកត្តាទាំងអស់ ដែលបង្កើតឱ្យមានការងារនិងប្រាក់ចំណូលសម្រាប់ប្រជាជនកម្ពុជា។ យើងសម្រេចបានវឌ្ឍនភាព នៅក្នុងកំណែទម្រង់កសិកម្ម និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គមនិងរូបវន្ត។ ជាមួយនឹងការទទួលស្គាល់សមិទ្ធផល ក្នុងការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តរក្សាទុក **របៀបវារៈនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម** នេះ ដោយគ្រាន់តែផ្លាស់ប្តូរបន្តិចបន្តួចនៅក្នុងនីតិកាលទីបួនរបស់រដ្ឋាភិបាល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទោះបីជាយ៉ាងណាក៏ដោយ យើងទាំងអស់គ្នានៅមានកិច្ចការ ដែលត្រូវធ្វើច្រើនទៀត ក្នុងការប្រយុទ្ធដើម្បីធានានូវភាពជោគជ័យសម្រាប់អនាគតរបស់កម្ពុជា។ កម្ពុជាសម្រេចបាននវឌ្ឍនភាព ក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ លើសពីគោលដៅដែលបានដាក់ចេញ នៅក្នុងអំឡុងឆ្នាំ ១៩៩៨-២០០៨។ ប៉ុន្តែ កម្ពុជានៅមានបញ្ហាប្រឈមជាច្រើន។ រាជរដ្ឋាភិបាលកម្ពុជាបានដឹងច្បាស់ណាស់ថានៅមានឧបសគ្គជាច្រើនដែលត្រូវជម្នះ មុននឹងសម្រេចបានភាពជឿនលឿនមួយប្រកបដោយចីរភាព និងធានាឱ្យបានភាពរុងរឿងយូរអង្វែងសម្រាប់ប្រទេសនិងប្រជាជនកម្ពុជា។ គុណភាពស្ថាប័នមានទួនាទីសំខាន់ណាស់ ក្នុងការធានាការអភិវឌ្ឍមួយប្រកបដោយចីរភាព និងសម្រេចបាននូវជោគជ័យមួយឱ្យបានឆាប់រហ័សនៅក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។ ហេតុដូច្នេះហើយ រដ្ឋាភិបាលនឹងយកចិត្តទុកដាក់ជាពិសេស ដើម្បីពន្លឿនកំណែទម្រង់ស្ថាប័ន នៅក្នុងវិស័យដូចខាងក្រោមនេះ៖ (១)កំណែទម្រង់រដ្ឋបាលសាធារណៈ (២) វិមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន (៣) កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

## ២៥.២. កំណែទម្រង់រដ្ឋបាលសាធារណៈ

កំណែទម្រង់រដ្ឋបាលសាធារណៈមានគោលបំណងទូលំទូលាយ៖ "បង្កើតមន្ត្រីរាជការក្នុងចំនួនសមស្របដែលមានជំនាញការលើកទឹកចិត្តគុណធម៌និងគណនេយ្យភាពការងារដើម្បីផ្តល់សេវាសាធារណៈដែលមានគុណភាព និងបំពេញភារកិច្ចដែលរដ្ឋបានកំណត់"។ បទពិសោធន៍នៃការអភិវឌ្ឍក្នុងពិភពលោកបានបង្ហាញឱ្យឃើញថា នូវទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធរវាងសមត្ថភាពរបស់មន្ត្រីរាជការ និងកម្រិតនៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ។ ប្រទេសខ្លះនៅអាស៊ីអាគ្នេយ៍ដូចជា សិង្ហបូរី និង ម៉ាឡេស៊ី ដែលមានមន្ត្រីប្រកបដោយប្រសិទ្ធភាព និងការលើកទឹកចិត្តខ្ពស់ ជាមួយនឹងកម្រិតវិជ្ជាជីវៈដ៏ខ្ពស់។ លើសពីនេះទៅទៀត រដ្ឋបាលសាធារណៈត្រូវតែបំពេញការងារសាធារណៈឱ្យបានល្អប្រសើរ ផ្តល់សេវាសាធារណៈរៀបចំ និងអនុវត្តគោលនយោបាយសេដ្ឋកិច្ចល្អប្រសើរនិងគ្រប់គ្រងចំណាយសាធារណៈឱ្យមានប្រសិទ្ធភាព។

ការពង្រឹងសមត្ថភាពនៅក្នុងវិស័យសាធារណៈ ដើម្បីធ្វើកែលម្អប្រសិទ្ធភាពសេវាសាធារណៈអាចសម្រេចទៅបាន តាមរយៈកំណែទម្រង់រចនាសម្ព័ន្ធ ការគ្រប់គ្រងរដ្ឋបាល និងយុទ្ធសាស្ត្រ។ អភិបាលកិច្ចល្អអាចធ្វើឱ្យរកឃើញនូវកត្តាមួយចំនួន ដែលមានសារៈសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍប្រកបដោយចីរភាព។ ប្រការនេះជួយកាត់បន្ថយចំណាយសេវាកម្ម និងធានាបាននូវការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល និងការអនុវត្តច្បាប់ ឱ្យមានប្រសិទ្ធភាពខ្ពស់។ អភិបាលកិច្ចដើរតួនាទីយ៉ាងសំខាន់ ក្នុងការប្រឡងជ្រើសរើសមន្ត្រីរាជការ ដែលមានសមត្ថភាពខ្ពស់ ដោយផ្តល់ឱកាសស្មើៗគ្នាសម្រាប់បេក្ខជនគ្រប់រូប។ ដោយសារហេតុផលទាំងអស់នេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកអភិបាលកិច្ចល្អ ជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ។

ប្រសិទ្ធភាពស្ថាប័នកាត់បន្ថយភាពមិនច្បាស់លាស់ និងការចំណាយសម្រាប់ធុរៈកិច្ច លើកទឹកចិត្តឱ្យមានលំហូរចូលមូលធននិងបច្ចេកវិទ្យា ដែលកត្តានេះនឹងជំរុញឱ្យមានកំណើនសេដ្ឋកិច្ច។ កម្ពុជាបានចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ ដើម្បីរៀបចំឡើងវិញរចនាសម្ព័ន្ធ និងចំនួនមន្ត្រីរាជការ ក្នុងគោលដៅកែលម្អគុណភាពសេវាសាធារណៈ។ ការកសាងសមត្ថភាព និងការពង្រឹងជំនាញបច្ចេកទេសនៅក្នុងរដ្ឋបាលសាធារណៈ មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានាបាននូវជោគជ័យក្នុងកិច្ចការកំណែទម្រង់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កម្ពុជាបានដាក់ចេញគំនិតផ្តួចផ្តើម ដើម្បីបង្កើនការប្រើប្រាស់បច្ចេកទេសអេឡិចត្រូនិក នៅក្នុងរដ្ឋបាលសាធារណៈ។ រដ្ឋាភិបាលអេឡិចត្រូនិកជួយបង្កើតប្រព័ន្ធរដ្ឋបាលប្រកបដោយប្រសិទ្ធភាព ហើយអាចឆ្លើយតប និង អាចបត់បែនបានទៅតាមការផ្លាស់ប្តូរដ៏ឆាប់រហ័ស នៅក្នុងបរិយាកាសតំបន់និងពិភពលោក ក៏ដូចជាទៅតាមតម្រូវការរបស់វិស័យឯកជន ដែលកំពុងតែមានការកើនឡើងយ៉ាងខ្លាំង។

ដើម្បីកំណត់ឱ្យបាននូវចំនួនចាំបាច់សមស្របរបស់មន្ត្រីរាជការ ប្រទេសនីមួយៗត្រូវពិចារណាទៅតាមភាពជាក់ស្តែងរបស់ខ្លួន ត្រូវគិតទៅលើកត្តាប្រវត្តិសាស្ត្រ និងតថភាពនៅតាមមូលដ្ឋាន ភារកិច្ចការងារដែលរដ្ឋបានកំណត់ កម្រិតនៃមជ្ឈការ គុណភាពវិជ្ជាជីវៈរបស់មន្ត្រីរាជការ និងធនធានថវិកាដែលមាន។ ទោះបីជានៅក្នុងអង្គភាពមួយដែលមានបុគ្គលិកច្រើន យើងមិនអាចចាប់ផ្តើមកំណែទម្រង់តាមរយៈការកាត់បន្ថយបុគ្គលិកបានទេ។ ទោះបីជាការកាត់បន្ថយបុគ្គលិកអាចផ្តល់ជាមធ្យោបាយបង្កើនការលើកទឹកចិត្តក៏ដោយ តែវាអាចនឹងនាំឱ្យមានបន្ទុកហិរញ្ញវត្ថុរយៈពេលខ្លី ហើយធ្ងន់ធ្ងរ នៅក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភឱ្យមន្ត្រីដែលកាត់ចោល ហើយវានឹងនាំឱ្យមានការខាតបង់ខាងនយោបាយខ្លះសម្រាប់កម្ពុជា ដែលទើបតែមានសន្តិភាពនៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅនេះ។

ទោះបីជាយ៉ាងណាក៏ដោយ គោលនយោបាយបៀវត្សនិងប្រាក់ឈ្នួល ត្រូវតែជាចំណុចស្នូលនៃកំណែទម្រង់មុខងារសាធារណៈ។ មន្ត្រីរាជការដែលទទួលប្រាក់បៀវត្សទាបពិបាកក្នុងការទប់ចិត្តមិនធ្វើអំពើមួយចំនួន ក្រោមទម្ងន់នៃការគាបសង្កត់ដោយសារវិស័យឯកជនដែលឥទ្ធិពលក្រុម ហើយមិនអាចបំពេញភារកិច្ចរបស់ខ្លួនឱ្យបានសមស្របឡើយ។ ប្រការនេះមិនត្រឹមតែធ្វើឱ្យខូចខាតដល់ការងារសាធារណៈ និងការផ្តល់សេវាសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែវាកាន់តែធ្វើឱ្យប៉ះពាល់ដល់វិស័យឯកជន និង នាំឱ្យចំណាយប្រតិបត្តិការគ្រប់ផ្នែកទាំងអស់នៅក្នុងសេដ្ឋកិច្ចមានការកើនឡើង។

យើងគួរពិចារណាដាក់ឱ្យអនុវត្តនូវទស្សនាទានស្តីអំពី ការផ្សារភ្ជាប់ប្រាក់បៀវត្សរបស់មន្ត្រីរាជការជាមួយនឹងលទ្ធផលការងារ។ ប៉ុន្តែ យើងក៏ត្រូវមានការប្រយ័ត្នប្រយែងជាពិសេស ទាំងចំពោះប្រសិទ្ធភាពទាំងចំពោះហានិភ័យ។ ការផ្តល់ការលើកទឹកចិត្តដោយមិនប្រើប្រាក់កាស គឺជាវិធានការមានប្រសិទ្ធភាពផងដែរ ដូចជាការប្រគល់ការងារដែលមន្ត្រីចាប់អារម្មណ៍ ការតម្លើងឱ្យមានតួនាទីខ្ពស់ ការទទួលស្គាល់ស្នាដៃការងារ និងការលើកទឹកចិត្តតាមវិជ្ជាជីវៈជាដើម។ ប៉ុន្តែ ប្រព័ន្ធប្រាក់បៀវត្សរ៍ដែលឈរលើមូលដ្ឋាននៃសមិទ្ធផលការងារ ត្រូវមានការវាយតម្លៃឱ្យបានត្រឹមត្រូវ ចំពោះលទ្ធផលដែលសម្រេចបាន។

កំណែទម្រង់រដ្ឋបាលសាធារណៈត្រូវមានប្រព័ន្ធវិភាគមុខងារ និងវាយតម្លៃការងាររបស់មន្ត្រីរាជការដោយមានរចនាសម្ព័ន្ធបែងចែកភារកិច្ចច្បាស់លាស់ និងវិធីសាស្ត្រក្នុងគោលបំណងតម្លើងកាំបៀវត្សរ៍ (ជាពិសេស ដើម្បីទាក់ទាញឧត្តមមន្ត្រីដែលមានសមត្ថភាពខ្ពស់ប្រកួតប្រជែងគ្នា) ដោយឱ្យតម្លៃជាសំខាន់ទៅលើស្នាដៃ ការផ្លាស់ប្តូរការងារក្នុងអង្គភាព ពង្រឹងការគ្រប់គ្រងបុគ្គលិក ផ្តល់ការអភិវឌ្ឍជំនាញ និងបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះសាធារណៈ។

ប្រព័ន្ធរដ្ឋបាលសាធារណៈ ដែលពឹងផ្អែកលើសមត្ថភាព ទទួលស្គាល់គោលការណ៍នៃការតែងតាំងដោយឈរលើស្នាដៃរបស់បុគ្គលនីមួយៗ (គុណវុឌ្ឍិ ជំនាញ សុចរិតភាពជាដើម) ដើម្បីធានាឱកាសស្មើគ្នា និងផ្តល់តម្លៃសារៈសំខាន់ដល់ការផ្តួចផ្តើមគំនិតរបស់បុគ្គលនីមួយៗ ក្នុងក្របខ័ណ្ឌនៃច្បាប់។ ដំណើរការប្រកួត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រជែង គឺជានីតិវិធីដែលធានាដល់ការផ្តល់តួនាទីដែលមានកិត្យានុភាពក្នុងសង្គម ទៅតាមឋានានុក្រម ដោយឈរលើស្នាដៃរបស់បេក្ខជន។ គោលការណ៍សំខាន់របស់ **គុណវុឌ្ឍិនិយម** (ដោយពឹងផ្អែកលើសមត្ថភាព) គឺថាបុគ្គលនីមួយៗត្រូវបានវាយតម្លៃចំពោះអ្វីដែលគេបានធ្វើ មិនមែនវាយតម្លៃដោយឈរលើតើគេជានរណានោះទេ។ ច្បាប់នេះប្រើជាបឋម និង ចាំបាច់បំផុតសម្រាប់ជានីតិវិធី ដែលនាំឈានទៅរកតួនាទីដែលមនុស្សគ្រប់គ្នាចង់បាន។ នៅក្នុងប្រព័ន្ធដែលជ្រើសរើសនេះ គឺមានតែបុគ្គលដែលមានសមត្ថភាពទេទើបត្រូវបានគេទទួលយក។ ដូច្នេះ វាបានឆ្លើយតបយ៉ាងពិតប្រាកដ និង ជាអតិបរមា ដែលថាបុគ្គលម្នាក់ៗនឹងត្រូវបានគេវាយតម្លៃ តាមរយៈស្នាដៃរបស់គេ ដោយមិនគិតទៅលើថាគេនោះជានរណាទេ។ ប៉ុន្តែការអនុវត្តនេះអាចនាំឱ្យមានការបែងចែកក្នុងសង្គមជាពីរធំៗ អ្នកឆ្នើមនៅខាងលើ និង អ្នកអន់នៅខាងក្រោម។

នៅក្នុងការវិភាគរដ្ឋបាលសាធារណៈ យើងបានអនុវត្តនូវគំនិតផ្តួចផ្តើមជាច្រើន រួមមានការធ្វើជំរឿនមន្ត្រីរាជការស៊ីវិល ការវិភាគមុខងារតាមក្រសួង ការធ្វើការស្ទង់មតិ និងការរៀបចំចងក្រងច្បាប់និងបទបញ្ញត្តិ។ ការធ្វើជំរឿនមិនត្រឹមតែឈានទៅរកឱ្យឃើញមន្ត្រីរាជការខ្មោច និងការទូទាត់ប្រាក់បៀវត្សមិនប្រក្រតីនោះទេ ប៉ុន្តែថែមទាំងជួយរៀបចំវិធីសាស្ត្រ ដើម្បីបង្កើតប្រព័ន្ធទិន្នន័យធនធានមនុស្ស ហើយធ្វើ ឱ្យប្រសើរឡើងការគ្រប់គ្រងបុគ្គលិក ហើយគ្រប់វិធានការចាំបាច់ទាំងអស់ ដើម្បីជៀសវាងការកើតឡើងជាថ្មីនៃភាពមិនប្រក្រតី។

បទពិសោធន៍បង្ហាញឱ្យឃើញថា ទោះបីក្នុងកម្រិតប្រាក់បៀវត្សទាបក៏ដោយ មន្ត្រីក្មេងៗ ដែលទទួលបានការបណ្តុះបណ្តាលបានល្អប្រសើរអាចមានការលើកទឹកចិត្តមកធ្វើការឱ្យរដ្ឋាភិបាល ប្រសិនបើពួកគេមានការចាប់អារម្មណ៍លើការទទួលខុសត្រូវ និងការបណ្តុះបណ្តាលដែលគេនឹងទទួលបាន។ **កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល** (NPAR) ដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅដើមឆ្នាំ ១៩៩៩ គឺពឹងផ្អែកលើវិធីសាស្ត្រនេះ។ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (CAR) បានទទួលភារកិច្ច ដើម្បីពន្លឿនកំណែទម្រង់សេវាសាធារណៈ និង ពង្រឹងការគ្រប់គ្រងសេវាសាធារណៈតាមរយៈ៖

- ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ
- ការកំណត់ឱ្យបានច្បាស់នូវមុខងារ និង សេវាសាធារណៈ
- ការវាយតម្លៃលើសមិទ្ធផលការងារ
- ការបង្កើនប្រាក់បៀវត្សរ៍ដើម្បីលើកកម្ពស់សមិទ្ធផលការងារ
- ការរៀបចំនីតិវិធី ក្នុងការជ្រើសរើសមន្ត្រីរាជការ ដើម្បីផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព និង
- លើកកម្ពស់ការគ្រប់គ្រងមន្ត្រីរាជការសាធារណៈ។

នៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាល រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងអនុវត្តសកម្មភាពប្រាំជាសំខាន់៖ រៀបចំឯកសារ និង កំណត់សមាសភាព និង ការបែងចែកមន្ត្រីរាជការ ការរៀបចំឧបករណ៍ដើម្បីលើកទឹកចិត្តមន្ត្រីរាជការ ការវាយតម្លៃតម្រូវការសេវាសាធារណៈនៅថ្នាក់កណ្តាលរបស់ក្រសួង (រដ្ឋបាល) ការបំពេញមុខងារជាបឋមដើម្បីធ្វើកែលម្អសេវាសាធារណៈជូនដល់ប្រជាជនឱ្យបានទូលំទូលាយ និង ការកសាងសមត្ថភាពសម្រាប់កំណែទម្រង់ ផែនការ និងការគ្រប់គ្រង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខាងក្រោមនេះ គឺជាសមិទ្ធផល ដែលសម្រេចបាននៅក្នុងក្របខ័ណ្ឌកម្មវិធីជាតិ សម្រាប់កំណែទម្រង់រដ្ឋបាល (NPAR )៖

- ទិន្នន័យស្តីពីសមាសភាព និង សេវាសាធារណៈ ដែលបានប្រមូលនិងវិភាគ។ ជាលទ្ធផល ឥឡូវនេះ រាជរដ្ឋាភិបាលមានទិន្នន័យច្បាស់លាស់ ទាក់ទងនឹងសមាសភាព និងបុគ្គលិកលក្ខណរបស់មន្ត្រីរាជការ នៅថ្នាក់ជាតិ និង នៅថ្នាក់ក្រោមជាតិ។
- មានក្របខ័ណ្ឌគតិយុត្តិ និង ប្រព័ន្ធគ្រប់គ្រងសេវាសាធារណៈ។
- ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សរួមមានប្រព័ន្ធគ្រប់គ្រងធនធានមនុស្សដោយព័ត៌មានវិទ្យា (HRMIS) គឺ ដែលត្រូវបានរៀបចំឡើង ដើម្បីការធ្វើផែនការ និងការគ្រប់គ្រងមន្ត្រីរាជការ។
- ប្រព័ន្ធថ្មីសម្រាប់ការជ្រើសរើស និង ប្រព័ន្ធប្រាក់បៀវត្ស ដែលមានលក្ខណល្អប្រសើរខ្ពស់ សម្រាប់ការវាយតម្លៃសកម្មភាពការងារ និងការតម្លើងតួនាទី ត្រូវបានគេរៀបចំឡើង ហើយឥឡូវនេះដាក់ឱ្យប្រើប្រាស់។
- គោលនយោបាយនវានុវត្តត្រូវបានគេរៀបចំឡើង ដើម្បីប្រមែប្រមូលធនធានដែលមាននិងបង្កើនសកម្មភាពការងារនៅក្នុងវិស័យដែលមានអាទិភាព រួមមានកន្សោមអាទិភាព (PMGs) ការផ្តល់លាភការតាមលទ្ធផលការងារ និងការិយាល័យច្រកចេញចូលសេវាកម្មតែមួយ សម្រាប់មន្ត្រីនៅថ្នាក់ក្រោមជាតិ។

ទាក់ទងនឹងគោលនយោបាយប្រាក់បៀវត្សសេវាសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាផ្តោតការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រពីរ។ ទីមួយ ការផ្លាស់ប្តូរណាក៏ដោយត្រូវតែគោរពទៅតាមគោលការណ៍ទំនាក់ទំនងរវាងក្របខ័ណ្ឌផ្សេងគ្នារបស់មន្ត្រីរាជការ (មន្ត្រីនយោបាយ មន្ត្រីរាជការ យោធា និងមន្ត្រីសន្តិសុខ)។ ទីពីរ ការផ្លាស់ប្តូរនេះត្រូវតែធ្វើឡើងទៅតាមលទ្ធភាពហិរញ្ញវត្ថុនៅក្នុងរយៈពេលវែង ដោយគោរពតាមក្របខ័ណ្ឌហិរញ្ញវត្ថុ។ ជាលទ្ធផល ការបង្កើនប្រាក់បៀវត្ស ត្រូវតែធ្វើឡើងទៅតាមធនធានដែលមាន និងលទ្ធភាពចំណូលថវិកា។ រាជរដ្ឋាភិបាលបានសន្យាបង្កើនប្រាក់បៀវត្សពី១០ ទៅ ១៥ភាគរយក្នុងមួយឆ្នាំ។ រាជរដ្ឋាភិបាលនឹងផ្តល់ថវិកាបន្ថែមទៅឱ្យតម្រូវការអាទិភាព ដូចជា **កម្មវិធីកន្សោមអាទិភាព** និង ប្រព័ន្ធផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន។ លេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលបានគិតគូរពីសេណារីយ៉ូ ដើម្បីធ្វើការវាយតម្លៃលើជម្រើសផ្សេងៗ។ របកគំហើញនៃការសិក្សាស្តីពីគោលនយោបាយប្រាក់បៀវត្សនឹងត្រូវយកមករៀបចំនូវគោលនយោបាយតម្លើងប្រាក់បៀវត្សជូនដល់មន្ត្រីរាជការ។

## ២៥.៣. ចមជ្ឈការ និង ការអភិវឌ្ឍមូលដ្ឋាន

នៅក្នុងដំណើការវិមជ្ឈការ ច្បាប់ស្តីពីរដ្ឋបាលឃុំ-សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបានអនុមតិ។ ការអនុវត្តវិមជ្ឈការនៅកម្រិតឃុំ-សង្កាត់ផ្តោតជាសំខាន់ លើវិមជ្ឈការអំណាចភារកិច្ចនិងការទទួលខុសត្រូវរបស់មន្ត្រីឃុំ-សង្កាត់ លក្ខខណ្ឌនៃការបំពេញការងារ សម្រាប់រដ្ឋបាលឃុំសង្កាត់ និងវិមជ្ឈការប្រជាធិបតេយ្យ។

វិមជ្ឈការអំណាច ភារកិច្ច និងលក្ខខណ្ឌនៃការបំពេញការងារមានន័យថា ការផ្តល់អំណាចភារកិច្ច សេវា និងយុត្តាធិការពីថ្នាក់កណ្តាលមកថ្នាក់ឃុំ ធ្វើយ៉ាងដូច្នេះដើម្បីឱ្យឃុំអាចធ្វើសេចក្តីសម្រេចចិត្តនិងគ្រប់គ្រងដោយខ្លួនឯង ជាមួយនិងការប្រើប្រាស់ធនធានផ្ទាល់ខ្លួនដែលមាន។ រដ្ឋបាលឃុំត្រូវគោរពតាមលក្ខខណ្ឌនៃការបំពេញការងារដូចខាងក្រោមៈ

- ធានាសុវត្ថិភាព សណ្តាប់ធ្នាប់ និងការគ្រប់គ្រងសាធារណៈ។
- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន។
- លើកកម្ពស់សុខភាពនិងសុខុមាលភាពរបស់ប្រជាជនដែលរស់នៅក្នុងឃុំ។
- ការពារធនធានធម្មជាតិនិងបរិស្ថាន និងធានាឱ្យបាននូវការគ្រប់គ្រង។
- សម្របសម្រួលនូវការខ្វែងគំនិតគ្នានៅក្នុងក្រុម ក៏ដូចជាសហគមន៍ ដើម្បីលើកកម្ពស់បរិយាកាសអត់ឱននិងគោរពគ្នាទៅវិញទៅមក។
- សម្រេចឱ្យបាននូវបេសកកម្មក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ឃុំត្រូវមានធនធានថវិកា និង ទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ ចំណូលរបស់ឃុំមានដូចជាៈ

- ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និង ចំណូលពីសេវាកម្ម។
- ឧបត្ថម្ភធនពីថវិកាជាតិដែលផ្តល់ឱ្យឃុំ។
- ចំណូលពីការមានតួនាទីជាភ្នាក់ងាររបស់រដ្ឋ។

នៅក្នុងប្រទេសកម្ពុជា ដំណើរការវិមជ្ឈការបានឆ្លងកាត់ដំណាក់កាលជាច្រើន។ លក្ខខណ្ឌនៃការបំពេញការងារ ដែលបានរៀបរាប់ខាងលើត្រូវបានពង្រាងឡើងដោយប្រុងប្រយ័ត្នដោយគិតទៅលើសមត្ថភាពរដ្ឋបាលនៅតាមមូលដ្ឋាន ប៉ុន្តែនៅក្នុងការអនុវត្ត គេអាចជួបនឹងផលវិបាកខ្លះជាក់ជាមិនខាន។ ការវាយតម្លៃមួយចំនួនបានលើកឡើងនូវបញ្ហាដូចតទៅៈ (១) ខ្វះធនធានសម្រាប់អាជ្ញាធរមូលដ្ឋាន ក្នុងការអនុវត្តលក្ខខណ្ឌនៃការបំពេញការងារដែលផ្តល់ឱ្យពួកគេ (២) ខ្វះកិច្ចសហប្រតិបត្តិការពីភ្នាក់ងាគាំទ្រ និង (៣) ការយល់ច្រឡំនូវអត្ថន័យនៃវិមជ្ឈការ។ នៅក្នុងរយៈពេលមធ្យម និង វែង រដ្ឋមានបំណងជំរុញក្របខ័ណ្ឌទូលាយមួយដែលរៀបចំឡើង ដើម្បីបង្កើនការអភិវឌ្ឍមូលដ្ឋាន ការកែលម្អការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់អាជ្ញាធរមូលដ្ឋាន ទន្ទឹមនឹងការខិតខំប្រឹងប្រែងអនុវត្តការអភិវឌ្ឍធនធានមនុស្ស កម្មវិធី និងការផ្តល់ហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការធានាឱ្យមានការចូលរួមពីសំណាក់ប្រជាជនមូលដ្ឋាន ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ។ ក៏ប៉ុន្តែ គេនៅតែមិនទាន់យល់ឱ្យបានច្បាស់ពីភាពចាំបាច់ ក្នុងកំណត់នូវគណនេយ្យភាពរបស់រដ្ឋបាលមូលដ្ឋាន ជាមួយនឹងតួនាទីទូលំទូលាយនៅក្នុងប្រព័ន្ធរដ្ឋបាល។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ ក្នុងការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងគោលដៅលើកកម្ពស់រដ្ឋបាលមូលដ្ឋានពិតប្រាកដ។ រាជរដ្ឋាភិបាលនឹងធ្វើការកែទម្រង់ប្រព័ន្ធពន្ធមូលដ្ឋាន ដើម្បីធ្វើឱ្យអាជ្ញាធរមូលដ្ឋានមានធនធានគ្រប់គ្រាន់ ក្នុងការផ្តល់ហិរញ្ញប្បទានលើការវិយោគសាធារណៈតាមមូលដ្ឋាន។ យុត្តាធិការរបស់អាជ្ញាធរមូលដ្ឋាននឹងត្រូវបានពង្រឹងនិងពង្រីក ហើយទន្ទឹមគ្នានោះផងដែរ ការកំណត់ព្រំដែនដីពិតប្រាកដ មួយនឹងត្រូវបានរៀបចំឡើង ដើម្បីបង្កើតជាអត្តសញ្ញាណដែនដី សម្រាប់ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ២៥.៤. កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ

រាជរដ្ឋាភិបាលកម្ពុជាយល់យ៉ាងច្បាស់ពីសារៈសំខាន់នៃការបង្កើតស្ថាប័នច្បាប់ និងបទបញ្ញត្តិ ដែលជាមូលដ្ឋាននៃទំនាក់ទំនងរបស់មនុស្សនៅក្នុងសង្គម សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការមានគោលដៅរៀបចំឡើងវិញសារជាថ្មី នូវក្របខ័ណ្ឌច្បាប់និងតុលាការរបស់កម្ពុជា ដែលត្រូវបានបំផ្លិចបំផ្លាញចោលដោយសារសង្គ្រាម របបប្រល័យពូជសាសន៍ និងកលិយុគជាច្រើនឆ្នាំ ដែលកម្ពុជាបានឆ្លងកាត់។ សហគមន៍អន្តរជាតិកំពុងតែគាំទ្ររាជរដ្ឋាភិបាលនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។ កំណែទម្រង់នេះមានគោលដៅបង្កើតសសរទ្រូងដ៏សំខាន់មួយ នៅក្នុងចំណោមសសរទ្រូងជាច្រើននៃលទ្ធិប្រជាធិបតេយ្យ ពោលគឺធានានូវសមភាពរបស់ប្រជាពលរដ្ឋនៅចំពោះមុខច្បាប់។ វាក៏មានគោលបំណងផងដែរ ក្នុងការបង្កើតលក្ខខណ្ឌអនុគ្រោះ ដើម្បីពង្រឹងសន្តិសុខច្បាប់នៃការវិនិយោគ ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា។

កំណែទម្រង់ច្បាប់និងតុលាការនេះ មានគោលបំណងប្រើប្រាស់ឱកាស ដើម្បីលើកកម្ពស់ប្រព័ន្ធតុលាការនៅកម្ពុជា ឱ្យឈានដល់កម្រិតអន្តរជាតិ។ កម្មវិធីកំណែទម្រង់ច្បាប់និងតុលាការកម្ពុជា (CLJR) បានរៀបចំផែនការសកម្មភាពពីរគឺ ផែនការសកម្មភាពខ្លី ដែលរៀបចំឡើងសម្រាប់អាទិភាពចំនួន៣៣ និងផែនការសកម្មភាពមធ្យម ដែលគ្របដណ្តប់លើអាទិភាពចំនួន២៧។ ផែនការសកម្មភាពទាំងពីរនេះពឹងផ្អែកលើសមិទ្ធផលតាមដំណាក់កាលនៃគោលដៅទាំង៧នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការតាមរយៈ៖

- ការលើកកម្ពស់នៃការការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋាន។
- ការធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌនីតិបញ្ញត្តិ។
- ការផ្តល់លទ្ធភាពក្នុងការទទួលបានព័ត៌មានច្បាប់និងតុលាការ។
- ការបង្កើនគុណភាពសេវាច្បាប់។
- ការពង្រឹងសេវាច្បាប់និងតុលាការ។
- ការបង្កើតមធ្យោបាយដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
- ការពង្រឹងស្ថាប័នច្បាប់និងតុលាការ ដោយរៀបចំលក្ខខណ្ឌការងារច្បាស់លាស់។

*ធាតុសំខាន់ៗនៃផែនការសកម្មភាពមានដូចតទៅ៖*

- រៀបចំឡើងវិញការចងក្រងច្បាប់កម្ពុជា ឱ្យបានទូលំទូលាយនិងជាប់លាប់។ ឧទាហរណ៍ ការអនុមតិនិង ការចូលជាធរមាននៃក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី ដោយមានការចូលរួមនិងការប្រឹក្សាយោបល់នៅក្នុងគ្រប់កម្រិត គឺជាសមិទ្ធផលដ៏ធំធេងមួយនៃការងារកំណែទម្រង់នេះ។
- ការបង្កើតសាលាភូមិន្ទនៃអង្គចៅក្រម នៅក្នុងខែកុម្ភៈ ឆ្នាំ២០០២ ដោយផ្តោតទៅលើវិជ្ជាជីវៈពិតប្រាកដរបស់ចៅក្រម។ សាលានេះនឹងផ្តោតផងដែរ លើការបណ្តុះបណ្តាលក្រឡាបញ្ជី សារការី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រះរាជអាជ្ញា និងភាគីពាក់ព័ន្ធដទៃទៀតនៅក្នុងប្រព័ន្ធតុលាការ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវីកំពុងតែដំណើរការដោយរលូនផងដែរ។

- ការបង្កើតតុលាការគំរូនៅខេត្តកណ្តាលមានគោលដៅ ពង្រឹងការអនុវត្តអាជីពល្អប្រសើរ នៅក្នុងការដោះស្រាយសំណុំរឿងតុលាការ។ តុលាការនេះចាប់ផ្តើមដំណើរការយ៉ាងពេញលេញ នៅក្នុងឆ្នាំ ២០០៦។ កំណែទម្រង់នេះមានគោលដៅបង្កើតតុលាការឯកទេស ដើម្បីដោះស្រាយឱ្យបានល្អប្រសើរនូវសំណុំរឿង ដែលពាក់ព័ន្ធនឹងអនីតិជន ពាណិជ្ជកម្ម និង កិច្ចការរដ្ឋបាល។
- ជាទីបញ្ចប់ ការដាក់បញ្ចូលក្របខ័ណ្ឌតុលាការ ទៅក្នុងក្របខ័ណ្ឌពិសេសនៃមុខងារសាធារណៈដែលទទួលបានប្រាក់បៀវត្សខ្ពស់ គឺ ជាការបំពេញបន្ថែមទៅដល់កិច្ចខិតខំប្រឹងប្រែងបណ្តុះបណ្តាលរយៈពេលវែង និងកំណែទម្រង់តុលាការ។ រដ្ឋត្រូវធានានូវយុត្តិធម៌ដល់ប្រជាពលរដ្ឋតាមរយៈការផ្តល់មធ្យោបាយមនុស្ស បច្ចេកទេស និងនយោបាយរួមមានទាំងហិរញ្ញវត្ថុ និងបៀវត្ស។ ប្រការនេះគឺជាវិធានការដ៏សំខាន់ ក្នុងការធានានូវឯករាជភាពរបស់តុលាការ។

*បញ្ហានៃកំណែទម្រង់វិស័យយុត្តិធម៌ដែលត្រូវដោះស្រាយ មានដូចតទៅ៖*

- ការធានានូវការបែងចែកអំណាចនិងឯករាជភាពរបស់តុលាការ រួមមានការកែសម្រួលសមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (SCM) និង ការលើកតម្កើងកិត្យានុភាពរបស់ចៅក្រម។ គណៈរដ្ឋមន្ត្រីបានធ្វើវិសោធនកម្មលើច្បាប់ស្តីអំពីកិច្ចដំណើរការនិងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយរដ្ឋសភា និង ព្រឹទ្ធសភាក៏បានផ្តល់សច្ចាប័នលើច្បាប់នេះផងដែរ។ កំណែសម្រួលសមាសភាពនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ កំពុងតែឈានទៅមុខយ៉ាងល្អប្រសើរ។ លេខាធិការដ្ឋានមួយត្រូវបានបង្កើតឡើង នៅនឹងកន្លែង និងតាមការចាំបាច់ ដើម្បី ធានានូវតួនាទីសមស្របនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និង ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញាត្រូវបានរៀបចំឡើងក្នុងឆ្នាំ ២០០៥ និងត្រូវបានអនុមតិនៅក្នុងឆ្នាំ ២០១៥។
- ការរៀបចំតុលាការពាណិជ្ជកម្ម និង តុលាការរដ្ឋបាលនៅមិនទាន់សម្រេចបានលទ្ធផលនៅឡើយ។
- ការបង្កើនថវិកាសម្រាប់ក្រសួងយុត្តិធម៌ គឺ ជាលក្ខខណ្ឌចាំបាច់ ក្នុងការពង្រឹងធនធានមនុស្ស និងការធានានូវគុណភាពនៃសេវាសាធារណៈក្នុងវិស័យយុត្តិធម៌។

លក្ខខណ្ឌដ៏សំខាន់នៃជោគជ័យក្នុងកំណែទម្រង់ច្បាប់និងតុលាការ គឺ ប្រជាជនក្រីក្រអាចទទួលបានដោយងាយស្រួល នូវសេវាកម្មច្បាប់និងតុលាការ ដើម្បីកាត់បន្ថយភាពអយុត្តិធម៌សង្គម និងភាពងាយរងគ្រោះ ពង្រឹងជំនឿរបស់សហគមន៍លើនីតិរដ្ឋ ធ្វើឱ្យប្រសើរឡើងគុណភាពជីវិត និងកាត់បន្ថយភាពក្រីក្រ។ សង្គ្រាមស៊ីវិល កលិយុគ និងជម្លោះផ្ទៃក្នុងជាងបីទសវត្សរ៍បណ្តាលឱ្យប្រជាជនកម្ពុជាមានវិបត្តិផ្លូវចិត្ត និង មានភាពតឹងតែងក្នុងអារម្មណ៍យ៉ាងធ្ងន់ធ្ងរ។ ប្រជាជនកម្ពុជាដែលមានវ័យក្មេងៗ និង ដែលមានកំណើនប្រជាសាស្ត្រខ្ពស់ និង ការផ្លាស់ប្តូរសង្គមយ៉ាងលឿនហួសពីការស្មាន ដែលបណ្តាលមកពីការវិវត្តនៃបច្ចេកវិទ្យា និងសមាហរណកម្មស៊ីជម្រៅទៅក្នុងតំបន់និងពិភពលោក កំពុងតែធ្វើឱ្យប៉ះពាល់ដល់ទំនៀមទំលាប់ និង ប្រពៃណីរបស់ប្រជាជនកម្ពុជា។ សង្គមកម្ពុជាកំពុងតែមានការផ្លាស់ប្តូរយ៉ាងលឿន។

ម្យ៉ាងទៀត ដើម្បីឱ្យវិនិយោគិនមានជំនឿលើប្រព័ន្ធតុលាការ កម្ពុជាត្រូវមានតុលាការ ដែលមានសុភវិនិច្ឆ័យ ក្នុងការកាត់ក្តី និងរកយុត្តិធម៌ដល់វិនិយោគិន។ កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការត្រូវធានាឱ្យបាននូវការការពារកម្មសិទ្ធិបញ្ញា និង ការបើកឬក៏បិទក្រុមហ៊ុនប្រកបដោយភាពរលូន។ ដើម្បីធានាបាននូវវិស័យហិរញ្ញវត្ថុមួយ ដែលមានប្រសិទ្ធភាពខ្ពស់ កម្ពុជាត្រូវមានប្រព័ន្ធច្បាប់ដែលល្អ សម្រាប់ធនាគារ ពន្ធដារ គណនេយ្យ ការធានារ៉ាប់រង ប្រតិបត្តិការដោយមានការធានា ប្រតិបត្តិការអាជីវកម្ម នីតិវិធីក្ស័យធន ការអនុវត្តកិច្ចសន្យា ឥណទានពាណិជ្ជកម្ម និងឧបករណ៍សម្រាប់ប្រតិបត្តិការផ្ទេរនិងទូទាត់ប្រាក់។

ការអនុវត្តនៃកំណែទម្រង់ច្បាប់និងតុលាការកំពុងជួបនឹងការលំបាក និង បញ្ហាប្រឈមជាច្រើន នៅក្នុងបរិបទសង្គមកម្ពុជាបច្ចុប្បន្ន។ កម្ពុជានៅខ្វះអ្នកជំនាញការខាងផ្នែកច្បាប់ ដែលមានសមត្ថភាព និងមនសិការវិជ្ជាជីវៈខ្ពស់។ ប្រការនេះធ្វើឱ្យការអនុវត្តកំណែទម្រង់នេះ អ្នកជំនាញការបរទេសអាចមានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើប្រព័ន្ធតុលាការកម្ពុជា។ កត្តានេះនាំឱ្យមានការកើនឡើងនូវភាពមិនស៊ីចង្វាក់គ្នា ដែលធ្វើឱ្យការអនុវត្តច្បាប់មានការពិបាក។ ការអនុវត្តច្បាប់នៅតែជាបញ្ហាប្រឈម ដោយសារហេតុផលមួយចំនួនជាពិសេសគឺ ប្រាក់បៀវត្សទាបខ្លាំងពេក។ វាពិបាកនៅក្នុងការអនុវត្តច្បាប់ ប្រកបដោយតម្លាភាព ប្រកបដោយភាពក្លាហាន និងមិនលម្អៀងនៅពេលដែលប្រាក់បៀវត្សរបស់មន្ត្រីដែលទទួលបន្ទុកអនុវត្តច្បាប់ នៅមិនទាន់ស៊ីគ្នានឹងការទទួលខុសត្រូវដ៏ធំធេង។

## ២៥.៥. អភិបាលកិច្ចល្អនិងទំនើបកម្មរដ្ឋបាល

ការពង្រឹងអភិបាលកិច្ច ដែលជាផ្នែកមួយនៃកំណែទម្រង់សេដ្ឋកិច្ច នឹងអាចជំរុញការអនុវត្តកម្មវិធីនិងសកម្មភាពជាក់លាក់ ប្រឆាំងនឹងអំពើពុករលួយ។ អភិបាលកិច្ចមានសារៈសំខាន់ផងដែរ សម្រាប់ធ្វើទំនើបកម្មរដ្ឋបាលសាធារណៈ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ វិមជ្ឈការ និងការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។

យុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយ ត្រូវតែដើរទន្ទឹមគ្នាជាមួយនឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈ ជាមួយនឹងគណនេយ្យភាពពេញលេញរបស់មន្ត្រីសាធារណៈ សម្រាប់ផ្តល់សេវាកម្មឱ្យបានទាន់ពេលវេលា។ កម្មវិធីជាក់លាក់មួយ ដើម្បីលើកតម្កើងយុត្តិធម៌ និង សមភាពសង្គម ដោយមានការចូលរួមកាន់តែច្រើនថែមទៀតពីប្រជាជន នៅក្នុងការសម្រេចចិត្តរបស់រដ្ឋ នឹងបង្កើនតម្លាភាពនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត គឺជាគុណភាពពិតប្រាកដរបស់ប្រព័ន្ធអភិបាលកិច្ចល្អ ហើយឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់សាធារណៈដែលគេត្រូវតែបម្រើ។

ដើម្បីសម្រេចគោលដៅនេះបាន យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលត្រូវផ្តោតជាពិសេសទៅលើៈ (១) ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅ និង ការងាររបស់ចៅក្រម ក្រឡាបញ្ជី និងព្រះរាជអាជ្ញា (២) ត្រួតពិនិត្យឱ្យបានហ្មត់ចត់ឯកសារច្បាប់ ដែលគ្រប់គ្រងដំណើរការសារសាធារណៈ (៣) ពង្រឹងប្រសិទ្ធភាពនៃប្រតិបត្តិការទីផ្សារ និង លុបបំបាត់យន្តការត្រួតពិនិត្យ ដោយការគៀបសង្កត់ និង(៤) បន្តកំណែទម្រង់សេវាសាធារណៈ ទៅតាមទិសដៅប្រកបដោយវិជ្ជាជីវៈ និង ប្រសិទ្ធភាពខ្ពស់ ជាមួយនឹងការបង្កើនការលើកទឹកចិត្តដល់មន្ត្រីរាជការ។

នៅក្នុងការធ្វើទំនើបកម្មរដ្ឋបាលវាមានបញ្ហាប្រឈមធំៗដែលយើងនឹងជួបៈ(១)គោរពគោលការណ៍តម្លាភាព (២) ធ្វើការផ្សព្វផ្សាយព័ត៌មានជាសាធារណៈស្តីអំពីច្បាប់ហិរញ្ញវត្ថុ ច្បាប់ទូទាត់ថវិកា និងការផ្សព្វ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្សាយឱ្យបានទាន់ពេលវេលានូវតារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋាភិបាល (tableau des operations fnan_ciers de l'Etat- TOFE) (៣) ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃចំណាយសាធារណៈ បន្តកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេស តាមរយៈការពង្រីកប្រព័ន្ធពន្ធដារមូលដ្ឋាន និងបង្កើនចំណែកពន្ធដារនៅក្នុងចំណូលសរុប និង (៤) ពង្រឹងយុត្តិធម៌។ ចំណុចស្នូលនៃកម្មវិធីទំនើបកម្ម គឺការបង្កើតប្រព័ន្ធព័ត៌មានវិទ្យា ដោយឈរលើបច្ចេកវិទ្យាទំនើប សម្រាប់ផ្តល់ព័ត៌មានឱ្យបានទាន់ពេលវេលា ដោយគ្របដណ្តប់លើវិស័យសំខាន់ៗនៃផលប្រយោជន៍សាធារណៈ (ពន្ធ និងចំណាយសាធារណៈ ស្ថិតិ ទិន្នន័យសេដ្ឋកិច្ចនិងសង្គម និងព័ត៌មានរដ្ឋបាលជាដើម...)។

ក្របខ័ណ្ឌច្បាប់ប្រឆាំងនឹងអំពើពុករលួយកំពុងតែត្រូវបានអនុវត្ត។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់នូវតម្រូវការនៃវិធានការរួម ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ គឺជាការបោះជំហានទៅមុខដ៏វែងមួយ សម្រាប់កម្ពុជា។ ការអនុវត្តច្បាប់ត្រូវតែឱ្យបានហ្មត់ចត់។ ការផ្លាស់ប្តូរនីតិវិធីរដ្ឋបាល ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្មប្រព័ន្ធពន្ធគយ ប្រព័ន្ធដារ និងប្រព័ន្ធថវិកា ការលុបបំបាត់ភាពអសកម្មក្នុងការអនុវត្តនីតិវិធីនានា និងបង្កើនការលើកទឹកចិត្តដល់មន្ត្រីរាជការ តាមរយៈការតម្លើងប្រាក់បៀវត្ស ទាំងអស់នេះនឹងចូលរួមចំណែកក្នុងការកាត់បន្ថយអំពើពុករលួយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ឯកសារយោង

## I. ឈ្មោះសៀវភៅយោងជាភាសាខ្មែរ


រាជរដ្ឋាភិបាលកម្ពុជា: គោលនយោបាយជាតិប្រជាជន ភ្នំពេញ ឆ្នាំ 2003

ហង់ជួនណារ៉ុន: ម៉ាក្រូសេដ្ឋកិច្ច ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ 2009

ហង់ជួនណារ៉ុន: ហិរញ្ញវត្ថុសាធារណៈ ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយព្រះវិហារ ឆ្នាំ 2009


## II. ឈ្មោះសៀវភៅជាភាសាបរទេស


Agenor, Pierre-Richard et Peter Montiel (1999), Development Macroeconomics. Princeton : Princeton University Press, 2nd edition.

Alexander, W., Balino, T., and Enoch, C. (1999), Adopting Indirect Instruments of Monetary Policy, Finance & Development, Washington, March.

Balino, T., Bennet, A. and Borensztein, E. (1999), Monetary Policy in Dollarized Economic, IMF Occasional Paper, No.171, (Washington: International Monetary Fund).

Berg, T., Bennett, A. and Borensztein, E. (2000a), The Choice of Exchange Rate Regime and Monetary Target in Highly Dollarized Economies, IMF Working Paper, No. 00/29, (Washington: International Monetary Fund).

-----, (2000b), Full Dollarization: The Pros and Cons, Economic Issues, No. 24, (Washington: International Monetary Fund).

Bogetic, Z. (2000), Official Dollarization: Current Experiences and Issues, Cato Journal, Vol. 20, No. 2.

Calvo, G.A. and Vegh, C.A. (1992), Currency Substitution in Developing Countries: An Introduction, IMF Working Paper 92/40, (Washington: International Monetary Fund).

CDRI (2007), Pro-Poor Tourism in the Greater Mekong Subregion. Phnom Penh, Development Analysis Network.

Center for Advanced Studies (2009), Ethnic Groups in Cambodia. Phnom Penh.

De Zamaroczy, M. and Sa, S. (2002), Macroeconomic Adjustment in a Highly Dollarized Economy: The Case of Cambodia, IMF Working Paper 02/92, (Washington: International Monetary Fund).

Delvert, Jean. (1961), Le Paysan Cambodgien. Mouton, Paris.

Fisher, S. (1997), Capital Account Liberalization and the Role of the IMF, Paper presented at the seminar Asia and the IMF, held in Hong Kong, China, on September 19, 1997. IMF, September 1997.

Gillis M., Perkins D., Roemer M. and Snodgrass D. (1987), Economics of Development. Balises.

RGC (2004), Implementation of Rectangular Strategy and Requirements for Development Assistance. Document presented to the 2004 Consultative Group Meeting for Cambodia, Phnom Penh.

El-Mensi, Mohamed (1995), La réforme des enterprises publiques au Cambodge. Annales de la faculté de droit et des sciences économiques de Phnom Penh. 1996

East Asia Vision Group (2001), "Towards an East Asian Community: Region of Peace, Prosperity and Progress," October.

Takahashi (F.) (2006), "Japan and East Asia – For better Partnership and Cooperation", Discours lors d'un Forum inaugural de l'Institut des Relations Internationales, Phnom Penh, Cambodge, octobre.

Hang Choun Naron (1988), Les problemes du dévelopment économique du Cambodge et les perspectives de sa relation économique extérieure. (Thesis in Russian on international economic relation. Moscow State Institute of International Relations. Moscow).

Hang Choun Naron (1995), L'économie du Cambodge : la lutte pour le dévelpopment, Phnom Penh.

Hang Choun Naron (1998), Three Essays on Macroeconomic Management of Cambodia, Phnom Penh.

Hirschaman, Albert (1964), Stratégie du dévelopment écononmique. Economie et Humanisme. Les Edition Ouvrières. Paris.

IFC and Aisa Foundation (2009), Listing of Business Establishment in Cambodia's Provincail Towns and selected Urban Areas. Phnom Penh

Jalilian, Hossein et Colin Kirpatrick (2005), "Does Financial Development Contribute to Poverty Reduction?" Jouranl of Development Studies, Vol. 41 (mai), Pages 636-56.

Jennar, R. (1995), Les clés du Cambodge. Maisonneuve & Larose.

NIS (2009), General Population Census of Cambodia 2008. Phnom Penh.

Keat Chhon (1998), 45 Months at Ministry of Economy and Finance: Outcomes, Diagnostic, Outlook. Phnom Penh.

McKinnon, R. (1996), Direct and Indirect Concepts of International Currency Substitution, in Paul Mizen and Eric Pentecost, (eds.), The macroeconomics of International Currencies: Theory, Policy, and Evidence (U.K.: Edward Elgar) pp.44-59.

Migozzi, Jacques. (1967), Contribution à l'étude de la population de Cambodge. Les facteurs de l'accroissement démographique au Cambodge. Phnom Penh.

Ministry of Commerce (2003), Integrated Framework. Phnom Penh.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Ministry of Tourism (2008), Tourism National Tourism Development Plan, 2001-2005. Phnom Penh.

Mitsui Mineral Development Engineering Co., Ltd (2008), Cambodia – Mining as a Source of Growth, Paper prepared for the "Sustaining Rapid Growth" report prepared by the World Bank. Draft.

Mongrué, P. et Robert, M. (2005), "L'Asie émergente et la libération du compete de capital", Bulletin du Ministere de l'économies, No 93, décembre.

National Institute of Public Health and National Institute of Statistics (2006), Cambodia Demographic and Health Survey 2005. December.

Okonjo-Iweala, Ngozi; Kwakwa, Victoria; Beckwith, Andrea; et Ahmed, Zafar (1999), L'impact de la crise financière asiatique sur le Cambodge et la RDP Lao, Finance & Development, September.

Ortiz, G. (1993), Currency Substitution in Mexico; the dollarization Problem, Journal of money, credit, and banking (U.S.), Vol, pp.174—185.

Palley, T. (2003), The Economic of Exchange Rate and the dollarization Debate: The Case Against Extremes, Institutional journal of political economy, vol.33, no.1, Spring 2003, pp.61-82.

Prud'homme, Remi (1969), L'écononmie du Cambodge. Tiers monde. PUF. Paris.

RGC (2000), Interim Poverty Reduction Strategy Paper. October 2000, Phnom Penh.

RGC (2001a), Second Socio-economic Development Plan, 2001-2005. Phnom Penh.

RGC (2002), National Poverty Reduction Strategy. Phnom Penh.

RGC (2005), Small and Medium Enterprise Development Framework. Sub-committee on small & medium enterprise, Phnom Penh.

RGC (2009), Overview on Transport Infrastructure Sectors in the Kingdom of Cambodia. Infrastructure and Regional Integration Technical Working Group. Phnom Penh.

Rioja, Felix et Naven Valev, (2004), "Does One Size Fit All? A Reexamination of the Finance and Growth Relationship", Journal of Development Economics, vol. 74, No 4, pages 429-47.

Rodrik, D. (1998), Who Needs Capital Account Convertibility?, http:// ksghomeharvard.edu/

Rodrik, D. (2002), Trade Policy Reform as Institutional Reform, in B.M. Hoekman, P. English, and A. Mattoo, eds., Development, Trade, and the WTO: A handbook, World Bank, Washington, D.C.

Supreme National Economic Council (2002), Dollarization in Cambodia, Phnom Penh, Internal document.

Tan Kim Houn, (1961), Géographie du Cambodge, de l'Asie des Moussons et des Principales puissances. Phnom Penh.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Titchit, Lucien (1981), L'agriculture au Cambodge. Agence de Cooperation Culturelle et Technique. Paris.

World Bank (1992), Cambodia: Agenda for Rehabilitation and Reconstruction, Washington, D.C.

World Bank (2003), Toward a Private Sector-led Strategy for Cambodia – Value Chain Analysis,Washington, D.C.

World Bank (2004), Seizing the Global Opportunity: Investment Climate Assessment and Reform Strategy for Cambodia, Washington, D.C.

World Bank and UNICEF (2006), Appraisal of Basic Education Component of Cambodia's Education Strategic Plan. Prepare for Submission to the EFA-FTI Secretariat by Cambodia's Education Sector Working Group. Phnom Penh.

World Bank (2009), Poverty Profile and Trend in Cambodia. East Asia and Pacific Region. Washington.

World Travel & Tourism Council (2007), Cambodia: The 2007 Travel & Tourism Economic Research (London: WTTC).

Zee, H., Castro, p. and Wu, C. (1999), Cambodia: Reforming Tariff Policy and Customs Administration. Fiscal Affairs Department, (Washington: International Monetary Fund).



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# បណ្ឌិត ហង់ ជួន ណារ៉ុន



បណ្ឌិត **ហង់ ជួន ណារ៉ុន** បច្ចុប្បន្ន ជាអនុប្រធាននៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ស្ថាប័នស្រាវជ្រាវរបស់រាជរដ្ឋាភិបាលកម្ពុជា និង ជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងនីតិកាលទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា។

លោកទទួលបាន សញ្ញាបត្រអនុបណ្ឌិត និងបណ្ឌិត ផ្នែកសេដ្ឋកិច្ចអន្តរជាតិ ពីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិទីក្រុងម៉ូស្គូ (១៩៨២-១៩៩១) ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពីវិទ្យាស្ថានធានារ៉ាប់រង (CII) ប្រទេសអង់គ្លេស និង វិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី (MII)។ ចាប់តាំងពីឆ្នាំ ២០០៨ មក លោកបណ្ឌិតបានក្លាយជាសមាជិកនៃវិទ្យាស្ថានធានារ៉ាប់រង ប្រទេសអង់គ្លេស (CII) និងវិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី (MII)។ នៅឆ្នាំ ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រអន្តរជាតិ ពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និង សាកលវិទ្យាល័យ Lyon II នៃប្រទេសបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែកនីតិសមុទ្រ ពីបណ្ឌិតសភា Rhodes ផ្នែកនីតិសាស្ត្រ និងគោលនយោបាយសមុទ្រ។

លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងបេសកកម្មការទូត ជាអ្នកស្រាវជ្រាវក្នុងវិទ្យាស្ថានស្រាវជ្រាវ និង ជាអ្នកវិភាគនយោបាយនិងសេដ្ឋកិច្ច។ ចាប់តាំងពី ឆ្នាំ១៩៩៩ មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារមួយចំនួន ដូចជា៖ អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកានិងហិរញ្ញកិច្ច ។ បន្ទាប់មក លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គលេខាធិការរង ទទួលបន្ទុកគោលនយោបាយ រួមមាន គោលនយោបាយសេដ្ឋកិច្ចសារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និង ទទួលខុសត្រូវ ក្នុងការសម្របសម្រួលជាមួយ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និង ធនាគារពិភពលោក (World Bank) ។

ពីឆ្នាំ ២០០៤ ដល់ ឆ្នាំ២០១០ លោកបណ្ឌិត ត្រូវបានតែងតាំង ជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ លោកបណ្ឌិតធ្លាប់ជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្ដាលអាស៊ាន និង អាស៊ានបូកបី ពី ឆ្នាំ២០០០ ដល់ ២០១០ និង ជាតំណាងប្រទេសកម្ពុជាក្នុងកិច្ចប្រជុំ រដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្ដាលនៃប្រទេស G20 ក្នុងឋានៈ ដែលកម្ពុជាជាប្រធានអាស៊ានក្នុងឆ្នាំ២០១២។លោកបណ្ឌិតធ្លាប់ជាអ្នកសម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និង ធនាគារពិភពលោក (World Bank) ។

នៅក្នុងតំណែង ជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ជាស្ថាប័នខួរក្បាលខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា លោកបណ្ឌិតបានសរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយក

រដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសីទអន្តរជាតិដូចជា មហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងវេទិកាអន្តរជាតិឯទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅមួយចំនួន ជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្ដីអំពីការអភិវឌ្ឍសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា។ ស្នាដៃចុងក្រោយរបស់លោក ដែលមានចំណងជើងថា "Cambodian Economy: Charting the Course for a Bright Future" ត្រូវបានបោះពុម្ពផ្សាយ ដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍ (ISEAS) នៃប្រទេសសឹង្ហបុរី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ស្នាដៃរបស់អ្នកនិពន្ធ


1-**Hang Chuon Naron** — L'Économie du Cambodg : La lt e pr le dév lop ment, Phom Penh 2005

2-**Hang Chuon Naron** — E ssais économiq s,P hom Penh 2007

3 **Hang Chuon Naron et Patrick Gilbert-Desvallons** — Les finances publiques du Cabodge, Phom Penh 2007

4-**Hang Chuon Naron** — Cambodia: Recent Macroeconomic and Financial Sector Dev lop ent,P hom Penh 2008

5-**Hang Chuon Naron** — Th ee Essay on Macroeconomic Manag ment of Cambodia, Phom Penh 2008

6 **Hang Chuon Naron** — I ntrodu tion to Insu ance,P hom Penh 2008

7-**ហង់ ជួន ណារ៉ុន-ម៉ាក្រូសេដ្ឋកិច្ច** ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយ **ព្រះវិហារ** ឆ្នាំ ២០០៩

8-**Hang Chuon Naron and Patrick Gilbert-Desvallons** — Pbl ic Finance in Cambodia, Phom Penh Preah Vih ar Editions,2009

9-**ហង់ ជួន ណារ៉ុន** និង**ហ្វីលប៊ែ ជីវ៉ាល់ឡុង-ហិរញ្ញវត្ថុសាធារណៈ** ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយ **ព្រះវិហារ** ឆ្នាំ ២០០៩

10-**ហង់ ជួន ណារ៉ុន-ប្រាសាទព្រះវិហារ** ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយ **ព្រះវិហារ** ឆ្នាំ ២០០៩

11-**Hang Chuon Naron—Cambodian Economy:** Cha rtering h Cou se of a Brigh er Fu u e. A su e y of Prog ess,P roblems and Prosp cts,P hom Penh Preah Vih ar Editions,2009

12-**Hang Chuon Naron—L'économie du Cambodge:** Nou lles frontières du dé e lop ment socio-économiq ,P hom Penh Preah Vih ar Editions,2010

13-**Hang Chuon Naron—Regards sur le différend maritime khméro-thaïlandais** à la lu ière de la ju isp de nce internationale,P hom Penh Preah Vih ar Editions,2012




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia